**មាត្រា ២១.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២២.-**

ច្បាប់នេះត្រូវប្រកាសទុកជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

**នរោត្តម សីហនុ**

## ព្រះរាជក្រមលេខ នស/រកម/០០៩៥/០៤

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស

## អគ្គមហាបុរសរតន៍ និករោត្តម

## ធម្មិកមហារាជាធិរាជ បរមនាថ

## បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលថ្វាយស្នើសុំអំពី សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**ប្រកាសអោយប្រើ**

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ១៩៩៥ ស្ដីពី វិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មដែលមានសេចក្ដីទាំងស្រុងដូចតទៅ :

# ច្បាប់

## ស្ដីពី

## វិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១ .-**

ពាណិជ្ជករគឺជារូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលធ្វើពាណិជ្ជកិច្ច ហើយដែលយកពាណិជ្ជកិច្ចនេះជាមុខរបរខ្លួនជាប្រចាំ ។

ពាណិជ្ជកិច្ចជាសកម្មភាព ទិញលក់ទំនិញ ឬសេវាដែលត្រូវបានអនុវត្តជាប្រចាំក្នុងគោលដៅធ្វើការដោះដូរ និងស្វែងរកចំណេញ ។

**មាត្រា ២ .-**

ច្បាប់នេះចាត់ទុកថា ជាពាណិជ្ជកិច្ចរាល់សកម្មភាព ដែលមានចែងជាអាទិ៍ដូចខាងក្រោម ៖

- ការទិញដើម្បីលក់ទៅវិញ គិតបញ្ចូលទាំងក្នុងវិស័យអចលនទ្រព្យ
- រាល់សកម្មភាពនៃ សហគ្រាសជួល សហគ្រាសការណកម្ម សហគ្រាសយកកំរៃជើងសារ សហគ្រាសដឹកជញ្ជូន សហគ្រាសបោះពុម្ពផ្សាយ និងសេវាដទៃទៀត
- ប្រតិបត្តិការនៃធនាគារប្តូររូបិយវត្ថុ
- ការផ្តល់សេវាអន្តរការ សេវាទីភ្នាក់ងារ ការិយាល័យសំរបសំរួលកិច្ចការសេវារប្បធម៌ និងការចាត់ចែងនូវទស្សនីយភាពជាសាធារណៈ

LAW-SOCIETY.ASIA

-ប្រតិបត្តិការនៃសហគ្រាសសំណង់ ការទិញឬការជួលនាវាដឹកជញ្ជូនក្នុងប្រទេស ឬក្រៅ ប្រទេស ការដឹកជញ្ជូន និងការផ្ញើបញ្ជូនតាមផ្លូវគោក ផ្លូវទឹក ឬផ្លូវអាកាស

- ការធានារ៉ាប់រងគ្រប់ប្រភេទ

- អាជីវកម្មនេសាទ អាជីវកម្មព្រៃឈើនិងរ៉ែ ។

**មាត្រា ៣ .-**

ច្បាប់នេះមិនចាត់ទុកថាជាពាណិជ្ជកិច្ចទេ រាល់សកម្មភាពដែលមានចែងជាអាទិ៍ដូចខាងក្រោម ៖

- ការផលិតដែលមិនមែនសម្រាប់លក់ទៅវិញ
- ការផលិតឬសេវាទាំងឡាយ ដែលមានលក្ខណៈជាគ្រួសារ
- ការផលិតសិល្បៈសុទ្ធសាធ
- ការបង្ហាត់បង្រៀនដោយឯកជនផ្ទាល់ខ្លួឬដោយសមាគមស្របច្បាប់

**មាត្រា ៤ .-**

មិនចាត់ទុកថាជាពាណិជ្ជករទេ ផលិតករ សិប្បករ ឬកសិករទាំងឡាយ ដែលធ្វើសកម្មភាពមានលក្ខណៈជាគ្រួសារ ។

**មាត្រា ៥.-**

បុគ្គលដែលគ្រាន់តែជួយលក់ទំនិញរបស់សហព័ទ្ធខ្លួនដែលជាពាណិជ្ជករ មិនចាត់ទុកថា ជាពាណិជ្ជករឡើយ ។

និយោជិតដែលលក់តែទំនិញរបស់ម្ចាស់សហគ្រាសខ្លួនដែលជាពាណិជ្ជករ មិនចាត់ទុក ថាជាពាណិជ្ជករឡើយ ។

**មាត្រា ៦ .-**

សហព័ទ្ធនៃពាណិជ្ជករ ត្រូវចាត់ទុកថាជាពាណិជ្ជករដែរ បើសហព័ទ្ធនោះប្រកបរបរ ពាណិជ្ជកម្ម ដែលមានចុះក្នុងបញ្ជីពាណិជ្ជកម្មដោយឡែក ។

ការយល់ព្រមពីសហព័ទ្ធ ត្រូវមានការចាំបាច់សំរាប់ពាណិជ្ជករនោះ ។

**មាត្រា ៧ .-**

តាមន័យនៃច្បាប់នេះ អនីតិជនមិនអាចជាពាណិជ្ជករបានទេ លើកលែង

តែអនីតិជននោះ រួចផុតពីអាណាព្យាបាល ។

**មាត្រា ៨ .-**

សិទ្ធិនិងកាតព្វកិច្ចរបស់ពាណិជ្ជករ ត្រូវស្ថិតនៅក្រោមអំណាចច្បាប់ពាណិជ្ជកម្ម លើកលែងតែមានភស្តុតាងផ្ទុយ ។

**មាត្រា ៩ .-**

សមត្ថភាពប្រកបកិច្ចការពាណិជ្ជកម្ម អាចត្រូវបានចាត់ទុកជាបាត់បង់ដោយមូលហេតុ ដូចតទៅ ៖

- ធនក្ស័យ
- សេចក្តីសំរេចរបស់តុលាការហាមឃាត់ការប្រកបកិច្ចការពាណិជ្ជកម្ម
- វិសមិតភាពក្នុងការងារពាណិជ្ជកម្ម និងការងារសាធារណៈ ។

# ជំពូកទី ២

## ផ្នែកទី ១

## បញ្ជីពាណិជ្ជកម្មនិងក្រុមហ៊ុន

## ការកាន់កាប់និងកម្មវត្ថុនៃបញ្ជី

**មាត្រា ១០ .-**

នៅការិយាល័យក្រឡាបញ្ជី នៃតុលាការពាណិជ្ជកម្ម មានកាន់កាប់នូវបញ្ជីមួយ ចុះអត្តលេខនៃពាណិជ្ជករនិងក្រុមហ៊ុនពាណិជ្ជកម្ម ហៅថា "បញ្ជីពាណិជ្ជកម្ម" ។

**មាត្រា ១១ .-**

ក្រឡាបញ្ជីនៃតុលាការពាណិជ្ជកម្ម ទទួលខុសត្រូវក្នុងការកាន់កាប់បញ្ជីនេះ ក្រោមការត្រួតពិនិត្យរបស់ប្រធានតុលាការ ពាណិជ្ជកម្ម ។

**មាត្រា ១២ .-**

ពាណិជ្ជករ និងក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយដែលមានគ្រឹះស្ថានរបស់ខ្លួន សាខាបុត្រសម្ព័ន្ធ ឬទីភ្នាក់ងាររបស់ខ្លួននៅព្រះរាជាណាចក្រកម្ពុជាមាន

កាតព្វកិច្ចចុះឈ្មោះក្នុងបញ្ជីនេះ លើកលែងតែពាណិជ្ជករដែលមិនជាប់ពន្ធលើប្រាក់ចំណេញ ។

**មាត្រា ១៣ .-**

ត្រូវកត់ចូលក្នុងបញ្ជីនេះ នូវនិទ្ទេសទាំងអស់ដែលទាក់ទងដល់ពាណិជ្ជករនិងក្រុមហ៊ុន ដែលធ្វើពាណិជ្ជកិច្ច ។

## ជំពូកទី ២
## ពាណិជ្ជករ ដែលមានគ្រឹះស្ថានដើមនៅកម្ពុជា

**មាត្រា ១៤ .-**

ដប់ប្រាំថ្ងៃយ៉ាងតិចមុនពេលចាប់ផ្តើមបើកធ្វើពាណិជ្ជកម្មរបស់ខ្លួន ពាណិជ្ជករ ត្រូវចុះឈ្មោះក្នុងបញ្ជីពាណិជ្ជនៅការិយាល័យក្រឡាបញ្ជីនៃតុលាការពាណិជ្ជកម្ម នាកន្លែងដែលខ្លួនធ្វើអាជីវកម្ម ។

ពាណិជ្ជករត្រូវប្រគល់ជូនការិយាល័យក្រឡាបញ្ជី នូវប្រតិវេទន៍មួយធ្វើជាពីរច្បាប់មានចុះហត្ថលេខា ឬស្នាមមេដៃរបស់សាមីខ្លួន ។

ប្រតិវេទន៍នេះត្រូវសរសេរលើលិខិតគំរូមួយដែលក្រឡាបញ្ជីបានផ្តល់ឲ្យ ។ ប្រតិវេទន៍ត្រូវចែងអំពី ៖

១- នាមត្រកូលនិងនាមខ្លួនរបស់ពាណិជ្ជករ និងលេខនៃលិខិតអត្តសញ្ញាណ របស់ខ្លួន ។

២- នាមប្រើប្រាស់ក្នុងពាណិជ្ជកម្ម ឬរហស្សនាម ។

៣- ថ្ងៃ-ខែ-ឆ្នាំ និងទីកន្លែងកំណើត ព្រមទាំងអាស័យដ្ឋានផ្ទាល់ខ្លួន ។

៤- សញ្ជាតិដើម ហើយក្នុងករណីដែលសាមីខ្លួនបានទទួលសញ្ជាតិមួយផ្សេងទៀតត្រូវ បញ្ជាក់អំពីបែបបទនិងថ្ងៃខែឆ្នាំដែលបានទទួលសញ្ជាតិនេះ ។

៥- កម្មវត្ថុពាណិជ្ជកម្ម ។

៦- ទីកន្លែងធ្វើអាជីវកម្ម និងអាស័យដ្ឋានគ្រឹះស្ថានឬសាខានៃមូលនិធិពាណិជកម្មដែលមានទីតាំងនៅព្រះរាជាណាកម្ពុជា ។

៧- ផ្លាកសញ្ញាពាណិជ្ជកម្មនៃគ្រឹះស្ថាននិងហាង... របស់សាមីខ្លួន ព្រមទាំងស្លាកត្រាគំរូ ។

៨- លិខិតអត្តសញ្ញាណរបស់អ្នកតំណាងពេញសិទ្ធិ ដែលទទួលរ៉ាប់រង ក្នុងការសុំចុះបញ្ជីពាណិជ្ជកម្ម ។

៩- គ្រឹះស្ថានពាណិជ្ជកម្មដែលអ្នកប្តឹងសុំបានធ្វើអាជីវកម្មពីមុនឬគ្រឹះស្ថានពាណិជ្ជកម្មដែល អ្នកប្តឹងសុំកំពុងធ្វើអាជីវកម្មនៅ ក្នុងវង្វង់សមត្ថកិច្ចតុលាការពាណិជ្ជកម្មដទៃទៀត ។

១០- សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់អ្នកប្តឹងសុំថាគ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្ម ។

១១- ក្នុងករណីចាំបាច់លិខិតអនុញ្ញាតឲ្យប្រកបមុខរបរ ចំពោះមុខរបរណា ឬចំពោះកម្មវត្ថុ ពាណិជ្ជកម្មណាដែលតម្រូវឲ្យមានសេចក្តីអនុញ្ញាត ។

ក្រឡាបញ្ជីត្រូវចម្លងសេចក្តីក្នុងប្រតិវេទន៍ដូចក្នុងបញ្ជីពាណិជ្ជកម្មដោយប្រគល់ប្រតិវេទន៍នេះ មួយច្បាប់ក្នុងចំណោមប្រតិវេទន៍ទាំងពីរច្បាប់ជូនដល់អ្នកប្តឹងសុំចុះឈ្មោះដោយ បញ្ជាក់នៅខាងក្រោមថា "បានចម្លងចូលបញ្ជីរួចហើយ" ។

**មាត្រា ១៥ .-**

ត្រូវចុះក្នុងបញ្ជីពាណិជ្ជកម្មនិងក្រុមហ៊ុនផងដែរនូវ ៖

១- រាល់ការផ្លាស់ប្តូរនិងការកែប្រែទាក់ទងទៅនឹងហេតុការណ៍ទាំងឡាយ ដែលមាត្រាមុនបានអនុញ្ញាតឲ្យចុះក្នុងបញ្ជីពាណិជ្ជកម្ម ។

២- សាលក្រមឬសាលដីកាដែលសំរេចឲ្យពាណិជ្ជករលែងលះប្តីប្រពន្ធ ។

៣- ប្រកាសនីយប័ត្រតក្កកម្មដែលត្រូវបានធ្វើអាជីវកម្មឬសញ្ញាផលិតកម្មឬសញ្ញា ដែលពាណិជ្ជករប្រើប្រាស់ ។

៤- សាលក្រម ឬសាលដីកាតែងតាំងក្រុមប្រឹក្សាជំនួយអមពាណិជ្ជករ ឬសាលក្រម ឬសាលដីកាឬប្រកាសហាមឃាត់ពាណិជ្ជករ មិនឲ្យធ្វើពាណិជ្ជកម្ម ព្រមទាំងសាលក្រម ឬសាលដីកាលើកការហាមឃាត់ចេញ ។

៥- លិខិតបញ្ចាំឬនិក្ខេប (អ៊ីប៉ូតែក) លើទ្រព្យសំខាន់ៗសំរាប់អាជីវកម្ម ។

៦- សាលក្រមប្រកាសធនក្ស័យ ឬការជម្រះតាមផ្លូវតុលាការ ។

៧- អនុប្បទានពាណិជ្ជមូលនីធិ ។

**មាត្រា ១៦ .-**

ការចុះនិទ្ទេសខាងលើនេះ ជាភារកិច្ចផ្ទាល់ខ្លួនរបស់ពាណិជ្ជករ ។ ប៉ុន្តែ ចំពោះករណី ដែលមានចែងនៅក្នុងចំណុច ២.៤ និង ៦ នៃមាត្រា ១៥ ក្រឡាបញ្ជី នៃតុលាការពាណិជ្ជកម្ម ឬសាលដីកា អាចចុះសេចក្ដីនោះជាបញ្ញត្តិក្នុងបញ្ជី ពាណិជ្ជកម្មដែលសាមីពាណិជ្ជករបានចុះឈ្មោះ ។

## ជំពូកទី ៣

## ក្រុមហ៊ុនដែលមានទីស្នាក់ការដើមនៅព្រះរាជាណាចក្រកម្ពុជា

**មាត្រា ១៧ .-**

ត្រូវចុះក្នុងបញ្ជីពាណិជ្ជកម្ម គ្រប់ក្រុមហ៊ុនដែលមានសកម្មភាពពាណិជ្ជកម្ម ទោះបីបែបបទនៃការបង្កើត និងថិរវេលារបស់ក្រុមហ៊ុនទាំងនោះមានលក្ខណៈបែបណាក៏ដោយ។

ការចុះឈ្មោះនេះត្រូវធ្វើឡើងដោយបណ្ណាធិការ ឬអភិបាល នៅក្នុងខែនៃការបង្កើតក្រុមហ៊ុន និងដប់ប្រាំថ្ងៃមុនកាលបរិច្ឆេទបើកប្រតិបត្តិការពាណិជ្ជកម្ម ។

អ្នកប្ដឹងសុំចុះឈ្មោះ ត្រូវផ្ដល់ជូនការិយាល័យក្រឡាបញ្ជីតុលាការពាណិជ្ជកម្ម នៃទីស្នាក់ការក្រុមហ៊ុន នូវប្រតិវេទន៍ចំនួនពីរច្បាប់ មានចុះហត្ថលេខារបស់សាមីខ្លួនអ្នកប្ដឹងសុំ ព្រមទាំងតំកល់លក្ខន្តិកៈក្រុមហ៊ុនផង ។

ប្រតិវេទន៍ដែលក្រឡាបញ្ជីផ្ដល់តំរូវជូននោះ ត្រូវចែងអំពី ៖

១- នាមត្រកូលនិងនាមខ្លួន របស្សនាមរបស់សមាជិកក្រុមហ៊ុន ថ្ងៃ-ខែ-ឆ្នាំ និងទីកន្លែង កំណើត ស្ថានភាពគ្រួសារ និងសញ្ជាតិ ។

២- ផ្លាកសញ្ញារបស់ក្រុមហ៊ុន

៣- កម្មវត្ថុនៃក្រុមហ៊ុន

៤- ទីកន្លែងទាំងឡាយ ដែលក្រុមហ៊ុនមានគ្រឹះស្ថានដើម មានសាខា

ឬទីភ្នាក់ងារនៅ ព្រះរាជាណាចក្រកម្ពុជា ។

៥- នាមនៃសមាជិក ឬតតិយជនដែលមានការអនុញ្ញាតឲ្យគ្រប់គ្រងចាត់ចែង និងចុះចាត់ចែង និងចុះហត្ថលេខាជំនួសមុខក្រុមហ៊ុន ថ្ងៃ-ខែ-ឆ្នាំ និងទីកន្លែងកំណើតនៃអ្នកទាំងនេះ ។

៦- ដើមទុនរបស់ក្រុមហ៊ុន ប្រភពដើមទុននិងចំនួនទឹកប្រាក់ ឬវត្ថុមានតំលៃ ដែលផ្តល់ដោយសមាជិកភាគហ៊ុន ប្រសិនបើជាក្រុមហ៊ុនដោយភាគហ៊ុន ។

៧- ថ្ងៃ-ខែ-ឆ្នាំ ដែលក្រុមហ៊ុននោះចាប់ផ្តើមនិងបញ្ចប់ ។

៨- ទ្រង់ទ្រាយក្រុមហ៊ុន ។

៩- ហត្ថលេខាគំរូរបស់សមាជិក ឬតតិយជនដូចមានចែងនៅចំណុចលេខ ៥ នៃមាត្រានេះ និងស្នាមត្រាគំរូរបស់ក្រុមហ៊ុន ។

១០- លិខិតបញ្ជាក់អំពីការតំកល់ដើមទុនចេញដោយធនាគារ ។

១១- សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់អ្នកប្តឹងសុំថា គ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការ ពាណិជ្ជកម្ម រដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ។

**មាត្រា ១៨ .-**

ត្រូវចុះក្នុងបញ្ជីពាណិជ្ជកម្មផងដែរនូវ ៖

១- រាល់ការផ្លាស់ប្តូរកែប្រែទាក់ទងនឹងហេតុការណ៍ដែលមាត្រាមុនបានបញ្ញត្តិឲ្យចុះសេចក្តីក្នុង បញ្ជីពាណិជ្ជកម្ម ។

២- នាមត្រកូលនិងនាមខ្លួនថ្ងៃ-ខែ-ឆ្នាំ និងទីកន្លែងកំណើតនៃបណ្ណាធិការ អភិបាល ឬនាយកដែលបានទទួលការតែងតាំងក្នុងអាយុកាលរបស់ក្រុមហ៊ុន ។

៣- ប្រកាសនីយប័ត្រតក្កកម្មដែលត្រូវបានធ្វើអាជីវកម្មនិងសញ្ញាផលិតកម្ម ដែលក្រុមហ៊ុនប្រើប្រាស់ ។

៤- សាលក្រមឬសាលដីកា ដែលប្រកាសរំលាយឬប្រកាសមោឃភាព នៃក្រុមហ៊ុន ។

៥- សាលក្រមឬសាលដីកាដែលប្រកាសធនក្ស័យ ឬការជំរះបញ្ជីតាមផ្លូវតុលាការរបស់ក្រុមហ៊ុន ។

## ផ្នែកទី ៤
## ក្រុមហ៊ុនបរទេសដែលមានតែសាខា ឬទីភ្នាក់ងារនៅព្រះរាជាណាចក្រកម្ពុជា

**មាត្រា ១៩ .-**

ត្រូវចុះបញ្ជីពាណិជ្ជកម្មផងដែរ រាល់ក្រុមហ៊ុនពាណិជ្ជកម្មបរទេសដែលមានត្រឹមតែសាខា ឬទីភ្នាក់ងារនៅព្រះរាជាណាចក្រកម្ពុជា ។

ចំពោះការចុះបញ្ជីនេះ ត្រូវបំពេញទំរង់ការដូចចែងក្នុងមាត្រា ១៧ និង ១៨ នៃច្បាប់ នេះ ។

**មាត្រា ២០ .-**

រាល់ការកែប្រែឬការផ្លាស់ប្តូរដែលកើតមានឡើងចំពោះសាខា ឬទីភ្នាក់ងារត្រូវកត់ត្រាចូលក្នុងបញ្ជីពាណិជ្ជកម្មតាមបញ្ញត្តិមាត្រា ១៨ នៃច្បាប់នេះ ។

## ផ្នែកទី ៥
## បទបញ្ញត្តិរួម

**មាត្រា ២១ .-**

ប្រតិវេទន៍ធ្វើឡើងជាពីរច្បាប់ ត្រូវយកទៅដាក់ដោយអ្នកប្តឹងសុំ ឬដោយអាណត្តិគាហក របស់សាមីជននោះ ។ ក្នុងករណីនេះអាណត្តិគាហកត្រូវមានលិខិតប្រគល់សិទ្ធិអំណាចដែលត្រូវតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃតុលាការ ពាណិជ្ជកម្ម ។

**មាត្រា ២២ .-**

បើប្រតិវេទន៍ត្រូវបានយកទៅដាក់ផ្ទាល់ដោយអ្នកប្តឹងសុំ នោះក្រឡាបញ្ជី ត្រូវពិនិត្យពិច័យ អត្តសញ្ញាណរបស់សាមីខ្លួនឲ្យបានច្បាស់លាស់ ។

បើសិន ប្រតិវេទន៍នេះត្រូវបានយកទៅតម្កល់ទុក ដោយអាណត្តិគាហក ក្រឡាបញ្ជីត្រូវតំរូវ ឲ្យមានការបញ្ជាក់អំពីហត្ថលេខារបស់អាណត្តិទាយក ឬការបញ្ជាក់អំពីស្នាមមេដៃ បើអាណត្តិ ទាយកមិនចេះចុះហត្ថលេខា និងតម្រូវឲ្យបង្ហាញលិខិតបញ្ជាក់ អត្តសញ្ញាណរបស់ អ្នកប្តឹងសុំ ។

**មាត្រា ២៣ .-**

និទ្ទេសទាំងឡាយដែលច្បាប់តម្រូវឲ្យធ្វើនោះ ត្រូវសរសេរជាលាយលក្ខណ៍អក្សរនៅលើប្រតិវេទន៍ដែលអាចអានបានដោយគ្មានបំព្រួញ គ្មានកោសលុប គ្មានជ្រៀត បន្ថែម ។ ការបន្ថែម ពាក្យនៅលើរឹមទំព័រ ត្រូវមានចុះហត្ថលេខាសង្ខេបបញ្ជាក់ ហើយចំនួនពាក្យបន្ថែមនោះព្រមទាំងចំនួនពាក្យដែលលុបចោល ត្រូវតែរាប់និងបញ្ជាក់ ។

**មាត្រា ២៤ .-**

ប្រកាសនីយប័ត្រតក្កកម្មដែលត្រូវបានធ្វើអាជីវកម្ម និងសញ្ញាផលិតករដែល បានតំកល់ទុក ត្រូវបញ្ជាក់លេខ ថ្ងៃ-ខែ-ឆ្នាំ នៃការតំកល់ទុកដែលចេញឲ្យដោយស្ថាប័ន មានសមត្ថកិច្ច ។

**មាត្រា ២៥ .-**

ក្រឡាបញ្ជីនឹងផ្ទៀងផ្ទាត់មើលក្រោមការទទួលខុសត្រូវផ្ទាល់របស់ខ្លួន អំពីបែបបទ ទាំងឡាយដែលបានបញ្ញត្តិ ។ ក្រឡាបញ្ជីត្រូវចុះនៅលើផ្នែកខាងលើនៃប្រតិវេទន៍នូវ ៖

១- ថ្ងៃ-ខែ-ឆ្នាំ ម៉ោងនៃការតម្កល់ទុកនិងទីកន្លែងតុលាការពាណិជ្ជកម្ម ។

២- លេខរៀងរបស់ប្រតិវេទន៍តាមលំដាប់លេខជាបន្តបន្ទាប់ ក៏ប៉ុន្តែការចុះលេខនេះត្រូវចាប់ផ្តើមឡើងវិញចាប់ពីថ្ងៃទី ១ មករា ជារៀងរាល់ឆ្នាំ ។

៣- អត្តលេខសំគាល់ទៅតាមបែបផែននៃសកម្មភាពរបស់ពាណិជ្ជករដែលចុះក្នុងបញ្ជីវិភាគី ដែលនឹងមានចែងខាងក្រោយ ។

ចំពោះអ្នកធ្វើប្រតិវេទន៍ណា ដែលមិនបានផ្តល់នូវរាលពត៌មានគ្រប់គ្រាន់ដល់ការចុះបញ្ជីនឹងត្រូវបានអនុញ្ញាតរយៈពេលពិសេសចំនួនដប់ប្រាំថ្ងៃបន្ថែម ។

**មាត្រា ២៦ .-**

ដោយបានឃើញប្រតិវេទន៍ជាលាយល័ក្ខណ៍អក្សរ និងរាល់ឯកសារតម្កល់ទុកក្រឡាបញ្ជី នឹងផ្តល់ជូននូវវិញ្ញាបនប័ត្រចុះបញ្ជីហៅថា "សំរង់" ដែលមានចែងអត្តលេខសំគាល់ចុះក្នុងបញ្ជីពាណិជ្ជកម្ម ។ វិញ្ញាបនប័ត្រនេះ ស្ថិតក្នុងលក្ខណៈជាបណ្តោះអាសន្នក្នុងចិរវេលាមួយខែគិតចាប់ពី កាលបរិច្ឆេទ ដែលបានផ្តល់ជូន ។ ក្នុងចិរវេលានេះ ក្រឡាបញ្ជីនៃតុលាការពាណិជ្ជកម្ម អាចជំទាស់នឹងការចុះបញ្ជី និងលុបចោលអត្តលេខសំគាល់ដែលមានចុះក្នុងបញ្ជីហើយនោះ ក្នុងករណីដែលរកឃើញថាជាប្រតិវេទន៍ក្លែងបន្លំ ។

ក្រឡាបញ្ជីដែលផ្តល់នូវវិញ្ញាបនប័ត្រក្លែងបន្លំ ដែលបានធ្វើឡើងដោយដឹងហេតុផលសព្វគ្រប់ត្រូវទទួលទោសតាមច្បាប់ ។

**មាត្រា ២៧ .-**

ប្រតិវេទន៍ទាំងឡាយណា ដែលបានធ្វើក្រោយការចុះអត្តលេខត្រូវស្រង់យកលេខ ប្រតិវេទន៍ដើម និងលេខបញ្ជីវិភាគីដែលបានផ្តល់ជូននៅពេលចុះអត្តលេខនោះ ។

**មាត្រា ២៨ .-**

កាលណាបើពាណិជ្ជករណាម្នាក់ ឈប់ប្រកបពាណិជ្ជកម្មរបស់ខ្លួន ឬទទួលមរណភាព ដោយពុំបានធ្វើអនុប្បទាននូវមូលនិធិពាណិជ្ជកម្មរបស់ខ្លួន ឬកាលណាបើក្រុមហ៊ុនណាមួយត្រូវរំលាយនោះ ត្រូវលុបឈ្មោះពាណិជ្ជករនោះ ឬក្រុមហ៊ុននោះចេញពីបញ្ជី ។

បើសិនជាគ្មានការសុំលុបឈ្មោះដោយពាណិជ្ជករ ឬដោយអ្នកទទួលមរតក ឬដោយអ្នក ជំរះបញ្ជី ការលុបឈ្មោះចេញពីបញ្ជីនេះត្រូវធ្វើឡើងដោយបញ្ញត្តិតាមសេចក្តី សម្រេចរបស់ចៅក្រមទទួលបន្ទុកត្រួតពិនិត្យបញ្ជី។

**មាត្រា ២៩ .-**

ជនណាក៏ដោយ អាចសុំឲ្យក្រឡាបញ្ជីចេញឲ្យខ្លួននូវវិញ្ញាបនប័ត្របញ្ជាក់អំពីចំណារទាំងឡាយដែលមានចុះក្នុងបញ្ជីពាណិជ្ជកម្ម ។ បើគ្មានចុះបញ្ជីទេ ក្រឡាបញ្ជី ត្រូវចេញវិញ្ញាបនប័ត្របញ្ជាក់ថាគ្មានចុះបញ្ជី ។

ការធ្វេសប្រហែស ឬការមិនព្រមចេញវិញ្ញាបនប័ត្រ ក្នុងរយៈពេលមួយសប្តាហ៍ គិតចាប់ពីថ្ងៃស្នើសុំ នឹងបណ្តាលឲ្យមានទណ្ឌកម្មតាមវិន័យចំពោះក្រឡាបញ្ជីព្រមទាំងមានការសងជំងឺចិត្តផង ។

សេចក្តីចម្លងដែលក្រឡាបញ្ជីចេញឲ្យនោះ មិនត្រូវចែងនូវសាលក្រមប្រកាសធនក្ស័យ ឬការជំរះបញ្ជីតាមផ្លូវតុលាការទេ បើក្រោយមកមាននីតិសម្បទាឡើងវិញ ។ សេចក្តីចម្លងក៏មិនត្រូវចុះផងដែរនូវសាលក្រម ឬសាលដីកាហាមឃាត់មិនឲ្យធ្វើពាណិជ្ជកម្ម ឬសាលក្រម សាលដីកាតែងតាំង ក្រុមប្រឹក្សាជំនួយបើមានលើកការហាមឃាត់ចេញរួចហើយ ។

## ផ្នែកទី ៦

## អំពីបញ្ជីពាណិជ្ជកម្ម រូបវន្តបុគ្គលនិងសមាសភាព

**មាត្រា ៣០ .-**

បញ្ជីពាណិជ្ជកម្មដែលតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃតុលាការពាណិជ្ជកម្មមានពីរបែបគឺ ៖

១- បញ្ជីកាលប្បវត្តិ

២- បញ្ជីវិភាគី

**មាត្រា ៣១ .-**

ប្រតិវេទន៍ត្រូវចុះក្នុងគល់បញ្ជីកាលប្បវត្តិតាមលំដាប់នៃការតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជី និងតាមលេខដែលចុះ ។

ត្រូវប្រគល់ចុងសន្លឹកនៃប្រតិវេទន៍មួយសន្លឹក ដែលដាច់ចេញពីគល់បញ្ជីហៅថា "សំរង់" ជាសំគាល់នៃការតំកល់ទុកដោយមានចែងនិទ្ទេសដូចតទៅ ៖

១- លេខរៀងនៃប្រតិវេទន៍
២- ថ្ងៃ-ខែ-ឆ្នាំ ម៉ោងនៃការតម្កល់ទុក និងទីកន្លែងនៃតុលាការពាណិជ្ជកម្ម
៣- នាមត្រកូលនាមខ្លួនផ្លាកសញ្ញាក្រុមហ៊ុន និងលំនៅដ្ឋានអ្នកធ្វើប្រតិវេទន៍ ។

ចំណែកឯបញ្ជីវិភាគីវិញមានទ្រង់ទ្រាយជាតារាងដែលត្រូវចុះជាអាទិ៍នូវលេខ ថ្ងៃ-ខែ-ឆ្នាំ ម៉ោង នៃការតម្កល់ទុកអត្តលេខ នាមករណ៍ក្រុមហ៊ុន កម្មវត្ថុនៃក្រុមហ៊ុនដើមទុននៃក្រុមហ៊ុន ។ គ្រឹះស្ថានពាណិជ្ជកម្មនីមួយៗ ដែលជាកម្មវត្ថុនៃការចុះអត្តលេខសំគាល់ដោយឡែក ត្រូវបានចុះលើសន្លឹកមួយទាំងសងខាងហើយនៅលើសន្លឹកនោះ ក្រឡាបញ្ជីត្រូវចារលេខប្រតិវេទន៍ដើមនៃការសុំចុះបញ្ជីនោះ ។

**មាត្រា ៣២ .-**

បើមានពាក្យសុំឲ្យចុះនិទ្ទេស ដែលបង្កឲ្យលុបចោលនិទ្ទេសដែលមានស្រាប់ក្រឡាបញ្ជី ត្រូវគូសលុបនិទ្ទេសនេះដោយទឹកខ្មៅក្រហម ឬលុបខ្វែងចំណាំតាមកម្មវិធីកុំព្យូទ័រ ដោយមានសរសេរបង្ហាញនៅលើរឹមទំព័រនូវសេចក្តីយោងនៃនិទ្ទេសថ្មីនិងលេខដែលក្រោមលេខនេះប្រតិវេទន៍ ឬពាក្យសុំចុះនិទ្ទេសនោះត្រូវបានចុះបញ្ជីដោយពិតប្រាកដ ។

**មាត្រា ៣៣ .-**

បើសិនមានការលុបឈ្មោះចេញពីបញ្ជី ការលុបនេះត្រូវធ្វើឡើងដោយគំនូសក្រហមពីរ ខ្វែងគ្នា ឬលុបតាមវិធីកុំព្យូទ័រ ។

សេចក្តីសំរេចលុបឈ្មោះបញ្ជីចេញពីបញ្ជីរបស់ចៅក្រមទទួលបន្ទុកត្រួតពិនិត្យបញ្ជី ឬ ពាក្យសុំឲ្យលុបឈ្មោះនោះ ត្រូវកំណត់សរសេរនៅលើរឹមទំព័រដោយទឹកខ្មៅក្រហមផងដែរ ។

ក្រឡាបញ្ជីបញ្ជាក់និទ្ទេសនេះដោយចុះហត្ថលេខាសង្ខេប ។

**មាត្រា ៣៤ .-**

កាលបើនិទ្ទេសដែលមាននៅក្នុងប្រតិវេទន៍ត្រូវបានកត់ត្រាបញ្ចូលទៅក្នុងបញ្ជីវិភាគីក្រឡាបញ្ជីត្រូវប្រគល់ជូនអ្នកដែលយកមកតំកល់ទុកនូវប្រតិវេទន៍មួយ

ច្បាប់ ដែលមានចុះហត្ថលេខាត្រឹមត្រូវសំរាប់ប្រើប្រាស់ជាវិញ្ញាបនប័ត្រចុះឈ្មោះ ។

សន្លឹកប្រតិវេទន៍ទាំងអស់ ដែលរក្សាទុកនៅការិយាល័យក្រឡាបញ្ជីនៃតុលាការពាណិជ្ជកម្ម ត្រូវក្រឡាបញ្ជីចងក្រងតាមលេខរៀងយ៉ាងហោចណាស់មួយដងក្នុងមួយឆ្នាំ ។

**មាត្រា ៣៥ .-**

បញ្ជីកាលប្បវត្តិ និងបញ្ជីវិភាគីត្រូវបានប្រធានតុលាការពាណិជ្ជកម្ម ឬចៅក្រមទទួលបន្ទុកត្រួតពិនិត្យ បញ្ជីជាអ្នកបង់លេខ ចុះហត្ថលេខាសង្ខេប និងពិនិត្យ បញ្ជាក់នៅ ពេលដាច់ខែម្តងៗ ។ ការពិនិត្យបញ្ជាក់នេះត្រូវមានបោះត្រារបស់តុលាការ និងចុះហត្ថលេខារបស់ចៅក្រមត្រួតពិនិត្យ ។

បើប្រធានតុលាការឬចៅក្រមទទួលបន្ទុកពិនិត្យបញ្ជីបញ្ជាក់ថាប្រតិវេទន៍ ណាមួយចូល ក្នុងករណីដែលមានចែងក្នុងមាត្រា ៤០ និង ៤១ នៃច្បាប់នេះប្រធានតុលាការ ឬចៅក្រមនោះត្រូវជូនដំណឹងអំពីរឿងនេះទៅព្រះរាជអាជ្ញាអមតុលាការមានសមត្ថកិច្ច ។

**មាត្រា ៣៦ .-**

ការចុះឈ្មោះ ការលុបឈ្មោះ ឬការចេញវិញ្ញាបនប័ត្រផ្សេងៗ ជាភារៈផ្ទាល់របស់ក្រឡាបញ្ជី ។ វិញ្ញាបនប័ត្រទាំងនេះត្រូវចេញអោយអ្នកសុំពីសៀវភៅក្បាលបញ្ជីមានលេខ ។ សោហ៊ុយបែបបទសុំចុះឈ្មោះលុបឈ្មោះឬចេញវិញ្ញាបនប័ត្រផ្សេងៗ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុហើយប្រមូលដោយក្រឡាបញ្ជីសំរាប់បង់ចូលថវិការដ្ឋ ។

**មាត្រា ៣៧ .-**

សេចក្តីចម្លងនៃការចុះឈ្មោះក្នុងបញ្ជី និងវិញ្ញាបនប័ត្របញ្ជាក់ពីការគ្មានចុះឈ្មោះចេញដោយក្រឡាបញ្ជី ត្រូវផ្តល់ជូនដោយឥតគិតថ្លៃតាមពាក្យសុំរបស់អាជ្ញាធរតុលាការ ឬរដ្ឋបាលបានលុះត្រាតែមានចុះនិទ្ទេសពីកន្លែងអ្នកទទួលលិខិតនោះ ។

**មាត្រា ៣៨ .-**

រាល់ការចុះឈ្មោះនិងលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម ត្រូវបានចុះផ្សាយដោយក្រឡាបញ្ជីក្នុងរាជកិច្ច ។ និទ្ទេសដែលត្រូវចុះផ្សាយមានដូចខាងក្រោមនេះ ៖

ក- ចំពោះពាណិជ្ជករ

១- លេខចុះបញ្ជី

២- នាមត្រកូល នាមខ្លួន រហស្សនាមព្រមទាំងនាមសហព័ទ្ធ

៣- សកម្មភាព ទីកន្លែង ថ្ងៃ-ខែ-ឆ្នាំ ចាប់ផ្តើមសកម្មភាព

៤- ផ្លាកសញ្ញា ។

ខ- ចំពោះក្រុមហ៊ុន

១- លេខចុះបញ្ជី

២- នាមករណ៍

៣- ចំនួនដើមទុន

៤- ទីស្នាក់ការ

៥- សកម្មភាព និង ថ្ងៃ-ខែ-ឆ្នាំ ចាប់ផ្តើម

៦- ទ្រង់ទ្រាយក្រុមហ៊ុន ។

## ផ្នែកទី ៧

## ទោសបញ្ញត្តិ

**មាត្រា ៣៩ .-**

រាល់ពាណិជ្ជករឬរាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណាដែល មិនបានសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមកាលបញ្ញត្តិ នឹងត្រូវប្តឹងទៅតុលាការអំពីបទប្រព្រឹត្តសកម្មភាពពាណិជ្ជកម្មមិនស្របច្បាប់ ។

**មាត្រា ៤០ .-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីប្រាំម៉ឺនរៀល (៥០.០០០រៀល) ទៅប្រាំសែនរៀល (៥០០.០០០រៀល) ចំពោះ ៖

១- រាល់ពាណិជ្ជករឬរាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណា ដែលមិនបានចុះ បញ្ជីពាណិជ្ជកម្មតាមកាលបញ្ញត្តិ ។

២- រាល់ពាណិជ្ជករឬរាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណា ដែលបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មហើយ តែមិនបានចុះនៅលើវិក័យប័ត្រ លិខិតស្នាមកំណត់បញ្ជាទិញ តារាងតម្លៃ និងឯកសារផ្សព្វផ្សាយអំពីទីកន្លែងនៃតុលាការដែលខ្លួនបានចុះឈ្មោះ និងលេខដែល ខ្លួនបានចុះក្នុងបញ្ជីពាណិជ្ជកម្ម ។

**មាត្រា ៤១ .-**

ការដែលមិនបានបំពេញកាតព្វកិច្ចសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមកាលបញ្ញត្តិអាចបណ្តាលឲ្យពាណិជ្ជករឬអ្នកដឹកនាំក្រុមហ៊ុនមានទោសនិទ្ធនភាពសាមញ្ញក្នុងករណីធនក្ស័យ ។

**មាត្រា ៤២ .-**

រាល់ពាណិជ្ជករ ឬរាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណា ដែលបានផ្តល់នូវពត៌មានមិនពិតដោយគំនិតអាក្រក់ ដើម្បីនឹងសុំចុះលេខ ឬសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មត្រូវផ្តន្ទាទោសដាក់គុកពីមួយឆ្នាំ (១ឆ្នាំ) ទៅប្រាំឆ្នាំ (៥ឆ្នាំ) និងត្រូវពិន័យជាប្រាក់ពីមួយលានរៀល (១.០០០.០០០ រៀល) ទៅដប់លានរៀល (១០.០០០.០០០ រៀល) ។

ក្នុងករណីដែលមានការផ្លាស់ប្តូរកែប្រែពត៌មាន ដូចបានកំណត់ក្នុងមាត្រា ១៥-១ ១៨-១ និង ២០ រាល់ពាណិជ្ជករ ឬអ្នកដឹកនាំក្រុមហ៊ុនណា ដែលមិនបានបំពេញបែបបទនៅការិយាល័យ ក្រឡាបញ្ជីតុលាការពាណិជ្ជកម្ម ក្នុងរយៈពេល ១៥ ថ្ងៃ ក្រោយពីមានការផ្លាស់ប្តូរកែប្រែនេះ ត្រូវពិន័យ ជាប្រាក់ចំនួនពីប្រាំសែនរៀល (៥០០.០០០ រៀល) ទៅមួយលានរៀល (១.០០០.០០០ រៀល) ។

**មាត្រា ៤៣ .-**

រាល់ពាណិជ្ជករឬរាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណាដែលប្រើឯកសារក្លែងក្លាយដោយចេតនានៅក្នុងទំនាក់ទំនងពាណិជ្ជកម្ម ត្រូវផ្តន្ទាទោសជាក់គុកពីមួយឆ្នាំ (១ឆ្នាំ) ទៅប្រាំឆ្នាំ (៥ឆ្នាំ) និងពិន័យជាប្រាក់ពីមួយលានរៀល (១.០០០.០០០ រៀល) ទៅដប់លានរៀល (១០.០០០.០០០ រៀល) ។

**មាត្រា ៤៤ .-**

ក្នុងករណីមិនរាងចាល ការផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ៤០, ៤២, ៤៣ នឹងត្រូវអនុវត្តក៏រិតអតិបរមា ហើយបើមានបទល្មើសដែលបានកំណត់ក្នុងមាត្រា ៤២-១ មិនរាងចាលនោះ រាល់ពាណិជ្ជករ ឬអ្នកដឹកនាំក្រុមហ៊ុន ត្រូវផ្តន្ទាទោសជាប់គុកពី ៣ ខែ ទៅ ១ ឆ្នាំ ។

**មាត្រា ៤៥ .-**

ជនណាដែលបានជំរិតឬបានទទួលនូវរបស់ ឬប្រាក់ដោយប្រើអំណាចនៃមុខងាររបស់ខ្លួន ជននោះត្រូវចាត់ទុកថាបានប្រព្រឹត្តបទល្មើស ហើយនិងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**មាត្រា ៤៦ .-**

ប្រាក់ពិន័យទាំងឡាយដូចមានចែងក្នុងច្បាប់នេះត្រូវបង់ចូលថវិការដ្ឋ ។

## ជំពូកទី ៣

## ភារកិច្ចគណនេយ្យ

**មាត្រា ៤៧ .-**

រាល់ពាណិជ្ជករ ឬរាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មមានភារកិច្ចកាន់កាប់គណនេយ្យមួយទៅតាមវិធានគណនេយ្យនិងតាមប្លង់គណនេយ្យទូទៅ នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងការណែនាំផ្សេងៗទៀតដែលទាក់ទងដល់ការអនុវត្តន៍ ។

រាល់ពាណិជ្ជករឬរាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណាដែល

ប្រព្រឹត្តល្មើសផ្ទុយនឹងបទបញ្ញាតណាមួយដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើនេះ ត្រូវចោទប្រកាន់និងផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**មាត្រា ៤៨ .-**

គ្រប់ក្រុមហ៊ុនពាណិជ្ជកម្ម ដែលបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មត្រូវបើកគណនីយ៉ាងហោចមួយនៅធនាគារណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤៩ .-**

រាល់ពាណិជ្ជកិច្ចដែលធ្វើឡើងរវាងអាជីវករនិងអាជីវករត្រូវមានវិក័យប័ត្រយ៉ាងហោចណាស់ពីរច្បាប់ ។ ច្បាប់ដើមមួយសន្លឹកសំរាប់ផ្តល់ជូនអតិថិជន ហើយសន្លឹកផ្សេងទៀតត្រូវរក្សាទុកដោយអ្នកលក់ ។

ចំពោះការលក់ទំនិញ ឬការធ្វើសេវាឲ្យអ្នកប្រើប្រាស់ពុំចាំបាច់ធ្វើវិក័យប័ត្រ ឬសក្ខីប័ត្រទេ លើកលែងតែអតិថិជនទាមទារ ។

**មាត្រា ៥០ .-**

ក្នុងវិក័យប័ត្រត្រូវមានចុះយ៉ាងហោចណាស់នូវនិទ្ទេស ដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ៥១ .-**

រាល់ពាណិជ្ជករត្រូវបិទតម្លៃនិងលក្ខខ័ណ្ឌនៃការលក់ដូរដែលនៅជាធរមាន ។ បែបបទ នៃការបិទផ្សាយ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ។

**មាត្រា ៥២ .-**

រាល់ថ្លៃទាំងឡាយត្រូវតែកំណត់ជាប្រាក់រៀល លើកលែងតែក្នុងករណីដែល មានការអនុញ្ញាតពីក្រសួងពាណិជ្ជកម្ម ។

**មាត្រា ៥៣ .-**

រាល់ការទិញឬការលក់រវាងពាណិជ្ជករនិងពាណិជ្ជករ ដែលមានទឹកប្រាក់ស្មើ ឬលើសពីដប់លានរៀល (១០.០០០.០០០រៀល) ឬសមមូលជារូបិយប័ណ្ណបរទេស ត្រូវតែធ្វើការទូទាត់ដោយមូលប្បទានប័ត្រ ឬដោយផលប័ត្រពាណិជ្ជកម្ម។

# ជំពូកទី ៤

## អន្តរប្បញ្ញត្តិ

**មាត្រា ៥៤ .-**

ក្នុងរយៈកាលដែលព្រះរាជាណាចក្រកម្ពុជានៅពុំទាន់មានតុលាការពាណិជ្ជកម្ម ការចាត់ចែងការកាន់កាប់បញ្ជីពាណិជ្ជកម្ម និងការគ្រប់គ្រងសមត្ថភាពពាណិជ្ជកម្ម ដែលមានចែងនៅក្នុងច្បាប់នេះ ត្រូវប្រគល់ជូនក្រសួងពាណិជ្ជកម្ម ។

**មាត្រា ៥៥ .-**

ក្នុងរយៈកាលដែលព្រះរាជាណាចក្រកម្ពុជានៅពុំទាន់មានតុលាការពាណិជ្ជកម្ម តុលាការ នីតិសាមញ្ញនៃព្រះរាជាណាចក្រកម្ពុជាមានសមត្ថកិច្ចលើរឿងក្តីពាណិជ្ជកម្ម ទាំងអស់ ។

**មាត្រា ៥៦ .-**

ក្រសួងនីមួយៗដែលពាក់ព័ន្ធត្រូវជំរុញរាល់ពាណិជ្ជករឬរាល់ក្រុមហ៊ុនពាណិជ្ជកម្មឲ្យចាត់ចែងធ្វើពាក្យសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម នៅពេលដែលច្បាប់នេះ ចូលជាធរមាន។

**មាត្រា ៥៧ .-**

នៅក្រោយពេលបញ្ចប់សម័យអន្តរកាល ក្រសួងពាណិជ្ជកម្មនិងតុលាការពាណិជ្ជកម្ម ត្រូវសហការគ្នាដើម្បីផ្ទេរបញ្ជីពាណិជ្ជកម្មជូនទៅការិយាល័យក្រឡាបញ្ជី នៃតុលាការពាណិជ្ជកម្ម ។

**មាត្រា ៥៨ .-**

រាល់ពាណិជ្ជករនិងរាល់ក្រុមហ៊ុនពាណិជ្ជកម្ម ដែលបានធ្វើសកម្មភាពមុនការប្រកាសឲ្យប្រើច្បាប់នេះ ត្រូវប្តឹងសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្មក្នុងរយៈពេល៦ខែ។បើមានការចាំបាច់ក្រសួងពាណិជ្ជកម្មអាចសំរេចបន្តរយៈពេលនេះបាន ៦ ខែ ទៀត ។

## ជំពូកទី ៥

## អវសានបញ្ញត្តិ

**មាត្រា ៥៩ .-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦០ .-**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ . ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

**នរោត្តម សីហនុ**

# ច្បាប់ស្តី

# វិ.ច្បាប់ស្តីពី

# វិធានពាណិជ្ជ

# កម្ម និងបញ្ញើ

# ពាណិជ្ជកម្ម

# ១៩៩៩

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ១- ព្រះរាជក្រម

### ព្រះរាជក្រម នស/រកម/១១៩៩/១២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់ទតរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ទតព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើជារដ្ឋការនូវច្បាប់ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ទតព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ទតព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់ទតព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់ទតព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៦ មាត្រា១៧ មាត្រា២១ មាត្រា២២ មាត្រា២៥ មាត្រា២៦ មាត្រា២៨ មាត្រា២៩ មាត្រា៣០ មាត្រា៣១ មាត្រា៣២ មាត្រា៣៣

មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៤០ មាត្រា៤២ មាត្រា៤៤ ក្នុងជំពូកទី២ មាត្រា៥៤ មាត្រា៥៧ មាត្រា៥៨ ក្នុងជំពូកទី៤ និង មាត្រា៥៩ មាត្រា៦០ ក្នុងជំពូកទី៥ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី២ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមទំរង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គលើកទី២ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

## ច្បាប់

## ស្តីពី

## វិសោធនកម្មមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៦ មាត្រា១៧ មាត្រា២១ មាត្រា២២ មាត្រា២៥ មាត្រា២៦ មាត្រា២៨ មាត្រា២៩ មាត្រា៣០ មាត្រា៣១ មាត្រា៣២ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៤០ មាត្រា៤២ មាត្រា៤៤ ក្នុងជំពូកទី២ មាត្រា៥៤ មាត្រា៥៧ មាត្រា៥៨ ក្នុងជំពូកទី៤ និង មាត្រា៥៩ មាត្រា៦០ ក្នុងជំពូកទី៥ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម

**មាត្រាតែមួយ.-** មាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៦ មាត្រា១៧ មាត្រា២១ មាត្រា២២ មាត្រា២៥ មាត្រា២៦ មាត្រា២៨ មាត្រា២៩ មាត្រា៣០ មាត្រា៣១ មាត្រា៣២ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៤០ មាត្រា៤២ មាត្រា៤៤ ក្នុងជំពូកទី២ មាត្រា៥៤ មាត្រា៥៧ មាត្រា៥៨ ក្នុងជំពូកទី៤ និងមាត្រា៥៩ មាត្រា៦០ ក្នុងជំពូកទី៥ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ត្រូវកែប្រែដូចតទៅ ៖

**មាត្រា១០ថ្មី.-** ការគ្រប់គ្រងនិងកាន់កាប់ទូវបញ្ជីអ្នកចុះអត្តសញ្ញាណនៃពាណិជ្ជករ និងក្រុមហ៊ុនពាណិជ្ជកម្ម ដែលហៅថា «បញ្ជីពាណិជ្ជកម្ម» ជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម ។

**មាត្រា១១ថ្មី.-** ក្រសួងពាណិជ្ជកម្មត្រូវបញ្ជូនច្បាប់ចំលងនៃសៀវភៅបញ្ជីពាណិជ្ជកម្ម និងរាល់ឯកសារដែលពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជកម្មនីមួយៗ ជូនទៅតុលាការពាណិជ្ជកម្ម ដើម្បីតំកល់ជាឯកសារសំរាប់យុត្តាធិការពាណិជ្ជកម្ម ។

**មាត្រា១៤ថ្មី.-** យ៉ាងតិចបំផុតដប់ប្រាំថ្ងៃ (១៥ថ្ងៃ) មុនពេលចាប់ផ្តើមបើកធ្វើពាណិជ្ជកម្មរបស់ខ្លួន ពាណិជ្ជករត្រូវចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនាកន្លែងដែលខ្លួនធ្វើអាជីវកម្ម ។

ទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មមាននៅតាមមន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង ឬនៅទីកន្លែងផ្សេងទៀត តាមការកំណត់របស់ក្រសួងពាណិជ្ជកម្ម ។

ពាណិជ្ជករត្រូវប្រគល់ទៅទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្ម នូវប្រតិវេទន៍មួយធ្វើជាពីរច្បាប់ មានចុះហត្ថលេខា ឬស្នាមមេដៃរបស់សាមីខ្លួន ។

ប្រតិវេទន៍នេះត្រូវសរសេរលើលិខិតគំរូមួយ ដែលមន្ត្រីចុះបញ្ជីពាណិជ្ជកម្មបានផ្តល់ឲ្យ ។ ប្រតិវេទន៍ត្រូវចែងអំពី :

១- នាមត្រកូល និងនាមខ្លួនរបស់ពាណិជ្ជករ និងលេខ នៃលិខិតអត្តសញ្ញាណរបស់ខ្លួន ។

២- នាមប្រើប្រាស់ក្នុងពាណិជ្ជកម្ម ឬរហស្សនាម ។

៣- ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត ព្រមទាំងអាសយដ្ឋានផ្ទាល់ខ្លួន ។

៤- សញ្ជាតិដើម ហើយក្នុងករណីដែលសាមីខ្លួនបានទទួលសញ្ជាតិមួយផ្សេងទៀត ត្រូវបញ្ជាក់អំពីរបៀប និងថ្ងៃ ខែ ឆ្នាំ ដែលបានទទួលសញ្ជាតិនេះ ។

៥- កម្មវត្ថុពាណិជ្ជកម្ម ។

៦- ទីកន្លែងធ្វើអាជីវកម្ម និងអាសយដ្ឋានគ្រឹះស្ថាន ឬសាខានៃមូលនិធិពាណិជ្ជកម្ម ដែលមានទីតាំងនៅព្រះរាជាណាចក្រកម្ពុជា

៧- ផ្លាកសញ្ញាពាណិជ្ជកម្មនៃគ្រឹះស្ថាន និងហត្ថលេខាផ្ទាល់របស់សាមីខ្លួន ព្រមទាំងស្នាមត្រាគំរូ ។

៨- លិខិតអត្តសញ្ញាណរបស់អ្នកតំណាងពេញសិទ្ធិ ដែលទទួលបន្ទុកក្នុងការសុំចុះ បញ្ជីពាណិជ្ជកម្ម ។

៩- គ្រឹះស្ថានពាណិជ្ជកម្មដែលអ្នកស្នើសុំបានធ្វើអាជីវកម្មពីមុន ឬគ្រឹះស្ថានពាណិជ្ជកម្មដែលអ្នកស្នើសុំកំពុងធ្វើអាជីវកម្មនៅក្នុងរង្វង់សមត្ថកិច្ច ក្រសួងពាណិជ្ជកម្ម ។

១០- សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់អ្នកស្នើសុំថា គ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្ម ។

១១- ក្នុងករណីចាំបាច់ លិខិតអនុញ្ញាតឲ្យប្រកបមុខរបរ ចំពោះមុខរបរណា ឬ ចំពោះកម្មវត្ថុពាណិជ្ជកម្មណាដែលតំរូវឲ្យមានសេចក្តីអនុញ្ញាត ។ មន្ត្រីចុះបញ្ជីពាណិជ្ជកម្មត្រូវចម្លងសេចក្តីក្នុងប្រតិវេទន៍ចូលក្នុងបញ្ជីពាណិជ្ជកម្ម ដោយប្រគល់ប្រតិវេទន៍នេះ មួយច្បាប់ក្នុងចំណោមប្រតិវេទន៍ទាំងពីរច្បាប់ ជូនទៅអ្នកស្នើសុំចុះឈ្មោះដោយបញ្ជាក់នៅខាងក្រោមថា "បានចម្លងចូលបញ្ជីរួចហើយ" ។

**មាត្រា១៦ថ្មី .-** ការចុះនិទ្ទេសផ្លូវការដែលចែងក្នុងមាត្រា១៥ នៃច្បាប់នេះ ជាភារកិច្ចផ្ទាល់ខ្លួនរបស់ពាណិជ្ជករ ។ ប៉ុន្តែចំពោះករណីដែលមានចែងនៅក្នុងចំណុច ២, ៤និង ៦

នៃមាត្រា១៥ មន្ត្រីចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្មអាចចុះសេចក្តីនោះជាបញ្ញត្តិក្នុងបញ្ជីពាណិជ្ជកម្ម ដែលសាមីពាណិជ្ជករបានចុះឈ្មោះ ។

**មាត្រា១៧ថ្មី .-** គ្រប់ក្រុមហ៊ុន ដែលមានសកម្មភាពពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា ត្រូវចុះក្នុងបញ្ជីពាណិជ្ជកម្ម ទោះកិរិយាបទនៃការបង្កើតនិងគោលដៅរបស់ក្រុមហ៊ុនទាំងនោះមានលក្ខណៈបែបណាក៏ដោយ ។

ការចុះឈ្មោះនេះ ត្រូវធ្វើឡើងដោយបណ្ណាធិការ ឬអភិបាលនៃសាមីក្រុមហ៊ុន នៅក្នុងខែនៃការបង្កើតក្រុមហ៊ុន និងដប់ប្រាំថ្ងៃ (១៥ថ្ងៃ) មុនកាលបរិច្ឆេទបើកប្រតិបត្តិការពាណិជ្ជកម្ម ។

អ្នកស្នើសុំចុះឈ្មោះ ត្រូវផ្តល់ជូនទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មនូវប្រតិវេទន៍ចំនួនពីរច្បាប់ មានចុះហត្ថលេខារបស់សាមីខ្លួនអ្នកស្នើសុំព្រមទាំងភ្ជាប់លក្ខន្តិកៈក្រុមហ៊ុនផង ។

ប្រតិវេទន៍ ដែលមន្ត្រីចុះបញ្ជីពាណិជ្ជកម្មផ្តល់គំរូជូននោះត្រូវចែងអំពី :

១- នាមត្រកូលនិងនាមខ្លួន រហស្សនាមរបស់សមាជិកក្រុមហ៊ុន ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត ស្ថានភាពគ្រួសារ និងសញ្ជាតិ ។

២- ផ្លាកសញ្ញារបស់ក្រុមហ៊ុន ។

៣- កម្មវត្ថុនៃក្រុមហ៊ុន ។

៤- ទីកន្លែងទាំងឡាយដែលក្រុមហ៊ុនមានគ្រឹះស្ថានដើមមានសាខា ឬទីភ្នាក់ងារនៅព្រះរាជាណាចក្រកម្ពុជា ។

៥- នាមនៃសមាជិកឬតតិយជនដែលមានការអនុញ្ញាតឲ្យគ្រប់គ្រង ចាត់ចែង ចុះចាត់ចែង និងចុះហត្ថលេខាជំនួសមុខក្រុមហ៊ុន ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើតនៃអ្នកទាំងនេះ ។

៦- ដើមទុនរបស់ក្រុមហ៊ុន ប្រភពដើមទុន និងចំនួនទឹកប្រាក់ ឬវត្ថុមានតំលៃដែលផ្តល់ដោយសមាជិកភាគហ៊ុន ប្រសិនបើជាក្រុមហ៊ុនដោយភាគហ៊ុន ។

៧- ថ្ងៃ ខែ ឆ្នាំ ដែលក្រុមហ៊ុននោះចាប់ផ្តើម និងបញ្ចប់ ។

៨- ទ្រង់ទ្រាយក្រុមហ៊ុន ។

៩- ហត្ថលេខាគំរូរបស់សមាជិក ឬតតិយជនដូចមានចែងនៅចំណុចលេខ៥ នៃមាត្រានេះ និងស្នាមត្រាគំរូរបស់ក្រុមហ៊ុន ។

១០- លិខិតបញ្ជាក់អំពីការតម្កល់ដើមទុនចេញដោយធនាគារ ។

១១- សេចក្ដីប្រកាសដោយកិត្តិយសរបស់អ្នកស្នើសុំថា គ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការ ពាណិជ្ជកម្ម រដ្ឋប្បវេណីឬព្រហ្មទណ្ឌ ។

**មាត្រា២១ថ្មី .-** ប្រតិវេទន៍ធ្វើឡើងជាពីរច្បាប់ត្រូវយកទៅដាក់ដោយអ្នកស្នើសុំ ឬដោយអាណត្តិគាហក របស់គាត់ផងនោះ ក្នុងករណីនេះ អាណត្តិគាហកត្រូវមានលិខិតប្រគល់សិទ្ធិអំណាច ដែលត្រូវតម្កល់ទុកនៅទីចាត់ផ្នែកចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

**មាត្រា២២ថ្មី .-** បើប្រតិវេទន៍ត្រូវបានយកទៅដាក់ផ្ទាល់ដោយអ្នកស្នើសុំនោះ មន្ត្រីចុះបញ្ជីពាណិជ្ជកម្ម ត្រូវពិនិត្យផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់សាមីខ្លួនឲ្យបានច្បាស់លាស់ ។ បើសិនប្រតិវេទន៍ នេះ ត្រូវបានយកទៅតម្កល់ទុកដោយអាណត្តិគាហក មន្ត្រីចុះបញ្ជីពាណិជ្ជកម្ម ត្រូវតម្រូវឲ្យមានការបញ្ជាក់អំពីអត្តសញ្ញាណរបស់អាណត្តិទាយក ឬការបញ្ជាក់អំពីស្នាម មេដៃ បើអាណត្តិទាយកមិនចេះចុះហត្ថលេខា និងតម្រូវឲ្យបង្ហាញលិខិតបញ្ជាក់ អត្តសញ្ញាណ របស់អ្នកស្នើសុំ ។

**មាត្រា២៥ថ្មី .-** មន្ត្រីចុះបញ្ជីពាណិជ្ជកម្មនឹងផ្ទៀងផ្ទាត់មើលក្រោមការទទួលខុសត្រូវផ្ទាល់ របស់ខ្លួន អំពីភាពពេញទាំងស្រុងដែលបានបញ្ជូន ។ មន្ត្រីចុះបញ្ជីពាណិជ្ជកម្មត្រូវចុះនៅលើផ្នែក ខាងលើនៃប្រតិវេទន៍នូវ ៖

១- ថ្ងៃ ខែ ឆ្នាំ ម៉ោងនៃការតម្កល់ទុក និងទីកន្លែងក្រសួងពាណិជ្ជកម្ម ។

២- លេខរៀងរបស់ប្រតិវេទន៍តាមលំដាប់លេខជាបន្តបន្ទាប់ ក៏ប៉ុន្តែការចុះលេខ នេះ ត្រូវចាប់ផ្ដើមឡើងវិញចាប់ពីថ្ងៃទី ០១ មករា ជារៀងរាល់ឆ្នាំ ។

៣- អត្តលេខសំគាល់ទៅតាមប្រភេទនៃសកម្មភាពរបស់ពាណិជ្ជករ ដែលចុះក្នុង បញ្ជីរាយដែលនឹងមានចែងខាងក្រោយ ។

ចំពោះអ្នកធ្វើប្រតិវេទន៍ណាដែលមិនបានផ្ដល់នូវរាល់ព័ត៌មានគ្រប់គ្រាន់ ដល់ ការចុះបញ្ជី នឹងត្រូវបានអនុញ្ញាតរយៈពេលពិសេសចំនួនដប់ប្រាំថ្ងៃ (១៥ថ្ងៃ)បន្ថែម ។

**មាត្រា២៦ថ្មី .-** ដោយបានឃើញប្រតិវេទន៍ជាលាយលក្ខណ៍អក្សរ និងរាល់ឯកសារតម្កល់ តម្កល់ទុក មន្ត្រីចុះបញ្ជីពាណិជ្ជកម្មនឹងផ្ដល់នូវវិញ្ញាបនប័ត្រចុះបញ្ជីហៅថា "សំរង់" ដែលមាន ចែងអត្តលេខសំគាល់ចុះក្នុងបញ្ជីពាណិជ្ជកម្ម ។ វិញ្ញាបនប័ត្រនេះ ស្ថិតក្នុងលក្ខណៈ បណ្ដោះអាសន្នក្នុងចំរយៈពេលមួយខែ (១ខែ) គិតចាប់ពីកាលបរិច្ឆេទ ដែលបានផ្ដល់ ជូន ។ ក្នុងចំរយៈពេលនេះ ប្រសិនបើរកឃើញថាជាប្រតិវេទន៍ក្លែងបន្លំ មន្ត្រីចុះបញ្ជី

ពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម អាចជំទាស់នឹងការចុះបញ្ជីនិងតបទៅលើអត្តលេខសំគាល់ ដែលមានចុះក្នុងបញ្ជីហើយនោះ ។

មន្ត្រីចុះបញ្ជីពាណិជ្ជកម្មដែលផ្តល់នូវវិញ្ញាបនប័ត្រក្លែងបន្លំ ដែលបានធ្វើឡើងដោយដឹងហេតុផលសព្វគ្រប់ ត្រូវទទួលទោសតាមច្បាប់ ។

**មាត្រា២៨ថ្មី .-** កាលណាបើពាណិជ្ជករណាម្នាក់ឈប់ប្រកបពាណិជ្ជកម្មរបស់ខ្លួន ឬទទួល មរណភាព ដោយពុំបានធ្វើអនុប្បទាននូវមូលនិធិពាណិជ្ជកម្មរបស់ខ្លួន ឬកាលណាបើក្រុមហ៊ុនណាមួយត្រូវរំលាយនោះ ត្រូវលុបឈ្មោះពាណិជ្ជករនោះ ឬក្រុមហ៊ុននោះចេញពីបញ្ជី។

បើសិនជាគ្មានការសុំលុបឈ្មោះដោយពាណិជ្ជករឬដោយអ្នកទទួលមរតក ឬដោយអ្នកជំរះបញ្ជី ការលុបឈ្មោះចេញពីបញ្ជីនេះត្រូវធ្វើឡើងដោយបញ្ញត្តិតាមសេចក្តីសំរេចរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

រាល់ឯកសារដែលពាក់ព័ន្ធនឹងការលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្មនេះ ត្រូវចំលងជូនទៅតុលាការពាណិជ្ជកម្ម ដើម្បីតំកល់ជាឯកសារសំរាប់យុត្តាធិការពាណិជ្ជកម្ម។

**មាត្រា២៩ថ្មី .-** ជនណាក៏ដោយអាចសុំឲ្យមន្ត្រីចុះបញ្ជីពាណិជ្ជកម្មចេញឲ្យខ្លួននូវវិញ្ញាបនប័ត្រ បញ្ជាក់អំពីចំណារទាំងឡាយ ដែលមានចុះក្នុងបញ្ជីពាណិជ្ជកម្ម ។ បើគ្មានចុះបញ្ជីទេ មន្ត្រីចុះបញ្ជីពាណិជ្ជកម្ម ត្រូវចេញវិញ្ញាបនប័ត្របញ្ជាក់ថា គ្មានចុះបញ្ជី ។

ការធ្វេសប្រហែស ឬការមិនព្រមចេញវិញ្ញាបនប័ត្រក្នុងរយៈពេលមួយសប្តាហ៍ គិតចាប់ពីថ្ងៃស្នើសុំ នឹងអាចនាំឲ្យមានទណ្ឌកម្មតាមវិន័យចំពោះមន្ត្រីចុះបញ្ជីពាណិជ្ជកម្ម ព្រមទាំងមានការសងជំងឺចិត្តផង ។

សេចក្តីចំឡង ដែលមន្ត្រីចុះបញ្ជីពាណិជ្ជកម្មចេញឲ្យនោះ មិនត្រូវចែងសាលក្រមប្រកាសធនក្ស័យឬការជំរះបញ្ជីតាមផ្លូវតុលាការទេ បើក្រោយមកមាននីតិសម្បទាឡើងវិញ ។ សេចក្តីចំឡងក៏មិនត្រូវចុះផងដែរនូវសាលក្រម ឬសាលដីកាហាមឃាត់មិនឲ្យធ្វើពាណិជ្ជកម្ម ឬសាលក្រម សាលដីកាតែងតាំងក្រុមប្រឹក្សាជំនួយ បើមានលើកការហាមឃាត់ចេញរួចហើយ ។

**មាត្រា៣០ថ្មី .-** បញ្ជីពាណិជ្ជកម្ម ដែលតំកល់ទុកនៅទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម មានពីរបែប គឺ:

១- បញ្ជីកាលប្បវត្តិ

២- បញ្ជីវិភាគី

មាត្រា៣១ថ្មី .- ប្រតិវេទន៍ត្រូវចុះក្នុងប្រគល់បញ្ជីកាលប្បវត្តិ តាមលំដាប់នៃការតំកល់ទុកនៅទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្ម និងតាមលេខដែលចុះ ។

ត្រូវប្រគល់ចុងសន្លឹកនៃប្រតិវេទន៍មួយសន្លឹក ដែលកាត់ចេញពីគល់បញ្ជីហៅថា "គល់វង់" ជាសំគាល់នៃការតំកល់ទុកដោយមានចែងនិទ្ទេសដូចតទៅ :

១- លេខរៀងនៃប្រតិវេទន៍

២- ថ្ងៃ ខែ ឆ្នាំ ម៉ោងនៃការតំកល់ទុក និងទីកន្លែងនៃក្រសួងពាណិជ្ជកម្ម

៣- នាមត្រកូល នាមខ្លួន ផ្លាកសញ្ញាក្រុមហ៊ុន និងលំនៅដ្ឋានអ្នកធ្វើប្រតិវេទន៍ ។

ចំណែកឯបញ្ជីវិភាគីវិញ មានទ្រង់ទ្រាយជាតារាងដែលត្រូវចុះជាអាទិ៍នូវលេខថ្ងៃ ខែ ឆ្នាំ ម៉ោងនៃការតំកល់ទុក អត្តលេខ នាមករណ៍ក្រុមហ៊ុន កម្មវត្ថុនៃក្រុមហ៊ុន ដើមទុននៃក្រុមហ៊ុន ។ គ្រឹះស្ថានពាណិជ្ជកម្មនីមួយៗដែលជាកម្មវត្ថុនៃការចុះអត្តលេខសំគាល់ដោយឡែក ត្រូវបានចុះលើសន្លឹកមួយទាំងសងខាង ហើយនៅលើសន្លឹកនោះ មន្ត្រីចុះបញ្ជីពាណិជ្ជកម្មត្រូវចារលេខប្រតិវេទន៍ដើមនៃការសុំចុះបញ្ជីនោះ ។

មាត្រា៣២ថ្មី .- បើមានពាក្យសុំឲ្យចុះនិទ្ទេសដែលបង្កឲ្យលុបចោលនិទ្ទេសដែលមានស្រាប់ មន្ត្រីចុះបញ្ជីពាណិជ្ជកម្មត្រូវគូសលុបនិទ្ទេសនេះ ដោយទឹកខ្មៅក្រហម ឬលុបខ្វែងចំណាំតាមកម្មវិធីកុំព្យូទ័រ ដោយមានគុសរសេរបង្ហាញនៅរឹមទំព័រនូវសេចក្តីយោងនៃនិទ្ទេសថ្មី និងលេខ ដែលក្រោមលេខនេះ ប្រតិវេទន៍ ឬពាក្យសុំចុះនិទ្ទេសនោះ ត្រូវបានចុះបញ្ជីដោយពិតប្រាកដ ។

មាត្រា៣៣ថ្មី .- បើសិនមានការលុបឈ្មោះចេញពីបញ្ជី ការលុបនេះត្រូវធ្វើឡើងដោយគំនូសក្រហមពីរខ្វែងគ្នា ឬលុបតាមវិធីកុំព្យូទ័រ ។

សេចក្តីសំរេចលុបឈ្មោះចេញពីបញ្ជីដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឬពាក្យសុំឲ្យលុបឈ្មោះនោះ ត្រូវកំណត់គុសរសេរនៅលើរឹមទំព័រដោយទឹកខ្មៅក្រហមផងដែរ ។

មន្ត្រីចុះបញ្ជីពាណិជ្ជកម្មបញ្ជាក់និទ្ទេសនេះ ដោយចុះហត្ថលេខាសង្ខេប ។

មាត្រា៣៤ថ្មី .- កាលបើនិទ្ទេសដែលមាននៅក្នុងប្រតិវេទន៍ ត្រូវបានកត់ត្រាបញ្ចូលទៅក្នុងបញ្ជី វិភាគី មន្ត្រីចុះបញ្ជីពាណិជ្ជកម្មត្រូវប្រគល់ជូនអ្នកដែលបានមកតំកល់ទុកនូវប្រតិវេទន៍ មួយច្បាប់ ដែលមានចុះហត្ថលេខាត្រឹមត្រូវសំរាប់ប្រើប្រាស់ជាវិញ្ញាបនប័ត្រចុះឈ្មោះ ។

សន្លឹកប្រតិវេទន៍ទាំងអស់ ដែលរក្សាទុកនៅទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ត្រូវមន្ត្រីចុះបញ្ជីពាណិជ្ជកម្មចងក្រងតាមលេខរៀងយ៉ាងហោចណាស់មួយដងក្នុងមួយឆ្នាំ ។

**មាត្រា៣៥ថ្មី .-** បញ្ជីកាលប្បវត្តិ និងបញ្ជីវិភាគត្រូវបានរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មជាអ្នកបង់លេខ ចុះហត្ថលេខាសង្ខេប និងពិនិត្យបញ្ចប់នៅពេលដាច់ខែម្តងៗ ។ ការពិនិត្យ បញ្ចប់នេះត្រូវមានបោះត្រារបស់ក្រសួងពាណិជ្ជកម្ម និងចុះហត្ថលេខារបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

ពេលរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មបញ្ជាក់ថាប្រតិវេទន៍ណាមួយពុំស្ថិតក្នុងករណីដែលមានចែងក្នុងមាត្រា៥០ថ្មី និងមាត្រា៥១ នៃច្បាប់នេះ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មត្រូវប្តឹងអំពីរឿងនេះ ទៅព្រះរាជអាជ្ញាអមតុលាការ មានសមត្ថកិច្ច ។

**មាត្រា៣៦ថ្មី .-** ការចុះឈ្មោះ ការលុបឈ្មោះ ឬការចេញវិញ្ញាបនប័ត្រផ្សេងៗជាភារៈផ្ទាល់របស់មន្ត្រីចុះបញ្ជីពាណិជ្ជកម្ម ។ វិញ្ញាបនប័ត្រទាំងនេះ ត្រូវចេញឲ្យអ្នកសុំពីគេស្រង់ពីក្បាលបញ្ជីមានលេខ ។ អាករលើបែបបទចុះឈ្មោះ លុបឈ្មោះ ឬចេញវិញ្ញាបនប័ត្រផ្សេងៗ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយប្រមូលដោយមន្ត្រីចុះបញ្ជីពាណិជ្ជកម្ម សំរាប់បង់ចូលថវិការដ្ឋ ។

**មាត្រា៣៧ថ្មី .-** សេចក្តីចំលងនៃការចុះឈ្មោះក្នុងបញ្ជី ការលុបឈ្មោះចេញពីបញ្ជី និងវិញ្ញាបនប័ត្របញ្ជាក់ពីការគ្មានចុះឈ្មោះចេញដោយមន្ត្រីចុះបញ្ជីពាណិជ្ជកម្ម ត្រូវផ្តល់ជូនដោយឥតគិតថ្លៃតាមពាក្យសុំរបស់អាជ្ញាធរតុលាការ ឬរដ្ឋបាលពន្ធ លុះត្រាតែអាចចុះនិទ្ទេសពីកន្លែងអ្នកទទួលលិខិតនោះ ។

**មាត្រា៣៨ថ្មី .-** រាល់ការចុះឈ្មោះក្នុងបញ្ជី និងលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម ត្រូវបានចុះផ្សាយដោយមន្ត្រីចុះបញ្ជីពាណិជ្ជកម្មក្នុងរាជកិច្ច ។ និទ្ទេសដែលត្រូវចុះផ្សាយមានដូចខាងក្រោមនេះ :

ក-ចំពោះពាណិជ្ជករ

១- លេខចុះបញ្ជី
២- នាមត្រកូល នាមខ្លួន រហស្សនាម ព្រមទាំងនាមសហព័ទ្ធ
៣- សកម្មភាព ទីកន្លែង ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើមសកម្មភាព
៤- ផ្លាកសញ្ញា ។

ខ-ចំពោះក្រុមហ៊ុន

១- លេខចុះបញ្ជី
២- នាមករណ៍
៣- ចំនួនដើមទុន
៤- ទីស្នាក់ការ
៥- សកម្មភាព និងថ្ងៃ ខែ ឆ្នាំចាប់ផ្តើម
៦- ទ្រង់ទ្រាយក្រុមហ៊ុន ។

មាត្រា៤០ថ្មី.- ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី (ប្រាំម៉ឺន) ៥០.០០០រៀល ទៅ(ប្រាំសែន) ៥០០.០០០រៀល ចំពោះ :

១- រាល់ពាណិជ្ជករ ឬរាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណា ដែលមិនបានចុះបញ្ជីពាណិជ្ជកម្មតាមការកំណត់ ។

២- រាល់ពាណិជ្ជករ ឬរាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណា ដែលបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មហើយ តែមិនបានចុះនៅលើវិក្កយបត្រ លិខិតស្នាម កំណត់បញ្ជាទិញ តារាងតំលៃឯកសារផ្សព្វផ្សាយអំពីទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្ម ដែលខ្លួនបានចុះឈ្មោះនិងលេខដែលខ្លួនបានចុះក្នុងបញ្ជីពាណិជ្ជកម្ម ។

មាត្រា៤២ថ្មី .- រាល់ពាណិជ្ជករ ឬរាល់អ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណា ដែលបានផ្តល់នូវពត៌មានមិនពិតដោយចេតនាទុច្ចរិត ដើម្បីនឹងសុំចុះលេខ ឬសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីមួយឆ្នាំ (១ឆ្នាំ) ទៅប្រាំឆ្នាំ (៥ឆ្នាំ) និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី មួយលាន (១.០០០.០០០) រៀល ទៅដប់លាន (១០.០០០.០០០) រៀល ។

ក្នុងករណីដែលមានការផ្លាស់ប្តូរកែប្រែពត៌មានដូចបានកំណត់ក្នុងមាត្រា ១៥ ចំណុច១ មាត្រា១៨ ចំណុច១ និងមាត្រា២០ រាល់ពាណិជ្ជករ ឬអ្នកដឹកនាំក្រុមហ៊ុនណាដែលមិនបានបំពេញបែបបទនៅទីកន្លែងទទួលពាក្យចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ក្នុងរយៈពេលដប់ប្រាំថ្ងៃ (១៥ថ្ងៃ) ក្រោយពីមានការផ្លាស់ប្តូរ កែប្រែនេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីប្រាំសែន (៥០០.០០០) រៀល ទៅមួយលាន (១.០០០.០០០) រៀល ។

មាត្រា៤៤ថ្មី .- ក្នុងករណីមិនរាងចាល ការផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ៤០ថ្មី វាក្យខណ្ឌទី១ នៃមាត្រា៤២ថ្មី មាត្រា៤៣ ត្រូវអនុវត្តកំរិតអតិបរមា ហើយបើមានបទល្មើស ដែលបានកំណត់ក្នុងវាក្យខណ្ឌទី២ នៃមាត្រា ៤២ថ្មី មិនរាងចាលនោះ រាល់ពាណិជ្ជករ ឬអ្នកដឹកនាំក្រុមហ៊ុនត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីបីខែ (៣ខែ) ទៅមួយឆ្នាំ (១ឆ្នាំ) ។

មាត្រា៥៤ថ្មី .- ក្នុងរយៈកាលដែលព្រះរាជាណាចក្រកម្ពុជានៅមិនទាន់មានតុលាការពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្មត្រូវរៀបចំថែរក្សាច្បាប់ចំលងនៃសៀវភៅបញ្ជីពាណិជ្ជកម្ម និង ច្បាប់ដើមនៃរាល់ឯកសារដែលពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជកម្ម ការលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម រហូតដល់តុលាការពាណិជ្ជកម្មត្រូវបានបង្កើតឡើង ។

មាត្រា៥៧ថ្មី .- (មាត្រា ៥៨ចាស់)

រាល់ពាណិជ្ជករ និងរាល់ក្រុមហ៊ុនពាណិជ្ជកម្ម ដែលបានធ្វើសកម្មភាពមុនការប្រកាសឲ្យប្រើច្បាប់នេះ ត្រូវប្តឹងសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជ

កម្ម ក្នុងរយៈពេលប្រាំមួយខែ(៦ខែ) ។ បើមានការចាំបាច់ក្រសួងពាណិជ្ជកម្មអាចសំរេចបន្ថែមរយៈពេលនេះបានប្រាំមួយខែ (៦ខែ) ទៀត ។

**មាត្រា៥៨ថ្មី .-** (មាត្រា ៥៩ចាស់)

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៥៩ថ្មី .-** (មាត្រា ៦០ចាស់)

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩

ព្រះហស្ថលេខា

នរោត្តម សីហនុ

***

## ព្រះរាជក្រម នស/រកម/១១៩៩/១៣

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើជាផ្លូវការនូវច្បាប់ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៥០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា

# I - ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រម

### ព្រះរាជក្រម ជស/រកម/០៦៩៦/០៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស-រកត-១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស-រកម-០១៩៦-១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

LAW-SOCIETY.ASIA

## ប្រកាសអោយប្រើ

ច្បាប់ស្ដីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២២ ឆ្នាំ ១៩៩៦ នាសម័យប្រជុំលើកទី ៦ នីតិកាលទី ១ ដែលមានសេចក្ដីទាំងស្រុងដូចតទៅ :

# ច្បាប់

# ស្ដីពី

# លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១ .-**

ច្បាប់នេះមានគោលដៅគ្រប់គ្រងផ្នែកសហគ្រាសសាធារណៈនិងកំណត់លក្ខខណ្ឌដែលត្រូវអនុវត្តចំពោះលក្ខន្តិកៈគតិយុត្តិ ការប្រព្រឹត្តិទៅ និង ការត្រួតពិនិត្យ ។

សហគ្រាសសាធារណៈ គឺជាសហគ្រាសដែលមានដើមទុនទាំងអស់ ឬ ភាគច្រើនជារបស់រដ្ឋ ។

**មាត្រា ២ .-**

សហគ្រាសសាធារណៈ គឺជាសហគ្រាសដែលមានដើមទុនទាំងអស់ ឬ ភាគច្រើនជារបស់រដ្ឋ ។ សហគ្រាសសាធារណៈមានបេសកម្មបង្កលក្ខណៈដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមកិច្ចជាអាទិ៍ក្នុងការបង្កើនតម្លៃធនធានធម្មជាតិ និងការបង្កើតអាជីព ។

**មាត្រា ៣ .-**

សហគ្រាសសាធារណៈមានទម្រង់ជា :

–គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច

–ក្រុមហ៊ុនរដ្ឋ

- ក្រុមហ៊ុនចំរុះដែលក្នុងនោះរដ្ឋកាន់កាប់ដោយផ្ទាល់ ឬ ដោយប្រយោលលើស ពី ៥១ ភាគរយ នៃដើមទុនក្រុមហ៊ុន ឬសិទ្ធិបោះឆ្នោត ។

**មាត្រា ៤ .-**

សហគ្រាសសាធារណៈ គឺជានីតិបុគ្គលដែលមានស្វ័យភាពហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលសហគ្រាសសាធារណៈដែលតទៅនេះហៅកាត់ថា ក្រុមប្រឹក្សាភិបាល ជាអង្គការដឹកនាំខ្ពស់បំផុតនៅក្នុងសហគ្រាសសាធារណៈ ហើយបំពេញមុខងារប្រកបដោយស្វ័យភាព បរិបូណ៌ ចំនួនសមាជិកនៃក្រុមប្រឹក្សាភិបាលមិនត្រូវលើសពីប្រាំពីរ រូបឡើយ ។

វៀរលែងតែមានចែងក្នុងបទបញ្ញត្តិទាំងឡាយនៃច្បាប់នេះ ការគ្រប់គ្រងលើគ្រប់ផ្នែករបស់សហគ្រាសសាធារណៈត្រូវអនុលោមតាមគោលការណ៍ និង បែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម ។

**មាត្រា ៥ .-**

លើកលែងតែមានបទបញ្ញត្តិដែលចែងដោយច្បាប់ សហគ្រាសសាធារណៈ ត្រូវស្ថិតនៅក្រោមរបបនីតិរួមចំពោះពន្ធនិងអាករ ។

**មាត្រា ៦ .-**

សហគ្រាសសាធារណៈ ត្រូវស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស នៃ ក្រសួងអាជ្ញាធរសាធារណៈណាមួយអាស្រ័យលើប្រភេទនៃសកម្មភាព របស់សហគ្រាសនោះ ។

**មាត្រា ៧ .-**

សហគ្រាសសាធារណៈ ត្រូវស្ថិតនៅក្រោម ៖

- ការត្រួតពិនិត្យរបស់រដ្ឋដូចមានចែងនៅក្នុងផ្នែកទី ៣ ជំពូកទី ២ នៃ ច្បាប់នេះ
- ការត្រួតពិនិត្យហិរញ្ញវត្ថុ និងអធិការកិច្ចរបស់ក្រសួង ឬស្ថាប័នពាក់ព័ន្ធ

**មាត្រា ៨ .-**

បុគ្គលិកដែលធ្វើការក្នុងសហគ្រាសសាធារណៈ ត្រូវស្ថិតនៅក្រោមលក្ខន្តិកៈដោយឡែកដែលសម្រេចដោយក្រុមប្រឹក្សាភិបាល ។

# ជំពូកទី ២

## បទបញ្ញត្តិរួមសម្រាប់សហគ្រាសសាធារណៈ

## ផ្នែកទី ១

## ភារកិច្ចនិងការប្រព្រឹត្តិទៅរបស់ក្រុមប្រឹក្សាភិបាល

**មាត្រា ៩ .-**

ក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាល ត្រូវមានអាសនៈមួយកន្លែងសម្រាប់តំណាងនិយោជិត នៃសហគ្រាសសាធារណៈ ដែលត្រូវបានបោះឆ្នោតជ្រើសរើសតាំងចេញពីនិយោជិត និងដោយនិយោជិតរបស់សហគ្រាស ។

**មាត្រា ១០ .-**

ក្រុមប្រឹក្សាភិបាលផ្ទេរអោយប្រធានអគ្គនាយក ឬ អគ្គនាយកនូវអំណាចចាំបាច់សម្រាប់ដំណើរការសហគ្រាសប្រចាំថ្ងៃ តែការផ្ទេរអំណាចនេះមិនមែនជាការផ្ទេរការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលឡើយ ។

មុខងារនៃប្រធានអគ្គនាយក អគ្គនាយក ឬសមាជិកក្រុមប្រឹក្សាភិបាល នៃ សហគ្រាសសាធារណៈមានវិសមិតភាពជាមួយមុខងារ នៃ សមាជិករដ្ឋសភាឬសមាជិក រាជរដ្ឋាភិបាល ។

**មាត្រា ១១ .-**

ក្រុមប្រឹក្សាភិបាលកំណត់ទិសដៅ និងត្រួតពិនិត្យការគ្រប់គ្រងសហគ្រាសព្រមទាំងធានាស្និទានភាព និងប្រសិទ្ធភាពនៃការរៀបចំ និង ការប្រព្រឹត្តិទៅរបស់សហគ្រាស ។

ដើម្បីបំពេញមុខងារនេះក្រុមប្រឹក្សាភិបាលមានភារកិច្ចជាអាទិ៍ដូចតទៅ៖

សម្រេចគម្រោងអភិវឌ្ឍន៍សហគ្រាស

- វាយតម្លៃក្នុងចន្លោះពេលមួយទៀងទាត់នូវលទ្ធផលសម្រេចបាន និងលើកវិធានការកែតម្រូវសំរាប់អនុវត្ត
- សម្រេចគម្រោងថវិកាសំរាប់ការប្រព្រឹត្តទៅនិងការវិនិយោគ ព្រមទាំងសេមាហិរញ្ញប្បទាន
- អនុម័តតុល្យការ និងគណនីគ្រប់គ្រង

- កំណត់រចនាសម្ព័ន្ធរបស់សហគ្រាស លក្ខន្តិកៈបុគ្គលិក និងរបបបៀវត្ស
- អនុម័តការដេញថ្លៃសាធារណៈ

**មាត្រា ១២ .-**

ក្រុមប្រឹក្សាភិបាល ត្រូវប្រជុំយ៉ាងតិចមួយដងក្នុងរៀងរាល់ ៣ ខែ ដើម្បី ពិភាក្សា និងសម្រេចនូវបញ្ហាដែលមានចុះក្នុងរបៀបវារៈ ។ របៀបវារៈនេះនឹងត្រូវ បានជូនដំណឹងជាមុនយ៉ាងតិច ១០ ថ្ងៃ ដល់គ្រប់សមាជិកក្រុមប្រឹក្សាភិបាល មន្ត្រីត្រួតពិនិត្យរដ្ឋ និងក្រសួងអាណាព្យាបាល ឬ អាជ្ញាធរអាណាព្យាបាល ។

ក្រុមប្រឹក្សាភិបាល ត្រូវចាត់ចែងធ្វើកំណត់ហេតុនានាអោយហើយក្នុងរយៈពេល ១០ ថ្ងៃ បន្ទាប់ពីការប្រជុំ ។

**មាត្រា ១៣ .-**

វៀរលែងតែមានចែងក្នុងបទបញ្ញត្តិនៃលក្ខន្តិកៈ ឬបទបញ្ជាដែលទាក់ទងទៅ នឹងការរៀបចំ និងការប្រព្រឹត្តទៅរបស់សហគ្រាសសាធារណៈណាមួយ ក្រុមប្រឹក្សាភិបាល អាចប្រជុំដោយចាត់ទុកជាបានការលុះត្រាតែមានសមាជិកភាគច្រើនចូលរួម ។ ក្រុមប្រឹក្សាភិបាលត្រូវសម្រេចតាមសំលេងភាគច្រើននៃសមាជិកវត្តមាន ។ ក្នុងករណីដែលមានសម្លេងស្មើគ្នានោះ សម្លេងរបស់ប្រធានក្រុមប្រឹក្សាភិបាលមានឧត្តមានុភាព ។

**មាត្រា ១៤ .-**

ក្រុមប្រឹក្សាភិបាលត្រូវសម្រេចយ៉ាងយូរបំផុតនៅថ្ងៃទី ៣០ ខែកញ្ញា រៀងរាល់ឆ្នាំ នូវគម្រោងថវិកាសំរាប់ការប្រព្រឹត្តិទៅនឹងការវិនិយោគ ព្រមទាំងសេមាហិរញ្ញប្បទាន ។

ឯកសារទាំងនេះ ត្រូវបានទទួលការយល់ព្រមពីក្រសួងអាណាព្យាបាល ឬ អាជ្ញាធរអាណាព្យាបាលបន្ទាប់ពីការផ្តល់យោបល់ឯកភាពរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុក្នុងរយៈពេលអតិបរមា ២ ខែ គិតចាប់ពីថ្ងៃដែលឯកសារ មកដល់ក្រសួងអាណាព្យាបាល ឬ អាជ្ញាធរអាណាព្យាបាល ។

**មាត្រា ១៥ .-**

ក្រុមប្រឹក្សាភិបាល ត្រូវសម្រេចលើរបាយការណ៍ស្ដីពីសកម្មភាពប្រចាំឆ្នាំ តុល្យការ និង គណនីគ្រប់គ្រងព្រមទាំងឯកសារឧបសម្ព័ន្ធនានាយ៉ាងយូរបំផុត ៣ ខែ ក្រោយពេលបិទបញ្ជី ។

## ផ្នែកទី ២

## ភារកិច្ចរបស់សហគ្រាសសាធារណៈ

**មាត្រា ១៦ .-**

សហគ្រាសសាធារណៈត្រូវផ្ដល់ជូនទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលនូវឯកសារដូច តទៅដែលពាក់ព័ន្ធទៅនឹង ÷

- កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល
- ថវិកា សម្រាប់ការប្រព្រឹត្តិទៅនិងការវិនិយោគ
- របាយការណ៍ស្ដីពីសកម្មភាព តុល្យការ និងគណនីគ្រប់គ្រងព្រមទាំងឯកសារ ឧបសម្ព័ន្ធ
- របាយការណ៍ស្ដីពីការត្រួតពិនិត្យគណនីនានា ។

ឯកសារនីមួយៗ ដែលធ្វើហើយស្រេចតាមកាលកំណត់ ត្រូវបានបញ្ជូនទៅអោយកន្លែង ទទួលក្នុងរយៈពេលមិនលើសពី ១៥ ថ្ងៃ ។

ក្រសួងអាណាព្យាបាល ឬ អាជ្ញាធរអាណាព្យាបាលមានរយៈពេល ១ ខែ សម្រាប់ជំទាស់ ក្នុងករណីចាំបាច់ ។ ក្រុមប្រឹក្សាភិបាលត្រូវបានផ្ដល់ពត៌មាន អំពីខ្លឹមសារនៃការជំទាស់នៅពេល ប្រជុំបន្ទាប់ដើម្បីចាត់វិធានការ ។

ក្នុងករណីដែលក្រុមប្រឹក្សាភិបាលមិនទទួលការជំទាស់របស់ក្រសួងអាណាព្យាបាលឬអាជ្ញា-ធរអាណាព្យាបាលនោះ ក្រុមប្រឹក្សាភិបាលត្រូវបង្ហាញហេតុផលហើយ ត្រូវជូនដំណឹងទៅក្រសួង អាណាព្យាបាលឬអាជ្ញាធរអាណាព្យាបាលវិញជាបន្ទាន់ ។

**មាត្រា ១៧ .-**

គណនីទាំងឡាយរបស់សហគ្រាសសាធារណៈ ត្រូវបានដាក់អោយស្ថិតនៅក្រោមការត្រួតពិនិត្យពីអ្នកជំនាញគណនេយ្យតាមលក្ខណ្ឌនិងបែបបទ ដែលកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៨ .-**

លទ្ធកម្មដោយសហគ្រាសសាធារណៈ ដាច់ខាតត្រូវធ្វើឡើងដោយអនុលោមតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ១៩ .-**

វិធានការដំឡើងថ្លៃការអនុវត្តនិងការត្រួតពិនិត្យការដេញថ្លៃត្រូវបានកំណត់ដោយអនុក្រឹត្យ ។

**ផ្នែកទី៣**

**ការត្រួតពិនិត្យសហគ្រាសសាធារណៈ**

**មាត្រា ២០ .-**

ក្រសួងអាណាព្យាបាលឬអាជ្ញាធរអាណាព្យាបាល ត្រូវធ្វើការត្រួតពិនិត្យសេដ្ឋកិច្ច ដល់សហគ្រាសតាមរយៈតំណាងរបស់ខ្លួនដែលនៅក្នុងក្រុមប្រឹក្សាភិបាល ។ ការត្រួតពិនិត្យសេដ្ឋកិច្ចត្រូវបានធ្វើឡើងដើម្បីធានាអោយសេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល មានលក្ខណៈអនុលោមតាមទិសដៅរបស់រាជរដ្ឋាភិបាល ឬ តាមការណែនាំរបស់ក្រសួងអាណាព្យាបាលឬអាជ្ញាធរអាណាព្យាបាល ។

**មាត្រា ២១ .-**

ត្រូវបានដាក់អោយនៅអមសហគ្រាសសាធារណៈនីមួយៗ នូវមន្ត្រីត្រួតពិនិត្យរដ្ឋដែលទទួលបន្ទុកខាងការងារត្រួតពិនិត្យជាអាទិ៍លើ ៖

-ការបំពេញកាតព្វកិច្ចរបស់សហគ្រាសសាធារណៈ ដែលមានចែងក្នុងច្បាប់និងបទបញ្ញត្តិទាំងឡាយជាធរមាន

-ការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល

-ការតាមដានការប្រព្រឹត្តទៅ និងការវិវឌ្ឍន៍របស់សហគ្រាស

-ប្រក្រតីភាពនៃសកម្មភាពទាំងឡាយ ដែលអាចជះឥទ្ធិពលដល់ស្ថានភាព ហិរញ្ញវត្ថុរបស់សហគ្រាស ។

**មាត្រា ២២ .-**

មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវបានតែងតាំងនិងបញ្ឈប់ពីតំណែងដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបានជ្រើសរើសពីក្នុងចំណោមមន្ត្រីជាន់ខ្ពស់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបាននិងកំពុងបំពេញការងារសាធារណៈយ៉ាងតិច ៥ ឆ្នាំ ។

មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបំពេញភារកិច្ចតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ហើយត្រូវរាយការណ៍ជូនក្រសួងអោយបានទៀងទាត់ អំពីការបំពេញ ភារកិច្ចរបស់ខ្លួន ។

**មាត្រា ២៣ .-**

មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវចូលរួមក្នុងអង្គប្រជុំឬរបស់ក្រុមប្រឹក្សាភិបាល មានសិទ្ធិផ្តល់យោបល់ពិគ្រោះ និងត្រូវបានអញ្ជើញអោយចូលរួមក្នុងមហាសន្និបាតជាទៀងទាត់ ។

មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវផ្តល់យោបល់លើបញ្ហាដែលមានចុះក្នុងរបៀបវារៈ នៃអង្គប្រជុំក្រុមប្រឹក្សាភិបាលក្នុងការអនុវត្តភារកិច្ចនេះ មន្ត្រីត្រួតពិនិត្យរដ្ឋអាចស្នើសុំពត៌មាន ឬ ស្វែងយល់នៅនឹងកន្លែងអំពីឯកសារ ឬបញ្ជីទាំងអស់ដែលមាននៅក្នុងសហគ្រាស ។

**មាត្រា ២៤ .-**

មន្ត្រីត្រួតពិនិត្យរដ្ឋអាចជំទាស់នឹងការចាត់វិធានការទាំងឡាយដែលខ្លួន យល់ឃើញថាផ្ទុយនឹងច្បាប់ និង ការប្រតិបត្តិដែលប៉ះពាល់ដល់សិទ្ធិនិងផល ប្រយោជន៍របស់សហគ្រាស ឬរបស់រដ្ឋពុំសមស្របនឹងគោលដៅរបស់សហគ្រាស ។

**មាត្រា ២៥ .-**

ការជំទាស់របស់មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាភិបាលនៅពេលប្រជុំឬយ៉ាងយូរបំផុតក្នុងរយៈពេល ៣ ថ្ងៃ « គិតតែថ្ងៃធ្វើការ» ក្រោយពីការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ។

មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវរាយការណ៍ជាបន្ទាន់ជូនក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេស នៃ សហគ្រាស អំពីការជំទាស់របស់ខ្លួនលើការអនុវត្តសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ។ ៤ ថ្ងៃធ្វើការ ក្រោយការជំទាស់របស់មន្ត្រីត្រួត

ពិនិត្យរដ្ឋ បើសិនជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬក្រសួងអាណាព្យាបាល ឬអាជ្ញាធរ អាណាព្យាបាលមិនបានបញ្ជាក់អំពីការជំទាស់នេះ ដោយចេញបញ្ជាអោយលុបចោល ឬ កែប្រែសេចក្តីសំរេចទេនោះ សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវចាត់ទុកជាបានការ ។

## ជំពូកទី ៣

## បទបញ្ញត្តិដោយឡែក សំរាប់ប្រភេទផ្សេងៗនៃសហគ្រាសសាធារណៈ

### ផ្នែកទី ១

### គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច

**មាត្រា ២៦ .-**

គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ចគឺជានីតិបុគ្គល នៃ នីតិសាធារណៈដែលមាន ស្វ័យភាពហិរញ្ញវត្ថុ ។ គ្រឹះស្ថាននេះផលិតផលិតផល ឬ ធ្វើសេវា សំរាប់ទីផ្សារ ។

**មាត្រា ២៧ .-**

គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ចត្រូវបានបង្កើតឡើងដោយអនុក្រឹត្យតាមការស្នើរមតិរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងអាណាព្យាបាលឬអាជ្ញាធរ អាណាព្យាបាល ។ អនុក្រឹត្យនេះកំណត់ជាអាទិ៍អំពីភារកិច្ច ដើមទុន ក្រសួងអាណាព្យាបាល ឬ អាជ្ញាធរអាណាព្យាបាលសមាសភាពក្រុមប្រឹក្សាភិបាល ការរៀបចំរដ្ឋបាល និង ហិរញ្ញវត្ថុ វិធាននៃការប្រព្រឹត្តិទៅរបស់គ្រឹះស្ថាន ។

**មាត្រា ២៨ .-**

គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ត្រូវបានដឹកនាំដោយ ប្រធានអគ្គនាយក មួយរូបជាប្រធានក្រុមប្រឹក្សាភិបាលផងនិងជាអគ្គនាយកផង ដែលបំពេញមុខងារក្រោមការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាភិបាល ។

តួនាទីរបស់ប្រធានក្រុមប្រឹក្សាភិបាលនិងអគ្គនាយកអាចញែកចេញដាច់ពីគ្នា។ក្នុងករណីនេះ ទីចាត់ការប្រតិបត្តិនៃគ្រឹះស្ថានត្រូវបានដឹកនាំដោយអគ្គនាយក ។

**មាត្រា ២៩ .-**

ប្រធានអគ្គនាយក ឬ អគ្គនាយក ត្រូវបានតែងតាំងដោយអនុក្រឹត្យតាម សំណើរបស់ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលនៃគ្រឹះស្ថាន សាធារណៈនោះ ។ សមាជិកដទៃទៀតនៃក្រុមប្រឹក្សាភិបាល ត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ឬ អាជ្ញាធរដែលជាសមាជិកនោះ ជាតំណាង និងត្រូវបានជ្រើសរើសតាមល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុងមាត្រា ៤៣ នៃច្បាប់នេះ ។

## ផ្នែកទី ២

## ក្រុមហ៊ុនរដ្ឋ

**មាត្រា ៣០ .-**

ក្រុមហ៊ុនរដ្ឋ គឺជាក្រុមហ៊ុនដែលមានដើមទុនទាំងអស់ជារបស់រដ្ឋ ។

**មាត្រា ៣១ .-**

ក្រុមហ៊ុនរដ្ឋ ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ តាមការស្នើរួមគ្នារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងអាណាព្យាបាល ឬ អាជ្ញាធរ អាណាព្យាបាល ។ អនុក្រឹត្យនេះកំណត់ជាអាទិ៍អំពីកម្មវត្ថុរបស់ក្រុមហ៊ុនទម្រង់ គតិយុត្តិ ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល របបត្រួតពិនិត្យដែលត្រូវអនុវត្ត សមាសភាពរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា ៣២ .-**

ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេសទទួលខុស ត្រូវបំពេញទម្រង់បែបបទនៃការបង្កើតក្រុមហ៊ុនដោយៈ÷

– រៀបចំលក្ខន្តិកៈរបស់ក្រុមហ៊ុនដោយមានការព្រមព្រៀងជាមួយ និង ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

– ចាត់ចែងចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម

– បំពេញទម្រង់បែបបទទាំងអស់តាមគោលការណ៍ និងបែបបទទាំងឡាយ នៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម ។

**មាត្រា ៣៣ .-**

វៀរលែងតែមានចែងក្នុងបទបញ្ញត្តិទាំងឡាយនៃច្បាប់នេះលក្ខន្តិកៈរបស់ក្រុមហ៊ុនរដ្ឋកំណត ជាអាទិ៍អំពីចំនួនទឹកប្រាក់និងប្រភេទនៃភាគទុនការរៀបចំរដ្ឋបាល និង ហិរញ្ញវត្ថុ វិធាននៃការប្រព្រឹត្តិទៅរបស់ក្រុមហ៊ុន ។

**មាត្រា ៣៤ .-**

តាមបដិបញ្ញត្តិលើគោលការណ៍ និងបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម អំណាចនៃមហាសន្និបាតរបស់ក្រុមហ៊ុនរដ្ឋ ត្រូវបានប្រគល់អោយក្រុមប្រឹក្សាភិបាល ។

**មាត្រា ៣៥ .-**

ភាគទុនដំបូងព្រមទាំងការកែប្រែជាក្រោយ នៃដើមទុនរបស់ក្រុមហ៊ុនរដ្ឋត្រូវបានធ្វើអោយសំរេចដោយអនុលោមតាមបទបញ្ញត្តិដែលមានចែងក្នុងច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ និង ច្បាប់ហិរញ្ញវត្ថុជាធរមាន ។

**មាត្រា ៣៦ .-**

ប្រធានអគ្គនាយក ឬ អគ្គនាយកក្រុមហ៊ុនរដ្ឋ ត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល ។ សមាជិកដទៃទៀត នៃក្រុមប្រឹក្សាភិបាលត្រូវបានតែងតាំងដោយអនុក្រឹត្យតាម សំណើរបស់ក្រសួង ឬ អាជ្ញាធរដែលសមាជិកនោះជាតំណាងនិងត្រូវបាន ជ្រើសរើសក្នុងល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុង មាត្រា ៤៣ នៃច្បាប់នេះ ។

## ផ្នែកទី ៣
## ក្រុមហ៊ុនចំរុះ

**មាត្រា ៣៧ .-**

ភាគកម្មសាធារណៈ គឺជាចំណែកនៃដើមទុនរបស់ក្រុមហ៊ុនចំរុះ ដែលកាន់កាប់ដោយរដ្ឋ ដោយគ្រឹះស្ថានសាធារណៈ ឬដោយក្រុមហ៊ុនរដ្ឋ ។

**មាត្រា ៣៨ .-**

ក្រុមហ៊ុនចំរុះ គឺជាក្រុមហ៊ុនដែលត្រូវបានបង្កើតឡើងតាមគោលការណ៍ និងតាមបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម ហើយដែលដើមទុនត្រូវបានកាន់កាប់រួមគ្នាដោយនីតិបុគ្គល ឬ រូបវន្តបុគ្គលឯកជន និងនីតិបុគ្គលរដ្ឋ ។

កាលណាភាគកម្មសាធារណៈលើសពី ៥១ ភាគរយនៃដើមទុន ឬ សិទ្ធិបោះឆ្នោតក្រុមហ៊ុនចំរុះត្រូវបានចាត់ទុកជាសហគ្រាសសាធារណៈ ។

**មាត្រា ៣៩ .-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរ៉ាប់រងខាងផ្នែករដ្ឋបាលលើភាគកម្មសាធារណៈ ។

**មាត្រា ៤០ .-**

ប្រតិបត្តិការហិរញ្ញវត្ថុអំពីភាគកម្មសាធារណៈ ត្រូវបានធ្វើអោយសំរេចដោយអនុលោមតាមបទបញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ និង ច្បាប់ហិរញ្ញវត្ថុ ជាធរមាន ។

**មាត្រា ៤១ .-**

តាមបដិបញ្ញត្តិលើគោលការណ៍ និងបែបបទទាំងឡាយនៃនីតិក្រុមហ៊ុន ពាណិជ្ជកម្ម រដ្ឋគ្រឹះស្ថានសាធារណៈ និងក្រុមហ៊ុនរដ្ឋ ត្រូវបានលើកលែងការ តំកល់ភាគហ៊ុនធានា សំរាប់តំណាងនៅក្នុងក្រុមប្រឹក្សាភិបាលសហគ្រាសដែលខ្លួនបានចូលរួម ។

**មាត្រា ៤២-**

តំណាងរបស់រដ្ឋ ឬ តំណាងរបស់គ្រឹះស្ថានសាធារណៈ នៅក្នុងក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុនចំរុះ ត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

តំណាងរបស់ក្រុមហ៊ុនរដ្ឋនៅក្នុងក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនចំរុះ ត្រូវបានតែងតាំងដោយសេចក្ដីសំរេចរបស់ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុននោះ ក្រោយពីមានយោបល់ឯកភាពរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ៤៣ .-**

តំណាងរបស់រដ្ឋ របស់គ្រឹះស្ថានសាធារណៈ ឬរបស់ក្រុមហ៊ុនរដ្ឋនៅក្នុងក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនចំរុះត្រូវបានជ្រើសរើសដោយផ្អែកលើគុណសម្បត្តិ និងបទពិសោធន៍របស់ខ្លួន ឬ មួយពីក្នុងចំណោមមន្ត្រីរាជការបំរើការងារយ៉ាង តិច ៥ ឆ្នាំ ឬចូលនិវត្តន៍តែ មានអាយុមិនលើសពី ៦៥ ឆ្នាំឬមួយពីក្នុងចំណោមឥស្សរជន ខ្មែរដែលមានសមត្ថភាពខាងសេដ្ឋកិច្ច ខាងនីតិសាស្ត្រ ឬ ខាងវិទ្យាសាស្ត្រ ។

តំណាងទាំងនោះ អាចអោយរួចផុតពីការបង់ប្រាក់ធានាសំរាប់មុខតំណែងនៅក្នុងក្រុម-ប្រឹក្សាភិបាលតែមិនត្រូវមានភាគហ៊ុនក្នុងសហគ្រាសឡើយ ។

**មាត្រា ៤៤ .-**

ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី របស់តំណាងទាំងនោះក្នុងការបំពេញភារកិច្ចរបស់ខ្លួននៅក្នុងក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុនចំរុះត្រូវធ្លាក់លើរដ្ឋ លើគ្រឹះ ស្ថានសាធារណៈ ឬលើក្រុមហ៊ុនរដ្ឋ តែតំណាងត្រូវទទួលខុសត្រូវដោយខ្លួនឯងខាង ផ្នែកព្រហ្មទណ្ឌ ។

**មាត្រា ៤៥ .-**

ហាមដាច់ខាតមិនអោយមន្ត្រីសាធារណៈដែលធ្លាប់ធ្វើជាតំណាងរបស់រដ្ឋ របស់គ្រឹះស្ថានសាធារណៈឬរបស់ក្រុមហ៊ុនរដ្ឋចូលធ្វើការនៅក្នុងមុខតំណែងណាមួយក្នុង សហគ្រាសដែលខ្លួនធ្លាប់ពាក់ព័ន្ធនៅមុនការផុតរយៈពេល ៣ ឆ្នាំ គិតចាប់ពីថ្ងៃឈប់ធ្វើការរបស់តំណាងនោះ លើកលែងតែមានការអនុញ្ញាតពិសេស ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ៤៦ .-**

ត្រូវមានអាណត្តិគាហកៈពិសេសមួយរូប តំណាងរដ្ឋនៅក្នុងមហាសន្និបាត ក្រុមហ៊ុនចំរុះ ។ អាណត្តិគាហកៈពិសេសមានវិសមិតភាពជាមួយតំណែងជាអគ្គនាយកនៃ សហគ្រាសនោះ ។

**មាត្រា ៤៧ .-**

អាណត្តិគាហកៈពិសេសមានភារកិច្ចការពារផលប្រយោជន៍រដ្ឋនៅក្នុងមហាសន្និបាតសាមញ្ញ និងវិសាមញ្ញ ហើយមានសិទ្ធិបោះឆ្នោតក្នុងនាមភាគីរដ្ឋ ។

**មាត្រា ៤៨ .-**

អាណត្តិគាហកៈពិសេស ត្រូវបានជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការដែលបាន និង កំពុងបំពេញការងារយ៉ាងតិច ៥ ឆ្នាំ ។ អាណត្តិគាហកៈពិសេសត្រូវ បានតែងតាំងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ អាណត្តិគាហកៈពិសេស ត្រូវសុំណែនាំពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមុន ពេលចូលរួមមហាសន្និបាតក្រុមហ៊ុនចំរុះ ។

## ជំពូកទី ៤

## អវសានបញ្ញត្តិ

**មាត្រា ៤៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

បានបង្គំទូលថ្វាយ និងជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២

ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការនីតិសម្បទា

និងអភិវឌ្ឍន៍ និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខា

**គាត ឈន់**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា ហត្ថលេខា

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

# ច្បាប់

# ស្តីពី

# សភាពាណិជ្ជកម្ម

# ១៩៩៥

# I-ខុទ្ទកាល័យព្រះមហាក្សត្រ

## ១—ព្រះរាជក្រម

## ព្រះរាជក្រមលេខ នស/រកម ០៦៩៥/០៣

## ព្រះរាជក្រម

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស**

**អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ**

**បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពី សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និងអំពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**ប្រកាសអោយប្រើ**

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ១៩៩៥ ស្តីពីសភាពាណិជ្ជកម្ម ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

## ច្បាប់ស្តីអំពីសភាពាណិជ្ជកម្ម

## ជំពូកទី ១

## ការរៀបចំនិងការប្រព្រឹត្តិទៅនៃសភាពាណិជ្ជកម្ម

**មាត្រា ១.-**

សភាពាណិជ្ជកម្ម គឺជាគ្រឹះស្ថានសាធារណៈនៅក្រោមអាណាព្យាបាលនៃក្រសួងពាណិជ្ជកម្ម ដែលធ្វើសកម្មភាពដើម្បីជាផលប្រយោជន៍ខាងវិស័យពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្ម និងសេវាកម្មក្នុងមណ្ឌលរបស់ខ្លួន ។

នៅតាមខេត្ត ក្រុងនីមួយៗ មានសភាពាណិជ្ជកម្មមួយ ។ ប៉ុន្តែមណ្ឌលនៃសភាពាណិជ្ជកម្មមួយអាចលាតសន្ធឹងទៅខេត្ត ក្រុង ច្រើនបានកាលណាស្ថានការណ៍សេដ្ឋកិច្ចតម្រូវឲ្យធ្វើដូច្នេះ ។

**មាត្រា ២.-**

សភាពាណិជ្ជកម្មនៅតាមខេត្ត ក្រុងនីមួយៗ ត្រូវបង្កើតឡើងដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងពាណិជ្ជកម្ម ។ ព្រំដែនមណ្ឌលនៃសភាពាណិ[illegible]មួយៗ ត្រូវកំណត់ឡើងដោយអនុក្រឹត្យដែលបង្កើតសភានោះ ។

**មាត្រា ៣.-**

សភាពាណិជ្ជកម្មនីមួយៗ ត្រូវគ្រប់គ្រងដោយក[illegible]ល័យមួយដឹកនាំដោយប្រធានមួយរូបនិងអនុប្រធានមួយរូបឬច្រើនរូប ។

ចំនួនសមាជិកនៃការិយាល័យ ទម្រង់បែបបទនៃការជ្រើសតាំងប្រធានព្រមទាំងការប្រព្រឹត្តិទៅនៃការិយាល័យនេះត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់សភាពាណិជ្ជកម្មដែលមានទម្រង់ដូចគ្នាតែមួយសំរាប់សភាពាណិជ្ជកម្មទូទៅ និងមានការយល់ព្រមពីគណៈរដ្ឋមន្ត្រី [illegible]សំណើរបស់ក្រសួងពាណិជ្ជកម្ម ។

**មាត្រា ៤.-**

សភាពាណិជ្ជកម្មមានសមាជិកសញ្ជាតិជាខ្មែរ ត្រូវបានជ្រើសតាំងដោយការបោះឆ្នោត ។ អាណត្តិ ចំនួនសមាជិក របៀបរបប និងការរៀបចំការបោះឆ្នោតត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥.-**

នៅអមសមាជិកជ្រើសតាំងដោយការបោះឆ្នោត សភាពាណិជ្ជកម្មមានសមាជិក ទីប្រឹក្សា មួយចំនួនទៀត ដែលចូលរួមក្នុងការពិភាក្សា តែមានភារកិច្ចត្រឹមតែជាអ្នកផ្តល់មតិប៉ុណ្ណោះ ។

ចំនួននៃទីប្រឹក្សា មិនអាចលើសពីចំនួនសមាជិកជ្រើសតាំងដោយការបោះឆ្នោតឡើយ ។ ទីប្រឹក្សាទាំងនេះត្រូវបានតែងតាំងនៅពេលផ្លាស់សភាជាថ្មីម្តងៗ ។ ទីប្រឹក្សា ត្រូវជ្រើសរើសក្នុងចំណោម

១- តំណាងអង្គការ ឬតំណាងសមាគម ម្ចាស់សហគ្រាសពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្ម និងសេវាកម្ម ។

២- តំណាងក្រុមខណ្ឌដឹកនាំនៃសហគ្រាសពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្ម និងសេវាកម្ម ។

៣- តំណាងបុគ្គលិកនៃសហគ្រាសពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្ម និង សេវាកម្ម ។

ក្រសួងពាណិជ្ជកម្មកំណត់តាមប្រកាស បន្ទាប់ពីបានទទួលសេចក្តីស្នើពីសភាពាណិជ្ជកម្ម នូវ ៖

- ចំនួនទីប្រឹក្សា
- ចំនួនសមាជិកប្រភេទនីមួយៗ ដូចមានចែងខាងលើនេះ
- បញ្ជីនៃអង្គការឬនៃសមាគមដែលមានសិទ្ធិចាត់តាំងតំណាងជាទីប្រឹក្សា ។

**មាត្រា ៦.-**

អភិបាលខេត្ត ក្រុង ឬតំណាង និងតំណាងក្រសួងពាណិជ្ជកម្មមានសិទ្ធិចូលរួមក្នុងសម័យប្រជុំសភាពាណិជ្ជកម្ម តែមានភារកិច្ចត្រឹមតែជាអ្នកផ្តល់មតិប៉ុណ្ណោះ ។

**មាត្រា ៧.-**

សមាជិកជ្រើសតាំងនិងទីប្រឹក្សានៃសភាពាណិជ្ជកម្ម បំពេញមុខងាររបស់ខ្លួន

ដោយមិនយកប្រាក់ខែឬប្រាក់បំណាច់អ្វីឡើយ ។

**មាត្រា ៨.-**

សភាពាណិជ្ជកម្មទាំងឡាយអាចសហការគ្នាតាមរយៈប្រធានរបស់ខ្លួនក្នុងក្របខ័ណ្ឌនៃភារកិច្ចស្តីពីបញ្ហាទាំងឡាយដែលពាក់ព័ន្ធទៅនឹងមណ្ឌលរៀងៗខ្លួន ។

## ជំពូកទី ២
## ភារកិច្ចរបស់សភាពាណិជ្ជកម្ម

**មាត្រា ៩.-**

សភាពាណិជ្ជកម្មមានភារកិច្ចដូចតទៅ ៖

១- ធ្វើទំនាក់ទំនងជាមួយនឹងប្រភពសេដ្ឋកិច្ចក្នុងប្រទេស និងក្រៅប្រទេស ដើម្បីស្រង់យកពត៌មានដែលពាក់ព័ន្ធនឹងកិច្ចអភិវឌ្ឍន៍សហគ្រាសជាតិ ។

២- បង្កើនប្រសិទ្ធភាពសហគ្រាសទាំងឡាយ ដើម្បីជាផលប្រយោជន៍ខាង វិស័យពាណិជ្ជកម្មឧស្សាហកម្មកសិកម្មសិប្បកម្មសេវាកម្មនិងសេដ្ឋកិច្ចទូទៅ ដូចជាការរៀបចំផ្សព្វផ្សាយ នូវស្ថិតិពាណិជ្ជកម្ម និងសេដ្ឋកិច្ច ការសិក្សាស្រាវជ្រាវពិចារណាលើបញ្ហាសេដ្ឋកិច្ចនិងពាណិជ្ជកម្ម ការលើកតំកើងផ្នែកទេសចរណ៍ ។

៣- ផ្តល់ជូនរាជរដ្ឋាភិបាលនិងអាជ្ញាធរខេត្ត ក្រុង នូវយោបល់និងពត៌មានទាំងឡាយស្តីពី បញ្ហាពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្ម និងសេវាកម្ម ។

៤- ដើរតួជាអ្នកតំណាងសហគមន៍ពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្មនិងសេវាកម្មសំរាប់សំរបសំរួលកិច្ចការជាមួយរដ្ឋអំណាច។

៥- ធានារ៉ាប់រងនូវការគ្រប់គ្រងសេវា ធានា និងអនុវត្តការងារចាំបាច់ដែលជាផលប្រយោជន៍ក្នុងសមត្ថកិច្ចរបស់ខ្លួន ។

៦- ដើរតជាអាជ្ញាកណ្តាលក្នុងការដោះស្រាយវិវាទពាណិជ្ជកម្ម ។

មាត្រា ១០.-

សភាពាណិជ្ជកម្មត្រូវផ្តល់យោបល់ :

១- អំពីគំរោងបទបញ្ញាទាំងឡាយផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្ម ។

២- អំពីតម្លៃ និង អាករលើសេវាទាំងឡាយដែលរដ្ឋធ្វើសម្បទានអោយសហគ្រាសណាមួយ ។

៣- អំពីផលប្រយោជន៍នៃគំរោងសំណង់សាធារណការ ដែលត្រូវអនុវត្តក្នុងមណ្ឌលនីមួយៗព្រមទាំងពន្ធអាករដែលត្រូវប្រមូលយកពីអ្នកប្រើប្រាស់ ដើម្បីកសាងសំណង់នោះ ។

៤- អំពីគំរោងវិសោធនកម្មច្បាប់វិស័យគយពាណិជ្ជកម្មនិងសេដ្ឋកិច្ច ។

៥- អំពីការកំណត់អត្រាពន្ធគយ ។

ម្យ៉ាងទៀត តាមគំនិតផ្តួចផ្តើមផ្ទាល់របស់ខ្លួន សភាពាណិជ្ជកម្មអាចធ្វើសំណូមពរទាំងឡាយដែលទាក់ទងនឹងសកម្មភាពពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្ម និងសេវាកម្ម ។

មាត្រា ១១.-

តាមសំណូមពរម្ចាស់អំណោយឯកជន ឬរដ្ឋ ព្រមទាំងមានការយល់ព្រមពីគណៈរដ្ឋមន្ត្រី តាមសំណើរបស់ក្រសួងពាណិជ្ជកម្ម សភាពាណិជ្ជកម្មអាចបង្កើត ឬគ្រប់គ្រងគ្រឹះស្ថានពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សិប្បកម្ម និងសេវាកម្ម ទោះជារបស់រដ្ឋក្តី របស់ឯកជនក្តី ដូចជាឃ្លាំងផ្ទុកទំនិញ សាលលក់ឥវ៉ាន់ភណ្ឌាគារ ពិព័ណ៌អចិន្ត្រៃយ៍ សារមន្ទីរពាណិជ្ជកម្ម សាលាបណ្តុះបណ្តាលវិជ្ជាជីវៈពាណិជ្ជកម្ម និងឧស្សាហកម្ម ទីផ្សារសាធារណៈ មហាសាលសំរាប់ទេសចរណ៍ ។

មាត្រា ១២.-

សភាពាណិជ្ជកម្មអាចទិញ ឬសង់អាគារសំរាប់ប្រើប្រាស់ជារបស់ខ្លួនផ្ទាល់ ឬសំរាប់ជួល ធ្វើអាជីវកម្ម បើគ្មានការជំទាស់ពីគណៈរដ្ឋមន្ត្រី តាមសំណើរបស់ក្រសួងពាណិជ្ជកម្ម ។

**មាត្រា ១៨.-**

បើគ្មានការជំទាស់ពីក្រសួងពាណិជ្ជកម្ម សភាពាណិជ្ជកម្មមួយចំនួនអាចនឹងខ្ចីឥណទានរួម ដើម្បីយកមកបង្កើត ផ្គត់ផ្គង់គ្រឹះស្ថានសេវា ឬសំណង់ដែលជាប្រយោជន៍រួម របស់សភាពាណិជ្ជកម្មទាំងនោះ ។

សំណងចំណុលនេះត្រូវរ៉ាប់រងដោយប្រាក់ចំណូលរួមនៃអាជីវកម្ម ។

**មាត្រា ១៩.-**

ការខ្ចីប្រាក់ដូចមានចែងក្នុងមាត្រា ១៦ ១៧ និង ១៨ ខាងលើនេះ អាចធ្វើតាមរយៈ ធនាគារណាដែលផ្តល់អត្ថប្រយោជន៍ប្រសើរជាងគេ ។

**មាត្រា ២០.-**

ក្រៅពីថវិកាសាមញ្ញ សភាពាណិជ្ជកម្មរៀបចំនូវថវិកាពិសេសសំរាប់គ្រឹះស្ថានពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម និងសិប្បកម្មដែលខ្លួនគ្រប់គ្រង ។

ក្នុងរយៈពេល ៦ ខែដំបូងនៃឆ្នាំនីមួយៗ សភាពាណិជ្ជកម្មត្រូវធ្វើជូនក្រសួងពាណិជ្ជកម្ម ដើម្បីសុំការយល់ព្រមលើរបាយការណ៍ស្តីពីចំណូលនិងចំណាយនៃឆ្នាំមុន ហើយនិងគំរោងថវិកាចំណូលចំណាយនៃឆ្នាំបន្ទាប់ដោយមានឯកសារគណនេយ្យភ្ជាប់ជាមួយផង ។

ម្យ៉ាងទៀតសភាពាណិជ្ជកម្មត្រូវធ្វើតារាងរំលោះប្រាក់ខ្ចីជូនទៅក្រសួងពាណិជ្ជកម្មជារៀងរាល់ឆ្នាំ ។

សភាពាណិជ្ជកម្មអាចបំរុងទុកទឹកប្រាក់ទាំងអស់ ឬមួយភាគនៃចំណូលលើសដែលបានពីការគ្រប់គ្រងសេវាធម្មតាសំរាប់បង្កើតមូលនិធិពិសេសមួយដើម្បីផ្គត់ផ្គត់ចំណាយជាបន្ទាន់ដែលមិនបានគ្រោងទុក ។ ទោះក្នុងករណីណាក្តីចំនួនមូលនិធិបំរុងនេះមិនអាចខ្ពស់ជាង ២០ ភាគរយនៃធនធានប្រចាំឆ្នាំរបស់ថវិកានោះបានឡើយ ។

## ជំពូកទី ៤

## អចសានប្បញ្ញត្តិ

**មាត្រា ២១.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២២.-**

ច្បាប់នេះត្រូវប្រកាសទុកជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

## ព្រះរាជក្រមលេខ នស/រកម/០០៩៥/០៤

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស

## អគ្គមហាបុរសរតន៍ និករោត្តម

## ធម្មិកមហារាជាធិរាជ បរមនាថ

## បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលថ្វាយស្នើសុំពី សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

# ច្បាប់ស្តីពី

# ទិ.សតា

# ពាណិជ្ជកម្ម

# ២០០៦

នស/រកម/០៨០៦/០២៧

# ព្រះរាជក្រម

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា២ និងមាត្រា១៥ នៃច្បាប់ស្តីពីសភាពាណិជ្ជកម្ម ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០០៦ នាសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភា នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ០៩ ខែសីហា ឆ្នាំ ២០០៦ នាសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# វិសោធនកម្មមាត្រា ២ និងមាត្រា ១៥
# នៃច្បាប់ស្តីពីសភាពាណិជ្ជកម្ម

**មាត្រាតែមួយ.-**

មាត្រា ២ និងមាត្រា ១៥ នៃច្បាប់ស្តីពីសភាពាណិជ្ជកម្ម ដែលបានប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ត្រូវបានកែប្រែដូចតទៅ :

**មាត្រា ២ ថ្មី.-**

សភាពាណិជ្ជកម្មនៅតាមខេត្ត ក្រុងនីមួយៗ ត្រូវបង្កើតឡើងដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងពាណិជ្ជកម្ម ។

ព្រំដែនមណ្ឌលនៃសភាពាណិជ្ជកម្មនីមួយៗ ត្រូវកំណត់ឡើងដោយអនុក្រឹត្យដែលបង្កើតសភាពាណិជ្ជកម្មនោះ ។

សភាពាណិជ្ជកម្មខេត្ត ក្រុង ប្រមូលផ្តុំបង្កើតជាសភាពាណិជ្ជកម្មថ្នាក់ជាតិមួយឈ្មោះហៅថា សភាពាណិជ្ជកម្មកម្ពុជា ដែលធ្វើសកម្មភាពទូទាំងព្រះរាជាណាចក្រកម្ពុជា ។ ការរៀបចំ និងការប្រព្រឹត្តទៅព្រមទាំងភារកិច្ចរបស់សភាពាណិជ្ជកម្មកម្ពុជានឹងត្រូវកំណត់

9/4k

ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងពាណិជ្ជកម្ម ។

**មាត្រា១៥ ថ្មី ៖**

ចំណាយសម្រាប់ការប្រព្រឹត្តទៅនៃសភាពាណិជ្ជកម្ម ត្រូវផ្គត់ផ្គង់ដោយ ៖

-វិភាគទានរបស់សមាជិក

-អំណោយក្នុងនិងក្រៅប្រទេស

-ចំណូលមកពីការគ្រប់គ្រងគ្រឹះស្ថាន និងការដេញថ្លៃនានា

-ចំណូលព្រមទាំងវិភាគទានមកពីប្រភពផ្សេងៗ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៦

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

ពរស.០៨០៦.៣៩៣ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ហត្ថលេខា**

**ចម ប្រសិទ្ធ**

លេខ ៖ ៣៤៥ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០០៦

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ច្បាប់ស្តីពី

# សហគ្រាស

# ពាណិជ្ជកម្ម

# ២០០៥

Khmer Law's Association

# ព្រះរាជក្រម

នស/រកម/០៦០៥/០១៩

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីសហគ្រាសពាណិជ្ជកម្មដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាល ពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# សហគ្រាសពាណិជ្ជកម្ម

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះកំណត់ទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិ និងក្រុមហ៊ុនមូលធន ដែលធ្វើពាណិជ្ជកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ក្រុមហ៊ុនសហកម្មសិទ្ធិមានក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ។ ក្រុមហ៊ុនមូលធនមានក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ។

**មាត្រា ២.-**

នៅក្នុងច្បាប់នេះ ពាក្យបច្ចេកទេសទាំងឡាយមាននិយមន័យដូចតទៅ :

១-បុគ្គលមានន័យថារូបវន្តបុគ្គល ឬ នីតិបុគ្គល ។

២-មន្ត្រីចុះបញ្ជីមានន័យថាអ្នកចុះបញ្ជី ដែលបានតែងតាំងដោយអនុលោមទៅតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ។

៣-ការិយាល័យចុះបញ្ជីពាណិជ្ជកម្មមានន័យថាការិយាល័យដែលបានបង្កើតឡើងដោយអនុលោមទៅតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម ។

៤-បុត្រសម្ព័ន្ធមានន័យថាក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធនដែលគ្រប់គ្រងដោយក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធនផ្សេងទៀត ដែលជា "ក្រុមហ៊ុនមេ" ។

ក-បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនសហកម្មសិទ្ធិគឺក្រុមហ៊ុនសហកម្មសិទ្ធិមេនោះកាន់កាប់អត្ថប្រយោជន៍ភាគច្រើននៃអត្ថប្រយោជន៍របស់បុត្រសម្ព័ន្ធនោះ ។

ខ-បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនមូលធនគឺក្រុមហ៊ុនមូលធនមេនោះត្រូវកាន់កាប់ភាគច្រើននៃភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុន ។

**មាត្រា ៣.-**

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ត្រូវមានទីស្នាក់ការចុះបញ្ជី និងភ្នាក់ងារចុះបញ្ជីជាអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធនត្រូវផ្តល់ដល់មន្ត្រីចុះបញ្ជីនូវទីកន្លែងជាក់លាក់របស់ទីស្នាក់ការចុះបញ្ជី ដែលមានអាសយដ្ឋានពិតប្រាកដ និងអាសយដ្ឋានសម្រាប់ទាក់ទងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើអាសយដ្ឋានទាំងនោះខុសគ្នា ។

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ត្រូវផ្តល់ដល់មន្ត្រីចុះបញ្ជីនូវឈ្មោះរបស់ភ្នាក់ងារចុះបញ្ជី ហើយភ្នាក់ងារចុះបញ្ជីនោះ ត្រូវតែជារូបវន្តបុគ្គល ដែលមានកាយសម្បទា និងសមត្ថភាពគ្រប់គ្រាន់ ។ ភ្នាក់ងារចុះបញ្ជីមានសិទ្ធិទទួលលិខិតផ្លូវការ និងឯកសារទាំងឡាយ ព្រមទាំងដីកាអញ្ជើញ ដីកាកោះពីតុលាការក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធននោះ ។

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ត្រូវផ្តល់ដល់មន្ត្រីចុះបញ្ជីនូវរាល់ការផ្លាស់ប្តូរទីស្នាក់ការចុះបញ្ជី និងការផ្លាស់ប្តូរភ្នាក់ងារចុះបញ្ជីក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីមានការផ្លាស់ប្តូរ ។

ក្រុមហ៊ុនដែលបង្កើតឡើងស្របតាមច្បាប់នេះ ត្រូវស្ថិតនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

ឯកសារទាំងឡាយនៃព័ត៌មានតម្រូវដោយច្បាប់ ដែលត្រូវផ្តល់ទៅឱ្យក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ត្រូវប្រគល់ឱ្យទៅភ្នាក់ងារចុះបញ្ជីនៅឯទីស្នាក់ការចុះបញ្ជី នៅក្នុងអំឡុងម៉ោងធ្វើការធម្មតារបស់ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធននោះ លើកលែងតែតាមមធ្យោបាយណាផ្សេងដែលកំណត់ដោយច្បាប់ ។

ឯកសារទាំងឡាយអាចប្រគល់ឱ្យទៅសហកម្មសិទ្ធិករបាន ក្នុងករណីក្រុមហ៊ុននោះជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ អាចប្រគល់ឱ្យទៅសហកម្មសិទ្ធិករទូទៅបានក្នុង

ករណីក្រុមហ៊ុននោះជាក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ឬ អាចប្រគល់ឱ្យទៅអភិបាលបាន ក្នុងករណីក្រុមហ៊ុននោះជាក្រុមហ៊ុនមូលធន ។

ប្រសិនបើការបញ្ជូនឯកសារមិនអាចធ្វើទៅតាមវិធីខាងលើនេះទេ ឯកសារទាំងនោះអាចប្រគល់ទៅឱ្យមន្ត្រីចុះបញ្ជី ហើយមន្ត្រីចុះបញ្ជីនោះ ត្រូវផ្ញើឱ្យទៅក្រុមហ៊ុនវិញតាមអាសយដ្ឋានចុងក្រោយរបស់ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធនដូចដែលមាននៅក្នុងបញ្ជីពាណិជ្ជកម្មស្រាប់ ។ ការបញ្ជូនឯកសារតាមរយៈមន្ត្រីចុះបញ្ជីត្រូវបានចាត់ទុកថាជាការបញ្ជូនទៅក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធននោះ ។

**មាត្រា ៥.-**

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ត្រូវប្រើនាមករណ៍ជាភាសាខ្មែរ ។ នាមករណ៍ជាភាសាខ្មែរ ត្រូវដាក់នៅជួរខាងលើបង្អស់ ហើយត្រូវមានទំហំធំជាងភាសាដទៃទៀតប្រសិនបើមាន ។ ការបកប្រែន័យរបស់នាមករណ៍ក្រុមហ៊ុនពីភាសាមួយទៅភាសាមួយទៀតត្រូវបានហាមឃាត់ ។ នាមករណ៍ជាភាសាខ្មែរ និងភាសាដទៃទៀតត្រូវមានសូរសព្ទដូចគ្នា ។

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ត្រូវចារឹកជាភាសាខ្មែរ នៅផ្នែកខាងលើនៃត្រាសញ្ញាក្បាលលិខិត បែបបទឯកសារ ឬឯកសារដែលប្រើប្រាស់ជាសាធារណៈ និងនៅផ្នែកលើនៃសញ្ញាផ្សព្វផ្សាយពាណិជ្ជកម្មជាសាធារណៈ ដែលតាំងនៅលើដែនដី ដែនទឹក និងដែនអាកាសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធនអាចប្រើប្រាស់ និងអាចកំណត់ឈ្មោះជាភាសាដទៃទៀតនៅក្រៅព្រះរាជាណាចក្រកម្ពុជា បាន ។

**មាត្រា ៦.-**

ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ដែលខកខានមិនបានបង់សោហ៊ុយ ប្រាក់ពិន័យ ការប្រាក់ដែលជំពាក់ក្រសួងពាណិជ្ជកម្ម ត្រូវហាមឃាត់ក្នុងការប្តឹងផ្តល់

ឬ ប្តឹងតវ៉ាក្នុងរឿងក្តីរដ្ឋប្បវេណីរហូតដល់បានសងគ្រប់នូវសោហ៊ុយ ប្រាក់ពិន័យ និងការប្រាក់នោះ ។

វាក្យខ័ណ្ឌនេះ មិនហាមឃាត់ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធនធ្វើការប្តឹងតវ៉ាចំពោះការកំណត់សោហ៊ុយ ប្រាក់ពិន័យ ឬ ការប្រាក់ដែលខ្លួនត្រូវជំពាក់ឡើយ ។

ប្រសិនបើភាគីមួយប្តឹងជំទាស់ថា ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធនជំពាក់ក្រសួងពាណិជ្ជកម្មនូវសោហ៊ុយ ប្រាក់ពិន័យ ឬ ការប្រាក់ពីក្រសួងពាណិជ្ជកម្ម ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធននោះ ត្រូវដាក់បង្កាន់ដៃទទួលប្រាក់របស់ក្រសួងពាណិជ្ជកម្មទៅឱ្យតុលាការពិនិត្យ ។ តុលាការត្រូវទទួលយកបង្កាន់ដៃនោះជាភស្តុតាង រហូតដល់មានភស្តុតាងផ្សេងៗទៀត ។

**មាត្រា ៧.-**

ក្រុមហ៊ុនដែលគ្រប់គ្រងដោយច្បាប់នេះ មានកាតព្វកិច្ចតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម ។

## ជំពូកទី ២
## ក្រុមហ៊ុនសហកម្មសិទ្ធិ
### ផ្នែកទី ១
### ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ
### ក-ការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

**មាត្រា ៨.-**

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ គឺជាកិច្ចសន្យារវាងបុគ្គលពីរ ឬ ច្រើន ដែលដាក់រួមគ្នានូវទ្រព្យសម្បត្តិ ចំណេះដឹង ឬ សកម្មភាពរបស់បុគ្គលទាំងនោះ ដើម្បីប្រកបពាណិជ្ជកិច្ចរួម ក្នុងគោលបំណងរកប្រាក់ចំណេញ ។

មាត្រា ៩.–

កិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ អាចធ្វើជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ ។ ប្រសិនបើកិច្ចសន្យាជាលាយលក្ខណ៍អក្សរ សហកម្មសិទ្ធិករទូទៅទាំងអស់ត្រូវចុះហត្ថលេខាលើកិច្ចសន្យានោះ ។

មាត្រា ១០.–

ក្នុងករណីដែលកិច្ចសន្យានោះមិនច្បាស់លាស់ តុលាការត្រូវពិចារណានូវវាល់វិធានដូចខាងក្រោម ដើម្បីកំណត់ថាតើភាគីទាំងអស់មានគោលបំណងរួមក្នុងការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះឬទេ :

ក-ក្នុងករណីដែលបុគ្គលពីរ ឬ ច្រើន កាន់កាប់ទ្រព្យសម្បត្តិរួមគ្នា ថាតើបុគ្គលទាំងនោះចែករំលែកប្រាក់ចំណេញដែលបានមកដោយទ្រព្យទាំងនោះឬទេ ថាតើក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ កើតឡើងដោយទ្រព្យសម្បត្តិរួមឬទេ ។

ខ-ក្នុងករណីដែលបុគ្គលពីរ ឬ ច្រើនចែករំលែកប្រាក់ចំណូលដែលបានមកពីការធ្វើពាណិជ្ជកិច្ច ថាតើបុគ្គលទាំងនោះ មានសិទ្ធិចូលរួមក្នុងទ្រព្យសម្បត្តិណាមួយដែលបង្កើតប្រាក់ចំណូលនោះឬទេ ថាតើក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះកើតឡើងដោយទ្រព្យសម្បត្តិរួមនោះឬទេ ។

មាត្រា ១១.–

នៅពេលដែលក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវបានបង្កើតឡើង ភាគីនៃកិច្ចសន្យាត្រូវជាប់កាតព្វកិច្ចចាប់ពីពេលដែលកិច្ចសន្យានោះ ត្រូវបានធ្វើឡើងចប់សព្វគ្រប់លើកលែងតែកិច្ចសន្យាមានចែងផ្សេងពីនេះ ។

មាត្រា ១២.–

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីសហកម្មសិទ្ធិករទូទៅម្នាក់ៗ ។ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មាននីតិបុគ្គលិកលក្ខណៈចាប់ពី

ពេលដែលបានចុះបញ្ជី ស្របតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម ហើយមានសិទ្ធិដូចតទៅ :

ក-ជាម្ចាស់លើចលននិងអចលនទ្រព្យក្នុងនាមក្រុមហ៊ុន ។

ខ-ធ្វើពាណិជ្ជកិច្ចក្នុងនាមក្រុមហ៊ុន ។

គ-ចុះកិច្ចសន្យាក្នុងនាមក្រុមហ៊ុន ។

ឃ-ប្តឹង ឬ ត្រូវគេប្តឹងក្នុងនាមក្រុមហ៊ុន ។

**មាត្រា ១៣.-**

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅទទួលបាននូវនីតិបុគ្គលិកលក្ខណៈសញ្ជាតិខ្មែរលុះត្រាតែ :

ក-ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មានទីស្នាក់ការចុះបញ្ជី និងទីកន្លែងធ្វើអាជីវកម្មស្ថិតក្នុងព្រះរាជាណាចក្រកម្ពុជា ។

ខ-អត្ថប្រយោជន៍នៅក្នុងក្រុមហ៊ុនចាប់ពី ៥១(ហាសិបមួយ)ភាគរយត្រូវបានកាន់កាប់ដោយរូបវន្តបុគ្គល ឬ នីតិបុគ្គលមានសញ្ជាតិខ្មែរ ។

**មាត្រា ១៤.-**

នាមករណ៍របស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវដាក់បញ្ចូលនូវនាមរបស់សហកម្មសិទ្ធិករទូទៅម្នាក់ ឬ ច្រើននាក់ ហើយនៅខាងក្រោយ ឬ ខាងក្រោមនាមករណ៍នោះត្រូវបន្ថែមពាក្យថា “ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ” ។ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវប្រើប្រាស់នាមករណ៍របស់ខ្លួននៅក្នុងពេលធ្វើពាណិជ្ជកិច្ច ។

**មាត្រា ១៥.-**

សហកម្មសិទ្ធិករទូទៅម្នាក់ៗ ត្រូវទទួលខុសត្រូវចំពោះការចុះបញ្ជីពាណិជ្ជកម្ម ការតម្កល់ទុកឯកសារ និងការចុះផ្សាយ ដែលតម្រូវសម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវរក្សាទុកជាឯកសារនូវសៀវភៅបញ្ជី និងកំណត់ហេតុទាំងឡាយនៅទីស្នាក់ការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន ។

## ខ- ទំនាក់ទំនងពីសហកម្មសិទ្ធិករទូទៅម្នាក់ទៅសហកម្មសិទ្ធិករទូទៅម្នាក់ទៀត

### មាត្រា ១៦.-

សហកម្មសិទ្ធិករទូទៅម្នាក់ៗអាច :

ក-បង់ភាគទុនចូលទៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ជាសាច់ប្រាក់ ជាវត្ថុ ជាសេវាពីមុនដែលបានផ្តល់រួចមកហើយយ៉ាងពិតប្រាកដ ឬ ជាការសន្យាថានឹងផ្តល់នូវសេវានាពេលអនាគត ។

ខ-ដាក់ភាគទុនជាសេវាដែលជាចំណេះដឹង ឬ សកម្មភាពផ្សេងៗ ប៉ុន្តែមិនត្រូវរាប់បញ្ចូលនូវការប្រើប្រាស់ឥទ្ធិពលដែលទទួលបានពីមុខងារជាមន្ត្រីសាធារណៈ ។

### មាត្រា ១៧.-

សហកម្មសិទ្ធិករទូទៅម្នាក់ៗ គឺជាកូនបំណុលនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ចំពោះរាល់អ្វីៗដែលខ្លួនបានសន្យាចូលរួមទៅក្នុងក្រុមហ៊ុន ។

### មាត្រា ១៨.-

នៅពេលសហកម្មសិទ្ធិករទូទៅបានទទួលយល់ព្រមដាក់ទ្រព្យសម្បត្តិជាភាគទុន សហកម្មសិទ្ធិករទូទៅនោះត្រូវធ្វើការផ្ទេរសិទ្ធិពីម្ចាស់ ឬ ពីសិទ្ធិដែលខ្លួនមានលើទ្រព្យនោះ ទៅដាក់ជាទ្រព្យរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។

### មាត្រា ១៩.-

នៅពេលសហកម្មសិទ្ធិករទូទៅ បានទទួលយល់ព្រមបង់ភាគទុននូវចំនួនទឹកប្រាក់ណាមួយ ហើយខកខានមិនបានបង់វិញ សហកម្មសិទ្ធិករទូទៅនោះត្រូវទទួល

ខុសត្រូវចំពោះការប្រាក់ ចាប់ពីថ្ងៃដែលបុគ្គលនោះបានសន្យាបង់ រួមទាំងការខូចខាតបន្ថែមទៀត ដែលត្រូវទាមទារពីសហកម្មសិទ្ធិករទូទៅនោះ ។

**មាត្រា ២០.-**

នៅពេលសហកម្មសិទ្ធិករទូទៅបានទទួលយល់ព្រមដាក់ភាគទុនជាចំណេះដឹង ជាសេវា ឬ ជាសកម្មភាព សហកម្មសិទ្ធិករទូទៅនោះត្រូវជាប់កាតព្វកិច្ចរហូត ដរាបណាបុគ្គលនោះនៅតែជាសហកម្មសិទ្ធិករទូទៅ ។

កិច្ចសន្យាជាលាយលក្ខណ៍អក្សរ សៀវភៅបញ្ជី និងកំណត់ហេតុរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ ប្រសិនបើភាគទុនរបស់សហកម្ម-សិទ្ធិករទូទៅជាចំណេះដឹង ជាសេវា ឬ ជាសកម្មភាព ។

**មាត្រា ២១.-**

ដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅរួមមានទាំងភាគទុនជាសាច់ប្រាក់ និងជាវត្ថុ ។ ភាគទុនជាវត្ថុត្រូវវាយតម្លៃជាសាច់ប្រាក់ ហើយសហកម្មសិទ្ធិករទូទៅទាំងអស់ត្រូវទទួលស្គាល់ការវាយតម្លៃនោះ ។

ការគណនាដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មិនត្រូវរាប់បញ្ចូលនូវភាគទុនជាចំណេះដឹង ជាសេវា ឬ ភាគទុនជាសកម្មភាពទេ ។

**មាត្រា ២២.-**

ដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវគណនាជារូបិយវត្ថុជាតិ ។

**មាត្រា ២៣.-**

សហកម្មសិទ្ធិករទូទៅម្នាក់ៗ ត្រូវមានសិទ្ធិទទួលប្រាក់ចំណេញ និងត្រូវរួមចំណែកការខាតបង់របស់ក្រុមហ៊ុន ។

ខទាំងឡាយនៃកិច្ចសន្យាណា ដែលដកសហកម្មសិទ្ធិករទូទៅពីសិទ្ធិទទួលប្រាក់ចំណេញត្រូវចាត់ទុកជាគ្មានប្រសិទ្ធភាព ។

ខទាំងឡាយនៃកិច្ចសន្យាណា ដែលដកសហកម្មសិទ្ធិករទូទៅពីការជាប់កាតព្វកិច្ចក្នុងការរួមចំណែកការខាតបង់ ត្រូវចាត់ទុកជាគ្មានប្រសិទ្ធភាពចំពោះតតិយជនឡើយ ។

**មាត្រា ២៤.-**

សមាមាត្រនៃផលប្រយោជន៍របស់សហកម្មសិទ្ធិករទូទៅម្នាក់ៗនៅក្នុងទ្រព្យសម្បត្តិ ប្រាក់ចំណេញ និងការខាតបង់គឺស្មើគ្នា លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចសន្យា ។

ប្រសិនបើកិច្ចសន្យាចែងអំពីផលប្រយោជន៍របស់សហកម្មសិទ្ធិករទូទៅ ដោយសំដៅចំពោះតែទ្រព្យសម្បត្តិ ប្រាក់ចំណេញ ឬការខាតបង់ ពេលនោះសមាមាត្រ ដែលបានបង្កើតឡើងក្នុងករណីនេះ ត្រូវបានសន្មតជាមុន ដើម្បីអនុវត្តទៅលើតែករណីទាំងបីនោះ ។

**មាត្រា ២៥.-**

សហកម្មសិទ្ធិករទូទៅម្នាក់ៗ ត្រូវទទួលខុសត្រូវចំពោះក្រុមហ៊ុននូវរាល់ផលកម្រៃ និងប្រាក់ចំណេញទាំងឡាយ ដែលសហកម្មសិទ្ធិករទូទៅនោះ បានមកពីការធ្វើអាជីវកម្មណាមួយនៅក្នុងពាណិជ្ជកិច្ច ឬ ពីការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ដែលគ្មានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅផ្សេងទៀត ។ សហកម្មសិទ្ធិករទូទៅទាំងឡាយ មិនអាចបដិសេធកាតព្វកិច្ចនេះបានឡើយ ។

**មាត្រា ២៦.-**

គ្មានសហកម្មសិទ្ធិករទូទៅណាម្នាក់ ត្រូវទទួលប្រាក់បៀវត្សពីការធ្វើពាណិជ្ជកិច្ចក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះឡើយ ។

**មាត្រា ២៧.-**

សហកម្មសិទ្ធិករទូទៅម្នាក់ៗ ត្រូវទទួលខុសត្រូវចំពោះក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ នូវរាល់ការខូចខាតដែលបង្កឡើងដោយកំហុសឆ្គងរបស់សហកម្មសិទ្ធិករទូទៅនោះ ។

**មាត្រា ២៨.-**

សហកម្មសិទ្ធិករទូទៅដែលប្រកបកិច្ចការពាណិជ្ជកម្មដោយស្មោះត្រង់ចំពោះ ក្រុមហ៊ុន មានសិទ្ធិទទួលនូវសំណងនៃការខូចខាតដែលខ្លួនបានធ្វើក្នុងនាមក្រុមហ៊ុន សហកម្មសិទ្ធិទូទៅនោះ ហើយមានសិទ្ធិទទួលនូវសំណងនៃការខូចខាតចំពោះកិច្ចសន្យា ដែលខ្លួនបានធ្វើ និងការខាតបង់ទាំងឡាយដែលខ្លួនទទួលរងនៅក្នុងការប្រតិបត្តិ ពាណិជ្ជកិច្ចសម្រាប់ក្រុមហ៊ុននោះ ។

**មាត្រា ២៩.-**

មាត្រា ២៨ នៃច្បាប់នេះអនុវត្តនៅពេលដែល :

ក-សហកម្មសិទ្ធិករទូទៅ ក្នុងនាមខ្លួនឯងផ្ទាល់ និងក្រុមហ៊ុនសហកម្មសិទ្ធិ ទូទៅរួមគ្នា ជាម្ចាស់បំណុលនៃកូនបំណុលតែមួយ ។

ខ-បំណុលទាំងពីរនឹងត្រូវសង ។

គ-កូនបំណុលត្រូវសងទៅសហកម្មសិទ្ធិករទូទៅ ប៉ុន្តែមិនសងទៅក្រុមហ៊ុន សហកម្មសិទ្ធិទូទៅទេ ។ ក្នុងករណីនេះ ចំនួននៃប្រាក់សំណងដែលសហកម្មសិទ្ធិករទូទៅ ទទួល ត្រូវបែងចែកទៅតាមសមាមាត្រទៅនឹងបំណុលផ្ទាល់ខ្លួន និងបំណុលចំពោះ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

**មាត្រា ៣០.-**

រាល់សហកម្មសិទ្ធិករទូទៅអាចប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្ម-សិទ្ធិទូទៅបាន លុះត្រាតែសហកម្មសិទ្ធិករទូទៅនោះ ប្រើប្រាស់ក្នុងប្រយោជន៍របស់ក្រុម ហ៊ុន ។

រាល់សហកម្មសិទ្ធិករទូទៅអាចប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបានក្នុងលក្ខណៈជាការប្រើប្រាស់ផ្ទាល់ខ្លួន លុះត្រាតែសហកម្មសិទ្ធិករទូទៅនោះមានការយល់ព្រមជាឯកច្ឆន្ទពីគ្រប់សហកម្មសិទ្ធិករទូទៅផ្សេងទៀត ។

រាល់សហកម្មសិទ្ធិករទូទៅ ត្រូវប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្ម-សិទ្ធិទូទៅ នៅក្នុងករណីមិនប៉ះពាល់ដល់សហកម្មសិទ្ធិករទូទៅផ្សេងទៀត ដែលប្រើប្រាស់ទ្រព្យសម្បត្តិនោះ ។

**មាត្រា ៣១.-**

គ្មានរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយអាចក្លាយជាសហកម្មសិទ្ធិករទូទៅដោយគ្មានការយល់ព្រមជាឯកច្ឆន្ទ ពីគ្រប់សហកម្មសិទ្ធិករទូទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបានឡើយ ។

សហកម្មសិទ្ធិករទូទៅម្នាក់ អាចប្រគល់សិទ្ធិឱ្យទៅបុគ្គលផ្សេង ដើម្បីទទួលប្រាក់កាសជំនួសខ្លួនបាន ដោយមិនចាំបាច់មានការយល់ព្រមពីសហកម្មសិទ្ធិករទូទៅដទៃទៀតឡើយ ។ ការប្រគល់សិទ្ធិបែបនេះ មិនធ្វើឱ្យអ្នកទទួលសិទ្ធិនោះក្លាយទៅជាសហ-កម្មសិទ្ធិករទូទៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅទេ ។

**មាត្រា ៣២.-**

សហកម្មសិទ្ធិករទូទៅម្នាក់ អាចផ្ទេរអត្ថប្រយោជន៍របស់ខ្លួននៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបាន ដោយមានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅទាំងអស់ ។

**មាត្រា ៣៣.-**

ភាគទុនជាទ្រព្យ ឬ ប្រាក់ចំណេញរបស់សហកម្មសិទ្ធិករទូទៅណាម្នាក់នៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ អាចត្រូវបានប្រើប្រាស់ជាទ្រព្យធានាន្ធូវកាតព្វកិច្ចផ្ទាល់ខ្លួនរបស់សហកម្មសិទ្ធិករទូទៅនោះ ។ ទ្រព្យធានានោះ ត្រូវមានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅទាំងអស់ ។

ការព្រមព្រៀងណាដែលផ្ទុយពីនេះ ត្រូវចាត់ទុកជាគ្មានប្រសិទ្ធភាព ។

**មាត្រា ៣៤.-**

សហកម្មសិទ្ធិករទូទៅទាំងឡាយអាចធ្វើសេចក្ដីសម្រេចអំពីសិទ្ធិរបស់ខ្លួននៅក្នុងការគ្រប់គ្រងរាល់កិច្ចការរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

**មាត្រា ៣៥.-**

សហកម្មសិទ្ធិករទូទៅទាំងឡាយ អាចតែងតាំងសហកម្មសិទ្ធិករទូទៅម្នាក់ ឬច្រើននាក់ ឬ បុគ្គលដែលមិនមែនជាសហកម្មសិទ្ធិករទូទៅ ឱ្យគ្រប់គ្រងកិច្ចការជំនួសខ្លួននៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះបាន ។

អ្នកគ្រប់គ្រងអាចអនុវត្តរាល់សកម្មភាពនៅក្នុងសិទ្ធិអំណាចរបស់ខ្លួនដរាបណាអ្នកគ្រប់គ្រងនោះមិនប្រព្រឹត្តអំពើក្លែងបន្លំ ។ ការប្រព្រឹត្តរបស់អ្នកគ្រប់គ្រងត្រូវជាប់កាតព្វកិច្ចទៅនឹងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

អ្នកគ្រប់គ្រងត្រូវបានដកហូតចេញពីមុខតំណែងដោយសំឡេងភាគច្រើនដោយប្រៀបនៃវត្តមានរបស់សហកម្មសិទ្ធិករទូទៅទាំងឡាយក្នុងពេលបោះឆ្នោត លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។

**មាត្រា ៣៦.-**

នៅពេលដែលបុគ្គលច្រើនរូបត្រូវបានតែងតាំងជាអ្នកគ្រប់គ្រងក្រុមហ៊ុន អ្នកគ្រប់គ្រងក្រុមហ៊ុនម្នាក់ៗ អាចអនុវត្តសកម្មភាពដាច់ដោយឡែកពីគ្នាបាន លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។

**មាត្រា ៣៧.-**

សហកម្មសិទ្ធិករទូទៅត្រូវបានចាត់ទុកថាមានសិទ្ធិគ្រប់គ្រងរាល់កិច្ចការរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

សកម្មភាពដែលបានអនុវត្តដោយសហកម្មសិទ្ធិករទូទៅម្នាក់ ដែលទាក់ទងទៅនឹងសកម្មភាពរួមរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ក៏ត្រូវជាប់កាតព្វកិច្ចទៅនឹងសហកម្មសិទ្ធិករទូទៅផ្សេងទៀតដែរ ។

**មាត្រា ៣៨.-**

រាល់សហកម្មសិទ្ធិករទូទៅមានសិទ្ធិចូលរួមក្នុងការធ្វើសេចក្តីសម្រេចរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ហើយការអនុវត្តសិទ្ធិនោះមិនត្រូវបានបង្អាក់ដោយសារកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះឡើយ ។

លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ រាល់សេចក្តីសម្រេចត្រូវធ្វើឡើងដោយការបោះឆ្នោតតាមសំឡេងភាគច្រើនដោយប្រៀបរបស់សហកម្មសិទ្ធិករទូទៅ ដោយមិនគិតតម្លៃអត្ថប្រយោជន៍របស់គេនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះទេ ។ ប៉ុន្តែសេចក្តីសម្រេចក្នុងការកែប្រែកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវធ្វើឡើងដោយសំឡេងឆ្នោតជាឯកច្ឆន្ទ ។

**មាត្រា ៣៩.-**

សហកម្មសិទ្ធិករទូទៅម្នាក់ៗមានសិទ្ធិទទួលព័ត៌មានអំពីកិច្ចការទាំងឡាយរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ហើយមានសិទ្ធិពិគ្រោះយោបល់លើសៀវភៅបញ្ជី និងកំណត់ហេតុ ទោះបីជាសហកម្មសិទ្ធិករទូទៅនោះគ្មានតួនាទីជាអ្នកគ្រប់គ្រងក៏ដោយ ។

នៅក្នុងការអនុវត្តសិទ្ធិនេះ សហកម្មសិទ្ធិករទូទៅមិនត្រូវបង្អាក់កិច្ចប្រតិបត្តិការរបស់ក្រុមហ៊ុនដោយគ្មានហេតុផលត្រឹមត្រូវ ឬ មិនត្រូវធ្វើឱ្យរាំងស្ទះដល់សហកម្មសិទ្ធិករទូទៅផ្សេងទៀតក្នុងការអនុវត្តសិទ្ធិដូចគ្នាឡើយ ។

## គ- ទំនាក់ទំនងនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅជាមួយតតិយជន

### មាត្រា ៤០.-

សហកម្មសិទ្ធិករទូទៅម្នាក់ៗគឺជាភ្នាក់ងាររបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ នៅក្នុងទំនាក់ទំនងជាមួយតតិយជនដែលធ្វើពាណិជ្ជកិច្ចជាមួយគ្នាដោយស្មោះត្រង់ ហើយសហកម្មសិទ្ធិករទូទៅទាំងនោះត្រូវជាប់កាតព្វកិច្ចចំពោះក្រុមហ៊ុននូវរាល់អំពើដែលខ្លួនបានអនុវត្ត ក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

ការព្រមព្រៀងណាដែលផ្ទុយពីនេះ ត្រូវបានចាត់ទុកជាគ្មានប្រសិទ្ធភាព ។

### មាត្រា ៤១.-

សហកម្មសិទ្ធិករទូទៅម្នាក់ដែលបានចុះកិច្ចសន្យាជាមួយតតិយជន ត្រូវបានជាប់កាតព្វកិច្ចទៅនឹងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ នៅពេលណាដែលកាតព្វកិច្ចនោះស្ថិតក្នុងវង្វង់អាជីវកម្មរបស់ក្រុមហ៊ុន ឬ នៅពេលណាដែលកម្មវត្ថុនៃកិច្ចសន្យានោះជាទ្រព្យសម្បត្តិដែលត្រូវបានប្រើប្រាស់ដោយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។

### មាត្រា ៤២.-

សហកម្មសិទ្ធិករទូទៅទាំងអស់ ត្រូវទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នានូវកាតព្វកិច្ចទាំងឡាយរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

តតិយជនត្រូវទាមទារការអនុវត្តកាតព្វកិច្ចបំណុល ឬ ទ្រព្យសម្បត្តិពីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅសិន មុននឹងទាមទារពីសហកម្មសិទ្ធិករទូទៅ ។

### មាត្រា ៤៣.-

បុគ្គលណាដែលចូលជាសហកម្មសិទ្ធិករទូទៅ នៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលកើតរួចហើយ ត្រូវទទួលខុសត្រូវចំពោះបំណុលទាំងអស់ ដែលកើតឡើងដោយសារក្រុមហ៊ុន មុនពេលដែលបុគ្គលនោះចូលជាសហកម្មសិទ្ធិករទូទៅដូចដែលខ្លួនជាសហកម្មសិទ្ធិករទូទៅនៅពេលបំណុលនោះកើតឡើងដែរ ។ ប៉ុន្តែបំណុលទាំងឡាយ

ណាដែលបានកើតឡើងមុនពេលបុគ្គលនោះចូលជាសហកម្មសិទ្ធិករទូទៅ បំណុលនោះ អាចត្រូវបានចេញសងដោយទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនតែប៉ុណ្ណោះ ហើយមិនត្រូវបាន ចេញសងដោយទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់បុគ្គលនោះឡើយ លើកលែងតែបុគ្គលនោះ មានការព្រមព្រៀងផ្សេងនៅក្នុងលិខិតជាលាយលក្ខណ៍អក្សរ ។

**មាត្រា ៤៤.-**

ការជូនដំណឹងទៅសហកម្មសិទ្ធិករទូទៅណាម្នាក់ ឬ ការដឹងឮរបស់សហកម្មសិទ្ធិ-ករទូទៅណាម្នាក់ដែលពាក់ព័ន្ធទៅនឹងការងាររបស់ក្រុមហ៊ុន ត្រូវចាត់ទុកថាជាសេចក្តីជូនដំណឹង និងការដឹងឮដល់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះដែរ លើកលែងតែមាន ការក្លែងបន្លំ ដែលប្រព្រឹត្តឡើងដោយការឃុបឃិតពីសហកម្មសិទ្ធិករទូទៅនោះចំពោះ ក្រុមហ៊ុន ។

**មាត្រា ៤៥.-**

បុគ្គលណាម្នាក់ដែលធ្វើឱ្យបុគ្គលផ្សេងទៀតជឿទុកចិត្តដោយផ្ទាល់ ឬ ដោយ ប្រយោលថាខ្លួនជាសហកម្មសិទ្ធិករទូទៅ ប៉ុន្តែការពិតបុគ្គលនោះមិនមែនជាសហកម្ម-សិទ្ធិករទូទៅទេ ត្រូវទទួលខុសត្រូវចំពោះតតិយជនដែលធ្វើពាណិជ្ជកិច្ចជាមួយដោយ ស្មោះត្រង់ដូចសហកម្មសិទ្ធិករទូទៅពិតៗដែរ ។

ក្នុងករណីមានបុគ្គលក្លែងបន្លំ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមិនទទួលខុសត្រូវ ចំពោះតតិយជនណាឡើយ លើកលែងតែក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះមិនបាន ចាត់វិធានការដើម្បីការពារតតិយជននោះ ក្រោយពេលដែលក្រុមហ៊ុនបានដឹងថាមាន ការក្លែងបន្លំហើយ ។

**មាត្រា ៤៦.-**

សហកម្មសិទ្ធិករទូទៅណាម្នាក់ ដែលមិនបានប្រកាសចេញមុខដោយក្រុមហ៊ុន សហកម្មសិទ្ធិទូទៅនោះទេ សហកម្មសិទ្ធិករទូទៅនោះត្រូវទទួលស្គាល់ថាជាសហកម្ម-សិទ្ធិករទូទៅកំបាំងមុខ ។ សហកម្មសិទ្ធិករទូទៅនោះ ត្រូវទទួលខុសត្រូវចំពោះតតិយ

ជនទាំងឡាយនូវរាល់កាតព្វកិច្ច ដូចសហកម្មសិទ្ធិករទូទៅទាំងឡាយដែលបានប្រកាសចេញមុនដែរ ។

**មាត្រា ៤៧.-**

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមិនអាចបោះចេញ ឬ បែងចែកមូលបត្រ ឬ ប័ណ្ណដែលអាចលក់ដូរបានទៅឱ្យសាធារណជនឡើយ ។

កិច្ចសន្យាដែលចូលជាធរមានទៅក្នុងការបោះចេញមូលបត្រ ឬ ប័ណ្ណដែលធ្វើឡើងផ្ទុយពីមាត្រានេះត្រូវចាត់ទុកជាមោឃៈ ។

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវសងនូវការខូចខាតទាំងឡាយដែលបង្កឡើងពីមោឃភាពនៃកិច្ចសន្យាមូលបត្រ ឬ ប័ណ្ណទៅឱ្យតតិយជនដែលធ្វើពាណិជ្ជកិច្ចជាមួយគ្នាដោយស្មោះត្រង់ ។

## ឃ- ការអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅ

**មាត្រា ៤៨.-**

បុគ្គលណាមួយអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ នៅពេលដែលបុគ្គលនោះ :

- បានផ្ទេរផលប្រយោជន៍របស់ខ្លួន
- បានទទួលមរណភាព
- ត្រូវបានដាក់ក្រោមការពិនិត្យអង្កេតពេលក្ស័យធន
- បានអនុវត្តសិទ្ធិដើម្បីដកខ្លួនចេញ
- ត្រូវបានបណ្តេញចេញពីក្រុមហ៊ុន
- បានទទួលសាលក្រមតុលាការអនុញ្ញាតឱ្យដកខ្លួនចេញ ឬ បញ្ជាឱ្យរឹបអូសអត្ថប្រយោជន៍របស់បុគ្គលនោះ ។

**មាត្រា ៤៩.-**

បុគ្គលណាមួយអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅ បង្កឱ្យមានការរំលាយជាស្វ័យប្រវត្តិនូវក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ លើកលែងតែកិច្ចសន្យាចែងផ្សេងពីនេះ ។

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅអាចបន្តសកម្មភាពទៅបាន ដោយមានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅទាំងអស់ និងដោយការអនុវត្តលក្ខខណ្ឌតម្រូវនៃការតម្កល់ទុក និងការចុះបញ្ជី ដើម្បីបង្ហាញអំពីការកែប្រែនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

ប្រសិនបើក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មានកិច្ចសន្យាជាលាយលក្ខណ៍អក្សរ កិច្ចសន្យានោះត្រូវធ្វើការកែប្រែឱ្យស្របតាមនោះដែរ ។

**មាត្រា ៥០.-**

បុគ្គលណាមួយដែលអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ក្រៅពីដោយសារការផ្ទេរ ឬដោយសារការរឹបអូស អត្ថប្រយោជន៍របស់ខ្លួនបុគ្គលនោះអាចទទួលនូវតម្លៃណាមួយនៃអត្ថប្រយោជន៍របស់ខ្លួន អំពីការអស់សិទ្ធិជាសហ-កម្មសិទ្ធិករទូទៅនេះបាន ។ សហកម្មសិទ្ធិករទូទៅដទៃទៀត ត្រូវបង់ការចំណាយជាចាំបាច់ដល់បុគ្គលនោះ នូវតម្លៃណាមួយដែលអាចធ្វើទៅបានដោយឆាប់រហ័សជាមួយនិងការប្រាក់ ចាប់ពីថ្ងៃដែលបុគ្គលនោះអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅ ។

តម្លៃនៃអត្ថប្រយោជន៍ត្រូវបានកំណត់ ដូចដែលមានចែងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ឬកិច្ចសន្យាក្នុងចំណោមសហកម្មសិទ្ធិករទូទៅទាំងឡាយ ។

បើមិនដូច្នោះទេ តម្លៃនោះត្រូវកំណត់ដោយអ្នកឯកទេសដែលបានជ្រើសតាំងដោយសហកម្មសិទ្ធិករទូទៅទាំងឡាយ ឬដោយតុលាការ ។

**មាត្រា ៥១.-**

សហកម្មសិទ្ធិករទូទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលបានរួមគ្នាបង្កើតឡើងដោយមានអាយុកាលមិនកំណត់ ឬ កិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ដែលមាន

ចែងអំពីការបម្រុងទុកនូវសិទ្ធិដកខ្លួន សហកម្មសិទ្ធិករទូទៅនោះអាចដកខ្លួនចេញពីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបាន តាមការជូនដំណឹងអំពីការដកខ្លួនដោយសុទ្ធចិត្ត ។

សហកម្មសិទ្ធិករទូទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលបានរួមគ្នាបង្កើតឡើងដោយមានអាយុកាលកំណត់ អាចដកខ្លួនចេញបាន តែក្នុងករណីមានការយល់ព្រមពីមតិភាគច្រើនដាច់ខាតរបស់សហកម្មសិទ្ធិករទូទៅទាំងឡាយ បើមិនដូច្នោះទេលុះត្រាតែកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅចែងផ្សេងពីនេះ ។

**មាត្រា ៥២.-**

សហកម្មសិទ្ធិករទូទៅទាំងឡាយអាចបណ្តេញចេញពីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនូវសហកម្មសិទ្ធិករទូទៅ ដែលខកខានមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន ឬ ដែលធ្វើឱ្យរាំងស្ទះដល់ដំណើរការរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ តាមរយៈការបោះឆ្នោតដោយសំឡេងភាគច្រើនដោយប្រៀប ។

ក្នុងករណីដែលមានការជំទាស់ សហកម្មសិទ្ធិករទូទៅទាំងឡាយអាចស្នើសុំការអនុញ្ញាតពីតុលាការ ដើម្បីដកសហកម្មសិទ្ធិករទូទៅនោះចេញពីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។ តុលាការអាចអនុញ្ញាតនូវការស្នើសុំនោះបាន លុះត្រាតែតុលាការពិចារណាឃើញថាការសុំដកចេញនោះសមស្រប ហើយចេញដីកាផ្អែកទៅតាមកំហុសរបស់សហកម្មសិទ្ធិករទូទៅ ។

## ១- ការរំលាយ និង ការជម្រះបញ្ជីក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

**មាត្រា ៥៣.-**

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវរំលាយដោយមូលហេតុដូចខាងក្រោម :

ក-មូលហេតុដែលមានចែងក្នុងកិច្ចសន្យា

-គោលបំណងធ្វើអាជីវកម្មរបស់ក្រុមហ៊ុនត្រូវបានបញ្ចប់

-គ្មានលទ្ធភាពធ្វើអាជីវកម្មបន្ត

-តាមការព្រមព្រៀងជាឯកច្ឆន្ទរបស់សហកម្មសិទ្ធិករទូទៅ

ខ- តុលាការអាចរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបានតាមមូលហេតុស្របច្បាប់ ។ នៅពេលក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវបានរំលាយ ក្រុមហ៊ុននោះអាចធ្វើការជម្រះបញ្ជីបាន ។

**មាត្រា ៥៤.-**

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលបានបង្កើតឡើងដោយមានកាលកំណត់មួយនៃកិច្ចសន្យា អាចពន្យារបន្តសកម្មភាពរបស់ខ្លួនបានដោយមានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅទាំងអស់ ។

**មាត្រា ៥៥.-**

ការទទួលផាក់រួមនូវអត្ថប្រយោជន៍ទាំងអស់ទៅក្នុងដៃសហកម្មសិទ្ធិករទូទៅតែម្នាក់ មិនមែនជាមូលហេតុនៃការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះទេ ដរាបណាមានបុគ្គលណាមួយផ្សេងទៀតក្លាយជាសហកម្មសិទ្ធិករទូទៅ ក្នុងអំឡុង ១២០ (មួយរយម្ភៃ)ថ្ងៃ គិតចាប់ពីថ្ងៃដែលអត្ថប្រយោជន៍នោះផាក់បញ្ចូលគ្នា ។

**មាត្រា ៥៦.-**

សិទ្ធិរបស់សហកម្មសិទ្ធិករទូទៅដែលធ្វើសកម្មភាពក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវចប់ នៅពេលដែលក្រុមហ៊ុននោះត្រូវបានរំលាយ លើកលែងតែចំពោះសកម្មភាពទាំងឡាយណាដែលជាវិបាកដ៏ចាំបាច់នៃពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន ដែលបានធ្វើពុំទាន់ចប់សព្វគ្រប់ ។ ប៉ុន្តែរាល់កិច្ចការដែលបានធ្វើជាប្រក្រតីក្នុងក្រុមហ៊ុនដោយសហកម្មសិទ្ធិករទូទៅ ដែលមិនបានដឹងជាមុនអំពីការរំលាយក្រុមហ៊ុននោះ ហើយនៅតែធ្វើសកម្មភាពដោយស្មោះត្រង់ សហកម្មសិទ្ធិករទូទៅនោះត្រូវជាប់កាតព្វកិច្ចជាមួយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងសហកម្មសិទ្ធិករទូទៅដទៃទៀត ដូចដែលក្រុមហ៊ុននោះនៅជាធរមាននៅឡើយ ។

**មាត្រា ៥៧.-**

ការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមិនប៉ះពាល់ទៅនឹងសិទ្ធិតតិយជនដែលធ្វើពាណិជ្ជកិច្ចជាមួយដោយស្មោះត្រង់ និងមិនប៉ះពាល់ទៅនឹងបុគ្គលណាមួយដែលបានចុះកិច្ចសន្យាជាមួយសហកម្មសិទ្ធិករទូទៅ ឬ មិនប៉ះពាល់ទៅនឹងភ្នាក់ងារណាម្នាក់ដែលធ្វើកិច្ចការក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះឡើយ ។

**មាត្រា ៥៨.-**

នីតិបុគ្គលិកលក្ខណៈរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ បន្តរហូតដល់ចប់នូវការជម្រះបញ្ជីរបស់ក្រុមហ៊ុននោះ ។

**មាត្រា ៥៩.-**

សហកម្មសិទ្ធិករទូទៅត្រូវធ្វើលិខិតជូនដំណឹងទៅមន្ត្រីចុះបញ្ជីអំពីការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ តាមទម្រង់បែបបទដែលបានកំណត់ និងត្រូវធ្វើការតែងតាំងអ្នកជម្រះបញ្ជីផង ។

សហកម្មសិទ្ធិករទូទៅ ត្រូវធ្វើការចុះផ្សាយជាបន្ទាន់អំពីការរំលាយក្រុមហ៊ុនក្នុងរយៈពេល ៤(បួន)សប្តាហ៍បន្តបន្ទាប់នៅក្នុងទំព័រសារព័ត៌មានជាភាសាខ្មែរនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលបោះពុម្ព ឬ ផ្សព្វផ្សាយនៅនឹងកន្លែងដែលក្រុមហ៊ុននោះមានការិយាល័យរបស់ខ្លួននៅទីនោះ ឬ នៅក្នុងការផ្សព្វផ្សាយផ្សេងទៀតដូចមានចែងក្នុងបទបញ្ញារបស់ក្រសួងពាណិជ្ជកម្ម ។ លិខិតជូនដំណឹងដែលបានចុះផ្សាយនៅក្នុងទំព័រសារព័ត៌មាន ត្រូវមានចែងក្នុងបទបញ្ញារបស់ក្រសួងពាណិជ្ជកម្ម ។

**មាត្រា ៦០.-**

នៅពេលធ្វើការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ សិទ្ធិក្នុងការកាន់កាប់ និងប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវប្រគល់ឱ្យអ្នកជម្រះបញ្ជី ។

អ្នកជម្រះបញ្ជីត្រូវធ្វើសកម្មភាពក្នុងនាមជាអ្នកចាត់ចែងលើទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ។ អ្នកជម្រះបញ្ជីត្រូវបានផ្តល់សិទ្ធិពេញលេញក្នុងការចាត់ចែងទាំងមូល ។

អ្នកជម្រះបញ្ជីមានសិទ្ធិទាមទារពីសហកម្មសិទ្ធិករទូទៅទាំងអស់នូវឯកសារនានា និងការបកស្រាយដែលពាក់ព័ន្ធដល់សិទ្ធិ និងកាតព្វកិច្ចនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។

**មាត្រា ៦១.-**

អ្នកជម្រះបញ្ជីត្រូវយកទ្រព្យសម្បត្តិទៅសងបំណុលបៀវត្សបុគ្គលិក បំណុលពន្ធរបស់រដ្ឋ និងបំណុលផ្សេងទៀតទៅតាមសិទ្ធិបុរិមាជាមុន រួចទើបធ្វើការបែងចែកភាគទុន ។

អ្នកជម្រះបញ្ជីត្រូវធ្វើការកាត់ចំណែកទ្រព្យសម្បត្តិដែលនៅសេសសល់ ឱ្យទៅសហកម្មសិទ្ធិករទូទៅទាំងឡាយទៅតាមសមាមាត្រស្មើៗគ្នា ប្រសិនបើគ្មានចែងផ្សេងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះទេ ។

ក្នុងករណីដែលទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនមានរួមទាំងទ្រព្យសម្បត្តិរបស់តតិយជនផង អ្នកជម្រះបញ្ជីត្រូវតែបង្វិលទ្រព្យសម្បត្តិរបស់តតិយជនទៅឱ្យតតិយជននោះវិញ ។

**មាត្រា ៦២.-**

អ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវសៀវភៅបញ្ជី និងកំណត់ហេតុផ្សេងៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅរហូតដល់រយៈពេល ១០(ដប់)ឆ្នាំ ចាប់ពីពេលដែលបានជម្រះបញ្ជីរួច ។ អ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវសៀវភៅបញ្ជី និងកំណត់ហេតុផ្សេងៗសម្រាប់រយៈពេលច្រើនជាងនេះ ប្រសិនបើឯកសារទាំងនេះតម្រូវឱ្យទុកជាភស្តុតាង ។

**មាត្រា ៦៣.-**

ការជម្រះបញ្ជីរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវបញ្ចប់ដោយធ្វើការតម្កល់ទុកនូវសេចក្តីជូនដំណឹងអំពីការបិទបញ្ជីនោះ នៅក្រសួងពាណិជ្ជកម្មតាមបែបបទដែលបានកំណត់ទុក ។ ការតម្កល់ទុកឯកសារនេះគឺជាការលុបចោលនូវនីតិបុគ្គលិកលក្ខណៈរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

## ផ្នែកទី ២
## ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត

**មាត្រា ៦៤.-**

ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតគឺជាកិច្ចសន្យាដែលធ្វើឡើងរវាងសហកម្មសិទ្ធិករទូទៅម្នាក់ ឬ ច្រើននាក់ ដែលមានបុគ្គលម្នាក់ត្រូវបានអនុញ្ញាតឱ្យគ្រប់គ្រងនិងមានកាតព្វកិច្ចនៅក្នុងក្រុមហ៊ុនជាមួយសហកម្មសិទ្ធិករមានកម្រិតម្នាក់ ឬ ច្រើននាក់ ដែលមានកាតព្វកិច្ចបង់ភាគទុនចូលទៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិនោះ ។

**មាត្រា ៦៥.-**

បុគ្គលម្នាក់អាចជាសហកម្មសិទ្ធិករទូទៅផង និងជាសហកម្មសិទ្ធិករមានកម្រិតផង នៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ។

បុគ្គលម្នាក់ដែលជាសហកម្មសិទ្ធិករទូទៅផង និងជាសហកម្មសិទ្ធិករមានកម្រិតផងក្នុងពេលតែមួយ នៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត មានសិទ្ធិ និងកាតព្វកិច្ចជាសហកម្មសិទ្ធិករទូទៅ ។

**មាត្រា ៦៦.-**

កិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត អាចធ្វើជាលាយលក្ខណ៍អក្សរ ឬ ផ្ទាល់មាត់ ។ ក្នុងករណីកិច្ចសន្យាធ្វើជាលាយលក្ខណ៍អក្សរ សហកម្មសិទ្ធិករទូទៅទាំងអស់ និងសហកម្មសិទ្ធិករមានកម្រិតយ៉ាងតិចម្នាក់ ត្រូវចុះហត្ថលេខាលើកិច្ចសន្យានោះ ។

រយៈពេលនៃកិច្ចសន្យារបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត មិនត្រូវលើសកំណត់ ៩៩(កៅសិបប្រាំបួន)ឆ្នាំឡើយ ប៉ុន្តែអាចពន្យារពេលបន្តបាន ។

**មាត្រា ៦៧.-**

ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតត្រូវបានបង្កើតតាមកាលបរិច្ឆេទដែលបានចុះបញ្ជីពាណិជ្ជកម្ម ស្របទៅតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ។

ក្នុងករណីក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតមិនបានចុះបញ្ជីពាណិជ្ជកម្មទេ ក្រុមហ៊ុននោះ ត្រូវបានចាត់ទុកថា ជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ។ ក្នុងករណីនេះ ក្រុមហ៊ុនប្រភេទនេះមិនមាននីតិបុគ្គលិកលក្ខណៈទេ ។

**មាត្រា ៦៨.-**

នាមករណ៍របស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ត្រូវបញ្ចូលឈ្មោះរបស់សហកម្មសិទ្ធិករទូទៅម្នាក់ ឬ ច្រើននាក់ ។ នៅខាងក្រោយ ឬ ក្រោមនាមករណ៍នោះ ត្រូវដាក់ពាក្យថា "ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត" ។ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតត្រូវប្រើឈ្មោះនោះក្នុងខណៈដែលខ្លួនធ្វើអាជីវកម្ម ។

**មាត្រា ៦៩.-**

សហកម្មសិទ្ធិករទូទៅទាំងឡាយ ត្រូវរក្សាទុកនូវកំណត់ហេតុដែលមានឈ្មោះ អាសយដ្ឋានរបស់សហកម្មសិទ្ធិករមានកម្រិតម្នាក់ៗ និងព័ត៌មានដែលទាក់ទងទៅនឹងការបង់ភាគទុននៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះ ។

សហកម្មសិទ្ធិករទូទៅទាំងឡាយ ត្រូវរក្សាកំណត់ហេតុទុកនៅទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះ ។

សហកម្មសិទ្ធិករទូទៅទាំងអស់ ត្រូវទទួលខុសត្រូវចំពោះការចុះបញ្ជី ការតម្កល់ទុក និងការផ្សព្វផ្សាយដែលតម្រូវឱ្យក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះអនុវត្ត ។

**មាត្រា ៧០.-**

ការបង់ភាគទុនរបស់សហកម្មសិទ្ធិករមានកម្រិត អាចជាទឹកប្រាក់ ឬ ជាទ្រព្យសម្បត្តិតែប៉ុណ្ណោះ ។ សហកម្មសិទ្ធិករមានកម្រិតអាចបន្ថែមភាគទុនបាននៅគ្រប់ពេលវេលា ។

ការបង់ភាគទុនរបស់សហកម្មសិទ្ធិករទូទៅ អាចជាសាច់ប្រាក់ ជាវត្ថុ ជាសេវាពីមុនដែលកំពុងបន្តនាពេលបច្ចុប្បន្ន ឬជាការសន្យាថានឹងផ្តល់សេវានាពេលអនាគត ។

**មាត្រា ៧១.-**

សហកម្មសិទ្ធិករមានកម្រិតម្នាក់ៗ មានសិទ្ធិទទួលចំណែកនៃប្រាក់ចំណេញរបស់ខ្លួន ។ ប៉ុន្តែប្រសិនបើការទទួលប្រាក់ចំណេញនោះ នៅតែធ្វើឱ្យមានអនិនភាពដល់ដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត សហកម្មសិទ្ធិករមានកម្រិតដែលបានទទួលចំណែកនៃប្រាក់ចំណេញនោះ ត្រូវបង្វិលចំនួនទឹកប្រាក់ចាំបាច់ណាមួយនៃប្រាក់ចំណេញចូលទៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតវិញ ដើម្បីទប់ទល់ទៅនឹងអនិនភាពភាគទុនរបស់ខ្លួន ។

**មាត្រា ៧២.-**

សហកម្មសិទ្ធិករមានកម្រិតទទួលខុសត្រូវទៅលើតែចំនួនទឹកប្រាក់ ឬ តម្លៃនៃទ្រព្យសម្បត្តិដែលខ្លួនបានព្រមព្រៀងដាក់ជាភាគទុនប៉ុណ្ណោះ ។

**មាត្រា ៧៣.-**

សហកម្មសិទ្ធិករមានកម្រិត ដែលមានឈ្មោះនៅក្នុងនាមករណ៍ក្រុមហ៊ុនសហ-កម្មសិទ្ធិមានកម្រិត ត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ចនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតដូចជាសហកម្មសិទ្ធិករទូទៅដែរ លើកលែងតែស្ថានភាពរបស់សហកម្មសិទ្ធិករមានកម្រិតនោះត្រូវបានបញ្ជាក់ច្បាស់លាស់ ។

**មាត្រា ៧៤.-**

សហកម្មសិទ្ធិករទូទៅមានសិទ្ធិនិងកាតព្វកិច្ចដូចជាសហកម្មសិទ្ធិករនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែរ ។ សហកម្មសិទ្ធិករទូទៅ ត្រូវរាយការណ៍ពីការគ្រប់គ្រងដល់សហកម្មសិទ្ធិករមានកម្រិតទាំងឡាយ ។

សហកម្មសិទ្ធិករទូទៅមានកាតព្វកិច្ចទទួលខុសត្រូវចំពោះទ្រព្យសម្បត្តិសហកម្មសិទ្ធិករមានកម្រិតដទៃទៀត ដែលមាននៅក្នុងដើមទុនរបស់ក្រុមហ៊ុន ។

កិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត មិនអាចជៀសវាងកាតព្វកិច្ចនេះបានទេ ។

**មាត្រា ៧៥.-**

សហកម្មសិទ្ធិករទូទៅទាំងឡាយ ត្រូវទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នានូវបំណុលទាំងឡាយរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតចំពោះតតិយជន ។

**មាត្រា ៧៦.-**

សហកម្មសិទ្ធិករមានកម្រិត អាចទទួលប្រាក់បៀវត្សពីក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតបាន ។

**មាត្រា ៧៧.-**

នៅពេលដែលក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតកើតឡើងនៅក្នុងករណីណាក៏ដោយ សហកម្មសិទ្ធិករមានកម្រិតមិនអាចដកចំណែកណាមួយនៃភាគទុនរបស់ខ្លួនបានទេ លើកលែងតែមានការយល់ព្រមពីមតិភាគច្រើនដាច់ខាតនៃសហកម្មសិទ្ធិករទាំងអស់ និងក្រោយពីការដកនោះ ទ្រព្យសម្បត្តិដែលនៅសល់ក្នុងក្រុមហ៊ុនមានគ្រប់គ្រាន់ដើម្បីដោះបំណុលរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះបាន ។

**មាត្រា ៧៨.-**

សហកម្មសិទ្ធិករមានកម្រិតម្នាក់ អាចធ្វើការផ្ទេរអត្ថប្រយោជន៍របស់ខ្លួនបាននៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះ ដោយពុំចាំបាច់មានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករដទៃទៀតឡើយ ។

ក្នុងទំនាក់ទំនងទៅនឹងតតិយជន សហកម្មសិទ្ធិករមានកម្រិតដែលបានផ្ទេរអត្ថប្រយោជន៍របស់ខ្លួនរួចមកហើយនោះ នៅតែជាប់កាតព្វកិច្ចដែលកើតមានឡើងនៅពេលដែលខ្លួននៅជាសហកម្មសិទ្ធិករមានកម្រិត ។

**មាត្រា ៧៩.-**

សហកម្មសិទ្ធិករមានកម្រិតមិនអាចចូលរួមនៅក្នុងការគ្រប់គ្រងអាជីវកម្មរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតបានទេ ។

សហកម្មសិទ្ធិករមានកម្រិតអាចធ្វើការពិនិត្យរបាយការណ៍ និងការរីកចំរើនរបស់ក្រុមហ៊ុន និងអាចផ្តល់ជាគំនិតក្នុងការគ្រប់គ្រងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះបានគ្រប់ដំណាក់កាល ។

សហកម្មសិទ្ធិករមានកម្រិតមិនអនុញ្ញាតឱ្យចរចាក្នុងកិច្ចការពាណិជ្ជកម្មណាមួយក្នុងនាមនៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត មិនអនុញ្ញាតឱ្យធ្វើជាភ្នាក់ងារក្រុមហ៊ុនសហកម្មសិទ្ធិនោះ ឬ មិនអនុញ្ញាតឱ្យប្រើឈ្មោះរបស់ខ្លួនក្នុងសកម្មភាពពាណិជ្ជកម្មណាមួយរបស់ក្រុមហ៊ុននោះឡើយ ។

សហកម្មសិទ្ធិករមានកម្រិតដែលប្រព្រឹត្តអំពើទាំងនេះ ត្រូវទទួលខុសត្រូវរាល់កាតព្វកិច្ចរបស់ក្រុមហ៊ុនដែលកើតឡើងដោយសារការប្រព្រឹត្តទាំងនោះ ។

សហកម្មសិទ្ធិករមានកម្រិត អាចអនុញ្ញាតឱ្យទទួលខុសត្រូវដូចសហកម្មសិទ្ធិករទូទៅដែរ ចំពោះកាតព្វកិច្ចនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិ ប្រសិនបើសកម្មភាពទាំងឡាយដែលបានរៀបរាប់រួចហើយ ឬ សារៈសំខាន់នៃសកម្មភាពទាំងនោះស្របតាមដំណើរការអាជីវកម្មរបស់ក្រុមហ៊ុន ហើយមានភស្តុតាងបញ្ជាក់ថា សហកម្មសិទ្ធិករមានកម្រិតធ្វើសកម្មភាពក្នុងនាមសហកម្មសិទ្ធិករទូទៅពិតប្រាកដមែន ។

**មាត្រា ៨០.-**

នៅពេលសហកម្មសិទ្ធិករទូទៅមិនអាចបំពេញការងារពាណិជ្ជកម្មតទៅមុខទៀតបានទេ សហកម្មសិទ្ធិករមានកម្រិតអាចបំពេញកិច្ចការរដ្ឋបាលប្រចាំថ្ងៃដែលជាតម្រូវការក្នុងដំណើរការគ្រប់គ្រងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះ ។

ក្នុងករណីដែលសហកម្មសិទ្ធិករទូទៅទាំងឡាយ មិនត្រូវបានជំនួសក្នុងរយៈពេល ១២០(មួយរយម្ភៃ)ថ្ងៃទេ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះនឹងត្រូវបានរំលាយ ។

**មាត្រា ៨១.-**

តតិយជនដែលជាម្ចាស់បំណុលអាចប្តឹងទាមទារបំណុលពីក្រុមហ៊ុនសហកម្ម-សិទ្ធិមានកម្រិតនិងពីសហកម្មសិទ្ធិករទូទៅបានដូចគ្នា ដូចក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែរ ។

**មាត្រា ៨២.-**

នៅពេលណាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតមិនគ្រប់គ្រាន់ទេ សហកម្មសិទ្ធិករទូទៅទាំងឡាយត្រូវទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នា ចំពោះតតិយជននូវបំណុលទាំងឡាយរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ។ សហ-កម្មសិទ្ធិករមានកម្រិត ត្រូវទទួលខុសត្រូវនូវបំណុលត្រឹមតែចំនួនភាគទុន ដែលខ្លួនបានព្រមព្រៀងដាក់ជាមួយគ្នា ដោយមិនគិតការផ្ទេរអត្ថប្រយោជន៍ណាមួយរបស់ខ្លួនឡើយ ។

**មាត្រា ៨៣.-**

ក្នុងករណីបំណុលកើនលើសពីដើមទុន ឬ ក្នុងករណីក្ស័យធននៃក្រុមហ៊ុនសហ-កម្មសិទ្ធិមានកម្រិត សហកម្មសិទ្ធិករមានកម្រិតម្នាក់ៗដែលជាម្ចាស់បំណុល មិនអាចទាមទារបំណុលពីក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតបានទេ រហូតដល់ម្ចាស់បំណុលដទៃទៀតនៃក្រុមហ៊ុនមានកម្រិតនេះ ត្រូវបានដោះស្រាយចប់សព្វគ្រប់ ។

**មាត្រា ៨៤.-**

វិធាននៃការគ្រប់គ្រងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ក៏ត្រូវអនុវត្តចំពោះក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតដែរ ។

# ជំពូកទី ៣
# ក្រុមហ៊ុនមូលធន
## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ៨៥.–**

ច្បាប់នេះអនុញ្ញាតឱ្យបង្កើតក្រុមហ៊ុនមូលធន ដែលមានក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដើម្បីប្រកបពាណិជ្ជកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត មិនអាចបង្កើតឡើងក្រោមច្បាប់នេះ ក្នុងគោលបំណងធ្វើអាជីវកម្ម ធនាគារ ក្រុមហ៊ុនធានារ៉ាប់រង និងក្រុមហ៊ុនឥណទានបានឡើយ ។

**មាត្រា ៨៦.–**

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតគឺជាទម្រង់ទ្រាយមួយនៃក្រុមហ៊ុនមូលធនហើយត្រូវមានលក្ខណៈសម្គាល់ដូចតទៅ :

ក-ក្រុមហ៊ុនអាចមានសមាជិកភាគហ៊ុនពី ០២(ពីរ)នាក់ រហូតដល់៣០(សាមសិប)នាក់ ។ ប៉ុន្តែបុគ្គលម្នាក់ក៏អាចបង្កើតក្រុមហ៊ុនបានដែរ ដែលមានឈ្មោះថាសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ។ សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត មានលក្ខខណ្ឌដូចគ្នាទៅនឹងលក្ខខណ្ឌទាំងឡាយរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតដែរ លើកលែងតែលក្ខខណ្ឌស្ដីពីទំនាក់ទំនងរវាងសមាជិកភាគហ៊ុន ។

ខ-ក្រុមហ៊ុននោះមិនអាចអនុញ្ញាតឱ្យលក់ភាគហ៊ុន ឬ មូលបត្រដទៃទៀតជាសាធារណៈបានឡើយ ។ ប៉ុន្តែអាចអនុញ្ញាតឱ្យធ្វើអនុប្បទានទៅសមាជិកភាគហ៊ុន

សមាជិកគ្រួសារ និងអ្នកគ្រប់គ្រងបាន ។ ក្នុងករណីផ្ទេរអនុប្បទានទៅឱ្យតតិយជនត្រូវមានការយល់ព្រមពីសមាជិកភាគហ៊ុនដទៃទៀតតាមសំឡេងភាគច្រើន ។

គ-ក្រុមហ៊ុននោះអាចមានការរឹតត្បិតមួយ ឬ ច្រើនបានទៅលើការផ្ទេរចំណែកនៃប្រភេទភាគហ៊ុនទាំងអស់ ។

ឃ-ក្រុមហ៊ុនត្រូវបានទទួលស្គាល់ថាជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ចាប់ពីពេលដែលបានចុះបញ្ជីពាណិជ្ជកម្មតាមទម្រង់បែបបទជាក់លាក់ដែលកំណត់ដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ។

**មាត្រា ៨៧.-**

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតគឺជាទ្រង់ទ្រាយមួយនៃក្រុមហ៊ុនមូលធនដែលត្រូវបានអនុញ្ញាតដោយច្បាប់នេះ ដើម្បីបោះចេញនូវមូលបត្រដែលអាចលក់ជាសាធារណៈបាន ។

**មាត្រា ៨៨.-**

នៅក្នុងជំពូកនេះ ពាក្យបច្ចេកទេសទាំងឡាយមាននិយមន័យដូចតទៅ :

១-លក្ខន្តិកៈ មានន័យថាលក្ខន្តិកៈដើម ឬ លក្ខន្តិកៈធ្វើការកែប្រែ ។

២-សវនករ មានន័យថាគណនេយ្យករជំនាញម្នាក់ដែលធ្វើកិច្ចការក្នុងលក្ខណៈជាបុគ្គល ឬ ធ្វើកិច្ចការក្នុងក្រុមហ៊ុនគណនេយ្យណាមួយ ។

៣-កាតព្វកិច្ចបំណុលគឺជាសញ្ញាប័ណ្ណ ឬ ជាលិខិតបញ្ជាក់បំណុលផ្សេងៗ ឬ លិខិតស្នាមរបស់ក្រុមហ៊ុនដែលអាចធានា ឬ មិនអាចធានាបាន ។

៤-មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មមានន័យថាមន្ត្រីដែលបានទទួលការតែងតាំងដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មដើម្បីអនុវត្តការងារនៃច្បាប់នេះ ។

៥-អភិបាលមានន័យថាសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ។

៦-ស្ថាបនិកក្រុមហ៊ុនមានន័យថារូបវន្តបុគ្គលដែលចុះហត្ថលេខាលើ

លក្ខន្តិកៈរបស់ក្រុមហ៊ុន ។

៧-សេចក្តីសម្រេចសាមញ្ញមានន័យថាជាសេចក្តីសម្រេចមួយត្រូវបានធ្វើឡើងដោយសំឡេងឆ្នោតភាគច្រើនដាច់ខាត ដែលបានចូលរួមក្នុងការបោះឆ្នោត ។

៨-ភាគហ៊ុនអាចរំលោះបានមានន័យថាជាភាគហ៊ុនដែលត្រូវបានចេញដោយក្រុមហ៊ុនណាមួយ :

-ក្រុមហ៊ុននោះអាចទិញ ឬ រំលោះបានទៅតាមតម្រូវការរបស់ក្រុមហ៊ុន

-ក្រុមហ៊ុននោះត្រូវបានតម្រូវឱ្យដោយលក្ខន្តិកៈរបស់ខ្លួនដើម្បីទិញ ឬរំលោះនៅពេលកំណត់ណាមួយ ឬ ក៏ទៅតាមតម្រូវការរបស់ម្ចាស់ហ៊ុនណាម្នាក់ ។

៩-ស៊េរីនៅក្នុងទំនាក់ទំនងទៅនឹងភាគហ៊ុនមានន័យថាជាការបែងចែកចំណាត់ថ្នាក់ភាគហ៊ុនឱ្យទៅជាប្រភេទភាគហ៊ុននីមួយៗ ។

១០-សេចក្តីសម្រេចពិសេសមានន័យថាជាសេចក្តីសម្រេចមួយត្រូវធ្វើឡើងដោយសំឡេងឆ្នោតភាគច្រើន ២/៣ (ពីរភាគបី) ដែលបានចូលរួមក្នុងការបោះឆ្នោត ឬ ពីការចុះហត្ថលេខារបស់សមាជិកភាគហ៊ុនទាំងឡាយ ដែលមានសិទ្ធិក្នុងការបោះឆ្នោតធ្វើសេចក្តីសម្រេចនោះ ។

១១-មូលបត្រមានន័យថា :

ក-ជាភាគហ៊ុននៅក្នុងស៊េរីនៃភាគហ៊ុនណាមួយ ឬ ជាភាគហ៊ុននៅក្នុងប្រភេទនៃភាគហ៊ុនណាមួយ ។

ខ-សញ្ញាប័ណ្ណ ។

គ-រួមបញ្ចូលទាំងវិញ្ញាបនបត្របញ្ជាក់ដែលផ្តល់ភស្តុតាងអំពីមូលបត្រទាំងឡាយ ។

**មាត្រា ៨៩.-**

ក្រុមហ៊ុនពាណិជ្ជកម្មមួយអាចធ្វើសម្ព័ន្ធភាពជាមួយក្រុមហ៊ុនណាមួយទៀតបាន ប្រសិនបើក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុននោះ ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនផ្សេង ឬ ក្រុមហ៊ុនទាំងពីរជាបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនតែមួយដូចគ្នា ឬ ក្រុមហ៊ុននីមួយៗត្រូវគ្រប់គ្រងដោយបុគ្គលតែមួយរូបដូចគ្នា ។

ប្រសិនបើក្រុមហ៊ុនពាណិជ្ជកម្មពីរ ធ្វើសម្ព័ន្ធភាពជាមួយក្រុមហ៊ុនមួយដូចគ្នា នៅក្នុងពេលតែមួយ ក្រុមហ៊ុនទាំងនោះត្រូវចាត់ទុកថាជាក្រុមហ៊ុនដែលមានទំនាក់ទំនងធ្វើសម្ព័ន្ធភាពជាមួយគ្នា ។

**មាត្រា ៩០.-**

ស្ថាបនិក ឬ អភិបាលម្នាក់ៗជាអ្នកទទួលខុសត្រូវចំពោះការអនុវត្តនូវការចុះបញ្ជីពាណិជ្ជកម្ម ការតម្កល់ទុក និងការផ្សព្វផ្សាយដែលបានតម្រូវដោយច្បាប់ ។

## ផ្នែកទី ២

## ក- ការបង្កើតក្រុមហ៊ុនមូលធន

**មាត្រា ៩១.-**

នីតិបុគ្គល ឬរូបវន្តបុគ្គលមួយ ឬ ច្រើន ដែលមានកាយសម្បទា និងសមត្ថភាពគ្រប់គ្រាន់អាចបង្កើតក្រុមហ៊ុនមូលធនបាន ដោយធ្វើការបំពេញតម្កល់លក្ខន្តិកៈទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។

**មាត្រា ៩២.-**

នាមករណ៍របស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវដាក់នូវពាក្យថា "ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត" ឬ សរសេរអក្សរកាត់ដាក់ខាងចុង ឬខាងក្រោម ។

នាមករណ៍របស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ត្រូវដាក់នូវពាក្យថា "ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត" ឬ សរសេរអក្សរកាត់ដាក់ខាងចុង ឬ ខាងក្រោម ។

មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវពិនិត្យនូវនាម-ករណ៍ ដែលបានស្នើសុំដោយក្រុមហ៊ុននោះ ហើយអាចបដិសេធនូវនាមករណ៍ណាដែលប្រហាក់ប្រហែលគ្នាធ្វើឱ្យមានការភាន់ច្រឡំទៅនឹងនាមករណ៍របស់ក្រុមហ៊ុនផ្សេងទៀត ដែលបានចុះបញ្ជីពាណិជ្ជកម្មមុនរួចហើយ ឬ នាមករណ៍មួយដែលផ្ទុយទៅនឹងសណ្តាប់ធ្នាប់សាធារណៈដែលមានឈ្មោះអាស្រូវ ឬ ដែលមិនសមរម្យ ។ សេចក្តីសម្រេចរបស់មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មដែលពាក់ព័ន្ធទៅនឹងនាមករណ៍របស់ក្រុមហ៊ុនគឺជាសេចក្តីសម្រេចចុងក្រោយ ។

**មាត្រា ៩៣.-**

លក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវចែងនូវលក្ខខណ្ឌដូចខាងក្រោម :

ក-នាមករណ៍របស់ក្រុមហ៊ុន ។

ខ-ទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

គ-កម្មវត្ថុអាជីវកម្មនៃក្រុមហ៊ុន និងការកំណត់នូវអាជីវកម្មដែលក្រុមហ៊ុននោះធ្វើពាណិជ្ជកិច្ច ។ កម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុនអាចមានមួយ ឬ ច្រើនប្រភេទដែលមិនផ្ទុយទៅនឹងបញ្ញត្តិណាមួយនៃច្បាប់ ។

ឃ-ដើមទុនត្រូវប្រកាសជារូបិយវត្ថុជាតិ ។

ង-ចំណាត់ប្រភេទ និងចំនួនអតិបរមានៃភាគហ៊ុនព្រមទាំងតម្លៃចារឹកលើប័ណ្ណភាគហ៊ុនដែលត្រូវបានអនុញ្ញាតឱ្យបោះចេញដោយក្រុមហ៊ុននោះ ។

ច-ក្នុងករណីក្រុមហ៊ុនត្រូវអនុញ្ញាតឱ្យបោះប័ណ្ណភាគហ៊ុនលើសពីមួយប្រភេទហ៊ុននោះ លក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវចែងចំនួនភាគហ៊ុនអតិបរមា និងតម្លៃចារឹកលើប័ណ្ណភាគហ៊ុន ហើយត្រូវរៀបរាប់ពីសិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌទាំងឡាយដែលភ្ជាប់ទៅនឹងប្រភេទនីមួយៗនៃប័ណ្ណភាគហ៊ុននោះ ។

ឆ-ក្នុងករណីប្រភេទភាគហ៊ុនត្រូវបោះជាស៊េរី លក្ខន្តិកៈក្រុមហ៊ុននោះត្រូវអនុញ្ញាតឱ្យអភិបាលកំណត់ចំនួនភាគហ៊ុននៃស៊េរីនីមួយៗ ដើម្បីកំណត់ឬបែងចែកស៊េរីនីមួយៗ ហើយឈានទៅកំណត់សិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌដែលភ្ជាប់ទៅនឹងស៊េរីនីមួយៗនោះ ។

ជ-ក្នុងករណីការបោះចេញ ការផ្ទេរ ឬ ការកាន់កាប់ប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនត្រូវហាមឃាត់ ពេលនោះត្រូវមានរបាយការណ៍ពីប្រសិទ្ធភាព និងមានរបាយការណ៍ពីការកម្រិតនោះ ។

ឈ-ឈ្មោះនិងអាសយដ្ឋានពិតប្រាកដរបស់សមាជិកក្រុមហ៊ុនម្នាក់ៗ ។

ញ- ចំនួនអភិបាល ឬ ចំនួនអប្បបរមា និងអតិបរមានៃអភិបាលរបស់ក្រុមហ៊ុននោះ ។

**មាត្រា ៩៤.-**

លក្ខន្តិកៈត្រូវរួមបញ្ចូលផងដែរ នូវរាល់ចំណុចផ្សេងទៀតតាមការចាំបាច់ ។

**មាត្រា ៩៥.-**

លក្ខន្តិកៈអាចធ្វើឡើងតាមរូបភាពជាលិខិតរវាងឯកជន ឬ ជាលិខិតសារការី ។ គ្រប់ទំព័រនៃលក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវចុះហត្ថលេខា ឬ ហត្ថលេខាសង្ខេបដោយសមាជិកទាំងអស់របស់ក្រុមហ៊ុននោះ ។

**មាត្រា ៩៦.-**

ស្ថាបនិកក្រុមហ៊ុន ត្រូវស្នើសុំទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ដើម្បីធ្វើការតម្កល់លក្ខន្តិកៈនោះជាមួយឯកសារសុំចុះបញ្ជីពាណិជ្ជកម្មផ្សេងទៀត ។

**មាត្រា ៩៧.-**

ក្រោយពីការយល់ព្រមតម្កល់នូវលក្ខន្តិកៈរបស់ក្រុមហ៊ុន និងក្រោយពីបានទទួលសោហ៊ុយនៃការតម្កល់នោះ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មត្រូវចេញនូវលិខិតបញ្ជាក់មួយជាសម្គាល់ ។

**មាត្រា ៩៨.-**

ក្រុមហ៊ុនទទួលបាននីតិបុគ្គលិកលក្ខណៈ ចាប់ពីកាលបរិច្ឆេទដែលបានចុះក្នុងបញ្ជីពាណិជ្ជកម្ម ។

## ខ- សមត្ថភាព និងសិទ្ធិរបស់ក្រុមហ៊ុន

**មាត្រា ៩៩.-**

ក្រុមហ៊ុនដែលបានបង្កើតឡើងតាមច្បាប់នេះមានសមត្ថភាព សិទ្ធិ និងបុព្វសិទ្ធិដូចរូបវន្តបុគ្គលដែរ ។

ក្រុមហ៊ុនអាចប្រកបពាណិជ្ជកិច្ចទូទាំងព្រះរាជាណាចក្រកម្ពុជាបាន ។

**មាត្រា ១០០.-**

ក្រុមហ៊ុនអាចប្រកបពាណិជ្ជកិច្ចរបស់ខ្លួនធ្វើកិច្ចការរបស់ខ្លួន និងអនុវត្តសិទ្ធិរបស់ខ្លួន នៅក្នុងដែនសមត្ថកិច្ចនៃប្រទេសណាមួយ ក្រៅពីព្រះរាជាណាចក្រកម្ពុជាបាន លុះត្រាតែច្បាប់នៃប្រទេសនោះបានអនុញ្ញាត ។

**មាត្រា ១០១.-**

ក្រុមហ៊ុនត្រូវបានចាត់ទុកជាក្រុមហ៊ុនមានសញ្ជាតិខ្មែរ លុះត្រាតែ :

ក-ក្រុមហ៊ុនមានទីកន្លែងធ្វើអាជីវកម្ម និងទីស្នាក់ការចុះបញ្ជីស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ខ-ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុនចាប់ពី ៥១ (ហាសិបមួយ) ភាគរយ ត្រូវបានកាន់កាប់ដោយរូបវន្តបុគ្គល ឬ នីតិបុគ្គលសញ្ជាតិខ្មែរ ។

**មាត្រា ១០២.-**

ក្រុមហ៊ុនមួយអាចរៀបចំបទបញ្ជាផ្ទៃក្នុងផ្ទាល់ ដើម្បីសម្រួលដល់កិច្ចការអាជីវកម្មរបស់ក្រុមហ៊ុន ។

មិនចាំបាច់មានបទបញ្ជាផ្ទៃក្នុងមួយ ដែលធ្វើឡើងក្នុងគោលបំណងដើម្បីបញ្ជាក់អំពីសិទ្ធិពិសេសណាមួយទៅលើក្រុមហ៊ុន និងអភិបាលក្រុមហ៊ុន ។

**មាត្រា ១០៣.-**

ក្រុមហ៊ុនមិនត្រូវប្រកបពាណិជ្ជកិច្ចណាមួយ ឬ អនុវត្តសិទ្ធិណាមួយ ដែលលក្ខន្តិកៈរបស់ខ្លួនបានហាមឃាត់ ឬ មិនត្រូវអនុវត្តសិទ្ធិណាមួយដែលផ្ទុយពីលក្ខន្តិកៈរបស់ខ្លួនឡើយ ។

**មាត្រា ១០៤.-**

ប្រការដែលក្រុមហ៊ុនបានប្រព្រឹត្តរំលោភលើលក្ខន្តិកៈរបស់ខ្លួន មិននាំឱ្យមានមោឃភាពដល់ការប្រព្រឹត្តនោះឡើយ ។ វិធាននេះអនុវត្តចំពោះគ្រប់ការប្រព្រឹត្ត រួមមានការផ្ទេរទ្រព្យសម្បត្តិទៅឱ្យក្រុមហ៊ុន ឬ ការផ្ទេរទ្រព្យសម្បត្តិពីក្រុមហ៊ុន ។

**មាត្រា ១០៥.-**

ប្រការដែលមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មតម្កល់ទុកឯកសាររបស់ក្រុមហ៊ុន ឬ ប្រការដែលឯកសារសម្រាប់ធ្វើអធិការកិច្ច ដែលថតចម្លងទុកនៅក្នុងការិយាល័យក្រុមហ៊ុនមិនត្រូវបានចាត់ទុកថាធ្វើឱ្យប៉ះពាល់ទៅលើបុគ្គលណាមួយ ឬ ជាការជូនដំណឹងដល់បុគ្គលណាមួយឡើយ ។

**មាត្រា ១០៦.-**

ក្រុមហ៊ុន ឬ បុគ្គលម្នាក់ដែលធានាកាតព្វកិច្ចមួយរបស់ក្រុមហ៊ុននោះមិនអាចយកចំណុចទាំងឡាយដូចខាងក្រោមជាលេសដើម្បីជៀសវាងពីកាតព្វកិច្ចចំពោះតតិយជនដែលពាក់ព័ន្ធជាមួយក្រុមហ៊ុននោះ ឬតតិយជនដែលទទួលសិទ្ធិពីក្រុមហ៊ុនបាន

ឡើយ ។ ប៉ុន្តែចំណុចទាំងឡាយនេះអាចត្រូវជៀសវាងបាន ប្រសិនបើតតិយជននោះបានស្គាល់ ឬ បានដឹងនូវចំណុចទាំងនោះដោយសារតួនាទីរបស់ខ្លួន ឬ ដោយសារទំនាក់ទំនងរបស់ខ្លួននៅក្នុងក្រុមហ៊ុននោះ :

ក-លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនមិនត្រូវបានអនុវត្តតាម ។

ខ-បុគ្គលដែលបានដាក់ឈ្មោះជាអភិបាលនៅក្នុងលិខិតជូនដំណឹងក្រោយគេបំផុត ដែលបានបញ្ជូនទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម មិនមែនជាអភិបាលរបស់ក្រុមហ៊ុនទេ ។

គ- ទីកន្លែងដែលបានដាក់ជាទីស្នាក់ការចុះបញ្ជីនៅក្នុងលិខិតជូនដំណឹងក្រោយគេបំផុត ដែលបានបញ្ជូនទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មមិនមែនជាទីស្នាក់ការចុះបញ្ជីពិតប្រាកដរបស់ក្រុមហ៊ុននោះទេ ។

ឃ-បុគ្គលដែលជាអភិបាល បុគ្គលិក ឬ ភ្នាក់ងាររបស់ក្រុមហ៊ុនមិនត្រូវបានតែងតាំង ឬ មិនត្រូវបានប្រគល់សិទ្ធិឱ្យអនុវត្ត និងប្រតិបត្តិភារកិច្ចដែលជាទម្លាប់ធ្វើពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន ។

ង-ឯកសារដែលបានចេញឱ្យដោយអភិបាល អ្នកគ្រប់គ្រង ឬ ភ្នាក់ងារណាម្នាក់របស់ក្រុមហ៊ុនមិនមានសុពលភាព ឬ មិនយកជាការបានឡើយ ។

ច-ប្រាក់ខ្ចី និង ការធានា ឬ ការលក់ ការជួល ឬការដោះដូរទ្រព្យសម្បត្តិមិនត្រូវបានអនុញ្ញាតឱ្យទេ ។

## គ_ ទីស្នាក់ការចុះបញ្ជី សៀវភៅបញ្ជី និង កំណត់ហេតុ

**មាត្រា ១០៧.-**

នៅគ្រប់ពេលវេលា ក្រុមហ៊ុនត្រូវមានទីស្នាក់ការចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជាដូចដែលបានបញ្ជាក់នៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

**មាត្រា ១០៨.-**

ក្រុមហ៊ុនត្រូវផ្តល់ឱ្យទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មនូវសេចក្តីជូនដំណឹងអំពីទីតាំង ទីស្នាក់ការចុះបញ្ជីជាមួយគ្នា និងលក្ខន្តិកៈដែលស្តីពីទីតាំង ឬ ពីការផ្លាស់ប្តូរទីតាំងស្នាក់ការចុះបញ្ជីនោះ ។

លិខិតជូនដំណឹងអំពីការផ្លាស់ប្តូរទីតាំងរបស់ទីស្នាក់ការចុះបញ្ជី ត្រូវផ្ញើទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មក្នុងរយៈពេល ១៥(ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីមានការផ្លាស់ប្តូរនោះ ។

**មាត្រា ១០៩.-**

ក្រុមហ៊ុនត្រូវរៀបចំនិងរក្សាទុកនៅក្នុងទីស្នាក់ការចុះបញ្ជីរបស់ខ្លួននូវ :

ក-លក្ខន្តិកៈ និងគ្រប់ការកែប្រែទាំងអស់ ។

ខ-កំណត់ហេតុអង្គប្រជុំ និងសេចក្តីសម្រេចទាំងឡាយរបស់ម្ចាស់ហ៊ុន ។

គ-ឯកសារនៃសេចក្តីជូនដំណឹងតម្រូវឱ្យផ្ញើ ឬ តម្កល់ទុកជាឯកសារ ។

ឃ-បញ្ជីមូលបត្រ ។

**មាត្រា ១១០.-**

ម្ចាស់ហ៊ុន និងម្ចាស់បំណុលរបស់ក្រុមហ៊ុន ភ្នាក់ងារ និងអ្នកតំណាងស្របច្បាប់របស់ខ្លួនព្រមទាំងមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មអាចពិនិត្យគ្រប់ឯកសារដូចដែលបានចែង នៅក្នុងអំឡុងពេលម៉ោងធ្វើអាជីវកម្មធម្មតារបស់ក្រុមហ៊ុននិងអាចធ្វើសម្រង់បានដោយមិនគិតកម្រៃ ។

ប្រសិនបើក្រុមហ៊ុន ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត បុគ្គលណាក៏ដោយក៏អាចធ្វើសម្រង់លើគ្រប់ឯកសារនោះបានដោយបង់ថ្លៃឈ្នួលសមស្រប ។

**មាត្រា ១១១.-**

រាល់បញ្ជីឈ្មោះម្ចាស់ហ៊ុន មិនត្រូវបានប្រើដោយបុគ្គលណាម្នាក់ឡើយ លើកលែងតែបុគ្គលនោះមានការពាក់ព័ន្ធជាមួយ :

ក-ការខិតខំប្រឹងប្រែងដើម្បីរកសំឡេងគាំទ្រក្នុងការបោះឆ្នោតពីម្ចាស់ហ៊ុនរបស់ក្រុមហ៊ុន ។

ខ-ការផ្តល់សំណើទិញភាគហ៊ុនរបស់ក្រុមហ៊ុន ។

គ-អ្វីផ្សេងៗទៀត ដែលទាក់ទងទៅនឹងការងាររបស់ក្រុមហ៊ុន ។

**មាត្រា ១១២.-**

ក្រុមហ៊ុនត្រូវរៀបចំ និងរក្សាទុកនូវកំណត់ហេតុរបស់ក្រុមប្រឹក្សាភិបាលទាំងឡាយ និងសេចក្តីសម្រេចរបស់គណៈកម្មាធិការអភិបាលឱ្យបានសព្វគ្រប់ ។

កំណត់ហេតុប្រជុំរបស់ក្រុមប្រឹក្សាភិបាល ត្រូវរក្សាទុកនៅក្នុងទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន ឬ នៅកន្លែងដទៃទៀត ដែលអភិបាលយល់ឃើញថាសមស្របហើយ ឯកសារទាំងនោះត្រូវបានបើកចំហ ដើម្បីឱ្យអភិបាលធ្វើការពិនិត្យបានគ្រប់ពេល ។

**មាត្រា ១១៣.-**

ក្រុមហ៊ុនត្រូវរៀបចំ និងរក្សាទុកនូវបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់សម្រាប់រយៈពេល ១០(ដប់)ឆ្នាំ បន្ទាប់ពីបញ្ចប់ឆ្នាំសារពើពន្ធ ។

ប្រសិនបើបញ្ជីគណនេយ្យត្រូវរក្សាទុកនៅក្រៅព្រះរាជាណាចក្រកម្ពុជា ឯកសារច្បាប់ចម្លងនៃបញ្ជីគណនេយ្យនោះ ក៏ត្រូវបានរក្សាទុកនៅក្នុងទីស្នាក់ការចុះបញ្ជីផងដែរ ។

**មាត្រា ១១៤.-**

ក្រុមហ៊ុន និងភ្នាក់ងាររបស់ក្រុមហ៊ុនត្រូវរក្សាការពារទុកសៀវភៅបញ្ជី និងកំណត់ហេតុរបស់ក្រុមហ៊ុនដោយប្រុងប្រយ័ត្នឱ្យបានទៀងទាត់ និងការពារឱ្យបានត្រឹមត្រូវ ។

**មាត្រា ១១៥.–**

លិខិតស្នាម ឬ កិច្ចសន្យា ដែលបានធ្វើក្នុងនាមក្រុមហ៊ុនដោយអភិបាលម្នាក់ ឬ អ្នកគ្រប់គ្រងម្នាក់ ឬ ភ្នាក់ងារម្នាក់របស់ក្រុមហ៊ុនមានសុពលភាព ទោះបីជាគ្មានត្រាសម្គាល់របស់ក្រុមហ៊ុនបោះភ្ជាប់ទៅលើឯកសារទាំងនោះក៏ដោយ ។

## ឃ.– អភិបាល និង អ្នកគ្រប់គ្រងក្រុមហ៊ុន

**មាត្រា ១១៦.–**

នៅពេលតម្កល់ទុកឯកសារ និងលក្ខន្តិកៈការបង្កើតក្រុមហ៊ុនពាណិជ្ជកម្ម ស្ថាបនិកទាំងឡាយត្រូវផ្តល់ទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មនូវលិខិតជូនដំណឹងរបស់អភិបាល ទៅតាមបែបបទដែលបានកំណត់ដោយក្រសួងពាណិជ្ជកម្ម ។

ក្រោយពីចេញវិញ្ញាបនបត្របញ្ជាក់ពីការបង្កើតក្រុមហ៊ុន ស្ថាបនិកម្នាក់ ឬ អភិបាលម្នាក់អាចកោះប្រជុំក្រុមប្រឹក្សាភិបាលបានដោយផ្តល់ការជូនដំណឹងយ៉ាងតិច ០៥ (ប្រាំ)ថ្ងៃ តាមរយៈលិខិតទៅគ្រប់អភិបាល ។ លិខិតជូនដំណឹងនោះ មានបញ្ជាក់ពីពេលវេលា និងទីកន្លែងប្រជុំផង ។

អភិបាលដំបូងត្រូវកាន់តំណែង ចាប់ពីកាលបរិច្ឆេទនៃការបង្កើតក្រុមហ៊ុនរហូតដល់មានមហាសន្និបាតម្ចាស់ហ៊ុនលើកទីមួយ ។

**មាត្រា ១១៧.–**

ក្រុមប្រឹក្សាភិបាលដំបូងទាំងឡាយ ត្រូវចាត់ចែងមហាសន្និបាតលើកទី ១ របស់ម្ចាស់ហ៊ុនក្នុងអំឡុងពេល ០១ (មួយ) ឆ្នាំ បន្ទាប់ពីក្រុមហ៊ុនបានបង្កើតឡើង ។ លិខិតជូនដំណឹងពីមហាសន្និបាតនោះ ត្រូវចែកយ៉ាងហោចណាស់ ២០ (ម្ភៃ)ថ្ងៃ មុនទៅបុគ្គលដែលមានសិទ្ធិចូលរួមមហាសន្និបាតនោះ ។ លិខិតជូនដំណឹងត្រូវបញ្ជាក់អំពីកាលបរិច្ឆេទទីកន្លែង និងរបៀបវារៈនៃមហាសន្និបាតនោះ ។

**មាត្រា ១១៨.-**

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវមានអភិបាលម្នាក់ ឬ ច្រើននាក់ ។

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវមានអភិបាលយ៉ាងតិច ០៣(បី) នាក់ ។

ម្ចាស់ហ៊ុន ត្រូវបោះឆ្នោតជ្រើសរើសអភិបាល តាមរយៈសេចក្តីសម្រេចសាមញ្ញនៃម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោត ។

**មាត្រា ១១៩.-**

ក្រុមប្រឹក្សាភិបាលត្រូវចាត់ចែងអាជីវកម្ម និងការងាររបស់ក្រុមហ៊ុន ។ លក្ខន្តិកៈក្រុមហ៊ុនត្រូវចែងពីសិទ្ធិរបស់អភិបាលដែលមានជាអាទិ៍ :

១-តែងតាំង និងដកហូតអ្នកគ្រប់គ្រងទាំងអស់ និងកំណត់នូវសិទ្ធិច្បាស់លាស់សម្រាប់អ្នកគ្រប់គ្រងទាំងនោះ ។

២-កំណត់ប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗដល់អ្នកគ្រប់គ្រងទាំងនោះ ។

៣-កម្រិតប្រាក់បៀវត្ស ឬ ប្រាក់បំណាច់ផ្សេងៗ សម្រាប់អភិបាលទាំងឡាយ ហើយដាក់ជូនទៅម្ចាស់ហ៊ុនដើម្បីសុំសេចក្តីសម្រេច ។

៤-ចេញប័ណ្ណកំណត់សន្យា សញ្ញាប័ណ្ណ និងលិខិតស្នាម ដែលបញ្ជាក់ថាមានបំណុល និងតឹកតាងផ្សេងៗនៃបំណុលរបស់ក្រុមហ៊ុន និងកំណត់នូវលក្ខណៈដាច់ខាត និងលក្ខណៈផ្សេងៗរបស់លិខិតស្នាមទាំងឡាយនោះ ។

៥-ស្នើសុំម្ចាស់ហ៊ុន ដើម្បីធ្វើការកែប្រែលក្ខន្តិកៈ ឬ លុបចោលលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

៦-ស្នើសុំម្ចាស់ហ៊ុននូវកិច្ចសន្យារំលាយចូលគ្នា ឬ រួមបញ្ចូលគ្នារវាងក្រុមហ៊ុន និងបុគ្គលផ្សេងណាមួយ ។

៧-ស្នើសុំម្ចាស់ហ៊ុនដើម្បីលក់ទ្រព្យសម្បត្តិក្រុមហ៊ុនទាំងអស់ឬមួយភាគ ។

៨-ស្នើសុំម្ចាស់ហ៊ុនដើម្បីរំលាយ ឬ ជម្រះបញ្ជីក្រុមហ៊ុន ។

៩-ប្រកាសភាគលាភទៅតាមគោលការណ៍គណនេយ្យ និងតាមលក្ខខណ្ឌនៃការដាក់ភាគហ៊ុន ប្រភេទនីមួយៗដែលមានសិទ្ធិទទួលភាគលាភ ។

១០-ចេញប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនទៅតាមវិសាលភាព ដែលបានចែងនៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

១១-ខ្ចីប្រាក់ ។

១២- បោះចេញ បោះចេញសាជាថ្មី ឬ លក់មូលបត្ររបស់ក្រុមហ៊ុន ។

១៣-ចុះកិច្ចសន្យាធានា ក្នុងនាមក្រុមហ៊ុន ។

១៤-ធ្វើអ៊ីប៉ូតែក ចុះកិច្ចសន្យាបញ្ចាំ បើមិនដូច្នេះទេបង្កើតផលប្រយោជន៍ពីមូលបត្រចំពោះទ្រព្យសម្បត្តិទាំងអស់ ឬ ទ្រព្យសម្បត្តិណាមួយរបស់ក្រុមហ៊ុនដើម្បីធ្វើការធានាកាតព្វកិច្ចណាមួយរបស់ក្រុមហ៊ុន ។

១៥-រៀបចំការបិទបញ្ជីគណនេយ្យនៃកាលបរិច្ឆេទនីមួយៗជូនម្ចាស់ហ៊ុន និងស្នើចាត់ចែងលទ្ធផលប្រចាំឆ្នាំដាក់ជូនមហាសន្និបាតនៃម្ចាស់ហ៊ុន ។

**មាត្រា ១២០.-**

រាល់រូបវន្តបុគ្គល ដែលមានសមត្ថភាពមានអាយុលើសពី ១៨ (ដប់ប្រាំបី)ឆ្នាំ អាចបម្រើការងារជាអភិបាល ឬ ជាអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនបាន ។ អភិបាលមិនចាំបាច់ជាម្ចាស់ហ៊ុនទេ ឬ មិនចាំបាច់តម្រូវឱ្យមានលក្ខណសម្បត្តិណាផ្សេងទៀតទេ លើកលែងតែលក្ខន្តិកៈរបស់ក្រុមហ៊ុនតម្រូវឱ្យមានលក្ខខណ្ឌតម្រូវ ។

**មាត្រា ១២១.-**

ក្នុងករណីលក្ខន្តិកៈក្រុមហ៊ុនមិនចែងអំពីអាណត្តិទេ អភិបាលម្នាក់ៗត្រូវមានអាណត្តិ ០២(ពីរ)ឆ្នាំ ហើយអាចត្រូវបោះឆ្នោតឱ្យសាជាថ្មីទៀតបាន ។

**មាត្រា ១២២.-**

អាណត្តិរបស់អភិបាល អាចត្រូវកំណត់ជាតំណាក់ៗ តែអាណត្តិរបស់អភិបាលទាំងឡាយមិនអាចបញ្ចប់ក្នុងឆ្នាំជាមួយគ្នាបានឡើយ ។

**មាត្រា ១២៣.-**

លក្ខន្តិកៈរបស់ក្រុមហ៊ុនអាចចែងបានផងដែរពីសិទ្ធិរបស់អ្នកកាន់ប័ណ្ណភាគហ៊ុននៃប្រភេទនីមួយៗ ដើម្បីបោះឆ្នោតជ្រើសរើសអភិបាលមួយ ឬ ច្រើន ដែលអភិបាលនោះបម្រើអាណត្តិ និងមានសិទ្ធិចាត់ចែងការងារផ្សេងៗ ដែលបានចែងក្នុងលក្ខន្តិកៈ ។ អាណត្តិនៃមុខតំណែង និង សិទ្ធិនៃការបោះឆ្នោតរបស់អភិបាលប្រភេទមួយអាចច្រើនជាង ឬ តិចជាងអភិបាលប្រភេទមួយផ្សេងទៀតបាន ។

**មាត្រា ១២៤.-**

អភិបាលអាចត្រូវដកហូតចេញពីមុខតំណែងបានដោយសំឡេងភាគច្រើនដាច់ខាតនៃម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោត ទោះជាមាន ឬគ្មានមូលហេតុក៏ដោយ ។

**មាត្រា ១២៥.-**

អភិបាលអាចលាលែងពីមុខតំណែងនៅពេលណាក៏បានដោយជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រុមហ៊ុន ។ ការលាលែងពីមុខតំណែងនេះ ត្រូវមានសុពលភាពភ្លាម ឬ មានប្រសិទ្ធភាពចាប់ពីពេលដែលបានចែងនៅក្នុងលិខិតជូនដំណឹងនោះ ។

អភិបាលម្នាក់ ដែលជាអភិបាលនៅសល់ចុងក្រោយក្នុងក្រុមហ៊ុន ហើយអភិបាលនោះធ្វើការលាលែងមុនពេលអភិបាលផ្សេងត្រូវបានតែងតាំង ត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលបានបង្កឡើងដល់ក្រុមហ៊ុនដោយសារការលាលែងរបស់ខ្លួន ។

**មាត្រា ១២៦.-**

បន្ទាប់ពីអាណត្តិរបស់ខ្លួនបានផុតកំណត់ អភិបាលត្រូវបន្តបម្រើការងាររបស់ខ្លួនរហូតដល់មានការបោះឆ្នោតជ្រើសតាំងជំនួសជាថ្មី ។

**មាត្រា ១២៧.-**

ក្រុមប្រឹក្សាភិបាល ត្រូវបោះឆ្នោតជ្រើសតាំងប្រធានពីក្នុងចំណោមសមាជិករបស់ខ្លួន ។ ប្រធានក្រុមប្រឹក្សាភិបាលអាចត្រូវដកហូតពីមុខតំណែងដោយសំឡេងភាគច្រើនដាច់ខាតរបស់អភិបាលទាំងឡាយ ប៉ុន្តែមិនត្រូវបានដកហូតពីឋានៈអភិបាលឡើយ ។

**មាត្រា ១២៨.-**

ប្រធានក្រុមប្រឹក្សាភិបាលមានសិទ្ធិអញ្ជើញអភិបាលប្រជុំ ។ មួយភាគបីនៃសមាជិកក្រុមប្រឹក្សាភិបាលដែលបម្រើការងារក៏អាចអញ្ជើញក្រុមប្រឹក្សាភិបាលប្រជុំបានដែរ ។

កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ត្រូវធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែលក្ខន្តិកៈរបស់ក្រុមហ៊ុនចែងផ្សេងពីនេះ ។

ក្រុមប្រឹក្សាភិបាលត្រូវរួមប្រជុំយ៉ាងតិចមួយដងក្នុងរៀងរាល់បីខែ ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលដែលយកជាបានការ លុះត្រាតែមានសំឡេងភាគច្រើនដោយប្រៀបរបស់សមាជិក ឬ តំណាងដែលមានវត្តមាន ។

**មាត្រា ១២៩.-**

ក្រុមប្រឹក្សាភិបាលអាចជួបប្រជុំនៅកន្លែងណាមួយទៅតាមលិខិតជូនដំណឹង ។ លិខិតជូនដំណឹងត្រូវបញ្ជាក់ផងដែរពីកាលបរិច្ឆេទ និងរបៀបវារៈពិស្តារ ។

អភិបាលអាចអនុគ្រោះដល់ការខ្វះខាតពីការមិនបានទទួលលិខិតជូនដំណឹងពីការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ។ ប៉ុន្តែនៅពេលចូលរួមប្រជុំ អភិបាលនោះអាចធ្វើការជំទាស់ទៅនឹងពាណិជ្ជកិច្ចណាមួយបាន ដោយសំអាងថាការប្រជុំនោះមិនបានកោះហៅត្រឹមត្រូវតាមច្បាប់កំណត់ ។

**មាត្រា ១៣០.-**

អភិបាលអាចធ្វើសកម្មភាពបានតាមរយៈការទាក់ទងគ្នាជាលិខិត លើកលែងតែលក្ខន្តិកៈចែងផ្សេង ។

រាល់អភិបាលត្រូវទទួលសំណុំរឿងនៃសេចក្ដីសម្រេចដែលត្រូវស្នើសុំការពិនិត្យ និងការសម្រេចគាំទ្រ ឬ មិនគាំទ្រ ព្រមទាំងសន្លឹកឆ្នោតសម្រាប់បោះ "ព្រម" ឬ "មិនព្រម" ចំពោះប្រធានបទនោះ ។

ក្នុងករណីដែលអភិបាលទាំងអស់ បោះឆ្នោតអនុម័តលើប្រធានបទមួយ ប្រធានបទនោះត្រូវចាត់ទុកថាមានការអនុម័តដោយក្រុមប្រឹក្សាភិបាល ។

ការឆ្លើយតបជាលិខិតត្រូវចូលជាផ្នែកមួយនៃកំណត់ហេតុរបស់ក្រុមប្រឹក្សាភិបាល ។ លេខាធិការរបស់ក្រុមហ៊ុន ត្រូវរៀបចំរបាយការណ៍ជាលាយលក្ខណ៍អក្សរពីការប្រាស្រ័យទាក់ទងគ្នាជាលិខិតនោះ និងត្រូវចែករបាយការណ៍នេះទៅអភិបាលទាំងអស់ ។

**មាត្រា ១៣១.–**

ដើម្បីសម្រួលការងាររបស់ខ្លួនក្រុមប្រឹក្សាភិបាល អាចបង្កើតគណៈកម្មាធិការផ្សេងៗបានតាមការចាំបាច់ ។ គណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល អាចត្រូវបង្កើតឡើងដោយសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរនៃសំឡេងភាគច្រើនដាច់ខាតរបស់ក្រុមប្រឹក្សាភិបាល ។ គណៈកម្មាធិការនីមួយៗត្រូវមានអភិបាលមួយរូប ឬ ច្រើនរូបដែលត្រូវតែងតាំងដោយសំឡេងភាគច្រើនដាច់ខាតរបស់ក្រុមប្រឹក្សាភិបាល ។ គណៈកម្មាធិការត្រូវអនុវត្តកិច្ចប្រជុំរបស់ខ្លួនតាមវិធីដូចគ្នានឹងក្រុមប្រឹក្សាភិបាលដែរ ។ គណៈកម្មាធិការនីមួយៗ ត្រូវមានសិទ្ធិដែលបានផ្ដល់ឱ្យដោយឯកសារជាលាយលក្ខណ៍អក្សរដែលបានបង្កើតគណៈកម្មាធិការនោះ ។ ប៉ុន្តែគណៈកម្មាធិការមួយមិនអាចត្រូវបានគេផ្ទេរអំណាចណាមួយដើម្បីធ្វើសកម្មភាពដូចតទៅនេះទេ :

ក-ស្នើសុំទៅម្ចាស់ហ៊ុនដើម្បីធ្វើការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

ខ-ស្នើសុំទៅម្ចាស់ហ៊ុនធ្វើកិច្ចសន្យារំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬ ការរួមបញ្ចូលគ្នារវាងក្រុមហ៊ុន និងបុគ្គលណាមួយផ្សេង ។

គ-ស្នើសុំទៅម្ចាស់ហ៊ុនធ្វើការលក់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនមួយភាគ ឬទាំងអស់ ។

ឃ-ស្នើសុំទៅម្ចាស់ហ៊ុនដើម្បីធ្វើការរំលាយ ឬ ជម្រះបញ្ជីក្រុមហ៊ុន ។

ង-ប្រកាសភាគលាភ ។

ច-បោះចេញនូវប័ណ្ណភាគហ៊ុននៅក្នុងក្រុមហ៊ុន ។

**មាត្រា ១៣២.-**

ចំនួនភាគច្រើននៃអភិបាលទាំងអស់ ដែលមានវត្តមាននៅក្នុងពេលប្រជុំបង្កើតបានជាកូរ៉ុមរបស់ក្រុមប្រឹក្សាភិបាល ឬរបស់គណៈកម្មាធិការក្រុមប្រឹក្សាភិបាលនោះ ប៉ុន្តែលក្ខន្តិកៈរបស់ក្រុមហ៊ុនអាចតម្រូវឱ្យកូរ៉ុមមានចំនួនច្រើនជាងនេះបាន ។

អភិបាលម្នាក់ ត្រូវមានសំឡេងឆ្នោតតែមួយ ។ អភិបាលអាចធ្វើជាអាណត្តិគាហកៈឱ្យអភិបាលមួយរូបផ្សេងទៀតបាន នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលដោយមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរ ដែលបានចុះហត្ថលេខាដោយអភិបាលដែលខ្លួនធ្វើតំណាងឱ្យ ។

លេខាធិការត្រូវរៀបចំ និងរក្សាទុកនូវកំណត់ហេតុនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាភិបាល ហើយត្រូវផ្ញើឯកសារថតចម្លងនៃកំណត់ហេតុនេះ ទៅឱ្យអភិបាលទាំងអស់ ។

**មាត្រា ១៣៣.-**

ក្រុមហ៊ុនអាចចេញសងការចំណាយដល់អភិបាលបច្ចុប្បន្ន ឬអភិបាលពីមុន អ្នកគ្រប់គ្រង ឬ បុគ្គលិករបស់ក្រុមហ៊ុនក្នុងការបំពេញភារកិច្ចដែលបានអនុវត្តដោយស្មោះត្រង់ និងសមហេតុសមផល ។

ការចេញសងត្រូវធ្វើឡើងនៅពេលដែលអភិបាល អ្នកគ្រប់គ្រង ឬ បុគ្គលិកបានសំអាងក្នុងឆន្ទៈល្អនៅលើកំណត់ហេតុ ឬ សៀវភៅបញ្ជី ដែលមានភាពត្រឹមត្រូវរបស់ក្រុមហ៊ុន ឬ នៅលើព័ត៌មានមតិយោបល់របាយការណ៍ផ្សេងៗ ឬ របាយការណ៍ ដែលបង្ហាញដោយអ្នកគ្រប់គ្រងណាម្នាក់របស់ក្រុមហ៊ុននោះ ឬ ជនណាម្នាក់ផ្សេងអំពីបុគ្គលទាំងនោះ ។

ការចេញសងត្រូវបានអនុវត្តចំពោះតែការចំណាយ ឬ ការខូចខាតសមហេតុសមផលដែលទទួលរងដោយអភិបាល អ្នកគ្រប់គ្រង ឬ បុគ្គលិកនៅពេលបម្រើការងារឱ្យក្រុមហ៊ុនប៉ុណ្ណោះ ។

**មាត្រា ១៣៤.-**

អភិបាល ឬ អ្នកគ្រប់គ្រងក្រុមហ៊ុន ត្រូវបង្ហាញនូវទំហំផលប្រយោជន៍របស់ខ្លួនជាលាយលក្ខណ៍អក្សរទៅឱ្យក្រុមហ៊ុន ឬ ស្នើឱ្យមានសេចក្តីប្រកាសដែលបានដាក់ចូលទៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលក្នុងករណី :

ក-ដែលខ្លួនជាភាគីនៃកិច្ចសន្យា ឬ ជាអ្នកស្នើធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុន ។

ខ-ដែលខ្លួនមានអត្ថប្រយោជន៍ជាមួយបុគ្គលណាម្នាក់ ដែលជាភាគីក្នុងកិច្ចសន្យា ឬ ភាគីដែលស្នើធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុន ។

**មាត្រា ១៣៥.-**

ក្នុងករណីជាអភិបាល ការបង្ហាញត្រូវធ្វើឡើង :

ក-នៅពេលប្រជុំ កិច្ចសន្យាដែលបានស្នើឡើងត្រូវពិចារណាជាលើកទីមួយ ។

ខ-នៅពេលប្រជុំលើកិច្ចសន្យា អភិបាលនោះមិនបានបង្ហាញថាមានការពាក់ព័ន្ធផលប្រយោជន៍ទេ ប៉ុន្តែក្រោយមកគាត់បានបញ្ជាក់ថាមានការពាក់ព័ន្ធ ។

គ-នៅក្រោយពេលកិច្ចសន្យាត្រូវបានធ្វើឡើង ហើយក្រោយមកអភិបាលនោះ បានបង្ហាញប្រាប់ថាមានការពាក់ព័ន្ធដល់ផលប្រយោជន៍របស់ខ្លួន ។

ឃ- ប្រសិនបើបុគ្គលដែលបានជាប់ពាក់ព័ន្ធលើកិច្ចសន្យាពីមុន ហើយក្រោយមកបុគ្គលនោះបានក្លាយជាអភិបាល ។

**មាត្រា ១៣៦.-**

ក្នុងករណីជាអ្នកគ្រប់គ្រងក្រុមហ៊ុន ការបង្ហាញត្រូវធ្វើឡើង :

ក-ក្រោយពីអ្នកគ្រប់គ្រងនោះ ដឹងភ្លាមថាកិច្ចសន្យា ឬ កិច្ចសន្យាដែលបានដាក់ស្នើសុំនោះត្រូវសម្រេច ឬ ត្រូវបានសម្រេចរួចហើយ នៅក្នុងអង្គប្រជុំក្រុមប្រឹក្សាភិបាល ។

ខ-ប្រសិនបើអ្នកគ្រប់គ្រងនោះ បានបកស្រាយបង្ហាញមុនពេលដែលកិច្ចសន្យានោះបានធ្វើរួចរាល់ ។

គ-ប្រសិនបើបុគ្គលដែលបានជាប់ពាក់ព័ន្ធលើកិច្ចសន្យាពីមុន ហើយក្រោយមកបុគ្គលនោះបានក្លាយជាអ្នកគ្រប់គ្រងក្រុមហ៊ុនម្នាក់ ។

**មាត្រា ១៣៧.-**

អភិបាលដែលមានពាក់ព័ន្ធពីផលប្រយោជន៍ មិនអនុញ្ញាតឱ្យចូលរួមបោះឆ្នោតក្នុងការធ្វើសេចក្ដីសម្រេចណាមួយក្នុងការអនុម័តកិច្ចសន្យាមួយទេ លើកលែងតែកិច្ចសន្យានោះជា :

ក-ការសម្របសម្រួលតាមរយៈការធានាសម្រាប់ទឹកប្រាក់ ដើម្បីឱ្យទៅអ្នកខ្ចី ឬកាតព្វកិច្ចទាំងឡាយ ដែលបានធានាអនុវត្តដោយអភិបាលនោះ ដើម្បីជាប្រយោជន៍ដល់ក្រុមហ៊ុន ឬ ដល់សាខាមួយរបស់ក្រុមហ៊ុន ។

ខ-កិច្ចសន្យាដែលទាក់ទងជាចម្បងទៅនឹងទឹកប្រាក់បំណាច់របស់ខ្លួនដែលជាអភិបាល អ្នកគ្រប់គ្រង បុគ្គលិកភ្នាក់ងាររបស់ក្រុមហ៊ុន ឬ សាខាមួយរបស់ក្រុមហ៊ុន ។

គ-កិច្ចសន្យាមួយធ្វើឡើងជាការរ៉ាប់រងសងការខូចខាត ឬជាការធានា ។

ឃ-កិច្ចសន្យាមួយធ្វើឡើងជាមួយសាខាណាមួយ ។

**មាត្រា ១៣៨.-**

លក្ខន្តិកៈ ឬ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនអាចមានចែង :

ក-ក្រុមប្រឹក្សាភិបាលក្រុមហ៊ុនមានសិទ្ធិចាត់ចែងការិយាល័យរបស់ក្រុម

ហ៊ុន តែងតាំងអ្នកគ្រប់គ្រងក្រុមហ៊ុន កំណត់តួនាទីភារកិច្ចនិងសិទ្ធិរបស់អ្នកទាំងនោះឱ្យបានច្បាស់លាស់ដើម្បីធ្វើការគ្រប់គ្រងអាជីវកម្ម និងការងាររបស់ក្រុមហ៊ុន ។

ខ-អភិបាលអាចត្រូវបានតែងតាំងឱ្យគ្រប់គ្រងការិយាល័យណាមួយរបស់ក្រុមហ៊ុន ។

គ-បុគ្គលម្នាក់អាចរៀបចំគ្រប់គ្រងការិយាល័យមួយ ឬ ច្រើនរបស់ក្រុមហ៊ុនបាន ។

**មាត្រា ១៣៩.-**

បុគ្គលម្នាក់ៗដែលបានចុះកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ក្នុងនាម ឬតំណាងឱ្យក្រុមហ៊ុនមុនពេលក្រុមហ៊ុននោះមានអត្ថិភាព ឬ បុគ្គលនោះត្រូវជាប់កាតព្វកិច្ចដោយផ្ទាល់នៅក្នុងកិច្ចសន្យានោះ និងមានសិទ្ធិក្នុងការទទួលផលប្រយោជន៍នោះដែរ ។

ក្រោយពីកិច្ចសន្យាមួយ បានបង្កើតឡើងក្នុងពេលវេលាមួយសមស្រប ក្រុមហ៊ុនអាចទទួលយកបាននូវកិច្ចសន្យាជាលាយលក្ខណ៍អក្សរនោះ ដែលបានធ្វើឡើងមុនពេលក្រុមហ៊ុនមានអត្ថិភាព និងមុនការទទួលយល់ព្រមនៅក្នុងក្រុមហ៊ុន ។ ការទទួលនេះផ្អែកលើសកម្មភាព ឬ ការប្រព្រឹត្តដែលផ្តោតទៅលើគោលបំណងដ៏សំខាន់នៃកិច្ចសន្យាដែលបានជាប់កាតព្វកិច្ចរួចមកហើយនោះ ។

ក្រុមហ៊ុនត្រូវជាប់កាតព្វកិច្ចដោយកិច្ចសន្យា ហើយមានសិទ្ធិក្នុងការទទួលផលប្រយោជន៍ដូចពេលដែលក្រុមហ៊ុនមានអត្ថិភាព ចាប់ពីកាលបរិច្ឆេទនៃកិច្ចសន្យា និងដូចពេលដែលក្រុមហ៊ុននោះជាចំណែកមួយនៃកិច្ចសន្យា ។

បុគ្គលម្នាក់ដែលប្តឹងទាមទារថាបានអនុវត្តក្នុងនាម ឬ តំណាងឱ្យក្រុមហ៊ុនមានកាតព្វកិច្ច ឬ មានសិទ្ធិទទួលផលប្រយោជន៍នៅក្នុងកិច្ចសន្យាបាន លុះត្រាតែមានដីកាសម្រេចរបស់តុលាការ ។

**មាត្រា ១៤០.-**

អភិបាលដែលបោះឆ្នោតឱ្យ ឬ យល់ព្រមក្នុងការធ្វើសេចក្តីសម្រេចលើការអនុញ្ញាតឱ្យចេញប័ណ្ណភាគហ៊ុនសម្រាប់តម្លៃសមមូល ដែលមិនមែនជាសាច់ប្រាក់ទេត្រូវ



ស

ទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នាចំពោះក្រុមហ៊ុនទៅតាមចំនួនតម្លៃសមមូលដែលបានទទួល ដែលតិចជាងតម្លៃត្រឹមត្រូវជាសាច់ប្រាក់ ដែលក្រុមហ៊ុនបានទទួល ប្រសិនបើប័ណ្ណភាគហ៊ុនដែលបានបោះចេញនោះសម្រាប់លក់យកជាប្រាក់នៅកាលបរិច្ឆេទនៃសេចក្តីសម្រេច ។

អភិបាលមិនទទួលខុសត្រូវទេ ប្រសិនបើអភិបាលនោះបង្ហាញថាមិនបានដឹងថាភាគហ៊ុនដែលបោះចេញសម្រាប់តម្លៃសមមូល ដែលតិចជាងសាច់ប្រាក់ ដែលក្រុមហ៊ុនអាចនឹងទទួលប្រសិនបើប័ណ្ណភាគហ៊ុននោះ ដែលបានបោះចេញសម្រាប់លក់យកជាប្រាក់ ។

សកម្មភាពក្នុងការអនុវត្តនូវការទទួលខុសត្រូវបំណុល ដែលតម្រូវដោយច្បាប់នេះមិនអាចចាប់ផ្តើមក្រោយរយៈពេល ០២ (ពីរ)ឆ្នាំបានទេ ចាប់ពីកាលបរិច្ឆេទនៃសេចក្តីសម្រេចរបស់អភិបាលនោះ ។

**មាត្រា ១៤១.-**

អភិបាលដែលបានបោះឆ្នោតឱ្យ ឬ យល់ព្រមចំពោះសេចក្តីសម្រេចដែលអនុញ្ញាតឱ្យមានការទិញមកវិញនូវភាគហ៊ុនរបស់ក្រុមហ៊ុនដែលបានលក់កន្លងមក ឬធ្វើការបន្ថយដើមទុនតាមវិធីណាមួយ ឬ ធ្វើការចែកភាគលាភដែលផ្ទុយពីបទប្បញ្ញត្តិនៃជំពូកនេះត្រូវទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នានូវរាល់ចំនួនដែលបានបែងចែក ឬ បានបង់ហើយ ដើម្បីស្តារក្រុមហ៊ុនឡើងវិញ ។

សកម្មភាពដើម្បីអនុវត្តការទទួលខុសត្រូវដែលតម្រូវដោយមាត្រានេះ មិនអាចចាប់ផ្តើមក្រោយរយៈពេល ០២ (ពីរ) ឆ្នាំ បានទេ ចាប់ពីកាលបរិច្ឆេទនៃសេចក្តីសម្រេចរបស់អភិបាលនោះ ។

**មាត្រា ១៤២.-**

អភិបាលម្នាក់ ដែលមានវត្តមាននៅក្នុងមហាសន្និបាតក្រុមប្រឹក្សាភិបាលត្រូវចាត់ទុកថាបានយល់ព្រមនូវរាល់សេចក្តីសម្រេចដែលបានអនុម័ត ឬ សកម្មភាពដែលបានធ្វើឡើងនៅក្នុងមហាសន្និបាតលើកលែងតែ :

១-អភិបាលនោះមានការជំទាស់ ដែលស្នើដាក់ចូលក្នុងកំណត់ហេតុអង្គប្រជុំនៃមហាសន្និបាតនោះ ។

២-អភិបាលនោះ ផ្ញើគំនិតជំទាស់ជាលាយលក្ខណ៍អក្សររបស់ខ្លួនទៅលេខាធិការរបស់មហាសន្និបាត មុនពេលបិទមហាសន្និបាតនោះ ។

អភិបាលដែលអវត្តមាននៅក្នុងមហាសន្និបាត នៅពេលសេចក្តីសម្រេចដែលត្រូវអនុម័ត ឬសកម្មភាពដែលបានធ្វើឡើងរួចមកហើយគឺចាត់ទុកថាបានយល់ព្រម លើកលែងតែក្នុងរយៈពេលដប់ប្រាំ (១៥)ថ្ងៃ ក្រោយពីបានដឹងសេចក្តីសម្រេចនោះ អភិបាលនោះបាន :

១-បង្ហាញមូលហេតុនៃការជំទាស់របស់គាត់ ដែលបានបញ្ចូលទៅក្នុងកំណត់ហេតុនៃមហាសន្និបាត ។

២-ផ្ញើគំនិតជំទាស់របស់ខ្លួនតាមរយៈលិខិតអនុសិដ្ឋ ឬ យកទៅប្រគល់ផ្ទាល់នៅឯការិយាល័យរបស់ក្រុមហ៊ុន ។

## ខ_ ភាគហ៊ុន និង ភាគលាភ

### មាត្រា ១៤៣._

ភាគហ៊ុននីមួយៗត្រូវចុះក្នុងបញ្ជីទៅតាមបែបបទដែលបានកំណត់ ។ ភាគហ៊ុននីមួយៗ ត្រូវមានតម្លៃចារឹកលើប័ណ្ណ ហើយក្រុមហ៊ុនមិនត្រូវចេញប័ណ្ណភាគហ៊ុនណាមួយដែលមានតម្លៃតិចជាងតម្លៃចារឹកលើប័ណ្ណនោះទេ ។ សិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌទាំងឡាយ ដែលភ្ជាប់ទៅនឹងប័ណ្ណភាគហ៊ុនប្រភេទនីមួយៗត្រូវបានកំណត់នៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

### មាត្រា ១៤៤._

ក្នុងករណីលក្ខន្តិកៈមិនបានចែងនូវចំនួន និងតម្លៃនៃប័ណ្ណភាគហ៊ុនទេ ក្រុមហ៊ុនត្រូវបោះលក់ចេញយ៉ាងតិចបំផុតមួយពាន់ភាគហ៊ុន ដែលមានតម្លៃចារឹកលើប័ណ្ណមិនតិចជាងបួនពាន់រៀលក្នុងមួយហ៊ុនៗ ។

ក្នុងករណីលក្ខន្តិកៈរបស់ក្រុមហ៊ុន មិនបានបញ្ជាក់នូវប្រភេទនៃភាគហ៊ុនទេនោះ ក្រុមហ៊ុនត្រូវមានប្រភេទភាគហ៊ុនតែមួយប៉ុណ្ណោះ ហើយសិទ្ធិរបស់សមាជិកហ៊ុននៃភាគហ៊ុនទាំងនេះគឺស្មើគ្នា និងរួមបញ្ចូលនូវសិទ្ធិ :

១-ក្នុងការបោះឆ្នោតនៅគ្រប់មហាសន្និបាតនៃម្ចាស់ហ៊ុនរបស់ក្រុមហ៊ុន ។

២-ក្នុងការទទួលនូវរាល់ភាគលាភ ដែលបានប្រកាសដោយក្រុមហ៊ុន ។

៣- ក្នុងការទទួលនូវទ្រព្យដែលនៅសេសសល់របស់ក្រុមហ៊ុន នៅពេលមានការរំលាយ ។

**មាត្រា ១៤៥.-**

លក្ខន្តិកៈរបស់ក្រុមហ៊ុន អាចចែងឱ្យមានបណ្ណភាគហ៊ុនច្រើនជាងមួយប្រភេទ ក្នុងករណីនេះ សិទ្ធិនៃប្រភេទរបស់បណ្ណភាគហ៊ុននីមួយៗអាចមានលក្ខណៈដាច់ខាត ឬ លក្ខណៈធៀប ។ សិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌទាំងឡាយដែលភ្ជាប់ទៅនឹងប្រភេទភាគហ៊ុននីមួយៗ ត្រូវកំណត់នៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុននោះ ។ សិទ្ធិដែលបានកំណត់នៅក្នុងមាត្រា ១៤៤ ត្រូវភ្ជាប់ដោយឡែក ឬ ទាំងស្រុងទៅនឹងភាគហ៊ុនមួយប្រភេទណាមួយ ។ សិទ្ធិទាំងនោះរួមមាន :

ក-ភាពដែលអាចផ្ទេរបាន ឬភាពដែលអាចផ្លាស់ប្តូរបាននៅក្នុងប្រភេទភាគហ៊ុនមួយផ្សេងទៀត ឬ មូលបត្រផ្សេងទៀតនៃក្រុមហ៊ុនមូលធន ឬ ក្រុមហ៊ុនផ្សេងទៀតអាស្រ័យទៅលើជម្រើសរបស់ក្រុមហ៊ុនមូលធន ឬ អាស្រ័យទៅលើជម្រើសរបស់ម្ចាស់ហ៊ុន ឬអាស្រ័យទៅលើការកើតឡើងនៃព្រឹត្តិការណ៍ជាក់លាក់ណាមួយ ។

ខ-អាទិភាពនៃការទទួលយកទ្រព្យសម្បត្តិ ដែលសល់ពីការជម្រះបញ្ជីនិងការរំលាយក្រុមហ៊ុនមូលធន ។

គ-ការលោះមកវិញ ការទិញឡើងវិញទៅតាមជម្រើសរបស់ក្រុមហ៊ុនមូលធន ឬ ទៅតាមជម្រើសរបស់អ្នកកាន់កាប់ភាគហ៊ុន ។

ឃ-ការរឹតត្បិតទៅលើភាពដែលអាចផ្ទេរបាន ។

**មាត្រា ១៤៦.-**

ផ្អែកទៅតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន និងរាល់សិទ្ធិដែលអាចទិញមុនគេរបស់ម្ចាស់ហ៊ុន ភាគហ៊ុន និងមូលបត្រ អាចអនុញ្ញាតឱ្យបោះចេញទៅតាមពេលវេលា និងចំពោះបុគ្គលទាំងឡាយដែលអភិបាលក្រុមហ៊ុនកំណត់ឱ្យ ។

អភិបាលត្រូវកំណត់តម្លៃរបស់ប័ណ្ណភាគហ៊ុន និងតម្លៃមូលបត្រដែលត្រូវលក់ចេញ ។

តម្លៃភាគហ៊ុនមិនត្រូវបោះចេញទេរហូតដល់ការបង់ថ្លៃសម្រាប់ភាគហ៊ុនត្រូវបានបំពេញចប់សព្វគ្រប់ជាសាច់ប្រាក់ ជាវត្ថុ ឬ ជាសេវាពីមុនទៅក្នុងក្រុមហ៊ុន ។

ការបង់ភាគហ៊ុនជាវត្ថុ អាចរួមបញ្ចូលពាណិជ្ជសញ្ញា សិទ្ធិនិពន្ធ ប្រកាសនីយ-បត្រតក្កកម្ម និងសិទ្ធិប្រើប្រាស់ទ្រព្យអរូបិយ ឬ សិទ្ធិប្រើប្រាស់លិខិតអនុញ្ញាតពាណិជ្ជ-សញ្ញា ។

អភិបាលទាំងឡាយកំណត់តម្លៃនៃការដាក់ភាគទុនជាវត្ថុ ឬ ជាសេវាកម្មពីមុននោះ ហើយសេចក្តីសម្រេចរបស់អភិបាលទាំងនេះចាត់ទុកជាបានការប្រសិនបើគ្មានការក្លែងបន្លំពាក់ព័ន្ធក្នុងរឿងនេះទេ ។

ចំពោះក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត មិនអនុញ្ញាតឱ្យមានភាគទុនជាសេវាទេ ។

**មាត្រា ១៤៧.-**

ការទទួលខុសត្រូវរបស់ម្ចាស់ហ៊ុនទាំងឡាយចំពោះបំណុលនៅក្នុងក្រុមហ៊ុនគឺមានកម្រិតត្រឹមតែលើតម្លៃជាវភាគហ៊ុនរបស់ម្ចាស់ហ៊ុនម្នាក់ៗប៉ុណ្ណោះ ។

**មាត្រា ១៤៨.-**

លក្ខន្តិកៈរបស់ក្រុមហ៊ុនអាចអនុញ្ញាតឱ្យបោះចេញលើគ្រប់ប្រភេទនៃប័ណ្ណភាគហ៊ុនតាមស៊េរីមួយ ឬ ច្រើន ។ លក្ខន្តិកៈនេះអាចអនុញ្ញាតឱ្យអភិបាលទាំងឡាយកំណត់ចំនួនប័ណ្ណ និងកំណត់ការបែងចែកសិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌដែលភ្ជាប់

ទៅនឹងប័ណ្ណភាគហ៊ុនក្នុងសេរីនីមួយៗ ដោយអនុលោមទៅតាមការកំណត់ដែលបានធ្វើឡើងនៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុននោះ ។ បើពុំដូច្នេះទេ សិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត ឬ លក្ខខណ្ឌដែលភ្ជាប់ទៅនឹងប័ណ្ណភាគហ៊ុន ប្រភេទនិងសេរីដូចគ្នា ត្រូវតែមានលក្ខណៈដូចគ្នា ។

**មាត្រា ១៤៩.-**

ក្រុមហ៊ុនត្រូវរក្សាទុកគណនីដើមទុន ដែលបានចុះបញ្ជីប្រកាសដោយឡែកពីគ្នាសម្រាប់ប្រភេទនិងសេរីភាគហ៊ុននីមួយៗ ដែលក្រុមហ៊ុនបានបោះចេញ ។

ក្រុមហ៊ុនត្រូវបន្ថែមទៅក្នុងគណនីដើមទុន ដែលបានប្រកាសនូវការបង់ពេញលេញណាមួយជាសាច់ប្រាក់ ជាវត្ថុ ឬ ជាសេវាពីមុនដែលក្រុមហ៊ុនបានទទួលចំពោះប័ណ្ណភាគហ៊ុនដែលបានបោះចេញ ។

**មាត្រា ១៥០.-**

ពេលណាក្រុមហ៊ុនស្នើសុំបន្ថែមនូវចំនួនណាមួយទៅក្នុងគណនីដើមទុន ដែលបានប្រកាសលើរាល់ប្រភេទ ឬ សេរីនៃភាគហ៊ុន ប្រសិនបើចំនួនដែលត្រូវបន្ថែមនោះក្រុមហ៊ុនមិនបានទទួលគ្រប់ចំនួនទេ ពេលនោះការបន្ថែមចំនួនចូលទៅក្នុងគណនីដើមទុន ត្រូវតែមានការយល់ព្រមដោយសេចក្ដីសម្រេចពិសេសរបស់ក្រុមប្រឹក្សាភិបាល ។

ក្រុមហ៊ុនមិនអាចបន្ថយគណនីដើមទុនដែលបានប្រកាស ឬ គណនីដើមទុនណាមួយបានឡើយ ។ ក្រុមហ៊ុនអាចបន្ថយគណនីដើមទុនរបស់ខ្លួនបានសម្រាប់គោលបំណងណាមួយតាមរយៈសេចក្ដីសម្រេចពិសេស ។ សេចក្ដីសម្រេចពិសេស ត្រូវបញ្ជាក់គណនីដើមទុនដែលនឹងត្រូវបន្ថយ ។

ក្រុមហ៊ុនមិនត្រូវបន្ថយគណនីដើមទុនរបស់ខ្លួនទេ ប្រសិនបើមានមូលហេតុដូចខាងក្រោម :

១-ក្រុមហ៊ុនមិនមានលទ្ធភាពសងបំណុលរបស់ខ្លួនបានទេ តាមកាលបរិច្ឆេទដែលបានកំណត់បន្ទាប់ពីការចំណាយ ។

២-តម្លៃទ្រព្យដែលអាចជាន់ស្មានបានរបស់ក្រុមហ៊ុនតិចជាងចំនួនសរុបនៃបំណុល ។

វិធាននេះមិនយកមកអនុវត្តទេ ប្រសិនបើក្រុមហ៊ុនកាត់បន្ថយគណនីដើមទុនរបស់ខ្លួន នូវចំនួនណាមួយដែលមិនពាក់ព័ន្ធដល់ទ្រព្យសម្បត្តិ ដែលអាចទទួលផលបាននៅពេលក្រោយ ។

ម្ចាស់បំណុលរបស់ក្រុមហ៊ុន អាចធ្វើបណ្តឹងទៅតុលាការសុំឱ្យក្រុមហ៊ុនសងមកវិញនូវសាច់ប្រាក់ ឬ ទ្រព្យសម្បត្តិ បន្ទាប់ពីការកាត់បន្ថយគណនីដើមទុនដែលបានធ្វើឡើងផ្ទុយពីមាត្រានេះ ។

បណ្តឹងទាមទារការសងបំណុលដែលបានចែងដោយមាត្រានេះ មិនត្រូវធ្វើឡើងក្រោយរយៈពេលពីរ (០២)ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលឡើយ ។

**មាត្រា ១៥១.-**

បើសិនជាលក្ខន្តិកៈក្រុមហ៊ុនផ្តល់នូវសិទ្ធិអាចទិញបានចំពោះប្រភេទណាមួយនៃប័ណ្ណភាគហ៊ុន គ្មានប័ណ្ណភាគហ៊ុនណាផ្សេងទៀតនៃប្រភេទនោះត្រូវបោះចេញទៀតឡើយ លើកលែងតែម្ចាស់ហ៊ុនដែលមានសិទ្ធិទិញមុនគេត្រូវបានផ្តល់សិទ្ធិដំបូងគេបង្អស់ ។

ម្ចាស់ហ៊ុនមានសិទ្ធិទិញបានមុននូវភាគហ៊ុន ដែលបានដាក់សំណើលក់ទៅតាមសមាមាត្រនៃការកាន់កាប់ភាគហ៊ុនប្រភេទនោះតាមតម្លៃ និងលក្ខខណ្ឌផ្សេងៗដូចដែលប័ណ្ណភាគហ៊ុនទាំងនោះ ត្រូវបានដាក់សំណើលក់ដល់តតិយជនផងដែរ ។

**មាត្រា ១៥២.-**

ក្រុមហ៊ុនអាចបោះចេញវិញ្ញាបនបត្របញ្ជាក់ពីឯកសិទ្ធិនៃការផ្លាស់ប្តូរ ជម្រើសនៃការផ្លាស់ប្តូរ ឬ សិទ្ធិនៃការផ្លាស់ប្តូរក្នុងការទទួលមូលបត្ររបស់ក្រុមហ៊ុន ។ នៅក្នុងករណីនេះ វិញ្ញាបនបត្របញ្ជាក់ ឬ ក៏មូលបត្រទាំងឡាយត្រូវកំណត់ចេញនូវលក្ខខណ្ឌ

ដែលអាចអនុវត្តបាននៅក្នុងឯកសិទ្ធិនៃការផ្លាស់ប្តូរជម្រើសនៃការផ្លាស់ប្តូរ ឬ សិទ្ធិនៃការផ្លាស់ប្តូរ ។

ឯកសិទ្ធិនៃការផ្លាស់ប្តូរជម្រើសនៃការផ្លាស់ប្តូរ ឬ សិទ្ធិនៃការផ្លាស់ប្តូរក្នុងការទិញមូលបត្ររបស់ក្រុមហ៊ុនអាចធ្វើឡើងឱ្យមានភាពដែលអាចផ្ទេរបាន ឬ មិនអាចផ្ទេរបាន ហើយជម្រើសនិងសិទ្ធិក្នុងការទិញអាចធ្វើដោយដាច់ពីគ្នា ឬ មិនដាច់ពីគ្នាពីរាល់មូលបត្រ ។

**មាត្រា ១៥៣.-**

ម្ចាស់ហ៊ុនម្នាក់មានសិទ្ធិទទួលវិញ្ញាបនបត្របញ្ជាក់ភាគហ៊ុន ។ នៅលើវិញ្ញាបនបត្រហ៊ុននីមួយៗ ដែលត្រូវបានបោះចេញដោយក្រុមហ៊ុនត្រូវមាននាមករណ៍ក្រុមហ៊ុន ឈ្មោះរបស់បុគ្គលដែលត្រូវបោះចេញឱ្យ ហើយនិងចំនួន និងប្រភេទរបស់បណ្ណភាគហ៊ុន និងការកំណត់នូវរាល់សេរីដែលវិញ្ញាបនបត្របញ្ជាក់ភាគហ៊ុននោះតំណាង ។

**មាត្រា ១៥៤.-**

យោងទៅតាមការរឹតត្បិតនៅក្នុងច្បាប់នេះ និងដោយលក្ខន្តិកៈរបស់ក្រុមហ៊ុន ភាគហ៊ុនទាំងឡាយអាចធ្វើការផ្ទេរបាន ។ ក្រុមហ៊ុនអាចផ្ទេរបាននូវភាគហ៊ុននោះនឹងធ្វើការកត់បញ្ជីទៅក្នុងសៀវភៅ និងបញ្ជីរបស់ក្រុមហ៊ុនទៅតាមសំណើរបស់ភាគីផ្ទេរ និងភាគីទទួល ។

**មាត្រា ១៥៥.-**

ផ្អែកទៅតាមលក្ខន្តិកៈរបស់ក្រុមហ៊ុន ក្រុមហ៊ុនអាចជាវ ឬ ទិញមកវិញនូវភាគហ៊ុនទាំងឡាយដែលបានបោះចេញ ។

ក្រុមហ៊ុនត្រូវមានបណ្ណភាគហ៊ុនដែលបោះចេញ យ៉ាងហោចណាស់ក៏មួយប្រភេទនៃបណ្ណភាគហ៊ុនដែលមានសិទ្ធិពេញលេញក្នុងសិទ្ធិបោះឆ្នោត និងដែលមិនស្ថិតក្រោមភាពចាំបាច់នៃការទិញមកវិញ ឬ ការលោះមកវិញនោះទេ ។

បើសិនជាប័ណ្ណភាគហ៊ុនត្រូវលោះយកមកវិញ ម្ចាស់ភាគហ៊ុនមានភារកិច្ចប្រគល់ប័ណ្ណភាគហ៊ុនទៅក្រុមហ៊ុនវិញ ដោយទទួលយកមកវិញនូវតម្លៃនៃការលោះនោះ ។ បើសិនជាម្ចាស់ហ៊ុនមិនព្រមប្រគល់ឱ្យវិញ ក្រុមហ៊ុនអាចកក់នូវតម្លៃនៃភាគហ៊ុន ដែលត្រូវលោះទៅក្នុងគណនីដាច់ដោយឡែកនៅក្នុងធនាគារមួយដែលទទួលស្គាល់ដោយក្រុមហ៊ុន ហើយក្រុមហ៊ុនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់ហ៊ុននោះ ។ ក្រុមហ៊ុនត្រូវលុបចោលភ្លាមពីសៀវភៅបញ្ជីនូវប័ណ្ណភាគហ៊ុនដែលបានលោះនៅពេលដែលលុយកក់ត្រូវបានទទួល ។ ប៉ុន្តែក្រុមហ៊ុនមិនត្រូវធ្វើការទូទាត់ណាមួយទៅលើការទិញ ឬ ការលោះប័ណ្ណភាគហ៊ុនទេ ដែលបានបោះចេញ ប្រសិនបើមានហេតុផលថា :

១-ក្រោយពេលទិញ ក្រុមហ៊ុនគ្មានលទ្ធភាពក្នុងការសងបំណុលឱ្យទាន់ពេល វេលាទេ ។

២-ក្រោយពេលទិញតម្លៃពិតប្រាកដនៃទ្រព្យរបស់ក្រុមហ៊ុននៅតិចជាងតម្លៃសរុបរបស់បំណុល ។

ប័ណ្ណភាគហ៊ុនដែលបានទិញ និងបានលោះរួចមកហើយ ឬ បានទទួលដោយក្រុមហ៊ុនត្រូវបានលុបចេញ ឬ ប្រសិនបើលក្ខន្តិកៈរបស់ក្រុមហ៊ុនកម្រិតនូវចំនួននៃប័ណ្ណភាគហ៊ុនដែលអនុញ្ញាតឱ្យបោះចេញ ក្រុមហ៊ុនអាចដាក់ប័ណ្ណភាគហ៊ុនក្នុងលក្ខណៈអនុញ្ញាត ប៉ុន្តែពុំទាន់លក់ចេញ ។

**មាត្រា ១៥៦.-**

នៅពេលក្រុមហ៊ុនទិញ លោះមកវិញ ឬ ទទួលភាគហ៊ុនចូលក្រុមហ៊ុនត្រូវធ្វើការកែតម្រូវដោយភ្ជាប់ទៅនឹងគណនីដើមទុនដែលរក្សាទុកសម្រាប់ប្រភេទ ឬ ស៊េរីនៃប័ណ្ណភាគហ៊ុនដែលបានទិញលោះមកវិញ ឬ បានទទួល ។

**មាត្រា ១៥៧.-**

ក្នុងករណីដែលមានការរឹតត្បិតនៅក្នុងលក្ខន្តិកៈ អភិបាលអាចប្រកាសចេញនូវភាគលាភសល់ ឬ ប្រាក់ចំណេញសុទ្ធរបស់ក្រុមហ៊ុន ។

អភិបាលអាចចាត់ចែងប្រាក់បម្រុងពិសេសមួយភាគ សម្រាប់ប្រើប្រាស់ក្នុងការអនុវត្តពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន ដោយប្រើប្រាស់មូលនិធិណាមួយរបស់ក្រុមហ៊ុនដែលមានសម្រាប់បែងចែកភាគលាភ ។

**មាត្រា ១៥៨.-**

ក្រុមហ៊ុនមិនអាចប្រកាស ឬ បែងចែកភាគលាភបានទេ ប្រសិនបើក្រុមហ៊ុនមានមូលហេតុសមហេតុសមផលដើម្បីធ្វើឱ្យជឿថា :

ក-ក្រោយពីការបែងចែកភាគលាភនោះ ក្រុមហ៊ុនគ្មានលទ្ធភាពសងបំណុលដូចដែលបានកំណត់ឱ្យសងនោះទេ ។

ខ-តម្លៃដែលអាចប៉ាន់ស្មានបាននៃទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនតិចជាងចំនួនសរុបនៃបំណុល និងដើមទុន ប្រកាសរបស់ភាគហ៊ុនគ្រប់ប្រភេទ ។

**មាត្រា ១៥៩.-**

ក្រុមហ៊ុនអាចបែងចែកភាគលាភ ដោយធ្វើការបោះចេញប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុន ។ ផ្អែកតាមការរឹតត្បិតនៅក្នុងផ្នែកនេះ ក្រុមហ៊ុនអាចបែងចែកភាគលាភជាសាច់ប្រាក់ ឬ ជាទ្រព្យសម្បត្តិបាន ។

**មាត្រា ១៦០.-**

ប្រសិនបើប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនត្រូវបានបោះចេញដើម្បីទូទាត់ភាគ-លាភ ចំនួនភាគលាភដែលបានប្រកាសបញ្ជាក់ចំនួនសាច់ប្រាក់ត្រូវបន្ថែមទៅក្នុងគណនីដើមទុន ឬ ត្រូវបានរក្សាទុកសម្រាប់ប្រភេទ ឬ ស៊េរីនៃប័ណ្ណភាគហ៊ុនដែលបានបោះចេញដើម្បីទូទាត់ភាគលាភនោះ ។

## ច- មូលបត្រ ការចុះបញ្ជី និងការផ្ទេរ

**មាត្រា ១៦១.-**

នៅក្នុងផ្នែកនេះ ពាក្យបច្ចេកទេសទាំងឡាយមាននិយមន័យដូចតទៅ :

១-គាហកៈ មានន័យថាបុគ្គលដែលកាន់កាប់មូលបត្រដែលអាចទូទាត់ឱ្យទៅគាហកៈផ្សេងបាន ឬដែលបានធ្វើបិដ្ឋិលេខដោយចំហទុក ។

២-អ្នកទិញដោយសុទ្ធចិត្ត មានន័យថាអ្នកទិញដែលបង់តម្លៃឱ្យត្រឹមត្រូវ និងដោយមិនដឹងថាមានការបណ្ដឹងទាមទារណាមួយ ហើយជាអ្នកដែលធ្វើការផ្ទេរការកាន់កាប់មូលបត្រតាមទម្រង់ជាអ្នកកាន់កាប់ ឬជាអ្នកបញ្ជាដែលទទួលការផ្ទេរការកាន់កាប់មូលបត្រតាមទម្រង់ចុះបញ្ជីដែលបានបោះចេញឱ្យ ឬដែលបានធ្វើបិដ្ឋិលេខឱ្យ ឬដែលបានធ្វើបិដ្ឋិលេខចំហ ។

៣-អ្នកជើងសា មានន័យថាជាបុគ្គលជាប់កាតព្វកិច្ចទាំងស្រុង ឬមួយភាគនៃពេលវេលារបស់ខ្លួនក្នុងកិច្ចការជំនួញ ទិញ និងលក់មូលបត្រ និងជាអ្នកធ្វើសកម្មភាពជំនួសគេ ឬទិញមូលបត្រពីអតិថិជន ឬលក់មូលបត្រទៅឱ្យអតិថិជនក្នុងកិច្ចការជំនួញដែលជាប់ពាក់ព័ន្ធនោះ ។

៤-ការប្រគល់ មានន័យថាជាការផ្ទេរការកាន់កាប់ដោយឆន្ទៈ ។

៥-សុទ្ធ មានន័យថាពិតប្រាកដមិនក្លែងក្លាយ ឬក្លែងបន្លំ ។

៦-ម្ចាស់មូលបត្រ មានន័យថាបុគ្គលមានមូលបត្រដែលបានចេញឱ្យ ឬដែលបានធ្វើបិដ្ឋិលេខឱ្យ ឬដែលមានធ្វើបិដ្ឋិលេខចំហ ។

៧-ចេញបន្ថែម មានន័យថាការចេញមូលបត្រលើសពីចំនួនអតិបរមានៃមូលបត្រ ដែលអ្នកចេញមូលបត្រត្រូវផ្ដល់សិទ្ធិតាមលក្ខន្តិកៈរបស់ខ្លួន ឬតាមកិច្ចសន្យាច្បាស់លាស់ក្នុងការចេញមូលបត្រ ។

៨-អ្នកជាវ មានន័យថាជាបុគ្គលដែលទាញរកចំណេញពីមូលបត្រដោយធ្វើការលក់បញ្ចាំ ធ្វើអ៊ីប៉ូតែកចេញប័ណ្ណចេញសាជាថ្មី ធ្វើអំណោយនូវមូលបត្រនោះឬក៏ទាញរកចំណេញតាមកិច្ចការជំនួញណាមួយផ្សេងទៀតដោយឆន្ទៈ ។

៩- មូលបត្រ មានន័យថាជាលិខិតស្នាមដែលចេញដោយក្រុមហ៊ុនហើយដែល :

ក-ស្ថិតក្នុងទ្រង់ទ្រាយគាហកៈ ទ្រង់ទ្រាយចុះបញ្ជី ឬទ្រង់ទ្រាយបញ្ជា

ខ-ជាគំរូប័ណ្ណមួយលក់ជាសាធារណៈនៅលើការដោះដូរ ឬ លើទីផ្សារមូលបត្រ ឬ បានទទួលស្គាល់នៅក្នុងវិស័យណាមួយដែលនៅក្នុងវិស័យនោះ មូលបត្រត្រូវបានបោះចេញ ឬ ត្រូវបានលក់ជារូបិយវត្ថុសម្រាប់បម្រើឱ្យការវិនិយោគ ។

គ-ជាប្រភេទមួយ ឬ ស៊េរីមួយមូលបត្រ ដែលចែកនៅក្នុងប្រភេទ ឬ ស៊េរីនៃលិខិតស្នាម ។

ឃ-ជាភស្តុតាងបញ្ជាក់ភាគហ៊ុន ភស្តុតាងនៃការចូលរួមចំណែក ឬភស្តុតាងនៃអត្ថប្រយោជន៍ផ្សេងៗក្នុងកាតព្វកិច្ចរបស់ក្រុមហ៊ុន ។

១០- ការផ្ទេរ មានន័យថាគឺជាការផ្ទេរដែលរួមបញ្ចូលទាំងការបញ្ជូនឱ្យដោយប្រតិបត្តិតាមច្បាប់ ។

១១-គ្មានសិទ្ធិក្នុងការចុះហត្ថលេខា ឬ ក្នុងការធ្វើបិដ្ឋិលេខ មានន័យថាមនុស្សម្នាក់ប្រព្រឹត្តដោយគ្មានសិទ្ធិពិតប្រាកដ ហើយរួមទាំងការក្លែងបន្លំផង ។

**មាត្រា ១៦២.-**

មូលបត្រគឺជាប្រភេទប័ណ្ណដែលអាចលក់ដូរបាន ។

**មាត្រា ១៦៣.-**

ក្រុមហ៊ុនណាដែលតម្កល់ទុក ឬ ចែកចាយនូវផែនការអាជីវកម្ម សេចក្តីប្រកាសពីព័ត៌មានសំខាន់ ការប្រកាសពីការចុះបញ្ជី សារាចរណែនាំពីការដោះដូរ មូលបត្រ ឬក៏ឯកសារប្រហាក់ប្រហែលដែលទាក់ទងទៅនឹងការចែកចាយមូលបត្ររបស់ក្រុមហ៊ុនដល់សាធារណជន ត្រូវផ្ញើជាបន្ទាន់ទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មនូវច្បាប់ចម្លងនៃឯកសារទាំងអស់នោះ ។

**មាត្រា ១៦៤.-**

មូលបត្រស្ថិតក្នុងទម្រង់ចុះបញ្ជី ប្រសិនបើមូលបត្រនោះ :

ក-បញ្ជាក់ច្បាស់លាស់នូវបុគ្គលដែលមានសិទ្ធិលើមូលបត្រនិងបញ្ជាក់ថាការផ្ទេរនោះ អាចកត់ចូលទៅក្នុងបញ្ជីមូលបត្របាន ។

ខ-មានភ្ជាប់ប្រកាសថា វាស្ថិតក្នុងបញ្ជីមូលបត្រ ។

**មាត្រា ១៦៥.-**

កាតព្វកិច្ចបំណុលស្ថិតក្នុងទម្រង់បញ្ញាដែលចែងថា កាតព្វកិច្ចបំណុលគឺអាចទូទាត់បានទៅតាមបំណង ឬ ចែងថាកាតព្វកិច្ចបំណុល ត្រូវចាត់ចែងទៅឱ្យបុគ្គលម្នាក់ដែលសម្គាល់បាន ។

**មាត្រា ១៦៦.-**

មូលបត្រស្ថិតក្នុងទម្រង់ "គាហកៈ" ប្រសិនបើមូលបត្រនោះ អាចទូទាត់ទៅឱ្យបុគ្គលណាម្នាក់ក៏បាន ។ មូលបត្រនៅក្នុងទម្រង់គាហកៈមិនមានបញ្ជាក់ឈ្មោះរបស់អ្នកកាន់កាប់ទេ ។

**មាត្រា ១៦៧.-**

រាល់អ្នកកាន់កាប់មូលបត្រមានសិទ្ធិជ្រើសរើសមូលបត្រស្របតាមច្បាប់នេះ ឬ តាមលិខិតទទួលស្គាល់ថាមិនផ្ទេរសិទ្ធិរបស់ខ្លួនក្នុងការទទួលមូលបត្រពីក្រុមហ៊ុន ។

ក្រុមហ៊ុនមិនត្រូវបោះចេញនូវមូលបត្រលើសពីមួយ ដែលបានកាន់កាប់រួមគ្នាដោយបុគ្គលច្រើននាក់ ។ ការប្រគល់នូវមូលបត្រមួយទៅឱ្យបុគ្គលម្នាក់គឺជាការគ្រប់គ្រាន់ ។

**មាត្រា ១៦៨.-**

មូលបត្រត្រូវចុះហត្ថលេខាផ្ទាល់ដៃដោយអភិបាលម្នាក់យ៉ាងតិច ហើយហត្ថលេខាបន្ថែមផ្សេងទៀត ដែលតម្រូវឱ្យមាននៅលើមូលបត្រ អាចត្រូវបានចុះហត្ថលេខាដោយត្រាឈ្មោះ ។

**មាត្រា ១៦៩.-**

នៅលើមូលបត្រដែលបោះចេញដោយក្រុមហ៊ុនត្រូវមាន :

១-នាមករណ៍របស់ក្រុមហ៊ុន ។

២- ពាក្យថា“ បានធ្វើអាជីវកម្មក្រោមច្បាប់សហគ្រាសពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា” ។

៣-ឈ្មោះរបស់បុគ្គលដែលត្រូវចេញឱ្យ ។

៤-លេខនិងប្រភេទរបស់ប័ណ្ណភាគហ៊ុននិងសេរីរបស់ប័ណ្ណភាគហ៊ុននោះ ។

៥-ដាក់ការរឹតត្បិតទៅលើការផ្ទេរ ។

នៅលើមូលបត្រចេញដោយក្រុមហ៊ុន ដែលត្រូវបានផ្តល់សិទ្ធិឱ្យបោះចេញច្រើនជាងមួយប្រភេទ ឬ មួយសេរី ត្រូវចែងឱ្យច្បាស់នូវ :

ក-សិទ្ធិ បុព្វសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌដែលភ្ជាប់ទៅនឹងប្រភេទសេរីរបស់ប័ណ្ណភាគហ៊ុននីមួយៗ ដែលបានបោះចេញ ។

ខ-ប្រភេទ ឬ សេរីនៃប័ណ្ណភាគហ៊ុនដែលបង្ហាញពីសិទ្ធិ បុព្វសិទ្ធិ ការរឹតត្បិត ឬ លក្ខខណ្ឌភ្ជាប់ ។ ក្រុមហ៊ុននឹងផ្តល់ឱ្យម្ចាស់ហ៊ុននូវរាល់តម្រូវការ និងដោយឥតគិតថ្លៃនូវឯកសារទាំងអស់ស្តីពីសិទ្ធិអាទិភាព ការរឹតត្បិត និងលក្ខខណ្ឌភ្ជាប់ទៅនឹងប្រភេទ និងសេរីនីមួយៗ ។

**មាត្រា ១៧០.-**

ក្រុមហ៊ុនត្រូវរក្សាទុកនូវបញ្ជីមូលបត្រ ដែលនៅក្នុងនោះមានកត់ត្រានូវមូលបត្រដែលក្រុមហ៊ុនបោះចេញដោយបញ្ជាក់ប្រភេទ និងសេរីរបស់មូលបត្រទាំងនោះជាអាទិ៍ :

ក-ឈ្មោះដែលរៀបតាមលំដាប់អក្សរ និងអាសយដ្ឋានក្រោយបង្អស់របស់បុគ្គលម្នាក់ៗដែលជាម្ចាស់មូលបត្រ ។

ខ-លេខមូលបត្រ ដែលកាន់កាប់ដោយម្ចាស់ហ៊ុនម្នាក់ៗ ។

គ-កាលបរិច្ឆេទ និងលក្ខណៈពិសេសនៃការចេញ និងការផ្ទេរមូលបត្រនីមួយៗ ។

**មាត្រា ១៧១.-**

ក្រុមហ៊ុនត្រូវទទួលស្គាល់ម្ចាស់មូលបត្រ ដែលបានទទួលការចុះបញ្ជីថាជាបុគ្គលដែលមានសិទ្ធិបោះឆ្នោត ទទួលលិខិតជូនដំណឹង ទទួលផលប្រយោជន៍ ទទួលភាគលាភ ឬ ការទូទាត់សងស្របតាមមូលបត្រ និងអនុវត្តរាល់សិទ្ធិរបស់ម្ចាស់មូលបត្រនោះ ។

ក្នុងករណីដែលមានការដាក់ការរឹតត្បិតទៅលើការផ្ទេរមូលបត្រ និងមូលបត្រដែលត្រូវបានផ្ទេរចេញ ឬ បញ្ជូនទៅបុគ្គលម្នាក់ដែលមិនមែនជាម្ចាស់មូលបត្រ បុគ្គលនោះត្រូវផ្តល់ភស្តុតាងអំពីការអនុញ្ញាតឱ្យខ្លួនអនុវត្តសិទ្ធិ ឬ បុព្វសិទ្ធិស្របតាមមូលបត្រ ។ ក្រុមហ៊ុនត្រូវទទួលស្គាល់បុគ្គលនោះថាជាអ្នកត្រូវបានផ្តល់សិទ្ធិក្នុងការអនុវត្តសិទ្ធិ ឬ បុព្វសិទ្ធិទាំងឡាយនោះ ។

**មាត្រា ១៧២.-**

ប្រសិនបើមានអនីតិជនម្នាក់ ដែលស្ថិតក្រោមអាណាព្យាបាលអនុវត្តសិទ្ធិជាម្ចាស់មូលបត្ររបស់ក្រុមហ៊ុនអនីតិជន ឬ តំណាងរបស់អនីតិជននោះមិនអាចបដិសេធសកម្មភាពរបស់ខ្លួនបានឡើយ ។

**មាត្រា ១៧៣.-**

កាលណាមូលបត្រមួយត្រូវផ្ទេរចេញ ឬ បញ្ជូនទៅបុគ្គលម្នាក់ដែលមិនមែនជាអ្នកមានឈ្មោះក្នុងបញ្ជីភាគហ៊ុន បុគ្គលនោះត្រូវមានសិទ្ធិក្លាយជា ឬ ចាត់ទុកជាអ្នកកាន់កាប់ដូចដែលបានចុះក្នុងបញ្ជីភាគហ៊ុនដែរ ប្រសិនបើបុគ្គលនោះបានតម្កល់ទុកនូវមូលបត្រដែលខ្លួនមានសិទ្ធិកាន់កាប់បានធ្វើជាម្ចាស់នោះ ។

ឯកសារតម្កល់ទុកនោះមាន :

ក-ឯកសារច្បាប់ដើមរបស់សារការី ឬ ឯកសារដើម ឬ ឯកសារដែលបញ្ជាក់ពីតុលាការ ឬ លិខិតស្នាមរដ្ឋបាលទាំងឡាយ ។

ខ-លិខិតបញ្ជាក់ភស្តុតាងអំពីការផ្ទេរមូលបត្រក្នុងនាមជាអ្នកកាន់កាប់ម្នាក់ដែលបានចុះក្នុងបញ្ជីពាណិជ្ជកម្ម :

-ដោយតំណាងស្របច្បាប់របស់អនីតិជន បុគ្គលអសមត្ថភាព ឬ បុគ្គលដែលបាត់ខ្លួន

-ដោយអ្នកជម្រះបញ្ជី ឬ

-ដោយអ្នកដែលបានទទួលទំនុកចិត្តក្នុងការគ្រប់គ្រងក្រុមហ៊ុនក្ស័យធន

**មាត្រា ១៧៤.-**

នៅក្នុងបណ្តឹងពាក់ព័ន្ធលើមូលបត្រ :

ក-រាល់ការចុះហត្ថលេខាលើមូលបត្រ ឬ ជាបិដ្ឋិលេខក្នុងករណីចាំបាច់ គឺត្រូវបានទទួលស្គាល់ លើកលែងតែមានការតវ៉ាបដិសេធនីជាក់លាក់ ។

ខ-ហត្ថលេខានៅលើមូលបត្រគឺត្រូវបានសន្មតថាត្រឹមត្រូវ និងមានការអនុញ្ញាត ។ ប៉ុន្តែប្រសិនបើប្រសិទ្ធភាពនៃហត្ថលេខា ត្រូវបានចោទជាបញ្ហាបន្ទុកនៃការរកភស្តុតាងគឺស្ថិតនៅលើភាគីប្តឹងតវ៉ា ។

គ-ប្រសិនបើហត្ថលេខាត្រូវបានទទួលស្គាល់ថាត្រឹមត្រូវ ឬ ត្រូវបានធ្វើឡើងរួចហើយ ការបង្ហាញមូលបត្រអាចផ្តល់សិទ្ធិឱ្យអ្នកកាន់កាប់គ្រប់គ្រងលើមូលបត្រនោះ លើកលែងតែភាគីចុងចោទបង្ហាញភស្តុតាងផ្ទុយ ឬ កង្វះខាតលើសុពលភាពមូលបត្រ ។

ឃ-បើភាគីចុងចោទលើកឡើងនូវភស្តុតាងផ្ទុយ ឬ ភាពមិនពេញលក្ខណៈនៃមូលបត្រ ភាគីដើមចោទត្រូវបង្ហាញភស្តុតាងផ្ទុយ ឬ ភាពមិនពេញលក្ខណៈនោះទៅវិញ ។

**មាត្រា ១៧៥.-**

លើកលែងតែមានការព្រមព្រៀងផ្សេង និងអនុលោមទៅតាមច្បាប់ដោយឡែក ឬបញ្ញត្តិពាក់ព័ន្ធណាផ្សេងទៀត បុគ្គលដែលច្បាប់អនុញ្ញាតអាចចេញលក់មូលបត្រដែល

បោះចេញក្នុងទម្រង់គាហកៈ ឬដែលបានចុះឈ្មោះអ្នកទទួល ឬដែលបានធ្វើបិដ្ឋិលេខទៅឱ្យអ្នកទទួល ឬបិដ្ឋិលេខចំហ ។

**មាត្រា ១៧៦.-**

លក្ខខណ្ឌនៃមូលបត្រដែលមានចែងនៅលើមូលបត្រ និងលក្ខខណ្ឌនៃមូលបត្រដោយយោងតាមឯកសារផ្សេងត្រូវឱ្យស្របគ្នា ។ ក្នុងករណីដែលលក្ខខណ្ឌទាំងពីរមិនស្របគ្នា លក្ខខណ្ឌដែលមានចែងលើមូលបត្រត្រូវបានចាត់ទុកថា ជាបានការ ។

ចំពោះអ្នកទិញដោយសុទ្ធចិត្ត ទោះជាមូលបត្រនោះមានលក្ខណៈមិនប្រក្រតីក៏ដោយ ក៏ក្រុមហ៊ុនត្រូវតែទទួលស្គាល់សិទ្ធិជាម្ចាស់មូលបត្រដែរ ។

មូលបត្រមានសុពលភាពចំពោះអ្នកទិញដោយសុទ្ធចិត្ត បើអ្នកទិញនោះមិនបានដឹងពីភាពមិនប្រក្រតីនៃមូលបត្រនោះ ។

**មាត្រា ១៧៧.-**

ហត្ថលេខាដែលគ្មានការអនុញ្ញាតនៅលើមូលបត្រនៅពេលមុន ឬ នៅក្នុងពេលចេញមូលបត្រគឺគ្មានប្រសិទ្ធភាពទេ ។ លើកលែងតែហត្ថលេខានោះមានប្រសិទ្ធភាពសម្រាប់អ្នកទិញ និងមិនចាំបាច់មានលិខិតជូនដំណឹងអំពីការខ្វះខាតការអនុញ្ញាតនោះទេ ប្រសិនបើការចុះហត្ថលេខានោះ ត្រូវបានធ្វើឡើងដោយបុគ្គលម្នាក់ដែលបានអនុញ្ញាតដោយអ្នកចេញប័ណ្ណ ដើម្បីចុះហត្ថលេខាលើមូលបត្រ ឬ មូលបត្រប្រហាក់ប្រហែល ។

**មាត្រា ១៧៨.-**

នៅពេលមូលបត្រមានចុះហត្ថលេខាចាំបាច់សម្រាប់បោះចេញ ឬ សម្រាប់ផ្ទេរ ប៉ុន្តែពុំទាន់មានលក្ខណៈគ្រប់គ្រាន់ ដោយប្រការណាមួយៈ

ក- បុគ្គលណាក៏អាចបំពេញនូវចន្លោះទំនេរនោះបានដែរ ដោយស្របទៅតាមសិទ្ធិរបស់បុគ្គលនោះ ។

ខ- ទោះជាការបំពេញនោះមិនគ្រប់គ្រាន់ក៏ដោយ ក៏មូលបត្រនោះចាត់ទុកជាមានលក្ខណៈពេញលេញអាចប្រើប្រាស់បាន ចំពោះអ្នកទិញដែលបានទិញពេញថ្លៃដោយមិនបានដឹងអំពីភាពមិនសុក្រឹតនោះឡើយ ។

គ-មូលបត្រដែលបានធ្វើចប់សព្វគ្រប់ហើយដែលមានការកែនោះ បើជាកែដោយក្លែងបន្លំក៏ដោយ ក៏មូលបត្រនោះនៅតែមានតម្លៃអាចអនុវត្តបាន ប៉ុន្តែការអនុវត្តនេះ ត្រូវយោងលើលក្ខខណ្ឌដើម ។

**មាត្រា ១៧៩.-**

អ្នកទទួលចុះបញ្ជីលក់ភាគហ៊ុន ឬ ផ្ទេរភាគហ៊ុនមិនទទួលខុសត្រូវចំពោះការក្លែងបន្លំមូលបត្រទេ ប្រសិនបើ :

ក-សកម្មភាពក្នុងការបោះចេញមូលបត្រស្ថិតក្នុងរង្វង់ការងារដែលបានអនុញ្ញាត ។

ខ-មានមូលហេតុត្រឹមត្រូវថាមូលបត្រនោះឋិតនៅក្នុងទម្រង់បែបបទនិងចំនួនដែលបានអនុញ្ញាតឱ្យបោះចេញ ។

**មាត្រា ១៨០.-**

នៅពេលប្រគល់មូលបត្រ អ្នកជាវទទួលសិទ្ធិពីមូលបត្រដូចអ្នកផ្ទេរមានដែរ ឬ អ្នកដែលមានការអនុញ្ញាតដើម្បីផ្ទេរ លើកលែងតែអ្នកជាវជាភាគីក្លែងបន្លំ ឬប្រព្រឹត្តអំពើល្មើសដែលប៉ះពាល់ដល់មូលបត្រមិនបានបង្ហាញអំពីសិទ្ធិកាន់កាប់ពីម្ចាស់ពិតប្រាកដ ។

**មាត្រា ១៨១.-**

បុគ្គលដែលធ្វើការផ្ទេរមូលបត្រ ទៅអ្នកជាវដោយសុចរិតធ្វើការធានាចំពោះតែ :

១-ការផ្ទេរនោះមានសុពលភាព និងត្រឹមត្រូវតាមច្បាប់ ។

២-មូលបត្រនោះត្រឹមត្រូវមិនក្លែងបន្លំ និងមិនមានការកែសំណៅដើមឡើយ ។

៣-ក្នុងករណីដែលខ្លួនមិនដឹងថាមានអ្វី ដែលអាចបង្កឱ្យខូចខាតដល់សុពលភាពរបស់មូលបត្រនោះទេ ។

អ្នកជើងសាផ្តល់ទៅអតិថិជនរបស់ខ្លួន ទៅអ្នកចេញមូលបត្រ និងអ្នកធានាបណ្ណ នូវការធានាដែលបានចែងក្នុងមាត្រានេះ ហើយមានសិទ្ធិ និងបុព្វសិទ្ធិជាអ្នកធានាស្ថិតក្រោមមាត្រានេះ ។ ការធានាទាំងនោះដែលសំដៅផ្តល់ប្រយោជន៍ដល់អ្នកជើងសាដែលធ្វើសកម្មភាពក្នុងឋានៈជាភ្នាក់ងារម្នាក់គឺបន្ថែមទៅលើការធានាដែលបានទទួលពីអតិថិជន និងការធានាដែលសំដៅផ្តល់ប្រយោជន៍ដល់អតិថិជន ។

**មាត្រា ១៨២.-**

នៅពេលមូលបត្រមួយស្ថិតក្នុងទម្រង់ចុះបញ្ជី ដែលត្រូវផ្ទេរកម្មសិទ្ធិទៅអ្នកទិញម្នាក់ដោយពុំទាន់មានបិដ្ឋិលេខ អ្នកទិញនោះនឹងក្លាយជាអ្នកទិញពិតប្រាកដដរាបណាបិដ្ឋិលេខត្រូវបានផ្តល់ឱ្យ ។

ទោះជាការផ្ទេរកម្មសិទ្ធិបានបំពេញសព្វគ្រប់ នៅពេលបញ្ចេញមូលបត្រក៏ដោយ ក៏អ្នកទិញមានសិទ្ធិទាមទារចំពោះអ្នកផ្ទេរកម្មសិទ្ធិនោះ ឱ្យផ្តល់ជូននូវបិដ្ឋិលេខជាចាំបាច់ ។

**មាត្រា ១៨៣.-**

បិដ្ឋិលេខមូលបត្រនៅក្នុងទម្រង់ចុះបញ្ជីកើតឡើងនៅពេលដែលបុគ្គលមានសិទ្ធិចុះហត្ថលេខាលើមូលបត្រ ឬលើឯកសារដោយឡែកលើការផ្តល់សិទ្ធិ ឬការផ្ទេរកម្មសិទ្ធិមូលបត្រនោះ ឬចុះហត្ថលេខាផ្តល់សិទ្ធិដើម្បីចាត់ចែង ឬផ្ទេរកម្មសិទ្ធិមូលបត្រនោះ ។ បិដ្ឋិលេខមូលបត្រមានលក្ខណៈដូចតទៅ :

-បិដ្ឋិលេខអាចជាលក្ខណៈពិសេស ឬ បិដ្ឋិលេខចំហ

-បិដ្ឋិលេខចំហរួមមានទាំងបដ្ឋិលេខអ្នកកាន់កាប់ផង

-បិដ្ឋិលេខពិសេសបញ្ជាក់ពីបុគ្គលដែលមូលបត្រត្រូវផ្ទេរទៅឱ្យ ឬបញ្ជាក់ពីសិទ្ធិរបស់បុគ្គលដែលមានសិទ្ធិក្នុងការផ្ទេរមូលបត្រនោះ ។

ម្ចាស់មូលបត្រអាចប្តូរបិដ្ឋិលេខចំហមួយទៅជាបិដ្ឋិលេខពិសេសមួយបាន ។

នៅក្នុងផ្នែកនេះបុគ្គលដែលមានសិទ្ធិធ្វើបិដ្ឋិលេខគឺ :

១-ជាបុគ្គលដែលបានបញ្ជាក់តាមរយៈមូលបត្រ ឬតាមរយៈបិដ្ឋិលេខពិសេស ដែលមានសិទ្ធិលើមូលបត្រ ។

២-ជាអ្នកតំណាងស្របច្បាប់ ប្រសិនបើបុគ្គលដែលបានចែងនៅក្នុងចំណុច ១ គឺជាបុគ្គលម្នាក់គ្មានលទ្ធភាពអនុវត្តពាណិជ្ជកិច្ចបានដោយមូលហេតុណាមួយ ។

៣-ជាបុគ្គលដែលមានសិទ្ធិចុះហត្ថលេខាតាមច្បាប់ជាធរមាន ឬ តាមលិខិតប្រគល់សិទ្ធិ ។

៤-ជាភ្នាក់ងារដែលបានទទួលការអនុញ្ញាតក្នុងន័យថាបុគ្គលដែលបានរៀបរាប់នៅក្នុងចំណុច (១) ដល់ចំណុច (៣) អាចធ្វើសកម្មភាពតាមរយៈភ្នាក់ងារបាន ។

**មាត្រា ១៨៤.-**

តាមរយៈបិដ្ឋិលេខរបស់ខ្លួន អ្នកធ្វើបិដ្ឋិលេខត្រូវបានសន្មតថាគ្មានកាតព្វកិច្ចធានាថាមូលបត្រនោះនឹងត្រូវបានទទួលស្គាល់ដោយអ្នកចេញមូលបត្រនោះទេ លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ ។

បិដ្ឋិលេខតែមួយផ្នែកនៃឯកតានៅលើមូលបត្រ ដែលអ្នកចេញបានបញ្ជាក់ថាអាចឱ្យមានការផ្ទេរដាច់ដោយឡែកពីគ្នាបានគឺមានប្រសិទ្ធភាពក្នុងការធ្វើបិដ្ឋិលេខបន្តទៅលើផ្នែកដទៃទៀតបាន ។

**មាត្រា ១៨៥.-**

បិដ្ឋិលេខពិសេស ឬបិដ្ឋិលេខចំហលើមូលបត្រមួយមិនអាចចាត់ទុកជាការផ្ទេរបានទេ បើសិនជាគ្មានការប្រគល់មូលបត្រដែលមានបិដ្ឋិលេខនោះទេ ។ បិដ្ឋិលេខចុះនៅលើឯកសារដោយឡែកអាចចាត់ទុកជាការផ្ទេរបានលុះត្រាតែមានការប្រគល់មូលបត្រផង និងឯកសារដោយឡែកនោះផង ។

**មាត្រា ១៨៦.-**

បិដ្ឋិលេខនៃមូលបត្រនៅក្នុងទម្រង់គាហកៈ មិនប៉ះពាល់ដល់សិទ្ធិនៃការចុះបញ្ជីរបស់អ្នកកាន់កាប់ភាគហ៊ុនឡើយ ។

**មាត្រា ១៨៧.-**

ម្ចាស់មូលបត្រអាចតវ៉ាពីសុពលភាពនៃបិដ្ឋិលេខទៅនឹងអ្នកចេញមូលបត្រ ឬទៅអ្នកទិញផ្សេងទៀតដែលមានឆន្ទៈល្អក្នុងការទទួលមូលបត្រថ្មី ដែលត្រូវបោះចេញ ឬចុះបញ្ជីផ្ទេរជាថ្មី ។

**មាត្រា ១៨៨.-**

អ្នកចេញមូលបត្រណា ដែលចុះបញ្ជីលើការផ្ទេរកម្មសិទ្ធិមូលបត្រ ដែលមានបិដ្ឋិលេខមិនត្រឹមត្រូវ អ្នកចេញមូលបត្រនោះត្រូវទទួលខុសត្រូវចំពោះការចុះបញ្ជីដែលមិនត្រឹមត្រូវនោះ ។

**មាត្រា ១៨៩.-**

បុគ្គលដែលធានាលើហត្ថលេខារបស់អ្នកធ្វើបិដ្ឋិលេខលើមូលបត្រធានាថាការចុះហត្ថលេខានៅពេលនោះជា :

១-ហត្ថលេខាត្រឹមត្រូវ ។

២-អ្នកចុះហត្ថលេខាគឺជាបុគ្គលដែលមានសិទ្ធិធ្វើបិដ្ឋិលេខ ។

៣-អ្នកចុះហត្ថលេខាមានសិទ្ធិស្របច្បាប់ក្នុងការចុះហត្ថលេខា ។

ប៉ុន្តែបុគ្គលដែលធានាលើហត្ថលេខារបស់អ្នកធ្វើបិដ្ឋិលេខមិនធានាអះអាងនូវសិទ្ធិស្របច្បាប់នៃការផ្ទេរដោយឡែកណាមួយឡើយ ។

អ្នកចេញមូលបត្រ មិនត្រូវតម្រូវយកការធានាលើបិដ្ឋិលេខជាលក្ខខណ្ឌសម្រាប់ការចុះបញ្ជីលើការផ្ទេរកម្មសិទ្ធិឡើយ ។

**មាត្រា ១៩០.-**

ការប្រគល់មូលបត្រទៅឱ្យអ្នកជាវកើតឡើងនៅពេលដែល :

ក-អ្នកជាវម្នាក់ ឬ បុគ្គលម្នាក់ ដែលបានចាត់តាំងដោយអ្នកជាវនោះ ទទួលកាន់កាប់មូលបត្រ ។

ខ-អ្នកជើងសារបស់អ្នកជាវទទួលកាន់កាប់មូលបត្រ ដែលមានបិដ្ឋិលេខទៅឱ្យអ្នកជាវ ឬ ដែលចេញក្នុងនាមរបស់អ្នកជាវ ។

គ-អ្នកជើងសារបស់អ្នកជាវ ធ្វើការអះអាងបញ្ជាក់អំពីការទិញទៅឱ្យអ្នកជាវ ហើយនៅក្នុងកំណត់ហេតុរបស់អ្នកជើងសាបញ្ជាក់លើអត្តសញ្ញាណរបស់មូល-បត្រជាក់លាក់មួយជារបស់អ្នកជាវនោះ ។

ឃ-យោងទៅតាមមូលបត្រ ដែលមានបញ្ជាក់អត្តសញ្ញាណ ដែលត្រូវផ្ទេរកម្មសិទ្ធិក្នុងពេលតតិយជននៅមានភាពជាម្ចាស់នៅឡើយ តតិយជននោះត្រូវបានទទួលស្គាល់ខ្លួនជាអ្នកកាន់កាប់បំណុឱ្យអ្នកជាវ ។

**មាត្រា ១៩១.-**

បើគ្មានការព្រមព្រៀងផ្សេងទេ ការលក់មូលបត្រមួយធ្វើឡើងដោយការផ្ទាស់ប្តូរ ឬ តាមរយៈអ្នកជើងសា :

១-អតិថិជនជាអ្នកលក់ ត្រូវបំពេញភារកិច្ចរបស់ខ្លួនក្នុងការផ្ទេរនៅពេលខ្លួនត្រូវផ្ទេរកម្មសិទ្ធិភាពជាម្ចាស់ទៅឱ្យអ្នកជើងសារបស់អ្នកលក់ ឬ ទៅឱ្យបុគ្គលដែលបានចាត់តាំងដោយអ្នកជើងសារបស់អ្នកលក់នោះឱ្យកាន់កាប់ជំនួសខ្លួន ។

២- អ្នកជើងសារបស់អ្នកលក់រួមមានអ្នកជើងសាជាប់ទាក់ទងដែលធ្វើសកម្មភាពឱ្យអតិថិជនជាអ្នកលក់ ត្រូវបំពេញភារកិច្ចរបស់ខ្លួន ដើម្បីធ្វើការផ្ទេរភាពជាម្ចាស់នៃមូលបត្រទៅឱ្យអ្នកជើងសារបស់អ្នកទិញ ឬ ឱ្យទៅបុគ្គលដែលបានចាត់តាំងដោយអ្នកជើងសារបស់អ្នកទិញ ឬ ដោយឥទ្ធិពលនៃភាពជាក់ស្តែងនៃការលក់ស្របតាមបទប្បញ្ញត្តិនៃការដោះដូរ ដែលបទប្បញ្ញត្តិនោះធ្វើឱ្យមានពាណិជ្ជកម្មកើតឡើង ។

ប្រសិនបើគ្មានការព្រមព្រៀងផ្សេងទេ ភារកិច្ចរបស់អ្នកផ្ទេរកម្មសិទ្ធិក្នុងការប្រគល់មូលបត្រទៅឱ្យអ្នកជាវក្រោមកិច្ចសន្យានៃការទិញគឺមិនទាន់គ្រប់គ្រាន់ទេលុះត្រាតែបុគ្គលនោះ ផ្ទេរមូលបត្រក្នុងបែបបទអាចដោះដូរបានទៅឱ្យអ្នកជាវ ឬ ឱ្យទៅបុគ្គលដែលបានប្រគល់សិទ្ធិដោយអ្នកជាវ ឬ ដោយសំអាងនូវការទទួលនឹងឮដែលត្រូវធ្វើឡើងទៅអ្នកជាវថាមូលបត្រនោះត្រូវខ្លួនកាន់កាប់ជំនួស ។

**មាត្រា ១៩២.-**

ប្រសិនបើមូលបត្រដែលត្រូវបានផ្ទេរកម្មសិទ្ធិ ដោយមិនត្រឹមត្រូវពីបុគ្គលណាមួយ ក្នុងមូលហេតុណាក៏ដោយរួមទាំងអសមត្ថភាពរបស់បុគ្គលនោះផង បុគ្គលនោះអាចធ្វើការទាមទារទៅអ្នកពាក់ព័ន្ធណាមួយ លើកលែងតែចំពោះអ្នកទិញដោយសុចរិតដើម្បី :

១-ទាមទារមកវិញនូវភាពជាម្ចាស់លើមូលបត្រនោះ ។

២-កាន់កាប់ភាពជាម្ចាស់លើមូលបត្រថ្មី បញ្ជាក់ច្បាស់នូវសិទ្ធិដូចគ្នាទាំងអស់ ឬ មួយផ្នែក ។

៣-ទាមទាររាល់ការខូចខាតទាំងឡាយ ។

ប្រសិនបើមូលបត្រ ដែលត្រូវបានផ្ទេរកម្មសិទ្ធិដោយមិនត្រឹមត្រូវដោយមូលហេតុធ្វើបិដ្ឋិលេខមិនមានការអនុញ្ញាតត្រឹមត្រូវ នៅពេលនោះម្ចាស់មូលបត្រអាចទាមទារមកវិញបាននូវភាពជាម្ចាស់នៃមូលបត្រនោះ ឬ ទាមទារឱ្យចេញមូលបត្រថ្មីមួយទៀតទោះបីចំពោះអ្នកទិញដោយសុចរិតក៏ដោយ ក្នុងករណីដែលមានភស្តុតាងបញ្ជាក់ថាបិដ្ឋិលេខនោះគ្មានប្រសិទ្ធភាពមែន ។

សិទ្ធិក្នុងការទាមទារមកវិញនូវភាពជាម្ចាស់លើមូលបត្រ ត្រូវអនុវត្តយ៉ាងជាក់លាក់ដែលការផ្ទេរកម្មសិទ្ធិត្រូវបានទប់ស្កាត់ ហើយមូលបត្រនោះត្រូវបានដកហូតយកមកតម្កល់ទុកវិញដើម្បីរង់ចាំបណ្តឹងតវ៉ា ។

**មាត្រា ១៩៣.-**

បើគ្មានការព្រមព្រៀងផ្សេងទេ អ្នកផ្ទេរកម្មសិទ្ធិត្រូវផ្តល់ឱ្យអ្នកជាវនូវភស្តុតាងអំពីសិទ្ធិក្នុងការផ្ទេររបស់ខ្លួន ឬផ្តល់នូវតម្រូវការណាមួយផ្សេងដែលចាំបាច់ដើម្បីទទួលបានការចុះបញ្ជីនូវការផ្ទេរមូលបត្រនោះ ។ ប៉ុន្តែប្រសិនបើការផ្ទេរកម្មសិទ្ធិនោះមិនមែនជាការផ្ទេរដែលមានបង់តម្លៃនោះ អ្នកផ្ទេរកម្មសិទ្ធិមិនចាំបាច់បង្ហាញភស្តុតាងដូចមានចែងខាងលើនេះទេ លុះត្រាតែអ្នកជាវបានបង់តម្លៃសមស្រប និង សោហ៊ុយចាំបាច់ផ្សេងៗទៀត ។

ប្រសិនបើអ្នកផ្ទេរកម្មសិទ្ធិខកខានក្នុងការអនុវត្ត ការទាមទារចាំបាច់របស់អ្នកជាវក្នុងរយៈពេលសមស្របមួយ ពេលនោះអ្នកទិញអាចប្រកែក ឬ បដិសេធការផ្ទេរកម្មសិទ្ធិនោះបាន ។

**មាត្រា ១៩៤.-**

មូលបត្រ ឬភាគលាភនៃផលប្រយោជន៍ផ្សេងៗមិនអាចរឹបអូសបានទេ លុះត្រាតែបុគ្គលដែលធ្វើការរឹបអូសនោះ បានទទួលសិទ្ធិជាម្ចាស់លើមូលបត្រដែលត្រូវរឹបអូសនោះ ។

**មាត្រា ១៩៥.-**

ពេលណាដែលមូលបត្រ នៅក្នុងទម្រង់ចុះបញ្ជីត្រូវធ្វើការផ្ទេរកម្មសិទ្ធិ ពេលនោះអ្នកចេញមូលបត្រ ត្រូវចុះបញ្ជីនូវការផ្ទេរកម្មសិទ្ធិនោះក្នុងករណីដូចតទៅ :

១-មូលបត្រមានបិដ្ឋិលេខរបស់បុគ្គលដែលមានសិទ្ធិធ្វើបិដ្ឋិលេខ ។

២-មានការធានាសមហេតុផលថា បិដ្ឋិលេខនោះមិនក្លែងបន្លំ ហើយមានសុពលភាព ។

៣-ច្បាប់ទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងការប្រមូលពន្ធដារត្រូវបានអនុវត្ត ។

៤-ការផ្ទេរកម្មសិទ្ធិនោះ គឺស្របតាមច្បាប់ ឬផ្ទេរទៅឱ្យអ្នកជាវពិតប្រាកដ ។

នៅពេលអ្នកចេញមូលបត្រមានភារកិច្ចចុះបញ្ជីការផ្ទេរកម្មសិទ្ធិមូលបត្រពេលនោះ អ្នកចេញមូលបត្រត្រូវទទួលខុសត្រូវចំពោះបុគ្គលដែលបានបង្ហាញមូលបត្រសម្រាប់ឱ្យចុះបញ្ជីនូវការខាតបង់ដែលកើតឡើងពីការពន្យារពេលមិនសមហេតុសមផលក្នុងការចុះបញ្ជី ឬ ពីការខកខាន ឬ ការប្រកែកក្នុងការចុះបញ្ជីលើការផ្ទេរនោះ ។

**មាត្រា ១៩៦.–**

អ្នកចេញមូលបត្រមិនទទួលខុសត្រូវចំពោះម្ចាស់មូលបត្រ ឬ បុគ្គលផ្សេងៗដែលទទួលការខាតបង់បណ្តាលមកពីការចុះបញ្ជីលើការផ្ទេរកម្មសិទ្ធិមូលបត្រឡើយ ប្រសិនបើបិដ្ឋិលេខចាំបាច់មានចារលើមូលបត្រហើយ អ្នកចេញមូលបត្រនោះបានធ្វើការយកចិត្តទុកដាក់ក្នុងការកំណត់នូវភាពគ្រប់ជ្រុងជ្រោយនៃបិដ្ឋិលេខនោះ ។

**មាត្រា ១៩៧.–**

នៅពេលមូលបត្រត្រូវបានបាត់បង់ ឬ ត្រូវបានបំផ្លាញ ហើយម្ចាស់មិនបានជូនដំណឹងជាលាយលក្ខណ៍អក្សរពីមូលហេតុទៅអ្នកចេញមូលបត្រនៅក្នុងពេលសមស្របទេ ក្រោយពីខ្លួនបានដឹងពីការបាត់បង់ ការបំផ្លាញនោះ ហើយពេលនោះអ្នកចេញមូលបត្របានចុះបញ្ជីនូវការផ្ទេរកម្មសិទ្ធិមូលបត្រនោះមុនការទទួលសេចក្តីជូនដំណឹងពីម្ចាស់មូលបត្រ ម្ចាស់មូលបត្រនោះត្រូវអស់សិទ្ធិក្នុងការទាមទារមូលបត្រថ្មីពីអ្នកចេញមូលបត្រ ។

**មាត្រា ១៩៨.–**

នៅពេលម្ចាស់មូលបត្រជូនដំណឹងថាមូលបត្រត្រូវបានបាត់បង់ ឬត្រូវបានបំផ្លាញពេលនោះអ្នកចេញមូលបត្រ ត្រូវចេញមូលបត្រថ្មីជំនួសមូលបត្រដើម ប្រសិនបើម្ចាស់មូលបត្រនោះ :

១-ស្នើសុំមុនពេលអ្នកចេញមូលបត្របានជូនដំណឹងថាមូលបត្រនោះត្រូវបានទទួលសិទ្ធិដោយអ្នកទិញពិតប្រាកដរួចទៅហើយ ។

២-យកមូលបត្រសងការខូចខាតមកបង្ហាញអ្នកចេញមូលបត្រ ។

៣-យល់ព្រមទទួលនូវរាល់លក្ខខណ្ឌតម្រូវ ដែលបានបង្គាប់ដោយអ្នកចេញមូលបត្រ ។

ក្រោយពីការចេញឱ្យនូវមូលបត្រថ្មី ក្រោមកថាខណ្ឌខាងលើ ប្រសិនបើអ្នកទិញមូលបត្រដើមពិតប្រាកដបង្ហាញមូលបត្រដើមនោះដើម្បីចុះបញ្ជីផ្ទេរកម្មសិទ្ធិ ពេលនោះអ្នកចេញមូលបត្រត្រូវចុះបញ្ជីលើការផ្ទេរកម្មសិទ្ធិនោះ ។

ក្នុងការបន្ថែមសិទ្ធិណាមួយទៅលើមូលបត្រសងការខូចខាត អ្នកចេញមូលបត្រអាចត្រូវតពិនិត្យឡើងវិញបាននូវមូលបត្រថ្មី ដែលបានចេញឱ្យពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត ។

## ង- អ្នកទទួលរក្សាទ្រព្យសម្បត្តិ និងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ

**មាត្រា ១៩៩.-**

លើកលែងតែមានការអនុញ្ញាតពីតុលាការ អ្នកទទួលរក្សាទ្រព្យសម្បត្តិមិនអាចអនុញ្ញាតឱ្យប្រកបពាណិជ្ជកិច្ចក្នុងក្រុមហ៊ុនបានឡើយ ។ អនុលោមតាមសិទ្ធិរបស់ឥណ-ទាយក អ្នកទទួលរក្សាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនអាចទទួលចំណូលអំពីទ្រព្យសម្បត្តិ និងអាចធ្វើការសងបំណុលដែលពាក់ព័ន្ធជាមួយទ្រព្យសម្បត្តិនោះ ។ អ្នកទទួលរក្សាទ្រព្យសម្បត្តិក៏អាចដឹងផងដែរពីអត្ថប្រយោជន៍នៃមូលបត្ររបស់ម្ចាស់មូលបត្រដែលបានតែងតាំងខ្លួន ។

**មាត្រា ២០០.-**

តុលាការអាចអនុញ្ញាតឱ្យអ្នកទទួលរក្សាទ្រព្យសម្បត្តិ ប្រកបពាណិជ្ជកិច្ចក្រុមហ៊ុនបានក្នុងគោលបំណងការពារមូលបត្រទាំងឡាយរបស់បុគ្គលដែលបានតែងតាំងខ្លួន ។ អ្នកទទួលរក្សាទ្រព្យសម្បត្តិនោះគឺជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ។

**មាត្រា ២០១.-**

ប្រសិនបើអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ត្រូវបានតែងតាំងដោយតុលាការ ឬ ដោយលិខិតណាមួយរបស់ក្រុមហ៊ុន សិទ្ធិរបស់អភិបាលទាំងឡាយត្រូវអស់តម្លៃរហូតដល់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិនោះត្រូវបានបញ្ចប់ ។

**មាត្រា ២០២.-**

អ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬ អ្នកគ្រប់គ្រងទ្រព្យសម្បត្តិដែលបានតែងតាំងដោយតុលាការត្រូវអនុវត្តទៅតាមការណែនាំរបស់តុលាការ ។

អ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដែលបានតែងតាំងតាមសេចក្តីសម្រេចណាមួយផ្សេង ត្រូវអនុវត្តទៅតាមសេចក្តីសម្រេចនេះនិងតាមការណែនាំរបស់តុលាការ ។

**មាត្រា ២០៣.-**

អ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬ អ្នកគ្រប់គ្រងទ្រព្យសម្បត្តិត្រូវ :

១-ប្រតិបត្តិដោយស្មោះត្រង់ និងដោយបំណងល្អហើយរក្សាទុកដាក់ទ្រព្យសម្បត្តិដែលស្ថិតក្នុងការកាន់កាប់របស់ខ្លួន ឬ ធ្វើការត្រួតពិនិត្យត្រឹមត្រូវតាមរបៀបពាណិជ្ជកម្ម ។

២-ជូនដំណឹងជាបន្ទាន់ទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មអំពីការតែងតាំង និងការបំពេញសិទ្ធិរបស់ខ្លួន ។

៣-ថែរក្សា និងត្រួតពិនិត្យទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនស្របទៅតាមបញ្ជារបស់តុលាការ ឬ តាមលិខិតស្នាមដែលខ្លួនត្រូវបានតែងតាំង ។

៤-បើក និងរក្សាទុកគណនីធនាគារក្នុងនាមរបស់ខ្លួនជាអ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬ ជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសម្រាប់ទឹកប្រាក់ក្រុមហ៊ុនដែលបានមកដោយស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន ។

៥-រក្សាទុកគណនីពិស្ដារពីកិច្ចការជំនួញទាំងអស់ ដែលបានសំរេចឡើង ដោយខ្លួនឯងដែលជាអ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬ ជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ។

៦-រក្សាទុកគណនីទាំងឡាយនៃការគ្រប់គ្រង និងសម្រាប់មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មត្រួតពិនិត្យក្នុងពេលម៉ោងធ្វើអាជីវកម្ម ។

៧-រៀបចំយ៉ាងហោចណាស់ម្ដងក្នុងមួយឆមាសនូវរបាយការណ៍ហិរញ្ញវត្ថុក្រោមការគ្រប់គ្រងរបស់ខ្លួន បន្ទាប់ពីកាលបរិច្ឆេទដែលខ្លួនត្រូវបានតែងតាំង ។

៨-ផ្ដល់នូវគណនីចុងក្រោយនៃការគ្រប់គ្រង ដើម្បីបំពេញបញ្ចប់ភារកិច្ចរបស់ខ្លួន ។

**មាត្រា ២០៩.–**

តាមការស្នើសុំដោយអ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬ អ្នកទទួលគ្រប់គ្រងទ្រព្យសម្បត្តិ ឬ ការស្នើសុំដោយបុគ្គលដែលមានផលប្រយោជន៍ តុលាការត្រូវចេញបញ្ជាដោយយល់ថាគួរបញ្ចូលបន្ថែមដោយគ្មានកម្រិតនូវ :

ក-ដីកាតែងតាំង ដីកាតែងតាំងជំនួស ឬ ដីកាបញ្ចប់សិទ្ធិអ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ និងដីកាដែលឱ្យសច្ចានុម័តលើគណនីរបស់អ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬ អ្នកគ្រប់គ្រងទ្រព្យសម្បត្តិនោះ ។

ខ-ដីកាកំណត់សេចក្ដីជូនដំណឹង ដែលត្រូវផ្ដល់ដល់បុគ្គលណាម្នាក់ ឬដីកាបញ្ជូនសេចក្ដីជូនដំណឹងដល់បុគ្គលណាម្នាក់ ។

គ-ដីកាកំណត់ប្រាក់ឧបត្ថម្ភដល់អ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬ អ្នកទទួលគ្រប់គ្រងទ្រព្យសម្បត្តិ ។

ឃ-ដីកាកំណត់ទិសដៅដល់រាល់បញ្ហាទាក់ទងទៅនឹងភារកិច្ចរបស់អ្នកទទួលរក្សាទ្រព្យសម្បត្តិ ឬ អ្នកទទួលគ្រប់គ្រងទ្រព្យសម្បត្តិ ។

## ៥_ ម្ចាស់ហ៊ុន

### មាត្រា ២០៥._

មហាសន្និបាតម្ចាស់ហ៊ុន ត្រូវធ្វើឡើងនៅទីកន្លែងណាមួយក្នុងព្រះរាជាណាចក្រកម្ពុជាដែលបានចែងក្នុងលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ឬតាមការកំណត់របស់ក្រុមប្រឹក្សាភិបាល ។

មហាសន្និបាតម្ចាស់ហ៊ុនអាចធ្វើឡើងនៅក្រៅព្រះរាជាណាចក្រកម្ពុជាបាន ប្រសិនបើមានការយល់ព្រមពីម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោតទាំងអស់ ។

### មាត្រា ២០៦._

អភិបាលទាំងឡាយរបស់ក្រុមហ៊ុន ត្រូវកោះប្រជុំមហាសន្និបាតម្ចាស់ហ៊ុនប្រចាំឆ្នាំមិនឱ្យលើសពី១២ (ដប់ពីរ)ខែ ក្រោយពីក្រុមហ៊ុននោះបានបង្កើតឡើងជាផ្លូវការ ។

អភិបាលទាំងឡាយរបស់ក្រុមហ៊ុន ត្រូវកោះប្រជុំមហាសន្និបាតវិសាមញ្ញរបស់ម្ចាស់ហ៊ុននៅពេលណាមួយក៏បានតាមការចាំបាច់ ។

### មាត្រា ២០៧._

ម្ចាស់ហ៊ុនទាំងឡាយ អាចធ្វើសំណូមពរទៅអភិបាលឱ្យ កោះប្រជុំមហាសន្និបាតម្ចាស់ហ៊ុនតាមគោលបំណង ដែលបានបញ្ជាក់នៅក្នុងសំណើនោះ ។

លិខិតស្នើសុំនោះត្រូវធ្វើឡើងដោយម្ចាស់មូលបត្រ ដែលកាន់កាប់ប័ណ្ណភាគហ៊ុនមិនតិចជាង៥១ (ហាសិបមួយ)ភាគរយនៃប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនដែលបានបោះចេញ ហើយដែលមានសិទ្ធិបោះឆ្នោតក្នុងមហាសន្និបាត ។

លិខិតស្នើសុំនោះ អាចធ្វើតាមបែបបទផ្សេងៗ ដែលបានចុះហត្ថលេខាដោយម្ចាស់ហ៊ុនម្នាក់ ឬ ច្រើននាក់ ។

លិខិតសំណើនៅក្នុងកិច្ចប្រជុំ ត្រូវបញ្ជាក់នូវពាណិជ្ជកិច្ចដែលត្រូវធ្វើ ហើយត្រូវផ្ញើទៅអភិបាលម្នាក់ៗ និងទៅទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន ។

នៅពេលទទួលសំណើ អភិបាលទាំងឡាយត្រូវកោះប្រជុំមហាសន្និបាតម្ចាស់ហ៊ុន ដើម្បីពិភាក្សាកិច្ចការពាណិជ្ជកម្មដែលបានចែងនៅក្នុងលិខិតស្នើសុំនោះ ។

ប្រសិនបើអភិបាលទាំងឡាយ មិនបានកោះប្រជុំក្នុងអំឡុងពេល២១ (ម្ភៃមួយ) ថ្ងៃ បន្ទាប់ពីបានទទួលលិខិតស្នើសុំនោះទេ ម្ចាស់ហ៊ុនណាមួយដែលបានចុះហត្ថលេខា លើលិខិតស្នើសុំនោះ អាចកោះប្រជុំមហាសន្និបាតបាន ។

លុះត្រាតែម្ចាស់ហ៊ុនទាំងឡាយបានធ្វើសេចក្តីសម្រេចនៅឯមហាសន្និបាតដែល ម្ចាស់ហ៊ុនបានកោះប្រជុំ ក្នុងករណីនេះក្រុមហ៊ុនត្រូវចេញសងម្ចាស់ហ៊ុនវិញនូវការចំណាយ លើកលែងតែម្ចាស់ហ៊ុនទាំងឡាយដែលបានសម្រេចផ្សេងពីនេះ ដែលបានធ្វើឡើង ដោយម្ចាស់ហ៊ុនដ៏សមហេតុសមផលក្នុងការស្នើសុំការកោះប្រជុំ និងការរៀបចំមហា សន្និបាតនោះ ។

**មាត្រា ២០៨.-**

ក្នុងករណីមិនអាចកោះប្រជុំ ឬ មិនអាចប្រព្រឹត្តទៅបាន ចំពោះកិច្ចប្រជុំមហា សន្និបាតម្ចាស់ហ៊ុនទៅតាមបែបបទ ដែលបានចែងក្នុងលក្ខន្តិកៈ ឬច្បាប់នេះ ឬដោយ មូលហេតុណាមួយផ្សេងទៀត អភិបាល ម្ចាស់ហ៊ុន ដែលមានសិទ្ធិបោះឆ្នោតក្នុងអង្គ ប្រជុំ ឬមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចស្នើសុំតុលាការ ឱ្យចាត់ចែងមហាសន្និបាតបាន ទៅតាមវិធីណាមួយ ដែលតុលាការពិចារណាឃើញ ថាសមស្រប ។

តុលាការអាចកំណត់កូរ៉ុមផ្សេងពីកូរ៉ុមដែលបានតម្រូវដោយលក្ខន្តិកៈ ឬ ច្បាប់ នេះចំពោះកិច្ចប្រជុំដែលបានកោះប្រជុំ ដែលបានរៀបចំនិងដែលបានប្រព្រឹត្តទៅដោយ ផ្អែកតាមមាត្រានេះ ។

**មាត្រា ២០៩.-**

ម្ចាស់ហ៊ុនដែលមានសិទ្ធិទទួលលិខិតជូនដំណឹងពីមហាសន្និបាតម្ចាស់ហ៊ុន គឺ ជាអ្នកកាន់កាប់ប័ណ្ណភាគហ៊ុន តាមប្រភេទ ឬ សេរី ដែលមានឈ្មោះក្នុងបញ្ជីមូល បត្រ នៅពេលបិទអាជីវកម្ម តាមកាលបរិច្ឆេទដែលកំណត់ទុកជាមុន ។

អភិបាលសម្រេចកាលបរិច្ឆេទដែលកំណត់ទុកមុនមិនច្រើនជាង ៥០ (ហា-សិប)ថ្ងៃ ឬតិចជាង ២០(ម្ភៃ)ថ្ងៃ មុនថ្ងៃធ្វើមហាសន្និបាតឡើយ ។

ប្រសិនបើអភិបាលមិនបានសម្រេចកាលបរិច្ឆេទកំណត់ទុកជាមុនទេ កាលបរិច្ឆេទកំណត់ទុកត្រូវធ្វើឡើង :

១- នៅពេលបិទអាជីវកម្ម មុនថ្ងៃជូនដំណឹងពីមហាសន្និបាត ។

២- នៅថ្ងៃមហាសន្និបាតត្រូវបានរៀបចំឡើង ប្រសិនបើគ្មានការជូនដំណឹងមុនទេ ។

ចំពោះកាលបរិច្ឆេទកំណត់ទុកមុនដើម្បីកំណត់ថា តើម្ចាស់ហ៊ុនមានសិទ្ធិផ្សេងទៀតឬទេ ក្រៅពីសិទ្ធិក្នុងការទទួលលិខិតជូនដំណឹងពីមហាសន្និបាត និងសិទ្ធិក្នុងការបោះឆ្នោត ។ សិទ្ធិនោះត្រូវកំណត់នៅថ្ងៃបិទអាជីវកម្ម ហើយដែលអភិបាលបានអនុម័តលើសេចក្ដីសម្រេចដែលពាក់ព័ន្ធដល់សិទ្ធិនោះ ។

**មាត្រា ២១០.-**

ប្រសិនបើអភិបាលបានកំណត់កាលបរិច្ឆេទកំណត់ទុកជាមុន អភិបាលត្រូវបោះផ្សាយលិខិតជូនដំណឹង ពីកាលបរិច្ឆេទកំណត់ទុកនោះនៅក្នុងសារព័ត៌មាន ដែលធ្វើចរាចរជាទូទៅដល់ទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន ។

អភិបាលត្រូវផ្ដល់ផងដែរ នូវលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅគ្រប់ទីផ្សារភាគហ៊ុននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលនៅទីនោះប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនមានចុះក្នុងបញ្ជីសម្រាប់លក់ដូរ ។

លិខិតជូនដំណឹងនេះត្រូវផ្ដល់ក្នុងអំឡុងពេល ០៧ (ប្រាំពីរ)ថ្ងៃ បន្ទាប់ពីអភិ-បាលបានបង្កើតកាលបរិច្ឆេទកំណត់ទុកនោះ ។

លិខិតជូនដំណឹងពីកាលបរិច្ឆេទកំណត់ទុកមិនតម្រូវឱ្យមានទេ ប្រសិនបើគ្រប់អ្នកកាន់កាប់ប័ណ្ណភាគហ៊ុនតាមប្រភេទ ឬ សេរីដែលមានឈ្មោះក្នុងបញ្ជីមូលបត្រនៅពេលបិទអាជីវកម្មនាថ្ងៃអភិបាលបង្កើតកាលបរិច្ឆេទកំណត់ទុក បានធ្វើលិខិត

ជំរាបក្រុមហ៊ុនបញ្ជាក់ពីការអនុគ្រោះរបស់ខ្លួនក្នុងការទទួលលិខិតជូនដំណឹងពីកាលបរិច្ឆេទកំណត់ទុក ។

**មាត្រា ២១១.-**

ក្រុមហ៊ុនត្រូវរៀបចំបញ្ជីឈ្មោះម្ចាស់ហ៊ុន ដែលមានសិទ្ធិទទួលលិខិតជូនដំណឹងពីការប្រជុំ ។ បញ្ជីឈ្មោះនោះ ត្រូវចាត់ចែងតាមលំដាប់អក្សរ និងបញ្ជាក់ចំនួនភាគហ៊ុនដែលបានកាន់កាប់ដោយម្ចាស់ហ៊ុនម្នាក់ៗ ។

ប្រសិនបើអភិបាលទាំងឡាយបានកំណត់កាលបរិច្ឆេទបញ្ជីត្រូវរៀបចំយ៉ាងយូរ ១០ (ដប់)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនោះ ។

ប្រសិនបើអភិបាលមិនបានកំណត់កាលបរិច្ឆេទ បញ្ជីត្រូវរៀបចំ :

១- នៅពេលបិទអាជីវកម្មនាថ្ងៃបន្ទាប់ ដែលលិខិតជូនដំណឹងត្រូវបានផ្ដល់ឱ្យជាបន្ទាន់ ។

២- នៅពេលដែលគ្មានការជូនដំណឹង បញ្ជីត្រូវរៀបចំនៅថ្ងៃបើកមហាសន្និបាត ។

**មាត្រា ២១២.-**

បុគ្គលដែលមានឈ្មោះក្នុងបញ្ជីឈ្មោះម្ចាស់ហ៊ុន មានសិទ្ធិបោះឆ្នោតសម្ដែងនៅត្រង់ប្រអប់ដែលមានឈ្មោះរបស់ខ្លួន ក្នុងអង្គប្រជុំដែលជាប់ទាក់ទងទៅនឹងបញ្ជីឈ្មោះនោះ ។

ប្រសិនបើបុគ្គលដែលមានឈ្មោះក្នុងបញ្ជីឈ្មោះម្ចាស់ហ៊ុន ដែលបានផ្ទេរកម្មសិទ្ធិភាគហ៊ុនណាមួយ ក្រោយពីកាលបរិច្ឆេទកំណត់ទុក បុគ្គលទទួលកម្មសិទ្ធិនោះត្រូវមានសិទ្ធិបោះឆ្នោតនៅក្នុងអង្គប្រជុំបាន ក្រោយពីបានបំពេញលក្ខខណ្ឌពីរ :

១- មានភាគហ៊ុនដែលមានបិដ្ឋិលេខត្រឹមត្រូវ ឬ បង្ហាញភស្តុតាងដែលបញ្ជាក់ថាខ្លួនជាម្ចាស់ភាគហ៊ុន ។

២- ទាមទារបញ្ចូលឈ្មោះរបស់ខ្លួនទៅក្នុងបញ្ជី ឱ្យបានមុនការប្រជុំយ៉ាង

យូរ១០(ដប់)ថ្ងៃ ឬ ដូចមានចែងនៅលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

**មាត្រា ២១៣.—**

ម្ចាស់ហ៊ុនម្នាក់ៗអាចពិនិត្យបញ្ជីឈ្មោះរបស់ម្ចាស់ហ៊ុនទាំងឡាយបាន :

ក- នៅទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន ឬនៅទីកន្លែងដែលរក្សាទុកបញ្ជីមូលបត្រនោះ នៅក្នុងម៉ោងធ្វើការធម្មតា ។

ខ- នៅពេលប្រជុំមហាសន្និបាតម្ចាស់ហ៊ុន បញ្ជីឈ្មោះត្រូវបានរៀបចំ ។

**មាត្រា ២១៤.—**

លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរ លើរាល់ការប្រជុំមហាសន្និបាតម្ចាស់ហ៊ុន ត្រូវផ្តល់ទៅឱ្យម្ចាស់ហ៊ុនទាំងអស់ អភិបាលទាំងអស់ និងសវនករផង ក្នុងរយៈពេល ២០(ម្ភៃ)ថ្ងៃ ទៅ ៥០(ហាសិប)ថ្ងៃ មុនកាលបរិច្ឆេទនៃមហាសន្និបាតនោះ ។

លិខិតជូនដំណឹងពីការប្រជុំមហាសន្និបាត ម្ចាស់ហ៊ុនត្រូវបញ្ជាក់ពីកាលបរិច្ឆេទ របៀបវារៈ និងទីកន្លែងនៃមហាសន្និបាតនោះ ។

នៅពេលដែលមានពាណិជ្ជកិច្ចសំខាន់ ត្រូវលើកយកមកពិភាក្សានៅក្នុងអង្គប្រជុំ :

-ឯកសារពិស្តារដែលចែងអំពីខ្លឹមសារនៃពាណិជ្ជកិច្ច ដើម្បីឱ្យម្ចាស់ហ៊ុនធ្វើការវិនិច្ឆ័យដោយសមហេតុផល និង

-អត្ថបទស្តីពីសេចក្តីសម្រេចពិសេស ត្រូវដាក់ស្នើសុំការពិនិត្យនៅក្នុងកិច្ចប្រជុំនោះ ។

ការខកខានក្នុងការទទួលលិខិតជូនដំណឹងគឺមិនដកសិទ្ធិម្ចាស់ហ៊ុនក្នុងការបោះឆ្នោតនៅឯមហាសន្និបាតនោះឡើយ ។

ប្រសិនបើកិច្ចប្រជុំមហាសន្និបាតម្ចាស់ហ៊ុន ត្រូវលើកវារៈប្រជុំទៅពេលក្រោយមានរយៈពេលតិចជាង ៣០ (សាមសិប)ថ្ងៃ គឺមិនចាំបាច់ផ្តល់លិខិតជូនដំណឹងអំពី

កិច្ចប្រជុំដែលបានលើកវារៈប្រជុំនោះឡើយ ។ ម្យ៉ាងទៀតអាច ធ្វើការជូនដំណឹងដោយការប្រកាសនៅឯអង្គប្រជុំ លើកលែងតែលក្ខន្តិកៈរបស់ក្រុមហ៊ុនចែងផ្សេងពីនេះ ។

**មាត្រា ២១៥.-**

ម្ចាស់ហ៊ុន និងបុគ្គលដែលមានសិទ្ធិចូលរួមមហាសន្និបាត អាចអនុគ្រោះដល់ការខ្វះខាតពីការមិនបានទទួលលិខិតជូនដំណឹងពីមហាសន្និបាតម្ចាស់ហ៊ុននេះបាន។

ប៉ុន្តែម្ចាស់ហ៊ុន ឬ បុគ្គលនោះ នៅពេលចូលរួមប្រជុំ អាចធ្វើការជំទាស់ទៅនឹងពាណិជ្ជកិច្ច ដោយសំអាងថា មហាសន្និបាតនោះមិនបានកោះប្រជុំត្រឹមត្រូវតាមច្បាប់កំណត់ ។

**មាត្រា ២១៦.-**

ម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោតក្នុងមហាសន្និបាតប្រចាំឆ្នាំអាច :

ក- ស្នើសុំឱ្យក្រុមហ៊ុនពិនិត្យនូវសេចក្តីជូនដំណឹងពីប្រធានបទមួយ ដែលខ្លួនស្នើសុំ ដើម្បីលើកឡើងនៅក្នុងអង្គប្រជុំ ។

ខ- ពិភាក្សាវែកញែក ពីប្រធានបទមួយ ដែលសមស្របទៅនឹងសំណូមពររបស់ខ្លួន ។

**មាត្រា ២១៧.-**

កូរ៉ុមនៃម្ចាស់ហ៊ុនសម្រាប់មហាសន្និបាត គឺវត្តមាននៃអ្នកកាន់កាប់ភាគហ៊ុនភាគច្រើន ដែលមានសិទ្ធិបោះឆ្នោត មានវត្តមានដោយផ្ទាល់ ឬដោយតំណាងជាអាណត្តិគាហកៈ លើកលែងតែមានចែងផ្សេងក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

ប្រសិនបើកូរ៉ុមមានគ្រប់ចំនួននៅពេលបើកមហាសន្និបាតម្ចាស់ហ៊ុនទាំងឡាយដែលមានវត្តមាន អាចពិភាក្សានៅក្នុងអង្គប្រជុំបាន ។

ប្រសិនបើកូរ៉ុមមិនមានគ្រប់ចំនួនក្នុងពេលបើកមហាសន្និបាតទេ ម្ចាស់ហ៊ុនដែលមានវត្តមានអាចលើកវារកាលប្រជុំនោះទៅពេលក្រោយ និងទីកន្លែងកំណត់មួយ

ប៉ុន្តែមហាសន្និបាតដែលបានលើកវារៈប្រជុំនោះ មិនត្រូវបានអនុញ្ញាតឱ្យពិភាក្សាលើកិច្ចការជំនួញណាមួយបានឡើយ ។

**មាត្រា ២១៨.-**

រាល់សមាជិកហ៊ុនជាម្ចាស់ប័ណ្ណភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត ឬ អាណត្តិគាហកៈរបស់ខ្លួន មានសិទ្ធិចូលរួម និងបោះឆ្នោត នៅក្នុងកិច្ចប្រជុំទៅតាមសិទ្ធិបោះឆ្នោត ដែលមានសម្រាប់ភាគហ៊ុនរបស់ខ្លួន ។

ក្នុងករណីបុគ្គលពីរនាក់ ឬច្រើននាក់កាន់កាប់ភាគហ៊ុនរួមគ្នា ហើយបុគ្គលម្នាក់ក្នុងចំណោមអ្នកទាំងនោះ មានវត្តមានក្នុងមហាសន្និបាតម្ចាស់ហ៊ុន អ្នកនោះអាចបោះឆ្នោតបាន ទោះជាអវត្តមានអ្នកឯទៀតក៏ដោយ ។

ប្រសិនបើមានបុគ្គលពីរនាក់ ឬ ច្រើននាក់ក្នុងចំណោមគាហកៈទាំងនោះ មានវត្តមានដោយផ្ទាល់ ឬ ដោយអាណត្តិគាហកៈរបស់ខ្លួន ពួកគេអាចបោះឆ្នោតសម្រាប់មួយសំឡេងលើភាគហ៊ុនដែលបានកាន់កាប់រួមគ្នានោះ ។

**មាត្រា ២១៩.-**

រាល់ម្ចាស់ហ៊ុនអាចផ្តល់សិទ្ធិ ឱ្យរូបវន្តបុគ្គលណាមួយផ្សេងដើម្បីធ្វើជាតំណាង និងដើម្បីបោះឆ្នោតក្នុងនាមជាអាណត្តិគាហកៈ ជំនួសខ្លួនបាននៅក្នុងកិច្ចប្រជុំ ។ ការប្រគល់សិទ្ធិត្រូវធ្វើជាលាយលក្ខណ៍អក្សរ មានចុះហត្ថលេខាដោយម្ចាស់ហ៊ុន ហើយត្រូវមានកាលបរិច្ឆេទ ។

ឯកសារប្រគល់សិទ្ធិ មិនត្រូវមានសុពលភាពលើសពី ០១ (មួយ)ឆ្នាំឡើយ បន្ទាប់ពីកាលបរិច្ឆេទនៃហត្ថលេខាលើលិខិតប្រគល់សិទ្ធិនោះ ឬ សម្រាប់រយៈពេលខ្លីជាងនេះ ដែលឯកសារប្រគល់សិទ្ធិនោះបានបញ្ជាក់ ។

ម្ចាស់ហ៊ុនមួយចំនួន អាចព្រមព្រៀងក្នុងចំណោមពួកគេជាលាយលក្ខណ៍អក្សរ ដើម្បីបញ្ចេញសំឡេងឆ្នោតនៃភាគហ៊ុនតាមវិធីណាមួយ ។

**មាត្រា ២២០.-**

ការបោះឆ្នោតជ្រើសរើសអភិបាល និងសេចក្តីសម្រេចលើប្រធានបទផ្សេងៗ ដែលបានផ្តល់សំឡេងឆ្នោត ដោយម្ចាស់ហ៊ុនត្រូវធ្វើតាមសន្លឹកឆ្នោតសម្ងាត់ លុះត្រាតែលក្ខន្តិកៈរបស់ក្រុមហ៊ុនចែងផ្សេងពីនេះ ។

**មាត្រា ២២១.-**

សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ដែលមានចុះហត្ថលេខារបស់ម្ចាស់ហ៊ុនទាំងអស់ ដែលមានសិទ្ធិបោះឆ្នោត មានសុពលភាពដូចគ្នានឹងសេចក្តីសម្រេច ដែលបានអនុម័តនៅឯមហាសន្និបាតម្ចាស់ហ៊ុនដែរ ។

សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ទាក់ទងនឹងប្រធានបទទាំងឡាយ ដែលពាក់ព័ន្ធទៅនឹងមហាសន្និបាតម្ចាស់ហ៊ុន ដែលបានចុះហត្ថលេខាដោយម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោតទាំងអស់ គឺរួចផុតអំពីលក្ខខណ្ឌតម្រូវនៃច្បាប់នេះ ដែលទាក់ទងទៅនឹងមហាសន្និបាតម្ចាស់ហ៊ុន ។

ឯកសារនៃជាសេចក្តីសម្រេចត្រូវរក្សាទុក ដោយមានភ្ជាប់ជាមួយកំណត់ហេតុមហាសន្និបាតម្ចាស់ហ៊ុននោះ ។

**មាត្រា ២២២.-**

ម្ចាស់ហ៊ុនណាដែលមិនបានទទួលលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរពីកិច្ចប្រជុំ ហើយមានតឹកតាងសមហេតុសមផលផង ម្ចាស់ហ៊ុននោះមានសិទ្ធិប្តឹងសុំទៅតុលាការ ដើម្បីទាត់ចោលសេចក្តីសម្រេចណាមួយ ដែលធ្វើឡើងនៅឯកិច្ចប្រជុំនោះ ។

ក្រុមហ៊ុន ម្ចាស់ហ៊ុន ឬ អភិបាល អាចស្នើសុំតុលាការឱ្យដោះស្រាយការខ្វែងគំនិតគ្នា ដែលពាក់ព័ន្ធដល់ការបោះឆ្នោត ឬ ការតែងតាំងអភិបាល ឬ សវនករនៃក្រុមហ៊ុននោះ ។

**មាត្រា ២២៣.-**

កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរស្របច្បាប់មួយ រវាងម្ចាស់ហ៊ុនទាំងអស់របស់ក្រុមហ៊ុន ដែលដាក់កម្រិតអំណាចទាំងស្រុង ឬ មួយផ្នែករបស់អភិបាលក្នុងការគ្រប់គ្រងអាជីវកម្ម និងកិច្ចការរបស់ក្រុមហ៊ុន គឺមានសុពលភាព ។

អ្នកទទួលការផ្ទេរភាគហ៊ុនដែលផ្អែកតាមការព្រមព្រៀងនោះជាឯកច្ឆន្ទរបស់ម្ចាស់ហ៊ុន ត្រូវចាត់ទុកជាភាគីនៃកិច្ចព្រមព្រៀងនោះ ។

ម្ចាស់ហ៊ុនដែលជាភាគីនៃកិច្ចព្រមព្រៀងជាឯកច្ឆន្ទបានទទួលនូវសិទ្ធិ ភារកិច្ចទាំងអស់របស់អភិបាលក្រុមហ៊ុន ដើម្បីគ្រប់គ្រងជំនួញ និងកិច្ចការក្រុមហ៊ុន ដែលមានទំនាក់ទំនងទៅនឹងកិច្ចព្រមព្រៀងនោះ ។ អភិបាលត្រូវបំពេញភារកិច្ច និង ការទទួលខុសត្រូវរបស់ខ្លួនតាមកិច្ចព្រមព្រៀងជាឯកច្ឆន្ទរបស់ម្ចាស់ហ៊ុន ។

កិច្ចព្រមព្រៀងជាឯកច្ឆន្ទរបស់ម្ចាស់ហ៊ុន ត្រូវធ្វើឡើងដោយសមាជិកហ៊ុន ។

កិច្ចព្រមព្រៀងជាឯកច្ឆន្ទរបស់ម្ចាស់ហ៊ុន ត្រូវរក្សាទុកក្នុងកំណត់ហេតុរបស់ក្រុមហ៊ុនដូចដែលបានចែងក្នុងមាត្រា ១០៩ ។

កិច្ចព្រមព្រៀងជាឯកច្ឆន្ទរបស់ម្ចាស់ហ៊ុន ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរនៅលើប័ណ្ណភាគហ៊ុន ។

## ឈ- របាយការណ៍ហិរញ្ញវត្ថុ

**មាត្រា ២២៤.-**

អភិបាលត្រូវបង្ហាញរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ នៅក្នុងមហាសន្និបាតម្ចាស់ហ៊ុនប្រចាំឆ្នាំ ។ របាយការណ៍នោះត្រូវមានទាំង :

ក- របាយការណ៍ហិរញ្ញវត្ថុ ដែលប្រៀបធៀបរវាងឆ្នាំសារពើពន្ធបច្ចុប្បន្ន និងឆ្នាំសារពើពន្ធឆ្នាំមុន ។ នៅក្នុងឆ្នាំដំបូងនៃអត្ថិភាពរបស់ក្រុមហ៊ុនរបាយការណ៍ហិរញ្ញវត្ថុត្រូវចាប់ផ្តើមពិនិត្យពីពេលក្រុមហ៊ុនមានអត្ថិភាព និងបញ្ចប់នៅកាលបរិច្ឆេទមិនលើសពី ៦ (ប្រាំមួយ)ខែ មុនមហាសន្និបាតប្រចាំឆ្នាំ ។

ខ- របាយការណ៍របស់សវនករ ។

គ- ព័ត៌មានផ្សេងទៀត ដែលធ្វើទៅតាមស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងលទ្ធផលដែលទទួលបានពីប្រតិបត្តិការរបស់ក្រុមហ៊ុន ដែលតម្រូវដោយលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ឬ កិច្ចព្រមព្រៀងជាឯកច្ឆន្ទនៃម្ចាស់ហ៊ុន ។

**មាត្រា ២២៥.-**

យោងតាមសំណើរបស់ខ្លួន ម្ចាស់ហ៊ុន ភ្នាក់ងារ និងអ្នកតំណាងស្របច្បាប់របស់ខ្លួន អាចត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ នៅក្នុងម៉ោងធ្វើការធម្មតារបស់ក្រុមហ៊ុន និងអាចដកស្រង់យករបាយការណ៍នោះបាន ដោយមិនគិតថ្លៃ ។

**មាត្រា ២២៦.-**

អភិបាលទទួលយល់ព្រមលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ហើយការយល់ព្រមនោះត្រូវមានហត្ថលេខារបស់អភិបាលម្នាក់ ឬ ច្រើននាក់ ។

ក្រុមហ៊ុនមិនត្រូវចេញឱ្យបោះផ្សាយ ឬ ធ្វើចរាចរឯកសារនៃរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំបានឡើយ ។ ក្រុមហ៊ុនអាចធ្វើកិច្ចការខាងលើបាន លុះត្រាតែរបាយការណ៍ហិរញ្ញវត្ថុនោះមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល និង ត្រូវអមដោយរបាយការណ៍របស់សវនករផង ។

**មាត្រា ២២៧.-**

ក្រុមហ៊ុនត្រូវបញ្ជូនឯកសាររបាយការណ៍ហិរញ្ញវត្ថុនិងឯកសារស្វែងយល់ទាំងឡាយទៅគ្រប់ម្ចាស់ហ៊ុនយ៉ាងយូរ ២១ (ម្ភៃមួយ)ថ្ងៃ មុនមហាសន្និបាតម្ចាស់ហ៊ុនប្រចាំឆ្នាំ ឬមុនការចុះហត្ថលេខាលើសេចក្តីសម្រេចក្នុងមហាសន្និបាតប្រចាំឆ្នាំនោះ លើកលែងតែម្ចាស់ហ៊ុនណាដែលបានជូនដំណឹងទៅក្រុមហ៊ុនជាលាយលក្ខណ៍អក្សរថាខ្លួនមិនត្រូវការឯកសារទាំងនោះទេ ។

**មាត្រា ២២៨.-**

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលបានបោះចេញមូលបត្រប្រភេទណាមួយទៅសាធារណជន ដែលត្រូវបានកាន់កាប់ដោយបុគ្គលលើសពីម្នាក់ ត្រូវធ្វើ

ឯកសាររបាយការណ៍ហិរញ្ញវត្ថុ និងឯកសារពាក់ព័ន្ធទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។

របាយការណ៍ និងឯកសារទាំងឡាយ ត្រូវផ្ញើទៅគ្រប់ម្ចាស់ហ៊ុនយ៉ាងយូរ ២១ (ម្ភៃមួយ)ថ្ងៃ មុនមហាសន្និបាតម្ចាស់ហ៊ុនប្រចាំឆ្នាំ ឬ ផ្ញើជាបន្ទាន់ បន្ទាប់ពីការចុះហត្ថលេខាលើសេចក្តីសម្រេចក្នុងមហាសន្និបាតប្រចាំឆ្នាំនោះ ។

**មាត្រា ២២៩.–**

ម្ចាស់ហ៊ុនត្រូវតែងតាំងសវនករមួយរូប ដោយសេចក្តីសម្រេចសាមញ្ញនៅក្នុងមហាសន្និបាតម្ចាស់ហ៊ុនប្រចាំឆ្នាំលើកទីមួយ និងនៅមហាសន្និបាតប្រចាំឆ្នាំនីមួយៗ ។

សវនករ ត្រូវកាន់តំណែងរហូតដល់ការបិទមហាសន្និបាតនៃឆ្នាំបន្ទាប់ ។

ប្រសិនបើសវនករថ្មីមិនបានតែងតាំងនៅក្នុងមហាសន្និបាតម្ចាស់ហ៊ុនទេ សវនករដែលកំពុងកាន់តំណែង ត្រូវបន្តរហូតដល់សវនករថ្មីត្រូវបានតែងតាំង ។

**មាត្រា ២៣០.–**

ម្ចាស់ហ៊ុននៃក្រុមហ៊ុនដែលមិនបានចេញមូលបត្រប្រភេទណាមួយទៅឱ្យសាធារណជន ឬ ដោយគ្មានមូលបត្រដែលកាន់ដោយបុគ្គលលើសពីម្នាក់ អាចធ្វើសេចក្តីសម្រេចមិនតែងតាំងសវនករបាន ។

**មាត្រា ២៣១.–**

សោហ៊ុយចំណាយសម្រាប់សវនករ អាចត្រូវបានកំណត់ឡើងដោយសេចក្តីសម្រេចសាមញ្ញរបស់ម្ចាស់ហ៊ុន ឬ បើមិនដូច្នេះទេ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល ។

**មាត្រា ២៣២.–**

ម្ចាស់ហ៊ុនទាំងឡាយអាចដកហូតសវនករពីមុខតំណែងបាន លើកលែងតែសវនករត្រូវបានតែងតាំងដោយតុលាការ ឬ ដោយសេចក្តីសម្រេចសាមញ្ញនៅក្នុង

មហាសន្និបាតពិសេស ។ នៅក្នុងអង្គប្រជុំដូចគ្នានោះ ម្ចាស់ហ៊ុនអាចតែងតាំងសវនករជំនួសបាន ។

នៅពេលណា ដែលមានភាពទំនេរនៃតំណែងសវនករ ក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំមហាសន្និបាតពិសេសនៃម្ចាស់ហ៊ុន ដើម្បីបំពេញភាពនៅទំនេរនោះ ដោយត្រូវធ្វើឡើងក្នុងរយៈពេល ២១ (ម្ភៃមួយ)ថ្ងៃ បន្ទាប់ពីមានភាពទំនេរនោះ ។

សវនករដែលត្រូវតែងតាំងដើម្បីបំពេញភាពទំនេរនោះ ត្រូវកាន់កាប់តំណែងបន្តជំនួសអាណត្តិដែលមិនទាន់ផុតកំណត់របស់សវនករមុន ។

**មាត្រា ២៣៣.-**

ប្រសិនបើក្រុមហ៊ុនមិនទាន់មានសវនករ តាមការស្នើសុំរបស់ម្ចាស់ហ៊ុន ឬ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម តុលាការអាចតែងតាំង និងដាក់កំណត់ដោះស្រាយចំណាយសម្រាប់សវនករ ដែលបានកាន់តំណែងរហូតដល់សវនករថ្មីត្រូវបានតែងតាំងដោយម្ចាស់ហ៊ុនទាំងឡាយ ។

**មាត្រា ២៣៤.-**

សវនករត្រូវធ្វើការត្រួតពិនិត្យ លើចំណុចដែលខ្លួនយល់ថាចាំបាច់ដើម្បីរាយការណ៍ជូនម្ចាស់ហ៊ុនទាំងឡាយ លើរបាយការណ៍ហិរញ្ញវត្ថុដែលបានតម្រូវដោយច្បាប់នេះ ។

តាមការស្នើសុំរបស់សវនករនៃក្រុមហ៊ុនមួយ អភិបាលមុន ឬ អភិបាលបច្ចុប្បន្ន អ្នកគ្រប់គ្រងក្រុមហ៊ុន បុគ្គលិក ឬ ភ្នាក់ងាររបស់ក្រុមហ៊ុន ត្រូវផ្តល់ព័ត៌មានការបកស្រាយបំភ្លឺ និងសៀវភៅបញ្ជី និងកំណត់ហេតុទាំងឡាយ ដែលសវនករនោះចាត់ទុកជាការចាំបាច់សម្រាប់ការបំពេញមុខងាររបស់គេ ។

សវនកររបស់ក្រុមហ៊ុន មានសិទ្ធិទទួលលិខិតជូនដំណឹងនៃមហាសន្និបាត ម្ចាស់ហ៊ុន និងចូលរួមដើម្បីដឹងឮនូវកម្មវត្ថុ ដែលទាក់ទងទៅនឹងភារកិច្ចរបស់ខ្លួនជាសវនករដែលចេញសោហ៊ុយចំណាយដោយក្រុមហ៊ុន ។

ប្រសិនបើអភិបាល ឬ ម្ចាស់ហ៊ុន ទោះបីជាម្ចាស់ហ៊ុននោះគ្មានសិទ្ធិបោះឆ្នោតក្នុងអង្គប្រជុំក៏ដោយ បានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅសវនករបច្ចុប្បន្ន ឬ ពីមុនក្នុងរយៈពេលយ៉ាងតិច ១០(ដប់)ថ្ងៃ មុនមហាសន្និបាត សវនករបច្ចុប្បន្ន ឬសវនករពីមុនត្រូវចូលរួមប្រជុំដែលចេញសោហ៊ុយចំណាយដោយក្រុមហ៊ុននោះនឹងត្រូវឆ្លើយនូវសំណួរដែលពាក់ព័ន្ធទៅនឹងភារកិច្ចរបស់ខ្លួនដែលជាសវនករ ។

## ៗ- ការកែប្រែលក្ខន្តិកៈក្រុមហ៊ុន

**មាត្រា ២៣៥.-**

ក្រុមហ៊ុនមូលធន អាចធ្វើការកែប្រែលក្ខន្តិកៈរបស់ខ្លួនគ្រប់ពេលវេលាបាន ។

**មាត្រា ២៣៦.-**

ក្រុមហ៊ុនមូលធនត្រូវធ្វើការកែប្រែលក្ខន្តិកៈតាមសេចក្ដីសម្រេចពិសេស។ អ្នកកាន់កាប់ភាគហ៊ុននៃប្រភេទ ឬ ស៊េរីនៃប័ណ្ណភាគហ៊ុនមានសិទ្ធិបោះឆ្នោតជាប្រភេទ ឬ ជាស៊េរី ដាច់ដោយឡែកពីគ្នា នៅពេលដែលសេចក្ដីស្នើសុំធ្វើការកែប្រែលក្ខន្តិកៈនោះក្នុងគោលបំណង :

១- បន្ថែម កែប្រែ ឬ ដកហូតនូវសិទ្ធិ ឯកសិទ្ធិ ការរឹតត្បិតទាំងឡាយដែលភ្ជាប់ទៅនឹងប្រភេទ ឬ ស៊េរីនៃប័ណ្ណភាគហ៊ុន ។

២- បង្កើន ឬបន្ថយនូវចំនួនអតិបរមានៃប័ណ្ណភាគហ៊ុន តាមប្រភេទ ឬ ស៊េរីនៃប័ណ្ណភាគហ៊ុននោះ ។

៣- បង្កើននូវចំនួនអតិបរមានៃប័ណ្ណភាគហ៊ុន ដែលមានសិទ្ធិចំពោះប្រភេទ ឬ ស៊េរីដែលមានសិទ្ធិ ឬ ឯកសិទ្ធិស្មើ ឬ ក៏លើសពីប័ណ្ណភាគហ៊ុនរបស់អ្នកកាន់កាប់នោះ ។

៤- បង្កើតប្រភេទថ្មីនៃប័ណ្ណដែលស្មើ ឬ លើសពីប័ណ្ណភាគហ៊ុននៃប្រភេទ ឬ ស៊េរីរបស់អ្នកកាន់កាប់នោះ ។

៥- បង្កើតប្រភេទនៃប័ណ្ណភាគហ៊ុនណាមួយដែលមានសិទ្ធិ ឬ ឯកសិទ្ធិតូចជាង ឬ ស្មើ ឬ លើសប័ណ្ណភាគហ៊ុនរបស់អ្នកកាន់កាប់នោះ ។

៦- បន្ថយគណនីដើមទុនចុះបញ្ជីនៃប្រភេទ ឬ ស៊េរីនៃប័ណ្ណភាគហ៊ុនរបស់អ្នកកាន់កាប់នោះ ។

ទោះបីជាលក្ខន្តិកៈក្រុមហ៊ុនចែងថាប្រភេទ ឬ ស៊េរីនៃប័ណ្ណភាគហ៊ុនជាក់លាក់មួយគ្មានសិទ្ធិក្នុងការបោះឆ្នោតក៏ដោយ ក៏ប្រភេទ ឬស៊េរីនៃប័ណ្ណភាគហ៊ុន នោះមានសិទ្ធិបោះឆ្នោតជានិច្ចទៅតាមប្រភេទ ឬ ស៊េរីដាច់ដោយឡែកពីគ្នា លើការកែប្រែណាមួយ ទៅតាមលក្ខន្តិកៈរបស់ក្រុមហ៊ុន ដែលកែប្រែដោយផ្ទាល់ ឬ ដោយប្រយោល ឬ ប៉ះពាល់ទៅនឹង សិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌទាំងឡាយ ដែលភ្ជាប់ទៅនឹងប្រភេទ ឬ ស៊េរីនៃប័ណ្ណភាគហ៊ុនរបស់អ្នកកាន់កាប់នោះ ។

សិទ្ធិក្នុងការបោះឆ្នោតដែលបានអនុញ្ញាតក្នុងមាត្រានេះ មិនត្រូវបានលុបចោល បន្ថយ ឬ ដាក់កម្រិតដោយលក្ខន្តិកៈរបស់ក្រុមហ៊ុន ឬ តាមរបៀបណាមួយផ្សេងទៀតឡើយ ។

**មាត្រា ២៣៧.-**

លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីពីមហាសន្និបាតធ្វើការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុន ត្រូវធ្វើជូនទៅម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោត យ៉ាងតិច ២០(ម្ភៃ) ថ្ងៃ មុនពេលបើកមហាសន្និបាត ។ លិខិតជូនដំណឹងនេះត្រូវធ្វើភ្ជាប់ជាមួយសេចក្តីព្រាងអត្ថបទដែលស្នើសុំធ្វើការកែប្រែលក្ខន្តិកៈ ។

**មាត្រា ២៣៨.-**

ការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុន អាចធ្វើបានចំពោះ :

ក- ការផ្លាស់ប្តូរនាមករណ៍ក្រុមហ៊ុន ។

ខ- ការបន្ថែម ការបន្ថយ ឬការផ្លាស់ប្តូរគោលបំណងកម្មវត្ថុអាជីវកម្ម ឬ សកម្មភាពប្រកបពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន ។

គ- ការបែងចែកសាជាថ្មី នូវចំនួនភាគហ៊ុនជាប្រភេទឡើងវិញ ដោយមានការកែប្រែលក្ខណៈដាច់ខាត និង លក្ខណៈធៀបរបស់ប្រភេទភាគហ៊ុនណាមួយ ។

ឃ- ការកែប្រែភាគលាភ នៃប្រភេទភាគហ៊ុនណាមួយ ។

ង- ការបង្កើនដើមទុនដោយបង្កើតភាគហ៊ុនប្រភេទថ្មី ដែលមានលក្ខណៈដាច់ខាត និងលក្ខណៈធៀបប្រសើរជាង ឬ ទាបជាងប្រភេទភាគហ៊ុន ដែលមានរួចហើយ ។

ច- ការបន្ថយដើមទុនចុះបញ្ជី ដោយបញ្ចុះតម្លៃចារឹកលើប័ណ្ណនៃប្រភេទភាគហ៊ុនណាមួយ ឬ ដោយបន្ថយចំនួនភាគហ៊ុនដែលបានអនុញ្ញាត ។ ដើមទុនចុះបញ្ជីមិនអាចកាត់បន្ថយឱ្យនៅតិចជាងពាក់កណ្ដាលនៃដើមទុនចុះបញ្ជីដំបូងបានឡើយដូចដែលមានចែងនៅក្នុងលក្ខន្តិកៈក្រុមហ៊ុន ។ ការបន្ថយដើមទុនមិនត្រូវហួសពី ៩០ (កៅសិប)ថ្ងៃ បន្ទាប់ពីការកែប្រែត្រូវបានកំណត់នៅក្រសួងពាណិជ្ជកម្ម ។ បើក្នុងរយៈពេលនេះមានការតវ៉ាជំទាស់ពីម្ចាស់បំណុល ដែលគ្មានវិវាទជាមួយក្រុមហ៊ុន ម្ចាស់បំណុលនេះត្រូវបានសងប្រាក់ទាំងស្រុង មុនការបន្ថយដើមទុនដែលអាចអនុវត្តទៅបាន ។

ឆ- ការកែប្រែថិរវេលានៃអត្ថិភាពរបស់ក្រុមហ៊ុន ។

ជ- ការផ្លាស់ប្ដូរទីស្នាក់ការចុះបញ្ជី ។

ឈ- ការកែប្រែចំនួនក្វរ៉ុម ។

ញ- បន្ថែមបទប្បញ្ញត្តិណាមួយ ដែលច្បាប់នេះអនុញ្ញាតឱ្យ ដាក់បញ្ចូលទៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

**មាត្រា ២៣៩.–**

គ្រប់ឯកសារស្ដីពីការធ្វើការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុន ត្រូវបញ្ជាក់ឱ្យ បានច្បាស់លាស់ពីកាលបរិច្ឆេទនៃការកែប្រែលក្ខន្តិកៈ ឬ ចំណុចកែប្រែទាំងឡាយដែលមហាសន្និបាតម្ចាស់ហ៊ុនបានសម្រេច ព្រមទាំងមានចុះហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល ឬ អភិបាលណាម្នាក់ដែលទទួលសិទ្ធិពីប្រធានក្រុមប្រឹក្សាភិបាល ។

ឯកសារទាំងនេះត្រូវតម្កល់ទុកនៅក្រសួងពាណិជ្ជកម្មយ៉ាងយូរ ១៥(ដប់ប្រាំ) ថ្ងៃ ក្រោយពីមហាសន្និបាតបានសម្រេច ។

**មាត្រា ២៤០.-**

ពេលបានទទួលឯកសារធ្វើការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុន ក្រសួងពាណិជ្ជកម្ម ត្រូវចេញវិញ្ញាបនបត្របញ្ជាក់អំពីការកែប្រែលក្ខន្តិកៈនោះ ។

ការកែប្រែលក្ខន្តិកៈមានប្រសិទ្ធភាព ចាប់ពីកាលបរិច្ឆេទដែលបានបញ្ជាក់នៅក្នុងវិញ្ញាបនបត្ររបស់ក្រសួងពាណិជ្ជកម្ម។ប្រសិនបើការកែប្រែលក្ខន្តិកៈបានបញ្ជាក់អំពីកាលបរិច្ឆេទមួយទៀត កាលបរិច្ឆេទនោះមិនឱ្យលើសពី ៩០(កៅសិប)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទកំណត់របស់វិញ្ញាបនបត្រឡើយ ។

## ៥.- ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា

**មាត្រា ២៤១.-**

ក្រុមហ៊ុនពីរ ឬច្រើន អាចរំលាយបញ្ចូលគ្នាជាក្រុមហ៊ុនតែមួយ ឬអាចបង្រួមចូលគ្នាជាក្រុមហ៊ុនថ្មីមួយផ្សេងទៀតបាន ។

ក្រុមហ៊ុនដែលរំលាយហៅថាក្រុមហ៊ុនដើម ។ ក្រុមហ៊ុនដែលទទួលបន្ទុកធ្វើអាជីវកម្មតទៅទៀតហៅថាក្រុមហ៊ុនថ្មី ។ ក្រុមហ៊ុនដើមនឹងត្រូវបាត់បង់នូវនីតិបុគ្គលិកលក្ខណៈ ចាប់ពីថ្ងៃដែលក្រសួងពាណិជ្ជកម្មចេញវិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

**មាត្រា ២៤២.-**

ក្រុមប្រឹក្សាភិបាល របស់ក្រុមហ៊ុននីមួយៗ ដែលស្នើរំលាយក្រុមហ៊ុនបញ្ចូលគ្នា ត្រូវអនុម័តនូវសេចក្ដីសម្រេចយល់ព្រមលើកិច្ចព្រមព្រៀងនៃការរំលាយបញ្ចូលគ្នា ។ លើកលែងតែមានចែងផ្សេងក្នុងលក្ខន្តិកៈ ការអនុម័តនេះត្រូវផ្អែកលើចំនួនភាគច្រើនដាច់ខាតនៃអភិបាលទាំងអស់ ។

**មាត្រា ២៤៣.-**

កិច្ចព្រមព្រៀងនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវចែងពី :

ក- ចំណុចសំខាន់ៗនិងលក្ខខណ្ឌនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

ខ- លក្ខន្តិកៈរបស់ក្រុមហ៊ុនថ្មីដែលទទួលបន្ទុកបន្តធ្វើអាជីវកម្ម ។

គ- របៀបបទនៃការផ្លាស់ប្តូរភាគហ៊ុននៃប្រភេទនីមួយៗរបស់ក្រុមហ៊ុនដើមឱ្យទៅជាភាគហ៊ុន ឬ មូលបត្រផ្សេងៗរបស់ក្រុមហ៊ុនថ្មី ដែលទទួលបន្ទុកបន្តអាជីវកម្ម ។

ឃ- របាយការណ៍ស្តីពីសាច់ប្រាក់ សិទ្ធិ មូលបត្រ ឬ កម្មសិទ្ធិផ្សេងៗទៀតដែលអ្នកកាន់កាប់ភាគហ៊ុនត្រូវទទួល ក្នុងការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ប្រសិនបើភាគហ៊ុនណាមួយរបស់ក្រុមហ៊ុនដើម មិនត្រូវប្តូរទៅជាភាគហ៊ុនរបស់ក្រុមហ៊ុនថ្មី ដែលទទួលបន្ទុកបន្តអាជីវកម្មនោះទេ ។

ង- ព័ត៌មានមានផងទៀតដែលម្ចាស់ហ៊ុនក្នុងប្រភេទនីមួយៗចង់ដឹង ដើម្បីជាមូលដ្ឋានធ្វើការសម្រេចចិត្តក្នុងការបោះឆ្នោតលើការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

ច- ព័ត៌មានលម្អិតនៃកិច្ចសម្របសម្រួលចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើង និងដើម្បីផ្តល់ដល់ការគ្រប់គ្រង ព្រមទាំងប្រតិបត្តិការនាពេលបន្ទាប់នៃក្រុមហ៊ុនថ្មីដែលទទួលបន្ទុកបន្តអាជីវកម្ម ។

**មាត្រា ២៤៤.-**

ក្រោយពីបានទទួលសេចក្តីសម្រេចពីក្រុមប្រឹក្សាភិបាលក្រុមហ៊ុនដើមនីមួយៗ ម្ចាស់ក្រុមហ៊ុនថ្មីត្រូវជូនដំណឹងទៅឱ្យម្ចាស់ហ៊ុនស្តីពីកិច្ចប្រជុំម្ចាស់ហ៊ុន ដែលមានសិទ្ធិបោះឆ្នោតនូវព័ត៌មានដូចតទៅ :

ក- នៅក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ ក្រោយកិច្ចព្រមព្រៀងនេះ ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនដើមនីមួយៗត្រូវធ្វើមហាសន្និបាតម្ចាស់ហ៊ុន ដើម្បីបោះឆ្នោតសម្រេចលើកិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

ខ- លិខិតជូនដំណឹងត្រូវភ្ជាប់ជាមួយនឹងច្បាប់ចម្លងនៃកិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

គ- ក្រុមហ៊ុនដើមនីមួយៗត្រូវផ្តល់លិខិតជូនដំណឹងស្តីពីកិច្ចប្រជុំម្ចាស់ហ៊ុនយ៉ាងតិច ២០(ម្ភៃ)ថ្ងៃមុន ។

**មាត្រា ២៤៥.–**

ការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវមានការយល់ព្រមដោយសេចក្តីសម្រេចពិសេសរបស់ម្ចាស់ហ៊ុនពីរភាគបី (២/៣) នៃក្រុមហ៊ុនដើមនីមួយៗ ។

**មាត្រា ២៤៦.–**

ទោះបីលក្ខន្តិកៈរបស់ក្រុមហ៊ុនមិនអនុញ្ញាតឱ្យប្រភេទភាគហ៊ុនណាមួយមានសិទ្ធិជាទូទៅ ក្នុងការបោះឆ្នោតក៏ដោយ ក៏ប្រភេទភាគហ៊ុននោះនឹងនៅតែមានសិទ្ធិដោយឡែក ក្នុងការបោះឆ្នោតទៅតាមប្រភេទភាគហ៊ុនរបស់ខ្លួន ដើម្បីសម្រេចលើការរំលាយក្រុមហ៊ុនបញ្ចូលគ្នាដែលអាចនឹងកែប្រែដោយផ្ទាល់ និងដោយប្រយោលនូវសិទ្ធិ ឯកសិទ្ធិ ការរឹតត្បិតនិងលក្ខខណ្ឌនៃប្រភេទ ឬ ស៊េរីនៃភាគហ៊ុនផ្សេងៗ ។

អំណាចបោះឆ្នោតដែលបង្កើតឡើងក្នុងមាត្រានេះមិនអាចបដិសេធឬកែប្រែដោយលក្ខន្តិកៈរបស់ក្រុមហ៊ុន ឬតាមរបៀបណាផ្សេងទៀតបានឡើយ ។

**មាត្រា ២៤៧.–**

អភិបាលរបស់ក្រុមហ៊ុនថ្មី ដែលទទួលធ្វើអាជីវកម្មបន្ត ត្រូវតម្កល់ឯកសារទុកនៅក្រសួងពាណិជ្ជកម្ម ដែលមានជាអាទិ៍ :

ក- កិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

ខ- សេចក្តីសម្រេចយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នានៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល និងនៃមហាសន្និបាតម្ចាស់ហ៊ុនរបស់ក្រុមហ៊ុនដើមនីមួយៗ ។

គ- លក្ខន្តិកៈរបស់ក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្ត ។

ឃ- សេចក្តីប្រកាសរបស់អភិបាលឬអ្នកគ្រប់គ្រងនៃក្រុមហ៊ុនដើមនីមួយៗ ដែលធ្វើឡើងតាមការទាមទារពីមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។ សេចក្តីប្រកាសនោះត្រូវមានមូលហេតុសមរម្យដូចតទៅ :

១- ក្រុមហ៊ុនដើមនិងក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្តនីមួយៗគឺមានលទ្ធភាពសងបំណុលរបស់ខ្លួន តាមពេលវេលាដែលត្រូវសង ។

២- ធនធានសរុបរបស់ក្រុមហ៊ុនថ្មី ដែលទទួលធ្វើអាជីវកម្មបន្ត មិនត្រូវតិចជាងចំនួនសរុបនៃបំណុលដែលខ្លួនជំពាក់ និងដើមទុនចុះបញ្ជីនៃក្រុមហ៊ុនដើម ។

៣- គ្មានម្ចាស់បំណុលណាមួយទទួលការខូចខាតដោយសារការរំលាយក្រុមហ៊ុនបញ្ចូលគ្នានេះទេ ។

៤- លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរ ត្រូវបានប្រគល់ឱ្យម្ចាស់បំណុលទាំងអស់របស់ក្រុមហ៊ុនដើមហើយគ្មានម្ចាស់បំណុលណាមួយធ្វើការជំទាស់ដែលមានមូលហេតុស្របទៅលើការរំលាយបញ្ចូលគ្នានោះទេ ។

**មាត្រា ២៤៨.-**

នៅពេលទទួលលក្ខន្តិកៈស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ក្រសួងពាណិជ្ជកម្មត្រូវចេញវិញ្ញាបនបត្របញ្ជាក់ពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នាចាប់ពីកាលបរិច្ឆេទដែលមានចុះនៅលើវិញ្ញាបនបត្រនេះ :

ក- ការរំលាយបញ្ចូលគ្នារបស់ក្រុមហ៊ុនដើម និងការបន្តជាក្រុមហ៊ុនតែមួយរបស់គេ ត្រូវចូលជាធរមាន ។

ខ- កម្មសិទ្ធិរបស់ក្រុមហ៊ុនដើមនីមួយៗ ត្រូវបានជាកម្មសិទ្ធិក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្ម ។

គ- ក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្មត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ចរបស់ក្រុមហ៊ុនដើមនីមួយៗ ។

ឃ- កិច្ចការរដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬរដ្ឋបាលណាមួយ ដែលពាក់ព័ន្ធដល់ក្រុមហ៊ុនដើមណាមួយនោះ នៅតែមានជាធរមានក្នុងទំនាក់ទំនងជាមួយក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្ម ។

ង- លក្ខន្តិកៈស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវចាត់ទុកជាលក្ខន្តិកៈសម្រាប់ការធ្វើអាជីវកម្មរបស់ក្រុមហ៊ុនថ្មី ហើយវិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ត្រូវចាត់ទុកជាវិញ្ញាបនបត្របញ្ជាក់ពីការធ្វើអាជីវកម្មសម្រាប់ក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្ម ។

**មាត្រា ២៤៩.-**

ក្នុងការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ម្ចាស់ហ៊ុនមួយចំនួននៃក្រុមហ៊ុនដើម មានសិទ្ធិទាមទារឱ្យមានការវាយតម្លៃ លើតម្លៃភាគហ៊ុនរបស់ខ្លួននៅក្នុងក្រុមហ៊ុនដើម ។ ប៉ុន្តែដើម្បីទទួលបានសិទ្ធិធ្វើការវាយតម្លៃ ម្ចាស់ហ៊ុនទាំងនោះត្រូវបំពេញលក្ខខណ្ឌដូចតទៅ :

ក- មុនពេលម្ចាស់ហ៊ុនបានបោះឆ្នោតធ្វើការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ម្ចាស់ហ៊ុនត្រូវកាន់កាប់ភាគហ៊ុននៅក្នុងក្រុមហ៊ុនដើមណាមួយ ។

ខ- នៅក្នុងពេលបោះឆ្នោត ម្ចាស់ហ៊ុននោះមិនបានបោះឆ្នោតគាំទ្រការរំលាយក្រុមហ៊ុនបញ្ចូលគ្នាទេ ។

គ- ម្ចាស់ហ៊ុននោះត្រូវធ្វើការទាមទារជាលាយលក្ខណ៍អក្សរចំពោះក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្ត ក្រោយពីលក្ខន្តិកៈស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវបានតម្កល់ទុកនៅក្រសួងពាណិជ្ជកម្ម ។

ឃ- នៅពេលដែលធ្វើការទាមទារវាយតម្លៃ ម្ចាស់ហ៊ុននោះត្រូវប្រគល់បណ្ណភាគហ៊ុនរបស់ខ្លួន ទៅឱ្យក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្ត ។

**មាត្រា ២៥០.-**

នៅពេលមានការទាមទារវាយតម្លៃលើតម្លៃភាគហ៊ុន ក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្តនិងម្ចាស់ហ៊ុនដែលធ្វើការទាមទារនេះ ត្រូវចរចាគ្នាដើម្បីសម្រុះសម្រួល

រកតម្លៃសមរម្យមួយក្នុងរយៈពេល ៩០(កៅសិប)ថ្ងៃ ដើម្បីឱ្យមានការព្រមព្រៀងលើតម្លៃសមរម្យមួយសម្រាប់ភាគហ៊ុនទាំងនោះ ។

តម្លៃសមរម្យត្រូវកំណត់តាមការពិនិត្យគ្រប់កត្តាដែលពាក់ព័ន្ធទាំងអស់ លើកលែងតែតម្លៃណាមួយដែលមានកំណត់រួចហើយ នៅក្នុងកិច្ចសន្យារំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

លក្ខន្តិកៈរបស់ក្រុមហ៊ុនដើមណាមួយ ឬកិច្ចព្រមព្រៀងនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នាអាចចែងថា គ្រប់វិវាទក្នុងការវាយតម្លៃ នឹងត្រូវសម្រេចដោយមជ្ឈត្តកម្ម ។ មុននឹងមជ្ឈត្តករចេញសេចក្តីសម្រេចចុងក្រោយ ម្ចាស់ហ៊ុនអាចដកបណ្តឹងទាមទាររបស់ខ្លួន ក្នុងការវាយតម្លៃនៅពេលណាមួយក៏បាន ។ ក្នុងករណីនេះ ម្ចាស់ហ៊ុននោះត្រូវមានសិទ្ធិទទួលពីក្រុមហ៊ុនថ្មី ដែលទទួលធ្វើអាជីវកម្មបន្តនូវតម្លៃសមមូល ដែលក្រុមហ៊ុនបានកំណត់ពីមុន ។

ប្រសិនបើមិនអាចព្រមព្រៀងគ្នាលើតម្លៃសមរម្យណាមួយបានទេ ភាគីទាំងពីរត្រូវប្រគល់ជូនតុលាការដែលមានសមត្ថកិច្ចសម្រេចពីតម្លៃសមរម្យមួយ ហើយម្ចាស់ហ៊ុនដែលទាមទារត្រូវទទួលទៅតាមចំនួននោះ ។

## ខ- ការរំលាយក្រុមហ៊ុន និង ការជម្រះបញ្ជី

**មាត្រា ២៥១.-**

ក្រុមហ៊ុនដែលគ្មានចេញប័ណ្ណភាគហ៊ុនណាមួយ អាចរំលាយនៅពេលណាក៏បាន តាមរយៈសេចក្តីសម្រេចរបស់អភិបាលទាំងអស់ ។

ក្រុមហ៊ុនគ្មានទ្រព្យសម្បត្តិនិងគ្មានបំណុល អាចធ្វើការរំលាយបាន តាមរយៈសេចក្តីសម្រេចចិត្តពិសេសរបស់ម្ចាស់ហ៊ុន ឬប្រសិនបើក្រុមហ៊ុនមានចេញប័ណ្ណភាគហ៊ុនច្រើនជាងមួយប្រភេទនោះ ការរំលាយត្រូវធ្វើតាមរយៈសេចក្តីសម្រេចពិសេសរបស់អ្នកកាន់កាប់ភាគហ៊ុននៃប្រភេទនីមួយៗ ទោះបីម្ចាស់ហ៊ុននោះមានសិទ្ធិ ឬគ្មានសិទ្ធិបោះឆ្នោតក៏ដោយ ។

ក្រុមហ៊ុនត្រូវបញ្ជូនសេចក្ដីសម្រេចរំលាយក្រុមហ៊ុនទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម ។

នៅពេលបានទទួលសេចក្ដីសម្រេចរំលាយក្រុមហ៊ុន មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវចេញវិញ្ញាបនបត្ររំលាយក្រុមហ៊ុនឱ្យដល់ក្រុមហ៊ុន ។

ក្រុមហ៊ុនត្រូវបានចាត់ទុកថាលែងមានអត្ថិភាពតទៅទៀត ចាប់ពីថ្ងៃចេញវិញ្ញាបនបត្ររំលាយក្រុមហ៊ុន ។

**មាត្រា ២៥២.-**

អភិបាលឬម្ចាស់ភាគហ៊ុនម្នាក់ដែលមានសិទ្ធិបោះឆ្នោត នៅពេលមហាសន្និបាតម្ចាស់ហ៊ុនអាចស្នើឱ្យជម្រះបញ្ជីនិងរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្ត ។

លិខិតជូនដំណឹងស្ដីពីការប្រជុំរបស់ម្ចាស់ហ៊ុនក្នុងបំណងជម្រះបញ្ជី ឬ រំលាយក្រុមហ៊ុនដែលស្នើឡើង ត្រូវចែងពីលក្ខខណ្ឌសម្រាប់ការជម្រះបញ្ជីនិងការរំលាយក្រុមហ៊ុននោះ ។

ក្រុមហ៊ុនដែលមានទ្រព្យសម្បត្តិ និង/ឬ មានបំណុល អាចធ្វើការរំលាយបានតាមរយៈសេចក្ដីសម្រេចចិត្តពិសេសមួយរបស់អ្នកកាន់ភាគហ៊ុននៃប្រភេទនីមួយៗ ។ ក្នុងករណីដែលក្រុមហ៊ុនមានចេញប័ណ្ណភាគហ៊ុនច្រើនជាងមួយប្រភេទ ត្រូវធ្វើការជម្រះបញ្ជី និងរំលាយតាមរយៈសេចក្ដីសម្រេចពិសេសរបស់អ្នកកាន់ភាគហ៊ុននៃប្រភេទនីមួយៗ ដោយមិនគិតថាម្ចាស់ហ៊ុននោះមានសិទ្ធិ ឬគ្មានសិទ្ធិបោះឆ្នោតទេ ប្រសិនបើ :

១- ម្ចាស់ហ៊ុនអនុញ្ញាតឱ្យអភិបាលធ្វើការបែងចែកទ្រព្យសម្បត្តិ និងទូទាត់បំណុលរបស់ក្រុមហ៊ុន តាមសេចក្ដីសម្រេចពិសេសឬ សេចក្ដីសម្រេចសាមញ្ញ ។

២- ក្រុមហ៊ុនបានធ្វើការបែងចែកទ្រព្យសម្បត្តិ និងទូទាត់បំណុលមុនពេលបញ្ជូនលក្ខន្តិកៈនៃការរំលាយក្រុមហ៊ុន ទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។

**មាត្រា ២៥៣.-**

ក្រោយពីមានការយល់ព្រមលើសេចក្ដីសម្រេចជម្រះបញ្ជី និងរំលាយក្រុមហ៊ុន ក្រុមហ៊ុនត្រូវធ្វើសេចក្ដីប្រកាសពីបំណងរំលាយជាទម្រង់លិខិតទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។

នៅពេលទទួលសេចក្ដីប្រកាសពីបំណងរំលាយ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវចេញវិញ្ញាបនបត្របញ្ជាក់ពីបំណងរំលាយក្រុមហ៊ុននោះ ។

នៅពេលដែលចេញវិញ្ញាបនបត្របញ្ជាក់បំណងនៃការរំលាយក្រុមហ៊ុនក្រុមហ៊ុនត្រូវបញ្ឈប់ការធ្វើអាជីវកម្ម លើកលែងតែចំពោះការពន្យារចាំបាច់សម្រាប់ការជម្រះបញ្ជី ប៉ុន្តែនីតិបុគ្គលិកលក្ខណៈរបស់ក្រុមហ៊ុន នៅតែមានសុពលភាពរហូតដល់ក្រសួងពាណិជ្ជកម្មចេញវិញ្ញាបនបត្របញ្ជាក់ការរំលាយជាស្ថាពរ ។

**មាត្រា ២៥៤.-**

ក្រោយពេលចេញវិញ្ញាបនបត្របញ្ជាក់ពីបំណងនៃការរំលាយក្រុមហ៊ុន ដោយមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ក្រុមហ៊ុនត្រូវ :

ក- ធ្វើលិខិតជូនដំណឹងស្ដីពីបំណងរំលាយជាបន្ទាន់ទៅឱ្យម្ចាស់បំណុលរបស់ក្រុមហ៊ុន ។

ខ- ចុះផ្សាយលិខិតជូនដំណឹងស្ដីពីបំណងនៃការរំលាយជាបន្ទាន់ សម្រាប់រយៈពេល ២ (ពីរ) សប្ដាហ៍ជាប់ៗគ្នានៅក្នុងសារព័ត៌មានដែលបោះផ្សាយ ឬចែកចាយក្នុងកន្លែងដែលក្រុមហ៊ុនមានស្នាក់ការចុះបញ្ជីពិតប្រាកដ ឬបោះពុម្ពផ្សាយដទៃទៀតដូចបានកំណត់ក្នុងបទបញ្ជារបស់ក្រសួងពាណិជ្ជកម្ម ។

**មាត្រា ២៥៥.-**

ក្រោយពីការចេញវិញ្ញាបនបត្របញ្ជាក់ពីបំណងនៃការរំលាយ ក្រុមហ៊ុនត្រូវ :

-ប្រមូលទ្រព្យសម្បត្តិ

-រក្សាទុកទ្រព្យសម្បត្តិជាវត្ថុដែលមិនអាចធ្វើការបែងចែកទៅឱ្យម្ចាស់ហ៊ុន

-បំពេញកាតព្វកិច្ចទាំងឡាយ

-ធ្វើសកម្មភាពផ្សេងទៀត ដែលតម្រូវសម្រាប់ធ្វើការជម្រះបញ្ជី ។

ក្រោយពីបានទទួលលិខិតជូនដំណឹងពីការរំលាយ និងការសងប្រាក់បានគ្រប់គ្រាន់ ឬការបញ្ឈប់សកម្មភាពទាំងអស់របស់ក្រុមហ៊ុន ក្រុមហ៊ុនត្រូវបែងចែកទ្រព្យសម្បត្តិដែលនៅសល់ ទាំងកម្មសិទ្ធិជាសាច់ប្រាក់ ឬ ជាវត្ថុទៅឱ្យម្ចាស់ហ៊ុន ដែលមានសិទ្ធិទទួលទ្រព្យសម្បត្តិនោះ ។

## មាត្រា ២៥៦.-

នៅគ្រប់ពេលក្នុងអំឡុងពេលនៃការជម្រះបញ្ជីរបស់ក្រុមហ៊ុន មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ឬជនដែលមានការពាក់ព័ន្ធផលប្រយោជន៍ អាចស្នើទៅតុលាការ ដើម្បីឱ្យការជម្រះបញ្ជីក្រោមការត្រួតពិនិត្យរបស់តុលាការ ។

អ្នកដាក់ពាក្យសុំត្រូវផ្តល់ឱ្យក្រសួងពាណិជ្ជកម្មនូវលិខិតជូនដំណឹងស្តីពីការអនុវត្ត ហើយមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម មានសិទ្ធិបង្ហាញតុលាការដោយផ្ទាល់ ឬតាមរយៈតំណាង ។

## មាត្រា ២៥៧.-

នៅពេលជម្រះបញ្ជីត្រូវបានបញ្ចប់ ក្រុមហ៊ុនត្រូវរៀបចំសេចក្តីសម្រេចស្តីពីការរំលាយក្រុមហ៊ុន ។

សេចក្តីសម្រេចស្តីពីការរំលាយត្រូវផ្ញើទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។

នៅពេលទទួលសេចក្តីសម្រេចស្តីពីការរំលាយក្រុមហ៊ុន មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវចេញវិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុមហ៊ុន ។

ក្រុមហ៊ុនត្រូវបញ្ឈប់អត្ថិភាពរបស់ខ្លួន ចាប់ពីថ្ងៃដែលមានចុះនៅក្នុងវិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុមហ៊ុន ។

**មាត្រា ២៥៨.-**

បទប្បញ្ញត្តិស្ដីពីការរំលាយ និងការជម្រះបញ្ជីខាងលើ មិនត្រូវអនុវត្តចំពោះក្រុមហ៊ុនដែលដាក់ពាក្យសុំក្ស័យធនទៅតុលាការឡើយ ។

## ខ.- មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម

**មាត្រា ២៥៩.-**

ក្រសួងពាណិជ្ជកម្មត្រូវតែងតាំងមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មម្នាក់ ឬច្រើននាក់តាមការចាំបាច់ ដើម្បីឱ្យបំពេញតួនាទីស្របតាមច្បាប់នេះ ។

**មាត្រា ២៦០.-**

ក្រសួងពាណិជ្ជកម្មចេញវិញ្ញាបនបត្រ ឬ បញ្ជាក់អំពីសកម្មភាពណាមួយរបស់ក្រុមហ៊ុន ។ វិញ្ញាបនបត្រនេះត្រូវចុះហត្ថលេខាដោយមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។

**មាត្រា ២៦១.-**

លិខិតជូនដំណឹង ឬឯកសារផ្សេងៗ ដែលពាក់ព័ន្ធដល់ការគ្រប់គ្រងក្រុមហ៊ុនត្រូវផ្ញើទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មអាចទទួលយកឯកសារថតចម្លងផ្សេងៗទាំងនោះបាន ។

**មាត្រា ២៦២.-**

មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចទាមទារឱ្យក្រុមហ៊ុនធ្វើឯកសារបញ្ជាក់ពីភាពត្រឹមត្រូវ ឬ ហេតុការណ៍ពិត ដែលមានចែងនៅក្នុងឯកសារស្របតាមច្បាប់នេះ ។

**មាត្រា ២៦៣.-**

ក្រសួងពាណិជ្ជកម្មអាចធ្វើសេចក្តីណែនាំដែលមានចំណុចដូចខាងក្រោម :

ក- ការតម្រូវឱ្យរៀបរាប់ហេតុផលសំខាន់ៗដោយលម្អិត តាមការអនុញ្ញាតនៃច្បាប់នេះ ។

ខ- ការតម្រូវឱ្យមានការបង់ថ្លៃឈ្នួលចំពោះការតម្កល់ទុក ការត្រួតពិនិត្យ ឬ ការថតចម្លងឯកសារណាមួយ ឬ ចំពោះសកម្មភាពណាមួយ ។

គ- ការរៀបរាប់ពីមាតិកាតាមប្រព័ន្ធអេឡិចត្រូនិច ឬ ទម្រង់បែបបទនៃលិខិតជូនដំណឹងដទៃទៀត ព្រមទាំងឯកសារចាំបាច់ដែលត្រូវធ្វើជូន ឬ ចេញដោយក្រសួងពាណិជ្ជកម្ម ។

ឃ- ការប្រតិបត្តិដែលទាក់ទងដល់ការបញ្ជូន ឬ ការចេញនូវលិខិតជូនដំណឹងនិងឯកសារផ្សេងៗ ។

ង- ការរៀបរាប់ពីវិធាននានា ដែលទាក់ទងដល់ការលើកលែងមួយចំនួនដែលអនុញ្ញាតដោយច្បាប់នេះ ។

**មាត្រា ២៦៤.-**

លក្ខន្តិកៈនិងផែនការរំលាយក្រុមហ៊ុន ត្រូវធ្វើទៅឱ្យក្រសួងពាណិជ្ជកម្ម ត្រូវមានហត្ថលេខាដោយអភិបាលម្នាក់ ឬ អ្នកគ្រប់គ្រងម្នាក់របស់ក្រុមហ៊ុន ឬ ដោយស្ថាបនិកម្នាក់ក្នុងករណីដែលតម្រូវដោយលក្ខន្តិកៈ ។

ក្រោយពីបានទទួលនូវឯកសារ ឬ ផែនការតាមទម្រង់កំណត់ហើយនោះ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មត្រូវ :



164/805

១- កត់ត្រាទុកកាលបរិច្ឆេទនៃការតម្កល់ទុក ។

២- ចេញវិញ្ញាបនបត្រ ។

៣- តម្កល់ទុកនូវវិញ្ញាបនបត្រនិងឯកសារ ឬ សេចក្តីប្រកាសរូបថត ព័ត៌មាន អេឡិចត្រូនិច ឬរាល់ការថតចម្លងឡើងវិញនៃវិញ្ញាបនបត្រនិងឯកសារ ឬ សេចក្តីប្រកាស ។

៤- ផ្ញើវិញ្ញាបនបត្រនិងឯកសារ ឬសេចក្តីប្រកាសរូបថតព័ត៌មាន អេឡិចត្រូនិច ឬរាល់ការថតចម្លងឡើងវិញនៃវិញ្ញាបនបត្រនិងឯកសារ ឬ សេចក្តីប្រកាសទៅឱ្យក្រុមហ៊ុន ឬ តំណាងរបស់ក្រុមហ៊ុន ។

៥- ចុះផ្សាយនូវលិខិតជូនដំណឹងនៃការចេញវិញ្ញាបនបត្រនៅក្នុងព្រឹត្តិបត្ររបស់ក្រសួងពាណិជ្ជកម្ម ។

**មាត្រា ២៦៥.-**

វិញ្ញាបនបត្រដែលបានចេញដោយក្រសួងពាណិជ្ជកម្ម អាចចុះកាលបរិច្ឆេទនៅថ្ងៃដែលទទួលឯកសារ ឬ ផែនការ ឬ ដីការបស់តុលាការដែលបញ្ជាឱ្យចេញវិញ្ញាបនបត្រ ឬ នៅថ្ងៃបន្ទាប់ទៀត ដែលបានបញ្ជាក់ដោយតុលាការ ឬ បុគ្គល ដែលបានចុះហត្ថលេខាលើឯកសារ ឬ ផែនការនោះ ។

**មាត្រា ២៦៦.-**

មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចផ្តល់ឱ្យបុគ្គលណាម្នាក់នូវវិញ្ញាបនបត្រ និងឯកសារចាំបាច់ដែលក្រុមហ៊ុនបានផ្ញើមកឱ្យក្រសួងពាណិជ្ជកម្មស្របតាមច្បាប់នេះ ។

**មាត្រា ២៦៧.-**

ប្រសិនបើវិញ្ញាបនបត្រដែលចេញឱ្យក្រុមហ៊ុន ដោយមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម មានកំហុសឆ្គងដោយអចេតនាណាមួយនោះ អភិបាល ឬ ម្ចាស់ហ៊ុនត្រូវបញ្ជូនទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម

ដើម្បីកែតម្រូវឡើងវិញតាមច្បាប់នេះ ។ បើមានហេតុផលត្រឹមត្រូវ ក្រសួងពាណិជ្ជកម្ម អាចបដិសេធវិញ្ញាបនបត្រដែលខុស និងចេញវិញ្ញាបនបត្រដែលត្រឹមត្រូវជំនួសវិញ ។

វិញ្ញាបនបត្រត្រឹមត្រូវថ្មីនេះ ត្រូវមានកាលបរិច្ឆេទតែមួយ ដូចវិញ្ញាបនបត្រចាស់ដែរ ។

ប្រសិនបើវិញ្ញាបនបត្រត្រឹមត្រូវថ្មីនេះ មានការកែប្រែលក្ខខណ្ឌផ្សេងពីវិញ្ញាបនបត្រដើមនោះមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវផ្តល់លិខិតជូនដំណឹងជាបន្ទាន់ចំពោះការកែប្រែនោះ នៅក្នុងព្រឹត្តិបត្ររបស់ក្រសួងពាណិជ្ជកម្ម ។

**មាត្រា ២៦៨.-**

បុគ្គលណាមួយដែលបានបង់ថ្លៃឈ្នួលរួចហើយ បុគ្គលនោះមានសិទ្ធិត្រួតពិនិត្យឯកសារនានា ដែលបានផ្ញើទៅក្រសួងពាណិជ្ជកម្មនៅគ្រប់ម៉ោងធ្វើការ ហើយអាចធ្វើការថតចម្លង ឬ ដកស្រង់របាយការណ៍ផ្សេងៗបាន ។ ការផ្តល់ឯកសារ ឬ ថតចម្លងឯកសារដល់បុគ្គលណាម្នាក់ មិនត្រូវបានអនុវត្តចំពោះរបាយការណ៍ស៊ើបអង្កេតរបស់តុលាការទេ ។

មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចផ្តល់ឱ្យបុគ្គលណាម្នាក់នូវច្បាប់ចម្លង ឬ ច្បាប់ចម្លងដែលមានការបញ្ជាក់របស់ឯកសារនានា ស្របតាមលក្ខខណ្ឌនៃមាត្រានេះ ។

នៅពេលដែលឯកសារត្រូវបានរក្សាទុកដោយក្រសួងពាណិជ្ជកម្ម ហើយឯកសារនោះមានទម្រង់ជាលាយលក្ខណ៍អក្សរ ត្រូវមានលក្ខខណ្ឌដូចតទៅនេះ :

ក- ក្រសួងពាណិជ្ជកម្មត្រូវផ្តល់ឯកសារចម្លងដែលតម្រូវឱ្យផ្តល់ ស្របតាមមាត្រានេះ ជាទម្រង់ឯកសារដែលអាចអានបាន ។

ខ- របាយការណ៍ដែលស្រង់ចេញពីឯកសារតម្កល់ទាំងនេះ ប្រសិនបើមានការបញ្ជាក់ពីមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មជាភស្តុតាងដែលមានតម្លៃដូចឯកសារដើមដែរ ។

**មាត្រា ២៦៩.–**

ក្រសួងពាណិជ្ជកម្មមិនមានកាតព្វកិច្ចផ្ដល់ឯកសារនានា ក្រៅពីវិញ្ញាបនបត្រ និងផែនការរំលាយក្រុមហ៊ុនដែលបានភ្ជាប់មកជាមួយ ក្រោយរយៈពេល ១០ (ដប់)ឆ្នាំ គិតចាប់ពីថ្ងៃដែលបានទទួល ។

## ជំពូកទី ៤
## ក្រុមហ៊ុនពាណិជ្ជកម្មបរទេស
## បទប្បញ្ញត្តិទូទៅ

**មាត្រា ២៧០.–**

ក្រុមហ៊ុនពាណិជ្ជកម្មបរទេសគឺជាក្រុមហ៊ុនដែលបង្កើតឡើងក្រោមច្បាប់នៃប្រទេសដទៃ ហើយបានមកបោះទីតាំងធ្វើពាណិជ្ជកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៧១.–**

ក្រុមហ៊ុនពាណិជ្ជកម្មបរទេស អាចមកបោះទីតាំងធ្វើពាណិជ្ជកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន តាមបែបបទផ្សេងៗដូចតទៅ :

ក- ការិយាល័យតំណាងពាណិជ្ជកម្ម ឬ ការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម ។

ខ- សាខាក្រុមហ៊ុនពាណិជ្ជកម្ម ។

គ- បុត្រសម្ព័ន្ធ ។

ការិយាល័យតំណាងពាណិជ្ជកម្ម និងសាខាក្រុមហ៊ុនគឺជាភ្នាក់ងាររបស់ក្រុមហ៊ុនដើម ហើយពុំមាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីក្រុមហ៊ុនដើមឡើយ ។

**មាត្រា ២៧២.–**

ក្រុមហ៊ុនពាណិជ្ជកម្មបរទេស ត្រូវចាត់ទុកថាកំពុងធ្វើសកម្មភាពពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើក្រុមហ៊ុនពាណិជ្ជកម្មបរទេសនោះ បានធ្វើសកម្មភាពនានាដូចខាងក្រោម :

ក- ជួលការិយាល័យ ជួលកន្លែងផលិត ឬ កែច្នៃ ឬ សេវាដែលមានរយៈពេលចាប់ពី ០១ (មួយ) ខែឡើងទៅ ។

ខ- ជួលបុគ្គលិកសម្រាប់បម្រើការងារឱ្យក្រុមហ៊ុន ដែលមានរយៈពេលចាប់ពីមួយខែឡើងទៅ ។

គ- ធ្វើសកម្មភាពដទៃណាមួយទៀត ដែលច្បាប់នៃព្រះរាជាណាចក្រកម្ពុជាអនុញ្ញាតចំពោះរូបវន្តបុគ្គល ឬ នីតិបុគ្គលបរទេស ។

**មាត្រា ២៨៣.-**

គ្រប់ក្រុមហ៊ុនបរទេសនានាធ្វើពាណិជ្ជកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទោះជាក្នុងរូបភាពណាមួយក៏ដោយ ក៏ត្រូវស្ថិតនៅក្រោមច្បាប់ និងយុត្តាធិការរបស់តុលាការនៃព្រះរាជាណាចក្រកម្ពុជា ។

ក្រុមហ៊ុនបរទេសទាំងនោះត្រូវបំពេញទម្រង់បែបបទនៃការចុះបញ្ជីពាណិជ្ជកម្មស្របតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ។

## គ- ការិយាល័យតំណាងពាណិជ្ជកម្ម

**មាត្រា ២៨៤.-**

ការិយាល័យតំណាងពាណិជ្ជកម្ម ឬ ការិយាល័យទំនាក់ទំនងពាណិជ្ជកម្មអាចធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន ជាអាទិ៍ :

ក- ទំនាក់ទំនងផ្សេងៗជាមួយអតិថិជននានា ក្នុងគោលដៅធ្វើឱ្យអតិថិជនទាំងនោះបានស្គាល់ក្រុមហ៊ុនដើមរបស់ខ្លួន ។

ខ- ស្រាវជ្រាវព័ត៌មានពាណិជ្ជកម្ម និងផ្តល់ព័ត៌មានទាំងនេះជូនទៅក្រុមហ៊ុនដើមនៅបរទេស ។

គ- ស្រាវជ្រាវទីផ្សារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ឃ- ឃោសនាផលិតផល តាំងពិព័រណ៍ពាណិជ្ជកម្ម បង្ហាញផលិតផល នៅការិយាល័យរបស់ខ្លួន ឬនៅកន្លែងតាំងពិព័រណ៍ផ្សេងទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ង- ទិញ និងរក្សាទុកទំនិញមួយចំនួន សម្រាប់គោលដៅបម្រើឱ្យការតាំងពិព័រណ៍ពាណិជ្ជកម្ម ។

ច- ជួលទីតាំងការិយាល័យ និងជួលបុគ្គលិកក្នុងស្រុក ដើម្បីបម្រើការងារ ។

ឆ- ចុះកិច្ចសន្យាពាណិជ្ជកម្មជាមួយអតិថិជនក្នុងស្រុកក្នុងនាមក្រុមហ៊ុនដើម ។

ប៉ុន្តែការិយាល័យតំណាងពាណិជ្ជកម្ម ឬ ការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម មិនអាចធ្វើសកម្មភាពទិញ លក់និងធ្វើសេវាជាអាជីពប្រចាំ ឬសកម្មភាពពាក់ព័ន្ធនឹងប្រតិបត្តិការផលិតកែច្នៃ និងសាងសង់ នៅក្នុងព្រះរាជាណាចក្រកម្ពុជាបានឡើយ ។

**មាត្រា ២៧៥.-**

ការិយាល័យតំណាងពាណិជ្ជកម្ម ឬការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម ត្រូវគ្រប់គ្រងដោយនាយកគ្រប់គ្រងមួយរូប ឬច្រើនរូបដែលត្រូវតែងតាំងនិងដកហូតដោយក្រុមហ៊ុនដើម ។

**មាត្រា ២៧៦.-**

នាមករណ៍របស់ការិយាល័យតំណាងពាណិជ្ជកម្ម ឬ ការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម ជានាមករណ៍របស់ក្រុមហ៊ុនដើមនៅឯបរទេស ។ នៅខាងលើឬ នៅពីមុខនាមករណ៍នេះត្រូវសរសេរដាក់ថា ការិយាល័យតំណាងពាណិជ្ជកម្ម ឬ ការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម ។

**មាត្រា ២៧៧.-**

ការិយាល័យតំណាងពាណិជ្ជកម្ម ឬការិយាល័យទំនាក់ទំនងពាណិជ្ជកម្មអាចត្រូវរំលាយបានដោយសេចក្តីសម្រេចរបស់ក្រុមហ៊ុនដើម ។

## ខ- សាខាក្រុមហ៊ុន

**មាត្រា ២៧៨.-**

សាខាក្រុមហ៊ុនអាចធ្វើសកម្មភាពបានដូចការិយាល័យតំណាងពាណិជ្ជកម្មដែរ ។

លើសពីនេះទៀត សាខាក្រុមហ៊ុនអាចទិញនិងលក់ជាប្រចាំបាននូវទំនិញ និងសេវាកម្ម ព្រមទាំងធ្វើសកម្មភាពដែលទាក់ទងទៅនឹងការផលិត ការកែច្នៃ និងការស្ថាបនាដូចសហគ្រាសក្នុងស្រុកដែរ លើកលែងតែសកម្មភាពណាដែលច្បាប់ហាមឃាត់ចំពោះរូបវន្តបុគ្គលនិង/ឬនីតិបុគ្គលបរទេស ។

**មាត្រា ២៧៩.-**

ទ្រព្យសកម្មរបស់សាខា គឺជាទ្រព្យសកម្មរបស់ក្រុមហ៊ុនដើម ។ ក្រុមហ៊ុនដើមត្រូវទទួលខុសត្រូវលើកាតព្វកិច្ចរបស់សាខា ។

**មាត្រា ២៨០.-**

សាខាក្រុមហ៊ុន ត្រូវគ្រប់គ្រងដោយនាយកគ្រប់គ្រងម្នាក់ ឬច្រើននាក់ ដែលត្រូវតែងតាំង និងដកហូតដោយក្រុមហ៊ុនដើម ។

**មាត្រា ២៨១.-**

នាមករណ៍របស់សាខាគឺជានាមករណ៍របស់ក្រុមហ៊ុនដើម ។ នៅពីលើ ឬ នៅពីមុខនាមករណ៍នោះត្រូវសរសេរពាក្យ "សាខាក្រុមហ៊ុន" ។

**មាត្រា ២៨២.–**

"សាខាក្រុមហ៊ុន" អាចត្រូវរំលាយបានដោយសេចក្ដីសម្រេចរបស់ក្រុមហ៊ុនដើម ។

## គ– បុត្រសម្ព័ន្ធ

**មាត្រា ២៨៣.–**

បុត្រសម្ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មបរទេស គឺជាក្រុមហ៊ុនដែលបង្កើតឡើងដោយក្រុមហ៊ុនពាណិជ្ជកម្មបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងដែលមានភាគហ៊ុនយ៉ាងតិច ៥១ (ហាសិបមួយ)ភាគរយ ត្រូវបានកាន់កាប់ដោយក្រុមហ៊ុនពាណិជ្ជកម្មបរទេសនោះ ។

**មាត្រា ២៨៤.–**

បុត្រសម្ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មបរទេស មាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីក្រុមហ៊ុនដើម ចាប់ពីកាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម តាមច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ។

**មាត្រា ២៨៥.–**

បុត្រសម្ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មបរទេស អាចត្រូវបានបង្កើតឡើងក្នុងទម្រង់ជាក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ជាក្រុមហ៊ុនមូលធន ។

**មាត្រា ២៨៦.–**

បុត្រសម្ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មបរទេស អាចធ្វើគ្រប់សកម្មភាពពាណិជ្ជកម្មជាមុខរបរជាប្រចាំរបស់ខ្លួន ដូចក្រុមហ៊ុនពាណិជ្ជកម្មក្នុងស្រុកដែរ លើកលែងតែសកម្ម-ភាពណា ដែលច្បាប់នៃព្រះរាជាណាចក្រកម្ពុជាហាមឃាត់ចំពោះរូបវន្តបុគ្គល និងនីតិ-បុគ្គលបរទេស ។

## ជំពូកទី ៥
## បណ្តឹងជំនួសមុខ

**មាត្រា ២៨៧.-**

ម្ចាស់ហ៊ុនអាចប្តឹង ឬ ធ្វើអន្តរាគមន៍ក្នុងនាម និងសិទ្ធិរបស់ក្រុមហ៊ុន ។ ម្ចាស់ហ៊ុនត្រូវបំពេញគ្រប់លក្ខខណ្ឌដូចខាងក្រោម :

ក- ជាម្ចាស់ហ៊ុននៅក្នុងក្រុមហ៊ុន ឬអ្នកស្នងមរតករបស់ម្ចាស់ហ៊ុន នៅក្នុងអំឡុងពេលដែលការប្តឹងតវ៉ានោះ កំពុងកើតមានឡើងដោយសារពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន ។

ខ- មិនបានបោះឆ្នោតគាំទ្រ ឬមិនបានឱ្យសច្ចានុម័តតាមរបៀបណាផ្សេងទៀតឡើយ ។

គ- បានតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាភិបាល ដើម្បីធ្វើការដោះស្រាយជម្លោះហើយដែលក្រុមប្រឹក្សាភិបាលដោះស្រាយមិនបាន ។

ឃ- ផ្តល់លិខិតជូនដំណឹងទៅឱ្យក្រុមប្រឹក្សាភិបាល មុនពេលដាក់បណ្តឹងទៅតុលាការ ។

បណ្តឹងជំនួសមុខ បន្ទាប់ពីបាននៅតុលាការ មិនត្រូវបានដោះស្រាយដោយគ្មានការព្រមព្រៀងពីតុលាការឡើយ ។

**មាត្រា ២៨៨.-**

រាល់ប្រាក់សំណងដែលបានមកពីបណ្តឹងនេះ ត្រូវជាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ។ ប្រសិនបើបណ្តឹងបានផ្តល់ផលដល់ក្រុមហ៊ុន ម្ចាស់ហ៊ុនដែលបានធ្វើបណ្តឹងជំនួសមុខ អាចស្នើសុំទៅតុលាការ ដើម្បីឱ្យខ្លួនបានទទួលសំណងសមស្រប ។

**មាត្រា ២៨៩.-**

រាល់អភិបាលនិងអ្នកគ្រប់គ្រងក្រុមហ៊ុនដែលកំពុងអនុវត្តតួនាទីរបស់ខ្លួនត្រូវ :

ក- ធ្វើសកម្មភាពស្មោះត្រង់ក្នុងបំណងល្អ ដើម្បីឱ្យមានផលប្រយោជន៍

ខ្ពស់ដល់ក្រុមហ៊ុន ។

ខ- អនុវត្តដោយយកចិត្តទុកដាក់ ព្យាយាម និងជំនាញ ដូចបុគ្គលដែលមានមធ្យ័ត អនុវត្តក្នុងកាលៈទេសៈមួយដូចគ្នាដែរ ។

លក្ខន្តិកៈ ឬ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន អាចចែងថាគ្រប់ជម្លោះដែលកើតមានឡើងរវាងអភិបាល និងរវាងម្ចាស់ហ៊ុនត្រូវបញ្ជូនទៅមជ្ឈមណ្ឌលមជ្ឈត្តកម្ម ។

## ជំពូកទី ៦

## ទោសប្បញ្ញត្តិ

### មាត្រា ២៩០.-

អ្នកប្រព្រឹត្តបទល្មើស ឬ អ្នកចូលរួមក្នុងការប្រព្រឹត្តបទល្មើស ឬ អ្នកនាំឱ្យមានការប្រព្រឹត្តបទល្មើស ក្នុងការធ្វើរបាយការណ៍ បញ្ជីប្រាក់ចំណូល កំណត់ហេតុ ឬឯក-សារផ្សេងៗទៀត ដែលត្រូវផ្ញើទៅក្រសួងពាណិជ្ជកម្ម ឬ ទៅបុគ្គលផ្សេងទៀត ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី ១.០០០.០០០(មួយលាន)រៀល ដល់ ១០.០០០.០០០ (ដប់លាន)រៀល និង/ ឬ ជាប់ពន្ធនាគារពី ១(មួយ) ខែ ដល់ ៦(ប្រាំមួយ) ខែ ដោយមិនទាន់គិតពីសំណងរដ្ឋប្បវេណី ឬ ទោសទណ្ឌដែលមានចែងក្នុងច្បាប់ពាក់ព័ន្ធផ្សេងៗទៀត ។

### មាត្រា ២៩១.-

នៅពេលក្រុមហ៊ុនប្រព្រឹត្តបទល្មើស អភិបាល ឬ បុគ្គលិករបស់ក្រុមហ៊ុនណាដែលបានប្រគល់សិទ្ធិឱ្យប្រព្រឹត្តបទល្មើស ឬអនុញ្ញាត ឬបានយល់ព្រមឱ្យប្រព្រឹត្តបទល្មើស ជាអ្នកទទួលខុសត្រូវមួយនៃបទល្មើសនោះ នឹងត្រូវទទួលទោសទណ្ឌដូចមានចែងក្នុងមាត្រា ២៩០ នៃច្បាប់នេះ ។

### មាត្រា ២៩២.-

បណ្តឹងចំពោះបទល្មើសដែលបានប្រព្រឹត្តក្រោមច្បាប់នេះ ត្រូវធ្វើឡើងរយៈពេល ៣(បី)ឆ្នាំយ៉ាងយូរ ចាប់តាំងពីថ្ងៃដែលកម្មវត្ថុនៃបណ្តឹងនោះបានកើតឡើង ។

**មាត្រា ២៩៣.-**

ការខកខានមិនបានអនុវត្តតាមច្បាប់នេះ ដំណោះស្រាយដោយសំណងរដ្ឋប្បវេណីមិនមានឥទ្ធិពលលើបទល្មើសនោះឡើយ ។

**មាត្រា ២៩៤.-**

ក្រុមហ៊ុន ឬរូបវន្តបុគ្គលដែលមិនបានអនុវត្តដោយគ្មានមូលហេតុត្រឹមត្រូវតាមបញ្ញត្តិស្តីពីការចុះបញ្ជីពាណិជ្ជកម្ម ការតម្កល់ឯកសារទុក ការផ្សព្វផ្សាយ តាមតម្រូវការនៃច្បាប់នេះ ត្រូវផ្តន្ទាទោសតាមមាត្រា ៤៣ និង ៤៤ថ្មី នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ។

**មាត្រា ២៩៥.-**

ក្រុមហ៊ុន ឬរូបវន្តបុគ្គលដែលបានប្រព្រឹត្តបទល្មើសនឹងបទប្បញ្ញត្តិនៅក្នុងចំណុច គ ផ្នែកទី ២ នៃជំពូកទី ៣ ដែលពាក់ព័ន្ធនឹងសៀវភៅបញ្ជី និងកំណត់ហេតុ ត្រូវផ្តន្ទាទោសតាមមាត្រា៤៣ និង ៤៤ ថ្មី នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីណិជ្ជកម្ម ។

**មាត្រា ២៩៦.-**

ក្រុមហ៊ុនដែលខកខានដោយគ្មានមូលហេតុត្រឹមត្រូវក្នុងការផ្ញើឯកសាររបាយការណ៍ហិរញ្ញវត្ថុទៅម្ចាស់ហ៊ុន និងការបញ្ជូនច្បាប់ចម្លងរបាយការណ៍ហិរញ្ញវត្ថុទៅឱ្យម្ចាស់ហ៊ុនដូចបានចែងក្នុងមាត្រា ២២៧ ត្រូវផ្តន្ទាទោសពិន័យជាទឹកប្រាក់ចំនួនពី ១.០០០.០០០(មួយលាន)រៀល ដល់ ១០.០០០.០០០(ដប់លាន)រៀល ។

**មាត្រា ២៩៧.-**

ក្រុមហ៊ុនដែលខកខានដោយគ្មានមូលហេតុត្រឹមត្រូវ ក្នុងការបញ្ជូនច្បាប់ចម្លងរបាយការណ៍ហិរញ្ញវត្ថុ ឱ្យទៅមន្ត្រីគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ដូចបានចែងក្នុងមាត្រា ២២៨ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី ១.០០០.០០០(មួយលាន) រៀល ដល់ ១០.០០០.០០០(ដប់លាន)រៀល ។

**មាត្រា ២៩៨.-**

សវនករបច្ចុប្បន្ន ឬ សវនករពីមុនរបស់ក្រុមហ៊ុនដែលខកខានដោយគ្មានមូល-ហេតុត្រឹមត្រូវ ក្នុងការបំពេញកាតព្វកិច្ច ការចូលរួមក្នុងមហាសន្និបាតម្ចាស់ហ៊ុនដូចបានចែងក្នុងមាត្រា ២៣៤ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី ១.០០០.០០០ (មួយលាន)រៀល ដល់១០.០០០.០០០(ដប់លាន)រៀល និង/ឬ ជាប់ពន្ធនាគារពី ១(មួយ)ខែ ដល់ ៦(ប្រាំមួយ)ខែ ។

**មាត្រា ២៩៩.-**

មន្ត្រីគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬ មិនគោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬ ជួយសម្រួលក្នុងការប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល និង/ឬ ត្រូវចោទប្រកាន់ចំពោះមុខតុលាការ ។

## ជំពូកទី ៧

## អន្តរប្បញ្ញត្តិ

**មាត្រា ៣០០.-**

ច្បាប់នេះមិនធ្វើឱ្យប៉ះពាល់ដល់សុពលភាព និង ដល់កិច្ចដំណើរការនៃក្រុមហ៊ុនទាំងអស់ ដែលបានធ្វើការចុះបញ្ជីត្រឹមត្រូវរួចស្រេចហើយនៅក្នុងបញ្ជីពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣០១.-**

ច្បាប់នេះត្រូវអនុវត្តចំពោះរាល់ដំណើរការរបស់ក្រុមហ៊ុនទាំងអស់ ក្នុងទំនាក់ទំនងផ្តល់ឯកសារ និងព័ត៌មានផ្សេងៗជូនក្រសួងពាណិជ្ជកម្ម ។

**មាត្រា ៣០២.-**

ក្រសួងពាណិជ្ជកម្មត្រូវរៀបចំគំរូលក្ខន្តិកៈនិងបែបបទកែលក្ខន្តិកៈស្របតាមច្បាប់នេះ ដើម្បីផ្សព្វផ្សាយជូនដល់ក្រុមហ៊ុនទាំងឡាយដែលបានចុះបញ្ជីពាណិជ្ជកម្មរួចហើយ ហើយដែលមានបំណងធ្វើការកែប្រែលក្ខន្តិកៈរបស់ខ្លួន ។

## ជំពូកទី ៨
## អវសានបញ្ញត្តិ

**មាត្រា ៣០៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣០៤.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស.០៥០៦.២៩៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**ហត្ថលេខា**
**ចម ប្រសិទ្ធ**

ព្រះ ២៥៤៥ - ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឈាឌី តាន់

**ខុទ្ទកាល័យព្រះមហាក្សត្រ**

**ព្រះរាជក្រម**

**ព្រះរាជក្រម/នស/រកម/០២៩៧/០៣**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកម-១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួល - សមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស-រកត-០១៩៦-១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រ - សួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និងអំពីទេសរដ្ឋមន្ត្រី ទទួលបន្ទុកនីតិសម្បទា និងអភិវឌ្ឍន៍ និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ប្រកាសអោយប្រើ**

ច្បាប់ស្តីពីសារពើពន្ធ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៨ ខែ មករា ឆ្នាំ ១៩៩៧ នាសម័យប្រជុំលើកទី ៧ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ជំពូកទី ១
# បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណេញ
## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណេញ ដូចមានចែងក្នុងច្បាប់ស្តីអំពីហិរញ្ញវត្ថុសម្រាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៨ នស ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខជស/រកម/០៩៩៥/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ត្រូវបានធ្វើវិសោធនកម្ម ដូចតទៅដើម្បីជាគុណប្រយោជន៍ដល់ថវិការដ្ឋ ។

**មាត្រា ២.-**

ពន្ធលើប្រាក់ចំណេញ គឺជាបំណុលរបស់បុគ្គលិកនិវាសនជនចំពោះប្រាក់ចំណូលប្រភពកម្ពុជា និងប្រាក់ចំណូលប្រភពបរទេស និងរបស់បុគ្គលអនិវាសនជន ចំពោះប្រាក់ចំណូលប្រភពកម្ពុជា ។

**មាត្រា ៣.-**

សម្រាប់គោលដៅនៃបទប្បញ្ញត្តិស្តីពីសារពើពន្ធ :

១ - ពាក្យ "អ្នកជាប់ពន្ធនិវាសនជន" សំដៅដល់ :

ក. រូបវន្តបុគ្គលដែលស្នាក់នៅ ឬមានកន្លែងស្នាក់នៅជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាលើសពី ១៨២ថ្ងៃនៅក្នុងឆ្នាំប្រតិទិន ។

ខ. នីតិបុគ្គល ឬក្រុមអាជីវកម្ម ដែលត្រូវបានបង្កើត ឬត្រូវបានគ្រប់គ្រងនៅព្រះរាជាណាចក្រកម្ពុជា ឬដែលមានកន្លែងប្រកបអាជីវកម្មជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ គ្រឹះស្ថានអចិន្ត្រៃយត្រូវចាត់ទុកជានីតិបុគ្គល និវាសនជន ចំពោះតែប្រាក់ចំណូលប្រភពកម្ពុជា ។

២ - ពាក្យ "អនិវាសនជន" មានន័យថា ដែលមិនមែនជានិវាសនជនកម្ពុជា ។

៣ - ពាក្យ (នីតិបុគ្គល) សំដៅដល់សហគ្រាស ឬអង្គការនានា ដែលប្រកបអាជីវកម្ម ទោះបីជាបាន ឬមិនទាន់បានទទួលស្គាល់ជាផ្លូវការពីស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលក្តី ។ ពាក្យ "នីតិបុគ្គល" រួមបញ្ចូលផងដែរ នូវស្ថាប័នរដ្ឋាភិបាល អង្គការសាសនា អង្គការសប្បុរសធម៌ ឬអង្គការមិនស្វែងរកចំណេញ ។ ចំពោះបុគ្គលអនិវាសនជន ពាក្យ "នីតិបុគ្គល" សំដៅដល់គ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ពាក្យ "នីតិបុគ្គល" ពុំរាប់បញ្ចូលទេនូវ ក្រុមអាជីវ

កម្ម ឬសហគ្រាសឯកបុគ្គល ។

៤ - ពាក្យ "គ្រឹះស្ថានអចិន្ត្រៃយ៍" សំដៅដល់ទីកន្លែងប្រកបអាជីវកម្មជាប់លាប់នៅព្រះរាជាណាចក្រកម្ពុជា សាខារបស់ក្រុមហ៊ុនបរទេស ឬភ្នាក់ងារនិវាសជននៅព្រះរាជាណាចក្រកម្ពុជា ដែលតាមរយៈនេះបុគ្គលអនិវាសនជនប្រកបអាជីវកម្មរបស់ខ្លួន ។ ពាក្យ "គ្រឹះស្ថានអចិន្ត្រៃយ៍" រួមបញ្ចូលផងដែរ នូវសមាគម ឬរូបភាពទំនាក់ទំនងផ្សេងទៀត ដែលតាមរយៈនេះបុគ្គល អនិវាសជនធ្វើសកម្មភាពសេដ្ឋកិច្ច នៅព្រះរាជាណាចក្រកម្ពុជា ។

៥ - ពាក្យ "ក្រុមអាជីវកម្ម" សំដៅដល់ក្រុមសមូហនាមដែលមានម្ចាស់ភាគទុនជារូបវន្តបុគ្គលនិវាសជនយ៉ាងច្រើន ១០នាក់ ហើយក្នុងនោះចំណែកសមាមាត្ររបស់ម្ចាស់ភាគទុននៅក្នុងខ្ទង់មូលធន ប្រាក់ចំណេញ និងការខាតបង់ត្រូវស្របតាមលក្ខណៈវិនិច្ឆ័យ ដែលត្រូវកំណត់ដោយអនុក្រឹត្យ ។ ក្នុងនិយមន័យនេះ "ក្រុមអាជីវកម្ម" មិនអាចជាសមាជិករបស់ក្រុមហ៊ុនបុគ្គលណាមួយ ហើយក៏មិនរាប់បញ្ចូលផងទេនូវក្រុមហ៊ុនដើមទុន គ្រឹះស្ថានអចិន្ត្រៃយ៍ ឬសហគ្រាសឯក-បុគ្គល ។

៦- ពាក្យ "សហគ្រាសឯកបុគ្គល" សំដៅដល់សហគ្រាសអាជីវកម្មដែលជាកម្មសិទ្ធិ ១០០ ភាគរយរបស់រូបវន្តបុគ្គលណាម្នាក់ ។ ក្នុងនិយមន័យនេះ ប្តី ប្រពន្ធ និងកូនក្នុងបន្ទុកត្រូវចាត់ទុក ថាជារូបវន្តបុគ្គលតែម្នាក់ ។

៧- ពាក្យ "អាជីវកម្ម" សំដៅដល់ សកម្មភាពសេដ្ឋកិច្ចរបស់បុគ្គលដែលមានគោលដៅទាញយកប្រាក់ចំណូលអំពីការផលិត និងលក់ទំនិញ ការផ្គត់ផ្គង់សេវា ភតិសន្យា ការជួល ឬការលក់ទ្រព្យសម្បត្តិ ឬសកម្មភាពផ្សេងទៀត ។

៨- ពាក្យ "ភាគលាភ" សំដៅដល់ ចំណែកជាសាច់ប្រាក់ ឬជាទ្រព្យដែលនីតិបុគ្គលបានចែកឱ្យអ្នកចូលហ៊ុនទៅតាមកម្រិត នៃភាគកម្មរបស់ខ្លួននៅក្នុងដើមទុនផ្ទាល់របស់នីតិបុគ្គល លើកលែងតែ ភាគលាភជាប័ណ្ណភាគហ៊ុន និងការបែងចែកនានា ក្នុងពេលជំរះបញ្ជីរំលាយក្រុមហ៊ុនទាំងស្រុង ។ ចំណែកណាមួយ ដែលចាត់ទុកថាជាភាគលាភ ឬមិនមែនជាភាគលាភត្រូវផ្អែកតាមលក្ខខណ្ឌខាងលើនេះ ដោយពុំគិតថានីតិបុគ្គលមាន ឬគ្មានប្រាក់ចំណូល ឬប្រាក់ចំណេញចរន្ត ឬលទ្ធផលយោងសារជាថ្មីឡើយ ។

៩- ពាក្យ "អ្នកចូលហ៊ុន" សំដៅដល់ បុគ្គលដែលមានចំណែកភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់នីតិបុគ្គល ។ សម្រាប់គោលដៅនៃពន្ធនេះ នីតិបុគ្គលណាមួយ ទោះបីមិនមែនជាក្រុមហ៊ុនដើមទុនក្តី ត្រូវចាត់ទុកដូចជាក្រុមហ៊ុនដើមទុន ហើយបុគ្គលដែលមានចំណែកភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់នីតិបុគ្គល ឬក៏បុគ្គលអាចបានទទួលប្រាក់ចំណូល ឬប្រាក់-ចំណេញក្នុងឋានៈជាអ្នកបានចូលរួមក្នុងនីតិបុគ្គលនោះ ត្រូវចាត់ទុកថាជាអ្នកចូលហ៊ុនរបស់នីតិបុគ្គលដែរ ។

១០-ពាក្យ "សហគ្រាសវិនិយោគ" សំដៅដល់ សហគ្រាសដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានទទួលស្គាល់ថាជាសហគ្រាសវិនិយោគ និងដែលបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ។

១១-ពាក្យ "បុគ្គលទាក់ទិន" សំដៅដល់ :

ក. សមាជិកណាម្នាក់ក្នុងគ្រួសារអ្នកជាប់ពន្ធ

ខ. សហគ្រាសដែលគ្រប់គ្រងលើអ្នកជាប់ពន្ធ ឬសហគ្រាសត្រូវបានអ្នកជាប់ពន្ធគ្រប់គ្រង ឬក៏សហគ្រាសនោះនិងអ្នកជាប់ពន្ធស្ថិតនៅក្រោមការគ្រប់គ្រងរួមគ្នា ពាក្យ "គ្រប់គ្រង" មានន័យថា មានកម្មសិទ្ធិចាប់

ពី ៥១ភាគរយឡើងទៅលើតំលៃ ឬសិទ្ធិបោះឆ្នោតនៃភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់សហគ្រាស ។ ដើម្បីកំណត់ទំហំនៃការគ្រប់គ្រងរបស់អ្នកជាប់ពន្ធជារូបវន្តបុគ្គលណាម្នាក់ ត្រូវគិតបញ្ចូលទាំងអស់នូវកម្មសិទ្ធិលើភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់រូបវន្តបុគ្គលនោះ និងកម្មសិទ្ធិផ្ទាល់ ឬប្រយោលរបស់សហព័ទ្ធអ្នកជាប់ពន្ធ ។

**មាត្រា ៤.~**

របបកំណត់ពន្ធមានដូចតទៅ :

១-ការកំណត់ពន្ធលើប្រាក់ចំណេញ ត្រូវអនុវត្តតាមរបបពិត របបបំព្រួញ និងរបបម៉ៅការ ។

២-វិធាន និង នីតិវិធីដើម្បីចាត់បញ្ចូលអ្នកជាប់ពន្ធអោយស្ថិតក្នុងរបបកំណត់ពន្ធណាមួយនៃរបបទាំង ៣ ខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ ដោយផ្អែកលើទ្រង់ទ្រាយអាជីវកម្ម ប្រភេទសកម្មភាពអាជីវកម្ម និងកម្រិតផលរបរ ។

## ផ្នែកទី ២

## ប្រាក់ចំណេញជាប់ពន្ធ និងអត្រាពន្ធ

**មាត្រា ៥.~**

ឆ្នាំជាប់ពន្ធត្រូវបានកំណត់ដូចខាងក្រោម :

១-ពន្ធលើប្រាក់ចំណេញអនុវត្តចំពោះរបបពិត ត្រូវគណនាចេញពីលទ្ធផលនៃតុល្យការសំរេចបានក្នុងឆ្នាំសារពើពន្ធកន្លងទៅ ។

២-ប្រសិនជាពុំមានតុល្យការណាមួយ បានបញ្ឈប់ក្នុងកំឡុងនៃឆ្នាំណាមួយទេនោះ ពន្ធដែលត្រូវបង់សំរាប់ឆ្នាំជាបន្ទាប់ត្រូវគិតយកលើប្រាក់ចំណេញក្នុងរយៈវេលាដែលកន្លងទៅ ចាប់តាំងពីថ្ងៃផុតរយៈពេលជាប់ពន្ធដែលកន្លងហួសទៅនោះ ។ ចំពោះសហគ្រាសថ្មី ត្រូវគិតចាប់តាំងពីថ្ងៃដែលផ្តើមធ្វើប្រតិបត្តិការមកទល់នឹងថ្ងៃទី ៣១ ធ្នូ នៃឆ្នាំដែលត្រូវគិតពន្ធ ។

៣-កាលបើមានធ្វើតុល្យការជាច្រើនតៗគ្នា ក្នុងកំឡុងនៃឆ្នាំមួយដដែលនោះ លទ្ធផលនៃតុល្យការទាំងឡាយនេះត្រូវបូករួមគ្នាធ្វើជាមូលដ្ឋាននៃពន្ធដែលត្រូវបង់ ។

៤-ពន្ធលើប្រាក់ចំណេញអនុវត្តចំពោះរបបបំព្រួញ និងរបបម៉ៅការត្រូវគណនាតាមវិធីគណនេយ្យមូលដ្ឋានសាច់ប្រាក់នៅក្នុងឆ្នាំប្រតិទិនកន្លងមក ។

៥-សេចក្តីណែនាំនានា ស្តីអំពីការធ្វើរបាយការណ៍ ការដាក់លិខិតប្រកាសចុងក្រោយសម្រាប់សហគ្រាសដែលបញ្ឈប់អាជីវកម្ម ឬរៀបចំឡើងវិញ ឬត្រូវបានលក់ ឬផ្ទេរក្នុងឆ្នាំប្រតិទិនត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៦.~**

វិធានគណនេយ្យត្រូវកំណត់ដូចខាងក្រោម :

១-ចំពោះអ្នកជាប់ពន្ធតាមរបបបំព្រួញដែលប្រើវិធីគណនេយ្យមូលដ្ឋានសាច់ប្រាក់ បាក់ចំណូលត្រូវគិតបញ្ចូល

ក្នុងឆ្នាំដែលបានទទួលជាក់ស្តែងនូវសាច់ប្រាក់ ឬទ្រព្យដទៃទៀត ទោះបីជាការទូទាត់បានធ្វើឡើងសំរាប់ឆ្នាំផ្សេងទៀតក្តី ។ ឯចំណាយ ឬការកាត់កងនានាអាចផាត់ចេញនៅក្នុងឆ្នាំដែលចំណាយ ឬខ្ចង់ផ្សេងទៀត ត្រូវបានទូទាត់សងជាក់ស្តែងលើកលែងតែចំណាយទូទាត់មុន និងទាយជូទានឱ្យដល់រំលស់ ។

២-ចំពោះអ្នកជាប់ពន្ធតាមរបបពិត ដែលប្រើវិធីគណនេយ្យតាមប្លង់គណនេយ្យទូទៅ ប្រាក់ចំណូលត្រូវគិត-បញ្ចូលនៅក្នុងឆ្នាំដែលចំណូលនោះបានកើតឡើង ទោះបីប្រាក់ចំណូលនោះបានទូទាត់ ឬមិនបានទូទាត់ក្តី ។ ការកាត់កងចំណាយណាមួយអាចធ្វើទៅបាន លុះណាតែហេតុការណ៍បញ្ជាក់នូវបន្ទុករបស់អ្នកជាប់ពន្ធបានកើតឡើង លទ្ធផលនៃសកម្មភាពសេដ្ឋកិច្ចដែលជាប់ទាក់ទងដល់ខ្ចង់ចំណាយនោះបានកើតឡើង និងចំនួនទឹកប្រាក់ដែលជាបន្ទុករបស់អ្នកជាប់ពន្ធអាចបង្ហាញច្បាស់លាស់ ។

៣-ចំពោះអ្នកជាប់ពន្ធតាមរបបពិត ចំណាយនានាធ្វើឡើងចំពោះបុគ្គលទាក់ទិនដែលស្ថិតក្រោមរបបបំព្រួញមិនអនុញ្ញាតអោយផាត់ចេញមុនការទូទាត់ជាក់ស្តែងឡើយ ។

៤-ចំពោះធនាគារ និងស្ថាប័នសញ្ញ័យធនក្នុងស្រុក ត្រូវបានអនុញ្ញាតអោយធ្វើសំវិធានធនសម្រាប់ឥណទេយ្យជាប់សង្ស័យ ដើម្បីកំណត់ប្រាក់ចំណេញជាប់ពន្ធ ។ វិធាន និងនីតិវិធីស្តីពីការកាត់កងនានាត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧.-**

ប្រាក់ចំណេញជាប់ពន្ធ គឺជាប្រាក់ចំណេញសុទ្ធបានមកពីលទ្ធផលទាំងអស់នៃប្រតិបត្តិការគ្រប់ប្រភេទដែលសហ-គ្រាសសំរេចបាន រួមបញ្ចូលទាំងតំលៃលើសបានមកពីការលក់ ចំណែកនានានៃទ្រព្យសកម្មក្នុងពេលកំពុងប្រកបអាជីវកម្ម ឬនៅពេលបញ្ចប់អាជីវកម្ម ព្រមទាំងប្រាក់ចំណូលអំពីកិច្ចប្រតិបត្តិការ ហិរញ្ញវត្ថុ ឬវិនិយោគ ការប្រាក់ ថ្លៃឈ្នួល និងសួយសារផង ។

**មាត្រា ៨.-**

ប្រាក់ចំណេញជាប់ពន្ធ កើតចេញពីចំនួនលើសនៃផលដុលដែលសំរេចបាន អាស្រ័យដោយមានការចំណាយ ដើម្បីនាំមកវិញ និងរក្សាទុកនូវចំណេញ ។

**មាត្រា ៩.-**

ប្រាក់ចំណេញលើកលែងពន្ធ ត្រូវបានកំណត់ដូចតទៅ :

១-វៀរលែងតែមានបទប្បញ្ញត្តិផ្ទុយ និងលើកលែងតែប្រាក់ចំណូលដែលត្រូវជាប់ពន្ធតាមមាត្រា ២២ នៃច្បាប់នេះ ពន្ធលើប្រាក់ចំណេញមិនត្រូវអនុវត្តចំពោះ :

ក-ប្រាក់ចំណូលរបស់រាជរដ្ឋាភិបាល ឬប្រាក់ចំណូលស្ថាប័នរាជរដ្ឋាភិបាល

ខ-ប្រាក់ចំណូលរបស់អង្គការណាមួយដែល :

- ត្រូវបានរៀបចំឡើង និងដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា សប្បុរសធម៌ វិទ្យា-សាស្ត្រ អក្សរសាស្ត្រ ឬអប់រំ

- គ្មានចំណែកណាមួយនៃទ្រព្យ ឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជន

គ-ប្រាក់ចំណូលរបស់អង្គការពលករ ឬសភាពាណិជ្ជកម្ម ឧស្សាហកម្ម ឬកសិកម្មក្នុងករណីដែលប្រាក់ចំណូលរបស់អង្គការទាំងនោះ មិនត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជន របស់អ្នកចូលហ៊ុន ឬរូបវន្តបុគ្គល

ឃ-ប្រាក់ចំណេញដែលបានមកពីការលក់ផលិតផលកសិកម្ម ដែលបុគ្គលមិនមែនជាអ្នកជាប់ពន្ធ តាមរបបពិតផលិតបានដោយខ្លួនឯង ទោះបីផលិតផលនោះមិនទាន់កែច្នៃ ឬកែច្នៃហើយក៏ដោយទៅតាមទម្លាប់នៃការងារកសិកម្ម ។ ប្រតិបត្តិការតាមមធ្យោបាយឧស្សាហកម្ម រួមទាំងការកែច្នៃ ការក្សាគុណភាព ការវេចខ្ចប់ សំរាប់លក់ពុំត្រូវបានចាត់ទុកជាទម្លាប់នៃការងារកសិកម្មឡើយ ។

២-ក្រសួងកសិកម្ម និងហិរញ្ញវត្ថុ ត្រូវកំណត់ដោយប្រកាសអំពីនីតិវិធីនៃការស្នើសុំលើកលែងពន្ធភាពបាត់បង់លក្ខណៈលើកលែងពន្ធ ការប្រកាសសារពើពន្ធ និងការចុះបញ្ជី ។

**មាត្រា ១០.-**

ប្រាក់ចំណូលរបស់ក្រុមអាជីវកម្មត្រូវបានកំណត់ដូចតទៅ :

១-ចំពោះក្រុមអាជីវកម្ម ក្នុងការកំណត់ប្រាក់ចំណូលរបស់ខ្លួនសំរាប់ឆ្នាំជាប់ពន្ធណាមួយសមាជិកម្នាក់ៗ ត្រូវគិតដាច់ដោយពីគ្នានូវចំណែករៀងៗខ្លួន នៅក្នុងខ្ទង់ចំណូល ចំណេញ ខាត ការកាត់កង ឥណទាន និងវិភាគទានសប្បុរសធម៌ក្នុងឆ្នាំនោះ ។ សម្រាប់គោលដៅនេះ ខ្ទង់នីមួយៗត្រូវរក្សាចរិតលក្ខណៈនៅដដែល ហើយត្រូវចាត់ទុកថា បានបែងចែកនៅក្នុងឆ្នាំជាប់ពន្ធ ទោះបីជាមាន ឬគ្មានការបែងចែកជាក់ស្តែងក្តី ។ ការខាតបង់ដែលត្រូវយោងទៅឆ្នាំមុខនឹងត្រូវកំណត់ឡើងក្រោយពីបានបែងចែកខ្ទង់នានាហើយ ។

២-វិធានសំរាប់កំណត់ចំនួនទឹកប្រាក់ដែលត្រូវបែងចែក ការចាត់ចែងចំពោះវិភាគទានផ្សេងៗ និងការកែតម្រូវទៅលើចំណែកជាមូលដ្ឋានរបស់សមាជិកម្នាក់ៗ នៃក្រុមអាជីវកម្មនៅក្នុងឆ្នាំជាប់ពន្ធណាមួយ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ផ្នែកទី ៣

## ការកាត់កង

**មាត្រា ១១.-**

ការកាត់កងដែលអនុញ្ញាតត្រូវបានកំណត់ដូចតទៅ :

១- វៀរលែងតែបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១២ ដល់មាត្រា១៨ នៃច្បាប់នេះ ចំណាយដែលអនុញ្ញាតឱ្យកាត់កងរួមមានបន្ទុកដែលអ្នកជាប់ពន្ធបានទូទាត់ ឬត្រូវសងនៅក្នុងឆ្នាំជាប់ពន្ធដើម្បីប្រកបអាជីវកម្ម ។

២- ថ្លៃឈ្នួល ការប្រាក់ ការប៉ះប៉ូវ ការទូទាត់ ឬកម្រៃនានាដែលបានបើកអោយអ្នកទទួលខុសត្រូវ ឬអភិបាលរបស់សហគ្រាស សមាជិកភាពទុន ឬសមាជិករបស់ក្រុមហ៊ុនអាជីវកម្ម សមាជិកនៃគ្រួសារអ្នកជាប់ពន្ធ ឬបុគ្គលទាក់ទិនផ្សេងទៀតក្នុងករណីមានភស្តុតាងបញ្ជាក់ថាការទូទាត់នោះបានអនុវត្តចំពោះការបំពេញសេវាជាក់ស្តែង ហើយក្នុងកំរិតសមហេតុសមផលផងដែរ ។

៣- ប្រាក់ដែលបានទូទាត់លើអាគារថ្មី ឬទ្រព្យសកម្មដទៃទៀត ការកែលំអជាប់លាប់ ឬការកែលំអនានាក្នុង នោះមានទាំងការប្រាក់ និងប្រាក់ពន្ធអាករ ដែលបានបង់ក្នុងរយៈពេលសាងសង់ ឬទិញចូលផង ។ ទឹក-ប្រាក់នេះត្រូវកត់ត្រាចូលក្នុងគណនីទ្រព្យសកម្មដែលពាក់ព័ន្ធ ហើយត្រូវកាត់កងតាមការរំលស់ ដូចមាន មានចែងក្នុងមាត្រា ១៣ នៃច្បាប់នេះ ។

**មាត្រា ១២.-**

ត្រូវបានអនុញ្ញាតឱ្យកាត់កងនូវចំណាយលើការប្រាក់ដែលអ្នកជាប់ពន្ធបានទូទាត់ ឬត្រូវសងនៅក្នុងឆ្នាំជាប់ពន្ធដើម្បីប្រកបអាជីវកម្ម ប៉ុន្តែមិនឱ្យលើសពីផលបូកនៃចំណូលការប្រាក់របស់អ្នកជាប់ពន្ធ និង៥០ភាគរយនៃប្រាក់ចំណូលសុទ្ធក្រៅពីការប្រាក់របស់អ្នកជាប់ពន្ធនៅក្នុងឆ្នាំជាប់ពន្ធ ។

ចំណូលសុទ្ធក្រៅពីការប្រាក់ គឺជាប្រាក់ចំណូលដុលក្រៅពីចំណូលការប្រាក់ ដកខ្ទង់ចំណាយនានាដែលអនុញ្ញាតឱ្យផាត់ចេញលើកលែងតែចំណាយការប្រាក់ ។

ចំណាយការប្រាក់ដែលសល់ពីការកាត់កងខាងលើ ត្រូវចាត់ទុកជាចំណាយការប្រាក់សម្រាប់ ឆ្នាំជាប់ពន្ធបន្ទាប់ ហើយការផាត់ចេញត្រូវអនុវត្តតាមខ្លឹមសារនៃមាត្រានេះដូចគ្នា ។

**មាត្រា ១៣.-**

ល័ក្ខខ័ណ្ឌនៃរំលស់ទ្រព្យរូបីត្រូវបានកំណត់ដូចតទៅ :

១- ទាយជ្ជទានឱ្យដល់រំលស់ត្រូវគណនាតាមវិធីរំលស់ស្មើភាគ ឬវិធីរំលស់ថយជាលំដាប់ ។ ទ្រព្យរូបីដែលអាចរំលស់បាន គឺទ្រព្យរូបីប្រើប្រាស់ក្នុងអាជីវកម្មដែលតែងតែបាត់បង់តម្លៃដោយការប្រើប្រាស់ ឬភាពហួសសម័យ ។ ដីធ្លីមិនមែនជាទ្រព្យអាចរំលស់បានទេ ។

២- ទ្រព្យរូបីទាំងអស់ ត្រូវបានបែងចែកជា ៤ ប្រភេទ :

ក.ប្រភេទទី១ រួមមាន អាគារ និងសំណង់ ដែលជាឧបសម្ព័ន្ធនៃអាគារនោះ ។ ទ្រព្យមួយៗក្នុងប្រភេទនេះ ត្រូវរំលស់តាមវិធីស្មើភាគតាមអត្រា ៥ភាគរយក្នុង១ឆ្នាំ ។

ខ.ប្រភេទទី២ រួមមានទ្រព្យដែលមានអាយុកាលប្រើប្រាស់ត្រឹម ៤ឆ្នាំ ហើយអត្រារំលស់ស្មើភាគលើទ្រព្យនីមួយៗ គឺ ២៥ ភាគរយ

គ.ប្រភេទទី៣ រួមមាន ទ្រព្យដែលមានអាយុកាលប្រើប្រាស់លើសពី ៤ឆ្នាំ ដល់៨ឆ្នាំ ហើយអត្រារំលស់ស្មើភាគលើទ្រព្យនីមួយៗ គឺ ១២,៥ ភាគរយ

ឃ.ប្រភេទទី៤ រួមមាន ទ្រព្យរូបីឯទៀតទាំងអស់ ហើយអត្រារំលស់ស្មើភាគលើទ្រព្យនីមួយៗ គឺ ១០ភាគរយ ។

៣- អ្នកជាប់ពន្ធដែលជ្រើសរើសយកវិធីរំលស់ថយជាលំដាប់ ត្រូវប្រើអត្រារំលស់ស្មើនឹង ២០០ភាគនៃអត្រារំលស់តាមវិធីស្មើភាគ ហើយត្រូវអនុវត្តលើតំលៃសរុបមិនទាន់រំលស់អស់នៃទ្រព្យទាំងអស់ នៅក្នុងប្រភេទនីមួយៗ ។ ត្រូវបានអនុញ្ញាតឱ្យប្រើវិធីរំលស់ថយជាលំដាប់តែចំពោះប្រភេទទ្រព្យ ទី២ ទី៣ និងទី៤

តែប៉ុណ្ណោះ ។

៤- សហគ្រាសដែលស្ថិតក្រោមច្បាប់វិនិយោគត្រូវប្រើវិធីរំលស់ស្មើភាគចំពោះទ្រព្យគ្រប់ប្រភេទ ។

៥- នីតិវិធីក្នុងការបង្កើតប្រភេទទ្រព្យ ការបញ្ចូលទ្រព្យថ្មីទៅក្នុងប្រភេទណាមួយ ការបញ្ចេញទ្រព្យពីប្រភេទណាមួយ ហើយនិងការចាត់ចែងចំពោះបញ្ហាជួសជុលព្រមទាំងចំណាយផ្សេងៗ ត្រូវកំណត់ដោយអនុក្រឹត្យ ។

៦- អ្នកជាប់ពន្ធដែលស្ថិតក្រោមច្បាប់ពន្ធលើប្រាក់ចំណាយនៅមុនថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៧ ត្រូវធ្វើការជ្រើសរើសដែលមិនអាចកែប្រែវិញបាន នូវវិធីរំលស់តាមវិធីស្មើភាគ ឬតាមវិធីរំលស់ថយជាលំដាប់ ចំពោះទ្រព្យដែលមិនទាន់រំលស់អស់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ។ ចំពោះអ្នកជាប់ពន្ធថ្មី ការជ្រើសរើសត្រូវធ្វើឡើងយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ នៃឆ្នាំចុះបញ្ជី ។

**មាត្រា ១៤.-**

ចំពោះទ្រព្យរូបី ដែលរួមមានប្រកាសនីយប័ត្រតក្កកម្ម សិទ្ធិចម្លង គំនូរប្លង់ គំរូ និងសិទ្ធិអាជីវកម្ម ដែលមានអាយុកាលមានកំណត់ អត្រារំលស់លើទ្រព្យនីមួយៗ ត្រូវគណនាដោយផ្អែកលើអាយុកាលរបស់ទ្រព្យនោះតាមវិធីរំលស់ស្មើភាគ ។ បើសិនជាអាយុកាលនៃទ្រព្យអរូបីមិនអាចកំណត់បាន រំលស់ប្រចាំឆ្នាំត្រូវអនុវត្តតាមអត្រា ១០ភាគរយ លើតម្លៃទ្រព្យអរូបី ។

**មាត្រា ១៥.-**

ការរំលស់ធនធានធម្មជាតិត្រូវបានកំណត់ដូចតទៅ :

១- ទាយជ្ជទានឱ្យដល់ការរំលស់លើធនធានធម្មជាតិ មានជាអាទិ៍ ប្រេងកាត និងឧស្ម័នធម្មជាតិត្រូវបានកំណត់ដូចតទៅ :

ក.ចំណាយក្នុងការរុករក និងអភិវឌ្ឍន៍ ក្នុងនោះមានទាំងការប្រាក់ដែលជាប់ទាក់ទងដល់ចំណាយនោះផង ត្រូវបូកបញ្ចូលទៅក្នុងគណនីទ្រព្យសកម្មនៃធនធាននោះ ។

ខ.ទឹកប្រាក់រំលស់លើធនធានធម្មជាតិនីមួយៗ ដែលត្រូវផាត់ចេញនៅក្នុងឆ្នាំជាប់ពន្ធណាមួយត្រូវគណនាដោយយកសមតុល្យនៃគណនីធនធានធម្មជាតិ ទៅគុណនឹងផលចែករវាងបរិមាណដែលបានផលិតចេញអំពីធនធានធម្មជាតិនៅក្នុងឆ្នាំ និងចំនួនប៉ាន់ស្មាននៃផលិតផលសរុបដែលអាចទាញយកបានពីធនធាននោះ ។

២- នីតិវិធីសំរាប់កំណត់ចំនួនប៉ាន់ស្មាននៃផលិតផលសរុប ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៦.-**

ត្រូវបានអនុញ្ញាតអោយផាត់ចេញ នូវវិភាគទានសប្បុរសធម៌ដែលបានបរិច្ចាគឱ្យអង្គការនានាដូចមានចែងក្នុងមាត្រា៩ នៃច្បាប់នេះ ប៉ុន្តែមិនត្រូវអោយលើសពី ៥ភាគរយ នៃប្រាក់ចំណេញជាប់ពន្ធមុនពេលកាត់កងវិភាគទានសប្បុរសធម៌ទាំងនោះឡើយ ។

លក្ខណៈវិនិច្ឆ័យនៃវិភាគទានសប្បុរសធម៌ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៧.-**

ក្នុងករណីដែលមានការខាតបង់នៅក្នុងឆ្នាំជាប់ពន្ធណាមួយ ការខាតបង់នោះត្រូវចាត់ទុកជាបន្ទុកសំរាប់ឆ្នាំជាប់ពន្ធបន្ទាប់ ហើយត្រូវកាត់ចេញពីប្រាក់ចំណេញសំរេចបាននៅក្នុងឆ្នាំជាប់ពន្ធបន្ទាប់នោះ ។ បើប្រាក់ចំណេញនេះមិនគ្រប់គ្រាន់សំរាប់ទូទាត់ជាស្ថាពរទេ ចំណែកនៃការខាតបង់ដែលនៅសេសសល់ ត្រូវយោងទៅឆ្នាំជាប់ពន្ធបន្តបន្ទាប់រហូតដល់ឆ្នាំជាប់ពន្ធទី ៥ ។

នៅពេលណាដែលការខាតបង់មានលើសពីមួយឆ្នាំ មាត្រានេះត្រូវអនុវត្តចំពោះការខាតបង់ទាំងឡាយតាមលំដាប់ដែលការខាតបង់បានកើតឡើង ។

**មាត្រា ១៨.-**

ក្នុងករណីសហគ្រាសចាប់ពី ២ ឡើងទៅ ទោះបីជាបានបង្កើត ឬរៀបចំឡើងនៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជា ហើយដែលស្ថិតក្រោមកម្មសិទ្ធិរួមគ្នា ក្នុងករណីចាំបាច់រដ្ឋបាលសារពើពន្ធអាចធ្វើការបែងចែកប្រាក់ចំណូលដុល ប្រាក់ផាត់ចេញ ឬអត្ថប្រយោជន៍ផ្សេងៗក្នុងចំណោមសហគ្រាស និងម្ចាស់កម្មសិទ្ធិទាំងនោះ ដើម្បីទប់ស្កាត់ការជៀសវាង ឬគេចវេសពន្ធ ឬក៏ដើម្បីឆ្លុះបញ្ចាំងឱ្យបានច្បាស់លាស់នូវប្រាក់ចំណូលរបស់សហគ្រាស ឬរបស់ម្ចាស់កម្មសិទ្ធិ ។

សម្រាប់គោលដៅនៃមាត្រានេះ សហគ្រាសចាប់ពី ២ ឡើងទៅ ត្រូវស្ថិតនៅក្រោមកម្មសិទ្ធិរួមគ្នាបើសិនជាមានបុគ្គលណាម្នាក់មានកម្មសិទ្ធិចាប់ពី ២០ភាគរយ ឡើងទៅ លើតម្លៃ ឬភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់សហគ្រាសនីមួយៗ ។

**មាត្រា ១៩.-**

សម្រាប់បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណេញចំណាយ ដែលមិនអនុញ្ញាតអោយផាត់ចេញមាន :

១- ចំណាយលើសកម្មភាពទាំងឡាយដែលជាទូទៅចាត់ទុកជាការកំសាន្ត ការសំរាកលំហែ ការទទួលភ្ញៀវ ឬការប្រើប្រាស់មធ្យោបាយណាមួយដែលជាប់ទាក់ទងនឹងសកម្មភាពទាំងនោះ ។

២- ចំណាយសម្រាប់ការរស់នៅផ្ទាល់ខ្លួន ឬក្រុមគ្រួសារ លើកលែងតែអត្ថប្រយោជន៍បន្ថែមជាប្រាក់ ឬជាវត្ថុដែលប្រាក់ជាប់ពន្ធត្រូវបានកាត់ទុកតាមបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស ។

៣- ប្រាក់ពន្ធដែលបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណេញ បានកំណត់ និងពន្ធកាត់ទុកដែលបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្សបានកំណត់ ។

៤- ការខាតបង់លើការលក់ ឬដោះដូរទ្រព្យសម្បត្តិ ទោះដោយផ្ទាល់ ឬប្រយោលក្តី រវាងបុគ្គលទាក់ទិន ។

៥- ចំណាយនានា វៀរលែងតែចំណាយដែលកើតមានហើយ ហើយអ្នកជាប់ពន្ធអាចបញ្ជាក់ច្បាស់លាស់នូវចំនួនទឹកប្រាក់ និងគោលដៅអាជីវកម្មស្របទៅតាមបែបបទ ដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

# ផ្នែកទី ៤
# អត្រាពន្ធ និងប្រាក់ពន្ធត្រូវបង់

## មាត្រា ២០.–

អត្រាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ មានដូចតទៅ :

១- ២០ភាគរយ ចំពោះប្រាក់ចំណេញដែលសម្រេចបានដោយនីតិបុគ្គល ។

២- ៣០ភាគរយ ចំពោះប្រាក់ចំណេញដែលសម្រេចបានក្រោមកិច្ចសន្យាបែងចែកផលិតផលប្រេងកាត និងឧស្ម័នធម្មជាតិ ឬសម្រេចបានពីការធ្វើអាជីវកម្មលើធនធានធម្មជាតិរួមទាំងព្រៃឈើ រ៉ែ មាស ឬត្បូងថ្មមានតម្លៃនានា ។

៣- ៩ភាគរយ ចំពោះសហគ្រាសវិនិយោគដែលផុតរយៈពេលលើកលែងពន្ធ ។

៤- ០ភាគរយ ចំពោះសហគ្រាសវិនិយោគ ដែលស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធ ។

៥- តាមតារាងអត្រាពន្ធកំណើនតាមថ្នាក់ខាងក្រោម ចំពោះប្រាក់ចំណេញដែលសម្រេចបានដោយរូបវន្តបុគ្គល និងចំណែកដែលត្រូវបែងចែកឱ្យសមាជិកម្នាក់ៗរបស់ក្រុមអាជីវកម្មដែលមិនត្រូវបានចាត់ទុកជានីតិបុគ្គល :

| ភាគនៃប្រាក់ចំណេញប្រចាំឆ្នាំ ដែលត្រូវជាប់ពន្ធ | អត្រាពន្ធ |
|---|---|
| ពី 0 ៛ ដល់ ៦.000.000៛ | 0% |
| ពី ៦.000.00១ ៛ ដល់ ១៥.000.000៛ | ៥% |
| ពី ១៥.000.00១ ៛ ដល់ ១0២.000.000៛ | ១0% |
| ពី ១0២.000.00១ ៛ ដល់ ១៥0.000.000៛ | ១៥% |
| លើសពី ១៥0.000.000៛ | ២0% |

## មាត្រា ២១.–

ពន្ធលើសហគ្រាសធានារ៉ាប់រងត្រូវបានកំណត់ដូចតទៅ :

១- ចំពោះសហគ្រាសដែលមានសកម្មភាពជាសំខាន់ ក្នុងការធានារ៉ាប់រង ឬធានារ៉ាប់រងបន្ត លើជីវិតទ្រព្យសម្បត្តិ ឬហានិភ័យផ្សេងៗ ពន្ធលើប្រាក់ចំណេញត្រូវបានកំណត់ដូចតទៅ :

ក. ៥ ភាគរយ នៃបុព្វលាភធានារ៉ាប់រងដុល ដែលទទួលបាននៅក្នុងឆ្នាំជាប់ពន្ធចំពោះការធានារ៉ាប់រង ឬធានារ៉ាប់រងបន្ត នូវហានិភ័យនៅព្រះរាជាណាចក្រកម្ពុជា

ខ. តាមអត្រាកំណត់ក្នុងមាត្រា ២០ នៃច្បាប់នេះ ចំពោះសកម្មភាពដទៃទៀតដែលមិនមែនជាការធានារ៉ាប់រង ឬធានារ៉ាប់រងបន្ត ។

២- វិធាន និងនីតិវិធីនៃការបង់ពន្ធលើប្រាក់ចំណេញរបស់សហគ្រាសធានារ៉ាប់រងត្រូវកំណត់ដោយប្រកាស

របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ២២.-**

ចំពោះអាជីវកម្មមិនទាក់ទិន ពន្ធលើប្រាក់ចំណេញត្រូវបានកំណត់ដូចតទៅ ៖

១- ពន្ធលើប្រាក់ចំណេញត្រូវកំណត់ស្មើនឹង ២០ភាគរយ លើចំនួនប្រាក់ចំណូលជាប់ពន្ធនៃអាជីវកម្មមិនទាក់-ទិនរបស់អង្គការនានា ដូចមានចែងក្នុងមាត្រា ៩ នៃច្បាប់នេះ ។

២- សម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណេញ ពាក្យ "ប្រាក់ចំណូលជាប់ពន្ធនៃអាជីវកម្មមិនទាក់ទិន" គឺជាផលដករវាងប្រាក់ចំណូលដុលសម្រេចបានពីអាជីវកម្មមិនទាក់ទិនដែលអង្គការណាមួយបានធ្វើជាទៀងទាត់ និងការកាត់កងនានាទាក់ទិនផ្ទាល់ទៅនឹងការធ្វើអាជីវកម្មដែលបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណេញបានអនុញ្ញាត ។

៣- ពាក្យ "អាជីវកម្មមិនទាក់ទិន" សំដៅដល់អាជីវកម្មខាងពាណិជ្ជកម្ម ឬឧស្សាហកម្ម ឬអាជីវកម្មផ្សេងទៀតរបស់អង្គការ ដើម្បីស្វែងរកប្រាក់ចំណេញ ឬមូលនិធិ ហើយពុំមានទាក់ទិនជាសំខាន់ដល់គោលដៅ ឬមុខងារដែលជាមូលដ្ឋាននៃការលើកលែងពន្ធ ដូចមានចែងក្នុងមាត្រា ៩ នៃច្បាប់នេះ ។

**មាត្រា ២៣.-**

ពន្ធបង់មុនលើការបែងចែកភាគលាភ ត្រូវបានកំណត់ដូចតទៅ ៖

១-បើសិនជាសហគ្រាសណាមួយបែងចែកភាគលាភអោយទៅអ្នកចូលហ៊ុនក្នុងស្រុក និងអ្នកចូលហ៊ុនបរទេសរបស់ខ្លួននៅក្នុងឆ្នាំជាប់ពន្ធ សហគ្រានោះត្រូវកាត់ទុក និងត្រូវបង់ប្រាក់ពន្ធដែលមានចំនួនស្មើនឹងផលគុណនៃទឹកប្រាក់ភាគលាភបំប៉ោងទៅតាមអត្រាពន្ធលើប្រាក់ចំណេញគុណនឹងអត្រាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ដូចមានចែងក្នុងមាត្រា ២០នៃច្បាប់នេះ ។

២-ប្រាក់ពន្ធដែលបានកាត់ទុកខាងលើនេះ ត្រូវក្លាយជាឥណទានពន្ធនៃពន្ធលើប្រាក់ចំណេញរបស់សហគ្រាសដែលបែងចែកភាគលាភសំរាប់ឆ្នាំជាប់ពន្ធដែលបានធ្វើការកាត់ទុកនោះ ។ បើសិនជាឥណទានពន្ធមានចំនួនលើសពីប្រាក់ពន្ធលើប្រាក់ចំណេញ ចំនួនលើសនោះត្រូវយោងទៅមុខ ហើយក្លាយទៅជាឥណទានពន្ធសំរាប់ឆ្នាំបន្ទាប់ ។ ដោយឡែកចំពោះពន្ធកាត់ទុកលើការបែងចែកភាគលាភដោយសហគ្រាសធានារ៉ាប់រង ដែលជាប់ពន្ធតាមមាត្រា ២១ នៃច្បាប់នេះ មិនអាចប្រើជាឥណទានពន្ធបានទេ ។

៣-សហគ្រាណាមួយ (តទៅនេះហៅថា "សហគ្រាសទីមួយ") ដែលមានកម្មសិទ្ធិចាប់ពី ២០ភាគរយឡើងទៅលើដើមទុនផ្ទាល់របស់សហគ្រាសទីពីរ ត្រូវតែបង្កើតនូវគណនីភាគលាភ ។ ពេលណាសហគ្រាសទីមួយបានទទួលភាគលាភបានបង់ពន្ធរួចហើយពីសហគ្រាសទីពីរ សហគ្រាសទីមួយត្រូវកត់ត្រាចំនួនប្រាក់ភាគលាភនោះទៅក្នុងគណនីភាគលាភរបស់ខ្លួន ។ ពេលណាសហគ្រាសទីមួយបែងចែកភាគលាភជាបន្តទៀតទៅអ្នកចូលហ៊ុនរបស់ខ្លួន ទឹកប្រាក់បែងចែកដែលត្រូវដកចេញពីគណនីភាគលាភមិនត្រូវមានការកាត់ទុកពន្ធដូចក្នុងកថាខ័ណ្ឌ១ នៃមាត្រានេះទេ ។

៤-រូបវន្តបុគ្គល ឬសហគ្រាស ដែលបានទទួលភាគលាភអំពីសហគ្រាស មានកាតព្វកិច្ចកាត់ពន្ធទុកតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ ឬក៏បានទទួលភាគលាភដកចេញពីគណនីភាគលាភដូចមានចែងក្នុងកថាខ័ណ្ឌ៣ នៃមាត្រានេះ មិនត្រូវកត់ត្រា ភាគលាភនេះក្នុងប្រាក់ចំណូលទេ ។

## ផ្នែកទី ៥

## ពន្ធដទៃទៀត

### មាត្រា ២៤.-

ពន្ធអប្បបរមា ត្រូវបានកំណត់លើអ្នកជាប់ពន្ធតាមរបបពិត ។ពន្ធអប្បបរមា ជាពន្ធមួយដាច់ដោយឡែក និងផ្សេងពីពន្ធលើប្រាក់ចំណេញ ។ ពន្ធនេះត្រូវបង់ដោយអ្នកជាប់ពន្ធតាមរបបពិត ទោះបីអ្នកជាប់ពន្ធនោះបានទទួលលក្ខណសម្បត្តិជាសហគ្រាសវិនិយោគក៏ដោយ ។ ពន្ធអប្បបរមា ត្រូវកំណត់តាមអត្រា ១ភាគរយ លើផលរបរប្រចាំឆ្នាំរួមបញ្ចូលទាំងពន្ធអាករនានាហើយត្រូវបង់នៅពេលទូទាត់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ។

ពន្ធអប្បបរមាត្រូវបានកាត់បន្ថយដោយពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំដែលបានបង់ ជាក់ស្តែងតាមវិធានដែលមានចែងក្នុងមាត្រា ៣៧ មាត្រា ៣៨ និងមាត្រា ៣៩ នៃច្បាប់នេះ ។

## ផ្នែកទី ៦

## ពន្ធកាត់ទុក និងប្រាក់រំដោះពន្ធលើប្រាក់ចំណេញ

### មាត្រា ២៥.-

ពន្ធកាត់ទុកទូទៅត្រូវបានកំណត់ដូចតទៅ :

១-អ្នកបើកប្រាក់និវាសនជនដែលបានធ្វើការទូទៅជាសាច់ប្រាក់ ឬជាវត្ថុអោយដល់បុគ្គលនិវាសនជន ត្រូវកាត់ទុក និងបង់ប្រាក់ទៅតាមអត្រាកំណត់ដូចខាងក្រោម លើចំនួនទូទាត់មុនការកាត់ទុកប្រាក់ពន្ធ :

ក- អត្រា ១៥ភាគរយចំពោះ :

- ប្រាក់ចំណូលដែលរូបវន្តបុគ្គលបានទទួលពីការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់ ឬសេវាប្រហាក់ប្រហែល
- សួយសារចំពោះទ្រព្យអរូបី និងភាគកម្មធនធានរ៉ែ ប្រេងកាត ឧស្ម័នធម្មជាតិ ហើយនិងការប្រាក់ដែលបង់ទៅឱ្យរូបវន្តបុគ្គលឬសហគ្រាស លើកលែងតែការប្រាក់ដែលបង់ទៅអោយធនាគារ និងស្ថាប័នសញ្ច័យធនក្នុងស្រុក

ខ-អត្រា ១០ភាគរយ ចំពោះចំណូលពីការអោយជួលចលន ឬអចលនទ្រព្យ

គ-អត្រា ៥ភាគរយ ចំពោះការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ច័យធនក្នុងស្រុកបង់អោយទៅរូបវន្តបុគ្គលនិវាសនជន ដែលមានគណនីសន្សំគ្មានកាលកំណត់ ។

២-ការកាត់ទុកក្នុងមាត្រានេះ មិនត្រូវអនុវត្តទេចំពោះការទូទាត់ ចំពោះប្រាក់ចំណូលលើកលែងពន្ធដូចមានចែងក្នុងមាត្រា ៩ នៃច្បាប់នេះ

៣-សំរាប់គោលដៅនៃមាត្រានេះ និងមាត្រា ២៦នៃច្បាប់នេះពាក្យ"អ្នកបើកប្រាក់និវាសនជន" សំដៅដល់ :

ក-សហគ្រាសនិវាសនជន ឬក្រុមអាជីវកម្មនិវាសនជន

ខ-រូបវន្តបុគ្គល ចំពោះតែការបើកប្រាក់ទាំងឡាយ ដែលរូបវន្តបុគ្គលនោះធ្វើឡើងក្នុងការប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៦.-**

អ្នកបើកប្រាក់និវាសនជន ដែលបានទូទាត់ប្រាក់ចំណូលប្រភពកម្ពុជាអោយទៅបុគ្គលអនិវាសនជន ត្រូវកាត់ទុក និងបង់នូវប្រាក់ពន្ធចំនួន ១៤ភាគរយនៃទឹកប្រាក់ត្រូវបើកមុនការកាត់ទុក ។ មាត្រានេះមិនត្រូវអនុវត្តចំពោះភាគលាភដែលមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះ ។

**មាត្រា ២៧.-**

ពន្ធកាត់ទុកដែលបានអនុវត្តលើការបែងចែកនានា តាមមាត្រា ២៣ នៃច្បាប់នេះ ពន្ធកាត់ទុកលើការទូទាត់អោយដល់រូបវន្តបុគ្គលនិវាសនជនតាមមាត្រា ២៥នៃច្បាប់នេះ និងពន្ធកាត់ទុកលើការទូទាត់អោយដល់បុគ្គលអនិវាសនជនតាមមាត្រា ២៦ នៃច្បាប់នេះត្រូវចាត់ទុកថាជាពន្ធចុងក្រោយសំរាប់អ្នកទទួលការទូទាត់ ឬការបែងចែកដែលមានបញ្ជាក់ក្នុងមាត្រាទាំងឡាយនេះ ។

**មាត្រា ២៨.-**

សហគ្រាសដែលជាប់ពន្ធលើប្រាក់ចំណេញតាមរបបពិត ក្នុងនោះមានទាំងសហគ្រាសវិនិយោគដែលជាប់ពន្ធលើប្រាក់ចំណេញតាមអត្រា៩ភាគរយ មានកាតព្វកិច្ចបង់ប្រាក់រំដោះប្រចាំខែ សំរាប់ពន្ធលើប្រាក់ចំណេញតាមអត្រា ១ ភាគរយនៃផលរបរ គិតរួមបញ្ចូលទាំងពន្ធអាករគ្រប់ប្រភេទ ដែលសំរេចបានក្នុងខែមុន ។ ប្រាក់រំដោះនេះនឹងត្រូវបានយកមកកាត់កងពីពន្ធលើប្រាក់ចំណេញនៅពេលធ្វើការទូទាត់ប្រចាំឆ្នាំ ។

## ផ្នែកទី ៧

## ភាគព្វកិច្ចរបស់អ្នកជាប់ពន្ធ

**មាត្រា ២៩.-**

អ្នកជាប់ពន្ធតាមរបបពិត និងរបបបំព្រួញ មានកាតព្វកិច្ច :

១- អ្នកជាប់ពន្ធលើប្រាក់ចំណេញដែលត្រូវបង់ពន្ធតាមរបបពិត ឬរបបបំព្រួញត្រូវផ្ញើជូនជារៀងរាល់ឆ្នាំទៅរដ្ឋបាលសារពើពន្ធនូវលិខិតប្រកាសប្រាក់ចំណេញដែលខ្លួនសំរេចបានក្នុងឆ្នាំសារពើពន្ធមុន ។ លិខិតប្រកាសនោះ ត្រូវចុះបញ្ជីជាដាច់ខាត ក្នុងរយៈវេលាបីខែ ក្រោយពីដំណាច់ឆ្នាំសារពើពន្ធ ។

២- អ្នកជាប់ពន្ធតាមរបបពិត ត្រូវដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធ ដោយភ្ជាប់ជាមួយនូវ :

ក-តារាងតុល្យការ

ខ-គណនីលទ្ធផល

គ-តារាងព័តិមានបន្ថែម ។

៣- អ្នកជាប់ពន្ធតាមរបបបំព្រួញ ត្រូវដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធ ដោយភ្ជាប់មកជាមួយនូវឯកសារនានា តាមគំរូដែលរដ្ឋបាលសារពើពន្ធបានផ្តល់ជូន ។

៤- ចំពោះសហគ្រាសដែលមានការខាតបង់ ក៏ត្រូវដាក់លិខិតប្រកាសសារពើពន្ធតាមបែបបទ និងក្នុងរយៈវេលាដូចគ្នាដែរ ។

**មាត្រា ៣០.-**

អ្នកជាប់ពន្ធតាមរបបម៉ៅការមានកាតព្វកិច្ច :

១- អ្នកជាប់ពន្ធតាមរបបម៉ៅការត្រូវដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធជារៀងរាល់ឆ្នាំ យ៉ាងយឺតបំផុតនៅថ្ងៃទី ៣១ ខែ តុលា តាមគំរូដែលរដ្ឋបាលសារពើពន្ធបានផ្តល់ជូន ។

២- ចំនួនប្រាក់ចំណេញម៉ៅការ ត្រូវកំណត់ដោយរដ្ឋបាលសារពើពន្ធបន្ទាប់ពីបានត្រួតពិនិត្យ និងពិភាក្សាជាមួយអ្នកជាប់ពន្ធ ឬអ្នកតំណាង ។ ប្រាក់ចំណេញម៉ៅការនេះ ត្រូវគិតតាមអត្រាចំណេញទៅតាមប្រភេទ និងតាមមុខរបរអាជីវកម្មដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៣- កំរិតពន្ធលើប្រាក់ចំណេញម៉ៅការ ត្រូវកំណត់ជាស្ថេរវន្តសំរាប់រយៈពេលមួយមានកំណត់ ៣ខែ ៦ខែ ឬ១ឆ្នាំ

៤- អ្នកជាប់ពន្ធលើប្រាក់ចំណេញតាមរបបម៉ៅការ ត្រូវបង់ពន្ធនេះជារៀងរាល់ខែ តាមពេលវេលាដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ ។

**មាត្រា ៣១.-**

បុគ្គល ឬអ្នកទទួលភារៈបើកប្រាក់ដែលកាត់ទុកប្រាក់ពន្ធតាមមាត្រា ២៥ និងមាត្រា ២៦ នៃច្បាប់នេះ ឬដែលបានកាត់ទុកប្រាក់ពន្ធពីភាគលាភតាមមាត្រា ២៣ នៃច្បាប់នេះ ត្រូវដាក់លិខិតប្រកាសសារពើពន្ធ និងបង់ប្រាក់ពន្ធដែលបានកាត់ទុកជូនរដ្ឋបាលសារពើពន្ធ ទៅតាមទំរង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ នៃខែបន្ទាប់ពីខែដែលបានធ្វើការកាត់ទុក ។

**មាត្រា ៣២.-**

បុគ្គលដែលមានកាតព្វកិច្ចបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ត្រូវដាក់លិខិតប្រកាសសារពើពន្ធ និងបង់ប្រាក់រំដោះលើប្រាក់ចំណេញជូនរដ្ឋបាលសារពើពន្ធ ទៅតាមទំរង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់ យ៉ាងយឺតត្រឹមថ្ងៃទី ១៥ នៃខែបន្ទាប់ពីខែដែលបំណុលបានកើតឡើង ។

## ផ្នែកទី ៨

## ប្រភពប្រាក់ចំណូល

**មាត្រា ៣៣.-**

វៀរលែងតែមានបទប្បញ្ញត្តិផ្ទុយនៅក្នុងច្បាប់នេះ ប្រាក់ចំណូលដូចខាងក្រោមត្រូវចាត់ទុកថាមានប្រភពក្នុងព្រះរាជាណាចក្រកម្ពុជា :

១- ការប្រាក់ដែលបង់ដោយសហគ្រាសនិវាសនជន ក្រុមអាជីវកម្មនិវាសនជន ឬស្ថាប័នរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

២- ភាគដែលបានបែងចែកដោយសហគ្រាសនិវាសនជននៃព្រះរាជាណាចក្រកម្ពុជា ។

៣- ប្រាក់ចំណូលពីសេវាកម្មដែលបានបំពេញនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៤- ប្រាក់ចំណូលដែលបានមកពីការអោយជួលចលន ឬអចលនទ្រព្យដែលប្រើប្រាស់ក្នុងព្រះរាជាណាចក្រកម្ពុជា

៥- ប្រាក់សួយសារដែលបានមកពីការប្រើប្រាស់ ឬសិទ្ធិប្រើប្រាស់ទ្រព្យអរូបីនៅក្នុងព្រះរាជាណាចក្រកម្ពុជា

៦- ផលចំណេញពីការលក់អចលនទ្រព្យដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬផលចំណេញពីការផ្ទេរផលប្រយោជន៍ណាមួយនៃអចលនទ្រព្យ ដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៧- ផលចំណេញពីការលក់ចលនទ្រព្យក្រៅពីសារពើភ័ណ្ឌ ក្នុងករណីដែលអ្នកលក់ជានិវាសនជននៃព្រះរាជាណាចក្រកម្ពុជា ។

៨- បុព្វលាភធានារ៉ាប់រង ឬធានារ៉ាប់រងបន្តចំពោះហានិភ័យនៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣៤.-**

និយមន័យនៃប្រាក់ចំណូលប្រភពបរទេស ត្រូវកំណត់ឡើងដោយយកនិយមន័យប្រាក់ចំណូលដូចមានចែងក្នុងមាត្រា ៣៣ នៃច្បាប់មកប្រើ ហើយក្នុងនោះពាក្យ "ព្រះរាជាណាចក្រកម្ពុជា" ត្រូវជំនួសដោយពាក្យ "ប្រទេសណាមួយក្រៅពីព្រះរាជាណាចក្រកម្ពុជា" ។

**មាត្រា ៣៥.-**

ក្នុងករណីដែលគ្មានព័ត៌មានគ្រប់គ្រាន់ ដើម្បីកំណត់ប្រភពចំណូល ឬបើសិនជាវិធាននានាដែលមានរួចមកហើយ ពុំអាចឆ្លុះបញ្ចាំងអោយបានច្បាស់លាស់នូវប្រាក់ចំណូលពីប្រភពណាមួយបានទេ នោះរដ្ឋបាលសារពើពន្ធជាអ្នកកំណត់ប្រភពនៃប្រាក់ចំណូលនោះ ។

## ផ្នែកទី ៩
## គណនាប្រាក់ពន្ធប្រចាំឆ្នាំត្រូវបង់

**មាត្រា ៣៦.-**

អ្នកជាប់ពន្ធនិវាសនជន ដែលបានទទួលប្រាក់ចំណូលប្រភពបរទេស និងបានបង់ពន្ធតាមច្បាប់ពន្ធដារបរទេស ត្រូវបានទទួលនូវឥណទានពន្ធសំរាប់កាត់កងពីប្រាក់ពន្ធលើប្រាក់ចំណេញ ដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែលុះណាតែមានការបង្ហាញឯកសារបញ្ជាក់អំពីការបង់ពន្ធនៅបរទេសនោះ ។

ដើម្បីគណនាប្រាក់ដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជា មុនពេលកាត់ឥណទានពន្ធនេះ ត្រូវយកចំនួនសរុបនៃប្រាក់ចំណូលដែលបានទទួលអំពីប្រភពកម្ពុជា និងប្រភពបរទេសមកគិត ។

ឥណទានពន្ធត្រូវបានកំណត់ដាច់ដោយឡែកពីគ្នា សំរាប់ប្រាក់ពន្ធដែលបានបង់ដោយនិវាសនជនកម្ពុជានៅប្រទេសក្រៅនីមួយៗ ។ ប៉ុន្តែឥណទានពន្ធដែលអនុញ្ញាតអោយកាត់កងសំរាប់ឆ្នាំជាប់ពន្ធ គឺចំនួនដែលទាបជាងគេក្នុងចំណោម :

ក-	ប្រាក់ពន្ធដែលបានបង់ជាក់ស្តែងនៅប្រទេសក្រៅណាមួយ

ខ-	ចំនួនដែលបានមកពីការយកប្រាក់ពន្ធលើប្រាក់ចំណេញសរុបពីគ្រប់ប្រភពសំរាប់រយៈពេលជាមួយគ្នាដែលគណនាតាមអត្រាពន្ធក្នុង មាត្រា ២០ នៃច្បាប់នេះ ទៅគុណនឹងផលចែករវាងប្រាក់ចំណូលដែលបានទទួលនៅប្រទេសក្រៅនោះ និងប្រាក់ចំណូលសរុបពីគ្រប់ប្រភព ។

ឥណទានពន្ធបរទេសអាចផ្តល់អោយបាន លុះណាតែអ្នកជាប់ពន្ធនិវាសនជនបានបំពេញបែបបទព្រមទាំងផ្តល់ឯកសារនានាកំណត់ដោយរដ្ឋបាលសារពើពន្ធ ជាពិសេសសេចក្តីបញ្ជាក់របស់អ្នកទូទាត់ប្រាក់ពន្ធនៅបរទេស និងរដ្ឋបាលសារពើពន្ធបរទេសនោះ ។

ក្នុងករណីឥណទានពន្ធមានចំនួនលើសពីបំណុលពន្ធ ចំនួនលើសនោះអាចយោងទៅប្រើនៅឆ្នាំបន្តបន្ទាប់រហូតដល់ឆ្នាំទី ៥ គិតពីឆ្នាំដែលបន្តនៃឆ្នាំឥណទានពន្ធនោះបានកើតឡើង ។ បើសិនជាមានឥណទានពន្ធច្រើនឆ្នាំ ត្រូវយកឥណទានពន្ធទាំងនោះមកប្រើតាមលំដាប់ឆ្នាំដែលបានកើតឡើង ។

**មាត្រា ៣៧.-**

ការគណនាបំណុលពន្ធលើប្រាក់ចំណេញត្រូវបានកំណត់ដូចតទៅ :

១-	គណនាបំណុលពន្ធសរុបតាមមាត្រា ២០ នៃច្បាប់នេះ ។

២-	ដកឥណទានពន្ធបរទេសតាមមាត្រា ៣៦ នៃច្បាប់នេះ ប៉ុន្តែមិនអោយលើសបំណុលពន្ធក្នុងកថាខណ្ឌ ១ នៃមាត្រានេះទេ ។

៣-	ដកប្រាក់ពន្ធដែលអ្នកជាប់ពន្ធបានបង់លើការបែងចែកភាគលាភតាមមាត្រា ២៣ នៃច្បាប់នេះ ប៉ុន្តែមិនឱ្យលើសពីបំណុលពន្ធក្រោយការកាត់កងឥណទានពន្ធបរទេស ដូចក្នុងកថាខ័ណ្ឌ២ នៃមាត្រានេះទេ ។

**មាត្រា ៣៨.-**

ការគណនាប្រាក់ពន្ធត្រូវបង់ ឬឥណទានពន្ធសំរាប់ឆ្នាំជាប់ពន្ធ ត្រូវបានកំណត់ដូចតទៅ :

១-	ក្នុងករណីដែលលទ្ធផលគណនាតាមមាត្រា ៣៧ នៃច្បាប់នេះ មានចំនួនច្រើនជាងផលបូកនៃចំនួនប្រាក់ពន្ធដែលបានកាត់ទុកក្នុងនាមអ្នកជាប់ពន្ធតាមមាត្រា ២៥ នៃច្បាប់នេះ និងចំនួនប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ដែលអ្នកជាប់ពន្ធបានបង់ប្រចាំឆ្នាំតាមមាត្រា ២៨ នៃច្បាប់នេះ អ្នកជាប់ពន្ធត្រូវបង់បន្ថែមចំនួនដែលលំអៀងនោះ ជូនរដ្ឋបាលសារពើពន្ធ ។

២-	ប្រសិនបើលទ្ធផលគណនាតាមមាត្រា ៣៧ នៃច្បាប់នេះ មានចំនួនតិចជាងផលបូកនៃចំនួនប្រាក់ពន្ធដែលបានកាត់ទុកក្នុងនាមអ្នកជាប់ពន្ធតាមមាត្រា ២៥ នៃច្បាប់នេះ និងចំនួនប្រាក់ដែលរំដោះពន្ធលើប្រាក់ចំណេញដែលអ្នកជាប់ពន្ធបានបង់សំរាប់ឆ្នាំជាប់ពន្ធតាមមាត្រា ២៨ នៃច្បាប់នេះ ក្រោយពីបានគិតបំណុលពន្ធអប្បបរមារួចហើយ អ្នកជាប់ពន្ធអាចសុំបង្វិលសងវិញនូវចំនួនដែលលំអៀង ឬយោងទៅប្រើជាប្រាក់រំដោះសំរាប់ឆ្នាំបន្ទាប់ ។

៣-	មុននឹងធ្វើការទូទាត់ប្រាក់ពន្ធតាមកថាខណ្ឌ១ ឬក៏សុំបង្វិលសងតាមកថាខណ្ឌ២ អ្នកជាប់ពន្ធត្រូវតែកំណត់ជាមុននូវបំណុលពន្ធអប្បបរមា តាមនីតិវិធីដែលមានចែងក្នុងមាត្រា ៣៩ នៃច្បាប់នេះ ។

**មាត្រា ៣៩.-**

ការគណនាប្រាក់ពន្ធអប្បបរមា ប្រាក់ពន្ធត្រូវបង់ ឬឥណទានពន្ធសំរាប់ឆ្នាំជាប់ពន្ធ ត្រូវបានកំណត់ដូចតទៅ :

១- អ្នកជាប់ពន្ធត្រូវបង់ពន្ធអប្បបរមានៅពេលធ្វើការទូទាត់ប្រាក់ពន្ធលើប្រាក់ចំណេញ ។ ពន្ធអប្បបរមាត្រូវបង់អាចត្រូវបានកាត់បន្ថយ ដោយបំណុលពន្ធលើប្រាក់ចំណេញក្នុងឆ្នាំជាប់ពន្ធជាមួយគ្នា តាមមាត្រា ២០ នៃច្បាប់នេះ ។

២- ក្នុងករណីបំណុលពន្ធលើប្រាក់ចំណេញ លើសពីបំណុលពន្ធអប្បបរមា :

ក- អ្នកជាប់ពន្ធត្រូវទូទាត់ប្រាក់ពន្ធ ត្រូវបង់តាមមាត្រា ៣៧ នៃច្បាប់នេះ នៅពេលដាក់លិខិតប្រកាសសារពើពន្ធ

ខ- ប្រសិនបើចំនួនទឹកប្រាក់ដែលបានកាត់ទុកតាមមាត្រា ២៥ និងមាត្រា ២៨ នៃ ច្បាប់នេះ មានចំនួនលើសពីបំណុលពន្ធអប្បបរមា អ្នកជាប់ពន្ធអាចស្នើសុំជាឥណទានពន្ធបាន

គ- ក្នុងករណីដូចក្នុងកថាខណ្ឌ២ នៃមាត្រានេះ អ្នកជាប់ពន្ធ មិនជាប់ពន្ធអប្បបរមាទេ ។

៣- ប្រសិនបើបំណុលពន្ធលើប្រាក់ចំណេញតិចជាងបំណុលពន្ធអប្បបរមា :

ក- ឥណទានពន្ធរបស់អ្នកជាប់ពន្ធតាមកថាខ័ណ្ឌ២ មាត្រា ៣៨ នៃច្បាប់នេះ ត្រូវបានកាត់បន្ថយដោយទឹកប្រាក់លំអៀងខាងលើ

ខ- ឥណទានពន្ធដែលបានកាត់បន្ថយចុះក្នុងការអនុវត្តតាមវាក្យខ័ណ្ឌ នៃកថាខ័ណ្ឌនេះ ត្រូវចាត់ជាការទូទាត់ប្រាក់ពន្ធអប្បបរមាសំរាប់ឆ្នាំជាប់ពន្ធ ។

## ជំពូកទី ២

## បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស

### ផ្នែកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ៤០.-**

បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស ដូចមានចែងក្នុង ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ដើម្បីជាគុណប្រយោជន៍ដល់ថវិការដ្ឋ ។

**មាត្រា ៤១.-**

ពន្ធលើប្រាក់បៀវត្ស គឺជាពន្ធប្រចាំខែកំណត់លើប្រាក់បៀវត្សដែលបានទទួលក្របខ័ណ្ឌនៃការបំពេញសកម្មភាពបំរើការងារ ។

រូបវន្តបុគ្គលនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់ពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជា និងប្រាក់បេវត្សប្រភពបរទេស ។

រូបវន្តបុគ្គលអនិវាសជន ត្រូវជាប់ពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជា ។

**មាត្រា ៤២.-**

សំរាប់គោលដៅនៃបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស :

១- ពាក្យ"និវាសនជន"ក្នុងករណីដែលប្រើចំពោះនិយោជិត អ្នកជាប់ពន្ធ ឬរូបវន្តបុគ្គល មានន័យថាដែលស្នាក់នៅ ឬមានកន្លែងស្នាក់នៅជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា លើសពី ១៨២ ថ្ងៃនៅក្នុងឆ្នាំប្រតិទិន ។

២- ពាក្យ"អនិវាសនជន" មានន័យថាដែលមិនមែនជានិវាសនជន ។

៣- វៀរលែងតែមានបទប្បញ្ញត្តិផ្ទុយ ការប្រើពាក្យនិយោជិត អ្នកជាប់ពន្ធ និងរូបវន្តបុគ្គល គឺសំដៅដល់ទាំងនិវាសនជន និងអនិវាសនជន ដូចមានចែងក្នុងមាត្រានេះ ។

៤- ពាក្យ"និយោជក" រួមមានស្ថាប័នរដ្ឋ នីតិបុគ្គលនិវាសនជន ក្រុមអាជីវកម្មនិវាសនជន គ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា អង្គការមិនស្វែងរកចំណេញ ឬរូបវន្តបុគ្គលនិវាសនជនដែលប្រកបអាជីវកម្ម ។

៥- ពាក្យ "និយោជិត" សំដៅដល់រូបវន្តបុគ្គលដែលបានទទួលប្រាក់បៀវត្សអំពីសកម្មភាពបំរើការងាររបស់ខ្លួន រួមទាំងបញ្ចូលទាំងមន្ត្រីរាជការ មន្ត្រីជ្រើសតាំងដោយការបោះឆ្នោត និងអ្នកទទួលខុសត្រូវ ឬអភិបាលរបស់ហគ្រាសផង។

៦- ពាក្យ"ប្រាក់បៀវត្សប្រភពកម្ពុជា" មានន័យថាប្រាក់បៀវត្សដែលបានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញសកម្មភាពបំរើការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដោយឡែកចំពោះប្រាក់បៀវត្ស ដែលអនិវាសនជនបានទទួលក្នុងការផ្តល់ជំនួយបច្ចេកទេស ត្រូវចាត់ទុកថាមានប្រភពនៅក្នុងប្រទេសដែលអ្នកទូទាត់ប្រាក់បៀវត្សនោះស្នាក់នៅ ។

៧- ពាក្យ" បរទេស" :

ក-ពេលណាប្រើជាមួយរូបវន្តបុគ្គល មានន័យថា ដែលជាអនិវាសនជន

ខ-ចំពោះការកំណត់ប្រភពប្រាក់ចំណូលមានន័យថា ក្រៅព្រះរាជាណាចក្រកម្ពុជា

៨- ពាក្យ"ប្រាក់បៀវត្ស" សំដៅដល់លាភការ ប្រាក់បំណាច់ បុព្វលាភ ប្រាក់ម៉ោងបន្ថែម ប្រាក់ប៉ះប៉ូវ នានា និងអត្ថប្រយោជន៍បន្ថែម ដែលបានទូទាត់អោយដល់និយោជិត ឬដែលបានទូទាត់ ដើម្បីជាប្រយោជន៍ផ្ទាល់ ឬប្រយោលដល់និយោជិត ចំពោះការបំពេញសកម្មភាពបំរើការងារ ។

## ផ្នែកទី ២

## ប្រាក់បៀវត្សលើកលែងពន្ធ

**មាត្រា ៤៣.-**

ការលើកលែងពន្ធលើប្រាក់បៀវត្សរបស់មន្ត្រីរាជការទូត និងមន្ត្រីបរទេសដទៃទៀតត្រូវបានកំណត់ដូចតទៅ :

១- ត្រូវបានលើកលែងពន្ធលើប្រាក់បៀវត្សចំពោះ :

ក- ប្រាក់បៀវត្សដែលមន្ត្រី និងនិយោជិតនៃបេសកម្មទូត ឬកុងស៊ុលរបស់រដ្ឋាភិបាលបរទេសណាមួយដែលកាន់លិខិតឆ្លងដែនការទូត ឬផ្លូវការរបស់ប្រទេសនោះ បានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារជាផ្លូវការនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ខ- ប្រាក់បៀវត្សដែលតំណាងមន្ត្រី និងនិយោជិតបរទេសរបស់អង្គការអន្តរជាតិ និងរបស់ទីភ្នាក់ងារខាងសហប្រតិបត្តិការបច្ចេកទេសនៃរដ្ឋាភិបាលដទៃទៀត បានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារជាផ្លូវការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- ការលើកលែងពន្ធក្នុងមាត្រានេះ ត្រូវឈរលើគោលការណ៍បដិការរវាងរដ្ឋាភិបាលដែលពាក់ព័ន្ធ ។

**មាត្រា ៤៤.-**

ត្រូវបានលើកលែងពន្ធ :

១- ប្រាក់សំណងដោយពិតប្រាកដនូវចំណាយខាងវិជ្ជាជីវៈ ដែលបានចាយដោយនិយោជិតតាមសេចក្តី បង្គាប់និងសំរាប់ជាប្រយោជន៍នៃនិយោជក ហើយដែលបានបំពេញល័ក្ខខ័ណ្ឌដូចតទៅ :

ក- បានចាយក្នុងផលប្រយោជន៍ផ្ទាល់ និងដាច់ខាតរបស់សហគ្រាស

ខ- មិនបង្ហាញលក្ខណៈហួសប្រមាណ ឬស្តុកស្តម្ភហួសហេតុ

គ- បានបង្ហាញជាភស្តុតាងដោយវិក្កយបត្ររាយលំអិត និងបានទូទាត់ស្រេចបាច់ ហើយដែលបានធ្វើក្នុងនាមអ្នកបានទទួលប្រាក់សំណងនូវចំណាយពិតប្រាកដ ។

២- ប្រាក់បំណាច់នៃការបញ្ឈប់លែងអោយធ្វើការក្នុងក៏រិតដែលបានបញ្ញត្តិក្នុងច្បាប់ការងារ ។

៣- លាភការបន្ថែមមានលក្ខណៈខាងសង្គមកិច្ច ក្នុងករណីដែលបានបញ្ញត្តិក្នុងច្បាប់ការងារ ។

៤- ការផ្គត់ផ្គង់អោយដោយឥតយកថ្លៃ ឬយកថ្លៃទាបជាងថ្លៃដើមនូវឯកសណ្ឋាន ឬបរិក្ខារសំរាប់វិជ្ជាជីវៈពិសេស ។

៥- ប្រាក់បំណាច់ម៉ោការសំរាប់ចំណាយបេសកម្ម និងការធ្វើដំណើរ ។ ប្រាក់បំណាច់នេះមិនត្រូវត្រួតគ្នាជាមួយប្រាក់សំណងពិតប្រាកដ នូវចំណាយដូចមានចែងក្នុងមាត្រានេះឡើយ ។

## ផ្នែកទី ៣

## មូលដ្ឋានគិតពន្ធប្រចាំខែ ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងការកំណត់ប្រាក់ពន្ធប្រចាំខែ

**មាត្រា ៤៥.-**

វៀរលែងតែអត្ថប្រយោជន៍បន្ថែមដែលត្រូវកំណត់ពន្ធតាមមាត្រា ៤៨ នៃច្បាប់នេះ មូលដ្ឋានគិតពន្ធប្រចាំខែរបស់និវាសនជន គឺជាប្រាក់បៀវត្សជាប់ពន្ធដោយផាត់ចេញនូវ :

១- ប្រាក់កាត់ទុកដែលជាកាតព្វកិច្ចក្នុងការប្រតិបត្តិការតាមច្បាប់ការងារ ដើម្បីបង្កើតបេឡាសោធន និងធានាសុខុមាលភាពសង្គម ។

២- ការទូទាត់នានា ដែលត្រូវបានលើកលែងពន្ធដូចមានចែងក្នុងមាត្រា ៤៤ នៃច្បាប់នេះ ។

**មាត្រា ៤៦.-**

ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ ត្រូវបានកំណត់ដូចតទៅ :

១- ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែរបស់និយោជិតនិវាសនជនរួមមាន :

ក- ប្រាក់បៀវត្សដែលបានទទួលពីប្រភពកម្ពុជា

ខ- ប្រាក់បៀវត្សដែលបានទទួលពីប្រភពបរទេស

គ- ប្រាក់បុរេប្រទាន ប្រាក់អោយខ្ចី ឬប្រាក់រំដោះដែលនិយោជកបានបើកអោយនិយោជិត ។ ប្រាក់បុរេប្រទាន ប្រាក់អោយខ្ចី ឬប្រាក់រំដោះដែលត្រូវបូកបន្ថែមលើបៀវត្សជាប់ពន្ធនៃខែដែលប្រាក់ទាំងនោះបានបើកហើយត្រូវកាត់បន្ថយពីប្រាក់បៀវត្សក្នុងខែដែលនិយោជិតបានបង់សងវិញ ។

២- ផ្អែកលើការបង្ហាញភស្តុតាងនៃស្ថានភាពគ្រួសារ និយោជិតនិវាសនជនណាមួយដែលមាន :

ក- កូនស្ថិតក្នុងបន្ទុកនាពេលដែលត្រូវបង់ពន្ធ ត្រូវបានទទួលការបន្ថយមូលដ្ឋានកំណត់ចំនួន ៧៥.០០០ រៀល (ប្រាំពីរម៉ឺនប្រាំពាន់រៀល) ក្នុងកូនម្នាក់ៗក្នុងមួយខែ ។

ខ- សហព័ទ្ធដែលធ្វើការតែជាមេផ្ទះ ត្រូវបានទទួលនូវការបន្ថយមូលដ្ឋានកំណត់ពន្ធចំនួន ៧៥.០០០ រៀល (ប្រាំពីរម៉ឺនប្រាំពាន់រៀល) ក្នុងកូនតែម្នាក់ក្នុងមួយខែ ។

៣- ចំពោះអ្នកជាប់ពន្ធអនិវាសនជន ប្រាក់បៀវត្សជាប់ពន្ធរួមមានប្រាក់បៀវត្សប្រភពកម្ពុជា ដែលត្រូវជាប់ពន្ធតាមបទប្បញ្ញត្តិទាំងឡាយនៃជំពូកនេះ ។

**មាត្រា ៤៧.-**

សំរាប់និយោជិតនិវាសនជន ប្រាក់ពន្ធត្រូវបង់ត្រូវកំណត់លើប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងត្រូវកាត់ទុកដោយនិយោជក តាមអត្រាកំណើនតាមថ្នាក់ដូចតទៅ :

| ភាគបៀវត្សប្រចាំខែត្រូវជាប់ពន្ធ | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | ០៛០០ | ដល់ | ៥០០.០០០៛០០ | 0% |
| ពី | ៥០០.០០១៛០០ | ដល់ | ១.២៥០.០០០៛០០ | ៥% |
| ពី | ១.២៥០.០០១៛០០ | ដល់ | ៨.៥០០.០០០៛០០ | ១០% |
| ពី | ៨.៥០០.០០១៛០០ | ដល់ | ១២.៥០០.០០០៛០០ | ១៥% |
| | | លើសពី | ១២.៥០០.០០០៛០០ | ២០% |

**មាត្រា ៤៨.-**

ចំពោះអត្ថប្រយោជន៍បន្ថែម ជារៀងរាល់ខែនិយោជកត្រូវកាត់ទុក និងបង់ប្រាក់ពន្ធតាមកាលកំណត់ តាមអត្រា ២០ ភាគរយនៃតំលៃសរុបរបស់អត្ថប្រយោជន៍បន្ថែម ដែលបានផ្តល់អោយនិយោជិតទាំងអស់ ។ តំលៃនៃ អត្ថប្រយោជន៍បន្ថែម គឺជាតំលៃទីផ្សាររួមទាំងពន្ធអាករទាំងអស់ ។

**មាត្រា ៤៩.-**

វៀរលែងតែអត្ថប្រយោជន៍បន្ថែមដែលត្រូវកំណត់ពន្ធតាមមាត្រា ៤៨ នៃច្បាប់នេះ សំរាប់អ្នកជាប់ពន្ធអនិវាសនជនប្រាក់ពន្ធត្រូវកាត់ទុកដោយអ្នកបើកប្រាក់អោយតាមមាត្រា ១៥ ភាគរយ លើករាល់ការទូទាត់ប្រាក់បៀវត្សជាប់ពន្ធដែលមានចែងក្នុងកថាខ័ណ្ឌ ៣ មាត្រា ៤៦ នៃច្បាប់នេះ ។ ពន្ធកាត់ទុកគឺជាពន្ធចុងក្រោយនៃពន្ធលើប្រាក់បៀវត្សសំរាប់អនិវាសនជនជាអ្នកទទួលប្រាក់បៀវត្ស ។

**មាត្រា ៥០.-**

អ្នកជាប់ពន្ធនិវាសនជនដែលបានទទួលប្រាក់បៀវត្សប្រភពបរទេស និងបានបង់ពន្ធតាមច្បាប់ពន្ធដារបរទេស ត្រូវបានទទួលនូវឥណទានពន្ធសំរាប់កាត់កងពីប្រាក់ពន្ធលើប្រាក់បៀវត្ស ដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែលុះណាតែមានការបង្ហាញឯកសារបញ្ជាក់អំពីការបង់ពន្ធនៅបរទេសនោះ ។

ក- ដើម្បីគណនាប្រាក់ពន្ធដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជា មុនពេលកាត់ឥណទានពន្ធនេះ ត្រូវយកចំនួនសរុបប្រាក់បៀវត្សដែលបានទទួលអំពីប្រភពកម្ពុជា និងប្រភពបរទេសមកគិត

ខ- ឥណទានពន្ធ ត្រូវបានកំណត់ដាច់ដោយឡែកពីគ្នា សំរាប់ប្រាក់ពន្ធដែលបានបង់ដោយនិវាសនជនកម្ពុជានៅប្រទេសក្រៅនីមួយៗ ។ ប៉ុន្តែឥណទានពន្ធផ្តល់អោយសំរាប់ពន្ធលើប្រាក់បៀវត្សដែលបានបង់នៅប្រទេសក្រៅ គឺជាចំនួនដែលទាបជាងគេក្នុងចំណោម :

- ប្រាក់ពន្ធដែលបានបង់ជាក់ស្តែងនៅប្រទេសក្រៅណាមួយ
- ចំនួនដែលបានមកពីការយកប្រាក់ពន្ធលើប្រាក់បៀវត្សសរុបពីគ្រប់ប្រភពក្នុងរយៈពេលជាមួយគ្នា ដែលគណនាតាមអត្រាកំណើនតាមថ្នាក់ក្នុងមាត្រា ៤៧ នៃច្បាប់នេះ ទៅគុណនឹងផលចែករវាងប្រាក់បៀវត្សដែលបានទទួលនៅប្រទេសក្រៅនោះ និងប្រាក់បៀវត្សសរុបពីគ្រប់ប្រភព ។

ការបង្វិលសងឥណទានពន្ធបរទេសអាចធ្វើទៅបាន លុះណាតែអ្នកជាប់ពន្ធនិវាសនជនបានបំពេញបែបបទព្រមផ្តល់ឯកសារនានាកំណត់ដោយរដ្ឋបាលសារពើពន្ធ ជាពិសេសសេចក្តីបញ្ជាក់របស់និយោជក និងរដ្ឋបាលសារពើពន្ធនៃទីកន្លែងបំរើការងារនៅឯបរទេស ។

## ផ្នែកទី ៤
## កាតព្វកិច្ចរបស់និយោជក និងនិយោជិត

**មាត្រា ៥១.-**

ការបើកបៀវត្ស បង្កើតជាហេតុផលបណ្តាលអោយជាប់ពន្ធ ។

**មាត្រា ៥២.-**

បំណុលពន្ធ និងកាតព្វកិច្ចកាត់ទុកជាប្រាក់ពន្ធត្រូវបានកំណត់ដូចតទៅ :

១- ពន្ធនេះ គឺជាបំណុលរបស់រូបវន្តបុគ្គលដែលបានទទួលប្រាក់បៀវត្ស រួមទាំងរូបវន្តបុគ្គលបរទេសផង វៀរលែងតែមានបទប្បញ្ញត្តិផ្ទុយដែលមានចែងក្នុងកិច្ចព្រមព្រៀងអន្តរជាតិ ។

២- ពន្ធលើប្រាក់បៀវត្សត្រូវប្រមូលតាមរបៀបកាត់ទុកជាមុនជារៀងរាល់ខែ ដោយនិយោជកនៅរាល់ពេលបើកប្រាក់បៀវត្ស ។

៣- ប្រសិនបើនិយោជកស្នាក់នៅបរទេស តំណាងសារពើពន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលនិយោជកចាត់តាំង គឺជាអ្នកទទួលភារៈកាត់ទុកពន្ធលើប្រាក់បៀវត្សមុនពេលបើកប្រាក់បៀវត្សទៅអោយនិយោជិត និងបង្វែរប្រាក់ពន្ធទាំងនោះជូនរដ្ឋ ។

៤- និយោជក ឬតំណាងនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់និយោជកបរទេស ហើយនិងនិយោជិតត្រូវទទួលខុសត្រូវរួមគ្នាក្នុងការបង់ពន្ធលើប្រាក់បៀវត្សក្នុងព្រះរាជាណាចក្រកម្ពុជា ដោយពុំកំណត់ថាប្រាក់បៀវត្សបានបើកអោយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេសឡើយ ។ ក្នុងករណីមិនបានកាត់ទុកប្រាក់ពន្ធលើប្រាក់បៀវត្ស និយោជកត្រូវទទួលខុសត្រូវចំពោះច្បាប់នេះ ទោះបីជាប្រាក់ពន្ធត្រូវបានបង់ដោយនិយោជិតរួចហើយក្តី ។

**មាត្រា ៥៣.-**

ប្រាក់ពន្ធកាត់ទុកដែលទាក់ទងដល់ការបើកប្រាក់បៀវត្សធ្វើឡើងក្នុងខែណាមួយ ត្រូវបង់យ៉ាងយឺតបំផុតនៅថ្ងៃទី ១៥ នៃខែបន្ទាប់ ជូនទៅរដ្ឋបាលសារពើពន្ធនៅទីកន្លែងនៃលំនៅដ្ឋាន ឬគ្រឹះស្ថានជាគោលដើមនៃអ្នកទទួលភារៈកាត់ទុកប្រាក់ពន្ធនេះ ។

**មាត្រា ៥៤.-**

គ្រប់និយោជកដែលបើកប្រាក់បៀវត្សត្រូវជាប់ពន្ធ ត្រូវទទួលបំពេញភារកិច្ច :

១- កាត់ទុកប្រាក់ពន្ធមុនពេលបើកបៀវត្ស ។

២- រាយការណ៍ជូនរដ្ឋបាលសារពើពន្ធ និងនិយោជិត អំពីស្ថានភាពប្រាក់ពន្ធដែលបានកាត់ទុក ។

៣- កាន់កាប់ និងថែរក្សាបញ្ជិកាដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៣

## បទប្បញ្ញត្តិស្តីអាករលើតំលៃបន្ថែម

### ផ្នែកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ៥៥.-**

ចាប់តាំងពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៨ តទៅ នឹងត្រូវបានបង្កើតអាករលើតំលៃបន្ថែមចំពោះការផ្គត់ផ្គង់ជាប់អាករ ដើម្បីជាប្រយោជន៍ដល់ថវិការដ្ឋ ។

**មាត្រា ៥៦.-**

សំរាប់គោលដៅនៃបទប្បញ្ញត្តិស្តីពីអាករលើតំលៃបន្ថែម :

១- ពាក្យ "ទំនិញ" សំដៅដល់ទ្រព្យរូបី ក្រៅពីដីធ្លី និងប្រាក់កាស ។

២- ពាក្យ "សេវា" សំដៅដល់ការផ្តល់អ្វីមួយដែលមានតំលៃក្រៅពីទំនិញ ដីធ្លី និងប្រាក់កាស ។

៣- ពាក្យ "ការផ្គត់ផ្គង់ទំនិញ" សំដៅដល់ការផ្ទេរសិទ្ធិប្រើប្រាស់ ឬសិទ្ធិចាត់ចែងក្នុងឋានៈជាម្ចាស់កម្មសិទ្ធិទំនិញ ទោះបីមានសំណង ឬគ្មានសំណងក្តី ។ ការផ្គត់ផ្គង់សេវាបន្ទាប់បន្សំដែលទាក់ទិននឹងការផ្គត់ផ្គង់ទំនិញ ត្រូវចាត់ទុកដូចជាការផ្គត់ផ្គង់ទំនិញ ។

៤- ពាក្យ "ការផ្គត់ផ្គង់សេវា" សំដៅដល់ការផ្គត់ផ្គង់ដែលមិនមែនជាការផ្គត់ផ្គង់ទំនិញ ដីធ្លី ឬប្រាក់កាសដែលធ្វើឡើងដើម្បីបានទទួលសំណងអ្វីមួយ ។ ការផ្គត់ផ្គង់ទំនិញបន្ទាប់បន្សំដែលទាក់ទិននឹងការផ្គត់ផ្គង់ សេវាត្រូវចាត់ទុកដូចជាការផ្គត់ផ្គង់សេវា ។

៥- ពាក្យ "បុគ្គល" សំដៅដល់បុគ្គល ឬក្រុមបុគ្គលដែលធ្វើអាជីវកម្ម ហើយនិងបុគ្គលណាមួយទៀតដែលទាក់ទិនជាមួយបុគ្គលនោះ ។

៦- ពាក្យ "ទាក់ទិន" ចំពោះបុគ្គលណាមួយ មានន័យថា :

ក- បុគ្គលណាមួយដែលមានកម្មសិទ្ធិចាប់ពី ២០ភាគរយឡើងទៅលើតំលៃ ឬសិទ្ធិបោះឆ្នោតនៃភាគកម្មនៅក្នុងដើមទុកផ្ទាល់នៃបុគ្គលដែលលើកយកមកពិចារណា

ខ- មានការគ្រប់គ្រងរួមគ្នា ឬមាននាយករួមគ្នាជាមួយបុគ្គល

គ- ជាសមាជិកគ្រួសារ ឬជាសហព័ទ្ធ ឬជាសមាជិកក្រុមគ្រួសារនៃសហព័ទ្ធរបស់បុគ្គល

ឃ- បានទិញចាប់ពី ៣០ភាគរយឡើងទៅនៃធាតុចេញសរុបរបស់បុគ្គល ក្នុងរយៈពេលបីខែបន្តបន្ទាប់ ។

៧- ពាក្យ "អាករ" ក្នុងជំពូកនេះសំដៅដល់អាករលើតំលៃបន្ថែម ។

**មាត្រា ៥៧.-**

ការផ្គត់ផ្គង់មិនជាប់អាករ មានដូចតទៅ :

១- សេវាប្រៃសណីយ៍សាធារណៈ ។

២- សេវារបស់មន្ទីរពេទ្យ និងគ្លីនិក សេវាខាងវេជ្ជសាស្ត្រ និងទន្តសាស្ត្រ និងការលក់ទំនិញបន្ទាប់បន្សំខាងវេជ្ជសាស្ត្រ និងទន្តសាស្ត្រដែលទាក់ទិននឹងការបំពេញសេវាទាំងនេះ ។

៣- សេវាដឹកជញ្ជូនអ្នកដំណើរដោយប្រព័ន្ធដឹកជញ្ជូនសាធារណៈ ដែលជាកម្មសិទ្ធិទាំងស្រុងរបស់រដ្ឋ ។

៤- សេវាធានារ៉ាប់រង ។

៥- សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុ ដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៦- ការនាំចូលសំភារៈប្រើប្រាស់ផ្ទាល់ខ្លួនដែលរួចពន្ធគយ ក្នុងកំរិតតំលៃដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៧- សកម្មភាពមិនស្វែងរកប្រាក់ចំណេញ ដើម្បីបំរើផលប្រយោជន៍សាធារណៈ ដែលបានទទួលស្គាល់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៥៨.-**

ការផ្គត់ផ្គង់មិនជាប់អាករចំពោះបេសកម្មទូត និងអង្គការអន្តរជាតិ ត្រូវបានកំណត់ដូចតទៅ :

១- ការនាំចូលនូវទំនិញសំរាប់ ឬដោយបេសកម្មទូត និងកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា សំរាប់យកមកប្រើនៅក្នុងការបំពេញមុខងារជាផ្លូវការរបស់ខ្លួន ត្រូវកំណត់ថាជាការផ្គត់ផ្គង់មិនជាប់អាករ ។ ការផ្គត់ផ្គង់មិនជាប់អាករត្រូវបានផ្តល់អោយតែក្នុងករណីមានការបញ្ជាក់អំពីប្រធានបេសកម្ម ជូននាយកដ្ឋានពន្ធដារថា ទំនិញទាំងនោះបាននាំចូលមកសំរាប់គោលដៅនៃការប្រើប្រាស់ខាងលើនេះមែន ។

២- ការនាំចូលទំនិញសំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួនរបស់បុគ្គលិកផ្លូវការនៃបេសកម្ម អង្គការ ដូចមានចែងក្នុងកថាខ័ណ្ឌ១ នៃមាត្រានេះត្រូវកំណត់ថា ជាការផ្គត់ផ្គង់មិនជាប់អាករចំពោះតែមុខទំនិញ ទាំងឡាយដែលមានចុះនៅក្នុងបញ្ជីរាយមុខទំនិញ ដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៣- ការផ្គត់ផ្គង់មិនជាប់អាករនៅក្នុងមាត្រានេះ ត្រូវឈរលើគោលការណ៍បដិការវាងរដ្ឋាភិបាលពាក់ព័ន្ធ ។

## ផ្នែកទី ២

## គោលការណ៍ទូទៅនៃអាករលើតំលៃបន្ថែម

### មាត្រា ៥៩.-

បុគ្គលជាប់អាករ សំដៅដល់បុគ្គលដែលត្រូវជាប់ពន្ធតាមរបបពិត ហើយដែលធ្វើការផ្គត់ផ្គង់ជាប់អាករ ដូចមានចែងក្នុងមាត្រា ៦០ នៃច្បាប់នេះ ។

បុគ្គលដែលជាប់ពន្ធតាមរបបបំព្រួញ អាចស្នើសុំអោយចាត់ជាបុគ្គលជាប់អាករបាន ។ ល័ក្ខខ័ណ្ឌ និងនីតិវិធីសំរាប់ការស្នើសុំនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

សំរាប់គោលដៅនៃជំពូកនេះ និយោជិតមិនត្រូវចាត់ទុកថាជាបុគ្គលជាប់អាករទេ ចំពោះសកម្មភាពដែលបានបំពេញក្នុងឋានៈជានិយោជិត ។

### មាត្រា ៦០.-

លើកលែងតែមានបទប្បញ្ញត្តិផ្ទុយនៅក្នុងជំពូកនេះពាក្យ "ការផ្គត់ផ្គង់ជាប់អាករ" សំដៅដល់ :

១- ការផ្គត់ផ្គង់ទំនិញ ឬសេវាដោយបុគ្គលជាប់អាករនៅក្នុងព្រះរាជាណាចក្រកម្ពុជា

២- ការដកយកទំនិញមកប្រើប្រាស់ផ្ទាល់ខ្លួនដោយបុគ្គលជាប់អាករ

៣- ការផ្តល់ជាអំណោយ ឬការផ្គត់ផ្គង់ក្រោមតំលៃពិតនូវទំនិញ ឬសេវាដោយបុគ្គលជាប់អាករ

៤- ការនាំចូលទំនិញមកក្នុងតំបន់ត្រួតពិនិត្យគយនៃព្រះរាជាណាចក្រកម្ពុជា ។

វិធាន និងនីតិវិធីសំរាប់ការអនុវត្តមាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

### មាត្រា ៦១.-

តំលៃជាប់អាករត្រូវបានកំណត់ដូចតទៅ :

១- តំលៃជាប់អាករនៃការផ្គត់ផ្គង់ គឺជាថ្លៃទំនិញ ឬសេវាដែលអ្នកលក់យកពីអ្នកទិញ ។ តំលៃជាប់អាករួមមាន បន្ទុកដឹកជញ្ជូន ហើយនិងខ្ទង់ដទៃទៀត ដែលត្រូវទូទាត់អោយអ្នកលក់ចំពោះការផ្គត់ផ្គង់នោះ រួមបញ្ចូល ទាំងអាករពិសេសលើទំនិញ និងសេវាមួយចំនួន លើកលែងតែអាករលើតំលៃបន្ថែម ។ នីតិវិធីសំរាប់ធ្វើការ កែតំរូវតំលៃជាប់អាករនៅពេលផ្គត់ផ្គង់ ឬក្រោយពេលផ្គត់ផ្គង់ ត្រូវកំណត់ដោយអនុក្រឹត្យ ។

២- ក្នុងករណីដែលការទូទាត់ចំពោះការផ្គត់ផ្គង់ជាប់អាករជាសំណងអ្វីមួយក្រៅពីប្រាក់កាស ដើម្បីជាផលប្រ-យោជន៍ផ្ទាល់ ឬប្រយោលដល់អ្នកលក់ សំណងនោះត្រូវគិតបញ្ចូលក្នុងតំលៃជាប់អាករតាមតំលៃទីផ្សារ ។

៣- តំលៃជាប់អាកររបស់ទំនិញនាំចូល គឺជាតំលៃគយ រួមបញ្ចូលទាំងតំលៃធានារ៉ាប់រង និងដឹកជញ្ជូនដោយបូក បន្ថែមនូវពន្ធគយ និងអាករពិសេសលើទំនិញ និងសេវាមួយចំនួន ។ បើសិនជាគ្មានតំលៃគយកែតំរូវទេ ត្រូវ កំណត់យកតាមតំលៃទីផ្សារ ។

៤- បើសិនជាតំលៃជាប់អាកររបស់អ្នកទិញ ឬសេវាដែលបានផ្គត់ផ្គង់មិនតំណាងអោយតំលៃពិតទេនោះ រដ្ឋបាល សារពើពន្ធ អាចកំណត់ចេញនូវតំលៃមួយសំរាប់ទំនិញ ឬសេវា ហើយតំលៃនោះ ត្រូវចាត់ទុកជាតំលៃត្រឹម ត្រូវរហូតដល់ពេលមានភស្តុតាងបញ្ជាក់ផ្សេង ដែលរដ្ឋបាលសារពើពន្ធបានយល់ព្រម ។

៥- តំលៃជាប់អាករនៃទំនិញប្រើរួចហើយ ដែលបុគ្គលជាប់អាករបានទិញពីអ្នកប្រើប្រាស់ ដើម្បីលក់ជាប្រចាំ ឬ លក់ជំនួសមុខអោយអ្នកប្រើប្រាស់ គឺជាចំនួនលំអៀងរវាងថ្លៃលក់ និងថ្លៃទិញ ឬប្រាក់កំរៃដែលបានមកពី ការលក់ទំនិញនោះ ។

**មាត្រា ៦២.-**

ពេលផ្គត់ផ្គង់ត្រូវបានកំណត់ដូចតទៅ :

១- អាករលើតំលៃបន្ថែមត្រូវដល់កំណត់ និងត្រូវបង់នៅពេលផ្គត់ផ្គង់ ។

២- ពេលផ្គត់ផ្គង់ទំនិញ និងសេវា គឺជាពេលដែលអ្នកលក់ត្រូវចេញវិក័យប័ត្រ ឬជាពេលដែលអ្នកលក់បានចេញ វិក័យប័ត្រ ប្រសិនបើវិក័យប័ត្រនោះត្រូវបានចេញមុនពេលដែលអ្នកលក់ត្រូវចេញវិក័យប័ត្រ ។

៣- វិក័យប័ត្រអាករលើតំលៃបន្ថែម ត្រូវចេញយ៉ាងយឺតបំផុត ៧ថ្ងៃ ក្រោយការបញ្ជូនទំនិញ ឬការបំពេញសេវា ឬក្រោយការទូទាត់ ក្នុងករណីដែលការទូទាត់ធ្វើឡើងមុនការបញ្ជូនទំនិញ ឬការបំពេញសេវា ។ ប្រសិនបើ ការបញ្ជូនទំនិញពុំមានវិក័យប័ត្រភ្ជាប់ជាមួយទេ ត្រូវមានភ្ជាប់ឯកសារបញ្ចូលទំនិញដែលបានកត់ត្រាត្រឹម-ត្រូវទិនានុប្បវត្តិបញ្ជូនទំនិញ ។

៤- ចំពោះការផ្គត់ផ្គង់ទំនិញ ឬសេវាដែលធ្វើឡើងជាបន្ត ឬដែលមានការទូទាត់ច្រើនលើក ពេលផ្គត់ផ្គង់ត្រូវ កំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៥- ចំពោះការនាំចូលទំនិញ ពេលផ្គត់ផ្គង់គឺជាពេលដែលអ្នកនាំចូលដាក់លិខិតប្រកាសជូនអាជ្ញាធរគយទៅតាម គោលការណ៍ជាធរមាន ។

**មាត្រា ៦៣.-**

ទីកន្លែងផ្គត់ផ្គង់ ត្រូវបានកំណត់ដូចតទៅ ៖

១- ការផ្គត់ផ្គង់ទំនិញ ត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា បើសិនជាទំនិញនោះត្រូវបានប្រគល់អោយ ទោះមានលក្ខណៈជាការផ្ទេរសិទ្ធិប្រើប្រាស់ ឬសិទ្ធិចាត់ចែងក្តី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ចំពោះករណីដែលការផ្គត់ផ្គង់ត្រូវមានការដឹកជញ្ជូន ការផ្គត់ផ្គង់ ត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះ - រាជាណាចក្រកម្ពុជា គឺបើសិនជាទំនិញស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅពេលដែលការដឹកជញ្ជូនត្រូវបានចាប់ផ្តើម ។

២- ការផ្គត់ផ្គង់សេវាត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា បើសិនជាសេវានោះបានបំពេញនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយឡែកតែ ៖

ក- ការផ្គត់ផ្គង់សេវាទាក់ទងនឹងអចលនទ្រព្យ ត្រូវកំណត់ថាសេវានោះបានធ្វើឡើងនៅទីកន្លែងដែលទ្រព្យនោះស្ថិតនៅ

ខ- ការផ្គត់ផ្គង់សេវាជាប់ទាក់ទងនឹងការដឹកជញ្ជូន ត្រូវកំណត់ថាសេវានោះបានធ្វើឡើងនៅទីកន្លែងនៃការដឹកជញ្ជូននោះ ។

៣- ទំនិញត្រូវចាតទុកថាបាននាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា បើសិនជាទំនិញនោះត្រូវបាននាំចូលមកក្នុងតំបន់ត្រួតពិនិត្យគយនៃព្រះរាជាណាចក្រកម្ពុជា ។

## ផ្នែកទី ៣

## អត្រាអាករ និងការកំណត់ប្រាក់អាករ

### មាត្រា ៦៤.-

អត្រាអាករត្រូវបានកំណត់ដូចតទៅ ៖

១- អាករលើតំលៃបន្ថែមត្រូវកំណត់តាមអត្រា ១០ភាគរយ លើតំលៃជាប់អាករនៃការផ្គត់ផ្គង់ជាប់អាករនីមួយៗនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- អាករលើតំលៃបន្ថែមត្រូវកំណត់តាមអត្រា ០ភាគរយ លើតំលៃជាប់អាករនៃការផ្គត់ផ្គង់ជាប់អាករនីមួយៗចំពោះទំនិញនាំចេញពីព្រះរាជាណាចក្រកម្ពុជា ហើយនិងការផ្គត់ផ្គង់សេវាជាប់អាករ ដែលបានបំពេញនៅក្រៅព្រះរាជាណាចក្រកម្ពុជា ដូចមានចែងក្នុងមាត្រា ៦៣ នៃច្បាប់នេះ ។

៣- រដ្ឋបាលសារពើពន្ធអាចប្រើប្រាស់ឯកសារមួយចំនួន ដើម្បីបញ្ជាក់ថាមានការនាំចេញជាក់ស្តែងមែនក្នុងនោះមានជាអាទិ៍ សេចក្តីបញ្ជាក់ការនាំចេញរបស់ទីចាត់ការគយ និងរដ្ឋាករ ឯកសារនាំចូលរបស់ប្រទេសនាំចូល លិខិតឥណទានបានប្រើប្រាស់ និងការទូទាត់ដែលធនាគារក្នុងស្រុកបានទទួល ។

### មាត្រា ៦៥.-

ឥណទានអាករលើធាតុចូល និងការផ្គត់ផ្គង់មិនជាប់អាករ ត្រូវបានកំណត់ដូចតទៅ ៖

១- ប្រាក់អាករដែលបុគ្គលជាប់អាករបានបង់លើទំនិញ និងសេវាសំរាប់ប្រើប្រាស់ក្នុងអាជីវកម្មដែលបុគ្គលជាប់អាករ ក្នុងឋានៈជាអ្នកនាំចូលលើទំនិញ ឬសេវានាំចូលសំរាប់ប្រើប្រាស់នៅក្នុងអាជីវកម្មរបស់ខ្លួន ត្រូវក្លាយជាឥណទានអាករលើធាតុចូលសំរាប់កាត់កងចេញពីអាករលើធាតុចេញ ។ ធាតុចូលមានន័យថា ទំនិញ ឬសេវាដែលបានទិញចូល ហើយធាតុចេញមានន័យថា ទំនិញ ឬសេវាដែលបានលក់ចេញ ។

២- ក្នុងករណីទំនិញ និងសេវាទិញចូលត្រូវបានប្រើប្រាស់មួយចំណែកជាការផ្គត់ផ្គង់ជាប់អាករ នឹងមួយចំណែក - ទៀតជាការផ្គត់ផ្គង់មិនជាប់អាករ ឥណទានអាករត្រូវបានអនុញ្ញាតអោយតែចំពោះចំណែកដែលបានប្រើប្រាស់ជាការផ្គត់ផ្គង់ជាប់អាករ ។

**មាត្រា ៦៦.-**

ប្រាក់អាករដែលត្រូវបានកំណត់ដូចតទៅ :

១- អាករដែលបានកំណត់ក្នុងមាត្រា ៦៤ នៃច្បាប់នេះ ត្រូវចាត់ទុកជាបំណុលចំពោះរដ្ឋនៅពេលផ្គត់ផ្គង់ ។

២- ប្រាក់អាករត្រូវបង់ជូនរដ្ឋ ស្មើនឹងប្រាក់អាករលើធាតុចេញសរុបតាមអត្រាក្នុងមាត្រា ៦៤ នៃច្បាប់នេះ ដកឥណទានអាករលើធាតុចូលដែលបានអនុញ្ញាតសរុបក្នុងខែជាមួយគ្នា ។

**មាត្រា ៦៧.-**

ក្នុងករណីអចលនកម្មរូបីនៃអាជីវកម្មណាមួយដែលបានទទួលឥណទានអាករ ដូចក្នុងមាត្រា ៦៥ នៃច្បាប់នេះ ត្រូវឈប់ប្រើប្រាស់នៅក្នុងអាជីវកម្មរបស់បុគ្គលជាប់អាករ ទ្រព្យនោះត្រូវចាត់ទុកថា បានលក់ និងត្រូវជាប់អាករតាមតំលៃទីផ្សារនៅពេលឈប់ប្រើការនោះ ។

**មាត្រា ៦៨.-**

សំណើសុំឥណទានអាករលើធាតុចូល ត្រូវភ្ជាប់មកជាមួយនូវ :

១- វិក័យបត្រអាករលើតំលៃបន្ថែមដែលបានធ្វើឡើងស្របតាមមាត្រា ៧៨ នៃច្បាប់នេះ ។

២- ប្រតិវេទន៍គយសំរាប់ការនាំចូលដែលអាជ្ញាធរគយបានបញ្ជាក់ត្រឹមត្រូវ ។ ប្រតិវេទន៍នោះ ត្រូវមានចុះឈ្មោះបុគ្គលជាប់អាករដែលជាអ្នកទទួលទិញ ឬជាអ្នកនាំចូល និងចំនួនប្រាក់ពន្ធអាករដែលបានបង់នៅពេលនាំចូល ។

**មាត្រា ៦៩.-**

អាករលើធាតុចូលដែលមិនអនុញ្ញាតឱ្យប្រើជាឥណទាន រួមមានប្រាក់អាករដែលបុគ្គលជាប់អាករបានបង់លើការចំណាយទទួលភ្ញៀវ កំសាន្ត ឬសំរាកលំហែ ការទិញរថយន្ត ឬការទិញផលិតផលតេលសិលាមួយចំនួន ។

## ផ្នែកទី ៤

## ការបង់ប្រាក់អាករ

**មាត្រា ៧០.-**

លិខិតប្រកាសអាករលើតំលៃបន្ថែមសំរាប់ខែណាមួយ ត្រូវដាក់ជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតត្រឹមថ្ងៃទី ២០នៃខែបន្ទាប់ ហើយត្រូវបង់ប្រាក់អាករទៅតាមចំនួនដែលប្រកាសនៅពេលដាក់លិខិតប្រកាសនោះ ។

**មាត្រា ៧១.-**

បើសិនជាអាករលើធាតុចូលដែលបុគ្គលជាប់អាករបានបង់តាមមាត្រា ៦៤ នៃច្បាប់នេះ មានចំនួនខ្ពស់ជាងអាករលើធាតុចេញ ដែលបុគ្គលនោះប្រមូលសំរាប់ខែណាមួយ :

១- ចំនួនលើសត្រូវប្រើជាឥណទានអាករចំពោះប្រាក់អាករលើតំលៃបន្ថែមដែលបុគ្គលនៅជំពាក់ខែកន្លងទៅ ។

២- ចំនួនលើសដែលនៅសល់ទៀតនោះ ត្រូវចាត់ទុកជាឥណទានអាករលើធាតុចូលនៃមាត្រា ៦៥ នៃច្បាប់នេះ -សំរាប់ខែបន្ទាប់ ។

**មាត្រា ៧២.-**

រដ្ឋបាលសារពើពន្ធអាចបង្វិលនូវឥណទានអាករលើធាតុចូលលើសប្រចាំខែតាមការស្នើសុំរបស់បុគ្គលជាប់អាករដែលមានសកម្មភាពនាំចេញជាសំខាន់ ប្រសិនបើបុគ្គលនោះបានបង្ហាញឯកសារបញ្ជាក់ច្បាស់លាស់ក្នុងការនាំចេញ ហើយនិងបានប្រតិបត្តិត្រឹមត្រូវនូវកាតព្វកិច្ចកាន់បញ្ជិកា និងឯកសារផ្សេងទៀត ។

**មាត្រា ៧៣.-**

បើសិនជាបុគ្គលជាប់អាករ មានឥណទានអាករលើធាតុចូលលើសចាប់ពីបីខែឡើងទៅ បុគ្គលនោះអាចដាក់ពាក្យសុំបង្វិលសងប្រាក់អាករនូវដំណាច់ខែទី ៣ ឬនៅក្នុងខែណាមួយជាបន្តមកទៀត ។ ដើម្បីអោយមានតំលៃអនុវត្តសំរាប់ខែណាមួយ ពាក្យសុំត្រូវដាក់ស្នើក្នុងរយៈពេល ២០ថ្ងៃ ក្រោយដំណាច់ខែទាំងនោះ ។

**មាត្រា ៧៤.-**

បេសកម្មទូត ឬកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានាអាចដាក់ពាក្យសុំបង្វិលសងប្រាក់អាករលើទំនិញដែលបានទិញនៅក្នុងស្រុកដែលនឹងមានចុះនៅក្នុងបញ្ជីរាយមុខទំនិញកំ-ណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ការបង្វិលសងប្រាក់អាករអាចអនុវត្តទៅបានតែក្នុងករណីមានការបញ្ជាក់អំពីប្រធានបេសកម្មជូនទៅរដ្ឋបាលសារពើពន្ធថា ទំនិញត្រូវបានទិញមកសំរាប់យកទៅប្រើប្រាស់នៅក្នុងការបំពេញមុខងារជាផ្លូវការរបស់អង្គភាពសាមី ។

**មាត្រា ៧៥.-**

ការទទួលខុសត្រូវចំពោះការប្រមូល និងការបង់អាករត្រូវបានកំណត់ដូចតទៅ :

១- បុគ្គលជាប់អាករ ឬអ្នកនាំចូលមានកាតព្វកិច្ចត្រូវបង់អាករដែលកំណត់ដោយមាត្រា ៦៤ នៃច្បាប់នេះលើរាល់ការផ្គត់ផ្គង់ជាប់អាករ ដែលបុគ្គលជាប់អាករ ឬអ្នកនាំចូលបានអនុវត្ត ។

២- លក្ខខណ្ឌពិសេសបញ្ជាក់អំពីការទទួលខុសត្រូវរបស់អ្នកទិញចំពោះប្រាក់អាករ ក្នុងករណីដែលអ្នកផ្គត់ផ្គង់គ្មានធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬក្នុងករណីដែលមានឧបសគ្គផ្សេងទៀតដល់ការប្រមូលប្រាក់អាករអំពីអ្នកផ្គត់ផ្គង់ត្រូវកំណត់ដោយអនុក្រឹត្យ ។

៣- បុគ្គលណាមួយដែលបានធ្វើការផ្គត់ផ្គង់ទំនិញ និងសេវាកម្មក្នុងនាមម្ចាស់កម្មសិទ្ធិ និងមិនមែនក្នុងឋានៈជានិយោជិតរបស់គេទេនោះ ហើយដែលមានការគ្រប់គ្រងលើការផ្គត់ផ្គង់ត្រូវចាត់ទុកថាជាបុគ្គលជាប់អាករសំ-រាប់ការផ្គត់ផ្គង់នោះ ។

## ផ្នែកទី ៥

## បទប្បញ្ញត្តិខាងរដ្ឋបាល

### មាត្រា ៧៦.-

គោលការណ៍ស្តីពីការចុះបញ្ជី ត្រូវបានកំណត់ដូចតទៅ :

១-បុគ្គលជាប់អាករដូចមានចែងក្នុងមាត្រា ៥៩ នៃច្បាប់នេះ ត្រូវធ្វើការចុះបញ្ជីសំរាប់អាករលើតំលៃបន្ថែមឱ្យបានស្រេចបាច់ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃដែលបុគ្គលនោះ ក្លាយជាបុគ្គលជាប់អាករ ។វិធាន និងនីតិវិធីសំរាប់ការចុះបញ្ជីនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

២-ចំពោះបុគ្គលដែលមានការតំរូវអោយធ្វើការចុះបញ្ជី ហើយដែលមិនបានធ្វើការចុះបញ្ជីនោះ រដ្ឋបាលសារពើពន្ធអាចធ្វើការចុះបញ្ជីបុគ្គលនោះ ចាប់តាំងពីពេលដែលបុគ្គលនោះត្រូវមកធ្វើការចុះបញ្ជី ។ បុគ្គលដែលត្រូវបានចុះបញ្ជីតាមបែបនេះ ត្រូវមានការទទួលខុសត្រូវចំពោះប្រាក់អាករទាំងអស់ក្នុងមាត្រា ៦៤ នៃច្បាប់នេះ ចាប់តាំងពីកាលបរិច្ឆេទដែលបុគ្គលនោះត្រូវមកធ្វើការចុះបញ្ជី ។

៣-បើសិនជាបុគ្គលជាប់អាករណាមួយ ដែលបានចុះបញ្ជីតាមមាត្រានេះ យល់ឃើញថាខ្លួនមិនត្រូវជាបុគ្គលជាប់អាករសំរាប់ឆ្នាំចរន្ត និងឆ្នាំបន្ទាប់ទេ បុគ្គលនោះអាចដាក់ពាក្យសុំលប់ការចុះបញ្ជីវិញ ។

៤-សំរាប់ក្រុមបុគ្គលទាក់ទិនពីរនាក់ ឬច្រើននាក់ ដែលក្នុងនោះបុគ្គលម្នាក់ ឬច្រើននាក់មិនមែនជាបុគ្គលជាប់អាករទេនោះ រដ្ឋបាលសារពើពន្ធអាចចាត់ទុកបុគ្គលជាប់អាករណាមួយ ថាបានចុះបញ្ជីសំរាប់សកម្មភាពសេដ្ឋកិច្ចទាក់ទិនទាំងមូល ឬភាគណាមួយ ។ បើសិនជាគ្មានបុគ្គលទាក់ទិនណាម្នាក់ ជាបុគ្គលជាប់អាករទេនោះ រដ្ឋបាលសារពើពន្ធអាចចុះបញ្ជីនូវបុគ្គលក្នុងក្រុមម្នាក់ ឬច្រើននាក់សំរាប់សកម្មភាពសេដ្ឋកិច្ចទាក់ទិនទាំងមូល ឬភាគណាមួយ។

៥-សំរាប់គោលដៅនៃការចុះបញ្ជី និងដោយមានការយល់ព្រមពីរដ្ឋបាលសារពើពន្ធផង ចំពោះបុគ្គលជាប់អាករមួយក្រុមដែលជាប់ទាក់ទិនគ្នា ដូចមានចែងក្នុងមាត្រា ៥៦ នៃច្បាប់នេះ សកម្មភាពរបស់សមាជិកនានានៅក្នុងក្រុមអាចចាត់ទុកជាសកម្មភាពរបស់សមាជិកជ្រើសតាំងតែម្នាក់ប៉ុណ្ណោះ ។ ក្នុងករណីនេះ សមាជិកម្នាក់ៗនៅក្នុងក្រុម ត្រូវមានការទទួលខុសត្រូវរួមគ្នានិងយ៉ាងពេញលេញ ចំពោះការប្រតិបត្តិតាមបទប្បញ្ញត្តិនៃជំពូកនេះ ។

### មាត្រា ៧៧.-

គោលការណ៍ស្តីពីវិក័យប័ត្រអាករលើតំលៃបន្ថែម ត្រូវបានកំណត់ដូចតទៅ :

១- បុគ្គលជាប់អាករដែលធ្វើការផ្គត់ផ្គង់ ត្រូវចេញវិក័យបត្រអាករលើតម្លៃបន្ថែមដែលបានចុះលេខរៀងត្រឹមត្រូវអោយទៅអ្នកទិញ ។

២- វិក័យបត្រដែលកថាខណ្ឌ១ នៃមាត្រានេះ បានតម្រូវឡើងសំរាប់ការផ្គត់ផ្គង់ណាមួយត្រូវដាក់ចំណងជើងថា "វិក័យបត្រអាករលើតម្លៃបន្ថែម" ហើយត្រូវមានចុះនិទ្ទេសដូចតទៅ :

ក- ឈ្មោះ និងលេខចុះបញ្ជីរបស់អ្នកលក់

ខ- កាលបរិច្ឆេទចេញវិក័យបត្រ

គ- ឈ្មោះរបស់អ្នកទិញ ឬរបស់និយោជិត ឬភ្នាក់ងាររបស់អ្នកទិញ

ឃ- បរិមាណ សេចក្តីបរិយាយ និងថ្លៃលក់ ទំនិញ ឬសេវា

ង- តម្លៃសរុបដែលមិនទាន់គិតអាករពិសេសលើទំនិញ និងសេវាមួយចំនួន ហើយនិងអាករលើតម្លៃបន្ថែម

ច- តម្លៃជាប់អាករសរុប បើសិនជាខុសគ្នាពីចំនួនទឹកប្រាក់នៅក្នុងវាក្យខ័ណ្ឌនៃកថាខ័ណ្ឌនេះ

ឆ- ប្រាក់អាករត្រូវបង់

ជ- កាលបរិច្ឆេទនៃការផ្គត់ផ្គង់ទំនិញ ឬសេវា បើសិនជាខុសគ្នាពីកាលបរិច្ឆេទចេញវិក័យបត្រ ។

៣- បុគ្គលទាំងឡាយមិនអាចចេញវិក័យបត្រ ឬឯកសារផ្សេងទៀតបញ្ជាក់នូវទឹកប្រាក់ណាមួយថាជាប្រាក់អាករលើការផ្គត់ផ្គង់ទំនិញ ឬសេវាបានទេ លើកលែងតែបុគ្គលនោះជាបុគ្គលជាប់អាករបានចុះបញ្ជីស្របតាមមាត្រា៧៧ នៃច្បាប់នេះ ហើយទំនិញ ឬសេវាផ្គត់ផ្គង់ គឺជាទំនិញ ឬសេវាជាប់អាករ ។

៤- ក្រៅអំពីទោសទណ្ឌកម្មដទៃទៀត បើសិនជាវិក័យបត្រណាមួយត្រូវបានប្រកាសអះអាងដោយក្លែងបន្លំថាជាវិក័យបត្រអាករបន្ថែម ហើយវិក័យបត្រនោះបានបង្ហាញថា មានទឹកប្រាក់អាករមួយចំនួនត្រូវបង់ បុគ្គលអ្នកចេញវិក័យប័ត្រត្រូវបង់ជូនរដ្ឋបាលសារពើពន្ធក្នុងរយៈពេលប្រាំពីរថ្ងៃក្រោយកាលបរិច្ឆេទវិក័យបត្រនូវទឹកប្រាក់ ដែលបានចុះលើវិក័យបត្រនោះ ទោះបីជាទឹកប្រាក់អាករត្រូវបង់មែន ឬមិនមែនក្តី ។

៥- ក្នុងករណីមានការលក់រាយដែលក្នុងនោះការលក់ភាគច្រើនមិនបានធ្វើជាមួយបុគ្គលជាប់អាករវិក័យបត្រដែលតំរូវដោយកថាខ័ណ្ឌ១ នៃមាត្រានេះ ត្រូវចាត់ទុកថាបានបំពេញគ្រប់គ្រាន់ បើសិនជាអ្នកលក់បានផ្តល់បង្កាន់ដៃទទួលប្រាក់លំអិតសំរាប់បញ្ជីបេឡា ឬក៏ឯកសារផ្សេងទៀតដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

៦- ចំពោះការនាំចូលប្រតិវេទន៍គយ ដែលបានបំពេញត្រឹមត្រូវ និងដែលមានសេចក្តីបញ្ជាក់អំពីការបង់ប្រាក់អាករ ត្រូវប្រើប្រាស់ជាឯកសារត្រួតពិនិត្យដើម្បីកំណត់លក្ខណៈអាចទទួលបាននូវឥណទានអាករ ។

**មាត្រា ៧៨.-**

ការមិនបានចេញវិក័យប័ត្រអាករលើតម្លៃបន្ថែម ត្រូវរងទោសទណ្ឌដូចតទៅ :

១- ក្រៅអំពីទោសទណ្ឌដទៃទៀត បើសិនជារដ្ឋបាលសារពើពន្ធរកឃើញជាលើកទី២ ថា គ្រឹះស្ថានណាមួយរបស់បុគ្គលជាប់អាករ មិនបានចេញវិក័យប័ត្រតាមការតម្រូវនោះ រដ្ឋបាលសារពើពន្ធអាចបិទគ្រឹះស្ថាននោះក្នុងរយៈពេលមានកំណត់មួយ ដែលមិនលើសពីប្រាំពីរថ្ងៃ ។

២- បើសិនជាគ្រឹះស្ថានណាមួយ ដែលធ្លាប់ត្រូវបានបិទដូចក្នុងកថាខ័ណ្ឌ១ នៃមាត្រានេះនៅតែប្រព្រឹត្តបទល្មើសបែបនោះជាថ្មីទៀត គ្រឹះស្ថាននោះអាចត្រូវបានបិទជាថ្មីទៀត ក្នុងរយៈពេលមានកំណត់មួយដែលមិនលើសពីប្រាំពីរថ្ងៃ ។

**មាត្រា ៧៩.-**

គោលការណ៍ស្តីពីបញ្ជីកំណត់ត្រាពតិមាន សំរាប់អាករលើតម្លៃបន្ថែមត្រូវបានកំណត់ដូចតទៅ :

១- សំរាប់គោលដៅបទប្បញ្ញត្តិទាំងឡាយណាក្នុងជំពូកនេះ បុគ្គលជាប់អាករត្រូវរក្សាទុកនូវច្បាប់ចម្លងវិក័យប័ត្រទាំងអស់ដែលបានធ្វើចេញ និងវិក័យប័ត្រទាំងអស់ដែលបានទទួល ។

២- បុគ្គលជាប់អាករត្រូវកត់ត្រា និងរក្សាទុកអោយបានត្រឹមត្រូវនូវបញ្ជី កំណត់ត្រានៃរាល់កិច្ចការជំនួញដែលបានធ្វើ ហើយត្រូវមានគណនីតាមដានទឹកប្រាក់អាករដែលបានប្រមូលលើការលក់ និងទឹកប្រាក់អាករដែលបានបង់លើការទិញនានារបស់ខ្លួន ព្រមទាំងសេចក្តីកែតំរូវផ្សេងៗ លើតម្លៃលក់ ឬទឹកប្រាក់អាករ ទៅតាមបែបបទដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ ។

៣- កិច្ចការដូចមានចែងក្នុងកថាខ័ណ្ឌ២ នៃមាត្រានេះ ត្រូវធ្វើប្រចាំថ្ងៃ ហើយត្រូវធ្វើការបូកសរុប និងគណនាសមតុល្យនៅដំណាច់ខែនីមួយៗ ។ បុគ្គលជាប់ពន្ធអាករត្រូវធ្វើជារៀងរាល់ខែនូវសម្រង់អាករលើតម្លៃបន្ថែមទៅតាមបែបបទកំណត់ដោយរដ្ឋបាលសារពើពន្ធ ។

៤- វិក័យប័ត្រ កំណត់ត្រា និងឯកសារផ្សេងទៀត ដែលជាប់ទាក់ទងនឹងអាករនេះត្រូវរក្សាទុកតាមលំដាប់ថ្ងៃខែតាមបែបបទ និងទីកន្លែងរដ្ឋបាលសារពើពន្ធបានកំណត់ក្នុងរយៈពេល ១០ឆ្នាំយ៉ាងតិច ក្រោយការបញ្ចប់កិច្ចការជំនួញចុងក្រោយបំផុត ដែលជាប់ទាក់ទងនឹងឯកសារទាំងនេះ ។

៥- ឯកសារ និងកំណត់ត្រាទាំងអស់ដែលត្រូវរក្សាទុកតាមមាត្រានេះ ហើយនិងឯកសារ និងកំណត់ត្រាឯទៀតដែលទាក់ទងនឹងអាជីវកម្មរបស់បុគ្គល ត្រូវផ្តល់អោយរដ្ឋបាលសារពើពន្ធត្រួតពិនិត្យនៅពេលមានសំណើ ។

**មាត្រា ៨០.-**

បទប្បញ្ញត្តិនានានៃជំពូកនេះ ដែលទាក់ទងនឹងការនាំចូលត្រូវគ្រប់គ្រងដោយទីចាត់ការគយ និងរដ្ឋាករទៅតាមបែបបទដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨១.-**

វិធាននៃការបញ្ឈប់អាជីវកម្ម ត្រូវបានកំណត់ដូចតទៅ :

១- ក្នុងរយៈពេល ១០ថ្ងៃ ក្រោយការបញ្ឈប់អាជីវកម្មដែលបុគ្គលជាប់អាករបានធ្វើការចុះបញ្ជី បុគ្គលនោះត្រូវដាក់លិខិតប្រកាសមួយទៅតាមទម្រង់ដែលបានកំណត់ ជូនរដ្ឋបាលសារពើពន្ធ ដោយភ្ជាប់មកជាមួយនូវព័តិមានលំអិតអំពីការលក់ និងការទិញនានា ក្រោយពីការធ្វើប្រកាសសារពើពន្ធចុងក្រោយបំផុត និងព័តិមានលំអិតអំពីទំនិញទាំងអស់នៅក្នុងស្តុកដែលមិនទាន់បង់អាករ ឬដែលបានទទួលឥណទានអាកររួចហើយ ព្រមទាំងបង់ប្រាក់អាករដល់កំណត់ទាំងនោះ ។

២-  វិធាន និងនីតិវិធី សម្រាប់ការបញ្ឈប់អាជីវកម្ម ការលុបឈ្មោះពីបញ្ជី ហើយនិងការទទួលខុសត្រូវរបស់អ្នកតំណាងតាមផ្លូវការ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨២.-**

ការផ្ទេរអាជីវកម្មពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតស្របតាមល័ក្ខខ័ណ្ឌ ដែលត្រូវកំណត់ដោយអនុក្រឹត្យមិនត្រូវជាប់អាករលើតម្លៃបន្ថែមទេ ។ វិធាន និងនីតិវិធីនៃការជូនដំណឹងអំពីការផ្ទេរ ការចុះបញ្ជីរបស់បុគ្គលអ្នកទទួលអាជីវកម្ម ការទទួលខុសត្រូវរបស់បុគ្គល អ្នកផ្ទេរអាជីវកម្ម ការទទួលខុសត្រូវរបស់បុគ្គលអ្នកទទួលអាជីវកម្ម និងកិច្ចរក្សាកំណត់ត្រាផ្សេងៗ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨៣.-**

គោលការណ៍អនុវត្តចំពោះកិច្ចសន្យាដែលបានធ្វើមុនកាលបរិច្ឆេទចូលជាធរមាននៃអាករត្រូវបានកំណត់ដូចតទៅ :

១-  ត្រូវដាក់អោយអនុវត្តនូវអាករតាមមាត្រា៥៥ នៃច្បាប់នេះ លើការផ្គត់ផ្គង់ជាប់អាករនានា ក្រោមកិច្ចសន្យាដែលបានធ្វើឡើងមុនកាលបរិច្ឆេទចូលជាធរមាននៃអាករនេះ បើសិនជាការផ្គត់ផ្គង់ត្រូវបានធ្វើឡើងនៅចំ ឬនៅក្រោយកាលបរិច្ឆេទចូលជាធរមាននៃអាករ ។

២-  ចំពោះការផ្គត់ផ្គង់ជាប់អាករដូចមានចែងក្នុងកថាខ័ណ្ឌ១ នៃមាត្រានេះ ប្រាក់អាករលើតម្លៃបន្ថែមដែលបានកត់ត្រាក្រៅពីកិច្ចសន្យា ត្រូវចាត់ទុកជាសំណងបន្ថែមចំពោះមុខទំនិញ ឬសេវាដែលបានទិញ និងជាកាតព្វ-កិច្ចតាមផ្លូវច្បាប់របស់អ្នកទិញចំពោះ អ្នកលក់ ។

**មាត្រា ៨៤.-**

ឥណទានអាករចំពោះទំនិញស្តុកត្រូវបានកំណត់ដូចតទៅ :

១-  ចំពោះបុគ្គលទើបបានចុះបញ្ជី ហើយនៅថ្ងៃចុះបញ្ជីនោះ មានស្តុកទំនិញដែលបានបង់អាករលើតម្លៃបន្ថែមឬអាករលើផលរបររួចហើយ បុគ្គលនោះអាចដាក់ពាក្យសុំអោយរដ្ឋបាលសារពើពន្ធអនុញ្ញាតនូវឥណទានអាករចំពោះប្រាក់អាករដែលបានបង់លើស្តុកទាំងនោះ បន្ទាប់ពីរដ្ឋបាលសារពើពន្ធបានត្រួតពិនិត្យឃើញថា វិក័យប័ត្រ ឬច្បាប់ចម្លង នៃប្រតិវេទន៍គយរបស់ទំនិញទាំងនោះមានលក្ខណៈត្រឹមត្រូវ ។

២-  បើមានការឯកភាពចំពោះលក្ខណៈត្រឹមត្រូវនៃឯកសារទាំងនោះហើយ រដ្ឋបាលសារពើពន្ធអាចអនុញ្ញាតនូវឥណទានអាករ ចំពោះការផ្គត់ផ្គង់ដែលបានធ្វើក្នុងអំឡុង ៦០ថ្ងៃ មុនថ្ងៃចុះបញ្ជី ឬមុនថ្ងៃដែលច្បាប់នេះចូលជាធរមាន ។ ឥណទានអាករនេះអាចទៅប្រើក្នុងប្រកាសសារពើពន្ធទាំងឡាយសម្រាប់អាករនេះ ទៅតាមល័ក្ខខ័ណ្ឌដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ ។

# ជំពូកទី ៤
# វិសោធនកម្មលើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ឆ្នាំ ១៩៩៤
# និងលើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
## ផ្នែកទី ១
## បទប្បញ្ញត្តិស្តីពីការកែប្រែអាករពិសេសលើទំនិញមួយចំនួន
## មកជាអាករពិសេសលើទំនិញ និងសេវាមួយចំនួន

**មាត្រា ៨៥.-**

ចាប់ពីថ្ងៃប្រកាសអោយប្រើច្បាប់នេះ អាករពិសេសលើទំនិញមួយចំនួននៃច្បាប់ ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស/រកម/0៩៩៥/0១ ចុះថ្ងៃទី 0១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ត្រូវហៅថា "អាករពិសេសលើទំនិញ និងសេវាមួយចំនួន" វិញ ហើយមាត្រាមួយចំនួនត្រូវបានធ្វើវិសោធនកម្ម ដូចមានចែងក្នុងជំពូកនេះ ។

មាត្រា ១៨ នៃច្បាប់ដូចបានយោងខាងលើត្រូវបានកែប្រែដូចតទៅ :

- ៣0ភាគរយ សម្រាប់រថយន្តដែលមានបញ្ជាក់ក្នុងតារាងពន្ធគយ លេខសំគាល់ ៨៧.0៣ ដែលមានស៊ីឡាំងជ្រេធំជាង ២.000 CC ព្រមទាំងគ្រឿងបន្លាស់សំរាប់ប្រភេទរថយន្តទាំងនេះ
- ២0ភាគរយ សំរាប់ផលិតផលតេលសិលា និងរថយន្ត ដែលមានបញ្ជាក់ក្នុងតារាងពន្ធគយលេខសំគាល់ ៨៧.0៣ ដែលមានស៊ីឡាំងជ្រេពី ២.000 CC ចុះក្រោម ព្រមទាំងគ្រឿងបន្លាស់សំរាប់ប្រភេទរថយន្តទាំងនេះ
- ១0ភាគរយ សំរាប់ភេសជ្ជៈ បារីគ្រប់ប្រភេទ សណ្ឋាគារ និងសេវាលំហែកំសាន្តផ្សេងៗ ព្រមទាំងយានយន្តគ្រប់ប្រភេទ និងគ្រឿងបន្លាស់ ដែលមានបញ្ជាក់ក្នុងតារាងពន្ធគយ លេខសំគាល់ ៨៧-0២-៨៧0៤-២១ ដល់ ៨៧0៤.៩0 ៨៧0៦ ៨៧0៨ ៨៧១៤ និង ៨៧១១ ដែលមានស៊ីឡាំងជ្រេចាប់ពី ១២៥ CC ឡើងទៅ
- ២ភាគរយ សម្រាប់ថ្លៃលក់សំបុត្រក្នុងស្រុក លើការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសពីក្នុងព្រះរាជាណាចក្រកម្ពុជាទៅបរទេស សេវាទូរគមនាគមន៍ពីក្នុងព្រះរាជាណាចក្រកម្ពុជាទៅបរទេស ។

ពាក្យ "ថ្លៃលក់កត់ត្រាក្នុងវិក័យបត្រ " ក្នុងកថាខ័ណ្ឌ២ នៃមាត្រា ២១ នៃច្បាប់ដូចយោងខាងលើត្រូវបានកែប្រែជា "ថ្លៃលក់ចេញពីរោងចក្រកត់ត្រាក្នុងវិក័យបត្រ" ។

បន្ថែមកថាខ័ណ្ឌខាងក្រោមក្នុងមាត្រា ២១ នៃច្បាប់ដូចយោងខាងលើ :

"៣-សេវាផ្គត់ផ្គង់នៅព្រះរាជាណាចក្រកម្ពុជាគឺថ្លៃក្នុងវិក័យប័ត្រនៃសេវាដែលបានផ្គត់ផ្គង់" ។

ពាក្យ "ចំពោះទំនិញផលិត" ក្នុងកថាខ័ណ្ឌ២ ក្នុងមាត្រា ២២ នៃច្បាប់ដូចយោងខាងលើត្រូវបានកែប្រែជា "ចំពោះទំនិញផលិត និងសេវាផ្គត់ផ្គង់ " ។

បន្ថែមកថាខ័ណ្ឌខាងក្រោមក្នុងមាត្រា ២៣ នៃច្បាប់ដូចយោងខាងលើ :

"៣-អ្នកផ្គត់ផ្គង់ ចំពោះសេវាផ្គត់ផ្គង់នៅព្រះរាជាណាចក្រកម្ពុជា" ។

បន្ថែមកថាខ័ណ្ឌខាងក្រោមក្នុងមាត្រា ២៤ នៃច្បាប់ដូចយោងខាងលើ :

"៣-ចំពោះសេវាទូរគមនាគមន៍ និងដឹកជញ្ជូន នៅព្រះរាជាណាចក្រកម្ពុជា ត្រូវមានបញ្ជីដោយឡែកដែលមានចុះកាលបរិច្ឆេទ និងតម្លៃនៃសេវាដែលបានផ្គត់ផ្គង់ពីចំណុចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទៅចំណុចនៅក្រៅព្រះរាជាណាចក្រកម្ពុជា " ។

## ផ្នែកទី ២

## បទប្បញ្ញត្តិស្តីពីការកែប្រែអាករលើផលរបរ

### មាត្រា ៨៦.-

អាករលើផលរបរ ដែលមានចែងក្នុងច្បាប់ស្តីអំពីហិរញ្ញវត្ថុសម្រាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ត្រូវបានកែប្រែដូចតទៅ :

១- លុបកថាខ័ណ្ឌ ២ ក្នុងមាត្រា ៣៩ នៃច្បាប់ដូចយោងខាងលើ ។

២- ពាក្យ"តម្លៃក្រៅគយ" ក្នុងមាត្រា ៤៦ នៃច្បាប់ដូចយោងខាងលើ ត្រូវបានកែប្រែជា "តម្លៃមានពន្ធគយ និងអាករពិសេសលើទំនិញ និងសេវាមួយចំនួន" ។

៣- បន្ថែមកថាខ័ណ្ឌខាងក្រោម ក្នុងមាត្រា ៤៧ នៃច្បាប់ដូចយោងខាងលើ :

"នាយករដ្ឋានពន្ធដារអាចប្រមូលអាករលើការប្រើប្រាស់ និងអនុវត្តទោសទណ្ឌលើរាល់ទំនិញដែលដាក់លក់នៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលអ្នកលក់ពុំមានឯកសារបញ្ជាក់គ្រប់គ្រាន់ថា បានបង់អាករលើការប្រើប្រាស់នៅពេលនាំចូល " ។

៤-បន្ថែមកថាខ័ណ្ឌ ង ដូចខាងក្រោម ក្នុងមាត្រា ៤៩ នៃច្បាប់ដូចយោងខាងលើ :

"ង-ចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៧ តទៅ អ្នកជាប់ពន្ធទាំងអស់ត្រូវ :

- ប្រើវិធាននៃពេលផ្គត់ផ្គង់ ដូចមានចែងក្នុងមាត្រា ៦២ នៃច្បាប់នេះដែលចែងអំពីអារករលើតម្លៃបន្ថែម ដើម្បីកំណត់កាលបរិច្ឆេទដែលអាករត្រូវក្លាយជាបំណុលរបស់អ្នកជាប់ពន្ធចំពោះរដ្ឋ ។
- ចេញវិក័យបត្រស្របតាមវិធាន និងនីតិវិធីដូចមានចែងក្នុងមាត្រា ៦២ នៃច្បាប់នេះ ដែលចែងអំពីអាករលើតម្លៃបន្ថែម ។
- ចាត់ទុកថារាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ និងទទួលរងទោសទណ្ឌតាមមាត្រា ១៣៣ នៃច្បាប់នេះ ក្នុងករណីមិនប្រតិបត្តិតាមមាត្រា ៤៩ កថាខ័ណ្ឌ ង នេះ ។

៥- ក្នុងច្បាប់ស្តីពីការកែតម្រូវច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ត្រូវបន្ថែមមួយកថាខ័ណ្ឌក្នុងមាត្រា ៣៣ ថា :

ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៨ តទៅ :

- អ្នកជាប់ពន្ធតាមរបបពិតប្រាកដ មិនត្រូវជាប់អាករលើផលរបរទេ
- អ្នកជាប់ពន្ធតាមរបបផ្សេងទៀត ត្រូវជាប់អាករលើផលរបរតាមអត្រា ២ភាគរយ
- មាត្រា ៤៤ មាត្រា ៤៥ មាត្រា ៤៦ មាត្រា ៤៧ និងមាត្រា ៤៨ នៃច្បាប់ស្តីអំពីហិរញ្ញវត្ថុសម្រាប់ឆ្នាំ ១៩៩៤ និងមាត្រា ៣៧ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ត្រូវចាត់ទុកជានិរាករណ៍ ។

## ជំពូកទី ៥

## បទប្បញ្ញត្តិស្តីពីវិធាន និងនីតិវិធីសារពើពន្ធ

### មាត្រា ៨៧.-

ត្រូវបានបង្កើតបទប្បញ្ញត្តិទាំងឡាយនៃជំពូកនេះ នូវសិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ និងរបស់រដ្ឋបាលសារពើពន្ធ នីតិវិធីនៃការពិនិត្យឡើងវិញនូវប្រាក់ពន្ធបានបង់ នីតិវិធីដោះស្រាយវិវាទបទល្មើសនិងទោសទណ្ឌសារពើពន្ធ ។

បទប្បញ្ញត្តិទាំងឡាយនៃជំពូកនេះ ត្រូវអនុវត្តចំពោះពន្ធគ្រប់ប្រភេទ វៀរលែងតែពន្ធដោយឡែកណាមួយដែលមានចែងផ្សេង ។

### មាត្រា ៨៨.-

សម្រាប់គោលដៅនៃជំពូកនេះ :

១- ពាក្យ"ពន្ធ" មានន័យថា ពន្ធនិងអាករទាំងឡាយ ។

២- ពាក្យ "បុគ្គល" មានន័យថា រូបវន្តបុគ្គល ឬនីតិបុគ្គល ។

៣- ពាក្យ "អ្នកជាប់ពន្ធ" មានន័យថាជាបុគ្គលដែលមានកាតព្វកិច្ចត្រូវបង់ពន្ធ ។

៤- ពាក្យ"រដ្ឋបាលសារពើពន្ធ "មានន័យថាជាអង្គការចាត់តាំងនៃនាយកដ្ឋានពន្ធដារ ។

៥- ពាក្យ"លិខិតប្រកាសសារពើពន្ធ" មានន័យថាជាឯកសារដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានតម្រូវអោយអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក បំពេញទៅតាមល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងច្បាប់នេះ ។

៦- ពាក្យ"ភ្នាក់ងារកាត់ទុក" មានន័យថាជាបុគ្គលដែលបទប្បញ្ញត្តិស្តីពីពន្ធដារតម្រូវអោយធ្វើការកាត់ទុក និងបង់ប្រាក់ពន្ធចូលថវិកាក្នុងនាមនៃតតិយជន ។

៧- ពាក្យ "សកម្មភាពសេដ្ឋកិច្ច " មានន័យថាជាសកម្មភាពរបស់បុគ្គលដែលធ្វើជានិច្ចកាល ជាប់បន្ត ឬមួយដងមួយគ្រា ដើម្បីរក ឬមិនរកចំណេញ ក្នុងការផ្គត់ផ្គង់ ឬមានបំណងផ្គត់ផ្គង់ទំនិញ ឬសេវាអោយដល់បុគ្គលដទៃ ក្នុងគោលដៅដើម្បីបានអត្ថប្រយោជន៍អ្វីមួយ ។

### មាត្រា ៨៩.-

បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងអន្តរជាតិទាក់ទិននឹងបញ្ហាពន្ធ ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយ ត្រូវមានវិសាលភាពគ្របដណ្តប់លើបទប្បញ្ញត្តិនៃច្បាប់នេះ ។

### មាត្រា ៩០.-

លិខិតប្រកាសសារពើពន្ធទាំងអស់ ក៏ដូចជាឯកសារ និងលិខិតទាក់ទងផ្សេងៗ ដែលចាំបាច់សម្រាប់ការកំណត់ពន្ធ ការប្រមូលពន្ធ និងការបង្ខំឱ្យប្រតិបត្តិតាមច្បាប់ពន្ធ ឬដែលជាប់ទាក់ទងនឹងបែបបទផ្សេងទៀតក្នុងការកំណត់ពន្ធត្រូវធ្វើជាភាសាខ្មែរ ។

## ផ្នែកទី ២
## សិទ្ធិ និងកាតព្វកិច្ច

**មាត្រា ៩១.-**

សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ ត្រូវបានកំណត់ដូចតទៅ :

១- អ្នកជាប់ពន្ធមានសិទ្ធិដូចតទៅ :

ក- ត្រូវបានទុកជាការសម្ងាត់ ហើយត្រូវបានយកមកប្រើប្រាស់តែក្នុងគោលដៅដែលមានបញ្ជាក់នៅក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ នូវព័ត៌មាននានាទាក់ទិននឹងកិច្ចការអាជីវកម្មរបស់ខ្លួនដែលបានផ្តល់អោយរដ្ឋបាលសារពើពន្ធដូចមានចែងក្នុងមាត្រា ៩៤ នៃច្បាប់នេះ ។

ខ- ទទួលព័ត៌មានជាប្រចាំអំពីកិច្ចការដំណើរការនៃប្រព័ន្ធពន្ធដារ ហើយនិងនីតិវិធីនៃការកំណត់ពន្ធ ដូចមានចែងក្នុងមាត្រា ៩៦ និងមាត្រា ១១៨ នៃច្បាប់នេះ ។

គ- ទទួលព័ត៌មានអំពីសិទ្ធិរបស់ខ្លួនរួមទាំងសិទ្ធិក្នុងការប្តឹងតវ៉ា ដូចមានចែងក្នុងមាត្រា ១១៨ និងមាត្រា ១២២ នៃច្បាប់នេះ

ឃ- ប្តឹងតវ៉ាដូចមានចែងនៅក្នុងច្បាប់នេះ ចំពោះរាល់សេចក្តីសម្រេចរបស់រដ្ឋបាលសារពើពន្ធដូចមានចែងក្នុងមាត្រា ១១៨ និងមាត្រា ១២២ នៃច្បាប់នេះ

ង- បង់ពន្ធមិនអោយលើសពីបទប្បញ្ញត្តិ ស្តីពីពន្ធដារកំណត់ដូចមានចែងក្នុងមាត្រា ១០៧ នៃច្បាប់នេះ ។

២- អ្នកជាប់ពន្ធមានកាតព្វកិច្ចដូចទៅ :

ក- ចុះឈ្មោះក្នុងបញ្ជីរបស់រដ្ឋបាលសារពើពន្ធ ដូចមានចែងក្នុងមាត្រា ១០១ នៃច្បាប់នេះ

ខ- ដាក់លិខិតប្រកាសសារពើពន្ធ និងផ្តល់ព័ត៌មានតាមការតម្រូវនៃបទប្បញ្ញត្តិស្តីពីពន្ធដារដូចមានចែងក្នុងមាត្រា ៩៨ និងមាត្រា ១០៤ នៃច្បាប់នេះ

គ- បង់ពន្ធតាមកាលបរិច្ឆេទកំណត់ ដូចមានចែងនៅក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ

ឃ- កាន់កាប់ ថែរក្សា និងត្រូវបង្ហាញបញ្ជី លិខិតយុត្តិការ និងឯកសារផ្សេងៗដល់រដ្ឋបាលសារពើពន្ធ ដូចមានចែងនៅក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ និងមាត្រា ៩៨ នៃច្បាប់នេះ

ង- បង្ហាញខ្លួនចំពោះរដ្ឋបាលសារពើពន្ធតាមកាលបរិច្ឆេទដែលមានចុះនៅក្នុងលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ ដូចមានចែងក្នុងមាត្រា ៩៩ នៃច្បាប់នេះ ។

ច- បង់ប្រាក់ពន្ធ ប្រាក់បន្ថែម និងការប្រាក់ផ្សេងៗ ដែលរដ្ឋបាលសារពើពន្ធកំណត់ទៅតាមកាលបរិច្ឆេទ ដូចមានចែងនៅក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ឬដែលរដ្ឋបាលសារពើពន្ធបានជូនដំណឹងជាលាយលក្ខណ៍អក្សរ ដូច

មានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ និងមាត្រា ១០៧ មាត្រា ១៣០ មាត្រា ១៣១ និងមាត្រា ១៣២ នៃច្បាប់នេះ ។

**មាត្រា ៩២.-**

អំណាចរបស់រដ្ឋបាលសារពើពន្ធមានដូចខាងក្រោមនេះ :

១- កំណត់មូលដ្ឋានគិតពន្ធ លើអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ដូចមានចែងក្នុងមាត្រា ១១៦ និងមាត្រា ១១៧ នៃច្បាប់នេះ ។

២- តម្រូវអោយអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកបង្ហាញខ្លួន ដូចមានចែងក្នុងមាត្រា ៩៩ នៃច្បាប់នេះ ។

៣- កំណត់បញ្ជី ឯកសារចាំបាច់នានា និងលិខិតយុត្តិការ ដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវបានរក្សាទុក និងផ្តល់ជូនរដ្ឋបាលសារពើពន្ធ ដូចមានចែងក្នុងមាត្រា ៩៨ និងមាត្រា ១០០ នៃច្បាប់នេះ ។

៤- ទាមទារអោយអ្នកជាប់ពន្ធ ឬតតិយជនផ្តល់ព័ត៌មានទាក់ទិននឹងអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកដូចមានចែងក្នុងមាត្រា ៩៩ នៃច្បាប់នេះ ។

៥- ចូលលំនៅដ្ឋាន ឬគ្រឹះស្ថានអាជីវកម្មរបស់អ្នកជាប់ពន្ធ ភ្នាក់ងារកាត់ទុក ឬតតិយជន ដើម្បីទទួលបាននូវព័ត៌មានទាក់ទិននឹងអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ដូចមានចែងក្នុងមាត្រា ១០០ នៃច្បាប់នេះ ។

៦- ទទួលពីស្ថាប័នរដ្ឋទាំងឡាយនូវព័ត៌មានស្តីពី ឬដែលទាក់ទិននឹងអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ដូចមានចែងក្នុងមាត្រា ១១៦ នៃច្បាប់នេះ ។

៧- អនុវត្តវិធានការតឹងទារចំពោះអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកនៅពេលដែលបុគ្គលនោះមិនបានបង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗតាមការតម្រូវនៃច្បាប់នេះ ដូចមានចែងក្នុងមាត្រា ១០៩ ដល់មាត្រា ១១៥ នៃច្បាប់នេះ ។

៨- កំណត់ឡើងវិញនូវកិច្ចការជំនួញរវាងអ្នកជាប់ពន្ធទាំងឡាយដែលមានជាប់ទាក់ទង ដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ។

រដ្ឋបាលសារពើពន្ធមានកាតព្វកិច្ចដូចតទៅ :

១- ប្រមូលប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗ ដូចមានចែងក្នុងមាត្រា ៩៣ នៃច្បាប់នេះ ។

២- រក្សាការសម្ងាត់នូវព័ត៌មាន ដែលអ្នកជាប់ពន្ធ ឬតតិយជនបានផ្តល់ឱ្យ ហើយផ្តល់ព័ត៌មានទាំងនេះឱ្យដល់តែបុគ្គលណាដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានកំណត់ប៉ុណ្ណោះ ដូចមានចែងក្នុងមាត្រា ៩៤ មាត្រា ១២៨ និងមាត្រា ១៣៨ នៃច្បាប់នេះ ។

៣- ផ្តល់ព័ត៌មានដល់អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក សំដៅធានាអោយការអនុវត្តបានសមស្របទៅតាមបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចមានចែងក្នុងមាត្រា ៩៦ នៃច្បាប់នេះ ។

៤- បង្វិលសងវិញ ឬចាត់ជាឥណទានពន្ធ នូវប្រាក់ពន្ធដែលបង់លើស ដូចដែលមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ។

៥- ផ្តល់លិខិតជូនដំណឹងស្តីពីការកំណត់ពន្ធអោយអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ដូចមានចែងនៅក្នុងមាត្រា ១១៦ ដល់មាត្រា ១១៨ នៃច្បាប់នេះ ។

## ផ្នែកទី ៣
## រដ្ឋបាលសារពើពន្ធ

### មាត្រា ៩៣.-

ស្ថាប័នទាំងឡាយដែលទទួលខុសត្រូវគ្រប់គ្រងការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារមានដូចខាងក្រោម :

- នាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ស្ថាប័នដទៃទៀតរបស់រាជរដ្ឋាភិបាលដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានផ្តល់អំណាចអោយ ។

រដ្ឋបាលសារពើពន្ធមានកាតព្វកិច្ចប្រមូលពន្ធ អនុវត្តទោសទណ្ឌតាមការកំណត់នៃបទប្បញ្ញត្តិស្តីពីពន្ធដារ និងការប្តឹងទៅតុលាការ ក្នុងករណីមានការរំលោភច្បាប់ ។

### មាត្រា ៩៤.-

រដ្ឋបាលសារពើពន្ធ ហើយនិងបុគ្គលគ្រប់រូបដែលជា ឬធ្លាប់ជាមន្ត្រី និងភ្នាក់ងារនៃរដ្ឋបាលសារពើពន្ធត្រូវរក្សាសម្ងាត់នូវព័ត៌មានទាក់ទននឹងអ្នកជាប់ពន្ធ ដែលបានទទួលនៅក្នុងពេលបំពេញភារកិច្ចជាផ្លូវការហើយ អាចផ្តល់ព័ត៌មានអោយទៅតែបុគ្គលដែលមាត្រានេះបានអនុញ្ញាតប៉ុណ្ណោះ ។

មន្ត្រី និងភ្នាក់ងារនៃរដ្ឋបាលសារពើពន្ធអាចផ្តល់ព័ត៌មានទាក់ទិននឹងអ្នកជាប់ពន្ធអោយចំពោះតែ :

១- មន្ត្រី និងភ្នាក់ងារផ្សេងទៀតរបស់រដ្ឋបាលសារពើពន្ធ នៅក្នុងពេល និងក្នុងគោលដៅបំពេញភារកិច្ចតាមបទប្បញ្ញត្តិស្តីពីពន្ធដារ ។

២- អាជ្ញាធរព្រហ្មទណ្ឌ សម្រាប់គោលដៅប្តឹងចោទប្រកាន់អំពីបទល្មើសពន្ធដារ ។

៣- តុលាការ នៅក្នុងដំណាក់ការជំរះក្តី ដើម្បីកំណត់ពន្ធត្រូវបង់របស់អ្នកជាប់ពន្ធ ឬក៏ការទទួលខុសត្រូវចំពោះការរំលោភបទប្បញ្ញត្តិស្តីពីពន្ធដារ ។

៤- អាជ្ញាធរពន្ធដាររបស់ប្រទេសណាមួយទៀត ស្របតាមកិច្ចព្រមព្រៀងអន្តរជាតិ ។ បុគ្គលដែលបានទទួលព័ត៌មានពីបុគ្គលម្នាក់ទៀតដែលបានការអនុញ្ញាតអោយផ្តល់ព័ត៌មាន ដូចមានចែងក្នុងកថាខណ្ឌ ២ នៃមាត្រានេះត្រូវរក្សាសម្ងាត់លើព័ត៌មាននោះទៅតាមការកំណត់ នៃមាត្រានេះ លើកលែងតែក៏រិតអប្បបរមាណាមួយដែលចាំបាច់ត្រូវអនុញ្ញាតអោយផ្តល់ព័ត៌មាននេះ ។

ព័ត៌មានទាក់ទិននឹងអ្នកជាប់ពន្ធអាចផ្តល់ទៅអោយបុគ្គលម្នាក់ទៀតបាន បើសិនមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអ្នកជាប់ពន្ធ ។

### មាត្រា ៩៥.-

លិខិតស្នាម ឬការជូនដំណឹងដែលរដ្ឋបាលសារពើពន្ធផ្តល់ឱ្យទៅអ្នកជាប់ពន្ធមានលក្ខណៈជាការដាក់អោយអ្នកជាប់ពន្ធនោះមានកាតព្វកិច្ច ចំពោះរដ្ឋបាលសារពើពន្ធ លុះណាតែលិខិតស្នាម ឬការជូនដំណឹងនោះត្រូវបានធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវបានប្រគល់អោយដល់អ្នកជាប់ពន្ធ ។

ក្នុងករណីដែលបទប្បញ្ញត្តិស្តីពីពន្ធដារ តម្រូវអោយរដ្ឋបាលសារពើពន្ធផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរទៅឱ្យបុគ្គល លិខិតជូនដំណឹងនោះត្រូវបានចាត់ទុកថា បានប្រគល់យ៉ាងត្រឹមត្រូវ លុះណាតែលិខិតនោះត្រូវបានប្រគល់អោយដោយផ្ទាល់ដល់បុគ្គលនោះ ឬក៏បានផ្ញើតាមប្រៃសណីយ៍ជាលិខិតអនុសិដ្ឋ ទៅអាស័យដ្ឋានតាមផ្លូវច្បាប់របស់បុគ្គលនោះ ។

កាលបរិច្ឆេទនៃការជូនដំណឹង ឬឯកសារផ្សេងៗ គឺជាកាលបរិច្ឆេទនៃការប្រគល់អោយដល់ដៃបុគ្គល ។ ក្នុងករណីលិខិតជូនដំណឹងត្រូវបានផ្ញើតាមលិខិតអនុសិដ្ឋ កាលបរិច្ឆេទនៃការជូនដំណឹង គឺជាកាលបរិច្ឆេទនៃការបោះត្រាលើលិខិតអនុសិដ្ឋរបស់ការិយាល័យប្រៃសណីយ៍ ដែលលិខិតអនុសិដ្ឋនោះត្រូវបានទទួលដោយអ្នកជាប់ពន្ធ ។

លិខិតជូនដំណឹងត្រូវចាត់ទុកថា បានប្រគល់ទទួលត្រឹមត្រូវ កាលបើលក្ខខណ្ឌក្នុងកថាខណ្ឌ២ នៃមាត្រានេះ ត្រូវបានបំពេញរួចហើយ ទោះបីជាបុគ្គលដែលត្រូវបានជូនដំណឹងនោះបដិសេធប្រគល់ដោយផ្ទាល់ ឬដោយលិខិតអនុសិដ្ឋក្តី ។

ក្នុងករណីដែលអាស័យដ្ឋានរបស់បុគ្គលត្រូវបានផ្លាស់ប្តូរ ហើយបុគ្គលមិនបានជូនដំណឹង ដល់រដ្ឋបាលសារពើពន្ធអំពីការផ្លាស់ប្តូរនោះទេ លិខិតជូនដំណឹងដែលបានបញ្ជូនទៅអាស័យដ្ឋានដែលបានស្គាល់ចុងក្រោយបង្អស់ ត្រូវចាត់ទុកថាបានប្រគល់ទទួលត្រឹមត្រូវ ។

**មាត្រា ៩៦.-**

រដ្ឋបាលសារពើពន្ធត្រូវរៀបចំសៀវភៅពន្យល់ខ្លីៗ ស្តីពីខ្លឹមសារសំខាន់ៗនៃប្រភេទពន្ធនីមួយៗ ។

ចំពោះប្រភេទពន្ធណាមួយដែលរដ្ឋបាលសារពើពន្ធកំណត់ថា គួរចុះធ្វើការពន្យល់ណែនាំនោះ មន្ត្រីពន្ធដារនៅតាមមូលដ្ឋាន ត្រូវចុះអប់រំដល់អ្នកជាប់ពន្ធអោយបានយល់អំពីកាតព្វកិច្ច និងសិទ្ធិរបស់អ្នកជាប់ពន្ធទាំងនោះ ។

**មាត្រា ៩៧.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវកសាងប្រព័ន្ធលើកទឹកចិត្តមួយសម្រាប់មន្ត្រី ភ្នាក់ងាររដ្ឋបាលសារពើពន្ធ ។ នីតិវិធីសម្រាប់ដំណើរការប្រព័ន្ធលើកទឹកចិត្តនេះត្រូវកំណត់ដោយប្រកាស ។

**មាត្រា ៩៨.-**

អ្នកជាប់ពន្ធត្រូវកាន់កាប់ កត់ត្រានិងរក្សាទុកបញ្ជី លិខិតយុត្តិការ និងឯកសារហិរញ្ញវត្ថុផ្សេងៗ ដូចដែលបទប្បញ្ញត្តិស្តីពីពន្ធដារកំណត់ និងត្រូវដាក់បញ្ជី និងឯកសារទាំងនោះ តាមការតម្រូវជូនរដ្ឋបាលសារពើពន្ធដើម្បីពិនិត្យ ។

ចំពោះអ្នកជាប់ពន្ធដែលពុំមានកាតព្វកិច្ចកាន់កាប់បញ្ជីគណនេយ្យតាមប្លង់គណនេយ្យទូទៅនៃព្រះរាជាណាចក្រ - កម្ពុជា ត្រូវកាន់ទិនានុប្បវត្តិដោយកត់ត្រាចុះតាមលំដាប់ថ្ងៃ ខែ នូវចំណូល និងចំណាយផ្សេងៗទាំងអស់ដែលទាក់ទិន និងអាជីវកម្មទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់ ។

បុគ្គលដែលត្រូវកាន់កាប់ កត់ត្រា ឬរក្សាទុកបញ្ជី ឯកសារនានា ឬទិនានុប្បវត្តិ ដែលបានកំណត់ដោយបទប្បញ្ញត្តិស្តីពីពន្ធដារ ឬបទប្បញ្ញត្តិដទៃ ត្រូវរក្សាទុកបញ្ជី ឬឯកសារទាំងនោះក្នុងរយៈពេល ១០ឆ្នាំ គិតពីដំណាច់ឆ្នាំជាប់ពន្ធ ។

វិក័យប័ត្រត្រូវតែចេញអោយលើរាល់កិច្ចការជំនួញរវាងអ្នកជាប់ពន្ធ និងបុគ្គលដទៃទៀត ។ វិធាន និងខ្លឹមសារនៃវិក័យប័ត្រ ត្រូវកំណត់ដោយអនុក្រឹត្យ ។

អ្នកជាប់ពន្ធត្រូវកត់ត្រាសេចក្តីរាយលំអិត នៃវិក័យប័ត្រអោយបានត្រឹមត្រូវចូលក្នុងទិនានុប្បវត្តិ ។

**មាត្រា ៩៩.-**

ក្នុងគោលដៅកំណត់ប្រាក់ពន្ធត្រូវបង់របស់បុគ្គលណាម្នាក់ ឬដើម្បីប្រមូលពន្ធរដ្ឋបាលសារពើពន្ធអាចធ្វើលិខិតជូនដំណឹងដល់អ្នកជាប់ពន្ធ ឬតតិយជនអោយ :

- ផ្តល់ព័ត៌មានដែលទាក់ទិននឹងអ្នកជាប់ពន្ធដូចមានចែងក្នុងលិខិតជូនដំណឹង ដូចជាព័ត៌មានស្តីពីអ្នកផ្គត់ផ្គង់អតិថិជន ឬគណនីនៅធនាគារ ។
- បង្ហាញខ្លួនទៅតាមពេលវេលា និងទីកន្លែងដែលមានបញ្ជាក់នៅក្នុងលិខិតជូនដំណឹងដើម្បីផ្តល់ព័ត៌មាន និង និងដើម្បីបង្ហាញ ឬផ្តល់ឯកសារ ឬទិន្នន័យដែលបុគ្គលនោះគ្រប់គ្រង ដែលមានបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងលិខិតជូនដំណឹង ។

បន្ថែមលើព័ត៌មានដែលបានតម្រូវដូចមានចែងក្នុងកថាខ័ណ្ឌ១ នៃមាត្រានេះ លិខិតជូនដំណឹងត្រូវមានចុះឈ្មោះ និងលេខអត្តសញ្ញាណកម្មនៃបុគ្គលអ្នកជាប់ពន្ធ (បើសិនជាមាន) ហើយនិងហត្ថលេខារបស់រដ្ឋបាលសារពើពន្ធដែលចេញលិខិតជូនដំណឹង ។

**មាត្រា ១០០.-**

ចំពោះមុខ សម្រាប់ការស៊ើបអង្កេតនីមួយៗដោយមានលិខិតបញ្ជាបេសកម្ម រដ្ឋបាលសារពើពន្ធមានសិទ្ធិចូលទៅក្នុងគ្រឹះស្ថានអាជីវកម្ម ទីកន្លែងដែលបានចាត់ទុកថាជាគ្រឹះស្ថានអាជីវកម្ម ជាកន្លែងដែលបើកសាធារណៈ ឬទីកន្លែងដទៃទៀត ដើម្បីធ្វើការកំណត់ប្រាក់ពន្ធត្រូវបង់របស់បុគ្គលណាម្នាក់ ឬដើម្បីប្រមូលពន្ធ :

- នៅក្នុងពេលម៉ោងអាជីវកម្ម
- នៅគ្រប់ពេលទាំងអស់ស្របតាមលក្ខខណ្ឌ និងហេតុផលដែលមានបញ្ជាក់នៅក្នុងដីកាដែលចៅក្រមបានចេញឱ្យ ។

រដ្ឋបាលសារពើពន្ធដែលបានចូលដោយស្របច្បាប់ទៅក្នុងទីកន្លែង ដូចដែលមានចែងក្នុងកថាខ័ណ្ឌ១ នៃមាត្រានេះ អាច :

- ធ្វើសម្រង់ ឬចម្លងឯកសារនានាដែលស្ថិតនៅក្នុងកន្លែងនោះ
- រឹបអូស ឯកសារនានា ឬវត្ថុតាងដទៃទៀត ដែលអាចក្លាយជាព័ត៌មានសម្រាប់កំណត់ប្រាក់ពន្ធត្រូវបង់របស់បុគ្គលណាម្នាក់
- ដាក់ឧបករណ៍សម្រាប់ត្រួតពិនិត្យផ្សេងៗ ឬបោះត្រាបិទសំគាល់ឃាត់ទុកទំនិញ បើសិនជាមានជាប់ទាក់ទងដល់ការអនុវត្តពន្ធណាមួយ
- ធ្វើសារពើភ័ណ្ឌទ្រព្យសកម្ម វត្ថុធាតុដើម ផលិតផលកំពុងផលិត ផលិតផលសម្រេច និងស្តុកដទៃទៀត

- រដ្ឋបាលសារពើពន្ធអាចតម្រូវអោយស្ថាប័នធនាគារដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ផ្តល់ព័ត៌មានអំពីគណនីរបស់អ្នកជាប់ពន្ធនៅធនាគារ ។

ពេលចូលទៅធ្វើការស៊ើបអង្កេត រដ្ឋបាលសារពើពន្ធត្រូវមានអាកប្បកិរិយាសមរម្យ ចៀសវាងប្រការដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងអាជីវកម្មរបស់អ្នកជាប់ពន្ធ ។ ទោះជាយ៉ាងណាក៏ដោយ ការស៊ើបអង្កេតដល់ទីកន្លែងនេះ ពុំត្រូវអនុវត្តអោយហួសកំរិតនៃការចាំបាច់ឡើយ ។

**មាត្រា ១០១.-**

បុគ្គលទាំងឡាយត្រូវទៅចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងកំឡុង ១៥ថ្ងៃ ក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ។

បុគ្គលទាំងឡាយត្រូវជូនដំណឹងទៅរដ្ឋបាលសារពើពន្ធក្នុងរយៈពេល ១៥ថ្ងៃ ក្រោយពីការផ្លាស់ប្តូរអាស័យដ្ឋាន ទ្រង់ទ្រាយ នាមករណ៍ កម្មវត្ថុអាជីវកម្ម ការផ្ទេរ ការបញ្ឈប់អាជីវកម្ម សមាសភាពអ្នកគ្រប់គ្រង ឬអ្នកទទួលបន្ទុកកិច្ចការពន្ធដាររបស់សហគ្រាស ។

**មាត្រា ១០២.-**

នៅពេលបានអនុវត្តការចុះបញ្ជីរួចរាល់ហើយ រដ្ឋបាលសារពើពន្ធត្រូវចេញនូវលិខិតបញ្ជាក់ការចុះបញ្ជីមួយ ដែលមានចុះលេខអត្តសញ្ញាណកម្មសារពើពន្ធរបស់បុគ្គល ។ លេខអត្តសញ្ញាណកម្មនេះ ត្រូវយកទៅប្រើលើគ្រប់ឯកសារទាក់-ទិននឹងពន្ធដារ ។

គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវតែប្រើលេខអត្តសញ្ញាណកម្មក្នុងមាត្រានេះ ។ រាល់កិច្ចសន្យាជាមួយស្ថាប័នរដ្ឋ ត្រូវតែមានចុះលេខអត្តសញ្ញាណកម្មសារពើពន្ធទើបទុកជាបានការ ។

**មាត្រា ១០៣.-**

រដ្ឋបាលសារពើពន្ធមានសិទ្ធិចុះបញ្ជី ចំពោះបុគ្គលទាំងឡាយដែលច្បាប់បានកំណត់អោយចុះបញ្ជី ហើយពុំបានមកចុះបញ្ជី ក្នុងករណីនេះរដ្ឋបាលសារពើពន្ធអាចកំណត់កាលបរិច្ឆេទមានប្រសិទ្ធភាពនៃការចុះបញ្ជី ។

## ផ្នែកទី ៤

## ប្រកាសសារពើពន្ធ

**មាត្រា ១០៤.-**

អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ត្រូវដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ ពេលវេលា និងទីកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់ ។

លិខិតប្រកាសសារពើពន្ធត្រូវ ចុះហត្ថលេខាដោយអ្នកជាប់ពន្ធ ឬតំណាងស្របច្បាប់របស់អ្នកជាប់ពន្ធ ។

**មាត្រា ១០៥.-**

បុគ្គលណាមួយដែលបានបើកប្រាក់អោយទៅបុគ្គលផ្សេងទៀត ត្រូវដាក់ជូនរដ្ឋបាលសារពើពន្ធនូវលិខិតប្រកាសព័ត៌មានស្តីពីការបើកប្រាក់នោះ ទៅតាមបែបបទដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ ។

**មាត្រា ១០៦.-**

បុគ្គលដែលជាតំណាងអ្នកជាប់ពន្ធត្រូវមានសិទ្ធិជំនួសមុខអោយអ្នកជាប់ពន្ធ ដើម្បី :

- ដាក់លិខិតប្រកាសសារពើពន្ធ
- បង្ហាញរបាយការណ៍ ឬលិខិតស្នាមផ្សេងៗ
- បង់ពន្ធអាករទាំងឡាយដែលកំណត់ដោយបទប្បញ្ញត្តិស្តីពីពន្ធដារ
- ធ្វើបណ្តឹងតវ៉ា និងបណ្តឹងឧទ្ធរណ៍
- បំពេញរាល់កាតព្វកិច្ចដែលអ្នកជាប់ពន្ធត្រូវទទួលខុសត្រូវចំពោះមុខបទប្បញ្ញត្តិស្តីពីពន្ធដារ ។

អ្នកជាប់ពន្ធអាចធ្វើការផ្ទេរសិទ្ធិ ជាលាយល័ក្ខណ៍អក្សរទៅអោយបុគ្គលម្នាក់ទៀត អោយធ្វើសកម្មភាពជំនួសមុខខ្លួនក្នុងបញ្ហាពន្ធដារ ដោយមានសិទ្ធិ និងកាតព្វកិច្ចដូចមានចែងនៅក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ ។ អ្នកជាប់ពន្ធដារអាចកំនត់ព្រំដែនសិទ្ធិអំណាចនៃការផ្ទេរសិទ្ធិនេះ ។

រដ្ឋបាលសារពើពន្ធអាចតំរូវអោយបុគ្គលដែលធ្វើសកម្មភាពក្នុងនាមអ្នកជាប់ពន្ធលើមូលដ្ឋាននៃការផ្ទេរសិទ្ធិដាក់ជូនពិនិត្យនូវភស្តុតាងជាលាយល័ក្ខណ៍អក្សរនៃការផ្ទេរសិទ្ធិនោះ ។

អ្នកជាប់ពន្ធត្រូវមានកាតព្វកិច្ចទទួលខុសត្រូវដោយផ្ទាល់ចំពោះរាល់សកម្មភាពរបស់បុគ្គលដែលជាតំណាងតាមផ្លូវច្បាប់របស់ខ្លួន ឬបុគ្គលដែលបានទទួលការផ្ទេរសិទ្ធិពីខ្លួន រហូតដល់ពេលណាដែលរដ្ឋបាលសារពើពន្ធបានទទួលសេចក្តីបញ្ជាក់ជាលាយល័ក្ខណ៍អក្សរពីអ្នកជាប់ពន្ធស្តីអំពីការលុបចោលនូវការផ្ទេរសិទ្ធិនោះ ។

បុគ្គលដែលជាតំណាងរបស់អ្នកជាប់ពន្ធត្រូវចុះបញ្ជីនូវទំនាក់ទំនងរបស់ខ្លួននៅរដ្ឋបាលសារពើពន្ធ ក្នុងកំឡុងពេល ១៥ថ្ងៃ ក្រោយពេលដែលទំនាក់ទំនងនោះបានកើតឡើង ។

## ផ្នែកទី ៥

## ការប្រមូលពន្ធ

**មាត្រា ១០៧.-**

ការបង់ពន្ធត្រូវបានកំណត់ដូចទៅ :

១- ប្រាក់ពន្ធត្រូវដល់កំណត់និងត្រូវបង់ នៅក្នុងរយៈពេលដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានតំរូវអោយធ្វើការដាក់លិខិតប្រកាសសារពើពន្ធ ។

២- បំណុលសារពើពន្ធ ត្រូវដល់កំណត់នឹងត្រូវបង់ ក្នុងរយៈពេល ៣០ថ្ងៃក្រោយពីការប្រគល់លិខិតជូនដំណឹងទារបំណុលពន្ធ ។

៣- ប្រាក់ពន្ធត្រូវដល់កំណត់និងត្រូវបង់ ក្នុងរយៈពេល ៣ថ្ងៃ ក្រោយពីការប្រគល់លិខិតជូនដំណឹងទារបំណុលពន្ធដូចមានចែងក្នុងកថាខណ្ឌ ៤ មាត្រា ១១៦ នៃច្បាប់នេះ ។

៤- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងកំណត់ដោយប្រកាសនូវវិធាន និង នីតិវិធីដើម្បី :

ក- កំណត់កាលបរិច្ឆេទទារបំណុលពន្ធ ដើម្បីចៀសវាងការខាតបង់ ដោយទារបំណុលពន្ធមិនបាន

ខ- ចាត់ទុកបំណុលពន្ធដារជាប្រាក់ពន្ធដែលមិនអាចប្រមូលបាន ។

**មាត្រា ១០៨.-**

ប្រសិនបើអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិកររបស់សហគ្រាសណាមួយដឹងឮ ឬមានចេតនាធ្វើអោយសហគ្រាសមិនរាយការណ៍ ឬរាយការណ៍បន្ថយនូវប្រាក់ពន្ធ ដោយរំលោភទៅលើបទប្បញ្ញត្តិស្តីពីពន្ធដារ ឬមិនអោយបង់ពន្ធកាត់ទុកជូនរដ្ឋបាលសារពើពន្ធអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករនោះ ត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះប្រាក់ពន្ធដែលត្រូវបង់ ។

# ផ្នែកទី ៦
# អំណាចរបស់រដ្ឋបាលសារពើពន្ធក្នុងការប្រមូលប្រាក់ពន្ធ

**មាត្រា ១០៩.-**

ប្រសិនបើបុគ្គលដែលមានកាតព្វកិច្ចបង់ពន្ធ តាមការតំរូវនៃបទប្បញ្ញត្តិស្តីពីពន្ធដារឆ្វេសប្រហែស ឬបដិសេធមិនព្រមបង់ពន្ធក្រោយពេលដែលលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធ ត្រូវបានប្រគល់ត្រឹមត្រូវ រដ្ឋបាលសារពើពន្ធត្រូវមានសិទ្ធិឃុំគ្រងលើទ្រព្យសម្បត្តិបុគ្គលនោះសមស្របនឹងបំណុលពន្ធ ។

សិទ្ធិឃុំគ្រងលើទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធកើតមានឡើងនៅថ្ងៃដែលលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធត្រូវបានប្រគល់ទៅអោយអ្នកជាប់ពន្ធ ដូចមានចែងក្នុងមាត្រា ៩៥ នៃច្បាប់នេះ ។

បើល័ក្ខខ័ណ្ឌទាំងឡាយនៃមាត្រានេះ ត្រូវបានបំពេញត្រឹមត្រូវហើយនោះ សិទ្ធិឃុំគ្រងលើទ្រព្យសម្បត្តិដូចមានចែងក្នុងកថាខ័ណ្ឌ ១ មានសុពលភាព និងអាទិភាពលើសិទ្ធិដទៃទៀតទាំងអស់ ដែលមានពីមុនមក ឬដែលកើតឡើងក្រោយសិទ្ធិឃុំគ្រងលើទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ ។

បុគ្គលទាំងឡាយអាចធ្វើការតវ៉ាទៅរដ្ឋបាលសារពើពន្ធ ដើម្បីសុំអោយលើកសិទ្ធិឃុំគ្រងលើទ្រព្យសម្បត្តិរបស់ខ្លួនដូចមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រានេះ ដោយលើកឡើងនូវកំហុសឆ្គងក្នុងការដាក់សិទ្ធិនោះ ។

ប្រសិនបើរដ្ឋបាលសារពើពន្ធបានពិនិត្យឃើញថា ការដាក់សិទ្ធិឃុំគ្រងលើទ្រព្យសម្បត្តិនោះមានការខុសឆ្គង រដ្ឋបាលសារពើពន្ធត្រូវចេញលិខិតបញ្ជាក់អំពីការលើកសិទ្ធិឃុំគ្រងលើទ្រព្យសម្បត្តិក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីពិនិត្យឃើញព្រមទាំងចុះក្នុងលិខិតបញ្ជាក់នោះថា ការដាក់សិទ្ធិឃុំគ្រងនេះមានការខុសឆ្គង ។

**មាត្រា ១១០.-**

រដ្ឋបាលសារពើពន្ធត្រូវធ្វើលិខិត ជូនដំណឹងរំលឹកការទារបំណុលពន្ធទៅអ្នកជាប់ពន្ធយ៉ាងតិច ១៥ថ្ងៃ មុនអនុវត្តវិធានការតឹងទារ ។

**មាត្រា ១១១.-**

ការរឹបអូសទ្រព្យសម្បត្តិអ្នកជាប់ពន្ធ ត្រូវបានកំណត់ដូចតទៅ :

១- ប្រសិនបើអ្នកជាប់ពន្ធមិនបានបង់បំណុលពន្ធក្នុងរយៈពេល ១៥ថ្ងៃ ក្រោយពីបានទទួលលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធ រដ្ឋបាលសារពើពន្ធអាចរឹបអូសទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ ដើម្បីធានាបំណុលពន្ធព្រមទាំងសោហ៊ុយចំណាយក្នុងការប្រមូលពន្ធនោះ ។ សំរាប់គោលដៅនៃច្បាប់នេះ ពាក្យ "ការរឹបអូស" សំដៅដល់ការរឹបអូសតាមគ្រប់មធ្យោបាយ និងការលក់ទ្រព្យសម្បត្តិអ្នកជាប់ពន្ធដោយរដ្ឋបាលសារពើពន្ធ តែមិនត្រូវរឹបអូសទ្រព្យសម្បត្តិអោយហួស ពីបំណុលពន្ធ និងចំណាយក្នុងការប្រមូលពន្ធឡើយ ។

២- បុគ្គលដែលមានភារៈកាន់កាប់ និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ ដែលត្រូវរដ្ឋបាលសារពើពន្ធរឹប-អូស ដូចក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ មិនអាចបង្វិលទ្រព្យសម្បត្តិនោះទៅអោយអ្នកជាប់ពន្ធវិញ ឬក៏យក

ទ្រព្យសម្បត្តិនោះ ទៅធ្វើការទូទាត់ផ្សេងៗបានទេ លើកលែងតែការទូទាត់ដែលរដ្ឋបាលសារពើពន្ធបានអនុ-ញ្ញាត ។

៣- រដ្ឋបាលសារពើពន្ធអាចអនុវត្តការរឹបអូសទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ ដែលកាន់កាប់ និងគ្រប់គ្រងដោយបុគ្គលដទៃទៀត យ៉ាងតិច ១៥ថ្ងៃ ក្រោយពេលជូនដំណឹងដល់អ្នកកាន់កាប់ និងគ្រប់គ្រងទ្រព្យសម្បត្តិនោះ ។

៤- បុគ្គលអ្នកកាន់កាប់និងគ្រប់គ្រងលើទ្រព្យសម្បត្តិដែលត្រូវរឹបអូសត្រូវប្រគល់ទ្រព្យសម្បត្តិនោះ ឬក៏បង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម ការប្រាក់ និងសោហ៊ុយចំណាយក្នុងការប្រមូលពន្ធជូនរដ្ឋបាលសារពើពន្ធ លើកលែងតែចំណែកទ្រព្យសម្បត្តិណាមួយដែលស្ថិតនៅក្នុងដំណើរការជំរះបញ្ជីរំលាយសកម្មភាពអាជីវកម្ម ។

៥- បុគ្គលដែលមិនបានប្រគល់ទ្រព្យសម្បត្តិដូចមានចែងក្នុងកថាខ័ណ្ឌ ៤ នៃមាត្រានេះ ត្រូវទទួលខុសត្រូវលើចំនួនទឹកប្រាក់នៃតំលៃទ្រព្យសម្បត្តិនោះ ប៉ុន្តែមិនលើសពីចំនួនទឹកប្រាក់ដែលជាកម្មវត្ថុនៃការរឹបអូសនោះទេ។

៦- បុគ្គលណាដែលមិនបានប្រតិបត្តិតាមការតំរូវក្នុងកថាខ័ណ្ឌ ២ និងកថាខ័ណ្ឌ ៤ នៃមាត្រានេះ ត្រូវបានរួចផុតអំពីការទទួលខុសត្រូវចំពោះអ្នកជាប់ពន្ធ ឬតតិយជន លើទ្រព្យសម្បត្តិ ប្រាក់ពន្ធ ឬកាតព្វកិច្ចផ្សេងទៀតដែលបានប្រគល់ជូនទៅរដ្ឋបាលសារពើពន្ធ ។

៧- ប្រសិនបើរដ្ឋបាលសារពើពន្ធមានមូលដ្ឋានត្រឹមត្រូវជឿជាក់ថា ការប្រមូលពន្ធអាចមានឧបសគ្គរដ្ឋបាលសារ-ពើពន្ធអាចទាមទារអោយអ្នកជាប់ពន្ធបង់ពន្ធភ្លាម ហើយបើអ្នកជាប់ពន្ធមិនបានបំពេញតាមការទាមទារនេះទេ អាចរឹបអូសទ្រព្យសម្បត្តិអ្នកជាប់ពន្ធភ្លាម ។

៨- ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ដូចមានកំណត់ក្នុងអនុក្រឹត្យ ត្រូវបានរួចផុតពីការរឹបអូស ។

៩- ការលក់ទ្រព្យសម្បត្តិរឹបអូសត្រូវធ្វើឡើងតាមការដាក់អោយដេញថ្លៃ ។ សោហ៊ុយចំណាយផ្សេងៗ ក្នុងការលក់ទ្រព្យសម្បត្តិ គឺជាបន្ទុករបស់អ្នកជាប់ពន្ធ ។

**មាត្រា ១១២.-**

ទ្រព្យសម្បត្តិដែលត្រូវរឹបអូសដោយច្បាប់នេះ ត្រូវរឹបអូស កាន់កាប់ និងទទួលខុសត្រូវដោយរដ្ឋបាលសារពើពន្ធតែប៉ុណ្ណោះ ។ ស្ថាប័នផ្សេងៗរបស់រាជរដ្ឋាភិបាលមិនអាចប្រើច្បាប់នេះដើម្បីរឹបអូស ឬកាន់កាប់ទ្រព្យសម្បត្តិនោះដោយផ្ទាល់ឡើយ ។ បើមានការលក់នូវទ្រព្យសម្បត្តិដែលបានរឹបអូសដោយច្បាប់នេះ ចំណែកណាមួយនៃប្រាក់លក់បានដែលលើសអំពីបំណុលពន្ធរបស់អ្នកជាប់ពន្ធនៅក្រោមច្បាប់នេះ ត្រូវបង្វិលទៅអោយម្ចាស់កម្មសិទ្ធិទ្រព្យសម្បត្តិនោះវិញ ។

**មាត្រា ១១៣.-**

ការរឹបអូសក្នុងមាត្រា ១១១ នៃច្បាប់នេះ អាចមានទាំងការឃាត់ទុកគណនីរបស់អ្នកជាប់ពន្ធនៅធនាគារ តាមលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ ហើយដែលមានប្រសិទ្ធភាពអនុវត្តភ្លាមក្រោយពីប្រគល់លិខិតនោះទៅអោយធនាគារ ។

តាមរយៈការជូនដំណឹងអោយឃាត់ទុកគណនីធនាគារនេះ ធនាគារមិនអាចបើកគណនីថ្មីទៀតអោយអ្នកជាប់ពន្ធដដែលបានទេ ហើយក៏មិនអាចធ្វើការទូទាត់ផ្សេងៗ ចេញពីគណនីនោះបានឡើយ លើកលែងតែការបង់ប្រាក់ដែលរដ្ឋបាលសារពើពន្ធកំណត់អោយ ដើម្បីទូទាត់ប្រាក់ពន្ធត្រូវបង់ ការប្រាក់ ហើយនិងពន្ធបន្ថែមផ្សេងទៀត ។

គណនីធនាគារដែលបានឃាត់ទុកអាចបើកអោយប្រើវិញបាន លុះត្រាតែមានលិខិតជូនដំណឹងពីរដ្ឋបាលសារពើពន្ធ។

ធនាគារដែលមិនបានអនុវត្តតាមលិខិតជូនដំណឹងក្នុងកថាខ័ណ្ឌ១ នៃមាត្រានេះ ត្រូវទទួលខុសត្រូវចំពោះរដ្ឋបាលសារពើពន្ធនូវកំរិតទឹកប្រាក់ដែលមាននៅក្នុងគណនីរបស់អ្នកជាប់ពន្ធនៅពេលដែលលិខិតជូនដំណឹងត្រូវបានប្រគល់ឱ្យ ។

**មាត្រា ១១៤.-**

ការរឹបអូស នៅក្នុងមាត្រា ១១១ នៃច្បាប់នេះ អាចរួមបញ្ចូលផងដែរនូវការបញ្ឈប់ប្រតិបត្តិការនាំចេញ-នាំចូល ។ ការបញ្ឈប់ប្រតិបត្តិការនាំចេញ-នាំចូល សំដៅដល់ការឃាត់ទុកដោយរដ្ឋបាលគយនូវទំនិញនាំចូលបញ្ជានអោយអ្នកជាប់ពន្ធ និងទំនិញដែលត្រូវនាំចេញដោយអ្នកជាប់ពន្ធ តាមលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ ដែលមានប្រសិទ្ធភាពអនុវត្តភ្លាម ក្រោយពេលដែលលិខិតនោះបានប្រគល់អោយរដ្ឋបាលគយ ។

រដ្ឋបាលសារពើពន្ធអាចរឹបអូស និងលក់ទំនិញរបស់អ្នកជាប់ពន្ធដែលបានឃាត់ទុកដោយរដ្ឋបាលគយទៅតាមលក្ខ-ខណ្ឌដែលមានចែងនៅក្នុងមាត្រា ១១១ នៃច្បាប់នេះ ។

ការអនុញ្ញាតអោយប្រតិបត្តិការ នាំចេញ-នាំចូល រួចពីការបញ្ឈប់ត្រូវអនុវត្តតាមលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ ។

ទំនិញឃាត់ទុកដោយរដ្ឋបាលគយ ដែលមិនមែនជារបស់អ្នកជាប់ពន្ធ ត្រូវបានរួចផុតពីការឃាត់ទុកដោយមានការយល់ព្រមពីរដ្ឋបាលសារពើពន្ធ ។

**មាត្រា ១១៥.-**

ការរឹបអូសក្នុងមាត្រា ១១១ នៃច្បាប់នេះ អាចមានទាំងការចេញលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ ទៅកាន់អាជ្ញាធរមានសមត្ថកិច្ចស្នើសុំអោយទុកជាមោឃៈនូវលិខិតអនុញ្ញាត និងអាជ្ញាប័ណ្ណផ្សេងៗរបស់អ្នកជាប់ពន្ធ ដើម្បីអនុវត្តសកម្មភាពណាមួយ ។

## ផ្នែកទី ៧

## ការកំណត់ពន្ធ

**មាត្រា ១១៦.-**

ចំនួនប្រាក់ពន្ធត្រូវបានកំណត់ដូចតទៅ :

១- ក្នុងករណីដែលប្រាក់ពន្ធរបស់អ្នកជាប់ពន្ធត្រូវបានបង់តាមវិធីកាត់ទុក ហើយអ្នកជាប់ពន្ធគ្មានកាតព្វកិច្ចធ្វើប្រកាសសារពើពន្ធទេនោះ ការកំណត់ពន្ធរបស់អ្នកជាប់ពន្ធ គឺជាការកំណត់ចំនួនប្រាក់ពន្ធដែលបានកាត់ទុកនៅក្នុងឆ្នាំប្រតិទិន ។

២-ក្នុងករណីដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកមានកាតព្វកិច្ចត្រូវដាក់លិខិតប្រកាសសារពើពន្ធការកំណត់ពន្ធរបស់អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក គឺជាការកំណត់ពន្ធដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកបានគណនានៅលើលិខិតប្រកាសសារពើពន្ធ ដែលដាក់ជូនរដ្ឋបាលសារពើពន្ធ ។

៣- ក្នុងករណីដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកមានកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធ ប៉ុន្តែមិនបានធ្វើលិខិតប្រកាស មិនបានរក្សាទុកអោយបានត្រឹមត្រូវនូវបញ្ជីកាគណនេយ្យ ឬឯកសារផ្សេងទៀតតាមការតំរូវ ឬមិនបានផ្តល់ព័ត៌មានចាំបាច់ជូនរដ្ឋបាលសារពើពន្ធ ដើម្បីកំណត់ពន្ធអោយបានត្រឹមត្រូវ ការកំណត់ពន្ធរបស់អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក គឺជាការកំណត់ពន្ធជាឯកតោភាគីដែលរដ្ឋបាលសារពើពន្ធបានធ្វើ និងបានប្រគល់អោយបុគ្គលនោះ ។ ការកំណត់ពន្ធជាឯកតោភាគីត្រូវផ្អែកលើ :

ក- ព័ត៌មានដែលមានចុះនៅក្នុងលិខិតប្រកាសសារពើពន្ធនានា ឬឯកសារផ្សេងទៀត ដែលអ្នកជាប់ពន្ធបានដាក់ជូនរដ្ឋបាលសារពើពន្ធ

ខ- ព័ត៌មានដែលមានចុះក្នុងលិខិតប្រកាសព័ត៌មាន

គ- ព័ត៌មានផ្សេងទៀត ដែលរដ្ឋបាលសារពើពន្ធបានទទួល ។

៤- បើសិនជាមានមូលដ្ឋានបញ្ជាក់ថា ការប្រមូលពន្ធអាចមានឧបសគ្គរដ្ឋបាលសារពើពន្ធអាចធ្វើការកំណត់ពន្ធលើអ្នកជាប់ពន្ធ នៅពេលណាមួយក៏បាន ។

**មាត្រា ១១៧.-**

ការកំណត់ពន្ធឡើងវិញ និងរយៈពេលកំណត់ពន្ធឡើងវិញ ត្រូវដំណើរការដូចតទៅ :

១- ចំពោះការកំណត់ពន្ធដែលផ្អែកតាមកថាខ័ណ្ឌ១ នៃមាត្រា ១១៦ នៃច្បាប់នេះរដ្ឋបាលសារពើពន្ធអាចធ្វើការកំណត់ពន្ធឡើងវិញក្នុងរយៈពេល ៣ឆ្នាំ បន្ទាប់ពីឆ្នាំប្រតិទិនដែល ការកាត់ទុកបានកើតឡើង ។

២- ចំពោះការកំណត់ពន្ធដែលផ្អែកតាមកថាខ័ណ្ឌ២ និងកថាខ័ណ្ឌ ៣ នៃមាត្រា ១១៦ នៃច្បាប់នេះ រដ្ឋបាលសារពើពន្ធអាចធ្វើការកំណត់ពន្ធឡើងវិញ ក្នុងរយៈពេលណាមួយខាងក្រោមនេះ :

ក- ក្នុងរយៈពេល ៣ឆ្នាំ ក្រោយថ្ងៃដាក់លិខិតប្រកាសសារពើពន្ធ

ខ- ក្នុងរយៈពេល ១០ឆ្នាំ ក្រោយកាលបរិច្ឆេទដែលតំរូវអោយដាក់លិខិតប្រកាសសារពើពន្ធ ប្រសិនបើមានភស្តុតាងបញ្ជាក់ថាមានអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ។

គ- ក្នុងរយៈពេលណាមួយក៏បានតាមការយល់ព្រមជាលាយល័ក្ខណ៍អក្សររបស់អ្នកជាប់ពន្ធ ។

៣- អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក អាចស្នើសុំធ្វើការកែតំរូវលិខិតប្រកាសសារពើពន្ធក្នុងរយៈពេល ៣ឆ្នាំក្រោយកាលបរិច្ឆេទនៃការដាក់លិខិតប្រកាសសារពើពន្ធតាមកថាខ័ណ្ឌ ២ នៃមាត្រា ១១៦ នៃច្បាប់នេះ ដោយផ្អែកលើមូលដ្ឋាននៃការភ័ន្តច្រឡំ ឬការភ្លាំងភ្លាត់ដែលអ្នកជាប់ពន្ធបានធ្វើនៅក្នុងលិខិតប្រកាសពីមុន ។ ប្រសិនបើលទ្ធផលប្រកាសសារពើពន្ធកែតំរូវនោះ បណ្តាលអោយមានការបង្វិលសងប្រាក់ពន្ធ ឬឥណទានពន្ធរដ្ឋបាលសារពើពន្ធអាចធ្វើការពិនិត្យបញ្ជាក់តាមនីតិវិធីត្រួតពិនិត្យសារពើពន្ធ ។

៤- អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក អាចស្នើសុំអោយរដ្ឋបាលសារពើពន្ធធ្វើការកែតំរូវការកំណត់ពន្ធឡើងវិញ ក្នុងរយៈពេល ៣ឆ្នាំ ក្រោយកាលបរិច្ឆេទដែលរដ្ឋបាលសារពើពន្ធកំណត់ពន្ធឡើងវិញ ដោយផ្អែកលើព័ត៌មានបន្ថែមដែលអ្នកជាប់ពន្ធ ឬរដ្ឋបាលសារពើពន្ធមិនបានទទួលក្នុងពេលកំណត់ពន្ធឡើងវិញនោះ ។

៥- ក្នុងករណីដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកធ្វើការកែតំរូវការកំណត់ពន្ធរបស់ខ្លួន ឬស្នើសុំឱ្យរដ្ឋបាលសារពើពន្ធកែតំរូវការកំណត់ពន្ធឡើងវិញ អាជ្ញាយុកាលនៃការកំណត់ពន្ធឡើងវិញក្នុងកថាខ័ណ្ឌ ១ និងកថាខ័ណ្ឌ ២ នៃមាត្រានេះត្រូវចាប់ផ្តើមគិតពីកាលបរិច្ឆេទនៃការដាក់លិខិត ប្រកាសសារពើពន្ធកែតំរូវ ឬកាលបរិច្ឆេទដែលរដ្ឋបាលសារពើពន្ធធ្វើការកែតំរូវកំណត់ពន្ធឡើងវិញ ។

**មាត្រា ១១៨.-**

ការកំណត់ពន្ធឡើងវិញ ត្រូវបានដំណើរការតាមនីតិវិធីដូចតទៅ :

១- រដ្ឋបាលសារពើពន្ធត្រូវជូនលិខិតជូនដំណឹង ស្តីពីការកំណត់ពន្ធឡើងវិញ ដល់អ្នកជាប់ពន្ធ ។

២- អ្នកជាប់ពន្ធមានរយៈពេល ៣០ថ្ងៃ ដើម្បីឆ្លើយតបចំពោះការកំណត់ពន្ធឡើងវិញទៅការិយាល័យរបស់នាយកដ្ឋានពន្ធដារ ដែលទទួលបន្ទុកធ្វើការកំណត់ពន្ធឡើងវិញនោះ ។ ក្នុងរយៈពេលនេះអ្នកជាប់ពន្ធអាចទទួលយក ឬជំទាស់ចំពោះការកំណត់ពន្ធឡើងវិញ ។ អ្នកជាប់ពន្ធត្រូវចាត់ទុកថា យល់ព្រមចំពោះការកំណត់ពន្ធឡើងវិញ បើសិនជាពុំបានឆ្លើយតប ។

៣- បើសិនជាមានការជំទាស់ចំពោះការកំណត់ពន្ធឡើងវិញ អ្នកជាប់ពន្ធត្រូវដាក់ពាក្យតវ៉ាទៅប្រធានយកដ្ឋានពន្ធដារតាមនីតិវិធីដែលមានចែងក្នុងមាត្រា ១២០ នៃច្បាប់នេះ ។

៤- ការិយាល័យទទួលបន្ទុកការកំណត់ពន្ធឡើងវិញ របស់នាយកដ្ឋានពន្ធដារ ត្រូវបញ្ជូនលទ្ធផលនៃការកំណត់ពន្ធឡើងវិញទៅការិយាល័យប្រមូលពន្ធក្នុងរយៈពេល ៣០ថ្ងៃ ក្រោយការចេញលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញ ។

**មាត្រា ១១៩.-**

នៅពេលដែលអ្នកជាប់ពន្ធមិនបានរក្សាទុកឯកសារគ្រប់គ្រាន់ ឬក៏មិនបានផ្តល់ព័ត៌មានគ្រប់គ្រាន់ រដ្ឋបាលសារពើពន្ធមានសិទ្ធិកំណត់ពន្ធលើអ្នកជាប់ពន្ធដោយផ្អែកលើមូលដ្ឋាន នៃព័ត៌មានជាក់លាក់ដែលរដ្ឋបាលសារពើពន្ធមាន ។ បន្ទុកភស្តុតាងដើម្បីបញ្ជាក់ថា ប្រាក់ពន្ធដែលរដ្ឋបាលសារពើពន្ធកំណត់មិនត្រឹមត្រូវ គឺស្ថិតនៅលើអ្នកជាប់ពន្ធ ។

នៅពេលណាដែលប្រាក់ចំណូលជាប់ពន្ធ ឬប្រាក់ចំណូលដែលបានប្រកាសដោយអ្នកជាប់ពន្ធមានភាពខុសគ្នាច្រើនធៀបទៅនឹងការទិញទ្រព្យសកម្ម ឬវត្ថុនានា ដែលធ្វើអោយឃើញចំណាយរបស់អ្នកជាប់ពន្ធលេចធ្លោឡើងនោះ រដ្ឋបាលសារពើពន្ធមានសិទ្ធិកំណត់ដោយផ្អែកលើមូលដ្ឋាននៃប្រាក់ចំណូលប៉ាន់ស្មាន សមស្របទៅនឹងទំហំនៃចំណាយដើម្បីទិញទ្រព្យ សកម្មភាព ឬវត្ថុនានាដែលលេចធ្លោនោះ ។ បន្ទុកភស្តុតាងដើម្បីបញ្ជាក់ថា ប្រាក់ពន្ធដែលរដ្ឋបាលសារពើពន្ធកំណត់មិនត្រឹមត្រូវ គឺស្ថិតនៅលើអ្នកជាប់ពន្ធ ។

## ផ្នែកទី ៨
## ដំណោះស្រាយការតវ៉ារបស់អ្នកជាប់ពន្ធ

### មាត្រា ១២០.-

វិធាននៃដំណោះស្រាយការតវ៉ារបស់អ្នកជាប់ពន្ធអំពីបញ្ហាសារពើពន្ធត្រូវបានកំណត់ដូចតទៅ :

១- អ្នកជាប់ពន្ធដែលមិនពេញចិត្តនឹងការកំណត់ឡើងវិញ ឬសេចក្តីសំរេចផ្សេងទៀត ដែលធ្វើឡើងដោយរដ្ឋបាលសារពើពន្ធ អាចធ្វើការតវ៉ាទៅប្រធាននាយកដ្ឋានពន្ធដារ ។ ការតវ៉ាត្រូវមានកំរិតព្រំដែនតែត្រឹមដើមហេតុ ឬព័ត៌មានផ្សេងទៀត ដែលមាននៅក្នុងការកំណត់ពន្ធ ឡើងវិញ សេចក្តីសំរេច ឬនីតិវិធីនៃការកំណត់ឡើងវិញតែប៉ុណ្ណោះ ។

២- ការតវ៉ាខាងរដ្ឋបាលត្រូវធ្វើជាលាយល័ក្ខណ៍អក្សរទៅតាមទំរង់ ដែលមានចែងនៅក្នុងមាត្រា ១២១ នៃច្បាប់នេះ និងត្រូវដាក់ជូនរដ្ឋបាលសារពើពន្ធក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃដែលអ្នកជាប់ពន្ធបានទទួលលិខិតជូនដំណឹងទារបំណុលពន្ធរបស់រដ្ឋបាលសារពើពន្ធ ។

៣- ការតវ៉ាខាងរដ្ឋបាលពុំធ្វើអោយអ្នកជាប់ពន្ធ រួចផុតពីកាតព្វកិច្ចបង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗ ដែលបញ្ជាក់នៅក្នុងលិខិតជូនដំណឹងទារបំណុលពន្ធឡើយ ។

### មាត្រា ១២១.-

ការតវ៉ាខាងរដ្ឋបាលអាចនឹងទទួលយកបាន បើសិនជាក្នុងពាក្យតវ៉ានោះមានខ្លឹមសារដូចខាងក្រោម :

១- លេខអត្តសញ្ញាណកម្មរបស់អ្នកជាប់ពន្ធដែលធ្វើពាក្យតវ៉ា បើសិនជាមាន ។

២- សេចក្តីយោងទៅរកការកំណត់សេចក្តីសំរេច ឬលទ្ធផល ដែលជាកម្មវត្ថុនៃពាក្យតវ៉ា ។

៣- ដើមហេតុ ឬអំពើដែលជាកម្មវត្ថុនៃពាក្យតវ៉ា ។

៤- ហេតុផលនៃការតវ៉ា ។

៥- កាលបរិច្ឆេទ និងហត្ថលេខារបស់អ្នកជាប់ពន្ធ និងហត្ថលេខារបស់តំណាងមានការអនុញ្ញាតរបស់អ្នកជាប់ពន្ធ បើសិនមានភាពចាំបាច់ ។

### មាត្រា ១២២.-

រដ្ឋបាលសារពើពន្ធត្រូវចេញសេចក្តីសំរេចជាថ្មីក្នុងរយៈពេល ៦០ថ្ងៃ ក្រោយពីថ្ងៃបានទទួលពាក្យតវ៉ាដើម្បីបញ្ជាក់ភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវទាំងស្រុង ឬចំណែក ណាមួយនៃការកំណត់ពន្ធ ឬសេចក្តីសំរេចផ្សេងៗដែលអ្នកជាប់ពន្ធតវ៉ា ។ រដ្ឋបាលសារពើពន្ធត្រូវបញ្ជាក់ផងដែរនូវមូលដ្ឋាននៃការសំរេចនេះ ។

ប្រសិនបើអ្នកជាប់ពន្ធមិនយល់ព្រមលើសេចក្តីសំរេចថ្មីនេះ របស់រដ្ឋបាលសារពើពន្ធទេ នោះអ្នកជាប់ពន្ធអាចដាក់ពាក្យតវ៉ាទៅគណៈកម្មាធិការសំរុះសំរួលសារពើពន្ធក្នុងរយៈពេលយ៉ាងយូរ ៣០ថ្ងៃ ។

**មាត្រា ១២៣.-**

ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការសំរុះសំរួលសារពើពន្ធ ត្រូវកំណត់ដោយអនុក្រឹត្យតាមសេចក្តីស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១២៤.-**

អ្នកជាប់ពន្ធមានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ចជំទាស់នឹងសេចក្តីសំរេចរបស់គណៈកម្មាធិការសំរុះសំរួលសារពើពន្ធក្នុងរយៈពេល ៣០ថ្ងៃ ក្រោយពីបានទទួលដំណឹងស្តីពីសេចក្តីសំរេចនោះ ។

អ្នកជាប់ពន្ធត្រូវតំកល់ទុកនៅរតនាគារជាតិនូវប្រាក់ចំនួនស្មើនឹងប្រាក់ពន្ធប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗ ដែលទាក់ទិននឹងវិវាទតាមការកំណត់របស់រដ្ឋបាលសារពើពន្ធ មុននឹងដាក់ពាក្យបណ្តឹងទៅតុលាការ ។

## ផ្នែកទី ៩

## បទល្មើសបទប្បញ្ញត្តិស្តីពីពន្ធដារ

**មាត្រា ១២៥.-**

អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ត្រូវបានចាត់ទុកថាមានការធ្វេសប្រហែស បើសិនជាប្រាក់ពន្ធដែលបានបង់មានចំនួនតិចជាងប្រាក់ពន្ធដែលបានកំណត់ដោយបទប្បញ្ញត្តិ ស្តីពីពន្ធដារមិនលើសពី ១០ភាគរយ ។

អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវបានចាត់ទុកថាមានការធ្វេសប្រហែសបើសិនជាមិនបានដាក់លិខិតប្រកាសសារពើពន្ធ ឬមិនបានបង់ពន្ធតាមកាលបរិច្ឆេទដែលច្បាប់បានកំណត់ ។

**មាត្រា ១២៦.-**

អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ត្រូវបានចាត់ទុកថា មានការធ្វេសប្រហែសធ្ងន់ធ្ងរ បើសិនជាប្រាក់ពន្ធដែលបានបង់មានចំនួនតិចជាងប្រាក់ពន្ធដែលបានកំណត់ដោយបទប្បញ្ញត្តិស្តីពីពន្ធដារលើសពី ១០ ភាគរយ ។

**មាត្រា ១២៧.-**

ការគេចវេសពន្ធ គឺជាបទល្មើសដោយចេតនា ដោយដឹងជាមុនមានការរៀបចំទុក និងច្រើនដងទៅលើបទប្បញ្ញត្តិស្តីពីពន្ធដារ ក្នុងបំណងបន្ថយ ឬបំបាត់ប្រាក់ពន្ធដែលបទប្បញ្ញត្តិស្តីពីពន្ធដារតំរូវអោយបង់ ។

ត្រូវបានចាត់ទុកថាជាការគេចវេសពន្ធផងដែរ ក្នុងករណីដែលការធ្វេសប្រហែសធ្ងន់ធ្ងរដូចមានចែងក្នុងមាត្រា១២៦ នៃច្បាប់នេះ បានប្រព្រឹត្តឡើង :

១- ពីរលើកដាច់ពីគ្នា ក្នុងរយៈពេល៣ឆ្នាំ នៃឆ្នាំប្រតិទិន ។

២- បីលើក ឬច្រើនជាងនេះដាច់ពីគ្នា ក្នុងរយៈពេលណាមួយក៏ដោយ ។

**មាត្រា ១២៨.-**

អំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ រួមមាន :

១- ករណីដែលបុគ្គល :

ក- មិនបានរក្សាបញ្ជិកាគណនេយ្យ និងឯកសារផ្សេងទៀត ឬមិនបានចេញវិក័យបត្រលើកិច្ចការជំនួញ ។

ខ- មិនអនុញ្ញាតអោយរដ្ឋបាលសារពើពន្ធធ្វើការពិនិត្យបញ្ជិកាគណនេយ្យ ឬឯកសារផ្សេងៗ

គ- មិនបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ

ឃ- មិនបានជូនដំណឹងទៅរដ្ឋបាលសារពើពន្ធ អំពីការផ្លាស់ប្តូរការចុះបញ្ជីដូចមានចែងក្នុងច្បាប់នេះ

ង- កសាង ឬផ្តល់នូវកំណត់ត្រា ឯកសារ របាយការណ៍ ឬព័តិមានក្លែងបន្លំផ្សេងៗ

ច- លាក់ទុក ឬបំផ្លាញចោលដោយចេតនានូវបញ្ជិកាគណនេយ្យ កំណត់ត្រាឯកសារ របាយការណ៍ ឬព័តិមានផ្សេងៗទៀត

ឆ- ព្យាយាមធ្វើអោយរាំងស្ទះដល់ការកំណត់ និងការប្រមូលពន្ធ

ជ- មិនបានដាក់លិខិតប្រកាសសារពើពន្ធដែលគ្មានប្រាក់ពន្ធត្រូវបង់ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយកាលបរិច្ឆេទដែលច្បាប់បានកំណត់

ឈ- ជួយជ្រោមជ្រែងដោយចេតនា ដល់អំពើទាំងឡាយខាងលើ ។

២- ករណីដែលមន្ត្រីរាជការ :

ក- ធ្វើអោយធ្លាយព័តិមានសម្ងាត់ដោយគ្មានការអនុញ្ញាត

ខ- ព្យាយាមធ្វើអោយរាំងស្ទះដល់ការកំណត់ និងការប្រមូលពន្ធ

គ- ជួយជ្រោមជ្រែងដោយចេតនា ដល់អំពើទាំងឡាយខាងលើ ។

**មាត្រា ១២៩.-**

ក្រៅពីទោសទណ្ឌផ្នែករដ្ឋបាលផ្សេងទៀត បុគ្គលណាមួយបានធ្វើសកម្មភាពគេចវេសពន្ធដូចមានចែងក្នុងមាត្រា ១២៧ នៃច្បាប់នេះ ឬធ្វើការរាំងស្ទះដល់ការគ្រប់គ្រងប្រព័ន្ធសារពើពន្ធដូចមានចែងក្នុងមាត្រា ១២៨ នៃច្បាប់នេះ ត្រូវចាត់ទុកថាបានប្រព្រឹត្តបទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ។

## ផ្នែកទី ១០

## ពន្ធបន្ថែម

**មាត្រា ១៣០.-**

ពន្ធបន្ថែមត្រូវអនុវត្តចំពោះបទល្មើសបទប្បញ្ញត្តិស្តីពីពន្ធដារ ។

ពន្ធបន្ថែមសំរាប់ការបង់ពន្ធខ្វះ ឬការបង់ពន្ធយឺត ត្រូវគណនាដាច់ដោយឡែកពីពន្ធបន្ថែមសម្រាប់ការរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ។

ក្នុងករណីមានការបង់ពន្ធខ្វះ ពន្ធបន្ថែម និងការប្រាក់ ត្រូវដល់កំណត់ និងត្រូវបង់តាមបែបបទដូចប្រាក់ពន្ធដែលបានបង់ខ្វះនោះ ។

ទោះជាក្នុងករណីណាក៏ដោយ ការដាក់អោយអនុវត្តពន្ធបន្ថែម មិនមានផលប៉ះពាល់ដល់ការអនុវត្តទោសទណ្ឌចំពោះបទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិ ស្តីពីពន្ធដារឡើយ ។

**មាត្រា ១៣១.-**

ចំពោះបុគ្គលណាដែលមានការធ្វេសប្រហែស ប្រាក់ពន្ធបន្ថែមត្រូវស្មើនឹង ១០ភាគរយ នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់ ២ភាគរយ នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសំរាប់ខែនីមួយៗ ឬចំណែក នៃខែដែលចំនួនប្រាក់ពន្ធខ្វះមិនទាន់បានបង់ ។

ចំពោះបុគ្គលដែលមានការធ្វេសប្រហែសធ្ងន់ធ្ងរ ប្រាក់ពន្ធបន្ថែមត្រូវស្មើនឹង ២៥ភាគរយ នៃចំនួនប្រាក់ដែលបង់ខ្វះ បូកបន្ថែមការប្រាក់ ២ភាគរយ នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលប្រាក់ពន្ធខ្វះមិនទាន់បានបង់ ។

ក្នុងករណីការកំណត់ពន្ធជាឯកតោភាគី ប្រាក់ពន្ធបន្ថែមត្រូវស្មើ ៤០ភាគរយ នៃចំនួនប្រាក់ដែលបង់ខ្វះបូកបន្ថែមការប្រាក់ ២ភាគរយនៃចំនួនប្រាក់ពន្ធដែល បង់ខ្វះសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលប្រាក់ពន្ធខ្វះមិនទាន់បានបង់ ។

ការប្រាក់មិនត្រូវអនុវត្តទេ ក្នុងរយៈពេលកំណត់ពន្ធឡើងវិញតាមមាត្រា ១១៨ នៃច្បាប់នេះ ឬក្នុងរយៈពេល ៣០ ថ្ងៃក្រោយការប្រគល់លិខិតជូនដំណឹងទារបំណុលពន្ធ ។

**មាត្រា ១៣២.-**

ចំពោះបុគ្គលដែលមិនបានបង់ពន្ធតាមកាលកំណត់ ពន្ធបន្ថែមត្រូវកំណត់តាមអត្រា ១០ភាគរយ នៃទឹកប្រាក់ពន្ធបង់យឺត បូកនឹងការប្រាក់ ២ភាគរយ នៃទឹកប្រាក់ពន្ធបង់យឺតសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលចំនួនប្រាក់ពន្ធនោះនៅមិនទាន់បានបង់ ។

បើសិនជាបុគ្គលមិនបានបង់ពន្ធរយៈពេល ១៥ថ្ងៃ ក្រោយពេលបានទទួលលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធ ពន្ធបន្ថែមត្រូវកំណត់តាមអត្រា ២៥ភាគរយ នៃទឹកប្រាក់ពន្ធបង់យឺត បូកនឹងការប្រាក់ ២ភាគរយ នៃទឹកប្រាក់ពន្ធបង់យឺតសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលចំនួនប្រាក់ពន្ធនោះនៅមិនទាន់បានបង់ ។

ក្នុងករណីការកំណត់ពន្ធជាឯកតោភាគី សម្រាប់ការមិនដាក់លិខិតប្រកាសប្រាក់ពន្ធបន្ថែមត្រូវស្មើ ៤០ភាគរយ នៃចំនួនប្រាក់ពន្ធដែលបានកំណត់ បូកបន្ថែមការប្រាក់ ២ភាគរយ នៃចំនួនប្រាក់ពន្ធដែលបានកំណត់សម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលប្រាក់ពន្ធមិនទាន់បានបង់ ។

ការប្រាក់យឺតយ៉ាវត្រូវគិតចាប់ពីថ្ងៃទី ០១ នៃខែបន្ទាប់ពីខែដែលត្រូវបង់ពន្ធ ។ ចំពោះពន្ធលើប្រាក់ចំណេញ ការប្រាក់យឺតយ៉ាវត្រូវគិតចាប់ពីថ្ងៃទី ០១ នៃខែបន្ទាប់ដែលជាខែផុតរយៈពេលកំណត់សម្រាប់ការដាក់លិខិតប្រកាសលទ្ធផលប្រចាំឆ្នាំ ។

ពន្ធបន្ថែមចំពោះការយឺតយ៉ាវក្នុងការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូនត្រូវស្មើនឹង ១០០ភាគរយ នៃប្រាក់ពន្ធត្រូវបង់ ។

**មាត្រា ១៣៣.-**

ចំពោះការប្រព្រឹត្តអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិ ស្តីពីពន្ធដារ ពន្ធបន្ថែមត្រូវកំណត់ដូចខាងក្រោមនេះ សម្រាប់អំពើនីមួយៗ :

១- ២.000.000 រៀល (ពីរលានរៀល) ចំពោះបុគ្គល អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកក្រោមរបបពិត ឬមន្ត្រីរាជការ ។

២- ៥00.000 រៀល (ប្រាំសែនរៀល) ចំពោះអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកក្រោមរបបបំព្រួញ ឬរបបម៉ៅការ ។

## ផ្នែកទី ១១
## អំពីបទល្មើសព្រហ្មទណ្ឌ

**មាត្រា ១៣៤.-**

លើកលែងតែចំពោះបទល្មើសមានចែងនៅក្នុងមាត្រា ១៣៩ និងមាត្រា ១៤0 នៃច្បាប់នេះ ការប្តឹងចោទប្រកាន់ និងទាមទារការដាក់ទោសចំពោះបទល្មើសព្រហ្មទណ្ឌ លើបទប្បញ្ញត្តិស្តីពីពន្ធដារ ត្រូវធ្វើឡើងដោយប្រធាននាយកដ្ឋានពន្ធដារ ដោយមានការយល់ព្រមពីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៣៥.-**

ដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀត អភិបាល បណ្ណាធិការ កម្មសិទ្ធិកររបស់សហគ្រាសណាមួយ ឬបុគ្គលទទួលខុសត្រូវអោយសហគ្រាសណាមួយដែលបានប្រព្រឹត្តអំពើគេចវេសពន្ធ ដូចមានចែងក្នុងមាត្រា ១២៧ នៃច្បាប់នេះ ត្រូវរងការផ្តន្ទាទោសពិន័យជាប្រាក់ពី ១0.000.000រៀល (ដប់លានរៀល) ដល់ ២0.000.000រៀល (ម្ភៃលានរៀល) ឬជាប់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ ឬទោសទាំងពីរនេះ ។

**មាត្រា ១៣៦.-**

ដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀត បុគ្គលណាដែលបានប្រព្រឹត្ត អំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចមានចែងក្នុងមាត្រា ១២៨ នៃច្បាប់នេះត្រូវរងការផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.000.000 រៀល (ប្រាំលានរៀល) ដល់ ១0.000.000រៀល (ដប់លានរៀល) ឬជាប់ពន្ធនាគារពី ១ខែ ដល់ ១ឆ្នាំ ឬទោសទាំងពីរនេះ ។

**មាត្រា ១៣៧.-**

បុគ្គលណាដែលមានចេតនាជួយជ្រោមជ្រែង ឬអូសទាញបុគ្គលម្នាក់ទៀតអោយប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌចំពោះច្បាប់នេះ ឬក៏ដោយចេតនបានផ្តល់គំនិត ឬជំរុញបុគ្គលម្នាក់ទៀតអោយប្រព្រឹត្តិបទល្មើសបែបនេះត្រូវជាប់ពិរុទ្ធ ហើយត្រូវទទួលរងការផ្តន្ទាទោសដូចគ្នានឹងការប្រព្រឹត្តបទល្មើសផ្ទាល់ខ្លួនផងដែរ ។

**មាត្រា ១៣៨.-**

ដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀត បុគ្គលណាដែលបានបំពានមាត្រា ៩៤ នៃច្បាប់នេះ ត្រូវជាប់ពិរុទ្ធអំពើល្មើសនឹងច្បាប់ ហើយត្រូវទទួលរងការផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០រៀល (ប្រាំលានរៀល) ដល់ ១០.០០០.០០០រៀល (ដប់លានរៀល)ឬជាប់ពន្ធនាគារពី ១ខែ ដល់ ១ឆ្នាំ ឬទោសទាំងពីរនេះ ។

**មាត្រា ១៣៩.-**

បុគ្គលណាដែលបានទទួលការចាត់តាំងជាអ្នកអនុវត្តបទប្បញ្ញត្តិ ស្តីពីពន្ធដារ ហើយដោយចេតនាបានប្រព្រឹត្តអំពើដូចខាងក្រោមនេះ ត្រូវជាប់ពិរុទ្ធអំពីបទល្មើសនឹងច្បាប់ ហើយត្រូវទទួលរងការផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ រៀល (ប្រាំលានរៀល) ដល់ ១០.០០០.០០០ រៀល (ដប់លានរៀល) ឬជាប់ពន្ធនាគារពី ១ខែ ដល់ ១ឆ្នាំ ឬទោសទាំងពីរនេះ :

១- ដកប្រាក់ពន្ធសំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ឬការប្រើប្រាស់ណាផ្សេង ដែលគ្មានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ។

២- ធ្វើរបាយការណ៍មិនត្រឹមត្រូវ អំពីចំនួនប្រាក់ដែលខ្លួនប្រមូលបាន ឬទទួលបាន ។

៣- ប្រើប្រាស់តួនាទីជាមន្ត្រីពន្ធដារ ដើម្បីទទួលយកប្រាក់ ឬប្រយោជន៍ផ្សេងទៀតពីអ្នកជាប់ពន្ធ ឬបុគ្គលផ្សេងទៀត ។

៤- ប្រមូល ឬព្យាយាមប្រមូលប្រាក់ពន្ធ ដោយគ្មានការអនុញ្ញាត ។

បុគ្គលណាដែលបានទទួលការចាត់តាំងជាអ្នកអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារហើយដោយចេតនាបានទាមទារ ឬទទួលសំណូក ត្រូវទទួលទោសពីបទស៊ីសំណូកតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។ អ្នកសូកត្រូវទទួលទោសពីបទសូកតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ១៤០.-**

បើសិនជាអ្នកជាប់ពន្ធយល់ឃើញថា ខ្លួនបានទទួលរងនូវការខូចខាតខាងហិរញ្ញវត្ថុ ឬការរងគ្រោះផ្ទាល់ខ្លួនអំពីសកម្មភាពខុសឆ្គង ឬខុសច្បាប់ពីសំណាក់រដ្ឋបាលសារពើពន្ធអ្នកជាប់ពន្ធអាចប្តឹងទាមទារសំណងនៃការខូចខាត ឬការរងគ្រោះនោះទៅតុលាការក្នុងរយៈពេល ៣ឆ្នាំ ក្រោយកាលបរិច្ឆេទ នៃការខូចខាតខាងហិរញ្ញវត្ថុ ឬការរងគ្រោះផ្ទាល់ខ្លួនចុងក្រោយបំផុត ។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**មាត្រា ១៤១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៤២.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

បានបង្គំទូលថ្វាយ និងជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី១ និងទី២

ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការនីតិ

សម្បទាន និងអភិវឌ្ឍន៍ និងជារដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

**គាត ឈន់**

ព្រះហស្តលេខា

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ព្រះហស្តលេខា ហត្ថលេខា

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

នស/រកម/០៣០៣/០១០

# ព្រះរាជក្រម

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែង-តាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេស-រដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសអោយប្រើ

ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់សារពើពន្ធ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៣ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៣ នាសម័យប្រជុំពេញអង្គលើកទី ៨ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ច្បាប់

# ស្តីពី

# វិសោធនកម្ម

# នៃច្បាប់ស្តីពីសារពើពន្ធ

**មាត្រាមួយ.-**

មាត្រា ៣ មាត្រា ៩ មាត្រា ១៣ មាត្រា ២០ មាត្រា ២៣ មាត្រា ២៤ មាត្រា ២៥ មាត្រា ២៦ មាត្រា ២៧ មាត្រា ២៨ មាត្រា ៣១ មាត្រា ៣៣ មាត្រា ៣៤ មាត្រា ៣៧ មាត្រា ៤២ មាត្រា ៤៩ មាត្រា ៩៥ និងមាត្រា ១០៤ នៃច្បាប់ស្តីពីសារពើពន្ធដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ :

**មាត្រា ៣.- ថ្មី**

សម្រាប់គោលដៅនៃបទប្បញ្ញត្តិស្តីពីសារពើពន្ធ :

១- ពាក្យ "អ្នកជាប់ពន្ធនិវាសនជន" សំដៅដល់ :

ក- រូបវន្តបុគ្គលដែលមាននិវាសនដ្ឋាន ឬមានកន្លែងស្នាក់នៅជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាលើសពី ១៨២ ថ្ងៃ នៅក្នុងរយៈពេល ១២ខែ ណាមួយដែលបានបញ្ចប់ក្នុងឆ្នាំសារពើពន្ធចរន្ត

ខ- នីតិបុគ្គល ឬក្រុមអាជីវកម្ម ដែលត្រូវបានបង្កើត ឬត្រូវបានគ្រប់គ្រងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដែលមានកន្លែងប្រកបអាជីវកម្ម ជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- ពាក្យ "អ្នកជាប់ពន្ធអនិវាសនជន" មានន័យថា បុគ្គលណាមួយដែលមិនមែនជាអ្នកជាប់ពន្ធនិវាសនជនតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ និងទទួលប្រាក់ចំណូលប្រភពកម្ពុជា ។

៣- ពាក្យ "នីតិបុគ្គល" សំដៅដល់សហគ្រាស ឬអង្គការនានា ដែលប្រកបអាជីវកម្ម ទោះបីជាបាន ឬមិនទាន់បានទទួលស្គាល់ជាផ្លូវការពីស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលក្តី ។ ពាក្យ "នីតិបុគ្គល" រួមបញ្ចូលផងដែរនូវស្ថាប័នរដ្ឋាភិបាលអង្គការសាសនា អង្គការសប្បុរសធម៌ ឬអង្គការមិនស្វែងរកចំណេញ ។ ចំពោះបុគ្គលអនិវាសនជន ពាក្យ "នីតិបុគ្គល" សំដៅដល់គ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ពាក្យ "នីតិបុគ្គល" ពុំរាប់បញ្ចូលទេនូវក្រុមអាជីវកម្ម ឬសហគ្រាសឯកបុគ្គល ។

៤- ពាក្យ "គ្រឹះស្ថានអចិន្ត្រៃយ៍" សំដៅដល់ទីកន្លែងប្រកបអាជីវកម្មជាប់លាប់នៅព្រះរាជាណាចក្រកម្ពុជា សាខារបស់ក្រុមហ៊ុនបរទេស ឬភ្នាក់ងារនិវាសនជននៅព្រះរាជាណាចក្រកម្ពុជា ដែលតាមរយៈនេះ បុគ្គលអនិវាសនជនប្រកបអាជីវកម្មរបស់ខ្លួន ។ ពាក្យ "គ្រឹះស្ថានអចិន្ត្រៃយ៍" រួមបញ្ចូលផងដែរនូវសមាគម ឬរូបភាពទំនាក់ទំនងផ្សេងទៀត ដែលតាមរយៈនេះ បុគ្គលអនិវាសនជនធ្វើសកម្មភាពសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ។

៥- ពាក្យ "ក្រុមអាជីវកម្ម" សំដៅដល់ក្រុមសមូហនាមដែលមានម្ចាស់ភាគទុនជារូបវន្តបុគ្គលនិវាសនជនយ៉ាងច្រើន ១០នាក់ ហើយក្នុងនោះចំណែកសមាមាត្ររបស់ម្ចាស់ភាគទុននៅក្នុងខ្ទង់មូលធន ប្រាក់ចំណេញ និងការខាតបង់ត្រូវស្របតាមលក្ខណៈវិនិច្ឆ័យ ដែលត្រូវកំណត់ដោយអនុក្រឹត្យ ។ ក្នុងនិយមន័យនេះ "ក្រុមអាជីវកម្ម" មិនអាចជាសមាជិករបស់ក្រុមហ៊ុនបុគ្គលណាមួយ ហើយក៏មិនរាប់បញ្ចូលផងទេនូវក្រុមហ៊ុនដើមទុនគ្រឹះស្ថានអចិន្ត្រៃយ៍ ឬសហគ្រាសឯកបុគ្គល ។

៦- ពាក្យ"សហគ្រាសឯកបុគ្គល" សំដៅដល់សហគ្រាសអាជីវកម្មដែលជាកម្មសិទ្ធិ ១០០ភាគរយ របស់រូបវន្តបុគ្គលណាម្នាក់ ។ ក្នុងនិយមន័យនេះ ប្តី ប្រពន្ធ និងកូនក្នុងបន្ទុកត្រូវចាត់ទុកថា ជារូបវន្តបុគ្គលតែម្នាក់ ។

៧- ពាក្យ"អាជីវកម្ម" សំដៅដល់សកម្មភាពសេដ្ឋកិច្ចរបស់បុគ្គលដែលមានគោលដៅទាញយកប្រាក់ចំណូលអំពីការផលិត និងលក់ទំនិញ ការផ្គត់ផ្គង់សេវាភតិសន្យា ការជួល ឬលក់ទ្រព្យសម្បត្តិ ឬសកម្មភាពផ្សេងទៀត ។

៨- ពាក្យ"ភាគលាភ" សំដៅដល់ចំណែកជាសាច់ប្រាក់ ឬជាទ្រព្យដែលនីតិបុគ្គលបានចែកឱ្យអ្នកចូលហ៊ុនទៅតាមកម្រិតនៃភាគកម្មរបស់ខ្លួន នៅក្នុងដើមទុនផ្ទាល់របស់នីតិបុគ្គល លើកលែងតែភាគលាភជាប័ណ្ណភាគហ៊ុន និងការបែងចែកនានាក្នុងពេលជំរះបញ្ជីរំលាយក្រុមហ៊ុនទាំងស្រុង ។ ចំណែកណាមួយដែលចាត់ទុកថាជាភាគលាភ ឬមិនមែនជាភាគលាភត្រូវផ្អែកតាមល័ក្ខខ័ណ្ឌខាងលើនេះ ដោយពុំគិតថានីតិបុគ្គលមាន ឬគ្មានប្រាក់ចំណូល ឬប្រាក់ចំណេញចរន្ត ឬលទ្ធផលយោងសាជាថ្មីឡើយ ។

៩- ពាក្យ"អ្នកចូលហ៊ុន" សំដៅដល់បុគ្គលដែលមានចំណែកភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់នីតិបុគ្គល ។ សំរាប់គោលដៅនៃពន្ធនេះ នីតិបុគ្គលណាមួយ ទោះបីមិនមែនជាក្រុមហ៊ុនដើមទុនក្តីត្រូវចាត់ទុកដូចជាក្រុមហ៊ុនដើមទុន ហើយបុគ្គលដែលមានចំណែកភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់នីតិបុគ្គល ឬក៏បុគ្គលអាចបានទទួលប្រាក់ចំណូល ឬប្រាក់ចំណេញក្នុងឋានៈជាអ្នកបានចូលរួមក្នុងនីតិបុគ្គលនោះ ត្រូវចាត់ទុកថាជាអ្នកចូលហ៊ុនរបស់នីតិបុគ្គលដែរ ។

១០- ពាក្យ"បុគ្គលទាក់ទិន" សំដៅដល់ :

ក- សមាជិកណាម្នាក់ ក្នុងគ្រួសារអ្នកជាប់ពន្ធ

ខ- សហគ្រាសដែលគ្រប់គ្រងលើអ្នកជាប់ពន្ធ ឬសហគ្រាសត្រូវបានអ្នកជាប់ពន្ធគ្រប់គ្រង ឬក៏សហគ្រាសនោះ និងអ្នកជាប់ពន្ធស្ថិតនៅក្រោមការគ្រប់គ្រងរួមគ្នា ។ ពាក្យ"គ្រប់គ្រង" មានន័យថាមានកម្មសិទ្ធិ ចាប់ពី៥១ ភាគរយ ឡើងទៅលើតម្លៃ ឬសិទ្ធិបោះឆ្នោតនៃភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់សហគ្រាស ។ ដើម្បីកំណត់ទំហំនៃការគ្រប់គ្រងរបស់អ្នកជាប់ពន្ធជារូបវន្តបុគ្គលណាម្នាក់ ត្រូវគិតបញ្ចូលទាំងអស់នូវកម្មសិទ្ធិលើភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់រូបវន្តបុគ្គលនោះ និងកម្មសិទ្ធិផ្ទាល់ ឬប្រយោលរបស់សហព័ទ្ធអ្នកជាប់ពន្ធ ។

១១- ពាក្យ"អ្នកវិនិយោគ" មានន័យថា បុគ្គលណាមួយដែលអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

១២- ពាក្យ "គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់" មានន័យថាគម្រោងវិនិយោគដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាទទួលស្គាល់ថា ជាគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ។

**មាត្រា ៩.- ថ្មី**

ប្រាក់ចំណូលលើកលែងពន្ធត្រូវបានកំណត់ដូចតទៅ :

១- វៀរលែងតែមានបទប្បញ្ញត្តិផ្ទុយ និងលើកលែងតែប្រាក់ចំណូលដែលត្រូវជាប់ពន្ធតាមមាត្រា ២២ នៃច្បាប់នេះ ពន្ធលើប្រាក់ចំណេញមិនត្រូវអនុវត្តចំពោះ :

ក- ប្រាក់ចំណូលរបស់រាជរដ្ឋាភិបាល ឬប្រាក់ចំណូលស្ថាប័នរាជរដ្ឋាភិបាល

ខ- ប្រាក់ចំណូលរបស់អង្គការណាមួយដែល :

- ត្រូវបានរៀបចំឡើង និងដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬអប់រំ
- គ្មានចំណែកណាមួយនៃទ្រព្យ ឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជន

គ- ប្រាក់ចំណូលរបស់អង្គការពលករ ឬសភាពាណិជ្ជកម្ម ឧស្សាហកម្ម ឬកសិកម្ម ក្នុងករណីដែលប្រាក់ចំ-ណូលរបស់អង្គការទាំងនោះមិនត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជនរបស់អ្នកចូលហ៊ុន ឬរូបវន្តបុគ្គល

ឃ- ប្រាក់ចំណេញដែលបានមកពីការលក់ផលិតផលកសិកម្ម ដែលបុគ្គលមិនមែនជាអ្នកជាប់ពន្ធតាមរបបពិតផលិតបានដោយខ្លួនឯង ទោះបីផលិតផលនោះមិនទាន់កែច្នៃ ឬកែច្នៃហើយក៏ដោយ ទៅតាមទម្លាប់នៃការងារកសិកម្ម ។ ប្រតិបត្តិការតាមមធ្យោបាយឧស្សាហកម្ម រួមទាំងការកែច្នៃ ការរក្សាគុណភាព ការវេចខ្ចប់សម្រាប់លក់ពុំត្រូវបានចាត់ទុកជាទម្លាប់នៃការងារកសិកម្មឡើយ

ង- ភាគលាភដែលបានទទួលមកពីសហគ្រាសនិវាសនជន ក្នុងករណីដែលប្រាក់ពន្ធត្រូវបង់តាមមាត្រា ២០ថ្មី មាត្រា ២៣ថ្មី និងមាត្រា ២៦ថ្មី នៃច្បាប់នេះត្រូវបានបង់រួចរាល់ ។

២- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវកំណត់ដោយប្រកាសអំពីនីតិវិធីនៃការស្នើសុំលើកលែងពន្ធ ភាពបាត់បង់លក្ខណៈលើកលែងពន្ធ ការប្រកាសសារពើពន្ធ និងការចុះបញ្ជី ។

## មាត្រា ១៣.~ ថ្មី

១- ល័ក្ខខ័ណ្ឌនៃរំលស់ធម្មតានៃទ្រព្យរូបីមានដូចតទៅ :

ក- ក្នុងការកំណត់ប្រាក់ចំណេញជាប់ពន្ធ ការកាត់កងសម្រាប់រំលស់ត្រូវបានផ្តល់ឱ្យម្ចាស់ទ្រព្យរូបី ឬអ្នកជួលទ្រព្យរូបី ក្នុងករណីដែលអ្នកទទួលខុសត្រូវលើហានិភ័យចំពោះការបាត់បង់ ឬការខូចខាតនៃទ្រព្យស្របតាមលក្ខខណ្ឌដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ខ- ទ្រព្យរូបីដែលអាចរំលស់បានគឺទ្រព្យរូបីប្រើប្រាស់ក្នុងអាជីវកម្មដែលតែងតែបាត់បង់តម្លៃដោយការប្រើ-ប្រាស់ ឬភាពហួសសម័យ ។ ដីធ្លីមិនមែនជាទ្រព្យអាចរំលស់បានទេ

គ- ទ្រព្យរូបីទាំងអស់ ត្រូវបានបែងចែកជាថ្នាក់ដូចតទៅ :

ថ្នាក់ ១ : អាគារនិងរចនាសម្ព័ន្ធព្រមទាំងសមាសភាគរបស់វា ។ អត្រារំលស់ ៥ភាគរយ តាមវិធីរំលស់ស្មើភាគ

ថ្នាក់ ២ : កុំព្យូទ័រ ប្រព័ន្ធព័ត៌មានអេឡិចត្រូនិច សហ្វវែរ និងបរិក្ខាទុកដាក់ទិន្នន័យ ។ អត្រារំលស់ ៥០ ភាគរយ តាមវិធីរំលស់ថយជាលំដាប់

ថ្នាក់ ៣ : រថយន្ត រថយន្តដឹកទំនិញ គ្រឿងសង្ហារឹម និងបរិក្ខាការិយាល័យ ។ អត្រារំលស់ ២៥ភាគរយ តាមវិធីរំលស់ថយជាលំដាប់

ថ្នាក់ ៤ : ទ្រព្យរូបីឯទៀតទាំងអស់ អត្រារំលស់ ២០ ភាគរយ តាមវិធីរំលស់ថយជាលំដាប់ ។

ឃ-នីតិវិធីក្នុងការបង្កើតថ្នាក់នៃទ្រព្យ ការបញ្ចូលទ្រព្យថ្មីទៅក្នុងថ្នាក់ណាមួយ ការបញ្ចេញទ្រព្យពីថ្នាក់ណាមួយ និងការចាត់ចែងចំពោះបញ្ហាជួសជុលព្រមទាំងចំណាយផ្សេងៗ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ង-វិធានអន្តរកាលសម្រាប់អ្នកជាប់ពន្ធក្នុងការប្រើវិធីរំលស់ ដូចមានចែងក្នុងកថាខណ្ឌនេះ សម្រាប់ឆ្នាំសារពើពន្ធ ២០០៣ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ច- ការកាត់កងសម្រាប់រំលស់នៅក្នុងកថាខណ្ឌនេះត្រូវគណនាដោយផ្អែកលើតម្លៃទ្រព្យ ក្រោយការកាត់កងទឹកប្រាក់រំលស់ពិសេសក្នុងកថាខណ្ឌ ២ នៃមាត្រានេះ ។

២- លក្ខខណ្ឌនៃរំលស់ពិសេសនៃទ្រព្យរូបីមានដូចតទៅ :

ក- រំលស់ពិសេសគឺជាចំនួនដែលអាចកាត់កងក្នុងឆ្នាំទី ១ នៃការទិញ ឬនាពេលក្រោយកមកទៀតនៅឆ្នាំទី ១ នៃការដាក់ប្រើប្រាស់ទ្រព្យរូបី ដោយគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដូចមានចែងក្នុងវាក្យខណ្ឌ ខ នៃកថាខណ្ឌនេះ ។ ចំនួនដែលអាចកាត់កងបាននេះស្មើនឹង ៤០ ភាគរយនៃតម្លៃមូលធននៃទ្រព្យរូបីថ្មី ឬទ្រព្យរូបីប្រើប្រាស់រួចដែលបានដាក់ប្រើប្រាស់ក្នុងផលិតកម្ម និងការកែច្នៃដែលនឹងកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ រំលស់ពិសេស នឹងកាត់បន្ថយនូវតម្លៃជាមូលធននៃទ្រព្យរូបីដែលប្រើប្រាស់សម្រាប់ការរំលស់ធម្មតាតាមកថាខណ្ឌ ១ នៃមាត្រានេះ

ខ- រំលស់ពិសេសនៃទ្រព្យរូបីនឹងត្រូវបានយកមកកាត់កងដើម្បីកំណត់ប្រាក់ចំណូលជាប់ពន្ធរបស់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់ឆ្នាំសារពើពន្ធ ប្រសិនបើអ្នកវិនិយោគមិនជ្រើសយកការប្រើប្រាស់សិទ្ធិទទួលរយៈពេលលើកលែងពន្ធ ដូចមានចែងក្នុងកថាខណ្ឌ ៤ នៃមាត្រា ២០ ថ្មី នៃច្បាប់នេះ

គ- ទ្រព្យរូបីដែលបានទទួលនូវកាត់កងរំលស់ពិសេសត្រូវដាក់ប្រើប្រាស់យ៉ាងតិចបំផុត ៤ឆ្នាំ សារពើពន្ធ បន្ទាប់ពីឆ្នាំសារពើពន្ធដែលរំលស់ពិសេសត្រូវបានកាត់កង ។ ប្រសិនបើទ្រព្យរូបីនោះត្រូវបានឈប់ប្រើប្រាស់មុនរយៈពេលនេះ អ្នកវិនិយោគត្រូវកត់ត្រាបញ្ចូលក្នុងប្រាក់ចំណេញជាប់ពន្ធវិញនូវចំនួនមួយស្មើនឹងទឹកប្រាក់រំលស់ពិសេស ដែលបានកាត់កង កាត់បន្ថយដោយចំនួនមួយស្មើនឹង ២ភាគរយនៃទឹកប្រាក់រំលស់ពិសេសដែលបានកាត់កង សម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលទ្រព្យនោះត្រូវបានដាក់ឱ្យប្រើប្រាស់ ។ ចំនួននេះនឹងមិនប៉ះពាល់តម្លៃពិតគណនេយ្យនៃទ្រព្យរូបីសម្រាប់ការកំណត់ផលចំណេញពីមូលធនជាប់ពន្ធតាមមាត្រា ៧ នៃច្បាប់នេះ ។

**មាត្រា ២០.~ ថ្មី**

អត្រាពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំមានដូចតទៅ :

១- ២០ ភាគរយ ចំពោះប្រាក់ចំណេញដែលសម្រេចបានដោយនីតិបុគ្គល ។

២- ៣០ ភាគរយ ចំពោះប្រាក់ចំណេញដែលសម្រេចបានក្រោមកិច្ចសន្យាបែងចែកផលិតផលប្រេងកាត និង ឧស្ម័នធម្មជាតិ ឬសម្រេចបានពីការធ្វើអាជីវកម្មលើធនធានធម្មជាតិ រួមទាំងព្រៃឈើ រ៉ែ មាស ឬត្បូងថ្ម មានតម្លៃនានា ។

៣- ៩ ភាគរយ ចំពោះប្រាក់ចំណេញរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលទទួលស្គាល់ ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សម្រាប់រយៈពេលអន្តរកាល ៥ឆ្នាំ ដោយគិតចាប់ផ្ដើមពីថ្ងៃប្រកាសឱ្យ ប្រើច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

៤- ០ ភាគរយ ចំពោះប្រាក់ចំណេញរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលស្ថិតនៅក្នុង រយៈពេលលើកលែងពន្ធ ដែលកំណត់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រោមច្បាប់ស្ដីពីវិសោធនកម្មនៃ ច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ក្នុងករណីដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់ គ្រាន់បានបំពេញតាមការតម្រូវរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងមាត្រា ១០៤ ថ្មី នៃច្បាប់នេះ ។

៥- តាមតារាងអត្រាពន្ធកំណើនតាមថ្នាក់ខាងក្រោម ចំពោះប្រាក់ចំណេញដែលសម្រេចបានដោយរូបវន្តបុគ្គល និងចំណែកដែលត្រូវបែងចែកឱ្យសមាជិកម្នាក់ៗរបស់ក្រុមអាជីវកម្មដែលមិនត្រូវបានចាត់ទុកជានីតិបុគ្គល

| ភាគនៃប្រាក់ចំណេញប្រចាំឆ្នាំដែលត្រូវជាប់ពន្ធ | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | ០ ៛ | ដល់ | ៦.០០០.០០០ ៛ | ០% |
| ពី | ៦.០០០.០០១ ៛ | ដល់ | ១៥.០០០.០០០ ៛ | ៥% |
| ពី | ១៥.០០០.០០១ ៛ | ដល់ | ១០២.០០០.០០០ ៛ | ១០% |
| ពី | ១០២.០០០.០០១ ៛ | ដល់ | ១៥០.០០០.០០០ ៛ | ១៥% |
| | | | លើសពី ១៥០.០០០.០០០៛ | ២០% |

៦- សិទ្ធិ បុព្វសិទ្ធិ និងសិទ្ធិដទៃទៀតដែលគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់បានទទួល ក្រោមច្បាប់ ច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា មិនអាចផ្ទេរ ឬប្រគល់ជូនទៅតតិយ ជនណាមួយឡើយ លើកលែងតែក្នុងករណីទិញ ឬរំលាយបញ្ចូលគ្នា ។

## មាត្រា ២៣.~ ថ្មី

ពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភត្រូវបានកំណត់ដូចតទៅ :

១- ពន្ធលើប្រាក់ចំណេញបន្ថែមត្រូវបង់ក្នុងចំនួនស្មើនឹង ២០ភាគរយ នៃទឹកប្រាក់ត្រូវបែងចែកចំពោះ :

ក- ការបែងចែកប្រាក់ចំណេញទុក ឬប្រាក់ចំណេញប្រចាំឆ្នាំក្រោយ ការបង់ពន្ធលើប្រាក់ចំណេញ ប្រសិនបើ សហគ្រាសធ្វើការបែងចែកប្រាក់ចំណេញរក្សាទុក ឬ ប្រាក់ចំណេញប្រចាំឆ្នាំដែលបានបង់ពន្ធលើប្រាក់ចំ- ណេញតាមអត្រា ០ ភាគរយ ដូចមានចែងក្នុងកថាខណ្ឌ ៤ នៃមាត្រា ២០ថ្មី នៃច្បាប់នេះ និង

ខ- ការបែងចែកដទៃទៀត វៀរលែងតែការបែងចែកដែលបានកំណត់ក្នុងកថាខណ្ឌ ២ និងកថាខណ្ឌ ៣ នៃមាត្រានេះ និងការបង់សងវិញនូវមូលធន ។

២- ពន្ធលើប្រាក់ចំណេញបន្ថែមត្រូវបង់ក្នុងចំនួនស្មើនឹង ១១ ភាគ ៩១ នៃទឹកប្រាក់ត្រូវបែងចែកចំពោះការបែងចែកប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំ ក្រោយការបង់ពន្ធលើប្រាក់ចំណេញ ប្រសិនបើសហគ្រាសធ្វើការបែងចែកប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំដែលបានបង់ពន្ធលើប្រាក់ចំណេញតាមអត្រា ៩ ភាគរយ តាមកថាខណ្ឌ ៣ នៃមាត្រា ២០ ថ្មី នៃច្បាប់នេះ ។

៣- ពន្ធលើប្រាក់ចំណេញបន្ថែមមិនត្រូវអនុវត្តទេ ចំពោះការបែងចែកប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំក្រោយការបង់ពន្ធលើប្រាក់ចំណេញ ប្រសិនបើសហគ្រាសធ្វើការបែងចែកប្រាក់ចំណេញរក្សាទុកឬប្រាក់ចំណេញប្រចាំឆ្នាំដែលបានបង់ពន្ធលើប្រាក់ចំណេញតាមអត្រា ២០ភាគរយ តាមកថាខណ្ឌ ១ នៃមាត្រា ២០ ថ្មី ឬអត្រា ៣០ ភាគរយ តាមកថាខណ្ឌ ២ នៃមាត្រា ២០ ថ្មី នៃច្បាប់នេះ ។

៤- ប្រសិនបើសហគ្រាសណាមួយបានទទួលភាគលាភបានបង់ពន្ធតាមកថាខណ្ឌ ១ កថាខណ្ឌ ២ និងកថាខណ្ឌ ៣ នៃមាត្រានេះ ពីសហគ្រាសមួយទៀត ត្រូវកត់ត្រាចំនួនប្រាក់ភាគលាភនោះទៅក្នុងគណនីភាគលាភរបស់ខ្លួន ។ ពេលសហគ្រាសនោះបែងចែកភាគលាភជាបន្តទៀតទៅអ្នកចូលហ៊ុនរបស់ខ្លួន ទឹកប្រាក់បែងចែកដែលត្រូវដកចេញពីគណនីភាគលាភមិនត្រូវជាប់ពន្ធលើប្រាក់ចំណេញបន្ថែម ដូចក្នុងកថាខណ្ឌ ១ កថាខណ្ឌ ២ និងកថាខណ្ឌ ៣ នៃមាត្រានេះទេ ។

៥- សម្រាប់គោលដៅនៃមាត្រានេះ ការបែងចែកណាមួយនៃប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំក្រោយការបង់ពន្ធលើប្រាក់ចំណេញ ត្រូវអនុវត្តតាមលំដាប់ដូចខាងក្រោម :

ក- ដំបូង យកចេញពីប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំ ក្រោយការបង់ពន្ធលើប្រាក់ចំណេញដែលបានបង់ពន្ធលើប្រាក់ចំណេញតាមអត្រា ២០ ភាគរយ តាមកថាខណ្ឌ ១ នៃមាត្រា ២០ ថ្មី នៃច្បាប់នេះ ឬអត្រា ៣០ ភាគរយ តាមកថាខណ្ឌ ២ នៃមាត្រា ២០ ថ្មីនៃច្បាប់នេះ

ខ- បន្ទាប់មក យកចេញពីប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំក្រោយការបង់ពន្ធលើប្រាក់ចំណេញដែលបានបង់ពន្ធលើប្រាក់ចំណេញ តាមអត្រា ៩ ភាគរយ តាមកថាខណ្ឌ ៣ នៃមាត្រា ២០ថ្មី នៃច្បាប់នេះ

គ- បន្ទាប់មកទៀត យកចេញពីប្រាក់ចំណេញរក្សាទុក ឬប្រាក់ចំណេញប្រចាំឆ្នាំក្រោយការបង់ពន្ធលើប្រាក់ចំណេញតាមអត្រា ០ ភាគរយ តាមកថាខណ្ឌ ៤ នៃមាត្រា ២០ ថ្មី នៃច្បាប់នេះ ។

**មាត្រា ២៤.. ថ្មី**

ពន្ធអប្បបរមាត្រូវបានកំណត់លើអ្នកជាប់ពន្ធតាមរបបពិត ។ ពន្ធអប្បបរមាជាពន្ធមួយដាច់ដោយឡែក និងផ្សេងពីពន្ធលើប្រាក់ចំណេញ ។ ពន្ធនេះត្រូវបង់ដោយអ្នកជាប់ពន្ធតាមរបបពិត លើកលែងតែគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ។ ពន្ធអប្បបរមាត្រូវកំណត់តាមអត្រា ១ភាគរយ លើផលរបរប្រចាំឆ្នាំ រួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម ហើយត្រូវបង់នៅពេលទូទាត់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ។ ពន្ធអប្បបរមាអាចត្រូវបាន

កាត់បន្ថយដោយពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំដែលបានបង់ជាក់ស្តែង តាមវិធានដែលមានចែងក្នុងមាត្រា ៣៧ ថ្មី មាត្រា ៣៨ និងមាត្រា ៣៩ នៃច្បាប់នេះ ។

**មាត្រា ២៥.-  ថ្មី**

ពន្ធកាត់ទុកទូទៅត្រូវបានកំណត់ដូចតទៅ  :

១-  អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ដែលបានធ្វើការទូទាត់ជាសាច់ប្រាក់ ឬជាវត្ថុឱ្យដល់អ្នកជាប់ពន្ធនិវាសនជន ត្រូវកាត់ទុក និងបង់ប្រាក់ពន្ធទៅតាមអត្រាកំណត់ដូចខាងក្រោម លើចំនួនទូទាត់មុនការកាត់ទុកប្រាក់ពន្ធ  :

ក- អត្រា ១៥ភាគរយ ចំពោះ  :

- ប្រាក់ចំណូលដែលរូបវន្តបុគ្គលបានទទួលពីការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់ ឬសេវាប្រហាក់ប្រហែល
- សួយសារចំពោះទ្រព្យអរូបី និងភាគកម្មក្នុងធនធានរ៉ែ ហើយនិងការប្រាក់ដែលអ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្មដែលមិនមែនជាធនាគារ ឬស្ថាប័នសញ្ញ័យធនក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន

ខ- អត្រា ១០ភាគរយ ចំពោះចំណូលពីការឱ្យជួលអចលនៈ ឬចលនៈទ្រព្យ

គ- អត្រា ៦ ភាគរយ ចំពោះការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ញ័យធនក្នុងស្រុកបង់ឱ្យ ទៅអ្នកជាប់ពន្ធនិវាសនជន ដែលមានគណនីបញ្ញើមានកាលកំណត់

ឃ-អត្រា ៤ភាគរយ ចំពោះការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ញ័យធនក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជនដែលមានគណនីសន្សំគ្មានកាលកំណត់ ។

២-  ការកាត់ទុកក្នុងមាត្រានេះ មិនត្រូវអនុវត្តទេចំពោះការប្រាក់ដែលបង់ឱ្យទៅធនាគារ និងស្ថាប័នសញ្ញ័យធនក្នុងស្រុក និងការទូទាត់ចំពោះប្រាក់ចំណូលលើកលែងពន្ធដូចមានចែងក្នុងមាត្រា ៩ ថ្មីនៃច្បាប់នេះ ។

**មាត្រា ២៦.-  ថ្មី**

អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ដែលបានទូទាត់ប្រាក់ចំណូលខាងក្រោមនេះឱ្យទៅអ្នកជាប់ពន្ធនិវាសនជនត្រូវកាត់ទុកប្រាក់ពន្ធចំនួន ១៤ភាគរយ នៃទឹកប្រាក់ត្រូវបើក  :

ក- ការប្រាក់

ខ- សួយសារ ថ្លៃឈ្នួល និងប្រាក់ចំណូលផ្សេងៗ ទាក់ទិននឹងការប្រើប្រាស់ទ្រព្យសម្បត្តិ

គ- ការទូទាត់ចំពោះសេវាគ្រប់គ្រង និងសេវាបច្ចេកទេសនានាដែលនឹងត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ឃ-ភាគលាភ ។

**មាត្រា ២៧.~ ថ្មី**

ពន្ធកាត់ទុកលើការទូទាត់ឱ្យដល់អ្នកជាប់ពន្ធនិវាសនជនតាមមាត្រា ២៥ ថ្មី នៃច្បាប់នេះ និងពន្ធកាត់ទុកលើការទូទាត់ឱ្យដល់អ្នកជាប់ពន្ធអនិវាសនជនតាមមាត្រា ២៦ ថ្មី នៃច្បាប់នេះ ត្រូវចាត់ទុកថាជាពន្ធចុងក្រោយសម្រាប់អ្នកទទួលការទូទាត់ដែលមានបញ្ជាក់ក្នុងមាត្រាទាំង ខាងលើនេះ ។

**មាត្រា ២៨.~ ថ្មី**

សហគ្រាសដែលជាប់ពន្ធលើប្រាក់ចំណេញតាមរបបពិត រួមទាំងគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលជាប់ពន្ធលើប្រាក់ចំណេញតាមអត្រា ៩ ភាគរយ មានកាតព្វកិច្ចបង់ប្រាក់រំដោះប្រចាំខែសម្រាប់ពន្ធលើប្រាក់ចំណេញតាមអត្រា ១ ភាគរយនៃផលរបរគិតរួមបញ្ចូលទាំងពន្ធអាករទាំងអស់ វៀរលែងតែអាករលើតម្លៃបន្ថែមដែលសម្រេចបានក្នុងខែមុន ។ ផលរបររបស់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងរយៈពេលលើកលែងពន្ធដែលកំណត់ដោយច្បាប់ស្តីពីវិនិយោគកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានលើកលែងពីការបង់ប្រាក់រំដោះនេះ ។ ប្រាក់រំដោះនឹងត្រូវបានយកមកកាត់កងពីពន្ធលើប្រាក់ចំណេញនៅពេលធ្វើការទូទាត់ប្រចាំឆ្នាំ ។

**មាត្រា ៣១.~ ថ្មី**

១- បុគ្គល ឬអ្នកទទួលភារៈបើកប្រាក់ដែលកាត់ទុកប្រាក់ពន្ធតាមមាត្រា ២៥ ថ្មី និងមាត្រា ២៦ ថ្មី នៃច្បាប់នេះ ត្រូវដាក់លិខិតប្រកាសសារពើពន្ធ និងបង់ប្រាក់ពន្ធដែលបានកាត់ទុកជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ នៃខែបន្ទាប់ពីខែដែលបានធ្វើការទូទាត់ ។

២- សហគ្រាសត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភដូចមានចែងក្នុងមាត្រា ២៣ ថ្មីនៃច្បាប់នេះ និងបង់ពន្ធជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ នៃខែបន្ទាប់ពីខែដែលការបែងចែកត្រូវបានទូទាត់ ។

**មាត្រា ៣៣.~ ថ្មី**

ដោយមិនមានការកម្រិតត្រឹមតែប្រាក់ចំណូលដូចខាងក្រោមនេះ ប្រាក់ចំណូលប្រភពកម្ពុជារួមមាន :

១- ការប្រាក់ដែលបង់ដោយសហគ្រាសនិវាសនជន ក្រុមអាជីវកម្មនិវាសនជន ឬស្ថាប័នរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

២- ភាគលាភដែលបានបែងចែកដោយសហគ្រាសនិវាសនជន ។

៣- ប្រាក់ចំណូលពីសេវាកម្មដែលបានបំពេញនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៤- ប្រាក់ចំណូលពីការគ្រប់គ្រង និងសេវាបច្ចេកទេសដែលបានទូទាត់ដោយបុគ្គលនិវាសនជន ។

៥- ប្រាក់ចំណូលដែលបានមកពីចលនៈ ឬអចលនទ្រព្យ ក្នុងករណីដែលទ្រព្យនោះស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៦- ប្រាក់សួយសារដែលបានមកពីការប្រើប្រាស់ ឬសិទ្ធិប្រើប្រាស់ទ្រព្យអរូបីដែលបានទូទាត់ដោយបុគ្គលនិវាសនជន ឬបុគ្គលអនិវាសនជន តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ដែលតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៧- ផលចំណេញពីការលក់អចលនទ្រព្យដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬផលចំណេញពីការផ្ទេរផលប្រយោជន៍ណាមួយនៃអចលនទ្រព្យដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៨- បុព្វលាភធានារ៉ាប់រង ឬធានារ៉ាប់រងបន្តចំពោះហានិភ័យនៅព្រះរាជាណាចក្រកម្ពុជា

៩- ផលចំណេញពីការលក់ចលនទ្រព្យដែលជាចំណែកនៃទ្រព្យអាជីវកម្មរបស់គ្រឹះស្ថានអចិន្ត្រៃយ៍របស់អ្នកជាប់ពន្ធអនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

១០- ប្រាក់ចំណូលពីសកម្មអាជីវកម្មរបស់បុគ្គលអនិវាសនជន តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## មាត្រា ៣៥.- ថ្មី

រាល់ប្រាក់ចំណូលដែលមិនមែនជាប្រាក់ចំណូលប្រភពកម្ពុជាដូចក្នុងមាត្រា ៣៣ ថ្មី នៃច្បាប់នេះ ត្រូវចាត់ទុកថាជាប្រាក់ចំណូលប្រភពបរទេស ។

## មាត្រា ៣៧.- ថ្មី

ការគណនាបំណុលពន្ធលើប្រាក់ចំណេញត្រូវបានកំណត់ដូចតទៅ :

១- គណនាបំណុលពន្ធសរុបតាមមាត្រា ២០ ថ្មី និងមាត្រា ២៣ ថ្មីនៃច្បាប់នេះ ។

២- ដកឥណទានពន្ធបរទេសតាមមាត្រា ៣៦ នៃច្បាប់នេះ ប៉ុន្តែមិនឱ្យលើសបំណុលពន្ធក្នុងកថាខណ្ឌ ១ នៃមាត្រានេះទេ ។

## មាត្រា ៤២.- ថ្មី

សម្រាប់គោលដៅនៃបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស :

១- ពាក្យ "និវាសនជន" ក្នុងករណីដែលប្រើចំពោះនិយោជិត អ្នកជាប់ពន្ធ ឬរូបវន្តបុគ្គលមានន័យថា ដែលមាននិវាសនដ្ឋាន ឬមានកន្លែងស្នាក់នៅជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាលើសពី ១៨២ ថ្ងៃនៅក្នុងរយៈពេល ១២ខែណាមួយដែលបានបញ្ចប់ក្នុងឆ្នាំសារពើពន្ធចរន្ត ។

២- ពាក្យ "អនិវាសនជន" មានន័យថា បុគ្គលណាមួយដែលមិនមែនជានិវាសនជនតាមកថាខណ្ឌ ១ នៃមាត្រានេះ និងទទួលប្រាក់បៀវត្សប្រភពកម្ពុជា ។

៣- វៀរលែងតែមានបទប្បញ្ញត្តិផ្ទុយ ការប្រើពាក្យនិយោជិត អ្នកជាប់ពន្ធ និងរូបវន្តបុគ្គល គឺសំដៅដល់ទាំងនិវាសនជន និងអនិវាសនជន ដូចមានចែងក្នុងមាត្រានេះ ។

៤- ពាក្យ "និយោជក" រួមមានស្ថាប័នរដ្ឋ នីតិបុគ្គលនិវាសនជន ក្រុមអាជីវកម្មនិវាសនជន គ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា អង្គការមិនស្វែងរកចំណេញ ឬរូបវន្តបុគ្គលនិវាសនជនដែលប្រកបអាជីវកម្ម ។

៥- ពាក្យ"និយោជិត" សំដៅដល់រូបវន្តបុគ្គលដែលបានទទួលប្រាក់បៀវត្សអំពីសកម្មភាពបំរើការងាររបស់ខ្លួន រួមបញ្ចូលទាំងអ្នកទទួលខុសត្រូវ ឬអភិបាលរបស់សហគ្រាសមន្ត្រីរាជការ មន្ត្រីជ្រើសតាំងដោយការបោះឆ្នោត លើកលែងតែសមាជិករដ្ឋសភា និងព្រឹទ្ធសភា ។

៦- ពាក្យ"ប្រាក់បៀវត្សប្រភពកម្ពុជា" មានន័យថា ប្រាក់បៀវត្សដែលបានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញសកម្មភាពបំរើការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដោយឡែក ចំពោះប្រាក់បៀវត្សដែលអនិវាសនជនបានទទួលក្នុងការផ្តល់ជំនួយបច្ចេកទេសត្រូវចាត់ទុកថាមានប្រភពនៅក្នុងប្រទេសដែលអ្នកទូទាត់ប្រាក់បៀវត្សនោះស្នាក់នៅ ។

៧- ពាក្យ"បរទេស" :

ក- ពេលណាប្រើជាមួយរូបវន្តបុគ្គល មានន័យថាដែលជាអនិវាសនជន

ខ- ចំពោះការកំណត់ប្រភពប្រាក់ចំណូលមានន័យថា ក្រៅព្រះរាជាណាចក្រកម្ពុជា ។

៨- ពាក្យ"ប្រាក់បៀវត្ស" ក្នុងច្បាប់នេះសំដៅដល់បៀវត្ស លាភការ ប្រាក់បំណាច់បុព្វលាភ ប្រាក់ម៉ោងបន្ថែម ប្រាក់ប៉ះប៉ូវនានា និងអត្ថប្រយោជន៍បន្ថែមដែលបានទូទាត់ឱ្យដល់និយោជិត ឬដែលបានទូទាត់ដើម្បីជាប្រ - យោជន៍ផ្ទាល់ ឬប្រយោលដល់និយោជិត ចំពោះការបំពេញសកម្មភាពបំរើការងារ ។

**មាត្រា ៩៤.~ ថ្មី**

វៀរលែងតែអត្ថប្រយោជន៍បន្ថែមដែលត្រូវកំណត់ពន្ធតាមមាត្រា ៤៨ នៃច្បាប់នេះ សម្រាប់អ្នកជាប់ពន្ធអនិវាសនជន ប្រាក់ពន្ធត្រូវកាត់ទុកដោយអ្នកបើកប្រាក់ឱ្យតាម អត្រា ២០ ភាគរយលើរាល់ការទូទាត់ប្រាក់បៀវត្សជាប់ពន្ធដែលមានចែងក្នុងកថាខណ្ឌ ៣ នៃមាត្រា ៤៦ នៃច្បាប់នេះ ។ ពន្ធកាត់ទុកនេះ គឺជាពន្ធចុងក្រោយនៃពន្ធលើប្រាក់បៀវត្សសំរាប់អនិវាសនជនជាអ្នកទទួលប្រាក់បៀវត្ស ។

**មាត្រា ៩៥.~ ថ្មី**

១- លិខិតស្នាម ឬ លិខិតជូនដំណឹងដែលរដ្ឋបាលសារពើពន្ធផ្តល់ទៅអ្នកជាប់ពន្ធមានលក្ខណៈជាការដាក់ឱ្យអ្នកជាប់ពន្ធនោះមានកាតព្វកិច្ចចំពោះរដ្ឋបាលសារពើពន្ធ លុះណាតែលិខិតស្នាម ឬលិខិតជូនដំណឹងនោះត្រូវបានធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវបានប្រគល់ឱ្យដល់អ្នកជាប់ពន្ធ ។

២- ក្នុងករណីដែលបទប្បញ្ញត្តិស្តីពីពន្ធដារតម្រូវឱ្យរដ្ឋបាលសារពើពន្ធផ្តល់លិខិតស្នាម ឬដំណឹងជាលាយលក្ខណ៍អក្សរទៅឱ្យបុគ្គល លិខិតស្នាម ឬលិខិតជូនដំណឹងនោះត្រូវបានចាត់ទុកថាបានប្រគល់យ៉ាងត្រឹមត្រូវ លុះណាតែបានប្រគល់ឱ្យបុគ្គលនោះ ឬក៏បានផ្ញើតាមប្រៃសណីយ៍ជាលិខិតអនុសិដ្ឋទៅអាស័យដ្ឋានតាមផ្លូវច្បាប់របស់បុគ្គលនោះ ។

៣- កាលបរិច្ឆេទនៃលិខិតស្នាម ឬលិខិតជូនដំណឹងផ្សេងៗ គឺជាកាលបរិច្ឆេទនៃការប្រគល់អោយបុគ្គល ។ ក្នុងករណីលិខិតស្នាម ឬលិខិតជូនដំណឹងត្រូវបានផ្ញើតាមលិខិតអនុសិដ្ឋ កាលបរិច្ឆេទនៃការជូនដំណឹងគឺជាកាលបរិច្ឆេទនៃការជូនដំណឹង គឺជាកាលបរិច្ឆេទនៃការបោះត្រាលើលិខិតអនុសិដ្ឋរបស់ការិយាល័យប្រៃសណីយ៍ ។

៤- លិខិតស្នាម ឬលិខិតជូនដំណឹងត្រូវចាត់ទុកថា បានប្រគល់ទទួលត្រឹមត្រូវកាលបើលក្ខខណ្ឌក្នុងកថាខណ្ឌ ២ នៃមាត្រានេះត្រូវបានបំពេញរួចហើយ ទោះបីជាបុគ្គលដែលត្រូវបានជូនដំណឹងនោះបដិសេធការប្រគល់ ឬការទទួលលិខិតអនុសិដ្ឋក្តី ។

៥- ក្នុងករណីដែលអាស័យដ្ឋានរបស់បុគ្គលត្រូវបានផ្លាស់ប្តូរ ហើយបុគ្គលមិនបានជូនដំណឹងដល់រដ្ឋបាលសារពើពន្ធអំពីការផ្លាស់ប្តូរនោះទេ លិខិតស្នាម ឬលិខិតជូនដំណឹងដែលបានបញ្ជូនទៅអាស័យដ្ឋានដែលបានស្គាល់ចុងក្រោយបង្អស់ ត្រូវចាត់ទុកថាបានប្រគល់ទទួលត្រឹមត្រូវ ។

៦- ក្នុងករណីដោយមូលហេតុណាមួយដែលលិខិតស្នាម ឬលិខិតជូនដំណឹងមិនអាចផ្តល់ដល់អ្នកជាប់ពន្ធ ដូចមានចែងក្នុងកថាខណ្ឌ ១ កថាខណ្ឌ ២ កថាខណ្ឌ ៣ កថាខណ្ឌ ៤ និងកថាខណ្ឌ ៥ នៃមាត្រានេះ លិខិតស្នាម ឬលិខិតជូនដំណឹងត្រូវបានចាត់ទុកថាបានប្រគល់យ៉ាងត្រឹមត្រូវ ប្រសិនបើរដ្ឋបាលសារពើពន្ធបាន :

ក- បិទលិខិតស្នាម ឬលិខិតជូនដំណឹងភ្ជាប់នៅនឹងទ្វារនិវាសនដ្ឋាន ឬទីកន្លែងប្រកបអាជីវកម្មរបស់អ្នកជាប់ពន្ធ ឬ

ខ- ផ្សព្វផ្សាយតាមសារព័ត៌មាន ដោយតម្រូវឱ្យអ្នកជាប់ពន្ធចូលមករដ្ឋបាលសារពើពន្ធមិនឱ្យលើសពី ១៥ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទផ្សព្វផ្សាយ ។

## មាត្រា ១០៤.~ ថ្មី

១- អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ពេលវេលា និងទីកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់ ។

២- លិខិតប្រកាសសារពើពន្ធត្រូវចុះហត្ថលេខាដោយអ្នកជាប់ពន្ធ ឬតំណាងស្របច្បាប់របស់អ្នកជាប់ពន្ធ ។

៣- អ្នកវិនិយោគទាំងអស់ត្រូវដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែ សម្រាប់ខែនីមួយៗ និងលិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំសម្រាប់ឆ្នាំសារពើពន្ធនោះ និងបង់ពន្ធអាករទាំងអស់ទៅតាមបទប្បញ្ញត្តិនៃពន្ធនីមួយៗ

៤- អ្នកវិនិយោគទាំងអស់ត្រូវភ្ជាប់នូវវិញ្ញាបនបត្ររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបញ្ជាក់ពីការគោរពប្រតិបត្តិជាមួយលិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំ សម្រាប់ឆ្នាំសារពើពន្ធនោះ ។

## មាត្រាពីរ.~

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣

នរល.០៣.០៣.១៣៨

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងត្រា**

**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ហត្ថលេខា**
**គាត ឈន់**

លេខ : ១១១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ.ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ហត្ថលេខា និងត្រា**
**ឈាងី តាន់**

# ព្រះរាជក្រម

នស/រកម/១២០៧/០៣១

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីកម្មសិទ្ធិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៧ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME du CAMBODGE

# ច្បាប់

# ស្តីពី

# ក្រុំឃេដន

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់អំពីវិធាន លក្ខខណ្ឌ នីតិវិធី និងដំណើរការក្តីពីក្ស័យធននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ច្បាប់នេះមានគោលបំណងផ្តល់នូវការទូទាត់ ឬការសងជាសមូហភាពតាមលំដាប់ និងត្រឹមត្រូវតាមសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលដោយយកទ្រព្យសម្បត្តិរបស់កូនបំណុលមកទូទាត់ ឬ សង និងផ្តល់នីតិសម្បទាដល់អាជីវកម្មរបស់កូនបំណុល កាលណាភាគីដែលមានផលប្រយោជន៍យល់ថាសមស្រប ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះពាណិជ្ជករ និងនីតិបុគ្គលដែលមានទ្រព្យសម្បត្តិនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

ពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងច្បាប់នេះ មានន័យដូចខាងក្រោម :

១-ក្ស័យធន សំដៅដល់ស្ថានភាពរបស់ពាណិជ្ជករ ឬ នីតិបុគ្គលមិនអាចទូទាត់សងបំណុលបាន ហើយត្រូវបានប្រកាសបញ្ជាក់ដោយតុលាការ ។

២-សិទ្ធិលើបំណុល សំដៅដល់សិទ្ធិទទួលការទូទាត់សងពីកូនបំណុល ឬ ការទូទាត់ពីទ្រព្យសកម្មរបស់កូនបំណុលដែលកើតមានឡើងមុនពេលបើកសំណុំរឿងក្ស័យធន ដោយមិនគិតថាសិទ្ធិលើបំណុលនោះមានលក្ខខណ្ឌមិនទាន់ទូទាត់បាន ឬ មានភាពបន្ទាន់ឡើយ លើកលែងតែច្បាប់ចែងច្បាស់ថាជាសិទ្ធិលើបំណុលខាងរដ្ឋបាល ។

៣-ក្រុមហ៊ុនមូលធន សំដៅដល់ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិតរួមមាន ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលបង្កើតឡើងក្រោមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ។

៤-ថ្លៃចំណាយក្នុងសំណុំរឿង និងថ្លៃចំណាយក្នុងការបន្តសំណុំរឿង សំដៅដល់ប្រាក់ប្រដាប់ក្តី ថ្លៃចំណាយ និងប្រាក់បំណាច់ថ្លៃឈ្នួលនិងការចំណាយរបស់អភិបាលបណ្តោះអាសន្ន ។

៥-តុលាការ សំដៅដល់តុលាការនៃព្រះរាជាណាចក្រកម្ពុជាហើយមានយុត្តាធិការលើសំណុំរឿងក្ស័យធនតាមអំណាចនៃច្បាប់នេះ ។

៦-ក្រុមហ៊ុនសហកម្មសិទ្ធិ សំដៅដល់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ឬ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតដែលបង្កើតឡើងតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ។

៧-បុគ្គលដែលពាក់ព័ន្ធសំដៅដល់ :

ក-ម្ចាស់ភាគហ៊ុន អភិបាល សហកម្មសិទ្ធិករ ឬ អ្នកចាត់ចែងការរបស់កូនបំណុល ក្នុងករណីដែលកូនបំណុលមិនមែនជារូបវន្តបុគ្គល

ខ-សហព័ន្ធរបស់កូនបំណុល ឬ សហព័ន្ធរបស់ម្ចាស់ភាគហ៊ុន អភិបាល សហកម្មសិទ្ធិករ ឬ អ្នកចាត់ការរបស់កូនបំណុល ក្នុងករណីដែលកូនបំណុលមិនមែនជារូបវន្តបុគ្គល

គ-បុព្វញាតិ ឬ បច្ឆាញាតិរបស់កូនបំណុល ឬ របស់បុគ្គលដូចបានរៀបរាប់ក្នុងចំណុច ក និងចំណុច ខ ខាងលើ

ឃ-សហព័ន្ធរបស់បុគ្គលដូចបានរៀបរាប់ក្នុងចំណុច គ ខាងលើ

ង-កូនបង្កើតរបស់សហព័ន្ធរបស់កូនបំណុល ឬ របស់បុគ្គលណាមួយដូចបានរៀបរាប់ក្នុងចំណុច ក ដល់ចំណុច ឃ ខាងលើ

ច-បុគ្គលដូចបានរៀបរាប់ក្នុងចំណុច ក ដល់ចំណុច ង នៃមាត្រានេះកាន់កាប់ភាគហ៊ុនច្រើនជាង ៥% (ប្រាំភាគរយ) នៃភាគហ៊ុន ឬ ជាអភិបាល ឬ ជាអ្នកចាត់ចែងការ

ឆ-ក្រុមហ៊ុនសហកម្មសិទ្ធិ ដែលបុគ្គលដូចបានរៀបរាប់ក្នុងចំណុច ក ដល់ចំណុច ង នៃមាត្រានេះជាសហកម្មសិទ្ធិករ ឬ ជាអ្នកចាត់ចែងការ

ជ-នីតិបុគ្គលដែលបង្កើតឡើងតាមច្បាប់បរទេស ដែលបុគ្គលដូចបានរៀបរាប់ក្នុងចំណុច ក ដល់ចំណុច ង នៃមាត្រានេះ កាន់កាប់ដើមទុន លើសពី ៥% (ប្រាំភាគរយ) ឬ ជាអភិបាល ឬ ជាអ្នកចាត់ចែងការ ឬ ជាសហកម្មសិទ្ធិករ

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS

ឈ-ជនដែលរស់នៅក្នុងគ្រួសាររបស់កូនបំណុល ក្នុងករណីដែលកូនបំណុលជារូបវន្តបុគ្គល

ញ-រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលតាមមូលហេតុវិជ្ជាជីវៈ ឬ ទំនាក់ទំនងពាណិជ្ជកម្មជាមួយកូនបំណុល បុគ្គលនេះមានលទ្ធភាពប្រើព័ត៌មានសម្ងាត់ស្ដីពីកិច្ចការពាណិជ្ជកម្ម ឬ ហិរញ្ញវត្ថុរបស់កូនបំណុល

ដ-ម្ចាស់បំណុលដែលទាមទារពីកូនបំណុល ដែលមានតម្លៃលើសពី ៥% (ប្រាំភាគរយ) នៃសិទ្ធិលើបំណុលសរុបរបស់ម្ចាស់បំណុលទាំងអស់ប្រឆាំងនឹងកូនបំណុល ។

៨-ម្ចាស់បំណុល សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលមានសិទ្ធិទាមទារសំណងពីកូនបំណុល ឬ ពីទ្រព្យសម្បត្តិរបស់កូនបំណុល ។

៩-ម្ចាស់បំណុលមានកិច្ចធានា សំដៅដល់ម្ចាស់បំណុលដែលមានសិទ្ធិលើទ្រព្យដែលកូនបំណុលបានដាក់ធានាកាតព្វកិច្ច ។ ម្ចាស់បំណុលនេះ មានសិទ្ធិជាអាទិភាពក្នុងការទទួលសំណងមុនម្ចាស់បំណុលផ្សេងទៀត ។

១០-កូនបំណុល សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលក្ស័យធន ។

១១-ការទូទាត់ជម្រះ សំដៅដល់បើម្ចាស់បំណុលក្លាយជាកូនបំណុលវិញដោយថែជន្យភាគីទាំង២អាចធ្វើការទូទាត់ជម្រះកាតព្វកិច្ចរៀងៗខ្លួនដោយកាត់កងបំណុលទៅវិញទៅមក ។

១២-គណៈកម្មការម្ចាស់បំណុល សំដៅដល់គណៈកម្មការតែងតាំងដោយម្ចាស់បំណុលក្នុងចំណោមម្ចាស់បំណុល ដើម្បីបំពេញការងារតំណាងឱ្យផលប្រយោជន៍របស់ម្ចាស់បំណុលទាំងមូល ។

**មាត្រា ៥.-**

១-បណ្ដឹងឧបាស្រ័យ ឬ បណ្ដឹងជំទាស់ មិនមានអានុភាពផ្អាកការអនុវត្តសេចក្ដីសម្រេចរបស់តុលាការលើបណ្ដឹងសុំបើកសំណុំរឿងក្ស័យធនឡើយ ។

២-ប្រសិនបើច្បាប់នេះមិនមានចែងពីបទប្បញ្ញត្តិពិសេសទេ បទប្បញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីត្រូវយកមកអនុវត្ត ។

## ជំពូកទី ២
## ការបើកសំណុំរឿងក្ស័យធន
## កម្មវត្ថុ មូលហេតុ និងបណ្តឹង

**មាត្រា ៦.-**

១-ភាគីដែលមានផលប្រយោជន៍អាចប្តឹងសុំបើកសំណុំរឿងក្ស័យធនតាមច្បាប់នេះ ទល់នឹងកូនបំណុលដែលជាពាណិជ្ជករ និងជានីតិបុគ្គលដូចខាងក្រោម :

ក-ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ នីតិបុគ្គលដែលបង្កើតឡើង តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា

ខ-រូបវន្តបុគ្គលដែលមានលំនៅឋាន និងទ្រព្យសម្បត្តិនៅក្នុងព្រះរាជាណាចក្រកម្ពុជា

គ-ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ នីតិបុគ្គល ដែលបង្កើតឡើងតាមច្បាប់បរទេស ដែលមានទ្រព្យសម្បត្តិនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ឃ-រូបវន្តបុគ្គលដែលមានលំនៅឋានក្រៅព្រះរាជាណាចក្រកម្ពុជា ដែលមានទ្រព្យសម្បត្តិនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២-សំណុំរឿងក្ស័យធនដែលបើកតាមច្បាប់នេះទល់នឹងបុគ្គល ឬ ក្រុមហ៊ុនសហកម្មសិទ្ធិដែលបានកំណត់ក្នុងចំណុចទី ១.គ និង ១.ឃ នៃមាត្រានេះត្រូវអនុវត្តចំពោះតែទ្រព្យសម្បត្តិរបស់បុគ្គល ឬ ក្រុមហ៊ុនសហកម្មសិទ្ធិ ដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមានទីស្នាក់ការកណ្តាលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ទ្រព្យសម្បត្តិខាងក្រោមនេះត្រូវចាត់ទុកថាស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា :

ក-រូបទ្រព្យដែលស្ថិតនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា

ខ-ទ្រព្យសម្បត្តិ និងសិទ្ធិលើកម្មសិទ្ធិ ឬ សិទ្ធិផ្សេងៗទៀតដែលតម្រូវឱ្យចុះបញ្ជីតាមច្បាប់ ឬតាមបទដ្ឋានគតិយុត្តិនៃព្រះរាជាណាចក្រកម្ពុជា ។

៣-សំណុំរឿងក្ស័យធនមិនអាចត្រូវបានបើកតាមច្បាប់នេះ ទល់នឹងកូនបំណុល ឬ កូនបំណុលដែលជាបុគ្គលស្ថិតនៅក្រោមវិសាលភាពនៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិង

ហិរញ្ញវត្ថុ ច្បាប់ស្តីពីការធានាភិបាល និងច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន លើកលែងតែមានបទប្បញ្ញត្តិចែងក្នុងច្បាប់ទាំងនោះ ។

**មាត្រា ៧.-**

១-សំណុំរឿងក្ស័យធនប្តឹងដោយកូនបំណុល ឬ ដោយម្ចាស់បំណុលម្នាក់ ឬ ច្រើននាក់ ក្នុងករណីដែលកូនបំណុលមិនបានបំពេញកាតព្វកិច្ចមួយ ឬ ច្រើនដែលមានសុពលភាព និងដល់កាលកំណត់សងដែលមានទឹកប្រាក់សរុបចំនួន ៥.០០០.០០០ (ប្រាំលាន) រៀល គឺជាមូលហេតុនៃការបើកសំណុំរឿងក្ស័យធនទល់នឹងកូនបំណុលនោះ លើកលែងតែកាតព្វកិច្ចទាំងឡាយដែលនាំឱ្យមានបណ្តឹងទាមទារដូចបានកំណត់ក្នុងមាត្រា ៣៦ ចំណុច ៣ រហូតដល់ចំណុច ៩ នៃច្បាប់នេះ ។

២-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចសម្រេចកែប្រែចំនួនប្រាក់កាតព្វកិច្ចអប្បបរមាដែលជាមូលហេតុនៃការបើកសំណុំរឿងក្ស័យធនដូចបានចែងក្នុងចំណុចទី ១ ខាងលើបាន ។

**មាត្រា ៨.-**

១-បណ្តឹងសុំបើកសំណុំរឿងក្ស័យធនអាចត្រូវបានធ្វើឡើងដោយកូនបំណុល ម្ចាស់បំណុលម្នាក់ ឬ ច្រើននាក់ អភិបាលក្រុមហ៊ុនមូលធន ឬ តំណាងអយ្យការ ។

២-បណ្តឹងសុំបើកសំណុំរឿងក្ស័យធនត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងចុះហត្ថលេខាដោយអ្នកប្តឹង ។ បណ្តឹងសុំនេះត្រូវសរសេរបញ្ជាក់ពីព័ត៌មានដូចខាងក្រោម :

ក-ឈ្មោះ និងអាសយដ្ឋានរបស់កូនបំណុល

ខ-ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង

គ-មូលហេតុតាមមាត្រា ៧ នៃច្បាប់នេះ ដែលជាបង្អែកនៃបណ្តឹង

ឃ-សេចក្តីបញ្ជាក់អំពីកាលៈទេសៈដែលនាំឱ្យមានមូលហេតុនៃបណ្តឹង

ង-ភស្តុតាងជាបង្អែកនៃបណ្តឹង រាប់បញ្ចូលទាំងរាល់ឯកសារភ្ជាប់ដែលអាចផ្តល់ទម្ងន់ដល់បណ្តឹង

ច-បញ្ជីរាយនាមម្ចាស់បំណុលទាំងអស់របស់កូនបំណុលបញ្ជាក់ឱ្យបានច្បាស់នូវឈ្មោះ អាសយដ្ឋានរបស់ម្ចាស់បំណុល និងទឹកប្រាក់ដែលគេទាមទារ ក្នុងករណីដែលសំណុំរឿងស្នើឡើងដោយកូនបំណុល ។

៣-ការពិនិត្យពាក្យបណ្ដឹង ការបង់ប្រាក់ប្រដាប់ក្ដី ការដាក់ប្រាតិភោគលើបណ្ដឹង ត្រូវអនុលោមតាមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**មាត្រា ៩.-**

១-ក្នុងករណីដែលកូនបំណុលលែងមានលទ្ធភាពបំពេញកាតព្វកិច្ចបង់ប្រាក់ដូចបានចែងក្នុងមាត្រា ៧ ដែលដល់កាលកំណត់អនុវត្ត និងនៅមានសុពលភាពក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃគិតចាប់ពីកាលបរិច្ឆេទត្រូវសង កូនបំណុលនោះត្រូវដាក់ពាក្យបណ្ដឹងបើកសំណុំរឿងក្ស័យធនទល់នឹងខ្លួនឯង ។

២-ក្នុងករណីដែលកូនបំណុលជារូបវន្តបុគ្គល កូនបំណុលនេះត្រូវមានកាតព្វកិច្ចធានាឱ្យបណ្ដឹងសុំបើកសំណុំរឿងក្ស័យធននេះ ស្របតាមចំណុចទី ១ ខាងលើ ។ ក្នុងករណីដែលកូនបំណុលជាក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ក្រុមហ៊ុនមូលធន ផ្អែកតាមករណីនីមួយៗ អភិបាល សហកម្មសិទ្ធិករ ឬ អ្នកចាត់ការគ្រប់រូប ត្រូវមានកាតព្វកិច្ចធានាឱ្យបណ្ដឹងសុំបើកសំណុំរឿងក្ស័យធននេះ ស្របតាមចំណុចទី ១ ខាងលើ ។

៣-បុគ្គលទាំងឡាយណាដែលមិនបានបំពេញកាតព្វកិច្ចដែលចែងក្នុងចំណុចទី ២ ខាងលើដោយចេតនា ឬ ដោយការធ្វេសប្រហែសក្ដី ត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនចំពោះម្ចាស់បំណុលម្នាក់ ឬ ច្រើននាក់របស់កូនបំណុលលើការខូចខាតដែលកើតឡើងដោយផ្ទាល់ពីការខកខាននោះ ។ បើកាតព្វកិច្ចធានាក្នុងចំណុចទី ២ ខាងលើធ្លាក់ទៅលើបុគ្គលច្រើននាក់ បុគ្គលដែលមានចេតនា ឬ មានការធ្វេសប្រហែសទាំងនេះត្រូវទទួលខុសត្រូវរួមគ្នាផង និងដាច់ដោយឡែកពីគ្នាផង ចំពោះការខូចខាតដែលកើតឡើងដោយផ្ទាល់ពីការមិនបានបំពេញកាតព្វកិច្ចនោះ ។ បើសំណុំរឿងក្ស័យធននេះត្រូវបានប្ដឹងទល់នឹងកូនបំណុល ការខូចខាតនេះ ត្រូវរាប់បញ្ចូលជាទ្រព្យសម្បត្តិ ហើយអភិបាលបណ្ដោះអាសន្នត្រូវចាត់វិធានការក្នុងនាមម្ចាស់បំណុលទាំងអស់ដើម្បីទារសំណងខូចខាតទាំងនេះ ។

**មាត្រា ១០.-**

តុលាការត្រូវផ្ញើពាក្យបណ្ដឹងសុំបើកសំណុំរឿងក្ស័យធនរបស់ម្ចាស់បំណុល ឬ របស់អភិបាលក្រុមហ៊ុនមូលធន ឬ តំណាងអយ្យការឱ្យទៅកូនបំណុល មិនឱ្យលើសពីរយៈពេល ៣ (បី)ថ្ងៃ នៃថ្ងៃធ្វើការចាប់ពីថ្ងៃបណ្ដឹងនោះ ចូលដល់តុលាការ ។

9/47

**មាត្រា ១១.-**

១-ចាប់ពីពេលដាក់ពាក្យប្ដឹងសុំបើកសំណុំរឿងក្ស័យធនរហូតដល់ពេលតុលាការចេញសេចក្ដីសម្រេចឱ្យបើកសំណុំរឿងក្ស័យធន តុលាការត្រូវចេញសេចក្ដីសម្រេចតែងតាំងអភិបាលបណ្ដោះអាសន្ន តាមពាក្យសុំជាលាយលក្ខណ៍អក្សររបស់កូនបំណុល ម្ចាស់បំណុល អភិបាលក្រុមហ៊ុនមូលធន ឬ តំណាងអយ្យការ ។

២-អភិបាលបណ្ដោះអាសន្នត្រូវចាត់រាល់វិធានការចាំបាច់ ឬ សមស្របដើម្បីការការពារផលប្រយោជន៍របស់ម្ចាស់បំណុល ។ ជាពិសេសបើយល់ឃើញថាចាំបាច់ អភិបាលបណ្ដោះអាសន្នអាចដាក់ពាក្យស្នើសុំទៅតុលាការដើម្បីឃាត់ទុកទ្រព្យសម្បត្តិ ឬ ឃួរបណ្ដឹងទាមទាររបស់ម្ចាស់បំណុលមានកិច្ចធានា ឬ គ្មានកិច្ចធានា ដែលប្ដឹងទល់នឹងកូនបំណុល ឬ ទ្រព្យសកម្ម ក្នុងទ្រព្យសម្បត្តិរបស់កូនបំណុល ។

៣-រាល់សេចក្ដីសម្រេចរបស់តុលាការដែលសម្រេចតាមចំណុចទី ១ និងចំណុចទី ២ នៃមាត្រានេះ ត្រូវជូនដំណឹងដល់ភាគីពាក់ព័ន្ធ និងផ្សព្វផ្សាយជាសាធារណៈតាមសារព័ត៌មានប្រចាំថ្ងៃ ។

## ជំពូកទី ៣

## សេចក្ដីសម្រេចលើបណ្ដឹងសុំបើកសំណុំរឿងក្ស័យធន

**មាត្រា ១២.-**

១-តុលាការត្រូវបើកសវនាការលើបណ្ដឹងសុំបើកសំណុំរឿងក្ស័យធនរបស់កូនបំណុលឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ក្រោយពីបានទទួលបណ្ដឹងសុំ ហើយទោះជាក្នុងករណីណាក៏ត្រូវបើកសវនាការមិនឱ្យលើសពី ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង ។

២-តុលាការត្រូវបើកសវនាការលើបណ្ដឹងសុំ ដែលធ្វើឡើងដោយម្ចាស់បំណុល អភិបាលក្រុមហ៊ុនមូលធន ឬ តំណាងអយ្យការ មិនឱ្យលើសពី ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង ។

៣- កូនបំណុល ម្ចាស់បំណុល អភិបាលក្រុមហ៊ុនមូលធន ឬ តំណាងអយ្យការមានសិទ្ធិចូលរួមក្នុងសវនាការ ។

**មាត្រា ១៣.-**

១-បន្ទាប់ពីបើកសវនាការលើបណ្តឹងសុំ ប្រសិនបើតុលាការយល់ឃើញថា បណ្តឹងសុំមានមូលហេតុសមស្របនោះ តុលាការត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ដើម្បី ៈ

ក-បើកសំណុំរឿងក្ស័យធនទល់នឹងកូនបំណុល

ខ-តែងតាំងអភិបាលបណ្តោះអាសន្នតាមមាត្រា ១១ នៃច្បាប់នេះ

គ-កំណត់កាលបរិច្ឆេទបើកកិច្ចប្រជុំម្ចាស់បំណុល ចាប់ពី ៣០ (សាមសិប) ថ្ងៃ តែមិនត្រូវលើសពី ៦០(ហុកសិប) ថ្ងៃ បន្ទាប់ពីបើកសំណុំរឿងក្ស័យធន

ឃ-បញ្ជាក់ពីកាលបរិច្ឆេទផុតកំណត់នៃការដាក់ជូនភស្តុតាងនៃបណ្តឹងទាមទារដែលត្រូវមានរយៈពេល៧(ប្រាំពីរ)ថ្ងៃ មុនកាលបរិច្ឆេទបើកកិច្ចប្រជុំម្ចាស់បំណុល ។

២-ក្នុងការកំណត់កាលបរិច្ឆេទបើកកិច្ចប្រជុំម្ចាស់បំណុលនេះ តុលាការត្រូវពិនិត្យថា តើកូនបំណុលបានដាក់ជូនសំណើផែនការសុំសម្របសម្រួលដែលកូនបំណុលអះអាងថា ផែនការនោះមាន ឬ គ្មានការគាំទ្រពីម្ចាស់បំណុល ។

៣-បន្ទាប់ពីបើកសវនាការលើបណ្តឹងសុំ ប្រសិនបើតុលាការយល់ថា គ្មានមូលហេតុសមស្របដែលជាមូលដ្ឋាននៃបណ្តឹងនេះ ឬ បើបណ្តឹងនេះធ្វើឡើងដោយកូនបំណុល ឬ ម្ចាស់បំណុល ដោយរួមជាមួយកូនបំណុលគឺជាឧបាយកល ឬ មានបំណងទុច្ចរិត តុលាការត្រូវសម្រេចលើកបណ្តឹងសុំនេះចោល ។

៤-តុលាការត្រូវចេញសេចក្តីសម្រេចបង្គាប់ឱ្យបើកសំណុំរឿងក្ស័យធន ឬ លើកបណ្តឹងសុំក្នុងរយៈពេលមិនលើសពី ១៤(ដប់បួន) ថ្ងៃ បន្ទាប់ពីបញ្ចប់សវនាការលើបណ្តឹងសុំ ។

៥-កូនបំណុល ឬ ម្ចាស់បំណុលអាចប្តឹងជំទាស់ចំពោះសេចក្តីសម្រេចរបស់តុលាការក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលដំណឹងអំពីសេចក្តីសម្រេចនោះ ។

**មាត្រា ១៤.-**

១-នៅពេលចេញសេចក្តីសម្រេចបង្គាប់ឱ្យបើកសំណុំរឿងក្ស័យធន ឬ នៅពេលណាមួយ បន្ទាប់ពីបានចេញសេចក្តីសម្រេចនេះ តុលាការត្រូវបង្គាប់ឱ្យជម្រះបញ្ជីលើអាជីវកម្ម

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

11/4?
-ទៀត

របស់កូនបំណុល ប្រសិនបើតុលាការយល់ថាអាជីវកម្មរបស់កូនបំណុលពីមុនមិនអាចនឹងមាននីតិសម្បទាឡើងវិញ ហើយមិនអាចមានការឯកភាពលើផែនការសម្របសម្រួល ។

២-តុលាការអាចចេញសេចក្តីសម្រេចបង្គាប់ឱ្យជម្រះបញ្ជីតាមចំណុចទី ១ ឬ តាមការស្នើសុំរបស់កូនបំណុល អភិបាលបណ្តោះអាសន្ន ម្ចាស់បំណុល អភិបាលក្រុមហ៊ុនមូលធន ឬ តំណាងអយ្យការ ។

**មាត្រា ១៥.-**

សំណុំរឿងក្ស័យធនត្រូវចាត់ទុកថាបានបើកនៅកាលបរិច្ឆេទដែលតុលាការចេញសេចក្តីសម្រេចបង្គាប់ឱ្យបើកសំណុំរឿងក្ស័យធន ។

**មាត្រា ១៦.-**

១-សំណុំរឿងក្ស័យធនមិនត្រូវបើកឡើយ ហើយបណ្តឹងសុំត្រូវបានលើកចោល បើទ្រព្យសកម្មរបស់កូនបំណុលមានចំនួនមិនគ្រប់គ្រាន់សម្រាប់ធានាការចំណាយក្នុងដំណើរការនៃនីតិវិធី ។

បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ប្រសិនបើមានបុគ្គលពាក់ព័ន្ធណាមួយផ្តល់ប្រាក់គ្រប់គ្រាន់ជាមុនសម្រាប់ធានាការចំណាយក្នុងការប្រព្រឹត្តទៅនៃនីតិវិធី ។

២-បុគ្គលដែលបានផ្តល់ប្រាក់ជាមុនតាមចំណុចទី ១ កថាខណ្ឌទី ២ អាចទាមទារយកប្រាក់នោះវិញពីរូបវន្តបុគ្គលដែលមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងនីតិវិធីបើកសំណុំរឿងក្ស័យធនទល់នឹងកូនបំណុល នៅពេលដែលមានបណ្តឹងសុំបើកសំណុំរឿងក្ស័យធន ។ ការទាមទារយកប្រាក់នោះវិញអាចធ្វើបានក្នុងរយៈពេល ៥(ប្រាំ)ឆ្នាំ គិតចាប់ពីពេលបានផ្តល់ប្រាក់ទៅឱ្យរូបវន្តបុគ្គលនោះ ។ ក្នុងករណីដែលមានវិវាទទាក់ទិននឹងបញ្ហាដែលថារូបវន្តបុគ្គលមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន រូបវន្តបុគ្គលនោះត្រូវផ្តល់ភស្តុតាងថាខ្លួនមិនបានខកខានក្នុងការបំពេញកាតព្វកិច្ចទេ ។



១-នៅពេលបដិសេធបណ្តឹងសុំបើកសំណុំរឿងក្ស័យធន ដោយសារបណ្តឹងសុំនោះគ្មានមូលហេតុសមស្រប តុលាការត្រូវចេញសេចក្តីសម្រេចបង្គាប់ឱ្យអ្នកប្តឹងចេញសងកូនបំណុល ឬ ម្ចាស់បំណុលនូវថ្លៃចំណាយផ្លូវច្បាប់ទាំងអស់ដែលភាគីទាំងឡាយបានចំណាយក្នុងការចូលរួមក្នុងបណ្តឹងសុំនេះ ។

២-បើតុលាការរកឃើញថា បណ្តឹងសុំនេះធ្វើឡើងដោយមានឧបាយកល ឬ បំណងទុច្ចរិត ឬ ដោយចេតនាទំលាក់កំហុសទៅលើកូនបំណុល ឬ ម្ចាស់បំណុល តុលាការសម្រេចបង្គាប់ឱ្យអ្នកប្តឹងទទួលខុសត្រូវចេញសំណងខូចខាត ដែលបង្កឡើងដោយបណ្តឹងសុំនេះ ។

**មាត្រា ១៨.-**

១-សេចក្តីសម្រេចបង្គាប់ឱ្យបើកសំណុំរឿងក្ស័យធនត្រូវចុះផ្សាយជាសាធារណៈក្នុងសារព័ត៌មានប្រចាំថ្ងៃ និងត្រូវជូនដំណឹងទៅការិយាល័យចុះបញ្ជី និងការិយាល័យតម្កល់ព័ត៌មានដែលគ្រប់គ្រងសិទ្ធិប្រាតិភោគឱ្យឆាប់បំផុតផងដែរ ។

២-ក្នុងរយៈពេលមិនលើសពី ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីការបើកសំណុំរឿងក្ស័យធនអភិបាលបណ្តោះអាសន្នត្រូវធ្វើការជូនដំណឹងរួមទាំងការចុះផ្សាយក្នុងសារព័ត៌មានប្រចាំថ្ងៃ យ៉ាងហោចណាស់ពីរ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយប្រកាសពីព័ត៌មានដូចខាងក្រោមនេះ :

ក-បញ្ជាក់ថាសំណុំរឿងក្ស័យធនត្រូវបានបើកទល់នឹងកូនបំណុល

ខ-ថ្ងៃផុតកំណត់សម្រាប់ការដាក់ជូនភស្តុតាងនៃបណ្តឹងទាមទារ ជាលាយលក្ខណ៍អក្សរ និងអាសយដ្ឋានដែលត្រូវបញ្ជូនភស្តុតាងនៃបណ្តឹងទាមទារជាលាយលក្ខណ៍អក្សរនេះទៅឱ្យ

គ-ប្រកាសពីពេលវេលា និងទីកន្លែងបើកកិច្ចប្រជុំម្ចាស់បំណុល ។

៣-ក្នុងរយៈពេលមិនលើសពី ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីអភិបាលបណ្តោះអាសន្នបានទទួលសេចក្តីប្រកាសរបស់កូនបំណុលដែលបានធ្វើឡើងស្របតាមមាត្រា ២៩ នៃច្បាប់នេះ អភិបាលបណ្តោះអាសន្នត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ម្ចាស់បំណុលទាំងអស់ដែលមានឈ្មោះក្នុងសេចក្តីប្រកាសនោះ ដូចមានចែងក្នុងចំណុចទី ២-ក ដល់ចំណុចទី ២-គ នៃមាត្រានេះ ។

13/47

## ជំពូកទី ៤
## អានុភាពនៃការបើកសំណុំរឿងក្ស័យធន
### ផ្នែកទី ១
### អានុភាពទូទៅ

**មាត្រា ១៩.-**

១-បន្ទាប់ពីតុលាការសម្រេចបង្គាប់ឱ្យបើកសំណុំរឿងក្ស័យធន និង រហូតទាល់តែសំណុំរឿងក្ស័យធននេះត្រូវបានបញ្ចប់ តុលាការត្រូវព្យួរដំណើរការក្តី ឬ នីតិវិធី ឬ បណ្តឹងផ្សេងទៀតទោះក្នុងរូបភាពណាក៏ដោយ ដែលធ្វើឡើងដោយម្ចាស់បំណុល ឬ ក្នុងនាមម្ចាស់បំណុលទល់នឹងកូនបំណុល ឬ ទ្រព្យសកម្មរបស់កូនបំណុល ។

២-ក្នុងករណីដែលយល់ឃើញថាទ្រព្យសម្បត្តិរបស់កូនបំណុលនៅមានផលប្រយោជន៍ អភិបាលបណ្តោះអាសន្នអាចអនុញ្ញាតជាលាយលក្ខណ៍អក្សរឱ្យម្ចាស់បំណុលយកទ្រព្យដែលដាក់ធានាតាមហ៊ីប៉ូតែកទៅកាន់កាប់ និងលក់ទ្រព្យធានាដោយអនុវត្តតាមច្បាប់ជាធរមាន ឬ អនុញ្ញាតឱ្យម្ចាស់បំណុលនេះ ប្រើប្រាស់ទ្រព្យធានាតាមមធ្យោបាយផ្សេង ដោយតម្រូវឱ្យម្ចាស់បំណុលទទួលការទូទាត់រំលោះបំណុលពីការប្រើប្រាស់នោះ ។

៣-ក្នុងករណីសំណុំរឿងក្ស័យធនត្រូវបានបើកទល់នឹងកូនបំណុល ដែលជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ការព្យួរពាក្យបណ្តឹងក្នុងចំណុចទី ១ នៃមាត្រានេះ
ក៏ត្រូវអនុវត្តចំពោះ រាល់បណ្តឹង ដំណើរការក្តី ឬ
នីតិវិធីអនុវត្តលើបំណុលរបស់កូនបំណុលព្រមទាំងទ្រព្យសម្បត្តិ
រៀងៗខ្លួនរបស់សហកម្មសិទ្ធិករ ។

ក្នុងករណីសំណុំរឿងក្ស័យធនទល់នឹងកូនបំណុលដែលជាក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ការព្យួរពាក្យបណ្តឹងក្នុងចំណុចទី ១ នៃមាត្រានេះក៏ត្រូវអនុវត្តចំពោះរាល់បណ្តឹង ដំណើរការក្តី ឬ នីតិវិធីអនុវត្តលើបំណុលរបស់កូនបំណុលព្រមទាំងទ្រព្យសម្បត្តិរៀងៗខ្លួនរបស់សហកម្មសិទ្ធិករទូទៅ ។

មានតែអភិបាលបណ្តោះអាសន្នទេ ដែលអាចទាមទារឱ្យសហកម្មសិទ្ធិករទទួលខុសត្រូវផ្ទាល់ខ្លួនលើបំណុលនៃកូនបំណុល ក្នុងកំឡុងពេលដំណើរការសំណុំរឿងក្ស័យធន ។

៤-ការព្យួរបណ្តឹងតាមចំណុចទី ១ នៃមាត្រានេះ មិនត្រូវអនុវត្តចំពោះបណ្តឹងទាមទារចំណាយខាងរដ្ឋបាលទាក់ទិននឹងប្រាក់បំណាច់ថ្លៃឈ្នួល និងថ្លៃចំណាយរបស់អភិបាលបណ្តោះអាសន្ន និងបណ្តឹងទាមទារចំណាយខាងរដ្ឋបាលផ្សេងទៀត ដែលធ្វើឡើងដោយអភិបាលបណ្តោះអាសន្នឡើយ ។

**មាត្រា ២០.-**

១-ការបើកសំណុំរឿងក្ស័យធន ត្រូវកំណត់ពីទ្រព្យនៃកូនបំណុល ។

២-ទ្រព្យនៃកូនបំណុលត្រូវរាប់បញ្ចូលទាំងរាល់ទ្រព្យសកម្ម សិទ្ធិ និងសិទ្ធិលើបំណុលគ្រប់ប្រភេទ ដែលកូនបំណុលមានផលប្រយោជន៍ពីកម្មសិទ្ធិ ឬ ផលប្រយោជន៍ផ្សេងទៀត ដែលកូនបំណុលមានសិទ្ធិទទួលនៅកាលបរិច្ឆេទបើកសំណុំរឿងក្ស័យធន ឬ បន្ទាប់ពីកាលបរិច្ឆេទនោះ ។

៣-ក្នុងករណីដែលកូនបំណុលជារូបវន្តបុគ្គល ទ្រព្យសម្បត្តិដូចខាងក្រោមមិនត្រូវរាប់បញ្ចូលជាទ្រព្យនៃកូនបំណុលទេ :

ក-ទីកន្លែងដែលជាលំនៅឋានចម្បងរបស់កូនបំណុល ដែលមានតម្លៃមិនលើសពី ២០.០០០.០០០ (ម្ភៃលាន) រៀល តាមតម្លៃទីផ្សារ

ខ-ទ្រព្យសកម្ម សិទ្ធិ ឬ សិទ្ធិលើបំណុលដែលក្រមនីតិវិធីរដ្ឋប្បវេណីលើកលែងមិនឱ្យអនុវត្តប្រឆាំងនឹងកូនបំណុល ។

**មាត្រា ២១.-**

ទ្រព្យនៃកូនបំណុលត្រូវស្ថិតនៅក្រោមការចាត់ចែង និងសិទ្ធិអំណាចរបស់អភិបាលបណ្តោះអាសន្ន ។

**មាត្រា ២២.-**

កូនបំណុលត្រូវសហការជាមួយអភិបាលបណ្តោះអាសន្នឱ្យអស់ពីសមត្ថភាព និងត្រូវផ្តល់ជូនអភិបាលបណ្តោះអាសន្ននូវព័ត៌មានចាំបាច់ទាំងអស់ ដែលទាក់ទិននឹងអាជីវកម្មរបស់ខ្លួន ។

មាត្រា ២៣.-

១-ដើម្បីបំពេញភារកិច្ចរបស់ខ្លួន និងកិច្ចការផ្សេងទៀត អភិបាលបណ្ដោះអាសន្ន ត្រូវមានសិទ្ធិអំណាចដូចខាងក្រោមនេះ :

ក-ធ្វើជាតំណាងកូនបំណុល និងចាត់ចែងអាជីវកម្មរបស់កូនបំណុលក្នុងសំណុំរឿងក្ស័យធន

ខ-ទទួលសំណុំលិខិតរបស់កូនបំណុលតាមប្រៃសណីយ៍ និងតាមប្រព័ន្ធអេឡិចត្រូនិកដែលផ្ញើជូនកូនបំណុល លើកលែងតែសំបុត្រ និងលិខិតទាក់ទងដែលមានលក្ខណៈ ឯកជនទាំងស្រុង

គ-អនុវត្តបន្តអាជីវកម្មរបស់កូនបំណុល ប៉ុន្តែចំពោះតែវិសាលភាពដែលចាំបាច់ដើម្បីសម្រេចគោលបំណងនៃសំណុំរឿងក្ស័យធន

ឃ-ទទួលទ្រព្យសកម្មរបស់កូនបំណុល រាប់បញ្ចូលទាំងបញ្ជីគណនេយ្យ និងឯកសាររបស់កូនបំណុល

ង-ប្រមូល និងបញ្ចូលក្នុងទ្រព្យរបស់កូនបំណុលនូវទឹកប្រាក់ ដែលនៅជំពាក់ពីការលក់ភាគហ៊ុនរបស់កូនបំណុល ឬ ការផ្ទេរភាគទុនដែលសហកម្មសិទ្ធិករមិនទាន់បង់ជូនកូនបំណុល

ច-ប្រើប្រាស់ និងយកទ្រព្យសកម្មរបស់កូនបំណុលធ្វើពាណិជ្ជកម្ម រាប់បញ្ចូលទាំងការលក់ទ្រព្យសកម្ម ដែលគ្មានជាប់សិទ្ធិពីទ្រព្យធានា និងការជួលឡើ

ឆ-ទទួលបន្ទុកជាតំណាងកូនបំណុលដែលជាភាគីក្នុងការដោះស្រាយសំណុំរឿងក្នុងតុលាការ

ជ-រៀបចំបញ្ជីនៃការទាមទារបំណុល

ឈ-អនុញ្ញាតឱ្យម្ចាស់បំណុលលក់ទ្រព្យសកម្មដែលជាកម្មវត្ថុនៃសិទ្ធិលើទ្រព្យធានារបស់ម្ចាស់បំណុលដោយអនុវត្តតាមច្បាប់ជាធរមាន ហើយយកថ្លៃលក់ទ្រព្យសកម្មនោះមកទូទាត់បណ្ដឹងទាមទាររបស់ម្ចាស់បំណុល

ញ-រក្សាទុកដោយឡែកនូវទ្រព្យសកម្មដែលបង្កការស្មុគស្មាញដល់ទ្រព្យរបស់កូនបំណុល

ROYAUME DU CAMBODGE * LE JOURNAL OFFICIEL ROYAL

ជ-ស្នើសុំឱ្យតុលាការពិនិត្យរាល់បញ្ហារបស់បុគ្គល ដែលទាក់ទិននឹងអាជីវកម្មរបស់កូនបំណុល

ឋ-បញ្ឈប់ លុបចោល ឬ ប្រកាសមោឃភាព នូវប្រតិបត្តិការអាជីវកម្ម កិច្ចសន្យា កិច្ចព្រមព្រៀង ឬ លិខិតផ្ទេរកម្មសិទ្ធិ ដែលកូនបំណុលជាភាគី ដោយអនុលោមតាមច្បាប់នេះ ឬ ច្បាប់ផ្សេងទៀត

ឌ-កោះប្រជុំ និងរៀបចំកិច្ចប្រជុំម្ចាស់បំណុល ដូចមានចែងក្នុងច្បាប់នេះ

ឍ-រៀបចំនិងលើកសំណើផែនការសម្របសម្រួល បើមានការចាំបាច់

ណ-ជួលភ្នាក់ងារ និងអ្នកមានវិជ្ជាជីវៈ ដើម្បីបម្រើកិច្ចការជាជំនួយការក្នុងភារកិច្ចរបស់ខ្លួន

ត-ធ្វើគ្រប់សកម្មភាពផ្សេងទៀត ដែលចាំបាច់ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ដែលស្របតាមគោលបំណងនៃសំណុំរឿងក្ស័យធន ។

២-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចចេញប្រកាសដើម្បីបំពេញបន្ថែមបទប្បញ្ញត្តិស្តីពីសិទ្ធិអំណាចរបស់អភិបាលបណ្តោះអាសន្នក្នុងចំណុចទី ១ នៃមាត្រានេះ ។

**មាត្រា ២៥.-**

១-ចាប់ពីថ្ងៃដែលត្រូវបានតែងតាំងរហូតដល់ពេលបើកកិច្ចប្រជុំម្ចាស់បំណុល អភិបាលបណ្តោះអាសន្នត្រូវ :

ក-បន្តអាជីវកម្មរបស់កូនបំណុល ប្រសិនបើអាជីវកម្មនេះអាចបន្តបានហើយនៅមានផលប្រយោជន៍សេដ្ឋកិច្ច

ខ-សិក្សា និងវិភាគពីស្ថានភាពហិរញ្ញវត្ថុ និងសេដ្ឋកិច្ចរបស់កូនបំណុល និងលទ្ធភាពនៃការស្តារនីតិសម្បទាឡើងវិញរបស់កូនបំណុល និង រៀបចំរបាយការណ៍ដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់នេះ ។

២-ក្នុងការបំពេញភារកិច្ចរបស់ខ្លួន អភិបាលបណ្តោះអាសន្នត្រូវប្រើប្រាស់ បទពិសោធន៍ ព័ត៌មាន និងឯកសារគ្រប់គ្រងរបស់កូនបំណុលតាមដែលអាចធ្វើទៅបាន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា ២៥.—**

១-អភិបាលបណ្តោះអាសន្ន ត្រូវមានការយល់ព្រមពីម្ចាស់បំណុល តាមរយៈកិច្ចប្រជុំម្ចាស់បំណុលមុននឹងធ្វើសកម្មភាពដូចខាងក្រោម :

ក-លក់អចលនទ្រព្យរបស់កូនបំណុលតាមកិច្ចសន្យាឯកជន

ខ-លក់ ឬ ផ្ទេរទ្រព្យសម្បត្តិណាមួយរបស់កូនបំណុលទៅឱ្យបុគ្គលដែលពាក់ព័ន្ធ ទោះជាតាមមធ្យោបាយណាក្តី

គ-អនុវត្តប្រតិបត្តិការណាមួយដែលអាចប៉ះពាល់ដល់ការអនុម័ត ឬ ការអនុវត្តផែនការសម្របសម្រួល ។

២-រាល់ប្រតិបត្តិការដែលបានអនុវត្តផ្ទុយពីចំណុចទី១ ក និង ខ នៃមាត្រានេះ ត្រូវចាត់ទុកជាការរំលោភលើភារកិច្ចរបស់អភិបាលបណ្តោះអាសន្ន ហើយនាំឱ្យអភិបាលបណ្តោះអាសន្ននេះមានការទទួលខុសត្រូវផ្ទាល់ខ្លួន ចំពោះការខូចខាតដល់ទ្រព្យសម្បត្តិរបស់កូនបំណុល ឬ ដល់ភាគីណាមួយក្នុងរឿងក្តីនេះ ។

**មាត្រា ២៦.—**

១-ក្នុងរយៈពេលមិនលើសពី ៣០(សាមសិប) ថ្ងៃ បន្ទាប់ពីការបើកសំណុំរឿងក្ស័យធន អភិបាលបណ្តោះអាសន្នត្រូវកំណត់តម្លៃលើទ្រព្យធានាដែលកាន់កាប់ដោយម្ចាស់បំណុល ដែលកូនបំណុលបានដាក់បញ្ចាំតាមគោលការណ៍សុចរិត ។ ការវាយតម្លៃរបស់អភិបាលបណ្តោះអាសន្ន ត្រូវចាត់ទុកជាការកំណត់តម្លៃត្រឹមត្រូវលើផ្នែកដែលមានកិច្ចធានានៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល លើកលែងតែមានការតវ៉ាពីកូនបំណុល ឬ ម្ចាស់បំណុល ។

២-សិទ្ធិលើបំណុលរបស់ម្ចាស់បំណុលដែលលើសពីតម្លៃ ដែលបានកំណត់ក្នុងចំណុចទី ១ នៃមាត្រានេះ ឬ មិនទាន់ទូទាត់គ្រប់បន្ទាប់ពីការយកថ្លៃលក់ទ្រព្យធានាមកសង ត្រូវមានសិទ្ធិទទួលការទូទាត់ពីសំណុំរឿងក្ស័យធនដូចគ្នានឹងសិទ្ធិលើបំណុលដែលគ្មានកិច្ចធានាដែរ ។ បញ្ញត្តិនេះមិនអនុវត្តទេបើទ្រព្យធានាត្រូវបានកូនបំណុលផ្តល់សម្រាប់ធានាបំណុលរបស់បុគ្គលណាមួយដែលមិនមែនជាកូនបំណុល ។

ROYAUME DU CAMBODGE • LE MINISTÈRE DU PALAIS ROYAL

៣-មុនពេលផុតរយៈពេល ៣០(សាមសិប)ថ្ងៃ ដែលបានកំណត់តាមចំណុចទី ១នៃមាត្រានេះ ការវាយតម្លៃមិនត្រូវអនុវត្តទេប្រសិនបើ :

ក-តុលាការបានបង្គាប់ឱ្យចាប់ផ្តើមជម្រះបញ្ជីលើអាជីវកម្មរបស់កូនបំណុល ឬ

ខ-អភិបាលបណ្តោះអាសន្នបានលក់ ឬ បានអនុញ្ញាតឱ្យម្ចាស់បំណុលលក់ទ្រព្យសកម្មតាមច្បាប់ជាធរមានដែលបានដាក់ធានា ឬ អនុញ្ញាតឱ្យអនុវត្តសិទ្ធិលើទ្រព្យធានា និងយកថ្លៃលក់ទ្រព្យនោះមកទូទាត់សិទ្ធិលើបំណុលរបស់ម្ចាស់បំណុល ។

**មាត្រា ២៧.-**

១-អភិបាលបណ្តោះអាសន្ន ត្រូវបង់ជូនម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគលើទ្រព្យសម្បត្តិរបស់កូនបំណុលនូវការប្រាក់ទាំងអស់ដែលកើតឡើង គិតតាមអត្រាការប្រាក់នៃកិច្ចសន្យាលើទ្រព្យធានា ។ បើសិទ្ធិលើទ្រព្យធានាត្រូវបានផ្តល់ដើម្បីធានាបំណុលរបស់បុគ្គលណាមួយក្រៅពីកូនបំណុល អភិបាលបណ្តោះអាសន្នត្រូវបង់តែការប្រាក់ដែលកើតពីការដាក់ទ្រព្យធានា ប្រសិនបើបុគ្គលនោះគ្មានលទ្ធភាពទូទាត់ប្រាក់ដែលជំពាក់ម្ចាស់បំណុល ។

២-ក្នុងករណីគ្មានអត្រាការប្រាក់កំណត់ក្នុងកិច្ចសន្យា អត្រាការប្រាក់ត្រូវគណនាតាមអត្រាការប្រាក់ទីផ្សារ ។

៣-អត្រាការប្រាក់តាមចំណុចទី ១ នៃមាត្រានេះដែលត្រូវបង់ប្រចាំខែត្រូវអនុវត្តតែនៅពេលផុតរយៈពេល ៣០(សាមសិប) ថ្ងៃ ក្រោយពេលបើកសំណុំរឿងក្ស័យធន ហើយបន្តបង់ក្នុងរយៈពេលដែលអភិបាលបណ្តោះអាសន្នមិនបានលក់ទ្រព្យនោះ ។ ប្រាក់បានពីការលក់ត្រូវបានយកមកទូទាត់សិទ្ធិលើបំណុលរបស់ម្ចាស់បំណុល ។

**មាត្រា ២៨.-**

១-តុលាការអាចសម្រេចថាកូនបំណុលជារូបវន្តបុគ្គល និងគ្រួសាររបស់កូនបំណុលអាចទទួល ឬ មិនអាចទទួលចំណែកពីការថែរក្សាទ្រព្យរបស់កូនបំណុល ។

២-មុនពេលមានសេចក្តីសម្រេចពីតុលាការតាមចំណុចទី ១ ខាងលើ អភិបាលបណ្តោះអាសន្នដោយមានការយល់ព្រមពីគណៈកម្មការម្ចាស់បំណុល អាចដកថ្លៃថែរក្សា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ទ្រព្យកូនបំណុលទៅឱ្យកូនបំណុលដែលជារូបវន្តបុគ្គល និងទៅឱ្យគ្រួសាររបស់កូនបំណុល តាមកម្រិតចាំបាច់សម្រាប់ទ្រទ្រង់ការរស់នៅ ។

មាត្រា ២៩.-

១-យ៉ាងយូរបំផុត ១៤(ដប់បួន)ថ្ងៃ ក្រោយពេលបើកសំណុំរឿងក្ស័យធន កូនបំណុល ត្រូវដាក់ជូនតុលាការ និងអភិបាលបណ្តោះអាសន្ននូវសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរដែលចែងលំអិតអំពី :

ក-ទ្រព្យរបស់កូនបំណុល និង

ខ-ម្ចាស់បំណុលទាំងអស់របស់កូនបំណុល ដោយបញ្ជាក់ពីឈ្មោះម្ចាស់បំណុល អាសយដ្ឋាន និងសេចក្តីបញ្ជាក់សង្ខេបអំពីបំណុលដែលជំពាក់ម្ចាស់បំណុលនីមួយៗ ។

២-កូនបំណុលត្រូវយល់ព្រមឱ្យមានការត្រួតពិនិត្យលើទ្រព្យសម្បត្តិនិងកិច្ចការអាជីវកម្មរបស់ខ្លួន នៅពេលដែលមានសំណើពីអភិបាលបណ្តោះអាសន្ន ឬ តុលាការ ។

## ផ្នែកទី ២

## ការថែរក្សាការពារ និងការពង្រីកទ្រព្យសម្បត្តិរបស់កូនបំណុល

មាត្រា ៣០.-

១-នៅពេលបើកសំណុំរឿងក្ស័យធន បើកិច្ចសន្យារវាងកូនបំណុល និង ភាគីនៃកិច្ចសន្យាមិនទាន់បានអនុវត្តចប់សព្វគ្រប់ដោយកូនបំណុល ឬ ដោយភាគីនៃកិច្ចសន្យា អភិបាលបណ្តោះអាសន្នអាចសម្រេចឱ្យបន្តអនុវត្តកិច្ចសន្យាស្របតាមបទប្បញ្ញត្តិនៃមាត្រានេះ ។

២-អភិបាលបណ្តោះអាសន្នដែលសម្រេចឱ្យបន្តអនុវត្តកិច្ចសន្យាត្រូវតែប្រកាសពីសេចក្តីសម្រេចនេះជាលាយលក្ខណ៍អក្សរជូនភាគីនៃកិច្ចសន្យា ក្នុងរយៈពេល ៣០(សាម សិប)ថ្ងៃ គិតចាប់ពីពេលបើកសំណុំរឿងក្ស័យធន ។

ក្នុងករណីគ្មានសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរដែលចេញដោយអភិបាលបណ្តោះអាសន្នទេ កិច្ចសន្យានឹងត្រូវចាត់ទុកថាបានរំលាយ ហើយភាគីនៃកិច្ចសន្យាអាចដាក់បណ្តឹងសុំទាមទារសំណងខូចខាតក្នុងឋានៈជាម្ចាស់បំណុលក្នុងសំណុំរឿងក្ស័យធន ។ នៅពេលទទួលពាក្យសុំពន្យារពេលជាលាយលក្ខណ៍

អក្សរពីអភិបាលបណ្តោះអាសន្ន តុលាការអាចពន្យារពេលដែលក្នុងរយៈពេលនេះ អភិបាលបណ្តោះអាសន្នត្រូវតែប្រកាសសេចក្តីសម្រេចថាត្រូវបន្ត ឬ មិនត្រូវបន្តកិច្ចសន្យា ។ រាល់ការពន្យារពេលបែបនេះ មិនត្រូវមានរយៈពេលលើសពី ១៤(ដប់បួន)ថ្ងៃឡើយ ។

៣-ភាគីនៃកិច្ចសន្យាក៏អាចធ្វើសំណើជាលាយលក្ខណ៍អក្សរ ជូនអភិបាលបណ្តោះអាសន្នគ្រប់ពេលវេលាបានដែរ ដោយសុំឱ្យអភិបាលបណ្តោះអាសន្នគោរពតាមកិច្ចសន្យានេះ ។ ក្នុងករណីគ្មានសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរពីអភិបាលបណ្តោះអាសន្នក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ គិតចាប់ពីថ្ងៃដែលភាគីនៃកិច្ចសន្យាបានដាក់សំណើនោះ កិច្ចសន្យានឹងត្រូវចាត់ទុកថាបានបញ្ចប់ ហើយភាគីនៃកិច្ចសន្យាអាចប្តឹងទាមទារសំណងខូចខាតក្នុងឋានៈជាម្ចាស់បំណុលក្នុងសំណុំរឿងក្ស័យធន ។ នៅពេលទទួលពាក្យសុំពន្យារពេលជាលាយលក្ខណ៍អក្សរពីអភិបាលបណ្តោះអាសន្ន តុលាការអាចពន្យារអំឡុងពេលមួយដែលក្នុងរយៈពេលនេះ អភិបាលបណ្តោះអាសន្នត្រូវតែប្រកាសសេចក្តីសម្រេចថា ខ្លួនត្រូវគោរពតាម ឬ មិនគោរពតាមកិច្ចសន្យា ។ រាល់ការពន្យារពេលបែបនេះមិនត្រូវមានរយៈពេលលើសពី ១៤(ដប់បួន) ថ្ងៃឡើយ ។

៤-ក្នុងករណីដែលកិច្ចសន្យាជាកិច្ចសន្យាទិញ-លក់មូលបត្រ សិទ្ធិ ឬ ទំនិញឯទៀតដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានេះនៅក្នុងទីផ្សារ ឬ ទីផ្សារមូលបត្រជាផ្នែកមួយនៃកិច្ចព្រមព្រៀងក្របខណ្ឌទូលំទូលាយដែលរួមបញ្ចូលនូវកិច្ចសន្យាជាច្រើន ការសម្រេចរបស់អភិបាលបណ្តោះអាសន្នថាត្រូវបន្តកិច្ចសន្យា ត្រូវតែធ្វើឡើងសម្រាប់ជាអត្ថប្រយោជន៍ដល់កិច្ចសន្យាទាំងអស់តាមកិច្ចព្រមព្រៀងក្របខណ្ឌរួម ។
អភិបាលបណ្តោះអាសន្នមិនអាច
សម្រេចបន្តអនុវត្តតែកិច្ចសន្យាមួយចំនួនដែលមានក្នុងកិច្ចព្រមព្រៀងក្របខណ្ឌនេះឡើយ ។

៥-ចំពោះការសម្រេចរបស់អភិបាលបណ្តោះអាសន្នក្នុងការបន្តអនុវត្តកិច្ចសន្យាដែលតម្រូវឱ្យមានការបង់ប្រាក់ជាទៀងទាត់ចំពោះភាគីនៃកិច្ចសន្យា ការសម្រេចនេះមិនមានអានុភាពកំណត់ការបង់ប្រាក់ដែលមិនទាន់បានបង់មុនពេលបើកសំណុំរឿងក្ស័យធនឡើយ ។

៦-រាល់សិទ្ធិលើបំណុលដែលកើតចេញពីកិច្ចសន្យា ដែលអភិបាលបណ្តោះអាសន្នបានសម្រេចឱ្យបន្តអនុវត្ត ត្រូវចាត់ទុកជាបណ្តឹងទាមទារចំណាយខាងរដ្ឋបាលដែលធ្វើ

ឡើង ដោយអភិបាលបណ្តោះអាសន្នក្នុងដំណើរការសំណុំរឿងក្ស័យធន ហើយត្រូវអនុលោមតាមលំដាប់អាទិភាពដែលមានចែងក្នុងមាត្រា ៥៧ នៃច្បាប់នេះ ។

**មាត្រា ៣១.-**

១-សេវាប្រើប្រាស់ចាំបាច់មិនត្រូវបញ្ចប់ កែប្រែ ឬ កាត់ផ្តាច់ពីអភិបាលបណ្តោះអាសន្ន ឬ កូនបំណុល ដោយផ្អែកតែលើមូលហេតុនៃការបើកសំណុំរឿងក្ស័យធនទល់នឹងកូនបំណុល ឬ មូលហេតុដែលកូនបំណុលនៅជំពាក់ថ្លៃសេវាប្រើប្រាស់ចាំបាច់ដែលបានប្រើប្រាស់ មុនពេលបើកសំណុំរឿងក្ស័យធននេះឡើយ ។

២-ដោយគ្មានប៉ះពាល់ដល់សិទ្ធិរបស់អភិបាលបណ្តោះអាសន្នក្នុងការសម្រេចបន្តអនុវត្តកិច្ចសន្យាដោយអនុលោមតាមមាត្រា ៣០ នៃច្បាប់នេះ អ្នកផ្តល់សេវាប្រើប្រាស់ចាំបាច់អាចបដិសេធការបន្តកិច្ចសន្យាក្នុងការផ្តល់សេវាជូនកូនបំណុល បើអភិបាលបណ្តោះអាសន្នមិនបានផ្តល់កិច្ចធានាបង់ប្រាក់គ្រប់គ្រាន់ ក្នុងរយៈពេល ៣០(សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃបើកសំណុំរឿងក្ស័យធនក្នុងរូបភាពជាប្រាក់កក់ ឬ ប្រាក់ធានាសម្រាប់សេវាដែលត្រូវផ្តល់តាមការបន្តកិច្ចសន្យា បន្ទាប់ពីថ្ងៃបើកសំណុំរឿងក្ស័យធន ។

**មាត្រា ៣២.-**

តាមបណ្តឹងរបស់អភិបាលបណ្តោះអាសន្ន និងក្រោយពេលស្តាប់សវនាការរបស់ភាគីម្ខាងទៀត តុលាការអាចសម្រេចចាត់ទុកជាមោឃៈនូវប្រតិបត្តិការមួយចំនួន ហើយអាចប្រកាសវិធានការសមស្របតាមមាត្រា ៣៣ នៃច្បាប់នេះ ។ ប្រតិបត្តិការជាក់លាក់ទាំងនោះមានដូចខាងក្រោម :

១-ប្រតិបត្តិការដែលធ្វើឡើងដោយកូនបំណុលក្នុងគោលបំណងបន្លំ ម្ចាស់បំណុលដោយលាក់បំបាំងទ្រព្យរបស់ខ្លួនមិនឱ្យម្ចាស់បំណុលរកឃើញ ។

២-ប្រតិបត្តិការដែលបានអនុវត្តក្នុងរយៈពេល ៣(បី) ឆ្នាំ មុនពេលបើកសំណុំរឿងក្ស័យធន ដែលកូនបំណុលមិនបានទទួលតម្លៃតបស្នងអ្វីពីប្រតិបត្តិការនោះ លើកលែងតែប្រតិបត្តិការធម្មតាដែលជាប្រយោជន៍របស់សហព័ទ្ធ របស់កូនបំណុល ឬ ញាតិខ្សែផ្ទាល់របស់ញាតិ ឬ បុព្វញាតិ ។

៣-ប្រតិបត្តិការដែលបានអនុវត្តក្នុងរយៈពេល ១(មួយ)ឆ្នាំ មុនពេលបើកសំណុំរឿងក្ស័យធន ដែលកាតព្វកិច្ចរបស់កូនបំណុលមានតម្លៃច្រើនជាងតម្លៃកាតព្វកិច្ចភាគីម្ខាងទៀត ។

៤-ប្រតិបត្តិការដែលបានអនុវត្តក្នុងរយៈពេល ១(មួយ)ឆ្នាំ មុនពេលបើកសំណុំរឿងក្ស័យធន ដែលកូនបំណុលបានទូទាត់បំណុលដែលមិនទាន់ដល់កាលកំណត់សង ឬ ផ្តល់វត្ថុធានាថ្មី ឬ វត្ថុធានាបន្ថែមលើបំណុលហើយ ដែលភាគីម្ខាងទៀតនៃប្រតិបត្តិការជាបុគ្គលមានការពាក់ព័ន្ធ ។

៥-ប្រតិបត្តិការដែលបានអនុវត្តក្នុងរយៈពេល ៦ (ប្រាំមួយ)ខែមុនពេលបើកសំណុំរឿងក្ស័យធន ដែលកូនបំណុលបានទូទាត់បំណុលដែលមិនទាន់ដល់កាលកំណត់សង ឬ ផ្តល់វត្ថុធានាថ្មី ឬវត្ថុធានាបន្ថែមលើបំណុលហើយដែលភាគីម្ខាងទៀតមិនមែនជាបុគ្គលមានការពាក់ព័ន្ធ ។

៦-ប្រតិបត្តិការដែលបានអនុវត្តក្នុងរយៈពេល ១(មួយ)ឆ្នាំ មុនពេលបើកសំណុំរឿងក្ស័យធន ដែលកូនបំណុលបានទូទាត់បំណុលដែលមិនទាន់ដល់កាលកំណត់សង ឬ ផ្តល់វត្ថុធានាថ្មី ឬ ផ្តល់សិទ្ធិលើទ្រព្យធានាសម្រាប់បំណុលដែលមានប្រភេទដូចបានរៀបរាប់ នៅក្នុងមាត្រា ៣៦ ចំណុចទី ៥ នៃច្បាប់នេះ ។

**មាត្រា ៣៣.-**

១-នៅពេលដែលប្រតិបត្តិការ ឬ ការផ្ទេរត្រូវបានប្រកាសមោឃភាពក្នុងមាត្រា ៣២ នៃច្បាប់នេះ រាល់សាច់ប្រាក់ទ្រព្យសម្បត្តិដែលបានផ្ទេរ ឬ ថ្លៃលក់ទ្រព្យសម្បត្តិដែលបានផ្ទេរនឹងត្រូវទាមទារយកវិញ និងត្រូវដាក់បញ្ចូលក្នុងទ្រព្យកូនបំណុល ។

២-បុគ្គលដែលត្រូវគេប្តឹងទារប្រាក់ ឬ ទ្រព្យសម្បត្តិដោយសារមោឃភាពនៃប្រតិបត្តិការមានសិទ្ធិទទួលតម្លៃតបស្នងចំពោះតម្លៃដែលខ្លួនបានផ្តល់សម្រាប់ប្រតិបត្តិការនោះ ។ ការសងមកវិញត្រូវដកចេញពីទ្រព្យកូនបំណុលត្រឹមកម្រិត ដែលទ្រព្យប្រតិបត្តិការនៅមានក្នុងចំណោមទ្រព្យកូនបំណុល ។ បុគ្គលនេះក៏ត្រូវមានសិទ្ធិប្តឹងទាមទារសំណងក្នុងឋានៈជាម្ចាស់បំណុលក្នុងសំណុំរឿងក្ស័យធនដែរ ។

១-នៅថ្ងៃបើកសំណុំរឿងក្ស័យធន តាមអានុភាពច្បាប់ ឬ តាមអានុភាពនៃកិច្ចសន្យា ម្រសិនបើម្ចាស់បំណុលមានសិទ្ធិធ្វើការទូទាត់ជម្រះការទាមទារសំណងជាមួយនឹងកាតព្វកិច្ចដែលខ្លួនជំពាក់កូនបំណុល ការបើកសំណុំរឿងក្ស័យធនមិនមានអានុភាពលើសិទ្ធិទូទាត់ជម្រះនេះទេ ។

២-ក្នុងករណីដែលមានបណ្តឹងតវ៉ាពីកូនបំណុល ការយកទ្រព្យកូនបំណុលមកទូទាត់ជម្រះដោយម្ចាស់បំណុល ត្រូវចាត់ទុកជាមោឃៈ ប្រសិនបើ :

ក-ម្ចាស់បំណុលបានក្លាយទៅជាកូនបំណុលនៃទ្រព្យ បន្ទាប់ពីការបើកសំណុំរឿងក្ស័យធន

ខ-ម្ចាស់បំណុលទទួលបានបណ្តឹងទាមទារពីម្ចាស់បំណុលម្នាក់ផ្សេងទៀត បន្ទាប់ពីការបើកសំណុំរឿងក្ស័យធន

គ-ម្ចាស់បំណុលទទួលបានសិទ្ធិធ្វើការទូទាត់ជម្រះ តាមរយៈប្រតិបត្តិការពាណិជ្ជកម្មដែលជាកម្មវត្ថុនៃការតវ៉ា ឬ មោឃភាពតាមច្បាប់នេះ ឬ ច្បាប់ផ្សេងទៀត

ឃ-បណ្តឹងទាមទាររបស់ម្ចាស់បំណុលស្ថិតនៅក្នុងប្រភេទដែលមានចែងក្នុងមាត្រា ៣៦ នៃច្បាប់នេះ ។

## ផ្នែកទី ៣
## សិទ្ធិលើបំណុល

**មាត្រា ៣៥.-**

១-ទ្រព្យកូនបំណុលត្រូវបានយកមកទូទាត់សងការទាមទារបំណុលសមស្របទល់នឹងកូនបំណុល និងការទាមទារចំណាយខាងរដ្ឋបាល ។ បណ្តឹងទាមទារចំណាយខាងរដ្ឋបាលត្រូវរួមបញ្ចូលនូវប្រាក់បំណាច់ថ្លៃសេវា និងការចំណាយនានារបស់អភិបាលបណ្តោះអាសន្នក្នុងដំណើរការរឿងក្តី ។

២-សិទ្ធិលើបំណុលដែលមិនទាន់ដល់កាលកំណត់សងនាកាលបរិច្ឆេទ ជម្រះបញ្ជី ត្រូវចាត់ទុកថាដល់កាលកំណត់សង នៅកាលបរិច្ឆេទជម្រះបញ្ជី ។

៣-សិទ្ធិលើបំណុលដែលស្ថិតនៅក្រោមលក្ខខណ្ឌដោះស្រាយ ត្រូវចាត់ទុកថាជាសិទ្ធិលើបំណុលគ្មានលក្ខខណ្ឌ ដរាបណាលក្ខខណ្ឌនោះមិនទាន់ត្រូវបានបំពេញទេ ។

**មាត្រា ៣៦.-**

បណ្តឹងទាមទារបំណុលដូចខាងក្រោមនេះ មិនអាចទទួលយកបានទេក្នុងសំណុំរឿងក្ស័យធន :

១-ការប្រាក់ដែលកើនលើសិទ្ធិលើបំណុល ចាប់ពីកាលបរិច្ឆេទនៃការបើកសំណុំរឿងក្ស័យធន ។

២-ថ្លៃចំណាយរបស់ម្ចាស់បំណុលក្នុងការចូលរួមក្នុងសំណុំរឿងក្ស័យធន ។

៣-ប្រាក់ពិន័យ និងផលវិបាកដែលកើតជាយថាហេតុពីបទល្មើសព្រហ្មទណ្ឌ ប្រាក់ពិន័យរដ្ឋបាល និងផលវិបាកដែលកើតជាយថាហេតុពីបទល្មើសរដ្ឋបាលដែលតម្រូវឱ្យកូនបំណុលបង់ប្រាក់ ។

៤-បណ្តឹងទាមទារឱ្យអនុវត្តកាតព្វកិច្ចដែលគ្មានតម្លៃតបស្នង ។

៥-បណ្តឹងទាមទារឱ្យ សងប្រាក់ធ្វើឡើងដោយបុគ្គលណាមួយដែលកាន់កាប់ផ្ទាល់ ឬ ដោយប្រយោលលើដើមទុនរបស់កូនបំណុលលើសពី ១០ (ដប់ភាគរយ) ដែលបានឱ្យខ្ចី ឬ បណ្តាលឱ្យមានបំណុលនោះដោយចៃដន្យ ឬ បានធ្វើកិច្ចធានា ឬ បានដាក់ទ្រព្យធានាឱ្យកូនបំណុល ។ ប្រសិនបើកូនបំណុលជាក្រុមហ៊ុនសហកម្មសិទ្ធិ បណ្តឹងទាមទារក្នុង កថាខណ្ឌនេះ ត្រូវអនុវត្តតែក្នុងករណីដែលសហកម្មសិទ្ធិករទូទៅរបស់កូនបំណុលជាក្រុម ហ៊ុនមូលធន ។

៦-បណ្តឹងទាមទារដែលកូនបំណុលរួមគ្នា ឬ អ្នកធានាអាចប្រឆាំងនឹងកូនបំណុល ប្រសិនបើកូនបំណុលរួមគ្នានេះបានទូទាត់តាមការទាមទាររបស់ម្ចាស់បំណុល ។

៧-សិទ្ធិលើបំណុលដែលភស្តុតាងនៃបណ្តឹងទាមទារ ត្រូវបានដាក់ជូនក្រោយកាលកំណត់ឱ្យដាក់ជូនភស្តុតាងនោះ ។

៨-បណ្តឹងទាមទារបំណុលបន្ទាប់បន្សំដែលគ្មានអានុភាពក្នុងសំណុំរឿងក្ស័យធនដែលបានព្រមព្រៀងរវាងម្ចាស់បំណុល និងកូនបំណុល ។

៩-ផលប្រយោជន៍នៃសិទ្ធិលើបំណុលដែលមានប្រភេទដូចពោលខាងលើ ។

**មាត្រា ៣៧.-**

បំណុលដែលមិនមែនជាសាច់ប្រាក់ ត្រូវវាយតម្លៃទាត់ជាតម្លៃប៉ាន់ស្មានជាប្រាក់រៀល នៅកាលបរិច្ឆេទបើកសំណុំរឿងក្ស័យធន ។ បណ្តឹងទាមទារបំណុលដែលកំណត់ប្រាក់ជារូបិយប័ណ្ណបរទេស ឬ កំណត់ឯកតាប្តូរប្រាក់ផ្សេងទៀតនឹងត្រូវប្តូរទៅជាប្រាក់រៀលតាមអត្រាប្តូរប្រាក់ដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា នៅកាលបរិច្ឆេទបើកសំណុំរឿងក្ស័យធន ។

**មាត្រា ៣៨.-**

១-ម្ចាស់បំណុលត្រូវដាក់រាល់ភស្តុតាងនៃសិទ្ធិលើបំណុលជូនអភិបាលបណ្តោះអាសន្នជាលាយលក្ខណ៍អក្សរនៅកាលបរិច្ឆេទដែលបានកំណត់ ។

២-ភស្តុតាងនៃសិទ្ធិលើបំណុលនីមួយៗ ត្រូវមានព័ត៌មានដូចខាងក្រោមនេះ :

ក-មូលដ្ឋានគតិយុត្ត និងមូលហេតុនៃបណ្តឹងទាមទារ

ខ-ពេលវេលាដែលបណ្តឹងទាមទារកើតឡើង

គ-ទឹកប្រាក់នៃបណ្តឹងទាមទារ

ឃ-រាល់សិទ្ធិអាទិភាពដែលអាចមានភ្ជាប់ជាមួយបណ្តឹងទាមទារ តាមមាត្រា ៥៧ នៃច្បាប់នេះ

ង-លក្ខណៈ និងលំដាប់ថ្នាក់នៃទ្រព្យធានាដែលបញ្ជាក់ក្នុងទ្រព្យសម្បត្តិនៃកូនបំណុល និងសេចក្តីបញ្ជាក់លម្អិតអំពីទ្រព្យដែលដាក់ធានា

ច-ឯកសារទាំងឡាយ និងភស្តុតាងដទៃទៀតប្រសិនបើមាន ។

៣-អភិបាលបណ្តោះអាសន្នត្រូវតែជួយម្ចាស់បំណុលក្នុងការបំពេញទម្រង់បែបបទច្បាប់ ។

**មាត្រា ៣៩.-**

១-អភិបាលបណ្តោះអាសន្នត្រូវរៀបចំបញ្ជីនៃបណ្តឹងទាមទារ ដោយបញ្ជាក់លម្អិតពីបណ្តឹងទាមទារទាំងអស់ដែលម្ចាស់បំណុលបានដាក់ជូន ដោយអនុលោមតាមមាត្រា ៣៨ នៃច្បាប់នេះ ។ បញ្ជីនៃបណ្តឹងទាមទារត្រូវដាក់ជូនតុលាការមិនឱ្យលើសពី ៥ (ប្រាំ) ថ្ងៃមុន

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ព្រះរាជវាំង

កាលបរិច្ឆេទបើកកិច្ចប្រជុំម្ចាស់បំណុលឡើយ ។ បញ្ជីនៃបណ្តឹងទាមទារត្រូវផ្តល់លទ្ធភាពឱ្យបុគ្គលគ្រប់រូបអាចពិនិត្យមើលបានដោយឥតគិតថ្លៃ ។

២-បញ្ជីនៃបណ្តឹងទាមទារ ត្រូវមានព័ត៌មានសង្ខេបតាមបែបបទងាយយល់ ដោយអនុលោមតាមមាត្រា ៣៨ ចំណុចទី ២ ក ដល់ចំណុចទី ២ ង ។ លើសពីនេះទៀតក្នុងករណីដែលទ្រព្យធានាស្ថិតក្នុងបណ្តឹងទាមទារ ការវាយតម្លៃលើផ្នែកដែលមានកិច្ចធានានៃបណ្តឹងទាមទារត្រូវកំណត់តាមមាត្រា ២៦ នៃច្បាប់នេះ ។

៣-បញ្ជីនៃបណ្តឹងទាមទារ នឹងត្រូវបានពិនិត្យផ្ទៀងផ្ទាត់នៅពេលបើកកិច្ចប្រជុំម្ចាស់បំណុល អនុលោមតាមបទប្បញ្ញត្តិនៃជំពូកទី ៦ នៃច្បាប់នេះ ។

## ជំពូកទី ៥
## ផែនការសម្របសម្រួល
### ផ្នែកទី ១
### ការរៀបចំផែនការ

**មាត្រា ៤០.-**

រាល់សំណើផែនការសម្របសម្រួល ត្រូវដាក់ជូនតុលាការមិនឱ្យលើសពី ៧ (ប្រាំពីរ) ថ្ងៃមុនកាលបរិច្ឆេទបើកកិច្ចប្រជុំម្ចាស់បំណុល ។ សំណើផែនការសម្របសម្រួលដែលបានដាក់ជូនតុលាការ ត្រូវផ្តល់លទ្ធភាពឱ្យសាធារណជនអាចពិនិត្យមើលបានដោយឥតគិតថ្លៃ ។

**មាត្រា ៤១.-**

១-ផែនការសម្របសម្រួល ត្រូវចែងពីរយៈពេលសម្រាប់អនុវត្ត និងអាចចែងពីវិធីដោះស្រាយអសាធនភាពរបស់កូនបំណុលដោយរាប់បញ្ចូលទាំង :

ក-ការលុបចោល ឬ ការកាត់បន្ថយទឹកប្រាក់ក្នុងសិទ្ធិលើបំណុលណាមួយដូចជាការប្តូរយកជាភាគហ៊ុន ឬ ទ្រព្យសម្បត្តិក្នុងអាជីវកម្មរបស់កូនបំណុល

ខ-ការកំណត់កាលវិភាគសម្រាប់ទូទាត់ប្រាក់ក្នុងបណ្តឹងទាមទារ

គ-ការបន្តអាជីវកម្មរបស់កូនបំណុល ឬ ផ្នែកណាមួយនៃអាជីវកម្មនេះដោយកូនបំណុលខ្លួនឯង ឬ បុគ្គលផ្សេងទៀត

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ឃ-ការលក់ ការជម្រះនូវទ្រព្យសម្បត្តិរបស់កូនបំណុល ទោះស្ថិតក្នុងការដាក់ធានា ឬ មិនស្ថិតក្នុងការដាក់ធានា ឬ សិទ្ធិឃាត់ទុករបស់ឥតិយជនក៏ដោយ ឬ ការបែងចែកទ្រព្យកូនបំណុលមួយផ្នែក ឬ ទាំងអស់ឱ្យទៅបុគ្គលដែលមានសិទ្ធិលើទ្រព្យទាំងនោះក៏ដោយ ។

២-ផែនការសម្របសម្រួល ត្រូវតែចែងពីការទូទាត់គ្រប់ចំនួននូវថ្លៃចំណាយក្នុងសំណុំរឿង និងបណ្តឹងទាមទារចំណាយខាងរដ្ឋបាលផ្សេងទៀត និង បណ្តឹងទាមទារដែលបានធ្វើឡើងដោយអភិបាលបណ្តោះអាសន្នក្នុងរយៈពេលដំណើរការសំណុំរឿងក្ស័យធន ។

**មាត្រា ៤២.-**

សិទ្ធិលើបំណុលដែលគ្មានការទទួលស្គាល់ មិនត្រូវបានដាក់ចូលក្នុងផែនការសម្របសម្រួលទេ លើកលែងតែសិទ្ធិលើបំណុលដែលធ្វើឡើងតាមមាត្រា ៣៩ ចំណុចទី ៣ នៃច្បាប់នេះ ។

**មាត្រា ៤៣.-**

ថ្លៃចំណាយដែលកើតឡើងពីការរៀបចំសំណើផែនការសម្របសម្រួលរបស់កូនបំណុល ឬ អភិបាលបណ្តោះអាសន្ន ត្រូវចាត់ទុកជាបន្ទុកចំណាយខាងរដ្ឋបាល ដែលត្រូវទូទាត់ដោយទ្រព្យរបស់កូនបំណុល ។ ឯថ្លៃចំណាយដែលកើតចេញពីសំណើផែនការផ្សេងៗទៀត ត្រូវចាត់ទុកជាបន្ទុកចំណាយរបស់ភាគីដែលលើកសំណើនោះ ។

## ផ្នែកទី ២

## ការឯកភាពលើផែនការសម្របសម្រួល

**មាត្រា ៤៤.-**

ផែនការសម្របសម្រួលត្រូវដាក់សុំការពិនិត្យ និងឯកភាពពីម្ចាស់បំណុលក្នុងពេលបើកកិច្ចប្រជុំម្ចាស់បំណុល ឬ កិច្ចប្រជុំផ្សេងទៀតដែលកោះប្រជុំសម្រាប់គោលបំណងនេះ ។

**មាត្រា ៤៥.-**

១-ក្នុងការអនុម័តផែនការសម្របសម្រួល ម្ចាស់បំណុលនឹងត្រូវបានបញ្ចូលជាក្រុមតាមប្រភេទ ហើយត្រូវបោះឆ្នោតស្របតាមចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនតាម[illegible]ដូចខាងក្រោមនេះ :

ក-ម្ចាស់បំណុលដែលមានបណ្តឹងទាមទារដែលមានកិច្ចធានា

ខ-ម្ចាស់បំណុលដែលមានសិទ្ធិលើបំណុលដែលស្ថិតនៅក្រោមមាត្រា ៥៧ ចំណុចទី ១-គ នៃច្បាប់នេះ

គ-ម្ចាស់បំណុលដែលមានសិទ្ធិលើបំណុលដែលស្ថិតនៅក្រោមមាត្រា ៥៧ ចំណុចទី ១-ឃ នៃច្បាប់នេះ ។

២-ផែនការសម្របសម្រួល ត្រូវតែមានការឯកភាពពី :

ក-ម្ចាស់បំណុលគ្រប់ប្រភេទ តាមរយៈការបោះឆ្នោតគាំទ្ររបស់ម្ចាស់បំណុលនៅតាមប្រភេទនីមួយៗ ដែលមានសិទ្ធិលើបំណុលមិនតិចជាង ៣/៤ (បីភាគបួន)នៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល ដែលមានវត្តមានក្នុងកិច្ចប្រជុំបោះឆ្នោត ឬ

ខ-យ៉ាងហោចណាស់ពីម្ចាស់បំណុលមួយប្រភេទ តាមរយៈការបោះឆ្នោតគាំទ្ររបស់ម្ចាស់បំណុលនៅក្នុងប្រភេទនោះដែលមានសិទ្ធិលើបំណុលមិនតិចជាង ៣/៤(បីភាគបួន) នៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលដែលមានវត្តមានក្នុងកិច្ចប្រជុំបោះឆ្នោត ។

**មាត្រា ៧៦.-**

សិទ្ធិបោះឆ្នោតរបស់ម្ចាស់បំណុលក្នុងការបោះឆ្នោតលើផែនការសម្របសម្រួលត្រូវអនុលោមតាមមាត្រា ៧៥ នៃច្បាប់នេះ និងត្រូវស្ថិតនៅក្រោមលក្ខខណ្ឌដូចខាងក្រោមនេះ :

១-ម្ចាស់បំណុលដែលសិទ្ធិលើបំណុលរបស់ខ្លួនមិនខូចខាត ឬ រងផលប៉ះពាល់ពីផែនការសម្របសម្រួល មិនត្រូវមានសិទ្ធិបោះឆ្នោតទេ និង

២-ម្ចាស់បំណុលដែលមានកិច្ចធានាមានសិទ្ធិបោះឆ្នោតចំពោះតែ :

ក-ក្នុងករណីដែលទឹកប្រាក់សរុបក្នុងសិទ្ធិលើបំណុលលើសពី :

-តម្លៃទ្រព្យដែលមានកិច្ចធានាតាមការកំណត់របស់មាត្រា ២៦ នៃច្បាប់នេះ ឬ

-លើសពីតម្លៃនៃប្រាក់ថ្លៃលក់ទ្រព្យធានា ឬ

ខ-ក្នុងករណីដែលម្ចាស់បំណុលលះបង់សិទ្ធិលើទ្រព្យដែលបានដាក់ធានា

**មាត្រា ៤៧.-**

១-ក្នុងរយៈពេលមិនលើសពី ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីម្ចាស់បំណុលទាំងអស់បានឯកភាពលើផែនការសម្របសម្រួលតាមលក្ខខណ្ឌនៃមាត្រា ៤៥ នៃច្បាប់នេះ អភិបាលបណ្តោះអាសន្នត្រូវដាក់ពាក្យសុំឱ្យតុលាការទទួលស្គាល់ផែនការសម្របសម្រួល ។

២-តុលាការត្រូវចេញសេចក្តីសម្រេចទទួលស្គាល់ផែនការសម្របសម្រួល បើលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ :

ក-ការបោះឆ្នោតត្រូវបានធ្វើឡើងស្របតាមលក្ខខណ្ឌនៃច្បាប់នេះ

ខ-តាមផែនការសម្របសម្រួល ម្ចាស់បំណុលគ្រប់ប្រភេទទាំងអស់នឹងត្រូវចាត់ទុកថា មានសិទ្ធិស្មើគ្នាក្នុងប្រភេទដូចគ្នា លើកលែងតែម្ចាស់បំណុលបានយល់ព្រមជាលាយលក្ខណ៍អក្សរថាស្ថិតក្នុងលំដាប់អាទិភាពទាបជាងម្ចាស់បំណុលផ្សេងទៀត

គ-តាមផែនការសម្របសម្រួល រាល់ម្ចាស់បំណុលដែលទាមទារនឹងទទួលបានការទូទាត់ចំពោះការទាមទារតាមកម្រិត ដែលមិនតិចជាងកម្រិតដែលម្ចាស់បំណុលនេះអាចនឹងទទួលបានពីការបែងចែកក្នុងពេលជម្រះបញ្ជីដោយអនុលោមតាមមាត្រា ៩៧ នៃច្បាប់នេះ

ឃ-តាមផែនការសម្របសម្រួលនេះ គ្មានម្ចាស់បំណុលណាម្នាក់អាចទទួលបានទឹកប្រាក់ច្រើនជាងទឹកប្រាក់សរុបក្នុងបណ្តឹងទាមទាររបស់ខ្លួនឡើយ

ង-តាមផែនការសម្របសម្រួលនេះ គ្មានការទូទាត់ដែលទាក់ទិននឹងប្រាក់ចំណូលភាគលាភ ឬ ភាគទុនទៅឱ្យម្ចាស់ភាគហ៊ុន ឬ សហកម្មសិទ្ធិករនៃកូនបំណុលឡើយ រហូតទាល់តែបានបែងចែកប្រាក់ជូនអ្នកមានសិទ្ធិតាមប្រភេទនៃម្ចាស់បំណុល ដែលមានការទាមទារក្នុងផែនការសម្របសម្រួលរួចរាល់សិន

ច-តាមផែនការសម្របសម្រួលនេះ មិនត្រូវធ្វើការទូទាត់ថ្លៃថែទាំណាដែលច្រើនជាងប្រាក់ថ្លៃថែទាំដែលតុលាការបានកំណត់ចំពោះកូនបំណុលដែលជារូបវន្តបុគ្គល ឬសហកម្មសិទ្ធិករទូទៅរបស់កូនបំណុលដែលជាក្រុមហ៊ុនសហកម្មសិទ្ធិឡើយ រហូតទាល់តែបានបែងចែកប្រាក់ជូនអ្នកមានសិទ្ធិតាមថ្នាក់នៃម្ចាស់បំណុលដែលមានការទាមទារក្នុងផែនការសម្របសម្រួលរួចហើយ ។

៣-បើផែនការសម្របសម្រួលមិនបានបំពេញតាមលក្ខខណ្ឌដែលចែងក្នុងចំណុចទី ២ នៃមាត្រានេះទេ តុលាការត្រូវសម្រេចដើម្បីចាប់ផ្តើមការជម្រះបញ្ជីលើទ្រព្យកូនបំណុល ។

៤-ការសម្រេចរបស់តុលាការតាមមាត្រានេះ ត្រូវធ្វើឡើងមិនឱ្យលើសពី ៧(ប្រាំពីរ) ថ្ងៃ បន្ទាប់ពីអភិបាលបណ្តោះអាសន្នបានដាក់ពាក្យសុំឱ្យតុលាការទទួលស្គាល់លើផែនការសម្របសម្រួល ។

**មាត្រា ៤៨.-**

១-ការទទួលស្គាល់របស់តុលាការលើផែនការសម្របសម្រួលត្រូវមានអានុភាពបញ្ចប់សំណុំរឿងក្ស័យធន ហើយត្រូវចាប់ផ្តើមរយៈពេលនៃការអនុវត្តផែនការសម្របសម្រួលដែលបានកំណត់ ប៉ុន្តែការអនុវត្តផែនការនេះមិនត្រូវលើសពីរយៈពេលអតិបរមា ២(ពីរ) ឆ្នាំឡើយ បន្ទាប់ពីតុលាការបានទទួលស្គាល់លើផែនការសម្របសម្រួល ។

២-ផែនការសម្របសម្រួលដែលត្រូវបានទទួលស្គាល់ដោយតុលាការ ត្រូវភ្ជាប់កាតព្វកិច្ចលើម្ចាស់បំណុលទាំងអស់ ហើយរំលត់រាល់សិទ្ធិលើបំណុលដែលមិនអាចទទួលស្គាល់ក្រៅពីសិទ្ធិលើបំណុលដូចមានចែងក្នុងមាត្រា ៣៦ ចំណុចទី ៣ នៃច្បាប់នេះ ។

**មាត្រា ៤៩.-**

១-ក្នុងរយៈពេលអនុវត្តផែនការសម្របសម្រួល រាល់ឯកសារអាជីវកម្មដែលចេញដោយកូនបំណុល ឬ ក្នុងនាមកូនបំណុលដែលមានសរសេរឈ្មោះកូនបំណុលត្រូវមានសេចក្តីបញ្ជាក់ពិស្តារ ដើម្បីអនុញ្ញាតឱ្យផែនការសម្របសម្រួលអាចអនុវត្តចំពោះកូនបំណុលបាន ។

២-នៅពេលអនុម័តផែនការសម្របសម្រួល ឬ នៅកាលបរិច្ឆេទក្រោយពីនេះ ក្នុងគោលបំណងធានាការអនុវត្តផែនការសម្របសម្រួល តុលាការអាចបង្គាប់ឱ្យអភិបាលបណ្តោះអាសន្នបន្តការគ្រប់គ្រងតាមលក្ខខណ្ឌដែលតុលាការយល់ថា សមស្របនូវសកម្មភាពរបស់កូនបំណុល ឬ សកម្មភាពអ្នកចាត់ចែងការងាររបស់កូនបំណុល ។ ក្នុងការធ្វើសេចក្តីសម្រេចតាមចំណុចនេះតុលាការក៏ត្រូវកំណត់ចំនួនប្រាក់ចំណាយនានាសម្រាប់

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

អភិបាលបណ្តោះអាសន្នដែលត្រូវទូទាត់ដោយកូនបំណុលដែរ ។

**មាត្រា ៥០.-**

១-ក្នុងករណីដែលផែនការសម្របសម្រួល មិនត្រូវបានអនុវត្តតាមរយៈពេលដែលបានកំណត់ តុលាការត្រូវសម្រេចបើកសំណុំរឿងក្ស័យធនទល់នឹងកូនបំណុល ។

២-ការដាក់ពាក្យសុំបើកសំណុំរឿងក្ស័យធនតាមចំណុចទី ១ ខាងលើអាចធ្វើឡើងដោយកូនបំណុល ម្ចាស់បំណុល ឬ តំណាងអយ្យការ ឬ អភិបាលបណ្តោះអាសន្ន ដូចចែងក្នុងមាត្រា ៤៩ ចំណុចទី ២ នៃច្បាប់នេះ ។

៣-សំណុំរឿងក្ស័យធនដែលបើកឡើងតាមចំណុចទី ១ ខាងលើ ត្រូវចាប់ផ្តើមភ្លាមៗជាមួយ និងការជម្រះបញ្ជីកូនបំណុល ។ អានុភាពនៃផែនការសម្របសម្រួលដែលទាក់ទិននឹងសិទ្ធិលើបំណុល សិទ្ធិលើទ្រព្យធានានិងសិទ្ធិផ្សេងៗទៀតរបស់ម្ចាស់បំណុល ត្រូវរក្សាទុកដដែលក្នុងការជម្រះបញ្ជីនេះ ។

## ជំពូកទី ៦
## ការបើកកិច្ចប្រជុំម្ចាស់បំណុល

**មាត្រា ៥១.-**

ដោយមានជំនួយពីអភិបាលបណ្តោះអាសន្ន ចៅក្រមត្រូវកោះប្រជុំ និងធ្វើជាអធិបតីក្នុងកិច្ចប្រជុំម្ចាស់បំណុលលើកដំបូង ។

**មាត្រា ៥២.-**

នៅពេលបើកកិច្ចប្រជុំម្ចាស់បំណុល អភិបាលបណ្តោះអាសន្នត្រូវរាយការណ៍ពីស្ថានភាពអាជីវកម្មរបស់កូនបំណុល និងមូលហេតុដែលនាំឱ្យមានស្ថានភាពអាជីវកម្មបែបនេះ ។ អភិបាលបណ្តោះអាសន្នត្រូវតែបង្ហាញថាមាន ឬ គ្មានលទ្ធភាពក្នុងការបន្តអាជីវកម្មទាំងមូល ឬ មួយផ្នែករបស់កូនបំណុល មាន ឬ គ្មានលទ្ធភាពដែលត្រូវស្នើសុំការឯកភាពលើផែនការសម្របសម្រួល និងការអនុវត្តផែនការសម្របសម្រួលព្រមទាំងបញ្ជាក់ពីផលវិបាកដែលនឹងកើតឡើងចំពោះការទូទាត់ឱ្យម្ចាស់បំណុល ។

**មាត្រា ៥៣.-**

នៅក្នុងកិច្ចប្រជុំម្ចាស់បំណុល ម្ចាស់បំណុលត្រូវសម្រេចលើបញ្ហាសំខាន់ៗមួយចំនួន ដូចខាងក្រោមនេះ :

១-សម្រេចលើផែនការបន្តសំណុំរឿងក្ស័យធន ដោយផ្អែកតាមរបាយការណ៍របស់អភិបាលបណ្តោះអាសន្ន ដែលរៀបចំសម្រាប់កិច្ចប្រជុំនេះ ។

២-សម្រេចលើផែនការសម្របសម្រួល ដែលត្រូវបានស្នើឡើងដោយកូនបំណុល ។

៣-ពិនិត្យផ្ទៀងផ្ទាត់សិទ្ធិលើបំណុល

៤-សម្រេចលើបញ្ហាផ្សេងទៀតដែលទាក់ទិននឹងសំណុំរឿងក្ស័យធន ។

**មាត្រា ៥៤.-**

១-បន្ទាប់ពីបានពិចារណាលើរបាយការណ៍របស់អភិបាលបណ្តោះអាសន្ន បើផែនការសម្របសម្រួលត្រូវបានឯកភាពដោយម្ចាស់បំណុល ម្ចាស់បំណុលត្រូវបោះឆ្នោតសម្រេចលើផែនការសម្របសម្រួលនេះ ។

២-ក្នុងករណីដែលគ្មានសំណើផែនការសម្របសម្រួលរបស់កូនបំណុល ឬ សំណើផែនការសម្របសម្រួលមិនត្រូវបានឯកភាពដោយម្ចាស់បំណុល ម្ចាស់បំណុលត្រូវសម្រេចដើម្បី :

ក-ផ្អាកកិច្ចប្រជុំម្ចាស់បំណុល ប៉ុន្តែមិនត្រូវផ្អាកលើសពី ៦០ (ហុកសិប) ថ្ងៃទេ ដើម្បីឱ្យកូនបំណុល អភិបាលបណ្តោះអាសន្ន ឬ ម្ចាស់បំណុលម្នាក់ ឬ ច្រើននាក់ដែលកាន់កាប់ទឹកប្រាក់សរុបមិនតិចជាង ១/៥ (មួយភាគប្រាំ) នៃបណ្តឹងទាមទារទាំងអស់លើកសំណើផែនការសម្របសម្រួល ឬ

ខ-ចាប់ផ្តើមការជម្រះបញ្ជីទ្រព្យកូនបំណុល ។

៣-បើកិច្ចប្រជុំម្ចាស់បំណុលត្រូវបានផ្អាកដោយអនុលោមតាមចំណុចទី ២ ក ខាងលើ នៅក្នុងកិច្ចប្រជុំដែលកោះហៅសាជាថ្មី ម្ចាស់បំណុលត្រូវពិចារណា និងបោះឆ្នោតតែលើផែនការសម្របសម្រួលណាដែលបានស្នើឡើងប៉ុណ្ណោះ ។ ក្នុងករណីដែលម្ចាស់បំណុល

LE MINISTRE du PALAIS ROYAL

មិនឯកភាពលើផែនការសម្របសម្រួលក្នុងកិច្ចប្រជុំដែលកោះហៅសាជាថ្មីនេះ ការជម្រះបញ្ជីទ្រព្យកូនបំណុលនឹងត្រូវចាប់ផ្តើម ។

**មាត្រា ៥៥.-**

១-អភិបាលបណ្តោះអាសន្ន កូនបំណុល ឬ ម្ចាស់បំណុលអាចតវ៉ា ពីសុពលភាព ចំនួនទឹកប្រាក់ ការកំណត់សិទ្ធិលើទ្រព្យធានា ឬ អាទិភាពផ្សេងទៀតនៃសិទ្ធិលើបំណុលក្នុងបញ្ជីនៃសិទ្ធិលើបំណុល ។ សិទ្ធិលើបំណុលត្រូវបានទទួលស្គាល់ដើម្បីទូទាត់ក្នុងសំណុំរឿងក្ស័យធន ប្រសិនបើក្នុងករណីដែលសិទ្ធិលើបំណុលនោះគ្មានការតវ៉ាពីអភិបាលបណ្តោះអាសន្ន ឬ ពីម្ចាស់បំណុលណាម្នាក់ក្នុងកិច្ចប្រជុំម្ចាស់បំណុល ។

២-ក្នុងករណីដែលអភិបាលបណ្តោះអាសន្ន ឬ ម្ចាស់បំណុលតវ៉ាទៅនឹងសុពលភាព ចំនួនទឹកប្រាក់ ការកំណត់សិទ្ធិលើទ្រព្យធានា ឬ អាទិភាពឯទៀតនៃសិទ្ធិលើបំណុលនេះ ម្ចាស់បំណុលត្រូវស្វែងរកសាលក្រមសម្រេចលើសិទ្ធិលើបំណុលនេះតាមផ្លូវតុលាការ ។ តុលាការត្រូវបើកសវនាការលើករណីនេះឱ្យបានឆាប់បំផុត ។

៣-បញ្ជីនៃសិទ្ធិលើបំណុល ត្រូវរៀបចំដោយអភិបាលបណ្តោះអាសន្ន និងត្រូវតម្កល់នៅតុលាការ បន្ទាប់ពីមានការកែប្រែដែលចាំបាច់តាមអានុភាពនៃសេចក្តីសម្រេចចុងក្រោយដែលចែងក្នុងចំណុចទី ២ ខាងលើនេះ ។

## ជំពូកទី ៧

## ការជម្រះបញ្ជី និងការទូទាត់សិទ្ធិលើបំណុល

**មាត្រា ៥៦.-**

១-នៅពេលចាប់ផ្តើមការជម្រះបញ្ជី អភិបាលបណ្តោះអាសន្នត្រូវប្តូរទ្រព្យសកម្មដែលមិនមែនជាសាច់ប្រាក់របស់កូនបំណុលឱ្យទៅជាសាច់ប្រាក់ឱ្យឆាប់បំផុតតាមដែលអាចធ្វើទៅបាន ដើម្បីឆ្លើយតបតម្រូវការនៃការទូទាត់បណ្តឹងទាមទាររបស់ម្ចាស់បំណុលក្នុងសំណុំរឿងក្ស័យធន ។

ROYAUME DU CAMBODGE

២-ក្នុងការចាត់ចែងទ្រព្យសកម្មរបស់កូនបំណុល អភិបាលបណ្តោះអាសន្នត្រូវប្រើប្រាស់មធ្យោបាយពាណិជ្ជកម្មសមស្របដែលនាំឱ្យទទួលបានទិន្នផលជាសាច់ប្រាក់ខ្ពស់បំផុតសម្រាប់កូនបំណុល ។

៣-ទ្រព្យសកម្មទាំងអស់របស់កូនបំណុលដែលមិនមែនជាសាច់ប្រាក់ ដែលអភិបាលបណ្តោះអាសន្នលក់ជម្រះត្រូវតែគ្មានជាប់បន្ទុក ឬសិទ្ធិរបស់តតិយជនណាមួយឡើយ ។

## មាត្រា ៥៧.-

១-ប្រាក់ដែលទទួលបានពីការជម្រះបញ្ជីទ្រព្យសម្បត្តិកូនបំណុល ត្រូវប្រើប្រាស់សម្រាប់ទូទាត់បណ្តឹងទាមទារតាមលំដាប់ដូចខាងក្រោមនេះ :

ក-ប្រាក់បៀវត្សបុគ្គលិក និងនិយោជិត ប្រាក់បំណាច់របស់អភិបាលបណ្តោះអាសន្ន សោហ៊ុយរដ្ឋបាល និងប្រាក់ចំណាយប្រដាប់ក្តី

ខ-បណ្តឹងទាមទារដែលមានកិច្ចធានា រហូតដល់ត្រឹមកម្រិតខ្ពស់នៃតម្លៃនៃផ្នែកដែលមានកិច្ចធានាក្នុងបណ្តឹងទាមទារដូចបានកំណត់ក្នុងមាត្រា ២៦ នៃច្បាប់នេះ ឬថ្លៃលក់សុទ្ធដែលបានមកពីការលក់ទ្រព្យធានានេះ

គ-ពន្ធដារបស់រដ្ឋ ដែលមិនបានតម្កល់លិខិតជូនដំណឹង

ឃ-បណ្តឹងទាមទារគ្មានកិច្ចធានាទាំងអស់ដែលបានទទួលស្គាល់ ។

២-ចំពោះបណ្តឹងទាមទារដែលកំណត់នៅក្នុងចំណុចទី១-ខ ទឹកប្រាក់នៃបណ្តឹងទាមទារទាំងនេះ ដែលលើសពីកម្រិតដែលចែងក្នុងចំណុចទាំងនេះនឹងមានសិទ្ធិទទួលការទូទាត់ដូចគ្នានឹងបណ្តឹងទាមទារទូទៅ ដែលគ្មានកិច្ចធានាតាមចំណុចទី ១-ឃ ។

៣-ប្រាក់ថ្លៃលក់ដែលនៅសល់ពីការបែងចែក បន្ទាប់ពីការទូទាត់បណ្តឹងទាមទារទាំងអស់ដែលមានចែងក្នុងចំណុចទី ១ ត្រូវប្រគល់ទៅឱ្យកូនបំណុល ។

## មាត្រា ៥៨.-

១-លើកលែងតែទ្រព្យសកម្មរបស់កូនបំណុលដែលមិនអាចលក់បាន អភិបាលបណ្តោះអាសន្នត្រូវអនុវត្តការជម្រះបញ្ជីចំពោះទ្រព្យរបស់កូនបំណុល ហើយបែងចែកប្រាក់បានមកពីការលក់មិនឱ្យលើសពី ៦ (ប្រាំមួយ) ខែ បន្ទាប់ពីការចាប់ផ្តើមការជម្រះបញ្ជី ។

តាមពាក្យសុំជាលាយលក្ខណ៍អក្សររបស់អភិបាលបណ្តោះអាសន្ន តុលាការអាចពន្យារពេល ៦ (ប្រាំមួយ) ខែ បន្ថែមសម្រាប់ការជម្រះបញ្ជីទ្រព្យកូនបំណុល និងការបែងចែកប្រាក់ដែលបានពីការលក់ ។

២-មូលនិធិអាចត្រូវបានបែងចែកឱ្យទៅម្ចាស់បំណុលក្នុងសំណុំរឿងក្ស័យធនភ្លាមៗ នៅពេលមានប្រាក់គ្រប់គ្រាន់ក្នុងទ្រព្យរបស់កូនបំណុល ។

## ជំពូកទី ៨
## ការបញ្ចប់សំណុំរឿងក្ស័យធន បន្ទាប់ពីការជម្រះបញ្ជី

**មាត្រា ៥៩.-**

អភិបាលបណ្តោះអាសន្ន ត្រូវដាក់ជូនតុលាការនូវរបាយការណ៍ជាលាយលក្ខណ៍អក្សរស្តីពីសកម្មភាពរបស់ខ្លួន ។ របាយការណ៍នេះត្រូវចែងពីគណនីចុងក្រោយនៃការបែងចែក និងបណ្តឹងទាមទារដែលមិនទាន់បានទូទាត់ ។ អភិបាលបណ្តោះអាសន្នត្រូវដាក់ជូននូវរបាយការណ៍នេះ មិនឱ្យលើសពី ៣០ (សាមសិប) ថ្ងៃបន្ទាប់ពីការជម្រះឱ្យអស់នូវផ្នែកដែលអាចលក់បានទាំងអស់ក្នុងទ្រព្យរបស់កូនបំណុល ។

**មាត្រា ៦០.-**

តុលាការត្រូវកោះអញ្ជើញកិច្ចប្រជុំចុងក្រោយម្ចាស់បំណុលក្នុងរយៈពេល ១៤ (ដប់បួន) ថ្ងៃ បន្ទាប់ពីខ្លួនបានទទួលរបាយការណ៍ពីអភិបាលបណ្តោះអាសន្ន អនុលោមតាមមាត្រា ៥៩ នៃច្បាប់នេះ ។ កិច្ចប្រជុំរបស់ម្ចាស់បំណុលនេះ ត្រូវអនុម័តគណនីចុងក្រោយនៃការបែងចែក និងបណ្តឹងទាមទារដែលមិនទាន់បានទូទាត់ និងត្រូវសម្រេចលើការប្រើប្រាស់ផ្នែកនៃទ្រព្យរបស់កូនបំណុលដែលមិនអាចលក់បាន ។

**មាត្រា ៦១.-**

១-តុលាការត្រូវចេញសេចក្តីសម្រេចបញ្ចប់សំណុំរឿងក្ស័យធនភ្លាមៗ បន្ទាប់ពីកិច្ចប្រជុំចុងក្រោយរបស់ម្ចាស់បំណុល ។

២-សេចក្តីសម្រេចបញ្ចប់សំណុំរឿងក្ស័យធនរបស់តុលាការត្រូវផ្សព្វផ្សាយក្នុងរាជកិច្ច និងសារព័ត៌មានប្រចាំថ្ងៃនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៦២.-**

នៅពេលបញ្ចប់សំណុំរឿងក្ស័យធនបន្ទាប់ពីការជម្រះបញ្ជីការិយាល័យរបស់អភិបាលបណ្តោះអាសន្ន និងការិយាល័យរបស់គណៈកម្មការម្ចាស់បំណុល ត្រូវបិទលែងមានតទៅទៀត ។ កូនបំណុលមានសិទ្ធិក្នុងការលក់ជម្រះនូវទ្រព្យសម្បត្តិដែលនៅសល់ ។

**មាត្រា ៦៣.-**

ក្នុងករណីដែលកូនបំណុលជាក្រុមហ៊ុនមូលធន ត្រូវចាត់ទុកថាក្រុមហ៊ុននេះបានរំលាយនៅពេលតុលាការចេញសេចក្តីសម្រេចបញ្ចប់សំណុំរឿងក្ស័យធននៅពេលជម្រះបញ្ជី លើកលែងតែការបញ្ចប់សំណុំរឿងក្ស័យធននេះកើតឡើងពីការទូទាត់បណ្តឹងទាមទារទាំងអស់ស្រប់តាមមាត្រា ៥៧ នៃច្បាប់នេះ ។

**មាត្រា ៦៤.-**

១-ក្នុងករណីដែលសំណុំរឿងក្ស័យធនបានបើកទល់នឹងកូនបំណុលដែលជារូបវន្តបុគ្គល ឬ ក្រុមហ៊ុនសហកម្មសិទ្ធិដែលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយមានការបញ្ចប់សំណុំរឿងក្ស័យធននៅពេលជម្រះបញ្ជី កូនបំណុលអាចដាក់បណ្តឹងសុំទៅតុលាការដើម្បីសុំឱ្យរួចខ្លួនពីបណ្តឹងទាមទារទាំងអស់ដែលមានការទទួលស្គាល់ ហើយមិនទាន់បានទូទាត់ក្នុងសំណុំរឿងក្ស័យធន លើកលែងតែកូនបំណុលបានទទួលទ្រព្យសកម្ម ឬ ប្រាក់ដែលបែងចែកមិនអស់ តាមមាត្រា ៥៧ ចំណុចទី ៣ នៃច្បាប់នេះ ។ ទោះបីមានសេចក្តីសម្រេចដូចចំណុចទី ១ ក៏ដោយ ក៏បណ្តឹងទាមទារដែលគ្មានការទទួលស្គាល់ត្រូវបានចាត់ទុកជាមោឃៈនៅពេលបញ្ចប់សំណុំរឿងក្ស័យធន លើកលែងតែបណ្តឹងទាមទារដែលមានចែងតាមមាត្រា ៣៦ ចំណុចទី ៣ នៃច្បាប់នេះ ។

២-ម្ចាស់បំណុលទាំងអស់ និងតំណាងអយ្យការមានសិទ្ធិចូលរួមក្នុងកិច្ចសវនាការស្តីពីការជំនុំជម្រះលើបណ្តឹងសុំតាមចំណុចទី ១ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ក្រសួងព្រះបរមរាជវាំង

៣-តុលាការត្រូវបដិសេធការរំដោះកូនបំណុលឱ្យរួចផុតពីបណ្តឹងទាមទារដែលមិនទាន់ទូទាត់ ប្រសិនបើ :

ក-កូនបំណុលមានពិរុទ្ធភាពពីបទព្រហ្មទណ្ឌដែលពាក់ព័ន្ធនឹងបទល្មើសឆបោក ឬ បទល្មើសរំលោភលើសេចក្តីទុកចិត្តទាក់ទិននឹងភាពក្ស័យធននៃអាជីវកម្មរបស់កូនបំណុល

ខ-ក្នុងរយៈពេល៣(បី)ឆ្នាំ ចុងក្រោយមុនពេលបើកសំណុំរឿងក្ស័យធនកូនបំណុលបានធ្វើសេចក្តីបញ្ជាក់ជាលាយលក្ខណ៍អក្សរមិនត្រឹមត្រូវ ឬ មិនគ្រប់គ្រាន់អំពីស្ថានភាពសេដ្ឋកិច្ចរបស់ខ្លួនដោយចេតនា ឬ ដោយធ្វេសប្រហែស ដើម្បីទទួលបានឥណទាន ឬ ទទួលបានការទូទាត់ពីមូលនិធិសាធារណៈ ឬ ដើម្បីជៀសវាងការទូទាត់ប្រាក់ឱ្យស្ថាប័នសាធារណៈ

គ-ក្នុងរយៈពេល ១០ (ដប់) ឆ្នាំ ចុងក្រោយមុនពេលបើកសំណុំរឿងក្ស័យធនកូនបំណុលត្រូវបានផ្តល់ការរំដោះឱ្យរួចពីបណ្តឹងទាមទារដែលមិនទាន់ទូទាត់ក្នុងសំណុំរឿងក្ស័យធនមួយរួចហើយ

ឃ-ក្នុងរយៈពេល ១២ (ដប់ពីរ) ខែចុងក្រោយមុនពេលបើកសំណុំរឿងក្ស័យធន កូនបំណុលមិនបានទូទាត់គ្រប់ចំនួនទៅឱ្យម្ចាស់បំណុលដោយសារការបង្កើតបំណុលមិនសមស្របធ្វើឱ្យខ្ជះខ្ជាយទ្រព្យសកម្ម ឬ ការពន្យារពេលក្នុងការបើកសំណុំរឿងក្ស័យធន ឬ ម្ចាស់បំណុលគ្មានបំណងកែលំអលក្ខខណ្ឌសេដ្ឋកិច្ចរបស់កូនបំណុលទោះបីជាដោយចេតនា ឬ អចេតនាក៏ដោយ

ង-កូនបំណុលមិនបានរំលត់កាតព្វកិច្ចរបស់ខ្លួនតាមមាត្រា ៩ នៃច្បាប់នេះ ទោះបីជាដោយចេតនា ឬ អចេតនាក្តី

ច-ក្នុងកំឡុងពេលបើកសំណុំរឿងក្ស័យធន កូនបំណុលបានបំពានកាតព្វកិច្ចក្នុងការផ្តល់ព័ត៌មាន និងកាតព្វកិច្ចក្នុងការសហការនៅក្នុងសំណុំរឿងក្ស័យធន ទោះបីជាដោយចេតនា ឬ អចេតនាក្តី

ឆ-កូនបំណុលបានផ្តល់ព័ត៌មានមិនពិត ឬ ព័ត៌មានមិនគ្រប់គ្រាន់ដោយអនុលោមតាមមាត្រា ២៩ នៃច្បាប់នេះ ទោះបីជាដោយចេតនា ឬ អចេតនាក្តី ។

៤-សេចក្តីសម្រេចធ្វើឡើងតាមមាត្រានេះ មិនត្រូវមានអានុភាពលើលទ្ធភាពរបស់ម្ចាស់បំណុលក្នុងការដាក់ពាក្យសុំបន្តសំណុំរឿងក្ស័យធនប្រឆាំងនឹងកូនបំណុលតាមជំពូកទី ៩ ឡើយ ។

## ជំពូកទី ៩

## ការបន្តសំណុំរឿងក្ស័យធន ដែលត្រូវបានបញ្ចប់ បន្ទាប់ពីការជម្រះបញ្ជី

**មាត្រា ៦៥.-**

រាល់ម្ចាស់បំណុលដែលមានបណ្តឹងទាមទារក្នុងបញ្ជីបណ្តឹងទាមទារ ហើយមិនទាន់បានទូទាត់គ្រប់ចំនួនអាចដាក់បណ្តឹងសុំជាលាយលក្ខណ៍អក្សរទៅតុលាការ ដើម្បីសុំបន្តសំណុំរឿងក្ស័យធនក្នុងរយៈពេល ១(មួយ) ឆ្នាំ គិតចាប់ពីការបញ្ចប់សំណុំរឿងក្ស័យធន ។

**មាត្រា ៦៦.-**

១-សំណុំរឿងក្ស័យធនត្រូវចាប់ផ្តើមបន្តជាថ្មីតាមសេចក្តីសម្រេចរបស់តុលាការកាលណា :

ក-ចំនួនទឹកប្រាក់ដែលកំណត់សម្រាប់បណ្តឹងទាមទារសំណងនេះត្រូវបានលុបចោលឱ្យរួចផុតពីបណ្តឹងទាមទារនៅក្នុងពេលបិទសំណុំរឿងក្ស័យធន ។

ខ-មានទ្រព្យសកម្មដែលអាចយកមកទូទាត់បណ្តឹងទាមទាររបស់ម្ចាស់បំណុលបាន ហើយក្នុងករណីដែលតុលាការរកឃើញថាអត្ថិភាពនៃទ្រព្យសកម្មនេះមិនត្រូវបានលើកមកពិចារណាក្នុងសំណុំរឿងក្ស័យធន ។

២-សំណុំរឿងក្ស័យធនមិនត្រូវបន្តទេ កាលណាទឹកប្រាក់ ឬ តម្លៃនៃទ្រព្យសកម្មដែលចែងក្នុងចំណុចទី ១ មិនគ្រប់គ្រាន់សម្រាប់ទូទាត់ថ្លៃចំណាយសម្រាប់បន្តសំណុំរឿងនេះ ។

**មាត្រា ៦៧.-**

១-សេចក្តីសម្រេចបន្តសំណុំរឿងក្ស័យធន បង្កើតសិទ្ធិរបស់អភិបាលបណ្តោះអាសន្ន ឬ អភិបាលលើ ជំរះកម្មការម្ចាស់បំណុលឡើងវិញ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

២-សំណុំរឿងក្ស័យធនដែលបន្ត ត្រូវអនុវត្តតាមរបៀបដូចគ្នានឹងការជម្រះបញ្ជី និងបទប្បញ្ញត្តិដែលទាក់ទិននឹងច្បាប់នេះត្រូវអនុវត្តដូចគ្នានឹងសំណុំរឿងក្ស័យធនធម្មតាដែរ ។

## ជំពូកទី ១០

## អភិបាលបណ្តោះអាសន្ន និងម្ចាស់បំណុល

### ផ្នែកទី ១

### អភិបាលបណ្តោះអាសន្ន

**មាត្រា ៦៨.-**

១-មានតែរូបវន្តបុគ្គលទេ ដែលអាចត្រូវបានតែងតាំងជាអភិបាលបណ្តោះអាសន្នបានដោយតុលាការ ។

២-អភិបាលបណ្តោះអាសន្នមិនត្រូវ :

ក-ជាបុគ្គលដែលតុលាការបានផ្តន្ទាទោសពីបទល្មើស ដែលទាក់ទិននឹងអំពើឆបោក ឬ រំលោភលើសេចក្តីទុកចិត្ត

ខ-ជាកូនបំណុល ម្ចាស់បំណុល ឬ បុគ្គលដែលមានការពាក់ព័ន្ធ ឬ

គ-ជាសហព័ទ្ធរបស់ម្ចាស់បំណុល ឬ កូនបំណុល ឬ ជាសាច់ញាតិរបស់កូនបំណុល ឬ ម្ចាស់បំណុលណាម្នាក់ ។

៣-ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចតម្រូវឱ្យ :

ក-អភិបាលបណ្តោះអាសន្នមានលក្ខណសម្បត្តិបន្ថែមដែលមានចែងក្នុងចំណុចទី ២

ខ-អភិបាលបណ្តោះអាសន្នទាំងអស់ត្រូវទទួលអាជ្ញាប័ណ្ណពីក្រសួងយុត្តិធម៌ដោយអនុលោមតាមលក្ខខណ្ឌដែលកំណត់ក្នុងប្រកាសរបស់ក្រសួងយុត្តិធម៌ ។

**មាត្រា ៦៩.-**

១-តុលាការត្រូវប្រកាសដកអភិបាលបណ្តោះអាសន្ន ចេញពីសំណុំរឿងក្ស័យធនក្នុងករណីណាមួយដូចខាងក្រោម :

ក-តាមសំណើលាលែងពីតំណែងរបស់អភិបាលបណ្តោះអាសន្ន

ខ-អភិបាលបណ្តោះអាសន្ន បាត់បង់លក្ខណសម្បត្តិដូចបានចែងក្នុងមាត្រា

៦៨ នៃច្បាប់នេះ

គ-មានសំណើពីម្ចាស់បំណុលដែលមានបណ្តឹងទាមទារមានតម្លៃទឹកប្រាក់យ៉ាងតិច ៥១៖ (ហាសិបមួយភាគរយ) នៃបណ្តឹងទាមទារសរុប

ឃ-មានភស្តុតាងបញ្ជាក់ថា អភិបាលបណ្តោះអាសន្នមិនបានបំពេញភារកិច្ច ឬ បានបំពេញភារកិច្ចតាមវិធីដែលនាំឱ្យខូចផលប្រយោជន៍របស់ម្ចាស់បំណុលជាទូទៅ ។

២-តុលាការអាចប្រកាសដកអភិបាលបណ្តោះអាសន្នចេញនៅពេលណាក៏បាន តាមសេចក្តីសម្រេចរបស់ខ្លួនដោយអនុលោមតាមចំណុច ១ ខាងលើ ។

៣-តុលាការត្រូវតែងតាំងអភិបាលបណ្តោះអាសន្នថ្មី ដើម្បីជំនួសអភិបាលបណ្តោះអាសន្នដែលត្រូវបានដកចេញ ។

**មាត្រា ៧០.-**

១-អភិបាលបណ្តោះអាសន្នត្រូវបានចាត់ទុកថាជាមន្ត្រីរបស់តុលាការ ហើយត្រូវមានកាតព្វកិច្ចស្មោះត្រង់ចំពោះតុលាការតែប៉ុណ្ណោះ ។

២-អភិបាលបណ្តោះអាសន្នត្រូវតែផ្តល់ព័ត៌មានដែលទាក់ទិននឹងការចាត់ចែងទ្រព្យរបស់កូនបំណុល ឬ ស្ថានភាពនៃសំណុំរឿងក្ស័យធនឱ្យបានឆាប់រហ័ស តាមសំណើជាលាយលក្ខណ៍អក្សររបស់ម្ចាស់បំណុលម្នាក់ ឬ ច្រើននាក់ ។

**មាត្រា ៧១.-**

១-អភិបាលបណ្តោះអាសន្ន ត្រូវតែបំពេញមុខងារដោយប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់ ប្រកបដោយវិចារណញ្ញាណតាមកាលៈទេសៈដូចគ្នានឹងអាជីវករដែរ ។

២-អភិបាលបណ្តោះអាសន្ន ត្រូវទទួលខុសត្រូវចំពោះរាល់ភាគីនៃសំណុំរឿងក្ស័យធនលើការខូចខាត ដែលបណ្តាលមកពីការមិនបានអនុវត្តមុខងារ ដោយប្រុងប្រយ័ត្ននិងខ្វះការយកចិត្តទុកដាក់ ។

**មាត្រា ៧២.-**

១-អភិបាលបណ្តោះអាសន្ន ត្រូវទទួលបានប្រាក់បំណាច់ និងសំណងរាល់ថ្លៃចំណាយសមស្របដែលបានធ្វើឡើងក្នុងពេលបំពេញភារកិច្ច ។ ការគណនាអត្រាប្រាក់បំណាច់នេះ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

41/476

ត្រូវពិចារណាលើកត្តាមួយចំនួនដូចជាពេលវេលាដែលអភិបាលបណ្តោះអាសន្នបានចំណាយក្នុងពេលបំពេញការងារ តម្លៃសរុបនៃទ្រព្យរបស់កូនបំណុល និងវិសាលភាព និងភាពស្មុគស្មាញនៃសំណុំរឿងក្ស័យធន ។

២-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចចេញប្រកាសសម្រាប់គ្រប់គ្រងអត្រាប្រាក់បំណាច់សម្រាប់អភិបាលបណ្តោះអាសន្នបានតាមសំណើរបស់ម្ចាស់បំណុល ។

## ផ្នែកទី ២
## ម្ចាស់បំណុល

**មាត្រា ៧៣.-**

១-កិច្ចប្រជុំម្ចាស់បំណុលអាចត្រូវបានកោះអញ្ជើញដោយអភិបាលបណ្តោះអាសន្ននៅពេលណាក៏បាន បើអភិបាលបណ្តោះអាសន្នយល់ថាកិច្ចប្រជុំនេះមានប្រយោជន៍ដល់ការចាត់ចែងសំណុំរឿងក្ស័យធន ។

២-រាល់ម្ចាស់បំណុល អាចធ្វើសំណើជាលាយលក្ខណ៍អក្សរទៅអភិបាលបណ្តោះអាសន្នដើម្បីកោះប្រជុំម្ចាស់បំណុល ។ សំណើជាលាយលក្ខណ៍អក្សរត្រូវបញ្ជាក់ពីបញ្ហាដែលស្នើសម្រាប់កិច្ចប្រជុំ ។

៣-កិច្ចប្រជុំម្ចាស់បំណុល ត្រូវកោះអញ្ជើញដោយអភិបាលបណ្តោះអាសន្នក្នុងរយៈពេល ១៤ (ដប់បួន) ថ្ងៃ បន្ទាប់ពីបានទទួលសំណើជាលាយលក្ខណ៍អក្សរពីម្ចាស់បំណុលដែលស្នើសុំកិច្ចប្រជុំនេះ ។

៤-រាល់កិច្ចប្រជុំម្ចាស់បំណុល ត្រូវដឹកនាំដោយអភិបាលបណ្តោះអាសន្ន ឬចៅក្រម ។

៥-មាត្រានេះមិនត្រូវអនុវត្តចំពោះកិច្ចប្រជុំដំបូងរបស់ម្ចាស់បំណុលឡើយ ។

**មាត្រា ៧៤.-**

១-អភិបាលបណ្តោះអាសន្ន ត្រូវជូនដំណឹងដល់ម្ចាស់បំណុលទាំងអស់ អំពីការកោះប្រជុំម្ចាស់បំណុល ដោយផ្ញើលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរជូនម្ចាស់បំណុលទាំងអស់ និងផ្សាយក្នុងសារព័ត៌មានប្រចាំថ្ងៃសំខាន់ៗ យ៉ាងហោចណាស់ចំនួន ២ (ពីរ) នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយប្រកាសអំពីព័ត៌មានដូចខាងក្រោមនេះ :

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ក-ពេលវេលានៃកិច្ចប្រជុំ

ខ-ទីកន្លែងដែលត្រូវរៀបចំកិច្ចប្រជុំ

គ-បញ្ហាផ្សេងៗដែលស្នើសម្រាប់ការពិភាក្សាក្នុងកិច្ចប្រជុំ ។

២-ត្រូវជូនដំណឹងដល់ម្ចាស់បំណុលទាំងអស់អំពីការកោះប្រជុំម្ចាស់បំណុល យ៉ាងហោចណាស់ ៧ (ប្រាំពីរ) ថ្ងៃ មុនបើកកិច្ចប្រជុំ ។

៣-ការមិនគោរពតាមលក្ខខណ្ឌតម្រូវនៃមាត្រានេះ នឹងបណ្តាលឱ្យសេចក្តីសម្រេចដែលធ្វើឡើងក្នុងកិច្ចប្រជុំរបស់ម្ចាស់បំណុលនោះក្លាយជាមោឃៈ ។

៤-មាត្រានេះមិនត្រូវអនុវត្តចំពោះកិច្ចប្រជុំដំបូងរបស់ម្ចាស់បំណុលឡើយ ។

**មាត្រា ៧៥.-**

១-សេចក្តីសម្រេចទាំងអស់ក្នុងគ្រប់កិច្ចប្រជុំម្ចាស់បំណុល ត្រូវធ្វើឡើងដោយសំឡេងឆ្នោតគាំទ្ររបស់ម្ចាស់បំណុល ដែលកាន់កាប់ភាគច្រើននៃតម្លៃសរុបក្នុងបណ្តឹងទាមទាររបស់ម្ចាស់បំណុលដែលមានវត្តមានក្នុងកិច្ចប្រជុំ ហើយដែលមានសិទ្ធិបោះឆ្នោតក្នុងកិច្ចប្រជុំនេះ ។

២-មានតែម្ចាស់បំណុលដែលបណ្តឹងទាមទារមិនត្រូវបានជំទាស់ដោយអភិបាលបណ្តោះអាសន្ន ឬ ដោយម្ចាស់បំណុលផ្សេងទៀតទើបមានសិទ្ធិបោះឆ្នោតក្នុងកិច្ចប្រជុំម្ចាស់បំណុល ។ ម្ចាស់បំណុលដែលបណ្តឹងទាមទារត្រូវបានជំទាស់អាចបោះឆ្នោតបានតែក្នុងករណីមានការអនុញ្ញាតពីអភិបាលបណ្តោះអាសន្ន ឬ ពីម្ចាស់បំណុលផ្សេងទៀតដែលមានសិទ្ធិបោះឆ្នោតក្នុងកិច្ចប្រជុំ ។ ក្នុងករណីដែលភាគីទាំងនោះ មិនអាចមានកិច្ចព្រមព្រៀងលើសិទ្ធិបោះឆ្នោតរបស់ម្ចាស់បំណុលនៅក្នុងកិច្ចប្រជុំម្ចាស់បំណុល អភិបាលបណ្តោះអាសន្នត្រូវធ្វើបណ្តឹងជាលាយលក្ខណ៍អក្សរទៅតុលាការ ដើម្បីសុំសេចក្តីសម្រេចលើបញ្ហានេះ ហើយកិច្ចប្រជុំរបស់ម្ចាស់បំណុលនឹងត្រូវផ្អាកត្រឹមកាលបរិច្ឆេទមួយដែលមានរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ គិតពីថ្ងៃតុលាការចេញសេចក្តីសម្រេចលើបញ្ហានេះ ។

៣-ទោះបីមានចែងក្នុងចំណុចទី ២ ខាងលើនេះក៏ដោយ ក៏ម្ចាស់បំណុលដែលមានបណ្តឹងទាមទារដែលគ្មានការទទួលស្គាល់គ្មានសិទ្ធិបោះឆ្នោតដែរ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

៤-ម្ចាស់បំណុលអាចចូលរួមក្នុងកិច្ចប្រជុំទាំងអស់ ហើយអាចបោះឆ្នោតជាបុគ្គល ឬ តាមរយៈអាណត្តិគាហក ។

**មាត្រា ៧៦.-**

កិច្ចប្រជុំម្ចាស់បំណុល អាចពិចារណា និងសម្រេចលើបញ្ហាដែលទាក់ទិននឹងសំណុំរឿងក្ស័យធនមានជាអាទិ៍ :

១-ការទទួល និងពិចារណាលើរបាយការណ៍ស្តីពីស្ថានភាពនៃសំណុំរឿងក្ស័យធនពីអភិបាលបណ្តោះអាសន្ន ។

២-ការរៀបចំផែនការសម្របសម្រួល រាប់បញ្ចូលទាំងផែនការដែលធ្វើឡើងដោយអភិបាលបណ្តោះអាសន្នផង ។

៣-ការអនុម័តលើផែនការសម្របសម្រួល ។

៤-ការសម្រេចប្តឹងទៅតុលាការ ដើម្បីបញ្ចប់ប្រតិបត្តិការអាជីវកម្មរបស់កូនបំណុល និងចាប់ផ្តើមការជម្រះបញ្ជីលើទ្រព្យរបស់កូនបំណុល ។

៥-ការបញ្ឈប់ និងការផ្លាស់ប្តូរអភិបាលបណ្តោះអាសន្ន ។

៦-ការធ្វើសំណើទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ទាក់ទិននឹងប្រាក់បំណាច់របស់អភិបាលបណ្តោះអាសន្ន ។

៧-ការតែងតាំងគណៈកម្មការម្ចាស់បំណុល ។

៨-ការទទួលរាល់អនុសាសន៍ពីគណៈកម្មការម្ចាស់បំណុល ។

**មាត្រា ៧៧.-**

រាល់សេចក្តីសម្រេចដែលបានធ្វើឡើងក្នុងកិច្ចប្រជុំម្ចាស់បំណុល ត្រូវភ្ជាប់កាតព្វកិច្ចរបស់ម្ចាស់បំណុលទាំងអស់ រាប់បញ្ចូលទាំងម្ចាស់បំណុលដែលអវត្តមានក្នុងកិច្ចប្រជុំផងដែរ ។

**មាត្រា ៧៨.-**

១-[illegible]ប់កិច្ចប្រជុំម្ចាស់បំណុល ម្ចាស់បំណុលអាចជ្រើសតាំងគណៈកម្មការម្ចាស់បំណុលដែលមានសមាជិកយ៉ាងហោចណាស់ ៣(បី) រូប ហើយមិនលើសពី ៩ (ប្រាំបួន)

រូប ដែលជ្រើសរើសក្នុងចំណោមតំណាងម្ចាស់បំណុលមានកិច្ចធានា និងម្ចាស់បំណុលគ្មានកិច្ចធានា ។

២-ថ្លៃចំណាយទាំងអស់ដែលម្ចាស់បំណុលបានចំណាយក្នុងការបង្កើត និងដំណើរការនៃគណៈកម្មការម្ចាស់បំណុល ត្រូវបានចាត់ទុកជាបណ្តឹងទាមទារដែលធ្វើឡើងដោយអភិបាលបណ្តោះអាសន្នក្នុងដំណើរការសំណុំរឿងក្ស័យធន ហើយត្រូវទូទាត់ករណីនេះដោយអនុលោមតាមមាត្រា ៥៧ នៃច្បាប់នេះ ។

**មាត្រា ៧៩.-**

១-គណៈកម្មការម្ចាស់បំណុល ត្រូវធ្វើការងារតំណាងឱ្យផលប្រយោជន៍របស់ម្ចាស់បំណុលទាំងមូល ។

២-គណៈកម្មការម្ចាស់បំណុលត្រូវតែបំពេញកាតព្វកិច្ចរបស់ខ្លួនតាមសេចក្តីសម្រេចរបស់ម្ចាស់បំណុលដែលមានទឹកប្រាក់ភាគច្រើនក្នុងបណ្តឹងទាមទារសរុបទល់នឹងកូនបំណុល ។ បើមានការស្នើសុំពីអភិបាលបណ្តោះអាសន្ន គណៈកម្មការម្ចាស់បំណុលអាចជួយអភិបាលបណ្តោះអាសន្នក្នុងការចាត់ចែងទ្រព្យរបស់កូនបំណុលបាន ។

៣-តាមការស្នើសុំពីគណៈកម្មការម្ចាស់បំណុល អភិបាលបណ្តោះអាសន្នត្រូវអនុញ្ញាតឱ្យគណៈកម្មការម្ចាស់បំណុលពិនិត្យបញ្ជីគណនេយ្យ និងគណនីទាំងឡាយរបស់កូនបំណុល ។

## ជំពូកទី ១១

## ការបញ្ជូនឯកសារ

**មាត្រា ៨០.-**

១-ការបញ្ជូនឯកសារដែលទាក់ទងនឹងសំណុំរឿងក្ស័យធនទៅឱ្យក្រុមហ៊ុនសហកម្មសិទ្ធិ ឬ នីតិបុគ្គល ត្រូវធ្វើឡើងតាមរយៈការប្រគល់ឯកសារនៅទីស្នាក់ការអាជីវកម្មរបស់ក្រុមហ៊ុនសហកម្មសិទ្ធិ ឬ នីតិបុគ្គលដែលបានចុះបញ្ជី ។

២-ការបញ្ជូនឯកសារដែលទាក់ទងនឹងសំណុំរឿងក្ស័យធនទៅឱ្យរូបវន្តបុគ្គលដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើឡើងតាមរយៈការប្រគល់ឯកសារនៅលំនៅឋានអចិន្ត្រៃយ៍របស់បុគ្គលនោះនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៣-ការបញ្ជូនឯកសារដែលទាក់ទងនឹងសំណុំរឿងក្ស័យធនទៅឱ្យនីតិបុគ្គលដែលបង្កើតឡើងតាមច្បាប់បរទេស ឬរូបវន្តបុគ្គលដែលរស់នៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើឡើងតាមរយៈការចុះផ្សាយជូនដំណឹងយ៉ាងហោចណាស់ក្នុងសារព័ត៌មានធំមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងក្នុងសារព័ត៌មានធំមួយទៀតនៅក្នុងប្រទេសដែលជាកន្លែងបង្កើតនីតិបុគ្គល ឬ ជាកន្លែងរូបវន្តបុគ្គលនោះរស់នៅ ។

៤-តាមបណ្តឹងសុំរបស់ភាគីពាក់ព័ន្ធ តុលាការអាចបញ្ជាឱ្យបញ្ជូនឯកសារដែលទាក់ទងនឹងសំណុំរឿងក្ស័យធន តាមវិធីផ្សេងពីវិធីដែលបានចែងក្នុងចំណុចទី ១ រហូតដល់ចំណុចទី ៣ នៃមាត្រានេះ ប្រសិនបើតុលាការយល់ថាវិធីផ្សេងនោះមានភាពសមស្រប និងជាក់លាក់ជាង ។

## ជំពូកទី ១២
## ទោសប្បញ្ញត្តិ

**មាត្រា ៨១.-**

រាល់បទល្មើសក្នុងសំណុំរឿងក្ស័យធនត្រូវផ្តន្ទាទោសតាមបញ្ញត្តិច្បាប់ព្រហ្មទណ្ឌជាធរមាន ។

## ជំពូកទី ១៣
## អន្តរប្បញ្ញត្តិ

**មាត្រា ៨២.-**

១-ក្នុងរយៈពេលដែលព្រះរាជាណាចក្រកម្ពុជានៅមិនទាន់មានតុលាការពាណិជ្ជកម្ម តុលាការសាមញ្ញមានសមត្ថកិច្ច លើរឿងក្តីក្ស័យធនទាំងអស់ដែលមានចែងក្នុងច្បាប់នេះ ។

២-នៅពេលដែលតុលាការពាណិជ្ជកម្មត្រូវបានបង្កើតឡើងនៅព្រះរាជាណាចក្រកម្ពុជា តុលាការសាមញ្ញត្រូវផ្ទេរសមត្ថកិច្ចលើរឿងក្តីក្ស័យធនទាំងអស់ជូនទៅតុលាការពាណិជ្ជកម្ម ។

## ជំពូកទី ១៤

## អវសានប្បញ្ញត្តិ

**មាត្រា ៨៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨៤.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៧

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសបន្ទាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋមន្ត្រីស្តីទី

**ហត្ថលេខា**

**គឹម ស៊ីថន**

លេខៈ ៥៧០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០០៧

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ជិនកេន

# ព្រះរាជក្រម

នស/រកម/០៦០៩/០០៧

## យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានទ្រង់យល់ សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្ដីពីភតិសន្យាហិរញ្ញវត្ថុ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ២០០៩ នាសម័យប្រជុំ រដ្ឋសភាលើកទី ២ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបាន យល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០០៩ នាសម័យប្រជុំវិសាមញ្ញ ច្បាប់នេះដែលមានសេចក្ដីទាំងស្រុង ដូចតទៅនេះ៖

SORITHY-PHEAKDEY.COM

# ច្បាប់

# ស្តីពី

# ភតិសន្យាហិរញ្ញវត្ថុ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់សិទ្ធិ និងកាតព្វកិច្ចដល់ភាគីពាក់ព័ន្ធនឹងប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ និងដាក់ចេញនូវវិធានការ ដើម្បីការពារសិទ្ធិទាំងនោះ ។

**មាត្រា ២.-**

ច្បាប់នេះមានគោលបំណងអភិវឌ្ឍប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ និងសហគ្រាស ដើម្បីបង្កលក្ខណៈធ្វើប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុដោយស្មើភាព សុវត្ថិភាព ប្រសិទ្ធភាព និងផលិតភាព ស្របតាមការវិវត្តនៃសេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាព គ្របដណ្តប់លើភតិសន្យាហិរញ្ញវត្ថុនៃចលនវត្ថុក្នុងព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះ ។

**មាត្រា ៤.-**

ពាក្យបច្ចេកទេសដែលប្រើក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ :

- **ភតិបតី** : សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលផ្ទេរសិទ្ធិកាន់កាប់ និងសិទ្ធិប្រើប្រាស់ចលនវត្ថុទៅឱ្យភតិកៈ ។
- **ភតិកៈ** : សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលទទួលសិទ្ធិកាន់កាប់ និងសិទ្ធិប្រើប្រាស់ចលនវត្ថុពីភតិបតី ។
- **ចលនវត្ថុ** : សំដៅដល់ទ្រព្យសម្បត្តិ គ្រឿងចក្រ និងឧបករណ៍ទាំងអស់ លើកលែងតែដី និងអគារ ។
- **រយៈពេល** : សំដៅដល់រយៈពេលដែលមានចែងក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ដែលក្នុងរយៈពេលនោះភតិកៈត្រូវបានអនុញ្ញាតឱ្យកាន់កាប់ និងប្រើប្រាស់ចលនវត្ថុដែលបានជួល ។
- **ភតិសន្យា** : សំដៅដល់ប្រតិបត្តិការដែលភតិបតីចុះកិច្ចព្រមព្រៀងជាមួយ

/.

ភតិកៈ ក្នុងនោះភតិកៈត្រូវបានផ្តល់សិទ្ធិឱ្យកាន់កាប់ និងប្រើប្រាស់ចលនវត្ថុក្នុងរយៈពេលមួយ ដោយការបង់ថ្លៃឈ្នួលតាមគ្រា ឬ តាមតម្លៃសមមូល ។ ភតិសន្យា ត្រូវរួមបញ្ចូលទាំងភតិសន្យាបន្តផងដែរ ។

- **ភតិសន្យាបន្ត** : សំដៅដល់ប្រតិបត្តិការដែលចលនវត្ថុ ត្រូវបានជួលដោយភតិកៈដំបូង ត្រូវបានជួលបន្តឱ្យភាគីផ្សេងទៀត ហើយកិច្ចព្រមព្រៀងភតិសន្យារវាងគូភាគីដំបូង នៅមានសុពលភាពដដែល ។

- **ភតិសន្យាហិរញ្ញវត្ថុ** : សំដៅដល់ភតិសន្យាសម្រាប់រយៈពេលដំបូងមួយឆ្នាំ ឬ ច្រើនជាងដែលរយៈពេលនោះមិនអាចកែប្រែបាន ក្នុងនោះ :

ក-ភតិកៈបញ្ជាក់ច្បាស់លាស់នូវចលនវត្ថុ និងជ្រើសរើសអ្នកផ្គត់ផ្គង់ដោយមិនផ្អែកសំខាន់លើជំនាញ និងការវិនិច្ឆ័យរបស់ភតិបតីឡើយ

ខ-ភតិបតីទិញចលនវត្ថុតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ដើម្បីជួលឱ្យភតិកៈ ។

ក៏ប៉ុន្តែ បើមានការជួលបន្តនូវចលនវត្ថុដែលបានជួលពីមុនពីភតិបតីដដែល ការជួលបន្តនោះអាចនៅតែជាភតិសន្យាហិរញ្ញវត្ថុដដែល ។

ភតិសន្យាអាចជាភតិសន្យាហិរញ្ញវត្ថុ ដោយមិនគិតដល់ :

ក- ការបង់ថ្លៃឈ្នួលភតិសន្យាត្រូវបាន ឬ មិនត្រូវបានគណនាបញ្ចូលនូវការរំលស់ទាំងមូល ឬ ការរំលស់មួយផ្នែកធំនៃតម្លៃចលនវត្ថុ ឬ

ខ- ភតិកៈមាន ឬ ពុំមានជម្រើស ឬ ក្រោយមកទទួលយកជម្រើសថាទិញ ឬ បន្តជួលចលនវត្ថុ មួយរយៈពេលបន្ថែមទៀត ។

- **ការបង់ថ្លៃឈ្នួលជាមុន** : សំដៅដល់ចំនួននៃការបង់ថ្លៃឈ្នួលតាមគ្រាដោយភតិកៈ នៅពេល ឬ មុនពេលចាប់ផ្តើមជួល ។ ការបង់ថ្លៃឈ្នួលជាមុន មិនមែនជាប្រាក់ប្រាតិភោគទេ ។

- **ប្រាក់ប្រាតិភោគ** : សំដៅដល់ចំនួនប្រាក់ដែលត្រូវបានបង់ដោយភតិកៈនិងត្រូវបានកាន់កាប់ដោយភតិបតី ដើម្បីធានាកាតព្វកិច្ច សម្រាប់ឱ្យភតិកៈអនុវត្តតាមភតិសន្យាហិរញ្ញវត្ថុ ដោយពេញលេញ និងទៀងទាត់ ។

- **អ្នកផ្គត់ផ្គង់** : សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលភតិបតីទទួលចលន-

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

វត្ថុដែលត្រូវជួលឱ្យភតិកៈ ។ លទ្ធកម្មរបស់ភតិបតីអាចប្រព្រឹត្តទៅតាមរយៈការទិញ ការជួល ការប្រគល់សិទ្ធិឱ្យទិញ ឬ ឱ្យជួល រួមទាំងការប្រគល់សិទ្ធិពីភតិកៈផងដែរ ។ នៅក្នុងប្រតិបត្តិការលក់ហើយជួលមកវិញ ភតិកៈអាចជាអ្នកផ្គត់ផ្គង់ ។

- **កិច្ចព្រមព្រៀងផ្គត់ផ្គង់** : សំដៅដល់កិច្ចព្រមព្រៀងដែលភតិបតីទិញចលនវត្ថុដែលត្រូវជួលឱ្យភតិកៈ ។

- **កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ** : សំដៅដល់កិច្ចព្រមព្រៀងដែលភតិបតីទិញចលនវត្ថុ ដែលភតិកៈបានជ្រើសរើសពីអ្នកផ្គត់ផ្គង់ ហើយជួលចលនវត្ថុនេះទៅឱ្យភតិកៈ និងអនុញ្ញាតឱ្យភតិកៈបង់ថ្លៃឈ្នួលតាមកាលកំណត់ ។

## ជំពូកទី ២
## កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ

**មាត្រា ៥.-**

កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុត្រូវតែសរសេរជាលាយលក្ខណ៍អក្សរ ចុះហត្ថលេខាដោយភតិបតីនិងភតិកៈ ហើយត្រូវកំណត់រយៈពេល និងលក្ខខណ្ឌនៃគ្រប់ភាគីទាក់ទងនឹងចលនវត្ថុដែលបានជួល ។ កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមិនចាំបាច់មានការបញ្ជាក់ពីសារការីក៏បានដែរ លើកលែងតែមានច្បាប់ណាមួយតម្រូវ ។

**មាត្រា ៦.-**

កិច្ចព្រមព្រៀងមួយដែលពេញលក្ខណៈជាកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ លុះត្រាតែកិច្ចព្រមព្រៀងនោះ មានចែងចំណុចសំខាន់ៗយ៉ាងតិច ដូចខាងក្រោម :

ក-ការពណ៌នាពីចលនវត្ថុដែលបានជួល

ខ-ចំនួនប្រាក់ ការកំណត់គ្រា និងរយៈពេលនៃការបង់ថ្លៃឈ្នួល

គ-កាលបរិច្ឆេទចាប់ផ្ដើមភតិសន្យាហិរញ្ញវត្ថុ និង

ឃ-ហត្ថលេខារបស់ភតិបតី និងភតិកៈ ។

**មាត្រា ៧.-**

កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុអាចមានចែងអំពីប្រាក់ប្រាតិភោគ ឬ ការបង់ថ្លៃឈ្នួលជាមុន ឬ ទាំងពីរ ។ សម្រាប់ភតិកៈ ប្រាក់ប្រាតិភោគ អាច ឬ មិនអាចទទួលបាននូវ

ROYAUME DU CAMBODGE
MINISTÈRE ... ROYAL
ព្រះរាជាណាចក្រកម្ពុជា

ចំណូលការប្រាក់ ហើយអាចត្រូវបានបង្វិលឱ្យភតិកៈវិញ ឬ អាចប្រើប្រាស់ ដោយភតិបតី ដូចមានចែងក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ។

ក្នុងករណីដែលកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ មិនមានចែងអំពីការប្រើប្រាក់ប្រាតិភោគទេ ប្រាក់ប្រាតិភោគនោះ មិនត្រូវទទួលការប្រាក់ឡើយ និងត្រូវបង្វិលទៅឱ្យភតិកៈវិញ ក្រោយពេលដែលភតិកៈបានបំពេញកាតព្វកិច្ចភតិសន្យាហិរញ្ញវត្ថុបានពេញលេញនិងតាមពេលកំណត់ហើយ ។ ការបង់ថ្លៃឈ្នួលជាមុនមិនត្រូវទទួលបានការប្រាក់ទេ ។ ប្រាក់ប្រាតិភោគ និងការបង់ថ្លៃឈ្នួលជាមុន អាចជាចំនួនប្រាក់ដែលបានព្រមព្រៀងគ្នារវាងភាគីទាំងពីរ ។

**មាត្រា ៨.-**

បើកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមានចែងថា ចលនវត្ថុត្រូវបិទស្លាកសម្គាល់ជាកម្មសិទ្ធិរបស់ភតិបតី ឬ ជាកម្មវត្ថុនៃភតិសន្យាពីភតិបតី ស្លាកសម្គាល់ទាំងនោះមិនត្រូវដកចេញ ឬ ធ្វើឱ្យមើលមិនស្គាល់ ដោយជនណាម្នាក់ ក្រៅពីភតិបតី ឬ អ្នកតំណាងរបស់ភតិបតីនោះឡើយ ។

នៅពេលបានរកឃើញការខូចខាតណាមួយនៃស្លាកសម្គាល់ដែលបណ្តាលឱ្យមើលមិនស្គាល់ ភតិកៈត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់ទៅឱ្យភតិបតី ឬ បើពុំដូច្នោះទេ ភតិកៈត្រូវទទួលខុសត្រូវក្នុងកម្រិតដូចដែលភតិកៈបានដកស្លាកសម្គាល់ចេញដោយគ្មានការអនុញ្ញាត ។ ភតិកៈមិនត្រូវទទួលខុសត្រូវក្រោមមាត្រានេះឡើយ ប្រសិនបើភតិបតីខកខានមិនបានផ្លាស់ប្តូរស្លាកសម្គាល់នោះ ក្រោយពីភតិកៈបានជូនដំណឹងទាន់ពេលវេលាឱ្យទៅភតិបតីរួចហើយ ។

**មាត្រា ៩.-**

បើភតិបតី និងភតិកៈព្រមព្រៀងគ្នាសងតាមវិធីមិនមែនរូបិយវត្ថុ ដូចជាផលិតផល សេវាកម្ម ការដោះដូរជាវត្ថុ តម្លៃនៃការទូទាត់សង ក្នុងទម្រង់មិនមែនរូបិយវត្ថុនោះ ត្រូវកំណត់តាមថ្លៃទីផ្សារ លើកលែងតែភាគីទាំងពីរ បានចែងក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុនូវតម្លៃណាមួយផ្សេងពីនេះ ។

**មាត្រា ១០.—**

នៅក្រោមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ភតិកៈទទួលយកការប្រើប្រាស់ចលនវត្ថុ ក្នុងរយៈពេលយ៉ាងតិចបំផុត ០១ (មួយ) ឆ្នាំ ។ នៅចុងបញ្ចប់នៃកិច្ចព្រមព្រៀងនោះ ភតិកៈអាច ឬ មិនអាចទិញផ្តាច់នូវចលនវត្ថុនោះ ។ ភតិបតីផ្តល់ហិរញ្ញប្បទានសម្រាប់ឱ្យភតិកៈប្រើប្រាស់ចលនវត្ថុ មិនមែនឱ្យធ្វើជាម្ចាស់កម្មសិទ្ធិលើចលនវត្ថុនោះទេ ។

## ជំពូកទី ៣
## សិទ្ធិ និងភារកិច្ចរបស់ភតិបតី

**មាត្រា ១១.—**

នៅក្នុង និងក្រោយរយៈពេលនៃភតិសន្យាហិរញ្ញវត្ថុ ភតិបតីនៅតែជាម្ចាស់កម្មសិទ្ធិលើចលនវត្ថុដែលបានផ្តល់ លើកលែងតែកម្មសិទ្ធិត្រូវបានផ្ទេរទៅឱ្យភតិកៈ ឬ ទៅឱ្យភាគីផ្សេងទៀត ។

**មាត្រា ១២.—**

ភតិបតីត្រូវទទួលខុសត្រូវបង់ពន្ធនាំចូល និងកាតព្វកិច្ចសារពើពន្ធផ្សេងៗទៀត តាមច្បាប់កំណត់ និងសោហ៊ុយចុះបញ្ជីលើចលនវត្ថុដែលបានផ្តល់ លើកលែងតែកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមានចែងផ្សេងពីនេះ ។

**មាត្រា ១៣.—**

ភតិបតីត្រូវទូទាត់សងថ្លៃទិញចលនវត្ថុទៅឱ្យអ្នកផ្គត់ផ្គង់ នៅពេលដែលភតិកៈបានយល់ព្រមទទួលចលនវត្ថុនោះ ដោយគ្មានលក្ខខណ្ឌ ។

**មាត្រា ១៤.—**

ភតិបតីត្រូវធានាយ៉ាងណាឱ្យភតិកៈបានប្រើប្រាស់ និងកាន់កាប់ចលនវត្ថុ ដែលបានផ្តល់ ដោយគ្មានការរំខាន នៅក្នុងរយៈពេលអនុវត្តភតិសន្យាហិរញ្ញវត្ថុ ដរាបណាភតិកៈអនុវត្តតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ។

-ភតិកៈគ្មានសាធនភាព ក្ស័យធន ត្រូវបានរំលាយ ឬ ទទួលមរណភាព ហើយពុំមានអ្នកស្នងបន្ត ។

គ-ទោះបីជាកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ត្រូវបាន ឬ មិនត្រូវបានរំលាយ នៅមុនពេលផុតរយៈពេលក៏ដោយ ភតិបតីអាច :

-ទាមទារយកចលនវត្ថុដែលបានជួលមកកាន់កាប់វិញ ដោយមិនចាំបាច់ប្តឹងទៅតុលាការ ប្រសិនបើការទាមទារនោះធ្វើឡើង ដោយគ្មានអំពើហិង្សា និង

-ទាមទារសំណងការខូចខាត ដែលភតិបតីត្រូវទទួលបានរាប់ទាំងចំណាយបន្ថែម បណ្តាលមកពីកំហុសរបស់ភតិកៈផង ។ កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុអាចចែងអំពីវិធីគណនាការខូចខាត ហើយវិធីគណនានេះ អាចអនុវត្តបានដោយភាគីទាំងពីរ លើកលែងតែវិធីគណនានេះ បណ្តាលឱ្យមានវិការៈធ្ងន់ធ្ងរលើសពីសំណងការខូចខាតដែលភតិបតីអាចនឹងទទួលបាន ប្រសិនបើភតិកៈអនុវត្តតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ។

ឃ-បើចាំបាច់ ភតិបតីអាចដាក់ពាក្យស្នើសុំដីកាសម្រេចពីតុលាការឱ្យភតិកៈប្រគល់ចលនវត្ថុជួលនោះមកភតិបតីវិញ ដោយភ្ជាប់ជាមួយនូវរាល់ឯកសារភស្តុតាងដែលបង្ហាញថា ភតិកៈមិនបានគោរពតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ។ ប៉ុន្តែ ភតិបតីនៅតែត្រូវទទួលខុសត្រូវចំពោះការខូចខាតទាំងឡាយដែលកើតឡើងដល់ភតិកៈ បើនៅពេលក្រោយមកមានភស្តុតាងបង្ហាញថា ការទាមទារចលនវត្ថុដែលបានជួលមកវិញដោយភតិបតីនោះ ជាការរំលោភលើកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ។

**មាត្រា ១៨.-**

ភតិបតីមានសិទ្ធិតម្រូវឱ្យភតិកៈសងការខាតបង់ បំណុល ការខូចខាត ឬ ផលវិបាកផ្សេងៗណាមួយ ឬ ទាំងអស់ ដែលកើតឡើងពី ឬ ពាក់ព័ន្ធទៅនឹងការប្រើប្រាស់ និងការកាន់កាប់របស់ភតិកៈលើចលនវត្ថុដែលបានជួល ។

**មាត្រា ១៩.-**

ភតិបតីអាចទាមទារឱ្យភតិកៈទិញ និងបង់ថ្លៃធានារ៉ាប់រងលើចលនវត្ថុ ដែលបានជួលនៅគ្រប់អំឡុងពេលដែលភតិកៈកាន់កាប់ ឬ គ្រប់គ្រងចលនវត្ថុនោះ ទោះបីជារយៈ

ksl

ពេលអនុវត្តភតិសន្យាហិរញ្ញវត្ថុ បានឈានដល់ទីបញ្ចប់ហើយ ឬ កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ត្រូវបានរំលាយមុនពេលក៏ដោយ រហូតដល់ពេលដែលចលនវត្ថុនោះ ត្រូវបានប្រគល់ឱ្យភតិបតីកាន់កាប់ និងគ្រប់គ្រងវិញ ។

ប្រសិនបើភតិកៈត្រូវទិញ និងបង់ថ្លៃធានារ៉ាប់រងហើយបែរជាខកខានទៅវិញ ភតិបតីមានសិទ្ធិទិញ តែមិនមានភារកិច្ចត្រូវទិញធានារ៉ាប់រងនេះទេ ហើយភតិកៈត្រូវសងរាល់ការចំណាយទៅឱ្យភតិបតីវិញភ្លាម ប្រសិនបើភតិបតីបានចំណាយរួចហើយ ។

**មាត្រា ២០.–**

ចលនវត្ថុដែលបានជួល មិនមែនជាចំណែកនៃទ្រព្យសម្បត្តិរបស់ភតិកៈទេ ក្នុងន័យនេះ នៅពេលដែលភតិកៈក្ស័យធន ម្ចាស់បំណុលទាំងឡាយរបស់ភតិកៈ រួមទាំងម្ចាស់បំណុលដែលបានទទួលសិទ្ធិរឹបអូសទ្រព្យសម្បត្តិភតិកៈ តាមសេចក្តីសម្រេចរបស់តុលាការផង គ្មានសិទ្ធិទាមទារយកចលនវត្ថុដែលបានជួលនោះទេ ។

**មាត្រា ២១.–**

ភតិបតីអាចចាត់ចែង ផ្ទេរ ឬ ម្យ៉ាងទៀតបែងចែកសិទ្ធិទាំងអស់ ឬ សិទ្ធិណាមួយរបស់ខ្លួនលើចលនវត្ថុដែលបានជួល ឬ តាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ទៅឱ្យភាគីណាមួយ ដោយមិនចាំបាច់មានការយល់ព្រមពីភតិកៈ ។ ការផ្ទេរបែបនេះ មិនត្រូវធ្វើឱ្យភតិបតីរួចផុតពីកាតព្វកិច្ចណាមួយ ឬ ផ្លាស់ប្តូរភាពដើមនៃកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុទេ ។ កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុអាចចែងថា ភតិកៈយល់ព្រមមិនទាមទារកាត់កងការពារ ឬ ទាមទារប្រឆាំងនឹងអ្នកដែលត្រូវបានប្រគល់សិទ្ធិ ឬ អនុប្បទានិករបស់ភតិបតីឡើយ ។

**មាត្រា ២២.–**

ក្នុងករណីភតិបតីក្ស័យធន ឥណទាយករបស់ភតិបតី និងភាគីពាក់ព័ន្ធផ្សេងទៀតមិនមានសិទ្ធិច្រើនជាងសិទ្ធិដែលភតិបតីមាន តាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុនោះ

## ជំពូកទី ៤

## សិទ្ធិ និងភារកិច្ចរបស់ភតិកៈ

**មាត្រា ២៣.–**

ភតិកៈមានកាតព្វកិច្ចយល់ព្រមទទួលចលនវត្ថុដែលបានជួល បើចលនវត្ថុនោះ ត្រូវបានប្រគល់ទាន់ពេលវេលាកំណត់ និងត្រឹមត្រូវតាមកិច្ចព្រមព្រៀងផ្តត់ផ្គង់ ។ បើចលនវត្ថុដែលបានជួលមិនត្រូវបានប្រគល់ ឬ ប្រគល់យឺតពេល ឬ មិនត្រូវតាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ទេនោះ នៅពេលយល់ព្រម ឬ មុនពេលយល់ព្រម ប៉ុន្តែពុំមែនក្រោយពេលយល់ព្រមទទួលនោះទេ ភតិកៈមានសិទ្ធិបដិសេធចលនវត្ថុនោះ ហើយទាមទារភ្លាមឱ្យអ្នកផ្គត់ផ្គង់ជួសជុលវិការៈនោះ ឬ រំលាយភតិសន្យាហិរញ្ញវត្ថុ ប៉ុន្តែគ្មានសិទ្ធិរំលាយ ដកហូត ឬ កែប្រែកិច្ចព្រមព្រៀងផ្គត់ផ្គង់ ដោយពុំមានការយល់ព្រមពីភតិបតីឡើយ ។

ភតិបតីមានសិទ្ធិឱ្យអ្នកផ្គត់ផ្គង់ប្រគល់ចលនវត្ថុ ស្របតាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ តែមិនមានកាតព្វកិច្ចទទួលខុសត្រូវលើការខូចខាត ដោយសារការខកខានរបស់អ្នកផ្គត់ផ្គង់ឡើយ ។

**មាត្រា ២៤.–**

ការយល់ព្រមទទួលចលនវត្ថុ អាចជាឯកសារឬអាចតាមរយៈមធ្យោបាយផ្សេងៗទៀត ដូចខាងក្រោម :

ក-ក្រោយពេលដែលភតិកៈបានពិនិត្យចលនវត្ថុ ដែលត្រូវជួលនោះរួចហើយ ហើយបានបញ្ជាក់ថា អាចទទួលយកបាន ទោះបីជាចលនវត្ថុនោះស្រប ឬ មិនស្រប តាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ក៏ដោយ

ខ-ភតិកៈមិនបានជូនដំណឹងទាន់ពេលវេលាដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងផ្គត់ផ្គង់ ពីភាពមិនស្របតាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ទៅភតិបតី និងអ្នកផ្គត់ផ្គង់ ដើម្បីឱ្យអ្នកផ្គត់ផ្គង់ ឬ ភតិបតីអាចដោះស្រាយទាន់ពេលវេលា ក្រោយពេលបានទទួលដំណឹងនោះ

គ-កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុអាចចែងថា ភតិកៈត្រូវបានចាត់ទុកថា

បានយល់ព្រមទទួលចលនវត្ថុ លើកលែងតែភតិបតីបានទទួលសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបដិសេធរបស់ភតិកៈ ដែលមានរាយលម្អិតពីមូលហេតុច្បាស់លាស់ក្នុងរយៈពេលកំណត់ដប់ (១០) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីភតិកៈបានទទួលចលនវត្ថុនោះ ។

**មាត្រា ២៥.-**

តាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ភតិកៈមានកាតព្វកិច្ចបង់ថ្លៃឈ្នួលតាមកិច្ចព្រមព្រៀងដោយមិនអាចបដិសេធបាន នៅពេលដែលភតិកៈ បានយល់ព្រមទទួលចលន-វត្ថុជាផ្លូវការហើយ ។

**មាត្រា ២៦.-**

ភតិកៈ ត្រូវប្រើប្រាស់ចលនវត្ថុឱ្យ បានត្រឹមត្រូវ តាមមុខសញ្ញាប្រើប្រាស់ស្របតាមច្បាប់វិធាន និងបទបញ្ញាជាធរមាន និងតាមលក្ខណៈបច្ចេកទេស ។ ភតិកៈក៏ត្រូវចំណាយលើការថែទាំ និងជួសជុលចលនវត្ថុឱ្យនៅល្អ និងអាចប្រើប្រាស់បាន លើកលែងតែកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមានចែងផ្សេងពីនេះ ។

**មាត្រា ២៧.-**

នៅដំណាក់កាលផុតរយៈពេល ឬ នៅពេលរំលាយកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ និងក្នុងករណីមិនបានទិញ ឬ មិនបានជួលបន្តទេនោះ ភតិកៈត្រូវប្រគល់ចលនវត្ថុដែលបានជួលទៅឱ្យភតិបតីវិញ ដោយរក្សាលក្ខណៈដូចដើម លើកលែងតែការសឹករេចរឹលធម្មតា ។

**មាត្រា ២៨.-**

ភតិកៈ ត្រូវទទួលខុសត្រូវចំពោះការបាត់បង់ចលនវត្ថុ ដែលបានជួល ចាប់ពីពេលទទួលរហូតដល់ពេលប្រគល់ចលនវត្ថុទៅភតិបតីវិញ ។

**មាត្រា ២៩.-**

ភតិកៈមិនត្រូវដាក់ជាហ៊ីប៉ូតែក ដាក់បញ្ចាំ ទាមទារឱ្យឃាត់ទុក ចលនវត្ថុដែលបានជួល ឬ ធ្វើឱ្យមានបន្ទុកផ្សេងទៀតទៅលើចលនវត្ថុដែលបានជួលឡើយ ។

ROYAUME DU CAMBODGE

**មាត្រា ៣០.-**

ភតិកៈ មានកាតព្វកិច្ចផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរទៅភតិបតី អំពីទីតាំងបច្ចុប្បន្ន និងការប្តូរទៅទីតាំងថ្មីនៃចលនវត្ថុដែលបានជួល លើកលែងតែកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមានចែងផ្សេងពីនេះ ។

**មាត្រា ៣១.-**

កាតព្វកិច្ចរបស់អ្នកផ្គត់ផ្គង់ តាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ ក៏ត្រូវពាក់ព័ន្ធជាមួយភតិកៈផងដែរ ប្រៀបដូចជាភតិកៈជាភាគីមួយនៃកិច្ចព្រមព្រៀងផ្គត់ផ្គង់ ហើយចលនវត្ថុដែលបានជួល ហាក់ដូចជាត្រូវបានផ្គត់ផ្គង់ផ្ទាល់ទៅឱ្យភតិកៈ ។ ប៉ុន្តែអ្នកផ្គត់ផ្គង់មិនទទួលខុសត្រូវលើវិការៈមួយចំពោះភតិកៈផង និងភតិបតីផងនោះទេ ។

សិទ្ធិរបស់ភតិកៈ នៅក្នុងកិច្ចព្រមព្រៀងផ្គត់ផ្គង់ដែលភតិកៈបានយល់ព្រម ហើយមិនត្រូវបានប៉ះពាល់ ដោយសារតែការកែប្រែលក្ខខណ្ឌណាមួយនៃកិច្ចព្រមព្រៀងផ្គត់ផ្គង់ទេ លើកលែងតែភតិកៈបានយល់ព្រមលើការកែប្រែនោះ ។

**មាត្រា ៣២.-**

ភតិកៈមិនត្រូវជួលបន្ត ចាត់ចែង ឬ ផ្ទេរសិទ្ធិកាន់កាប់ ឬ ប្រើប្រាស់ចលនវត្ថុ ដែលបានជួល ឬ សិទ្ធិណាមួយផ្សេងទៀត ក្រោមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីភតិបតី និងមិនត្រូវចំណុះសិទ្ធិរបស់តតិយភាគីឡើយ ។ ការជួលបន្ត ការចាត់ចែង ឬ ការផ្ទេរ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីភតិបតី ត្រូវចាត់ទុកជាមោឃៈ និងត្រូវបានចាត់ទុកថា ល្មើសច្បាប់នេះ និងច្បាប់ផ្សេងទៀត ។

## ជំពូកទី ៥

## អាជ្ញាធរអាណាព្យាបាល និងអំណាចចេញបទបញ្ជា

**មាត្រា ៣៣.-**

ធនាគារជាតិនៃកម្ពុជា បំពេញតួនាទីជាអាជ្ញាធរអាណាព្យាបាលលើគ្រឹះស្ថាន ភតិសន្យាហិរញ្ញវត្ថុ ដែលក្នុងតួនាទីនេះ ធនាគារជាតិនៃកម្ពុជា :

១-ចេញ ព្យួរ ឬ ដកហូតអាជ្ញាបណ្ណធ្វើប្រតិបត្តិការ ភតិសន្យាហិរញ្ញវត្ថុ និង កំណត់នីតិវិធីនិងបែបបទនានាអំពីការចេញអាជ្ញាបណ្ណនេះ ។

២-ចេញបទបញ្ជា ដើម្បីអនុវត្តច្បាប់នេះ ដែលអនុញ្ញាតឱ្យកំណត់ច្បាស់ជាអាទិ៍នូវ :

ក-កម្រិតដើមទុនអប្បបរមា

ខ-អនុបាតប្រុងប្រយ័ត្នផ្សេងៗ

គ-ចំណាត់ថ្នាក់ប្រភេទឥណទាន និងការធ្វើសំវិធានធន

ឃ-ប្រព័ន្ធគណនេយ្យ និងបទដ្ឋានដែលពាក់ព័ន្ធ ។

៣-ត្រួតពិនិត្យ តាមវិធីពិនិត្យផ្ទៀងផ្ទាត់ ជាអចិន្ត្រៃយ៍លើឯកសារ និងតាមវិធីត្រួតពិនិត្យតាមកាលវេលាចាំបាច់ ដល់ទីកន្លែងនៃគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ។

៤-អាចសម្រេចដាក់ទណ្ឌកម្មខាងវិន័យ ក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៣៥ នៃច្បាប់នេះ ។

**មាត្រា ៣៤.-**

ប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ អាចអនុវត្តបានដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលទទួលបានអាជ្ញាបណ្ណប្រកបមុខរបរធនាគារពីធនាគារជាតិនៃកម្ពុជា ។

ប្រតិបត្តិការទាំងនេះក៏អាចអនុវត្តបានផងដែរ ដោយគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ដែលត្រូវបានបង្កើតឡើង ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ត្រូវសុំអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីប្រកបអាជីវកម្មភតិសន្យាហិរញ្ញវត្ថុ ។

គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ មិនត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការផ្សេងទៀតរបស់ធនាគារ ក្រៅពីប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុឡើយ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

## ជំពូកទី ៦

## ទណ្ឌកម្ម

**មាត្រា ៣៥.-**

ប្រសិនបើគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ បានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ ឬ នៃបទបញ្ជាពាក់ព័ន្ធនឹងសកម្មភាពរបស់ខ្លួន ឬ មិនបានធ្វើតាមការដាស់តឿន ឬ មិនបានធ្វើតាមអធិបញ្ជា អាជ្ញាធរអាណាព្យាបាល អាចដាក់ទណ្ឌកម្មខាងវិន័យណាមួយដូចខាងក្រោមនេះ :

-ព្រមាន

-ស្តីបន្ទោស

-ហាមធ្វើប្រតិបត្តិការមួយចំនួន និងកំណត់ព្រំដែនសកម្មភាព

-ព្យួរមុខងារបណ្តោះអាសន្ន ចំពោះអ្នកដឹកនាំម្នាក់ ឬ ច្រើននាក់ ដោយមាន ឬ គ្មានការតែងតាំងអភិបាលបណ្តោះអាសន្ន

-តម្រូវឱ្យលាឈប់ពីការងារជាស្វ័យប្រវត្តិចំពោះអ្នកដឹកនាំម្នាក់ ឬ ច្រើននាក់ ដោយមាន ឬ គ្មានការតែងតាំងអភិបាលបណ្តោះអាសន្ន

-ដាក់ឱ្យស្ថិតនៅក្រោមការអភិបាលបណ្តោះអាសន្ន ជាបន្តបន្ទាប់

-ដកហូតអាជ្ញាបណ្ណជាស្ថាពរ និងការដាក់ឱ្យជម្រះបញ្ជីជាបន្ទាន់ ។

## ជំពូកទី ៧

## អន្តរប្បញ្ញត្តិ

**មាត្រា ៣៦.-**

គ្រឹះស្ថានណាដែលកំពុងធ្វើប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ ដោយគ្មាននីតិសម្បទា ត្រូវដាក់ពាក្យសុំអាជ្ញាបណ្ណទៅអាជ្ញាធរអាណាព្យាបាល ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ក្នុងរយៈពេល ១២ (ដប់ពីរ) ខែ បន្ទាប់ពីច្បាប់នេះចូលជាធរមាន ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៣៧.-**

ច្បាប់នេះត្រូវមានអាទិភាព ប្រសិនបើមានបទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀត មិនស្របគ្នានឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៣៨.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៩

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

ពរល.០៩០៦.៦៤០ នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

ហត្ថលេខា

ជា ចាន់តូ

លេខ : ៦១៥ ច.ល

…ចម្លងចេញ

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ២០០៩

អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

17/17

# ច្បាប់

# ស្ដីពី

# មូលបត្ររដ្ឋ

# ២០០៧

# ព្រះរាជក្រម

នស/រកម/០១០៧/០០១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីមូលបត្ររដ្ឋ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៦ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី២ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

7/13

# ច្បាប់

# ស្តីពី

# មូលបត្ររដ្ឋ

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

ច្បាប់នេះមានគោលបំណងផ្តល់នូវក្របខ័ណ្ឌមួយសម្រាប់ការបោះផ្សាយ និងការគ្រប់គ្រងមូលបត្ររដ្ឋប្រកបដោយប្រសិទ្ធភាព ដើម្បីធានាថាកាតព្វកិច្ចទូទាត់សងចំពោះតម្រូវការហិរញ្ញប្បទានរបស់រដ្ឋ ត្រូវចំណាយក្នុងតម្លៃមួយដែលទាបបំផុត សម្រាប់មូលបត្ររយៈពេលមធ្យម ឬ វែង ហើយត្រូវសមស្របទៅតាមកម្រិតហានិភ័យ ដែលអាចកើតមានឡើង និងដើម្បីចូលរួមក្នុងការអភិវឌ្ឍន៍ទីផ្សារមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.–**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងច្បាប់នេះ មានដូចខាងក្រោម ៖

១-**មូលបត្ររដ្ឋ** សំដៅដល់ប័ណ្ណ សញ្ញាប័ណ្ណ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀតដែលបញ្ជាក់ពីការទទួលស្គាល់បំណុល ដែលបានបោះផ្សាយក្នុងនាមរាជរដ្ឋាភិបាល នៅក្រោមច្បាប់នេះ រួមមាន ៖

ក-ប័ណ្ណរតនាគារដែលមានឥណប្រតិទានតិចជាងមួយឆ្នាំ ។

ខ-សញ្ញាប័ណ្ណរតនាគារដែលមានឥណប្រតិទានចាប់ពីមួយឆ្នាំឡើងទៅ ។

គ-សញ្ញាប័ណ្ណដែលផលចំណូលផ្សារភ្ជាប់នឹងអត្រាអតិផរណា ឬ អត្រាប្តូរប្រាក់ ឬអត្រាផ្សេងៗ។

ឃ-មូលបត្ររដ្ឋដែលមិនអាចជួញដូរបាននៅលើទីផ្សារ ។

ង-មូលបត្ររដ្ឋផ្សេងៗដទៃទៀត ។

មូលបត្ររដ្ឋទាំងអស់ខាងលើនេះ មិនរួមបញ្ចូលនូវមូលបត្រ ដែលបោះផ្សាយដោយអាជ្ញាធរខេត្ត-ក្រុង និង សហគ្រាសសាធារណៈ ឬ ការសុំខ្ចីផ្សេងៗរបស់រាជរដ្ឋាភិបាលដែលមិនស្របទៅនឹងច្បាប់នេះទេ ។

**២-មូលបត្ររដ្ឋមិនអាចជួញដូរបាន** សំដៅដល់មូលបត្រទាំងឡាយណាដែលត្រូវសងទៅឱ្យអ្នកកាន់កាប់មូលបត្រដែលបានចុះបញ្ជី ឬ សន្តតិជនពេញសិទ្ធិតាមលក្ខខណ្ឌរបស់មូលបត្រនោះ ដោយស្របទៅតាមវិសាលភាព និងការកំណត់របស់ប្រកាសដែលដាក់ឱ្យអនុវត្តដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ អ្នកកាន់កាប់មូលបត្រ ឬសន្តតិជនពេញសិទ្ធិមានសិទ្ធិស្នើសុំការទូទាត់សងមុនកាលប្រតិទាន ទៅតាមលក្ខខណ្ឌនៃមូលបត្រទាំងនោះ ។

**៣-វិញ្ញាបនប័ត្រមូលបត្ររដ្ឋ** សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុជាលាយលក្ខណ៍អក្សរ ដោយមានការធានានូវការបំពេញកាតព្វកិច្ចទូទាត់ពេញលេញពីរាជរដ្ឋាភិបាលកម្ពុ-ជា ដោយមានចែងអំពីរយៈពេល លក្ខខណ្ឌ និងកាតព្វកិច្ចផ្សេងៗទៀតរបស់មូលបត្រនោះ ។

**៤-គណនី** សំដៅដល់គណនីទូទៅ និងគណនីពិសេសរបស់រតនាគារជាតិដូចមានចែងនៅក្នុងច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ ០១ ន.ស. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ និងគណនីពិសេសផ្សេងទៀត ដែលបានបង្កើតដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

**៥-សន្តតិជន** សំដៅដល់ជនដែលទទួលបន្តនូវសិទ្ធិ និងករណីកិច្ចរបស់មតក-ជនតាមរយៈសន្តតិកម្ម ។

**៦-សន្តតិកម្ម** សំដៅដល់ការផ្ទេរសិទ្ធិ និងករណីកិច្ចរបស់មតកជនម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬ តាមច្បាប់ ។

**៧-មូលនិធិផ្សេងៗ** សំដៅដល់មូលនិធិពិសេស ដែលបង្កើតដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ មូលនិធិនេះ ត្រូវប្រើប្រាស់សម្រាប់ប្រតិបត្តិការមួយជាក់លាក់ក្នុងគោលបំណងច្បាស់លាស់ ហើយប្រតិបត្តិការនៃមូលនិធិនេះ មិនពាក់ព័ន្ធនឹងថវិកាចំណូល-ចំណាយរបស់រាជរដ្ឋាភិបាល ដែលស្ថិតនៅក្រោមច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលត្រូវបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ ០១ ន.ស. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ នោះទេ លើកលែងតែមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ ហៅកាត់ថា **ម.គ.ម.រ.** ដែលមានចែងក្នុងមាត្រា ៧ នៃច្បាប់នេះ ។

**៨-មូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ (ម.គ.ម.រ.)** សំដៅដល់ប្រាក់ដែលផ្តល់ឱ្យ

ដោយរាជរដ្ឋាភិបាល និងប្រាក់ដែលបានមកពីស្ថាប័នឯកជន និងសាធារណៈតាមរយៈការបោះផ្សាយមូលបត្ររដ្ឋ ប្រាក់នេះត្រូវបានប្រើប្រាស់សម្រាប់កិច្ចការទូទាត់សងប្រាក់ដើម និងការប្រាក់នៃមូលបត្ររដ្ឋទាំងឡាយណាដែលបានបោះផ្សាយរួច ។ មូលនិធិនេះ មិនមែនជាមូលនិធិដែលបង្កើតឡើងក្នុងគោលដៅមនុស្សធម៌នោះទេ ។

**៩-ប្រធានស្ថាប័នរដ្ឋបាលកណ្តាល** សំដៅដល់ថ្នាក់ដឹកនាំក្រសួងនានា និងថ្នាក់ដឹកនាំនៃស្ថាប័នរដ្ឋបាលកណ្តាលផ្សេងទៀត ដែលទទួលបានសិទ្ធិស្របច្បាប់ និងមានតួនាទីស្មើក្រសួងនានា ។

**១០-ឥណប្រតិទាន** សំដៅដល់កាលបរិច្ឆេទមូលបត្រត្រូវដល់កាលកំណត់សង ។

**១១-រដ្ឋមន្ត្រី** សំដៅដល់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**១២-ច្បាប់ធនាគារជាតិ** សំដៅដល់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ន.ស/រ.ក.ម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ។

**១៣-ក្រសួង** សំដៅដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ២

## ការបោះផ្សាយ និង ការដាក់លក់មូលបត្ររដ្ឋ

**មាត្រា ៣.-**

ការបោះផ្សាយ និងការដាក់លក់មូលបត្ររដ្ឋ ត្រូវអនុវត្តដូចខាងក្រោម :

ក-មានតែរដ្ឋមន្ត្រីម្នាក់ប៉ុណ្ណោះ ដែលអាចបោះផ្សាយមូលបត្ររដ្ឋក្នុងក្របខ័ណ្ឌចំណាយនៃ ម.គ.ម.ស. ដូចមានចែងក្នុងមាត្រា ៧ នៃច្បាប់នេះ ។ រដ្ឋមន្ត្រីអាចទិញ ទូទាត់សង និងផ្តល់ប្រាក់វិញនូវរាល់មូលបត្ររដ្ឋដែលដល់ ឬ មិនទាន់ដល់ឥណប្រតិទាន ។ ប្រាក់ដើម និងការប្រាក់នៃមូលបត្ររដ្ឋត្រូវបានធានាដោយគ្មានលក្ខខណ្ឌពីរាជរដ្ឋាភិបាល ។

ﾒ

ខ-រតនាគារជាតិ និងនាយកដ្ឋានពាក់ព័ន្ធ ដែលស្ថិតនៅក្រោមការដឹកនាំរបស់រដ្ឋមន្ត្រី ត្រូវទទួលបន្ទុករាល់កិច្ចការពាក់ព័ន្ធនឹងមូលបត្ររដ្ឋ លើកលែងតែរដ្ឋមន្ត្រីបានផ្ទេរសិទ្ធិអំណាចជាលាយលក្ខណ៍អក្សរទៅឱ្យស្ថាប័នរដ្ឋដទៃទៀត ។

គ-ដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់ធនាគារជាតិ រាល់ការងារបច្ចេកទេស និងប្រតិបត្តិការទាក់ទងនឹងមូលបត្ររដ្ឋ អាចអនុវត្តដោយធនាគារជាតិនៃកម្ពុជា ដោយមានការណែនាំពីរដ្ឋមន្ត្រី ដែលមានចែងនៅក្នុងអនុក្រឹត្យ លើកលែងតែមានចែងក្នុងច្បាប់ផ្សេងទៀត ។ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ត្រូវបង្កើតនូវនីតិវិធីដើម្បីបែងចែកឱ្យដាច់ដោយឡែកពីគ្នានូវមុខងារប្រតិបត្តិការទាក់ទងនឹងមូលបត្ររដ្ឋ និងមុខងារគោលនយោ-បាយរូបិយវត្ថុ ។

ប្រសិនបើប្រធានស្ថាប័នរដ្ឋបាលកណ្តាលណាមួយ ដែលគ្រប់គ្រងគណនី និងមូលនិធិដទៃទៀត ដែលស្ថិតនៅក្រោមច្បាប់ផ្សេង ហើយមានបំណងបោះផ្សាយមូលបត្ររដ្ឋ ត្រូវធ្វើសំណើទៅរដ្ឋមន្ត្រីអំពីការបោះផ្សាយមូលបត្រនោះ ។

អាជ្ញាធរខេត្ត-ក្រុង គ្រឹះស្ថានសាធារណៈ និងសហគ្រាសសាធារណៈមិនអាចបោះផ្សាយសញ្ញាប័ណ្ណរដ្ឋ ដោយពុំមានការយល់ព្រមពីរដ្ឋមន្ត្រីជាមុននោះទេ ។

មូលបត្ររដ្ឋអាចត្រូវបានបោះផ្សាយជារូបិយវត្ថុជាតិ ឬ ជារូបិយប័ណ្ណបរទេស ។

**មាត្រា ៤.-**

ចំនួនទឹកប្រាក់សរុបនៃការបោះផ្សាយមូលបត្ររដ្ឋសម្រាប់ឆ្នាំសារពើពន្ធនីមួយៗ ត្រូវបានអនុម័តដោយរដ្ឋសភា ។

នាយករដ្ឋមន្ត្រី ត្រូវធ្វើជូនរដ្ឋសភានូវចំនួនទឹកប្រាក់សរុបនៃមូលបត្ររដ្ឋ ដែលត្រូវបោះផ្សាយ ដែលជាផ្នែកមួយនៃសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ ។

នាយករដ្ឋមន្ត្រី អាចធ្វើសំណើទៅរដ្ឋសភា ដើម្បីសុំការអនុម័តលើការបោះផ្សាយមូលបត្ររដ្ឋបន្ថែម ទៅលើចំនួនទឹកប្រាក់សរុប ដែលរដ្ឋសភាបានអនុម័តរួចហើយ ។ ជាមួយនឹងសំណើនេះ នាយករដ្ឋមន្ត្រី ត្រូវផ្តល់នូវការពន្យល់ឱ្យបានច្បាស់លាស់នូវហេតុផលដ៏ចាំបាច់នៃការបោះផ្សាយមូលបត្របន្ថែមនេះ ។

**មាត្រា ៥.-**

មូលបត្ររដ្ឋត្រូវបានបោះផ្សាយលក់ជាសាធារណៈ នៅលើទីផ្សារក្នុងតម្លៃសមស្រប តាមវិសាលភាពដែលអាចធ្វើទៅបាន ព្រមទាំងផ្តល់និកាសស្មើភាពគ្នាដល់សាធារណជន ក្នុងការចូលរួមទិញមូលបត្រទាំងនេះ ។

រដ្ឋមន្ត្រីអាចសម្រេចលើការបោះផ្សាយមូលបត្ររដ្ឋ តាមវិធីសាស្ត្រផ្សេងៗ ដើម្បីបម្រើផលប្រយោជន៍សាធារណៈ ដែលកំណត់ក្នុងអនុក្រឹត្យ ។ ការបោះផ្សាយមូលបត្ររដ្ឋរួមទាំងរបៀបបោះផ្សាយ និងអត្រាការប្រាក់ត្រូវកំណត់ក្នុងអនុក្រឹត្យ ។

មូលបត្ររដ្ឋត្រូវបានដាក់លក់ជាសាធារណៈ នៅទីផ្សារដំបូងដោយការដេញថ្លៃ ។ នៅពេលដែលមានមូលបត្ររដ្ឋនៅសល់ពីការលក់ដោយការដេញថ្លៃ រដ្ឋមន្ត្រីអាចប្រើប្រាស់គណនីរាជរដ្ឋាភិបាល ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីទិញមូលបត្រទាំងនោះមកវិញតាមលក្ខខណ្ឌ និង រយៈពេលដូចដែលបានលក់តាមរយៈការដេញថ្លៃ ។

**មាត្រា ៦.-**

រាល់បញ្ហាទាក់ទងនឹងការគ្រប់គ្រងវិញ្ញាបនប័ត្រមូលបត្ររដ្ឋ ការចុះបញ្ជី និងការទូទាត់សងប្រាក់ដើម និងការប្រាក់នៃមូលបត្ររដ្ឋ ត្រូវកំណត់ក្នុងអនុក្រឹត្យ ។

## ជំពូកទី ៣
## មូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ

**មាត្រា ៧.-**

រាជរដ្ឋាភិបាលត្រូវបង្កើត ម.គ.ម.រ. ដើម្បីគ្រប់គ្រងការបោះផ្សាយ និងការទូទាត់សងមូលបត្ររដ្ឋ ប្រកបដោយប្រសិទ្ធភាព និងបញ្ហាពាក់ព័ន្ធផ្សេងទៀត ។

ម.គ.ម.រ. អាចធ្វើប្រតិបត្តិការ ក្រៅនីតិវិធីហិរញ្ញវត្ថុ ដែលកំណត់ដោយច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ ០១ ន.ស. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ។

/.

៩/១៣

**មាត្រា ៨.-**

រដ្ឋមន្ត្រីដាក់ឱ្យធ្វើប្រតិបត្តិការ និងគ្រប់គ្រង **ម.គ.ម.វ.** ។

រដ្ឋមន្ត្រីប្រគល់សិទ្ធិ ជូនទេសាភិបាលធនាគារជាតិនៃកម្ពុជា ដើម្បីដាក់ឱ្យធ្វើប្រតិបត្តិការ និងគ្រប់គ្រង **ម.គ.ម.វ.** ។

ក្នុងករណីមានការប្រគល់សិទ្ធិ ដូចមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រានេះ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំ ជូនទៅរដ្ឋមន្ត្រីអំពីការទូទាត់លើគណនីរបស់ ម.គ.ម.វ. នៅមុនដំណាច់ខែកុម្ភៈនៃឆ្នាំសារពើពន្ធបន្ទាប់ ។ របាយការណ៍ប្រចាំឆ្នាំនេះ ត្រូវមានចំណុចដូចខាងក្រោម :

-របាយការណ៍ស្តីពីស្ថានភាពទូទៅ និងការវិភាគលើ **ម.គ.ម.វ.**

-តារាងតុល្យការ

-របាយការណ៍ចំណូល-ចំណាយ

-របាយការណ៍លំហូរសាច់ប្រាក់ និងឯកសារដើមផ្សេងៗ

-ឯកសារពាក់ព័ន្ធផ្សេងៗដែលទាក់ទងនឹងការទូទាត់លើគណនីរបស់ **ម.គ.ម.វ.** ។

បញ្ហាផ្សេងៗពាក់ព័ន្ធទៅនឹងប្រតិបត្តិការ និងការគ្រប់គ្រងនៃ **ម.គ.ម.វ.** ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៩.-**

·ប្រភពហិរញ្ញវត្ថុរបស់ **ម.គ.ម.វ.** អាចបានមកពីប្រភពចំណូលដូចខាងក្រោម :

-ចំណូលបានមកពីការបោះផ្សាយមូលបត្ររដ្ឋ

-ចំណូលការប្រាក់ដែលបានពីគណនីប្រាក់បញ្ញើ និងមូលនិធិផ្សេងទៀត

-អតិរេកនៃការទូទាត់ប្រចាំឆ្នាំ

-វិភាគទានពីរាជរដ្ឋាភិបាល

-ចំណូលបានពីប្រតិបត្តិការផ្សេងៗរបស់ **ម.គ.ម.វ.** ។

**ម.គ.ម.វ.** ត្រូវបានប្រើប្រាស់ដើម្បីបំពេញគោលដៅដូចខាងក្រោម :

-ទូទាត់សងប្រាក់ដើម និងការប្រាក់នៃមូលបត្ររដ្ឋដែលបានបោះផ្សាយ

→

-ដាក់ទៅក្នុងគណនី និងក្នុងមូលនិធិផ្សេងៗនូវប្រាក់ចំណូលរបស់ ម.គ.ម.រ.

-ទូទាត់សងរាល់ចំណាយចាំបាច់នៃការគ្រប់គ្រង ម.គ.ម.រ.

-អាចទិញមូលបត្ររដ្ឋ និងសញ្ញាប័ណ្ណមហាជនផ្សេងៗ និងដាក់ប្រាក់បញ្ញើរយៈពេលខ្លី ឬ ផ្តល់ឥណទាន រយៈពេលខ្លីទៅឱ្យគ្រឹះស្ថានហិរញ្ញវត្ថុនានា ។ រដ្ឋមន្ត្រីអាចចេញប្រកាសឱ្យប្រើប្រាស់សាច់ប្រាក់ ដែលនៅសល់ក្នុងគោលបំណងផ្សេងៗ ។

**មាត្រា ១០.–**

រដ្ឋមន្ត្រីត្រូវធ្វើផែនការប្រតិបត្តិការរបស់ ម.គ.ម.រ. ហៅថា "ផែនការប្រតិបត្តិការ" ដោយលើកមកពិចារណានូវតម្រូវការចាំបាច់នៃការបោះផ្សាយមូលបត្ររដ្ឋសម្រាប់ឆ្នាំសារពើពន្ធបន្ទាប់ ។

រដ្ឋមន្ត្រីត្រូវដាក់ផែនការប្រតិបត្តិការនេះ ជូនទៅគណៈរដ្ឋមន្ត្រី ដើម្បីពិភាក្សានិងសម្រេច ។

## ជំពូកទី ៤
## ការត្រួតពិនិត្យ និងតួនាទីរបស់រដ្ឋក្នុងមូលនិធិគ្រប់គ្រងមូលបត្ររដ្ឋ

**មាត្រា ១១.–**

អាជ្ញាធរសវនកម្មជាតិ អាចត្រួតពិនិត្យនូវរាល់បញ្ហាទាក់ទងនឹងមូលបត្ររដ្ឋនានារបស់ក្រសួង និងរបស់ធនាគារជាតិនៃកម្ពុជា ដែលត្រូវបានផ្ទេរសិទ្ធិដោយរដ្ឋមន្ត្រី ដោយអនុលោមតាមច្បាប់នេះ ។

នាយកដ្ឋាន ឬ អង្គភាពទទួលបន្ទុកត្រួតពិនិត្យរបស់ក្រសួង និងធនាគារជាតិនៃកម្ពុជាត្រូវធ្វើការត្រួតពិនិត្យជាប្រចាំលើរតនាគារជាតិ និងនាយកដ្ឋានពាក់ព័ន្ធរបស់ខ្លួន ដែលទទួល

ខុសត្រូវទូវរាល់បញ្ហាទាក់ទងនឹងមូលបត្ររដ្ឋទៅតាមការទទួលខុសត្រូវរៀងៗខ្លួន ហើយត្រូវធ្វើរបាយការណ៍អំពីលទ្ធផលនៃការត្រួតពិនិត្យ ដើម្បីដាក់ជូនរដ្ឋមន្ត្រី និងទេសាភិបាលធនាគារជាតិនៃកម្ពុជា ពិនិត្យ និងផ្តល់អនុសាសន៍ ។

**មាត្រា ១២.-**

គណៈកម្មាធិការចម្រុះសម្រាប់ការអភិវឌ្ឍន៍ទីផ្សារមូលបត្ររដ្ឋ អាចត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋមន្ត្រីដើម្បីពិភាក្សា និងសម្រេចលើគោលនយោបាយសំខាន់ៗដែលទាក់ទងនឹងការអភិវឌ្ឍន៍ទីផ្សារមូលបត្ររដ្ឋ ។

គណៈកម្មាធិការចម្រុះនេះត្រូវមានសមាសភាពដូចតទៅ :

-រដ្ឋមន្ត្រី

-ទេសាភិបាលធនាគារជាតិនៃកម្ពុជា

-ប្រធានស្ថាប័នរដ្ឋបាលកណ្តាលផ្សេងទៀតដែលពាក់ព័ន្ធ ប្រសិនបើមាន

-ជំនាញការមកពីផ្នែកឯកជន ។

រដ្ឋមន្ត្រីអាចបង្កើតក្រុមការងារជំនាញ ដើម្បីសិក្សាពីវិធីសាស្ត្រ និងមធ្យោបាយសម្រាប់អភិវឌ្ឍទីផ្សារដំបូង និងទីផ្សារបន្ទាប់នៃមូលបត្ររដ្ឋឱ្យបានឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាព ព្រមទាំងផ្តល់អនុសាសន៍ជូនដល់រដ្ឋមន្ត្រី ។

**មាត្រា ១៣.-**

បន្ទាប់ពីបានពិភាក្សា និងសម្រេចពីគណៈរដ្ឋមន្ត្រី នាយករដ្ឋមន្ត្រីត្រូវដាក់របាយការណ៍ប្រចាំឆ្នាំ ស្តីពីប្រតិបត្តិការបំណុលសាធារណៈរបស់ក្រសួងក្នុងនោះរួមមានព័ត៌មានទាំងអស់ ដែលទាក់ទងនឹងបំណុលសាធារណៈសរុប បំណុលសាធារណៈសុទ្ធ ឥណប្រតិទានតារាងពេលវេលាសងប្រាក់ដើម និងការប្រាក់ ព័ត៌មានម្ចាស់បំណុលសាធារណៈ ប្រតិបត្តិ-ការរបស់ម.គ.ម.រ. និងផ្តល់សេចក្តីពន្យល់លើយុទ្ធសាស្ត្រហិរញ្ញប្បទាន សម្រាប់ឆ្នាំសារពើ-ពន្ធបច្ចុប្បន្ន និង សម្រាប់ ៥ឆ្នាំ (ប្រាំឆ្នាំ) សារពើពន្ធបន្តបន្ទាប់ជូនទៅរដ្ឋសភា ។

**មាត្រា ១៤.-**

ក្នុងករណីចាំបាច់ដើម្បីឱ្យការបោះផ្សាយ និងការគ្រប់គ្រងមូលបត្ររដ្ឋ ប្រព្រឹត្តទៅដោយភាពត្រឹមត្រូវ រដ្ឋមន្ត្រីអាចស្នើសុំប្រធានស្ថាប័នរដ្ឋបាលកណ្តាលបង្ហាញនូវឯកសារពាក់ព័ន្ធផ្សេងៗ ។

បន្ទាប់ពីទទួលបានការស្នើសុំឱ្យបង្ហាញនូវឯកសារពាក់ព័ន្ធ ដូចមានចែងក្នុងកថាខណ្ឌទី ១ ប្រធានស្ថាប័នរដ្ឋបាលកណ្តាលពាក់ព័ន្ធ ត្រូវអនុវត្តតាមការស្នើសុំនោះ លើកលែងតែមានមូលហេតុពិសេសផ្សេងទៀត ។

**មាត្រា ១៥.-**

រាជរដ្ឋាភិបាលមិនត្រូវបង្កើតកិច្ចសន្យា ឬ ការបញ្ចាំណាមួយ ឬ ការដាក់ទ្រព្យសកម្មសាធារណៈ ឬ ធនធានផ្សេងៗ ដើម្បីធានាការបោះផ្សាយមូលបត្ររដ្ឋឡើយ លើកលែងតែមានចែងក្នុងច្បាប់ផ្សេងទៀត ។ ទ្រព្យសកម្មសាធារណៈ និងប្រាក់ចំណូលរបស់រដ្ឋ ត្រូវបានការពារពីការរឹបអូស និងការហាមឃាត់ផ្សេងៗ ។

សិទ្ធិប្តឹងទាមទារសំណងនូវចំនួនទឹកប្រាក់នៃមូលបត្ររដ្ឋត្រូវអនុវត្តក្នុងរយៈពេល ៥ (ប្រាំ)ឆ្នាំ ចំពោះប្រាក់ដើម និង ២ (ពីរ)ឆ្នាំ ចំពោះការប្រាក់គិតចាប់ពីកាលបរិច្ឆេទឥណប្រតិទាន ។

## ជំពូកទី ៥

## ទោសប្បញ្ញត្តិ

**មាត្រា ១៦.-**

បុគ្គលដែលក្លែងមូលបត្ររដ្ឋ តាមរូបភាពណាក៏ដោយ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**មាត្រា ១៧.-**

បុគ្គល ឬមន្ត្រី ដែលពាក់ព័ន្ធក្នុងការអនុវត្តដេញថ្លៃ ឬ ពាក់ព័ន្ធក្នុងកាតព្វកិច្ចផ្សេងទៀត ហើយមិនបានបំពេញត្រឹមត្រូវតាមការកំណត់របស់ច្បាប់នេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

## ជំពូកទី ៦

## អន្តរប្បញ្ញត្តិ

**មាត្រា ១៨.-**

ក្នុងករណីមូលបត្ររដ្ឋណាមួយ ដែលបានបោះផ្សាយហើយ មិនទាន់បានទូទាត់សង ដោយគិតត្រឹមថ្ងៃដែលច្បាប់នេះចូលជាធរមាន មូលបត្ររដ្ឋទាំងនោះ ត្រូវតែទទួលបានការទូទាត់សងតាមគណនី និងនីតិវិធីដែលបានបោះផ្សាយ ។

## ជំពូកទី ៧

## អវសានប្បញ្ញត្តិ

**មាត្រា ១៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១០ ខែមករា ឆ្នាំ ២០០៧

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកម.០១០៧.០១៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ហត្ថលេខា**

**គាត ឈន់**

លេខ : ៣១ ធ.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០០៧
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រម

នស/រកម/០៨០៩/០១៦

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្មរ៉ែនិងថាមពល
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីមាត្រាសាស្ត្រ ដែលរដ្ឋសភាបានអនុម័តកាលពី ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភា លើកទី២ នីតិកាលទី៤ និង ដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩ នាសម័យប្រជុំវិសាមញ្ញ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# មាត្រាសាស្ត្រកម្ពុជា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

ច្បាប់នេះមានគោលដៅ កំណត់អំពីយន្តការ និងវិធានគ្រប់គ្រងមាត្រាសាស្ត្រ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.–**

ច្បាប់នេះមានគោលបំណង :

-ធានាឱ្យការធ្វើពាណិជ្ជកម្ម មានភាពយុត្តិធម៌និងត្រឹមត្រូវ

-បង្កឱ្យការប្រើប្រាស់ ឧបករណ៍មាត្រាសាស្ត្រ មានភាពត្រឹមត្រូវសុចរិត

-ធានាផលប្រយោជន៍រវាងអ្នកផ្គត់ផ្គង់ និង អ្នកប្រើប្រាស់ ផលិតផលទំនិញ និងសេវាកម្ម

-ធានាធ្វើឱ្យកាន់តែប្រសើរឡើងនូវគុណភាពទំនិញ ផលិតផល សេវាកម្ម និងគ្រប់គ្រង

-កំណត់អត្តសញ្ញាណ និង លុបបំបាត់របាំងបច្ចេកទេស ដើម្បីឱ្យមានសុខដុមនីយកម្មក្នុងសកម្មភាពពាណិជ្ជកម្ម លើវិស័យនីត្យានុកូលមាត្រាសាស្ត្រ

-ធ្វើឱ្យមានជំនឿ និង ទំនុកចិត្តលើការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រក្នុងសកម្មភាពពាណិជ្ជកម្ម និង វិស័យផ្សេងៗទៀត ដើម្បីសុខភាព សុវត្ថិភាព និង បរិស្ថាន

-សម្រួលការអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស ដើម្បីភាពរីកចម្រើននៃសេដ្ឋកិច្ច ។

**មាត្រា ៣.–**

ច្បាប់នេះ មានវិសាលភាពអនុវត្តជាអាទិ៍ ចំពោះការផលិត ការនាំចូល ការដំឡើង ការប្រើប្រាស់ ការជួសជុល ការថែទាំ និង ការតាំងលក់ឧបករណ៍មាត្រាសាស្ត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

វាក្យស័ព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះមានដូចតទៅ :

**មាត្រាសាស្ត្រ** សំដៅដល់វិទ្យាសាស្ត្រ និង ការគ្រប់គ្រងទម្ងន់និងរង្វាស់រង្វាល់ ។

**ឧបករណ៍មាត្រាសាស្ត្រ** សំដៅដល់ ឧបករណ៍ទម្ងន់ និង រង្វាស់រង្វាល់ដែលបម្រើឱ្យវិស័យមាត្រាសាស្ត្រ ។

**រដ្ឋមន្ត្រី** សំដៅដល់ រដ្ឋមន្ត្រីទទួលបន្ទុកវិស័យឧស្សាហកម្ម ដែលគ្រប់គ្រងរាល់សកម្មភាព និង សេវាកម្មពាក់ព័ន្ធនឹងមាត្រាសាស្ត្រក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ឯកតាទម្ងន់និងរង្វាស់រង្វាល់ដែលបានអនុញ្ញាត** សំដៅដល់ ឯកតាទម្ងន់ និង រង្វាស់រង្វាល់នៃមាត្រាសាស្ត្រ ។

**ព្យាសកម្ម** សំដៅដល់វិធីសាស្ត្រ និង បទប្បញ្ញត្តិនៃការងារក្រិតខ្នាតឧបករណ៍មាត្រាសាស្ត្រ ។

**មន្ត្រីត្រួតពិនិត្យ** សំដៅដល់ មន្ត្រីមានសមត្ថកិច្ចដែលកំណត់ដោយច្បាប់នេះ ។

**បរិក្ខារ** សំដៅដល់សម្ភារៈសម្រាប់ថ្លឹង ឬ វាស់ វាល់ ឬ គ្រឿងផ្សំសម្រាប់ឧបករណ៍មាត្រាសាស្ត្រ ។

**អ្នកនាំចូល** សំដៅដល់ បុគ្គលដែលបានអនុញ្ញាតឱ្យនាំចូលនូវឧបករណ៍មាត្រាសាស្ត្រ ។

**ការត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង** សំដៅដល់ ការត្រួតពិនិត្យផ្ទៀងផ្ទាត់លើឧបករណ៍មាត្រាសាស្ត្រថ្មី ឬ ដែលបានជួសជុលរួច មុនពេលដាក់ឱ្យប្រើប្រាស់ ។

**ការត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់** សំដៅដល់ បណ្តាប្រភេទនៃការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ឧបករណ៍ទម្ងន់ និង រង្វាស់រង្វាល់ ដែលបានត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូងរួចហើយ និង កំពុងប្រើប្រាស់ ។

**ឧបករណ៍វាស់វាល់** សំដៅដល់ ឧបករណ៍មាត្រាសាស្ត្រសម្រាប់ប្រើប្រាស់រកបរិមាណ នៃប្រព័ន្ធឯកតាចំណុះវត្ថុរាវ ប្រវែង សម្ពាធ សំឡេង ពន្លឺ ថាមពល ។ល។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**ការអនុម័តគំរូ** សំដៅដល់ ការអនុម័តលើគំរូជាក់លាក់ណាមួយនៃឧបករណ៍មាត្រាសាស្ត្រ សម្រាប់ដាក់ឱ្យប្រើប្រាស់ បន្ទាប់ពីបានសាកល្បងឧបករណ៍មួយ ឬ ច្រើនស្របតាមការតម្រូវដែលបានកំណត់ ។

**សញ្ញាផ្ទៀងផ្ទាត់ដែលបានបញ្ជាក់** សំដៅដល់ សញ្ញាសម្គាល់ដែលកំណត់ដោយរដ្ឋមន្ត្រី ស្របតាមច្បាប់នេះ ។

**មន្ទីរពិសោធន៍ដែលបានកំណត់** សំដៅដល់ មន្ទីរពិសោធន៍ជាតិ ឬ មន្ទីរពិសោធន៍របស់ប្រទេសណាមួយ ឬ មន្ទីរពិសោធន៍អន្តរជាតិណាមួយដែលកំណត់ដោយរដ្ឋមន្ត្រី ។

**ពាណិជ្ជកម្ម** សំដៅដល់ ទំនាក់ទំនង ឬ កិច្ចសន្យាកិច្ចព្រមព្រៀង ការលក់ ការទិញ យោងតាមមាត្រា ១៩ នៃច្បាប់នេះ និង រាប់បញ្ចូលទាំងការវេចខ្ចប់ទំនិញ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ស្តង់ដារមាត្រាសាស្ត្រ** សំដៅដល់ ឧបករណ៍ខ្នាតគំរូមាត្រាសាស្ត្រ ។

**ស្តង់ដារគោលជាតិ** សំដៅដល់ ស្តង់ដារថ្នាក់ខ្ពស់បំផុតរបស់ជាតិ ដែលភាពត្រឹមត្រូវរបស់វាត្រូវបានព្យាសកម្មនិងទទួលស្គាល់ដោយមន្ទីរពិសោធន៍ណាមួយដែលកំណត់ដោយរដ្ឋមន្ត្រី ។

**ស្តង់ដារបន្ទាប់** សំដៅដល់ ស្តង់ដារថ្នាក់ទី ២ ដែលភាពត្រឹមត្រូវរបស់វាត្រូវបានព្យាសកម្ម ដោយស្តង់ដារគោលជាតិ ឬ ស្តង់ដារកម្រិតខ្ពស់ជាង ។

**ស្តង់ដារប្រតិបត្តិ** សំដៅដល់ ស្តង់ដារថ្នាក់ទី ៣ ដែលភាពត្រឹមត្រូវរបស់វាត្រូវបានព្យាសកម្ម ដោយស្តង់ដារបន្ទាប់ ឬ ស្តង់ដារកម្រិតខ្ពស់ជាង ។

**បុគ្គល** សំដៅដល់ នីតិបុគ្គល ឬ រូបវន្តបុគ្គល ។

**ពាណិជ្ជសញ្ញា** សំដៅដល់ ម៉ាកដែលប្រើប្រាស់សម្រាប់សេវា ហៅថាសេវាសញ្ញាមាត្រាសាស្ត្រ ។

ROYAUME DU CAMBODGE
MINISTERE DU PALAIS ROYAL

## ជំពូកទី ២
## សមត្ថកិច្ចគ្រប់គ្រងមាត្រាសាស្ត្រ

**មាត្រា ៥.-**

ត្រូវបានបង្កើតអង្គភាពមួយមានឈ្មោះថា **មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ** សរសេរជាអក្សរកាត់ ម.ម.ជ សម្រាប់គ្រប់គ្រងរាល់សកម្មភាព និង សេវាកម្មពាក់ព័ន្ធនឹងការងារមាត្រាសាស្ត្រ ជាអាទិ៍ វិទ្យាសាស្ត្រមាត្រាសាស្ត្រ មាត្រាសាស្ត្រឧស្សាហកម្ម និង នីត្យានុកូលមាត្រាសាស្ត្រ ស្របតាមគោលនយោបាយជាតិផ្នែកមាត្រាសាស្ត្រ ។ ម.ម.ជ ស្ថិតនៅក្រោមក្រសួងទទួលបន្ទុកវិស័យឧស្សាហកម្ម មានឋានៈស្មើនឹងអគ្គនាយកដ្ឋាន និង មានត្រាសម្គាល់របស់ខ្លួនមួយដោយឡែក ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៣
## ប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់

**មាត្រា ៦.-**

ប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានកំណត់ដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី ១ និង ឧបសម្ព័ន្ធទី ២ ក្នុងច្បាប់នេះ ។

ការប្រើប្រាស់ប្រព័ន្ធឯកតា ក្រៅពីប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់ ដូចចែងក្នុងឧបសម្ព័ន្ធទី ១ និង ឧបសម្ព័ន្ធទី ២ ត្រូវមានប្រកាសស្តីពីសមមូលនៃប្រព័ន្ធឯកតានោះដោយរដ្ឋមន្ត្រី ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ជំពូកទី ៤
## ស្តង់ដារនៃឯកតាមាត្រាសាស្ត្រ

**មាត្រា ៧.–**

ស្តង់ដារមាត្រាសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានចាត់ថ្នាក់ជាប្រភេទ ដូចតទៅ :

- ស្តង់ដារគោលជាតិ
- ស្តង់ដារបន្ទាប់
- ស្តង់ដារប្រតិបត្តិ ។

**មាត្រា ៨.–**

ត្រូវចាត់ទុកស្តង់ដារគោលជាតិ ម៉ែត្រ និង ស្តង់ដារគោលជាតិ គីឡូក្រាម ជាស្តង់ដារនៃឯកតាមូលដ្ឋានជាតិ ។

នៅពេលណាមួយ ប្រសិនបើពិនិត្យឃើញថាចាំបាច់ រដ្ឋមន្ត្រីត្រូវរៀបចំស្តង់ដារ នៃឯកតាមាត្រាសាស្ត្រផ្សេងទៀត ជាស្តង់ដារនៃឯកតាមូលដ្ឋានជាតិ ។

**មាត្រា ៩.–**

រាល់ប្រភេទស្តង់ដារ ដែលមានចែងក្នុងមាត្រា ៧ នៃច្បាប់នេះ និង ស្តង់ដារ យោងទៅតាមពហុគុណ ឬ អនុពហុគុណ នៃឯកតាមាត្រាសាស្ត្រ ត្រូវគោរពតាមលក្ខខណ្ឌជាក់លាក់ ដោយកំណត់ វត្ថុធាតុផ្សំ និង បទបញ្ញាបច្ចេកទេសនៃការផលិត ធានាការប៉ះទង្គិច មេកានិច បរិយាកាសជុំវិញ និង ប្រភពនៃភាពលំអៀងផ្សេងទៀត ។

**មាត្រា ១០.–**

ស្តង់ដារគោលជាតិចែងក្នុងមាត្រា ៧ និង មាត្រា ៨ ខាងលើ មុននឹងយកមកប្រើប្រាស់ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើព្យាសកម្មនិងធ្វើការបញ្ជាក់ទទួលស្គាល់នៅមន្ទីរពិសោធន៍ណាមួយដែលបានកំណត់ ។

**មាត្រា ១១.-**

ស្តង់ដារគោលជាតិ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

ស្តង់ដារគោលជាតិ ត្រូវតម្កល់ទុកនៅមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ។

**មាត្រា ១២.-**

រដ្ឋមន្ត្រីត្រូវចាត់ឱ្យធ្វើព្យាសកម្មស្តង់ដារគោលជាតិ យ៉ាងតិចមួយដង ក្នុងរយៈពេល ១០(ដប់)ឆ្នាំ នៅមន្ទីរពិសោធន៍ណាមួយដែលបានកំណត់ ។

នៅពេលស្តង់ដារគោលជាតិ ត្រូវបញ្ជូនទៅធ្វើព្យាសកម្ម នៅមន្ទីរពិសោធន៍ណាមួយ ដែលបានកំណត់ រដ្ឋមន្ត្រីត្រូវចាត់យកស្តង់ដារបន្ទាប់ណាមួយ មកធ្វើជាស្តង់ដារជំនួសឱ្យ ស្តង់ដារគោលជាតិ ហើយតម្កល់ទុកនៅមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ។ ស្តង់ដារបន្ទាប់នេះ នឹងត្រូវចាត់ទុកជាស្តង់ដារគោលជាតិបណ្តោះអាសន្ន ។

**មាត្រា ១៣.-**

ស្របតាមបញ្ញត្តិនៃច្បាប់នេះ រដ្ឋមន្ត្រីត្រូវចម្លងពីស្តង់ដារគោលជាតិ ដើម្បីប្រកាស ស្តង់ដារបន្ទាប់ ។ ស្តង់ដារចម្លងនេះត្រូវមានលក្ខណៈបច្ចេកទេស សម្ភារៈ រូបរាង ដូចស្តង់ដារ គោលជាតិ ។

ស្តង់ដារបន្ទាប់ ត្រូវកំណត់និងទទួលស្គាល់ដោយប្រកាសរបស់រដ្ឋមន្ត្រី ទទួលបន្ទុក វិស័យឧស្សាហកម្ម ។

**មាត្រា ១៤.-**

ស្តង់ដារបន្ទាប់ ត្រូវបានរក្សាទុកនៅមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ឬ នៅសាខា ម.ឧ.ក និង ត្រូវធ្វើព្យាសកម្មជាមួយស្តង់ដារគោលជាតិយ៉ាងតិចមួយដងក្នុងរយៈពេល ៥(ប្រាំ)ឆ្នាំ

**មាត្រា ១៥.-**

ក្នុងករណីដែលការធ្វើព្យាសកម្ម បង្ហាញឱ្យឃើញថា ស្តង់ដារបន្ទាប់ មានលក្ខណៈ [illegible] មាត្រា ១៣ នៃច្បាប់នេះ រដ្ឋមន្ត្រីត្រូវចេញប្រកាសបដិសេធ និង ឈប់ឱ្យប្រើប្រាស់ស្តង់[illegible]

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

បន្ទាប់នោះ រួចចុះផ្សាយក្នុងរាជកិច្ច ។

**មាត្រា ១៦.-**

ស្តង់ដារប្រតិបត្តិ ត្រូវកំណត់ និង ទទួលស្គាល់ដោយវិញ្ញាបនបត្ររបស់ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ។

ស្តង់ដារប្រតិបត្តិត្រូវចម្លង និងមានលក្ខណៈបច្ចេកទេស សម្ភារៈ រូបរាង ដូចស្តង់ដារបន្ទាប់ ។

**មាត្រា ១៧.-**

ស្តង់ដារប្រតិបត្តិដែលមានលក្ខណៈបច្ចេកទេស សម្ភារៈ រូបរាង តាមការ ដូចបានកំណត់ក្នុងមាត្រា ១៦ នៃច្បាប់នេះ ត្រូវចាត់ទុកថា មានភាពត្រឹមត្រូវ លើកលែងតែមានភស្តុតាងផ្ទុយ ។

**មាត្រា ១៨.-**

ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ត្រូវចាត់មន្ត្រីត្រួតពិនិត្យ ដើម្បីថែរក្សាការពាររាល់ស្តង់ដារប្រតិបត្តិ និង ធ្វើផ្ទៀងផ្ទាត់កម្មជាមួយស្តង់ដារបន្ទាប់ជាប្រចាំ រយៈពេល ២(ពីរ)ឆ្នាំម្តង ។

## ជំពូកទី ៥
## ការប្រើប្រាស់ប្រព័ន្ធឯកតាមាត្រាសាស្ត្រដែលបានអនុញ្ញាត

**មាត្រា ១៩.-**

រាល់កិច្ចសន្យា កិច្ចព្រមព្រៀង ឬ ទំនាក់ទំនងពាណិជ្ជកម្ម ពាក់ព័ន្ធនឹងទំនិញ ឬ វត្ថុផ្សេងៗដែលត្រូវបានផលិត ទិញ លក់ ជួល ប្រគល់ ទទួល ដឹកជញ្ជូន ថ្លឹង វាស់វែង គណនាទូទាត់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែប្រើប្រាស់ប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់ ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ។

ROYAUME DU CAMBODGE • MINISTERE DU PALAIS ROYAL

**មាត្រា ២០.-**

រាល់ពន្ធអាករ និង សេវាកម្ម ដែលពាក់ព័ន្ធនឹងវិស័យមាត្រាសាស្ត្រ ដែលត្រូវទូទាត់ ឬ ត្រូវប្រមូលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើឡើងដោយផ្អែកលើឯកតាមាត្រាសាស្ត្រ ដែលបានអនុញ្ញាត ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ។

**មាត្រា ២១.-**

រាល់ទំនិញផលិតនិងវេចខ្ចប់ សម្រាប់លក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើឡើងស្របតាមឯកតាណាមួយ នៃឯកតាមាត្រាសាស្ត្រ ដែលបានអនុញ្ញាត ដូចមានចែងក្នុង មាត្រា ៦ នៃច្បាប់នេះ ។

ការនាំចូលនូវរាល់ទំនិញផលិតនិងវេចខ្ចប់ ដែលមានលក្ខណៈមិនសមស្របនឹងច្បាប់ នេះ អាចត្រូវបានអនុញ្ញាត ប្រសិនណា រាល់ទំនិញផលិតនិងវេចខ្ចប់នោះ ត្រូវដឹកជញ្ជូនជាលក្ខណៈឆ្លងកាត់ សម្រាប់ធ្វើការនាំចេញបន្តតែប៉ុណ្ណោះ ។

## ជំពូកទី ៦
## ការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រ

**មាត្រា ២២.-**

ឧបករណ៍មាត្រាសាស្ត្រទាំងអស់ សម្រាប់ប្រើប្រាស់ក្នុងសកម្មភាពពាណិជ្ជកម្ម និង វិស័យផ្សេងៗទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវស្របតាមប្រព័ន្ធឯកតាមាត្រាសាស្ត្រ ជាតិស្របច្បាប់ ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី ១ និងឧបសម្ព័ន្ធទី ២ ។

**មាត្រា ២៣.-**

ឧបករណ៍មាត្រាសាស្ត្រ ដែលបានអនុញ្ញាតឱ្យប្រើប្រាស់ ឬ កាន់កាប់សម្រាប់ប្រើប្រាស់ ក្នុងសកម្មភាពពាណិជ្ជកម្មបាន ត្រូវតែមានភាពត្រឹមត្រូវ ឬ សមមូលទៅនឹងប្រព័ន្ធឯកតា មាត្រាសាស្ត្រជាតិស្របច្បាប់ ដូចបានកំណត់ក្នុង ឧបសម្ព័ន្ធទី ១ និង ឧបសម្ព័ន្ធទី ២ នៃច្បាប់ នេះហើយ ត្រូវមានចារឹកលេខ និង អក្សរ ច្បាស់លាស់ មិនអាចលុបបាននៅផ្ទៃខាងលើ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ចំហៀង នៃឧបករណ៍នោះ ។

លក្ខខណ្ឌនេះ មិនអនុវត្តចំពោះឧបករណ៍មាត្រាសាស្ត្រ ដែលមានទំហំតូច មិនអាចចារឹក លេខ និង អក្សរបាន ។

**មាត្រា ២៤.—**

ឧបករណ៍មាត្រាសាស្ត្រដែលអនុញ្ញាតឱ្យប្រើប្រាស់ ឬ កាន់កាប់បានក្នុងសកម្មភាពពាណិជ្ជកម្ម និង វិស័យផ្សេងទៀត ត្រូវតែមានការបញ្ជាក់សមត្ថភាព អប្បបរមា និង អតិបរមា អំពីទម្ងន់ និង/ ឬ រង្វាស់រង្វាល់នៃឧបករណ៍នោះ ។

**មាត្រា ២៥.—**

ឧបករណ៍មាត្រាសាស្ត្រ អាចលក់ ឬ ដាក់តាំងបាន លុះត្រាតែឧបករណ៍នោះមានពាណិជ្ជសញ្ញា និងមានការបញ្ជាក់ពីការពិនិត្យផ្ទៀងផ្ទាត់លើកដំបូង របស់មន្ត្រីត្រួតពិនិត្យនៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ។

**មាត្រា ២៦.—**

ការថ្លឹង ឬ វាស់ វាល់ទំនិញ ឬ ផលិតផលត្រូវអនុវត្តដូចខាងក្រោម :

ក-ក្នុងហាង ឃ្លាំង ទីផ្សារ ឬ កន្លែងសាធារណៈ ត្រូវថ្លឹង ឬ វាស់ វាល់នៅចំពោះមុខអ្នកទិញ លើកលែងតែការទិញលក់ទំនិញ ឬ ផលិតផលធ្វើតាមរូបភាពផ្សេងទៀត ។

ខ-កថាខណ្ឌ ក នៃមាត្រានេះ មិនអនុវត្តទៅលើទំនិញដែលវេចខ្ចប់ហើយ លើកលែងតែមានសំណូមពរពីអ្នកទិញ ។

## ជំពូកទី ៧

## ការផ្ទៀងផ្ទាត់ និង ការដាក់សញ្ញាត្រួតពិនិត្យលើឧបករណ៍មាត្រាសាស្ត្រ

**មាត្រា ២៧.—**

ឧបករណ៍មាត្រាសាស្ត្រទាំងអស់ សម្រាប់ប្រើប្រាស់ក្នុងសកម្មភាពពាណិជ្ជកម្ម និង

វិស័យផ្សេងៗទៀត ដែលមានចែងនៅក្នុងមាត្រា ២៨ នៃច្បាប់នេះត្រូវ :

ក-គោរពតាមការអនុម័តគំរូ ដូចមានចែងក្នុងមាត្រា ៣២ នៃច្បាប់នេះ

ខ-គោរពតាមការត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី

គ-គោរពតាមការត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់ ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី

ឃ-គោរពតាមការត្រួតពិនិត្យផ្ទៀងផ្ទាត់ បន្ទាប់ពីការជួសជុល ឬ ការកែតម្រូវរួច ។

**មាត្រា ២៨.–**

ឧបករណ៍មាត្រាសាស្ត្រ សម្រាប់ប្រើប្រាស់នៅក្នុងវិស័យដូចខាងក្រោម ត្រូវគោរពតាមបញ្ញត្តិនៃមាត្រា ២៧ នៃច្បាប់នេះ :

ក-ឧបករណ៍មាត្រាសាស្ត្រជាក់លាក់ដែលបានបញ្ញត្ត សម្រាប់ប្រើប្រាស់ក្នុងវិស័យសុខភាពសាធារណៈ

ខ-ឧបករណ៍មាត្រាសាស្ត្រជាក់លាក់ដែលបានបញ្ញត្ត សម្រាប់ប្រើប្រាស់ក្នុងសេវាកម្មប្រៃសណីយ៍

គ-ឧបករណ៍មាត្រាសាស្ត្រជាក់លាក់ដែលបានបញ្ញត្ត សម្រាប់ប្រើប្រាស់ក្នុងវិស័យអគ្គិសនី ឥន្ធនៈ និង ទឹក

ឃ-ឧបករណ៍មាត្រាសាស្ត្រជាក់លាក់ដែលបានបញ្ញត្ត សម្រាប់ប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម កសិកម្ម ឬវិស័យផ្សេងទៀត ។

**មាត្រា ២៩.–**

ការត្រួតពិនិត្យឧបករណ៍មាត្រាសាស្ត្រ និង សេវាកម្មមាត្រាសាស្ត្រ ត្រូវអនុវត្តដូចខាងក្រោម ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ក-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ត្រូវកំណត់ពេលវេលា និង ទីកន្លែងដែលត្រូវត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់

ខ-មុននឹងអនុវត្តការត្រួតពិនិត្យ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ត្រូវធ្វើសេចក្តីជូនដំណឹងជាសាធារណៈ

គ-ដោយអនុវត្តប្រកាស ឬ បទបញ្ជាកំណត់ដោយរដ្ឋមន្ត្រី មន្ត្រីត្រួតពិនិត្យត្រូវប្រើប្រាស់ស្តង់ដារប្រតិបត្តិសម្រាប់អនុវត្តតាមពេលវេលានិងទីកន្លែង ដែលបានកំណត់

ឃ-ការត្រួតពិនិត្យឧបករណ៍មាត្រាសាស្ត្រ និង សេវាកម្មមាត្រាសាស្ត្រ ដែលមានចែងក្នុងមាត្រានេះ ត្រូវគិតថ្លៃសេវា តាមការកំណត់ដោយប្រកាសរួម របស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យឧស្សាហកម្ម និង រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ៣០.-**

ការដាក់សញ្ញាត្រួតពិនិត្យលើឧបករណ៍មាត្រាសាស្ត្រ ត្រូវអនុវត្ត ដូចខាងក្រោម :

ក-អនុលោមតាមមាត្រា ២៩ នៅពេលដែលពិនិត្យឃើញថា ឧបករណ៍មាត្រា-សាស្ត្រ មានលក្ខណៈត្រឹមត្រូវស្របតាមប្រកាស និង បទបញ្ជានានារបស់រដ្ឋមន្ត្រី មន្ត្រីត្រួតពិនិត្យត្រូវដាក់សញ្ញាត្រួតពិនិត្យលើឧបករណ៍មាត្រាសាស្ត្រ តាមរបៀប និង សញ្ញាផ្ទៀងផ្ទាត់ដែលបានកំណត់

ខ-មន្ត្រីត្រួតពិនិត្យ មិនត្រូវដាក់សញ្ញាត្រួតពិនិត្យលើឧបករណ៍មាត្រាសាស្ត្រដែលមិនមានភាពត្រឹមត្រូវ តាមប្រកាស និង បទបញ្ជានានាឡើយ

គ-មន្ត្រីត្រួតពិនិត្យ អាចដាក់សញ្ញាត្រួតពិនិត្យលើឧបករណ៍មាត្រាសាស្ត្របានលុះត្រាតែ :

១-ឧបករណ៍មាត្រាសាស្ត្រនោះ ជាប្រភេទដែលបានអនុញ្ញាត

២-បានត្រួតពិនិត្យផ្ទៀងផ្ទាត់ ដោយធ្វើការប្រៀបធៀបជាមួយនឹងស្តង់ដារប្រតិបត្តិ ឬ ស្តង់ដារកម្រិតខ្ពស់ជាង ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៣១.–**

ឧបករណ៍មាត្រាសាស្ត្រដែលបានដាក់សញ្ញាត្រួតពិនិត្យ ដោយមន្ត្រីត្រួតពិនិត្យ ស្របតាមការកំណត់នៃច្បាប់នេះ អាចយកទៅប្រើប្រាស់បានគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣២.–**

ការអនុម័តគំរូនៃឧបករណ៍មាត្រាសាស្ត្រ ត្រូវមានលក្ខខណ្ឌដូចខាងក្រោម :

ក-ឧបករណ៍មាត្រាសាស្ត្រ ដូចមានចែងក្នុងមាត្រា ២៧ និង មាត្រា ២៨ នៃច្បាប់នេះ ត្រូវអនុវត្តតាមគំរូដែលអនុម័តដោយប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ស្របតាមប្រភេទ និង ដែនកម្រិតនៃលំអៀង ដូចដែលបានកំណត់ ។ ការត្រួតពិនិត្យ និង ការអនុម័តគំរូត្រូវគិតថ្លៃសេវាតាមការកំណត់ ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យឧស្សាហកម្ម និង រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ខ-ឧបករណ៍មាត្រាសាស្ត្រណាមួយ ដែលបានអនុម័តកន្លងមកហើយ ប្រសិនបើពិនិត្យលើកក្រោយឃើញថា មានភាពមិនត្រឹមត្រូវ ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិមានសិទ្ធិលុបការអនុម័តពីមុននោះ ហើយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ម្ចាស់ឧបករណ៍នោះ ។ ក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីការជូនដំណឹង ម្ចាស់ឧបករណ៍មានសិទ្ធិតវ៉ាដើម្បីស្នើសុំពិនិត្យបញ្ជាក់ ។ ផុតកំណត់តវ៉ានេះ ការលុបការអនុម័ត គំរូត្រូវចាត់ទុកជាបានការតាមផ្លូវច្បាប់ ។

## ជំពូកទី ៨
## លក្ខខណ្ឌនៃទំនិញវេចខ្ចប់

**មាត្រា ៣៣.–**

រាល់ទំនិញវេចខ្ចប់ សម្រាប់លក់ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវគោរពតាមលក្ខខណ្ឌសំខាន់ៗដូចតទៅ :

ក-ត្រូវបញ្ជាក់អំពីបរិមាណសុទ្ធ និង ធានាភាពត្រឹមត្រូវនៃទម្ងន់ និង រង្វាស់ផ្ទាល់ នៅលើសម្ភារៈវេចខ្ចប់ទំនិញនោះ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ខ-ត្រូវគោរពតាមប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិ ស្របច្បាប់ដូចមានបញ្ជាក់ក្នុងឧបសម្ព័ន្ធទី ១ និង ឧបសម្ព័ន្ធទី ២ នៃច្បាប់នេះ

គ-ត្រូវធ្វើ ឬ រៀបចំឡើង តាមការបញ្ជាក់ជាលក្ខណៈដើមនៃគំរូ ដែលបាន អនុម័តពីទម្ងន់ ឬ រង្វាស់រង្វាល់

ឃ-ត្រូវបញ្ជាក់ឈ្មោះ និង អាសយដ្ឋានរបស់អ្នកផលិត ឬ អ្នកវេចខ្ចប់ ឬ ពាណិជ្ជសញ្ញា ដើម្បីធានាភាពច្បាស់លាស់ ។

លក្ខខណ្ឌលំអិតនៃទំនិញវេចខ្ចប់ ដែលទាក់ទងដល់ផ្នែកមាត្រាសាស្ត្រ នឹងត្រូវកំណត់ ដោយប្រកាសរបស់រដ្ឋមន្ត្រី ។

## ជំពូកទី ៩
## ការផលិត និង ការជួសជុលឧបករណ៍មាត្រាសាស្ត្រ

**មាត្រា ៣៤.-**

បែបបទនៃការផលិត និង ការជួសជុល ត្រូវអនុវត្តដូចខាងក្រោម :

ក-ការផលិត និង ការជួសជុលឧបករណ៍មាត្រាសាស្ត្រ ត្រូវមានអាជ្ញាប័ណ្ណ ដែលចេញដោយប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ

ខ-អាជ្ញាប័ណ្ណត្រូវធ្វើឡើងតាមទម្រង់បែបបទ និង លក្ខខណ្ឌ និង ត្រូវមាន សុពលភាព

គ-ទម្រង់បែបបទ និង លក្ខខណ្ឌនៃការចេញអាជ្ញាប័ណ្ណ ត្រូវកំណត់ដោយ ប្រកាសរបស់រដ្ឋមន្ត្រី

ឃ-រាល់អាជ្ញាប័ណ្ណត្រូវគិតថ្លៃសេវា តាមការកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យឧស្សាហកម្ម និង រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

**មាត្រា ៣៥.–**

អ្នកផលិតឧបករណ៍មាត្រាសាស្ត្រត្រូវគោរពតាមបទប្បញ្ញត្តិនិងលក្ខខណ្ឌ ដូចតទៅ :

ក-ត្រូវបញ្ជាក់អំពីសមត្ថភាពរបស់ខ្លួន ឬ សមត្ថភាពបុគ្គលដែលខ្លួនប្រើប្រាស់ចាត់តាំងឱ្យផលិតឧបករណ៍មាត្រាសាស្ត្រ ដែលខ្លួនមានបំណងផលិត

ខ-ត្រូវបញ្ជាក់ឧបករណ៍ បរិក្ខារ បរិធាន និងមធ្យោបាយផ្សេងទៀត តាមការកំណត់ សម្រាប់ធ្វើការផលិតឧបករណ៍មាត្រាសាស្ត្រនោះ

គ-ត្រូវដាក់គំនូសបច្ចេកទេស និង គំរូឧបករណ៍មាត្រាសាស្ត្រ ដែលខ្លួនមានបំណងផលិត ជូនប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ដើម្បីអនុម័ត ។

**មាត្រា ៣៦.–**

អ្នកជួសជុលឧបករណ៍មាត្រាសាស្ត្រ ត្រូវគោរពតាមបទប្បញ្ញត្តិនិងលក្ខខណ្ឌ ដូចតទៅ :

ក-ត្រូវបញ្ជាក់អំពីសមត្ថភាពរបស់ខ្លួន ឬ សមត្ថភាពបុគ្គលដែលខ្លួនប្រើប្រាស់ចាត់តាំងឱ្យជួសជុលឧបករណ៍មាត្រាសាស្ត្រ ដែលខ្លួនមានបំណងជួសជុល

ខ-ត្រូវបញ្ជាក់ឧបករណ៍ បរិក្ខារ បរិធាន និង មធ្យោបាយផ្សេងទៀតតាមការកំណត់ សម្រាប់ធ្វើការជួសជុលឧបករណ៍មាត្រាសាស្ត្រនោះ ។

**មាត្រា ៣៧.–**

មន្ត្រីត្រួតពិនិត្យ ត្រូវប្រើប្រាស់ស្តង់ដារប្រតិបត្តិ ដែលមានចែងក្នុងមាត្រា១៦ និង មាត្រា ១៨ នៃច្បាប់នេះ សម្រាប់ធ្វើការត្រួតពិនិត្យ ។

ពេលបំពេញភារកិច្ច មន្ត្រីត្រួតពិនិត្យ ត្រូវគោរពតាមបទប្បញ្ញត្តិ និង លក្ខខណ្ឌ ដូចតទៅ :

ក-មិនត្រូវទាញយកផលប្រយោជន៍ផ្ទាល់ខ្លួន ពីការបំពេញភារកិច្ចរបស់ខ្លួនឡើ

ខ-មិនត្រូវជួសជុល ផ្លាស់ប្ដូរទម្ងន់ ឬ រង្វាស់រង្វាល់ ឬ កែតម្រូវ ឧបករណ៍មាត្រាសាស្ត្រឡើយ ។ ការកែតម្រូវទម្ងន់និងរង្វាស់រង្វាល់ និង ឧបករណ៍មាត្រាសាស្ត្រ ត្រូវធ្វើនៅ

ROYAUME DU CAMBODGE * LE MINISTERE DU PALAIS ROYAL *

កន្លែងណាមួយ ដែលមានការអនុញ្ញាតពីប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ។

**មាត្រា ៣៨.–**

មន្ត្រីត្រួតពិនិត្យនៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ត្រូវរក្សាទុកនូវបញ្ជីតាមដានការត្រួតពិនិត្យ តាមទម្រង់ដែលបានកំណត់ ហើយនៅក្នុងបញ្ជីនោះ ត្រូវចុះនូវរាល់សកម្មភាពដែលពាក់ព័ន្ធទៅនឹងការបំពេញភារកិច្ចរបស់ខ្លួនស្របតាមច្បាប់នេះ ។

## ជំពូកទី ១០

## ទោសប្បញ្ញត្តិ

**មាត្រា ៣៩.–**

ជនណាដែលប្រើប្រាស់ ឬ កាន់កាប់សម្រាប់ប្រើប្រាស់ក្នុងសកម្មភាពពាណិជ្ជកម្ម នូវឧបករណ៍មាត្រាសាស្ត្រដែលមិនមានពាណិជ្ជសញ្ញា ត្រូវទទួលការព្រមាន ឬ ពិន័យអន្តរការណ៍ក្នុងមួយគ្រឿងជាប្រាក់ពី ១០.០០០(មួយម៉ឺន)រៀល ទៅ ៥០០.០០០(ប្រាំសែន)រៀល ។

ក្នុងករណីមិនរាងចាល ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង ។

**មាត្រា ៤០.–**

ជនណាដែលលក់ ដាក់តាំងដើម្បីលក់ ដើម្បីចែកចាយ ឬ ដើម្បីផ្តល់នូវឧបករណ៍មាត្រាសាស្ត្រ ដែលមិនមានពាណិជ្ជសញ្ញា ត្រូវទទួលការពិន័យអន្តរការណ៍ក្នុងមួយគ្រឿងជាប្រាក់ពី ៥០.០០០(ប្រាំម៉ឺន)រៀល ទៅ ១.០០០.០០០(មួយលាន)រៀល ។

ក្នុងករណីមិនរាងចាល ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង ។

**មាត្រា ៤១.–**

ជនណាដែលប្រើប្រាស់ ឬ កាន់កាប់សម្រាប់ប្រើប្រាស់ក្នុងសកម្មភាពពាណិជ្ជកម្ម ឬ ដាក់តាំងដើម្បីលក់ ឬ ដើម្បីចែកចាយ នូវឧបករណ៍មាត្រាសាស្ត្រ ដែលមិនបានដាក់

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ព្រះបរមរាជវាំង

សញ្ញាត្រួតពិនិត្យ ដោយមន្ត្រីត្រួតពិនិត្យ ត្រូវទទួលការព្រមាន ឬ ពិន័យអន្តរការណ៍ក្នុងមួយគ្រឿង ជាប្រាក់ពី ១០.០០០ (មួយម៉ឺន)រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល ។

ក្នុងករណីមិនរាងចាល ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង ។

**មាត្រា ៤២.–**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ១.០០០.០០០(មួយលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល ចំពោះជនណាដែល:

ក-នាំចូល និង/ឬ ផលិតឧបករណ៍មាត្រាសាស្ត្រ ដោយមិនអនុវត្តតាមគំរូដែលអនុម័តពី ទម្ងន់ និង រង្វាស់រង្វាល់ ឬ គ្មានការអនុម័តគំរូ ឬ

ខ-ផលិត និង/ឬ ជួសជុលឧបករណ៍មាត្រាសាស្ត្រ ដែលគ្មានអាជ្ញាប័ណ្ណ ដែលចេញដោយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ឬ

គ-កាន់អាជ្ញាប័ណ្ណ តែបំពានលើលក្ខខណ្ឌ ដែលមានចែងនៅក្នុងអាជ្ញាប័ណ្ណ ។

ក្នុងករណីមិនរាងចាល ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង ។

**មាត្រា ៤៣.–**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ)ថ្ងៃ ទៅ ១(មួយ) ខែ ឬ ពិន័យជាប្រាក់ ពី ១.០០០.០០០ (មួយលាន)រៀល ទៅ ៥.០០០.០០០ (ប្រាំលាន)រៀល ចំពោះជនណាដែល នាំចូល និង/ឬ ផលិតឧបករណ៍មាត្រាសាស្ត្រ ដោយប្រើពាណិជ្ជសញ្ញាក្លែងក្លាយ ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ និង/ឬ ពិន័យជាប្រាក់ទ្វេដង ។

**មាត្រា ៤៤.–**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ១.០០០.០០០(មួយលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល ចំពោះជនណាដែល:

ក-ប្រើប្រាស់ ឬ កាន់កាប់សម្រាប់ប្រើប្រាស់ក្នុងសកម្មភាពពាណិជ្ជកម្ម ឬ លក់ ដាក់តាំងដើម្បីលក់ ឬ ដើម្បីចែកចាយនូវឧបករណ៍មាត្រាសាស្ត្រ ដែលមានពាណិជ្ជសញ្ញា ដែលខ្លួនបានដឹងថា ជាពាណិជ្ជសញ្ញាក្លែងក្លាយ ឬ



ខ-ដកចេញ ឬ ប្តូរសញ្ញាត្រួតពិនិត្យ ដែលបានដាក់ដោយមន្ត្រីត្រួតពិនិត្យលើឧបករណ៍មាត្រាសាស្ត្រ ហើយដាក់បញ្ចូលសញ្ញានោះលើឧបករណ៍មាត្រាសាស្ត្រផ្សេងទៀត ។

ក្នុងករណីមិនរាងចាល ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង ។

**មាត្រា ៤៥.-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ) ថ្ងៃ ទៅ ១ (មួយ) ខែ និង/ឬ ពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៥.០០០.០០០(ប្រាំលាន) រៀល ចំពោះជនណាដែល :

ក-បង្កើន បន្ថយ ឬ បន្លំ ទម្ងន់ឬ រង្វាស់រង្វាល់នៃឧបករណ៍មាត្រាសាស្ត្រដែលបានដាក់សញ្ញាត្រួតពិនិត្យរួច ឬ

ខ-ប្រើប្រាស់ ឬ កាន់កាប់សម្រាប់ប្រើប្រាស់ក្នុងសកម្មភាពពាណិជ្ជកម្ម ឬ លក់ ដាក់តាំងដើម្បីលក់ ឬ ដើម្បីចែកចាយនូវឧបករណ៍មាត្រាសាស្ត្រដែលខ្លួនបានដឹងថាបានបង្កើន បន្ថយ ឬ បន្លំ ។

ក្នុងករណីមិនរាងចាលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ និង/ឬ ពិន័យជាប្រាក់ទ្វេដង ។

**មាត្រា ៤៦.-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ១ (មួយ) ខែ និង/ឬ ពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៥.០០០.០០០(ប្រាំលាន) រៀល ចំពោះជនណាដែល :

ក-ធ្វើសេចក្តីបញ្ជាក់ដោយក្លែងបន្លំ មិនត្រឹមត្រូវ ឬ មិនពិតអំពីលេខ បរិមាណ រង្វាស់រង្វាល់ ឬ គណនាថ្លៃសេវាកម្ម ដែលខ្លួនត្រូវផ្តល់ទៅតាមទម្ងន់ ឬ រង្វាស់រង្វាល់ ដែលបានព្រមព្រៀងគ្នា

ខ-លក់ ឬ ប្រគល់ទំនិញទៅឱ្យអ្នកទិញដោយមានបរិមាណ ឬ រង្វាស់រង្វាល់តិចជាងបរិមាណដែលបានព្រមព្រៀងគ្នា ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ និង/ឬ ពិន័យជាប្រាក់ទ្វេដង ។

**មាត្រា ៤៧.-**

ជនណាដែលផ្គត់ផ្គង់ លក់ ឬ ដាក់តាំងលក់នូវទំនិញវេចខ្ចប់ដែលបំភាន់អំពីលក្ខណៈទម្ងន់ ឬ រង្វាស់រង្វាល់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ)ថ្ងៃ ទៅ ១(មួយ) ខែ និង/ឬ ពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន)រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ និង/ឬពិន័យជាប្រាក់ទ្វេដង ។

**មាត្រា ៤៨.-**

អ្នកនាំចូលទំនិញ ឬ អ្នកផលិតទំនិញវេចខ្ចប់ដែល :

ក-នាំចូល ឬ វេចខ្ចប់ទំនិញជាកញ្ចប់ផ្ទុយនឹងការតម្រូវនៃកថាខណ្ឌ ក នៃមាត្រា ៣៣ នៃច្បាប់នេះ

ខ-ខកខានមិនបានដាក់សញ្ញាជាឯកតា ដែលអនុញ្ញាតនៅលើសម្ភារៈវេចខ្ចប់រួចនូវចំនួនទម្ងន់សុទ្ធ ឬ រង្វាស់រង្វាល់ ដែលមានបញ្ជាក់លើសម្ភារៈវេចខ្ចប់នៅក្នុងកញ្ចប់នោះ ឬ

គ-ខកខានមិនបានបង្ហាញឈ្មោះ និង អាសយដ្ឋានរបស់អ្នកផលិត ឬ អ្នកនាំចូល ឬ សញ្ញាសម្គាល់សម្រាប់កំណត់អត្តសញ្ញាណនៃឈ្មោះ និង អាសយដ្ឋាន ។

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ១.០០០.០០០(មួយលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល ។

ក្នុងករណីមិនរាងចាល ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង ហើយទំនិញដែលជាកម្មវត្ថុនៃបទល្មើសត្រូវរឹបអូស ។

**មាត្រា ៤៩.-**

ជនណាដែលលក់ ឬ ដាក់លក់នូវទំនិញវេចខ្ចប់ ដែលមិនមានដាក់ចំនួនទម្ងន់ ឬ រង្វាស់រង្វាល់លើសម្ភារៈវេចខ្ចប់នូវឯកតាដែលមានចែងក្នុងឧបសម្ព័ន្ធទី ១ និងឧបសម្ព័ន្ធទី ២ ត្រូវព្រមាន ឬ ពិន័យអន្តរការណ៍ជាប្រាក់ពី ១០.០០០(មួយម៉ឺន) រៀល ទៅ ៥០០.០០០(ប្រាំសែន) រៀល ។

ក្នុងករណីមិនរាងចាល ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង ។

**មាត្រា ៥០.-**

ជនណា ដែលរារាំង ឬ បដិសេធមិនឱ្យមន្ត្រីត្រួតពិនិត្យអនុវត្តសិទ្ធិក្នុងប្រតិបត្តិការដែលមានចែងក្នុងច្បាប់នេះ ត្រូវព្រមាន ឬ ពិន័យអន្តរការណ៍ ជាប្រាក់ចំនួនពី ១.០០០.០០០ (មួយលាន)រៀល ទៅ ៥.០០០.០០០ (ប្រាំលាន)រៀល ។

ក្នុងករណីមិនរាងចាល ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង ។

**មាត្រា ៥១.-**

មន្ត្រីត្រួតពិនិត្យណាដែលបំពានលើមាត្រាណាមួយនៃច្បាប់នេះ ជាអាទិ៍លើបទប្បញ្ញត្តិទាក់ទងនឹងការត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ ឬ សេវាមាត្រាសាស្ត្រ ត្រូវទទួលទណ្ឌកម្មខាងវិន័យ តាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

ទណ្ឌកម្មខាងវិន័យនេះ មិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសណាមួយត្រូវបានប្រព្រឹត្ត ។

**មាត្រា ៥២.-**

ស្របតាមបញ្ញត្តិនៃច្បាប់នេះ នៅពេលដែលមានបទល្មើសណាមួយត្រូវបានប្រព្រឹត្តនិយោជិតរបស់សហគ្រាសផលិត ឬ ពាណិជ្ជករ បទល្មើសនោះត្រូវបានចាត់ទុកថាបានប្រព្រឹត្តដោយអ្នកផលិត ឬ ពាណិជ្ជករនោះ លើកលែងតែមានភស្តុតាងបញ្ជាក់ថា បទល្មើសនោះត្រូវបានប្រព្រឹត្តឡើងដោយអ្នកផលិត ឬ ពាណិជ្ជករ នោះពុំបានដឹង ឬ ពុំបានចូលរួម ។

**មាត្រា ៥៣.-**

ស្របតាមបញ្ញត្តិនៃច្បាប់នេះ បទល្មើសត្រូវបានចាត់ទុកថា បានប្រព្រឹត្តដោយនីតិបុគ្គល ប្រសិនបើនិយោជិត ភ្នាក់ងារ ឬ បុគ្គលិករបស់នីតិបុគ្គល ដែលធ្វើសកម្មភាពក្នុងក្របខ័ណ្ឌនៃការងាររបស់ខ្លួន ឬ ដោយមានបញ្ជាពីនីតិបុគ្គល បានធ្វើសកម្មភាពដែលជាបទល្មើស ដូចមានចែងនៅក្នុងច្បាប់នេះ ហើយសកម្មភាពនោះត្រូវបានផ្សារភ្ជាប់ទៅនឹងនីតិបុគ្គលនោះ ។

ROYAUME DU CAMBODGE * MINISTRE DU PALAIS ROYAL

ក៏ប៉ុន្តែនីតិបុគ្គល មិនត្រូវបានចាត់ទុកថា ប្រព្រឹត្តបទល្មើសទេ ប្រសិនបើមានភស្តុតាងបញ្ជាក់ថា បទល្មើសនោះត្រូវបានប្រព្រឹត្តឡើងដោយខ្លួនពុំបានដឹង ឬ ពុំបានចូលរួម ។

**មាត្រា ៥៤.-**

មន្ត្រីត្រួតពិនិត្យត្រូវមាននីតិសម្បទា ដើម្បីពិនិត្យបទល្មើសដូចមានចែងនៅក្នុងជំពូកនេះ ។

សេចក្តីកំណត់ហេតុដែលបានធ្វើឡើង តាមកិច្ចអនុវត្តនៃកថាខណ្ឌខាងលើ ត្រូវបានចាត់ទុកថាបានការ ចំពោះតុលាការ រហូតមានភស្តុតាងផ្ទុយទៅវិញ ។

បទប្បញ្ញត្តិដែលមានចែងនៅក្នុងមាត្រា ៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្ត លើកលែងតែចំណុចដែលផ្ទុយពីការកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រានេះ ។

**មាត្រា ៥៥.-**

ទណ្ឌកម្ម ព្រមាន និង ពិន័យអន្តរការណ៍ដែលមានចែងក្នុងច្បាប់នេះ ត្រូវអនុវត្តដោយមន្ត្រីត្រួតពិនិត្យ ។

ករណីជនល្មើស មិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ និងករណីរឹបអូសទំនិញ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ត្រូវបញ្ជូនសំណុំរឿងទៅតុលាការមានសមត្ថកិច្ច ។

## ជំពូកទី ១១

## អន្តរប្បញ្ញត្តិ

**មាត្រា ៥៦.-**

បន្ទាប់ពីច្បាប់នេះចូលជាធរមាន រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលផ្តល់សេវាទាក់ទងនឹងការផលិត និង/ឬការជួសជុល នូវឧបករណ៍មាត្រាសាស្ត្រ ត្រូវបំពេញបែបបទ ដើម្បីទទួលអាជ្ញាប័ណ្ណក្នុងរយៈពេលមិនលើសពី ៦ (ប្រាំមួយ)ខែ នៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ចំពោះរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលកាន់កាប់ ដើម្បីប្រើប្រាស់ ជួល ឬ ចែកចាយនូវឧបករណ៍មាត្រាសាស្ត្រ ត្រូវមកបំពេញបែបបទ ដើម្បីសុំការពិនិត្យផ្ទៀងផ្ទាត់ និងដាក់សញ្ញាត្រួតពិនិត្យលើកដំបូងដោយមន្ត្រីមានសមត្ថកិច្ច ក្នុងរយៈពេលមិនលើសពី ៦ (ប្រាំមួយ)ខែ បន្ទាប់ពីពេលដែលច្បាប់នេះចូលជាធរមាន នៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ក្នុងករណីមិនគោរពតាមបទប្បញ្ញត្តិនេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ៥០.០០០ (ប្រាំម៉ឺន)រៀល ទៅ ៥០០.០០០ (ប្រាំសែន)រៀល ។

## ជំពូកទី ១២

## អវសានប្បញ្ញត្តិ

**មាត្រា ៥៧.–**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រល.០៩០៥.៤៣៤

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ហត្ថលេខា

ស៊ុយ សែម

លេខ : ៧៦១ ច.ល
ដើម្បីចម្លងចែកចាយ
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៥
អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល
ជិនកេន

## ឧបសម្ព័ន្ធទី ១

## និយមន័យនៃប្រព័ន្ធឯកតាមាត្រាសាស្ត្រអន្តរជាតិ

**១.ប្រភេទនៃប្រព័ន្ធឯកតាមាត្រាសាស្ត្រអន្តរជាតិ**

**១.១. ប្រព័ន្ធឯកតា** SI (អេសអ៊ី) គឺជាប្រព័ន្ធឯកតាមាត្រាសាស្ត្រអន្តរជាតិ ដែលមានឈ្មោះហៅកាត់ថា SI ។

**១.២. ប្រព័ន្ធឯកតា** SI រួមមាន :

-ឯកតាមូលដ្ឋាន មានកំណត់និយមន័យ និង និមិត្តសញ្ញាក្នុងចំណុច ១.២.១. និង ១.២.២. នៃឧបសម្ព័ន្ធទី ១ ។

-ឯកតាបំបែក មានកំណត់និយមន័យ និង និមិត្តសញ្ញាក្នុងចំណុច ២ ។

**១.២.១. ឯកតាមូលដ្ឋាននៃប្រព័ន្ធឯកតាមាត្រាសាស្ត្រអន្តរជាតិ** SI ជាប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់មានដូចខាងក្រោម :

-ម៉ែត្រដែលមាននិមិត្តសញ្ញា m (អឹម) និង និមិត្តសញ្ញារបស់ជាតិ គឺ ម.(ម៉ែត្រ)

-គីឡូក្រាម ដែលមាននិមិត្តសញ្ញា kg (ការហ្សេ) និង និមិត្តសញ្ញារបស់ជាតិ គឺ គ.ក្រ. (គីឡូក្រាម)

-វិនាទី ដែលមាននិមិត្តសញ្ញា S (អេស) និង និមិត្តសញ្ញារបស់ជាតិ គឺ ″ (វិនាទី)

-អំពែ ដែលមាននិមិត្តសញ្ញា A (អា) និង និមិត្តសញ្ញារបស់ជាតិ គឺ A (អំពែ)

-កែលវិន ដែលមាននិមិត្តសញ្ញា K (កា) និង និមិត្តសញ្ញារបស់ជាតិ គឺ °K (កែលវិន)

-ម៉ូល ដែលមាននិមិត្តសញ្ញា mol (ម៉ូល) និង និមិត្តសញ្ញារបស់ជាតិ គឺ mol (ម៉ូល)

-ខេនដេឡា ដែលមាននិមិត្តសញ្ញា cd (សេដេ) និង និមិត្តសញ្ញារបស់ជាតិ គឺ cd (ខេនដាឡា)

**១.២.២.** កំណត់និយមន័យឯកតាមូលដ្ឋាននៃប្រព័ន្ធឯកតាមាត្រាសាស្ត្រអន្តរជាតិ SI ជាប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់មានដូចតទៅ :

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

-ម៉ែត្រ ជាប្រវែងនៃល្បឿនពន្លឺដែលចរក្នុងសុញ្ញកាសនៃចន្លោះពេល ១/២៩៩៧៩២៤៥៨ វិនាទី ។

-គីឡូក្រាម ជាម៉ាស់នៃគីឡូក្រាមស្មើនឹងម៉ាស់នៃគំរូដើមអន្តរជាតិ ដែលបានរក្សាទុកនៅការិយាល័យទម្ងន់ និង រង្វាស់រង្វាល់អន្តរជាតិនៃអង្គការនីត្យានុកូលមាត្រាសាស្ត្រអន្តរជាតិ ។

-វិនាទី ជាពេលវេលាស្មើនឹង ៩១៩២៦៣១៧៧០ ខួប របស់កាំរស្មីដែលត្រូវគ្នានឹងការផ្លាស់ប្តូររវាងកម្ពស់អ៊ីពែកហ្វីន (Hyperfine) ទាំងពីរនៃភាគខាងក្រោមរបស់សេស្យូម -១៣៣ អាតូម ។

-អំពែ ជាចរន្តអគ្គិសនីថេរក្នុងនោះមានអង្គធាតុចម្លងមុខកាត់រាងមូលចំនួនពីរស្របគ្នាដែលមានប្រវែង ១ម៉ែត្រ ក្នុងសុញ្ញកាសដែលបង្កើតបាន កម្លាំង$២ \times ១០^{-៧}$ N ក្នុងប្រវែង ១ម៉ែត្រ ។

-កែលវិន ជាប្រភាគ១/២៧១,១៦ នៃសីតុណ្ហភាពទែម៉ូឌីណាមិចរបស់ត្រីចំណុចនៃទឹក ។

-ម៉ូល ជាបរិមាណនៃប្រព័ន្ធសារធាតុមួយ ដែលផ្គុំឡើងដោយអង្គធាតុរួមផ្សំជាច្រើនដែលមានអាតូម ០,០១២ គីឡូក្រាម នៃកាបោន ១២ ។ កត់សម្គាល់ កាលណាម៉ូលត្រូវបានគេប្រើប្រាស់អង្គធាតុផ្សំជាច្រើន ត្រូវបានគេបញ្ជាក់ និង អាចជាអាតូមម៉ូលេគុល អ៊ីយ៉ុង អេឡិចត្រុង និង ធាតុផ្សេងៗទៀត ឬ ក្រុមនៃធាតុទាំងនោះ ។

-ខេនដេឡា ជាអាំងតង់ស៊ីតេនៃពន្លឺដែលមានទិសក្នុងប្រភពមួយ ដែលបំភាយបាន រស្មីម៉ូណូក្រូម៉ាទិចនៃវិទ្យុសកម្ម ចំនួនប្រេកង់ ពី $៥៤០ \times ១០^{១២}$ និង មានកាំនៃរង្វង់នៃអាំងតង់ស៊ីតេស្មើនឹង ១/៦៨៣ វ៉ាត់ នៃ ១ មុំបំពេញ ។

**២.ឯកតាបំបែក**

ឯកតាបំបែក ត្រូវបានកំណត់តាមវិធី ដែលស្របទៅនឹងឯកតាមូលដ្ឋានដែលអាចនិយាយបានថា ឯកតានេះត្រូវបានកំណត់ដោយការបង្ហាញជា លេខពិជគណិត តាមទម្រង់

នៃការបង្កើតឱ្យមានស្វ័យគុណដោយឯកតាមូលដ្ឋានទៅតាមកត្តាលេខរៀងស្មើនឹងមួយ ។ ឯកតាបំបែកភាគច្រើនបំផុត ត្រូវបានបង្ហាញជូន ទៅក្នុងផ្នែក ក. ខ. គ. ឃ. ង. និង ច. ។

**ក. ឯកតានៃលំហ និង ពេល** (Units of space and time)

**២.១.១.** មុំរាបៈ រ៉ាឌីយ៉ង (**Radian**) (និមិត្តសញ្ញា :**rad**) គឺជាមុំរាបចន្លោះកាំពីរ ដែលកាត់ផ្តាច់វណ្ឌមណ្ឌលនៃរង្វង់ជាធ្នូ ហើយមានប្រវែងស្មើនឹងកាំរង្វង់ ។

$$1\ \text{rad} = \frac{1\text{m}}{1\text{m}} = 1$$

**២.១.២.** មុំបំពេញ : ស្តេរ៉ាឌីយ៉ង (**Steradian**) (និមិត្តសញ្ញា : sr) គឺជាមុំដែល គឺជាមុំដែលមានកំពូលស្ថិតនៅចំកណ្តាលផ្ចិតស្វែរ កាត់ផ្តាច់តំបន់នៃផ្ទៃស្វែរស្មើទៅនឹងផ្ទៃ សងខាង ស្មើទៅនឹងប្រវែងកាំនៃស្វែរនោះ ។

$$1\ \text{sr} = \frac{1\text{m}^2}{1\text{m}^2} = 1$$

**២.១.៣.** ចំនួននៃរលក (**Wave**) : ១ ក្នុងមួយម៉ែត្រ (និមិត្តសញ្ញា : $១\,\text{m}^{-1}$) គឺជាចំនួនរលកនៃមួណ្ឌភ្លេម៉ាទិច (**monochromatic**) ចំហាយវិទ្យុសកម្ម (**radiation**) ដែលប្រវែងរលកចំហាយនេះស្មើនឹង ១ ម៉ែត្រ ។

$$1\ \text{m}^{-1} = \frac{1}{1\text{m}}$$

**២.១.៤.** ផ្ទៃក្រឡា (**Surface, Area**) : ម៉ែត្រការ៉េ (និមិត្តសញ្ញា : $\text{m}^2$) គឺជាឯកតានៃផ្ទៃក្រឡាដែលមានបួនជ្រុងហើយជ្រុងនីមួយៗស្មើនឹង ១ ម៉ែត្រ ។

$$1\text{m}^2 = 1\text{m} \times 1\text{m}$$

**២.១.៥.** មាឌចំណុះ (Volume) : ម៉ែត្រគូប (និមិត្តសញ្ញា : $\text{m}^3$) គឺជាឯកតានៃមាឌ ដែលជ្រុងនីមួយៗស្មើនឹង ១ ម៉ែត្រ ។

$$1\text{m}^3 = 1\text{m} \times 1\text{m} \times 1\text{m}$$

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**២.១.៦.** ហ្វ្រេកង់ (Frequency) : hertz ( និមិត្តសញ្ញា : Hz ) គឺជាហ្វ្រេកង់មួយខួបនៃបាតុភូត ដែលថេរវេលាមួយខួបស្មើនឹង ១ វិនាទី ។

$$1\ \mathrm{Hz} = 1\ \mathrm{s}^{-1} = \frac{1}{1\mathrm{s}}$$

**២.១.៧.** ល្បឿនមុំ ( Angular velocity ) : រ៉ាឌីយ៉ង់ ( radian ) ក្នុងមួយវិនាទី (និមិត្តសញ្ញា : rad/s ឬ $\mathrm{rad} \times \mathrm{s}^{-1}$) គឺជាល្បឿនមុំនៃអង្គធាតុមួយដែលធ្វើសកម្មភាពដោយចលនាថេរ វិលជុំវិញអ័ក្ស ប្រែប្រួលមួយ radian ក្នុងមួយវិនាទី ។

$$1\ \mathrm{rad/s} = \frac{1\mathrm{rad}}{1\mathrm{s}}$$

**២.១.៨.** សន្ទុះមុំ (Angular acceleration) : រ៉ាឌីយ៉ង (radian) ក្នុងមួយវិនាទីការ៉េ ( និមិត្តសញ្ញា : $\mathrm{rad/s}^2$ ឬ $\mathrm{rad} \times \mathrm{s}^2$ ) គឺជាសន្ទុះមុំនៃអង្គធាតុមួយដែលធ្វើសកម្មភាព ដោយចលនាអថេរជុំវិញអ័ក្ស ហើយល្បឿនមុំប្រែប្រួលក្នុងមួយវិនាទី ។

$$1\ \mathrm{rad/s}^2 = \frac{1\mathrm{rad/s}}{1\mathrm{s}}$$

**២.១.៩.** ល្បឿន (speed) : មួយម៉ែត្រក្នុងមួយវិនាទី ( និមិត្តសញ្ញា : m/s ឬ $\mathrm{m} \times \mathrm{s}^{-1}$) គឺជាល្បឿននៃវត្ថុអង្គធាតុមួយដែលធ្វើសកម្មភាព ដោយចលនាថេរ បានមួយម៉ែត្រ ក្នុងមួយវិនាទី ។

$$1\ \mathrm{m/s} = \frac{1\mathrm{m}}{1\mathrm{s}}$$

**២.១.១០.** សន្ទុះអាក់សេឡេរ៉ាស្យុង (Acceleration) : ល្បឿនមួយម៉ែត្រក្នុងមួយវិនាទីការ៉េ ( និមិត្តសញ្ញា : $\mathrm{m/s}^2$ ឬ $\mathrm{m} \times \mathrm{s}^{-2}$ ) គឺជាសន្ទុះនៃអង្គធាតុមួយ ដែលធ្វើសកម្មភាពដោយចលនាអថេរក្នុងមួយវិនាទី ដោយល្បឿនមួយម៉ែត្រក្នុងមួយវិនាទី ។

$$1\ \mathrm{m/s}^3 = \frac{1\mathrm{m/s}}{1\mathrm{s}}$$



**ខ. ឯកតានៃមេកានិក** ( Units of Mechanics )

**២.២.១.** ដង់ស៊ីតេនៃសាច់បណ្តោយ(Linear density) : គីឡូក្រាមក្នុងមួយម៉ែត្រ ( និមិត្តសញ្ញា : kg/m ឬ $kg \times m^{-1}$ ) គឺជាដង់ស៊ីតេនៃសាច់បណ្តោយរបស់អង្គធាតុស្មើសាច់មួយ ដែលមុខកាត់ឯកសណ្ឋានវាមានម៉ាស់ ១គីឡូក្រាម និងមានប្រវែង ១ម៉ែត្រ ។

$$1\ kg/m = \frac{1kg}{1m}$$

**២.២.២.** ដង់ស៊ីតេផ្ទៃក្រឡា (Surface density) : គីឡូក្រាមក្នុងមួយម៉ែត្រការ៉េ ( និមិត្តសញ្ញា : $kg/m^2$ ឬ $kg \times m^{-2}$ ) គឺជាដង់ស៊ីតេនៃអង្គធាតុស្មើសាច់ដែលមានម៉ាស់ ១គីឡូក្រាម និងផ្ទៃមួយម៉ែត្រការ៉េ ។

$$1\ kg/m^2 = \frac{1kg}{1m^2}$$

**២.២.៣.** ដង់ស៊ីតេ(Density) ( ដង់ស៊ីតេទម្ងន់ ) : គីឡូក្រាមក្នុងមួយម៉ែត្រគូប ( និមិត្តសញ្ញា : $kg/m^3$ ឬ $kg \times m^{-3}$ ) គឺជាដង់ស៊ីតេនៃអង្គធាតុស្មើសាច់ ដែលមានម៉ាស់ ១គីឡូក្រាម និងមានមួយម៉ែត្រគូប ។

$$1\ kg/m^3 = \frac{1kg}{1m^3}$$

**២.២.៤.** កម្លាំង (Force) : ញូតុន(Newton) ( និមិត្តសញ្ញា : N ) គឺជាកម្លាំងដែលមានទៅលើអង្គធាតុមួយ ដែលមានម៉ាស់ ១គីឡូក្រាម ហើយផ្តល់នូវសន្ទុះ ១ម៉ែត្រ ក្នុងមួយវិនាទីការ៉េ ។

$$1\ N = 1\ kg \times m/s^2$$

**២.២.៥.** សម្ពាធ(Pressure, Stress) : ប៉ាស្កាល់(Pascal) (និមិត្តសញ្ញា : Pa) គឺជាសម្ពាធឯកសណ្ឋានមួយ ដែលរងនូវអំពើនៃកម្លាំងសង្កត់ ១ញូតុន កែងទៅនឹងផ្ទៃដីរាប ១ម៉ែត្រការ៉េ ។ ប៉ាស្កាល់គឺជាសង្កត់ឯកសណ្ឋានផងដែរទៅលើផ្ទៃរាបស្មើ ១ម៉ែត្រការ៉េ នូវកម្លាំង ស្មើនឹង១ញូតុនដែរ ។

$$1Pa = \frac{1N}{1m^2}$$

**២.២.៦. ភាពអន្ទិលឌីណាមិច** (Dynamic viscosity) : ប៉ាស្កាល់វិនាទី ( និមិត្តសញ្ញា : Pa × s ) គឺជាភាពអន្ទិលឌីណាមិចនៃអង្គធាតុរាវស្មើសាច់ ដែលក្នុងនោះចលនាសាច់បណ្តោយឯកសណ្ឋានមួយ នៃផ្ទៃរាបមួយម៉ែត្រការ៉េ ដែលមានការពន្យារ កម្លាំង១ញូតុន នៅពេលដែលមានល្បឿនខុសគ្នា មួយម៉ែត្រ ក្នុងមួយវិនាទី រវាងផ្ទៃរាបស្របគ្នា ដែលបែងចែកដោយចម្ងាយ ១ម៉ែត្រ ។

$$1\ Pa \times s = \frac{1Pa \times 1m}{1m/s}$$

**២.២.៧. ភាពអន្ទិលស៊ីនេទិច** (Kinetic viscosity) : មួយម៉ែត្រការ៉េក្នុងមួយនាទី ( និមិត្តសញ្ញា :$m^2/s$ ឬ $m^2 \times s^{-1}$ ) គឺជាភាពអន្ទិលស៊ីនេទិចនៃវត្ថុរាវ ដែលភាពអន្ទិលឌីណាមិចមានមួយប៉ាស្កាល់វិនាទីធៀបនឹងដង់ស៊ីតេ ១ គីឡូក្រាមក្នុងមួយម៉ែត្រគូប ។

$$1\ m^2\ /s = \frac{1Pa \times s}{1kg/\ m^3}$$

**២.២.៨. កម្មន្ត ថាមពល បរិមាណនៃកម្តៅ** (Work, Energy, Quantity of heat) : ស៊ូល (Joule ) ( និមិត្តសញ្ញា : J )គឺជាការងារដែលបានបំពេញរួច នៅត្រង់ចំណុចនៃការអនុវត្តកម្លាំង ១ញូតុន ត្រូវបានផ្លាស់ទីដោយចម្ងាយ ១ ម៉ែត្រ ក្នុងទិសដៅនៃកម្លាំង ។

$$1\ J = 1\ N \times 1\ m$$

**២.២.៩. ថាមពល អត្រាលំហូរថាមពល អត្រាលំហូរកម្តៅ**(Power, Energy flow rate, Heat flow rate) : វ៉ាត់ ( និមិត្តសញ្ញា :W ) គឺជាកម្លាំងដែលបង្កើតថាមពលស្មើនឹង ១ស៊ូល ក្នុងមួយវិនាទី ។

$$1\ W = \frac{1J}{1s}$$

**២.២.១០. អត្រាលំហូរមាឌ** ( Volume flow rate ) : មួយម៉ែត្រគូបក្នុងមួយវិនាទី

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

( និមិត្តសញ្ញា :$m^3/s$ ឬ $m^3 \times s^{-1}$ ) គឺជាអត្រាលំហូរមាឌដែលបរិមាណអង្គធាតុមានមាឌ ១ ម៉ែត្រគូប បញ្ជូនបន្ត កាត់តាមផ្ទៃមុខកាត់ ដែលកំណត់ក្នុងមួយវិនាទី ។

$$1\ m^3/s = \frac{1m^3}{1s}$$

**២.២.១១.** អត្រាលំហូរទម្ងន់(Mass flow rate) : មួយគីឡូក្រាមក្នុងមួយវិនាទី ( និមិត្តសញ្ញា :kg/s ឬ $kg \times s^{-1}$ ) គឺជាអត្រាលំហូរទម្ងន់ជាឯកសណ្ឋាន ដែលបរិមាណមានទម្ងន់ ១ គីឡូក្រាម បញ្ជូនបន្តកាត់តាមផ្ទៃមុខកាត់ ដែលកំណត់ក្នុងមួយវិនាទី ។

$$1\ kg/s = \frac{1kg}{1s}$$

**គ. ឯកតានៃកម្តៅ**(Unit of Heat)

**២.៣.១.** Entropy : Joule per Kelvin : ( និមិត្តសញ្ញា :J/K ឬ $J \times K^{-1}$ ) គឺជាកំណើន Entropy នៃប្រព័ន្ធទទួលបរិមាណកម្តៅក្នុង ១ ស៊ូល នៅសីតុណ្ហភាព ១ កែលវិន លើកលែងតែ មិនមានការផ្លាស់ប្តូរណាមួយកើតឡើង នៅក្នុងប្រព័ន្ធនោះ ។

$$1\ J/K = \frac{1J}{1K}$$

**២.៣.២.** បរិមាណកម្តៅជាក់លាក់(Specific heat capacity) : Joule ក្នុងមួយគីឡូក្រាម Kelvin ( និមិត្តសញ្ញា :J/(kg×K) ឬ $J/kg^{-1} \times K^{-1}$ ) គឺជាបរិមាណកម្តៅជាក់លាក់នៃអង្គធាតុស្មើសាច់ ដែលមានទម្ងន់ គីឡូក្រាម នៅក្នុងនោះបរិមាណបន្ថែមនៃកម្តៅ ១ ស៊ូល ធ្វើឱ្យកើនឡើង នូវសីតុណ្ហភាព ១ កែលវិន ។

$$1\ J/(kg \times k) = \frac{1J}{1kg \times 1k}$$

**២.៣.៣.** កម្តៅកុងឌុចតង់(Thermal conductivity) : វ៉ាត់ក្នុងមួយម៉ែត្រកែលវិន ( និមិត្តសញ្ញា :W/(m×K) ឬ $W \times m^{-1} \times K^{-1}$ ) គឺជាកម្តៅកុងឌុចតង់នៃអង្គធាតុស្មើសាច់ ដែលក្នុង

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

39/50

នោះ ភាពខុសគ្នានៃសីតុណ្ហភាព ១ កែលវិនរវាងផ្ទៃរាបស្របគ្នា២ ដែលមានផ្ទៃ ១ ម៉ែត្រការ៉េ ហើយបង្កើតឱ្យមានចម្ងាយ ១ម៉ែត្រ រវាងផ្ទៃរាបនេះនូវអត្រាលំហូរកម្តៅ១វ៉ាត់ ។

$$1\ W/(m \times K) = \frac{1W/m^2}{1K/1m}$$

**ឃ. ឯកតានៃអគ្គិសនី និង ម៉ាញ៉េទិច** ( Unit of Electricity and Magnetism )

**២.៤.១.** បរិមាណអគ្គិសនី បន្ទុកអគ្គិសនី ( Quantity electricity, Electric charge ) : គូឡុម (coulomb ) ( និមិត្តសញ្ញា :C ) គឺជាបរិមាណអគ្គិសនី ដែលដំណើរការក្នុងមួយវិនាទី ដោយចរន្ត ១ អំពែ ។

$$1\ C = 1\ A \times 1s = 1A \times s$$

**២.៤.២.** ផលសងប៉ូតង់ស្យែល តង់ស្យុងអគ្គិសនី កម្លាំង(Electric potential, Electric tension, Electromotive force) : វ៉ុល(Volt) ( និមិត្តសញ្ញា :V ) គឺជាផលសងប៉ូតង់ស្យែលរវាងចំណុច ២ នៃការរៀបចំខ្សែអគ្គិសនី ដែលមានចរន្តថេរ ១ អំពែ នៅពេលថាមពលបាត់បង់រវាងចំណុចទាំងពីរនោះ ស្មើនឹង ១ វ៉ាត់ ។

$$1\ V = \frac{1W}{1A}$$

**២.៤.៣.** កម្លាំងដែនអគ្គិសនី (Electric field strength) : វ៉ុលក្នុងមួយម៉ែត្រ ( និមិត្តសញ្ញា :V/m ) គឺជាកម្លាំងដែនអគ្គិសនីដែលបញ្ចេញកម្លាំង ១ ញូតុន ទៅលើវត្ថុដែលមានបរិមាណអគ្គិសនី ១ គូឡុម ។

$$1\ V/m = \frac{1N}{1C}$$

**២.៤.៤.** រ៉េស៊ីស្តង់អគ្គិសនី (Electric resistance) : អូម (ohm ) ( និមិត្តសញ្ញា : Ω ) គឺជារ៉េស៊ីស្តង់អគ្គិសនីរវាងចំណុច ២ នៃខ្សែចម្លង នៅពេលភាពខុសគ្នា នៃផលសងប៉ូតង់ស្យែលថេរ ១ វ៉ុល មានទៅលើចំណុចទាំងពីរ បង្កើតឱ្យមាននូវចរន្ត ១ អំពែ ។ ពេលនោះខ្សែចម្លងមិនមែនជាកន្លែងផ្ទុកកម្លាំងអគ្គិសនីចលករណាមួយទេ ។

$$1\Omega = \frac{1\,V}{1\,A}$$

**២.៤.៥.** កុងឌុចតង់ (Conductance) : Siemens ( និមិត្តសញ្ញា :S ) គឺជាកុងឌុចតង់នៃខ្សែចម្លងដែលមានរ៉េស៊ីស្តង់អគ្គិសនី ១ អូម ។

$$1\,S = 1\Omega^{-1} = \frac{1}{1\,\Omega}$$

**២.៤.៦.** កាប៉ាស៊ីទ័រអគ្គិសនី (Electric capacitance) : farad ( និមិត្តសញ្ញា : F ) គឺជាកាប៉ាស៊ីទិននៃកាប៉ាស៊ីទ័រ រវាងបន្ទះបរិក្ខារ ដែលបង្កើតឱ្យមានផលសងប៉ូតង់ស្យែល ១ វ៉ុល ហើយដែលត្រូវបានបញ្ចូលដោយបរិមាណអគ្គិសនីចំនួន ១ គូឡុម ។

$$1\,F = \frac{1C}{1V}$$

**២.៤.៧.** Inductance :henry ( និមិត្តសញ្ញ :H ) គឺជាInductance អគ្គិសនីនៃសៀគ្វីបិទ ដែលក្នុងនោះកម្លាំង electromotive ១ វ៉ុល ត្រូវបានបង្កើតឡើងនៅពេលចរន្តអគ្គិសនីប្រែប្រួលថេរនៅក្នុងសៀគ្វីតាមអត្រា ១ អំពែក្នុងមួយវិនាទី ។

$$1\,H = \frac{1V \times 1s}{1A}$$

**២.៤.៨.** ភ្លុចម៉ាញ៉េទិច ភ្លុចអាំងឌុចស្យុងម៉ាញ៉េទិច (Magnetic flux, magnetic induction flux) ( និមិត្តសញ្ញា:Wb ) គឺជាភ្លុចម៉ាញ៉េទិច ដែលផ្សាយភ្ជាប់សៀគ្វីបិទ ១ ដែលអាចបង្កើតឱ្យមានកម្លាំង electromotive ១ វ៉ុល ប្រសិនបើវាបន្ថយតាមអត្រាថេរមកនៅត្រឹមសូន្យក្នុងមួយវិនាទី ។

$$1\,Wb = 1\,V \times 1\,s$$

**២.៤.៩.** អាំងឌុចស្យុងម៉ាញ៉េទិច ម៉ាញ៉េទិច ភ្លុចដង់ស៊ីតេ (Magnetic induction, Magnetic, flux density : tesla ( និមិត្តសញ្ញា : T ) គឺជាអាំងឌុចស្យុងម៉ាញ៉េទិច ឯកសណ្ឋានមួយ

ROYAUME DU CAMBODGE * LE MINISTERE DU PALAIS ROYAL *
ក្រសួងព្រះបរមរាជវាំង

ដែលបែងចែកជាធម្មតាទៅលើផ្ទៃរាប ១ម៉ែត្រការ៉េ បង្កើតលើផ្ទៃរាបទាំងមូលនូវភ្លុចម៉ាញ៉េទិច ១ វ៉េប៊ែរ ។

$$1\ T = \frac{1\,Wb}{1\,m^2}$$

**២.៤.១០.** កម្លាំងម៉ាញ៉េទិច (Magnetomotive force) : អំពែ ( និមិត្តសញ្ញា : A) គឺជាកម្លាំងម៉ាញ៉េទិចមួយនៅបណ្តោយខ្សែកោងបិទជិត ដែលហ៊ុំព័ទ្ធនៅពេលខ្សែចម្លងអគ្គិសនីតាមរយៈចរន្តអគ្គិសនី ១អំពែ ឆ្លងកាត់ ។

**២.៤.១១.** កម្លាំងនៃដែនម៉ាញ៉េទិច (Magnetic fieldstrength) : អំពែក្នុងមួយម៉ែត្រ ( និមិត្តសញ្ញា : A/m ឬ $A \times m^{-1}$ ) គឺជាកម្លាំងនៃដែនម៉ាញេទិចដែលកកើតឡើង ក្នុងសុញ្ញាកាស តាមវណ្ឌមណ្ឌល មួយម៉ែត្រជុំវិញដោយចរន្តអគ្គិសនីមួយអំពែ ស្ថិតក្នុងខ្សែចម្លងអគ្គិសនីត្រង់មួយមានចម្ងាយ អនន្ត បង្កើតបានជាអ័ក្សនៃវណ្ឌមណ្ឌលជុំវិញនោះ ។

$$1\ A/m = \frac{1\,A}{1\,m}$$

**៥. ឯកតារ៉ាឌីយ៉ូសកម្ម និងពន្លឺ** (Unit of Radiation and Light)

**២.៥.១.** អាំងតង់ស៊ីតេពន្លឺ (Radiant intensity) : វ៉ាត់ក្នុងមួយស្តេរ៉ាឌីយ៉ង ( និមិត្តសញ្ញា : W/sr ឬ $W \times sr^{-1}$ ) គឺជាអាំងតង់ស៊ីតេនៃប្រភពចំណុចពន្លឺ ដែលបញ្ចេញពន្លឺ ១វ៉ាត់ក្នុងមុំបំពេញ ១ ស្តេរ៉ាឌីយ៉ង ។

$$1\ W/sr = \frac{1\,W}{1\,sr}$$

**២.៥.២.** ការបញ្ចេញពន្លឺ (Luminance) : ខនដេឡា (candela) ក្នុងមួយម៉ែត្រការ៉េ (និមិត្តសញ្ញា : $cd/m^2$ ឬ $cd \times m^{-2}$ ) គឺជាការបញ្ចេញពន្លឺច្បាស់កាត់កែងទៅនឹងផ្ទៃរាប ១ម៉ែត្រការ៉េ នៃប្រភពដែលអាំងតង់ស៊ីតេពន្លឺកាត់កែងទៅកាន់ផ្ទៃនោះគឺ ១ ខនដេឡា ។

$$1\ cd/m^2 = \frac{1\,cd}{1\,m^2}$$

ROYAUME DU CAMBODGE
ក្រសួងព្រះបរមរាជវាំង
MINISTRE DU PALAIS ROYAL

**២.៥.៣.** ការប្រែប្រួលពន្លឺ (Luminous flux) : លូមិន (lumen) (និមិត្តសញ្ញា : lm) គឺជាការប្រែប្រួលពន្លឺដែលបញ្ចេញក្នុងមុំបំពេញ ( ស្តេរ៉ាឌីយ៉ង ) ពីប្រភពចំណុចដូចគ្នា ដោយមានអាំងតង់ស៊ីតេពន្លឺ ១ខេដេឡា ។

$$1\ \mathrm{lm} = 1\ \mathrm{cd} \times 1\ \mathrm{sr}$$

**២.៥.៤.** អៀលុយមីនិន (Illuminance) : ឡាក់ (lux) ( និមិត្តសញ្ញា : lx ) គឺជាអៀលុយមីនិននៃផ្ទៃមួយដែលទទួលការប្រែប្រួលនៃពន្លឺ ១លូមិន ដែលគ្របដណ្តប់ជាទូទៅលើផ្ទៃមួយម៉ែត្រការ៉េ ។

$$1\ \mathrm{lx} = \frac{1\mathrm{lm}}{1\mathrm{m}^2}$$

**៦. ឯកតាសម្រាប់វាស់វិទ្យុសកម្ម** (Unit of Ionizing Radiations)

**២.៦.១.** សកម្មភាពនៃប្រភពវិទ្យុសកម្ម (Activities of radioactive source) : បិកខឺរ៉ែល (becquerel) ( និមិត្តសញ្ញា : Bq ) គឺជាសកម្មភាពនៃប្រភពវិទ្យុសកម្មដែលប្តូរ ១នុយក្លេអ៊ែ ឬ ការបញ្ជូនដែលកើតឡើងក្នុងមួយវិនាទី ។

$$1\ \mathrm{Bq} = \frac{1}{1\mathrm{s}}$$

**២.៦.២.** កម្រិតបឺត (Absorbed dose) : ហ្គ្រាយ (gray) ( និមិត្តសញ្ញា : Gy ) គឺជាកម្រិតបឺតក្នុងធាតុផ្សំនៃទម្ងន់ ១គីឡូក្រាម ដែលថាមពល ១ស៊ូល ចែកការវាស់វិទ្យុសកម្មដោយថាមពលមិនប្រែប្រួល ។

$$1\ \mathrm{Gy} = \frac{1\mathrm{W}}{1\mathrm{kg}}$$

**២.៦.៣.** ការបញ្ចេញ (Exposure) : គូឡុមក្នុងមួយគីឡូក្រាម ( និមិត្តសញ្ញា : C/kg ឬ $\mathrm{C} \times \mathrm{kg}^{-1}$ ) គឺជាការបញ្ចេញហ្វូតូនិចវិទ្យុសកម្ម ដែលអាចបង្កើតចំនួនខ្យល់ក្នុងទម្ងន់

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

មួយគីឡូក្រាមអ៊ីយ៉ុង នៃសញ្ញាមួយដែលផ្ទុកថាមពលអគ្គិសនីសរុប ១ គូឡុំម នៅនឹងដោយសារ តែបរិមាណខ្យល់ ។

$$1\ \mathrm{C/kg} = \frac{1\mathrm{C}}{1\mathrm{kg}}$$

## ៣.ពហុគុណ និងអនុពហុគុណទសភាគ នៃប្រព័ន្ធឯកតាមាត្រាសាស្ត្រអន្តរជាតិ SI

**៣.១.** ពហុគុណ និងអនុពហុគុណទសភាគនៃឯកតាSI ត្រូវបានបង្កើតឡើងតាមវិធី ជាកត្តាលេខទសភាគ ដូចមានចែងក្នុងកថាខណ្ឌខាងក្រោមដែលក្នុងនោះ ឯកតាSI ត្រូវបានគេគុណ ។

**៣.២.** ឈ្មោះនៃពហុគុណ និងអនុពហុគុណទសភាគនៃឯកតាSI ត្រូវបានបង្កើតឡើងតាមវិធីដាក់បុព្វបទ SI សម្គាល់កត្តាជាលេខទសភាគ ។

| កត្តា | បុព្វបទ SI | និមិត្តសញ្ញា |
|---|---|---|
| 1 000 000 000 000 000 000 $=10^{18}$ | exa | E |
| 1 000 000 000 000 000 $=10^{15}$ | peta | P |
| 1 000 000 000 000 $=10^{12}$ | tera | T |
| 1 000 000 000 $=10^{9}$ | giga | G |
| 1 000 000 $=10^{6}$ | mega | M |
| 1 000 $=10^{3}$ | kilo | k |
| 100 $=10^{2}$ | hecto | h |
| 10 $=10^{1}$ | deca | da |
| 0.1$=10^{-1}$ | deci | d |
| 0.01$=10^{-2}$ | centi | c |
| 0.001$=10^{-3}$ | milli | m |
| 0.000.001$=10^{-6}$ | micro | μ |
| 0.000.000.001$=10^{-9}$ | nano | n |
| 0.000.000.000.001$=10^{-12}$ | pico | p |
| 0.000.000.000.000.001$=10^{-15}$ | femto | f |
| 0.000.000.000.000.000.001$=10^{-18}$ | atto | a |

**៣.៣.** បុព្វបទត្រូវបានចាត់ទុកថា បានរួមបញ្ចូលជាមួយឈ្មោះឯកតា ដែលវាបានភ្ជាប់ដោយផ្ទាល់ ។

**៣.៤.** និមិត្តសញ្ញានៃបុព្វបទ ត្រូវដាក់នៅពីមុខនិមិត្តសញ្ញានៃឯកតាដោយគ្មានដកឃ្លា ដែលទាំងអស់នេះហើយបង្កើតបានជានិមិត្តសញ្ញាពហុគុណ ឬអនុពហុគុណនៃឯកតា ។ និមិត្តសញ្ញានៃបុព្វបទ ត្រូវបានចាត់ទុកថាបានរួមគ្នាជាមួយនិមិត្តសញ្ញានៃឯកតា ដែលវាបានភ្ជាប់ដោយផ្ទាល់ដែលបង្កើតបានជានិមិត្តសញ្ញាឯកតាថ្មីមួយ ដែលអាចកកើតស្វ័យគុណវិជ្ជមាន ឬអវិជ្ជមាន និងដែលអាចរួមបញ្ចូលជាមួយនិមិត្តសញ្ញាឯកតាផ្សេងៗទៀត ដើម្បីបង្កើតនិមិត្តសញ្ញាជាច្រើនសម្រាប់ឯកតាចម្រុះ ។

**៣.៥.** មិនអនុញ្ញាតឱ្យបុព្វបទលាយបញ្ចូលគ្នាច្រើន ដែលបង្កើតឡើងដោយការដាក់ទល់មុខគ្នានៃបុព្វបទ SI ច្រើនបានទេ ។

**៣.៦.** ឈ្មោះ និងនិមិត្តសញ្ញារបស់ពហុគុណទសភាគនៃឯកតាទម្ងន់បង្កើតឡើងដោយការបន្ថែមបុព្វបទ SI នៅពីមុខពាក្យក្រាម ( និមិត្តសញ្ញា : g ) ១ក្រាម = ០,០០១ គីឡូក្រាម =$១០^{-៣}$ គីឡូក្រាម ។

**៣.៧.** ដើម្បីសម្គាល់ពហុគុណ និងអនុពហុគុណទសភាគនៃឯកតាបំបែក ដែលបង្ហាញក្នុងទម្រង់ជាប្រភាគបុព្វបទមួយ អាចដាក់ភ្ជាប់ទៅឯកតា ដែលមានភាគយក ឬភាគបែង ឬទាំងភាគយក និងភាគបែង ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

## ឧបសម្ព័ន្ធទី ២

## ប្រព័ន្ធឯកតាមាត្រាសាស្ត្រដែលអនុញ្ញាតឱ្យប្រើប្រាស់ក្នុងផលិតកម្ម-អាជីវកម្ម

### ផ្នែកទី ១

### ពហុគុណ-អនុពហុគុណនៃប្រព័ន្ធឯកតាមាត្រាសាស្ត្រអន្តរជាតិ SI

**១.១. រង្វាស់នៃប្រវែង**

**១.១.១.** ឯកតា SI

| | | |
|---|---|---|
| គីឡូម៉ែត្រ (km) | = | ១.០០០ ម៉ែត្រ |
| ម៉ែត្រ (m) | = | ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១ |
| សង់ទីម៉ែត្រ (cm) | = | ១/១០០ ម៉ែត្រ |
| មីលីម៉ែត្រ (mm) | = | ១/១.០០០ ម៉ែត្រ |
| មីក្រូម៉ែត្រ (µm) | = | ១/១.០០០.០០០ ម៉ែត្រ |

**១.២. រង្វាស់នៃក្រឡាផ្ទៃ**

**១.២.១.** ឯកតា SI

| | | |
|---|---|---|
| ម៉ែត្រការ៉េ ($m^2$) | = | ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១ |
| គីឡូម៉ែត្រការ៉េ ($km^2$) | = | ១.០០០.០០០ ម៉ែត្រការ៉េ |
| មីលីម៉ែត្រការ៉េ ($mm^2$) | = | ១/១.០០០.០០០ ម៉ែត្រការ៉េ |
| ហិចតា (ha) | = | ១០.០០០ ម៉ែត្រការ៉េ |
| អា (a) | = | ១០០ ម៉ែត្រការ៉េ |
| សង់ទីម៉ែត្រការ៉េ ($cm^2$) | = | ១/១០.០០០ ម៉ែត្រការ៉េ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ១.៣. រង្វាស់នៃមុំរាប និងមុំបំពេញ

### ១.៣.១. មុំរាប

| | | |
|---|---|---|
| រ៉ាឌីយ៉ង់ (radian "rad") | = | ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១ |
| ដឺក្រេ ( ⁰ ) | = | II/១៨០ radians |
| នាទី ( ' ) | = | II/១០៨០០ radians |
| វិនាទី ( " ) | = | II/៦៤៨០០ radians |

### ១.៣.២. មុំបំពេញ

ស្តេរ៉ាឌីយ៉ង់ (staradians "sr") = ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១

## ១.៤. រង្វាស់នៃល្បឿន

### ១.៤.១. ឯកតា SI

ម៉ែត្រក្នុងមួយវិនាទី (m/s) = ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១

### ១.៤.២. ឯកតាដែលប្រើពហុគុណនៃម៉ែត្រ

គីឡូម៉ែត្រក្នុងមួយម៉ោង (km/h) = ១ល្បឿនជាគីឡូម៉ែត្រក្នុងមួយម៉ោង

## ១.៥. រង្វាស់នៃសម្លេង

**១.៥.១.** បែល (bel) ( និមិត្តសញ្ញា :B ) គឺជាកម្រិតនៃដែនបរិមាណតម្លៃវាស់វែង (F) ពេលដែលតម្លៃវាស់វែងចែកនឹងតម្លៃយោង ស្មើនឹងឫបស្វ័យគុណកន្ទះ ($F/Fo=10^{1/2}$) ដោយតម្លៃយោង (Fo) ជាបរិមាណយោងប្រភេទដូចគ្នា ។

$$1\text{B} = \ln(F/Fo)$$

Fo : តម្លៃយោង , F : តម្លៃវាស់វែង

អនុពហុគុណដេស៊ីបែល(Decibel) ដែលមាននិមិត្តសញ្ញា (dB) ត្រូវបាននិយមប្រើប្រាស់ជាទូទៅ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ១.៦. ខ្នាតនៃមាឌ ឬ ចំណុះ

### ១.៦.១. ឯកតា SI

| | | |
|---|---|---|
| ម៉ែត្រគូប ($m^3$) | = | ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១ |

### ១.៦.២. ឯកតាដែលប្រើអនុពហុគុណនៃម៉ែត្រ

| | | |
|---|---|---|
| ហិចតូលីត្រ (hℓ) | = | ១០០ លីត្រ |
| លីត្រ (ℓ) | = | ១/១.០០០ ម៉ែត្រគូប |
| សង់ទីម៉ែត្រគូប ($cm^3$) | = | ១/១.០០០.០០០ ម៉ែត្រគូប |
| ដេស៊ីលីត្រ (dℓ) | = | ១/១០ លីត្រ |
| សង់ទីលីត្រ (cℓ) | = | ១/១០០ លីត្រ |
| មីលីលីត្រ (mℓ) | = | ១/១.០០០ លីត្រ |

## ១.៧. ខ្នាតនៃទម្ងន់

### ១.៧.១. ឯកតា SI

| | | |
|---|---|---|
| គីឡូក្រាម (kg) | = | ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១ |
| ក្រាម (g) | = | ១/១.០០០ គីឡូក្រាម |
| មីលីក្រាម (mg) | = | ១/១.០០០.០០០ គីឡូក្រាម |
| មីក្រូក្រាម (μg) | = | ១/១.០០០.០០០.០០០ គីឡូក្រាម |

### ១.៧.២. ឯកតានៃទម្ងន់ផ្សេងៗទៀត

| | | |
|---|---|---|
| តោន (t) | = | ១.០០០ គីឡូក្រាម |
| ការ៉ាត់ | = | ១/៥ ក្រាម |

## ១.៨. ខ្នាតដង់ស៊ីតេ (ដង់ស៊ីតេទម្ងន់)

### ១.៨.១. ឯកតា SI

| | | |
|---|---|---|
| គីឡូក្រាមក្នុងមួយម៉ែត្រគូប ($kg/m^3$) | = | ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១ |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**១.៨.២.** ឯកតាទម្ងន់ផ្សេងៗទៀត

តោនក្នុងមួយម៉ែត្រគូប ($t/m^3$) = ១.០០០ គីឡូក្រាមក្នុងមួយម៉ែត្រគូប

## ១.៩. រង្វាស់នៃកម្លាំង

**១.៩.១.** ឯកតា SI

មេហ្គាញូតុន (MN) = ១.០០០.០០០ ញូតុន

គីឡូញូតុន (kN) = ១.០០០ ញូតុន

ញូតុន (N) = ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១

មីលីញូតុន (mN) = ១/១.០០០ ញូតុន

## ១.១០. រង្វាស់នៃសម្ពាធ

**១.១០.១.** ឯកតា SI

មេហ្គាប៉ាស្កាល់ (MPa) = ១.០០០.០០០ប៉ាស្កាល់

គីឡូប៉ាស្កាល់ (kPa) = ១.០០០ប៉ាស្កាល់

ប៉ាស្កាល់(Pa) = ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១

## ១.១១. រង្វាស់នៃដង់ស៊ីតេសរសៃវាយនភណ្ឌ

**១.១១.១.** ឯកតាដែលប្រើម៉ែត្រជាមូលដ្ឋានផ្សេងៗទៀត

តិច (tex) = ទម្ងន់ជាក្រាមនៃសរសៃអំបោះមួយគីឡូម៉ែត្រ

= ១g/1km=១០$^{-៦}$ kg/m

មីលីតិច (mtex) = ១/១.០០០ តិច

ដេស៊ីតិច (dtex) = ១/១០ តិច

គីឡូតិច (ktex) = ១.០០០ តិច

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ព្រះបរមរាជវាំង

## ១.១២. ខ្នាតនៃពេល និងប្រេកង់

### ១.១២.១. ពេល

| | | |
|---|---|---|
| នាទី (min) | = | ៦០ វិនាទី |
| ម៉ោង (h) | = | ៣.៦០០ វិនាទី |
| ថ្ងៃ (d) | = | ៨៦.៤០០ វិនាទី |
| សប្តាហ៍ | = | ៧ ថ្ងៃ |

### ១.១២.២. ប្រេកង់

| | | |
|---|---|---|
| គីហ្គាហឺត (GHz) | = | ១.០០០.០០០.០០០ ហឺត |
| មេហ្គាហឺត (MHz) | = | ១.០០០.០០០ ហឺត |
| គីឡូហឺត (kHz) | = | ១.០០០ ហឺត |
| ហឺត (Hz) | = | ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១ |

## ១.១៣. ខ្នាតនៃសីតុណ្ហភាព

### ១.១៣.១. ឯកតា SI

| | | |
|---|---|---|
| កែលវិន (Kelvin "K") | = | ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១ |

### ១.១៣.២. ឯកតាផ្សេងៗទៀត

| | | |
|---|---|---|
| ដឺក្រេសេ ($^0C$) | = | ១ កែលវិន |

មាត្រដ្ឋាននេះ ត្រូវបានបកស្រាយតាមសមីការដូចខាងក្រោម:

t = T - To ដោយ

t ជាសីតុណ្ហភាពគិតជា ដឺក្រេសេ

T ជាសីតុណ្ហភាពគិតជា កែលវិន

To = ២៧៣,១៥ កែលវិន

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ១.១៤. ខ្នាតនៃថាមពល និងកម្លាំង

### ១.១៤.១. ថាមពល កម្មន្ត និងបរិមាណនៃកម្តៅ

ស៊ូល ( Joule " J " ) = ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១

គីឡូស៊ូល ( Kilojoule " KJ ") = ១.០០០ ស៊ូល

មេហ្គាស៊ូល ( Megajoule " MK " )= ១.០០០.០០០ ស៊ូល

វ៉ាត់ម៉ោង (Wh) = ៣.៦០០០ ស៊ូល ($3,6\times10^3$)

គីឡូវ៉ាត់ម៉ោង ( kWh ) = ១.០០០ វ៉ាត់ម៉ោង

វ៉ុលអេលិចត្រុង ( ev ) = ថាមពលដែលទទួលបានដោយអេលិចត្រុង ឆ្លងកាត់តាមរយៈភាពខុសគ្នាដីខ្សាំង ១ វ៉ុល ក្នុងសុញ្ញាកាស ។

រាល់ពហុគុណនិងអនុពហុគុណទាំងឡាយ ដែលបានកំណត់ក្នុងចំណុចទី៣ នៃឧបសម្ព័ន្ធទី១ ។

### ១.១៤.២. កម្លាំង ថាមពល និងកម្តៅ

មីលីវ៉ាត់ ( mW ) = ១/១.០០០ វ៉ាត់

វ៉ាត់ ( W ) = ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១

គីឡូវ៉ាត់ ( kW ) = ១.០០០ វ៉ាត់

មេហ្គាវ៉ាត់ ( MW) = ១.០០០.០០០ វ៉ាត់

រាល់ពហុគុណនិងអនុពហុគុណទាំងឡាយដែលបានកំណត់ក្នុងចំណុចទី៣នៃឧបសម្ព័ន្ធ ទី១ ។

## ១.១៥. យថាប្រភេទថាមពល

### ១.១៥.១. ឯកតា SI

គីឡូស៊ូលក្នុងមួយគីឡូក្រាម (KJ/kg)= ១.០០០ ស៊ូល ក្នុងមួយគីឡូក្រាម

ស៊ូលក្នុងមួយគីឡូក្រាម ( J/kg ) = ១ ស៊ូល ក្នុងមួយគីឡូក្រាម

### ១.១៥.២. ឯកតាផ្សេងៗទៀត



ស៊ូលក្នុងមួយក្រាម (J/g ) = ១/១.០០០ ស៊ូល ក្នុងមួយគីឡូក្រាម

**១.១៦.១. ឯកតា SI**

អំពែ (A ) = ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១

មីលីអំពែ (mA ) = ១/១.០០០ អំពែ

មីក្រូអំពែ (μA ) = ១/១.០០០.០០០ អំពែ

## ១.១៧. កម្លាំងអគ្គិសនី

**១.១៧.១. ឯកតា SI**

គីឡូវ៉ុល (kV ) = ១.០០០ វ៉ុល

វ៉ុល (V ) = ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១

មីលីវ៉ុល (mV ) = ១/១.០០០ វ៉ុល

មីក្រូវ៉ុល (μV ) = ១ /១.០០០.០០០វ៉ុល

## ១.១៨. បរិមាណផ្ទុកអគ្គិសនី

**១.១៨.១. ឯកតា SI**

ហិនរី (Henry "H" ) = ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១

មីលីហិនរី (Milihenry "mH" ) = ១ /១.០០០ ហិនរី

មីក្រូហិនរី (Microhenry "μH" ) = ១ /១.០០០.០០០ ហិនរី

## ១.១៩. រេស៊ីស្តង់អគ្គិសនី

**១.១៩.១. ឯកតាSI**

មេហ្គាអូម (MΩ ) = ១.០០០.០០០ អូម

គីឡូអូម (kΩ ) = ១.០០០ អូម

អូម (Ω ) = ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

| | | |
|---|---|---|
| មីលីអូម (mΩ) | = | ១/១.០០០ អូម |
| មីក្រូអូម (μΩ) | = | ១/១.០០០.០០០ អូម |

**១.២០. បរិមាណអគ្គិសនី**

**១.២០.១. ឯកតាSI**

| | | |
|---|---|---|
| គូឡុម (Coulom "C") | = | ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១ |
| មីលីគូឡុម (Milicoulomb "mC") | = | ១ /១.០០០.០០០ គូឡុម |
| មីក្រូគូឡុម (Microcoulomb "μC") | = | ១ /១.០០០.០០០ គូឡុម |

**១.២០.២. ឯកតាផ្សេងទៀត**

| | | |
|---|---|---|
| អំពែម៉ោង (Ah) | = | ៣.៦០០ គូឡុម |

**១.២១. អាំងតង់ស៊ីតេពន្លឺ**

**១.២១.១. ឯកតាSI**

| | | |
|---|---|---|
| ខេនដេឡា (Candela "cd") | = | ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១ |

**១.២២. ពន្លឺ**

**១.២២.១. ឯកតាSI**

| | | |
|---|---|---|
| ឡុច (Lux "lx") | = | ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១ |

**១.២៣. ល្បឿននៃពន្លឺ**

**១.២៣.១. ឯកតាSI**

| | | |
|---|---|---|
| លូមិន (Lumen "lm") | = | ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១ |

**១.២៤. សកម្មភាព**

**១.២៤.១. ឯកតាSI**

| | | |
|---|---|---|
| Becquerel (Bq) | = | ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១ |

Milibecquerel (mBq) = ១ /១.០០០ becquerel

**១.២៥. កម្រិតស្រូប**

**១.២៥.១.** ឯកតា SI

ហ្គ្រេហ៍ (Gray " Gy " ) = ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១

មីលីហ្គ្រេយ៍ (Miligray " mGy ") = ១ /១.០០០ ហ្គ្រេយ៍

**១.២៦. ការបញ្ចេញ**

**១.២៦.១.** ឯកតា SI

គូឡុមក្នុងមួយគីឡូក្រាម (C/kg ) = ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១

## ឧបសម្ព័ន្ធទី ២

## ផ្នែកទី ២

## ការកំណត់ស្តង់ដារនៃប្រព័ន្ធឯកតាមាត្រាសាស្ត្រអន្តរជាតិ SI

### ១.១. រង្វាស់ប្រវែងដោយម៉ែត្រជាគោល

រង្វាស់ :

៥០០ ម៉ែត្រ
២០០ ម៉ែត្រ
១០០ ម៉ែត្រ
៥០ ម៉ែត្រ
២០ ម៉ែត្រ
១០ ម៉ែត្រ
៥ ម៉ែត្រ
២ ម៉ែត្រ
១ ម៉ែត្រ
១ សង់ទីម៉ែត្រ
១ មីលីម៉ែត្រ
១ មីក្រូម៉ែត្រ

### ១.២. រង្វាស់ការ៉េដោយការ៉េជាគោល

គឺជាការវាស់ ឬ គុណនឹងមួយឯកតាស្មើគ្នា ។

### ១.៣. រង្វាស់គូបដោយគូបជាគោល

គឺជាការវាស់ ឬ គុណនឹងមួយឯកតា និង ០១ ឯកតាទៀត ស្មើគ្នា ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

**១.៤. រង្វាស់ចំណុះដោយលីត្រជាគោល**

រង្វាស់:

| | |
|---|---|
| ១០ | លីត្រ |
| ៥ | លីត្រ |
| ២ | លីត្រ |
| ១ | លីត្រ |
| ៥០០ | មីលីលីត្រ |
| ២០០ | មីលីលីត្រ |
| ១០០ | មីលីលីត្រ |
| ៥០ | មីលីលីត្រ |
| ២០ | មីលីលីត្រ |
| ១០ | មីលីលីត្រ |
| ៥ | មីលីលីត្រ |
| ២ | មីលីលីត្រ |
| ១ | មីលីលីត្រ |

**១.៥. ទម្ងន់ដោយគីឡូក្រាមជាគោល**

**១.៥.១.** ទម្ងន់ :

| | |
|---|---|
| ៥០ | គីឡូក្រាម |
| ២០ | គីឡូក្រាម |
| ១០ | គីឡូក្រាម |
| ៥ | គីឡូក្រាម |
| ២ | គីឡូក្រាម |
| ១ | គីឡូក្រាម |



| | |
|---|---|
| ៥០០ ក្រាម | ៥០០ មីលីក្រាម |
| ២០០ ក្រាម | ២០០ មីលីក្រាម |
| ១០០ ក្រាម | ១០០ មីលីក្រាម |
| ៥០ ក្រាម | ៥០ មីលីក្រាម |
| ២០ ក្រាម | ២០ មីលីក្រាម |
| ១០ ក្រាម | ១០ មីលីក្រាម |
| ៥ ក្រាម | ៥ មីលីក្រាម |
| ២ ក្រាម | ២ មីលីក្រាម |
| ១ ក្រាម | ១ មីលីក្រាម |

**១.៥.២. ទម្ងន់ដោយការ៉ាត់ជាគោល៖**

៥០០ ការ៉ាត់

២០០ ការ៉ាត់

១០០ ការ៉ាត់

៥០ ការ៉ាត់

២០ ការ៉ាត់

១០ ការ៉ាត់

៥ ការ៉ាត់

២ ការ៉ាត់

១ ការ៉ាត់

០,៥ ការ៉ាត់

០,២៥ ការ៉ាត់

០,២ ការ៉ាត់

០,១ ការ៉ាត់

០,០៥ ការ៉ាត់

០,០២ ការ៉ាត់

០,០១ ការ៉ាត់

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

# ច្បាប់
# ស្តីពី
# វិសោធនកម្ម
# ច្បាប់ស្តីពី
# វិនិយោគ
# ២០០៣

# ព្រះរាជក្រម

នស/រកម/០៣០៣/០០៩ យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបាន អនុម័តកាលពីថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាល ទី ២ ហើយដែលព្រឹទ្ធសភាបានយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៣ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុង ដូចតទៅ :

**មាត្រាតែមួយ .-**

ត្រូវបានកែប្រែមាត្រា ១, មាត្រា ២, មាត្រា ៦, មាត្រា ៧, មាត្រា ៨, មាត្រា ១០, មាត្រា ១២, មាត្រា ១៤, មាត្រា ១៥, មាត្រា ១៦, មាត្រា ១៨, មាត្រា ២០, មាត្រា ២១, មាត្រា ២២, មាត្រា ២៣ ជំពូកទី ៩ មាត្រា ២៤ និងជំពូកទី ១០ មាត្រា ២៥ មាត្រា ២៦ និងមាត្រា ២៧ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដូចតទៅ :

**មាត្រា ១.-ថ្មី**

ច្បាប់នេះមានវិសាលភាពចំពោះរាល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងកំណត់នីតិវិធីនៃការបង្កើតគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលធ្វើឡើងដោយបុគ្គលណាមួយ ។

មានតែគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទេ ដែលមានសិទ្ធិទទួលបាននូវផលប្រយោជន៍ដែលស្ថិតក្នុងក្របខ័ណ្ឌនៃច្បាប់នេះ ។

**មាត្រា ២.-ថ្មី**

ក្នុងន័យនៃច្បាប់នេះ វាក្យសព្ទដូចខាងក្រោម :

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់** ហៅកាត់ គ.ល.គ មានន័យថា គម្រោងវិនិយោគដែលទទួលបានវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញ** មានន័យថា ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលផលិតផលរបស់គម្រោងត្រូវបាននាំចេញ ដែលនឹងកំណត់ដោយអនុក្រឹត្យ

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលជាប្រភេទឧស្សាហកម្មគាំទ្រ** មានន័យថា គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលផលិតផលរបស់ខ្លួន ១០០% (មួយរយភាគរយ) ត្រូវផ្គត់ផ្គង់ដល់ឧស្សាហកម្មនាំចេញជិនូសវត្ថុធាតុដើម ឬសម្ភារៈបន្ទាប់បន្សំដែលតែងតែនាំចូល

**ថ្ងៃធ្វើការ** មានន័យថា ថ្ងៃប្រតិទិនដែលជាថ្ងៃធ្វើការជាផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជា

**នីតិបុគ្គលសញ្ជាតិខ្មែរ** មានន័យថា ក្រុមហ៊ុនដែលមានទីកន្លែងធ្វើអាជីវកម្ម និងដែលបានធ្វើការចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជានិងភាគហ៊ុន ៥១% (ហាសិបមួយភាគរយ) ឬលើសក្នុងក្រុមហ៊ុន ត្រូវបានកាន់កាប់ដោយបុគ្គលមានសញ្ជាតិជាខ្មែរ

**បុគ្គល** មានន័យថា រូបវ័ន្តបុគ្គល ឬនីតិបុគ្គល

**វិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ** មានន័យថា ឯកសារដែលចេញដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដូចមានចែងក្នុងកថាខណ្ឌ ៣ មាត្រា ៧ ថ្មី នៃច្បាប់នេះ

**វិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ** មានន័យថា ឯកសារដែលចេញដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដូចមានចែងក្នុងកថាខណ្ឌ ៧ មាត្រា ៧ ថ្មី នៃច្បាប់នេះ

**សំណើវិនិយោគ** មានន័យថា សំណើដែលបានដាក់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដោយបុគ្គលណាមួយក្នុងគោលបំណងបង្កើតគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

**អ្នកដាក់ពាក្យស្នើ** មានន័យថា បុគ្គលឬក្រុមបុគ្គលដែលដាក់សំណើវិនិយោគទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**អ្នកវិនិយោគ** មានន័យថា បុគ្គលដែលអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

**មាត្រា ៦.-ថ្មី**

រាល់បុគ្គលដែលមានបំណងបង្កើតគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវដាក់សំណើវិនិយោគទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាតាមទម្រង់និងតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់នេះនិងអនុក្រឹត្យ ។

**មាត្រា ៧.-ថ្មី**

ក្នុងរយៈពេល ០៣(បី)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាទទួលបានសំណើវិនិយោគ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌឬលិខិតបដិសេធទៅឱ្យអ្នកស្នើសុំ ។

បសិនបើសំណើវិនិយោគផ្តល់ជូននូវពត៌មានទាំងអស់ដែលតម្រូវដោយអនុក្រឹត្យ និងប្រសិនបើសកម្មភាពដែលបានស្នើសុំពុំមានបញ្ជាក់នៅក្នុងបញ្ជីគម្រោងហាមឃាត់ដែលមានចែងនៅក្នុងអនុក្រឹត្យទេនោះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ។ ផ្ទុយទៅវិញ បើសំណើវិនិយោគនោះពុំឆ្លើយតបតាមលក្ខខណ្ឌខាងលើនោះទេ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវចេញលិខិតបដិសេធជូនទៅអ្នកស្នើសុំ ។

វិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ពីការយល់ព្រម ការអនុញ្ញាត ការជំរះបញ្ជី អាជ្ញាប័ណ្ណ លិខិតអនុញ្ញាតឬបញ្ញិកានានា ដែលត្រូវជាតម្រូវការសម្រាប់ដំណើរការគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់រួមទាំងបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលដែលទទួលបន្ទុកក្នុងការចេញលិខិតយល់ព្រមការជំរះបញ្ជី អាជ្ញាប័ណ្ណលិខិតអនុញ្ញាតឬបញ្ញិកាទាំងនោះផង ។ វិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌត្រូវបញ្ជាក់ផងដែរនូវការលើកទឹកចិត្តនានា ដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានសិទ្ធិទទួល ដូចមានចែងក្នុងមាត្រា ១៤ ថ្មី នៃច្បាប់នេះ និងការទទួលស្គាល់លើលក្ខន្តិកៈនៃនីតិបុគ្គលដែលជាអ្នកអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

ប្រសិនបើក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាខកខានពុំបានចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌឬលិខិតបដិសេធក្នុងរយៈពេល ៣ថ្ងៃ(បី) នៃថ្ងៃធ្វើការទេ វិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌត្រូវបានចាត់ទុកថា បានយល់ព្រមដោយស្វ័យប្រវត្តិ តាមទម្រង់ដូចមានកំណត់ដោយអនុក្រឹត្យ ។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវទទួលយកនូវអាជ្ញាប័ណ្ណទាំងអស់ពីក្រសួងស្ថាប័នពាក់ព័ន្ធ ដូចមានចែងក្នុងវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ជំនួសមុខឱ្យអ្នកស្នើសុំ ។

រាល់ស្ថាប័នមានសមត្ថកិច្ចរបស់រដ្ឋាភិបាលដែលទទួលបន្ទុកចេញលិខិតអនុញ្ញាតការជំរះបញ្ជី រាជ្ញាប័ណ្ណ លេខិតយល់ព្រមឬបញ្ញិកាដែលមានរាយបញ្ជាក់នៅក្នុងវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ត្រូវចេញឯកសារទាំងនេះ យ៉ាងយូរបំផុតអោយបានមុន ២៨ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទនៃវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ។

មន្ត្រីរាជការណាមួយដែលខកខានពុំបានឆ្លើយតបទៅនឹងពាក្យស្នើសុំដោយគ្មានមូលហេតុត្រឹមត្រូវតាមកាលកំណត់ ត្រូវផ្តន្ទាទោសតាមច្បាប់ ។

ក្នុងរយៈពេល ២៨ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ។ ការចេញវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ មិនមែនជាការលើកលែងឱ្យគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់រួចផុតពីការទទួលនូវលិខិតអនុញ្ញាតនានាដែលក្រសួងស្ថាប័នមានសមត្ថកិច្ចបានកំណត់ឡើយ ។ ទោះបីផុតរយៈពេល ២៨ថ្ងៃដូចមានចែងក្នុងកថាខណ្ឌ ៦ ខាងលើក៏ដោយ រាល់ស្ថាប័នមានសមត្ថកិច្ចត្រូវតែចេញលិខិតអនុញ្ញាតតាមការកំណត់ដោយច្បាប់និងបទប្បញ្ញត្តិនានា ។ កាលបរិច្ឆេទនៃការចេញជូននូវវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរគឺជាកាលបរិច្ឆេទនៃការចាប់ផ្តើមគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

រាល់លិខិតបដិសេធត្រូវមានបញ្ជាក់មូលហេតុច្បាស់លាស់ពីការមិនអាចទទួលសំណើវិនិយោគរួមទាំងព័ត៌មានបន្ថែម ដើម្បីផ្តល់លទ្ធភាពឱ្យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាអាចចេញវិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌបាន ។

**មាត្រា ៨.–ថ្មី**

អ្នកវិនិយោគបរទេសត្រូវបានទទួលស្គាល់និងមិនត្រូវជាកម្មវត្ថុនៃការរើសអើងដោយសារតែមូលហេតុសញ្ជាតិបរទេសទេ លើកលែងតែចំពោះដីធ្លី ដូចដែលមានចែងនៅក្នុងច្បាប់ភូមិបាល ។

**មាត្រា ១០.–ថ្មី**

រាជរដ្ឋាភិបាលមិនកំណត់ថ្លៃផលិតផលឬថ្លៃសេវានានានៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នោះឡើយ ។

**មាត្រា ១២.–ថ្មី**

រាជរដ្ឋាភិបាលផ្តល់ការលើកទឹកចិត្តដែលមានចែងក្នុងជំពូកនេះ ដល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

**មាត្រា ១៤..ថ្មី**

ការលើកទឹកចិត្តដែលមានចែងក្នុងមាត្រា ១៣ រួមមានដូចខាងក្រោម ៖

១-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានសិទ្ធិទទួលការលើកលែងពន្ធលើប្រាក់ចំណេញដែលមានកំណត់ក្នុងច្បាប់ស្ដីពីសារពើពន្ធ ដោយទទួលបាននូវរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ ។ រយៈពេលលើកលែងពន្ធរួមមាន ៖ រយៈពេលគន្លឹះបូករយៈពេល ៣(បី)ឆ្នាំបូករយៈពេលអាទិភាព ។ រយៈពេលអាទិភាពនឹងត្រូវកំណត់ក្នុងច្បាប់ស្ដីពីការគ្រប់គ្រងហិរញ្ញវត្ថុ ។ រយៈពេលគន្លឹះជាអតិបរមាគឺជាឆ្នាំទី ១ ដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបានប្រាក់ចំណេញ ឬរយៈពេល ៣(បី)ឆ្នាំ បន្ទាប់ពីគម្រោងវិនិយោគនោះបានទទួលប្រាក់ចំណូលដំបូងរបស់ខ្លួនដោយជ្រើសយកជម្រើសណាមួយដែលឆាប់ជាង ។

២-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានសិទ្ធិទទួលបាននូវការលើកទឹកចិត្តផ្អែកតាមកថាខណ្ឌ ១ ខាងលើ លុះត្រាតែគម្រោងនោះទទួលបានពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានូវវិញ្ញាបនប័ត្រប្រចាំឆ្នាំបញ្ជាក់ពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

៣-បន្ទាប់ពីផុតរយៈពេលលើកលែងពន្ធ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវជាប់ពន្ធលើប្រាក់ចំណេញ ។

៤-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលប្រើប្រាស់សិទ្ធិទទួលបាននូវការលើកទឹកចិត្តផ្អែកតាមកថាខណ្ឌ ១ ខាងលើ ពុំមានសិទ្ធិធ្វើការទាមទារការរំលោះពិសេសណាមួយឡើយ ។

៥-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលបម្រើទីផ្សារក្នុងស្រុក មានសិទ្ធិនាំចូលដោយរួចពន្ធគយនូវគ្រឿងសម្ភារៈបរិក្ខាផលិតកម្ម សម្ភារៈសាងសង់ បម្រើផលិតកម្ម ដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

៦-ក្រៅពីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញដែលជ្រើសរើសឬបានជ្រើសរើសយកយន្តការ ភណ្ឌាគារផលិតកម្មក្រោមការគ្រប់គ្រងរបស់គយ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញដទៃទៀត មានសិទ្ធិនាំចូលដោយរួចពន្ធគយនូវគ្រឿងសម្ភារៈបរិក្ខាផលិតកម្ម សម្ភារៈសាង

សង់ វត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេចនិងសម្ភារៈបន្ទាប់បន្សំបម្រើផលិតកម្ម ដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

៧-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលជាប្រភេទឧស្សាហកម្មគាំទ្រមានសិទ្ធិនាំចូល ដោយរួចពន្ធគយ នូវគ្រឿងសម្ភារៈបរិក្ខាផលិតកម្មសម្ភារៈសាងសង់ វត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេចនិងសម្ភារៈបន្ទាប់បន្សំបម្រើផលិតកម្មដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

៨-បុគ្គលណាដែលបានទិញឬវិនិយោគដែលបានរំលាយបញ្ចូលគ្នាជាមួយអ្នកវិនិយោគណាមួយ អាចទទួលស្នងពីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយធ្វើសំណើទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានូវរាល់ការធានា សិទ្ធិ បុព្វសិទ្ធិ និងកាតព្វកិច្ចទាំងអស់ ដោយយោងទៅតាមនីតិវិធីនៃការទិញឬការរំលាយបញ្ចូលគ្នាដែលត្រូវកំណត់ដោយអនុក្រឹត្យ ។

៩-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលមានទីតាំងនៅក្នុងតំបន់អភិវឌ្ឍន៍ពិសេសឬតំបន់ផលិតកែច្នៃនាំចេញដែលមានក្នុងបញ្ជីអាទិភាពសម្រាប់អភិវឌ្ឍន៍ ប្រកាសដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានសិទ្ធិទទួលបាននូវការលើកទឹកចិត្តនិងបុព្វសិទ្ធិដូចគ្នានឹងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ផ្សេងៗទៀតដូចមានចែងនៅក្នុងច្បាប់នេះ ។

១០-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានសិទ្ធិទទួលបាននូវការលើកលែងពន្ធនាំចេញ ១០០%(មួយរយភាគរយ) លើកលែងតែចំពោះសកម្មភាពទាំងឡាយ ដូចមានចែងនៅក្នុងច្បាប់ជាធរមាន ។

១១-គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានសិទ្ធិទទួលបាននូវទិដ្ឋាការនិងប័ណ្ណការងារ ដើម្បីធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ជនបរទេសដែលធ្វើជាអ្នកគ្រប់គ្រង អ្នកបច្ចេកទេសនិងកម្មករជំនាញ រួមទាំងទិដ្ឋាការស្នាក់នៅសម្រាប់សហព័ទ្ធនិងអ្នកនៅក្នុងបន្ទុករបស់ជនបរទេសទាំងនោះ ដែលអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្របតាមច្បាប់ស្តីពីអន្តោប្រវេសន៍និងច្បាប់ស្តីពីការងារ ។

**មាត្រា ១៥.‒ថ្មី**

សិទ្ធិ បុព្វសិទ្ធិនិងសិទ្ធិដទៃទៀតដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បានទទួល មិនអាចផ្ទេរឬប្រគល់ជូនទៅតតិយជនណាមួយឡើយ លើកលែងតែក្នុងករណីទិញ ឬរំលាយបញ្ចូលគ្នា ដូចមានចែងនៅក្នុងកថាខណ្ឌ ៨ នៃមាត្រា ១៤ ថ្មី ។

**មាត្រា ១៦.‒ថ្មី**

កម្មសិទ្ធិដីធ្លីរបស់អ្នកវិនិយោគសម្រាប់មជ្រើឱ្យ គោលដៅអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវបានអនុញ្ញាតចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរ ។

អ្នកវិនិយោគអាចប្រើប្រាស់ដីធ្លីតាមរយៈដីសម្បទានឬការជួលរយៈពេលមិនកំណត់ និងការជួលរយៈពេលមានកំណត់ដែលអាចបន្តជាថ្មីបាន ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងច្បាប់ភូមិបាល ។

អ្នកវិនិយោគមានសិទ្ធិកាន់កាប់និងដាក់បញ្ចាំសម្រាប់ធានានិងផ្ទេរនូវចលនទ្រព្យនិងអចលនទ្រព្យដែលស្ថិតនៅលើដីនិងដីដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ប្រើប្រាស់ តាមរយៈពេលមិនលើសពីរយៈពេលដែលមានកំណត់ក្នុងកិច្ចសន្យាសម្បទានដី ឬកិច្ចសន្យាជួល ដូចដែលបានអនុញ្ញាតដោយច្បាប់ ។

ចំពោះដីសម្បទានណាដែលពុំទាន់បានដំណើរការ អ្នកវិនិយោគមិនអាចផ្ទេរ ឬបញ្ចាំបន្តទៀតជាដាច់ខាត ។

**មាត្រា ១៨.‒ថ្មី**

អ្នកវិនិយោគត្រូវបានអនុញ្ញាតឱ្យជួលនិយោជិតបរទេសតាមលក្ខខណ្ឌដូចតទៅ :

- គុណភាព សមត្ថភាពនិងជំនាញមិនអាចរកបាននៅព្រះរាជាណាចក្រកម្ពុជាក្នុងចំណោមប្រជាពលរដ្ឋខ្មែរ ។ ក្នុងករណីមានការជួលនិយោជិតប្រភេទនេះ ត្រូវផ្ញើជូនមកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានូវឯកសាររួមមាន សេចក្តីចម្លងលិខិតឆ្លងដែន សញ្ញាប័ត្រនិងប្រវត្តិរូបសង្ខេបរបស់និយោជិតនោះ

- ត្រូវមានលិខិតអះអាងពីតម្រូវការជួលនិយោជិតបរទេស ។ អ្នកវិនិយោគត្រូវមានការយល់ព្រម និងលិខិតអនុញ្ញាតពីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា

- មុននឹងចូលបម្រើការងារឱ្យអ្នកវិនិយោគ និយោជិតបរទេសត្រូវមានលិខិតអនុញ្ញាតឱ្យធ្វើការនៅព្រះរាជាណាចក្រកម្ពុជាពីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា ។

អ្នកវិនិយោគមានកាតព្វកិច្ចដូចតទៅ :

- ធ្វើការបណ្តុះបណ្តាលសមស្របជូននិយោជិតខ្មែរជាប្រចាំ

- ជំរុញលើកកំពស់ដល់និយោជិតខ្មែរដើម្បីអាចក្លាយទៅជាអ្នកមានតួនាទីដែលមានកម្រិតខ្ពស់ ត្រូវធ្វើជាប្រចាំ ។

## មាត្រា ២០..ថ្មី

វិវាទដែលទាក់ទងទៅនឹងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ពាក់ព័ន្ធទៅនឹងសិទ្ធិនិងកាតព្វកិច្ចដែលមានចែងនៅក្នុងច្បាប់នេះ លើកលែងតែករណីទាក់ទងនឹងវិវាទដីធ្លី ត្រូវដោះស្រាយដោយសម្រុះសម្រួលតាមដែលអាចធ្វើទៅបាន តាមរយៈការពិគ្រោះគ្នារវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អ្នកវិនិយោគ និងភាគីណាមួយផ្សេងទៀតដែលពាក់ព័ន្ធក្នុងវិវាទ ។

ក្នុងរយៈពេលពីរខែ បន្ទាប់ពីកាលបរិច្ឆេទនៃសំណើជាលាយលក្ខណ៍អក្សរដំបូងដែលស្នើសុំធ្វើការពិគ្រោះគ្នានេះ ប្រសិនបើភាគីមានវិវាទពុំអាចដោះស្រាយតាមការសម្រុះសម្រួលគ្នាទេ ភាគីណាមួយអាចលើកយកវិវាទនោះទៅ :

- សុំការផ្សះផ្សាសម្រុះសម្រួលនៅចំពោះមុខក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬ

- សុំធ្វើមជ្ឈត្តវិនិច្ឆ័យពីក្នុង ឬក្រៅប្រទេសកម្ពុជាតាមការព្រមព្រៀងរបស់តួភាគី ឬ

- សុំការជំនុំជំរះពីសាលាជំរះក្តីនៃព្រះរាជាណាចក្រកម្ពុជា ។

## មាត្រា ២១.–ថ្មី

ក្នុងករណីអ្នកវិនិយោគមានបំណងចង់បញ្ឈប់សកម្មភាពរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា អ្នកវិនិយោគនោះត្រូវជូនពត៌មានទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាតាមរយៈលិខិតអនុសិដ្ឋឬលិខិតប្រគល់ផ្ទាល់ដៃ ដោយបញ្ជាក់អំពីមូលហេតុនៃការបញ្ឈប់សកម្មភាពនោះ និងចុះហត្ថលេខាដោយអ្នកវិនិយោគ ឬមេធាវីតំណាងផ្ទាល់របស់ខ្លួន ។

## មាត្រា ២២.–ថ្មី

ប្រសិនបើអ្នកវិនិយោគមានបំណងចង់បញ្ឈប់សកម្មភាពនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់របស់ខ្លួនក្រៅផ្លូវតុលាការ អ្នកវិនិយោគត្រូវផ្តល់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានូវភស្តុតាងបញ្ជាក់ថា គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បានដោះស្រាយជំរះបំណុលរបស់ខ្លួនយ៉ាងត្រឹមត្រូវ រួមមានអ្នកប្តឹងឬការទាមទារណាមួយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទើបអ្នកវិនិយោគនោះត្រូវបានអនុញ្ញាតឱ្យបញ្ឈប់សកម្មភាពនៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាផ្លូវការឬរំលាយដោយយោងទៅតាមច្បាប់ជាធរមានពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម ។

## មាត្រា ២៣.–ថ្មី

ក្នុងករណីដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវបានអនុញ្ញាតឱ្យបញ្ឈប់សកម្មភាពរបស់ខ្លួន ទោះតាមផ្លូវតុលាការក្តីឬក្រៅផ្លូវតុលាការក្តី អ្នកវិនិយោគអាចផ្ទេរនូវទ្រព្យសម្បត្តិដែលសេសសល់ទៅក្រៅប្រទេសឬមួយប្រើនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ប៉ុន្តែក្នុងករណីដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បានប្រើគ្រឿងម៉ាស៊ីននិងសម្ភារៈបរិក្ខាដែលបាននាំចូលដោយរួចពន្ធ ក្នុងអំឡុងពេលតិចជាង ៥(ប្រាំ)ឆ្នាំ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានកាតព្វកិច្ចបង់ពន្ធលើគ្រឿងម៉ាស៊ីននិងសម្ភារៈបរិក្ខាទាំងនោះ យោងតាមការកំណត់របស់អនុក្រឹត្យ ។

## ជំពូកទី ៩ ថ្មី
## អន្តរប្បញ្ញត្តិ

**មាត្រា ២៤.–ថ្មី**

ការវិនិយោគទាំងឡាយដែលបានទទួលការអនុញ្ញាតដោយច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ និងអនុក្រឹត្យនានា ត្រូវបានចាត់ទុកថាជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដូចមានចែងក្នុងច្បាប់នេះនិងអនុក្រឹត្យពាក់ព័ន្ធ ។

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលមានសិទ្ធិទទួលបាននូវអត្រាពន្ធលើប្រាក់ចំណេញ ៩% (ប្រាំបួនភាគរយ) មុនពេលប្រកាសឱ្យប្រើនូវច្បាប់នេះ និងដែលបានចាប់ផ្តើមសកម្មភាពវិនិយោគដោយទទួលបានការយល់ព្រមអនុម័ត មានសិទ្ធិទទួលបានអត្រាពន្ធ ៩% (ប្រាំបួនភាគរយ)នេះ សម្រាប់រយៈពេល ៥(ប្រាំ)ឆ្នាំ ដោយចាប់ផ្តើមពីឆ្នាំសារពើពន្ធ បន្ទាប់ពីការប្រកាសឱ្យប្រើនូវច្បាប់នេះ លុះត្រាតែអ្នកវិនិយោគនោះបានដាក់ជាទៀងរាល់ឆ្នាំសារពើពន្ធនូវវិញ្ញាបនប័ត្រប្រចាំឆ្នាំ បញ្ជាក់ពីការបំពេញកាតព្វកិច្ចចំពោះរដ្ឋដែលត្រូវកំណត់ដោយអនុក្រឹត្យ ដូចមានចែងក្នុងកថាខណ្ឌ ២ មាត្រា ១៤ ថ្មីបន្ទាប់ពីការប្រកាសឱ្យប្រើច្បាប់នេះ ។

គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលមានសិទ្ធិត្រូវបានការលើកលែងពន្ធលើប្រាក់ចំណេញ តាមការយល់ព្រមជាលាយលក្ខណ៍អក្សររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មុនពេលប្រកាសឱ្យប្រើច្បាប់នេះ មានសិទ្ធិទទួលបន្តការលើកលែងពន្ធលើប្រាក់ចំណេញ លុះត្រាតែអ្នកវិនិយោគនោះ បានដាក់ជាទៀងរាល់ឆ្នាំសារពើពន្ធនូវវិញ្ញាបនប័ត្រប្រចាំឆ្នាំ បញ្ជាក់ពីការបំពេញកាតព្វកិច្ចចំពោះរដ្ឋដែលត្រូវកំណត់ដោយអនុក្រឹត្យ ដូចមានចែងក្នុងកថាខណ្ឌ ២ មាត្រា ១៤ ថ្មី បន្ទាប់ពីការប្រកាសឱ្យប្រើច្បាប់នេះ ។

## ជំពូកទី ១០ថ្មី

## អវសានប្បញ្ញត្តិ

**មាត្រា ២៥.-ថ្មី**

ក្នុងករណីដែលគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់រំលោភឬមិនអនុវត្តតាមលក្ខខណ្ឌទាំងឡាយដែលបានកំណត់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នោះក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានសិទ្ធិអំណាចដកហូតសិទ្ធិផ្សេងៗនិងផលប្រយោជន៍ទាំងអស់ឬមួយផ្នែកដែលបានផ្តល់ជូនអ្នកវិនិយោគកន្លងមក ។

**មាត្រា ២៦.-ថ្មី**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៧.-ថ្មី**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣

ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ពាល.០៣០៣.១៣៤

ហត្ថលេខា និង ត្រា

ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

លេខ: ១០៧ ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ខែមីនា ឆ្នាំ

# ច្បាប់

# ស្តីពី

# វិនិយោគ

# ១៩៩៤

Khmer Law's Association

# ច្បាប់

# ស្តីពី

# វិនិយោគ

# នៃព្រះរាជាណាចក្រកម្ពុជា

# ព្រះរាជក្រម

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

យោងតាមមាត្រាទី ១១ ជំពូកទី ២ ស្តីអំពី ព្រះមហាក្សត្រ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រ កម្ពុជា ដែលត្រូវបានសភាធម្មនុញ្ញអនុម័ត នៅថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ១៩៩៣

## បង្គាប់

មាត្រា ១. ប្រកាសអោយប្រើជាផ្លូវការ នូវច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភា បានអនុម័តនៅថ្ងៃទី ០៤ ខែសីហា ឆ្នាំ១៩៩៤ ។

មាត្រា ២. ព្រះរាជក្រមនេះចូលជាធរមានច្បាប់ ចាប់ពីពេលចុះហត្ថលេខានេះតទៅ ។

ធ្វើនៅព្រះរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែសីហា ឆ្នាំ១៩៩៤

ក្នុងព្រះបរមនាម និង ដោយព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

# ច្បាប់

## ស្តីពី

## វិនិយោគ

## នៃព្រះរាជាណាចក្រកម្ពុជា

### ជំពូកទី ១

### បទបញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះមានវិសាលភាពគ្របដណ្តប់លើការវិនិយោគនានា ដែលអនុវត្តនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដោយអ្នកវិនិយោគជាជនជាតិខ្មែរនិង / ឬ ជនបរទេស ។

មាត្រា ២.-

អ្នកវិនិយោគទាំងអស់ត្រូវស្ថិតនៅក្រោមច្បាប់នេះ ហើយអាចជារូបវន្តបុគ្គលឬជានីតិបុគ្គល ។

:

### ជំពូកទី ២

### ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

មាត្រា ៣.-

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាអង្គការមានសមត្ថកិច្ច និងជាច្រកចេញចូលតែមួយគត់ក្នុងការទទួលបន្ទុកការងារនីតិសម្បទា អភិវឌ្ឍន៍និងការវិនិយោគ ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការពិនិត្យនិងសំរេចការងារនីតិសម្បទានិងអភិវឌ្ឍន៍ និងការវិនិយោគនានា ។

មាត្រា ៤.-

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានគណៈកម្មាធិការពីរសំរាប់ជំនួយការគឺ ៖

១- គណៈកម្មាធិការនីតិសម្បទា និង អភិវឌ្ឍន៍

២- គណៈកម្មាធិការវិនិយោគកម្ពុជា ។

មាត្រា ៥.-

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៣
## នីតិវិធីនៃការវិនិយោគ

មាត្រា ៦.-

អ្នកវិនិយោគត្រូវដាក់ពាក្យសុំទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដើម្បីពិនិត្យ និងសំរេច ។

មាត្រា ៧.-

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវឆ្លើយតបអំពីការសំរេចរបស់ខ្លួនទៅអ្នកវិនិយោគ ក្នុងរយៈពេល ៤៥ ថ្ងៃយ៉ាងយូរ គិតពីថ្ងៃទទួលពាក្យសុំដែលបានបំពេញបែបបទត្រឹមត្រូវនិងគ្រប់គ្រាន់ ។ បើគ្មានមូលហេតុត្រឹមត្រូវ មន្ត្រីរាជការណាដែលប្រកែកមិនព្រមទទួលពិនិត្យនិងឆ្លើយតបអំពីការសំរេចរបស់ខ្លួនទៅអ្នកវិនិយោគវិញ ហួសកាលកំណត់ខាងលើ ត្រូវផ្តន្ទាទោសតាមបញ្ញត្តិច្បាប់ ។

## ជំពូកទី ៤
## ការធានាលើការវិនិយោគ

មាត្រា ៨.-

អ្នកវិនិយោគត្រូវបានទទួលស្គាល់និងចាត់ទុកដោយស្មើភាពគ្នាចំពោះមុខច្បាប់ គ្មានការរើសអើងអំពីសញ្ជាតិឬពូជសាសន៍ទេ លើកលែងតែចំពោះកម្មសិទ្ធិលើដីធ្លី ដូចដែលមានចែងក្នុងបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៩._

រាជរដ្ឋាភិបាលនឹងមិនធ្វើជាតូបនីយកម្ម ដែលនាំឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់អ្នកវិនិយោគក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ ។

មាត្រា ១០._

រាជរដ្ឋាភិបាលមិនត្រួតពិនិត្យលើថ្លៃផលិតផលឬថ្លៃសេវានានារបស់អ្នកវិនិយោគ ដែលបានទទួលការអនុញ្ញាតរួចហើយនោះឡើយ ។

មាត្រា ១១._

ដោយអនុលោមទៅតាមច្បាប់ទាំងឡាយដែលពាក់ព័ន្ធ ព្រមទាំងបទបញ្ញត្តិទាំងឡាយដែលបានកំណត់និងប្រកាសផ្សាយដោយធនាគារជាតិកម្ពុជា រាជរដ្ឋាភិបាលអនុញ្ញាតដល់អ្នកវិនិយោគ មានសិទ្ធិទិញរូបិយប័ណ្ណបរទេសតាមរយៈប្រព័ន្ធធនាគារ សំរាប់បង្វិលទៅបរទេសវិញ ដើម្បីទូទាត់កាតព្វកិច្ចខាងហិរញ្ញវត្ថុដែលពាក់ព័ន្ធនឹងការវិនិយោគរបស់ខ្លួន ។

ការទូទាត់ខាងលើនេះរួមមាន ៖

១_ ការទូទាត់លើការនាំចូល និងការបង្វិលទៅក្រៅប្រទេសទាំងដើមទាំងការនូវប្រាក់ចងការ ។

២_ ការទូទាត់ចំណាយសួយសារ និង ថ្លៃសេវាគ្រប់គ្រង ។

៣_ ការផ្ទេរប្រាក់ចំណេញ ។

៤_ ការបង្វិលដើមទុនវិនិយោគទៅក្រៅប្រទេសវិញ ដូចមានចែងក្នុងជំពូកទី ៨ ។

## ជំពូកទី ៥
## ការលើកទឹកចិត្តវិនិយោគ

មាត្រា ១២._

រាជរដ្ឋាភិបាលលើកទឹកចិត្ត ដើម្បីជំរុញការវិនិយោគលើវិស័យសំខាន់ៗដូចតទៅ ៖

១_ ឧស្សាហកម្មនាំមុខ ឬ ឧស្សាហកម្មដែលមានបច្ចេកវិទ្យាខ្ពស់

២_ ការបង្កើតការងារ

៣_ ការបង្កើនការនាំចេញ

៤_ ឧស្សាហកម្មទេសចរណ៍

៥_ ការផលិតទំនិញកសិ_ឧស្សាហកម្ម និង ឧស្សាហកម្មកែច្នៃ

៦_ ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ការផលិតថាមពល

៧_ អភិវឌ្ឍន៍ខេត្ត និងជនបទ

៨_ ការការពារបរិស្ថាន

៩_ ការវិនិយោគក្នុងតំបន់អភិវឌ្ឍន៍ពិសេស ដែលនឹងត្រូវបង្កើតឡើងដោយច្បាប់ ។

មាត្រា ១៣._

ការលើកទឹកចិត្តមាន ការលើកលែងទាំងស្រុង ឬមួយផ្នែកនៃពន្ធគយនិងពន្ធអាករ ។

មាត្រា ១៤._

ការលើកទឹកចិត្តទាំងឡាយ រួមមានដូចខាងក្រោមនេះ ៖

១_ អត្រាពន្ធលើប្រាក់ចំណេញសុទ្ធ ៩% លើកលែងតែអត្រាពន្ធផ្សេងៗលើការរុករក និង អាជីវកម្មធនធានធម្មជាតិ ព្រៃឈើ ប្រេងកាត រ៉ែ មាស ត្បូងថ្មមានតម្លៃ ។ល។ ដែលត្រូវចែងក្នុងច្បាប់ដោយឡែក ។

២_ ពន្ធលើប្រាក់ចំណេញអាចលើកលែងបានរហូតដល់រយៈពេល ៨ ឆ្នាំ គឺអាស្រ័យលើលក្ខណៈសម្បត្តិរបស់ការវិនិយោគនីមួយៗនិងអាទិភាព ដែលរាជរដ្ឋាភិបាលនឹងកំណត់ដោយអនុក្រឹត្យ ។ ការលើកលែងពន្ធលើប្រាក់ចំណេញនឹងត្រូវអនុវត្តចាប់ពីឆ្នាំដែលបានទទួលប្រាក់ចំណេញលើកទីមួយ ។ ការខាតបង់រយៈពេល ៥ ឆ្នាំបន្តបន្ទាប់ ត្រូវបានអនុញ្ញាតឱ្យយកមកទូទាត់និងប្រាក់ចំណេញ ។ ក្នុងករណីយកប្រាក់ចំណេញមកធ្វើវិនិយោគបន្ត ប្រាក់ចំណេញត្រូវបានអនុញ្ញាតឱ្យរួចពន្ធទាំងស្រុង ។

៣_ មិនយកអាករលើការបែងចែកប្រាក់ចំណេញនៃការវិនិយោគ ទោះជាប្រាក់ទាំងនោះត្រូវផ្ទេរទៅបរទេសក្តី ឬបែងចែកក្នុងប្រទេសក្តី ។

៤_ ការលើកលែងពន្ធគយ និងពន្ធអាករ ១០០% ក្នុងការនាំចូលសម្ភារៈសំណង់ មធ្យោបាយផលិតកម្ម គ្រឿងសម្ភារៈបរិក្ខារ ទំនិញពាក់កណ្តាលសំរេច វត្ថុធាតុដើម និងគ្រឿងបន្លាស់សំរាប់ប្រើប្រាស់ ត្រូវមានលក្ខខ័ណ្ឌណាមួយដូចតទៅ ៖

ក_ ការវិនិយោគដែលមានទិសដៅសំរាប់បំរើឱ្យការនាំចេញ ក្នុងកំរិតអប្បបរមា ៨០% នៃផលិតផលសរុប ។

ខ_ មានទីតាំងនៅក្នុងតំបន់អភិវឌ្ឍន៍ពិសេស ដែលមានក្នុងបញ្ជីអាទិភាពសំរាប់អភិវឌ្ឍន៍ប្រកាសដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

គ_ ឧស្សាហកម្មទេសចរណ៍

ឃ_ ឧស្សាហកម្មប្រើប្រាស់កម្លាំងពលកម្មច្រើន ឧស្សាហកម្មកែច្នៃ កសិ_ឧស្សាហកម្ម ។

ង_ ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងការផលិតថាមពល ។

ការលើកលែងពន្ធគយ និងពន្ធអាករ ១០០% ខាងលើនេះ ត្រូវអនុវត្តជាបន្ត រហូតស្របតាមរយៈពេលដែលកំណត់ក្នុងកិច្ចសន្យា ឬ សៀវភៅបន្ទុក សំរាប់ការវិនិ_យោគដែលផលិតទំនិញនាំចេញក្នុងកំរិតអប្បបរមា ៨០% នៃផលិតកម្មសរុប ដូចមានចែងក្នុងចំណុច ( ៤ )ក ខាងលើ និងសំរាប់ការវិនិយោគដែលមានទីតាំងក្នុងតំបន់អភិវឌ្ឍន៍ពិសេស ដូចមានចែងក្នុងចំណុច ( ៤ )ខ ។

ក្រៅពីប្រភេទការវិនិយោគដែលមានចែងក្នុងចំណុច( ៤ )ក និងចំណុច ( ៤ )ខ ខាងលើនេះ ការលើកលែងពន្ធគយ និង ពន្ធអាករ ១០០% ត្រូវបានអនុញ្ញាតឱ្យសំរាប់តែក្នុងរយៈពេលនៃការរៀបចំកសាងសហគ្រាស រោងចក្រ អាគារនិងការចាប់ដំណើរការអាជីវកម្ម ផលិតកម្មនៅឆ្នាំដំបូងប៉ុណ្ណោះ ។

៥_ ការលើកលែងពន្ធគយ ១០០% ក្នុងការនាំចេញផលិតផលទៅក្រៅប្រទេស ។

៦_ ការអនុញ្ញាតឱ្យយកចូលមកក្នុងព្រះរាជាណាចក្រកម្ពុជានូវជនបរទេសណាដែលជា ៖

- បុគ្គលិក និង អ្នកជំនាញការខាងគ្រប់គ្រង
- បុគ្គលិកបច្ចេកទេស
- កម្មករជំនាញ
- សហព័ទ្ធនិងអ្នកក្នុងបន្ទុករបស់ខ្លួន ដែលអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ហើយស្របទៅតាមច្បាប់អន្តោប្រវេសន៍និងច្បាប់ការងារ ។

មាត្រា ១៥._

ការអនុញ្ញាតនិងការលើកទឹកចិត្តដែលបានផ្តល់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមិនអាចផ្ទេរ ឬ លក់បានឡើយ ។

## ជំពូកទី ៦

## កម្មសិទ្ធិ និង ការប្រើប្រាស់ដីធ្លី

មាត្រា ១៦._

អនុលោមតាមរដ្ឋធម្មនុញ្ញ ច្បាប់និងបទបញ្ញត្តិទាំងឡាយ ដែលពាក់ព័ន្ធទៅនឹងកម្មសិទ្ធិ និងការប្រើប្រាស់ដីធ្លី ៖

១- កម្មសិទ្ធិលើដីសំរាប់បំរើឱ្យគោលដៅនៃសកម្មភាពវិនិយោគ ត្រូវបានប្រគល់ជូនចំពោះអ្នកវិនិយោគដែលជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរ ។ នីតិបុគ្គលមានសញ្ជាតិជាខ្មែរ គឺជានីតិបុគ្គលដែលភាគហ៊ុនចាប់តាំងពី ៥១% ឡើងទៅនៃដើមទុនសរុបជាកម្មសិទ្ធិនៃរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរ ។

២- អ្នកវិនិយោគអាចប្រើប្រាស់ដីធ្លីតាមរយៈការជួលសំរាប់រយៈពេលវែងរហូតដល់ ៧០ ឆ្នាំ ហើយអាចស្នើសុំជួលបន្ត ។ ការប្រើប្រាស់ដីធ្លីនេះ រាប់បញ្ចូលទាំងសិទ្ធិនៃកម្មសិទ្ធិទាំងឡាយនៅលើផ្ទៃដីនោះ ត្រូវអនុវត្តស្របតាមច្បាប់ ។

## ជំពូកទី ៧
## ការប្រើប្រាស់កំលាំងពលកម្ម

**មាត្រា ១៧.-**

អ្នកវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិធ្វើការជ្រើសរើស និងជួលនិយោជិតខ្មែរ និង បរទេសបានដោយសេរី ផ្អែកលើមូលដ្ឋាននៃច្បាប់ការងារ និង ច្បាប់អន្តោប្រវេសន៍ ។

**មាត្រា ១៨.-**

អ្នកវិនិយោគត្រូវបានអនុញ្ញាតឱ្យជួលនិយោជិតបរទេស ដូចមានចែងក្នុងមាត្រា១៤ (៦) ក្នុងលក្ខខ័ណ្ឌដូចតទៅ ៖

១- គុណភាព សមត្ថភាព និងជំនាញមិនអាចរកបាននៅព្រះរាជាណាចក្រកម្ពុជាក្នុងចំណោមប្រជាពលរដ្ឋខ្មែរ ។ បើមានការជួលនិយោជិតប្រភេទនេះ ត្រូវភ្ជាប់មកជាមួយនូវសេចក្តីចម្លងលិខិតឆ្លងដែន សញ្ញាប័ត្រ និងប្រវត្តិរូបសង្ខេបរបស់និយោជិតនោះ ។

២- អ្នកវិនិយោគមានកាតព្វកិច្ចធ្វើការបណ្តុះបណ្តាលជាប្រចាំ និងសមស្របជូននិយោជិតខ្មែរ ។

៣- ការដំឡើងលើកកំពស់ដល់និយោជិតខ្មែរ ដើម្បីអាចក្លាយទៅជាអ្នកមានឋានៈខ្ពស់ត្រូវធ្វើជាប្រចាំ ។

**មាត្រា ១៩.-**

និយោជិតបរទេស ត្រូវបានអនុញ្ញាតអោយផ្ទេរទៅក្រៅប្រទេសនូវប្រាក់បៀវត្ស ដែលទទួលបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈប្រព័ន្ធធនាគារ ក្រោយពីបានបង់ពន្ធរួចហើយ ។

## ជំពូកទី ៨
## វិវាទ និង ការរំលាយ

មាត្រា ២០.-

វិវាទដែលទាក់ទងទៅនឹងកិច្ចការវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់អ្នកវិនិ-យោគ ដែលពាក់ព័ន្ធទៅនឹងសិទ្ធិ និងភារកិច្ចដែលមានចែងក្នុងច្បាប់នេះអាច ៖

១- ដោះស្រាយដោយសម្រុះសម្រួលតាមរយៈការពិគ្រោះគ្នារវាងភាគីជំលោះទាំងសងខាង ។

២- ក្នុងអំឡុងពេលពីរខែ បើវិវាទមិនបានដោះស្រាយតាមការសម្រុះសម្រួលគ្នាទេ វិវាទនេះអាច :

- លើកយកមកដាក់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាផ្តល់យោបល់
- ដោះស្រាយតាមផ្លូវតុលាការនៃព្រះរាជាណាចក្រកម្ពុជា
- ឬដោះស្រាយតាមនីតិវិធីអន្តរជាតិណាមួយ តាមការព្រមព្រៀងនៃភាគី ។

មាត្រា ២១.-

ក្នុងករណីអ្នកវិនិយោគមានបំណងចង់បញ្ឈប់សកម្មភាពរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា អ្នកវិនិយោគនោះ ត្រូវជូនពត៌មានទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាតាមរយៈលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃ ដោយមានបញ្ជាក់ថាបានទទួលត្រឹមត្រូវ ។ លិខិតខាងលើនេះ ត្រូវចុះហត្ថលេខាដោយអ្នកវិនិយោគឬអ្នកតំណាងពេញសិទ្ធិរបស់ក្រុមហ៊ុនហើយត្រូវបញ្ជាក់អំពីមូលហេតុនៃការបញ្ឈប់សកម្មភាពនោះផង ។

មាត្រា ២២.-

ក្នុងករណីដែលមានការសុំរំលាយក្រៅផ្លូវតុលាការ អ្នកវិនិយោគត្រូវផ្តល់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នូវលិខិតបញ្ជាក់ពីម្ចាស់បំណុល ពីអ្នកប្តឹងរបស់ខ្លួន និងពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ថាបញ្ហាទាំងឡាយត្រូវបានដោះស្រាយចប់ជាស្ថាពរហើយ ទើបអ្នកវិនិយោគនោះអាចត្រូវបានអនុញ្ញាតអោយរំលាយក្រុមហ៊ុន ឬ សហគ្រាសរបស់ខ្លួនជាផ្លូវការបាន តាមបែបបទនៃច្បាប់ពាណិជ្ជកម្ម ។

មាត្រា ២៣.-

ក្នុងករណីដែលអ្នកវិនិយោគត្រូវបានអនុញ្ញាតអោយរំលាយក្រុមហ៊ុន ឬសហគ្រាសរបស់ខ្លួនជាផ្លូវការ ទោះតាមផ្លូវតុលាការក្តី ឬក្រៅផ្លូវតុលាការក្តី អ្នកវិនិយោគអាចផ្ទេរនូវទ្រព្យសម្បត្តិដែលសេសសល់ទៅក្រៅប្រទេស ឬមួយប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ចំពោះគ្រឿងម៉ាស៊ីន និង

សម្ភារៈបរិក្ខារដែលបានការអនុញ្ញាតអោយនាំចូលដោយរួចពន្ធហើយបានប្រើប្រាស់ក្នុងអំឡុងពេលតិចជាងប្រាំឆ្នាំ ( ៥ឆ្នាំ)អ្នកវិនិយោគត្រូវបង់ពន្ធតាមច្បាប់ជាធរមាន ។

## ជំពូកទី ៩
## អវសានបញ្ញត្តិ

**មាត្រា ២៤._**

ការវិនិយោគទាំងឡាយ ដែលបានទទួលការអនុញ្ញាត ក្រោមច្បាប់ស្តីពីការវិនិយោគនៅរដ្ឋកម្ពុជា និងអនុក្រឹត្យស្តីពីការវិនិយោគរបស់បរទេសនៅរដ្ឋកម្ពុជា ត្រូវបានទទួលផលប្រយោជន៍ និងកាតព្វកិច្ចដូចមានចែងក្នុងច្បាប់នេះដែរ ប៉ុន្តែច្បាប់នេះពុំមានអានុភាពប្រតិសកម្មទេ ។

**មាត្រា ២៥._**

ក្នុងករណីដែលអ្នកវិនិយោគរំលោភ ឬមិនអនុវត្តតាមលក្ខខ័ណ្ឌទាំងឡាយដែលបានកំណត់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានសិទ្ធិអំណាចដកហូតសិទ្ធិផ្សេងៗនិងផលប្រយោជន៍ទាំងអស់ ឬមួយផ្នែកដែលបានផ្តល់ជូនអ្នកវិនិយោគកន្លងមក ។

**មាត្រា ២៦._**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩៤
នាសម័យប្រជុំវិសាមញ្ញនីតិកាលទី ១
ភ្នំពេញ.ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩៤
**ប្រធានរដ្ឋសភាស្តីទី**

លយ ស៊ីមឈាង

# ច្បាប់ ស្តីពី ស្តង់ដារ នៅកម្ពុជា ២០០៧

# ព្រះរាជក្រម

នស/រកម/០៦០៧/០១៣

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ស្តង់ដារកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៣ នីតិកាលទី២ រួចហើយ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# ស្តង់ដារកម្ពុជា

ROYAUME DU CAMBODGE * LE MINISTERE DU PALAIS ROYAL *

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានវិសាលភាពលើរាល់សកម្មភាព ដែលទាក់ទងនឹងស្តង់ដារូបនីយកម្ម ការធានាគុណភាពនិងសកម្មភាពពាក់ព័ន្ធទាំងឡាយ ដែលមានក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ច្បាប់នេះមានគោលបំណង :

ក-ធ្វើឱ្យកាន់តែប្រសើរឡើងនូវគុណភាពផលិតផល សេវាកម្ម និងការគ្រប់គ្រង ។

ខ-បង្កើនប្រសិទ្ធភាពផលិតកម្មឱ្យកាន់តែប្រសើរឡើង និងងាយស្រួល ។

គ-ធានាឱ្យការធ្វើពាណិជ្ជកម្ម មានលក្ខណៈត្រឹមត្រូវ និងងាយស្រួល ។

ឃ-បង្កឱ្យការប្រើប្រាស់ផលិតផលមានលក្ខណៈងាយស្រួល ។

ង-បង្កើនការការពារអ្នកប្រើប្រាស់ និងលើកកម្ពស់សុខុមាលភាពសាធារណៈ ។

**មាត្រា ៣.-**

លើកលែងតែមានសេចក្តីចែងផ្សេងពីនេះ បណ្តាពាក្យដែលប្រើប្រាស់ក្នុងច្បាប់នេះ មានអត្ថន័យនិងការបកស្រាយដូចខាងក្រោម :

- **អង្គភាពវាយតម្លៃទទួលស្គាល់** សំដៅដល់អង្គភាពដែលអនុវត្តនិងគ្រប់គ្រងប្រព័ន្ធវាយតម្លៃទទួលស្គាល់ និងផ្តល់នូវវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ។

- **ការវាយតម្លៃទទួលស្គាល់** សំដៅដល់នីតិវិធីមួយដែលប្រតិបត្តិដោយអង្គភាពមានសមត្ថកិច្ច ដើម្បីផ្តល់ការទទួលស្គាល់ជាផ្លូវការថា អង្គភាពមួយ ឬបុគ្គលណាមួយមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តតាមភារកិច្ចកំណត់ ។

- **ស្តង់ដារ** មានន័យថា ជាឯកសារដែលត្រូវបានបង្កើតឡើងដោយការព្រមព្រៀងគ្នា និងបានអនុម័តដោយស្ថាប័នមានសមត្ថកិច្ច ដែលមានលក្ខណៈជាក្បួន ជាគោល-ការណ៍ណែនាំ ឬ ជាចរិតលក្ខណៈសម្រាប់សកម្មភាព ឬ លទ្ធផល ដើម្បីទុកសម្រាប់ប្រើប្រាស់ជាទូទៅនិងជាបន្តបន្ទាប់ សំដៅធានាសម្រេចឱ្យបានដល់ចំណុចប្រសើរបំផុតនៃបរិបទមួយ ។

- **ស្តង់ដារូបនីយកម្ម** មានន័យថា ជាសកម្មភាពនៃការបង្កើតនូវបញ្ញត្តិទាំងឡាយ ដែលទាក់ទិនដល់បញ្ហាជាក់ស្តែង ឬ បញ្ហាសំខាន់ៗ ដើម្បីទុកសម្រាប់ការប្រើប្រាស់ជារួម និងប្រើប្រាស់តទៅ សំដៅធានាឱ្យ បានដល់ចំណុចប្រសើរបំផុតនៃបរិបទមួយ ។ សកម្មភាពខាងលើនេះមានជាអាទិ៍ ដំណើរការនៃការបង្កើត ការចេញ និងការអនុវត្តស្តង់ដារ ។

- **ស្តង់ដារកម្ពុជា** សំដៅដល់ ស្តង់ដារដែលអនុម័តដោយក្រុមប្រឹក្សាស្តង់ដារជាតិ និងប្រកាសឱ្យប្រើដោយរដ្ឋមន្ត្រី ។

- **ស្តង់ដារបង្ខំ** សំដៅដល់ស្តង់ដារដែលត្រូវអនុវត្តតាមជាដាច់ខាត ។

- **សញ្ញាស្តង់ដារ** សំដៅដល់សញ្ញាបញ្ជាក់ផលិតផល ឬ សញ្ញាបញ្ជាក់ប្រព័ន្ធ ។

- **សញ្ញាបញ្ជាក់ផលិតផល** សំដៅដល់សញ្ញាដែលបញ្ជាក់ពីភាពអនុលោមនៃផលិតផលមួយ តាមការតម្រូវនៃស្តង់ដារផលិតផលមួយ មានសញ្ញាបញ្ជាក់គុណភាព សុវត្ថិភាព ចុះបញ្ជីផលិតផល ។ល។

- **សញ្ញាបញ្ជាក់ប្រព័ន្ធ** សំដៅដល់សញ្ញាដែលបញ្ជាក់ពីភាពអនុលោមនៃប្រព័ន្ធមួយទៅតាមការតម្រូវនៃស្តង់ដារជាតិ ឬ ស្តង់ដារអន្តរជាតិមួយដែលបានទទួលស្គាល់ ក្នុងនោះមានសញ្ញាបញ្ជាក់ប្រព័ន្ធគ្រប់គ្រងគុណភាព ប្រព័ន្ធគ្រប់គ្រងបរិស្ថាន ប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ ។ល។

- **អាជ្ញាប័ណ្ណ** គឺជាលិខិតអនុញ្ញាត ដែលវិទ្យាស្ថានបានចេញឱ្យតាមការស្នើសុំ ដើម្បីប្រើសញ្ញាស្តង់ដារ ។

- **ការបញ្ជាក់** សំដៅដល់ នីតិវិធីមួយដែលក្នុងនោះ តតិយជនម្នាក់ផ្តល់ការធានាជាលាយលក្ខណ៍អក្សរថាទំនិញ ដំណើរការ ការអនុវត្ត ឬ សេវាកម្មសមស្របទៅតាមការតម្រូវដែលបានកំណត់ ។ (តតិយជន សំដៅដល់អង្គភាព ឬបុគ្គលណាមួយដែលទទួលស្គាល់ថាមានភាពឯករាជ្យចំពោះអ្នកផ្គត់ផ្គង់និងអ្នកទិញ) ។

- **ការវាយតម្លៃភាពអនុលោម** សំដៅដល់សកម្មភាពណាមួយដែលពាក់ព័ន្ធដល់ការកំណត់ដោយផ្ទាល់ ឬ ដោយប្រយោលថា ការតម្រូវដែលពាក់ព័ន្ធទាំងឡាយត្រូវបាន

- **ការធានាគុណភាព** សំដៅដល់សកម្មភាពដែលបានគ្រោងទុក និងបានរៀបចំ

ជាប្រព័ន្ធគុណភាព ដើម្បីផ្តល់នូវទំនុកចិត្តគ្រប់គ្រាន់ដែលផលិតផល ឬសេវាកម្មនឹងបំពេញតាមការតម្រូវសម្រាប់គុណភាព ។

- **ទំនិញ** សំដៅដល់របស់របរ ផលិតផល ឬ ជាវត្ថុអ្វីមួយ ដែលជាកម្មវត្ថុក្នុងការធ្វើពាណិជ្ជកម្ម ។

- **ក្រុមប្រឹក្សា** សំដៅដល់ក្រុមប្រឹក្សាស្តង់ដារជាតិ ។

- **វិទ្យាស្ថាន** សំដៅដល់វិទ្យាស្ថានស្តង់ដារកម្ពុជា ។

- **ប្រធាន** សំដៅដល់ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា ។

- **អធិការ** សំដៅដល់បុគ្គលណាមួយដែលប្រធានបានតែងតាំងឡើង ដើម្បីអនុវត្តច្បាប់នេះ ។

- **រដ្ឋមន្ត្រី** សំដៅដល់រដ្ឋមន្ត្រីដែលទទួលបន្ទុកវិស័យឧស្សាហកម្ម និងត្រួតពិនិត្យមើលលើស្តង់ដារូបនីយកម្ម និងការធានាគុណភាព ។

## ជំពូកទី ២

## វិទ្យាស្ថានស្តង់ដារកម្ពុជា

**មាត្រា ៤.-**

ត្រូវបានបង្កើតអង្គភាពស្តង់ដារជាតិមួយមានឈ្មោះថា**វិទ្យាស្ថានស្តង់ដារកម្ពុជា** ដែលស្ថិតនៅក្រោមក្រសួងទទួលបន្ទុកវិស័យឧស្សាហកម្ម ។ វិទ្យាស្ថានមានត្រាសម្គាល់របស់ខ្លួនមួយដោយឡែក ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់វិទ្យាស្ថាន ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥.-**

មុខងារនិងភារកិច្ចសំខាន់ៗរបស់វិទ្យាស្ថានស្តង់ដារកម្ពុជាមានជាអាទិ៍ដូចខាងក្រោម :

ក-រៀបចំស្តង់ដារជាតិសម្រាប់ផលិតផល ទំនិញ សម្ភារៈ សេវា ការអនុវត្ត និងការប្រតិបត្តិ និងផ្សព្វផ្សាយ ដើម្បីឱ្យមានការទទួលយកជាទូទៅនៃស្តង់ដារទាំងនោះ ។

ខ-អនុវត្តការវាយតម្លៃភាពអនុលោមស្របតាមបញ្ញត្តិ ដែលមានចែងក្នុងច្បាប់

ROYAUME DU CAMBODGE LE MINISTERE DU PALAIS ROYAL

គ-បង្កើត និងថែទាំមន្ទីរពិសោធន៍ បណ្ណាល័យ មធ្យោបាយ និងឧបករណ៍ផ្សេងទៀត ដើម្បីលើកកម្ពស់ស្តង់ដារូបនីយកម្មនិងគុណភាព ។

ឃ-បញ្ជាក់ភាពអនុលោមតាមស្តង់ដារសម្រាប់ផលិតផល ទំនិញ សារធាតុ សម្ភារៈ និងបរិក្ខារសម្រាប់ការប្រើប្រាស់ក្នុងស្រុក ឬសម្រាប់ការនាំចេញតាមសំណើរបស់អ្នកស្នើសុំ ។

ង-បញ្ជាក់ភាពអនុលោមតាមស្តង់ដារសុវត្ថិភាព សម្រាប់ផលិតផល ទំនិញ សារធាតុ សម្ភារៈ និងបរិក្ខារ សម្រាប់ការប្រើប្រាស់ក្នុងស្រុក ឬ សម្រាប់ការនាំចេញ តាមសំណើរបស់អ្នកស្នើសុំ ។

ច-បញ្ជាក់ភាពអនុលោមតាមស្តង់ដារសម្រាប់ប្រព័ន្ធគ្រប់គ្រងផលិតកម្ម និងសេវាតាមសំណើរបស់អ្នកស្នើសុំ ។

ឆ-ព្យួរទុក ដកហូត និងលុបចោលអាជ្ញាប័ណ្ណបញ្ជាក់ផលិតផល ឬវិញ្ញាបនបត្របញ្ជាក់ភាពអនុលោម ឬវិញ្ញាបនបត្របញ្ជាក់ឬចុះបញ្ជីប្រព័ន្ធ ឬវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬ ចុះបញ្ជី ។

ជ-ស្រាវជ្រាវអំពីស្តង់ដារូបនីយកម្ម ។

ឈ-ផ្តល់សេវាអប់រំ បណ្តុះបណ្តាល និងការពិគ្រោះយោបល់ ដើម្បីផ្សព្វផ្សាយស្តង់ដារូបនីយកម្ម និងគុណភាព ។

ញ-ទទួលស្គាល់មន្ទីរពិសោធន៍ មធ្យោបាយ និងឧបករណ៍ផ្សេងទៀតរបស់អង្គភាពក្នុងស្រុក និងបរទេសសម្រាប់គោលបំណងរបស់វិទ្យាស្ថាន ។

ដ-ផ្តល់កិច្ចសហប្រតិបត្តិការជាមួយបុគ្គល អង្គការអន្តរជាតិ ឬសមាគមក្រៅប្រទេស ដែលមានកម្មវត្ថុនិងគោលបំណងដូចគ្នា ។

ឋ-ជំរុញនិងលើកទឹកចិត្តការអនុវត្តស្តង់ដារ និងស្តង់ដារូបនីយកម្មឱ្យទៅជាមធ្យោបាយមួយ សម្រាប់ការរីកចំរើននៃសេដ្ឋកិច្ចជាតិ សម្រាប់សុខភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ ។

ឌ-សហការជាមួយអាជ្ញាធរមូលដ្ឋាន ផ្នែកឧស្សាហកម្ម ពាណិជ្ជកម្ម និងអង្គការនានា ដើម្បីធានានូវការអនុវត្តស្តង់ដារ ។

**មាត្រា ៦.-**

វិទ្យាស្ថានស្តង់ដារកម្ពុជា ត្រូវដឹកនាំគ្រប់គ្រងដោយប្រធានមួយរូប មានឋានៈស្មើអគ្គនាយក ដែលមានលក្ខណសម្បត្តិសមស្រប មានសញ្ញាប័ត្រកម្រិតឧត្តមសិក្សាខាងផ្នែកវិទ្យាសាស្ត្របច្ចេកទេសព្រមទាំងមានបទពិសោធន៍យ៉ាងតិចប្រាំឆ្នាំក្នុងការងារស្តង់ដារូបនីយកម្ម ។

ប្រធានអាចមានអនុប្រធានមួយរូប ឬ ច្រើនរូបតាមការចាំបាច់ ។

**មាត្រា ៧.-**

ប្រធានអាចចាត់តាំងបុគ្គលិករបស់វិទ្យាស្ថាន ឬបុគ្គលផ្សេងទៀត ដែលប្រធានយល់ថា មានលក្ខណសម្បត្តិសមស្របឱ្យធ្វើជាអធិការនិងត្រូវចេញលិខិតបញ្ជាក់ដល់អធិការ ដើម្បីជាការបញ្ជាក់ថា អធិការរូបនោះ ត្រូវចាត់តាំងឱ្យបំពេញការងារស្របតាមគោលបំណងនៃច្បាប់នេះ ។

**មាត្រា ៨.-**

បែបបទនៃការធ្វើអធិការកិច្ច ត្រូវបានកំណត់ដូចតទៅ :

១-តាមការណែនាំជាលាយលក្ខណ៍អក្សររបស់ប្រធាន អធិការអាចចូលក្នុងបរិវេណ ទីតាំង ដោយបង្ហាញលិខិតអនុញ្ញាតដល់អ្នកកាន់កាប់ដើម្បី :

ក-ពិនិត្យនិងយកគំរូផលិតផលឬទំនិញ ឬ សម្ភារៈ ឬ សារធាតុ ដែលបានប្រើប្រាស់ ឬ ដែលសង្ស័យថានឹងយកមកប្រើប្រាស់ក្នុងកម្មន្តសាល

ខ-បើកកញ្ចប់ ឬ កុងតឺន័រណាដែលមានផ្ទុក ឬ ដែលសង្ស័យថាមានផ្ទុកផលិតផល ឬ ទំនិញ ឬ សម្ភារៈ ឬ សារធាតុ ចំពោះផលិតផលឬទំនិញ :

-ដែលស្នើសុំអាជ្ញាប័ណ្ណ ឬ

-ដែលមានប្រើសញ្ញាស្តង់ដារដោយគ្មានអាជ្ញាប័ណ្ណ ឬ

-ដែលមានអាជ្ញាប័ណ្ណហើយ តែត្រូវសង្ស័យថាបានផលិត ឬបានកែច្នៃក្នុងផលិតកម្មដែលមិនអនុលោមទៅតាមស្តង់ដារពាក់ព័ន្ធ ឬ

-ដែលតម្រូវឱ្យអនុលោមតាមស្តង់ដារបញ្ជា ។

២-យោងតាមវាក្យខណ្ឌទី ១ អធិការអាច :

ROYAUME DU CAMBODGE
LE MINISTERE DU PALAIS ROYAL

ក-តម្រូវឱ្យបុគ្គលដែលគ្រប់គ្រងកម្មន្តសាល បង្ហាញសៀវភៅ លិខិតជូនដំណឹង កំណត់ត្រា បញ្ជី ឬ ឯកសារផ្សេងទៀតដែលពាក់ព័ន្ធ

ខ-ពិនិត្យកត់ត្រា ឬ ថតចម្លងឯកសារផ្សេងៗ ដែលទាក់ទិនទៅនឹងកម្មន្តសាល ឬ ផលិតផល ឬ ទំនិញដែលបានចេញលិខិតអនុញ្ញាតឱ្យ ដោយតម្រូវឱ្យបុគ្គលគ្រប់គ្រងពន្យល់ និងរឹបអូសយកឯកសារទាំងនោះក្នុងករណីមានកំហុសឆ្គង

គ-សាកសួរព័ត៌មានពីគ្រប់បុគ្គលដែលយល់ឃើញថាចាំបាច់

ឃ-តម្រូវឱ្យបុគ្គលពាក់ព័ន្ធចូលមកបង្ហាញខ្លួននៅចំពោះមុខតាមពេលវេលានិងទីកន្លែងកំណត់ ដើម្បីផ្តល់ព័ត៌មានបន្ថែម ។

៣-អធិការដែលចុះទៅបំពេញភារកិច្ចក្នុងបរិវេណទីតាំង ត្រូវអនុវត្តតាមនីតិវិធីរដ្ឋបាលទូទៅស្តីពីការត្រួតពិនិត្យ ។

៤-អធិការត្រូវធ្វើកំណត់ហេតុនិងរបាយការណ៍ស្តីពីការចុះត្រួតពិនិត្យនេះ ។

៥-បុគ្គលគ្រប់គ្រងក្នុងបរិវេណទីតាំង ត្រូវបង្កលក្ខណៈងាយស្រួលដល់អធិការគ្រប់ពេលក្នុងការចូលបំពេញភារកិច្ចក្នុងបរិវេណទីតាំងរបស់ខ្លួន ។

**មាត្រា ៩.-**

មុនពេលចុះទៅបំពេញភារកិច្ច ប្រធាននិងបុគ្គលិកវិទ្យាស្ថាន ត្រូវចុះហត្ថលេខាលើប្រតិវេទន៍មួយ ដែលមានខសន្យារក្សាការសម្ងាត់ ក្នុងពេលចុះបំពេញភារកិច្ច ឬ អនុវត្តមុខងាររបស់ខ្លួន ថានឹងមិនលាតត្រដាងព័ត៌មានចេញទៅខាងក្រៅឡើយ លើកលែងតែ :

-មានការតម្រូវពីរដ្ឋមន្ត្រី ឬ ពីតុលាការ

-ដើម្បីអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់នេះ ឬ ច្បាប់ផ្សេងទៀត ។

## ជំពូកទី ៣

## ក្រុមប្រឹក្សាស្តង់ដារជាតិ

**មាត្រា ១០.-**

ត្រូវបង្កើតក្រុមប្រឹក្សាមួយមានឈ្មោះថា**ក្រុមប្រឹក្សាស្តង់ដារជាតិ** ដែលមានវិទ្យាស្ថានស្តង់ដារកម្ពុជាទទួលបន្ទុកជាលេខាធិការដ្ឋាន ។

ន

**មាត្រា ១១.-**

ក្រុមប្រឹក្សាស្តង់ដារជាតិមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| -តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ជាប្រធាន |
| -ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា | ជាអនុប្រធានអចិន្ត្រៃយ៍ |
| -តំណាងក្រសួងពាណិជ្ជកម្ម | ជាអនុប្រធាន |
| -តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាអនុប្រធាន |
| -តំណាងក្រសួងសុខាភិបាល | ជាអនុប្រធាន |
| -តំណាងក្រសួងបរិស្ថាន | ជាសមាជិក |
| -តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | ជាសមាជិក |
| -តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ | ជាសមាជិក |
| -តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| -តំណាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ជាសមាជិក |
| - តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ជាសមាជិក |
| -តំណាងក្រសួងទេសចរណ៍ | ជាសមាជិក |
| -តំណាងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | ជាសមាជិក |
| -តំណាងរាជបណ្ឌិតសភាកម្ពុជា | ជាសមាជិក |
| -តំណាងសកលវិទ្យាល័យភូមិន្ទភ្នំពេញ | ជាសមាជិក |
| -តំណាងសកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល | ជាសមាជិក |
| -តំណាងសកលវិទ្យាល័យភូមិន្ទកសិកម្ម | ជាសមាជិក |
| -តំណាងសភាពាណិជ្ជកម្មកម្ពុជា | ជាសមាជិក |
| -តំណាងសមាគមអ្នកផលិត | ជាសមាជិក |

ROYAUME DU CAMBODGE * LE MINISTÈRE DU PALAIS ROYAL

10/32

-តំណាងសមាគមអ្នកប្រើប្រាស់ ជាសមាជិក និង

-តំណាងក្រសួងស្ថាប័នផ្សេងទៀតតាមការចាំបាច់ ជាសមាជិក ។

ឈ្មោះប្រធាន អនុប្រធាន និងសមាជិកក្រុមប្រឹក្សា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យឧស្សាហកម្ម ។

សមាជិកក្រុមប្រឹក្សាមានអាណត្តិបីឆ្នាំ និងអាចត្រូវតែងតាំងជាថ្មី សម្រាប់រយៈពេលបន្តទៀត លើកលែងតែក្នុងករណី~~លាលែង ឬ បោះបង់ចោលតំណែង~~ ឬ ដកហូតតំណែង ។

សមាជិកនៃក្រុមប្រឹក្សាត្រូវមានលក្ខណសម្បត្តិដូចតទៅ :

-មានសញ្ជាតិខ្មែរ

-មិនដែលមានទោសពីបទឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ

-មានសញ្ញាប័ត្រកម្រិតឧត្តមសិក្សាក្នុងផ្នែកវិទ្យាសាស្ត្រ ឬវិស្វកម្ម និង

-មានបទពិសោធន៏ការងារយ៉ាងតិចប្រាំឆ្នាំ ។

**មាត្រា ១២.-**

ក្រុមប្រឹក្សាស្តង់ដារជាតិមានភារកិច្ចដូចខាងក្រោម :

ក-សម្រេចយល់ព្រម កែសម្រួល ឬ លុបចោលស្តង់ដារជាតិណាមួយ ។

ខ-សម្រេចយល់ព្រម កែសម្រួល ឬ លុបចោលសញ្ញាស្តង់ដារណាមួយ ។

គ-កំណត់អំពីស្តង់ដារស្ម័គ្រចិត្ត ឬស្តង់ដារបញ្ជា ឬសញ្ញាស្តង់ដារ ។

ឃ-ជូនយោបល់ដល់រដ្ឋមន្ត្រីអំពីអាទិភាព និងគោលនយោបាយនៃស្តង់ដារូបនីយកម្ម កម្មវិធី ផែនការ គម្រោង និងសកម្មភាពនានា ដើម្បីធានាឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត ។

ង-ជូនយោបល់ និងលើកអនុសាសន៍ជូនរដ្ឋមន្ត្រី អំពីការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃស្តង់ដារសម្រាប់ផលិតផល ដំណើរការ ការអនុវត្ត ការធ្វើតេស្ត និងសេវាកម្ម និងសម្រេចយល់ព្រមលើកម្មវិធី ផែនការ គម្រោង និងសកម្មភាពនានា សំដៅជំរុញប្រសិទ្ធ-ភាព និងភាពអភិវឌ្ឍឧស្សាហកម្ម និង សម្រាប់ការពារអ្នកប្រើប្រាស់ តាមរយៈសកម្មភាពស្តង់ដារូបនីយកម្ម ។

ច-ណែនាំវិទ្យាស្ថានអំពីលក្ខណវិនិច្ឆ័យ និងនីតិវិធីដែលទាក់ទិនដល់ការរៀប

ចំ ការសម្រេចយល់ព្រម ការទទួលយក និងការជ្រើសរើសស្តង់ដារ ។

ឆ-រៀបចំបទបញ្ជាផ្ទៃក្នុង សម្រាប់ការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សា ។

ជ-បំពេញមុខងារដទៃទៀតទៅតាមការកំណត់ ឬ តាមការប្រគល់សិទ្ធិរបស់រដ្ឋមន្ត្រី ។

**មាត្រា ១៣.-**

សម័យប្រជុំក្រុមប្រឹក្សាអាចប្រព្រឹត្តទៅបាន លុះត្រាតែមានកូរ៉ុមចំនួនលើសពីពាក់កណ្តាលនៃសមាជិកសរុប ។ រាល់សេចក្តីសម្រេចណាមួយរបស់ក្រុមប្រឹក្សា ត្រូវប្រព្រឹត្តទៅដោយមតិភាគច្រើន ពីរភាគបីនៃចំនួនសមាជិកវត្តមានក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា លើកលែងតែការពិនិត្យសម្រេច ឬ ការកែសម្រួលស្តង់ដារជាតិ ដែលត្រូវអនុម័តតាមមតិបីភាគបួននៃចំនួនសមាជិកចូលរួមប្រជុំ ។

**មាត្រា ១៤.-**

ក្រុមប្រឹក្សាអាចបង្កើតគណៈកម្មការមួយចំនួនបាន ដើម្បីជួយបំពេញមុខងារ និងភារកិច្ច ឬ សម្រាប់គោលបំណងផ្សេងទៀត ដែលកើតឡើង ឬ ដែលទាក់ទិនដល់មុខងារ និងភារកិច្ចរបស់ខ្លួន ។ ក្រុមប្រឹក្សាអាចធ្វើការកែសម្រួល ឬ លុបចោលសេចក្តីសម្រេចណាមួយដែលគណៈកម្មការបានអនុម័តរួចហើយ ។

## ជំពូកទី ៤
## ស្តង់ដារកម្ពុជា

**មាត្រា ១៥.-**

រដ្ឋមន្ត្រីត្រូវចេញសេចក្តីប្រកាសចំពោះស្តង់ដារណាមួយថាជាស្តង់ដារកម្ពុជា ដែលក្រុមប្រឹក្សាបានសម្រេចស្របតាមគោលបំណងនៃច្បាប់នេះ ដោយចុះផ្សាយក្នុងរាជកិច្ច ។

រដ្ឋមន្ត្រីអាចកំណត់កាលបរិច្ឆេទចូលជាធរមាន អាចធ្វើការកែសម្រួល និងដកហូតស្តង់ដារ ទៅតាមការស្នើរបស់ក្រុមប្រឹក្សា ។

13/32

រដ្ឋមន្ត្រីត្រូវបញ្ជាក់ពីមូលហេតុ ដែលនឹងត្រូវចុះផ្សាយក្នុងរាជកិច្ចអំពីការកំណត់កាលបរិច្ឆេទចូលជាធរមាននៃការកែសម្រួល និងការដកហូតស្តង់ដារ ។

**មាត្រា ១៦.-**

ក្នុងគោលបំណងធានាឱ្យមានសុវត្ថិភាពពិតប្រាកដ ដើម្បីបង្ការភាពមហន្តរាយដែលប៉ះពាល់ជាសាធារណៈ ឬ ប៉ះពាល់ដល់វិស័យឧស្សាហកម្ម ឬ សេដ្ឋកិច្ចជាតិ ប្រភេទនៃផលិតផល ឬ ប្រព័ន្ធណាមួយ ត្រូវអនុលោមទៅតាមស្តង់ដារណាមួយជាកំណត់ ហើយស្តង់ដារនោះត្រូវកំណត់ជាស្តង់ដារបញ្ជា តាមការស្នើរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងតាមការសម្រេចរបស់ក្រុមប្រឹក្សា ។

ការកំណត់ស្តង់ដារបញ្ជាត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រី ហើយកាលបរិច្ឆេទចូលជាធរមានមិនត្រូវឱ្យតិចជាងហុកសិប(៦០)ថ្ងៃ ចាប់ពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាស ។

**មាត្រា ១៧.-**

មុនពេលរដ្ឋមន្ត្រីចេញប្រកាស ដូចមានចែងក្នុងមាត្រា ១៥និងមាត្រា ១៦ នៃច្បាប់នេះ :

ក-វិទ្យាស្ថានត្រូវផ្សព្វផ្សាយជាសាធារណៈ និងយ៉ាងហោចណាស់នៅក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានណាមួយប្រចាំថ្ងៃជាភាសាខ្មែរ ក្នុងរយៈពេលមួយមិនតិចជាងប្រាំពីរ(៧) ថ្ងៃ នូវសេចក្តីប្រកាសមួយបញ្ជាក់អំពីគោលបំណង និងខ្លឹមសារសង្ខេបនៃស្តង់ដារណាមួយ ។ បុគ្គលណាមានបំណងតវ៉ា ត្រូវធ្វើការតវ៉ាជាលាយលក្ខណ៍អក្សរទៅវិទ្យាស្ថាន ក្នុងរយៈពេលសាមសិប (៣០)ថ្ងៃ គិតចាប់ពីថ្ងៃចុះផ្សាយព័ត៌មាននោះ ។

ខ-ប្រសិនបើពុំមានការតវ៉ាទេ វិទ្យាស្ថានត្រូវធ្វើរបាយការណ៍ទៅក្រុមប្រឹក្សាហើយក្នុងករណីនេះ ក្រុមប្រឹក្សាត្រូវដំណើរការបន្តទៀត ។

គ-ក្នុងករណីដែលមានការតវ៉ា វិទ្យាស្ថានត្រូវបញ្ជូនពាក្យតវ៉ាទៅក្រុមប្រឹក្សា ។

ឃ-វិទ្យាស្ថានត្រូវបិទសេចក្តីជូនដំណឹងមួយនៅក្នុងវិទ្យាស្ថាន ដោយបញ្ជាក់ពី

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងដែលត្រូវធ្វើការដោះស្រាយលើពាក្យតវ៉ា ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកតវ៉ា យ៉ាងហោចណាស់ប្រាំពីរ (៧)ថ្ងៃ មុនកាលបរិច្ឆេទធ្វើការដោះស្រាយ ។

ង-ក្រុមប្រឹក្សាត្រូវផ្ដល់ឱកាសដល់ជនទាំងឡាយណាដែលមានការចាប់អារម្មណ៍ចូលរួមនិងផ្ដល់មតិនៅក្នុងការដោះស្រាយនោះ ។

ច-ប្រសិនបើអ្នកតវ៉ាមិនបានមកចូលរួមក្នុងការដោះស្រាយតាមពេលវេលាដែលបានកំណត់ទេ ក្រុមប្រឹក្សាមានសិទ្ធិដំណើរការដូចដែលខ្លួនគិតថាសមស្រប ។

ឆ-នៅពេលដែលក្រុមប្រឹក្សាធ្វើសេចក្ដីសម្រេចរួចហើយ វិទ្យាស្ថានត្រូវបិទផ្សាយសេចក្ដីសម្រេចថតចម្លងនៅក្នុងវិទ្យាស្ថាន ហើយត្រូវផ្ញើសេចក្ដីសម្រេចថតចម្លងមួយច្បាប់ទៅអ្នកតវ៉ា ។

**មាត្រា ១៨.-**

បុគ្គលណាដែលពាក់ព័ន្ធនឹងការសម្រេចរបស់ក្រុមប្រឹក្សាស្របតាមមាត្រា ១៧ ចំណុច ឆ នៃច្បាប់នេះ មានសិទ្ធិតវ៉ាទៅរដ្ឋមន្ត្រី ដើម្បីជំទាស់ទៅនឹងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាក្នុងរយៈពេលសាមសិប(៣០)ថ្ងៃ គិតចាប់ពីថ្ងៃបិទផ្សាយសេចក្ដីសម្រេចថតចម្លងនៅក្នុងវិទ្យាស្ថាន ។ រដ្ឋមន្ត្រីត្រូវបញ្ជូនលិខិតតវ៉ាទៅក្រុមប្រឹក្សា ដោយភ្ជាប់ជាមួយនូវអនុសាសន៍របស់ខ្លួន ។ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាពេលនេះ គឺជាសេចក្ដីសម្រេចចុងក្រោយ ។

រដ្ឋមន្ត្រីត្រូវជូនដំណឹងទៅអ្នកតវ៉ាអំពីសេចក្ដីសម្រេចចុងក្រោយនេះ ។

**មាត្រា ១៩.-**

ក្រសួង ស្ថាប័ន ឬ អង្គភាពពាក់ព័ន្ធណាមួយ អាចធ្វើសំណើទៅក្រុមប្រឹក្សា ដើម្បីសុំបង្កើតស្តង់ដារកម្ពុជាជាក់លាក់មួយ ។ ប្រសិនបើក្រុមប្រឹក្សាយល់ថា មិនជាការចាំបាច់ទេនោះ ក្រុមប្រឹក្សាត្រូវបញ្ជាក់ពីមូលហេតុ និងជូនដំណឹងទៅក្រសួង ស្ថាប័ន ឬ អង្គភាពពាក់ព័ន្ធនោះវិញ ។

# ជំពូកទី ៥

# សញ្ញាស្តង់ដារកម្ពុជា

**មាត្រា ២០.-**

យោងតាមមាត្រា ២២ នៃច្បាប់នេះ និងដោយមានការសម្រេចយល់ព្រមពីក្រុមប្រឹក្សា វិទ្យាស្ថានត្រូវផ្សព្វផ្សាយជាសាធារណៈ និងយ៉ាងហោចណាស់ ក៏នៅក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានណាមួយប្រចាំថ្ងៃជាភាសាខ្មែរ ក្នុងរយៈពេលមួយមិនតិចជាងប្រាំពីរ(៧)ថ្ងៃ បញ្ជាក់អំពីសញ្ញាស្តង់ដារណាមួយ ដែលក្រុមប្រឹក្សាបានសម្រេចយល់ព្រមទាក់ទិនទៅនឹងស្តង់ដារកម្ពុជា សម្រាប់ផលិតផលឬទំនិញ ឬ សម្រាប់ផលិតកម្ម ខ្សែសង្វាក់ផលិតកម្ម ការកែច្នៃ ឬ ប្រព្រឹត្តិកម្មលើផលិតផលឬទំនិញ ឬ សេវាកម្ម ឬ សម្រាប់ប្រព័ន្ធនោះ ។

សេចក្តីជូនដំណឹងក្នុងកថាខណ្ឌ ១ ត្រូវមានព័ត៌មានអំពីស្តង់ដារពាក់ព័ន្ធ ដែលត្រូវបញ្ជាក់ដោយសញ្ញាស្តង់ដារណាមួយនោះ ។ បុគ្គលណាមានបំណងតវ៉ា ត្រូវធ្វើការតវ៉ាជាលាយលក្ខណ៍អក្សរទៅវិទ្យាស្ថានក្នុងរយៈពេលសាមសិប (៣០)ថ្ងៃ គិតចាប់ពីថ្ងៃផ្សាយសេចក្តីជូនដំណឹងនោះ ។

ប្រសិនបើពុំមានការតវ៉ា វិទ្យាស្ថានត្រូវធ្វើរបាយការណ៍ទៅក្រុមប្រឹក្សា ហើយក្នុងករណីនេះ ក្រុមប្រឹក្សាត្រូវដំណើរការបន្តទៀត ។ ក្នុងករណីដែលមានការតវ៉ា វិទ្យាស្ថានត្រូវបញ្ជូនពាក្យតវ៉ាទៅក្រុមប្រឹក្សា ។ ក្រុមប្រឹក្សាត្រូវពិចារណាលើការតវ៉ា និងត្រូវធ្វើការស៊ើបអង្កេត ព្រមទាំងធ្វើការសាកសួរព័ត៌មានផ្សេងៗប្រសិនបើចាំបាច់ ។

ក្នុងករណីចាំបាច់ត្រូវសាកសួរព័ត៌មាន ក្រុមប្រឹក្សាត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ដោយមានការបញ្ជាក់កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងសាកសួរព័ត៌មានទៅឱ្យអ្នកតវ៉ា ។ អ្នកតវ៉ានោះ ត្រូវមកបង្ហាញខ្លួននៅកន្លែងសាកសួរព័ត៌មាន និងមានសិទ្ធិទទួលដំណឹងអំពីការសម្រេចរបស់ក្រុមប្រឹក្សា ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាលើការតវ៉ាខាងលើ ត្រូវប្រគល់ជូនទៅវិទ្យាស្ថាន ដើម្បីធ្វើជាសេចក្តីសម្រេចចុងក្រោយ សេចក្តីសម្រេចថតចម្លងនៅក្នុងវិទ្យាស្ថាន ហើយត្រូវធ្វើសេចក្តីសម្រេចថតចម្លងមួយច្បាប់ទៅរាល់បុគ្គលពាក់ព័ន្ធ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL ក្រសួងព្រះបរមរាជវាំង

៤

16132

**មាត្រា ២១.-**

បុគ្គលដែលពាក់ព័ន្ធដល់ការសម្រេចរបស់ក្រុមប្រឹក្សាស្របតាមកថាខណ្ឌ ៥ នៃមាត្រា ២០ នៃច្បាប់នេះ មានសិទ្ធិតវ៉ាទៅរដ្ឋមន្ត្រីដើម្បីជំទាស់ទៅនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាក្នុងរយៈពេលដប់ប្រាំ(១៥)ថ្ងៃ គិតចាប់ពីថ្ងៃបិទផ្សាយសេចក្តីសម្រេចថតចម្លងនៅក្នុងវិទ្យាស្ថាន ។ រដ្ឋមន្ត្រីត្រូវបញ្ជូនលិខិតតវ៉ាទៅក្រុមប្រឹក្សា ដោយភ្ជាប់ជាមួយនូវអនុសាសន៍របស់ខ្លួន ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាពេលនេះ គឺជាសេចក្តីសម្រេចចុងក្រោយ ។ រដ្ឋមន្ត្រីត្រូវជូនដំណឹងទៅអ្នកតវ៉ាអំពីការសម្រេចចុងក្រោយនេះ ។

**មាត្រា ២២.-**

គ្មានសញ្ញាស្តង់ដារណាដែលដូចគ្នាទៅនឹងពាណិជ្ជសញ្ញាណាមួយ ដែលបានចុះបញ្ជីរួចហើយសម្រាប់ផលិតផលឬទំនិញក្រោមច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឬ ដែលស្ទើរតែដូចគ្នាទាំងស្រុង ធ្វើឱ្យច្រឡំគ្នាទៅនឹងពាណិជ្ជសញ្ញានោះ អាចប្រកាសថាជាសញ្ញាស្តង់ដារដែលមានបញ្ជាក់ក្នុងមាត្រា ២០ នៃច្បាប់នេះបានឡើយ ។

គ្មានបុគ្គលណាមួយអាចប្រើប្រាស់ពាណិជ្ជសញ្ញាណា ដែលដូចគ្នានឹងសញ្ញាស្តង់ដារដែលបានប្រកាសស្របតាមមាត្រា ២០ នៃច្បាប់នេះ ឬ ប្រើប្រាស់ពាណិជ្ជសញ្ញាណាដែលស្ទើរតែដូចគ្នាទាំងស្រុងធ្វើឱ្យច្រឡំគ្នាទៅនឹងសញ្ញាស្តង់ដារបានឡើយ ។

**មាត្រា ២៣.-**

យោងតាមមាត្រា ២០ មាត្រា ២១ និងមាត្រា ២២ នៃច្បាប់នេះ និងតាមសំណើរបស់ក្រុមប្រឹក្សា រដ្ឋមន្ត្រីត្រូវចេញប្រកាសមួយដែលនឹងចុះផ្សាយក្នុងរាជកិច្ចអំពីការដាក់ឱ្យប្រើ ឬ លុបចោល ឬ ធ្វើការកែសម្រួលសញ្ញាស្តង់ដារចំពោះផលិតផលឬទំនិញ ឬ សម្រាប់ផលិតកម្ម ខ្សែសង្វាក់ផលិតកម្ម ការកែច្នៃ ឬ ប្រព្រឹត្តិកម្មលើផលិតផលឬទំនិញ ឬ សេវាកម្ម ឬ សម្រាប់ប្រព័ន្ធគ្រប់គ្រងនោះ ដែលនឹងចូលជាធរមានចាប់ពីថ្ងៃដែលបានបញ្ជាក់ក្នុងប្រកាសនោះ ។ កាលបរិច្ឆេទចូលជាធរមានមិនត្រូវឱ្យលើសពីបី(៣)ខែ គិតចាប់ពីថ្ងៃចេញប្រកាសនេះ ។

## ជំពូកទី ៦

## អាជ្ញាប័ណ្ណបញ្ជាក់ផលិតផល

**មាត្រា ២៤.–**

រាល់ការស្នើសុំអាជ្ញាប័ណ្ណ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរទៅវិទ្យាស្ថាន ។

អាជ្ញាប័ណ្ណអាចចេញឱ្យបាន លុះត្រាតែបានបំពេញតាមលក្ខខណ្ឌដូចខាងក្រោម :

- បានធ្វើអធិការកិច្ច និងការយកគំរូផលិតផលមកធ្វើតេស្ត ដើម្បីបញ្ជាក់ពីភាពអនុលោមតាមស្តង់ដារពាក់ព័ន្ធ
- អ្នកស្នើសុំយល់ព្រមទទួលយកលក្ខខណ្ឌទាំងឡាយ ដែលមានចែងក្នុងអាជ្ញាប័ណ្ណ
- អ្នកស្នើសុំបានបង់កម្រៃស្នើសុំអាជ្ញាប័ណ្ណទៅវិទ្យាស្ថាន តាមការកំណត់ដោយប្រកាសរួមរបស់ក្រសួងទទួលបន្ទុកវិស័យឧស្សាហកម្ម និងក្រសួងទទួលបន្ទុកវិស័យហិរញ្ញវត្ថុ ។

អាជ្ញាប័ណ្ណមានសុពលភាពសម្រាប់រយៈពេលបី(៣)ឆ្នាំ និងអាចត្រូវបន្តជាថ្មីបានសម្រាប់រយៈពេលបី(៣)ឆ្នាំម្តង ប្រសិនបើបានអនុវត្តត្រឹមត្រូវតាមលក្ខខណ្ឌដែលមានចែងក្នុងអាជ្ញាប័ណ្ណនោះ ។

ក្នុងករណីសំណើសុំអាជ្ញាប័ណ្ណត្រូវបដិសេធ វិទ្យាស្ថានត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីពីការបដិសេធទៅបុគ្គលដែលស្នើសុំអាជ្ញាប័ណ្ណនោះយ៉ាងយូរប្រាំពីរ(៧)ថ្ងៃ បន្ទាប់ពីថ្ងៃបញ្ចប់ការវាយតម្លៃភាពអនុលោមតាមស្តង់ដារពាក់ព័ន្ធ ។

**មាត្រា ២៥.–**

បុគ្គលណាមួយដែលផលិត ឬ កែច្នៃផលិតផលអនុលោមតាមស្តង់ដារដែលបានប្រកាសឱ្យប្រើ និងបានចូលជាធរមានរួចហើយ អាចបិទសញ្ញាស្តង់ដារនៅលើផលិតផលរបស់ខ្លួនបាន បន្ទាប់ពីបានទទួលអាជ្ញាប័ណ្ណពីវិទ្យាស្ថានស្របតាមមាត្រា ២៤ នៃច្បាប់នេះ ។

**មាត្រា ២៦.-**

នៅពេលដែលស្តង់ដារបញ្ញាមួយ ត្រូវប្រកាសដូចមានចែងក្នុងមាត្រា ១៦ នៃច្បាប់នេះ និងក្រោយកាលបរិច្ឆេទចូលជាធរមានដែលបានកំណត់បញ្ជាក់ក្នុងប្រកាសនោះ ការផលិត ឬ ការបន្តផលិតនូវផលិតផលណាមួយ ឬ ការរៀបចំខ្សែសង្វាក់ផលិតកម្មណាមួយ ឬផលិតផលនាំចូលណាមួយ ត្រូវអនុលោមតាមស្តង់ដារបញ្ញានោះ ។

**មាត្រា ២៧.-**

អ្នកកាន់អាជ្ញាប័ណ្ណត្រូវដាក់តាំងអាជ្ញាប័ណ្ណរបស់ខ្លួននៅកន្លែងដែលអាចមើលឃើញច្បាស់ នៅក្នុងទីតាំងផលិតដែលបានបញ្ជាក់ក្នុងអាជ្ញាប័ណ្ណ ។

ប្រសិនបើអាជ្ញាប័ណ្ណត្រូវបាត់ ឬ ខូចខាតទាំងស្រុងនោះ អ្នកកាន់អាជ្ញាប័ណ្ណត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណទុតិយតាទៅវិទ្យាស្ថានក្នុងរយៈពេលសាមសិប(៣០)ថ្ងៃ គិតចាប់ពីថ្ងៃដែលដឹងឮជាសាធារណៈ ។

ចំពោះការផ្លាស់ប្តូរទីតាំងផលិតដែលបានបញ្ជាក់ក្នុងអាជ្ញាប័ណ្ណ ឬ បង្កើតសាខា ឬ ពង្រីកផលិតកម្ម អ្នកកាន់អាជ្ញាប័ណ្ណត្រូវសុំអាជ្ញាប័ណ្ណថ្មីពីវិទ្យាស្ថានមុនដំណើរការផលិត ។

សំណុំលិខិតស្នើសុំនិងការចេញអាជ្ញាប័ណ្ណថ្មី ត្រូវអនុលោមតាមគោលការណ៍ និងនីតិវិធីនៃការចេញអាជ្ញាប័ណ្ណ ។

**មាត្រា ២៨.-**

ក្នុងករណីសំណុំលិខិតស្នើសុំអាជ្ញាប័ណ្ណស្របតាមមាត្រា ២៤ មាត្រា ២៥ មាត្រា ២៦ និងមាត្រា ២៧ នៃច្បាប់នេះត្រូវបានបដិសេធដោយវិទ្យាស្ថាន អ្នកស្នើសុំមានសិទ្ធិតវ៉ាទៅរដ្ឋមន្ត្រីក្នុងរយៈពេលសាមសិប(៣០)ថ្ងៃ គិតចាប់ពីថ្ងៃជូនព័ត៌មានអំពីការបដិសេធនោះ ។ សេចក្តីសម្រេចរបស់រដ្ឋមន្ត្រី គឺជាសេចក្តីសម្រេចចុងក្រោយ ។

**មាត្រា ២៩.-**

អាជ្ញាប័ណ្ណមួយត្រូវលុបចោលនៅពេល :

-អ្នកកាន់អាជ្ញាប័ណ្ណបញ្ឈប់ដំណើរការ ឬ

-អ្នកកាន់អាជ្ញាប័ណ្ណស្នើសុំឈប់ប្រើសញ្ញាស្តង់ដារនៅលើផលិតផលរបស់ខ្លួន ឬ

4

18/32

-មានសេចក្តីជូនដំណឹង ឬ ប្រកាសដែលកំណត់អំពីស្តង់ដារថ្មីណាមួយ ឬ ការកែប្រែស្តង់ដារណាមួយ ឬ ការដកហូតស្តង់ដារណាមួយដែលទាក់ទិនទៅនឹងប្រភេទផលិតផលទាំងនោះ ចូលជាធរមាន ។

**មាត្រា ៣០.-**

នៅពេលបញ្ចប់ដំណើរការរបស់ខ្លួន អ្នកកាន់អាជ្ញាប័ណ្ណត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅវិទ្យាស្ថាន ក្នុងរយៈពេលសាមសិប(៣០)ថ្ងៃ គិតចាប់ពីថ្ងៃដែលបានបញ្ចប់ដំណើរការនោះ ។

ក្នុងករណីមានការកំណត់ស្តង់ដារថ្មីមួយ ឬ មានការកែប្រែស្តង់ដារ អ្នកកាន់អាជ្ញាប័ណ្ណដែលមានបំណងអនុលោមតាមស្តង់ដារថ្មី ឬ ស្តង់ដារដែលបានកែប្រែនោះ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណឱ្យបានមុនកាលបរិច្ឆេទចូលជាធរមាននៃស្តង់ដារថ្មី ឬ ស្តង់ដារដែលបានកែប្រែនោះ ។ បន្ទាប់ពីបានដាក់ពាក្យស្នើសុំរួច អ្នកកាន់អាជ្ញាប័ណ្ណអាចបន្តដំណើរការរបស់ខ្លួន នៅក្រោមអាជ្ញាប័ណ្ណនិងស្តង់ដារចាស់ ក្នុងរយៈពេលមួយដែលបានកំណត់ដោយវិទ្យាស្ថាន គឺមិនលើសពីមួយ(១)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃស្តង់ដារថ្មី ឬ ស្តង់ដារដែលបានកែប្រែ ។

**មាត្រា ៣១.-**

វិទ្យាស្ថានមានសិទ្ធិព្យួរអាជ្ញាប័ណ្ណ ក្នុងរយៈពេលមួយមិនលើសពីបី(៣)ខែ ក្នុងមួយលើក នៅពេលដែលបានរកឃើញថាអ្នកកាន់អាជ្ញាប័ណ្ណរំលោភទៅនឹងបញ្ញត្តិនៃច្បាប់នេះ ឬបទបញ្ជាដែលក្រសួងបានចេញស្របតាមច្បាប់នេះ ឬ លក្ខខណ្ឌដែលបានដាក់ជាបញ្ញត្តិដោយវិទ្យាស្ថាន ឬរកឃើញថាផលិតផលមិនអនុលោមទៅតាមស្តង់ដារដែលបានកំណត់ ។

នៅពេលដែលអាជ្ញាប័ណ្ណ សម្រាប់ផលិតផលណាមួយត្រូវបានព្យួរ អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវបញ្ជាក់តាមរូបភាពណាមួយបង្ហាញថាផលិតផលនោះមានអាជ្ញាប័ណ្ណឡើយ ។

ប្រសិនបើបុគ្គលដែលត្រូវព្យួរអាជ្ញាប័ណ្ណ បានកែតម្រូវដោយអនុលោមតាមច្បាប់និងបញ្ញត្តិនានារួចហើយ វិទ្យាស្ថានអាចលុបចោលការព្យួរអាជ្ញាប័ណ្ណ នៅមុនពេលផុតកំណត់រយៈពេលព្យួរ ។

៤

9/32

**មាត្រា ៣២.-**

វិទ្យាស្ថានមានសិទ្ធិដកហូតអាជ្ញាប័ណ្ណ នៅពេលដែលបានរកឃើញថា អ្នកកាន់អាជ្ញាប័ណ្ណ :

-អនុវត្តខុសធ្ងន់ធ្ងរទៅនឹងការតម្រូវនៃលក្ខខណ្ឌនៃការផ្តល់ និងការប្រើប្រាស់អាជ្ញាប័ណ្ណ ឬ

-មិនបានបំពេញនូវលក្ខខណ្ឌទាំងឡាយ ដែលបានតម្រូវឱ្យធ្វើការកែតម្រូវក្នុងរយៈពេលព្យួរ ឬ

-បានប្រព្រឹត្តកំហុសដូចគ្នាទៅនឹងកំហុសដែលបណ្តាលឱ្យមានការព្យួរអាជ្ញាប័ណ្ណលើកមុន ក្នុងរយៈពេលបី(៣)ឆ្នាំកន្លងមក ឬ

-ខកខានមិនបានបង់កម្រៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ ។

**មាត្រា ៣៣.-**

មុនពេលព្យួរអាជ្ញាប័ណ្ណដូចមានចែងក្នុងមាត្រា ៣១ ឬ ដកហូតអាជ្ញាប័ណ្ណដូចមានចែងក្នុងមាត្រា៣២ នៃច្បាប់នេះ វិទ្យាស្ថានត្រូវជូនដំណឹងពីបំណងរបស់ខ្លួនដល់អ្នកកាន់អាជ្ញាប័ណ្ណឱ្យបានដប់ប្រាំ(១៥)ថ្ងៃមុន និងបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹងនោះអំពីមូលហេតុណាមួយដែលនាំឱ្យមានការព្យួរ ឬ ដកហូតអាជ្ញាប័ណ្ណ ។

**មាត្រា ៣៤.-**

បុគ្គលណាដែលពុំសុខចិត្តចំពោះការព្យួរ ឬ ការដកហូតអាជ្ញាប័ណ្ណដូចដែលបានកំណត់នៅមាត្រា៣១ និងមាត្រា៣២ នៃច្បាប់នេះ អាចធ្វើការតវ៉ាជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រី ក្នុងអំឡុងពេលដប់ប្រាំ(១៥)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលសេចក្តីជូនដំណឹងអំពីការព្យួរ ឬ ការដកហូតនោះ ។ ក្នុងអំឡុងពេលតវ៉ា អ្នកតវ៉ាអាចធ្វើសំណើទៅរដ្ឋមន្ត្រី ដើម្បីសុំពន្យារកាលបរិច្ឆេទចូលជាធរមាននៃបទប្បញ្ញត្តិអំពីការព្យួរ ឬ ការដកហូតអាជ្ញាប័ណ្ណ ។ សេចក្តីសម្រេចរបស់រដ្ឋមន្ត្រី គឺជាការសម្រេចចុងក្រោយ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ក្រសួងព្រះបរមរាជវាំង

៤

**មាត្រា ៣៥.-**

បុគ្គលដែលត្រូវដកហូតអាជ្ញាប័ណ្ណសម្រាប់ប្រភេទនៃផលិតផលដោយឡែកណាមួយ មិនអាចស្នើសុំអាជ្ញាប័ណ្ណថ្មីសម្រាប់ផលិតផលនោះបានឡើយ ក្នុងអំឡុងពេលប្រាំមួយ(៦) ខែ គិតចាប់ពីថ្ងៃដែលបានដកហូត ។

**មាត្រា ៣៦.-**

គ្មានបុគ្គលណាអាចផ្សព្វផ្សាយពាណិជ្ជកម្មលក់ ឬ លក់ផលិតផលណាមួយដែលមានបិទសញ្ញាដោយរំលោភទៅនឹងកថាខណ្ឌ ២ នៃមាត្រា ២២ មាត្រា ២៥ និងមាត្រា ២៦ ឬ ផលិតផល ឬ ទំនិញមានបិទសញ្ញាស្តង់ដារដែលអាជ្ញាប័ណ្ណត្រូវលុបចោល ឬ ព្យួរ ឬ ដកហូតដូចមានចែងក្នុងមាត្រា ២៩ មាត្រា ៣១ និងមាត្រា ៣២ នៃច្បាប់នេះបានឡើយ ។

**មាត្រា ៣៧.-**

ការលុបចោលអាជ្ញាប័ណ្ណស្របតាមមាត្រា ២៩ និងការដកហូតអាជ្ញាប័ណ្ណស្របតាមមាត្រា ៣២ នៃច្បាប់នេះ ត្រូវផ្សព្វផ្សាយជាសាធារណៈដោយវិទ្យាស្ថាន ។

## ជំពូកទី ៧
## វិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ

**មាត្រា ៣៨.-**

អង្គភាពណាដែលមានបំណងចង់បានទទួលវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ អាចធ្វើពាក្យស្នើសុំទៅវិទ្យាស្ថាន ។

អ្នកស្នើសុំត្រូវបង់កម្រៃស្នើសុំវិញ្ញាបនបត្រទៅវិទ្យាស្ថានតាមការកំណត់ដោយប្រកាសរួមរបស់ក្រសួងទទួលបន្ទុកវិស័យឧស្សាហកម្មនិងក្រសួងទទួលបន្ទុកវិស័យហិរញ្ញវត្ថុ ។

ក្រោយពីអនុវត្តតាមនីតិវិធីជាបន្តបន្ទាប់រួចហើយវិទ្យាស្ថានត្រូវវាយតម្លៃពីភាពអនុលោមនៃប្រព័ន្ធគ្រប់គ្រងរបស់អ្នកស្នើសុំទៅនឹងការតម្រូវនៃស្តង់ដារប្រព័ន្ធពាក់ព័ន្ធ ។

ក្រោយពីមានការសម្រេចយល់ព្រមរបស់វិទ្យាស្ថានលើការស្នើសុំនោះហើយ អង្គភាពដែលបានរៀបរាប់ក្នុងកថាខណ្ឌ ១ ខាងលើនឹងបានទទួលនូវវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធនោះ ដោយត្រូវអនុវត្តតាមលក្ខខណ្ឌដែលបានកំណត់របស់វិទ្យាស្ថាន ។

វិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធមានសុពលភាពសម្រាប់រយៈពេលបី(៣)ឆ្នាំ ប៉ុន្តែប្រសិនបើបានអនុវត្តតាមលក្ខខណ្ឌដែលមានចែងហើយវិញ្ញាបនបត្រនោះអាចត្រូវបន្តជាថ្មីសម្រាប់រយៈពេលបី(៣)ឆ្នាំ ម្តងបាន ។

អង្គភាពដែលដាក់ពាក្យសុំវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ និងអង្គភាពទាំងឡាយដែលបានទទួលវិញ្ញាបនបត្ររួចហើយ ត្រូវដាក់ជូនឯកសារដូចខាងក្រោម :

-ឯកសារទាំងឡាយសម្រាប់ការវាយតម្លៃ ឬ ត្រួតពិនិត្យ និង

-ព័ត៌មានដែលទាក់ទិនដល់ដំណើរការ ឬ ការរៀបចំការដាក់ពាក្យសុំ ឬ ការបានទទួលវិញ្ញាបនបត្រនោះ ។

វិទ្យាស្ថានត្រូវធ្វើបញ្ជីមួយដែលត្រូវកត់ត្រាលម្អិតអំពីវិញ្ញាបនបត្រទាំងឡាយដែលបានផ្តល់ឱ្យរួចហើយ ។ បញ្ជីនេះត្រូវមានតម្កល់សម្រាប់សាធារណជនពិនិត្យនៅវិទ្យាស្ថាន ។

**មាត្រា ៣៩.-**

អ្នកកាន់វិញ្ញាបនបត្រអាចប្រើប្រាស់វិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ ឬ សញ្ញាបញ្ជាក់ប្រព័ន្ធបាន ដើម្បីកំណត់ថាប្រព័ន្ធគ្រប់គ្រងរបស់អង្គភាពខ្លួនអនុលោមតាមការតម្រូវនៃស្តង់ដារដែលបានកំណត់ នៅក្រោយពេលធ្វើសវនកម្ម និងបន្ទាប់ពីបានទទួលវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធពីវិទ្យាស្ថានស្របតាមមាត្រា ៣៨ នៃច្បាប់នេះ ។

**មាត្រា ៤០.-**

វិទ្យាស្ថានមានសិទ្ធិព្យួរវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធណាមួយ ក្នុងរយៈពេលមួយមិនលើសពីប្រាំមួយ(៦)ខែ ក្នុងករណីដូចខាងក្រោម :

-ការពិនិត្យអង្កេតបង្ហាញឱ្យឃើញថា មានការអនុវត្តមិនសមស្របតាមការតម្រូវនៃលក្ខខណ្ឌនៃការចេញ និងការប្រើប្រាស់វិញ្ញាបនបត្រ ឬ

-ការប្រើប្រាស់វិញ្ញាបនបត្រ ឬ សញ្ញាបញ្ជាក់ប្រព័ន្ធមិនបានត្រឹមត្រូវ ។

នៅពេលដែលវិញ្ញាបនបត្រសម្រាប់ប្រព័ន្ធគ្រប់គ្រងណាមួយត្រូវព្យួរ អ្នកកាន់វិញ្ញាបនបត្រមិនត្រូវបញ្ជាក់តាមរូបភាពណាមួយបង្ហាញថា ប្រព័ន្ធគ្រប់គ្រងនោះមានវិញ្ញាបនបត្រឡើយ ។

ប្រសិនបើអង្គភាពដែលត្រូវព្យួរវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធបានចាត់និងអនុវត្តវិធានការកែតម្រូវត្រឹមត្រូវរួចហើយ វិទ្យាស្ថានអាចលុបចោលការព្យួរវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធនៅមុនពេលផុតកំណត់នៃរយៈពេលព្យួរ ។

**មាត្រា ៤១.-**

វិទ្យាស្ថានមានសិទ្ធិដកហូតវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ ក្នុងករណីដូចខាងក្រោម ៖

-ការពិនិត្យអង្កេតបង្ហាញឱ្យឃើញថា ការអនុវត្តមានលក្ខណៈខុសធ្ងន់ធ្ងរទៅនឹងការតម្រូវនៃលក្ខខណ្ឌនៃការផ្តល់ និងការប្រើប្រាស់វិញ្ញាបនបត្រ ឬ

-អ្នកកាន់វិញ្ញាបនបត្ររំលោភទៅនឹងបញ្ញត្តិ ឬ បទបញ្ជាដែលក្រសួងបានចេញ ស្របតាមច្បាប់នេះ ឬ លក្ខខណ្ឌដែលបានដាក់ជាបញ្ញត្តិដោយវិទ្យាស្ថាន ឬ រកឃើញថាប្រព័ន្ធនោះមិនអនុលោមទៅតាមស្តង់ដារដែលបានកំណត់ ឬ

-អ្នកកាន់វិញ្ញាបនបត្រខកខានមិនបានបង់កម្រៃវិញ្ញាបនបត្រប្រចាំឆ្នាំ ឬ

-ការរំលោភទៅនឹងបទប្បញ្ញត្តិណាមួយ ដែលមានចែងក្នុងកិច្ចព្រមព្រៀងវិញ្ញាបនបត្រ ឬ

-មិនបានបំពេញវិធានការកែតម្រូវទាំងឡាយឱ្យបានគ្រប់គ្រាន់ក្នុងអំឡុងពេលនៃការព្យួរ ។

ការដកហូតវិញ្ញាបនបត្រខាងលើ ត្រូវផ្សព្វផ្សាយជាសាធារណៈដោយវិទ្យាស្ថាន ។

**មាត្រា ៤២.-**

មុនពេលលុបវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធដូចមានចែងក្នុងមាត្រា ៤០ ឬ ដកហូតវិញ្ញា-បនបត្របញ្ជាក់ប្រព័ន្ធដូចមានចែងក្នុងមាត្រា ៤១ នៃច្បាប់នេះ វិទ្យាស្ថានត្រូវជូនដំណឹងពីបំណងរបស់ខ្លួនដល់អ្នកកាន់វិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធឱ្យបានដប់ប្រាំ (១៥) ថ្ងៃមុន និងបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹងនោះ អំពីមូលហេតុណាមួយដែលនាំឱ្យមានការលុប ឬ ដកហូតវិញ្ញាបនបត្រ ។

**មាត្រា ៤៣.-**

គ្មានបុគ្គលណាមួយអាចផ្សព្វផ្សាយពាណិជ្ជកម្មអំពីការទទួលវិញ្ញាបនបត្របញ្ជាក់ណាមួយដែលមិនអនុលោមទៅតាមលក្ខខណ្ឌនៃមាត្រា ៣៨ ឬ ប្រើសញ្ញាដោយរំលោភទៅនឹងកថាខណ្ឌ ២ នៃមាត្រា ២២ នៃច្បាប់នេះ ឬ អង្គភាពរបស់ខ្លួន ត្រូវបានលុប ឬ ដកហូតវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធដូចមានចែងក្នុងមាត្រា ៤០ និងមាត្រា ៤១ នៃច្បាប់នេះបានឡើយ ។

## ជំពូកទី ៨
## ការវាយតម្លៃទទួលស្គាល់ និងការចុះបញ្ជី

**មាត្រា ៤៤.-**

ត្រូវដាក់ពាក្យសុំទៅវិទ្យាស្ថាន ចំពោះបុគ្គល ឬ អង្គភាពណាមួយ ដែលមានបំណងចង់ទទួលយកការវាយតម្លៃទទួលស្គាល់ ឬ ការចុះបញ្ជីដូចជា :

ក-អង្គភាពវាយតម្លៃភាពអនុលោម ។

ខ-មន្ទីរពិសោធន៍ធ្វើតេស្ត ឬ ក្រិតខ្នាត ។

គ-អង្គភាពបណ្តុះបណ្តាលសម្រាប់វាយតម្លៃភាពអនុលោម ។

ឃ-បុគ្គលណាមួយដែលមានលក្ខណសម្បត្តិ ដើម្បីអនុវត្តការវាយតម្លៃភាពអនុ-លោម និងសវនកម្មនានា ។

អ្នកស្នើសុំត្រូវបង់កម្រៃស្នើសុំវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ និងវិញ្ញាបនបត្រចុះបញ្ជីទៅវិទ្យាស្ថានតាមការកំណត់ដោយប្រកាសរួមរបស់ក្រសួងទទួលបន្ទុកវិស័យឧស្សាហកម្ម និងក្រសួងទទួលបន្ទុកវិស័យហិរញ្ញវត្ថុ ។

ក្រោយពីអនុវត្តតាមនីតិវិធីជាបន្តបន្ទាប់រួចហើយ វិទ្យាស្ថានត្រូវវាយតម្លៃទទួលស្គាល់ ឬ ទទួលចុះបញ្ជីបុគ្គលដូចមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រានេះ ទៅនឹងការតម្រូវនៃស្តង់ដារពាក់ព័ន្ធ ។

ក្រោយពីមានការសម្រេចយល់ព្រមរបស់វិទ្យាស្ថានលើការស្នើសុំនោះហើយ បុគ្គលដូចមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រានេះនឹងបានទទួលនូវវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជី ដោយត្រូវអនុវត្តតាមលក្ខខណ្ឌដែលបានកំណត់ដោយវិទ្យាស្ថាន ។

វិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជីមានសុពលភាពសម្រាប់រយៈពេលបី(៣)ឆ្នាំ ប៉ុន្តែប្រសិនបើបានអនុវត្តតាមលក្ខខណ្ឌដែលមានចែងហើយ វិញ្ញាបនបត្រនោះអាចត្រូវបន្តជាថ្មីបាន សម្រាប់រយៈពេលបី(៣)ឆ្នាំម្តង ។

បុគ្គល ឬ អង្គភាពដែលដាក់ពាក្យសុំវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជី និងបុគ្គល ឬ អង្គភាពទាំងឡាយដែលបានទទួលវិញ្ញាបនបត្ររួចហើយ ត្រូវដាក់ជូនឯកសារដូចខាងក្រោម :

-ឯកសារទាំងឡាយសម្រាប់ការវាយតម្លៃ ឬ ត្រួតពិនិត្យ និង

-ព័ត៌មានដែលទាក់ទិនដល់ដំណើរការ ឬ ការរៀបចំការដាក់ពាក្យសុំ ឬការបានទទួលវិញ្ញាបនបត្រនោះ ។

វិទ្យាស្ថានត្រូវធ្វើបញ្ជីមួយដែលត្រូវកត់ត្រាលម្អិតអំពីវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជីទាំងឡាយដែលបានផ្តល់ឱ្យរួចហើយ ។ បញ្ជីនេះត្រូវមានតម្កល់ទុកសម្រាប់សាធារណជនពិនិត្យនៅវិទ្យាស្ថាន ។

ROYAUME DU CAMBODGE LE MINISTRE du PALAIS ROYAL

**មាត្រា ៤៥.-**

អ្នកកាន់វិញ្ញាបនបត្រអាចប្រើប្រាស់វិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬ វិញ្ញាបនបត្រចុះបញ្ជីបាន ដើម្បីកំណត់ថា បុគ្គល ឬ អង្គភាពរបស់ខ្លួនអនុលោមតាមការតម្រូវនៃស្តង់ដារដែលបានកំណត់ នៅក្រោយពេលធ្វើសវនកម្ម និងបន្ទាប់ពី បានទទួលវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជីពីវិទ្យាស្ថានស្របតាមមាត្រា ៤៤ នៃច្បាប់នេះ ។

**មាត្រា ៤៦.-**

វិទ្យាស្ថានមានសិទ្ធិព្យួរទុក ឬ ដកហូតវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ និងចុះបញ្ជីក្នុងរយៈពេលមួយមិនលើសពីប្រាំមួយ(៦)ខែ ឬ មានសិទ្ធិដកហូត ឬ លុបចោល ប្រសិនបើពេលវេលា និងលក្ខខណ្ឌដែលបានសរសេរភ្ជាប់ទៅនឹងវិញ្ញាបនបត្រទាំងនេះមិនត្រូវបានគោរពតាម ប៉ុន្តែអ្នកកាន់វិញ្ញាបនបត្រណាដែលត្រូវវិទ្យាស្ថានព្យួរទុក ឬ ដកហូតនូវវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជី អាចដាក់ពាក្យប្តឹងតវ៉ាទៅរដ្ឋមន្ត្រីដើម្បីធ្វើការវិនិច្ឆ័យជាចុងក្រោយ ។

ប្រសិនបើអង្គភាពដែលត្រូវព្យួរវិញ្ញាបនបត្របានចាត់និងអនុវត្តវិធានការកែតម្រូវត្រឹមត្រូវរួចហើយ វិទ្យាស្ថានអាចលុបចោលការព្យួរវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬ វិញ្ញាបនបត្រចុះបញ្ជីនៅមុនពេលផុតកំណត់នៃរយៈពេលព្យួរ ។

នៅពេលដែលវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជីណាមួយត្រូវព្យួរទុក ឬ ដកហូត អ្នកកាន់វិញ្ញាបនបត្រមិនត្រូវបញ្ជាក់តាមរូបភាពណាមួយ បង្ហាញថាបុគ្គល ឬ អង្គភាពរបស់ខ្លួនមានវិញ្ញាបនបត្រឡើយ ។

## ជំពូកទី ៩

## បទប្បញ្ញត្តិដោយឡែក

**មាត្រា ៤៧.-**

ផលិតផល ឬ ខ្សែសង្វាក់ផលិតកម្មដែលអនុលោមតាមស្តង់ដារ ឬ ប្រើសញ្ញាសម្គាល់ផ្សេងពីការកំណត់នៅក្នុងច្បាប់នេះ មិនត្រូវលើកជាលេសមកអះអាងដើម្បីតវ៉ាប្រឆាំងទៅនឹងបទប្បញ្ញត្តិនៃច្បាប់នេះបានឡើយ ។

**មាត្រា ៤៨.-**

គ្មានបុគ្គល ឬ អង្គភាពណាមួយអាចផ្សព្វផ្សាយពាណិជ្ជកម្មអំពីការទទួលវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធណាមួយ ទោះបីអង្គភាពនោះបានទទួលវិញ្ញាបនបត្រចេញដោយអង្គភាពចេញវិញ្ញាបនបត្រនៅក្នុងប្រទេស ឬ ក្រៅប្រទេសក៏ដោយ វៀរលែងតែបានចុះបញ្ជី និងបានទទួលទិដ្ឋាការពីវិទ្យាស្ថានស្តង់ដារកម្ពុជា ។

**មាត្រា ៤៩.-**

ត្រូវហាមឃាត់ចំពោះសកម្មភាពដូចខាងក្រោម :

ក-ធ្វើអាជីវកម្មដោយប្រើឈ្មោះដែលមានពាក្យ **ស្តង់ដារកម្ពុជា** ឬ អក្សរកាត់ ISC ។

ខ-ចុះបញ្ជីពាណិជ្ជសញ្ញាណាដែលមានពាក្យ **ស្តង់ដារកម្ពុជា** នៅក្រោមច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ។

គ-បោះពុម្ព ឬ ថតចម្លងឯកសារស្តង់ដារកម្ពុជា វៀរលែងតែមានការអនុញ្ញាតពីវិទ្យាស្ថាន ។

## ជំពូកទី ១០
## ទោសប្បញ្ញត្តិ

**មាត្រា ៥០.-**

បុគ្គលណាមួយដែលប្រើប្រាស់ពាណិជ្ជសញ្ញា ដែលដូចគ្នានឹងសញ្ញាស្តង់ដារដែលបានប្រកាសស្របតាមមាត្រា ២០ នៃច្បាប់នេះ ឬ ប្រើប្រាស់ពាណិជ្ជសញ្ញាណាដែលស្ទើរតែដូចគ្នាទាំងស្រុងធ្វើឱ្យច្រឡំគ្នាទៅនឹងសញ្ញាស្តង់ដារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីប្រាំមួយ (៦)ថ្ងៃ ដល់មួយ(១)ខែ និងពិន័យជាប្រាក់ចំនួនពីប្រាំសិបម៉ឺន (៥០០.០០០)រៀល ទៅពីរលាន(២.០០០.០០០)រៀល ឬ ទោសណាមួយនៃទោសទាំងពីរ ។

**មាត្រា ៥១.-**

អ្នកកាន់អាជ្ញាប័ណ្ណ ដែលមិនបានដាក់តាំងអាជ្ញាប័ណ្ណរបស់ខ្លួន នៅកន្លែងដែលអាចមើលឃើញច្បាស់នៅក្នុងទីតាំងផលិតដែលបានបញ្ជាក់ក្នុងអាជ្ញាប័ណ្ណ ឬ មិនបានសុំអាជ្ញា-

ប័ណ្ណទុតិយតា ពីវិទ្យាស្ថានក្នុងរយៈពេលសាមសិប(៣០)ថ្ងៃ គិតចាប់ពីថ្ងៃដែលដឹងឮជាសាធារណៈអំពីអាជ្ញាប័ណ្ណរបស់ខ្លួនត្រូវបាត់ឬខូចខាតទាំងស្រុង ឬ មិនបានសុំអាជ្ញាប័ណ្ណថ្មីពីវិទ្យាស្ថាន មុនដំណើរការផលិតនៅពេលមានការផ្លាស់ប្តូរទីតាំងផលិត ឬ បង្កើតសាខា ឬ ពង្រីកផលិតកម្ម ត្រូវពិន័យជាប្រាក់ចំនួនពីហាសិបម៉ឺន (៥០០.០០០)រៀល ទៅពីរលាន (២.០០០.០០០)រៀល ។

**មាត្រា ៥២.–**

បុគ្គលណាផ្សព្វផ្សាយពាណិជ្ជកម្មអំពីការទទួលវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធណាមួយដែលមិនបានចុះបញ្ជីនិងបានទទួលទិដ្ឋាការពីវិទ្យាស្ថានស្តង់ដារកម្ពុជា ត្រូវពិន័យជាប្រាក់ចំនួនពីហាសិបម៉ឺន (៥០០.០០០)រៀល ទៅពីរលាន (២.០០០.០០០)រៀល ។

**មាត្រា ៥៣.–**

បុគ្គលណាមួយដែលធ្វើអាជីវកម្មដោយប្រើឈ្មោះដែលមានពាក្យ **ស្តង់ដារកម្ពុជា** ឬ អក្សរកាត់ISC ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីប្រាំមួយ(៦)ថ្ងៃ ដល់មួយ(១) ខែ និងពិន័យជាប្រាក់ចំនួនពីហាសិបម៉ឺន (៥០០.០០០)រៀល ទៅពីរលាន (២.០០០.០០០)រៀល ឬ ទោសណាមួយនៃទោសទាំងពីរ ។

**មាត្រា ៥៤.–**

នៅពេលមានការកំណត់ស្តង់ដារថ្មីមួយ ឬ ក៏មានការកែប្រែស្តង់ដារណាមួយ អ្នកកាន់អាជ្ញាប័ណ្ណដែលមានប្រើសញ្ញាស្តង់ដារ ដោយអនុលោមតាមស្តង់ដារចាស់មិនបានសុំការអនុញ្ញាតពីវិទ្យាស្ថាន ឬ ប្រើហួសកាលបរិច្ឆេទកំណត់របស់វិទ្យាស្ថាន ត្រូវពិន័យជាប្រាក់ចំនួនពីមួយលាន (១.០០០.០០០)រៀល ទៅប្រាំលាន (៥.០០០.០០០)រៀល ។

**មាត្រា ៥៥.–**

បុគ្គលណាមួយដែលផលិត ឬ កែច្នៃ ឬ នាំចូលផលិតផល ឬ ផ្សព្វផ្សាយពាណិជ្ជកម្ម លក់ ឬ ចែកផលិតផលណាមួយ ដែលមានបិទសញ្ញាស្តង់ដារក្លែងបន្លំក្នុងគោលបំណងបំភាន់ ហេតុការណ៍ធ្វើឱ្យជឿថា ផលិតផលរបស់ខ្លួនមានអាជ្ញាប័ណ្ណនិងបានអនុលោមតាមស្តង់ដារកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ(១)ខែ ដល់បី(៣)ខែ និងពិន័យជាប្រាក់ចំនួន

៤

ពីពីរលាន (២.០០០.០០០)រៀល ទៅប្រាំមួយលាន(៦.០០០.០០០)រៀល ឬទោសណាមួយនៃទោសទាំងពីរ ។

**មាត្រា ៥៦.-**

បុគ្គលណាមួយដែលផ្សព្វផ្សាយ ឬ ប្រើប្រាស់វិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ ឬ សញ្ញាបញ្ជាក់ប្រព័ន្ធណាមួយក្លែងបន្លំក្នុងគោលបំណងបំភាន់សាធារណជនឱ្យជឿថា ប្រព័ន្ធរបស់ខ្លួនមានវិញ្ញាបនបត្រ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ(១)ខែ ដល់បី(៣)ខែ និងពិន័យជាប្រាក់ចំនួនពីពីរលាន (២.០០០.០០០)រៀល ទៅប្រាំមួយលាន (៦.០០០.០០០)រៀល ឬទោសណាមួយនៃទោសទាំងពីរ ។

**មាត្រា ៥៧.-**

បុគ្គល ឬ អង្គភាពដែលផ្សព្វផ្សាយឬប្រើប្រាស់វិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬ វិញ្ញាបនបត្រចុះបញ្ជីក្លែងបន្លំ ក្នុងគោលបំណងបំភាន់សាធារណជនឱ្យជឿថា បុគ្គល ឬអង្គភាពរបស់ខ្លួនបានទទួលការវាយតម្លៃទទួលស្គាល់ ឬ បានចុះបញ្ជី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ(១)ខែ ដល់បី(៣)ខែ និងពិន័យជាប្រាក់ចំនួនពីពីរលាន (២.០០០.០០០) រៀល ទៅប្រាំមួយលាន (៦.០០០.០០០)រៀល ឬ ទោសណាមួយនៃទោសទាំងពីរ ។

**មាត្រា ៥៨.-**

បុគ្គលណាមួយដែលបោះពុម្ព ឬ ថតចម្លងឯកសារស្តង់ដារកម្ពុជា ដោយមិនមានការអនុញ្ញាតពីវិទ្យាស្ថាន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ(១)ខែ ដល់បី(៣)ខែ និងពិន័យជាប្រាក់ចំនួនពីពីរលាន(២.០០០.០០០)រៀល ទៅប្រាំមួយលាន (៦.០០០.០០០)រៀល ឬទោសណាមួយនៃទោសទាំងពីរ ។

**មាត្រា ៥៩.-**

បុគ្គលណាមួយដែលផលិត ឬ កែច្នៃ ឬ នាំចូលផលិតផល ឬ ផ្សព្វផ្សាយពាណិជ្ជកម្ម ឬ ម៉ាកផលិតផលណាមួយ ដែលមានស្តង់ដារប្រភេទស្តង់ដារបញ្ជា ដែលបានប្រកាសដូចមានចែងក្នុងមាត្រា ១៦ នៃច្បាប់នេះ និងក្រោយកាលបរិច្ឆេទចូលជាធរមានដែលបានកំណត់ក្នុងប្រកាសនោះរួចហើយ មិនមានបិទសញ្ញាស្តង់ដារ ឬ គ្មានអាជ្ញាប័ណ្ណ ឬ

មិនអនុលោមតាមស្តង់ដារបញ្ជានោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ(១)ខែ ដល់មួយ (១)ឆ្នាំ និងពិន័យជាប្រាក់ចំនួនពីពីរលាន (២.០០០.០០០)រៀល ទៅម្ភៃបួនលាន (២៤.០០០.០០០)រៀល ឬ ទោសណាមួយនៃទោសទាំងពីរ ។

**មាត្រា ៦០.-**

បុគ្គលណាមួយផ្សព្វផ្សាយពាណិជ្ជកម្មលក់ ឬ លក់ផលិតផលណាមួយ ដែលមានប្រើ ឬ បិទសញ្ញាស្តង់ដារដែលខ្លួនដឹងថាអាជ្ញាប័ណ្ណត្រូវលុបចោល ឬ ព្យួរ ឬ ដកហូត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ(១)ខែ ដល់មួយ(១)ឆ្នាំ និងពិន័យជាប្រាក់ចំនួនពីពីរលាន (២.០០០.០០០)រៀល ទៅម្ភៃបួនលាន (២៤.០០០.០០០)រៀល ឬ ទោសណាមួយនៃទោសទាំងពីរ ។

**មាត្រា ៦១.-**

នៅពេលវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធគ្រប់គ្រងណាមួយត្រូវព្យួរ ឬ ដកហូត អ្នកកាន់វិញ្ញាបនបត្រដែលបញ្ជាក់ ឬ បង្ហាញតាមរូបភាពណាមួយថា ប្រព័ន្ធគ្រប់គ្រងនោះមានវិញ្ញាបនបត្រ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ(១)ខែ ដល់មួយ(១)ឆ្នាំ និងពិន័យជាប្រាក់ចំនួនពីពីរលាន (២.០០០.០០០)រៀល ទៅម្ភៃបួនលាន (២៤.០០០.០០០)រៀល ឬទោសណាមួយនៃទោសទាំងពីរ ។

**មាត្រា ៦២.-**

បុគ្គលណាមួយផ្សព្វផ្សាយ ឬ ប្រើប្រាស់វិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជី នៅពេលដែលវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជីត្រូវព្យួរទុក ឬ ដកហូត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ(១)ខែ ដល់មួយ(១)ឆ្នាំ និងពិន័យជាប្រាក់ចំនួនពីពីរលាន (២.០០០.០០០)រៀល ទៅម្ភៃបួនលាន (២៤.០០០.០០០)រៀល ឬ ទោសណាមួយនៃទោសទាំងពីរ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

30/32

**មាត្រា ៦៣.-**

បន្ថែមពីលើទោសពិន័យ ឬពន្ធនាគារ បុគ្គលណាដែលប្រព្រឹត្តល្មើសដូចមានចែងក្នុងមាត្រា ៥៩ និងមាត្រា ៦០ នៃច្បាប់នេះ តុលាការអាចសម្រេចរឹបអូសនូវផលិតផលល្មើសទាំងអស់ ឬ មួយផ្នែក ។

**មាត្រា ៦៤.-**

ក្នុងករណីមិនរាងចាលចំពោះបទល្មើសនឹងមាត្រា ៥០ មាត្រា ៥១ មាត្រា ៥២ មាត្រា ៥៣ មាត្រា ៥៤ មាត្រា ៥៥ មាត្រា ៥៦ មាត្រា ៥៧ មាត្រា ៥៨ មាត្រា ៥៩ មាត្រា ៦០ មាត្រា ៦១ និងមាត្រា ៦២ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសទ្វេឡើង ទាំងការផ្តន្ទាទោសពិន័យជាប្រាក់ ទាំងការផ្តន្ទាទោសដាក់ពន្ធនាគារ ដោយពុំទាន់គិតបញ្ចូលនូវទោសព្រហ្មទណ្ឌធ្ងន់ធ្ងរចំពោះបច្ច័យនៃបទល្មើសដែលបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាព សុវត្ថិភាព ឬ ដល់អាយុជីវិតរបស់អ្នកប្រើប្រាស់ ។

**មាត្រា ៦៥.-**

ជនណាដែលរារាំងអធិការក្នុងពេលបំពេញភារកិច្ច ត្រូវពិន័យជាប្រាក់ចំនួនពីមួយលាន (១.០០០.០០០)រៀល ទៅប្រាំលាន (៥.០០០.០០០)រៀល ។

**មាត្រា ៦៦.-**

ជនណាដែលក្លែងបន្លំខ្លួនជាអធិការ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ(១)ខែ ដល់មួយ(១)ឆ្នាំ និងពិន័យជាប្រាក់ចំនួនពីហាសិបម៉ឺន (៥០០.០០០)រៀល ទៅពីរលាន (២.០០០.០០០)រៀល ឬ ទោសណាមួយនៃទោសទាំងពីរ ។

**មាត្រា ៦៧.-**

អធិការដែលមានចែងក្នុងមាត្រា ៧ នៃច្បាប់នេះ ត្រូវទទួលខុសត្រូវចំពោះទណ្ឌកម្មរដ្ឋបាល ។

អធិការត្រូវទទួលខុសត្រូវចំពោះការធ្វេសប្រហែស ដែលបណ្តាលឱ្យមានការថ្លោះធ្លោយនិងបច្ច័យផ្សេងៗដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

ទណ្ឌកម្មរដ្ឋបាលដែលមានចែងខាងលើនេះ មិនធ្វើជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាឡើយ ប្រសិនបើមានបទល្មើសណាមួយត្រូវប្រព្រឹត្ត ។

មាត្រា ៦៨.-

ទណ្ឌកម្មរដ្ឋបាលដែលត្រូវយកមកអនុវត្តចំពោះអធិការរួមមាន :

ក-ទណ្ឌកម្មរដ្ឋបាលកម្រិតដំបូងគឺការព្រមាន ឬ ការស្តីបន្ទោសពីប្រធាន ។

ខ-ទណ្ឌកម្មរដ្ឋបាលកម្រិតមធ្យមគឺការបញ្ឈប់ការផ្តល់ប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗទៀត ក្នុងរយៈពេលចាប់ពីប្រាំមួយ(៦)ខែឡើងទៅ ។

គ-ទណ្ឌកម្មរដ្ឋបាលកម្រិតធ្ងន់គឺការដកហូតតួនាទី ឬ មុខតំណែង ឬ ការបញ្ឈប់ពីការងារតែម្តង ។

ទណ្ឌកម្មរដ្ឋបាលដែលមានចែងខាងលើនេះ នៅពុំទាន់គិតដល់បទល្មើសព្រហ្មទណ្ឌ និងសំណងរដ្ឋប្បវេណីផ្សេងៗទៀត ។

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

មាត្រា ៦៩.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកម.០៦០៧.០២៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

**ហត្ថលេខា**

**ស៊ុយ សែម**

លេខ: ២៦២៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុំ ម៉ៃ ជំនោរ

32/82

# ព្រះរាជក្រម

នស/រកម/០១១៤/០០២

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមររាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី៤ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ច្បាប់
# ស្តីពី
# ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

២/១៩

## មាតិកា

**ជំពូកទី ១ បទប្បញ្ញត្តិទូទៅ**
មាត្រា ១.- គោលបំណង
មាត្រា ២.- គោលដៅ
មាត្រា ៣.- វិសាលភាព
មាត្រា ៤.- និយមន័យ
**ជំពូកទី ២ សមត្ថកិច្ចគ្រប់គ្រង**
មាត្រា ៥.- ភារកិច្ចរបស់ក្រសួងពាណិជ្ជកម្ម
មាត្រា ៦.- ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ
**ជំពូកទី ៣ នីតិវិធីចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ**
**ផ្នែកទី ១ អ្នកដាក់ពាក្យស្នើសុំនិងការដាក់ពាក្យស្នើសុំ**
មាត្រា ៧.- អ្នកដាក់ពាក្យស្នើសុំ
មាត្រា ៨.- ការដាក់ពាក្យស្នើសុំចុះបញ្ជី
**ផ្នែកទី ២ នីតិវិធីនៃការពិនិត្យពាក្យស្នើសុំ**
មាត្រា ៩.- ការពិនិត្យពាក្យស្នើសុំចុះបញ្ជី
មាត្រា ១០.- ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលមិនអាចចុះបញ្ជីបាន
មាត្រា ១១.- ការត្រួតពិនិត្យខ្លឹមសារពាក្យស្នើសុំចុះបញ្ជី
មាត្រា ១២.- ការចុះបញ្ជីនិងការបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រផ្លូវការ
មាត្រា ១៣.- ការកែតម្រូវលើការកត់ត្រា
មាត្រា ១៤.- រូបសញ្ញាជាតិសម្រាប់បញ្ជាក់លើទំនិញសម្គាល់ភូមិសាស្ត្រ
**ផ្នែកទី ៣ បណ្ដឹងជំទាស់**
មាត្រា ១៥.- រយៈពេលបណ្ដឹងជំទាស់
មាត្រា ១៦.- លក្ខខណ្ឌបណ្ដឹងជំទាស់
មាត្រា ១៧.- នីតិវិធីបណ្ដឹងជំទាស់
**ជំពូកទី ៤ បណ្ដឹងតវ៉ា**
មាត្រា ១៨.- សិទ្ធិនិងរយៈពេលនៃបណ្ដឹងតវ៉ា
**ជំពូកទី ៥ ការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស**
មាត្រា ១៩.- លក្ខខណ្ឌនៃការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស
មាត្រា ២០.- នីតិវិធីចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស
មាត្រា ២១.- បណ្ដឹងជំទាស់និងបណ្ដឹងតវ៉ាចំពោះម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស
**ជំពូកទី ៦ អានុភាពនៃការចុះបញ្ជី**
មាត្រា ២២.- សិទ្ធិដែលទទួលបានពីការចុះបញ្ជី

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

មាត្រា ២៣.. កិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រកម្ពុជានិងបរទេស
មាត្រា ២៤.. រយៈពេលនៃកិច្ចការពារ
មាត្រា ២៥.. ការទទួលស្គាល់ការចុះបញ្ជី
**ជំពូកទី ៧ ការត្រួតពិនិត្យអនុលោមភាពនៃសៀវភៅបន្ទុកក្នុងការចុះបញ្ជី ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ**
មាត្រា ២៦.. ការត្រួតពិនិត្យអនុលោមភាព
មាត្រា ២៧.. ប្រសិទ្ធភាពរបស់អង្គភាពចេញវិញ្ញាបនបត្របញ្ជាក់ពីអនុលោមភាព
**ជំពូកទី ៨ ការកែសម្រួលមោឃភាព និងការលុបម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ចេញពីបញ្ជី**
មាត្រា ២៨.. ការកែសម្រួល
មាត្រា ២៩.. មូលដ្ឋាននៃការផ្តល់មោឃភាពនិងការលុបម៉ាកសម្គាល់ភូមិសាស្ត្រទំនិញចេញពីបញ្ជី
មាត្រា ៣០.. អានុភាពនៃមោឃភាពនិងការលុបការចុះបញ្ជី
**ជំពូកទី ៩ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនិងការទទួលស្គាល់ឬការបដិសេធម៉ាក**
មាត្រា ៣១.. ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនិងម៉ាក
**ជំពូកទី ១០ វិធានការបណ្តោះអាសន្ននិងវិធានការតាមមាត់ច្រកព្រំដែន**
មាត្រា ៣២.. ការអនុវត្តវិធានការបណ្តោះអាសន្ននិងវិធានការតាមមាត់ច្រកព្រំដែន
**ជំពូកទី ១១ ភ្នាក់ងារ**
មាត្រា ៣៣.. ភ្នាក់ងារតំណាង
មាត្រា ៣៤.. លក្ខណសម្បត្តិ
**ជំពូកទី ១២ បទបញ្ជានិងសេចក្តីណែនាំរដ្ឋបាល**
មាត្រា ៣៥.. បទបញ្ជាអនុវត្ត
**ជំពូកទី ១៣ ការអនុវត្តសន្ធិសញ្ញាអន្តរជាតិនិងការបកស្រាយ**
មាត្រា ៣៦.. ការអនុវត្ត
**ជំពូកទី ១៤ ការឃាត់ទុកនិងការរឹបអូស**
មាត្រា ៣៧.. ការឃាត់ទុកនិងការរឹបអូស
**ជំពូកទី ១៥ ទោសប្បញ្ញត្តិ**
មាត្រា ៣៨.. បទក្លែងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ
មាត្រា ៣៩.. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល
**ជំពូកទី ១៦ អន្តរប្បញ្ញត្តិ**
មាត្រា ៤០.. អន្តរប្បញ្ញត្តិ
**ជំពូកទី ១៧ អវសានប្បញ្ញត្តិ**
មាត្រា ៤១.. និរាករណ៍

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### មាត្រា ១.- គោលបំណង

ច្បាប់នេះមានគោលបំណងការពារកម្មសិទ្ធិបញ្ញារបស់ផលិតករ ប្រតិបត្តិករ និងការពារអ្នកប្រើប្រាស់ផលិតផលដែលពាក់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ព្រមទាំងរក្សាអត្តសញ្ញាណជាតិ និងពង្រឹងចំណេះដឹង ចំណេះធ្វើតាមបែបប្រពៃណី និងរួមចំណែកកាត់បន្ថយភាពក្រីក្រ ។

### មាត្រា ២.- គោលដៅ

ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រង ការចុះបញ្ជី ការទទួលស្គាល់ និងការការពារម៉ាកសម្គាល់ ភូមិសាស្ត្រទំនិញនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

### មាត្រា ៣.- វិសាលភាព

ច្បាប់នេះមានវិសាលភាពអនុវត្តលើការចុះបញ្ជីនិងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងព្រះរាជាណាចក្រកម្ពុជា ចំពោះទំនិញកសិផល ទំនិញកសិចំណីអាហារ ទំនិញសិប្បកម្ម ឬទំនិញផ្សេងៗទៀតដែលផលិតក្នុងតំបន់ភូមិសាស្ត្រឬកែច្នៃស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

### មាត្រា ៤.- និយមន័យ

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យដូចតទៅ៖

**ការត្រួតពិនិត្យ** សំដៅដល់ការត្រួតពិនិត្យផ្ទៃក្នុងនិងការត្រួតពិនិត្យពីខាងក្រៅ ។ ការត្រួតពិនិត្យសំដៅដល់ការផ្ទៀងផ្ទាត់អនុលោមភាពរបស់ផលិតផលជាមួយនឹងសៀវភៅបន្ទុក ដោយសមាគមសម្គាល់ភូមិសាស្ត្រទំនិញ និងអង្គភាពចេញវិញ្ញាបនបត្រឬអាជ្ញាធរដែលត្រូវបានចាត់តាំង ។

**ការប្រើប្រាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ** សំដៅដល់ការស្នើលក់ ការផលិត ការដាក់លក់ ការនាំចេញ និងការនាំចូលទំនិញសម្គាល់ភូមិសាស្ត្រ ។

**ការនឹកគិតទៅដល់** សំដៅដល់ស្ថានភាពដែលការប្រើប្រាស់ពាក្យឬរូបភាពដើម្បីសម្គាល់ទំនិញមួយ ការបញ្ចូលផ្នែកនៃឈ្មោះឬរូបភាពនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលបានចុះបញ្ជីរួចធ្វើឲ្យអ្នកប្រើប្រាស់កើតមានអារម្មណ៍ថាជាទំនិញសម្គាល់ភូមិសាស្ត្រ ។

**កិត្តិសព្ទ** សំដៅដល់ការទទួលស្គាល់យ៉ាងទូលំទូលាយនូវទំនិញ និងឈ្មោះ ទំនិញនៅ ក្នុងផ្នែកផលិតកម្មឬពាណិជ្ជកម្មឬតាមរយៈការប្រើប្រាស់ទំនិញដែលពាក់ព័ន្ធ ។

**ទំនិញដែលអាចប្រៀបធៀបបាន** សំដៅដល់ទំនិញទាំងឡាយណាដែលមានទំនាក់ទំនងទៅនឹងចរិតលក្ខណៈគោលដៅឬការប្រើប្រាស់ដែលប្រហាក់ប្រហែលគ្នារបស់ទំនិញ ។

**ទំនិញសម្គាល់ភូមិសាស្ត្រ** សំដៅដល់ទំនិញពាក់ម៉ាកសម្គាល់ភូមិសាស្ត្រដែលបានចុះបញ្ជីរួច ។

**នាមទូទៅ** សំដៅដល់នាមដែលមហាជនស្គាល់ជាទូទៅថាជាការបង្ហាញពីប្រភេទនៃទំនិញ ។



៥

**បណ្តឹងជំទាស់** សំដៅដល់បណ្តឹងជំទាស់ទៅនឹងការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញណាមួយពីសំណាក់បុគ្គលពាក់ព័ន្ធ ។

**បណ្តឹងតវ៉ា** សំដៅដល់ការប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចចុងក្រោយរបស់ក្រសួងពាណិជ្ជកម្ម ឬក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ។

**ប្រតិបត្តិករ** សំដៅដល់បុគ្គលដែលពាក់ព័ន្ធនៅក្នុងដំណើរការប្រមូលទិញកែច្នៃធ្វើពាណិជ្ជកម្ម ឬចែកចាយទំនិញសម្គាល់ភូមិសាស្ត្រ ។

**ព្រឹត្តិបត្រផ្លូវការ** សំដៅដល់ព្រឹត្តិបត្រផ្លូវការរបស់ក្រសួងពាណិជ្ជកម្ម ។

**ម៉ាក** សំដៅដល់សញ្ញាដែលមើលឃើញហើយអាចសម្គាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវានៃសហគ្រាសនីមួយៗ ។

**ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ** សំដៅដល់ឈ្មោះ សញ្ញាសម្គាល់ និង/ឬ រូបភាព ផ្សេងៗទៀតដែលមានលក្ខណៈពិសេសដាច់ដែលជាឈ្មោះ ឬតំណាងឲ្យប្រភពដើមនៃតំបន់ភូមិសាស្ត្រមួយហើយឈ្មោះសញ្ញាសម្គាល់ និង/ឬ រូបភាពនោះសម្រាប់កំណត់អត្តសញ្ញាណទំនិញមានប្រភពក្នុងភូមិសាស្ត្រនោះដែលបានផ្តល់ជាមូលដ្ឋានគ្រឹះដល់គុណភាព កិត្តិសព្ទ ឬចរិតលក្ខណៈផ្សេងទៀតនៃទំនិញដែលកើតចេញពីតំបន់ភូមិសាស្ត្រនោះ ។

**សវនាការ** សំដៅដល់ការប្រជុំដោះស្រាយវិវាទរបស់មន្ត្រីកាន់កាប់បញ្ជីមុននឹងសម្រេចករណីជំទាស់នានារបស់ដើមបណ្តឹង ។

**សេចក្តីថ្លែងតប** សំដៅដល់ការផ្តល់ទឡ្ហីករណ៍ និងភស្តុតាងរបស់ភាគីណាមួយតតាំងទៅនឹងសេចក្តីរាយការណ៍របស់ភាគីបដិបក្ខ ។

**សៀវភៅបន្ទុក** សំដៅដល់ឯកសារកំណត់យ៉ាងច្បាស់លាស់នូវចំណុចសំខាន់ៗ អំពីតំបន់ភូមិ-សាស្ត្រនៃការផលិតលក្ខខណ្ឌនៃការផលិត និងដំណើរការត្រួតពិនិត្យគុណភាព ទំនិញសម្គាល់ភូមិសាស្ត្រជាដើម ដែលចងក្រងឡើងដោយអ្នកដាក់ពាក្យស្នើសុំ ។

**អង្គភាពចេញវិញ្ញាបនបត្រ** សំដៅដល់ស្ថាប័នសាធារណៈ ឬអង្គភាពឯកជនដែលចេញវិញ្ញាបន-បត្របញ្ជាក់ពីអនុលោមភាពស្របតាមសៀវភៅបន្ទុក ។

## ជំពូកទី ២
## សមត្ថកិច្ចគ្រប់គ្រង

### មាត្រា ៥.- ភារកិច្ចរបស់ក្រសួងពាណិជ្ជកម្ម

ក្រសួងពាណិជ្ជកម្មជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រង កាន់កាប់ និងចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

### មាត្រា ៦.- ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

ត្រូវរៀបចំឲ្យមានក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដើម្បីសិក្សា និងជំរុញមុខ

ទំនិញដែលមានសក្ដានុពលអាចចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងដោះស្រាយបណ្ដឹងតវ៉ាពីការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៣
## នីតិវិធីចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ
## ផ្នែកទី ១ អ្នកដាក់ពាក្យស្នើសុំនិងការដាក់ពាក្យស្នើសុំ

### មាត្រា ៧.- អ្នកដាក់ពាក្យស្នើសុំ

សមាគមសម្គាល់ភូមិសាស្ត្រ ឬក្រុមតំណាងផលិតករ ឬអង្គភាពតំណាងផលិតករ និង/ឬប្រតិបត្តិករ ដែលអាចទទួលផលប្រយោជន៍ពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនោះ មានសិទ្ធិដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ។

ការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញកម្ពុជា ត្រូវធ្វើតាមរយៈសមាគមសម្គាល់ភូមិសាស្ត្រទំនិញ ។ អ្នកដាក់ពាក្យស្នើសុំ គឺជាម្ចាស់សិទ្ធិលើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្រោយការចុះបញ្ជី ។

ក្រុមផលិតករ ប្រតិបត្តិករ ស្ថាប័ន និង/ឬបុគ្គលពាក់ព័ន្ធ ដែលមានបំណងចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញកម្ពុជា ត្រូវរៀបចំបង្កើតជាសមាគមសម្គាល់ភូមិសាស្ត្រទំនិញ ដោយផ្អែកលើតំបន់ភូមិ-សាស្ត្រ និងមុខទំនិញមួយ ហើយត្រូវមានលក្ខន្តិកៈដើម្បីគ្រប់គ្រង និងចាត់ចែងការងាររបស់ខ្លួនក្នុងគោលដៅមិនរកប្រាក់ចំណេញ ។ សមាជិកភាពរបស់សមាគមត្រូវមានលក្ខណៈបើកចំហ ។ សមាគមសម្គាល់ភូមិសាស្ត្រទំនិញត្រូវមានការទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ច ។ លក្ខន្តិកៈរបស់សមាគមត្រូវយកមកតម្កល់នៅក្រសួងពាណិជ្ជកម្ម ។ សមាគមត្រូវធានាឲ្យសមាជិករបស់ខ្លួនអនុវត្តតាមសៀវភៅបន្ទុកនិងកាតព្វកិច្ចផ្សេងៗទៀតដែលកំណត់ដោយច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

### មាត្រា ៨.- ការដាក់ពាក្យស្នើសុំចុះបញ្ជី

ពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវដាក់នៅក្រសួងពាណិជ្ជកម្ម ដោយភ្ជាប់មកជាមួយនូវសៀវភៅបន្ទុកនិងសំណុំឯកសារពាក់ព័ន្ធ ។ ទម្រង់បែបបទនៃការដាក់ពាក្យស្នើសុំគំរូសៀវភៅបន្ទុក និងសំណុំឯកសារពាក់ព័ន្ធសម្រាប់ការចុះបញ្ជីត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

## ផ្នែកទី ២
## នីតិវិធីនៃការពិនិត្យពាក្យស្នើសុំ

### មាត្រា ៩.- ការពិនិត្យពាក្យស្នើសុំចុះបញ្ជី

ក្រសួងពាណិជ្ជកម្មត្រូវពិនិត្យពាក្យស្នើសុំនិងត្រូវឆ្លើយតបក្នុងរយៈពេលយ៉ាងយូរ ៤៥ (សែសិបប្រាំ) ថ្ងៃគិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ ។

បន្ទាប់ពីបានពិនិត្យឃើញថា ពាក្យស្នើសុំបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌដែលបានកំណត់ ក្រសួងពាណិជ្ជកម្មត្រូវចេញលិខិតទទួលស្គាល់ការដាក់ពាក្យស្នើសុំនោះជាផ្លូវការ ។

ក្នុងករណីពិនិត្យឃើញថាពាក្យស្នើសុំមិនបានបំពេញគ្រប់គ្រាន់តាមលក្ខខណ្ឌដែលបានកំណត់ ក្រសួងពាណិជ្ជកម្មត្រូវចេញលិខិតឲ្យអ្នកដាក់ពាក្យស្នើសុំដើម្បីធ្វើការបំពេញបន្ថែម ឬកែតម្រូវដោយបញ្ជាក់ពីចំណុចខ្វះខាត ។ អ្នកដាក់ពាក្យស្នើសុំអាចធ្វើការបំពេញបន្ថែមឬកែតម្រូវពាក្យស្នើសុំក្នុងរយៈពេល ០៦(ប្រាំមួយ)ខែគិតចាប់ពីថ្ងៃចេញលិខិត ។ ពាក្យស្នើសុំចុះបញ្ជីនោះត្រូវចាត់ទុកថាបានបោះបង់ចោលប្រសិនបើគ្មានការបំពេញបន្ថែមឬការកែតម្រូវ ឬមិនបានផ្តល់នូវការឆ្លើយតបឬការពន្យល់ជាវិជ្ជមានក្នុងរយៈពេលដែលបានកំណត់ខាងលើ ។ក្រសួងពាណិជ្ជកម្មអាចពន្យារពេលបន្ថែម០៦ (ប្រាំមួយ)ខែទៀតសម្រាប់ការកែតម្រូវពាក្យស្នើសុំ ប្រសិនបើមានសំណូមពរសមហេតុផលពីអ្នកដាក់ពាក្យស្នើសុំ ។

ក្រសួងពាណិជ្ជកម្មត្រូវពិនិត្យឯកសារបំពេញបន្ថែមឬឯកសារកែតម្រូវនេះ និងត្រូវឆ្លើយតបក្នុងរយៈពេលយ៉ាងយូរ ៤៥ (សែសិបប្រាំ)ថ្ងៃគិតចាប់ពីថ្ងៃទទួលឯកសារបំពេញបន្ថែម ឬឯកសារកែតម្រូវនេះ ។

## មាត្រា ១០.- ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលមិនអាចចុះបញ្ជីបាន

ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញមិនអាចចុះបញ្ជីបាន ប្រសិនបើ៖

ក-ម៉ាកនោះផ្ទុយនឹងច្បាប់ បទប្បញ្ញត្តិ តម្លៃសីលធម៌សង្គមសាសនាប្រពៃណីល្អរបស់ជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ ។

ខ-ម៉ាកនោះធ្វើឲ្យសាធារណជនយល់ខុសឬភាន់ច្រឡំពីចរិតលក្ខណៈ ដូចជាប្រភេទ គុណភាព ទីកន្លែងនៃប្រភពដើមដំណើរការផលិតឬការប្រើប្រាស់ ។

គ-ម៉ាកនោះត្រូវបានគេប្រើប្រាស់ជាឈ្មោះពូជដំណាំឬពូជសត្វ ។

ឃ-ម៉ាកនោះជានាមទូទៅ ។

## មាត្រា ១១.- ការត្រួតពិនិត្យខ្លឹមសារពាក្យស្នើសុំចុះបញ្ជី

ក្រសួងពាណិជ្ជកម្មត្រូវត្រួតពិនិត្យខ្លឹមសារនៃពាក្យស្នើសុំលើចំណុចសំខាន់ៗដូចខាងក្រោម៖

១- ភាពត្រឹមត្រូវនៃព័ត៌មានលម្អិតក្នុងពាក្យស្នើសុំដូចមានចែងក្នុងមាត្រា ៧ និងមាត្រា ៨ នៃច្បាប់នេះ ។

២- ចំណុចទាំងឡាយដូចមានចែងក្នុងមាត្រា ៤ ត្រង់ចំណុចនិយមន័យ លើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងមាត្រា ១០ នៃច្បាប់នេះ ។

៣- ភាពជាក់ស្តែងនៅមូលដ្ឋានផលិតកម្ម ចំពោះម៉ាតសម្គាល់ភូមិសាស្ត្រទំនិញកម្ពុជា ។

៤- ចំពោះម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដែលមានសូរសំឡេងដូចគ្នា ត្រូវអនុវត្តតាមលក្ខខណ្ឌដែលកំណត់ដោយក្រសួងពាណិជ្ជកម្ម ។

ក្នុងការត្រួតពិនិត្យខ្លឹមសារនៃពាក្យស្នើសុំ ក្រសួងពាណិជ្ជកម្មអាចអញ្ជើញអ្នកដាក់ពាក្យស្នើសុំឬបុគ្គលដែលមានការពាក់ព័ន្ធមកពន្យល់ ឬផ្តល់ភស្តុតាងបន្ថែម ។ ក្នុងករណីចាំបាច់ក្រសួងពាណិជ្ជកម្ម

អាចស្នើសុំមតិពីអ្នកជំនាញក្នុងវិស័យពាក់ព័ន្ធដើម្បីធ្វើការពិនិត្យពិចារណានិងសម្រេច ។

**មាត្រា ១២.- ការចុះបញ្ជីនិងការបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រផ្លូវការ**

ក្រសួងពាណិជ្ជកម្មត្រូវចុះបញ្ជី និងចេញវិញ្ញាបនបត្រជូនដល់អ្នកដាក់ពាក្យស្នើសុំ ក្រោយពីបានពិនិត្យឃើញថាពាក្យស្នើសុំត្រូវបានបំពេញស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

បន្ទាប់ពីបានចុះបញ្ជី ក្រសួងពាណិជ្ជកម្មត្រូវបោះពុម្ពផ្សាយការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្នុងព្រឹត្តិបត្រផ្លូវការ ដើម្បីទុកលទ្ធភាពឲ្យភាគីមានផលប្រយោជន៍ធ្វើការប្តឹងជំទាស់ទៅនឹងការចុះបញ្ជី ។

**មាត្រា ១៣.- ការកែតម្រូវលើការកត់ត្រា**

ក្រសួងពាណិជ្ជកម្ម អាចកែតម្រូវកំហុសផ្សេងៗក្នុងកំណត់ត្រាដែលបានធ្វើឡើងដោយអនុលោមតាមច្បាប់នេះឬបទប្បញ្ញត្តិដែលពាក់ព័ន្ធ ។

**មាត្រា ១៤.- រូបសញ្ញាជាតិសម្រាប់បញ្ជាក់លើទំនិញសម្គាល់ភូមិសាស្ត្រ**

ក្រសួងពាណិជ្ជកម្ម ត្រូវរៀបចំបង្កើតរូបសញ្ញាជាតិមួយសម្រាប់បញ្ជាក់លើគ្រប់មុខទំនិញសម្គាល់ភូមិសាស្ត្រដែលបានចុះបញ្ជីរួចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៣
## បណ្តឹងជំទាស់

**មាត្រា ១៥.- រយៈពេលបណ្តឹងជំទាស់**

ភាគីដែលមានការពាក់ព័ន្ធអាចប្តឹងជំទាស់នឹងការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញទៅក្រសួងពាណិជ្ជកម្មក្នុងរយៈពេល ៩០ (កៅសិប)ថ្ងៃគិតចាប់ពីកាលបរិច្ឆេទនៃការបោះពុម្ពផ្សាយការចុះបញ្ជីដូចមានចែងក្នុងមាត្រា ១២ នៃច្បាប់នេះ ។

**មាត្រា ១៦.- លក្ខខណ្ឌបណ្តឹងជំទាស់**

បណ្តឹងជំទាស់ចំពោះការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវមានមូលដ្ឋានណាមួយ ដូចខាងក្រោម ៖

ក-មិនស្របតាមមាត្រា ៤ ត្រង់ចំណុចនិយមន័យលើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនៃច្បាប់នេះ ។

ខ-ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលបានចុះបញ្ជីនោះ ជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលមិនអាចចុះបញ្ជីបានដូចមានចែងក្នុងមាត្រា ១០ នៃច្បាប់នេះ និងបទប្បញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធ ។

## មាត្រា ១៧.- នីតិវិធីបណ្ដឹងជំទាស់

ក្រសួងពាណិជ្ជកម្មត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីបណ្ដឹងជំទាស់ដល់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ។ អ្នកដាក់ពាក្យស្នើសុំមានរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃគិតចាប់ពីកាលបរិច្ឆេទជូនដំណឹងដើម្បីធ្វើសេចក្ដីថ្លែងតប ។ ក្រសួងពាណិជ្ជកម្មអាចពន្យារពេល ៤៥ (សែសិបប្រាំ) ថ្ងៃទៀត ប្រសិនបើមានសំណូមពរពីអ្នកស្នើសុំ ។

ក្រសួងពាណិជ្ជកម្មត្រូវជូនដំណឹងពីសេចក្ដីសម្រេចរបស់ខ្លួន ដោយមានបញ្ជាក់ពីហេតុផលសមស្របទៅអ្នកដាក់ពាក្យស្នើសុំនិងអ្នកបណ្ដឹងជំទាស់ ។

អ្នកដាក់ពាក្យស្នើសុំ និង/ឬអ្នកបណ្ដឹងជំទាស់អាចប្ដឹងតវ៉ានឹងសេចក្ដីសម្រេចរបស់ក្រសួងពាណិជ្ជកម្មស្របតាមមាត្រា ១៨ នៃច្បាប់នេះ ។

ក្នុងករណីចាំបាច់ឬតាមការស្នើសុំពីភាគីណាមួយ ក្រសួងពាណិជ្ជកម្មត្រូវរៀបចំឲ្យមានសវនាការលើបណ្ដឹងជំទាស់ ។

សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ត្រូវបោះពុម្ពផ្សាយនៅក្នុងព្រឹត្តិបត្រផ្លូវការ ។

នីតិវិធីលម្អិតនៃបណ្ដឹងជំទាស់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

### ជំពូកទី ៤
### បណ្ដឹងតវ៉ា

## មាត្រា ១៨.- សិទ្ធិនិងរយៈពេលនៃបណ្ដឹងតវ៉ា

បុគ្គលដែលពាក់ព័ន្ធអាចប្ដឹងតវ៉ានឹងសេចក្ដីសម្រេចរបស់ក្រសួងពាណិជ្ជកម្មទៅក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញឬទៅតុលាការមានសមត្ថកិច្ច ។

បុគ្គលដែលពាក់ព័ន្ធអាចប្ដឹងតវ៉ា នឹងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញទៅតុលាការមានសមត្ថកិច្ច ។

បណ្ដឹងតវ៉ាត្រូវធ្វើឡើងក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃគិតចាប់ពីថ្ងៃដែលបានទទួលដំណឹងពីសេចក្ដីសម្រេច ។

សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញលើបណ្ដឹងតវ៉ា ត្រូវបោះពុម្ពផ្សាយនៅក្នុងព្រឹត្តិបត្រផ្លូវការនិងផ្សព្វផ្សាយជាសាធារណៈ ។

### ជំពូកទី ៥
### ការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស

## មាត្រា ១៩.- លក្ខខណ្ឌនៃការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស

ការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេសអាចធ្វើទៅបាន លុះត្រាតែម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនោះបានចុះបញ្ជីស្របតាមបទប្បញ្ញត្តិនានាក្នុងប្រទេសដើមរួចហើយ ។



៤

ក្រសួងពាណិជ្ជកម្មមិនអនុញ្ញាតឲ្យចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ចំពោះម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេសណាដែលមិនបានទទួលកិច្ចការពារ ឬត្រូវបានបញ្ឈប់កិច្ចការពារ ឬត្រូវបានឈប់ប្រើប្រាស់ក្នុងប្រទេសដើមរបស់ខ្លួន ។

ក្រសួងពាណិជ្ជកម្មអាចចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេសបាន លុះត្រាតែការដាក់ពាក្យស្នើសុំនោះធ្វើឡើងដោយតំណាងស្របច្បាប់ ឬតំណាងរដ្ឋបាល ឬអាជ្ញាធរបរទេសនៃប្រទេសនោះ តាមរយៈភ្នាក់ងារតំណាងស្របច្បាប់ដូចចែងក្នុងជំពូកទី ១១ នៃច្បាប់នេះ ។

## មាត្រា ២០.- នីតិវិធីចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស

ពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស ត្រូវដាក់នៅក្រសួងពាណិជ្ជកម្ម ។

នីតិវិធីនៃការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស ត្រូវអនុវត្តតាមបទប្បញ្ញត្តិដែលមានចែងក្នុងមាត្រា ៧ មាត្រា ៨ មាត្រា ៩ មាត្រា ១០ មាត្រា ១១ មាត្រា ១២ និងមាត្រា ១៣ នៃច្បាប់នេះ ។

ក្រោយពេលដាក់ពាក្យក្រសួងពាណិជ្ជកម្មមានសិទ្ធិតម្រូវឲ្យអ្នកដាក់ពាក្យស្នើសុំ បញ្ជូនរាល់ព័ត៌មានផ្សេងទៀតទាក់ទងនឹងការចុះបញ្ជីនៅបរទេស ដែលអាចជាមូលដ្ឋានសម្រាប់ការចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## មាត្រា ២១.- បណ្តឹងជំទាស់និងបណ្តឹងតវ៉ាចំពោះម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស

បទប្បញ្ញត្តិស្តីពីរយៈពេល លក្ខខណ្ឌ នីតិវិធីបណ្តឹងជំទាស់ និងនីតិវិធីបណ្តឹងតវ៉ានៃច្បាប់នេះ ត្រូវយកមកអនុវត្តចំពោះម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស ។

# ជំពូកទី ៦
# អានុភាពនៃការចុះបញ្ជី

## មាត្រា ២២.- សិទ្ធិដែលទទួលបានពីការចុះបញ្ជី

នៅពេលដែលម៉ាកសម្គាល់ភូមិសាស្ត្រទំនិញមួយត្រូវបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មស្របតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ សមាជិកសមាគមសម្គាល់ភូមិសាស្ត្រទំនិញដែលជាផលិតករ និង/ឬប្រតិបត្តិករដែលអនុវត្តស្របតាមសៀវភៅបន្ទុក មានសិទ្ធិប្រើប្រាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនោះ ។ សិទ្ធិប្រើប្រាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញមិនអាចផ្ទេរបានឡើយ ។

ម្ចាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញមានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ច ចំពោះបុគ្គលណាម្នាក់ដែលបានប្រើប្រាស់ដោយរំលោភនូវម៉ាកសម្គាល់ភូមិសាស្ត្រទំនិញរបស់ខ្លួន ដោយគ្មានការយល់ព្រមពីម្ចាស់នោះ ហើយក៏មានសិទ្ធិប្តឹងចំពោះសមាជិកណាម្នាក់នៃសមាគមសម្គាល់ភូមិសាស្ត្រទំនិញដែលបានប្រើប្រាស់ដោយរំលោភនូវម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •



៤

នេះ នៅលើទំនិញដែលចេញមកពីតំបន់ភូមិសាស្ត្រផ្សេងៗទៀតផងដែរ ។

សិទ្ធិដែលទទួលបានតាមរយៈការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ មិនរាប់បញ្ចូលនូវការដាក់លក់ទំនិញនៅលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ដោយម្ចាស់សិទ្ធិដែលបានចុះបញ្ជី ឬដោយមានការយល់ព្រមពីម្ចាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនោះទេ ។

## មាត្រា ២៣.- កិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញកម្ពុជានិងបរទេស

ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញកម្ពុជានិងបរទេស ដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានការពារទល់នឹង ៖

ក-ការប្រើប្រាស់មិនត្រឹមត្រូវក្នុងគោលបំណងពាណិជ្ជកម្មដោយផ្ទាល់ ឬដោយប្រយោលនូវម៉ាកសម្គាល់ភូមិសាស្ត្រដែលបានចុះបញ្ជីរួចហើយ ចំពោះទំនិញដែលដូចគ្នាឬទំនិញដែលអាចប្រៀបធៀបបានទៅនឹងទំនិញដែលបានចុះបញ្ជីដើម្បីឲ្យការប្រើប្រាស់នោះទទួលផលប្រយោជន៍ ឬអាចនឹងទទួលផលប្រយោជន៍ពីកេរ្តិ៍ឈ្មោះរបស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ។

ខ-ការប្រើប្រាស់ដោយគ្មានការអនុញ្ញាត ការធ្វើត្រាប់តាម ការធ្វើឲ្យនឹកគិតទៅដល់ ឬការបកប្រែម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ទោះបីប្រភពពិតប្រាកដនៃទំនិញត្រូវបានអមដោយពាក្យដូចជា "ស្ទីល" "យថាប្រភេទ" "ប្រភេទ" "វិធីសាស្ត្រ" "របៀប" "ត្រាប់តាម" ឬការបកប្រែនៃពាក្យទាំងនេះ ឬពាក្យប្រហាក់ប្រហែលធ្វើឲ្យសាធារណជនភាន់ច្រឡំក៏ដោយ ។

គ-ការក្លែងបន្លំ ឬការធ្វើឲ្យភាន់ច្រឡំអំពីប្រភពដើម ប្រភេទ ឬគុណភាពពិសេសនៃទំនិញដែលបង្ហាញលើសំបកវេចខ្ចប់គ្រប់ប្រភេទ ឬលើឯកសារផ្សាយពាណិជ្ជកម្ម ឬលើឯកសារផ្សេងទៀតដែលទាក់ទងនឹងទំនិញ ដែលអាចនាំឲ្យមានការយល់ខុសអំពីប្រភពដើមរបស់ផលិតផល ។

ឃ-ការអនុវត្តផ្សេងៗទៀតដែលអាចធ្វើឲ្យសាធារណជនទូទៅភាន់ច្រឡំអំពីប្រភព ដើមពិតប្រាកដនៃទំនិញ។

## មាត្រា ២៤.- រយៈពេលនៃកិច្ចការពារ

ការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវមានសុពលភាពចាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំចុះបញ្ជីប្រសិនបើគ្មានការលុបឬមោឃភាព ស្របតាមច្បាប់នេះ។

## មាត្រា ២៥.- ការទទួលស្គាល់ការចុះបញ្ជី

ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដែលបានចុះបញ្ជីត្រឹមត្រូវរួចហើយមុនច្បាប់នេះចូលជាធរមាន ត្រូវមានសុពលភាពបន្ត ។

## ជំពូកទី៧
## ការត្រួតពិនិត្យអនុលោមភាពនៃសៀវភៅបន្ទុក
## ក្នុងការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

### មាត្រា ២៦.- ការត្រួតពិនិត្យអនុលោមភាព

អ្នកដាក់ពាក្យស្នើសុំអាចជ្រើសរើសអង្គភាពចេញវិញ្ញាបនបត្រឬអង្គភាពត្រួតពិនិត្យដែលមានការចុះបញ្ជីស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជានិងមានការទទួលស្គាល់ពីក្រសួងពាណិជ្ជកម្ម ។ អង្គភាពចេញវិញ្ញាបនបត្រ ឬអង្គភាពត្រួតពិនិត្យជាអាជ្ញាធរសាធារណៈមានសមត្ថកិច្ចឬអង្គភាពឯកជនដែលទទួលស្គាល់ជាផ្លូវការដោយអង្គការស្តង់ដាអន្តរជាតិ ឬស្ថាប័នណាមួយដែលមានប្រព័ន្ធត្រួតពិនិត្យអាចជឿជាក់បាន ។

ក្នុងការត្រួតពិនិត្យក្រោយការចុះបញ្ជីក្រសួងពាណិជ្ជកម្មអាចអញ្ជើញម្ចាស់សិទ្ធិ ឬបុគ្គលដែលមានការពាក់ព័ន្ធមកផ្តល់ការពន្យល់ឬផ្តល់ភស្តុតាងបន្ថែម ។ ក្នុងករណីចាំបាច់ក្រសួងពាណិជ្ជកម្មអាចស្នើសុំមតិពីអ្នកជំនាញក្នុងវិស័យពាក់ព័ន្ធដើម្បីធ្វើការពិនិត្យពិចារណានិងសម្រេច ។

អង្គភាពចេញវិញ្ញាបនបត្រឬអង្គភាពត្រួតពិនិត្យត្រូវផ្ទៀងផ្ទាត់អនុលោមភាពរបស់ទំនិញសម្គាល់ភូមិសាស្ត្រជាមួយនឹងសៀវភៅបន្ទុក ។ អង្គភាពចេញវិញ្ញាបនបត្រ ឬអង្គភាពត្រួតពិនិត្យត្រូវផ្ញើរបាយការណ៍ប្រចាំឆ្នាំជូនក្រសួងពាណិជ្ជកម្មជារៀងរាល់ឆ្នាំដោយរាប់បញ្ចូលនូវបញ្ជីឈ្មោះផលិតករប្រតិបត្តិករផលិតផលបរិមាណដែលខ្លួនបានបញ្ជាក់ទទួលស្គាល់និងវិធានការដែលបានដាក់ ចេញប្រសិនបើមាន ។ ក្រសួងពាណិជ្ជកម្មជាអ្នកកំណត់កាលបរិច្ឆេទនៃការផ្តល់របាយការណ៍ ដោយផ្អែកតាមវដ្តវប្រមូលផល ឬចុងការិយបរិច្ឆេទ ។ ចំពោះឯកសារក្រៅពីភាសាខ្មែរត្រូវភ្ជាប់មកជាមួយនូវការបកប្រែជាភាសាខ្មែរដោយមានការបញ្ជាក់ពីភាពត្រឹមត្រូវ ។

ក្នុងករណីដែលផលិតករ ឬប្រតិបត្តិករណាមួយ ឬច្រើន មិនបានបំពេញតាមលក្ខខណ្ឌនៅក្នុងសៀវភៅបន្ទុក អង្គភាពចេញវិញ្ញាបនបត្រ ឬអង្គភាពត្រួតពិនិត្យត្រូវរាយការណ៍ជូនក្រសួងពាណិជ្ជកម្មដើម្បីដាក់ចេញនូវវិធានការសមស្របដូចខាងក្រោម៖

១-ធ្វើការកត់សម្គាល់កំហុសនិងណែនាំ ។

២-ព្រមាន ។

៣-បដិសេធមិនទទួលស្គាល់ឡូត៍ណាមួយនៃផលិតផល ។

៤-មិនទទួលស្គាល់សិទ្ធិនៃការប្រើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញជាបណ្តោះអាសន្ន ។

៥-ហាមឃាត់ជាស្ថាពរការប្រើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ។

សមាគមសម្គាល់ភូមិសាស្ត្រទំនិញត្រូវអនុវត្តតាមការសម្រេចរបស់ក្រសួងពាណិជ្ជកម្ម ។

សមាគមសម្គាល់ភូមិសាស្ត្រទំនិញត្រូវរាយការណ៍ជូនក្រសួងពាណិជ្ជកម្ម ចំពោះការអនុវត្តតាមវិធានការរបស់ក្រសួង ។



៥

**មាត្រា ២៧.- ប្រសិទ្ធភាពរបស់អង្គភាពចេញវិញ្ញាបនបត្របញ្ជាក់ពីអនុលោមភាព**

ក្រសួងពាណិជ្ជកម្ម ត្រូវពិនិត្យមើលពីប្រសិទ្ធភាពរបស់អង្គភាពដែលចេញវិញ្ញាបនបត្រ ឬអង្គភាពត្រួតពិនិត្យ ។ ក្នុងករណីគ្មានប្រសិទ្ធភាព ក្រសួងពាណិជ្ជកម្ម មានអំណាចបដិសេធជាលាយលក្ខណ៍អក្សរ ដោយមានសំអាងហេតុចំពោះអង្គភាពដែលចេញវិញ្ញាបនបត្រ ឬអង្គភាពត្រួតពិនិត្យនិងអាចឲ្យអ្នកដាក់ពាក្យស្នើសុំជ្រើសរើសអង្គភាពចេញវិញ្ញាបនបត្រឬអង្គភាពត្រួតពិនិត្យថ្មី ។

ក្នុងករណីចាំបាច់ ក្រសួងពាណិជ្ជកម្មអាចកំណត់បទប្បញ្ញត្តិបន្ថែមសម្រាប់ការត្រួតពិនិត្យក្រោយការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ។

## ជំពូកទី៨
## ការកែសម្រួល មោឃភាព និងការលុបម៉ាក
## សម្គាល់ភូមិសាស្ត្រទំនិញចេញពីបញ្ជី

**មាត្រា ២៨.- ការកែសម្រួល**

ក្រោយការចុះបញ្ជី ម្ចាស់សិទ្ធិអាចស្នើសុំធ្វើការកែសម្រួលសៀវភៅបន្ទុកបាន ជាពិសេសលើចំណុចដែលទាក់ទងនឹងការវិវត្តចំណេះដឹងបច្ចេកទេស និងវិទ្យាសាស្ត្រនិងការកំណត់ព្រំដែនភូមិសាស្ត្រជាដើម ។

បុគ្គលដែលមានការពាក់ព័ន្ធអាចស្នើទៅក្រសួងពាណិជ្ជកម្ម ដើម្បីធ្វើការកែសម្រួលការចុះបញ្ជី និង/ឬសៀវភៅបន្ទុកបាន ។

ការកែសម្រួលសៀវភៅបន្ទុកអាចធ្វើទៅបាន លុះត្រាតែមិនប៉ះពាល់ដល់ចំណុចជាសារវន្តនៃការសម្រេចក្នុងការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ។

**មាត្រា ២៩.- មូលដ្ឋាននៃការធ្វើមោឃភាព និងការលុបម៉ាកសម្គាល់ភូមិសាស្ត្រទំនិញចេញពីបញ្ជី**

បុគ្គលដែលមានការពាក់ព័ន្ធអាចបញ្ជូនសេចក្តីសង្កេតទៅក្រសួងពាណិជ្ជកម្ម ដើម្បីធ្វើការណែនាំផល់សមាគម ។

បុគ្គលដែលមានការពាក់ព័ន្ធអាចស្នើសុំទៅក្រសួងពាណិជ្ជកម្មឲ្យផ្តល់មោឃភាព ឬលុបចោលការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបាន ។

ក្រសួងពាណិជ្ជកម្មអាចចាត់ទុកការចុះបញ្ជីជាមោឃៈប្រសិនបើ៖

១- មានលក្ខខណ្ឌណាមួយនៃមាត្រា ៤ ត្រង់ចំណុចនិយមន័យលើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ មាត្រា ៧ និង មាត្រា ១០ នៃច្បាប់នេះមិនត្រូវបានបំពេញ ។

២- ជឿជាក់ដោយផ្អែកលើភស្តុតាងដែលបង្ហាញថា ម្ចាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលបានចុះបញ្ជីរួចហើយ មិនមែនជាម្ចាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញស្របច្បាប់ ។

ក្រសួងពាណិជ្ជកម្មមានសិទ្ធិលុបម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលបានចុះបញ្ជីរួច ក្នុងករណីដែល៖

១-ម្ចាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលបានចុះបញ្ជីរួចហើយ ស្នើសុំលុប ។

២-ទំនិញសម្គាល់ភូមិសាស្ត្រដែលបានចុះបញ្ជីរួចហើយ បានបាត់បង់លក្ខណសម្បត្តិពិសេសជាទំនិញសម្គាល់ភូមិសាស្ត្រ ។

៣-ម្ចាស់សិទ្ធិមិនគោរព និងមិនអនុវត្តតាមលក្ខខណ្ឌនានាដូចមានចែងក្នុងពាក្យស្នើសុំ ។

៤-ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេសដែលមិនបានការពារ ឬបញ្ឈប់កិច្ចការពារឬមិនបានប្រើប្រាស់បន្តបន្ទាប់នៅក្នុងប្រទេសដើម ។

៥-អាសយដ្ឋានទំនាក់ទំនងក្នុងព្រះរាជាណាចក្រកម្ពុជារបស់ម្ចាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញមិនអាចទាក់ទងបានយ៉ាងតិចចំនួនបីដងតាមគ្រប់មធ្យោបាយក្នុងរយៈពេលបីខែ ។

៦-ម្ចាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលបានចុះបញ្ជីរួចហើយ មិនគោរពតាមលក្ខខណ្ឌនៃការតម្រូវឲ្យផ្តល់ឯកសារគាំទ្រ ដូចមានចែងក្នុងមាត្រា ១៧ នៃច្បាប់នេះ ។

៧-ម្ចាស់សិទ្ធិអនុវត្តផ្ទុយនឹងច្បាប់ និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ។

## មាត្រា ៣០.- អានុភាពនៃមោឃភាពនិងការលុបការចុះបញ្ជី

ក្រសួងពាណិជ្ជកម្មត្រូវពិនិត្យលើសេចក្តីសង្កេតសំណើសុំមោឃភាព ឬសំណើសុំលុបដោយពិនិត្យកស្តុតាងជាក់ស្តែងនិងវាយតម្លៃដើម្បីឈានដល់ការសម្រេចតម្កល់ កែតម្រូវឬលុបម៉ាកសម្គាល់ភូមិសាស្ត្រទំនិញចេញពីបញ្ជីស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

នីតិវិធីនៃការសម្រេចតម្កល់កែតម្រូវ ឬលុបម៉ាកសម្គាល់ភូមិសាស្ត្រទំនិញចេញពីបញ្ជីត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

មោឃភាពនៃការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវមានអានុភាពចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជី ។

ការលុបម៉ាកសម្គាល់ភូមិសាស្ត្រទំនិញត្រូវមានអានុភាពចាប់ពីកាលបរិច្ឆេទនៃការចេញសេចក្តីសម្រេច ។

រាល់ការធ្វើមោឃភាពនិងការលុបម៉ាកសម្គាល់ភូមិសាស្ត្រទំនិញត្រូវកត់ត្រា និងបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រផ្លូវការនិងផ្សព្វផ្សាយជាសាធារណៈភ្លាម ។

# ជំពូកទី៩

# ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងការទទួលស្គាល់ឬការបដិសេធម៉ាក

## មាត្រា ៣១.- ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនិងម៉ាក

ក្រសួងពាណិជ្ជកម្មត្រូវបដិសេធការស្នើសុំចុះបញ្ជីម៉ាកណាដែលដូច ឬប្រហាក់ប្រហែលធ្វើឲ្យកាន់ច្រឡំនឹងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលបានដាក់ពាក្យមុនកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកនេះ ចំពោះទំនិញដូចគ្នាដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះ ។

នៅពេលដែលម៉ាកសម្គាល់ភូមិសាស្ត្រទំនិញត្រូវបានចុះបញ្ជីស្របតាមច្បាប់នេះរួចជាស្ថាពរការស្នើសុំចុះបញ្ជីម៉ាកដែលស្របគ្នានឹងស្ថានភាពណាមួយក្នុងមាត្រា ២៣ នៃច្បាប់នេះហើយដែលទាក់ទងនឹងប្រភេទទំនិញដូចគ្នា ត្រូវបានបដិសេធ ។

ក្រសួងពាណិជ្ជកម្មត្រូវបដិសេធការស្នើសុំចុះបញ្ជីម៉ាកសាជាថ្មី ប្រសិនបើការស្នើសុំនោះរំលោភលើបទប្បញ្ញត្តិទាំងឡាយដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះ ។ សេចក្តីសម្រេចបដិសេធនេះត្រូវធ្វើដោយក្រសួងពាណិជ្ជកម្មដោយខ្លួនឯងឬដោយមានសំណើពីបុគ្គលដែលពាក់ព័ន្ធ ។

ការប្រើប្រាស់ម៉ាកដែលពាក់ព័ន្ធនឹងចំណុចណាមួយនៃមាត្រា ២៣ នៃច្បាប់នេះ ដែលបានចុះបញ្ជីម៉ាកដោយសុចរិតរួចហើយ មុនកាលបរិច្ឆេទនៃកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ឬមុនកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចអនុញ្ញាតឲ្យបន្តប្រើប្រាស់ម៉ាកនោះបាន ប្រសិនបើគ្មានមូលដ្ឋានចាត់ទុកជាមោឃៈ ។

## ជំពូកទី១០
## វិធានការបណ្តោះអាសន្ននិងវិធានការតាមមាត់ច្រកព្រំដែន

### មាត្រា ៣២ .- ការអនុវត្តវិធានការបណ្តោះអាសន្ននិងវិធានការតាមមាត់ច្រកព្រំដែន

បទប្បញ្ញត្តិទាំងឡាយស្តីពីវិធានការបណ្តោះអាសន្ន និងវិធានការតាមមាត់ច្រកព្រំដែនដែលមានចែងក្នុងច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ព្រមទាំងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងវិធានការបណ្តោះអាសន្ននិងវិធានការតាមមាត់ច្រកព្រំដែនត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ។

## ជំពូកទី១១
## ភ្នាក់ងារ

### មាត្រា ៣៣.- ភ្នាក់ងារតំណាង

ក្នុងករណីដែលលំនៅឋានអចិន្ត្រៃយ៍ឬទីតាំងប្រកបអាជីវកម្មសំខាន់របស់អ្នកដាក់ពាក្យស្នើសុំស្ថិតនៅក្រៅព្រះរាជាណាចក្រកម្ពុជាអ្នកដាក់ពាក្យស្នើសុំនោះ ត្រូវមានតំណាងជាភ្នាក់ងារដែលមានលំនៅឋាននិងកំពុងប្រកបវិជ្ជាជីវៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

### មាត្រា ៣៤.- លក្ខណសម្បត្តិ

អ្នកតំណាងដែលជាភ្នាក់ងារក្នុងការដាក់ពាក្យសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដូចមានចែងក្នុងប្រកាសស្តីពីភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជារបស់ក្រសួងពាណិជ្ជកម្ម ។

ROYAUME DU CAMBODGE · SECRETARIAT DU PALAIS ROYAL

## ជំពូកទី១២
## បទបញ្ជានិងសេចក្ដីណែនាំរដ្ឋបាល

**មាត្រា ៣៥.- បទបញ្ជាអនុវត្តន៍**

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មត្រូវចេញបទបញ្ជាចាំបាច់ណែនាំលម្អិតអំពីការអនុវត្តច្បាប់នេះ។

អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញត្រូវបង់កម្រៃរដ្ឋបាលក្នុងការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនិងកម្រៃពាក់ព័ន្ធនានា ដែលត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

## ជំពូកទី១៣
## ការអនុវត្តសន្ធិសញ្ញាអន្តរជាតិនិងការបកស្រាយ

**មាត្រា ៣៦.- ការអនុវត្ត**

បទប្បញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញាអន្តរជាតិអំពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីមួយនៃសន្ធិសញ្ញានោះត្រូវយកមកអនុវត្តជាមួយនឹងច្បាប់នេះបានផងដែរ ។

ក្នុងករណីមានទំនាស់ជាមួយនឹងមាត្រាទាំងឡាយនៃច្បាប់នេះបទប្បញ្ញត្តិនៃសន្ធិសញ្ញាអន្តរជាតិទាំងនោះត្រូវចាត់ទុកជាបទប្បញ្ញត្តិគោល ។

## ជំពូកទី១៤
## ការឃាត់ទុកនិងការរឹបអូស

**មាត្រា ៣៧.- ការឃាត់ទុកនិងការរឹបអូស**

តុលាការមានសមត្ថកិច្ចមានអំណាចបញ្ជាឲ្យឃាត់ទុកទំនិញ ប្រសិនបើមានការសង្ស័យថាទំនិញនោះមានការបំពានសិទ្ធិរបស់ម្ចាស់សិទ្ធិ ។

បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះ ត្រូវយកមកអនុវត្តផងដែរ ប្រសិនបើមានការសង្ស័យថាសម្ភារនិងឧបករណ៍សំខាន់ៗដែលប្រើប្រាស់ក្នុងការផលិតទំនិញនោះបំពានសិទ្ធិរបស់ម្ចាស់សិទ្ធិ ។

ទំនិញដែលមានការបំពានសិទ្ធិរបស់ម្ចាស់សិទ្ធិដែលត្រូវបាននាំចូល នាំចេញ លក់ ឬផ្ដល់សម្រាប់លក់ត្រូវរឹបអូសដោយអាជ្ញាធរមានសមត្ថកិច្ចតាមសេចក្ដីសម្រេចរបស់តុលាការ ទោះជាមាន ឬគ្មានអ្នកណាម្នាក់បានជាប់ទោសចំពោះបទល្មើសនោះក៏ដោយ ។

## ជំពូកទី១៥
## ទោសប្បញ្ញត្តិ

**មាត្រា ៣៨.- បទក្លែងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ**

ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៥(ប្រាំ)ឆ្នាំនិងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន)រៀល ទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល ចំពោះ៖

-អំពើប្រើប្រាស់មិនត្រឹមត្រូវក្នុងគោលបំណងពាណិជ្ជកម្មដោយផ្ទាល់ឬដោយប្រយោលនូវម៉ាកសម្គាល់ភូមិសាស្ត្រដែលបានចុះបញ្ជីរួចហើយ ចំពោះទំនិញដែលដូចគ្នា ឬទំនិញដែលអាចប្រៀបធៀបបានទៅនឹងទំនិញដែលបានចុះបញ្ជីរួច ដើម្បីឲ្យការប្រើប្រាស់នោះទទួលផលប្រយោជន៍ ឬអាចនឹងទទួលផលប្រយោជន៍ពីកេរ្តិ៍ឈ្មោះរបស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

-អំពើប្រើប្រាស់ដោយគ្មានការអនុញ្ញាត ការធ្វើត្រាប់តាម ការធ្វើឲ្យនឹកគិតទៅដល់ ឬការបេកប្រែម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ទោះបីជាប្រភពពិតប្រាកដនៃទំនិញត្រូវបានអមដោយពាក្យដូចជា "ស្ទីល" "យថាប្រភេទ" "ប្រភេទ" "វិធីសាស្ត្រ" "របៀប" "ត្រាប់តាម" ឬការបេកប្រែនៃពាក្យទាំងនេះឬពាក្យប្រហាក់ប្រហែលធ្វើឲ្យសាធារណជនភាន់ច្រឡំក៏ដោយ

-អំពើក្លែងបន្លំឬធ្វើឲ្យភាន់ច្រឡំអំពីប្រភពដើម ប្រភេទ ឬគុណភាពពិសេសនៃទំនិញដែលបង្ហាញលើសំបកវេចខ្ចប់គ្រប់ប្រភេទ ឬលើឯកសារផ្សាយពាណិជ្ជកម្ម ឬលើឯកសារផ្សេងទៀតដែលទាក់ទងទៅនឹងទំនិញ ដែលអាចនាំឲ្យមានការយល់ខុសពីប្រភពដើមរបស់ផលិតផល

-អំពើផ្សេងៗទៀតដែលអាចធ្វើឲ្យសាធារណជនទូទៅភាន់ច្រឡំពីប្រភពដើមពិតប្រាកដនៃទំនិញ ។

## មាត្រា ៣៩.- ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា៣៨(បទក្លែងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ)ខាងលើនេះ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០ ០០០ ០០០(ម្ភៃលាន)រៀល ទៅ ៥០ ០០០ ០០០ (ហាសិបលាន)រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើនដូចតទៅនេះ៖

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា១៧០(ការរំលាយនីតិបុគ្គលនិងការជម្រះបញ្ជីនៃនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ។

២-ការដាក់ឲ្យស្ថិតក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការតាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមព្រហ្មទណ្ឌ ។

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយឬច្រើនតាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមព្រហ្មទណ្ឌ ។

៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈតាមបែបបទកំណត់ដោយមាត្រា ១៧៣ (ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ) នៃក្រមព្រហ្មទណ្ឌ ។

៥-រឹបអូសវត្ថុឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើសតាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូសនិងសិទ្ធិតតិយជន) នៃក្រមព្រហ្មទណ្ឌ ។

៦-រឹបអូសផលទុនឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើសតាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូសនិងសិទ្ធិតតិយជន) នៃក្រមព្រហ្មទណ្ឌ ។

៧-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមព្រហ្មទណ្ឌ ។

៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមគ្រប់មធ្យោបាយតាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមព្រហ្មទណ្ឌ ។

## **ជំពូកទី១៦**
## **អន្តរប្បញ្ញត្តិ**

**មាត្រា ៤០._ អន្តរប្បញ្ញត្តិ**

បទដ្ឋានគតិយុត្តដែលនៅជាធរមាន ត្រូវបន្តអានុភាពអនុវត្តរហូតដល់មានបទដ្ឋានគតិយុត្តថ្មីមកជំនួស ។

## **ជំពូកទី១៧**
## **អវសានប្បញ្ញត្តិ**

**មាត្រា ៤១._ និរាករណ៍**

បទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀតដែលមានអានុភាពនៅពេលច្បាប់នេះ ត្រូវបានអនុវត្ត ហើយផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវចាត់ទុកជា គ្មានអានុភាពត្រឹមទំហំដែលផ្ទុយនឹងច្បាប់នេះ ចាប់ពីថ្ងៃដែលច្បាប់នេះត្រូវបានអនុវត្ត។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៤

នរោត្តម សីហមុនី

នស/រកម. ១៤០១. ០៦១

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

Chanthol Sun

**ស៊ុន ចាន់ថុល**

# ព្រះរាជក្រម

នស/រកម/០៧០១/១០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ការយល់ព្រម និងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិ ចែងអំពីការទទួលស្គាល់និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តការបរទេស ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៦ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាម លើទម្រង់ និង គតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គ លើកទី ៥ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖ ៚

# ច្បាប់

# ស្តីពី

# ការយល់ព្រមនិងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិ

# ចែងអំពីការទទួលស្គាល់និងការប្រតិបត្តិ

# សេចក្តីសម្រេចមជ្ឈត្តការបរទេស

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះចែងអំពីការយល់ព្រមនិងការអនុវត្តនូវអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការទទួលស្គាល់ និងការប្រតិបត្តិនូវសេចក្តីសម្រេចមជ្ឈត្តករបរទេសដែលបានធ្វើនៅទីក្រុងញូវយ៉ក ថ្ងៃ ១០ ខែ មិថុនា ឆ្នាំ ១៩៥៨ និងដែលបានទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៦០ ។ ច្បាប់នេះក៏កំណត់អំពីនីតិវិធីនិងសមត្ថកិច្ចនៃតុលាការព្រះរាជាណាចក្រកម្ពុជាដែរ នៅពេលមានការទទួលស្គាល់និងការប្រតិបត្តិនូវសេចក្តីសម្រេចមជ្ឈត្តករបរទេស ដោយផ្អែកលើអនុសញ្ញាទីក្រុងញូវយ៉ក ដូចមានចែងខាងលើ ។

## ជំពូកទី ២
## និយមន័យ

**មាត្រា ២.-**

សម្រាប់ការអនុវត្តនូវច្បាប់នេះ ពាក្យថា

១-សេចក្តីសម្រេចមជ្ឈត្តករបរទេសមានន័យថា សេចក្តីសម្រេចរបស់អង្គអាជ្ញាកណ្តាលមួយ ដែលបានធ្វើនៅក្នុងប្រទេសណាមួយផ្សេងពីព្រះរាជាណាចក្រកម្ពុជា ឬ នៅក្រោមនីតិវិធីនៃច្បាប់របស់ប្រទេសមួយផ្សេងពីព្រះរាជាណាចក្រកម្ពុជា ។

២-មជ្ឈត្តវិនិច្ឆ័យមានន័យថា សេចក្តីសម្រេចនៃអាជ្ញាកណ្តាលណាមួយទោះមានការគ្រប់គ្រងដោយស្ថាប័នមជ្ឈត្តករអចិន្ត្រៃយ៍ក្តី ឬ មិនមែនអចិន្ត្រៃយ៍ក្តី ។

៣-អនុសញ្ញាទីក្រុងញូវយ៉កមានន័យថាអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការទទួលស្គាល់និងការប្រតិបត្តិនូវសេចក្តីសម្រេចមជ្ឈត្តករបរទេសដែលបានធ្វើនៅទីក្រុងញូវយ៉ក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៥៨ ។

៤-សាលាឧទ្ធរណ៍មានន័យថា អង្គវិនិច្ឆ័យនៃសាលាឧទ្ធរណ៍ក្រុងភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជាដែលមានសមាសភាពចៅក្រមពេញសិទ្ធិ ៣ (បី) រូប ។

៥-តុលាការកំពូលមានន័យថា អង្គវិនិច្ឆ័យនៃតុលាការកំពូលព្រះរាជាណាចក្រកម្ពុជាដែលមានសមាសភាពចៅក្រមពេញសិទ្ធិ ៥ (ប្រាំ) រូប ។

៦-តុលាការកម្ពុជាមានន័យថា សាលាឧទ្ធរណ៍ឬតុលាការកំពូលនៃព្រះរាជាណាចក្រកម្ពុជាដែលមានសមត្ថកិច្ចដើម្បីពិនិត្យឡើងវិញ និងវិនិច្ឆ័យអំពីការទទួលស្គាល់និងការប្រតិបត្តិនូវសេចក្តីសម្រេចមជ្ឈត្តករបរទេស ។

៧-ផ្ទុយនឹងបន្ទាត់នយោបាយសាធារណៈមានន័យថា សេចក្តីសម្រេចដែលនាំឱ្យផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ។

## ជំពូកទី ៣
## សមត្ថកិច្ចនិងដែនអនុវត្ត

**មាត្រា ៣.-**

តុលាការកម្ពុជាត្រូវបានប្រគល់សមត្ថកិច្ចវិនិច្ឆ័យលើសំណើសុំការទទួលស្គាល់និងការប្រតិបត្តិនូវសេចក្តីសម្រេចរបស់មជ្ឈត្តករបរទេស ។

**មាត្រា ៤.-**

តុលាការកម្ពុជាត្រូវតែសម្រេចឱ្យស្របតាមអនុសញ្ញាទីក្រុងញូវយ៉ក ក្នុងការវិនិច្ឆ័យលើការទទួលស្គាល់និងការប្រតិបត្តិនូវសេចក្តីសម្រេចមជ្ឈត្តករបរទេស ។

**មាត្រា ៥.-**

តុលាការកម្ពុជាត្រូវទទួលពាក្យស្នើសុំពីអ្នកដាក់ពាក្យសុំឱ្យមានការទទួលស្គាល់និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស ទោះអ្នកសុំមានសញ្ជាតិអ្វីក៏ដោយ ។

**មាត្រា ៦.-**

អ្នកសុំការទទួលស្គាល់និងការប្រតិបត្តិត្រូវចាប់ផ្តើមដាក់ពាក្យសុំជាដំបូងទៅសាលាឧទ្ធរណ៍ ។ល។

## ជំពូកទី ៤
## នីតិវិធី

**មាត្រា ៧.-**

ដើម្បីទទួលបាននូវការទទួលស្គាល់និងការប្រតិបត្តិនូវសេចក្តីសម្រេចរបស់មជ្ឈត្តករបរទេសណាមួយ ភាគីដែលដាក់ពាក្យសុំការទទួលស្គាល់និងការប្រតិបត្តិត្រូវផ្តល់សំណៅដើមត្រឹមត្រូវតាមច្បាប់នៃសេចក្តីសម្រេចរបស់មជ្ឈត្តករបរទេស ឬក៏សំណៅថតចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ ហើយនិងច្បាប់ដើមនៃកិច្ចសន្យាមជ្ឈត្តវិនិច្ឆ័យដែលភាគីទាំងពីរបានធ្វើ ឬក៏សំណៅថតចម្លងនៃកិច្ចសន្យាដែលមានការបញ្ជាក់ត្រឹមត្រូវ ។ បើសិនជាសេចក្តីសម្រេចរបស់មជ្ឈត្តករបរទេសឬកិច្ចសន្យាពុំមានជាភាសាផ្លូវការរបស់ព្រះរាជាណាចក្រកម្ពុជាទេ ភាគីត្រូវតែផ្តល់ការបកប្រែដែលមានការបញ្ជាក់ត្រឹមត្រូវ ។

**មាត្រា ៨.-**

សាលាឧទ្ធរណ៍ ក្រោយពីថ្ងៃទទួលពាក្យសុំឱ្យមានការទទួលស្គាល់និងការប្រតិបត្តិត្រូវធ្វើលិខិតជូនដំណឹងអំពីបណ្តឹងនេះទៅភាគីដែលសេចក្តីសម្រេចត្រូវអនុវត្តចំពោះខ្លួនក្នុងរយៈពេល ១០ (ដប់) ថ្ងៃប្រតិទិន ក្រោយពីតុលាការបានទទួលនូវពាក្យស្នើសុំ ។

**មាត្រា ៩.-**

ភាគីដែលសេចក្តីសម្រេចត្រូវអនុវត្តចំពោះខ្លួន មានសិទ្ធិប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍កុំឱ្យទទួលស្គាល់និងកុំឱ្យប្រតិបត្តិនូវសេចក្តីសម្រេចមជ្ឈត្តករបរទេស ដោយផ្តល់នូវភស្តុតាងយ៉ាងរឹងមាំនិងនូវមូលដ្ឋានណាមួយស្របច្បាប់ ក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃប្រតិទិន ក្រោយពីសាលាឧទ្ធរណ៍បានទទួលនូវពាក្យសុំឱ្យទទួលស្គាល់និងការប្រតិបត្តិ។

**មាត្រា ១០.-**

ក្នុងករណីការប្តឹងទាស់បានធ្វើទាន់ពេលវេលា សាលាឧទ្ធរណ៍ត្រូវចេញសេចក្តីសម្រេចបញ្ជាក់លើសេចក្តីសម្រេចរបស់មជ្ឈត្តករបរទេសថា ត្រូវបានទទួលស្គាល់ឬមិនត្រូវបានទទួលស្គាល់ និងមិនត្រូវប្រតិបត្តិក្នុងរយៈពេល ៦០(ហុកសិប) ថ្ងៃប្រតិទិនចាប់ពី...

ពីថ្ងៃដែលបានទទួលពាក្យសុំកុំឱ្យទទួលស្គាល់និងកុំឱ្យប្រតិបត្តិនូវសេចក្តីសម្រេចមជ្ឈត្តករបរទេស ។

**មាត្រា ១១.-**

សាលាឧទ្ធរណ៍អាចតម្រូវឱ្យអ្នកដាក់ពាក្យជំទាស់ដាក់ប្រាក់ធានា ក្នុងទឹកប្រាក់ដែលមិនឱ្យលើសពីចំនួនទឹកប្រាក់នៃសេចក្តីសម្រេចមជ្ឈត្តករបរទេស បូកនឹងការចាំន់ស្មានកម្រៃសេវាមេធាវីនិងសោហ៊ុយផ្សេងទៀតលើការវិនិច្ឆ័យ ។ ប្រសិនបើអ្នកដាក់ពាក្យសុំជំទាស់មិនមានលទ្ធភាពដាក់ប្រាក់ធានាដូចបានចែងខាងលើទេ សាលាឧទ្ធរណ៍ត្រូវចេញបញ្ជាឃាត់ទុកជាបណ្តោះអាសន្នឬបើពុំនោះទេ កាន់កាប់ជាបណ្តោះអាសន្ននូវទ្រព្យសម្បត្តិឬទ្រព្យធនដទៃទៀតដែលជាកម្មសិទ្ធិរបស់អ្នកប្តឹងទាស់ ។

**មាត្រា ១២.-**

សាលដីកាសាលាឧទ្ធរណ៍ឬសាលដីកាតុលាការកំពូលដែលទទួលស្គាល់និងប្រតិបត្តិ ឬបដិសេធមិនទទួលស្គាល់និងមិនប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេសត្រូវចាត់ទុកថាជាសេចក្តីសម្រេចចុងក្រោយរបស់តុលាការ ហើយត្រូវអនុវត្តឱ្យស្របតាមនីតិវិធីជាធរមានស្តីពីការអនុវត្តសាលដីកា ។

**មាត្រា ១៣.-**

ក្នុងពេលរង់ចាំសេចក្តីសម្រេចចុងក្រោយពីតុលាការកម្ពុជា ភាគីណាមួយដែលពាក់ព័ន្ធលើសេចក្តីសម្រេចនៃមជ្ឈត្តករបរទេស នៅពេលណាក៏បានអាចដាក់ពាក្យតវ៉ាទៅសាលាឧទ្ធរណ៍ចាត់វិធានការបណ្តោះអាសន្ននិងដើម្បីការពារដល់សេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យរួមមានការចេញសេចក្តីសម្រេចឃាត់ឃាំងឬស្នើសុំសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិកូនបំណុលជាបណ្តោះអាសន្ន ឬទ្រព្យសម្បត្តិដទៃទៀតដែលជាកម្មសិទ្ធិនៃភាគីម្ខាងទៀត ឬភាគីច្រើនដែលពាក់ព័ន្ធនឹងមជ្ឈត្តវិនិច្ឆ័យ ។ល។

## ជំពូកទី ៥

## មូលដ្ឋានដើម្បីបដិសេធការទទួលស្គាល់ឬ/និងការប្រតិបត្តិ

**មាត្រា ១៤.-**

តុលាការកម្ពុជាអាចធ្វើការបដិសេធនូវការទទួលស្គាល់និងការប្រតិបត្តិនូវសេចក្តីសម្រេចមជ្ឈត្តករបរទេស ដោយយោងលើចំណុចទាំងឡាយនៃមាត្រា ១៥ និង ១៦ ខាងក្រោម ។

**មាត្រា ១៥.-**

ការបដិសេធលើការទទួលស្គាល់និងការប្រតិបត្តិនូវសេចក្តីសម្រេចមជ្ឈត្តករបរទេសនឹងអាចធ្វើទៅបានលុះត្រាតែ ÷

ក-តាមសំណើរបស់ភាគីដែលខ្លួនត្រូវគេអំពាវនាវរកពាក់ព័ន្ធនឹងបណ្តឹងឱ្យមានការទទួលស្គាល់និងប្រតិបត្តិ ប្រសិនបើភាគីរូបនេះបង្ហាញភស្តុតាងទៅតុលាការថា :

១-ភាគីដែលបានចុះកិច្ចព្រមព្រៀងមជ្ឈត្តការដែលបានដាក់ពាក្យទៅតុលាការមានសមត្ថកិច្ច ស្ថិតក្នុងករណីអសមត្ថភាព ឬកិច្ចព្រមព្រៀង ដែលបានចុះហត្ថលេខានេះក្រោមច្បាប់មួយ ដែលភាគីសងខាងត្រូវតែគោរពតាម គ្មានសុពលភាព ឬកិច្ចព្រមព្រៀងមិនបានបង្ហាញនូវចំណុចណាមួយច្បាស់លាស់ក្រោមច្បាប់នៃប្រទេសណាមួយដែលការសម្រេចមជ្ឈត្តករបរទេសបានធ្វើឡើង ឬ

២-ភាគីដែលសេចក្តីសម្រេចមជ្ឈត្តករបរទេសត្រូវអនុវត្តចំពោះខ្លួនពុំបានទទួលនូវសេចក្តីជូនដំណឹងត្រឹមត្រូវស្តីពីការតែងតាំងមជ្ឈត្តករ ឬ ពីនីតិវិធីនៃអាជ្ញាកណ្តាល ឬ បើពុំនោះទេ ខ្លួនពុំអាចចូលឆ្លើយពីក្តីរបស់ខ្លួនបានឡើយ ឬ

៣-សេចក្តីសម្រេចនៃមជ្ឈត្តករបរទេសស្តីពីជម្លោះដែលមិនស្រប ឬមិនចូលក្នុងន័យនៃការដាក់ស្នើសុំមជ្ឈត្តវិនិច្ឆ័យ ឬសេចក្តីសម្រេចដែលមានខ្លឹមសារហួសពីវិសាលភាពនៃការដាក់ស្នើសុំមជ្ឈត្តវិនិច្ឆ័យ ។ តែប្រសិនបើសេចក្តីសម្រេចដែលបានដាក់សុំមជ្ឈត្តវិនិច្ឆ័យអាចត្រូវបានបំបែកចេញពីរឿងដែលពុំបានដាក់ស្នើចំណែកនៃសេចក្តីសម្រេចមជ្ឈត្តករបរទេសដែលមានសេចក្តីសម្រេចលើរឿងដែលបានដាក់ស្នើសុំមជ្ឈត្តវិនិច្ឆ័យអាចត្រូវបានទទួលស្គាល់និងប្រតិបត្តិ ឬ ល.។.

៤-សមាសភាពនៃសាលាធ្វើមជ្ឈត្តវិនិច្ឆ័យឬនីតិវិធីនៃមជ្ឈត្តវិនិច្ឆ័យ មានលក្ខណៈពុំស្របនឹងកិច្ចសន្យារបស់ភាគីឬក្នុងករណីដែលគ្មានកិច្ចសន្យាបែបនេះ សមាសភាពដែលធ្វើមជ្ឈត្តវិនិច្ឆ័យពុំស្របតាមច្បាប់នៃប្រទេសដែលមជ្ឈត្តវិនិច្ឆ័យបានធ្វើ ឬ

៥-សេចក្តីសម្រេចនៃមជ្ឈត្តករបរទេសពុំទាន់មានភ្ជាប់កាតព្វកិច្ចលើ ភាគីទាំងឡាយឬត្រូវបានទុកមួយអន្លើសិនឬផ្អាកដោយតុលាការឬដោយច្បាប់នៃប្រទេស ដែលធ្វើមជ្ឈត្តវិនិច្ឆ័យនោះបានសម្រេចឡើងឬ

ខ-តុលាការកម្ពុជារកឃើញថា :

១-រឿងក្តីដែលមានទំនាស់នេះ មិនអាចនឹងធ្វើការដោះស្រាយតាម វិធីមជ្ឈត្តកម្មបានក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬ

២-ការទទួលស្គាល់ឬការប្រតិបត្តិនូវសេចក្តីសម្រេចមជ្ឈត្តករបរទេស ផ្ទុយនឹងបន្ទាត់នយោបាយសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ។ ក្នុងការកំណត់ស្តង់-ដារ នៃបន្ទាត់នយោបាយសាធារណៈដែលត្រូវអនុវត្តដើម្បីបដិសេធការវិនិច្ឆ័យរបស់មជ្ឈត្ត-ករបរទេសតុលាការត្រូវពិចារណាលើស្តង់ដារនៃបន្ទាត់នយោបាយសាធារណៈដែលបាន អនុវត្តដោយតុលាការនៃរដ្ឋដទៃទៀតដែលជាភាគីនៃអនុសញ្ញាទីក្រុងញូវយ៉ក ។

**មាត្រា ១៦.-**

យោងតាមកថាខណ្ឌ (ក) (៥) នៃមាត្រា ១៥ ក្នុងករណីដែលមានពាក្យបណ្តឹងសុំ បដិសេធការទទួលស្គាល់និងការប្រតិបត្តិនូវសេចក្តីសម្រេចមជ្ឈត្តករ ប្រសិនបើតុលាការ កម្ពុជាដែលទទួលនូវពាក្យសុំពិចារណាទៅឃើញថាសមស្រប តុលាការកម្ពុជាអាចពន្យារ សេចក្តីសម្រេចរបស់ខ្លួនហើយក៏អាចបញ្ជាឱ្យភាគីម្ខាងទៀតបង់នូវប្រាក់ធានាដ៏សមស្រប ។ល។

## ជំពូកទី ៦
## សិទ្ធិអំណាចនិងសមាសភាពសាលាឧទ្ធរណ៍

**មាត្រា ១៧.-**

សាលាឧទ្ធរណ៍ ក្រោយពីបានទទួលពាក្យបណ្ដឹងអស់រយៈពេលហុកសិប (៦០)ថ្ងៃ ប្រតិទិននៅចុងម៉ោងធ្វើការ ក្នុងករណីដែលគ្មានពាក្យស្នើសុំដើម្បីបដិសេធការទទួលស្គាល់ និងការប្រតិបត្តិនូវសេចក្ដីសម្រេចរបស់មជ្ឈត្តករបរទេសត្រូវធ្វើការ/សម្រេចទទួលស្គាល់ សេចក្ដីសម្រេចមជ្ឈត្តករបរទេសនោះ ។ សាលាឧទ្ធរណ៍ត្រូវធ្វើការចុះបញ្ជីនៅក្នុងបញ្ជី សៀវភៅសេចក្ដីសម្រេចនៃសាលាឧទ្ធរណ៍ ហើយត្រូវចុះហត្ថលេខាបញ្ជាក់ទទួលស្គាល់ នូវសេចក្ដីសម្រេចមជ្ឈត្តករបរទេសជាសេចក្ដីសម្រេចចុងក្រោយនិងជាស្ថាពរ និងត្រូវ អនុវត្តសេចក្ដីសម្រេចនេះភ្លាមៗតាមច្បាប់និងនីតិវិធីដែលមានជាធរមាន ។ ក្នុងករណី បែបនេះសាលដីកាសាលាឧទ្ធរណ៍ គឺជាសេចក្ដីសម្រេចចុងក្រោយ និងជាស្ថាពរមិនអាច ជាកម្មវត្ថុប្ដឹងជំទាស់នៅតុលាការកំពូលទៀតទេ ។

**មាត្រា ១៨.-**

សាលាឧទ្ធរណ៍ត្រូវពិចារណានូវសេចក្ដីសម្រេចរបស់ខ្លួនឱ្យបានហ្មត់ចត់ស្របតាម លក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១៥ និងមាត្រា ១៦ នៃច្បាប់នេះ មុននឹងសម្រេចបដិសេធ-ការទទួលស្គាល់និងការប្រតិបត្តិនូវសេចក្ដីសម្រេចរបស់មជ្ឈត្តករបរទេស ។

**មាត្រា ១៩.-**

សាលាឧទ្ធរណ៍ នៅពេលធ្វើការសម្រេចការទទួលស្គាល់និងការប្រតិបត្តិឬបដិសេធ ការទទួលស្គាល់និងការប្រតិបត្តិនូវសេចក្ដីសម្រេចមជ្ឈត្តករបរទេសលើកលែងតែមាត្រា ១៧ ខាងលើ ត្រូវបើកផ្លូវឱ្យភាគីម្ខាងទៀតធ្វើការប្ដឹងជំទាស់នឹងសេចក្ដីសម្រេចរបស់ខ្លួនទៅ តុលាការកំពូលក្នុងរយៈពេលហុកសិប (៦០)ថ្ងៃ ប្រតិទិនគិតពីថ្ងៃចេញសេចក្ដីសម្រេច ។

**មាត្រា ២០.-**

សាលាឧទ្ធរណ៍ ក្នុងសវនាការដើម្បីសំរេចលើករណីចំពោះមុខដូចខាងលើនេះត្រូវ មានសមាសភាពចៅក្រមពេញសិទ្ធិចំនួន ៣(បី) រូប ។ល។

## ជំពូកទី ៧
## សិទ្ធិ អំណាចនិងសមាសភាពតុលាការកំពូល

**មាត្រា ២១.-**

តុលាការកំពូលជាសាលាជំរះក្តីដែលមានសមត្ថកិច្ចជំនុំជំរះបណ្តឹងជំទាស់របស់ភាគីម្ខាងទៀតដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ ដែលទទួលស្គាល់និងប្រតិបត្តិឬបដិសេធការទទួលស្គាល់និងការប្រតិបត្តិនូវសេចក្តីសម្រេចរបស់មជ្ឈត្តករបរទេស ។

**មាត្រា ២២.-**

តុលាការកំពូលត្រូវជំនុំជំរះចេញសាលដីកា ក្នុងរយៈពេល ៦០ (ហុកសិប)ថ្ងៃប្រតិទិន ចាប់ពីថ្ងៃដែលភាគីបានដាក់ពាក្យបណ្តឹង ដោយពុំចាំបាច់បញ្ជូនសំណុំរឿងត្រឡប់មកសាលាឧទ្ធរណ៍ឱ្យពិនិត្យសម្រេចឡើងវិញទេ ។

**មាត្រា ២៣.-**

សាលដីកាតុលាការកំពូលជាសេចក្តីសម្រេចចុងក្រោយនិងស្ថាពរហើយមិនត្រូវជាកម្មវត្ថុប្តឹងជំទាស់ឬប្តឹងតវ៉ាផ្សេងៗទៀត ដោយមធ្យោបាយណាមួយឡើយ ។

**មាត្រា ២៤.-**

តុលាការកំពូលត្រូវចាត់វិធានការធ្វើការអនុវត្តភ្លាមៗនូវសាលដីការបស់ខ្លួនអំពីសេចក្តីសម្រេចដែលបានធ្វើការទទួលស្គាល់និងការប្រតិបត្តិនូវសេចក្តីសម្រេចរបស់មជ្ឈត្តករបរទេសតាមនីតិវិធីដូចមានចែងក្នុងមាត្រា ១២ នៃច្បាប់នេះ ។

**មាត្រា ២៥.-**

តុលាការកំពូល ក្នុងសវនាការដើម្បីសម្រេចលើករណីដូចខាងលើនេះ ត្រូវមានសមាសភាពចៅក្រមពេញសិទ្ធិចំនួន ៥(ប្រាំ) រូប ។/.

# ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ២៦.-**

បទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះមានប្រសិទ្ធិភាពអនុវត្តតែក្នុងករណីមជ្ឈត្តករបរទេសប៉ុណ្ណោះ ។

**មាត្រា ២៧.-**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។/.

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ ២០០១

បានបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**
ហត្ថលេខា
ហ៊ុន សែន

ព្រះហស្តលេខា
នរោត្តម សីហនុ

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
ហត្ថលេខា
សុខ អាន

លេខៈ ១៥០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០១
អគ្គលេខាធិការរដ្ឋាភិបាល

USAID | CAMBODIA
FROM THE AMERICAN PEOPLE

EAST · WEST MANAGEMENT INSTITUTE
Program on Rights and Justice (PRAJ)

ABA Rule of Law Initiative

# ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ : ប្រទេសកម្ពុជា



## សៀវភៅសិក្សាស្តីពីទស្សនានានាសំខាន់ៗ


មេធាវី ស្ទីវិន អ៊ែម អូស្ទើរមីឡឺរ៍



សៀវភៅនេះត្រូវបានរៀបចំឡើង ដោយមានការត្រួតពិនិត្យពីទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ
លោក ស្ទីវិន អូស្ទើរមីឡឺរ៍ បានរៀបរៀងសៀវភៅនេះឡើង ជាឯកសារផ្សព្វផ្សាយនៃកម្មវិធី
ផ្តួចផ្តើមដើម្បីនីតិរដ្ឋ នៃគណៈមេធាវីអាមេរិក។

ខែមករា ឆ្នាំ២០១០

(បោះពុម្ពលើកទី ២)

# ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ : ប្រទេសកម្ពុជា

## សៀវភៅសិក្សាស្តីពីឧស្សនាទានសំខាន់ៗ


**មេធាវី ស្ទីវិន អ៊ែម អូស្ទើរមីឡឺរ**


**ឆ្នាំ២០១០**


ឯកសារផ្សព្វផ្សាយនៃកម្មវិធីផ្តួចផ្តើមដើម្បីនីតិរដ្ឋ នៃគណៈមេធាវីអាមេរិក

USAID | CAMBODIA
FROM THE AMERICAN PEOPLE

EAST • WEST MANAGEMENT INSTITUTE
Program on Rights and Justice (PRAJ)
កម្មវិធីសិទ្ធិ និង យុត្តិធម៌ (ប្រាជ្ញ)

ABA Rule of Law Initiative

ពាក្យថ្លែង និងការវិភាគដែលមាននៅក្នុងសៀវភៅនេះ គឺជាស្នាដៃរបស់កម្មវិធីផ្តួចផ្តើមដើម្បីនីតិរដ្ឋនៃគណៈមេធាវីអាមេរិក ។ ពាក្យថ្លែង និងការវិភាគដែលបានលើកឡើងគឺសុទ្ធតែជារបស់អ្នកនិពន្ធទាំងអស់ ហើយមិនបានទទួលការអនុម័តពីសភាប្រតិភូរ ឬក្រុមប្រឹក្សាភិបាលនៃគណៈមេធាវីអាមេរិកទេ ព្រមទាំងមិនតំណាងឱ្យគោលជំហរ ឬគោលនយោបាយនៃគណៈមេធាវីអាមេរិកឡើយ ។ ជាងនេះទៅទៀត មិនមានចំណុចណាមួយនៅក្នុងសៀវភៅនេះដែលអាចចាត់ទុកថាជាការផ្តល់ដំបូន្មានផ្នែកច្បាប់សម្រាប់ករណីណាមួយឡើយ ។

ការបោះពុម្ពសៀវភៅនេះ អាចធ្វើទៅបានដោយមានការគាំទ្រដ៏សប្បុរសពីសំណាក់ប្រជាពលរដ្ឋអាមេរិក តាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ។ មាតិកាទាំងអស់គឺជាការទទួលខុសត្រូវ របស់កម្មវិធីផ្តួចផ្តើមដើម្បីនីតិរដ្ឋនៃគណៈមេធាវីអាមេរិក ហើយក៏មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ USAID រដ្ឋាភិបាលអាមេរិក និង វិទ្យាស្ថានគ្រប់គ្រងបូព៌ា-បស្ចឹមឡើយ ។

ISBN: 978-1-60422-330-3 (paperback)
ISBN: 978-1-60442-331-0 (PDF)

បោះពុម្ពច្បាប់ដើមនៅប្រទេសកម្ពុជា នាឆ្នាំ២០០៩
បោះពុម្ពលើកទី ២ នៅប្រទេសកម្ពុជា ដោយមានការបន្ថែម និងកែសម្រួលបន្តិចបន្តួច ឆ្នាំ២០១០
រក្សាសិទ្ធិ © នៅឆ្នាំ២០០៩, ២០១០ ដោយគណៈមេធាវីអាមេរិក
អសយដ្ឋាន លេខ៧៤០ ផ្លូវលេខ១៥ NW រដ្ឋវ៉ាស៊ីនតោន ២០០០៥

គណៈមេធាវីអាមេរិកផ្តល់សិទ្ធិចម្លងឯកសារនេះ ទាំងស្រុង និងដោយផ្នែក សម្រាប់ការសិក្សាក្នុងថ្នាក់រៀននៅតាមស្ថាប័នឧត្តមសិក្សា ឬអង្គការមិនរកកម្រៃនានា ក្នុងលក្ខខណ្ឌដែលថា គោលបំណងនៃការប្រើប្រាស់នោះគឺដើម្បីជាព័ត៌មាន និងមិនធ្វើអាជីវកម្មតែប៉ុណ្ណោះ ដោយត្រូវរក្សាសំណៅដើមរបស់គណៈមេធាវីអាមេរិក រួមមានចំណងជើងឯកសារ ឈ្មោះអ្នកនិពន្ធ ព្រមទាំងសារបញ្ជាក់ថា "បោះពុម្ភឡើងវិញក្រោមការអនុញ្ញាតិពីគណៈមេធាវីអាមេរិក" ។

USAID មានសិទ្ធិដែលមិនបង់តម្លៃ មិនដាច់ដោយឡែក និងមិនអាចដកហូតបាន ក្នុងការផលិត ផ្សព្វផ្សាយ ឬប្រើប្រាស់តាមមធ្យោបាយផ្សេងទៀត ក៏ដូចជាអនុញ្ញាតិឱ្យអ្នកដទៃទៀតប្រើប្រាស់ដើម្បីបម្រើរដ្ឋាភិបាល ។

# សេចក្តីថ្លែងអំណរគុណ

សៀវភៅនេះ គឺជាកិច្ចខិតខំប្រឹងប្រែងជាក្រុមតាមរូបភាពច្រើនយ៉ាង។ សៀវភៅនេះនឹងមិនអាចលេចចេញជាផ្លែផ្កាបានឡើយ ប្រសិនបើគ្មានការជួយគាំទ្រពីសំណាក់មនុស្សជាច្រើននោះទេ។ វាជាការធ្វេសប្រហែសមួយ ប្រសិនបើខ្ញុំមិនបានថ្លែងអំណរគុណជាបឋមចំពោះប្រភពថវិកា ដែលនោះគឺជាប្រជាពលរដ្ឋអាមេរិក។ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ដែលបានទទួលថវិកាពីការបង់ពន្ធរបស់ពលរដ្ឋអាមេរិក គឺជាស្ថាប័នផ្តល់មូលនិធិដល់កម្មវិធីដែលគាំទ្រការបោះពុម្ពផ្សាយសៀវភៅនេះ។

ជាបន្ទាប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះអ្នកពិនិត្យផ្ទៀងផ្ទាត់ចំនួនបីរូប ដែលបានស្ម័គ្រចិត្តជួយធ្វើឱ្យសៀវភៅនេះ កាន់តែខ្លីហើយច្បាស់លាស់ ក្នុងនោះរួមមាន Naomi Svensson, Sara Eliot និង Monica Saxena។ ពួកគេបានផ្តល់យោបល់ល្អៗ ហើយបានរួមចំណែកយ៉ាងសំខាន់ ក្នុងការធ្វើឱ្យការសរសេរសៀវភៅនេះជាភាសាអង់គ្លេស មានលក្ខណៈត្រឹមត្រូវពិតប្រាកដ។ ចំពោះអ្នកដែលបានជួយធ្វើសៀវភៅនេះជាភាសាខ្មែរ ខ្ញុំសូមថ្លែងអំណរគុណដល់ គីម សាន និងប៉េង សុគន្ធា។ ការបកប្រែពីភាសាអង់គ្លេសមកជាភាសាខ្មែរ មិនមែនជាកិច្ចការដែលងាយស្រួល និងរលូនទៅមុខរហូតនោះឡើយ ហេតុនេះខ្ញុំសូមអរគុណចំពោះពេលវេលា និងកម្លាំងកាយចិត្ត ដែលពួកគេបានចំណាយលើការងារនេះ។ សុគន្ធា មិនត្រឹមតែជួយក្នុងការបកប្រែតែប៉ុណ្ណោះទេ ថែមទាំងជួយក្នុងកិច្ចការជាច្រើនទៀតដូចជាការស្រាវជ្រាវផ្នែកច្បាប់ ការពិនិត្យផ្ទៀងផ្ទាត់អត្ថបទ ព្រមទាំងធានាថាខ្លឹមសារសៀវភៅនេះមានភាព សមស្របចំពោះវប្បធម៌កម្ពុជាផងដែរ។

ខ្ញុំសូមថ្លែងអំណរគុណដល់សហការីរបស់ខ្ញុំនៅវិទ្យាស្ថានគ្រប់គ្រងបូពា-បស្ចិម (EWMI) គឺ Herb Bowman និង Nick Mansfield ដែលបានអត់ធ្មត់ចំពោះការអូសបន្លាយពេលវេលា និងផ្តល់សេរីភាពក្នុងការកំណត់ពេលវេលាដើម្បីសម្រេចគម្រោងនេះ។ គណៈមេធាវីអាមេរិក (ABA) បានផ្តល់ការគាំពារដ៏សំខាន់ក្នុងការស្រាវជ្រាវនេះ។ ដូច្នេះខ្ញុំសូមថ្លែងអំណរគុណ ដល់អ្នកស្រាវជ្រាវមួយចំនួនដូចជា Kun-Fang Lee, Dominic Jerry Nardi, Jr., Nathan Nagy ព្រមទាំងបុគ្គលិកទាំងអស់នៃ វិទ្យាស្ថាននីតិរដ្ឋរបស់គណៈមេធាវីអាមេរិក (ABA-ROLI)។

និងជាចុងក្រោយ ខ្ញុំសូមអរគុណភរិយារបស់ខ្ញុំ Amy Antoniades Austermiller ដែលបានជួយពិនិត្យផ្ទៀងផ្ទាត់ និងជានិច្ចជាកាលតែងតែជួយគាំទ្រ និងលើកទឹកចិត្តដល់ខ្ញុំ ទោះជានៅពេលចុងសប្តាហ៍ ដែលខ្ញុំគួរតែចំណាយពេលវេលាហែលទឹក ជាមួយកូនៗ ជាជាងអង្គុយនៅមុខកុំព្យូទ័រហើយសរសេរអំពី ADR នៅកម្ពុជាក៏ដោយ។

ទោះជាគម្រោងនេះមានការជួយជ្រោមជ្រែងពីសំណាក់បុគ្គលទាំងអស់ខាងលើក្តី ខ្ញុំសូមបញ្ជាក់ថា រាល់ទស្សនៈដែលបានបង្ហាញ ក៏ដូចជាកំហុសផ្សេងៗដែលមាន នៅតែជាការទទួលខុសត្រូវរបស់ខ្ញុំផ្ទាល់។

# មាតិកា


គោលបំណងនៃសៀវភៅសិក្សានេះ ........ ១

**ជំពូកទី១៖ សេចក្តីផ្តើមអំពីដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ** ........ ៣

**ក.តើអ្វីទៅជាដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ** ........ ៣

**ខ.ការដោះស្រាយបញ្ហា** ........ ៣

**គ.បញ្ហាមួយក្លាយទៅជាវិវាទ** ........ ៦

**ឃ.ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ** ........ ១១

**ជំពូកទី២៖ ការចរចា** ........ ១៣

**ក.សេចក្តីផ្តើម** ........ ១៣

**ខ.គុណសម្បត្តិនៃការចរចា** ........ ១៥

**គ.គុណវិបត្តិនៃការចរចា** ........ ១៧

**ឃ.វិធីសាស្ត្រជាមូលដ្ឋានពីរក្នុងការចរចា** ........ ១៨

១. ការចរចាបែបបែងចែក ( ឈ្នះ-ចាញ់) ........ ១៨

២. ការចរចាផ្អែកលើផលប្រយោជន៍ ( ឈ្នះ-ឈ្នះ) ........ ១៩

**ង.សេចក្តីលម្អិតនៃវិធីសាស្ត្របែបបែងចែក** ........ ២១

១. គោលការណ៍ទូទៅនៃវិធីសាស្ត្របែបបែងចែក ........ ២១

២. វិធីសាស្ត្របែបបែងចែកក្នុងដំណោះស្រាយវិវាទ ........ ២២

ក) តម្លៃជាទីកប្រាក់ដែលរំពឹងទុក ........ ២២

ខ) ជម្រើសល្អបំផុតក្រៅពីដំណោះស្រាយតាមការចរចា ........ ២៦

គ) តម្លៃបម្រុង ........ ២៧

៣. កលយុទ្ធនៅក្នុងការចរចាបែបបែងចែក ........ ៣០

៤. គុណសម្បត្តិ និងគុណវិបត្តិនៃការចរចាបែបបែងចែក ........ ៣៥

**ច.ទ្វេគ្រោះរបស់អ្នកទោស** ........ ៣៦

**ឆ.សេចក្តីលម្អិតអំពីវិធីសាស្ត្រចរចាផ្អែកលើផលប្រយោជន៍** ........ ៣៩

១. គោលដៅទូទៅនៃវិធីសាស្ត្រចរចាផ្អែកលើផលប្រយោជន៍ ........ ៣៩

២. ផ្តាច់កត្តាមនុស្សចេញពីបញ្ហា ........ ៤០

ក) ការយល់ឃើញ ........ ៤១

ខ) អារម្មណ៍ ........ ៤៦

គ) ការទំនាក់ទំនង ........ ៥០

៣. ផ្តោតលើផលប្រយោជន៍ មិនមែនលើជំហរ ........ ៥២

៤. បង្កើតជម្រើសសម្រាប់ផលចំណេញរួម ........ ៥៦
ក) ផ្ដាច់ការបង្កើត ចេញពីការវិនិច្ឆ័យ ........ ៥៧
ខ) ពង្រីកជម្រើស ........ ៥៨
គ) ស្វែងរកផលចំណេញរួម ........ ៥៨
ឃ) ធ្វើឱ្យការសម្រេចចិត្តមានភាពងាយស្រួល ........ ៦១
៥. សង្កត់ធ្ងន់លើការប្រើប្រាស់លក្ខណៈវិនិច្ឆ័យមិនលម្អៀង ........ ៦៣
ក) បទដ្ឋានយុត្តិធម៌ ........ ៦៤
ខ) នីតិវិធីយុត្តិធម ........ ៦៤
**ជ.ដំណាក់កាលនៃដំណើរការចរចា** ........ ៦៦
១. ដំណាក់កាលត្រៀម ........ ៦៦
២. ដំណាក់កាលផ្ដើម ........ ៦៨
៣. ដំណាក់កាលព័ត៌មាន ........ ៧០
៤. ដំណាក់កាលបែងចែក/ផ្អែកលើផលប្រយោជន ........ ៧១
៥. ដំណាក់កាលបញ្ចប ........ ៧២
**ឈ.អនុវត្តន៍ការចរចា** ........ ៧៣
១. ទំព័រកិច្ចការ: ការរៀបចំផែនការសម្រាប់ការចរចា ........ ៧៥
២. ទំព័រកិច្ចការ: ការចូលរួមនៅក្នុងការចរចា (បញ្ហាទូទៅ) ........ ៧៦
៣. ទំព័រកិច្ចការ: ការចូលរួមនៅក្នុងការចរចា (ការតស៊ូមតិលើបញ្ហា) ........ ៧៧
៤. ទំព័រកិច្ចការ: ការចូលរួមក្នុងការចរចា (យុទ្ធសាស្ត្រផ្អែកលើផលប្រយោជន៍) ........ ៧៨
៥. ទំព័រកិច្ចការ: ការចូលរួមក្នុងការចរចា (តារាងដំណោះស្រាយ) ........ ៧៩
៦. ទំព័រកិច្ចការ: ចូលរួមក្នុងការចរចា (កិច្ចព្រមព្រៀង) ........ ៨០
៧. ទំព័រកិច្ចការ: ការសង្កេតលើការចរចា ........ ៨១
**ជំពូកទី៣: សន្ធានកម្ម (ឬការសម្រុះសម្រួល)** ........ ៨៣
**ក.តើអ្វីទៅជាសន្ធានកម្ម?** ........ ៨៣
១. សេចក្ដីផ្ដើម ........ ៨៣
២. ប្រវត្តិនៃសន្ធានកម្ម ........ ៨៦
៣. សន្ធានកម្មនៅប្រទេសកម្ពុជា ........ ៨៧
៤. សន្ធានកម្មធៀបនឹងការចរចា ........ ៩១
៥. តើវិវាទណាខ្លះដែលស័ក្ដិសមបំផុតចំពោះសន្ធានកម្ម? ........ ៩២
៦. តើសន្ធានកម្មគួរកើតឡើងនៅពេលណា? ........ ៩៤

**ខ.សន្ទានកម្មជាឯកជន និងសន្ទានកម្មចំណុះស្ថាប័នតុលាការ** ........ ៩៦
**គ.គុណសម្បត្តិ និងគុណវិបត្តិនៃសន្ទានកម្ម** ........ ៩៩
១. គុណសម្បតិ ........ ៩៩
២. គុណវិបត្តិ ........ ១០២
**ឃ.ការធ្វើសេចក្តីព្រាងលើប្បញ្ញត្តិអំពីសន្ទានកម្ម** ........ ១០៤
**ង.ដំណើរការសន្ទានកម្ម** ........ ១០៧
១. ការផ្តួចផ្តើមសន្ទានកម្ម ........ ១០៧
២. ការជ្រើសរើសសន្ទានការ ........ ១០៨
៣. ការផ្តល់ព័តិមានដល់សន្ទានការី ........ ១០៩
៤. ការបើកកិច្ចប្រជុំ ........ ១១០
៥. កិច្ចប្រជុំដោះស្រាយបញ្ហាទូទៅ ........ ១១៣
ក) ការស្តាប់ ........ ១១៥
ខ) ការបកស្រាយឡើងវិញ ........ ១១៦
គ) ការបង្កើតជម្រើស ........ ១១៨
៦. ជំនួបឯកជន ........ ១១៩
៧. ការបិទកិច្ចប្រជុំ ........ ១២១
**ច.តួនាទីរបស់សន្ទានការី** ........ ១២៣
**ឆ.តួនាទីរបស់មេធាវី** ........ ១២៥
**ជ.ក្រមសីលធម៌សម្រាប់សន្ទានការ** ........ ១២៧
**ឈ.ការផ្តល់អាជ្ញាប័ណ្ណ និងគុណវុឌ្ឍិ** ........ ១៣៤
**ញ.សំបោត់សន្ទានកម្មគម្រូ** ........ ១៣៥
១- ទំព័រកិច្ចការ: ផលប្រយោជន៍ និងបញ្ហា ........ ១៤១
២- ទំព័រកិច្ចការ: ដំណោះស្រាយចេញពីសន្ទានកម្ម ........ ១៤២
**ជំពូកទី៤: មជ្ឈត្តការ** ........ ១៤៣
**ក.តើមជ្ឈត្តការគឺជាអ្វី?** ........ ១៤៣
១. ប្រវត្តិនៃមជ្ឈត្តការ ........ ១៤៣
២. មជ្ឈត្តការសម្រាប់ប្រភេទវិវាទជាច្រើន ........ ១៤៥
៣.តើមជ្ឈត្តការខុសប្លែកពីបណ្តឹងទៅតុលាការនិងសន្ទានកម្មយ៉ាងដូចម្តេច? ........ ១៤៦
៤.ប្រភេទផ្សេងៗនៃមជ្ឈត្តការ ........ ១៤៧

**ខ.គុណសម្បត្តិ និងគុណវិបត្តិនៃមជ្ឈត្តការ** ១៥០
១. គុណសម្បតិ ១៥០
២. គុណវិបត្តិ ១៥២
**គ.កិច្ចព្រមព្រៀងមជ្ឈត្តការ** ១៥៣
១. ខចែងស្តីពីមជ្ឈត្តការជាមូលដ្ឋាននៅក្នុងកិច្ចសន្យា ១៥៣
២. ការតាក់តែងខចែងស្តីពីមជ្ឈត្តការ ១៥៤
ក) តើមជ្ឈត្តការនោះគួរភ្ជាប់កាតព្វកិច្ចដែរឬទេ? ១៥៤
ខ) តើមជ្ឈត្តការនោះគួរតែជាមជ្ឈត្តការមានការគ្រប់គ្រងឬមជ្ឈត្តការពិសេស? ១៥៥
គ) តើមជ្ឈត្តការនឹងធ្វើឡើងនៅកន្លែងណា? ១៥៥
ឃ) តើត្រូវជ្រើសរើសមជ្ឈត្តករប៉ុន្មាននាក់និងប្រើប្រាស់វិធីសាស្ត្រអ្វីក្នុងការជ្រើសរើស? ១៥៦
ង) តើគូភាគីគួរធ្វើការចរចា ឬសន្ទានកម្មជាមុនសិនដែរឬទេ? ១៥៧
ច) តើវេទិកាមជ្ឈត្តកម្មនឹងមានអំណាចក្នុងការចេញវិធានការបណ្តោះអាសន្នដែរ ១៥៨
ឆ) តើគូភាគីអាចរួមបញ្ចូលមជ្ឈត្តការរបស់ពួកគេជាមួយរបស់អ្នកដទៃបានដែរឬទេ? ១៥៩
ជ) តើនឹងមានការតម្រូវឱ្យគូភាគីបង្ហាញព័ត៌មានក្នុងកម្រិតណា? ១៥៩
ឈ) តើមជ្ឈត្តករអាចដាក់ចេញនូវដំណោះស្រាយអ្វីខ្លះ? ១៦០
ញ) តើវិធានអ្វីនឹងគ្រប់គ្រងដំណើរការនេះ? ១៦១
ដ) តើភាសាអ្វីនឹងត្រូវប្រើនៅក្នុងដំណើរការមជ្ឈត្តការនេះ? ១៦១
ឋ) តើច្បាប់ណាដែលនឹងគ្រប់គ្រងដំណើរការនេះ? ១៦១
ឌ) តើដំណើរការនេះត្រូវទុកជាការសម្ងាត់ដែរឬទេ? ១៦២
ឍ) តើមជ្ឈត្តករត្រូវតែធ្វើការពន្យល់ជាលាយលក្ខណ៍អក្សរដែរឬទេ? ១៦២
ណ) តើនរណាជាអ្នកបង់ថ្លៃចំណាយ? ១៦៣
**ឃ.ដំណើរការមជ្ឈត្តការ** ១៦៥
១. ការផ្តួចផ្តើមដំណើរការមជ្ឈត្តការ ១៦៧
ក) ការដាក់ពាក្យរបស់ភាគីប្តឹង ១៦៨
ខ) ការដាក់ពាក្យរបស់ភាគីឆ្លើយតប ១៦៩
២. ការជ្រើសរើស និង ការជំទាស់នឹងវេទិកាមជ្ឈត្តកម្ម ១៦៩
ក) ការជ្រើសរើសមជ្ឈត្តករ ១៦៩
ខ) ការជំទាស់នឹងមជ្ឈត្តករដែលត្រូវបានជ្រើសរើស ១៧០
គ) ការជំទាស់នឹងយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម ១៧១

៣. ដំណើរការមុនសវនាការ ១៧២
ក) វិធានស្តីពីនីតិវិធី ១៧២
ខ) ទីកន្លែងធ្វើមជ្ឈត្តការ ១៧២
គ) ភាសា ១៧៣
ឃ) សន្ទានកម្ម ១៧៣
ង) វិធានការបណ្តោះអាសន្ន ១៧៤
ច) ការបង្ហាញព័ត៌មានឱ្យដឹង ឬការជូនដំណឹងគ្នាទៅវិញទៅមក ១៧៤
ឆ) អ្នកជំនាញ ១៧៥
៤. សវនាការមជ្ឈត្តការ ១៧៥
៥. ការធ្វើសេចក្តីសម្រេច ១៧៦
ក) ជាចៅក្រម ឬជាអ្នកជួយសម្រុះសម្រួល? ១៧៧
ខ) បទដ្ឋានឧស្សាហកម្ម ឬពាណិជ្ជកម្ម ១៧៧
គ) សេចក្តីសម្រេចដោយសម្លេងភាគច្រើន ១៧៧
ឃ) វិធានក្នុងករណីខកខាន ១៧៨
ង) ទម្រង់នៃមជ្ឈត្តវិនិច្ឆ័យ ១៧៨
៦. ការប្តឹងឧបាស្រ័យ និងការដាក់ឱ្យអនុវត្ត ១៧៩
ក) ការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ ១៧៩
ខ) ការទទួលស្គាល់ និងការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ ១៨០
គ) ការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យអន្តរជាតិ ១៨២
**ង.មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម** ១៨៤
**ច.បញ្ញាក្រមសីលធម៌** ១៨៦
**ឆ.ក្រុមប្រឹក្សាអាជ្ញាកណ្តាលកម្ពុជា** ១៨៩
១. យុត្តាធិការ ១៨៩
២. ដំណើរការរបស់ក្រុមប្រឹក្សាអជ្ញាកណ្តាល ១៩២
៣. សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ១៩៤
**ជំពូកទី៥: សន្និដ្ឋាន** ១៩៩
**ក.ការប្រៀបធៀបដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យរួម** ២០០
**ខ.ការប្រៀបធៀបដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដោយផ្អែកលើភាពចត់ស័ននៃលទ្ធផល** ២០២
**គ.ការប្រៀបធៀបដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ផ្អែកលើការរក្សាទំនាក់ទំនងរបស់ភាគី** ២០៣

ឃ.ការប្រៀបធៀបដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ចំពោះវិវាទអំពីគោលការណ៍ ២០៥
ង.ការប្រៀបធៀបដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅក្នុងករណីអតុល្យភាពនៃអំណាច ២០៦
ច.ការជ្រើសរើសដំណើរការដ៏ប្រសើរបំផុត ២០៩
ឆ.វិធីសាស្ត្រថ្មីៗនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ២១៤
អក្ខរានុក្រមនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ២១៨
ឧបសម្ព័ន្ធ ក *វិធានផ្សះផ្សារ UNCITRAL* ២២១
ឧបសម្ព័ន្ធ ខ *បទដ្ឋានប្រតិបត្តិគម្រូសម្រាប់សន្ធានការី* ២៣១
ឧបសម្ព័ន្ធ គ *វិធានមជ្ឈត្តការ UNCITRAL* ២៣៩
ឧបសម្ព័ន្ធ ឃ *ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មជ្ឈត្តករនៅក្នុងវិវាទពាណិជ្ជកម្ម* ២៦១
ឧបសម្ព័ន្ធ ង *ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា* ២៧៦

# តារាងលំហាត់

**ការចរចា**


គណនាតម្លៃជាទឹកប្រាក់ដែលត្រូវរំពឹងទុក ២៤
តម្លៃបម្រុង ២៩
ការចរចារបែបបែងចែក ៣៣
ល្បែងទ្វេគ្រោះរបស់អ្នកទោស ៣៧
បញ្ហាពាក់ព័ន្ធនឹងទស្សនៈយល់ឃើញ ៤៥
រិះរកគំនិត ៥៨
ករណីចរចារទី១: ក្រុមហ៊ុនឈើហ៊ុបខ្មែរ ៧៣
ករណីចរចារទី២: សាជីវកម្មឈើបារាំង ៧៤


**សន្ធានកម្ម**


ស្វែងយល់អំពីការប្រាស្រ័យទាក់ទងដែលមិនមែនជាពាក្យសម្តី ១១៥
ការបកស្រាយឡើងវិញ ១១៨
ក្រមសីលធមិសន្ធានការី : មុនពេលធ្វើសន្ធានកម្ម ១២៩
ក្រមសីលធមិសន្ធានការី :ក្នុងកំឡុងពេលធ្វើសន្ធាកម្ម ១៣១
ក្រមសីលធមិសន្ធានការី : ក្រោយពេលសន្ធានកម្ម ១៣៣
រឿងក្តីសន្ធានកម្មទី១ : របងរលំ ១៣៦
រឿងក្តីសន្ធានកម្មទី២ : ការប្រកែកគ្នាអំពីកិច្ចការរដ្ឋបាល ១៣៧
រឿងក្តីសន្ធានកម្មទី៣ : ការប្រកែកគ្នាអំពីគម្រោងរួម ១៣៨
រឿងក្តីសន្ធានកម្មទី៤ : តារាភាពយន្ត ១៣៩


**មជ្ឈត្តការ**


ការតាត់តែងខថែងស្តីពីមជ្ឈត្តការ ១៦៤
ក្រមសីលធមិមជ្ឈត្តករ ១៨៧
រឿងក្តីមជ្ឈត្តការ :ការបៀតបៀននៅកន្លែងធ្វើការ ១៩៧


**មជ្ឈត្តការ/សន្ធានកម្ម**


តុព្រះមហាក្សត្រ ២០៧

# គោលបំណងនៃសៀវភៅសិក្សានេះ

គោលបំណងជាបឋមនៃសៀវភៅនេះ គឺដើម្បីណែនាំឱ្យនិស្សិត និងអ្នកមានវិជ្ជាជីវៈកម្ពុជា បានស្គាល់អំពីទស្សនាទានទំនើបនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ឬ“ADR” ។ ទោះបីជាប្រជាជនកម្ពុជាជាច្រើនដឹងថាវិវាទអាចដោះស្រាយក្រៅប្រព័ន្ធតុលាការដោយមិនបាច់មានការជំនុំជម្រះដែលមានពីមុនមកដោយតុលាការក៏ដោយ ក៏បច្ចុ-ប្បន្ននេះ មានឯកសារតិចតួចណាស់ដែលពន្យល់អំពីមធ្យោបាយដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការទាំងនេះ ។ ជាលទ្ធផល និស្សិត អ្នកអនុវត្តផ្ទាល់ ព្រមទាំងអ្នកប្រកបវិជ្ជាជីវៈច្បាប់ និងតុលាការកម្ពុជា មិនសូវបានជួបប្រទះការអនុវត្តទំនើបៗក្នុងដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ព្រមទាំងតួនាទីរបស់វានៅក្នុងប្រព័ន្ធយុត្តិធម៌កម្ពុជាឡើយ ។ ដោយសារតែដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺជាផ្នែកចម្បងនៃទិដ្ឋភាពច្បាប់ក្នុងអតីតកាល បច្ចុប្បន្នកាល និងអនាគតកាលរបស់ប្រទេសកម្ពុជា សៀវភៅនេះមានគោលដៅផ្តល់ដល់អ្នកអាន នូវការយល់ដឹងជាមូលដ្ឋានអំពីគោលការណ៍ទំនើបៗនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការទាំងនេះ ។

ទស្សនាទានជាមូលដ្ឋាននៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺជាផ្នែកមួយដែលគេអាចមើលឃើញនៅក្នុងការអនុវត្តន៍ប្រចាំថ្ងៃក្នុងប្រទេសកម្ពុជា ។ ឧទាហរណ៍ ការចរចាគឺជាផ្នែកចម្បងនៃកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសកម្ពុជាក្នុងដំណោះស្រាយវិវាទផ្សេងៗ ។ វាគឺជាជំហានដំបូងជាធម្មជាតិក្នុងដំណោះស្រាយវិវាទភាគច្រើន ចាប់ពីវិវាទដ៏សាមញ្ញលើតម្លៃបន្លែនៅតាមទីផ្សារ រហូតដល់វិវាទដែលមានវិសាលភាពជាងនេះ ដូចជាពាក់ព័ន្ធទៅនឹងគម្រោងសាងសង់ដ៏ធំមួយជាដើម ។ ស្រដៀងគ្នានេះ សន្ធានកម្មក៏ជាផ្នែកមួយនៃប្រពៃណីរបស់កម្ពុជាដែរ ។ ឧទាហរណ៍ គូស្វាមីភរិយាទាំងឡាយ តែងតែស្វែងរកសន្ធានកម្ម ជាញឹកញាប់ ពីសំណាក់ព្រឹទ្ធាចារ្យក្នុងភូមិ ដែលមានការគោរពរាប់អានពីអ្នកផងឬពីក្រុមប្រឹក្សាឃុំសង្កាត់នៅតាមមូលដ្ឋាន លើវិវាទក្នុងជីវិតអាពាហ៍ពិពាហ៍របស់ខ្លួន ។ ហើយទោះបីជា មជ្ឈត្តការមិនមានការនិយមដូចនោះក៏ដោយ ក៏ក្នុងដំណោះស្រាយវិវាទទំនើបៗ វាបានក្លាយទៅជាយន្តការមួយដែលមានសារៈ-សំខាន់កាន់តែខ្លាំងឡើងដែរ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលត្រូវបានគេទទួលស្គាល់ជាទូទៅនោះ បានធ្វើមជ្ឈត្តការលើបញ្ហាសំខាន់ៗជាច្រើន ពាក់ព័ន្ធនឹងការគ្រប់គ្រងកម្មករនិយោជិក ក្នុងវិស័យឧស្សាហកម្មកាត់ដេរ និងវាយនភ័ណ្ឌ និងវិស័យសណ្ឋាគារ ។ ឥឡូវនេះ ដោយសាររាជរដ្ឋាភិបាលបានអនុម័តច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មរួចមក តួនាទីរបស់មជ្ឈត្តការនឹងពង្រីកទៅដល់មជ្ឈដ្ឋានពាណិជ្ជកម្មថែមទៀត ជាពិសេស នៅពេលដែលមជ្ឈមណ្ឌលមជ្ឈត្តការជាតិរបស់ក្រសួងពាណិជ្ជកម្ម ចាប់ផ្តើមដំណើរការ ។

ផ្នែកនីមួយៗនៃសៀវភៅនេះពន្យល់អំពីដំណើរការដោះស្រាយស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងក្របខ័ណ្ឌច្បាប់ ជុំវិញដំណើរការទាំងនោះ ក៏ដូចជាផ្តល់ឧទាហរណ៍អំពីរបៀបប្រើប្រាស់ដំណើរការទាំងនោះ ព្រមទាំងដាក់បញ្ចូលបញ្ហាសម្រាប់សិក្សា ដែលផ្អែកលើរឿងក្តីជាសម្មតិកម្ម និងលំហាត់អនុវត្តន៍ ដែលអាចឱ្យអ្នកអានមានឱកាសស្គាល់កាន់តែច្បាស់នូវវិធីសាស្ត្រនីមួយៗ ។ គេអាចប្រើសៀវភៅនេះ ក្នុងថ្នាក់រៀនអន្តរកម្មដែលសិស្សនិស្សិតរៀនអាចរៀនសូត្របានតាមរយៈការចូលរួមធ្វើលំហាត់ទាំងនោះ ។

## រចនាសម្ព័ន្ធនៃសៀវភៅនេះ

សៀវភៅនេះចាប់ផ្តើមដោយធ្វើសេចក្តីផ្តើមអំពីដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ មុននឹងពិនិត្យមើលចំណុចលម្អិតនៃដំណើរការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការណាមួយ អ្នកអានត្រូវយល់ថា អ្វីទៅជាដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ហើយតើហេតុអ្វីបានជាគេប្រើប្រាស់ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះ ហើយតើវាពាក់ព័ន្ធយ៉ាងដូចម្តេចចំពោះអ្នកប្រកបវិជ្ជាជីវៈច្បាប់កម្ពុជា។ អាស្រ័យហេតុនេះ ជំពូកទី១ ផ្តោតទៅលើចំណុចដែលស្តីពី អ្វីទៅជាដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ហេតុអ្វីបានជាត្រូវប្រើប្រាស់ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងដោយរបៀបណា។ ជំពូកទី២ ផ្តោតលើការចរចា ដែលជាទម្រង់ពេញនិយមបំផុតនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ជំពូកទី៣ ផ្តោតលើសន្ទានកម្ម ដែលស្ថាបនាបន្ថែមលើទស្សនាទានជាច្រើន ដែលបានបកស្រាយនៅក្នុងជំពូកមុន។ ជំពូកទី៤ ផ្តោតលើមជ្ឈត្តការ។ ជំពូកនេះពន្យល់អំពីភាពខុសគ្នា និងដូចគ្នារវាង មជ្ឈត្តការ និងបណ្តឹងទៅតុលាការ ដែលមានពីមុនមក។ ជំពូកទី៥ ធ្វើការប្រៀបធៀបវិធីសាស្ត្រទាំងបី ដើម្បីជួយឱ្យអ្នកអានកំណត់ថា តើវិធីសាស្ត្រមួយណាដែលសមស្របបំផុតនៅក្នុងកាលៈទេសៈផ្សេងៗគ្នា។ ជំពូកនេះក៏រៀបរាប់ផងដែរ អំពីការអង្កេតជាសង្ខេបលើវិធីសាស្ត្រនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការបន្ថែមទៀត ដែលត្រូវបានបង្កើតឡើងកាលពីប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ។

# ជំពូកទី១: សេចក្តីផ្តើមអំពីដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

## ក. តើអ្វីទៅជាដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (ADR)?

Alternative Dispute Resolution ឬ ADR មានន័យថាដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ វាសំដៅដល់វិធីផ្សេងៗដែលភាគីដែលមានវិវាទនឹងគ្នា អាចដោះស្រាយវិវាទក្រៅអំពីប្រព័ន្ធជំនុំជម្រះដែលមានពីមុនមក ដែលពឹងផ្អែកទាំងស្រុងលើតុលាការ។ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រមូលផ្តុំទៅដោយទម្រង់ជាច្រើននៃ វិធីដោះស្រាយវិវាទ ដែលមួយចំនួនមានលក្ខណៈសាមញ្ញ និងខ្លះទៀតមានលក្ខណៈថ្មីប្លែក។ មជ្ឈត្តការ ការចរចា និង សន្ធានកម្ម គឺជាទម្រង់ទូទៅបំផុតនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ អ្នកច្បាប់បានហៅទម្រង់នៃទាំងនេះថា *"ក្រៅប្រព័ន្ធតុលាការ"* ពីព្រោះសព្វថ្ងៃនេះប្រជាជនជាច្រើន ចាត់ទុកតុលាការជាទម្រង់ចម្បងនៃដំណោះស្រាយវិវាទ ចំណែកឯទម្រង់ដទៃទៀត គឺជាទម្រង់ក្រៅដោយឡែក។

ប៉ុន្តែដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មានឬសគល់ប្រវត្តិសាស្ត្រយ៉ាងជ្រាលជ្រៅ នៅក្នុងបណ្តាប្រទេស និងវប្បធម៌ជាច្រើន។ ឧទាហរណ៍ នៅប្រទេសកម្ពុជា ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជាផ្នែកមួយដ៏សំខាន់នៅក្នុងប្រព័ន្ធដោះស្រាយវិវាទតាមទំនៀមទម្លាប់នៅតាមភូមិ។ ចំនុចនេះនឹងមានបកស្រាយលម្អិតក្នុងជំពូកជាបន្តបន្ទាប់។

សព្វថ្ងៃនេះ ប្រទេសកម្ពុជាកំពុងបង្កើតយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជាផ្លូវការតាមរយៈច្បាប់។ នៅឆ្នាំ២០០១ កម្ពុជាបានអនុម័តច្បាប់ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដំបូងរបស់ខ្លួន ដែលបានបង្កើតឡើងនូវក្រុមប្រឹក្សាអាជ្ញាកណ្តាល។[១] បន្ទាប់មក នៅឆ្នាំ២០០៦ ប្រទេសកម្ពុជាបានអនុម័តច្បាប់ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជាលើកទីពីរ ហៅថាច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។[២] នៅឆ្នាំដដែលនោះ ប្រទេសកម្ពុជាក៏បានអនុម័តផងដែរនូវក្រមនីតិវិធីរដ្ឋប្បវេណីថ្មី ដែលអនុញ្ញាតយ៉ាងជាក់លាក់ឱ្យមានការប្រើប្រាស់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ទោះបីជាបន្ទាប់ពីភាគីដើមចោទបានដាក់ពាក្យបណ្តឹងទៅតុលាការរួចក៏ដោយ។ ជាលទ្ធផល ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ បានក្លាយជាផ្នែកដ៏សំខាន់នៃប្រព័ន្ធច្បាប់ជាផ្លូវការរបស់ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។

ហេតុអ្វីបានជាប្រទេសកម្ពុជា អនុម័តច្បាប់ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការទាំងនេះ? ដើម្បីយល់ដឹងអំពីផលប្រយោជន៍នៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គេត្រូវត្រឡប់ទៅស្វែងយល់អំពីចរិតនៃវិវាទជាមុនសិន។

## ខ. ការដោះស្រាយបញ្ហា

ជាឧទាហរណ៍ យើងទាំងអស់គ្នាធ្លាប់ឆ្លងកាត់ពេលវេលា ឬទេសកាលណាមួយនៅក្នុងជីវិត ដែលយើងចង់បាននូវអ្វីដែលយើងមិនមាន។ គេអាចហៅការណ៍នេះថាជាបញ្ហា។ យើងអាចជ្រើសរើសដោយមិនអើពើចំពោះបញ្ហានោះ ឬយើងអាចធ្វើអ្វីម្យ៉ាង។ ប្រសិនបើយើងសម្រេចចិត្តថានឹងធ្វើអ្វីម្យ៉ាង នោះជាទូទៅ យើងអាចជ្រើសរើសនូវវិធីដើម្បីបានអ្វី

[១] **ប្រកាសរបស់ក្រសួងការងារ** លេខ ៣១៧-០១ (ឆ្នាំ២០០១)

[២] **ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា** រាជកិច្ចលេខ ៣៧ ទំព័រ ៣០០០ (ឆ្នាំ២០០៦)

ដែលយើងចង់បាន។ ប្រសិនបើយើងសាកល្បង ហើយបរាជ័យនោះ បញ្ហានោះអាចក្លាយទៅជាវិវាទ។ ចូរពិនិត្យរឿងរ៉ាវខាងក្រោមនេះ ជាឧទាហរណ៍:

សុភា ជាយុវតីដែលមានអាយុ១៩ឆ្នាំ ។ នាងមានបងស្រីម្នាក់ឈ្មោះ ស្រីមុំ ។ ថ្ងៃមួយ ស្រីមុំ សម្រេចចិត្តថា នឹងនឹងយកម៉ូតូរបស់គ្រួសារនាង ទៅជិះដើរលេងនៅទីក្រុងពេញមួយថ្ងៃ ជាមួយសង្សាររបស់នាង។ សុភា អន់ចិត្តយ៉ាងខ្លាំង ពីព្រោះនាងត្រូវការម៉ូតូនៅថ្ងៃនោះ ដើម្បីទៅផ្ទះបងប្អូនជីដូនមួយរបស់នាង។ នាងអាចជ្រើសរើសដោយមិនធ្វើអ្វីទាំងអស់ចំពោះរឿងនោះ ឬនាងអាចព្យាយាមយកម៉ូតូនោះ ។ នាងសម្រេចចិត្តថានាងពិតចង់ទៅមែនទែន ដូច្នេះនាងក៏សុំ ស្រីមុំ ដើម្បីប្រើម៉ូតូនោះ។

ប្រសិនបើនាងសុំស្រីមុំប្រើម៉ូតូនោះ ហើយស្រីមុំព្រមប្រគល់ម៉ូតូឱ្យនាង ពេលនោះនាងនឹងសម្រេចបានគោលដៅរបស់ខ្លួន ពោលគឺនាងទទួលបានកម្មសិទ្ធិលើម៉ូតូសម្រាប់ថ្ងៃនោះ។ សំរាប់នាង បញ្ហានោះគឺត្រូវបានដោះស្រាយហើយ។ ប្រសិនបើ ស្រីមុំនិយាយថា: "ទេ! ថ្ងៃនេះឯងមិនអាចយកម៉ូតូបានទេ។ បងត្រូវប្រើវា។" ពេលនោះសុភា មានជម្រើសមួយ។ នាងអាច មិនអើពើរចំពោះបញ្ហានេះ ហើយប្រហែលជាប្រាប់ខ្លួនឯងថានាងអាចទៅជួបបងប្អូនជីដូនមួយរបស់នាងនាថ្ងៃស្អែកក៏បាន។ ឬ នាងអាចបន្តព្យាយាមយកម៉ូតូនោះឱ្យបាន។ ប្រសិនបើនាងជ្រើសរើសជម្រើសទីមួយ គឺនាងជ្រើសរើសមិនធ្វើអ្វីទាំងអស់ ដែលជួនកាលត្រូវបានហៅថា "ការមិនចាត់វិធានការអ្វីទាំងអស់"។ ប្រសិនបើនាងជ្រើសរើសជម្រើសទីពីរ ពេលនោះនាងនឹងបង្វែរស្ថានភាពនោះឱ្យទៅជាវិវាទមួយ។

រឿងដ៏សាមញ្ញនេះអាចត្រូវបានវិភាគកាន់តែលម្អិតថែមទៀត តាមរយៈក្រាហ្វិកនៅទំព័របន្ទាប់នេះ។

# ដើមហេតុនៃវិវាទ



បញ្ហាជាអាទិ៍ : សុភាចង់ប្រើម៉ូតូ ដែលស្រីមុំគ្រោងនឹងប្រើដែរ ។
ជម្រើសរបស់សុភា
មិនចាត់វិធានការអ្វីទាំងអស់
ព្យាយាមយកម៉ូតូទៅប្រើប្រាស់
ព្យាយាមបញ្ចុះបញ្ចូល ស្រីមុំ ឱ្យប្រគល់ម៉ូតូឱ្យនាង
ព្យាយាមយកម៉ូតូពី ស្រីមុំ ដោយបង្ខំ
សុំម្ដាយ ឬអ្នកផ្សេង ឱ្យជួយយកម៉ូតូ
ស្រីមុំ ឆ្លើយថាយល់ព្រម ហើយប្រគល់ម៉ូតូឱ្យ សុភា
ស្រីមុំ និយាយថាទេ ហើយបដិសេធមិនប្រគល់ម៉ូតូឱ្យ សុភា
?
មិនចាត់វិធានការអ្វីទាំងអស់
សុភា សម្រេចចិត្តចាត់វិធានការបន្តទៀត ។ ឥឡូវនេះ វិវាទកើតមានហើយ

ក្រាហ្វិកនេះបង្ហាញពីការគណនាដ៏ស្មុគស្មាញ ដែលអាចមាននៅក្នុងខួរក្បាលរបស់សុភា នៅពេលដែលនាងពិចារណាលើស្ថានភាព ហើយសម្រេចចិត្តថាមានប្រតិកម្មយ៉ាងដូចម្តេច។ នាងអាចថ្លឹងថ្លែងផលវិបាកនៃសកម្មភាពរបស់នាងដោយតក្កនុលោមរបៀបនេះ ប៉ុន្តែគិតវានៅក្នុងកម្រិតអនុសម្បជញ្ញៈមួយយ៉ាងឆាប់រហ័ស។ នាងអាចនឹងមិនដឹងថាខួរក្បាលរបស់នាងបានធ្វើលំហាត់នេះផង។

ដូចដែលក្រាហ្វិកបានបង្ហាញ សុភាមានឱកាសច្រើនក្នុងការបញ្ចប់បញ្ហា ដោយមិនបង្វែរវាឱ្យទៅជាវិវាទ។

**សំណួរសិក្សា**

- ហេតុអ្វីបានជា សុភា អាចជ្រើសរើសមិនចាត់វិធានការអ្វីទាំងអស់ ប្រសិនបើនាងចង់ប្រើប្រាស់ម៉ូតូនោះ?
- តើមានផលវិបាកអ្វីខ្លះចំពោះ សុភា ប្រសិនបើនាងសម្រេចចិត្តបង្វែរបញ្ហានោះឱ្យទៅជាវិវាទ?
- នៅក្នុងជីវិតផ្ទាល់ខ្លួនរបស់អ្នក តើអ្នកធ្លាប់ជ្រើសរើសមិនចាត់វិធានការអ្វីទាំងអស់ចំពោះបញ្ហាដែលអ្នកមានដែរឬទេ ? ប្រសិនបើធ្លាប់ ហេតុអ្វី ?

ជីវិតគឺពោរពេញទៅដោយបញ្ហាសាមញ្ញៗទាំងនេះ ហើយជាធម្មតា យើងដោះស្រាយបញ្ហាតាមវិធីណាមួយដែលងាយស្រួល ឆាប់រហ័ស និងដោយមិនមានការបាត់បង់អ្វីច្រើន។ ជួនកាល ការមិនអើពើរចំពោះបញ្ហាគឺជាយុទ្ធសាស្រ្តដ៏ល្អបំផុត។ នៅក្នុងឧទាហរណ៍ខាងលើ សុភា អាចមានលទ្ធភាពទៅសួរសុខទុក្ខបងប្អូនជីដូនមួយរបស់នាង នៅថ្ងៃបន្ទាប់។ ឬ នាងអាចដឹងថាឪពុកម្តាយរបស់នាង គ្រោងនឹងទិញម៉ូតូមួយគ្រឿងទៀត ដូច្នេះនាងអាចជិះម៉ូតូណាមួយបានគ្រប់ពេលទាំងអស់។ ប្រសិនបើនាងនៅតែទទូចយកម៉ូតូពី ស្រីមុំ ម្តាយរបស់នាងអាចជ្រើសរើសមិនទិញម៉ូតូ ពីព្រោះគាត់ អាចខឹងនឹងសុភា ដែលជាមនុស្សអាត្មានិយមបែបនេះ។

ការបង្វែរបញ្ហាឱ្យទៅជាវិវាទ ក៏មានសក្តានុពលក្នុងការបំផ្លាញទំនាក់ទំនងរវាងបុគ្គលនីមួយៗដែលជាប់ពាក់ព័ន្ធផងដែរ។ វិវាទប៉ះពាល់ដល់ទំនាក់ទំនង ដោយបង្កើតជាអារម្មណ៍មិនល្អរវាងគ្នា និងគ្នា ជាពិសេសប្រសិនបើមានភាគីណាមួយត្រូវចាញ់។ ប្រសិនបើ សុភា ឱ្យតម្លៃខ្ពស់លើទំនាក់ទំនងរបស់នាងជាមួយ ស្រីមុំ នាងអាចសម្រេចចិត្តថាការបង្កវិវាទអំពីរឿងម៉ូតូមិនមានផលអ្វីនោះទេ។

## គ. បញ្ហាមួយក្លាយទៅជាវិវាទ

ដើម្បីដឹងថាតើទំនាក់ទំនងត្រូវបានប៉ះពាល់ដោយវិវាទយ៉ាងដូចម្តេច ចូរពិចារណាលើបញ្ហាដូចខាងក្រោម ។

ឥឡូវនេះ សុភា មានអាយុច្រើនជាងមុន ហើយបានមកធ្វើការនៅក្នុងភោជនីយដ្ឋានមួយនៅក្នុងខេត្តកំពង់ចាម។ នាងទទួលបានប្រាក់បៀវត្សរ៍ ៧៥ដុល្លាអាមេរិក ក្នុងមួយខែ ប៉ុន្តែនាងបានដឹងថាបុគ្គលិកផ្សេងទៀត ទទួលបានប្រាក់បៀវត្សរ៍ច្រើនជាងនាង ដោយធ្វើការដូចគ្នា។ នាងមានអារម្មណ៍មិនល្អអំពីរឿងនេះ ដោយសារនាងធ្វើការច្រើនជាងគេនៅក្នុងភោជនីយដ្ឋាន ហើយបានធ្វើការនៅទីនោះយូរជាងអ្នកផ្សេងទៀត ។ តើនាងអាចធ្វើអ្វីបាន ?

នាងអាចមិនអើពើរចំពោះបញ្ហានោះហើយព្យាយាមមិនខ្វាយខ្វល់ពីវា។ ឬ នាងអាចសម្រេចចិត្តចាត់វិធានការណាមួយ។ វិធានការមួយដែលនាងអាចធ្វើបាន គឺជួបតទល់ក្រៅផ្លូវការជាមួយអ្នកចាត់ការភោជនីយដ្ឋាន ហើយពន្យល់គាត់ថា នាងទទួលបានប្រាក់បៀវត្សរ៍មិនគ្រប់គ្រាន់។ ប្រសិនបើអ្នកចាត់ការយល់ព្រម ហើយដំឡើងប្រាក់បៀវត្សរ៍ឱ្យនាងពេលនោះ បញ្ហាត្រូវបានដោះស្រាយហើយ។ ប្រសិនបើអ្នកចាត់ការមិនយល់ព្រម ពេលនោះនឹងមានវិវាទកើតឡើង ហើយសុភា ត្រូវជ្រើសរើសថាត្រូវចាត់វិធានការបន្ត ឬអត់។ ប្រសិនបើនាងសម្រេចចិត្តថានឹងចាត់វិធានការទៀត នាងអាចគំរាមអ្នកចាត់ការនោះ អំពីផលវិបាកមួយចំនួន។ ឬនាងអាចដាក់ពាក្យប្ដឹងគាត់។ ក្រាហ្វិកខាងក្រោមបង្ហាញអំពីជម្រើសផ្សេងៗ។

## ជម្រើសនៃដំណោះស្រាយវិវាទដែលមានពីមុនមក

បញ្ហាជាអាទិ៍: សុភា ចង់បានប្រាក់បៀវត្សរ៍ច្រើនជាងមុន ហើយស្នើសុំអ្នកចាត់ការឱ្យដំឡើង

អ្នកចាត់ការនិយាយថាយល់ព្រម
ហើយដំឡើងប្រាក់បៀវត្សរ៍ដល់ សុភា

មិនចាត់វិធានការ
អ្វីទាំងអស់

គំរាមអ្នកចាត់ការអំពីការបាត់បង់
ផលប្រយោជន៍ (ដោះស្រាយខ្លួនឯង)

?

សុភា ឈ្នះក្ដី ប៉ុន្តែឥឡូវនេះ ត្រូវអនុវត្ត
សាលក្រមចំពោះម្ចាស់ភោជនីយដ្ឋាន

?

អ្នកចាត់ការនិយាយថាទេ ហើយបដិសេធ
មិនដំឡើងប្រាក់បៀវត្សរ៍ដល់ សុភា

សុភា សម្រេចចិត្តចាត់វិធានការបន្ថែមទៀត ។
ឥឡូវនេះ វិវាទកើតមានឡើង

ដាក់ពាក្យប្ដឹងភោជនីយដ្ឋាន
(បណ្ដឹងទៅតុលាការដូចដែលមានពីមុនមក)

ភោជនីយដ្ឋានបណ្ដេញ សុភា ចេញ ។
ឥឡូវនេះ នាងត្រូវរកការងារថ្មីធ្វើ

សុភា ត្រូវជួលមេធាវីសម្រាប់រយៈពេល១ឆ្នាំ ទៅ២ឆ្នាំ
ដើម្បីប្ដឹងភោជនីយដ្ឋានតាមផ្លូវច្បាប់

សុភាចាញ់ក្ដី

នៅក្នុងក្រាហ្វិកខាងលើ លទ្ធផលល្អត្រូវបានតំណាងដោយប្រអប់ពណ៌បៃតង ហើយលទ្ធផលមិនល្អត្រូវបានតំណាងដោយប្រអប់ពណ៌ក្រហម។ ប្រអប់ពណ៌លឿងតំណាងឱ្យវិធានការរបស់ សុភា។ ដូចដែលក្រាហ្វិកនេះបានបង្ហាញ លទ្ធផលល្អតែមួយគត់ គឺប្រសិនបើអ្នកចាត់ការដំឡើងប្រាក់បៀវត្សរ៍ដល់នាងតាំងពីដំបូង។

### ១. ជម្រើសទីមួយ: ការដោះស្រាយដោយខ្លួនឯង

ប្រសិនបើនាងគំរាមអ្នកចាត់ការអំពីការខូចប្រយោជន៍ណាមួយ (អាចជាផ្នែករូបរាងកាយ ឬហិរញ្ញវត្ថុ) លទ្ធផលមានភាពមិនច្បាស់លាស់។ អ្នកចាត់ការអាចគំរាមវិញថានឹងធ្វើឱ្យនាងខូចប្រយោជន៍ ឬអាចជាក់ស្តែងបានធ្វើឱ្យនាងខូចប្រយោជន៍រួចទៅហើយតាមវិធីណាមួយ។ គាត់ទំនងជាអាចបណ្តេញនាងចេញពីការងារ។ គាត់អាចហៅនគរបាលឱ្យចាប់ខ្លួននាង។ ទោះបីជាគាត់មានប្រតិកម្មបែបណាក៏ដោយ វាមានសង្ឃឹមតិចតួចណាស់ថាគាត់នឹងយល់ព្រមដំឡើងប្រាក់បៀវត្សរ៍ឱ្យនាង។ ការគំរាមកំហែងអំពីការខូចប្រយោជន៍ គឺជាឧទាហរណ៍មួយនៃ "ការដោះស្រាយដោយខ្លួនឯង"។

នៅក្នុងករណីជាច្រើន យើងសង្ឃឹមលើដំណោះស្រាយដោយការជួយខ្លួនឯង ដើម្បីដោះស្រាយបញ្ហារបស់យើង។ ប៉ុន្តែជាញឹកញាប់វាអាចជាចំណេះជិះកងង ហើយមិនដោះស្រាយបញ្ហានោះបានឡើយ ប៉ុន្តែបែរជាធ្វើឱ្យបញ្ហានោះកាន់តែធ្ងន់ធ្ងរថែមទៀត។ លើសពីនេះទៅទៀត ដំណោះស្រាយដោយខ្លួនឯងច្រើនតែខុសច្បាប់។ ជម្រើសនេះមិនមែនជាជម្រើសដែលល្អបំផុតសម្រាប់ សុភា នោះទេ។

## សំណួរសិក្សា

- តើអ្នកអាចគិតពីស្ថានភាពណាមួយ ដែលខ្លួនអ្នកផ្ទាល់ ឬអ្នកណាម្នាក់ដែលអ្នកស្គាល់ជ្រើសរើសយក ដំណោះស្រាយ "ដោយខ្លួនឯង" នៅក្នុងវិវាទដែរឬទេ?
- តើបានលទ្ធផលយ៉ាងដូចម្តេច?

### ២. ជម្រើសទីពីរ: បណ្តឹងទៅតុលាការតាមទម្លាប់ពីមុនមក

សុភា អាចជ្រើសរើសយកការដាក់បណ្តឹងទៅតុលាការតាមទម្លាប់ពីមុនមក ដោយធ្វើពាក្យប្តឹងភោជនីយដ្ឋាននោះ។ ដូចដែលក្រាហ្វិកខាងលើបានបង្ហាញ លទ្ធផលអាចនឹងមិនមែនជាទីគាប់ចិត្តឡើយ។ នាងអាចនឹងបាត់បង់ការងាររបស់ខ្លួន។ នាងអាចនឹងត្រូវបង់ថ្លៃឈ្នួលមេធាវីដ៏ខ្ពស់សម្រាប់រយៈពេលជាងមួយឆ្នាំ។ នាងអាចនឹងត្រូវឆ្លើយសំណួរផ្សេងៗ របស់ចៅក្រម និងមេធាវីរបស់ភោជនីយដ្ឋានថែមទៀត។

ជាកិច្ចការពារខ្លួន ភោជនីយដ្ឋានអាចតវ៉ាថា សុភាមិនមែនជាបុគ្គលិកល្អ ហើយអាចលើកឡើងនូវឧទាហរណ៍កំហុសពីអតីតកាលដែលនាងប្រព្រឹត្ត។ ភោជនីយដ្ឋានអាចស្នើសុំឱ្យអតិថិជន និងបុគ្គលិកដទៃទៀតធ្វើជាសាក្សីដាក់បន្ទុកលើសុភា ហើយតវ៉ាថានាងមិនមែនជាបុគ្គលិកល្អនោះទេ។ បុគ្គលិកដទៃទៀតទាំងនេះអាចមិនចង់ធ្វើបែបនោះទេ ប៉ុន្តែអាចមានអារម្មណ៍ថាពួកគេត្រូវតែធ្វើ ដើម្បីរក្សាការងាររបស់ខ្លួននៅភោជនីយដ្ឋាន។ ចំណុចនេះអាចជាករណី គួរឱ្យរំខាន និងតានតឹងសម្រាប់សុភា។ នៅទីបញ្ចប់សុភាអាចចាញ់ក្តីនោះ។ ទោះបីជានាងឈ្នះក៏ដោយ ក៏នាងប្រហែលជាត្រូវបាត់បង់

ការងារ បង់ថ្លៃឈ្នួលមេធាវីដ៏ច្រើនលើសលុប ឆ្លងកាត់បទពិសោធន៍ឈឺចាប់ដ៏យូរអង្វែង ហើយនាងអាចមិនមានលទ្ធភាពអនុវត្តសាលក្រមឡើយ ប្រសិនបើភោជនីយដ្ឋានលាក់បាំងទ្រព្យសម្បត្តិរបស់ខ្លួន ឬឈប់ប្រកបអាជីវកម្ម។

ដូច្នេះ វិធានការទាំងពីរយ៉ាង គឺការដោះស្រាយដោយខ្លួនឯង និងការដាក់បណ្ដឹងតាមទំនៀមទម្លាប់ ហាក់ដូចជាបំផ្លាញទំនាក់ទំនងរបស់សុភាជាមួយអ្នកចាត់ការ ក៏ដូចជាជាមួយភោជនីយដ្ឋាននោះផ្ទាល់។ វិធានការទាំងពីរអាចនឹងធ្វើឱ្យសុភាបាត់បង់ការងាររបស់ខ្លួន។

## សំណួរសិក្សា

- តើលោកអ្នក ឬអ្នកដែលលោកអ្នកស្គាល់ ធ្លាប់ដាក់ពាក្យប្ដឹងទៅតុលាការដែរឬទេ ?
- តើវាត្រូវការរយៈពេលប៉ុន្មានទើបដំណើរការក្ដីនោះបានបញ្ចប់ ?
- តើត្រូវបង់ប្រាក់អស់ប៉ុន្មានសម្រាប់ថ្លៃឈ្នួលមេធាវី និងកម្រៃដទៃទៀត ?
- តើទទួលបានលទ្ធផលយ៉ាងណា ?

### ៣. ជម្រើសទីបី: *ការមិនអើពើចំពោះបញ្ហា*

ឥឡូវចំពោះសុភា ការកែខៃបញ្ហាដោយការជួយខ្លួនឯង និងការដាក់បណ្ដឹងតាមទំនៀមទម្លាប់នោះ មិនសូវជាមានភាពទាក់ទាញប៉ុន្មានទេ។ យ៉ាងណាមិញ ក្នុងរឿងនេះ ការធ្វើមិនអើពើចំពោះបញ្ហាក៏អាចមិនមែនជាដំណោះស្រាយដ៏វិសេសវិសាលបំផុតនោះដែរ។ ការមិនអើពើចំពោះបញ្ហាប្រាក់បៀវត្ស៍ អាចធ្វើឱ្យសុភាធ្វើការតិចជាងមុន។ នាងអាចពោលប្រាប់ខ្លួនឯងដោយមិនដឹងខ្លួនថា: "បើខ្ញុំទទួលបានប្រាក់បៀវត្ស៍មិនត្រឹមត្រូវនោះ មានហេតុផលអ្វីដែលខ្ញុំត្រូវធ្វើការងារច្រើននោះ?"។ ប៉ុន្តែ ប្រសិនបើអ្នកចាត់ការកត់សម្គាល់ឃើញថានាងធ្វើការតិច អ្នកចាត់ការអាចបណ្ដេញនាងចេញក៏ថាបាន។ ទោះជានាងមិនត្រូវបានបណ្ដេញចេញក៏ដោយ ក៏នាងអាចមានអារម្មណ៍តានតឹងចំពោះបញ្ហានេះ ហើយវាអាចប៉ះពាល់ដល់រូបនាងទាំងផ្លូវកាយ និងផ្លូវចិត្ត ។ ប្រហែលជាលើកក្រោយ នៅពេលដែលនាងមានការឈឺចាប់ជាមួយភោជនីយដ្ឋាននោះ នាងអាចមានប្រតិកម្មជ្រុល ពីព្រោះនាងនៅតែអន់ចិត្តពីរឿងប្រាក់បៀវត្ស៍នៅឡើយ។ ជួនកាលបញ្ហាតូចតាចទាំងនេះ ប្រសិនបើទុកក្នុងចិត្ត ហើយមិនដោះស្រាយ វាអាចរីកធំឡើង ហើយដល់ពេលណាមួយ នឹងក្លាយទៅជាអំពើហិង្សា ឬទម្រង់ផ្សេងទៀតនៃឥរិយាបថដែលមិនអំណោយផល និងប្រឆាំងនឹងសង្គម[៣] ។ ដោយសារ មូលហេតុទាំងនេះ លទ្ធផលរបស់សុភាក្នុងការជ្រើសរើសមិនចាត់វិធានការអ្វីទាំងអស់ គឺការមិនអើពើចំពោះបញ្ហា ត្រូវបានតំណាងដោយប្រអប់ពណ៌ក្រហម ដើម្បីបង្ហាញថានេះក៏ប្រហែលជាមិនមែនគំនិតដ៏ល្អនោះដែរ ។

ប្រសិនបើដំណោះស្រាយទាំងបីដែលបានបង្ហាញជូនខាងលើ គឺការជួយខ្លួនឯង ការដាក់បណ្ដឹងតាមទំនៀមទម្លាប់ និងការមិនអើពើចំពោះបញ្ហា មិនផ្ដល់លទ្ធផលល្អសម្រាប់ សុភា តើមានអ្វីក្រៅពីនេះទៀតដែរឬទេ?

---

[៣] ទស្សនាទានរបស់ខ្មែរដូចជា *គុំ គុំគួន គំនុំ* និង *គង្គួន* មានភាពជាប់ពាក់ព័ន្ធនៅទីនេះ ។ ដូចអ្នកអាចដឹងហើយថា គុំ សំដៅដល់ការផ្ទុកកំហឹង ដែលអាចបណ្ដាលឱ្យមានការសងសឹកនាពេលអនាគត។ ជាញឹកញាប់ ការសងសឹកមានវិសមាមាត្រទៅនឹងអំពើបង្កវិវាទខាងដើម ។ *សូមមើល ឧទាហរណ៍* Alexander Laban Hinton **ហេតុអ្វីបានជាពួកគេសម្លាប់?** ទំព័រ ៦៤ - ៧២ (គ្រឹះស្ថានបោះពុម្ពផ្សាយនៃសាកលវិទ្យាល័យកាលីហ្វ័រនីញ៉ា ឆ្នាំ២០០៥) ។

## ឃ. ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ផ្តល់លទ្ធភាពមួយចំនួនក្នុងជម្រើសដោះស្រាយបញ្ហា។ សព្វថ្ងៃនេះ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការបានក្លាយទៅជាផ្នែកដ៏សំខាន់នៃទិដ្ឋភាពច្បាប់ នៅប្រទេសកម្ពុជា និងនៅប្រទេសដទៃទៀត ដោយសារតែបញ្ហាដែលគេមើលឃើញនៅក្នុងប្រព័ន្ធតុលាការតាមទំនៀមទម្លាប់។ បញ្ហាទាំងនេះរួមមាន:

- ជាញឹកញាប់ រឿងក្តីត្រូវការពេលវេលាជាច្រើនឆ្នាំក្នុងការជំនុំជម្រះ។
- ភាគីវិវាទច្រើនស្ថិតនៅក្នុងស្ថានភាពលំបាក នៅពេលដែលវិវាទរបស់ពួកគេត្រូវបាន "តម្កល់" មិនចាត់ការ។
- ប្រសិនបើភាគីជួលមេធាវីឱ្យធ្វើជាតំណាងពួកគេ ភាគច្រើនពួកគេត្រូវបង់ប្រាក់កម្រៃ និងការចំណាយខ្ពស់ដើម្បីបន្តវិវាទរបស់ខ្លួនតទៅទៀត។
- ជាញឹកញាប់ភាគីនៃបណ្តឹងមានអារម្មណ៍ថា ពួកគេមិនមានលទ្ធភាពគ្រប់គ្រងលើដំណើរការនោះ។
- ជួនកាលភាគីមានការព្រួយបារម្ភអំពីអំពើពុករលួយនៅក្នុងប្រព័ន្ធតុលាការ។
- ចៅក្រមក៏មានកត្តារាំងស្ទះនៅក្នុងលទ្ធភាពធ្វើសេចក្តីសម្រេចរបស់ខ្លួន- ជាទូទៅ ពួកគេគ្រាន់តែអាចបង្គាប់ឱ្យបង់សំណងខូចខាតដល់ភាគីម្ខាង ឬភាគីម្ខាងទៀតប៉ុណ្ណោះ ហើយ
- ជាញឹកញាប់ ការវិនិច្ឆ័យនោះតែងបណ្តាលឱ្យមានការខាតបង់ទាំងស្រុងចំពោះភាគីម្ខាង ហើយអាចជះឥទ្ធិពលជាអវិជ្ជមានដល់ទំនាក់ទំនងរវាងភាគីវិវាទ។

ដោយសារបញ្ហាទាំងនេះ វាមិនមែនជាការដ៏គួរឱ្យភ្ញាក់ផ្អើលទេ ដែលភស្តុតាងជាបទពិសោធន៍នៅក្នុងប្រទេសកម្ពុជា បង្ហាញឱ្យឃើញថា កិច្ចសន្យាអន្តរជាតិភាគច្រើនតែងកំណត់យកវេទិកាដោះស្រាយវិវាទនៅក្រៅប្រទេស ដោយសារការមើលឃើញពីភាពមិនគួរឱ្យជឿជាក់បាននៃតុលាការក្នុងស្រុក។ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិរបស់ធនាគារពិភពលោក បានរាយការណ៍ថា :

> ការប្តឹងទៅតុលាការត្រូវបានសហគ្រិនទាំងឡាយចាត់ទុកថាកម្រនឹងអាចសម្រេចបាន ប៉ុន្តែជម្រើសនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធផ្សេងទៀតក៏មានភាពខ្វះចន្លោះចម្បងៗដែរ។ ដោយហេតុនេះ ទើបអាជីវកម្មជាច្រើនជ្រើសយកការ "កាត់បន្ថយការខាតបង់របស់ពួកគេ" ហើយគេចចេញឆ្ងាយពីវិវាទជាជាងស្វះស្វែងរកសិទ្ធិ និងអំណាចតាមផ្លូវច្បាប់របស់ខ្លួន។[៤]

ដោយសារមូលហេតុនេះ ដើម្បីជួយទាក់ទាញវិនិយោគបរទេសសំខាន់ៗ ប្រទេសកម្ពុជាត្រូវបន្តអភិវឌ្ឍបញ្ជីដ៏រឹងមា នៃជម្រើសក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។[៥]

---

[៤] *ព្រឹត្តបត្របញ្ហាអាជីវកម្ម* កម្មវិធីអភិវឌ្ឍវិស័យឯកជនតំបន់ទន្លេមេគង្គ នៅទំព័រទី ១ (សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ខែសីហា ឆ្នាំ២០០៧)។

[៥] គេអាចនិយាយបានថា ក្របខ័ណ្ឌគតិយុត្តិកំពុងតែប្រដេញជាមួយនឹងកំណើនសេដ្ឋកិច្ចដែលដូចសត្វខ្លារបស់ប្រទេសកម្ពុជា ។ ធនាគារពិភពលោកបានរាយការណ៍ថា ផលិតផលសរុបក្នុងស្រុករបស់ប្រទេសកម្ពុជាបានកើនដល់ ១៣.៥% ក្នុងឆ្នាំ២០០៥ ១០.៨% ក្នុងឆ្នាំ២០០៦ និង១០.៣ក្នុងឆ្នាំ២០០៧។ *ប្រវត្តិទិន្នន័យប្រទេសកម្ពុជា* ប្រព័ន្ធទិន្នន័យសូចនាកររបស់ធនាគារពិភពលោក (ខែមេសា ឆ្នាំ២០០៧) *មាននៅ* http://devdata.worldbank.org/external/CPProfile.asp?PTYPE=CP&CCODE=KHM (ចូលទស្សនាចុងក្រោយនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨)។

កាលពីប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះ ប្រជាជនជាច្រើនរំពឹងលើដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដើម្បីស្វែងរកចម្លើយក្នុងការដោះស្រាយវិវាទដែលជួយសម្រាល ឬជៀសវាងនូវកំហិតទាំងឡាយដូចដែលបានមើលឃើញនៅក្នុងប្រព័ន្ធតុលាការដែលមានពីមុនមក។ ឧទាហរណ៍ មជ្ឈត្តការកាន់តែក្លាយជាវិធីសាស្ត្រដ៏ឆាប់រហ័ស និងមានតម្លៃថោកក្នុងការដោះស្រាយវិវាទផ្សេងៗ បើប្រៀបធៀបជាមួយតុលាការ។ មជ្ឈត្តការគឺជាចម្លើយក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មុនគេបង្អស់ ដែលទទួលបានការគាំទ្រយ៉ាងទូលំទូលាយ ហើយនៅតែជាយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជាផ្លូវការ ដែលមានប្រជាប្រិយជាងគេបំផុតនៅក្នុងប្រព័ន្ធច្បាប់ដែលអភិវឌ្ឍភាគច្រើន។

យ៉ាងណាមិញ នាពេលថ្មីៗនេះសន្ធានកម្មក៏កាន់តែមានការទទួលស្គាល់ផងដែរ ថាជាយន្តការដោះស្រាយវិវាទមួយ។ សន្ធានកម្មផ្តល់ឱ្យភាគីនៃវិវាទនូវដំណោះស្រាយដ៏ឆាប់រហ័ស និងមានតម្លៃកាន់តែថោក ព្រមជាមួយនិងឱកាសរកដំណោះស្រាយដែលងាយបត់បែន និងដែលអាចរក្សាបាននូវទំនាក់ទំនងជាបន្តរវាងភាគីវិវាទ។ សន្ធានកម្មក៏មានលក្ខណៈស្ម័គ្រចិត្តដែរ ដោយភាគីអាចដោះស្រាយវិវាទ នៅពេលណាដែលពួកគេឯកភាពលើការស្រុះស្រួលតែប៉ុណ្ណោះ។

ជាងនេះទៅទៀត សន្ធានកម្ម និងទម្រង់ផ្សេងទៀតនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការត្រូវបានគេប្រើប្រាស់ជាឧបករណ៍សំរាប់ស្ថាបនាលទ្ធភាពទទួលបានយុត្តិធម៌។ នៅក្នុងប្រទេសជាច្រើន រួមទាំងប្រទេសកម្ពុជាផងដែរ ប្រព័ន្ធតុលាការផ្លូវការមានតម្លៃថ្លៃជ្រុលហួស សំរាប់ប្រជាជនក្រីក្របំផុតនៅក្នុងសង្គម។ ពួកគេមិនអាចរ៉ាប់រងប្រាក់ប្រដាប់ក្តី និងថ្លៃឈ្នួលមេធាវី ដែលមានភាពចាំបាច់ដល់ពួកគេក្នុងការទទួលបាន នូវការសម្រេចសេចក្តីពីតុលាការចំពោះវិវាទរបស់ពួកគេឡើយ។ ដោយសារតែទម្រង់ភាគច្រើននៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការអនុញ្ញាតឱ្យភាគីវិវាទដោះស្រាយវិវាទរបស់ពួកគេនៅក្នុងលក្ខណៈកាន់តែក្រៅផ្លូវការ និងមានតម្លៃថោកនោះ ទម្រង់ទាំងនេះអាចក្លាយជាមធ្យោបាយយ៉ាងសំខាន់ក្នុងការជួយប្រជាជនក្រីក្រ ដើម្បីដោះស្រាយវិវាទរបស់ពួកគេ ។

ដោយសារមូលហេតុទាំងនេះ និងមូលហេតុដទៃទៀតដែលនឹងត្រូវលើកយកមកពិភាក្សានៅក្នុងសៀវភៅនេះ វិធីសាស្ត្រដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការសម័យទំនើបកំពុងក្លាយជាផ្នែកដ៏សំខាន់ និងចម្បងនៃប្រព័ន្ធច្បាប់របស់ប្រទេសកម្ពុជា។ សៀវភៅនេះនឹងជួយអ្នកអានឱ្យយល់ដឹងបន្ថែមទៀតអំពីដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងរបៀបប្រើប្រាស់វាឱ្យមានប្រសិទ្ធភាពខ្ពស់។

# ជំពូកទី២: ការចរចា




**ចេះឯងអោយក្រែងចេះគេ។**

## ក. សេចក្តីផ្តើម

ជំពូកនេះផ្តោតទៅលើការចរចា។ វាមានគោលបំណងជួយដល់អ្នកទាំងឡាយ ដែលមានជាប់ពាក់ព័ន្ធក្នុងការចរចា ទោះជាការចរចាដើម្បីខ្លួនឯង ឬក្នុងនាមអ្នកដទៃក៏ដោយ។ ការចរចាគឺជាដំណើរការនៃការឆ្លើយឆ្លងគ្នាទៅវិញទៅមក ដែលតាមរយៈនេះ ភាគីទាំងអស់ដាក់ជូន ឬពិចារណាលើសំណើផ្សេងៗ រហូតដល់សំណើណាមួយត្រូវបានធ្វើឡើង ហើយត្រូវបានគេទទួលយក។[៦] ការចរចាគឺជាទម្រង់ដ៏សាមញ្ញបំផុតនៃដំណើរការដោះស្រាយវិវាទនៅទូទាំងពិភពលោក ដែលគេឃើញមានទាំងនៅក្នុងយុត្តាធិការនៃច្បាប់ស៊ីវិល (Civil Law) និងច្បាប់អង់គ្លេស (Common Law)។ ការចរចា អាចដោះស្រាយវិវាទធំ និងតូច ហើយអាចជាដំណើរការដ៏ស្មុគស្មាញបំផុត ឬសាមញ្ញធម្មតាមួយ។

មនុស្សធ្វើការចរចានៅគ្រប់ពេលទាំងអស់។ វាគឺជាទម្រង់សំខាន់បំផុតនៃការប្រាស្រ័យទាក់ទងរវាងមនុស្ស និងមនុស្ស។ មនុស្សធ្វើការចរចាទោះបីជានៅពេលគ្មានវិវាទក៏ដោយ។ ជាក់ស្តែង មនុស្សអាចចរចាគ្នាអំពីតម្លៃផ្លែស្វាយ ឬតម្លៃលក់ម៉ូតូជាដើម។ ពេលខ្លះ ពួកគេមិនទាំងដឹងផង ថាខ្លួនកំពុងតែចរចា។ ឧទាហរណ៍ នៅពេលបុគ្គលណាម្នាក់ព្យាយាមបញ្ចុះបញ្ចូលឱ្យក្រុមគ្រួសាររបស់ខ្លួនទៅធ្វើដំណើរកំសាន្ត ការចរចាអំពីកន្លែងដែលត្រូវទៅ ឬពេលវេលាចេញដំណើរ អាចនឹងកើតមាន។

ការចរចាអាចធ្វើឡើងតាមវិធីជាច្រើនយ៉ាងដូចជា ដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ។ ការចរចាអាចធ្វើឡើងដោយផ្ទាល់រវាងភាគីពីរ ឬតាមរយៈតំណាងរបស់ភាគីទាំងនោះ។ ការចរចាអាចធ្វើឡើងតាមបែបធម្មតា ឬមានលក្ខណៈផ្លូវការ។ គេអាចធ្វើការចរចាតាមរយៈសំបុត្រ ឬអ៊ីមែលផងដែរ។ នៅក្នុងប្រទេសកម្ពុជា ការចរចាច្រើនតែធ្វើឡើងនៅចំពោះមុខគ្នាផ្ទាល់ ប៉ុន្តែគេក៏អាចចរចាតាមទូរស័ព្ទផងដែរ។ នៅពេលមានការចរចាពាក់ព័ន្ធនឹងវិវាទតាមផ្លូវច្បាប់ ការចរចាអាចនឹងរួមផ្សំទៅដោយមធ្យោបាយទំនាក់ទំនងទាំងអស់នេះ។

---

[៦] *Gainey v. Brotherhood of Railway and S.S. Clerks, Freight Handlers, Exp. & Station Employees,* 275 F. Supp. 292, 300 (E.D. Pa. 1967)

ច្បាប់របស់ប្រទេសកម្ពុជាគាំទ្រឱ្យមានការចរចា។ ក្រមនីតិវិធីរដ្ឋប្បវេណីរបស់ប្រទេសកម្ពុជា លើកទឹកចិត្តឱ្យមានការស្រុះស្រួលគ្នាតាមការចរចារវាងភាគីពីរ។[៧] នៅសហរដ្ឋអាមេរិក និងយុត្តាធិការផ្សេងទៀត ការចរចា ក៏ត្រូវបានលើកទឹកចិត្តផងដែរ តាមរយៈវិធាននៃនីតិវិធីជាច្រើនផ្សេងគ្នា។[៨]

យុត្តាធិការជាច្រើនផ្តល់ភាពអនុគ្រោះដល់ដំណោះស្រាយវិវាទតាមរយៈការចរចា ដោយសារតែមានហេតុផលល្អ។ ដោយហេតុថាយុត្តាធិការជាច្រើនមានបញ្ជីរឿងក្តីជាច្រើនដែលមិនទាន់វិនិច្ឆ័យ វិធីតែម្យ៉ាងគត់ក្នុងការដោះស្រាយវិវាទឱ្យទាន់ពេលវេលា គឺលើកទឹកចិត្តភាគីវិវាទឱ្យពិភាក្សាអំពីបញ្ហានោះជាមួយគ្នា ហើយព្យាយាមឈានទៅរកការព្រមព្រៀងមួយ។ តួយ៉ាងដូចជានៅសហរដ្ឋអាមេរិក ៩០%នៃរឿងក្តីត្រូវបានដោះស្រាយក្រៅប្រព័ន្ធតុលាការ[៩] ហើយការចរចាគឺជាទម្រង់ដែលមានប្រជាប្រិយបំផុតនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ នៅប្រទេសកម្ពុជា ការអង្កេតលើក្រុមហ៊ុនតូចៗមួយចំនួន ដែលធ្វើឡើងដោយធនាគារពិភពលោក បានរកឃើញថា ការចរចាគឺជាវិធីសាស្ត្រដែលមានការនិយមជាងគេបំផុត ក្នុងការដោះស្រាយវិវាទ។[១០]

---

[៧] **ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,** រាជកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ទំព័រ៥២៩៦, ៥៣៣៦, មាត្រា៩៧ (ឆ្នាំ២០០៦) (" តុលាការអាចសាកល្បងធ្វើការផ្សះផ្សាបាន ទោះបីជាបណ្តឹងស្ថិតនៅក្នុងដំណាក់កាលណាក៏ដោយ ។") និងមាត្រា១០៤ (" នៅក្នុង នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវសាកល្បងផ្សះផ្សាជាដំបូងសិន...") [អំណឹះតទៅហៅកាត់ថា "ក.ន.រ.-ព.ក."]។ តាមមាត្រាទាំងនេះ តុលាការអាចលើកទឹកចិត្តឱ្យភាគីវិវាទធ្វើការការចរចា ឬអាចដើរតួនាទីសកម្មជាងនេះ ដោយក្នុងករណីណាមួយក៏ដោយ កិច្ចអន្តរាគមន៍របស់តុលាការគឺអាចធ្វើឡើងក្នុងរូបភាពជាសន្ទានការី។

[៨] នៅស.រ.អា.ក្នុងរឿងក្តីភាគច្រើន វិធាននីតិវិធីរដ្ឋប្បវេណីនៃសហព័ន្ធតម្រូវឱ្យមានកិច្ចប្រជុំដោះស្រាយមុនសវនាការ ដែលក្នុងនោះភាគីវិវាទត្រូវបានលើកទឹកចិត្តឱ្យចរចាគ្នារកការស្រុះស្រួល។ វិ.នីតិវិ.រដ្ឋប្ប.សហ. 169(a)(5); 16(c)(7). វិធានរដ្ឋសហព័ន្ធក៏ចែងផងដែរថា ការខកខានរបស់ភាគីក្នុងការទទួលយកសម្ទើស្រុះស្រួលសមស្របណាមួយ អាចបណ្តាលឱ្យភាគីនោះត្រូវបង់ប្រាក់ប្រដាប់ក្តីរបស់ភាគីម្ខាងទៀត។ វិ.នីតិវិ.រដ្ឋប្ប.សហ. 68 ។ ជាចុងក្រោយ វិធានស្តីពីភ័ស្តុតាងរបស់សហព័ន្ធលើកកំពស់ការស្រុះស្រួល ដោយមិនអនុញ្ញាតិឱ្យយកសម្ទើផ្សេងៗក្នុងការបញ្ចប់រឿងក្តី មកធ្វើជាភ័ស្តុតាងឡើយ។ វិ.ភ័ស្តុ.សហ. 408 ។

[៩] SUSAN PATTERSON និង GRANT SEABOLT **សារធាតុសំខាន់ៗនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ** ទំព័រទី៥ (បោះពុម្ពលើកទី២ ឆ្នាំ២០០១)។

[១០] *ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តនៃប្រទេសកម្ពុជា: ការវាស់ស្ទង់អភិបាលកិច្ចសេដ្ឋកិច្ច និងគោលនយោបាយបទបញ្ញត្តិ* ធនាគារពិភពលោក/IFC-MPDF និង AusAid/មូលនិធិអាស៊ី ទំព័រ៤៨ (២០០៧)។ ការអង្កេតបានរកឃើញថា ៩២% នៃក្រុមហ៊ុនក្នុងប្រទេសកម្ពុជា ជ្រើសយកការចរចារជាជម្រើសខ្ពស់បំផុតរបស់ខ្លួនក្នុងការដោះស្រាយវិវាទ។ ផ្ទុយទៅវិញ មានក្រុមហ៊ុនតែ ១% ប៉ុណ្ណោះដែលអះអាងថាការប្តឹងទៅតុលាការគឺជា វិធីសាស្ត្រដោះស្រាយវិវាទដ៏ទូទៅបំផុតសំរាប់ពួកគេ។

## ៦. គុណសម្បត្តិនៃការចរចា

បើប្រៀបធៀបជាមួយវិធីសាស្ត្រទូទៅផ្សេងទៀតនៃដំណោះស្រាយវិវាទ ការចរចាមានអត្ថប្រយោជន៍សំខាន់ៗមួយចំនួនដូចជា :

- **សន្សំសំចៃការចំណាយ**

  ការចរចាចំណាយអស់ប្រាក់តិចជាងវិធីសាស្ត្រដោះស្រាយវិវាទផ្សេងទៀត។ នេះគឺជាចំណែកមួយដែលនាំឱ្យការចរចាមានប្រជាប្រិយភាព។ វាមិនមានប្រាក់ប្រដាប់ក្តី ឬថ្លៃចំណាយផ្សេងទៀតឡើយ។

- **ភាពឯកជន**

  ការចរចាអាចជាដំណើរការឯកជនទាំងស្រុង ដោយគ្រាន់តែធ្វើឡើងរវាងភាគី និងភាគី ឬតំណាងរបស់ពួកគេតែប៉ុណ្ណោះ។ គ្មានការចូលរួមពីតុលាការ គ្មានអ្នកសារព័ត៌មាន និងគ្មានអ្នកដទៃទៀតចូលរួមទេ។ សូម្បីតែមេធាវី ក៏ភាគីវិវាទមិនចាំបាច់អញ្ជើញឱ្យចូលរួមដែរ បើទោះជាក្នុងជំពូកនេះមានបញ្ជាក់យ៉ាងច្បាស់ថាមេធាវីមានតួនាទីដ៏សំខាន់ នៅក្នុងវិវាទតាមផ្លូវច្បាប់ភាគច្រើនក៏ដោយ។ ប៉ុន្តែ ទោះបីជាមានវត្តមានមេធាវីក្តី ក៏សេចក្តីលម្អិតនៃវិវាទនឹង នៅតែជាលក្ខណៈឯកជនដដែល[១១] ដែលប្រការនេះអាចមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់មនុស្ស និងអាជីវកម្មរបស់ពួកគេ។

- **ភាពបត់បែន**

  ការចរចាមានភាពបត់បែនទាំងក្នុងដំណើរការ និងលទ្ធផល។ ទីមួយ *ដំណើរការ* នៃការចរចាអាចមានលក្ខណៈបត់បែនយ៉ាងខ្លាំង ពីព្រោះដូចបានរៀបរាប់ខាងលើ ដំណើរការអាចធ្វើឡើងក្រៅផ្លូវការ ឬជាផ្លូវការ។ ការចរចាអាចធ្វើឡើងក្រៅផ្លូវការ ដោយមនុស្សពីរនាក់នៅតាមផ្លូវ ឬអាចធ្វើឡើងជាផ្លូវការ ដោយភាគីវិវាទ និងមេធាវីរបស់ពួកគេ ផ្ញើសំបុត្រជាលាយលក្ខណ៍ឱ្យគ្នាទៅវិញទៅមក។

  ទីពីរ *លទ្ធផល* នៃការចរចាអាចមានលក្ខណៈបត់បែនយ៉ាងខ្លាំង។ ដោយសារភាគីវិវាទផ្ទាល់ជាអ្នកឈានដល់ការសម្រុះសម្រួល ពួកគេអាចព្រមព្រៀងគ្នាទៅលើដំណោះស្រាយផ្សេងៗជាច្រើន ដែលពុំនោះសោតមិនអាចធ្វើទៅបានឡើយតាមរយៈមជ្ឈត្តការ ឬបណ្តឹងតុលាការ។ ឧទាហរណ៍ មនុស្សម្នាក់អាចយល់ព្រមបង់ប្រាក់រំលោះដែលមានតម្លៃកាន់តែខ្ពស់ ប្រសិនបើបង់ក្នុងរយៈពេលច្រើនឆ្នាំ ជំនួសឱ្យការបង់ប្រាក់សរុបតែមួយ

---

[១១] នៅក្នុងប្រទេសកម្ពុជា មេធាវីត្រូវតែរក្សាការសម្ងាត់ជាដាច់ខាតចំពោះទំនាក់ទំនងជាមួយកូនក្តីរបស់ខ្លួន។ **ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា** មាត្រា៥៨ (ឆ្នាំ១៩៩៥) [អំណើះតទៅហៅកាត់ថា "ច្បាប់ ល.ម-ព.ក."] **ក្រមសីលធម៌សម្រាប់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា** មាត្រា៧ [អំណើះតទៅហៅកាត់ថា "ក្រមសីលធមិគណៈមេធាវីកម្ពុជា"]។ វិធានស្រដៀងគ្នានៅសហរដ្ឋអាមេរិកត្រូវបានស្គាល់ថាជា "បុព្វសិទ្ធិរវាងមេធាវី និងកូនក្តី" ឬ "វិធានរក្សាការសម្ងាត់" (*សូមមើលឧ.* វិធានប្រតិបត្តិវិជ្ជាជីវៈគម្រូរបស់ ABA វិ.១៦)។ នៅអឺរ៉ុប វិធាននេះត្រូវបានហៅថា "បុព្វសិទ្ធិស្របច្បាប់" ឬ "ការសម្ងាត់វិជ្ជាជីវៈ" (ក្រុមប្រឹក្សាមេធាវី និងសមាគមច្បាប់អឺរ៉ុប, ក្រមប្រតិបត្តិ មាត្រា២.៣) ហើយនៅប្រទេសអង់គ្លេសត្រូវបានគេស្គាល់ថាជា "បុព្វសិទ្ធិវិជ្ជាជីវៈស្របច្បាប់" ឬកាន់តែទូលំទូលាយថែមទៀតនោះគឺ "ករណីយកិច្ចរក្សាការសម្ងាត់" (ក្រមប្រតិបត្តិសម្រាប់ស្មាក្តីអង់គ្លេស និងវែលស៍ វិ.៤.0១)។ *សូមមើលផងដែរ* **ក្រមសីលធម៌វិជ្ជាជីវៈអន្តរជាតិ**, គណៈមេធាវីអន្តរជាតិ, វិ.១៤។

លើក។ ខណៈពេលដែលការចរចាផ្តល់លទ្ធភាពនេះទាំងស្រុង សេចក្តីសម្រេចរបៀបនេះមិនត្រូវបានអនុញ្ញាតជាទូទៅឡើយ នៅក្នុងដំណើរការបណ្តឹងទៅតុលាការ។

- **ល្បឿន**

ការចរចាមានសក្តានុពលក្នុងការដោះស្រាយបញ្ហាបានយ៉ាងឆាប់រហ័ស និងមានប្រសិទ្ធភាព។ ភាគីមិនចាំបាច់ត្រូវរង់ចាំចៅក្រម មជ្ឈត្តករ ឬសន្ទានការី ដើម្បីធ្វើសវនការ និងសម្រេចលើរឿងក្តីនោះឡើយ។ បញ្ហាអាចត្រូវបានដោះស្រាយភ្លាមៗ ឱ្យតែភាគីឈានដល់ការស្រុះស្រួលគ្នា។

- **លទ្ធភាពគ្រប់គ្រងរបស់ភាគី**

ការចរចាផ្តល់ឱ្យភាគីវិវាទនូវលទ្ធភាពគ្រប់គ្រងយ៉ាងពេញលេញទៅលើដំណើរការ និងការបញ្ចប់។ ភាគីវិវាទជាអ្នកកំណត់ថាតើត្រូវធ្វើការចរចាតាមរបៀបណា និងថាតើនឹងមានការស្រុះស្រួលដែរឬទេ។ នៅក្នុងការចរចា គេមិនអាចបង្ខំភាគីណាមួយ ឱ្យចូលក្នុងដំណើរការចរចា ឬការស្រុះស្រួលណាមួយ ដោយគ្មានការព្រមព្រៀងពីភាគីនោះឡើយ។[១២]

- **ការរក្សាទំនាក់ទំនងជាបន្ត**

ការចរចាផ្តល់លទ្ធភាពដល់ភាគីវិវាទក្នុងការរិះរកការស្រុះស្រួលមួយ ដែលអាចរក្សាទំនាក់ទំនងដែលពួកគេមាន។ ឧទាហរណ៍ ប្រសិនបើនិយោជក និងនិយោជិតមានវិវាទពាក់ព័ន្ធនឹងពេលវេលាឈប់សម្រាក ហើយពួកគេចរចាលើការព្រមព្រៀងណាមួយ ពួកគេនឹងមានលទ្ធភាពរក្សានូវទំនាក់ទំនងនោះ ដើម្បីឱ្យនិយោជិតនោះនៅរក្សាការងាររបស់ខ្លួនដដែល។ នៅក្នុងបណ្តឹងតុលាការ ឬមជ្ឈត្តការ ដែលមានភាគីទីបី ជាអ្នកសម្រេចបញ្ហានោះ ដំណោះស្រាយអាចនឹងមិនជួយឱ្យភាគីទាំងសងខាងរីករាយគ្រប់គ្រាន់ក្នុងការបន្តធ្វើការងារជាមួយគ្នាទៀតបានឡើយ។ យ៉ាងណាមិញ តាមរយៈការចរចា ភាគីវិវាទអាចធ្វើការជាមួយគ្នាដើម្បីស្វែងរកដំណោះសាយណាមួយដែលអាចទទួលយកបានចំពោះភាគីទាំងសងខាង។

- **ការអនុវត្តដំណោះស្រាយ**

ការស្រុះស្រួលតាមរយៈការចរចាលើរឿងក្តីណាមួយ អាចត្រូវបានកត់បញ្ចូលក្នុងនីតិវិធីតុលាការ នៅចំពោះមុខចៅក្រម ហើយនឹងអាចអនុវត្តបាន ដូចជាសាលក្រមដែរ។[១៣]

---

[១២] យោងតាមច្បាប់របស់ប្រទេសកម្ពុជា ភាគីម្ខាងអាចចាត់ទុកការស្រុះស្រួលតាមរយៈការចរចាណាមួយជាមោឃៈបាន ប្រសិនបើខ្លួនអាចបង្ហាញថា ភាគីម្ខាងទៀតបានបង្ខិតបង្ខំ ឬបន្លំបោកប្រាស់ ដើម្បីជំរុញឱ្យខ្លួនព្រមស្រុះស្រួល. *សូមមើល* **ក្រឹត្យ-ច្បាប់លេខ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា** មាត្រា៦ ដល់មាត្រា១០ [អំណើះតទៅហៅកាត់ថា"ក្រឹត្យ-ច្បាប់លេខ ៣៨"]។ យោងតាមមាត្រា១០ អំពើបញ្ឆោត អំពើភូតភរឬបន្លំ បង្កើតបានជាអំពើបន្លំបោកប្រាស់ដែលគ្រប់គ្រាន់ដើម្បីធ្វើមោឃភាពកិច្ចសន្យាណាមួយ ដូចជាកិច្ចព្រមព្រៀងស្រុះស្រួលជាដើម, *ដូចមុន* នៅមាត្រា ១០។ យោងតាមក្រមនីតិវិធីរដ្ឋប្បវេណីថ្មីរបស់កម្ពុជា "ការសះជាតាមផ្លូវតុលាការ" (ការស្រុះស្រួលរវាងភាគីនៅក្នុងរឿងក្តីមួយ) អាចត្រូវបានលុបចោលដោយសារការភាន់ច្រឡំ ឬការបន្លំបោកប្រាស់ ។ល។ ***សៀវភៅសិក្សាស្តីពីក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា*** ក្រុមការងារស្តីពីក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា គន្ថីទី៣ ជំ.ទី៤ ផ្នែកទី២(៥)(៣)(ឆ្នាំ២០០៧)។ [អំណើះតទៅហៅកាត់ថា **បទអត្ថាធិប្បាយ** ក.ន.វ.-ព.ក.]

[១៣] *សូមមើល* ក.ន.រ.-ព.ក. កំណត់សម្គាល់ *ខាងលើ* លេខ៧, មាត្រា២២២, រាជកិច្ចនៃព្រះរាជាណាចក្រកម្ពុជាលេខ៥៦ ទំព័រ៥៤៦២។ ភាគីដែលបានដាក់ពាក្យប្តឹងរួចហើយនៅក្នុងតុលាការកម្ពុជា អាចព្យាយាមដោះស្រាយរឿងក្តីរបស់ខ្លួនបាន។ បើពួកគេឈានដល់

## គ. គុណវិបត្តិនៃការចរចា

ទោះបីការចរចាមានគុណសម្បត្តិជាច្រើនក៏ដោយ ក៏មានមូលហេតុមួយចំនួនដែលភាគីអាចមិនជ្រើសយកវិធីនេះ:

- **ការពន្យារពេល**

គុណវិបត្តិមួយនៃការចរចាគឺថា ភាគីម្ខាងអាចពន្យារពេលដំណើរការប្រសិនបើខ្លួនចង់។ នៅក្នុងស្ថានភាពចរចាសុទ្ធសាធមួយ គ្មានវិធីអ្វីអាចបង្ខំឱ្យភាគីណាមួយឱ្យពន្លឿនសកម្មភាពបានឡើយ។ វាជាលទ្ធភាពមួយ ដែលថាភាគីល្មើសអាចមិនទាំងប្រាកដប្រជាអំពីការស្រុះស្រួលផង ហើយប្រើប្រាស់ការចរចាជាវិធីសម្រាប់ពន្យាបញ្ហា ឬគេចវេសពីបណ្តឹងតុលាការ។

- **ភាគីគ្មានហេតុផល**

ជាកំណត់សម្គាល់ស្រដៀងគ្នានេះ ភាគីក៏ពើបប្រទះផងដែរ នូវលទ្ធភាពដែលភាគីម្ខាងទៀតអាចប្រកាន់ជំហរមិនសមហេតុផលនៅក្នុងការចរចា។ ដូចបានរៀបរាប់ពីខាងលើ ករណីនេះអាចដោយសារតែពួកគេមិនប្រាកដប្រជាចំពោះការចរចានោះ ហើយកំពុងប្រើប្រាស់មធ្យោបាយនេះដើម្បីបង្អិនពេលវេលា ឬគេចវេសពីបណ្តឹងតុលាការ។

- **ការអនុវត្តដំណោះស្រាយ**

បន្ទាប់ពីការចរចារួច ភាគីអាចឯកភាពគ្នាលើកិច្ចព្រមព្រៀងស្រុះស្រួលមួយ ដែលត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងមានចុះហត្ថលេខា។ ប៉ុន្តែ មួយរយៈក្រោយមក ភាគីណាមួយអាចមិនគោរពតាមល័ក្ខខ័ណ្ឌនៃការស្រុះស្រួលនោះ។ តួយ៉ាង ភាគីម្ខាងអាចខកខានក្នុងការប្រគល់ទំនិញក្នុងបរិមាណមួយ ដែលខ្លួនយល់ព្រមប្រគល់ឱ្យនៅពេលស្រុះស្រួល។ ដោយសារតែការស្រុះស្រួលនោះ គ្រាន់តែជាកិច្ចព្រមព្រៀងតាមរយៈការចរចា ភាគីម្ខាងទៀតគ្មានវិធី ដោយផ្ទាល់ក្នុងការដាក់ឱ្យអនុវត្តតាមផ្លូវតុលាការឡើយ។ ជាលទ្ធផល ភាគីនោះអាចនៅតែត្រូវដាក់ពាក្យប្តឹងទៅ តុលាការ ហើយត្រូវរង់ចាំក្នុងរយៈពេលយូរ ដើម្បីអនុវត្តកិច្ចព្រមព្រៀងស្រុះស្រួលខាងដើមនោះ។[១៤]

"ការសះជាតាមផ្លូវតុលាការ" ដែលត្រូវបានកត់ត្រាចូលក្នុងពិធីសារតុលាការ (កំណត់ហេតុតុលាការ) ការស្រុះស្រួលនោះមានធរមានភាព និងអានុភាពដូចសាលក្រមតុលាការដែរ ហើយអាចត្រូវបានអនុវត្តដោយស្វ័យប្រវត្តិតាមរយៈតុលាការ, ក.ន.រ.-ព.ក. មាត្រា ២២២។ ប្រសិនបើភាគីវិវាទមិនបានប្តឹងទៅតុលាការទេ កិច្ចព្រមព្រៀងស្រុះស្រួលនោះមិនអាចក្លាយជា "ការសះជាតាមផ្លូវតុលាការ" និងមិនអាចយកមកអនុវត្តដោយស្វ័យប្រវត្តិបានឡើយ។ កិច្ចព្រមព្រៀងស្រុះស្រួលនោះគ្រាន់តែជាកិច្ចសន្យាតែប៉ុណ្ណោះ, **ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា** [អំណើះតទៅហៅកាត់ថា ក.រ.-ព.ក.], **បទអត្ថាធិប្បាយ** ក.ន.រ.-ព.ក., កំណត់សម្គាល់ *ខាងលើ* លេខ១២, គន្ថីទី៣ ជំ.ទី៤ ផ្នែកទី២(៥)(១), ទំព័រ១០៨។ ជាលទ្ធផល មាត្រា២២២ បង្កើតជាការលើកទឹកចិត្តដ៏គួរឱ្យចាប់អារម្មណ៍ ក្នុងការដាក់ពាក្យបណ្តឹង *ជាមុនសិន* ហើយបន្ទាប់មកទើបព្យាយាមស្រុះស្រួលគ្នា ដើម្បីឱ្យភាគីវិវាទអាចទាមទារយក "ការសះជាតាមផ្លូវតុលាការ" ហើយទទួលអត្ថប្រយោជន៍ ពីការដាក់ឱ្យអនុវត្តបានជាស្វ័យប្រវត្តិបាន។

[១៤] **ក្រមនីតិវិធីរដ្ឋប្បវេណី** កំណត់សម្គាល់ *ខាងលើ* លេខ៧ មាត្រា ២២២ ដែលរៀបរាប់អំពី "ការសះជាតាមផ្លូវតុលាការ" មានសម្រាប់តែភាគីដែលមានបណ្តឹងរួចហើយ នៅក្នុងតុលាការកម្ពុជា។

- **ភាគីម្ខាងមានអំណាចខ្លាំងពេក**

    មានកាលៈទេសៈមួយចំនួនដែលភាគីមានវិសមភាពនឹងគ្នានៅក្នុងអំណាចចរចា ជាហេតុនាំឱ្យភាគីម្ខាងមានសិទ្ធិត្រួតត្រាហួសពេក។ ឧទាហរណ៍ អ្នកជំនួញដ៏ស្តុកស្តម និងមានអំណាចម្នាក់ អាចខកខានមិនបានបង់ប្រាក់ឱ្យជាងជួសជុលរថយន្តម្នាក់។ ជាងជួលជុលរថយន្តអាចស្ថិតនៅក្រោមសម្ពាធ ឬការគំរាមកំហែងពីអ្នកជំនួញរូបនោះ ក្នុងកំឡុងពេលចរចាជាឯកជន។ វាជាលទ្ធភាពមួយដែលថា ជាងជួសជុលរថយន្តនោះនឹងចុះញ៉មចំពោះការគំរាមកំហែង ហើយព្រមទទួលយកដំណោះស្រាយមិនសមស្របមួយ។ ក្នុងការចរចាជាឯកជន មិនមានភាគីទីបីណាមួយអាចបង្ការ លទ្ធផលដ៏អយុត្តិធម៌បែបនោះឡើយ។

គុណវិបត្តិទាំងនេះ ទោះជាគួរឱ្យពិចារណាក្តី កម្រនឹងកើតមានណាស់។ ជាធម្មតា ការចរចាគឺជាជម្រើសដំបូងដ៏ល្អបំផុត។ មុននឹងដាក់ពាក្យបណ្តឹង ឬសំអាងលើខស្តីពីមជ្ឈត្តការ មេធាវីជាច្រើន តែងសាកល្បងធ្វើការចរចា ពីព្រោះវាមានភាពឆាប់រហ័ស និងមានតម្លៃថោកជាងវិធីដោះស្រាយវិវាទផ្សេងទៀត។ ជាទូទៅ គ្មានអ្វីត្រូវបាត់បង់ក្នុងការព្យាយាមចរចាលើវិវាទមួយឡើយ។

## ឃ. វិធីសាស្ត្រជាមូលដ្ឋានពីរក្នុងការចរចា

ភាគីអាចធ្វើការចរចាតាមវិធីសាស្ត្រជាមូលដ្ឋានពីរយ៉ាង។ ទីមួយ គឺវិធីសាស្ត្រ*បែបបែងចែក* ឬរបៀបចរចាបែបឈ្នះ-ចាញ់។[១៥] ទីពីរ គឺវិធីសាស្ត្រ*ផ្អែកលើផលប្រយោជន៍* ឬ របៀបចរចាបែបឈ្នះ-ឈ្នះ។[១៦]

### ***១. ការចរចាបែបបែងចែក ( ឈ្នះ-ចាញ់)***

នៅក្នុងការចរចាបែបបែងចែក ភាគីវិវាទសន្មត់ថាមានធនធានដែលមានចំនួនជាក់លាក់មួយ ដែលពួកគេត្រូវបែងចែករវាងគ្នា និងគ្នា។ ជួនកាល គេហៅវាថាជាល្បែងផលសរុបស្មើសូន្យ (zero-sum game)។ ប្រសិនបើភាគីម្ខាងទទួលបានកាន់តែច្រើន ភាគីម្ខាងទៀតទទួលបានកាន់តែតិច។ ជាទូទៅ ពាក្យថាធនធានគឺសំដៅលើតម្លៃគិតជាទឹកប្រាក់។

នៅក្នុងកំឡុងពេលចរចា ភាគីវិវាទកំណត់ពីជំហរខ្លួនឯងរៀងៗខ្លួន។ ភាគីចុងចម្លើយដឹងអំពីចំនួនអតិបរមាដែលខ្លួនមានឆន្ទៈក្នុងការបង់ ហើយភាគីរងគ្រោះដឹងអំពីចំនួនអប្បបរមាដែលខ្លួនមានឆន្ទៈក្នុងការទទួលយក។ ការពិភាក្សានៃចរចា ព្រមទាំងលទ្ធផលសក្តានុភូតរបស់វា ត្រូវបានកម្រិតត្រឹមតែជំហរដែលភាគីនីមួយៗប្រកាន់យកនោះ។ គោលដៅរបស់ភាគីនីមួយៗ គឺទទួលបានធនធានជាអតិបរមានៅក្នុងចន្លោះសម្រាប់តវ៉ានេះ។

ឧទាហរណ៍ ភាគីម្ខាងអាចអះអាងថា ខ្លួនមានរបួសដោយសាររថយន្តដែលបើកបរដោយភាគីម្ខាងទៀត។ ភាគីរងគ្រោះអាចមានរបួសដែលមានតម្លៃជាទឹកប្រាក់ចំនួន១.០០០ដុល្លាអាមេរិក។ នៅពេលភាគីទាំងពីរចរចាតាមបែបបែងចែក ពួកគេប្រកាន់ជំហររៀងខ្លួនអំពីចំនួនទឹកប្រាក់ដែលត្រូវបង់។ ភាគីរងគ្រោះនឹងព្យាយាមបញ្ចុះបញ្ចូលភាគីចុង

---

[១៥] ជួនកាល គេហៅថាជា "ការតថ្លៃដោយប្រកាន់ជំហរ" ឬការចរចា "ផលសរុបស្មើសូន្យ"។

[១៦] ជួនកាល គេហៅថាជា វិធីសាស្ត្រ "សហការ" ក្នុងការចរចា ឬការចរចា "ផលសរុបមិនស្មើសូន្យ"។

ចម្លើយឱ្យបង់ប្រាក់ចំនួន ១.០០០ដុល្លាអាមេរិក ឬប្រហាក់ប្រហែលនោះតាមដែលអាចធ្វើទៅបាន។ ភាគីចុងចម្លើយ នឹងព្យាយាមបញ្ចុះបញ្ចូលភាគីរងគ្រោះ ឱ្យយល់ព្រមទទួលយកទឹកប្រាក់កាន់តែតិចតួចឡើងតាមដែលអាចធ្វើទៅបាន។

***ដំណើរការនៃការចរចាតំបន់បែងចែក ជាទូទៅមានសភាពប្រកួតប្រជែងយ៉ាងខ្លាំង។***

### ២. *ការចរចាផ្អែកលើផលប្រយោជន៍ ( ឈ្នះ-ឈ្នះ)*

ការចរចាផ្អែកលើផលប្រយោជន៍មានលក្ខណៈសហការជាងការចរចាបែបបែងចែក។ គេត្រូវសន្មត់ថាមានផល-ប្រយោជន៍សំខាន់ៗដទៃទៀតដែលគេត្រូវរកឱ្យឃើញ និងតម្រូវតាម។ ភាគីវិវាទអាចមានផលប្រយោជន៍មួយចំនួនរួមគ្នា ឬយ៉ាងហោចណាស់ផលប្រយោជន៍មួយចំនួនដែលបំពេញបន្ថែមឱ្យគ្នា។

ដើម្បីពន្យល់បង្ហាញអំពីវិធីសាស្ត្រខុសៗគ្នា យើងលើកយកករណីធម្មតាមួយនៃវិវាទលើផ្លែក្រូចៈ

នៅក្នុងការចរចាបែបបែងចែក ផារីទាមទារធ្វើជាម្ចាស់កម្មសិទ្ធិលើក្រូចមួយ ដោយលើកឡើងពីអំណះអំណាង និងព្រឹត្តិការណ៍ដែលជួយគាំទ្រខ្លួន (ឧទាហរណ៍ ផារីបានចេញលុយថ្លៃក្រូច ឬក៏អាចថា ខ្លួនជាអ្នកស្នើឱ្យទិញក្រូចនោះ)។ សុជាតា លើកឡើងពីអំណះអំណាង និងព្រឹត្តិការណ៍ផ្ទុយពីនេះ (ឧទាហរណ៍ នាងបានជ្រើសរើសក្រូចនោះ ឬជាអ្នករក្សាទុកក្រូចនោះ)។ ភាគីនីមួយៗព្យាយាមបង្ខូច អំណះអំណាងរបស់ភាគីម្ខាងទៀត ឬក៏អាចបង្ខូចជំនឿទុកចិត្តទៅលើភាគីម្ខាងទៀត។ ជម្រើសដែលអាចមានសម្រាប់ដំណោះស្រាយដោយការចរចា បែបបែងចែក មានកម្រិតត្រឹមតែៈ

១) ភាគីម្ខាង ឬភាគីម្ខាងទៀតយកក្រូចទាំងមូល ។

២) ក្រូចត្រូវបានបែងចែករវាងភាគីទាំងពីរ ៥០-៥០ ឬ ៦០-៤០ ឬជាសមាមាត្រផ្សេងទៀត។

៣) ដោយមិនអាចឈានដល់ការព្រមព្រៀងគ្នា ភាគីវិវាទក៏ទៅប្តឹងចៅក្រម ឬមជ្ឈត្តករ ហើយភាគីវិវាទលើកពីអំណះអំណាងរៀងៗខ្លួន និងព្យាយាមបន្ទុះបង្អាប់ភាគីម្ខាងទៀតកាន់តែខ្លាំងក្លាជាងមុនទៅទៀត។ ចៅក្រម/មជ្ឈត្តករនឹងសម្រេចតាមជម្រើស(១) ឬជម្រើស(២) ដូចមានរៀបរាប់ខាងលើ។

ជាលទ្ធផល ភាគីម្ខាង ឬក៏ភាគីទាំងសងខាង អាចមានការមិនពេញចិត្ត ហើយទំនាក់ទំនងជាបន្តរបស់ពួកគេត្រូវបានបំផ្លាញដោយសារមធ្យោបាយដាក់សម្ពាធដែលត្រូវបានប្រើប្រាស់នៅក្នុងដំណើរការចរចានោះ។[១៧]

នៅក្នុងការចរចាផ្អែកលើផលប្រយោជន៍ ផារី និងសុជាតាអង្គុយជាមួយគ្នា ហើយរៀបរាប់អំពីសមាសភាពផ្សេងៗរបស់ក្រូច បន្ទាប់មកពួកគេព្យាយាមស្វែងរកគំនិតនានា។ គេអាចរកឃើញថា ផលប្រយោជន៍ចម្បងរបស់ផារីគឺយកសំបកក្រូចទៅធ្វើនំ ចំណែកឯផលប្រយោជន៍ចម្បងរបស់សុជាតាគឺយកទឹកក្រូចទៅធ្វើជាភេសជ្ជៈ។ ហើយគ្រាប់ក្រូច

---

[១៧] *សូមមើល* B. Daniel Lynch *ចិតសំបកក្រូច - ការចរចាសម្រាប់ការលែងលះដោយមេត្រីភាពនៅក្នុងការសម្រុះសម្រួល* ការសម្រុះសម្រួលការលែងលះនៅ ផាសាឌីណា ក្រុងឡូសអែងជែលេស រដ្ឋកាលីហ្វ័រញ៉ា។ មាននៅវែបសាយត៍ http://www.mediationdivorce.net/id8.html (ចូលទស្សនាលើកចុងក្រោយ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨)។

អាចមានសារៈប្រយោជន៍ចំពោះភាគីម្ខាង ឬភាគីទាំងពីរ ដូច្នេះពួកគេក៏ចែកគ្នាទៅតាមនោះ។ ដោយអនុវត្តវិធីនេះ ភាគីទាំងពីរអាចឈានដល់ការព្រមព្រៀងគ្នា ដែលតាមរយៈនោះ ភាគីទាំងសងខាងនឹងទទួលបានយ៉ាងច្រើនបំផុត នូវអ្វីដែលពួកគេចង់បាន ហើយចំណងទាក់ទងរវាងគ្នានឹងនៅរក្សាបានដដែល។

**ឈើវាកទុកធ្វើកង់ ឈើត្រង់ទុកធ្វើកាំ។**

ទោះជាយ៉ាងណា វាជាការសំខាន់ដែលត្រូវចងចាំថា ការចរចាផ្អែកលើផលប្រយោជន៍មិនមែនសុទ្ធតែទទួលបានជោគជ័យរហូតនោះទេ។ ការចរចាមួយចំនួនមានលក្ខណៈសាមញ្ញបំផុត និងផ្អែកទាំងស្រុងទៅរឿងប្រាក់កាសតែមួយមុខគត់។ ការទិញទំនិញភាគច្រើននៅតាមទីផ្សារគឺជាការចរចាដែលសាមញ្ញ និងផ្អែកលើប្រាក់កាស។ នៅក្នុងករណីទាំងនោះ ការចរចាបែបបែងចែក ទំនងជាមានភាពសមស្របបំផុត។ ក៏ប៉ុន្តែ នៅក្នុងការចរចាដោះស្រាយវិវាទភាគច្រើន ជាការល្អគឺយ៉ាងហោចណាស់ គេគប្បីពិចារណាលើវិធីសាស្ត្រផ្អែកលើផលប្រយោជន៍ជាមុនសិន ពីព្រោះវាច្រើនតែអាចនាំទៅរកលទ្ធផលកាន់តែប្រសើរសម្រាប់ភាគីទាំងពីរ។ កថាភាគបន្ទាប់នៅខាងក្រោមនេះ នឹងផ្តោតជាចម្បងលើសេចក្តីលម្អិតនៃវិធីសាស្ត្របែបបែងចែក។

***វិធីសាស្ត្រផ្អែកលើផលប្រយោជន៍នៃការចរចា តែងមានសកម្មភាពនិងលក្ខណៈសហការច្រើនជាងប្រកួតប្រជែង ។***

# ខ. សេចក្តីលម្អិតនៃវិធីសាស្ត្របែបបែងចែក

## *១. គោលការណ៍ទូទៅនៃវិធីសាស្ត្របែបបែងចែក*

ជួនកាល វិធីសាស្ត្របែបបែងចែកត្រូវបានគេហៅថាជា "ការតថ្លៃ"។[១៨] ជាគោលការណ៍ ភាគីនីមួយៗនិយាយតតាំងគ្នាចុះឡើងអំពីតម្លៃដែលខ្លួនស្នើ។ ជួនកាល ភាគីទាំងសងខាងអាចឈានដល់ការព្រមព្រៀងគ្នា ហើយជួនកាលទៀត គឺមិនមានការព្រមព្រៀងគ្នាទេ។ ឧទាហរណ៍ថា ធា ទៅផ្សារហើយចង់ទិញតុមួយពី វណ្ណា។ វណ្ណា បញ្ជាក់ថាតុនោះត្រូវលក់ក្នុងតម្លៃ២៥ដុល្លាអាមេរិក។ ធា និយាយថា "អូ! តុនេះស្អាតណាស់ ប៉ុន្តែអ្នកទារថ្លៃណាស់។ ខ្ញុំរីករាយនឹងឱ្យត្រឹម១០ដុល្លា ប៉ុន្តែលើសពីហ្នឹង គឺមិនបានទេ"។ បន្ទាប់មកវណ្ណា ក៏ឆ្លើយតបថា "មែនហើយ តុនេះស្អាតណាស់ វាធ្វើពីឈើដែលល្អ។ យើងត្រូវចំណាយពេលអស់៥ថ្ងៃដើម្បីធ្វើវា ខ្ញុំមិនអាចលក់ខាតបានទេ។ ខ្ញុំអាចចុះថ្លៃជាពិសេសឱ្យអ្នកបានត្រឹម២០ដុល្លាប៉ុណ្ណោះ ប៉ុន្តែមិនអាចចុះក្រោមហ្នឹងទៀតទេ ខ្ញុំត្រូវចំណេញតិចតួចដែរ"។ បន្ទាប់មក ធា និយាយថា "១២ដុល្លាបានទេ?" ហើយ ការតថ្លៃនោះក៏ចេះតែបន្តទៅទៀត។

អ្នកទាំងពីរអាចឈានទៅដល់ការព្រមព្រៀងគ្នា ប៉ុន្តែលុះត្រាតែតម្លៃទិញអតិបរមារបស់ ធា ស្មើឬធំជាង តម្លៃលក់អប្បបរមារបស់វណ្ណាប៉ុណ្ណោះ។ តម្លៃអតិបរមាសម្ងាត់របស់ធា ដែលនាងមានឆន្ទៈក្នុងការផ្តល់ឱ្យ ត្រូវបានគេហៅថាជា *តម្លៃបម្រុង*[១៩] របស់នាង។ ឯតម្លៃលក់អប្បបរមាជាសម្ងាត់របស់ វណ្ណា ក៏ជា *តម្លៃបម្រុង* របស់នាងដែរ។ ប្រសិនបើតម្លៃទាំងពីរនេះត្រូវគ្នា ពួកគេអាចបញ្ចប់ការលក់។ ក្រាហ្វិកខាងក្រោម អាចបង្ហាញអំពីតម្លៃបម្រុងនៃភាគីទាំងពីររៀងៗខ្លួន:




គំនូរខាងលើបង្ហាញថាតម្លៃលក់អប្បបរមារបស់វណ្ណា ដែលជាតម្លៃបម្រុងរបស់នាងគឺ ១៤ដុល្លា ចំណែកឯតម្លៃអតិបរមាដែលធានឹងចំណាយទិញតុនោះគឺ១៨ដុល្លា ពោលគឺវាតម្លៃបម្រុងរបស់នាង។ ផ្នែកដែលតម្លៃបម្រុងរបស់ភាគីទាំងពីរត្រួតលើគ្នានោះ ហៅថា *តំបន់តថ្លៃ*។ ដូចដែលគំនូរខាងលើបង្ហាញ តំបន់តថ្លៃសម្រាប់ការលក់នេះ គឺស្ថិតនៅចន្លោះ១៤ និង១៨ដុល្លា ដែលជាបរិវេណពណ៌ប្រផេះខាងលើ។ ការព្រមព្រៀងលក់អាចត្រូវបានធ្វើឡើងនៅចំនុចណាមួយនៅក្នុងតំបន់តថ្លៃនោះ។

ក្នុងការចរចាប្រភេទនេះ ប្រការសំខាន់គឺគេត្រូវព្យាយាមកំណត់តម្លៃបម្រុងរបស់ភាគីម្ខាងទៀតឱ្យបានត្រឹមត្រូវបំផុតតាមដែលអាចធ្វើបាន។ ប្រសិនបើ ធា ដឹងថាតម្លៃបម្រុងរបស់ វណ្ណា គឺ ១៤ដុល្លា ធានឹងមិនទិញឱ្យថ្លៃជាង ១៤ដុល្លាឡើយ។ ម្យ៉ាងវិញទៀត ប្រសិនបើវណ្ណាគឺជាអ្នកលក់ឆ្លាតវៃ នាងនឹងព្យាយាមកំណត់ថា តើធាមានឆន្ទៈទិញក្នុងតម្លៃ

---

[១៨] Bruce Patton *ការចរចា*, **សៀវភៅណែនាំអំពីដំណោះស្រាយវិវាទ** ទំព័រ ២៧៩, ២៨៨ (Michael L. Moffitt, Robert C. Bordone ed., ឆ្នាំ២០០៥)។

[១៩] តម្លៃបម្រុងរបស់ភាគី ជួនកាលត្រូវបានគេហៅថា "តម្លៃរឹងទទឹង"។

ប៉ុន្មាន (ពោលគឺតម្លៃបម្រុងរបស់ធា) ហើយនាងនឹងព្យាយាមលក់តុក្នុងតម្លៃដែលកៀកបំផុតនឹងតម្លៃបម្រុងរបស់ធា គឺ ១៨ ដុល្លា។ ដូច្នេះ ការប្រមូលព័ត៌មានគឺជាទិដ្ឋភាពសំខាន់នៃការចរចាដែលប្រកបដោយជោគជ័យ។

អាស្រ័យហេតុនេះ នៅក្នុងការចរចាបែបបែងចែក ភាគីនីមួយៗតែងមានបំណងព្យាយាមរក្សាការសម្ងាត់អំពីតម្លៃបម្រុងរបស់ខ្លួន ឬធ្វើឱ្យភាគីម្ខាងទៀតជឿលើអ្វីដែលខុសពីនោះ។ វណ្ណា ចង់ឱ្យ ធា ជឿថាតម្លៃបម្រុងរបស់នាងគឺច្រើនជាង១៨ដុល្លា។ នាងនឹងចំណេញកាន់តែច្រើន ប្រសិនបើធាទិញតុនោះក្នុងតម្លៃ១៥ឬ១៦ដុល្លា។ ដូច្នេះ នាងអាចនឹងព្យាយាមធ្វើឱ្យធាជឿថា ១៥ឬ១៦ដុល្លាគឺជាតម្លៃបម្រុងរបស់នាង។ ប៉ុន្តែ នេះគឺជាល្បែងដ៏គ្រោះថ្នាក់មួយ។ ប្រសិនបើ ធា ជឿថាតម្លៃបម្រុងរបស់វណ្ណាខ្ពស់ពេក ធាអាចនឹងបោះបង់វាចោល ហើយដើរចេញដោយមិនទិញ។

ជាងនេះទៅទៀត នៅក្នុងការចរចា ជួនកាលវាមានប្រយោជន៍ក្នុងការព្យាយាមបញ្ចុះបញ្ចូលឱ្យភាគីម្ខាងទៀតជឿថាតម្លៃបម្រុងរបស់ខ្លួន *គួរតែ* មានតម្លៃតិចជាង ឬច្រើនជាងតម្លៃពិតប្រាកដ។ ធា អាចនិយាយទៅកាន់ វណ្ណា ថាគេអាចទិញតុនោះនៅកន្លែងផ្សេង តម្លៃតែ១២ដុល្លា មិនមែន១៤ដុល្លាទេ។ ប្រាកដណាស់ វណ្ណា អាចនិយាយផ្ទុយពីនោះដោយប្រាប់ ធា ថានាងលក់តុដូចគ្នានេះកាលពីម្សិលមិញក្នុងតម្លៃ២០ដុល្លា ដូច្នេះធាត្រូវតែដំឡើងតម្លៃបម្រុងរបស់នាងរហូតដល់២០ដុល្លា។ ប៉ុន្តែ វាក៏អាចជាការប្រថុយប្រថានដែរ ពីព្រោះភាគីម្ខាងអាចទៀតបាត់បង់ការជឿជាក់ ប្រសិនបើការអះអាងនោះ ជាការបោកប្រាស់ ឬមិនសមហេតុផល។

**សំណួរសិក្សា**

- តើ វណ្ណា អាចនិយាយអ្វីខ្លះដើម្បីអាចបញ្ចុះបញ្ចូល ធា ឱ្យជឿថាតម្លៃបម្រុងរបស់ ធា ទាបពេក ហើយត្រូវតែដំឡើង?
- តើ ធា អាចនិយាយអ្វីខ្លះដើម្បីអាចបញ្ចុះបញ្ចូល វណ្ណា ឱ្យជឿថាតម្លៃបម្រុងរបស់ វណ្ណា ខ្ពស់ពេក ហើយត្រូវតែបញ្ចុះ?

## ២. វិធីសាស្ត្របែបបែងចែកក្នុងដំណោះស្រាយវិវាទ

ដំណោះស្រាយវិវាទនៅក្រោមវិធីសាស្ត្របែបបែងចែក មានធាតុផ្សំជាមូលដ្ឋានដូចគ្នានឹងការរៀបរាប់ត្រួសៗ ខាងលើពាក់ព័ន្ធនឹងការលក់តុរបស់វណ្ណា ព្រមទាំងបម្រែបម្រួលបន្ថែមមួយចំនួនទៀត។ ដើម្បីកំណត់តម្លៃបម្រុងរបស់ភាគីនៅក្នុងវិវាទមួយ ជាដំបូងគេត្រូវគណនា EMV (the expected monetary value of the case ឬ តម្លៃជាទឹកប្រាក់ដែលរំពឹងទុកនៃរឿងក្តី) និងបន្ទាប់មកគឺ BATNA (the best available alternative to a negotiated settlement ឬ ជម្រើសល្អបំផុតដែលអាចរកបានក្រៅពីដំណោះស្រាយតាមការចរចា)។ បន្ទាប់មកទៀត គេនឹងអាចកំណត់បានដោយងាយ នូវតម្លៃបម្រុងដែលសមស្របបំផុតសម្រាប់ការចរចាបែបបែងចែកនៅក្នុងវិវាទមួយ។

### ក) តម្លៃជាទឹកប្រាក់ដែលរំពឹងទុក ឬ EMV (Expected Monetary Value)

#### ១) ការគណនា EMV

រឿងក្តីនីមួយៗតែងមានតម្លៃជាទឹកប្រាក់ដែលរំពឹងទុក (EMV)។ វាគឺជា "តម្លៃ" នៃរឿងក្តីនោះបន្ទាប់ពីការពិចារណាលើគ្រប់សេណារីយោដែលអាចកើតឡើងរួច។ វាគឺជាការគណនាដ៏សំខាន់ ដែលមេធាវីត្រូវធ្វើសម្រាប់គ្រប់រឿង

ក្តីនីមួយៗ។ ឧទាហរណ៍ យើងនឹងយកឧទាហរណ៍ពីខាងដើមនៃគ្រោះថ្នាក់រថយន្តមួយ ដែលវុត្ថាបានបើកឡានរបស់ខ្លួន ហើយទៅបុកនឹងថាវីដែលកំពុងដើរនៅលើផ្លូវ។ ក្នុងឧទាហរណ៍នេះ មេធាវីដែលតំណាងឱ្យបុគ្គលនីមួយៗ នឹងត្រូវគណនា EMV សម្រាប់រឿងក្តីនេះជាមុនសិន។

ជំហានដំបូងនៅក្នុងការគណនា EMV គឺត្រូវកំណត់ការខូតខាតសរុបដែលថាវីមាន។ ឧបមាថា នាងបាក់ជើង នៅក្នុងគ្រោះថ្នាក់នោះ ហើយនាងត្រូវចំណាយប្រាក់៥០០ដុល្លា លើវិក្កយបត្រវេជ្ជសាស្ត្រ និងថ្លៃថ្នាំពេទ្យ។ ឧបមាដែរថា នាងកាន់ទូរស័ព្ទថ្មីតម្លៃ១០០ដុល្លា ហើយទូរស័ព្ទនោះបាក់បែកនៅក្នុងគ្រោះថ្នាក់នោះ។ ជាចុងក្រោយ យើងឧបមាថានាង កំពុងតែដើរទៅសម្ភាសន៍ចូលធ្វើការងារ ប៉ុន្តែនាងមិនអាចចូលរួមការសម្ភាសន៍បានដោយសារតែគ្រោះថ្នាក់នោះ។ ក្រុមហ៊ុន នោះក៏បានជ្រើសរើសអ្នកផ្សេង ហើយថាវីអាចទាមទារថានាងអាចនឹងទទួលបានប្រាក់បៀវត្សរ៍ប្រចាំខែចំនួន ៤០០ដុល្លា ប្រសិនបើនាងអាចទទួលបានការងារនោះ។ ប៉ុន្តែដោយសារតែគ្រោះថ្នាក់នោះ នាងមិនបានទៅសម្ភាសន៍ ហើយមិនអាច ធ្វើការងារបានក្នុងរយៈពេល៣ខែបន្ទាប់មកទៀត។

នេះគឺជាបញ្ជីនៃការខូចខាតសក្តានុភូត ដែលវុត្ថាអាចនឹងត្រូវបង់៖

| | |
|---|---|
| ថ្លៃព្យាបាល | ៥០០ ដុល្លា |
| ទូរស័ព្ទ | ១០០ ដុល្លា |
| ការបាត់បង់ចំណូល | ១ ២០០ ដុល្លា |
| សរុបការខូចខាត | ១ ៨០០ ដុល្លា |

ជំហានបន្ទាប់គឺត្រូវកំណត់លទ្ធភាពដែលតុលាការអាចផ្តល់ជូនថាវីចំពោះការខូចខាតនីមួយៗ។

ប្រហែលចៅក្រមកម្ពុជាយល់ឃើញថា វុត្ថាបើកឡានលឿនពេក ហើយមិនបានមើលផ្លូវដោយប្រុងប្រយ័ត្ន។ ទោះបីជាថាវីមិនបានឆ្លងផ្លូវត្រង់កាច់ជ្រុងក្តី ប៉ុន្តែនាងដើរយឺតៗ និងដោយប្រុងប្រយ័ត្ន។ នៅក្នុងករណីនេះ ចៅក្រមអាច មានទំនោរយល់ឃើញថា វុត្ថាត្រូវទទួលខុសត្រូវ ហើយសំរេចឱ្យសងថ្លៃព្យាបាល និងថ្លៃទូរស័ព្ទដល់ថាវី ។ ប៉ុន្តែការបាត់ បង់ប្រាក់ចំណូល ប្រហែលជាការប៉ាន់ស្មានជ្រុលពេក។ ថាវីអាចមិនទទួលបានការងារនោះផង ទោះបីជានាងអាចទៅ សម្ភាសន៍ក៏ដោយ។ ប៉ុន្តែ ក៏អាចមានឱកាសតិចតួចដែលចៅក្រមនឹងយល់ឃើញថា វុត្ថាបើកបរធ្វេសប្រហែស និងអាច ផ្តល់ថ្លៃបាត់បង់ចំណូលដល់ថាវីផងដែរ។

នេះគឺជាបញ្ជីនៃអត្រាជោគជ័យរបស់ថាវីនៅក្នុងចំណុចខូចខាតទាំងបី ដែលមេធាវីរបស់នាងអាចគណនា៖

| | |
|---|---|
| ថ្លៃព្យាបាល | ៩០% |
| ទូរស័ព្ទ | ៩០% |
| ការបាត់បង់ចំណូល | ១០% |

ជំហានបន្ទាប់ គឺត្រូវរួមបញ្ចូលអត្រាជោគជ័យសម្រាប់ចំណុចខូចខាតនីមួយៗ ជាមួយនិងថ្លៃខូចខាតទាំងនោះ៖

| | | | |
|---|---|---|---|
| ថ្លៃព្យាបាល | ៥០០ ដុល្លា × ០,៩ | = | ៤៥០ ដុល្លា |
| ទូរស័ព្ទ | ១០០ ដុល្លា × ០,៩ | = | ៩០ ដុល្លា |
| ការបាត់បង់ចំណូល | ១ ២០០ ដុល្លា × ០,១ | = | ១២០ ដុល្លា |
| EMV សរុប | | | ៦៦០ ដុល្លា |

ផ្អែកលើការវិភាគនេះ តម្លៃជាទឹកប្រាក់ដែលរំពឹងទុកនៃរឿងក្តីនេះគឺ ៦៦០ដុល្លាស.រ.អា។ នេះមិនមែនមានន័យថាថាវីនឹងទទួលបាន ៦៦០ ដុល្លារអាមេរិកនោះទេ ប្រសិនបើរឿងរបស់នាង និងវុត្ថា ឡើងសវនាការនោះ។ នាងអាចមិនទទួលបានអ្វីទាំងអស់ ប្រសិនបើចៅក្រមសម្រេចថានាងខុសទាំងស្រុង។ ឬនាងអាចទទួលបាននូវទឹកប្រាក់ទាំង១៨០០ ដុល្លា សម្រាប់ការខូចខាតនោះ ប្រសិនបើចៅក្រមសម្រេចផ្ទុយពីនោះ។ EMV ឆ្លុះបញ្ចាំងចំនួនទឹកប្រាក់សំណងជាមធ្យមដែលនាងអាចទទួលបាន ប្រសិនបើរឿងនេះត្រូវបានវិនិច្ឆ័យជាច្រើនដង។ វាជួយឱ្យភាគីយល់អំពី "តម្លៃ" នៃរឿងក្តី ប្រសិនបើភាគីចង់ពិចារណាដោះស្រាយតាមការចរចា។

## លំហាត់ ៖ គណនា EMV

ចូរគណនា EMV របស់ គឹម សាន សម្រាប់ករណីខាងក្រោម:

គឹម សាន បានបញ្ជាទិញអង្ករ ១០០០បាវ ក្នុងតម្លៃ៩ដុល្លាក្នុងមួយបាវ។ គាត់មានកិច្ចសន្យាលក់អង្ករជាបន្តទៅឱ្យក្រុមហ៊ុននាំចេញមួយរបស់ចិន ក្នុងតម្លៃ១២ដុល្លាក្នុងមួយបាវ។ អ្នកផ្គត់ផ្គង់ គឺក្រុមហ៊ុនអង្ករទន្លេសាប បានខកខានក្នុងការប្រគល់អង្ករដល់គឹម សាន ឱ្យបានទាន់ពេលវេលា ហើយក្រុមហ៊ុនចិនបានគំរាមប្តឹង គឹម សាន ដោយសារតែការខកខានរបស់គាត់ក្នុងការប្រគល់អង្ករ។ បន្ទាប់ពីបានទាមទារជាបន្តបន្ទាប់ទៅក្រុមហ៊ុនទន្លេសាបមក គឹម សាន ត្រូវបង្ខំចិត្តទិញអង្ករ៥០០បាវ ពីក្រុមហ៊ុនអង្ករកំពង់ចាមក្នុងតម្លៃ១២ដុល្លាក្នុងមួយបាវ មកលក់បន្តឱ្យក្រុមហ៊ុនចិនវិញ ក្នុងតម្លៃដដែល គឺ១២ដុល្លាក្នុងមួយបាវ។

នៅទីបញ្ចប់ បន្ទាប់ពីមានការពន្យារអស់រយៈពេលពីរសប្តាហ៍មក ក្រុមហ៊ុនទន្លេសាប បានប្រគល់អង្ករខាងដើមចំនួន១០០០បាវ ដល់ គឹម សាន។ គឹម សាន បានយល់ព្រមទទួលយក ៥០០បាវ ហើយលក់បន្តទៅឱ្យក្រុមហ៊ុនចិនវិញ ក្នុងតម្លៃ ១២ដុល្លាក្នុងមួយបាវ ដោយយកចំណេញក្នុងមួយបាវ ៣ដុល្លា។ ក្រុមហ៊ុនចិនមានការមិនពេញចិត្តជាខ្លាំងចំពោះការយឺតយ៉ាវនោះ ហើយប្រាប់ គឹម សាន ថាពួកគេឈប់ទិញអង្ករពីគាត់ទៀតហើយ។ គឹម សាន មិនមានអ្នកទិញអង្ករ ៥០០ បាវទៀតឡើយ ដូច្នេះគាត់ក៏បញ្ជូនអង្ករទៅឱ្យក្រុមហ៊ុនទន្លេសាបវិញ អស់ទឹកប្រាក់ចំនួន ៥០០ ដុល្លា។

គឹម សាន ជឿថាគាត់ទទួលរងការខូចខាតដូចជា ក) ការខាតបង់ប្រាក់ចំណេញ ខ) ថ្លៃបញ្ជូនអង្ករត្រឡប់ទៅឱ្យក្រុមហ៊ុនទន្លេសាបវិញ និង គ) ការខាតបង់ប្រាក់ចំណេញនាពេលអនាគត ពីកិច្ចសន្យាជាមួយក្រុមហ៊ុនចិន ដោយសារតែការប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់គាត់។

## ២) ឥរិយាបថចំពោះហានិភ័យ

ប្រការសំខាន់ដែលគេត្រូវកត់សម្គាល់គឺថា EMV មិនបានគិតបញ្ចូលអំពីឥរិយាបថរបស់ភាគីវិវាទចំពោះហានិភ័យទេ។ អ្នកខ្លះមានការភ័យព្រួយយ៉ាងខ្លាំងចំពោះការខាតបង់លុយកាក់ ចំណែកឯអ្នកខ្លះទៀតមិនឥចឹងឡើយ។ ចូរពិចារណាលើករណីចំនួនពីរ ដោយករណីនីមួយៗមាន EMV ចំនួន ៥,០០០ដុល្លា ដូចគ្នា។[២០] នៅក្នុងករណីទីមួយ ភាគីម្ខាងមានឱកាស ៥០%ក្នុងការឈ្នះប្រាក់១០,០០០ដុល្លា និង៥០%មិនបានទទួលអ្វីទាំងអស់ ប៉ុន្តែក៏មិនចំណាយលើអ្វីដែរ។ នៅក្នុងករណីទីពីរ ភាគីដដែលមានឱកាស ៦០%ក្នុងការទទួលបានប្រាក់១០,០០០ដុល្លា និង ២០%ក្នុងការមិនបានទទួលអ្វីទាំងអស់ និងមិនចំណាយលើអ្វីទាំងអស់ ប៉ុន្តែក៏មានឱកាស ២០%ក្នុងការដែលត្រូវបង់ប្រាក់ ៥,០០០ដុល្លា ទៅភាគីម្ខាងទៀតដែរ។ ករណីទាំងពីរនេះនឹងមានតម្លៃគណនា EMV ជាចុងក្រោយចំនួន ៥,០០០ដុល្លា ប៉ុន្តែអាមានលទ្ធផលខុសគ្នាស្រលះ អាស្រ័យទៅលើឥរិយាបថរបស់ភាគីចំពោះហានិភ័យ។

គេអាចបង្ហាញការគណនា EMV ទាំងពីរករណីដូចខាងក្រោម ៖

| **ករណីទី១** | | **ករណីទី២** | |
|---|---|---|---|
| ១០, ០០០ ដុល្លា (ទឹកប្រាក់ទទួលបាន) | | ១០,០០០ ដុល្លារ (ទឹកប្រាក់ទទួលបាន) | |
| ×០.៥ (អត្រាជោគជ័យ) | = ៥,០០០ដុល្លា + | × ០.៦ (អត្រាជោគជ័យ) | = ៦,០០០ ដុល្លា + |
| ០ ដុល្លា (ទឹកប្រាក់ទទួលបាន) | | ០ ដុល្លា (ទឹកប្រាក់ទទួលបាន) | |
| ×០.៥ (អត្រាក្នុងការឈ្នះ) | = ០០០០ ដុល្លា | × ០.២ (អត្រាជោគជ័យ) | = ០០០០ ដុល្លា + |
| | | -៥,០០០ ដុល្លា (ទឹកប្រាក់ទទួលបាន) | |
| | | × ០.២ (អត្រាជោគជ័យ) | =-១,០០០ ដុល្លា |
| **EMV សរុប** | **៥,០០០ ដុល្លា** | **EMV សរុប** | **៥,០០០ ដុល្លា** |

## សំណួរសិក្សា

- តើអ្នកមានឆន្ទៈដោះស្រាយ សម្រាប់ចំនួនទឹកប្រាក់ដូចគ្នានៅក្នុងករណីទី២ដែរឬទេ បើប្រៀបធៀបនឹងករណីទី១? ចូរពន្យល់ ។
- តើអ្នកមានការព្រួយបារម្ភដែរឬទេ ចំពោះឱកាស២០%ដែលជាក់ស្តែងអ្នកអាចបាត់បង់ប្រាក់ចំនួន១,០០០ដុល្លា នៅក្នុងករណីទី២?

---

[២០] ដកស្រង់ចេញពី Marjorie Corman Aaron *ការស្វែងរកដំណោះស្រាយជាមួយចំនួន ផែនទី និងដើមឈើ* **សៀវភៅណែនាំអំពីដំណោះស្រាយវិវាទ** ទំព័រ ២០២, ២០៦ (Moffitt និង Bordone, ed., ឆ្នាំ២០០៥)។

### ៣) ការគណនា EMV ខុសៗគ្នា

ជាប្រការសំខាន់ផងដែរ ដែលត្រូវចងចាំថា ភាគីទាំងពីរនៅក្នុងឧទាហរណ៍ខាងលើ នឹងគណនា EMV ដោយឡែកពីគ្នា។ ជាលទ្ធផល ពួកគេអាចរកឃើញតួលេខ EMV ខុសគ្នាសម្រាប់ករណីតែមួយ។ ឧទាហរណ៍ ប្រហែលជាវុត្ថាគិតថាគាត់មិនបានធ្វើអ្វីខុសទេ ហើយថាវីជាអ្នករត់កាត់មុខឡានរបស់វុត្ថាដោយមិនប្រយ័ត្នខ្លួនឯង។ នៅក្នុងករណីនេះ គាត់អាចជឿជាក់ថា ចៅក្រមទំនងជាមិនបង្គាប់ឱ្យផ្តល់ប្រាក់សំណងដូចដែលថាវីជឿជាក់នោះទេ។ ឬមួយ ប្រហែលជាវុត្ថាជឿថា ថ្លៃព្យាបាលរបស់ថាវីមិនសមរម្យទេ ពីព្រោះវាពាក់ព័ន្ធទៅនឹងបញ្ហាដែលនាងមានមុនពេលគ្រោះថ្នាក់។ ក្នុងករណីនេះ ការគណនា EMV របស់វុត្ថាអាចតិចជាងការគណនារបស់ថាវីយ៉ាងច្រើន។

> ***ភាគីវិវាទដែលមានការគណនា EMV ប្រហាក់ប្រហែលគ្នា អាចឈានទៅរកដំណោះស្រាយតាមការចរចាច្រើនជាងភាគីដែលមានការគណនា EMV ខុសគ្នាខ្លាំង។***

### ខ) ជម្រើសល្អបំផុតក្រៅពីដំណោះស្រាយតាមការចរចា ឬ BATNA (Best Alternative to a Negotiated Settlement)

បន្ទាប់ពីភាគីទាំងអស់បានគណនា EMV រួចហើយ ពួកគេនឹងប្រើប្រាស់តួលេខនោះដើម្បីគណនាចំណុចមួយទៀតគឺ BATNA ។ ពាក្យកាត់ BATNA មានន័យថាជម្រើសល្អបំផុតក្រៅពីដំណោះស្រាយតាមការចរចា។ BATNA ជាចំណុចដ៏សំខាន់មួយនៅក្នុងដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ BATNA ប្រាប់ដល់ភាគីម្ខាងៗអំពីអ្វីដែលអាចនឹងកើតឡើង ប្រសិនបើមិនមានការព្រមព្រៀងគ្នាទេនោះ។ ជាទូទៅ BATNA បានមកពីការយក EMV ទៅបន្ថែមចំណុចមួយចំនួនទៀត។

នៅក្នុងឧទាហរណ៍ខាងលើ ថាវីត្រូវពិចារណាថាតើនាងត្រូវចំណាយប្រាក់អស់ប៉ុន្មានទៅលើមេធាវី ដើម្បីដាក់ពាក្យប្តឹងវុត្ថា។ ប្រសិនបើអស់១៥០ដុល្លា ពេលនោះនាងត្រូវដកចំនួនទឹកប្រាក់១៥០ដុល្លាចេញពី EMV របស់នាង។ ប្រសិនបើនាងមិនឈានដល់ដំណោះស្រាយដោយការចរចាជាមួយវុត្ថាទេ នាងទំនងជាទទួលបានប្រាក់សំណងជាមធ្យមតែប្រមាណ៥១០ដុល្លាប៉ុណ្ណោះ តាមរយៈការប្តឹងវុត្ថានៅតុលាការ (៦៦០ដុល្លា [EMV] - ១៥០ដុល្លា [ថ្លៃឈ្នួល/កម្រៃមេធាវី] = ៥១០ ដុល្លា)។

យ៉ាងណាមិញ នាងក៏ត្រូវពិចារណាផងដែរថា ការសងប្រាក់អាចមិនកើតឡើងយ៉ាងហោចណាស់ក៏ក្នុងរយៈពេល ១ឆ្នាំដែរ ពីព្រោះប្រព័ន្ធតុលាការដំណើរការយឺតណាស់។[២១] នាងក៏ត្រូវព្រួយបារម្ភអំពីភាពតានតឹងក្នុងចិត្តនៅពេលផ្តល់ចម្លើយនៅចំពោះមុខតុលាការផងដែរ។ ចុងក្រោយ នាងក៏កំពុងប្រថុយប្រថានជាមួយលទ្ធភាពដែលថា តុលាការអាចសម្រេចឱ្យវុត្ថាឈ្នះ ដោយបន្សល់ទុកឱ្យថាវីនូវប្រាក់សំណងដ៏តិចតួច ឬគ្មានប្រាក់សំណងសោះតែម្តង។ ប្រសិនបើនាងត្រូវការប្រាក់ភ្លាមៗ ឬប្រសិនបើនាងមានការភ័យព្រួយចំពោះភាពតានតឹងក្នុងការផ្តល់ចម្លើយនៅមុខតុលាការ ពេលនោះ

---

[២១] ជាទូទៅ តម្លៃពេលវេលានៃសាច់ប្រាក់ (អត្រាការប្រាក់) ក៏ជាផ្នែកមួយនៃការគណនា BATNA ផងដែរ។ ដើម្បីភាពងាយស្រួល តម្លៃនេះត្រូវបានដកចេញពីសមីការនេះ។

នាងអាចពិចារណាដកទឹកប្រាក់មួយចំនួនចេញពី BATNAដើមរបស់នាង ដោយយកកត្តាយល់ឃើញទាំងនេះមកធ្វើការពិចារណា។ ទោះជាយ៉ាងណា វាជាការពិបាកក្នុងការឱ្យតម្លៃជាទឹកប្រាក់ទៅលើភាពតានតឹង ឬទៅលើតម្រូវការក្នុងការទទួលប្រាក់ភ្លាមៗ។ ប៉ុន្តែនាងអាចគិតថាបញ្ហាទាំងនេះ (ភាពតានតឹង និងតម្រូវការប្រាក់ភ្លាមៗ) មានតម្លៃ ១០០ដុល្លា នៅក្នុងការគណនារបស់នាង។[២២] ប្រសិនបើដូច្នេះមែន ជាគោលការណ៍នាងកំពុងនិយាយប្រាប់ខ្លួនឯងថា:

> ខ្ញុំពិតជាត្រូវការលុយឥឡូវនេះ ហើយខ្ញុំភ័យខ្លាចក្នុងការទៅតុលាការ។ ខ្ញុំមានឆន្ទៈក្នុងដំណោះស្រាយសម្រាប់ប្រាក់ដែលតិចជាងនោះ ដើម្បីធានាថាខ្ញុំទទួលបានប្រាក់យ៉ាងឆាប់រហ័ស និងជៀសវាងឱ្យបាននូវដំណើរការក្តីនៅតុលាការ ដែលមានភាពតានតឹង ត្រូវការពេលវេលាយូរ។

នៅក្នុងករណីបែបនោះ BATNA ចុងក្រោយរបស់ថាវីត្រូវបានគណនាដូចខាងក្រោម:

| | |
|---|---:|
| EMV ដំបូងរបស់ថាវី | ៦៦០ ដុល្លា |
| សោហ៊ុយមេធាវីរបស់ថាវី និងប្រាក់ប្រដាប់ក្តី | -១៥០ ដុល្លា |
| កង្វល់របស់ថាវីអំពីភាពលម្បៀងនៅក្នុងតុលាការ | -១០០ ដុល្លា |
| BATNA របស់ថាវី | ៤១០ ដុល្លា |

ដូច្នេះ BATNA (ជម្រើសល្អបំផុតក្រៅពីដំណោះស្រាយតាមរយៈការចរចា) របស់ថាវី គឺ៤១០ ដុល្លា។

### គ) តម្លៃបម្រុង

ភាគីទាំងអស់នៅក្នុងការចរចាលើវិវាទណាមួយត្រូវមានតម្លៃបម្រុងរបស់ខ្លួន (សូមរំឮកឡើងវិញនូវឧទាហរណ៍ដែលមាន វណ្ណា និងធា តថ្លៃគ្នាពីតម្លៃរបស់តុ)។ វាស្ទើរតែស្មើនឹង "តម្លៃចុងក្រោយ" សម្រាប់ភាគីទៅហើយ មានន័យថា វាគឺជាចំនួនទឹកប្រាក់តិចបំផុតដែលភាគីម្ខាងមានឆន្ទៈក្នុងការទទួលយក និងច្រើនបំផុតដែលភាគីម្ខាងទៀតមានឆន្ទៈក្នុងការផ្តល់ឱ្យ។ នៅត្រង់ចំណុចបម្រុងរបស់ខ្លួន ភាគីនីមួយៗព្រងើយកន្តើយចំពោះដំណោះស្រាយ មានន័យថា លទ្ធផលដែលរំពឹងទុកពីការស្រុះស្រួល និងការប្តឹងផ្តល់គឺដូចគ្នា ដោយហេតុនោះ ទើបភាគីវិវាទព្រងើយកន្តើយចំពោះដំណើរការណាមួយដែលខ្លួនត្រូវជ្រើសរើស។ នៅក្នុងស្ថានភាពទាំងនេះ ជាទូទៅតម្លៃបម្រុងរបស់ភាគីគឺជា BATNA របស់ភាគីនោះ។

ដូច្នេះ នៅក្នុងឧទាហរណ៍ពីថាវី និងវុត្ថាវិញ BATNAរបស់ថាវី និងតម្លៃបម្រុងរបស់នាង ដូចបានពិភាក្សាខាងលើគឺ៤១០ដុល្លា។ ប្រសិនបើនាងស្រុះស្រួលត្រឹម៤១០ដុល្លា នាងមិនបានច្រើន ឬតិចជាងការដែលនាងបន្តប្តឹងទៅតុលាការនោះទេ។ គេអាចនិយាយថា នាងគួរតែមានឆន្ទៈដោះស្រាយរឿងក្តីនេះក្នុងតម្លៃសំណង ៤១០ដុល្លា ឬច្រើនជាង

---

[២២] វាអាចទៅរួច ប៉ុន្តែមិនសូវជាទំនងប៉ុន្មានទេ ដែលថាវីនឹងមានអារម្មណ៍ផ្ទុយពីនោះ ក្នុងការបញ្ជូនរឿងក្តីនោះទៅធ្វើសវនាការ។ នាងអាចកើតក្នុងគ្រួសារអ្នកមានស្តុកស្តម្ភ និងមិនសូវជាត្រូវការប្រាក់សំណងទេ។ ហើយនាងអាចខឹងវុត្ថាយ៉ាងខ្លាំង និងថែមទាំងចង់ប្តឹងវុត្ថានៅតុលាការ ដើម្បីឱ្យនាងអាចបង្ហាញថាគាត់ខុសជាសាធារណៈ។ នៅក្នុងសេណារីយោនោះ នាងអាចធ្វើលេខបូកជំនួសឱ្យលេខដក នូវទឹកប្រាក់មួយចំនួនទៅក្នុងBATNAរបស់នាង ដើម្បីរាប់បញ្ចូលអំពីបំណងរបស់នាងក្នុងការមិនស្រុះស្រួល ហើយចង់ទៅតុលាការជំនួសវិញ។

នោះ។ ប៉ុន្តែ នាងនឹងបដិសេធសម្ដីណាដែលមានតម្លៃតិចជាង៤១០ដុល្លា ពីព្រោះវានឹងតិចជាងជម្រើសល្អបំផុតក្រៅពីដំណោះស្រាយតាមការចរចា គឺការប្ដឹងទៅតុលាការ។ ប្រសិនបើតម្លៃបម្រុងរបស់វុត្ថា ខ្ពស់ជាងរបស់ថាវី (មានន័យថា វុត្ថាមានឆន្ទៈក្នុងការសងច្រើនជាង៤១០ដុល្លា) ពេលនោះ ភាគីវិវាទគួរតែអាចដោះស្រាយរឿងក្ដីនេះបាន។ បានសេចក្ដីថា វាជាការប្រសើរដែលពួកគេឈានដល់ដំណោះស្រាយមួយតាមការចរចាជាជាងទៅតុលាការ។

ក្រាហ្វិកខាងក្រោមបង្ហាញអំពីដំណោះស្រាយដែលអាចមាន ប្រសិនបើតម្លៃបម្រុងរបស់ថាវីគឺ ៤១០ដុល្លា ហើយតម្លៃបម្រុងរបស់វុត្ថាគឺ ៦០០ដុល្លា៖




ដំណោះស្រាយអាចកើតមាន នៅត្រង់ចំនុចណាមួយនៅក្នុងតំបន់ចរចានោះ។ ផ្ទុយទៅវិញ ប្រសិនបើវុត្ថាគណនាតម្លៃបម្រុងរបស់ខ្លួនឃើញត្រឹមតែ ៣១០ដុល្លា ដែលតិចជាងតម្លៃបម្រុងរបស់ថាវីចំនួន១០០ដុល្លានោះ ដំណោះ-ស្រាយនឹងមិនមានឡើយ។ បែបនេះនឹងមានន័យថា ការគណនាតម្លៃបម្រុងរបស់ភាគីវិវាទបង្ហាញថា ពួកគួរតែទៅតុលាការប្រសើរជាងស្រុះស្រួលលើរឿងក្ដីនេះ។ ក្រាហ្វិកខាងក្រោមនេះបង្ហាញអំពីសេណារីយោនោះ និងគម្លាតរវាងតម្លៃបម្រុងទាំងពីរ៖




ដូចគ្នានឹងវិធានដែលប្រើនៅតាមទីផ្សារដែរ គេអាចយកមកអនុវត្តផងដែរនៅក្នុងការចរចាអំពីវិវាទមួយ ដោយយកហេតុការណ៍ខាងក្រៅដែលពាក់ព័ន្ធមកកំណត់តម្លៃបម្រុង។ នៅក្នុងកំឡុងពេលចរចា ថាវីអាចព្យាយាមបញ្ចុះបញ្ចូលវុត្ថាថា តម្លៃបម្រុងរបស់វុត្ថាគួតែមានតម្លៃខ្ពស់ ដោយអាចមកពីរបួសធ្ងន់ដែលនាងបានទទួលរង។ វុត្ថាអាចព្យាយាមបញ្ចុះបញ្ចូលថាវីថាតម្លៃបម្រុងរបស់នាងគួរតែមានតម្លៃទាប ដោយសារតុលាការមានភាពមិនច្បាស់លាស់ មេធាវីមានតម្លៃថ្លៃ នាងនឹងត្រូវរង់ចាំរយៈពេលយូរ ម្យ៉ាងវាជាកំហុសរបស់នាង មិនមែនជាកំហុសរបស់គេនោះទេ ។ល។

## លំហាត់_តម្លៃបម្រុង

សុផល ជាម្ចាស់ហាងលក់ទូរស័ព្ទដៃមួយនៅទីក្រុងភ្នំពេញ។ គាត់ទិញទូរស័ព្ទជាច្រើនពីក្រុមហ៊ុននាំចូលរបស់ ណូរ៉ា។ នៅខែកក្កដា សុផលបញ្ជាទិញទូរស័ព្ទថ្មីម៉ាកម៉ូតូរ៉ូឡាចំនួន១០០គ្រឿង ពីណូរ៉ា។ ណូរ៉ាគិតតម្លៃ១០០ដុល្លារអាមេរិក សម្រាប់ទូរស័ព្ទមួយគ្រឿង។ សុផលមានសេចក្តីរំភើបយ៉ាងខ្លាំងក្នុងការទទួលបានទូរស័ព្ទទាំងនេះ ពីព្រោះវាជាទូរស័ព្ទថ្មីនៅក្នុងទីផ្សារកម្ពុជា។ ក្រុមហ៊ុនម៉ូតូឡូរ៉ាទើបតែចាប់ផ្តើមផលិតទូរស័ព្ទទាំងនេះ ហើយវាមានរូបរាងថ្មី ស្តើងមែនទែន និងមានប្រជាប្រិយភាពយ៉ាងខ្លាំងនៅសហរដ្ឋអាមេរិក និងប្រទេសជប៉ុន។ សុផលមានផែនការលក់វាយទូរស័ព្ទនេះ ក្នុងមួយគ្រឿង តម្លៃ២០០ដុល្លា។ សុផលបានចំណាយប្រាក់អស់៥០០ដុល្លា សម្រាប់ការផ្សាយពាណិជ្ជកម្មអំពីទូរស័ព្ទថ្មីទាំងនេះ ហើយបានបញ្ជាក់ថា នឹងមានដាក់លក់ចាប់ពីថ្ងៃសៅរ៍ ទី០៨ ខែសីហា តទៅ។ ហាងរបស់សុផលជាហាងដំបូងបង្អស់ដែលមានលក់ទូរស័ព្ទទាំងនេះនៅក្នុងប្រទេសកម្ពុជា។

នៅខែកក្កដា សុផលបានបង់ថ្លៃទិញចំនួនពាក់កណ្តាល(៥០០០ដុល្លា)ដល់ណូរ៉ា ហើយយល់ព្រមបង់ពាក់កណ្តាលទៀត នៅពេលប្រគល់ទំនិញនៅថ្ងៃទី០៧ ខែសីហា។ ប៉ុន្តែ នៅថ្ងៃទី០៧ ខែសីហា ទូរស័ព្ទមិនបានយកមកដល់ឡើយ។ នៅថ្ងៃទី០៨ អតិថិជនជាច្រើនបានមកហាងរបស់សុផល ដើម្បីទិញទូរស័ព្ទថ្មីនេះ ប៉ុន្តែគាត់មិនទាន់មានទូរស័ព្ទនោះទេ។ អតិថិជនមិនសប្បាយចិត្តដែលគាត់មិនមានទូរស័ព្ទថ្មីនៅថ្ងៃសៅរ៍ ដូចដែលគាត់បានសន្យានៅក្នុងការផ្សាយពាណិជ្ជកម្ម។ ណូរ៉ាសន្យាថា នឹងប្រគល់នៅក្នុងពេលប៉ុន្មានថ្ងៃទៀត ដោយបញ្ជាក់ថាខ្លួនមានបញ្ហាជាមួយគយ។

ទីបំផុត នៅថ្ងៃទី១៥ ខែសីហា ណូរ៉ាបានយកទូរស័ព្ទ ម៉ូតូរ៉ូឡា នោះមក ប៉ុន្តែអតិថិជនជាច្រើនរបស់សុផលបានទិញទូរស័ព្ទថ្មីម៉ាកណូគា នៅហាងដែលប្រកួតប្រជែងជាមួយគាត់រួចទៅហើយ។ សុផលក៏រកឃើញផងដែរថាទូរស័ព្ទទាំងនោះមានបញ្ហា និងដំណើរការមិនសូវល្អ។ គាត់មិនបានបង់ប្រាក់ពាក់កណ្តាលទៀតឱ្យណូរ៉ាទេ ហើយថែមទាំងទាមទារឱ្យ ណូរ៉ា សងប្រាក់មុនចំនួន៥.០០០ដុល្លា ដែលគាត់បានបង់នៅក្នុងខែកក្កដាមកវិញ។ ណូរ៉ាបានបដិសេធ ហើយសន្យាថានឹងផ្ញើទូរស័ព្ទម៉ូតូរ៉ូឡាចំនួន១០០គ្រឿងផ្សេងទៀតឱ្យ ក្នុងរយៈពេលពីរសប្តាហ៍ ប្រសិនបើសុផលប្រគល់ទូរស័ព្ទដែលមានបញ្ហានោះឱ្យមកខ្លួនវិញ។

សុផលបានមករកអ្នក ហើយសួរអ្នកអំពីការចរចារកដំណោះស្រាយ ឬក៏អាចដាក់ពាក្យប្តឹងណូរ៉ាទៅតុលាការ។ សុផលមានការព្រួយបារម្ភថាការដាក់បណ្តឹងអាចចំណាយពេលវេលាច្រើនពីមុខរបររបស់គាត់។ គាត់ក៏មានការភ័យព្រួយក្នុងការផ្តល់ចម្លើយនៅចំពោះតុលាការ ប្រឆាំងនឹងណូរ៉ាផងដែរ ។ គាត់ដឹងថាណូរ៉ាមានអំណាចខ្លាំងណាស់។

សូមគណនា EMV BATNA និងតម្លៃបម្រុងសម្រាប់សុផល។

បន្ទាប់មក ចូរព្យាយាមប៉ាន់ស្មានតម្លៃបម្រុងរបស់ណូរ៉ា។ តើលោកអ្នកត្រូវការព័ត៌មានបន្ថែមអ្វីខ្លះទៀត ដើម្បីប៉ាន់ស្មានតម្លៃបម្រុងរបស់ណូរ៉ា?

## ៣. កលយុទ្ធនៅក្នុងការចរចាបែបបែងចែក

គេអាចសម្រេចបានលទ្ធផលកាន់តែប្រសើរពីការចរចាបែបបែងចែក ដោយប្រើប្រាស់កលយុទ្ធមួយចំនួនដែលត្រូវបានគេស្គាល់ជាទូទៅរួចមកហើយ។ ខាងក្រោមនេះគឺជាកលយុទ្ធមួយចំនួនដែលអ្នកចរចាបានប្រើប្រាស់។ កលយុទ្ធទាំងនេះត្រូវបានផ្តល់ជូនជាឧបករណ៍សម្រាប់ប្រើនៅក្នុងការចរចាបែបបែងចែក ប៉ុន្តែមិនមានភាពចាំបាច់នៅក្នុងការចរចាផ្អែកលើផលប្រយោជន៍ឡើយ។

- **តម្លៃបម្រុងរបស់អ្នក:** កលយុទ្ធទីមួយគឺគណនាដោយប្រុងប្រយ័ត្ន និងប្រាកដប្រជានូវ EMV និង BATNA ក៏ដូចជាតម្លៃបម្រុងដែលជាលទ្ធផលចុងក្រោយ។ ដូចបានរៀបរាប់ពីខាងលើរួចមកហើយថា នេះជាការចាំបាច់ក្នុងការកំណត់ថាត្រូវមានវិធានការយ៉ាងដូចម្តេចនៅពេលមានវិវាទ។
- **តម្លៃបម្រុងរបស់ភាគីម្ខាងទៀត:** កលយុទ្ធទីពីរគឺព្យាយាមកំណត់ឱ្យបានត្រឹមត្រូវនូវតម្លៃបម្រុងរបស់ភាគីម្ខាងទៀត។ ចំណុចនេះអាចជាការលំបាក។ វិធីមួយក្នុងការកំណត់នេះគឺត្រូវព្យាយាមប្រមូលព័ត៌មានឱ្យបានច្រើនបំផុតតាមដែលអាចធ្វើបានអំពីភាគីម្ខាងទៀត និងកម្មវត្ថុនៃវិវាទ។ ជាងនេះទៅទៀត វាជាប្រការសំខាន់ដែលគេត្រូវស្តាប់ដោយប្រុងប្រយ័ត្ននូវអ្វីៗទាំងអស់ដែលភាគីម្ខាងទៀតនិយាយ ឬសរសេរ នៅក្នុងកំឡុងពេលចរចា។ ត្រូវពិចារណាលើតួលេខដែលភាគីនោះស្នើ និងថាភាគីនោះតើមានភាពបត់បែនប៉ុណ្ណា នៅក្នុងកំឡុងពេលចរចា។ ចំណុចនេះអាចផ្តល់នូវគំនិតស៊ីជម្រៅមួយចំនួន ពាក់ព័ន្ធនឹងតម្លៃបម្រុងរបស់ភាគីនោះ។ ផ្ទុយទៅវិញ ប្រការដែលសំខាន់ គឺអ្នកមិនត្រូវលះបង់តម្លៃបម្រុងរបស់ខ្លួនឯងឡើយ។
- **"ការកម្លា":** ការកម្លា គឺជាការបង្ហាញនូវចេតនាធ្វើអ្វីមួយ ដែលមិនមែនជាចេតនាពិតប្រាកដ ដូចជា ចំណាយប្រាក់តែក្នុងចំនួនណាមួយ ឬឈប់សហការជាមួយភាគីម្ខាងទៀត ឬដើរចេញពីការចរចាជាដើម។ ដោយប្រើការកម្លា អ្នកអាចមានលទ្ធភាពបង្កើតអំណាចតថ្លៃបន្ថែមទៀត។ វាអាចបណ្តាលឱ្យភាគីម្ខាងទៀតកែប្រែតម្លៃបម្រុងរបស់ខ្លួន ឬកែប្រែការប៉ាន់ស្មានតម្លៃបម្រុងរបស់អ្នក។ ទោះក្នុងផ្លូវណាក៏ដោយ វាអាចហុចលទ្ធផលកាន់តែប្រសើរសម្រាប់បុគ្គលដែលធ្វើការកម្លានោះ។

ប៉ុន្តែ វាជាការប្រថុយប្រថាន ដោយសារមានពេលខ្លះ ការកម្លានោះត្រូវបានគេ "ជំរុញ"។ នេះមានន័យថាភាគីម្ខាងទៀតអាចបង្ខំអ្នកឱ្យធ្វើនូវអ្វីដែលអ្នកបានគំរាមថានឹងធ្វើ។ ប្រសិនបើលោកអ្នកមិនធ្វើតាមនោះទេ អ្នកនឹងបាត់បង់ភាពដែលអាចជឿជាក់បានពីក្រសែភ្នែករបស់ភាគីម្ខាងទៀត។ ហើយនាពេលអនាគតភាគីម្ខាងទៀត អាចនឹងមិនជឿនូវអ្វីដែលអ្នកនិយាយ។ ប្រសិនបើការកម្លាត្រូវបានគេជំរុញ លទ្ធផលចុង-ក្រោយទំនងជាកាន់តែអាក្រក់ជាងមុនទៅទៀត។

ជាងនេះទៅទៀត ការកម្លាជួនកាលអាចបំផ្លាញដល់ទំនាក់ទំនងយូរអង្វែងរវាងភាគីទាំងពីរ ដោយ-សារកង្វះទំនុកចិត្ត។ កាកម្លាត្រូវបានប្រើប្រាស់បានល្អបំផុត នៅក្នុងការចរចារវាងគូភាគី ដែលមិនមានចេតនាបន្តទំនាក់ទំនងទៅពេលអនាគត ដូចជាករណីទិញទំនិញនៅផ្សារ នៅថ្ងៃឈប់សម្រាកជាដើម។

- **ការកាត់ថ្លៃ :** ការកាត់ថ្លៃគឺជាការប្រើប្រាស់តួលេខ ទោះតិចក្តីច្រើនក្តី ដើម្បីជះឥទ្ធិពលទៅលើការយល់ឃើញរបស់ភាគីម្ខាងទៀតចំពោះតម្លៃ។ ការស្រាវជ្រាវបានបង្ហាញឱ្យឃើញថា មនុស្សនឹងផ្លាស់ប្តូរការវាយតម្លៃ

និងសេចក្តីស្នើតបរបស់ខ្លួន ដោយផ្អែកលើសម្ទើដំបូង។[២៣] ឧទាហរណ៍ ការសិក្សាមួយរបស់ប្រទេសស៊ុយអែត បានបង្ហាញឱ្យឃើញថា អ្នកទិញផ្ទះល្វែងបានផ្តល់តម្លៃដំបូងខ្ពស់ ប្រសិនបើតម្លៃនៅក្នុងបញ្ជីដំបូងខ្ពស់។ អ្នកទិញផ្ទះល្វែងបានផ្តល់តម្លៃដំបូងទាប ប្រសិនបើតម្លៃនៅក្នុងបញ្ជីដំបូងទាប សម្រាប់អចលនទ្រព្យដដែលនោះ។ គេអាចនិយាយបានថា ការយល់ឃើញរបស់អ្នកទិញអំពីតម្លៃទីផ្សាររបស់អចលនទ្រព្យ ទទួលឥទ្ធិពលពីតម្លៃដំបូងដែលអ្នកលក់កំណត់។[២៤] ការកាត់ថ្លៃមានឥទ្ធិពលចំពោះ សូម្បីតែ អ្នកជំនាញ។ ក្នុងការសិក្សាមួយរបស់ប្រទេសអាល្លឺម៉ង់ អ្នកស្រាវជ្រាវបានរកឃើញថា ការប៉ាន់ស្មានតម្លៃរថយន្ត ដោយយន្តការីអាជីព ទទួលឥទ្ធិពលយ៉ាងខ្លាំងពីសំណួរកាត់ថ្លៃដំបូងដែលអតិថិជនសួរ។[២៥]

ការកាត់ថ្លៃមានប្រសិទ្ធភាព ពីព្រោះវាហាក់ដូចជាធ្វើឱ្យមនុស្សផ្តោតអារម្មណ៍ទៅលើទិដ្ឋភាពមួយចំនួននៃកម្មវត្ថុមួយ។ ការកាត់ថ្លៃខ្ពស់ពាក់ព័ន្ធនឹងផលិតផលមួយនឹងហាក់បណ្តាលឱ្យមនុស្សផ្តោតទៅលើទិដ្ឋភាពវិជ្ជមាននៃផលិតផលនោះ ចំណែកឯការកាត់ថ្លៃទាបនឹងបណ្តាលឱ្យមានឥទ្ធិពលផ្ទុយពីនោះ។ អ្នកចរចាអាចទាញយកអត្ថប្រយោជន៍ពីចំណុចនេះ ដោយបង្ហាញនូវការទាមទារដំបូងដ៏ខ្ពស់ពីភាគីម្ខាងទៀត (ដូចគ្នានឹងអ្នកលក់អចលនទ្រព្យស៊ុយអែតដែរ) ឬសម្ទើដំបូងដ៏ទាប ប្រសិនបើខ្លួនជាអ្នកបង់ប្រាក់។ គួរកត់សម្គាល់ថា ការកាត់ថ្លៃដំបូងខ្ពស់ ឬទាបហួសហេតុពេក មានប្រសិទ្ធភាពកាន់តែតិច ហើយមានភាពប្រថុយប្រថានក្នុងការធ្វើឱ្យភាគីម្ខាង ទៀតដើរចេញ។[២៦]

- **"តម្លៃចុងក្រោយ" ដែលមិនអាចកែប្រែបាន:** ជួនកាលភាគីម្ខាងអាចទាមទារថាខ្លួនកំពុងផ្តល់នូវជំហរដែលដាច់ខាត និងជាចុងក្រោយ។ នេះគឺជាសម្ទើដ៏ល្អបំផុតរបស់ខ្លួន ហើយខ្លួនមិនអាចព្រមឱ្យហួសពីនោះទៀតបានទេ។ ជួនកាល ការបង្ហាញតម្លៃចុងក្រោយដែលមិនអាចកែប្រែបាន គឺស្រដៀងទៅនឹងការកម្លាដែរ ប៉ុន្តែតម្លៃចុងក្រោយ គឺជាជំហរដ៏ពិតប្រាកដរបស់ភាគី ហើយមិនមែនគ្រាន់តែជាការកម្លានោះទេ។ ជាទូទៅ តម្លៃចុងក្រោយគឺជាតម្លៃបម្រុងនោះឯង។ ឧទាហរណ៍ ប្រសិនបើបន្ទាប់ពីព្យាយាមចរចារកដំណោះស្រាយរួចមក ភាគីម្ខាងមានឆន្ទៈចំណាយតែ ១,០០០ដុល្លានោះ ភាគីនោះអាចប្រាប់ដល់ភាគីម្ខាងទៀតថានេះគឺជាតម្លៃចុងក្រោយ។ នៅ

---

[២៣] Henrik Kristensen និង Tommy Gärling *ចំណុចគោល ចំណុចយោង និងសម្ទើតបនៅក្នុងការចរចា។* របាយការណ៍ចិត្តវិទ្យានៃសាកលវិទ្យាល័យ Goteborge លេខ៧ ទំព័រ២៧ (ឆ្នាំ១៩៩៧)។

[២៤] *ដូចមុន*

[២៥] Adam D. Galinsky, *តើអ្នកគួរផ្តល់សម្ទើដំបូងដែរឬទេ?*, **ការចរចា** (មហាវិ.ពាណិជ្ជ. នៃសាកលវិ.ហាវើដ, ឆ្នាំ២០០៤)។ "នៅក្នុងការសិក្សានេះ អ្នកស្រាវជ្រាវតម្រូវឱ្យអតិថិជនមួយចំនួន យករថយន្តជាច្រើន ដែលប្រើរួច ហើយត្រូវការការជួសជុល ទៅរកយន្តការីអាល្លឺម៉ង់ ដែលជាអ្នកដែលគេរំពឹងថានឹងដឹងអំពីតម្លៃពិតប្រាកដនៃរថយន្ត។ បន្ទាប់ពីបានផ្តល់យោបល់ផ្ទាល់ខ្លួនអំពីតម្លៃរថយន្តនោះរួច អតិថិជនសួរយន្តការីអំពីតម្លៃដែលគាត់ប៉ាន់ស្មាន។ យន្តការីចំនួនពាក់កណ្តាលត្រូវបានផ្តល់ការកាត់ថ្លៃទាប។ អតិថិជននិយាយថា "ខ្ញុំគិតថារថយន្តនោះត្រូវលក់ក្នុងតម្លៃ២,៨០០ម៉ាក"។ យន្តការីចំនួនពាក់កណ្តាលទៀតត្រូវបានផ្តល់ការកាត់ថ្លៃខ្ពស់: "ខ្ញុំគិតថារថយន្ត នោះត្រូវលក់ក្នុងតម្លៃ៥,០០០ម៉ាក"។ យន្តការីទាំងនោះប៉ាន់ស្មានតម្លៃរថយន្តក្នុងតម្លៃ ១,០០០ម៉ាក បន្ថែមទៀតនៅពេលដែលពួកគេត្រូវបានផ្តល់ការកាត់ថ្លៃខ្ពស់!" *ដូចមុន*។

[២៦] *ដូចមុន*

សហរដ្ឋអាមេរិក ភាគីម្ខាងអាចនិយាយថាខ្លួនមាន "ដៃដែលជាប់ចំណង" ។ នេះមានន័យថា ខ្លួនមិនមានលទ្ធភាពក្នុងការផ្លាស់ប្តូរជំហររបស់ខ្លួនឱ្យហួសពីនេះទៀតបានឡើយ ។

ប្រការនេះគួរអនុវត្តតែនៅពេលណាដែលការចរចាបានឈានទៅដល់ចំណុចមួយ ដែលភាគីនោះដឹងថាខ្លួននឹងមិនទទួលបានអ្វីច្រើនជាងតម្លៃបម្រុងរបស់ខ្លួននោះទេ។ ការប្រកាសតម្លៃចុងក្រោយឆាប់ពេក អាចបណ្តាលឱ្យទទួលបានលទ្ធផលដែលមិនសូវមានប្រយោជន៍។ ឧទាហរណ៍ ប្រសិនបើភាគីម្ខាងប្រកាសឆាប់រហ័សពេកនៅក្នុងការចរចា ថាខ្លួននឹងមិនចំណាយច្រើនជាង១,០០០ ដុល្លាឡើយ នោះគាត់នឹងបាត់បង់ឱកាសក្នុងការចំណាយតិចជាងនោះ គឺ៩០០ដុល្លា។ ភាគីត្រូវមានភាពជឿជាក់ជាដាច់ខាតថា អ្វីដែលតិចជាង ១,០០០ ដុល្លា គឺមិនអាចទៅរួច។ បន្ទាប់មក គឺពេលនោះហើយដែលគេគួរប្រកាសតម្លៃចុងក្រោយដល់ភាគីម្ខាងទៀត។

ការប្រកាសតម្លៃចុងក្រោយអាចនឹងបញ្ចប់ការចរចា ទោះជាមានការព្រមព្រៀង ឬបរាជ័យក្តី។ ជាលទ្ធផល នេះគឺជាកលយុទ្ធផ្អែកលើភាពអំណោយផលនៃពេលវេលា ប៉ុន្តែអាចមានភាពប្រថុយប្រថាន ប្រសិនបើប្រើប្រាស់ឆាប់រហ័សពេកនៅក្នុងដំណើរការ។ ព័ត៌មានថ្មីៗដែលទើបតែបញ្ចេញក្នុងពេលចរចា អាចផ្លាស់ប្តូរតម្លៃចុងក្រោយបាន។

- **ការផ្លាស់ប្តូរតម្លៃបម្រុង:** ភាគីម្ខាងអាចទាមទារភាគីម្ខាងទៀតឱ្យផ្លាស់ប្តូរតម្លៃបម្រុង ដោយផ្អែកលើអង្គហេតុ ឬទស្សនៈដែលបានលើកឡើងនៅក្នុងកំឡុងពេលចរចា និងព័ត៌មានសំខាន់ដែលភាគីម្ខាងទៀតអាចមិនមាន។ នេះគឺជាតួនាទីមួយរបស់មេធាវី ជាអ្នកថ្លែងការពារឱ្យអតិថិជនរបស់ខ្លួន។ ឧទាហរណ៍ ភាគីម្ខាងអាចផ្តល់ភស្តុតាងនៃការខូចខាតធ្ងន់ធ្ងរដល់អាជីវកម្មមួយ ដែលបណ្តាលមកពីផលិតផលខូចគុណភាព របស់ភាគីម្ខាងទៀត។

ទោះជាយ៉ាងណា មេធាវីមិនត្រូវការពារជំហរកូនក្តីរបស់ខ្លួនហួសហេតុពេក ហើយបំភ្លៃព័ត៌មានដោយកុហកបោកប្រាស់ឡើយ។ យុត្តាធិការជាច្រើនផ្តល់ការសង្គ្រោះដល់ភាគីរងគ្រោះ ដោយសេចក្តីថ្លែងការណ៍បោកប្រាស់ ដែលនាំឱ្យមានការព្រមព្រៀងស្រុះស្រួល។ ការសង្គ្រោះទាំងនោះអាចមាន ដូចជាការប្តឹងទារសំណងជំងឺចិត្ត ចំពោះការក្លែងបន្លំ ឬលុបចោលកិច្ចព្រមព្រៀងនោះ បន្ទាប់មកដាក់ពាក្យប្តឹងឡើងវិញទៅតុលាការជាដើម។[២៧] នៅក្នុងប្រទេសកម្ពុជា អំពើបំភាន់ មិនទៀងត្រង់ ឬបំភ្លៃព័ត៌មាន អាចបង្កើតបាន ជាបទឆបោកដែលគ្រប់គ្រាន់សំរាប់រំលាយកិច្ចព្រមព្រៀងស្រុះស្រួលបាន។[២៨] វាមានរេខាខណ្ឌច្បាស់លាស់រវាងអំពើឆបោក

---

[២៧] កិច្ចព្រមព្រៀងស្រុះស្រួលក៏ដូចជាកិច្ចសន្យាដទៃទៀតដែរ អាចលុបចោលបានក្នុងករណីមានការក្លែងបន្លំ ឬការបំភ្លៃ។ នៅសហរដ្ឋអាមេរិក *សូមមើល ឧ.* UCC 2-721; *Phipps v. Winneshiek County*, 593 N.W.2d 143 (Iowa ឆ្នាំ១៩៩៩)។ នៅអង់គ្លេស *សូមមើល ឧ. Fulton Co. Ltd. v. Totes Isotoner (UK) Ltd.*, 2002 WL 32068011 (PCC), R.P.C. 27 (ឆ្នាំ២០០៣)។ ចំពោះកិច្ចសន្យានៅសហភាពអឺរ៉ុប *សូមមើលឧ.* ***គោលការណ៍នៃច្បាប់កិច្ចសន្យាអឺរ៉ុប*** មាត្រា ៤.១០៧ គណៈកម្មការស្តីពីច្បាប់កិច្ចសន្យាអឺរ៉ុប (ឆ្នាំ១៩៩៨)។

[២៨] ក្រឹត្យ-ច្បាប់លេខ៣៨ មាត្រា៦ ដល់មាត្រា១០ កំណត់សម្គាល់ *ខាងលើ* លេខ១២, ក.រ.-ព.ក កំណត់សម្គាល់ *ខាងលើ* លេខ១៣ មាត្រា៣៤៧-៣៤៩ (ការលុបចោលកិច្ចសន្យាដោយការឆបោក ព័ត៌មានមិនពិត និងរំលោភបំពានលើស្ថានភាព), **បទអត្ថាធិប្បាយ** ក.ន.រ.-ព.ក. កំណត់ សម្គាល់ *ខាងលើ* លេខ១២ គន្ថីទី៣ ជំពូក៤ ផ្នែកទី២ (៥)(៣)(ឆ្នាំ ២០០៧), ទំព័រ ១១០។ ការឆបោក

និងកលយុទ្ធចរចាដ៏មុតស្រួចដែលគេប្រើដើម្បីផ្លាស់ប្តូរតម្លៃបម្រុងរបស់ភាគីម្ខាងទៀត។ អ្នកប្រកបវិជ្ជាជីវៈច្បាប់ គួរមានការប្រុងប្រយ័ត្នកុំឆ្លងរេខានោះឱ្យសោះ បើដូច្នោះទេ ខ្លួននឹងប្រថុយប្រថាន ក្នុងការបង្កើតកិច្ចព្រមព្រៀងមួយដែលគេអាចរំលាយបាន ព្រមទាំងត្រូវរំលោភក្រមសីលធម៌វិជ្ជាជីវៈមេធាវីកម្ពុជាទៀតផង។[២៩]

## សំណួរសិក្សា

- តើលោកអ្នកធ្លាប់ប្រើប្រាស់កលយុទ្ធទាំងនេះនៅក្នុងការចរចាដែរឬទេ?
- ប្រសិនបើធ្លាប់ តើកលយុទ្ធណាមួយ ដែលមានភាពជោគជ័យជាងគេបំផុត ហើយហេតុអ្វី?
- មេធាវី ផារី ទាមទារចំពោះមេធាវី សុកញ្ញា ថា កូនក្តីរបស់ខ្លួន "មានបំណងយ៉ាងមុតមាំ" ក្នុងការទៅតុលាការ និងទុកឱ្យចៅក្រមកំណត់ថាអ្នកណាត្រូវអ្នកណាខុស។ ប៉ុន្តែ ជាការសម្ងាត់ ផារីដឹងថាកូនក្តីរបស់ខ្លួនភ័យខ្លាចក្នុងការទៅតុលាការណាស់។ ប្រសិនបើភាគីដោះស្រាយវិវាទបានដោយជោគជ័យ តើការអះអាងរបស់ផារី ជាអំពើឆបោកដែលធ្វើឱ្យការព្រមព្រៀងស្រុះស្រួលនោះអាចត្រូវលុបចោលបានដែរឬទេ?
- តើលោកអ្នកចង់ដឹងអង្គហេតុច្រើនជាងនេះដែរឬទេ ដើម្បីឆ្លើយនឹងសំណួរនេះ? ប្រសិនបើចង់ តើអង្គហេតុអ្វីខ្លះដែលអាចមានសារៈប្រយោជន៍?

## លំហាត់ ៖ ការចរចាបែបបែងចែក

ក្រុមហ៊ុនសំណង់សៀមរាបកំពុងសាងសង់សណ្ឋាគារដ៏ធំស្កឹមស្កៃមួយនៅក្នុងខេត្តសៀមរាប ដែលមានឈ្មោះថា "បន្ទាយអង្គរ"។ ក្រុមហ៊ុនស៊ីម៉ង់ត៍អាស៊ានទើបតែចុះហត្ថលេខាផ្គត់ផ្គង់ក្រុមហ៊ុនសៀមនូវស៊ីម៉ង់ត៍សម្រាប់គម្រោងនោះ។ កិច្ចសន្យាតម្រូវឱ្យក្រុមហ៊ុនអាស៊ានប្រគល់ស៊ីម៉ង់ត៍លាយស្រេចចំនួន ១០,០០០គីឡូក្រាម ដល់ក្រុមហ៊ុនសៀមនៅថ្ងៃទី១៥ ខែមករា។ បន្ទាប់មកអាស៊ានត្រូវប្រគល់ស៊ីម៉ង់ត៍ចំនួន ៥,០០០គីឡូក្រាមទៀត នៅថ្ងៃទី១៥ រៀងរាល់ខែ រហូតដល់ថ្ងៃទី១៥ ខែធ្នូ។ កិច្ចសន្យានោះមានតម្លៃសរុប ៦៥,០០០ដុល្លាអាមេរិក (១ដុល្លា /ស៊ីម៉ង់ត៍១គីឡូ × ៦៥,០០០ គីឡូ)។

ក្រុមហ៊ុនអាស៊ានបានប្រគល់ស៊ីម៉ង់ត៍ពីរលើកដំបូងទាន់ពេលវេលា ហើយក្រុមហ៊ុនសៀមក៏បានបង់ប្រាក់ពីរលើក

---

ព័ត៌មានមិនពិត និងរំលោភបំពានលើស្ថានភាព ត្រូវបែងចែកឱ្យដាច់ពីការដែលគ្រាន់តែភ័ន្តច្រលំលើអង្គហេតុ ឬអង្គច្បាប់ ដែលពិតជាមិនមែនជាមូលហេតុដែលអាចលុបចោលកិច្ចព្រមព្រៀងសះជាបានឡើយ។ ក.រ.-ព.ក មាត្រា៧២៧-៧២៨។

[២៩] ក្រមសីលធម៌មេធាវីចែងថា "គ្រប់ការទំនាក់ទំនងរវាងមេធាវីគ្នាឯង ត្រូវប្រព្រឹត្តឡើងក្នុងស្មារតីនៃសហភាតាសមរម្យ និងគួរសមជានិច្ច។ ក្នុងការគោរពផលប្រយោជន៍អតិថិជនរបស់ខ្លួន មេធាវីមិនត្រូវធ្វើអ្វីដែលអាចនឹងនាំឱ្យខូចខាតដល់សហភាតានៃខ្លួនឡើយ។..." ក្រមសីលធម៌មេធាវី មាត្រា២៥ (បកប្រែក្រៅផ្លូវការដោយគណៈមេធាវីក្នុង *វិជ្ជាជីវៈច្បាប់នៅកម្ពុជា [Legal Profession in Cambodia]* គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៥)។ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីចែងផងដែរថា "ត្រូវទទួលទណ្ឌកម្មជាបទវិន័យ ចំពោះមេធាវីណាដែលប្រព្រឹត្តល្មើសនឹងវិធាននៃវិជ្ជាជីវៈ ឬប្រព្រឹត្តអំពើណាមួយដែលប៉ះពាល់ដល់សីលធម៌ ឬកិត្តិយសមេធាវី ទោះបីប្រព្រឹត្តក្រៅពីការប្រកបវិជ្ជាជីវៈរបស់ខ្លួនក៏ដោយ" **ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី** មាត្រា៥៩ (បកប្រែក្រៅផ្លូវការដោយគណៈមេធាវីក្នុង *វិជ្ជាជីវៈច្បាប់នៅកម្ពុជា* គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៥)។

ដំបូងទាន់ពេលវេលាដែរ។ បន្ទាប់មក នៅក្នុងខែមីនា ក្រុមហ៊ុនសៀមរាបបដិសេធមិនព្រមបង់ប្រាក់សម្រាប់ការប្រគល់លើកទីបី ដោយខ្លួនតវ៉ាថាស៊ីម៉ង់ត៍មានគុណភាពអន់។ ក្រុមហ៊ុនអាស៊ាន ឆ្លើយតបថាខ្លួនបានត្រួតពិនិត្យស៊ីម៉ង់ត៍ឃើញថាមានគុណភាពល្អនៅពេលប្រគល់ ប៉ុន្តែដោយសារកម្មកររបស់ក្រុមហ៊ុនសៀមរាបទៅវិញទេ ដែលមិនបានរៀបចំទុកដាក់ឱ្យបានត្រឹមត្រូវនៅឯការដ្ឋានសាងសង់ ដោយផ្អែកលើការសង្កេត និងត្រួតពិនិត្យរបស់ខ្លួន។ ក្រុមហ៊ុនអាស៊ានថែមទាំងបញ្ជាក់ទៀតថា ប្រសិនបើក្រុមហ៊ុនសៀមរាប មិនព្រមបង់ប្រាក់ទេ ខ្លួននឹងមិនប្រគល់ស៊ីម៉ង់ត៍បន្ថែមទៀតឡើយ។

ក្រោយមក ក្រុមហ៊ុនសៀមរាបបានសម្រេចចិត្តចុះកិច្ចសន្យាបន្ទាន់មួយជាមួយក្រុមហ៊ុនផ្គត់ផ្គង់ស៊ីម៉ត៍មួយទៀត ក្នុងតម្លៃថ្លៃជាងក្រុមហ៊ុនអាស៊ានពីរដង។

ក្រុមហ៊ុនសៀមរាបបានទាក់ទងទៅមេធាវីរបស់ខ្លួន ហើយបានទាមទារថាខ្លួនទទួលបានស៊ីម៉ង់ត៍គុណភាពអន់ ចំនួន៥,០០០គីឡូក្រាមពីក្រុមហ៊ុនអាស៊ាន។ ក្រុមហ៊ុនខ្លួនបានចំណាយអស់ប្រាក់៥,០០០ដុល្លា សំរាប់កម្លាំងពលកម្ម និងសោហ៊ុយមួយចំនួនទៀតពាក់ព័ន្ធទៅនឹងការរៀបចំទុកដាក់ និងក្រោយមករុះរើស៊ីម៉ង់ត៍មិនល្អនោះចេញ។ ដោយសារតែខ្លួននឹងប្រឈមមុខនឹងការខាតបង់លើសពីនោះទៀត ប្រសិនបើខ្លួនមានការយឺតយ៉ាវក្នុងការបញ្ចប់ការសាងសង់ ក្រុមហ៊ុនសៀមរាបបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនផ្គត់ផ្គង់ផ្សេងដែលមានតែមួយគត់ ហើយត្រូវបង់ប្រាក់ទ្វេដងនៃតម្លៃ ក្នុងកិច្ចសន្យាដែលខ្លួនបានចុះជាមួយក្រុមហ៊ុនអាស៊ាន។ ពោលគឺ ក្រុមហ៊ុនសៀមរាបនឹងត្រូវបង់ប្រាក់ចំនួន ១០០.០០០ ដុល្លា សំរាប់តម្រូវការស៊ីម៉ង់ត៍របស់ខ្លួននាពេលអនាគត (២ដុល្លា/១គីឡូ×៥០.០០០គីឡូ) គឺច្រើនជាងតម្លៃដែលខ្លួនបានចុះកិច្ចសន្យាបង់ឱ្យក្រុមហ៊ុនអាស៊ានចំនួន៥០,០០០ដុល្លា។ យ៉ាងណាមិញ ក្រោយពីស៊ើបអង្កេតលើការដ្ឋានរួចមក ក្រុមហ៊ុនសៀមរាបលួចគិតតែឯងថា ខ្លួនអាចមានកំហុសមួយផ្នែកពាក់ព័ន្ធនឹងបញ្ហាស៊ីម៉ង់ត៍នោះដែរ។

ក្រុមហ៊ុនអាស៊ានបានទាក់ទងមេធាវីរបស់ខ្លួន ហើយបានទាមទារថាក្រុមហ៊ុនសៀមរាបជ្រើសរើសកម្មករគ្មានជំនាញដែលមិនដឹងអំពីរបៀបរៀបចំទុកដាក់ស៊ីម៉ង់ត៍ឱ្យបានត្រឹមត្រូវ។ ក្រុមហ៊ុនថាវាគឺជាកំហុសរបស់ក្រុមហ៊ុនសៀមរាបដែលនាំឱ្យមានបញ្ហានៅឯការដ្ឋាន។ ក្រុមហ៊ុនជឿថាខ្លួនអាចពិសោធន៍រឿងនេះបាន ប៉ុន្តែក៏លួចគិតតែឯងដែរថាវាអាចជាកំហុសមួយផ្នែករបស់ខ្លួន។ ក្រុមហ៊ុនអាស៊ានមិនបានទទួលប្រាក់សម្រាប់ការប្រគល់ស៊ីម៉ង់ត៍ចំនួន ៥.០០០គីឡូក្រាមលើកទីបីឡើយ។ លើសពីនេះទៅទៀត ក្រុមហ៊ុនសៀមរាបបានរំលោភលើកិច្ចសន្យាដោយបដិសេធមិនទទួលយកការប្រគល់ចំនួនប្រាំបួនលើកទៀត។ ក្រុមហ៊ុនអាស៊ានអាចទទួលបានប្រាក់ចំណេញចំនួន ២៥.០០០ដុល្លា ពីការប្រគល់ស៊ីម៉ង់ត៍ដែលនៅសល់។ ម្យ៉ាង ក្រុមហ៊ុនអាស៊ានបានដឹកជញ្ជូនសម្ភារៈ និងគ្រឿងបរិក្ខារស៊ីម៉ង់ត៍ជាច្រើនទៅសៀមរាប សម្រាប់ការងារនោះរួចហើយ។ ឥឡូវខ្លួនមិនត្រឹមតែខាតបង់ប្រាក់ចំណេញពីកិច្ចសន្យាប៉ុណ្ណោះទេ ថែមទាំងត្រូវចំណាយប្រាក់ចំនួន ៥,០០០ដុល្លាទៀត ដើម្បីដឹកស៊ីម៉ង់ត៍ សម្ភារៈ និងគ្រឿងបរិក្ខារទៅកាន់កន្លែងផ្សេងទៀត។

ប្រសិនបើវិវាទត្រូវបានបញ្ជូនទៅតុលាការ ភាគីនីមួយៗនឹងត្រូវចំណាយប្រាក់ប្រហែល ១០,០០០ ដុល្លា សម្រាប់សោហ៊ុយ និងកម្រៃមេធាវី។ ក្រុមហ៊ុនទាំងពីរក៏មានការភ័យខ្លាចផងដែរថា ការជំនុំជម្រះក្តីជាសាធារណៈអាចបណ្តាលឱ្យគេមើលឃើញថា ក្រុមហ៊ុនរបស់ខ្លួនអសមត្ថភាព និងនាំឱ្យប៉ះពាល់ដល់អាជីវកម្ម។

និស្សិតគួរបែងចែកគ្នាជាក្រុមមេធាវីដែលតំណាងឱ្យក្រុមហ៊ុនសៀមរាប និងក្រុមហ៊ុនអាស៊ាន។ ពួកគេត្រូវគណនាដោយខ្លួនឯង នូវតម្លៃបម្រុងរបស់ភាគីនីមួយៗ និងចូលរួមក្នុងការចរចាបែបបែងចែកក្នុងរយៈពេលមួយដ៏ខ្លី ដើម្បីឱ្យដឹងថា តើអាចឈានដល់ការព្រមព្រៀងគ្នាដែរឬទេ។

## *៤. គុណសម្បត្តិ និងគុណវិបត្តិនៃការចរចាបែបបែងចែក*

វិធីសាស្ត្របែបបែងចែកមានលក្ខណៈពេញនិយមនៅទូទាំងពិភពលោក។ នេះដោយសារតែវាមានគុណសម្បត្តិសំខាន់ៗមួយចំនួន។ ទីមួយ ការចរចាបែបបែងចែកមានភាពសាមញ្ញ។ អ្នកណាក៏អាចធ្វើការចរចារបៀបនេះបានដែរ។ ជាទូទៅ គឺមានតួលេខចំនួនពីរតែប៉ុណ្ណោះដែលភាគីទាំងពីរទាមទារពីគ្នាទៅវិញទៅមក។ ទីពីរ ការចរចាបែបបែងចែកត្រូវបានគេយល់ជាសាកល។ មនុស្សដែលមានវប្បធម៌ខុសៗគ្នាក៏អាចចរចាគ្នាអំពីតម្លៃមាន់នៅតាមទីផ្សារបានយ៉ាងងាយ។ ទីបី ការចរចាបែបបែងចែកមានលក្ខណៈច្បាស់លាស់។ ភាគីម្ខាងធ្វើសម្ដើអ្វីម្យ៉ាង ហើយភាគីម្ខាងទៀតផ្ដល់ស្ដីការ ឬសម្ដើតបទៅវិញ។ ប្រសិនបើពួកគេឯកភាព គឺមានការព្រមព្រៀងគ្នា។ ទីបួន ជាធម្មតា ការចរចាបែបបែងចែកមានប្រសិទ្ធភាព។ ជាញឹកញាប់ ការចរចាបែបបែងចែកអាចត្រូវបានធ្វើឡើងក្នុងរយៈពេលតែប៉ុន្មាននាទីប៉ុណ្ណោះ។ ទោះបីជាមានកម្មវត្ថុដែលធំក៏ដោយ ភាគីវិវាទមិនចាំបាច់ចំណាយពេលវេលាដ៏ច្រើនឡើយ ប្រសិនបើពួកគេធ្វើជំនួញតែលើតួលេខនោះ។ ហើយជាចុងក្រោយ ការផ្ដោតលើតួលេខនៃកាចរចាបែបបែងចែក អនុញ្ញាតឱ្យភាគីវិវាទជៀសវាងបាននូវការលះបង់ព័តិមានជាច្រើនអំពីផលប្រយោជន៍របស់ផងខ្លួន។

***ការចរចាបែបបែងចែកហាក់មានប្រសិទ្ធភាពបំផុត នៅពេលដែលបញ្ហាមានលក្ខណៈសាមញ្ញ ប្រាក់ថ្នូរមានតម្លៃទាបសមល្មម ហើយការតម្លៃក៏ត្រូវបានបង្ហាញ និងរំពឹងទុកយ៉ាងត្រឹមត្រូវ។***

យ៉ាងណាមិញ វិធីសាស្ត្រចរចាបែបបែងចែកមានគុណវិបត្តិមួយចំនួនគួរឱ្យកត់សម្គាល់។ ដោយផ្ដោតលើជំហរ និងឆន្ទៈច្បាស់លាស់ វិធីនេះមិនលើកទឹកចិត្តឱ្យស្វែងរកជម្រើសដែលប្រកបដោយការច្នៃប្រឌិត និងដែលបង្កើនតម្លៃជាអតិបរមាឡើយ។ វិធីនេះសន្មត់ថាគ្មានឱកាសដើម្បីឱ្យភាគីវិវាទស្វែងរកផលចំណេញរួមឡើយ។[៣០] វាលើកទឹកចិត្តឱ្យមានលទ្ធផលដែលបានមកពី "ការខាតបង់ពាក់កណ្ដាលម្នាក់" ដោយឥតប្រកែកបាន ដែលការនេះអាចគ្មានមូលដ្ឋានតក្កនុលោម និងអាចមានការលំបាកក្នុងការពន្យល់ ឬផ្ដល់ហេតុផលដល់ភាគីទីបី ឬចៅហ្វាយនាយ។

លើសពីនេះទៅទៀត វិធីនេះអាចនាំអ្នកចូលរួមទៅរកការសម្រេចចិត្តមិនល្អ។ នៅពេលភាគីវិវាទធ្វើការចរចាបែបបែងចែក ពួកគេមានបំណងចងខ្លួនឯងនឹងជំហររបស់ខ្លួន។ ពួកគេការពារ និងផ្ដល់ហេតុផលលើជំហរទាំងនោះ ដែលធ្វើឱ្យមានការលំបាកក្នុងការរើខ្លួនចេញ។ ពួកគេក៏ចាប់ផ្ដើមមានទំនោរក្នុងការ "ទុកមុខ" និងរក្សាជំហរខ្លួនឯង។[៣១]

សំខាន់ជាងនេះទៅទៀត ការចរចាបែបបែងចែកហាក់ជំរុញឱ្យភាគីទវិវាទបង្កើតទំនាក់ទំនងនឹងគ្នាក្នុងនាមជាគូបដិបក្ស។[៣២] វាធ្វើឱ្យភាគីត្រូវតទល់គ្នា "មួយទល់នឹងមួយ"។ ភាគីនីមួយៗនឹងព្យាយាមកេងយកចំណេញលើប្រយោជន៍របស់ភាគីម្ខាងទៀត។ ជួនកាល ដើម្បីតម្រូវចិត្តខ្លួនឯង វានាំទៅរកការមើលមុខគ្នាទៅវិញទៅមកមិនចំ ដោយភាគី

---

[៣០] Patton កំណត់សម្គាល់ *ខាងលើ* លេខ១៨ នៅទំព័រ២៨៨។

[៣១] ROGER FISHER, WILLIALM URY និង BRUCE PATTON, **ឈានទៅរកការយល់ព្រម** (GETTING TO YES) ទំព័រ ៤-៥ (បោះពុម្ពលើកទីពីរ ឆ្នាំ១៩៩១)។

[៣២] *ដូចមុន*

នីមួយៗចាប់ផ្ដើមសម្លឹងមើលគោលបំណងរបស់ភាគីម្ខាងទៀតដោយការសង្ស័យ និងអារម្មណ៍មិនល្អ។[៣៣] ត្រង់ចំណុចនេះ ទំនាក់ទំនងរបស់ភាគីនឹងមានការប៉ះពាល់ជាអវិជ្ជមាន។ ទោះបីជាពួកគេមានការព្រមព្រៀងគ្នាក៏ដោយ ក៏ភាគីអាចមានការព្រួយបារម្ភថាខ្លួនបាន "ចាញ់ប្រៀប"។ ពួកគេអាចមិនពេញចិត្តចំពោះលក្ខណៈដែលការចរចាបានកើតឡើង ហើយអាចជ្រើសយកការបញ្ចប់ទំនាក់ទំនងរវាងគ្នា។

## ច. ទ្វេគ្រោះរបស់អ្នកទោស

ល្បែងដ៏ល្បីមួយឈ្មោះថា*ទ្វេគ្រោះរបស់អ្នកទោស* បង្ហាញពីសារៈសំខាន់នៃកិច្ចសហការ និងការគិតពិចារណាក្នុងន័យឈ្នះ-ឈ្នះជំនួសឱ្យផ្នត់គំនិតឈ្នះ-ចាញ់តាមទម្លាប់ នៅក្នុងការចរចាបែបបែងចែក។ ទ្វេគ្រោះរបស់អ្នកទោសត្រូវបានបង្កើតឡើងដោយ មៀររៀល ហ្វ្លឺឡាត់ដឺ (Merill Flood) និង មែលវីន ដ្រេស្ស៊ើរ (Melvin Dresher) នៅសហរដ្ឋអាមេរិក នាឆ្នាំ១៩៥០ ជាផ្នែកមួយនៃវិស័យវិទ្យាសាស្ត្រដែលទើបលេចឡើងថ្មី ដែលគេស្គាល់ថាជា "ទ្រឹស្ដីបទល្បែង (Game Theory)"។[៣៤] គណិតវិទូឈ្មោះ អាល់ប៊ើត ថាក់ឃើរ (Albert Tucker) គឺជាជនទីមួយ ដែលជ្រើសយកទស្សនាទាននៃការផ្ដន្ទាទោសឱ្យជាប់ពន្ធនាគារ ហើយដាក់ឈ្មោះដ៏ល្បីឱ្យល្បែងនោះថា ទ្វេគ្រោះរបស់អ្នកទោស។[៣៥]

ទ្វេគ្រោះរបស់អ្នកទោស គឺជារឿងរ៉ាវរបស់អ្នកទោសពីរនាក់ដែលត្រូវប៉ូលីសចាប់ខ្លួនបាន។ ពួកគេត្រូវបានជាប់ក្នុងមន្ទីរឃុំឃាំងមុនសវនាការ ហើយបានព្រមព្រៀងថានឹងមិនក្បត់គ្នា និងមិនសារភាពពីបទល្មើសឡើយ។ ប៉ុន្តែក្រោយមក ពួកគេទាំងពីរនាក់ត្រូវបានដាក់ឱ្យនៅដាច់ដោយឡែកពីគ្នា និងមិនអាចទំនាក់ទំនងគ្នាបាន។ ប៉ូលីសមានភ័ស្តុតាងតិចតួចប៉ុណ្ណោះសំរាប់ការផ្ដន្ទាទោស។ ពួកគេក៏ទៅជួបអ្នកទោសនីមួយៗហើយផ្ដល់នូវសម្ដីដូចគ្នា គឺៈ ប្រសិនបើមានអ្នកសារភាព និងធ្វើជាសាក្សីឱ្យអយ្យការប្រឆាំងនឹងម្នាក់ទៀត ហើយម្នាក់ទៀតនៅស្ងៀម អ្នកទោសដែល"ក្បត់"នឹងត្រូវដោះលែងឱ្យមានសេរីភាព បន្ទាប់ពីជាប់ពន្ធនាគារអស់រយៈពេលតែដប់ថ្ងៃប៉ុណ្ណោះ ចំណែកអ្នកសមគំនិតដែលនៅស្ងៀម នឹងត្រូវផ្ដន្ទាទោសឱ្យជាប់ពន្ធនាគារដប់ឆ្នាំពេញ ដោយផ្អែកលើសក្ខីកម្មរបស់អ្នកទោសម្នាក់ទៀត។ ប្រសិនបើអ្នកទោសទាំងពីរនាក់នៅស្ងៀម ហើយមិនព្រមក្បត់គ្នា ពួកគេនឹងត្រូវបានផ្ដន្ទាទោសឱ្យជាប់ពន្ធនាគារតែប្រាំមួយខែប៉ុណ្ណោះ ពីព្រោះប៉ូលីសមានភ័ស្តុតាងមិនគ្រប់គ្រាន់។ ប្រសិនបើអ្នកទោសទាំងពីរនាក់សារភាព និងក្បត់គ្នាទៅវិញទៅមកនោះ អ្នកទោសនីមួយៗនឹងត្រូវផ្ដន្ទាទោសឱ្យជាប់ពន្ធនាគារ៥ឆ្នាំពេញ។ អ្នកទោសនីមួយៗត្រូវជ្រើសរើសរវាងការ សហការគ្នាហើយនៅស្ងៀម ឬក៏ក្បត់គ្នាហើយសារភាព។ យ៉ាងណាមិញ អ្នកទោសនីមួយៗមិនដឹងទេថា អ្នកទោសម្នាក់ទៀតនឹងជ្រើសរើសយ៉ាងណា ហើយពួកគេមិនអាចនិយាយគ្នាអំពីរឿងនេះបានទេ។

ល្បែងទ្វេគ្រោះរបស់អ្នកទោស ដាក់ជាសំណួរថា តើអ្នកទោសនីមួយៗត្រូវធ្វើយ៉ាងណា? ក្រាហ្វិកខាងក្រោមនឹងពន្យល់អំពីជម្រើស និងផលវិបាកផ្សេងៗៈ

---

[៣៣] *ដូចមុន*

[៣៤] WILLIAM POUNDSTONE, *ទ្វេគ្រោះរបស់អ្នកទោស* (Doubleday ed., ឆ្នាំ១៩៩២) ។

[៣៥] *ដូចមុន*

## ជម្រើសសម្រាប់ អ្នកទោស ខ

| ជម្រើសសម្រាប់អ្នកទោស ក | | អ្នកទោស ខ<br>នៅស្ងៀម/សហការ | អ្នកទោស ខ<br>ក្បត់ |
|---|---|---|---|
| | អ្នកទោស ក<br>នៅស្ងៀម/សហការ | អ្នកទោស នីមួយៗ<br>ជាប់ពន្ធនាគារ ៦ ខែ | អ្នកទោស ក<br>ជាប់ពន្ធនាគារ ១០ ឆ្នាំ<br>អ្នកទោស ខ<br>ជាប់ពន្ធនាគារ ១០ ថ្ងៃ |
| | អ្នកទោស ក<br>ក្បត់ | អ្នកទោស ក<br>ជាប់ពន្ធនាគារ ១០ ថ្ងៃ<br>អ្នកទោស ខ<br>ជាប់ពន្ធនាគារ ១០ ឆ្នាំ | អ្នកទោស នីមួយៗ<br>ជាប់ពន្ធនាគារ ៥ ឆ្នាំ |

ទ្វេគ្រោះកើតមាន ពីព្រោះអ្នកទោសទាំងពីរនាក់ទំនងជានឹងយកចិត្តទុកដាក់ខ្លាំងបំផុត ទៅលើការកាត់បន្ថយការជាប់ពន្ធនាគាររបស់ខ្លួន ឱ្យមានរយៈពេលតិចបំផុត។ អ្នកទោសនីមួយៗមានជម្រើសពីរ នៅស្ងៀម ឬក្បត់គ្នា ដើម្បីទទួលទោសស្រាល។ អ្នកទោសនីមួយៗត្រូវធ្វើការជ្រើសរើស ដោយមិនដឹងថាម្នាក់ទៀតនឹងជ្រើសរើសយកអ្វីឡើយ។

### សំណួរសិក្សា

- យោងតាមតារាងខាងលើ ប្រសិនបើអ្នកទោស ក ជ្រើសរើសនៅស្ងៀម និងសហការ តើការសម្រេចចិត្តណាមួយដែលផ្តល់លទ្ធផលល្អបំផុតដល់អ្នកទោស ខ : ក្បត់ ឬនៅស្ងៀម/សហការ?
- យោងតាមតារាងខាងលើ ប្រសិនបើអ្នកទោស ក នឹងក្បត់ តើការសម្រេចចិត្តណាមួយ ដែលផ្តល់លទ្ធផលល្អបំផុតដល់ អ្នកទោស ខ : ក្បត់ ឬនៅស្ងៀម/សហការ?
- ចុះប្រសិនបើអ្នកទោស ខ មិនដឹងថាតើអ្នកទោស ក នឹងធ្វើអ្វីនោះ ? ក្នុងករណីនេះ តើការសម្រេចចិត្តណាមួយដែលផ្តល់លទ្ធផលល្អបំផុតដល់អ្នកទោស ខ?

### លំហាត់ ៖ ល្បែងទ្វេគ្រោះរបស់អ្នកទោស

សិស្សក្នុងថ្នាក់គួរបែងចែកជាក្រុមដែលមានចំនួនពីរនាក់។ ក្រុមនីមួយៗត្រូវលេងល្បែងទ្វេគ្រោះរបស់អ្នកទោសជាពីរជុំ។ នៅក្នុងជុំទាំងពីរ អ្នកលេងនឹងដើរតួជាអ្នកទោសនៅក្នុងល្បែងទ្វេគ្រោះរបស់អ្នកទោស។

នៅក្នុងជុំទីមួយ អ្នកលេងត្រូវក្តាប់ដៃម្ខាងរបស់ខ្លួន ហើយដាក់វាទៅខាងក្រោយខ្នង។ អ្នកលេងនីមួយៗត្រូវលាក់ម្រាមដៃមួយ ឬពីរ នៅខាងក្រោយខ្នងនោះជាសម្ងាត់។ ប្រសិនបើអ្នកលេងលាក់ម្រាមដៃមួយ អ្នកលេងនោះបាន

សម្រេចចិត្តថានៅស្ងៀម ហើយសហការជាមួយអ្នកទោសម្នាក់ទៀត។ ប្រសិនបើអ្នកលេងលាក់ម្រាមដៃពីរ គឺអ្នកលេងនោះបានសម្រេចចិត្តក្បត់អ្នកទោសម្នាក់ទៀត។

នៅពេលរាប់ដល់បី អ្នកលេងទាំងអស់ត្រូវដាក់ដៃរបស់ខ្លួនមកខាងមុខក្នុងពេលដំណាលគ្នា ដើម្បីបង្ហាញដល់អ្នកលេងផ្សេងទៀតថាខ្លួនបានលាក់ម្រាមដៃប៉ុន្មាន។ គោលដៅនៃល្បែងនេះ គឺធ្វើយ៉ាងណាឱ្យបានលទ្ធផលល្អបំផុតសម្រាប់ខ្លួនឯង ពោលគឺឱ្យមានរយៈពេលជាប់ពន្ធនាគារតិចបំផុត។ នៅក្នុងជុំទីមួយ គ្មានអ្នកលេងណាម្នាក់អាចបង្ហើបប្រាប់គ្នាពីជម្រើសរបស់ខ្លួន មុននឹងលាកណ្ដាប់ដៃក្នុងពេលដំណាលគ្នានោះឡើយ ហើយពួកគេមិនអាចពិភាក្សាគ្នាអំពីការសម្រេចចិត្តរបស់ខ្លួនជាមួយអ្នកលេងផ្សេងទៀត ឬធ្វើការព្រមព្រៀងណាមួយឡើយ។ គឺជាប្រការដែលមានសារៈប្រយោជន៍ ដែលគេគួរពិនិត្យមើលតារាងទ្វេគ្រោះរបស់អ្នកទោសឡើងវិញ មុននឹងធ្វើការសម្រេចចិត្ត។

បន្ទាប់ពីអ្នកលេងបង្ហាញពីជម្រើសរបស់ខ្លួនរួចហើយ ពួកគេត្រូវកត់ត្រាជម្រើសនោះ ក្នុងតារាងខាងក្រោម។ គូសរង្វង់លើចំនួនម្រាមដៃ ដែលអ្នកលេងនីមួយៗជ្រើសរើស។ បន្ទាប់មក ពិនិត្យមើលតារាងខាងលើ និងបំពេញលទ្ធផលដើម្បីកំណត់ថាបុគ្គលនីមួយៗទទួលទោសជាប់ពន្ធនាគារប៉ុន្មានឆ្នាំ។

នៅក្នុងជុំទីពីរ អ្នកលេងនឹងលេងល្បែងដូចនៅក្នុងជុំទីមួយដែរ លើកលែងតែមានភាពខុសគ្នាដ៏សំខាន់មួយ។ នៅក្នុងជុំទីពីរ អ្នកលេងអាចនិយាយប្រាប់គ្នាអំពីការសម្រេចចិត្តរបស់ខ្លួនបាន។ ពួកគេមានឱកាស ប្រសិនបើពួកគេចង់ ក្នុងការសហការគ្នា ឬមានការព្រមព្រៀងគ្នា មុននឹងបង្ហាញម្រាមដៃរបស់ខ្លួន។ បន្ទាប់ពីប្រាប់ការសម្រេចចិត្តរបស់ពួកគេរួចហើយ អ្នកលេងកត់ត្រាលទ្ធផលនៅក្នុងតារាង។

| | **អ្នកលេង ក** | **អ្នកលេង ខ** | **លទ្ធផល (ចំនួនឆ្នាំជាប់ ពន្ធនាគារ)** |
|---|---|---|---|
| **ជុំទី ១ (គ្មានការទាក់ទងគ្នា)** | ម្រាមដៃមួយ/នៅស្ងៀម<br>ម្រាមដៃពីរ/ក្បត់ | ម្រាមដៃមួយ/នៅស្ងៀម<br>ម្រាមដៃពីរ/ក្បត់ | អ្នកលេង ក _______<br>អ្នកលេង ខ _______ |
| **ជុំទី ២ (អាចទាក់ទងគ្នាបាន)** | ម្រាមដៃមួយ/នៅស្ងៀម<br>ម្រាមដៃពីរ/ក្បត់ | ម្រាមដៃមួយ/នៅស្ងៀម<br>ម្រាមដៃពីរ/ក្បត់ | អ្នកលេង ក _______<br>អ្នកលេង ខ _______ |

- តើមានភាពខុសគ្នាផ្នែកអាកប្បកិរិយា យ៉ាងណាខ្លះរវាងជុំទាំងពីរ ?
- តើអ្នកមានការព្រមព្រៀងជាមួយអ្នកលេងផ្សេងទៀតនៅក្នុងជុំទីពីរដែរឬទេ? ប្រសិនបើមាន តើមានការព្រមព្រៀងលើ អ្វីខ្លះ?
- ប្រសិនបើអ្នកជាអ្នកទោសក្នុងស្ថានភាពនេះ តើអ្នកចូលចិត្តរូបមន្តណាមួយជាង រូបមន្តនៅក្នុងជុំទី១ ដែលគ្មានការទំនាក់ទំនង ឬរូបមន្តនៅក្នុងជុំទី២ ដែលមានការទំនាក់ទំនង?
- ប្រសិនបើអ្នកបន្ថែមរយៈពេលជាប់ពន្ធនាគារសរុបសម្រាប់អ្នកទោសទាំងពីរក្នុងជុំទី១ ហើយធ្វើការប្រៀបធៀបជាមួយរយៈពេលសរុបនៅក្នុងជុំទី២ តើរូបមន្តណាមួយមានរយៈពេលជាប់ពន្ធនាគារសរុបតិច ជាងគេ?

## ឆ. សេចក្ដីលម្អិតអំពីវិធីសាស្ត្រចរចាផ្អែកលើផលប្រយោជន៍

### ១. *គោលដៅទូទៅនៃវិធីសាស្ត្រចរចាផ្អែកលើផលប្រយោជន៍*

ទ្វេគ្រោះរបស់អ្នកទោស គឺជាគម្រូចរចាដែលអនុញ្ញាតឱ្យមានលទ្ធផលឈ្នះ-ឈ្នះ។ វាបានបង្ហាញឱ្យឃើញថា មានអត្ថប្រយោជន៍ជារួមកាន់តែច្រើន ដែលអ្នកចរចាអាចចែករំលែកគ្នានៅក្នុងក្របខ័ណ្ឌនៃការសហការរួម ជាជាងក្នុងក្របខ័ណ្ឌក្បត់គ្នាទៅវិញទៅមក។ ក្នុងន័យនេះគឺ ប្រសិនបើអ្នកលេងសហការគ្នា ពួកគេអាចសម្រេចបានលទ្ធផលប្រសើរជាងការដែលពួកគេត្រូវបានបំបែកឱ្យនៅដោយឡែកពីគ្នា ហើយត្រូវតែធ្វើការសម្រេចចិត្តដោយឯករាជ្យ។ ប្រសិនបើពួកគេសហការគ្នាពួកគេអាចពង្រីកអត្ថប្រយោជន៍នានា ដែលជួនកាលគេប្រដូចទៅនឹង "នំផាយ" នៅសហរដ្ឋអាមេរិក។

ការចរចាផ្អែកលើផលប្រយោជន៍ មានភាពស្រដៀងគ្នាទៅនឹងទ្វេគ្រោះរបស់អ្នកទោសដែរ។[៣៦] ការចរចាផ្អែកលើផលប្រយោជន៍ ព្យាយាមជម្នះលើគុណវិបត្តិនៃការចរចាបែបបែងចែក ដោយពង្រីកអត្ថប្រយោជន៍សរុបសម្រាប់ភាគីទាំងពីរតាមរយៈការសហការ។ នៅក្នុងវិធីដូចគ្នាដែលអ្នកទោសទាំងពីរនាក់អាចសហការគ្នា និងទទួលបានទោសស្រាល (ផ្ទុយនឹងតក្កវិជ្ជាដែលងាយមើលឃើញ និងដែលមានភាពអំណោយដល់ការក្បត់គ្នានោះ) ភាគីទាំងពីរនៅក្នុងការចរចាផ្អែកលើផលប្រយោជន៍ រិះរកវិធីប្រកបដោយការច្នៃប្រឌិត ដើម្បីស្វែងរកដំណោះស្រាយដ៏ប្រសើរបំផុតសម្រាប់ ភាគីនីមួយៗ។ ការចរចាផ្អែកលើផលប្រយោជន៍អាចជម្នះលើគុណវិបត្តិនៃការចរចាបែបបែងចែក តាមវិធីខាងក្រោម:

- ជំនួសឱ្យការផ្ដោតទៅលើជំហររៀងខ្លួន ការចរចាផ្អែកលើផលប្រយោជន៍ផ្ដោតលើការបំពេញផលប្រយោជន៍ជាអាទិភាពរបស់ភាគីវិវាទ។
- ជំនួសឱ្យការតម្រូវឱ្យមានការសន្យា និងសម្បទានផ្សេងៗ វិធីសាស្ត្រផ្អែកលើផលប្រយោជន៍ពន្យាការសន្យាផ្លូវការទាំងអស់ទៅដល់ចុងបញ្ចប់នៃការចរចា។ ជំនួសឱ្យការទាមទារ និងសម្ដី ភាគីធ្វើការរួមគ្នាដើម្បីបំពេញផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក។ រហូតទាល់តែដល់ទីបញ្ចប់នៃការចរចា ទើបពួកគេស្រុះស្រួលគ្នាលើការសន្យាផ្សេងៗ។
- ជំនួសឱ្យលទ្ធផលដែលបំពាន ការចរចាផ្អែកលើផលប្រយោជន៍ជួយផ្ដល់នូវលទ្ធផលយុត្តិធម៌ មានហេតុផល និងអាចយល់បាន។
- ជំនួសឱ្យការបំផ្លាញទំនាក់ទំនងរវាងភាគី ការចរចាផ្អែកលើផលប្រយោជន៍អនុញ្ញាតឱ្យភាគីរក្សាបាននូវ ទំនាក់ទំនង និងជួនកាលថែមទាំងពង្រឹងទំនាក់ទំនងនោះទៀតផង។[៣៧]

---

[៣៦] ទ្វេគ្រោះរបស់អ្នកទោសមិនមែនជាឧទាហរណ៍ដែលឥតខ្ចោះ សម្រាប់ការចរចាផ្អែកលើផលប្រយោជន៍ឡើយ។ ទ្វេគ្រោះរបស់អ្នកទោសសន្មត់ថាមានជម្រើសតែពីរប៉ុណ្ណោះ គឺសហការ ឬក្បត់។ នៅក្នុងតថភាពជាក់ស្ដែង ជាទូទៅ អ្នកចរចាមានជម្រើសជាច្រើនសន្ធឹកសន្ធាប់ ហើយជម្រើសខ្លះមិនអាចចាត់ចូលក្នុងប្រភេទណាមួយឡើយឱ្យប្រាកដឡើយ។ ប៉ុន្តែ វាពិតជាចាប់យកសារៈសំខាន់ នៃការសហការជាមួយគូបដិបក្ស ទោះជានៅពេលដែលអត្ថប្រយោជន៍ដែលល្អបំផុតរបស់ភាគីនីមួយៗ ហាក់ដូចជាអាចទទួលបានពីការប្រើវិធីសាស្ត្រឈ្នះ-ចាញ់ដោយបដិបក្សក៏ដោយ។ *សូមមើល* Michael L. Moffitt *វិវាទជាឱកាសបង្កើតតម្លៃ* **សៀវភៅណែនាំអំពីដំណោះស្រាយវិវាទ** នៅទំព័រ ១៧៣, ១៨១-១៨៣ (Michael L. Moffitt, Robert C. Bordone ed. ឆ្នាំ២០០៥)។

[៣៧] Patton កំណត់សម្គាល់ *ខាងលើ* លេខ១៨, នៅទំព័រ ២៩២-២៩៣។

អ្នកផ្តើមគំនិតដំបូងនៃវិធីសាស្ត្រចរចាផ្អែកលើផលប្រយោជន៍គឺ រ៉ូជើរ ហ្វីស្ស៊ើរ (Roger Fisher) និង វីលៀម យូរី (William Ury) ប្រចាំនៅគម្រោងចរចាហាវើដ នៃមហាវិទ្យាល័យនីតិសាស្ត្រ សាកលវិទ្យាល័យហាវើដ។ នៅក្នុងសៀវភៅដ៏ល្បីឈ្មោះរបស់ពួកគេដែលមានចំណងជើងថា *ឈានទៅរកការព្រមព្រៀង (Getting to Yes)*[៣៨] ពួកគេបានកំណត់គោលការណ៍ចម្បងចំនួនបួននៃវិធីសាស្ត្រចរចាផ្អែកលើផលប្រយោជន៍៖

- ផ្តាច់កត្តាមនុស្សចេញពីបញ្ហា
- ផ្តោតលើផលប្រយោជន៍ មិនមែនលើជំហរ
- បង្កើតជម្រើសសម្រាប់ផលចំណេញរួម
- សង្កត់ធ្ងន់លើការប្រើប្រាស់លក្ខណៈវិនិច្ឆ័យមិនលម្អៀង

## ២. *ផ្តាច់កត្តាមនុស្សចេញពីបញ្ហា*[៣៩]

ដោយសារតែការចរចាត្រូវបានធ្វើឡើងរវាងមនុស្ស និងមនុស្ស ជួនកាលអ្នកចូលរួមតែងមានការភាន់ច្រឡំថា ការចរចាជាការប្រកួតប្រជែង និងជាចម្បាំងនៃឆន្ទៈ ជាជាងការពិភាក្សាអំពីល័ក្ខខ័ណ្ឌនានានៃកិច្ចព្រមព្រៀង។ ជាមួយគ្នានេះ មនុស្សតែងតែមានមនោសញ្ចេតនា។ ពួកគេអាចយល់ខុសនូវអ្វីដែលបាននិយាយចេញមក។ នៅក្នុងកំឡុងពេលចរចា ភាគីអាចមានការខឹងសម្បា មិនស៊ីសង្វាក់គ្នា អាក់អន់ ឬទើសចិត្តគ្នា ដែលបង្កជាភាពស្មុគស្មាញដល់អ្វីដែលផ្ទុយទៅវិញ អាចជាការចរចាដ៏សាមញ្ញមួយ។ នៅពេលមានបញ្ហាបែបនេះ ភាគីអាចមិនមានលទ្ធភាពឈានដល់ការព្រមព្រៀងគ្នា។ មធ្យោបាយក្នុងការបន្ធូរបន្ថយស្ថានភាពនេះ គឺត្រូវព្យាយាមផ្តាច់កត្តាមនុស្សឱ្យដាច់ចេញពីបញ្ហា។

នៅក្នុងការចរចាភាគីនីមួយៗមានផលប្រយោជន៍ពីរដាច់ដោយឡែកពីគ្នា៖ (១)ខ្លឹមសារនៃការចរចា និង(២) ទំនាក់ទំនងជាមួយភាគីម្ខាងទៀត។ ឧទាហរណ៍មួយអំពីខ្លឹមសារនៃការចរចាអាចថា តើអ្នកណាត្រូវចេញថ្លៃវត្ថុអ្វីមួយ ឬ តើត្រូវសងដល់ភាគីម្ខាងចំនួនប៉ុន្មាន សម្រាប់ការខូចខាតដែលបង្កឡើងដោយភាគីម្ខាងទៀត។ ឧទាហរណ៍អំពីទំនាក់ទំនងរបស់ភាគីគឺ អាចជាដៃគូអាជីវកម្មយូរអង្វែងពីរនាក់ អាចជាប្តី-ប្រពន្ធ ឬក៏អាចជាប្រទេសពីរដែលនៅជិតខាងគ្នាផងដែរ។ នៅក្នុងករណីជាច្រើន ទំនាក់ទំនងអាចមានភាពសំខាន់ច្រើនជាងខ្លឹមសារនៃការចរចា។ ផ្ទុយទៅវិញ ទំនាក់ទំនងអាចត្រូវបានបំផ្លាញនៅពេលមនុស្សធ្វើការចរចាគ្នា។ ពួកគេអាចមានការខឹងសម្បានឹងគ្នា ដោយសារតែការមើលងាយគ្នា ឬកង្វះការគោរពគ្នា ឬដោយសារតែជំហរដ៏តឹងរឹងណាមួយ។

មានចំនុចចំនួនបី ដែលអ្នកចរចាវៃឆ្លាតអាចផ្តោតលើកត្តាមនុស្ស (ពោលគឺមិនមែនជាកត្តាខ្លឹមសារនៃវិវាទ) និងរក្សាទំនាក់ទំនងរវាងគ្នានិងគ្នា។ នោះគឺការយល់ឃើញ មនោសញ្ចេតនា និងការប្រាស្រ័យទាក់ទងគ្នា។[៤០]

---

[៣៨] Fisher *et al.* កំណត់សម្គាល់ *ខាងលើ* លេខ៣១ នៅទំព័រ ៤-៥។

[៣៩] *ដូចមុន* នៅទំព័រ ១៧-៣៩។

[៤០] *ដូចមុន* នៅទំព័រ ១៨។

### ក) ការយល់ឃើញ

នៅក្នុងឆ្នាំ១៧៨៧ មានបុរសម្នាក់នៅសហរដ្ឋអាមេរិក បានរកឃើញឆ្អឹងសត្វ ដាយណូស៊័រ ដ៏សែនធំនៅក្នុងស្ទឹងមួយ។ ការនេះអាចជាលើកដំបូងបង្អស់នៅក្នុងប្រវត្តិសាស្ត្រទំនើបដែលមនុស្សមានរបកគំហើញបែបនេះ។ គាត់ក៏បានបង្ហាញឆ្អឹងនោះដល់លោកបណ្ឌិត ឃែស្ពើ វីស្តារ៍ (Casper Wistar) ដែលជាអ្នកជំនាញការខាងមនុស្សកាយវិភាគវិទ្យា។ បន្ទាប់ពីបានវិភាគរួច គាត់បានកំណត់ថាមិនមានអ្វីសំខាន់ឡើយ។ បណ្ឌិតវីស្តារ៍មិនដឹងថា វាជាអ្វីនោះទេ រីឯឆ្អឹងនោះក៏បានបាត់ទៅដោយថាហេតុ។ ប្រហែលហាសិបឆ្នាំក្រោយមក អ្នកផ្សេងទៀតបានរកឃើញឆ្អឹងសត្វ ដាយណូស៊័រ ដទៃទៀត ហើយក៏បង្កើតបានជាប្រវត្តិសាស្ត្រ ដោយបានស្នើឡើងជាសាធារណៈថា ឆ្អឹងទាំងនោះតំណាងឱ្យភ័ស្តុតាងនៃសត្វលោកដ៏ធំសម្បើម ដែលកើតមាននៅលើផែនដីតាំងពីយូរលង់មុនកំណើតមនុស្សជាតិទៅទៀត។ គាត់ហៅថាសត្វទាំងនោះថា ដាយណូស៊័រ (dinosaurs ឬជីងចក់យក្ស) ហើយការនោះត្រូវបានចាត់ទុកថាជារបកគំហើញដ៏ល្បីល្បាញ។[៤១]

សព្វថ្ងៃនេះយើងអាចនឹងចាត់ទុកបណ្ឌិត វីស្តារ៍ ថាជាមនុស្សល្ងីល្ងើ ដែលមិនដឹងពីអ្វីដែលខ្លួនបានរកឃើញ ក៏ប៉ុន្តែយើងត្រូវតែចងចាំពីទស្សនវិស័យរបស់គាត់។ នៅជំនាន់នោះ គ្មាននរណាធ្លាប់បានដឹងឮអំពីសត្វដាយណូស៊័រពីមុនមកទេ។ ដោយសារមានការយល់ដឹង យើងមើលឃើញឆ្អឹងរបស់វាថាជាភ័ស្តុតាងដ៏ជាក់ស្តែង នៃវត្តមានសត្វយក្សទាំងនោះនៅក្នុងអតីតកាល។ ប៉ុន្តែលោកបណ្ឌិតវីស្តារ៍ មិនអាចមើលឃើញចំណុចនេះទេ ដោយសារតែទស្សនវិស័យរបស់គាត់ និងចំណេះដឹងផ្នែកវិទ្យាសាស្ត្រក្នុងសម័យនោះនៅមានកម្រិត។ នេះគឺជាឧទាហរណ៍មួយអំពីការដែលមនុស្ស រួមផ្សំការយល់ឃើញជាមួយនឹងចំណេះដឹងដែលមាន ដើម្បីកំណត់លើ "តថភាព" នៅដែលពួកគេជួបប្រទះ។ ប្រសិនបើបណ្ឌិត វីស្តារ៍ មានជីវិតរស់នៅហាសិបឆ្នាំក្រោយមកទៀត ហើយបានដឹងពីទ្រឹស្តីផ្សេងៗអំពីការវិវត្តន៍ និងរបកគំហើញផ្សេងទៀតនោះ គាត់អាចនឹងមានលទ្ធភាពក្នុងការ "មើលឃើញ" សត្វដាយណូស៊័រ តាមរយៈឆ្អឹងរបស់វាកាន់តែងាយស្រួលថែមទៀត។

នេះក៏ជាភាពជាក់ស្តែងផងដែរនៅក្នុងការចរចា។ មនុស្សតែងតែមានទំនោរមើលឃើញបញ្ហាខុសពីគ្នា។ សូម្បីតែលំដាប់នៃអង្គហេតុដែលដូចគ្នា ក៏អាចមានបកស្រាយខុសពីគ្នាដាច់ស្រឡះផងដែរ។ ជួនកាល ការបកស្រាយអាចហាក់ដូចជាមិនសមហេតុផល ឬមិនទំនងឡើយ ប៉ុន្តែគេត្រូវតែប្រឈមដោះស្រាយជាមួយបញ្ហានេះ ប្រសិនបើភាគីចង់ឈានទៅរកការព្រមព្រៀងគ្នា។

***ជំនាញដ៏សំខាន់មួយសម្រាប់អ្នកចរចាម្នាក់ៗ គឺព្យាយាមមើលទៅលើបញ្ហាចេញពីទស្សនៈរបស់ភាគីម្ខាងទៀត។***

កថាភាគខាងក្រោមនេះ ពិភាក្សាអំពីបញ្ហាចំនួនបីដែលសំខាន់ ពាក់ព័ន្ធនឹងការយល់ឃើញ សម្រាប់គ្រប់ៗគ្នា។

### ១. មជ្ឈត្តនិយម

ជាទូទៅ មនុស្សមើលឃើញពិភពលោកទៅតាមទស្សនវិស័យផ្ទាល់ខ្លួន និងផ្តោតទៅលើតម្រូវការ ទស្សនៈ និងផលប្រយោជន៍ផ្ទាល់របស់ខ្លួន។ ជាតួយ៉ាង មនុស្សមិនចំណាយពេលវេលាមើលពិភពលោកទៅតាមទស្សនវិស័យ របស់អ្នកដទៃឡើយ។ គេហៅការនេះថា "មជ្ឈត្តនិយម"។

---

[៤១] *សូមមើល* BILL BRYSON, *ប្រវត្តិខ្លីៗអំពីស្ទើរតែគ្រប់អ្វីៗទាំងអស់* នៅទំព័រ ១០៩-១២៩ (Black Swan ed., ឆ្នាំ២០០៤)។

ឧទាហរណ៍មួយអំពីវ័យកុមារភាពៈ

គន្ធីជាក្មេងអាយុ៤ឆ្នាំ ដែលកំពុងនិយាយទៅកាន់ម្ដាយរបស់នាងឈ្មោះ ចរិយា តាមទូរស័ព្ទ។ គន្ធីនៅឯផ្ទះ ចំណែក ចរិយា នៅធ្វើការនៅការិយាល័យ។ ចរិយាសួរទៅគន្ធីថា "តើប៉ាកូននៅឯណា?" ជំនួសឱ្យការនិយាយប្រាប់ទៅ ចរិយា គន្ធីយកដៃចង្អុលទៅឪពុករបស់នាងដែលអង្គុយនៅជិតនោះ។ គន្ធីមិនយល់ទេថា ម្ដាយរបស់នាងមិនអាចមើលឃើញការចង្អុលរបស់នាង។ នាងមិនទាន់អាចអភិវឌ្ឍសមត្ថភាព ក្នុងការមើលពិភពលោកចេញពីទស្សនវិស័យរបស់អ្នកដទៃទៀតឡើយ។

មនុស្សធំមានសមត្ថភាពក្នុងការយល់អំពីទស្សនវិស័យរបស់អ្នកដទៃទៀត ប៉ុន្តែពួកគេច្រើនតែភ្លេចប្រើប្រាស់ជំនាញនេះ។ មនុស្សចង់មានទស្សនៈជាវិជ្ជមានអំពីខ្លួនឯង ហេតុនេះ ពួកគេច្រើនតែបកស្រាយហេតុការណ៍ ទៅតាមគំនិតដែលមានអំណោយផលល្អបំផុតចំពោះខ្លួនឯង។ ឧទាហរណ៍ពីមនុស្សពេញវ័យ គឺអាចជាប្ដីប្រពន្ធមួយគូ ដែលត្រូវចចាបែងចែកទ្រព្យសម្បត្តិក្នុងការលែងលះគ្នា។ រិទ្ធីជឿថាខ្លួនត្រូវមានសិទ្ធិទទួលបានទ្រព្យសម្បត្តិ៧០% ប៉ុន្តែវណ្ណាយល់ថានាងត្រូវមានសិទ្ធិទទួលបានទ្រព្យសម្បត្តិ៦០%។ ក៏ប៉ុន្តែ ពួកគេមិនអាចគិតត្រូវទាំងពីរនាក់បានទេ ដោយសារការទាមទារសរុបរបស់ពួកគេគឺ១៣០%។ ឧទាហរណ៍ម្យ៉ាងទៀតគឺជាស្ថានភាពដែលដៃគូការងារពីរនាក់ទាមទារថា គេម្នាក់ៗបំពេញការងារបាន៨០%ក្នុងគម្រោងមួយ។

**សំណួរសិក្សា**

មនុស្សភាគច្រើនមានមជ្ឈត្តនិយមក្នុងកម្រិតណាមួយៈ

- ចូរអ្នកសួរដៃគូអាជីវកម្មម្នាក់ ក្នុងចំណោមពីរនាក់ អំពីភាគរយនៃការងាររួមដែលនាងបំពេញជារៀងរាល់សប្ដាហ៍។ បន្ទាប់មកសួរដៃគូម្ខាងទៀត។ បូកភាគរយទាំងពីរនោះបញ្ចូលគ្នា។ តើសរុបបាន ១០០% ឬក៏លើសពីនេះ?
- តើលោកអ្នកអាចគិតឃើញឧទាហរណ៍ផ្ទាល់ខ្លួននៃមជ្ឈត្តនិយមរបស់មិត្តភក្ដិ ឬសហការីរបស់ខ្លួនដែរឬទេ ?

## ២. ការជឿជាក់ជ្រុល

ការកាត់យល់ដែលបំរើឱ្យខ្លួនឯង និងមានលក្ខណៈមជ្ឈត្តនិយម ក៏អាចបណ្ដាលឱ្យមានការជឿជាក់ជ្រុលផងដែរ។ នៅក្នុងការសិក្សាមួយ និស្សិតពាណិជ្ជសាស្ត្រ ដែលបរាជ័យក្នុងការឈានទៅដល់ការព្រមព្រៀងនៅក្នុងវិវាទប្រឌិតមួយរវាងមនុស្សពីរនាក់លើការគ្រប់គ្រងនិយោជិក ត្រូវបានស្នើឱ្យដាក់សម្ពើចុងក្រោយរបស់ខ្លួនទៅកាន់មជ្ឈត្តករដែលនឹងជ្រើសយកសម្ពើមួយក្នុងចំណោមសម្ពើទាំងពីរ។ បន្ទាប់មក និស្សិតត្រូវបានសួរឱ្យសន្និដ្ឋានអំពីឱកាសដែលមជ្ឈត្តករអាចជ្រើសរើសសម្ពើ *របស់ខ្លួន* ជាជាងសម្ពើរបស់គូបដិបក្ស។ និស្សិតកំរិតមធ្យមយល់ឃើញថាសម្ពើរបស់នាងមាន

ឱកាស៦៨%ដែលនឹងត្រូវបានជ្រើសយក ទោះបីជាអ្នកទាំងអស់គ្នាដឹងថាគ្រប់សម្ទើមានឱកាសតែ៥០%ប៉ុណ្ណោះ ក្នុងការទទួលបានការជ្រើសយកក៏ដោយ។[៤២] ការនេះបង្ហាញឱ្យឃើញថា និស្សិតទាំងនោះមានការជឿជាក់ជ្រុលពេក។

***នៅពេលភាគីម្ខាង មានការជឿជាក់ជ្រុលពេកអំពីជំហររបស់ខ្លួន គេនឹងបរាជ័យក្នុងការស្រុះស្រួលសមស្រប ហើយអាចបំផ្លាញផលលទ្ធភាពក្នុងការឈានដល់ការព្រមព្រៀងធំមទៀត។***

## ៣. ភាពលម្អៀងដោយការបញ្ជាក់បន្ថែម

បញ្ហាពាក់ព័ន្ធមួយទៀត គឺជាភាពលម្អៀងដោយការបញ្ជាក់បន្ថែម ដែលមនុស្សម្នាក់បកស្រាយព័ត៌មានក្នុងន័យមួយដែលបញ្ជាក់បន្ថែមទៅលើជំនឿ ឬជំហរដែលខ្លួនមានពីមុនមក។ ចំណុចនេះបណ្តាលឱ្យភាគីច្រានចោល ឬបន្ទាបព័ត៌មានណាដែលផ្ទុយនឹងទស្សនៈរបស់ពួកគេ និងសង្កត់ធ្ងន់ហួសហេតុនូវព័ត៌មានដែលត្រូវនឹងអំពីទស្សនៈរបស់ពួកគេ។[៤៣]

តារាងខាងក្រោមផ្តល់ឧទាហរណ៍អំពីការយល់ឃើញខុសៗគ្នារវាងម្ចាស់ផ្ទះ និងអ្នកជួលផ្ទះ[៤៤]

| **ការយល់ឃើញរបស់អ្នកជួលផ្ទះ** | | **ការយល់ឃើញរបស់ម្ចាស់ផ្ទះ** |
|---|---|---|
| ឈ្នួលផ្ទះគឺជាប្រាក់ដ៏ច្រើនពេកហើយ។ | | ឈ្នួលផ្ទះមិនទាន់បានដំឡើងពីរឆ្នាំមកហើយ។ |
| ដោយសារម្ហូបអាហារ និងទំនិញឡើងថ្លៃ ខ្ញុំគ្មានលទ្ធភាពបង់ថ្លៃឈ្នួលផ្ទះ លើសពីនេះទៀតទេ។ | | ដោយសារម្ហូបអាហារ និងទំនិញឡើងថ្លៃ ខ្ញុំត្រូវការប្រាក់ចំណូលពីផ្ទះនេះបន្ថែមទៀត។ |
| ផ្ទះនេះត្រូវការលាបថ្នាំ និងកែលម្អបន្ថែមទៀត។ | | អ្នកជួលផ្ទះធ្វើឱ្យផ្ទះខូចខាតច្រើនមែនទែន។ |
| ខ្ញុំស្គាល់អ្នកដែលបង់ថ្លៃឈ្នួលតិចជាងនេះ សំរាប់ផ្ទះដែលប្រហាក់ប្រហែលនេះ។ | | ខ្ញុំស្គាល់ម្ចាស់ផ្ទះដែលយកថ្លៃឈ្នួលច្រើនជាងនេះ សំរាប់ផ្ទះដែលប្រហាក់ប្រហែលនេះ។ |
| យុវវ័យដូចជាខ្ញុំគ្មានលទ្ធភាពបង់ថ្លៃឈ្នួលដ៏ខ្ពស់បែបនេះបានទេ ។ | | យុវវ័យដូចជាគេនេះ ច្រើនតែបង្កបញ្ហា ហើយអាចបំផ្លាញដល់ផ្ទះសម្បែងថែមទៀត។ |
| ថ្លៃឈ្នួលគួរតែថោកជាងនេះ ពីព្រោះនៅម្តុំនេះគ្មានសុវត្ថិភាពសោះ។ | | យើងជាម្ចាស់ផ្ទះត្រូវតែដំឡើងថ្លៃឈ្នួល ដើម្បីកែលម្អគុណភាពអ្នកជួលផ្ទះនៅតំបន់នេះ។ |
| ពេលដែលម្ចាស់ផ្ទះទារលុយ ខ្ញុំតែងតែបង់ប្រាក់ឱ្យគាត់ភ្លាមៗ។ | | គេមិនដែលបង់ប្រាក់ឱ្យខ្ញុំទេ ចាំទាល់តែខ្ញុំទារទើបបង់។ |
| ម្ចាស់ផ្ទះចិត្តមិនសូវបានសោះ មិនដែលសួរសុខទុក្ខខ្ញុំ ឬក៏បង្ហាញការយកចិត្តទុកដាក់ចំពោះខ្ញុំអ្វីបន្តិចសោះ។ | | ខ្ញុំជាមនុស្សចេះគិតវែងឆ្ងាយ ដែលតែងតែគោរពចំពោះភាពឯកជនរបស់អ្នកជួលផ្ទះ។ |

---

[៤២] Max H. Bazerman, Katie Shonk *ទស្សនវិស័យអំពីការសម្រេចចិត្តនៅក្នុងការចរចា* សៀវភៅណែនាំអំពីជំលោះស្រាយវិវាទ នៅទំព័រ៥២, ៥៥-៥៦ (Michael L. Moffitt, Robert C. Bordone ed., ឆ្នាំ២០០៥) ។

[៤៣] *សូមមើល ជាឧទាហរណ៍* Keith G. Allred *ចរន្តទំនាក់ទំនងនៅក្នុងវិវាទ* **សៀវភៅណែនាំអំពីជំលោះស្រាយវិវាទ** នៅទំព័រ៨៣ និង៨៤ (Michael L. Moffitt, Robert C. Bordone ឆ្នាំ២០០៥)។

[៤៤] Fisher et. al., កំណត់សម្គាល់ *ខាងលើ* លេខ៣១ នៅទំព័រ២៤។

## ៤. ជៀសវាងបញ្ហាពាក់ព័ន្ធនឹងទស្សនៈយល់ឃើញ

មានវិធីប្រាំយ៉ាងក្នុងការជៀសវាងបញ្ហាពាក់ព័ន្ធនឹងទស្សនៈយល់ឃើញទាំងនេះ នៅពេលចរចាៈ

- ត្រូវមានភាពមិនលម្អៀង
- ពិចារណាទស្សនវិស័យរបស់ភាគីម្ខាងទៀត
- ពិភាក្សាអំពីទស្សនវិស័យ
- ផ្សាភ្ជាប់ជាមួយភាគីម្ខាងទៀតជាមួយការរកហេតុផលរបស់អ្នក
- រក្សាមុខមាត់ឱ្យភាគីម្ខាងទៀត[៤៥]

វិធីមួយក្នុងការជៀសវាងមជ្ឈត្តនិយម និងការជឿជាក់ជ្រុល គឺព្យាយាមសំឡឹងមើលវិវាទក្នុងលក្ខណៈមិនលម្អៀងបំផុតតាមដែលអាចធ្វើបាន ពោលគឺត្រូវសំឡឹងមើលវិវាទហាក់បីដូចជាអ្នកមិនមានផលប្រយោជន៍នៅក្នុងនោះប្រហែលនឹងការដែលអ្នកជាចៅក្រមដូច្នោះដែរ។[៤៦] ដំណោះស្រាយដ៏សាមញ្ញមួយទៀត គឺត្រូវគិតឱ្យបានជិតដល់បំផុតអំពីទស្សនវិស័យរបស់ភាគីម្ខាងទៀត ដោយវានឹងជួយអ្នកឱ្យមើលឃើញទស្សនវិស័យរបស់ខ្លួនកាន់តែច្បាស់ថែម ទៀត។ ឧទាហរណ៍ ក្នុងការសិក្សាលើសហអ្នកនិពន្ធផ្នែកសិក្សាស្រាវជ្រាវ អ្នកនិពន្ធពីរក្រុមត្រូវបានសួរដោយឡែកពីគ្នាអំពីកម្រិតភាគរយនៃកិត្តិគុណ ដែលពួកគេម្នាក់ៗស័ក្តិសមនឹងទទួលបានចំពោះការងាររបស់ពួកគេ។ ក្រុមអ្នកនិពន្ធដែលត្រូវបានសួរឱ្យគិតអំពីវិភាគទានរបស់សហអ្នកនិពន្ធរបស់ខ្លួន ច្រើនតែកម្រិតកិត្តិគុណរបស់ខ្លួនទាបជាងអ្នកនិពន្ធទាំងឡាយណា ដែលត្រូវបានសួរឱ្យគ្រាន់តែកម្រិតវិភាគទានរបស់ខ្លួនឯងផ្ទាល់ ដោយមិនចាំបាច់គិតអំពីសហអ្នកនិពន្ធម្នាក់ទៀត។[៤៧] ដូច្នេះ ដោយគ្រាន់តែគិតអំពីការងាររបស់អ្នកដទៃ ធ្វើឱ្យអ្នកនិពន្ធទាំងនោះបន្ទាបកម្រិតអគតិជាមជ្ឈត្តិកៈរបស់ខ្លួនបាន។

ក្រៅពីការធ្វើវិភេទទៅលើអាកប្បកិរិយា និងការគិតរបស់អ្នកផ្ទាល់មក ជាការសំខាន់អ្នកគួរព្យាយាមជះឥទ្ធិពលលើអាកប្បកិរិយា និងការគិតរបស់ដៃគូចរចារបស់អ្នកផង។ ទីមួយ ជាដំបូងគេត្រូវយល់អំពីអារម្មណ៍របស់ភាគីម្ខាងទៀត និងរបៀបដែលគេជឿលើអ្វីដែលគេនិយាយ ទោះបីជាជាក់ស្តែងវាហាក់ដូចជាខុសយ៉ាងណាក៏ដោយ។ វិធីមួយដើម្បីយល់ឱ្យបានពីបញ្ហានេះ គឺត្រូវពិភាក្សាឱ្យបានជាក់លាក់អំពីការយល់ឃើញផ្សេងៗ។ ទោះជាវាហាក់ដូចជាមិនសំខាន់ និងមិនពាក់ព័ន្ធនឹង "ខ្លឹមសារពិតប្រាកដ" នៃវិវាទក៏ដោយ ការពិភាក្សាលម្អិតអំពីទស្សនៈយល់ឃើញអាចធ្វើឱ្យភាគីមានអារម្មណ៍ងាយស្រួលក្នុងចិត្ត និងទុកចិត្តគ្នា។ ឧទាហរណ៍ ភាគីម្ខាងអាចនិយាយថា "តើខ្ញុំនិយាយត្រូវឬទេដែលថា អ្នកចាត់ទុកវិវាទនេះជាការគំរាមកំហែងចំពោះសិទ្ធិអំណាចរបស់អ្នក?"។

---

[៤៥] *ដូចមុន* នៅទំព័រ ២៣-២៩។

[៤៦] ទស្សនវិទូដ៏ល្បីល្បាញឈ្មោះ ចន រ៉ោលស៍ (John Rawls) បានផ្តល់អនុសាសន៍ឱ្យព្យាយាមធ្វើការសម្រេចចិត្តក្រោម "ការធ្វើពុតជាមិនចេះ"។ John Rawls **ទ្រឹស្តីមួយនៃយុត្តិធម៌** (គ្រឹះស្ថានបោះពុម្ពផ្សាយ សាកលវិទ្យាល័យ ហាវើដ ឆ្នាំ១៩៧១)។

[៤៧] Bazerman *et. al.* កំណត់សម្គាល់ *ខាងលើ* លេខ៣១ នៅទំព័រ ៥៦។

វិធីមួយទៀតក្នុងការស្វែងយល់ និងមានលទ្ធភាពជះឥទ្ធិពលទៅលើការយល់ឃើញនានា គឺត្រូវធ្វើឱ្យប្រាកដថា អ្នកបានផ្សារភ្ជាប់ភាគីម្ខាងទៀតក្នុងដំណើរការរកហេតុផលរបស់លោកអ្នក។[៤៨] កុំគ្រាន់តែបញ្ជាក់សេចក្ដីសន្និដ្ឋានណាមួយ ប៉ុន្តែត្រូវធ្វើការជាមួយភាគីម្ខាងទៀតដើម្បីជួយឱ្យលោកអ្នកឈានទៅរកវា។ សេចក្ដីសន្និដ្ឋានដែលត្រូវបានឈានដល់រួមគ្នា ទំនងជាអាចទទួលយកបានដោយភាគីម្ខាងទៀត។

ក្នុងការស្វែងយល់អំពីទស្សនៈយល់ឃើញរបស់ភាគីម្ខាងទៀត ចូរកុំសន្និដ្ឋានថាភាគីម្ខាងទៀតមានចេតនាមិនល្អឱ្យសោះ។ សូមកុំបន្ទោសភាគីម្ខាងទៀតចំពោះបញ្ហា ឬការលំបាករបស់អ្នក។ ការបន្ទោសភាគីម្ខាងទៀតអាចនឹងជាបង្ខំឱ្យមានការឆ្លើយតបការពារខ្លួន។

***គួរព្យាយាមជៀសវាងការបន្ទោសនៅក្នុងកំឡុងពេលចរចា។***

ជាចុងក្រោយ សូមកុំភ្លេចអំពីសារៈសំខាន់នៃការទុកមុខឱ្យគ្នា។[៤៩] ចូរព្យាយាមផ្ដល់សម្ដើទាំងឡាយណាដែលហាក់មានភាពសមស្របជាមួយនឹងគោលការណ៍ ឬតម្រូវការរបស់ភាគីម្ខាងទៀត។ ការនេះអាចមានន័យយ៉ាងសាមញ្ញថា គេត្រូវរៀបគម្រោងសម្ដើនោះយ៉ាងប្រុងប្រយ័ត្ន។

## លំហាត់ ៖ បញ្ហាពាក់ព័ន្ធនឹងទស្សនៈយល់ឃើញ

តើអ្នកគួរជៀសវាងបញ្ហានៃទស្សនៈយល់ឃើញដោយរបៀបណាក្នុងករណីនេះ?

សុវណ្ណចង់ឱ្យអ្នកធ្វើជាតំណាងរបស់គាត់។ គាត់ទើបតែបណ្ដេញបុគ្គលិកចាមម្នាក់ចេញពីរោងចក្រ ដោយសារតែបុគ្គលិកនោះបញ្ឈប់ខ្សែសង្វាក់ផលិតកម្ម ហើយអធិដ្ឋានបីដងក្នុងមួយថ្ងៃ។ ទង្វើនេះបានធ្វើឱ្យកម្រិតផលិតកម្មធ្លាក់ទាប ហើយនៅពេលសុវណ្ណស្នើឱ្យបុគ្គលិកនោះឈប់អធិដ្ឋានទៀត បុគ្គលិកនោះបានបដិសេធ។

បុគ្គលិកនោះខឹងយ៉ាងខ្លាំង ហើយគំរាមថានឹងដាក់បណ្ដឹងតុលាការប្ដឹងសុវណ្ណ។ គាត់យល់ឃើញថាសុវណ្ណរើសអើងនឹងគាត់ ដោយសារតែសាសនាអ៊ីស្លាមរបស់គាត់។ គាត់ក៏ពិចារណាផងដែរក្នុងការស្នើឱ្យជនជាតិចាមដែលធ្វើការនៅក្នុងរោងចក្រទាំងអស់ នាំគ្នាធ្វើកូដកម្ម។

តើអ្នកមានសម្ដើអ្វីខ្លះដល់សុវណ្ណ ដើម្បីចរចានៅពេលឆាប់ៗនេះ ជាមួយបុគ្គលិកចាមដែលគាត់បានបណ្ដេញចេញនោះ?

---

[៤៨] Fisher et. al., កំណត់សម្គាល់ *ខាងលើ* លេខ៣១ នៅទំព័រ២៧-២៨។

[៤៩] នៅសហរដ្ឋអាមេរិក ជួនកាលការសង្គ្រោះមុខមាត់ត្រូវបានគេប្រមាថថាជាកង្វល់ឥតន័យ។ ប៉ុន្តែ ប្រសិនបើវាមានសារៈសំខាន់ចំពោះបុគ្គលនោះ កង្វល់នោះត្រូវតែដោះស្រាយ។ វប្បធម៌កម្ពុជាចាត់ទុកការសង្គ្រោះមុខមាត់ជាបញ្ហាសំខាន់ជាង ហើយវាអាចជាផ្នែកដ៏សំខាន់បំផុតនៃកិច្ចព្រមព្រៀងស្រុះស្រួល។

### ខ) អារម្មណ៍

**សំណួរផ្ដើមការសិក្សា**

ណានីកំពុងធ្វើការនៅក្នុងការិយាល័យជាមួយប៊ុនសាង។ ថ្ងៃមួយ ប៊ុនសាងចូលទៅក្នុងការិយាល័យរបស់ណានី ហើយហាក់ដូចជាមានការភ័យព្រួយខ្លាំង។

"មានរឿងអ្វីហ្នឹង ?" ណានីសួរ។

"ខ្ញុំមានការចរចាដ៏សំខាន់មួយជាមួយអតិថិជនរបស់យើងនៅថ្ងៃស្អែកនេះ។ ខ្ញុំបានត្រៀមអស់មួយសប្ដាហ៍ហើយ ប៉ុន្តែខ្ញុំនៅតែភ័យព្រួយ។ ខ្ញុំដឹងថា អតិថិជនរបស់យើងអាចមានអារម្មណ៍រំជួលអំពីការចរចានេះ ហើយខ្ញុំក៏អាចមានអារម្មណ៍ដូចគ្នានេះដែរ"។

តើណានីត្រូវផ្ដល់ការណែនាំអ្វីខ្លះដល់ប៊ុនសាង ?[៥០]

ក. ប្រើប្រាស់អារម្មណ៍របស់អ្នកដើម្បីសម្ដែងពីសិទ្ធិអំណាច និងភាពប្រាកដប្រជារបស់ខ្លួន។

ខ. បំភ្លេចចោលអំពីកង្វល់នេះ ហើយផ្ដោតទៅលើបញ្ហាទាំងឡាយណាដែលជាក់លាក់។

គ. លាក់បាំងអារម្មណ៍ទាំងអស់ ហើយរក្សាការគ្រប់គ្រងស្ថានការណ៍ឱ្យបានពេញលេញ។

#### ១. អារម្មណ៍អវិជ្ជមាន

ដូចសំណួរសិក្សាខាងលើបានបង្ហាញ អារម្មណ៍អាចក្លាយជាបញ្ហានៅក្នុងកំឡុងពេលចរចាដ៏ស្វិតស្វាញណាមួយ។ នៅក្នុងស្ថានភាពដែលអារម្មណ៍ច្របូកច្របល់ ការចងចាំកាន់តែមានសភាពសាមញ្ញច្រើនជាងមុន និងលែងច្បាស់ ទោះបីវាអាចមានសភាពរស់រវើកជាពិសេសក៏ដោយ។[៥១] ហើយនៅពេលដែលអារម្មណ៍ទាំងនេះមានភាពអវិជ្ជមាន វាអាចកាត់បន្ថយយ៉ាងខ្លាំងនូវឱកាសនៃការសុះស្រួលគ្នា។[៥២] ការខឹងសម្បា និងអារម្មណ៍អវិជ្ជមានដែលជ្រាលជ្រៅផ្សេងទៀត អាច

[៥០] *សូមមើល* Daniel L. Shapiro *សត្រូវ សម្ព័ន្ធមិត្ត និងមនោសញ្ចេតនា* **សៀវភៅណែនាំអំពីការដោះស្រាយវិវាទ** នៅទំព័រ ៦៦, ៦៨ (Michael L. Moffitt, Robert C. Bordone ed., 2005)។

[៥១] *ដូចមុន* នៅទំព័រ១៥៤។ ការនេះជួយពន្យល់អំពីរបៀបដែលភាគីវិវាទអាចមានការនឹកឃើញឡើងវិញខុសគ្នាយ៉ាងខ្លាំងទៅលើហេតុការណ៍តែមួយដូចគ្នា។

[៥២] ទោះបីទស្សនៈនេះមានលក្ខណៈស្ទើរតែទូទៅក្ដី អាចមានការលើកលែងចំពោះការចរចាបែបបែងចែកមួយចំនួន។ មានអ្នកជំនាញខ្លះប្រកាន់ថានៅក្នុងការចរចាបែបបែងចែកម្ដងម្កាល ដូចជានៅតាមទីផ្សារ ដែលភាគីមិនខ្វាយខ្វល់អំពីទំនាក់ទំនងនាពេលអនាគត មនោសញ្ចេតនាអវិជ្ជមានអាចផ្ដល់នូវលទ្ធផលកាន់តែប្រសើរឡើង។ ការបង្ហាញនូវការខឹងសម្បាចំពោះតម្លៃខ្ពស់ហួសប្រមាណ នៃផលិតផលមួយនៅតាមទីផ្សារអាចបង្ហាញយ៉ាងមានប្រសិទ្ធភាពនូវទម្ងន់នៃអារម្មណ៍អំពីតម្លៃនោះ។ វាអាចនាំឱ្យមាន លទ្ធផលប្រសើរជាងប្រតិកម្មដែលខុសពីអារម្មណ៍ ឬដែលជាមនោសញ្ចេតនាវិជ្ជមាន ។ *ដូចមុន* នៅទំព័រ ៧៣-៧៤។

បណ្តាលឱ្យមានការវិនិច្ឆ័យមិនល្អ និងកាត់បន្ថយនូវការគិតគូរចំពោះ អ្នកដទៃទៀត។[៥៣] អារម្មណ៍ក៏អាចមានភាពរាល-ដាលផងដែរ។ ដូច្នេះអារម្មណ៍អវិជ្ជមានដែលជ្រាលជ្រៅរបស់ភាគីម្ខាង ក៏អាចបណ្តាលឱ្យភាគីម្ខាងទៀតមានអារម្មណ៍អវិជ្ជមានខ្លាំងក្លាដូចគ្នាដែរ។[៥៤] មនុស្សគ្រប់រូបសុទ្ធតែធ្លាប់ឃើញឥទ្ធិពលនៃរឿងរ៉ាវដូចខាងក្រោមនេះ:

កញ្ញាមិនសប្បាយចិត្ត ដោយសារនាងមិនបានទទួលការដំឡើងប្រាក់បៀវត្សរ៍នៅភោជ-នីយដ្ឋានដែលនាងធ្វើការ។ នាងទៅស្ទាត់មុខចៅហ្វាយរបស់នាងឈ្មោះគន្ធី ហើយក៏រំលេចអារម្មណ៍រំជួលឡើង។

"ខ្ញុំខិតខំប្រឹងប្រែងធ្វើការយ៉ាងខ្លាំងនៅទីនេះអស់រយៈពេលជាង១៥ខែមកហើយ ហើយខ្ញុំធ្វើកិច្ចការបន្ថែមតាមដែលអ្នកស្នើសុំ។ ហេតុអ្វីអ្នកអាចដំឡើងប្រាក់បៀវត្សរ៍ដល់គឹមសៀន ដែលទើបតែធ្វើការបាន៣ខែប៉ុណ្ណោះ? វាច្បាស់ហើយថាអ្នកមិនចូលចិត្តខ្ញុំ ប៉ុន្តែប្រាក់ខែដែលត្រូវដំឡើងគឺជាកម្លាំងញើសឈាមរបស់ខ្ញុំ!"

គន្ធី ដែលទើបតែមានអារម្មណ៍រំជួលនៅពេលនេះ និយាយថា "ហេតុអ្វីបានជាឯងហ៊ានចោទខ្ញុំថាចូលចិត្តបុគ្គលិកនេះ ជាងបុគ្គលិកនោះយ៉ាងនេះ? ខ្ញុំប្រព្រឹត្តស្មើៗគ្នាចំពោះបុគ្គលិកទាំងអស់។ មកពីឯងមិនល្អដូចគឹមសៀន។ ឯងមិនដែលនៅដល់យប់។ ឯងមិនដែលជួយសម្អាតគេទេ..."។

ការអះអាងនីមួយៗធ្វើឱ្យភាគីម្ខាងទៀតកាន់តែខឹងសម្បានឹងគ្នាទៅវិញទៅមកថែមទៀត។ ការតវ៉ាគ្នារបៀបនេះអាចនឹងបន្ត ក្នុងរយៈពេលដ៏យូរមួយ។

**ទីងខុស ទីងខូច ទីងខាត។**

អាស្រ័យហេតុនេះ ប្រការសំខាន់គឺត្រូវព្យាយាមជៀសវាងនូវអាកប្បកិរិយាណាដែលអាចបង្កើត ឬបង្កើនការអារម្មណ៍រំជួលជាអវិជ្ជមាននៅក្នុងកំឡុងពេលចរចា។ ក្នុងសៀវភៅដ៏មានប្រជាប្រិយភាពរបស់លោក ប្លីង ម៉ាល់ខុន ហ្គ្លែដវែល (Blink Malcom Gladwell) មានរៀបរាប់អំពីបណ្ឌិត ចន ហ្គត់មែន (John Gottman) ដែលមានលទ្ធភាពវិភាគលើវីដេអូខ្លីៗ របស់ប្តីប្រពន្ធដែលក្នុងនោះពួកគេជជែកគ្នាអំពីបញ្ហាលំបាកផ្សេងៗ។[៥៥] ដោយផ្អែកលើវីដេអូខ្លីៗទាំងនោះ លោក ហ្គត់មែន អាចកំណត់បានថាពួកគេនឹងលែងលះគ្នា ដោយមានភាពត្រឹមត្រូវដ៏គួរឱ្យភ្ញាក់ផ្អើលរហូតដល់៩៥%។[៥៦]

---

[៥៣] Keith G. Allred, John S. Mallozzi, Fusako Matsui និង Chistopher P. Raia *ឥទ្ធិពលនៃកំហឹង និងមេត្តាធម៌នៅក្នុងការសម្លែងការចរចា* **អាកប្បកិរិយារៀបចំ និងដំណើរការនៃការសម្រេចចិត្តរបស់មនុស្ស** ទំព័រ ៧០, ១៧៥-១៨៧ (ឆ្នាំ១៩៩៧)។

[៥៤] Shapiro កំណត់សម្គាល់ *ខាងលើ* លេខ៥០ នៅទំព័រ៧៦។

[៥៥] MALCOM GLADWELL, **ការព្រិចភ្នែក** ទំព័រ១៨ (Little, Brown ed., ឆ្នាំ២០០៥)។

[៥៦] *ដូចមុន* នៅទំព័រ ២១។

គាត់ធ្វើដូច្នេះបាន ដោយពិនិត្យរកមើលអាកប្បកិរិយាជាអវិជ្ជមានចំនួនបួន ដែលអាចបណ្តាលឱ្យកើតមានអារម្មណ៍អវិជ្ជមាន និងលទ្ធផលចុងក្រោយ ដែលជាការលែងលះគ្នានោះ។ អាកប្បកិរិយាអវិជ្ជមានសំខាន់ទាំងបួននោះ រួមមានៈ

១) ការរិះគន់លើអត្តចរិតរបស់អ្នកដទៃ (ឧ. "អ្នកឯងមិនសម្អាតផ្ទះបាយ អ្នកឯងអាត្មានិយមណាស់")
២) ការបង្ហាញអំពីការមើលងាយ (ឧ. ការធ្វើភ្នែកក្រឡឹតក្រឡាប់ នៅពេលអ្នកដទៃនិយាយ)
៣) ការដោះសារយករួចខ្លួន ("ខ្ញុំប្រហែលជាមកយឺតព្រឹកនេះ ប៉ុន្តែអ្នកឯងយឺតតែរហូតនៅពេលព្រឹក")
៤) ការឃាឃាំង (បដិសេធមិនពិភាក្សាបញ្ហាផ្សេងៗ នៅពេលដែលអ្នកដទៃចង់ពិភាក្សា)[៥៧]

ប្រការទាំងនេះបានបង្ហាញយ៉ាងច្បាស់ថា គេគួរតែព្យាយាមជៀសវាងនូវអាកប្បកិរិយាអវិជ្ជមានទាំងបួននេះនៅក្នុងការចរចា។ ប៉ុន្តែ តើគេត្រូវធ្វើយ៉ាងដូចម្តេច ប្រសិនបើភាគីម្ខាងទៀតបញ្ចេញអាកប្បកិរិយាទាំងនេះ? វិធីមួយក្នុងការសម្រាលឥទ្ធិពលនៃអារម្មណ៍ទាំងនេះ គឺត្រូវផ្តល់ពេលវេលាសមល្មមឱ្យភាគីម្ខាងទៀត បានរ៉ាយរ៉ាប់ពីអារម្មណ៍រំជួលរបស់ខ្លួន។ គេអាចមានអារម្មណ៍ល្អឡើងវិញ បន្ទាប់ពីនិយាយរួច។[៥៨] ភាគីក៏អាចសំដែងអាកប្បកិរិយានានាដើម្បីអត្ថប្រយោជន៍របស់អតិថិជន ឬមិត្តរួមការងាររបស់ខ្លួនផងដែរ។ ឧទាហរណ៍អាចមានដូចជា មេធាវីវ័យក្មេងម្នាក់អាចបង្ហាញនូវភាពតឹងតែងនៅចំពោះមុខកូនក្តីរបស់ខ្លួន ដើម្បីឱ្យពួកគេមានអារម្មណ៍កាន់តែជឿជាក់ថាផលប្រយោជន៍របស់ខ្លួនត្រូវបានការពារយ៉ាងស្វិតស្វាញ។ វាជាប្រការសំខាន់ក្នុងការមិនមានប្រតិកម្មតបតហួសហេតុពេក ចំពោះការវាយប្រហារខាងផ្លូវអារម្មណ៍បែបនោះ។

កលយុទ្ធមួយទៀតគឺការទទួលស្គាល់ដោយជាក់លាក់ និងសំដែងការឯកភាពចំពោះអារម្មណ៍របស់ភាគីម្ខាងទៀត។ ឧទាហរណ៍ គេអាចនិយាយថា "ខ្ញុំយល់ ថាអ្នកមិនសប្បាយចិត្តអំពីអាជីវកម្មរបស់ខ្លួន។ បើជាខ្ញុំវិញ ក៏មិនសប្បាយចិត្តដែរប្រសិនបើខ្ញុំបាត់បង់កិច្ចសន្យាដ៏ធំបំផុតដូច្នេះនោះ"។ នេះមិនមែនមានន័យថាអ្នកគាំទ្រចំពោះការសន្និដ្ឋាននានារបស់ភាគីម្ខាងទៀតនោះទេ។ ប៉ុន្តែ ដោយសារការឯកភាពចំពោះអារម្មណ៍របស់ពួកគេ ភាគីនោះនឹងមានអារម្មណ៍ថា អ្នកយល់អំពីស្ថានភាពរបស់ពួកគេ ហើយអាចមានអាម្មណ៍វិជ្ជមានចំពោះអ្នក។

## សំណួរសិក្សា

- តើអ្នកធ្លាប់មានអារម្មណ៍រំជួល ក្នុងកំឡុងពេលចរចាណាមួយដែលសំខាន់ដែរឬទេ?
- តើអារម្មណ៍ទាំងនោះ ជួយដល់អ្នក ឬក៏បំផ្លាញអ្នក?
- តើភាគីម្ខាងទៀតមានប្រតិកម្មបែបណាចំពោះអារម្មណ៍របស់អ្នក?
- តើលោកអ្នកមានប្រតិកម្មបែបណាចំពោះអារម្មណ៍របស់ភាគីម្ខាងទៀត ?

[៥៧] *ដូចមុន* នៅទំព័រ៣២។ លោកហ្គត់មែន ចាត់ទុកការប្រមាថថាជាចំណុចសំខាន់បំផុតនៅក្នុងការទស្សន៍ទាយនៃការលែងលះ។ ហេតុនេះ ទើបនៅក្នុងការចរចា ការបង្ហាញនូវការប្រមាថអាចជាការកត្តាអុចអាលចំបងបំផុតនៃរាល់បញ្ហាមនោសញ្ចេតនាទាំងអស់។

[៥៨] ការបង្ហាញនូវអារម្មណ៍អវិជ្ជមានអាចជាយន្តការសំរួលចិត្ត ក្នុងការជួយឱ្យមនុស្សអាចប្រឈមចំពោះទុក្ខលំបាករបស់ខ្លួន។ Shapiro កំណត់សម្គាល់ *ខាងលើ* លេខ៥០ នៅទំព័រ៧២ *គុណកថា* Eileen Kennedy-Moore and Jeanne C. Watson, **ការបង្ហាញអារម្មណ៍**, (គ្រឹះស្ថានបោះពុម្ពផ្សាយ ហ្គៀលហ្វដ, ឆ្នាំ១៩៩៩)។

## ២. អារម្មណ៍វិជ្ជមាន

អារម្មណ៍វិជ្ជមាន អាចមានភាពអំណោយដល់ការគិតបែបច្នៃប្រឌិត ដែលមានសារៈសំខាន់ក្នុងការឈានទៅរកការព្រមព្រៀងគ្នា។[៥៩] អារម្មណ៍ទាំងនេះក៏អាចជួយឱ្យភាគីទាំងអស់រក្សាបាននូវទំនាក់ទំនងការងារដ៏ល្អរវាងគ្នា និងគ្នាផងដែរ។ ហើយអារម្មណ៍វិជ្ជមានពិតជាអាចជួយឱ្យគេអាចជៀសវាងបាននូវអន្លង់នៃអារម្មណ៍អវិជ្ជមានផ្សេងៗ។

**ឃ្វាលចិត្ត លំបាកពេកពិត ដូចឃ្វាលពពក។**

ទោះបីជាមានគតិបណ្ឌិតពីមុនមកដូចដែលសុភាសិតខាងលើបានបង្ហាញក្តី គេនៅតែអាចបង្កើតនូវអារម្មណ៍ជាវិជ្ជមានផ្សេងៗតាមសេចក្តីប្រាថ្នាបានដែរ។ អារម្មណ៍មិនមែនគ្រាន់តែ "កើតមាន" ចំពោះមនុស្សនោះទេ ពោលគឺគេក៏អាចបង្កើតវាផងដែរ។ ការគិតអវិជ្ជមានអាចបង្កើតជាអារម្មណ៍អវិជ្ជមាន។ ឧទាហរណ៍ដូចជា លក្ខិណា អាចគិតច្រើនអំពីការដែលនាងលេងប៉េងប៉ុងចាញ់បងស្រីរបស់នាងឈ្មោះ នីន។ ការគិតអវិជ្ជមាននេះអាចបណ្តាលឱ្យកើតមាននូវអារម្មណ៍អវិជ្ជមាន។ ប៉ុន្តែ ប្រសិនបើនាងអាចបង្វែការគិតឱ្យបានកាន់តែច្រើនអំពីការដែល បងស្រីនាងចូលចិត្តអាហារពេលល្ងាចដែលនាងរៀបចំ បន្ទាប់ពីលេងហើយនោះ នាងនឹងចាប់ផ្តើមមានអារម្មណ៍វិជ្ជមានវិញជាមិនខាន។ នៅក្នុងការ ស្រាវ-ជ្រាវរបស់បណ្ឌិតហ្គត់មែន (Gottman) គាត់បានរកឃើញថា គូស្រកដែលរៀបការរួច ត្រូវរក្សាឱ្យបាននូវផលធៀបយ៉ាងហោចណាស់ ប្រាំទល់នឹងមួយ រវាងអន្តរកម្មវិជ្ជមាន និងអវិជ្ជមាន ដើម្បីជៀសវាងនូវការលែងលះ។[៦០]

នៅក្នុងការចរចា អ្នកចរចាដែលមានប្រសិទ្ធភាពអាចព្យាយាមបង្កើតនូវអារម្មណ៍វិជ្ជមាន ដោយសកម្មភាពងាយៗ។ ឧទាហរណ៍ ការញញឹមអាចបណ្តាលឱ្យភាគីម្ខាងទៀតញញឹមតបមកវិញ ដែលការនេះបង្កើតបានជាអារម្មណ៍វិជ្ជមាន។ ជួនកាល ការសួរសំណួរផ្ទាល់ខ្លួនពីរ-បីសំណួរ អាចជួយបង្កើតអារម្មណ៍កាន់តែវិជ្ជមានថែមទៀត។ ឧទាហរណ៍ៈ

> ឡានី ចង់លក់រថយន្តរបស់នាងឱ្យ ប៊ុនថា ។ ពួកគេបានឈានដល់ស្ថានភាពទ័លច្រក ពីព្រោះប៊ុនថាចង់ឱ្យថ្លៃត្រឹមតែ ២,០០០ ដុល្លា ប៉ុន្តែឡានីចង់លក់ក្នុងតម្លៃ ២,៥០០ ដុល្លា។ នៅក្នុងកំឡុងពេលចរចា ឡានីសួរប៊ុនថា ថាតើគាត់មានកូនដែរឬទេ។ ប៊ុនថាឆ្លើយតបដោយញញឹមថា "បាទ ខ្ញុំមានកូនបីនាក់ អាយុ២ឆ្នាំ ៤ឆ្នាំ និង៩ឆ្នាំ" ។ ឡានីឆ្លើយតប "អូ! អស្ចារ្យណាស់។ ខ្ញុំក៏មានកូនអាយុ២ឆ្នាំដែរ។ វាជាអាយុដែលល្អណាស់មែនទេ? ពួកគេគួរឱ្យស្រឡាញ់ណាស់នៅអាយុប៉ុណ្ណេះ"។ ឥឡូវនេះ ប៊ុនថា និងឡានីកំពុងគិតអំពីកូនរបស់ខ្លួន ហើយមានអារម្មណ៍វិជ្ជមាន។ ពួកគេក៏អាចមានអារម្មណ៍កាន់តែជិតស្និទ្ធនឹងគ្នាផងដែរ ដោយសារពួកគេមានអ្វីៗដែលដូចគ្នា។ ជាលទ្ធផល ពួកគេអាចមានភាពងាយស្រួលជាងមុនក្នុងការចរចា ឬកាន់តែព្យាយាមឈានទៅរកការព្រមព្រៀងគ្នាថែមទៀត។

គេអាចជជែកគ្នាអំពីអ្វីក៏បាន ប៉ុន្តែវានឹងមានប្រសិទ្ធិភាព ប្រសិនបើវាពាក់ព័ន្ធទៅនឹងអ្វីដែលគួរឱ្យរីករាយ ឬវិជ្ជមាន ហើយជាអ្វីមួយដែលមនុស្សពីរនាក់អាចមានដូចគ្នា។ ជាការពិតណាស់ វាជាប្រការសំខាន់ដែលគេមិនត្រូវប្រើប្រាស់កលយុទ្ធនេះច្រើនដងពេក ហើយសម្តែងភាពមិនស្មោះត្រង់ ឬលក្ខណៈបោកបញ្ឆោត។

---

[៥៩] *ដូចមុន* នៅទំព័រ ៧៥។

[៦០] Gladwell, កំណត់សម្គាល់ *ខាងលើ* លេខ ៥៥ នៅទំព័រ២៦។

ជាទីបញ្ចប់ កាយវិការជានិមិត្តរូប ដូចជាការសុំទោស ឬការសម្តែងនូវការសោកស្តាយ ខណៈដែលមិនមានរួមបញ្ចូលនូវការសារភាព អាចបោះជំហ៊ានយ៉ាងវែងឆ្ពោះទៅបង្កើតបរិយាកាសវិជ្ជមាន។[៦១] កាយវិការទាំងនេះធ្វើឱ្យភាគីម្ខាងទៀត មានអារម្មណ៍ធូរស្រាល និងអាចបង្កើតនូវអារម្មណ៍វិជ្ជមានមួយចំនួន។

***ប្រការដែលល្អបំផុតនោះគឺថា ជាទូទៅកាយវិការជានិមិត្តរូបមិនត្រូវការការចំណាយអ្វីទាំងអស់។***

ចូរគិតអំពីសំណួរនៅខាងដើមដំបូងនៃជំពូកនេះ តើណានីត្រូវផ្តល់ការណែនាំអ្វីខ្លះដល់ប៊ុនសាងអំពីអារម្មណ៍នៅក្នុងការចរចាដែលនឹងឈានមកដល់ខាងមុខនេះ? នាងគួរផ្តល់ការណែនាំដល់ប៊ុនសាងថា :

- មិនត្រូវមិនអើពើចំពោះអារម្មណ៍ឡើយ។
- ត្រូវទទួលស្គាល់ថា អ្នកអាចមានអារម្មណ៍អវិជ្ជមានដែលអាចចោទជាបញ្ហា។
- ត្រូវចងចាំក្នុងការដោះស្រាយចំពោះអារម្មណ៍របស់អ្នក និងអតិថិជនអ្នក ដោយប្រុងប្រយ័ត្នជាទីបំផុត ហើយ
- ព្យាយាមបង្កើតអារម្មណ៍វិជ្ជមានខ្លះៗ។

### គ) ការទំនាក់ទំនង

ពិតប្រាកដណាស់ ការទំនាក់ទំនងគឺជាមូលដ្ឋានគ្រឹះនៃអន្តរកម្មរបស់មនុស្សទាំងអស់ រួមទាំងការចរចាផងដែរ ។ ជួនកាល របៀបដែលភាគីម្ខាងបង្ហាញគំនិត សម្មតិ ឬដំណោះស្រាយ មានសារៈសំខាន់ជាងខ្លឹមសារនៃគំនិតនោះទៅទៀត។ ការលំបាកជាចម្បងៗចំនួនពីរនៅក្នុងការទំនាក់ទំនង រួមមាន ការស្តាប់ និងការយល់ខុស។[៦២]

### ១. ការស្តាប់

ជាញឹកញាប់ នៅពេលដែលភាគីពីរធ្វើការចរចាដ៏ក្តៅគគុកណាមួយ ពួកគេស្តាប់បានតែផ្នែកដំបូងនៃពាក្យពេចន៍របស់ភាគីម្ខាងទៀតតែប៉ុណ្ណោះ។ ខួរក្បាលរបស់គេបំពេញការគិតនោះ លឿនជាងការដែលភាគីម្ខាងទៀតអាចនិយាយទៅទៀត។ ជួនកាលគំនិតដែលខួរក្បាលរបស់ពួកគេបំពេញនោះ មិនមែនជាអ្វីដែលភាគីម្ខាងទៀតបាននិយាយពិតប្រាកដនោះទេ ហើយពួកគេក៏បាត់បង់គំនិតនោះទាំងស្រុងតែម្តង។ ជួនកាល ភាគីម្ខាងនឹងស្តាប់តែមួយផ្នែកនៃពាក្យពេចន៍បន្ទាប់មកក៏ចាប់ផ្តើមរៀបចំចម្លើយតបវិញ ដោយមិនបានស្តាប់ពាក្យពេចន៍ដែលនៅសេសសល់នោះឡើយ។

ដំណើរការស្តាប់មិនល្អប្រភេទនេះគឺជាអ្វីដែលនាំឱ្យមានបញ្ហា។ ទីមួយ ការមិនបានស្តាប់នូវរឿងរ៉ាវទាំងស្រុងធ្វើឱ្យមានការលំបាកដល់ភាគីក្នុងការទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ ដើម្បីឈានទៅដល់ការព្រមព្រៀង។ ទីពីរ និងដែលមានសារៈសំខាន់ដូចគ្នានោះ គឺប្រសិនបើភាគីម្ខាងសម្តែងអាការៈយ៉ាងច្បាស់ក្រឡែតថាខ្លួនមិនស្តាប់គេទាំងស្រុងនោះ ភាគីម្ខាងទៀតអាចមានអារម្មណ៍ថាមិនមានការគោរពដល់ខ្លួន និងអាចឆ្លើយតបដោយការមិនស្តាប់ទាំងស្រុងវិញដែរ។ ដោយភាគីទាំងពីរមិនព្រមស្តាប់គ្នាឱ្យបានពេញលេញ នោះការទំនាក់ទំនងមិនអាចដំណើរការទៅបានឡើយ ហើយក៏មិនមានការព្រមព្រៀងណាមួយដែលអាចធ្វើទៅរួចដែរ។

---

[៦១] Fisher *et al.* កំណត់សម្គាល់ ខាងលើ លេខ៣១ នៅទំព័រ ៣២។

[៦២] Fisher *et al.* បញ្ហានៃការទំនាក់ទំនងចំនួនបីត្រូវបានកំនត់ឡើង។ ប៉ុន្តែអ្នកនិពន្ធនៃសៀវភៅនេះជឿជាក់ថា គេអាចស្វែងយល់អំពីបញ្ហាទាំងនេះបានកាន់តែប្រសើរ តាមរយៈចំនុចសំខាន់ចំនួនពីរ។ ដូចមុន នៅទំព័រ ៣២-៣៤។

វិធីមួយដើម្បីជៀសវាងបញ្ហានេះគឺត្រូវស្តាប់យ៉ាង *យកចិត្តទុកដាក់* នូវអ្វីដែលភាគីបដិបក្ខនិយាយ។ ភាគីទាំងអស់ត្រូវព្យាយាមកុំកាត់សម្តីគ្នា។ ភាគីទាំងអស់ត្រូវធ្វើការកត់ត្រាផងដែរ។ គឺជាសារៈប្រយោជន៍សំរាប់យើង ដោយនៅដំណាក់កាលនីមួយៗ គួរនិយាយនូវពាក្យពេចន៍ ដូចជា "ខ្ញុំចង់បញ្ជាក់បន្តិចថាខ្ញុំយល់ពីអ្វីដែលអ្នកនិយាយ។ តើអ្នកនិយាយថា.........មែនទេ?"។[៦៣] វាក៏មានសារៈសំខាន់ផងដែរក្នុងការបង្ហាញតាមរយៈកាយវិការថា អ្នកមានចំណាប់អារម្មណ៍ក្នុងការស្តាប់ ដោយត្រូវរក្សាទំនាក់ទំនងតាមរយៈកែវភ្នែក និងឥរិយាបថរាងកាយឱ្យបានល្អ។[៦៤] ដោយអនុវត្តតាមវិធានទាំងនេះ គេអាចសម្រេចបាននូវគោលដៅចំនួនពីរ។ ទីមួយ គឺការទទួលបាននូវព័ត៌មានដែលត្រឹមត្រូវ។ ទីពីរ គឺភាគីម្ខាងទៀតមានអារម្មណ៍ថា សម្លេងរបស់ខ្លួនកំពុងត្រូវបានស្តាប់ និងយល់ជ្រួតជ្រាប។

## ២. ការយល់ច្រឡំ

បញ្ហាចម្បងមួយផ្សេងទៀតពាក់ព័ន្ធនឹងការទំនាក់ទំនង គឺការយល់ច្រឡំ។ ដូចបានរៀបរាប់ខាងលើ មនុស្សមានការយល់ឃើញចំពោះតថភាពនានា តាមរបៀបផ្សេងៗគ្នា។ ពួកគេក៏មានការយល់ឃើញចំពោះពាក្យសម្តី តាមន័យផ្សេងពីគ្នាផងដែរ។ ភាគីម្ខាងអាចនិយាយថា:

*"ខ្ញុំបានផ្តល់ឱកាសចំនួនពីរ ដល់អ្នកក្នុងការបំពេញការងារនេះ"។*

ភាគីដែលនិយាយនេះកំពុងព្យាយាមបង្ហាញថា ខ្លួនមានចិត្តសប្បុរស យុត្តិធម៌ និងអត់ធ្មត់ប៉ុណ្ណា។ ប៉ុន្តែ ភាគីម្ខាងទៀតអាចមានការប្រកាន់ចំពោះការនិយាយបែបនេះ ហើយបែរជាយល់ក្នុងន័យថា:

*អ្នកពិតជាគ្មានសមត្ថភាពមែន។ អ្នកមានឱកាសពីរដងក្នុងការបំពេញការងារនេះ ហើយបរាជ័យរហូត។*

លើសពីនេះទៅទៀត ពាក្យខ្លះអាចមានអត្ថន័យស្រពេចស្រពិល ឬមិនច្បាស់លាស់ ដែលអាចធ្វើឱ្យមានការបកស្រាយ ឬការយល់ច្រឡំផ្សេងៗ។ ប្រសិនបើភាគីនិយាយភាសាខុសគ្នាទៀតនោះ បញ្ហាទាំងនេះអាចនឹងរឹតតែធំឡើងថែមទៀត។

វិធីមួយក្នុងការជៀសវាងការយល់ច្រឡំ គឺត្រូវប្រុងប្រយ័ត្នចំពោះពាក្យសម្តីដែលលោកអ្នកជ្រើសរើស យកមកប្រើប្រាស់។ កលយុទ្ធសំខាន់មួយទៀតគឺបញ្ជាក់បញ្ហាផ្សេងៗជាអត្ថន័យផ្ទាល់ខ្លួន និងមិនមែនជាអត្ថន័យដែលពាក់ព័ន្ធនឹងភាគីម្ខាងទៀតឡើយ។[៦៥] ឧទាហរណ៍ វាមិនមែនជាការឆ្លាតវៃទេ ដែលអ្នកនិយាយថា: "អ្នកមិនគោរពគ្រួសារខ្ញុំសោះ"។ នេះគឺជាការចោទប្រកាន់។ លទ្ធផលដែលប្រសើរបំផុត គឺវានាំឱ្យមានការបដិសេធ។ ឯលទ្ធផលដែលអាក្រក់បំផុត

---

[៦៣] ព្យាយាមទប់ចិត្តដោយមិនត្រូវយកអំណះអំណាងរបស់ភាគីម្ខាងទៀតមកបញ្ជាក់ តាមន័យបន្ទះបង្អាប់ ន័យសាមញ្ញ ឬន័យចំអកឡើយ។ Fisher, *et al.* នៅក្នុង *Getting to Yes*. ឈានទៅមុខមួយជំហានទៀត ហើយបង្ហាញថាអ្នកបញ្ជាក់ នូវអំណះ-អំណាងនោះក្នុងន័យវិជ្ជមាន ដោយធ្វើឱ្យចំណុចខ្លាំងនៃការទាមទាររបស់ភាគីម្ខាងទៀតមានភាពច្បាស់លាស់។ Fisher *et al. ដូចមុន* នៅទំព័រ៣៥។ ចំនុចនេះប្រហែលជាលំបាកជ្រុលសម្រាប់អ្នកចរចាភាគច្រើន ប៉ុន្តែវាជាការសំខាន់ដែលត្រូវព្យាយាមជៀសវាងនូវការបញ្ជាក់ឡើងវិញនូវអំណះអំណាងរបស់ភាគីម្ខាងទៀតក្នុងន័យអវិជ្ជមាន។

[៦៤] ពាក្យនិយាយគឺជាភាគរយដ៏តិចតួចប៉ុណ្ណោះ ក្នុងចំណោមព័ត៌មានដែលបញ្ជូនបន្តដោយភាគីម្ខាងទៀត។ *សូមមើល* សមាគមនៃការស្តាប់អន្តរជាតិ, វែបសាយត៍ *មាននៅ* http://www.listen.org/Templates/try_new.htm, *ធ្វើគុណកថាដល់, ក្នុងនោះរួមមាន* Ray L. Birdwhistell, KINESICS AND CONTEXT (សារព័ត៌មានសាកលវិទ្យាល័យ ភែនស៊ីលវ៉ៃនៀ ឆ្នាំ១៩៧០)។

[៦៥] Fisher, *et al.* កំណត់សម្គាល់ *ខាងលើ* លេខ៣១ នៅទំព័រ៣៦។

គឺវាអាចបណ្តាលឱ្យមានការអន់ចិត្ត និងការចោទប្រកាន់តបមកវិញ។ ផ្ទុយទៅវិញ ទោះបីជាយើងមានអារម្មណ៍ថាមិនមានការគោរពក៏ដោយ ប្រការដែលប្រសើរបំផុតគឺត្រូវនិយាយអ្វីដែលអារម្មណ៍ផ្ទាល់ខ្លួន ដូចជា "គ្រួសាររបស់ខ្ញុំមានអារម្មណ៍ឈឺចាប់ណាស់ ចំពោះអ្វីដែលបាននិយាយចេញមក"។ ពេលនេះ ភាគីម្ខាងទៀតហាក់ដូចជាមិនសូវចង់ឈ្នះចាញ់ ឬមានអារម្មណ៍ខឹងសម្បាកាន់តែតិច។ គ្មាននរណាម្នាក់ត្រូវបានចោទប្រកាន់ឡើយ។ ប៉ុន្តែ ខ្លឹមសារដូចគ្នាត្រូវបានបញ្ជូន។

ឧទាហរណ៍មួយទៀត គឺនៅពេលមាននរណាម្នាក់និយាយថា "អ្នកមិនត្រូវធ្វើដូច្នេះទេ!" ឬ "អ្នកមិនអាចធ្វើដូច្នេះបានទេ!"។ នេះគឺគំរាមកំហែងដល់ភាគីម្ខាងទៀត ហើយដូចករណីខាងលើដែរ គឺវានាំឱ្យមានការនិយាយជំនះពីភាគីម្ខាងទៀត ថាខ្លួនពិតជា **អាច** ធ្វើបាន។ ផ្ទុយទៅវិញ ចូរព្យាយាមនិយាយថា "ខ្ញុំមិនមានអារម្មណ៍ល្អទេ នៅពេលដែលអ្នកធ្វើដូច្នេះ"។ ឥឡូវនេះ អ្នកបានបង្ហាញនូវកង្វល់របស់អ្នក តាមអារម្មណ៍ផ្ទាល់ខ្លួន ជំនួសឱ្យអត្ថន័យដែលចោទប្រកាន់ទៅភាគីម្ខាងទៀត។

## សំណួរសិក្សា

តើសម្តីអះអាងខាងក្រោមនេះ អាចត្រូវបានបញ្ជាក់ឡើងវិញយ៉ាងដូចម្តេច ដើម្បីឱ្យកាន់តែមានប្រសិទ្ធភាព?

- "អ្នកបានបង្កការខូចខាតយ៉ាងធ្ងន់ធ្ងរដល់ក្រុមហ៊ុនរបស់ខ្ញុំ"។
- "សកម្មភាពរបស់អ្នក គឺខុសច្បាប់ និងរំលោភលើកិច្ចសន្យារបស់យើង"។
- "អ្នកពិតជាមិនខ្វល់អំពីសុខភាព និងសុខុមាលភាពសហគមន៍ បើមិនអីចឹងទេ អ្នកមិនបោះចោលសំរាមនោះទេ"។
- "អ្នកបានលួចដីរបស់យើង"។
- "សម្តីរបស់អ្នកមានលក្ខណៈទាបហួស ដែលវាជាការប្រមាថចំពោះរូបខ្ញុំ"។

### ៣. ផ្តោតលើផលប្រយោជន៍ មិនមែនលើជំហរ[៦៦]

ចូរពិចារណាលើរឿងខាងក្រោម[៦៧] :

ណូរ៉ា និងស៊ីថា កំពុងនៅក្នុងបណ្ណាល័យអានសៀវភៅទាំងពីរនាក់។ ណូរ៉ាចង់បើកបង្អួច ឯស៊ីថាចង់ បិទបង្អួច។ ពួកគេប្រកែកគ្នាថា គួរបិទពាក់កណ្តាល ឬត្រឹមណា ឬក៏បង្ហើបតែបន្តិច ។ល។ ប៉ុន្តែ ពួកគេមិនអាចព្រមព្រៀងគ្នាបាន។

បន្ទាប់មក សុវណ្ណារ័ត្ន ដែលជាបណ្ណារក្សក៏ដើរចូលមក ហើយសួរ ពួកគេ អំពីការមិនព្រមព្រៀងគ្នានោះ។ គាត់សួរណូរ៉ាថា ហេតុអ្វីបានជាចង់បើកបង្អួច។ ណូរ៉ាឆ្លើយតបថា "ខ្ញុំចង់បានខ្យល់អាកាសបរិសុទ្ធខ្លះៗ"។ បន្ទាប់មក គាត់សួរស៊ីថា ហេតុអ្វីបានជាចង់បិទបង្អួច ហើយស៊ីថាឆ្លើយតបថា "ខ្ញុំចង់ជៀសវាងលម្ហើយនៃខ្យល់។ វាមិនល្អសម្រាប់សុខភាពទេ ហើយខ្ញុំរកកលនឹងឈឺ"។ បន្ទាប់មក សុវណ្ណារ័ត្នគិតមួយនាទី ហើយក៏ដោះស្រាយបញ្ហានោះបានយ៉ាងងាយស្រួល។ គាត់ក៏ទៅ បើកបង្អួច

[៦៦] *ដូចមុន* នៅទំព័រ ៤០-៥៥ ។

[៦៧] *ដូចមុន* នៅទំព័រ ៤០។

មួយផ្សេងទៀតដែលនៅឆ្ងាយពីនោះបន្តិច។ គាត់អាចនាំខ្យល់បរិសុទ្ធចូលសម្រាប់ណូរ៉ា ហើយក៏គ្មានលម្អើយទៅរំខានស៊ីថាដែរ។

រឿងនេះបង្ហាញអំពីសារៈសំខាន់នៃការផ្តោតទៅលើ *ផលប្រយោជន៍* ជាជាងលើជំហរ។ ជំហររបស់ណូរ៉ាគឺ គាត់ចង់បើកបង្អួចទាំងស្រុង។ ជំហររបស់ស៊ីថា គឺថាគាត់ចង់បិទបង្អួចទាំងស្រុង។ ផលប្រយោជន៍ចម្បងរបស់ពួកគេគឺខុសគ្នា។ ផលប្រយោជន៍ពិតប្រាកដដែលណូរ៉ាចង់បាន គឺមានខ្យល់បរិសុទ្ធនៅក្នុងបន្ទប់។ ចំណែក ផលប្រយោជន៍ដែលស៊ីថាចង់បាន គឺជៀសវាងលម្អើយខ្យល់ ដែលអាចធ្វើឱ្យគាត់មានអារម្មណ៍កាន់តែមិនស្រួលខ្លួន។ ផលប្រយោជន៍ និងជំហររបស់ពួកគេទាំងពីរ មានបង្ហាញនៅក្នុងតារាងខាងក្រោមៈ

| | ជំហរ | ផលប្រយោជន៍ |
|---|---|---|
| **ណូរ៉ា** | គួរបើកបង្អួចទាំងស្រុង។ | ចង់បានខ្យល់ បរិសុទ្ធ ។ បន្ទប់ហាក់ដូចជាមានក្លិនផ្សរ ។ |
| **ស៊ីថា** | គួរបិទបង្អួចទាំងស្រុង។ | មានអារម្មណ៍ថារកកលនឹងឈឺ និងបារម្ភថាលម្អើយខ្យល់ធ្វើឱ្យខ្លួនកាន់តែមានអារម្មណ៍កាន់តែពិបាកថែមទៀត។ |

នៅពេលសុវណ្ណារ័ត្នដឹងអំពីផលប្រយោជន៍របស់ភាគីទាំងពីរ គាត់មានលទ្ធភាពស្វែងរកដំណោះស្រាយដែលត្រូវចិត្តពួកគេទាំងពីរនាក់។ ផ្ទុយទៅវិញ នៅក្នុងការចរចាបែបបែងចែក ភាគីទាំងពីរប្រហែលជាដោះស្រាយបញ្ហានោះដោយទុកឱ្យបង្អួចបើកមួយផ្នែក។ ការនេះអាចធ្វើឱ្យស៊ីថាមានអារម្មណ៍មិនស្រួលខ្លួន ហើយណូរ៉ានៅតែមានអារម្មណ៍ថាគ្មានផាសុកភាព ហើយក្តៅ។ ដូច្នេះ នៅពេលដែលការការចរចាផ្អែកលើផលប្រយោជន៍អាចធ្វើទៅបាន ជាទូទៅ ពួកគេមានការពេញចិត្ត និងមានភាពជោគជ័យ ជាងការចរចាបែបបែងចែក ដែលផ្តោតតែលើជំហរ។

ផលប្រយោជន៍គឺជាសេចក្តីសង្ឃឹម ការភ័យខ្លាច បំណងប្រាថ្នា តម្រូវការ និងចំណង់ ... របស់ភាគី។ ជំហរគឺជាការទាមទារ សំណូមពរ សម្តី ... ដ៏ជាក់លាក់របស់ភាគី ។ ជំហរ គឺងាយស្រួលក្នុងការកំណត់។ ភាគីតែងប្រកាសអំពីជំហររបស់ខ្លួនយ៉ាងស្រេចបាច់។ ភាគច្រើន ពួកគេគិតក្នុងជំហរដែលជាក់លាក់ដូចជា "ខ្ញុំពិតជាចង់បានរបស់ទាំងនេះចំនួន១០ ជាការទូទាត់"។ ប៉ុន្តែផលប្រយោជន៍មានការលំបាកក្នុងការកំណត់ជាង។ ជួនកាល ភាគីមិនចង់បង្ហាញពីវាឡើយ។ កាន់តែញឹកញាប់ជាងនេះទៅទៀត ភាគីមិនបានពិចារណាពីផលប្រយោជន៍ដែលកប់ជ្រៅរបស់ខ្លួនឡើយ។

***ហ្វ៊ីស្ស៊ើរ និងយូរី បានអះអាងថា ផលប្រយោជន៍ដែលមានឥទ្ធិពលបំផុតគឺតម្រូវការជាមូលដ្ឋានរបស់មនុស្ស ដូចជាៈ***

- ***សុវត្ថិភាព***
- ***សុខមាលភាពសេដ្ឋកិច្ច***
- ***អារម្មណ៍នៃភាពជាម្ចាស់កម្មសិទ្ធិ***
- ***ការទទួលស្គាល់ពីអ្នកដទៃ***
- ***ការគ្រប់គ្រងលើជីវិតរបស់ខ្លួនឯង***[៦៨]

[៦៨] *ដូចមុន* នៅទំព័រ ៤៨ ។

ទោះបីក្នុងករណីដែលគេមើលឃើញថាប្រាក់កាសគឺជាបញ្ហាតែមួយគត់ក្តី ក៏អាចមានបញ្ហាជាច្រើនទៀត ដែលមានជាប់ពាក់ព័ន្ធដែរ។ ឧទាហរណ៍ សុផល ដែលជាវិចិត្រករ មានផ្ទាំងគំនូរសម្រាប់លក់ ហើយទទូចចង់បានតម្លៃខ្ពស់សម្រាប់ស្នាដៃរបស់ខ្លួន។ សំណាងគឺជាយុវកំលោះ ដែលមានមិត្តភក្តិមួយចំនួនជាអ្នកសារព័ត៌មាន ហើយមិនមានលទ្ធភាពទិញក្នុងតម្លៃនោះ ប៉ុន្តែចូលចិត្តផ្ទាំងគំនូរនោះយ៉ាងខ្លាំង។ ប្រហែលជា សុផលចាប់អារម្មណ៍ពីការទទួលស្គាល់ថាខ្លួនជាវិចិត្រករដែលមានភាពហ្មត់ចត់ ស្មើនឹងការធានាសុខុមាលភាពសេដ្ឋកិច្ចរបស់ខ្លួនដែរ។ ប្រហែលជាសំណាងអាចជួយបំពេញផលប្រយោជន៍នេះបាន ដោយព្រមចុះផ្សាយអត្ថបទមួយអំពីផ្ទាំងគំនូរនោះ នៅក្នុងទស្សនាវដ្តីណាមួយ ជាថ្នូរនឹងតម្លៃដែលទាបជាងមុន។

បញ្ហាមួយទៀតដែលត្រូវចងចាំគឺថា មនុស្សភាគច្រើនមានអត្ថប្រយោជន៍ច្រើនជាងមួយ។ ចូរគិតអំពីអ្នកចាត់ការក្រុមហ៊ុនមួយដែលត្រូវគិតពីផលប្រយោជន៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន (ក្រុមហ៊ុនត្រូវការសន្សំប្រាក់) ផលប្រយោជន៍នៃអាជីពផ្ទាល់ខ្លួន (គាត់ត្រូវតែបានគេមើលឃើញថាបានបំពេញបានតាមកូតាផលិតកម្ម) ផលប្រយោជន៍បុគ្គលិករបស់គាត់ (ពួកគេត្រូវមានសុខភាពល្អ និងសុវត្ថិភាព) និងផលប្រយោជន៍គ្រួសាររបស់គាត់ (ពួកគេចង់ឱ្យគាត់ឈប់សម្រាកពីការងារ)។ បើអ្នកចរចាម្នាក់យល់កាន់តែច្រើនអំពីភាពប្រទាក់ក្រឡាគ្នានៃផលប្រយោជន៍ គាត់អាចរកដំណោះស្រាយដែលមានប្រសិទ្ធភាព កាន់តែច្រើនតាមនោះដែរ។

វិធីមួយក្នុងការកំណត់អំពីផលប្រយោជន៍របស់ភាគីណាមួយ គឺត្រូវសួរ។ ដូចបានរៀបរាប់រួចមកហើយថា គេអាចនិយាយថា ភាគីមិនបានសូម្បីតែពិចារណាឱ្យបានច្បាស់លាស់អំពីផលប្រយោជន៍របស់ខ្លួនផង។ ដោយគ្រាន់តែសួរនូវសំណួរផ្សេងៗ វាធ្វើឱ្យអ្នកសួរនោះមើលទៅហាក់ដូចជាគិតគូអំពីសុខុមាលភាពរបស់ភាគីម្ខាងទៀត។ វិធីមួយទៀតក្នុងការកំណត់អំពីផលប្រយោជន៍របស់ភាគីណាមួយ គឺត្រូវស្តាប់យ៉ាងប្រុងប្រយ័ត្ននូវអ្វីដែលពួកគេនិយាយ នៅក្នុងកំឡុងពេលចរចា។ ពួកគេអាចបង្ហើបឱ្យដឹងពីកង្វល់ចម្បងរបស់ពួកគេ តាមរយៈរបៀបដែលពួកគេប្រាស្រ័យទាក់ទង ឬបញ្ជាក់ពីជំហររបស់ខ្លួន។ បញ្ច្រាស់ទៅវិញ ជួនកាលវាជាប្រការសំខាន់ដែលត្រូវបង្ហាញឱ្យបានច្បាស់អំពីផលប្រយោជន៍ផ្ទាល់ខ្លួនរបស់អ្នកចំពោះភាគីម្ខាងទៀត។ ការនេះនឹងអនុញ្ញាតឱ្យគេ គិតអំពីមធ្យោបាយបំពេញតាមតម្រូវការរបស់អ្នកវិញដែរ។

លើសពីនេះទៅទៀត ជួនកាលវាមានសារៈប្រយោជន៍ក្នុងការបង្ហាញទាំងបញ្ហា និងដំណោះស្រាយ។ នៅពេលធ្វើទំនាក់ទំនងក្នុងការចរចាណាមួយ គេគប្បីលើកឡើងនូវបញ្ហា *ជាមុន* និងបន្ទាប់មកទើបស្នើនូវដំណោះស្រាយ។[៦៥] ប្រសិនបើភាគីមួយ ទូរស័ព្ទទៅអ្នកជិតខាង ហើយនិយាយថា:

*"អ្នកត្រូវឈប់លេងភ្លេងនៅពេលយប់ ! ថ្លង់ណាស់..."*

ភាគីនេះមិនបានបង្ហាញពីបញ្ហាទេ គ្រាន់តែបង្ហាញនូវដំណោះស្រាយប៉ុណ្ណោះ គឺឈប់លេងភ្លេង។ មុននឹងភាគីអាចពន្យល់អំពីបញ្ហា ឬផលប្រយោជន៍របស់ខ្លួន អ្នកជិតខាងនោះប្រហែលជាខឹង ឬលែងស្តាប់ទៅហើយ។ គាត់ក៏អាចរៀបចំចម្លើយទុកដែលស្តាប់គេទៅ អាចមានន័យដូចខាងក្រោមនេះ:

*"ខ្ញុំមានសិទ្ធិក្នុងការលេងភ្លេងនៅក្នុងផ្ទះរបស់ខ្ញុំ ។ ម្យ៉ាងទៀត វាមិនថ្លង់ពេកទេ..."* ។

---

[៦៥] *ដូចមុន* នៅទំព័រ ៥២ ។

វិធីសាស្ត្រដ៏ប្រសើរជាងនោះគឺត្រូវបង្ហាញដល់អ្នកជិតខាងនោះនូវបញ្ហា និងផលប្រយោជន៍ជាមុនសិន បន្ទាប់មក ទើប បង្ហាញដំណោះស្រាយៈ

*អ្នកជិតខាងជាទីរាប់អាន ពួកយើងកំពុងមានបញ្ហាលំបាកជាមួយកូនរបស់យើង។ ពួកគេមិនបានដេក ពួនទៅពេលយប់សោះ ហើយចេះតែដាស់ពួកយើងដែរ។ ការមិនបានដេកធ្វើឱ្យពួកគេរៀនមិនបានល្អ នៅសាលា។ វាពិតជាធ្វើឱ្យពួកយើងខ្វល់ខ្វាយមែនទែន។ ពួកយើងចង់ឱ្យកូនក្លាយជាសិស្សល្អ និងទៅ រៀននៅសាកលវិទ្យាល័យដូចជា ទែក កូនរបស់អ្នកដែរ។ ប៉ុន្តែ ក្នុងពេលនេះ ពួកយើងមានការ ព្រួយបារម្ភ...។ ខ្ញុំគិតថាប្រសិនបើពេលយប់មានសភាពស្ងប់ស្ងាត់ជាងនេះ ពួកគេប្រហែលជាអាចដេក បានលក់ស្រួលជាងមុន...។*

ឥឡូវនេះ អ្នកជិតខាងបានយល់ (ហើយអាចផ្សាភ្ជាប់) ចំពោះបញ្ហា និងផលប្រយោជន៍របស់លោកអ្នក។ គាត់អាចស្តាប់ និងពិចារណាដំណោះស្រាយរបស់លោកអ្នក នៅពេលអ្នកបង្ហាញវាតាមវិធីនេះ។ អ្នកជិតខាងអាចស្នើឡើង នូវអ្វីដែលស្របទៅនឹងផលប្រយោជន៍របស់គាត់ (ថាគាត់មានសិទ្ធិលេងភ្លេង) ប៉ុន្តែក៏បំពេញតាមការព្រួយបារម្ភរបស់អ្នក ដែរ។ គាត់អាចសុំលេងភ្លេងខ្លាំងៗ នៅពេលផ្សេងជំនួស ឱ្យពេលយប់ នៅពេលក្មេងៗព្យាយាមដេក។

ត្រឡប់ទៅកាន់ផ្ទះកមុនវិញ យើងបានពិភាក្សាអំពីទស្សនៈយល់ឃើញផ្សេងៗរវាងម្ចាស់ផ្ទះ និងអ្នកជួលផ្ទះ។ ហ្វ៊ីស្ស៊ើរ (Fisher) និង យូរី (Ury) បង្ហាញថាតើផលប្រយោជន៍របស់ពួកគេអាចមានភាពស្រដៀងដូចគ្នាយ៉ាងដូចម្តេចៈ

១. អ្នកទាំងពីរចង់បានស្ថិរភាព។ ម្ចាស់ផ្ទះចង់បានអ្នកជួលផ្ទះរយៈពេលយូរ អ្នកជួលចង់បានផ្ទះ រយៈ-ពេលយូរដែរ។

២. អ្នកទាំងពីរចង់ឃើញផ្ទះត្រូវបានថែរក្សាយ៉ាងល្អ។ ម្ចាស់ផ្ទះមើលឃើញផ្ទះដែលថែទាំបានល្អ មាន សារៈសំខាន់ចំពោះ តម្លៃនៃអចលនទ្រព្យរបស់ខ្លួន។ អ្នកជួលចង់ឱ្យផ្ទះត្រូវបានថែទាំយ៉ាងល្អ ដោយសារ គាត់រស់នៅទីនោះ។

៣. អ្នកទាំងពីរចង់មានទំនាក់ទំនងល្អជាមួយគ្នាទៅវិញទៅមក។ ម្ចាស់ផ្ទះចង់បានថ្លៃឈ្នួលផ្ទះទៀងទាត់ ដោយគ្មានបញ្ហាអ្វី ឯអ្នកជួល ចង់ឱ្យម្ចាស់ផ្ទះជួសជុលដោយគ្មានបញ្ហាអ្វីទាំងអស់។[៧០]

ដូច្នេះ ទោះបីជាមានទស្សនៈយល់ឃើញផ្សេងគ្នាជាច្រើនរវាងម្ចាស់ផ្ទះ និងអ្នកជួលក៏ដោយ ក៏នៅតែមានផល-ប្រយោជន៍ប្រហាក់ប្រហែលគ្នាមួយចំនួនដែរ។ នៅក្នុងការចរចាភាគច្រើន យ៉ាងហោចណាស់ក៏មានផលប្រយោជន៍ ប្រហាក់ប្រហែលគ្នាមួយ ឬពីរ ដែលគេអាចយកមកប្រើប្រាស់ដើម្បីស្វែងរកការព្រមព្រៀងគ្នា។

***អ្នកចរចាដែលឆ្លាតវៃ ត្រូវផ្តោតលើផលប្រយោជន៍ដែលប្រហាក់ប្រហែលគ្នាទាំងនោះ ជាចំណុចចាប់ផ្តើមនៃ ការស្វែងរកដំណោះស្រាយណាមួយ។***

[៧០] *ដូចមុន* នៅទំព័រ ៤២-៤៣។

### សំនួរសិក្សា

តើផលប្រយោជន៍អ្វីខ្លះដែលអាចមានភាពប្រហាក់ប្រហែលគ្នា នឹងឧទាហរណ៍ខាងក្រោម?

- និយោជក និងនិយោជិតកំពុងចរចាគ្នាអំពីបញ្ហាប្រាក់បៀវត្សរ៍។
- អ្នកជំនួញម្នាក់បានរកឃើញមានកំហុសនៅក្នុងការប្រគល់ក្រណាត់លើកចុងក្រោយ ពីអ្នកផ្គត់ផ្គង់ដ៏យូរអង្វែង និងទៀងទាត់របស់ខ្លួន។
- ប្ដីប្រពន្ធមួយគូកំពុងប្រកែកគ្នាអំពីអ្វីដែលត្រូវធ្វើនៅថ្ងៃឈប់សម្រាកបុណ្យចូលឆ្នាំថ្មី។ ប្ដីចង់ទៅលេងទីក្រុង ដើម្បីសួរសុខទុក្ខមិត្តភក្តិ ឯប្រពន្ធចង់ទៅលេងឆ្នេរសមុទ្រ។
- ក្រុមហ៊ុនអភិវឌ្ឍន៍មួយចង់សាងសង់សណ្ឋាគារដ៏ធំមួយនៅលើដីរបស់ខ្លួន ប៉ុន្តែរដ្ឋាភិបាលព្រួយបារម្ភអំពីការចេញលិខិតអនុញ្ញាត ពីព្រោះមានចរាចរណ៍ និងសម្លេងរំខានច្រើនពេកទៅហើយនៅក្នុងសហគមន៍នោះ។

### ៤. *បង្កើតជម្រើសសម្រាប់ផលចំណេញរួម*[៧១]

ប្រសិនបើភាគីចង់ដោះស្រាយវិវាទដោយជោគជ័យ ពួកគេត្រូវបង្កើតជម្រើសសម្រាប់ផលចំណេញរួម។ ប៉ុន្តែជាញឹកញាប់ ការនេះហាក់ដូចជាពិបាក។ មានមូលហេតុចម្បងៗចំនួនបួនដែលបណ្ដាលមានភាពពិបាក សម្រាប់ភាគី:

- ○ មានពេលខ្លះ ភាគីធ្វើការវិនិច្ឆ័យមុនកាលកំណត់ទៅលើជម្រើសដែលមាន។ មុននឹងជម្រើសនោះត្រូវបានពិភាក្សា ឬស្នើឡើង ភាគីអាចបដិសេធដោយចាត់ថាវាជាគំនិតអាក្រក់ទៅហើយ។ ឬភាគីអាចមានការខ្មាស់អៀនក្នុងការស្នើនូវជម្រើសនោះឡើង។ ឬមួយ អាចដោយសារតែការសំណូមពរនោះ អាចធ្វើឱ្យភាគីត្រូវបង្ហាញព័ត៌មានឯកជន។
- ○ ពេលខ្លះ ភាគីតែងផ្ដោតទៅលើការស្វែងរកចម្លើយល្អឥតខ្ចោះតែមួយណានោះ ជាជាងការស្វែងរក ដំណោះ-ស្រាយ ជាច្រើនដែលអាចមាន។
- ○ ជាញឹកញាប់បំផុត ភាគីតែងជឿជាក់ថា វិវាទកើតឡើងដោយសារតែរឿងប្រាក់កាសមួយចំនួន ឬជឿក៏ថាវាជាល្បែងដែលមានផលសរុបស្មើសូន្យ យកចាញ់-ឈ្នះ។ ប្រសិនបើភាគីម្ខាងចំណាយប្រាក់បន្ថែម ចំនួន១០០ដុល្លា នោះគឺជាការចំណេញសម្រាប់ភាគីទទួលប្រាក់ និងជាការខាតបង់សម្រាប់ភាគីបង់ប្រាក់។
- ○ ភាគីនីមួយៗខ្វល់ខ្វាយតែអំពីផលប្រយោជន៍ផ្ទាល់របស់ខ្លួនប៉ុណ្ណោះ។ ផ្ទុយទៅវិញ អ្នកចរចាដែលវៃឆ្លាតត្រូវគិតអំពីការបំពេញឱ្យផលប្រយោជន៍ភាគីម្ខាងទៀតផងដែរ ព្រោះវាជាវិធីតែមួយគត់ក្នុងការឈានទៅដល់ការព្រមព្រៀង។[៧២]

**ងប់នឹងជំនឿ រឿគំនិត។**

មានចម្លើយសំខាន់ៗបួនចំពោះបញ្ហាទាំងនេះ ដែលនឹងជួយដល់អ្នកចរចាក្នុងការបង្កើតជម្រើស:[៧៣]

---

[៧១] *ដូចមុន* នៅទំព័រ ៥៦-៨០។

[៧២] *ដូចមុន*។

- ផ្តាច់ការបង្កើតជម្រើសចេញពីការវិនិច្ឆ័យជម្រើស។
- ព្យាយាមពង្រីកជម្រើសសម្រាប់ពិចារណាជាជាងការស្វែងរកចម្លើយតែមួយ ។
- ស្វែងរកផលចំណេញរួម និង
- គិតអំពីវិធីដែលធ្វើឱ្យមានភាពងាយស្រួលដល់ការសម្រេចចិត្តរបស់ភាគីម្ខាងទៀត។[៧៤]

### ក. ផ្តាច់ការបង្កើត ចេញពីការវិនិច្ឆ័យ

ចម្លើយទីមួយ គឺផ្តាច់ការបង្កើតជម្រើសចេញពីការវិនិច្ឆ័យជម្រើស។ មានវិធីមួយគឺការប្រើប្រាស់បច្ចេកទេសដែលត្រូវបានស្គាល់ថាជា "ការរិះរកគំនិតថ្មីៗ (Brainstorming)"។ កិច្ចប្រជុំរិះរកគំនិតថ្មីៗ (brainstorming session) ត្រូវបានគេប្រើប្រាស់នៅក្នុងសង្គមពាណិជ្ជកម្ម អង្គការមិនមែនរដ្ឋាភិបាល និងរដ្ឋាភិបាល ដើម្បីជួយឱ្យមនុស្សឱ្យបង្កើតគំនិតតាមរបៀបដែលឆាប់រហ័ស ងាយស្រួល និងសប្បាយរីករាយ។ ដំណើរការនេះមានលក្ខណៈសាមញ្ញគឺៈ វាចាប់ផ្តើមដោយឱ្យមនុស្សជួបជុំគ្នានៅក្នុងបន្ទប់មួយ ដោយមានក្តារខៀន ក្រដាស ឬកន្លែងផ្សេងទៀតសម្រាប់សរសេរ។ មនុស្សម្នាក់ត្រូវធ្វើជាអ្នកសម្របសម្រួល ហើយសួរទៅសមាជិកក្រុមឱ្យបញ្ចេញគំនិត ឬដំណោះស្រាយចំពោះបញ្ហាដ៏ជាក់លាក់ណាមួយ ដែលអ្នកសម្របសម្រួលនឹងសរសេរនៅលើក្តារខៀន ដើម្បីឱ្យអ្នកទាំងអស់គ្នាមើលឃើញ។ គ្រប់គ្នាត្រូវបានលើកទឹកចិត្តឱ្យបញ្ចេញគំនិតទាំងឡាយណាដែលខ្លួនអាចគិតឃើញ ទោះបីជាមិនដាច់ស្រេចក៏ដោយ។ កិច្ចប្រជុំបែបនេះត្រូវមានវត្តមានសមាជិកយ៉ាងហោចណាស់បីរូប និងឱ្យមានចំនួនច្រើនដល់ដប់រូប ទើបជាការប្រពៃ។ ពួកគេក៏ត្រូវការផងដែរនូវបរិយាកាសវិជ្ជមាន និងស្និទ្ធស្នាល ដោយគ្មាននរណាម្នាក់និយាយអវិជ្ជមានចំពោះគំនិតណាមួយដែលបានបញ្ចេញឡើយ។ គ្មាននរណាម្នាក់មានតំណែង ឬសិទ្ធិអំណាចលើអ្នកដទៃទៀត ក្នុងកិច្ចប្រជុំរិះរកគំនិតបែបនេះទេ។

ជាការប្រសើរបំផុត អ្នកចូលរួមត្រូវអង្គុយជិតៗគ្នា ហើយទាំងអស់គ្នាបែរមុខទៅរកក្តារខៀន ជាការបញ្ជាក់ន័យថាពួកគេកំពុងធ្វើការរួមគ្នាដើម្បីស្វែងរកចម្លើយ។ ជាទូទៅ មនុស្សចាប់ផ្តើមគិតអំពីគំនិតថ្មីៗបន្ទាប់ពីស្តាប់ឮគំនិតរបស់អ្នកដទៃរួច។ នៅចុងបញ្ចប់ការពិភាក្សា គំនិតទាំងអស់នឹងត្រូវបានកត់ត្រា លុះនៅពេលក្រោយមកទៀតទើបមានការវិភាគលើគំនិតទាំងនោះ។

ការរិះរកគំនិតថ្មីៗ អាចត្រូវបានបំពេញឡើងរួមគ្នាសូម្បីជាមួយភាគីម្ខាងទៀត។ គំនិតនេះហាក់ដូចជាមិនមានភាពប្រាកដនិយម ប៉ុន្តែការរិះរកគំនិតថ្មីៗរួមគ្នាមានអត្ថប្រយោជន៍មួយចំនួនគួរឱ្យកត់សម្គាល់។ ទីមួយ មនុស្សនឹងមានទំនុកចិត្តលើគ្នាកាន់តែច្រើន ប្រសិនបើពួកគេធ្វើការជាមួយក្នុងការរិះរកដំណោះស្រាយផ្សេងៗ។ ទីពីរ ពួកគេរឹតតែអាចលើកឡើងនូវជម្រើសកាន់តែច្រើនសម្រាប់ការស្រុះស្រួល។ និងជាចុងក្រោយ ភាគីទាំងអស់នឹងរៀនយល់អំពីផលប្រយោជន៍របស់អ្នកដទៃបានកាន់តែប្រសើរ។ ទោះជាយ៉ាងណាក្តី វាជាការសំខាន់ដែលអ្នកចូលរួមទាំងអស់យល់ថាការពិភាក្សារិះរកគំនិតថ្មីៗមិនមែនជាការចរចានោះទេ។ វាមិនបង្ខំឱ្យភាគីណាមួយធ្វើសម្បទាន ឬប្រកាន់ជំហរជាក់លាក់ណាមួយឡើយ។ គោលបំណងដ៏ច្បាស់លាស់របស់វាគឺដើម្បីបង្កើតជម្រើស ដែលអាចមានសារៈប្រយោជន៍សម្រាប់ការស្រុះស្រួលនៅពេលក្រោយ។

---

[៧៣] *ដូចមុន* នៅទំព័រ៦០។

[៧៤] *ដូចមុន* នៅទំព័រ៦០-៦៥។

**លំហាត់ រិះរកគំនិត**

| |
|---|
| ចូរបង្កើតជម្រើសសម្រាប់ការស្រុះស្រួល ដោយប្រើប្រាស់កិច្ចប្រជុំរិះរកគំនិតថ្មីៗសម្រាប់ករណីនេះ ៖ |
| គីម លន់ គឺជាបុគ្គលិកដ៏មានតម្លៃនៅ PP Mobile ជាក្រុមហ៊ុនទូរស័ព្ទ និងអ៊ីនធើណិត។ នាងគឺជាអ្នកជំនាញសរសេរកម្មវិធីកុំព្យូទ័រ។ នាងទើបតែសម្រាលកូនដំបូង។ នាងចង់ធ្វើការតិចជាងមុនពីរ-បីម៉ោង ដើម្បីឱ្យនាងមានពេលវេលាច្រើន នៅជាមួយកូនរបស់នាង។ ប៉ុន្តែ នាងក៏ចង់បានប្រាក់ចំណូលផងដែរ ដូច្នេះនាងមិនចង់ឈប់ធ្វើការទេ។ ក្រុមហ៊ុន PP Mobile មានការព្រួយបារម្ភ ពីព្រោះពួកគេត្រូវការបទពិសោធន៍ជំនាញរបស់នាងស្ទើរតែពេញម៉ោង ប៉ុន្តែពួកគេមិនមានលទ្ធភាព ដំឡើងប្រាក់បៀវត្សរ៍ខ្ពស់ ដើម្បីរក្សានាងឱ្យនៅធ្វើការដដែលឡើយ។ |
| តើដំណោះស្រាយអ្វីខ្លះអាចបំពេញតាមផលប្រយោជន៍របស់ភាគីទាំងពីរបាន? |

### ខ. ពង្រីកជម្រើស[៧៥]

កលយុទ្ធនេះមានសារៈប្រយោជន៍ បន្ទាប់ពីភាគីមួយ ឬច្រើន បានបង្កើតនូវជម្រើសដែលគួរឱ្យចាប់អារម្មណ៍មួយចំនួនរួច។ ដំណើរការនេះចាប់ផ្ដើមដោយចាប់យកជម្រើសដែលគួរឱ្យចាប់អារម្មណ៍ទាំងអស់មក *ពង្រីក* វា។ ពោលគឺដែលត្រូវគិតដល់គំនិតទូទៅបន្ថែមទៀតដែលពាក់ព័ន្ធនឹងជម្រើសនីមួយៗ។ វិធីមួយដើម្បីធ្វើបែបនេះ គឺត្រូវសំលឹងមើលបញ្ហាតាមរយៈចក្ខុវិស័យរបស់អ្នកជំនាញផ្សេងៗ។ ប្រសិនបើវិវាទពាក់ព័ន្ធនឹងកិច្ចសន្យាពាណិជ្ជកម្ម ចូរសំលឹងមើលបញ្ហានោះពីទស្សនៈវិស័យរបស់គណនេយ្យករ ឬអ្នកគ្រប់គ្រងអាជីវកម្ម ឬមេធាវី ឬមន្ត្រីរដ្ឋាភិបាល ។ល។ ចូរគិតអំពីដំណោះ-ស្រាយដែលអ្នកជំនាញទាំងនេះអាចគិតឃើញ។ វាមិនសំខាន់ទេថាអ្នកជាអ្នកជំនាញប្រភេទនេះ គ្រាន់តែអ្នកសាកល្បងគិតដូចគេតែប៉ុណ្ណោះ។

វិធីមួយទៀតគឺត្រូវបំបែកបញ្ហានោះជាបំណែកតូចៗ ហើយស្វែងរកដំណោះស្រាយតាមនោះ។ ឧទាហរណ៍ថា បើមានអ្នកប្រចាំការនៅហាងលក់ទំនិញម្នាក់ មានវិវាទជាមួយអ្នកផ្គត់ផ្គង់អំពីផលិតផលដែលមានគុណភាពអន់ គាត់អាចយល់ព្រមឱ្យប្រគល់ផលិតផលផ្សេងមកម្ដងទៀតនាពេលខាងមុខ ហើយធ្វើតេស្តគុណភាពផលិតផលនោះ។ លុះបន្ទាប់ពីនោះមក ទើបគេត្រូវពិចារណាអំពីដំណោះស្រាយជាអចិន្ត្រៃយ៍។

### គ. ស្វែងរកផលចំណេញរួម[៧៦]

#### ១) ផលប្រយោជន៍ដូចគ្នា

ជាជាងសន្មត់ថាការចំណេញសម្រាប់អ្នក គឺជាការខាតបង់សម្រាប់ភាគីម្ខាងទៀត ចូរពិចារណាឱកាសដើម្បីផលចំណេញរួម។ ដូចបានរៀបរាប់ខាងលើ ស្ទើរតែគ្រប់ករណីទាំងអស់ ភាគីតែងតែមានផលប្រយោជន៍ដូចគ្នាមួយចំនួន ដែលគេអាចទាញយកមកប្រើនៅពេលស្រុះស្រួលគ្នា។ ចូរពិនិត្យមើលឧទាហរណ៍ដោយការសម្មត់ខាងក្រោម ដែលស្ដីពីវិវាទអាជីវកម្មមួយ សម្រាប់អនាគត៖

[៧៥] *ដូចមុន* នៅទំព័រ ៦៥-៧០។

[៧៦] *ដូចមុន* នៅទំព័រ ៧០-៧៦ ។

ឃែម-ឆាយណា (Cam-China) គឺជាក្រុមហ៊ុនប្រេងឥន្ធនៈ ដែលបូម ប្រេងឆៅចេញពីឆ្នេរសមុទ្រក្រុងព្រះសីហនុ និងបញ្ជូនទៅកំពង់ផែក្រុងព្រះសីហនុ សម្រាប់ផ្ទុកទៅក្នុងនាវាដឹកប្រេងដែលនឹងបញ្ជូនប្រេងនោះទៅប្រទេសសិង្ហបុរី ដើម្បីធ្វើការចម្រាញ់ជាប្រេងសាំង។ អភិបាលក្រុងព្រះសីហនុបានប្រាប់ក្រុមហ៊ុនឃែម-ឆាយណាថា គាត់ចង់ដំឡើងពន្ធប្រចាំឆ្នាំ ពីមួយលានដុល្លាក្នុងមួយឆ្នាំទៅពីរលានដុល្លាក្នុងមួយឆ្នាំ។ ក្រុមហ៊ុនឃែម-ឆាយណាជឿថា ខ្លួនបង់ពន្ធប្រចាំឆ្នាំលើសពីគ្រប់គ្រាន់ទៅហើយ និងចង់រក្សាអត្រាពន្ធឱ្យនៅត្រឹមមួយលានដុល្លានោះដដែល។ ប្រសិនបើអ្នកជាមេធាវីសម្រាប់ក្រុមហ៊ុន ឃែម-ឆាយណា តើអ្នកអាចធ្វើអ្វីបានខ្លះ?

ស្វែងរកផលប្រយោជន៍ណាដែលដូចគ្នា។ អភិបាលក្រុងចង់បានប្រាក់។ ប្រាក់នេះ អាចជួយដល់ការចំណាយលើអាគារសាលាក្រុងថ្មី ស្ថានីយពន្លត់អគ្គិភ័យថ្មី និងផ្លូវថ្នល់ថ្មី។ ប៉ុន្តែអភិបាលក្រុងមិនអាចយកពន្ធពីក្រុមហ៊ុន ឃែម-ឆាយណាតែមួយ មកចំណាយលើផ្នែកទាំងនេះបានទេ។ ក្រុមហ៊ុនឃែម-ឆាយណា មានចំណាប់អារម្មណ៍ចង់ឱ្យក្រុមហ៊ុនចម្រាញ់ប្រេង ឃែម-ចាភែន (Cam-Japan) ធ្វើការសាងសង់រោងចក្រចម្រាញ់ប្រេងថ្មីមួយ នៅកំពង់ផែក្រុងព្រះសីហនុ។ ប្រសិនបើមាន រោងចក្រចម្រាញ់ប្រេងនៅក្រុងព្រះសីហនុ ក្រុមហ៊ុនឃែម-ឆាយណា អាចមានលទ្ធភាពលក់ប្រេងឆៅនៅក្នុងស្រុកបានយ៉ាងងាយស្រួល ដោយមិនចាំបាច់ចំណាយថ្លៃដឹកជញ្ជូនទៅប្រទេសសិង្ហបុរី។ អភិបាលក្រុងក៏ចង់ឱ្យក្រុមហ៊ុន ឃែម-ចាភែន បោះទីតាំងនៅក្រុងព្រះសីហនុដែរ ពីព្រោះវាអាចផ្តល់ការងារថ្មីរាប់សិបពាន់ និងកែលម្អសេដ្ឋកិច្ចក្នុងមូលដ្ឋានបាន។ វាក៏ផ្តល់ជាមូលដ្ឋានពន្ធកាន់តែធំផងដែរ។

ដូច្នេះមេធាវីរបស់ក្រុមហ៊ុនឃែម-ឆាយណាអាចធ្វើសម្ពើ ដែលប្រើប្រាស់ផលប្រយោជន៍ដែលដូចគ្នារវាងភាគីទាំងពីរ។ ក្រុមហ៊ុនឃែម-ឆាយណា និងអភិបាលក្រុង អាចធ្វើការរួមគ្នាដើម្បីទាក់ទាញក្រុមហ៊ុន ឃែម-ចាភែន មកកាន់ក្រុងព្រះសីហនុ។ អភិបាលក្រុង ប្រហែលជាអាចផ្តល់ការអនុគ្រោះពន្ធពិសេសសម្រាប់ការវិនិយោគថ្មីៗនៅកំពង់ផែ ក្រុងព្រះស៊ីហនុ (ដូចជារោងចក្រចម្រាញ់ប្រេងរបស់ក្រុមហ៊ុន ឃែម-ចាភែន) ហើយក៏ប្រហែលជាអាចរក្សាអត្រាពន្ធក្រុមហ៊ុនឃែម-ឆាយណា ឱ្យនៅត្រឹមមួយលានដុល្លាដដែល **ប្រសិនបើ** ភាគីទាំងពីរបញ្ចុះបញ្ចូលឱ្យក្រុមហ៊ុនឃែម-ចាភែន សាងសង់រោងចក្រនៅទីនោះដោយជោគជ័យ។ ការនេះនឹងជួយឱ្យមានអត្រាពន្ធ កាន់តែទាប សម្រាប់ក្រុមហ៊ុន ឃែម-ឆាយណា និងអត្រាពន្ធទាបសម្រាប់ក្រុមហ៊ុន ឃែម-ចាភែន ប៉ុន្តែនៅតែមានចំណូលពន្ធសរុបគ្រប់គ្រាន់ដដែល សម្រាប់ផែនការអភិវឌ្ឍន៍របស់អភិបាលក្រុង។

សូម្បីនៅក្នុងស្ថានភាពលំបាកបំផុត ក៏ភាគីវិវាទនៅតែអាចមានផលប្រយោជន៍រួមខ្លះដែរ។ វិវាទតែងតែត្រូវការការចំណាយខ្ពស់ និងពេលវេលាច្រើនសម្រាប់ដោះស្រាយ។ ការចំណាយដ៏ខ្ពស់ លើកម្រៃមេធាវីតែងតែអាចកើតមាន។ ទោះជាវិវាទនោះមានទំហំតូចក៏ដោយ ក៏នៅតែអាចនឹងត្រូវចំណាយប្រាក់ច្រើនដែរ។ ឧទាហរណ៍ ប្រសិនបើម្ចាស់ផ្ទះ និងអ្នកជួលផ្ទះវិវាទគ្នាអំពីរឿងដែលថា អ្នកណានឹងត្រូវជាអ្នកជួសជុលក្បាលរូប៊ីណេទឹកដែលលេច ក្នុងរយៈពេលយូរពេកនោះ ទឹកដែលស្រក់អាចម្តងបន្តិចៗបណ្តាលឱ្យមានការខូចខាតជាអចិន្ត្រៃយ៍មិនខាន។ អ្នកជិតខាងពីរនាក់ដែលខឹងគ្នាអំពី

បញ្ហាសម្លេងរំខាន អាចខាតបង់ការសំរាកបស់ខ្លួន និងឱកាសដែលកូនរបស់ពួកគេអាចលេងជាមួយគ្នា។ ដូច្នេះ សូម្បីតែក្នុងករណីទាំងនេះ ក៏ភាគីមានផលប្រយោជន៍រួមក្នុងការបញ្ចប់វិវាទដែរ ។

## ២) ផលប្រយោជន៍ខុសគ្នា

មានពេលខ្លះ ផលប្រយោជន៍ដែលខុសគ្នាក៏បង្ហាញនូវឱកាសផ្សេងៗគ្នាសម្រាប់ផលចំណេញផងដែរ ។ ចូរគិតដល់ឧទាហរណ៍អំពីផារី និងសុជាតា ដែលប្រកែកគ្នាពីរឿងផ្លែក្រូច ។ ផលប្រយោជន៍ របស់ផារីគឺស្វែងរកគ្រឿងផ្សំមកធ្វើជានំរបស់ខ្លួន រីឯផលប្រយោជន៍របស់សុជាតាវិញគឺប្រើប្រាស់ទឹកក្រូចសម្រាប់ជាភេសជ្ជៈ ។ ផលប្រយោជន៍របស់ពួកគេគឺខុសគ្នា ប៉ុន្តែវាបានក្លាយជាឱកាសមួយ សម្រាប់ឱ្យពួកគេស្រុះស្រួលគ្នា។ ប្រសិនបើគេទាំងពីរមានផលប្រយោជន៍ដូចគ្នាដូចជាការធ្វើនំជាដើមនោះ គឺមានន័យថាពួកគេអាចកាន់តែលំបាកក្នុងដោះស្រាយវិវាទរបស់ពួកគេ។ ប៉ុន្តែ ដោយសារតែពួកគេមានផលប្រយោជន៍ផ្សេងគ្នា ដំណោះស្រាយកាន់តែមានភាពងាយស្រួលទៅវិញ។ ហេតុដូច្នេះ ទោះបីជាភាគីមានផលប្រយោជន៍ផ្សេងគ្នាក៏ដោយ ក៏គេនៅតែអាចឈានទៅរកដំណោះស្រាយដែរ ។

នេះគឺជាឧទាហរណ៍ពីរទៀត ស្តីពីផលប្រយោជន៍ខុសគ្នាដែលអាចនឹងត្រូវបានគេយកប្រើប្រាស់ ក្នុងការដោះស្រាយៈ

- ម៉ារ៉ាត្រូវការទិញម៉ូតូមួយគ្រឿងជាបន្ទាន់ដើម្បីជិះទៅធ្វើការ និងត្រឡប់មកផ្ទះវិញ។ ប៉ុន្តែគាត់មិនមានប្រាក់៥០០ដុល្លា សម្រាប់ទិញម៉ូតូដែលស៊ីណែតលក់ទេ។ ស៊ីណែតចង់លក់ម៉ូតូរបស់នាងក្នុងតម្លៃខ្ពស់បំផុត បើអាចទៅរួច ។

  ផលប្រយោជន៍របស់ម៉ារ៉ា : ប្រើប្រាស់ម៉ូតូជាបន្ទាន់ ។

  ផលប្រយោជន៍របស់ស៊ីណែត : បង្កើនតម្លៃសរុបដែលបានមកពីការលក់ម៉ូតូជាអតិបរមា។

  ដំណោះស្រាយៈ ពួកគេទាំងពីរព្រមព្រៀងថា ម៉ារ៉ានឹងទិញ ហើយធ្វើជាម្ចាស់ម៉ូតូភ្លាម និងបង់ប្រាក់ចំនួន ៦០០ ដុល្លា ឱ្យដល់ស៊ីណែត ក្នុងរយៈពេល១២ខែខាងមុខ (៥០ដុល្លាក្នុងមួយខែ) ជំនួសឱ្យតម្លៃ៥០០ដុល្លាដែលស៊ីណែតចង់លក់។

- ម៉ារ៉ាត្រូវការកាត់បន្ថយចំណាយផ្សេងៗ ពីព្រោះអាជីវកម្មរបស់គាត់ត្រូវបានពង្រីកលឿនពេក។ ម្តងម្កាលគាត់បញ្ជាទិញសម្លៀកបំពាក់ធ្វើអំពីសូត្រ ពីស៊ីណែត។ ស៊ីណែតព្រួយបារម្ភថានាងមិនអាចលក់ផលិតផលបានគ្រប់គ្រាន់ សម្រាប់ឱ្យអាជីវកម្មរបស់នាងបានបន្តដល់ពេលអនាគត។

  ផលប្រយោជន៍របស់ម៉ារ៉ា : កាត់បន្ថយចំណាយ និងសន្សំសំចៃប្រាក់។

  ផលប្រយោជន៍របស់ស៊ីណែតៈ សុវត្ថិភាពរយៈពេលយូរចំពោះអាជីវកម្មរបស់នាង។

  ដំណោះស្រាយៈ ម៉ារ៉ាយល់ព្រមបង្កើនការទិញពីស៊ីណែត និងធ្វើការទិញជាទៀងទាត់នាពេលអនាគត។ ស៊ីណែតព្រមបញ្ចុះតម្លៃ ២០% សម្រាប់ផលិតផលរបស់នាង ជាថ្នូរនឹងការបញ្ជាទិញដែលទៀងទាត់រយៈពេលយូរ។

### ៣) ឧបសគ្គដទៃទៀត

ក្រៅពីបញ្ហាវាំងស្ទះពាក់ព័ន្ធនឹងផលប្រយោជន៍ដែលដូចគ្នា ឬខុសគ្នា ភាគីអាចមានការវាយតម្លៃផ្សេងពីគ្នា ចំពោះអង្គហេតុនានា។ ការវាយតម្លៃលើអង្គហេតុដែលខុសគ្នានោះ អាចជាឧបសគ្គមួយ ប៉ុន្តែក៏អាចជាឱកាសផងដែរ។ ឧទាហរណ៍ នៅក្នុងវិវាទមួយដែលពាក់ពន្ធនឹងមេដឹកនាំសហជីពស្តីពីសម្ទើសុំប្រាក់ឈ្នួលណាមួយ ដែលមានអត្ថប្រយោជន៍បំផុតចំពោះកម្មករនិយោជិតនៃរោងចក្រមួយ មេដឹកនាំទាំងពីរអាចដោះស្រាយវិវាទនេះដោយដាក់សម្ទើ នោះឱ្យសមាជិកធ្វើការបោះឆ្នោត។

ភាគីវិវាទអាចមានកម្រិតអត់ធ្មត់ចំពោះភាពប្រថុយប្រថានផ្សេងៗគ្នា។ នៅក្នុងវិវាទអំពីប្រាក់បៀវត្សរ៍របស់កីឡាករបាល់ទាត់ម្នាក់ ក្រុមបាល់ទាត់អាចព្រួយបារម្ភអំពីការប្រថុយលើការ ចំណាយប្រាក់ច្រើនពេកចំពោះកីឡាករណាដែលមិនផ្តល់លទ្ធផលជាវិជ្ជមាន។ កីឡាករអាចប្រថុយ យកប្រាក់ខែទាបជាថ្នូរនឹងការលើកទឹកចិត្តមួយចំនួន។ ហេតុនេះក្រុមអាចស្នើឱ្យប្រាក់ខែក្នុងតម្លៃ ១,០០០ដុល្លាក្នុងមួយខែ ជំនួសឱ្យ២,០០០ដុល្លា តាមដែលកីឡាករនោះទាមទារ។ ផ្ទុយទៅវិញ ក្រុមក៏យល់ព្រមបន្ថែមប្រាក់ចំនួន២,០០០ដុល្លាទៀត នៅរាល់ខែណាដែលកីឡាករនោះទាត់ចូលចំនួនពីរគ្រាប់។ តាមវិធីនេះ កីឡាករជាអ្នកទទួលរ៉ាប់រងហានិភ័យហិរញ្ញវត្ថុដែលខ្លួនមិនអាចផ្តល់ លទ្ធផលវិជ្ជមានសម្រាប់ក្រុម។

### ឃ) ធ្វើឱ្យការសម្រេចចិត្តមានភាពងាយស្រួល[៧៧]

ដំណោះស្រាយវិវាទតម្រូវឱ្យភាគីទាំងពីរយល់ព្រមជាយថាហេតុទៅលើអ្វីមួយ។ ការងាររបស់អ្នក ក្នុងនាមជាអ្នកចរចា គឺត្រូវព្យាយាមបញ្ចុះបញ្ចូលភាគីម្ខាងទៀតឱ្យយល់ព្រម។ ការធ្វើបែបនេះ នឹងរឹតតែងាយស្រួលទៅទៀត ប្រសិនបើលោកអ្នកអាចពិចារណាលើវិវាទចេញពីជំហររបស់ភាគីម្ខាងទៀត ហើយព្យាយាមស្នើឡើងនូវដំណោះស្រាយដែលនឹងមានភាពទាក់ទាញចំពោះភាគីម្ខាងទៀត។

ជួនកាល វាគ្រាន់តែជាបញ្ហានៃរបៀបរៀបចំជម្រើសតែប៉ុណ្ណោះ។ ជាទូទៅ ការបញ្ឈប់អ្វីមួយមិនឱ្យចាប់ផ្តើម តែងមានភាពងាយស្រួលជាងការបញ្ឈប់នូវអ្វីមួយដែលកើតឡើងទៅហើយ។ ដូចគ្នានេះ ការបញ្ឈប់នូវអ្វីដែលកំពុងតែកើតឡើង តែងមានភាពងាយស្រួលជាងការចាប់ផ្តើមនូវអ្វីដែលថ្មី។ ដូចជាឧទាហរណ៍ថា ប្រសិនបើកម្មករ-និយោជិតរោងចក្រកាត់ដេរចង់ហាត់ប្រាណក្បាច់គុណតៃជិនៅពេលព្រឹក វាប្រហែលជាងាយស្រួលក្នុងការដែលក្រុមហ៊ុនព្រមព្រៀងមិនរារាំងដល់កម្មវិធីហាត់ប្រាណសាកល្បង ដែលដំណើរការដោយសហជីព ឬកម្មករនិយោជិត ជាជាងការដែលឱ្យក្រុមហ៊ុនយល់ព្រមផ្តួចផ្តើមកម្មវិធីតៃជិដោយខ្លួនឯង។

ជាងនេះទៅទៀត អ្វីដែលមានជាអាទិ៍ អាចមានសារៈប្រយោជន៍ ចំពោះលទ្ធភាពទទួលយកសម្ទើរបស់អ្នក។ ប្រសិនបើសម្ទើរបស់អ្នក ធ្លាប់កើតមានពីមុនមកហើយនោះ វានឹងមើលទៅហាក់ដូចជាមានភាពត្រឹមត្រូវចំពោះភាគីម្ខាងទៀត។ ដូច្នេះចូរព្យាយាមបង្ហាញដំណោះស្រាយ តាមរបៀបមួយដែលមើលទៅសមស្របជាមួយនឹងអ្វីដែលភាគីម្ខាងទៀតបាននិយាយ ឬធ្វើ។ តួយ៉ាងដូចជានៅក្នុងឧទាហរណ៍ខាងលើ កម្មករ-និយោជិត អាចយោងទៅលើសៀវភៅ

---

[៧៧] *ដូចមុន* ទំព័រ ៧៦-៨០។

ណែនាំរបស់ក្រុមហ៊ុន ដែលលើកសរសើរពីគុណសម្បត្តិនៃកំលាំងពលកម្មដែលមានសុខភាពល្អ។ ឬអាចថា គ្លីនិកសុខភាពរបស់រោងចក្រមានឯកសារដែលណែនាំថា តែជិគឺជាវិធានការបង្ការដ៏សំខាន់។

មានបាតុភូតចិត្តសាស្ត្រដែលពាក់ព័ន្ធមួយទៀត ហៅថា "ទំនាស់ចិត្តដោយភាពជ្រុលនិយម"[៧៨]។ តាមការស្រាវជ្រាវបានបង្ហាញថា មនុស្សកាន់តែឱ្យតម្លៃទៅជម្រើសណាមួយ ប្រសិនបើមានជម្រើសដែល "ជ្រុលនិយម" ផ្សេងៗស្ថិតនៅលាយលំជាមួយវា។ ប្រការនេះត្រូវបានលើកមកបង្ហាញនៅក្នុងការសិក្សាមួយ ដែលពាក់ព័ន្ធនឹងការទិញម៉ាស៊ីនថតរូប។[៧៩] អ្នកចូលរួមក្នុងការស្រាវជ្រាវនោះត្រូវបានស្នើឱ្យវាយតម្លៃថា ខ្លួនគួរទិញម៉ាស៊ីនថតរូបណាមួយ។ ពួកគេត្រូវបានបែងចែកជាពីរក្រុម។ ក្រុមទីមួយត្រូវបានផ្ដល់នូវជម្រើសចំនួនពីរគឺៈ ម៉ាស៊ីនថតគុណភាពអន់ តម្លៃថោក ឬ ម៉ាស៊ីនគុណភាពមធ្យម តម្លៃមធ្យម។ ក្រុមទីពីរត្រូវបានផ្ដល់ជម្រើសទាំងពីរនេះដែរ ព្រមទាំងជម្រើសទីបីមួយទៀតគឺៈ មាស៊ីនថត គុណភាពខ្ពស់ តម្លៃខ្ពស់។

នៅក្នុងក្រុមទីមួយ អ្នកចូលរួមពាក់កណ្ដាលជ្រើសរើសម៉ាស៊ីនថតគុណភាពអន់ និងពាក់កណ្ដាលទៀតជ្រើស-រើសម៉ាស៊ីនថតគុណភាពមធ្យម។ ប៉ុន្តែនៅក្នុងក្រុមទីពីរ ដែលម៉ាស៊ីនថតគុណភាពមធ្យមត្រូវបានផ្ដល់ជាជម្រើសមួយអមជាមួយម៉ាស៊ីនដែលមានតម្លៃថោក និងតម្លៃថ្លៃនោះ ប្រហែលបីភាគបួននៃសមាជិកក្រុម ជ្រើសរើសយកម៉ាស៊ីនថតគុណភាពមធ្យម។[៨០]

***មេរៀននៅត្រង់នេះគឺថា មនុស្សតែងមានទំនោរទៅរកអ្វីដែលមើលទៅហាក់ដូចជាជម្រើសដែលនៅកណ្ដាល និងទាស់ចិត្តចំពោះជម្រើសណាដែល "ជ្រុលនិយម "។***

នៅពេលបង្ហាញអំពីជម្រើសសម្រាប់ដោះស្រាយវិវាទ កលយុទ្ធដ៏វៃឆ្លាតនោះគឺត្រូវគិតពីការបន្ថែមជម្រើសជ្រុលនិយមមួយចំនួនទៀត ដើម្បីឱ្យភាគីម្ខាងទៀតមើលឃើញជម្រើសកណ្ដាលរបស់អ្នក កាន់តែមានភាពគួរឱ្យពិចារណាឡើង។ ហេតុនេះ នៅក្នុងឧទាហរណ៍ខាងលើស្ដីពីក្បាច់គុណតៃជិ កម្មករ-និយោជិតអាចស្នើថា ក) ក្រុមហ៊ុន (ដែលមិនមែនជាសហជីព) គឺជាអ្នករៀបចំវគ្គហ្វឹកហាត់តៃជិ ឬ ខ) ក្រុមហ៊ុនបង់ប្រាក់ឱ្យនិយោជិត ចូលវគ្គហ្វឹកហាត់តៃជិដោយខ្លួនឯងនៅឯមជ្ឈមណ្ឌលសហគមន៍ណាមួយ។ នៅពេលប្រៀបធៀបជាមួយជម្រើសជ្រុលនិយមទាំងពីរនេះ គំនិតដែលថាក្រុមហ៊ុនមិនត្រូវរារាំងដល់កម្មវិធីតៃជិដែលរៀបចំឡើងដោយកម្មករ-និយោជិត ឬសហជីពនោះ ហាក់ដូចជាមានលក្ខណៈកាន់តែអាចទទួលយកបានថែមទៀត។

ផ្ទុយទៅវិញ ក៏មានការស្រាវជ្រាវគួរឱ្យកត់សម្គាល់ខ្លះ ដែលចង្អុរបង្ហាញថា ការបង្ហាញដល់មនុស្សម្នាក់នូវ *ជម្រើសដ៏ច្រើនពេក* ក៏អាចបង្កបញ្ហាបានដែរ។ គេហៅបាតុភូតទាំងអស់នេះថាជា "ទំនាស់ចិត្តនឹងការសម្រេចចិត្ត" និង "ការបន្ថយតម្លៃនៃជម្រើស" ដែលនឹងត្រូវលើកយកមកពិភាក្សានៅក្នុងជំពូកស្ដីពីសន្ទានកម្មនៃសៀវភៅនេះ។[៨១]

---

[៧៨] Itamar Simonson និង Amos Tversky, "ជម្រើសក្នុងបរិបទៈ ភាពផ្ទុយគ្នានៃថ្នូរ និងទំនាស់ចិត្តដោយភាពជ្រុលហួសហេតុ", *ទិនានុប្បវត្តិនៃការស្រាវជ្រាវទីផ្សារ* លេខ២៩ ទំព័រ ២៨១, ២៩២ (ឆ្នាំ១៩៩២)។

[៧៩] *ដូចមុន។*

[៨០] *ដូចមុន។*

[៨១] *សូមមើល* ជំពូកទី៣ ស្ដីពីសន្ទានកម្ម *ខាងក្រោម* ។

## ៥. *សង្កត់ធ្ងន់លើការប្រើប្រាស់លក្ខណៈវិនិច្ឆ័យមិនលម្អៀង*[៨២]

ជួនកាល នៅពេលដែលការចរចាប្រែជាតឹងតែង ភាគីក៏ងាកមកតស៊ូជាមួយគ្នាដោយឆន្ទៈ ដូចជាថា "យ៉ាងច្រើនខ្ញុំអាចព្រមត្រឹម៥០០ដុល្លាប៉ុណ្ណោះ" ។ នេះមិនមែនជាវិធីប្រសើរបំផុតសម្រាប់ដោះស្រាយវិវាទទេ ពីព្រោះដំណោះស្រាយដែលផ្អែកលើមូលដ្ឋានរបៀបនេះ មានន័យថា ភាគីម្ខាងត្រូវចុះចាញ់ហើយអាម៉ាសមុខ ទើបឈានទៅដល់ដំណោះស្រាយនោះបាន ។ ប្រការនេះអាចបង្កគ្រោះថ្នាក់ដល់ទំនាក់ទំនងរយៈពេលវែងរបស់ភាគីវិវាទ ។ ភាគីដែលចុះចាញ់អាចមានការប៉ះទង្គិចផ្លូវចិត្ត ហើយគុំគួនចំពោះភាគីម្ខាងទៀត ។ នៅពេលក្រោយ ភាគីនោះប្រហែលជានឹងប្រកាន់ជំហរកាន់តែរឹងថែមទៀត ។ ឬក៏ប្រហែលជា ភាគីនោះនឹងលែងទទួលស្គាល់ការព្រមព្រៀង ហើយមិនគោរពតាមលក្ខខណ្ឌដែលបានព្រមព្រៀងក៏អាចថាបាន ។

ការប្រើប្រាស់លក្ខណៈវិនិច្ឆ័យមិនលម្អៀងសម្រាប់ដំណោះស្រាយបញ្ហា ធ្វើឱ្យមនុស្សយល់ថាដំណោះស្រាយសម្រាប់ខ្លួនមានភាពយុត្តិធម៌ ។ ប្រសិនបើ សិទ្ធី និងអ្នកម៉ៅការសំណង់របស់គាត់មានវិវាទនឹងគ្នាអំពីជម្រៅគ្រឹះ ដែលអ្នកម៉ៅការសំណង់នោះត្រូវជីកសម្រាប់ផ្ទះរបស់គាត់ ភាគីទាំងពីរត្រូវស្វែងរកលក្ខណៈវិនិច្ឆ័យមិនលម្អៀង ដើម្បីរៀបចំដំណោះស្រាយរបស់ពួកគេ ។ ប្រហែលជាពួកគេអាចពិនិត្យមើល ថាតើមានបទដ្ឋានសុវត្ថិភាពរបស់រដ្ឋាភិបាលសម្រាប់ដីប្រភេទនេះដែរឬទេ ។ ផ្ទុយពីនោះ ពួកគេអាចស្វែងរកថា តើបទដ្ឋានឧស្សាហកម្មស្ថិតនៅក្នុងសង្កាត់នោះមានអ្វីខ្លះ ។ ឬក៏ប្រហែលជាពួកគេអាចស្វែងរកអ្នកជំនាញឱ្យមកផ្តល់ការយល់ឃើញរបស់ខ្លួន ។ ទោះជាពួកគេប្រើបទដ្ឋានណាក៏ដោយ ប្រសិនបើផ្អែកវាលើលក្ខណៈវិនិច្ឆ័យមិនលម្អៀងនោះ ភាគីវិវាទនឹងយល់ឃើញថាវាមានភាពយុត្តិធម៌ ។ ប្រសិនបើវាត្រូវបានយល់ឃើញថាមានភាពយុត្តិធម៌នោះ វាកាន់តែអាចរក្សាទំនាក់ទំនងរបស់ពួកគេដែរ ។ ហើយភាគីក៏កាន់តែអាចព្រមព្រៀងថែមទៀត ប្រសិនបើគេមើលឃើញថាវាយុត្តិធម៌ ។

> *វាជាការងាយស្រួលក្នុងការយោគយល់ និងសុខចិត្តចាញ់ ដោយសារបទដ្ឋានយុត្តិធម៌មិនលម្អៀង ជាជាងដោយសារឆន្ទៈរបស់បុគ្គលម្ខាងទៀត ។*

ភាពយុត្តិធម៌គឺជាផ្នែកដ៏សំខាន់នៃការចរចាដែលជោគជ័យ ។ ការសិក្សានានាបង្ហាញឱ្យឃើញថា មនុស្សនឹងបដិសេធការព្រមព្រៀង ទោះបីជាមានផលប្រយោជន៍ប្រសើរបំផុតរបស់ខ្លួនក៏ដោយ ពីព្រោះពួកគេមានអារម្មណ៍ថាវាមិនមានភាពយុត្តិធម៌ចំពោះពួកគេ ។ ដូចជាឧទាហរណ៍ នៅក្នុងការសិក្សាមួយ គេបានផ្តល់ប្រាក់ចំនួន១០ដុល្លាដល់ មនុស្សមួយចំនួន ហើយប្រាប់ថាពួកគេត្រូវចែកប្រាក់នោះជាមួយនឹងមនុស្សទីពីរដែលមិនស្គាល់គ្នា ។ អ្នកទីមួយអាចជ្រើសរើសបំណែងចែកបែបណាដែលខ្លួនចង់បាន ហើយអ្នកទាំងពីរត្រូវបានអនុញ្ញាតឱ្យរក្សាទុកប្រាក់នោះ ប៉ុន្តែលុះត្រាតែអ្នកទីពីរយល់ព្រមចំពោះបំណែងចែករបស់អ្នកទីមួយនោះសិន ។ នឹងមិនមានការចរចា ឬបំណែងចែកក្រៅពីនោះឡើយ ឯអ្នកទីពីរមានសិទ្ធិត្រឹមតែអាចទទួលយក ឬបដិសេធបំណែងចែកដែលបានស្នើឡើងតែប៉ុណ្ណោះ ។ ប្រសិនបើអ្នកទីពីរបដិសេធបំណែងចែកនោះ អ្នកទាំងពីរនឹងមិនបានទទួលអ្វីទាំងអស់ ។ ជាតក្កនុលោម អ្នកទីពីរនោះគួរតែព្រមទទួលយកគ្រប់ចំណែកទាំងអស់

[៨២] Fisher, et al., កំណត់សម្គាល់ *ខាងលើ* លេខ៣១, នៅទំព័រ ៨១-៩៤ ។

(សូម្បីតែបានតិចជាង១ដុល្លាក្តី) ពីព្រោះខ្លួនគង់នឹងទទួលប្រាក់បន្ថែមដដែល បើទោះជាមានបំណែងចែកបែបណាក៏ដោយ ជាងជាងការដែលពួកគេបដិសេធ (ព្រោះបើដូច្នេះ ពួកគេនឹងមិនបានទទួលអ្វីទាំងអស់)។ ក៏ប៉ុន្តែ មនុស្សភាគច្រើនបែរជាបដិសេធចំពោះចំណែកដែលតិចជាង ៥ដុល្លា ពីព្រោះពួកគេមិនជឿថាវាមានភាពយុត្តិធម៌ឡើយ។[៨៣]

### ក)បទដ្ឋានយុត្តិធម៌

មានលក្ខណៈវិនិច្ឆ័យមិនលម្អៀងពីរប្រភេទ គឺបទដ្ឋានយុត្តិធម៌ និងនីតិវិធីយុត្តិធម៌។ ឧទាហរណ៍ស្តីពីបទដ្ឋានយុត្តិធម៌មានដូចខាងក្រោម:

> រថយន្តរបស់ អឿង ប៉ះរថយន្តរបស់ វង្ស ហើយបណ្តាលឱ្យរថយន្តរបស់ វង្ស ខូចខាតយ៉ាងធ្ងន់ធ្ងរ។ វង្ស និង អឿង សម្រេចចិត្តចរចាអំពីចំនួនទឹកប្រាក់ដែល អឿង ត្រូវសងទៅ វង្ស។ វង្ស អាចស្នើឡើងនូវបទដ្ឋានមិនលម្អៀង និងយុត្តិធម៌មួយចំនួន ដើម្បីកំណត់អត្រាប្រាក់សំណង:
>
> - ថ្លៃជួសជុល : តើត្រូវ វង្ស ចំណាយប៉ុន្មានសម្រាប់ការជួសជុលរថយន្តនោះ ?
> - ថ្លៃទិញថ្មី : តើ វង្ស ត្រូវចំណាយប៉ុន្មានដើម្បីទិញរថយន្តប្រហាក់ប្រហែលនោះ?
> - តម្លៃបាត់បង់ : តើរថយន្តដែលទទួលរងគ្រោះថ្នាក់នោះ ត្រូវធ្លាក់ចុះតម្លៃចំនួនប៉ុន្មាន?

### ខ) នីតិវិធីយុត្តិធម៌

នីតិវិធីយុត្តិធម៌ ជាប្រភេទមួយទៀតនៃលក្ខណៈវិនិច្ឆ័យមិនលម្អៀង។ ឧទាហរណ៍ថា ប្រសិនបើកុមារពីរនាក់នឹងវាយគ្នាដណ្តើមនំខេកមួយដុំនោះ ពួកគេអាចព្រមព្រៀងលើនីតិវិធីយុត្តិធម៌ដោយក្នុងនោះ: ណានី ជាអ្នកកាត់នំនោះ ឯ ធឿន ជាអ្នកជ្រើសរើសចំណែកណាមួយនៃនំទាំងពីរដុំ ដែលខ្លួនចង់បាន។ ឧទាហរណ៍មួយទៀតគឺសម្រាប់មនុស្សពីរនាក់ដែលដាក់វេនគ្នាដើម្បីទទួលយកអ្វីមួយដែលត្រូវបាន។ តួយ៉ាងដូចជា ប្រសិនបើសមាជិកស្ថាបនិកពីរនាក់នៃក្លឹបមួយចង់ក្លាយជាអ្នកនាំពាក្យក្លឹបនោះ ពួកគេអាចសម្រេចថា ឱ្យមនុស្សម្នាក់ទទួលមុខតំណែងនេះជាមុនសិន លុះមួយឆ្នាំក្រោយមក មនុស្សម្នាក់ទៀតនឹងទទួលមុខតំណែងនេះវិញម្តង។ គំនិតមួយទៀត គឺឱ្យភាគីវិវាទជ្រើសរើសយកលទ្ធផលចុងក្រោយជាមុនសិន ទើបធ្វើការសម្រេចចិត្តថាតើអ្នកណាស័ក្តិសមនឹងអ្វី។ តួយ៉ាងដូចជាថា បើមានអ្នកជិតខាងគ្នាពីររូប ឈ្លោះគ្នាដណ្តើមភាពជាម្ចាស់កម្មសិទ្ធិលើដីនៅចន្លោះផ្ទះរបស់ពួកគេ ពួកគេអាចព្រមព្រៀងគ្នាថាភាគីម្ខាងនឹងក្លាយជាម្ចាស់កម្មសិទ្ធិ ប៉ុន្តែភាគីម្ខាងទៀតនឹងមានសេរីភាពជាអចិន្ត្រៃយ៍ក្នុងការប្រើប្រាស់ដីនេះសម្រាប់ការធ្វើដំណើរទៅមក។ ក្រោយពីបានកំណត់រួចហើយ ការសម្រេចអំពីបញ្ហាភាពជាម្ចាស់កម្មសិទ្ធិមិនមានការលំបាកទៀតឡើយ។ ជាទ្រឹស្តី ប្រការនេះធ្វើឱ្យភាគីនីមួយៗកាន់តែមានហេតុផលថែមទៀត។

ពាក់ព័ន្ធនឹងការបង្ហាញសម្មើ ប្រការដែលសំខាន់គឺត្រូវព្យាយាមរៀបចំការចរចានោះ ឱ្យទៅជាការស្វែងរករួមគ្នានូវលក្ខណៈវិនិច្ឆ័យយុត្តិធម៌ និងមិនលម្អៀង។ ដូចបានរៀបរាប់ខាងលើ ប្រសិនបើអ្នក និងភាគីម្ខាងទៀតអាចធ្វើការ

---

[៨៣] *សូមមើល* RICHARD THALER, **បណ្ណាសាររបស់អ្នកឈ្នះ: បរមតិ និងអប្រក្រតីភាពនៃជីវិតសេដ្ឋកិច្ច** (Free Press ed., ឆ្នាំ១៩៩១)។

រួមគ្នាដើម្បីស្វែងរកលក្ខណៈវិនិច្ឆ័យសមស្របនោះ អ្នកកាន់តែមានលទ្ធភាពឈានទៅដល់ការព្រមព្រៀង។ វាជាការល្អដែលត្រូវព្យាយាមធ្វើឱ្យភាគីម្ខាងទៀតយល់ព្រមចំពោះលក្ខណៈវិនិច្ឆ័យ នៅពេលផ្តើមការចរចា។ ឧទាហរណ៍ ប្រសិនបើការចរចាពាក់ព័ន្ធនឹងការទិញផ្ទះ អ្នកលក់អាចទាមទារតម្លៃ ដោយផ្អែកលើផ្ទះស្រដៀងគ្នានៅលើផ្លូវតែមួយ។ គេហៅវិធីថាជាការប៉ាន់តម្លៃផ្អែកលើ "ហាងឆេង"។ ប្រសិនបើវាជាលក្ខណៈវិនិច្ឆ័យមិនលម្អៀងនោះ អ្នកទិញអាចនឹងស៊ើបរកហាងឆេងផ្សេងទៀតនៅលើផ្លូវក្បែរៗនោះ ដែលទាញទៅរកតម្លៃកាន់តែទាប។ អ្នកលក់មិនអាចតវ៉ាថាវាអយុត្តិធម៌ ឬមិនពាក់ព័ន្ធនោះទេ ពីព្រោះគាត់បានអះអាងរួចទៅហើយថាការប៉ាន់តម្លៃផ្អែកលើហាងឆេង គឺជាវិធីយុត្តិធម៌ និងមិនលម្អៀង ក្នុងការកំណត់តម្លៃផ្ទះរបស់គាត់។

## ៥. ដំណាក់កាលនៃដំណើរការចរចា

ក្រៅពីការហាមឃាត់ចំពោះការបំភ័ន្ត ឬបង្ខិតបង្ខំ ដំណើរការចរចាមិនមានប្រើវិធានអ្វីឱ្យជាក់លាក់នោះទេ។ មិនមានច្បាប់ ឬលក្ខន្តិកៈណាមួយដែលណែនាំអំពីដំណើរការកាចរចាឡើយ។ ប៉ុន្តែគេអាចស្វែងយល់អំពីដំណើរការរបស់វាបានកាន់តែប្រសើរ តាមរយៈដំណាក់កាលចំនួនប្រាំដូចខាងក្រោម៖

- ➢ ដំណាក់កាលត្រៀម
- ➢ ដំណាក់កាលផ្តើម
- ➢ ដំណាក់កាលព័ត៌មាន
- ➢ ដំណាក់កាលបែងចែក/ផ្អែកលើផលប្រយោជន៍
- ➢ ដំណាក់កាលបញ្ចប់

ការចរចានីមួយៗមានភាពខុសគ្នា។ ចំពោះការទិញទំនិញនៅផ្សារ ភាគច្រើននៃដំណាក់កាលទាំងនេះនឹងកន្លងទៅតែក្នុងរយៈពេលប៉ុន្មាននាទីតែប៉ុណ្ណោះ។ នៅក្នុងការចរចាផ្លូវច្បាប់ស្មុគស្មាញ ដំណាក់កាលទាំងនោះអាចត្រូវការរយៈពេលជាច្រើនថ្ងៃ ឬជាច្រើនសប្តាហ៍ដើម្បីបំពេញ។

### ១. *ដំណាក់កាលត្រៀម*

- ស្វែងរកអង្គហេតុ
- វិភាគច្បាប់
- ស្វែងយល់អំពីផលប្រយោជន៍ និងគោលដៅរបស់អតិថិជន
- កំណត់ BATNA
- ពិចារណាលើការទាមទាររបស់ភាគីដទៃទៀត
- បង្កើតយុទ្ធសាស្ត្រ

ដំណាក់កាលទីមួយនៃការចរចា គឺជាដំណាក់កាលត្រៀម។ នៅក្នុងដំណាក់កាលនេះ ភាគី និងមេធាវីរបស់ខ្លួនត្រូវពិនិត្យមើលរឿងក្តីយ៉ាងប្រុងប្រយ័ត្ន ហើយព្យាយាមធ្វើសេចក្តីសន្និដ្ឋានជាមូលដ្ឋានមួយចំនួន មុននឹងចាប់ផ្តើមដំណើរការចរចា។ ជំហាន ទីមួយរបស់មេធាវី គឺធ្វើការស្រាវជ្រាវ និងស្វែងរកអង្គហេតុដែលពាក់ព័ន្ធនឹងរឿងក្តីទាំងអស់។ ការនេះជាទូទៅមានន័យថា ជាការសម្ភាសជាមួយមនុស្សម្នាក់ ឬច្រើននាក់ដោយផ្ទាល់។ វាក៏អាចពាក់ព័ន្ធនឹងការពិនិត្យមើលឡើងវិញនូវភស្តុតាងជាឯកសារ ដូចជា កិច្ចសន្យា ឬវិក័យប័ត្រផ្សេងៗ។

បន្ទាប់ពីមេធាវីយល់ច្បាស់អំពីអង្គហេតុមក ជំហានបន្ទាប់គឺធ្វើការវិភាគច្បាប់ ដោយផ្អែកលើអង្គហេតុទាំងនោះ។ ច្បាប់អាចមិនមានចម្លើយដែលច្បាប់លាស់។ បើមិនដូច្នោះទេ បទដ្ឋានច្បាប់អាចមានភាពច្បាស់លាស់ ប៉ុន្តែអង្គហេតុអាចមានភាពចំរូងចំរាស់។ ត្រង់ចំណុចនេះ ប្រការដែលសំខាន់គឺ មេធាវីត្រូវព្យាយាមបង្កើតអំណះអំណាងផ្លូវច្បាប់ឱ្យបានច្រើនតាមដែលអាចធ្វើបាន ព្រមទាំងវាយតម្លៃដោយមិនលម្អៀងអំពីចំណុចខ្លាំងនៃអំណះអំណាងទាំងនេះ។

ជំហានបន្ទាប់មកទៀត គឺត្រូវស្វែងយល់អំពីផលប្រយោជន៍ និងគោលដៅរបស់កូនក្តី។ ប្រការនេះទាមទារឱ្យមេធាវីសួរសំណួរជាមូលដ្ឋានបន្ថែមទៀត ដូចជាអាជីវកម្ម សម្ព័ន្ធភាព ការភ័យព្រួយ បំណងប្រាថ្នា និងគោលដៅ របស់កូនក្តី ១៧។ ខាងក្រោមនេះគឺជាបញ្ជីនៃផលប្រយោជន៍មួយចំនួនដែលកូនក្តីអាចមានក្រៅពីបញ្ហាប្រាក់កាស:

- ការរក្សាសម្ងាត់
- សុវត្ថិភាពរាងកាយ
- ការរក្សាកេរ្តិ៍ឈ្មោះ
- ការរក្សាទំនាក់ទំនងល្អជាមួយភាគីម្ខាងទៀត
- ការបន្តការងារ
- ការទទួលស្គាល់ចំពោះកិច្ចប្រឹងប្រែងរបស់កូនក្តីនោះ
- ការទទួលបាននូវការសម្តែងភាពសោកស្តាយ ទឹកចិត្តអាណិតអាសូរ ឬការសុំទោស
- ការមាន "ថ្ងៃឡើងតុលាការ" របស់កូនក្តីនោះ
- ឱ្យភាគីម្ខាងទៀតស្តាប់ និងយល់ពីកូនក្តីនោះ
- ការសង្គ្រោះមុខមាត់
- ការធ្វើឱ្យភាគីម្ខាងទៀតអាម៉ាសមុខ ឬអៀនខ្មាស់ជាសាធារណៈ
- ការចង់ផ្សាភ្ជាប់ខ្លួនទៅនឹងវប្បធម៌ គ្រួសារ ឬអង្គការស្ថាប័នណាមួយ
- ការសបញ្ជាក់ឱ្យឃើញថាកូនក្តីនោះគឺជាអ្នកត្រូវ

នៅក្នុងករណីខ្លះ ផលប្រយោជន៍ និងគោលដៅទាំងនេះអាចមានសារៈសំខាន់ជាងប្រាក់កាសសម្រាប់ភាគីម្ខាង។ ឧទាហរណ៍ កូនក្តីអាចមានអំណះអំណាងរឹងមាំផ្អែកលើទស្សនៈផ្លូវច្បាប់ ប៉ុន្តែផលប្រយោជន៍របស់កូនក្តីនោះអាចជាការជៀសវាងនូវការប្រឈមមុខជាសាធារណៈ។ ឬក៏ថា កូនក្តីអាចត្រូវការដំណោះស្រាយមួយដែលឆាប់រហ័ស ដោយសារតែការលំបាកផ្អែកហិរញ្ញវត្ថុ ឬពេលកំណត់នៃអាជីវកម្ម ដែលការនេះធ្វើឱ្យដំណោះស្រាយដែលឆាប់រហ័ស កាន់តែមានសារៈសំខាន់ ជាងការទទួលបានជាអតិបរមាពីការព្រមព្រៀងស្រុះស្រួល។

ដូចបានពិភាក្សាពីខាងដើមនៅក្នុងជំពូកនេះ ក្រោយពេលដែលអង្គហេតុ ការវិភាគច្បាប់ និងផលប្រយោជន៍ត្រូវបានស្វែងយល់រួច មេធាវីអាចគណនា BATNA ពោលគឺជម្រើសប្រសើរបំផុតរបស់កូនក្តីក្រៅពីការព្រមព្រៀងតាមរយៈការចរចា។

ក្រោយពីគណនា BATNA របស់កូនក្តីរួច មេធាវីត្រូវពិនិត្យលើរឿងក្តីតាមទស្សនៈរបស់ភាគីម្ខាងទៀត។ ប្រហែលជាភាគីម្ខាងទៀតមិនយល់ស្របលើអង្គហេតុ ហើយជឿថាភាគីរបស់អ្នក ឬភាគីម្ខាងទៀត មានកំហុស។ ប្រហែលជាភាគីម្ខាងទៀតមានផលប្រយោជន៍ដែលសំខាន់ ដែលទំនងនឹងធ្វើឱ្យគេកាន់តែចង់ដោះស្រាយរឿងក្តីនោះថែមទៀត។ ចូរកត់សម្គាល់ថាការគណនា BATNA របស់ភាគីម្ខាងទៀត ជាទូទៅ មានលក្ខណៈមិនពិតប្រាកដ ជាងការគណនា BATNA សម្រាប់ភាគីអ្នកផ្ទាល់។ មេធាវីមានកូនក្តីដែលអាចនិយាយដោយស្មោះត្រង់ និងជាសម្ងាត់ អំពីផល-ប្រយោជន៍របស់ខ្លួន ដែលផ្ទុយទៅវិញ មេធាវីមិនអាចដឹងច្រើនបែបនោះពីភាគីម្ខាងទៀតឡើយ។ ដូច្នេះមេធាវីត្រូវនិយាយជាមួយកូនក្តី និងអាចនិយាយជាមួយអ្នកដទៃទៀតដើម្បីឱ្យដឹងថាតើមានផលប្រយោជន៍សំខាន់អ្វី ដែលអាច

ជំរុញទឹកចិត្តភាគីម្ខាងទៀតបាន។ វាក៏មានសារៈសំខាន់យ៉ាងខ្លាំងផងដែរដែល មេធាវីត្រូវធ្វើការវិនិច្ឆ័យដោយឯករាជ្យអំពីចំនុចខ្លាំងនៃអំណះអំណាងរបស់ភាគីទាំងពីរ។ ការគណនា BATNA របស់មេធាវី ត្រូវមានឯករាជ្យភាពពីបុរេ-វិនិច្ឆ័យ របស់កូនក្តីពាក់ព័ន្ធទៅនឹងភាពរឹងមាំនៃអំណះអំណាងផ្ទាល់របស់ខ្លួន និង"ភាពត្រឹមត្រូវ"នៃជំហររបស់ខ្លួន។

***ចូរចងចាំថាកូនក្តី និងមេធាវីអាចមានទំនោរបញ្ញត្តនិយម និងជឿជាក់ជ្រុល ដូចបានពិភាក្សាពីខាងដើមក្នុងជំពូកនេះ។***

ក្រោយពេលជំហានខាងលើត្រូវបានបំពេញរួច មេធាវីត្រូវបង្កើតយុទ្ធសាស្រ្តសម្រាប់ការចរចា។ យុទ្ធសាស្រ្តនេះត្រូវផ្តោតលើរបៀបបង្ហាញការទាមទារទៅភាគីម្ខាងទៀត តើសម្បទានអ្វីខ្លះដែលកូនក្តីរបស់អ្នកអាចធ្វើជាយថាហេតុ តើផលប្រយោជន៍ដែលសំខាន់មានអ្វីខ្លះ ដំណោះស្រាយដែលអាចមាន ព្រមទាំង BATNA ឬតម្លៃបម្រុង។ យុទ្ធសាស្រ្តនេះអាចកំណត់ឡើងដោយការឆ្លើយសំណួរនៅក្នុងទំព័រទិន្នានុប្បវត្តិនៃការចរចា ដែលមានចំណងជើងថា *ការរៀបចំផែនការសម្រាប់ការចរចា* ដែលស្ថិតនៅចុងបញ្ចប់នៃជំពូកនេះ។ ត្រូវពិនិត្យមើលយុទ្ធសាស្រ្តនេះឡើងវិញជាមួយកូនក្តីដើម្បីធានាថាកូនក្តីពេញចិត្តចំពោះយុទ្ធសាស្រ្តទាំងនេះ រីឯកូនក្តីវិញក៏ត្រូវផ្តល់សិទ្ធិអំណាចពេញលេញដល់មេធាវីក្នុងការចរចាដោយអនុលោមតាមយុទ្ធសាស្រ្តនេះផងដែរ។

## 2. *ដំណាក់កាលផ្តើម*

ជាញឹកញាប់ ដំណាក់កាលផ្តើមនៃការចរចាត្រូវបានបំភ្លេចចោល ដោយចាត់ទុកថាវាមិនសំខាន់។ ផ្ទុយទៅវិញដំណាក់កាលនេះមានភាពចាំបាច់ចំពោះភាពជោគជ័យនាពេលក្រោយមកទៀត។ នៅក្នុងដំណាក់កាលនេះ មេធាវីធ្វើទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ដើម្បីពិភាក្សាអំពីបែបបទនៃការចរចា ដូចជា តើគួរតែមានការចរចា **ដែរឬទេ** និងតើការចរចាទាំងនេះត្រូវធ្វើ ឡើងនៅ **ពេលណា នៅកន្លែងណា** និង**ដោយរបៀបណា**។

- តើគួរតែមានការចរចាដែរ **ឬទេ**
- តើការចរចាទាំងនេះត្រូវធ្វើឡើង **នៅពេលណា**
- តើការចរចាទាំងនេះត្រូវធ្វើឡើង **នៅកន្លែងណា**
- តើការចរចាទាំងនេះត្រូវធ្វើឡើង **ដោយរបៀបណា**

### គួរឬទេ

សំណួរថា "គួរឬទេ" (តើគួរមានការចរចាដែរឬទេ?) មានសារៈសំខាន់ណាស់។ នៅក្នុងករណីមួយចំនួន ភាគីទីមួយដែលស្នើឱ្យមានការចរចា អាចត្រូវបានគេមើលឃើញថាជាការបង្ហាញភាពទន់ខ្សោយរបស់ខ្លួន។ ប្រសិនបើមានករណីបែបនេះមែន មេធាវីត្រូវគិតដោយប្រុងប្រយ័ត្នអំពីរបៀបបង្ហាញសម្ពើនោះ។ ជាគោលការណ៍ទូទៅ ប្រសិនបើភាគីមានផលប្រយោជន៍កាន់តែតិចនៅក្នុងការចរចា ភាគីនោះកាន់តែមានជំហររឹងមាំស្តែងឡើង។ អាស្រ័យហេតុនេះ

ការព្យាយាមបង្ហាញការមិនមានចំណាប់អារម្មណ៍នៅក្នុងការចរចា ប៉ុន្តែនៅតែយល់ព្រមចូលរួមក្នុងការចរចា ជូនកាលក៏ជាប្រការដែលមានសារៈប្រយោជន៍ដែរ។

## នៅពេលណា

ជួនកាល សំណួរផ្សេងទៀតត្រូវបានចាត់ទុកថាជាបែបបទផ្លូវការការសុទ្ធសាធ។ ប៉ុន្តែ សំណួរទាំងនេះអាចមានសារៈសំខាន់ផងដែរ។ ពាក់ព័ន្ធនឹងសំណួរថា "នៅពេលណា" ផលប្រយោជន៍ខ្ពស់របស់ភាគីក្នុងការឱ្យមានការចរចាជាបន្ទាន់ អាចចង្អុលបង្ហាញកម្រិតមួយនៃតម្រូវការ ឬសេចក្តីអស់សង្ឃឹម។ ប្រសិនបើភាគីម្ខាងយល់ថាការចរចាត្រូវតែធ្វើឡើងជាបន្ទាន់ ភាគីនោះអាចប្រឈមមុខនឹងតម្រូវការប្រាក់។ ឬអាចថា ភាគីនោះអាចប្រឈមមុខនឹងរយៈពេលកំណត់ផ្នែកអាជីវកម្មដ៏សំខាន់ណាមួយ។ ឬភាគីនោះអាចមានការភ័យខ្លាចថា វិវាទនោះនឹងត្រូវបើកចំហរជាសាធារណៈដែលអាចបង្កមហន្តរាយធ្ងន់ធ្ងរដល់ខ្លួនបាន។ ទោះបីជាមានមូលហេតុអ្វីក៏ដោយ វាមានសារៈប្រយោជន៍ក្នុងការចងចាំ ចំណុចនេះ និងត្រូវធានាថាកូនក្តីរបស់អ្នកមិនហាក់ដូចជាមានចំណង់ជ្រុលពេក ក្នុងការឱ្យមានការចរចាជាបន្ទាន់។

## នៅកន្លែងណា

សំណួរថា "នៅកន្លែងណា" និង "ដោយរបៀបណា" មានលក្ខណៈកាន់តែល្អិតល្អន់នៅក្នុងសារៈសំខាន់របស់វា។ ប្រសិនបើការចរចាត្រូវបានធ្វើឡើងនៅឯការិយាល័យមេធាវីរបស់អ្នក នោះអ្នកនឹងមានប្រៀបខាង "ទីតាំង"។ អ្នកអាចមានអារម្មណ៍ងាយស្រួលជាងភាគីម្ខាងទៀត ដែលអាចមានអារម្មណ៍មិនសុខស្រួល នៅក្នុងបរិយាកាសដែលខ្លួនមិនធ្លាប់ស្គាល់។ លើសពីនេះទៅទៀត នៅក្នុងវប្បធម៌មួយចំនួន គេអាចចាត់ថាភាគីជាភ្ញៀវមានតម្រូវការជាងក្នុងការព្រមព្រៀងដោះស្រាយ ពីព្រោះពួកគេសុខចិត្តធ្វើដំណើរមកជួប។ ដោយសារមូលហេតុនេះ ជួនកាលការចរចាត្រូវបានធ្វើឡើងនៅកន្លែងអព្យាក្រឹត ដូចជាការិយាល័យគណៈមេធាវី មជ្ឈមណ្ឌលតុលាការ ឬមជ្ឈមណ្ឌលសម្រុះសម្រួលឯកជន។

## ដោយរបៀបណា

សំណួរ "របៀបណា" ពាក់ព័ន្ធទៅនឹងដំណើរការចរចាផ្ទាល់។ តើភាគីទាំងពីរគួរផ្ញើរអ៊ីមែលឱ្យគ្នាឬទេ? តើពួកគេគួរចរចាតាមទូរស័ព្ទដែរឬទេ? តើពួកគេត្រូវចរចាទល់មុខគ្នាដោយផ្ទាល់ដែរឬទេ? ប្រសិនបើជួបផ្ទាល់ តើកូនក្តីត្រូវមានវត្តមាននៅពេលចរចាដែរឬទេ? ប្រសិនបើកូនក្តីរបស់អ្នកជាអ្នកមានប្រាក់ច្រើនជាង ឬជាមនុស្សដែលពោរពេញទៅដោយភាពជឿជាក់ពីធម្មជាតិនោះ ការចរចាទល់មុខគ្នាជាមួយកូនក្តីទាំងពីរអាចមានប្រយោជន៍។ ឬកូនក្តីរបស់អ្នកអាចមានលទ្ធភាពផ្តល់ព័ត៌មានដល់អ្នក ពាក់ព័ន្ធនឹងអង្គហេតុដែលមានសារៈសំខាន់ នៅក្នុងកំឡុងពេលចរចា។ ឬអាចថាពីដំបូងមកកូនក្តីរបស់អ្នកអាចមានការរំពឹងទុកចំពោះដំណោះស្រាយដែលមិនប្រាកដនិយម ហើយការស្តាប់រឿងរ៉ាវរបស់ភាគីម្ខាងទៀតអាចជួយបន្ធូរបន្ថយការរំពឹងទុកទាំងនោះបាន។

ផ្ទុយទៅវិញ ប្រសិនបើកូនក្តីរបស់អ្នកត្រូវបានគំរាមកំហែងដោយភាគីម្ខាងទៀត ឬឆាប់រំជួលអារម្មណ៍នោះគួរតែជៀសវាងកុំឱ្យមានការចូលរួមរបស់កូនក្តីទៅក្នុងការជួបចរចាផ្ទាល់។ ប្រសិនបើកូនក្តីរបស់អ្នក អាចនឹងផ្តល់ព័ត៌មានសំខាន់ ឬផ្តល់សញ្ញាជាកាយវិការ(ដូចជា ការបង្ហាញការភ័យខ្លាច)នោះ អ្នកអាច ពិចារណាបញ្ចៀសការចូលរួមដោយផ្ទាល់របស់កូនក្តីទៅក្នុងការចរចា។

## ៣. ដំណាក់កាលព័ត៌មាន

ដំណាក់កាលព័ត៌មានចាប់ផ្តើម នៅពេលភាគីពីរចាប់ផ្តើមចរចាគ្នាយ៉ាងសកម្ម ទាំងដោយខ្លួនឯងផ្ទាល់ ឬតាមរយៈមេធាវី។ នៅក្នុងដំណាក់កាលនេះ ភាគីទាំងពីរចាប់ផ្តើមផ្តល់ព័ត៌មានដល់គ្នាទៅវិញទៅមក។ ភាគីម្ខាងអាចចាប់ផ្តើមដោយរៀបរាប់ពីអង្គហេតុ តាមការយល់ឃើញរបស់កូនក្តីខ្លួន រួចបន្តទៅពិនិត្យឡើងវិញដោយសង្ខេបលើលក្ខខណ្ឌច្បាប់ និងផ្តល់សម្ពៃដើម្បីដោះស្រាយ។ ដូចបានរៀបរាប់ខាងលើ ចំណុចនេះអាចត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរ តាមរយៈអ៊ីមែល ឬលិខិត ឬអាចឆ្លើយឆ្លងតាមរយៈការសន្ទនាតាមទូរស័ព្ទ។ ប៉ុន្តែ ដើម្បីធ្វើឱ្យចំនុចនេះមានលក្ខណៈសាមញ្ញ ចូរសន្មត់ថាការចចារនឹងប្រព្រឹត្តិទៅដោយការពិភាក្សាផ្ទាល់ទល់មុខគ្នា។ បន្ទាប់ពីភាគីទីមួយ ផ្តល់ព័ត៌មានទាំងនោះរួច ភាគីម្ខាងទៀតនឹងធ្វើដូចគ្នា គឺពិភាក្សាអំពីអង្គហេតុ និងអង្គច្បាប់ហើយបន្ទាប់មកផ្តល់ជូននូវសម្ពៃដើម្បីដោះស្រាយ។

នៅពេលពិភាក្សាអំពីអង្គហេតុ និងអង្គច្បាប់ ភាគីត្រូវផ្តល់ហេតុផលដែលមិនលម្អៀងចំពោះជំហរដោះស្រាយរបស់ខ្លួន។ ពួកគេត្រូវបង្ហាញដោយតក្កនុលោមថាហេតុអ្វីបានជាពួកគេអាចឈ្នះរឿងក្តីនេះ ហេតុអ្វីបានជាពួកគេមានសិទ្ធិទទួលប្រាក់សំណង ឬក៏អ្វីផ្សេងពីនេះ ដោយមិនមានកាតព្វកិច្ចបង់ប្រាក់សំណង ក៏ដូចជាហេតុអ្វីបានជាអំណះអំណាងដែលជំទាស់ខ្លួនមានចំនុចខ្សោយ។ នៅដំណាក់កាលនេះ មេធាវីត្រូវដើរតួនាទីឱ្យមានសមភាពរវាងការព្យាយាមដឹងព័ត៌មានឱ្យបានច្រើនបំផុតពាក់ព័ន្ធនឹងផលប្រយោជន៍ និង BATNA របស់ភាគីម្ខាងទៀត ហើយនិងការព្យាយាមបង្ហាញ BATNA របស់ខ្លួន យ៉ាងតិចបំផុត។ ប៉ុន្តែ ពួកគេនៅតែត្រូវផ្តល់ព័ត៌មានឱ្យបានសមល្មមដើម្បីឱ្យការចរចាអាចបន្តទៅទៀតបាន។

ការដែលភាគីចរចាព្រមព្រៀងគ្នាទុកពេលចន្លោះជាញឹកញាប់នោះ ក៏ជាប្រការដែលមានអត្ថប្រយោជន៍ផងដែរ ដើម្បីដកថយមកធ្វើការពិចារណាលើព័ត៌មានទាំងអស់ដែលពួកគេស្វែងយល់ពីគ្នាទៅវិញទៅមក។ ឧទាហរណ៍ អាចថាភាគីម្ខាងទៀតបានបង្ហាញនូវភ័ស្តុតាងសំខាន់មួយចំនួន ដែលកូនក្តីរបស់អ្នកមិនបានពិចារណា។ ហើយប្រហែលជាភ័ស្តុតាងនោះអាចផ្លាស់ប្តូរការវាយតម្លៃរបស់លោកអ្នកចំពោះកម្រិតនៃភាពជោគជ័យនៅតុលាការបាន ហើយក៏អាចនឹងផ្លាស់ប្តូរ BATNA និងតម្លៃបម្រុងនៃកូនក្តីរបស់អ្នកតាមនោះដែរ។ ប្រសិនមានករណីបែបនេះមែន អ្នកត្រូវវាយតម្លៃយុទ្ធសាស្ត្រចរចាឡើងវិញ។ ឬបើមិនដូច្នោះទេ ប្រហែលជាភាគីម្ខាងទៀតបានបញ្ចេញឱ្យដឹងថាអាជីវកម្មរបស់គេកំពុងទទួលរងនូវការខូចខាតធ្ងន់ធ្ងរពីប្រភពផ្សេងទៀត ហើយគេត្រូវដំណោះស្រាយមួយដែលឆាប់រហ័ស។ ដូច្នេះ កូនក្តីរបស់អ្នកគឺស្ថិតនៅក្នុងស្ថានភាពមួយដែលប្រសើរជាងអ្វីដែលអ្នកបានគិតទៅទៀត ហើយអ្នកអាចនឹងចង់កែតម្រូវយុទ្ធសាស្ត្រដោះស្រាយរបស់ខ្លួនឱ្យស្របតាមនោះដែរ។

នៅក្នុងដំណើរការចរចារទាំងមូល ប្រការដែលសំខាន់គឺការសួរសំណួរទៅភាគីម្ខាងទៀត។ ត្រូវជំរុញពួកគេឱ្យពន្យល់អំពីជំហររបស់ពួកគេចំពោះអ្វីៗគ្រប់យ៉ាង តាំងពីទំនួលខុសត្រូវរហូតដល់ការខូចខាតនានា។ ជាការសំខាន់គឺត្រូវព្យាយាមរក្សាភាពវិជ្ជមានជានិច្ច ទោះបីជាបញ្ហាហាក់ដូចជាមិនមានភាពអនុគ្រោះចំពោះកូនក្តីរបស់អ្នកពីដំបូងមកក្តី។ ព្យាយាមប្រើប្រាស់ប្រយោគវិជ្ជមាន ជំនួសឱ្យការគំរាមកំហែង ឬពាក្យពេចន៍ដែលមានភាពអវិជ្ជមាន។

ពាក្យពេចន៍អវិជ្ជមាន : *"ប្រសិនបើអ្នកមិនបន្តទិញផលិតផលពីកូនក្តីរបស់ខ្ញុំទេនោះ គាត់នឹងប្តឹងទៅតុលាការដើម្បីយកលុយរាប់ពាន់ពីអ្នក"*។

ពាក្យពេចន៍វិជ្ជមាន : *"ខ្ញុំប្រហែលជាអាចស្រុះស្រួលចំពោះ ការទាមទារសំណងរបស់យើង ប្រសិនបើអ្នកអាចពិចារណាបន្តទំនាក់ទំនងអាជីវកម្មរបស់ពួកគេតទៅទៀត"* ។

ការព្យាយាមធ្វើឱ្យភាគីម្ខាងទៀតបន្តការនិយាយនៅក្នុងកំឡុងពេលចរចា គឺជាប្រការដ៏មានសារៈប្រយោជន៍។ ប្រសិនបើភាគីម្ខាងនោះនិយាយកាន់តែច្រើន គាត់អាចបញ្ចេញព័ត៌មានកាន់តែបានច្រើន។ អ្នកចរចាដែលពូកែតែងតែនឹងព្យាយាមស្តាប់យ៉ាងសកម្មបំផុតនៅក្នុងដំណាក់កាលនេះ។ យ៉ាងណាមិញ ព័ត៌មានដែលមិនមែនជាពាក្យសម្តីក៏មានច្រើនដែរ ដែលអ្នកចរចាចរចាអាចរកបាន។ ខាងក្រោមនេះគឺជាបញ្ជីនៃទំនាក់ទំនងតាមរយៈកាយវិការនៅក្នុងវប្បធម៌មស្ទីមប្រទេស ដែលភាគីម្ខាងទៀតអាចផ្តល់ឱ្យដោយមិនដឹងខ្លួនៈ

- មានពេលខ្លះ មនុស្សតែងតែគ្រហែមសិន នៅមុនពេលពួកគេធ្វើការបកស្រាយដែលមិនពិត។
- ពាក្យដែលគេនិយាយយឺតៗ និងដោយប្រុងប្រយ័ត្ន ក៏អាចជាសម្តីមិនពិតដែរ។
- ប្រសិនបើសម្លេងរបស់អ្នកនិយាយបែរជាកាន់តែឮឡើង ឬញាប់ឡើងនោះ វាគឺជាសញ្ញានៃការថប់អារម្មណ៍ ឬទុក្ខព្រួយ។
- នៅពេលដែលមនុស្សម្នាក់ញ៉ីភ្នែក ឬយកដៃទាំងពីររបស់ខ្លួនមកឈ្លីលើផ្ទៃមុខនោះ វាគឺជាសញ្ញាថា គេមិនអាចទទួលយកបាននូវអ្វីដែលកំពុងនិយាយនោះទេ។
- ការឱបដៃ ឬគងជើងខ្វែងគ្នាគឺជាសញ្ញាថាគេកំពុងមានអារម្មណ៍ថាត្រូវការពារខ្លួន ឬប្រុងប្រយ័ត្ន។
- ការគោះម្រាមដៃនៅលើតុ ច្រើនតែជាសញ្ញានៃកង្វះភាពអត់ធ្មត់។
- ការបែកញើស និងការព្រិចភ្នែកជាញឹកញាប់ គឺជាសញ្ញានៃការភ័យបារម្ភ ឬការតានតឹង ។
- ប្រសិនបើមនុស្សអង្គុយលើកៅអីផ្អែកទៅក្រោយ វាគឺជាសញ្ញាថាគេកំពុងមានអារម្មណ៍ថាមានទំនុកទុកចិត្ត។
- ប្រសិនបើអ្នកនិយាយលើកដៃឡើងលើ មានន័យថាអ្នកនិយាយនោះចង់ឱ្យគេមើលឃើញពីភក្តីភាព និងភាពស្មោះត្រង់របស់ខ្លួន។[៨៤]

សញ្ញាទាំងនេះអាច ឬមិនអាចត្រឹមត្រូវតាមវប្បធម៌កម្ពុជា។ ចំនុចចម្បងនៅទីនេះគឺថា អ្នកចរចាគួរស្វែងរកកាយវិការជាសញ្ញាបង្ហាញទាំងនេះ ដែលពាក់ព័ន្ធនឹងវប្បធម៌របស់ភាគីម្ខាងទៀត។

### *៤. ដំណាក់កាលបែងចែក/ផ្អែកលើផលប្រយោជន៍*

បន្ទាប់ពីភាគីវិវាទមានឱកាសពន្យល់អំពី ការយល់ដឹងរបស់ខ្លួនចំពោះអង្គហេតុ ការវិភាគរបស់ខ្លួនលើអង្គច្បាប់ព្រមទាំងជំហរ និងផលប្រយោជន៍របស់ពួកគេរួចមក ដំណាក់កាលបែងចែក/ផ្អែកលើផលប្រយោជន៍ ក៏ចាប់ផ្តើម។ នេះគឺជាដំណាក់កាលដែលភាគីទាំងពីរស្វែងរកដំណោះស្រាយផ្អែកលើផលប្រយោជន៍ ដែលអាចមាន ជាមុនសិន ហើយប្រសិនបើមិនមានលទ្ធភាពណាមួយនោះទេ ទើបបន្តទៅរកដំណោះស្រាយបែបបែងចែកទៀត។ ដូចក្នុងផ្នែកខាងលើ

[៨៤] Patterson, *et al.* កំណត់សម្គាល់ *ខាងលើ* លេខ៩ នៅទំព័រ៣៥។

ដែលស្ដីពីការចរចាផ្អែកលើផលប្រយោជន៍ បានពន្យល់ដោយលម្អិតរួចមកហើយ គឺមានចំណុចផ្សេងៗជាច្រើនដែលគេត្រូវចងចាំ។

***គួរចងចាំថា គេត្រូវៈ ផ្ដាច់មនុស្សចេញពីបញ្ហា ផ្ដោតលើផលប្រយោជន៍មិនមែនលើជំហរ បង្កើតជម្រើសសម្រាប់ផលចំណេញរួម និងសង្កត់ធ្ងន់លើការប្រើប្រាស់លក្ខណៈវិនិច្ឆ័យមិនលម្អៀង ។***

លើកលែងតែការចរចាដែលកំពុងប្រព្រឹត្តទៅ គឺជាប្រភេទមួយដែលទាមទារឱ្យប្រើវិធីសាស្ត្របែងចែក ដូចជាការទិញម្ហូបនៅតាមទីផ្សារ វិធីសាស្ត្រផ្អែកលើផលប្រយោជន៍គួរតែត្រូវបានលើកយកមកសាកល្បងមុនដំបូងគេ។ ប្រសិនបើវិធីសាស្ត្រផ្អែកលើផលប្រយោជន៍ដែលអាចមានទាំងអម្បាលមាន ត្រូវបានប្រើប្រាស់អស់ហើយ ទើបភាគីវិវាទគួរផ្ដល់កិច្ចខិតខំប្រឹងប្រែងជាចុងក្រោយ ដោយការចរចាតាមបែបបែងចែក។

### ***៥. ដំណាក់កាលបញ្ចប់***

នៅពេលដែលមានការព្រមព្រៀងនៅក្នុងកំឡុងពេលចរចាហើយ ត្រូវធានាថាល័ក្ខខ័ណ្ឌព្រមព្រៀងទាំងនោះត្រូវបានសរសេរចូលជាលាយលក្ខណ៍អក្សរភ្លាមៗ ។ ការចងចាំរបស់មនុស្សតែងរលត់ទៅ ហើយប្រសិនបើភាគីចរចារពន្យាពេលដោយគ្រាន់តែចងចាំអំពីល័ក្ខខ័ណ្ឌនៃការព្រមព្រៀងនោះ ក្រោមមកទៀត ពួកគេអាចមិនឯកភាពទៅលើល័ក្ខខ័ណ្ឌជាក់លាក់ណាមួយ នៅពេលដែលពួកគេព្យាយាមសរសេរវាចូល។ ម្យ៉ាងវិញទៀត ប្រសិនបើភាគីមានពេលវេលាច្រើនជ្រុលពេកនោះ ពួកគេអាចពិចារណាឡើងវិញនូវសម្បទានរបស់ខ្លួន ហើយនឹងព្យាយាមចរចាឡើងវិញ ដើម្បីទទួលបានល័ក្ខខ័ណ្ឌកាន់តែប្រសើរជាងមុន។ ដើម្បីជៀសវាងបញ្ហានេះ ភាគីចរចាត្រូវត្រៀមខ្លួនជានិច្ចក្នុងការសរសេរចូលនូវល័ក្ខខ័ណ្ឌជាមូលដ្ឋាននៃកិច្ចព្រមព្រៀង និងចុះហត្ថលេខា ហើយបន្ទាប់មក ប្រហែលជាត្រូវសរសេរល័ក្ខខ័ណ្ឌស្ថាពរឱ្យបានឆាប់បន្ទាប់ពីនោះ ពោលគឺនៅពេលដែលមេធាវីទាំងអស់មានលទ្ធភាពប្រើប្រាស់ទម្រង់ច្បាប់សមស្រប។

ជាងនេះទៅទៀត ប្រការដែលសំខាន់ គឺអ្នកមិនត្រូវប្រើក្រសែរភ្នែកថាខ្លួនឈ្នះ ឬនិយាយពាក្យពេចន៍ដូចជា "វាបែរជាល្អសម្រាប់ខ្ញុំ ជាងអ្វីដែលបានខ្ញុំគិតទៅទៀត"។ ការណ៍នេះអាចបង្កើតអារម្មណ៍មិនល្អរវាងភាគីទៅវិញទៅមក ហើយអាចឈានទៅដល់ការរំសាយកិច្ចព្រមព្រៀងនោះវិញក៏ថាបាន។

## ឈ. អនុវត្តន៍ការចរចា

ឥឡូវនេះ ដោយសារតែទ្រឹស្តីជាច្រើន និងសេចក្តីលម្អិតអំពីការចរចាត្រូវបានពិនិត្យមើលឡើងវិញរួច ផ្នែកនេះនឹងផ្តល់នូវលំហាត់បន្ថែមចំនួនពីរស្តីពីការចរចាដើម្បីពិចារណា:

### លំហាត់_ករណីចរចារទី១: ក្រុមហ៊ុនឈើហ៊ុបខ្មែរ

អ្នកជាមេធាវីតំណាងឱ្យក្រុមហ៊ុនឈើហ៊ុបខ្មែរ Khmer Timber Company (KTC)។ KTC កំពុងស្វែងរកការអនុញ្ញាតឱ្យកាប់ឈើនៅតំបន់មួយលើជួរភ្នំក្រវាញ ដែលមិនមែនជាតំបន់ការពារនៃឧទ្យានជាតិ។ មានវិវាទមួយពាក់ព័ន្ធនឹងចំនួនឈើហ៊ុបដែលរដ្ឋាភិបាលត្រូវអនុញ្ញាតឱ្យ KTC ទាញយកផលជារៀងរាល់ឆ្នាំ។ អ្នកចង់បាននូវកិច្ចព្រមព្រៀងដែលមានលក្ខណៈអនុគ្រោះដល់កូនក្តីរបស់ខ្លួន ប៉ុន្តែ អ្នកក៏ដឹងដែរថា អ្នកអាចនឹងត្រូវធ្វើសម្បទានខ្លះ ដើម្បីសម្រេចគោលដៅនេះ។ KTC បានផ្តល់ឱ្យអ្នកនូវសិទ្ធិសម្រេច និងអំណាចដ៏ធំធេងក្នុងការបំពេញកិច្ចព្រមព្រៀង ដោយមិនចាំបាច់ពិគ្រោះយោបល់ជាមួយក្រុមហ៊ុនជាមុនឡើយ។

គោលដៅរបស់អ្នក គឺធ្វើយ៉ាងណាឱ្យ ១) KTC អាចកាប់ឈើបានយ៉ាងហោចណាស់ ១៣.០០០ ម៉ែត្រគូបជារៀងរាល់ឆ្នាំ ២) KTC មានសិទ្ធិផ្តាច់មុខក្នុងការកាប់ឈើនៅតំបន់នោះក្នុងរយៈពេល យ៉ាងហោចណាស់ ចំនួនប្រាំឆ្នាំ ៣) រដ្ឋាភិបាលនឹងមិនឱ្យ KTC ទទួលខុសត្រូវចំពោះការខូចខាតផ្សេងៗដែលបណ្តាលមកពីការកាប់ឈើឡើយ។

អ្នកបានឮថា រដ្ឋាភិបាលមានឆន្ទៈអនុញ្ញាតតាមគោលដៅមួយចំនួនរបស់អ្នក ប៉ុន្តែក៏ចង់បានមកវិញផងដែរ នូវសម្បទាន ដូចតទៅនេះ: KTC ត្រូវ ១) ជំនួសវិញនូវដើមឈើណាដែលខ្លួនកាប់រួច ដោយដាំកូនឈើថ្មី ២) ធ្វើអំណោយជាប្រាក់ចំនួន ១០.០០០ ដុល្លា ដល់កម្មវិធីអភិរក្សព្រៃឈើនៅតំបន់ជួរភ្នំក្រវាញ ៣) អនុញ្ញាតឱ្យក្រុមហ៊ុនផ្សេងទៀតកាប់ឈើនៅក្នុងតំបន់នោះ ក្នុងរយៈពេលបីឆ្នាំក្រោយមក និង ៤) ទទួលខុសត្រូវចំពោះការខូចខាតមួយចំនួន ប្រសិនបើក្រុមហ៊ុនខកខានមិនបានដាំកូនឈើឡើងវិញស្របតាមកិច្ចព្រមព្រៀងនេះ ឬការខូចខាតផ្សេងទៀតដោយការរំលោភទៅលើ កិច្ចព្រមព្រៀងស្ថាពររបស់ពួកគេ។

អ្នកយល់ឃើញថាការទាមទារមួយចំនួនមានភាពហួសប្រមាណ ទោះបីជា KTC ចង់ជៀសវាងបំផុតចំពោះចំណុចទី៣ ក៏ដោយ។ អ្នកក៏ដឹងផងដែរថា ក្រុមហ៊ុនកាប់ឈើផ្សេងទៀតកំពុងពិភាក្សាជាមួយរដ្ឋាភិបាល។ ប្រសិនបើអ្នកមិនអាចឈានដល់ការព្រមព្រៀងឱ្យបានឆាប់រហ័សទេនោះ ក្រុមហ៊ុនផ្សេងទៀតអាចសម្រេចកិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាល ឱ្យផ្តល់សិទ្ធិផ្តាច់មុខក្នុងការកាប់ឈើនៅក្នុងតំបន់នោះជាមិនខាន។

- តើអ្នកត្រូវដំណើរការការចរចាដោយរបៀបណា? តើអ្នកត្រូវធ្វើសម្ដើដំបូងឬទេ? តើសម្ដើរបស់អ្នកគួរបញ្ចូលនូវសម្បទានមួយចំនួនដែលលោកអ្នកគិតថា (ប៉ុន្តែមិនអាចបញ្ជាក់ថា) រដ្ឋាភិបាលចង់បាន ដែរឬទេ?
- តើមានផលប្រយោជន៍រួមរវាងអ្នក និងរដ្ឋាភិបាលដែរឬទេ ? ប្រសិនបើមាន តើជាផលប្រយោជន៍អ្វីខ្លះ?
- តើមានផលប្រយោជន៍ផ្សេងគ្នារវាងអ្នក និងរដ្ឋាភិបាលដែរឬទេ? ប្រសិនបើមាន តើជាតើផលប្រយោជន៍អ្វីខ្លះ?
- តើមានផលប្រយោជន៍មួយចំនួន ដែលសំខាន់ជាងផលប្រយោជន៍ដទៃទៀតដែរឬទេ?
- តើអ្នកគួរបំពេញផលប្រយោជន៍របស់ភាគីទាំងពីរដោយរបៀបណា? តើអ្នកនឹងបង្ហាញគំនិតនេះ ដល់ភាគីម្ខាងទៀតដោយរបៀបណា?

## លំហាត់_ករណីចរចារទី២: សាជីវកម្មឈើបារ៉ុង

នៅក្នុងករណីនេះ និស្សិតនឹងត្រូវបែងចែកជាក្រុមតូច ដែលតំណាងឱ្យសាជីវកម្មឈើបារ៉ុង Barong Wood Corporation (BWC) ឬ តំណាងឱ្យលោកលឹម សុផល ប្រធានសហជីពនិយោជិត BWC ។

សាជីវកម្មឈើបារ៉ុង (BWC) គឺជាសាជីវកម្មពហុជាតិដែលមានទីស្នាក់ការកណ្ដាលនៅទីក្រុងប៉ារីស និងជាក្រុមហ៊ុនផលិត និងលក់ផលិតផលធ្វើអំពីឈើធំជាងគេបង្អស់មួយ នៅលើពិភពលោក។ BWC-កម្ពុជា គឺជាសាខាដែលគ្រប់គ្រងទាំងស្រុងដោយ BWC ដែលមានកម្មករជិត ២០០នាក់នៅប្រទេសកម្ពុជា។ ថ្មីៗនេះ BWC បានកត់សម្គាល់ឃើញថាផលិតភាពរបស់សាខា BWC-កម្ពុជា ធ្លាក់ចុះ។ BWC បានបញ្ជូនលោក លូពី (Loup) ពីទីក្រុងប៉ារីសមកកាន់ភ្នំពេញ ដើម្បីរកវិធីសន្សំសំចៃប្រាក់។ លោក លូ បានសម្រេចចិត្តកាត់បន្ថយប្រាក់ចំណាយនៅក្នុង BWC-កម្ពុជា ដោយបញ្ឈប់បុគ្គលិកសំខាន់ៗចំនួនប្រាំមួយរូប ពីផ្នែកស្រាវជ្រាវព្រៃឈើ។ នៅរសៀលថ្ងៃសុក្រ (ពីរសប្ដាហ៍មុន) គាត់បានផ្ញើលិខិតទៅបុគ្គលិកនីមួយៗ ទាំងប្រាំមួយរូបនោះ ដើម្បីជូនដំណឹងពួកគេអំពីការបញ្ឈប់ជាបន្ទាន់ពីក្រុមហ៊ុន គិតចាប់ពីពេលព្រឹកថ្ងៃច័ន្ទសប្ដាហ៍បន្ទាប់ ហើយបានប្រាប់ពួកគេអំពីប្រាក់បំណាច់ពេលឈប់ពីការងារ។ សំបុត្ររបស់លោក លូពី បានពន្យល់ថាការបញ្ឈប់នេះគឺចាំបាច់ដោយសារតែផលិតភាពទាបរបស់ពួកគេ ក៏ដូចជាវិធានការកាត់បន្ថយថវិកាដែលចេញដោយទីស្នាក់ការកណ្ដាលនៅទីក្រុងប៉ារីស។ បន្ថែមពីលើប្រាក់ចូលនិវត្តន៍សរុប និងប្រាក់បំណាច់ផ្សេងៗទៀតដែលតម្រូវដោយវិធានការងាររបស់ BWC ប្រាក់បំណាច់ពេលឈប់ពីការងារប្រកបដោយភាពសប្បុរសត្រូវបានសន្យានៅក្នុងសំបុត្រនោះ។

នៅថ្ងៃច័ន្ទសប្ដាហ៍បន្ទាប់ កូដកម្មទូទៅមួយប្រឆាំងនឹង BWC-កម្ពុជា ត្រូវបានធ្វើឡើងដោយសហព័ន្ធកម្មករ-និយោជិតកម្ពុជា Federation of Cambodian Workers (FCW)។ ទោះបីជាបុគ្គលិករបស់ BWC-កម្ពុជា មានសហជីពតូចមួយរបស់ខ្លួន គឺសហជីពនិយោជិត BWC ឬ BWC Employee's Union (BWC-EU) និងមិនមែនជាសមាជិករបស់ FCWក្តី ក៏កម្មករ BWC-កម្ពុជា មានការភ័យខ្លាចក្នុងការឆ្លងកាត់របាំងកូដកម្មដើម្បីទៅធ្វើការដែរ។ ប្រធាន JWC-EU គឺលោក លឹម សុផល គឺជាបុគ្គលិកដែលបំរើការអស់រយៈពេល១៥ឆ្នាំមកហើយ និងដែលកំពុងត្រូវបានពិចារណាចំពោះមុខតំណែងដ៏សំខាន់មួយ នៅក្នុងគណៈគ្រប់គ្រងរបស់ក្រុមហ៊ុន បន្ទាប់ពីគាត់បញ្ចប់អាណត្តិជាប្រធានសហជីពក្រុមហ៊ុន។ គាត់បានដើរតួជាអ្នកនាំពាក្យរបស់បុគ្គលិកដែលត្រូវបានបញ្ឈប់ពីការងារ ក៏ដូចជាសហជីពទាំងមូល នៅក្នុងកំឡុងពេលវិវាទនេះ។

BWC-កម្ពុជា ចាប់ផ្ដើមទទួលរងនូវការខូចខាតដោយសារកូដកម្ម និងសាធារណៈភាពមិនល្អ។ បុគ្គលិកជាច្រើនមិនចូលការិយាល័យ ជាហេតុនាំឱ្យការងារមិនអាចបញ្ចប់រួច។ លើសពីនេះទៅទៀត អតិថិជនក្នុងស្រុករបស់ BWC-កម្ពុជា មានការភ័យខ្លាចក្នុងការធ្វើអាជីវកម្មជាមួយពួកគេ ដោយសារតែសាធារណៈភាពមិនល្អនោះ។ មានអត្ថបទមួយបានចុះផ្សាយនៅក្នុងសារព័ត៌មានក្នុងស្រុកមួយ កាលពីពេលថ្មីៗនេះ ដោយអះអាងថា BWC មិនបានប្រព្រឹត្តចំពោះបុគ្គលិកកម្ពុជាដោយមិនមានភាពយុត្តិធម៌ឡើយ។

BWC បានសម្រេចចិត្តបញ្ជូនក្រុមចរចាដ៏ពូកែបំផុតរបស់ខ្លួនឱ្យទៅជួបលោកសុផល និងមិត្តរួមការងាររបស់គាត់ ដើម្បីព្យាយាមដោះស្រាយវិវាទឱ្យបានឆាប់បំផុត។ ភាគីទាំងពីរយល់ថា វាមិនមានប្រយោជន៍អ្វីដែលត្រូវបន្តកូដកម្មរយៈពេលយូរនោះទេ។

ក្រុមចរចានីមួយៗអាចនឹងទទួលបានព័ត៌មានសម្ងាត់ អាស្រ័យទៅលើភាគីដែលខ្លួនតំណាង។ បន្ទាប់ពីពិនិត្យមើលព័ត៌មានសម្ងាត់រួចហើយ ក្រុមទាំងពីរនឹងត្រូវស្នើឱ្យចូលរួមក្នុងការចរចាជាមួយសមភាគី ដើម្បីឱ្យដឹងថាតើគេអាចឈានដល់ការព្រមព្រៀងគ្នាដែរឬទេ។

**១. ទំព័រកិច្ចការៈ  ការរៀបចំផែនការសម្រាប់ការចរចា**

ខាងក្រោមនេះគឺជាទិន្នានុប្បវត្តិនៃការចរចាសំខាន់ៗសម្រាប់ការចរចាៈ

- ចូររៀបរាប់ដោយសង្ខេបអំពីបញ្ហា។

- តើអ្នកត្រូវការព័ត៌មានបន្ថែមអ្វីខ្លះទៀត ដើម្បីបញ្ជាក់ ឬស្វែងយល់ឱ្យកាន់តែច្បាស់ពីហេតុការណ៍/បញ្ហានោះ?

- តើអ្នកមានគោលដៅអ្វី (តើខ្ញុំចង់សម្រេចអ្វី)?

- តើផលប្រយោជន៍របស់អ្នកមានអ្វីខ្លះ (ចូររៀបរាប់តាមលំដាប់អាទិភាព)?

- តើ BATNA និងចំណុចប្រឆាំងរបស់អ្នកគឺអ្វី ?

- តើភាគីម្ខាងទៀតមានគោលដៅអ្វី ?

- តើផលប្រយោជន៍របស់ភាគីម្ខាងទៀតមានអ្វីខ្លះ (ចូររៀបរាប់តាមលំដាប់អាទិភាពដែលអាចមាន)?

- តើលោកអ្នកនឹងប្រើប្រាស់យុទ្ធសាស្ត្រអ្វីនៅក្នុងការចរចា ?

## ៧. ទំព័រកិច្ចការៈ ការចូលរួមនៅក្នុងការចរចា (បញ្ហាទូទៅ)

| បញ្ហា | អ្វីដែលភាគីរបស់ខ្ញុំចង់បាន | អ្វីដែលភាគីរបស់ខ្ញុំមានឆន្ទៈទទួលយក |
|---|---|---|
| | | |
| **បញ្ហា** | **អ្វីដែលភាគីម្ខាងទៀតចង់បាន** | **អ្វីដែលភាគីម្ខាងទៀតមានឆន្ទៈទទួលយក** |
| | | |

## ៣. ទំព័រកិច្ចការៈ ការចូលរួមនៅក្នុងការចរចា (ការតស៊ូមតិលើបញ្ហា)

| បញ្ហានៃភាគីរបស់ខ្ញុំ | អំណះអំណាងគាំទ្រ | អំណះអំណាងប្រឆាំង |
|---|---|---|
| | | |
| **បញ្ហារបស់ភាគីម្ខាងទៀត** | **អំណះអំណាងគាំទ្រ** | **អំណះអំណាងប្រឆាំង** |
| | | |

## ៤. ទំព័រកិច្ចការៈ ការចូលរួមក្នុងការចរចា (យុទ្ធសាស្ត្រផ្អែកលើផលប្រយោជន៍)

- តើអ្នកបានពិចារណាលើទស្សនវិស័យរបស់ភាគីម្ខាងទៀតដែរឬទេ? តើអ្នកបានឱ្យភាគីម្ខាងទៀតដឹង ថាអ្នកកំពុងពិចារណាទស្សនវិស័យរបស់ពួកគេដែរឬទេ?

- តើអ្នកបានបញ្ចូលភាគីម្ខាងទៀតនៅក្នុងដំណើរការរកហេតុផលរបស់លោកអ្នកដែរឬទេ?

- តើអ្នកបានផ្តល់ឱកាសដល់ភាគីម្ខាងទៀតឱ្យសង្គ្រោះមុខមាត់របស់គេដែរឬទេ?

- តើអ្នកបានដឹងអំពីអារម្មណ៍ដែលកើតមានចំពោះភាគីទាំងសងខាងដែរឬទេ?

- តើអ្នកបានស្តាប់យ៉ាងយកចិត្តទុកដាក់នូវអ្វីដែលភាគីម្ខាងទៀតនិយាយ ( ទាំងសម្តី និងកាយវិការ) ដែរឬទេ?

- តើភាគីទាំងពីរមានផលប្រយោជន៍ប្រហាក់ប្រហែលគ្នាដែរឬទេ? គឺអ្វីខ្លះ?

- តើផលប្រយោជន៍ដែលខុសគ្នាស័ក្តិសមជួយអាចឱ្យមានការព្រមព្រៀងគ្នាដែរឬទេ? ប្រសិនបើអាច តើដោយរបៀបណា?

- តើអ្នកបានព្យាយាមបង្កើតជម្រើសរួមគ្នាជាមួយភាគីម្ខាងទៀតដែរឬទេ?

- តើអ្នកបានពិចារណាអំពីការបង្ហាញជម្រើសដ៏ប្រសើរបំផុតរបស់អ្នក រួមជាមួយជម្រើសផ្សេងទៀតដែលជ្រុលនិយមជាងនេះដែរឬទេ?

- តើអ្នកកំពុងតែប្រើប្រាស់លក្ខណៈវិនិច្ឆ័យដែលអាចទទួលយកបាន និងមិនមានភាពលម្អៀងដែរឬទេ ?

**៥. ទំព័រកិច្ចការៈ ការចូលរួមក្នុងការចរចា (តារាងដំណោះស្រាយ)**

| បញ្ហា | ជំហរ ឬសម្មើរបស់យើង | ជំហរ ឬសម្មើរបស់ពួកគេ |
|---|---|---|
| | | |

## ៦. ទំព័រកិច្ចការៈ ចូលរួមក្នុងការចរចា (កិច្ចព្រមព្រៀង)

| បញ្ហា | លក្ខខ័ណ្ឌដោះស្រាយ |
|---|---|
| | |

### ៧. ទំព័រកិច្ចការៈ ការសង្កេតលើការចរចា

១. តើអ្នកបានត្រៀមខ្លួនពេញលេញហើយឬនៅ? តើមានការត្រៀមណាដែលលោកអ្នកគួរតែបានធ្វើផ្ទុយពីនោះដែរឬទេ ?

២. តើអ្នកបានផ្លាស់ប្តូរ BATNA ឬចំណុចបម្រុង នៅពេលណាមួយ ក្នុងកំឡុងពេលចរចាដែរឬទេ?

៣. តើអ្នកធ្វើកិច្ចការមានប្រសិទ្ធភាពកំរិតណា ក្នុងនាមជាមេធាវី?

៤. តើភាគីម្ខាងទៀតធ្វើកិច្ចការមានប្រសិទ្ធភាពកំរិតណា ក្នុងនាមជាមេធាវី?

៥. តើអ្នកបានសម្រេចគោលដៅរបស់ខ្លួនដែរឬទេ?

៦. តើភាគីម្ខាងទៀតបានសម្រេចគោលដៅរបស់ខ្លួនដែរឬទេ?

៧. តើអ្នកគួរតែធ្វើអ្វីផ្ទុយពីនេះដែរឬទេ ប្រសិនបើអ្នកអាចធ្វើឡើងវិញម្តងទៀត ?

៨. តើយុទ្ធសាស្រ្តណាខ្លះដែលប្រើបានផលល្អសម្រាប់អ្នក?

៩. តើយុទ្ធសាស្រ្តណាខ្លះដែលប្រើមិនបានផលល្អ?

១០. តើមានយុទ្ធសាស្រ្តណាខ្លះដែលភាគីម្ខាងទៀតបានប្រើ ហើយមានប្រសិទ្ធភាពជាពិសេស?

# ជំពូកទី៣: សន្ធានកម្ម (ឬការសម្រុះសម្រួល)




**ចង់ផ្ចាញ់មនុស្សលោភដោយធនធាន ចង់ឈ្នះមនុស្សអកុសលដោយកុសល**

**ចង់ផ្ចាញ់អ្នកកំណាញ់ដោយការធ្វើទាន ចង់ផ្ចាញ់អ្នកកុហកដោយសច្ចៈ។**

## ក. តើអ្វីទៅជាសន្ធានកម្ម?

### ១. *សេចក្តីផ្តើម*

សន្ធានកម្ម អាចត្រូវបានផ្តល់និយមន័យយ៉ាងទូលំទូលាយថា ជាការចរចាដែលមានជំនួយ ឬការជួយសម្របសម្រួល។[៨៥] ជាទូទៅ សន្ធានកម្មត្រូវមានភាគីវិវាទពីរ ឬច្រើន ដែលព្យាយាមចរចាលើដំណោះស្រាយមួយ ដោយមានជំនួយពីភាគីទីបី គឺសន្ធានការី ដែលមានអព្យាក្រឹតភាពចំពោះភាគីទាំងនោះ ក៏ដូចជាលទ្ធផលនៃដំណោះស្រាយនោះផ្ទាល់។ សន្ធានការីមិនមានសិទ្ធិអំណាចក្នុងការចាប់បង្ខំឱ្យយកដំណោះស្រាយណាមួយឡើយ។ ផ្ទុយទៅវិញ ភាគីវិវាទនៅតែមានសិទ្ធិអំណាចក្នុងការសម្រេចថាតើខ្លួនចង់ ឬមិនចង់ដោះស្រាយ។ ប្រសិនបើភាគីវិវាទមិនចង់ដោះស្រាយ ឬមិនមានការព្រមព្រៀងគ្នា នោះនឹងគ្មានដំណោះស្រាយឡើយ ទោះជាមានការខិតខំប្រឹងប្រែងរបស់សន្ធានការី យ៉ាងណា

---

[៨៥] Patterson, *et al.* កំណត់សម្គាល់ខាងលើលេខ ៩ នៅទំព័រ៥៣។ សន្ធានកម្មក៏ត្រូវបានកំណត់និយមន័យផងដែរ ថាជា "ដំណើរការដែលនៅក្នុងនោះ អ្នកធ្វើអន្តរាគមន៍មិនលម្អៀងម្នាក់ជួយភាគីចរចាពីរ ឬច្រើន ឱ្យកំណត់ពីបញ្ហាកង្វល់ ហើយបន្ទាប់មកបង្កើតនូវសម្ទើនានា ដែលអាចទទួលយកបានទៅវិញទៅមក ដើម្បីដោះស្រាយកង្វល់ទាំងនោះ"។ ALFINI ET AL. **ទ្រឹស្តី និងការអនុវត្តសន្ធានកម្ម** (បោះពុម្ពលើកទី ១ ដោយ Matthew Bender ឆ្នាំ២០០១) ធ្វើគុណកថាដោយ Steven Austermiller *ការសម្រុះសម្រួល នៅក្នុងប្រទេសបូស្នី និងហ៊ែកហ្សេហ្គោវីនៈ ការអនុវត្តលើកទី ២,* **ទិនានុប្បវត្តិច្បាប់ស្តីពីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៃសាកលវិទ្យាល័យយេល** លេខ៩ ទំព័រ ១៣១, ១៤១ (ឆ្នាំ២០០៦)។

ក៏ដោយ ។ មិនដូចក្នុងមជ្ឈត្តការ ឬបណ្តឹងទៅតុលាការឡើយ សន្ទានការីគ្រាន់តែអាចស្នើឡើងនូវដំណោះស្រាយចំពោះភាគីតែប៉ុណ្ណោះ ។

នៅក្នុងដំណើរការសន្ទានកម្ម ជាធម្មតាសន្ទានការី ១) ស្តាប់ភាគីនីមួយៗ ២) លើកទឹកចិត្តភាគីនីមួយៗឱ្យ ស្តាប់ និងពិចារណាអំពីការស្រុះស្រួលគ្នា ៣) ជួយស្វែងរកដំណោះស្រាយដែលប្រកបដោយគំនិតច្នៃប្រឌិត ៤) ជួយឱ្យភាគីស្វែងយល់អំពីអង្គហេតុ និងអង្គច្បាប់ ដូចដែលអ្នកអញ្ជាក្រីតម្នាក់មើលឃើញ និងនៅពេលដែលសមស្រប ៥) បង្កើតចំណុចជាក់លាក់នៅក្នុងកិច្ចព្រមព្រៀងស្រុះស្រួល ។

ពាក្យថា *សន្ទានកម្ម* ឬ *ការសម្រុះសម្រួល (mediation)* និងពាក្យថា *ការផ្សះផ្សា (conciliation)* ត្រូវបានប្រើលាយឡំគ្នាអស់រយៈពេលជាច្រើនឆ្នាំមកហើយ ដោយមជ្ឈដ្ឋានអ្នកសិក្សា ក៏ដូចជាអ្នកប្រកបវិជ្ជាជីវៈផ្នែកច្បាប់ និងតុលាការ ។ សព្វថ្ងៃនេះ ពាក្យថា *សន្ទានកម្ម* និង *ផ្សះផ្សា* ជាញឹកញាប់ ត្រូវបានប្រើប្រាស់ជំនួសគ្នាទៅវិញទៅមក ដើម្បីសំដៅដល់ដំណើរការតែមួយ ។ ទោះបីជាមានអ្នកខ្លះព្យាយាមគូសបង្ហាញពីភាពខុសគ្នារបស់វាក៏ដោយ ក៏មិនមានអាជ្ញាធរច្បាប់អន្តរជាតិរួមណាមួយកំណត់ថា តើពាក្យទាំងពីរអាចមានភាពខុសគ្នាយ៉ាងដូចម្តេចឡើយ ។[៨៦] ទោះជាគេឃើញមានពាក្យថា *សន្ទានកម្ម* ត្រូវបានប្រើប្រាស់ជាអន្តរជាតិក៏ដោយ ពាក្យថា *ផ្សះផ្សា* គឺជាពាក្យដែលត្រូវបាននិយមប្រើប្រាស់បំផុតនៅក្នុងឯកសារអន្តរជាតិ ។ ឧទាហរណ៍ ច្បាប់គម្រូរបស់ UNCITRAL ស្តីពីការផ្សះផ្សាផ្នែកពាណិជ្ជកម្មអន្តរជាតិ (ដែលហៅកាត់ថា "ច្បាប់ផ្សះផ្សា UNCITRAL")[៨៧] ប្រើប្រាស់ពាក្យថា "ផ្សះផ្សា" ដើម្បីសំដៅដល់

---

[៨៦] នៅប្រទេសអូស្ត្រាលី ក្រុមប្រឹក្សាយោបល់ជាតិស្តីពីដំណោះស្រាយវិវាទក្រៅផ្លូវតុលាការ National Alternative Dispute Resolution Advisory Council (NADRAC) បានគូសបញ្ជាក់ថា មានការច្រឡំគ្នាគួរឱ្យកត់សម្គាល់ ទាំងនៅក្នុងប្រទេសអូស្ត្រាលី និងនៅបណ្តាប្រទេសផ្សេងទៀត ពាក់ព័ន្ធនឹងពាក្យទាំងពីរនេះ ។ *សូមមើលជាទូទៅ* ឯកសារពិភាក្សាអំពីបច្ចេកស័ព្ទរបស់ NADRAC *មាននៅ* http://www.nadrac.gov.au/agd/www/Disputeresolutionhome.nsf/Page/RWP7E251CA71B8E7700CA256BD100135550?OpenDocument (ចូលទស្សនាលើកចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨) ។

[៨៧] **ច្បាប់គម្រូ** UNCITRAL **ស្តីពីការផ្សះផ្សាផ្នែកពាណិជ្ជកម្មអន្តរជាតិ** U.N.GAOR, សម័យប្រជុំលើកទី ៥៧ ឯ.បន្ថែមលេខ១៧ ឯ. អ.ស.ប លេខ A/57/17 ឧបសម្ព័ន្ធទី I មាត្រា៩ (ឆ្នាំ២០០២) *មាននៅ* http://www.uncitral.org/pdf/english/texts/arbitration/ml-conc/ml-conc-e.pdf [អំណើះតទៅហៅកាត់ថា ច្បាប់ផ្សះផ្សា UNCITRAL] ។ ច្បាប់ផ្សះផ្សា UNCITRAL គឺជាកិច្ចខិតខំប្រឹងប្រែងរបស់អ.ស.ប. ក្នុងការទទួលស្គាល់ផលប្រយោជន៍កាន់តែធំឡើង នៃការសម្រុះសម្រួល និងការលើកស្ទួយវិធីសាស្ត្រប្រកបដោយសន្តិវិធីក្នុងការដោះស្រាយវិវាទ ។ Luis M. Diaz និង Nancy A. Oretskin *ច្បាប់ឯកសណ្ឋានស្តីពីសន្ទានកម្មរបស់សហរដ្ឋអាមេរិក និងសេចក្តីព្រាងគម្រូច្បាប់របស់ UNCITRAL ស្តីពីការផ្សះផ្សាផ្នែកពាណិជ្ជកម្មអន្តរជាតិ* នៅក្នុង **បណ្តឹងតុលាការ និងមជ្ឈត្តការផ្នែកជំនួញអន្តរជាតិ** ឆ្នាំ២០០២. នៅទំព័រ ៧៩១, ៧៩៧ (សៀវភៅសិក្សាភាគ ថ្នាក់អនុវត្តន៍ ស្តីពីបណ្តឹងតុលាការ និងរដ្ឋបាល PLI, លេខបញ្ជាទិញ H0-00GP, ឆ្នាំ២០០២) ។ វាក៏តំណាងឱ្យកិច្ចខិតខំប្រឹងប្រែង ក្នុងការផ្តល់ជាវិធានសម្រុះសម្រួលជាឯកសណ្ឋាន នៅទូទាំងប្រទេសជាច្រើនផងដែរ ជាពិសេសក្នុងវិស័យពាណិជ្ជកម្មដែលទើបនឹង លេចឡើង ដូចជា វិវាទក្នុងប្រព័ន្ធអ៊ីនធើនែតជាដើម ។ **មគ្គុទ្ទេសក៍អនុម័ត និងប្រើប្រាស់ច្បាប់គម្រូរបស់** UNCITRAL **ស្តីពីការផ្សះផ្សាផ្នែកពាណិជ្ជកម្មអន្តរជាតិ,** កថាខ័ណ្ឌ១៧ (UNCITRAL ឆ្នាំ២០០២) [អំណើះតទៅហៅកាត់ថា មគ្គុទ្ទេសក៍ផ្សះផ្សា UNCITRAL] ។ តាមបទពិសោធន៍របស់អ្នកនិពន្ធនេះ ច្បាប់គម្រូ

ដំណើរការគ្រប់ប្រភេទទាំងអស់ដែលបុគ្គលអព្យាក្រិតម្នាក់ ឬច្រើននាក់ជួយដល់ភាគីឱ្យឈានទៅ ដល់ដំណោះស្រាយដោយការស្រុះស្រួលគ្នា រួមទាំងដំណើរការសន្ធានកម្មផងដែរ។[៨៨] ផ្ទុយទៅវិញ សន្ធានកម្ម គឺជាពាក្យដែលត្រូវបានគេនិយមប្រើបំផុតនៅក្នុងប្រព័ន្ធច្បាប់របស់សហរដ្ឋអាមេរិក ដោយពាក្យថា ផ្សះផ្សា មិនសូវត្រូវបានប្រើប្រាស់តទៅទៀតឡើយ។ ឧទាហរណ៍ដូចជាក្នុងច្បាប់ឯកសណ្ឋានស្តីពីសន្ធានកម្មរបស់អាមេរិកជាដើម។[៨៩]

ពាក្យទាំងពីរនេះសំដៅដល់ដំណើរការចរចា ដែលមានភាគីទីបីដែលអព្យាក្រឹតជួយសម្របសម្រួល។ នៅក្នុងប្រទេសខុសគ្នា និងប្រពៃណីខុសគ្នា ដំណើរការ ឬកម្រិតនៃការចូលរួមពីសំណាក់ភាគីអព្យាក្រឹតមានភាពដោយឡែកពីគ្នាយ៉ាងខ្លាំង។[៩០] នៅក្នុងប្រពៃណីខ្លះ ភាគីអព្យាក្រឹតមានសេរីភាពក្នុងការជម្រុញការស្រុះស្រួលដោយសកម្ម តាមរយៈកិច្ចប្រជុំជាឯកជនជាមួយភាគីវិវាទ (ដែលគេហៅថាជា កិច្ចប្រជុំដោះស្រាយ caucuses) និងតាមរយៈការស្នើនូវដំណោះស្រាយជាក់លាក់នានា។[៩១] នៅក្នុងប្រពៃណីខ្លះទៀត សន្ធានការី ឬក៏អ្នកផ្សះផ្សា ប្រើប្រាស់វិធីសាស្ត្រអកម្មជាង

---

UNCITRAL មានការទទួលស្គាល់យ៉ាងទូលំទូលាយ ហើយ ប្រទេសក្នុងអន្តរកាលជាច្រើនបានចាត់ទុកវាថាជាគម្រូសមស្រប។ នេះអាចដោយសារតែក្រុមការងាររបស់ UNCITRAL មានសមាសភាពមកពីប្រទេស និងប្រពៃណីច្បាប់ចម្រុះ។

[៨៨] មគ្គុទ្ទេសក៏ផ្សះផ្សា UNCITRAL, កំណត់សម្គាល់ខាងលើលេខ៨៧ កថាខ័ណ្ឌ៧, Diaz និង Oretskin កំណត់សម្គាល់ *ខាងលើ* លេខ៨៧ នៅទំព័រ៧៩៧។

[៨៩] **ច្បាប់ឯកសណ្ឋានស្តីពីសន្ធានកម្ម** UNIFORM MEDIATION ACT (ធ្វើវិសោធនកម្មនៅឆ្នាំ២០០៣) *មាននៅ* http://www.law.upenn.edu/bll/ulc/mediat/2003finaldraft.pdf [អំណឹះតទៅហៅកាត់ថា UMA]។ ច្បាប់នេះគឺជាលទ្ធផលនៃកិច្ចសហការរវាងគណៈកម្មាធិការច្បាប់ឯកសណ្ឋាន នៃសន្និសីទជាតិរបស់ស្នងការស្តីពីរដ្ឋដែលប្រើច្បាប់ឯកសណ្ឋាន និង គណៈ-កម្មាធិការ ពង្រាងនៃគណៈមេធាវីអាមេរិក។ *សូមមើល* Diaz និង Oretskin, កំណត់សម្គាល់ *ខាងលើ* លេខ៨៧ នៅទំព័រ៧៩៣។ ច្បាប់នេះត្រូវបានធ្វើចប់រួចរាល់ និងអនុម័តនៅឆ្នាំ២០០១។ គោលបំណងនៃ UMA គឺដើម្បីផ្តល់ឯកសណ្ឋានភាពនៅក្នុងច្បាប់សន្ធានកម្ម នៅទូទាំងសហរដ្ឋអាមេរិក។ អារម្ភកថារបស់ UMA បានបង្ហាញថា គេឃើញមានវិធានច្បាប់ពាក់ព័ន្ធនឹងសន្ធានកម្មនៅសហរដ្ឋអាមេរិក នៅក្នុងឧបញ្ញត្តិ (statute) ជាង២ ៥០០ ដែលភាគច្រើន អាចត្រូវបានជំនួសដោយច្បាប់នេះ។ UMA, អារម្ភកថា (prefactory note) កថាខ័ណ្ឌ ៣។ រដ្ឋរបស់អាមេរិកចំនួនប្រាំបួន (អ៊ីលីណ័រ អាយអូវ៉ា នៃប្រាស្កា ញូជើស៊ី អុហាយ៉ូ សោតស៏ដាកូតា អ៊ូតា វែរម៉ុនត៍ និងវ៉ាស៊ីនតោន) ព្រមទាំង ខ័ណ្ឌខូឡំបៀ (District of Columbia) បានអនុម័តច្បាប់នេះរួចហើយ ហើយUMA ក៏ត្រូវបានបញ្ចូល ជាច្បាប់នៅក្នុងរដ្ឋពីរទៀតផងដែរ។ *សូមមើល* វែបសាយត៏របស់ NCCUSL *នៅ* http://www.nccusl.org/Update/uniformact_factsheets/uniformacts-fs-uma2001.asp (ចូលទស្សនាលើកចុងក្រោយ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨)។ នៅឆ្នាំ២០០៣ UMA ត្រូវបានធ្វើវិសោធនកម្មដើម្បីបញ្ចូលជាឯកសារយោងនូវ ច្បាប់ផ្សះផ្សា UNCITRAL សម្រាប់ដំណើរការដែលមានលក្ខណៈជាអន្តរជាតិ។ *សូមមើល* ច្បាប់ស្តីពីវិសោធនកម្មច្បាប់ឯកសណ្ឋាណស្តីពីសន្ធានកម្ម ឆ្នាំ២០០៣, កថាខ័ណ្ឌ១១។

[៩០] *ដូចមុន*។ M. Jagannadha Rao *ទស្សនាទាននៃការផ្សះផ្សា និងការសន្ធានកម្ម និងភាពខុសគ្នានៃពាក្យទាំងពីរនេះ* (ឆ្នាំ២០០២) (ប្រៀបធៀបពាក្យថាផ្សះផ្សា និងសន្ធានកម្ម ដូច ដែលមានប្រើនៅប្រទេសឥណ្ឌា) *មាននៅ* http://1.1.1.1/472008168/472002888T080531111635.txt.binXMysM0dapplication/pdfXsysM0dhttp://lawcommissionofindia.nic.in/adr_conf/concepts%20med%20Rao%201.pdf

[៩១] មានអាជ្ញាធរនៅប្រទេសខ្លះឱ្យនិយមន័យពាក្យ ផ្សះផ្សា ថាជាដំណើរការ ដែលនៅក្នុងនោះភាគីអព្យាក្រឹតដើរតួនាទីស្នើដំណោះស្រាយកាន់តែសកម្ម ចំណែកឯពាក្យ សន្ធានកម្ម ត្រូវបានកំណត់ថាជាដំណើរការដែលនៅក្នុងនោះភាគីអព្យាក្រឹតមានតួនាទីគ្រាន់តែជួយ

ហើយបណ្តោយឱ្យភាគីជាអ្នកគ្រប់គ្រងដំណើរការ។ វិធីសាស្ត្រទាំងពីរនេះសុទ្ធតែមានសុពលភាព ឯសម្រាប់សៀវភៅនេះ ពាក្យសន្ធានកម្មនឹងត្រូវបានប្រើប្រាស់សម្រាប់សំដៅដល់ទាំងការផ្សះផ្សា និងការសម្រុះសម្រួល។ យ៉ាងណាមិញ នៅពេលមានច្បាប់ណាមួយប្រើប្រាស់ពាក្យផ្សះផ្សា ពាក្យនោះក៏នឹងត្រូវបានលើកមកប្រើប្រាស់ដែរ។

## ២. *ប្រវត្តិនៃសន្ធានកម្ម*

សន្ធានកម្មកើតមានស្ទើរតែតាំងពីពេលកកើតសង្គមមនុស្សមកម្ល៉េះ។ មិនជាការលំបាកទេក្នុងការនឹកស្រមៃអំពីសមាជិកគ្រួសារ ឬសមាជិកកុលសម្ព័ន្ធម្នាក់ ជួយបុគ្គលពីរនាក់ក្នុងការដោះស្រាយវិវាទ ដោយប្រកាន់តួនាទីអព្យាក្រិត និងជួយសម្រួលឱ្យមានដំណោះស្រាយ។ សន្ធានកម្មទំនងជាមានអាយុចំណាស់ជាងប្រព័ន្ធតុលាការផ្លូវការដំបូង ហើយអាចត្រូវបានប្រើប្រាស់ជាគម្រូសម្រាប់ការបង្កើតតុលាការនៃប្រព័ន្ធច្បាប់នានា។[៩២] ជាងនេះទៅទៀត គម្រូនៃដំណោះស្រាយវិវាទក្រៅផ្លូវការបែបនេះ បានកើតមានឡើងនៅទូទាំងពិភពលោក។ សន្ធានកម្មត្រូវបានអនុវត្តនៅក្នុងប្រវត្តិសាស្ត្របុរេទំនើបនៅកន្លែងជាច្រើនដូចជាៈ ប្រទេសចិនដែលកាន់លទ្ធិខុងជឺ ជនបទនៃប្រទេសអាល់បានី ប្រទេសអង់គ្លេសនាសតវត្សន៍ទី១២ ជនជាតិដើមភាគតិចនៅទ្វីបអាមេរិកខាងជើង និងដែលស្ថិតនៅក្រោមអាណានិគម ព្រមទាំងនៅទ្វីបអាហ្វ្រិកមុនសម័យអាណានិគមជាដើម។[៩៣] នៅប្រទេសចិនដែលកាន់លទ្ធិខុងជឺ ជាឧទាហរណ៍ ប្រជាជនចាត់ទុកការប្រើប្រាស់អន្តរការីថាជាមធ្យោបាយដែលសង្គមទទួលស្គាល់ក្នុងការដោះស្រាយវិវាទ។[៩៤] នៅប្រទេសអង់គ្លេស ដែលប្រកាន់

---

សម្រួល និងកាន់តែអកម្ម។ *សូមមើល ពាក្យក្នុងដំណោះស្រាយវិវាទ,* ក្រុមប្រឹក្សាយោបល់ជាតិ ស្តីពីដំណោះស្រាយវិវាទក្រៅផ្លូវតុលាការ (អូស្ត្រាលី), នៅទំព័រ៣, (ឆ្នាំ២០០៣), *មាននៅ* http://1.1.1.1/467929504/472002888T080531121212.txt.binXMysM0dapplication/pdfXsysM0dhttp://www.nadrac.gov.au/agd/WWW/rwpattach.nsf/VAP/(CFD7369FCAE9B8F32F341DBE097801FF)~1Report8_6Dec.pdf/$file/1Report8_6Dec.pdf (ចូលទស្សនាលើកចុងក្រោយ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨)។

[៩២] Patterson, *et al.,* កំណត់សម្គាល់ *ខាងលើ* លេខ៩ នៅទំព័រ៩៥។

[៩៣] Betty Southard Murphy, *ផលប៉ះពាល់របស់ ADR លើវិស័យពាណិជ្ជកម្មអន្តរជាតិ,* **ឱនាឌុ.ដំណោះ.ខិ.** លេខ ៦៨ , ទំព័រ ៤៨, ៧៣ (ឆ្នាំ១៩៩៣)។ Cynthia Alkon *រោគសញ្ញាគ្មានភិនភាគៈ ជំនួយផ្នែកកំណែទម្រង់ច្បាប់ក្រោមកម្មវិធីប្រជាធិបតេយ្យភាវូបនីយកម្មក្រោយរបបកុម្មុយនីស្ត,* **ឱនាឌុ.ដំណោះ.ខិ.** ទំព័រ ៣២៧, ៣៤១ (ឆ្នាំ២០០២)។ Howard L. Brown *ការិយាល័យអ្នកកសាងសន្តិភាពនៃប្រជាជាតិណាវ៉ាចូៈ វេទិកាដំណោះស្រាយវិវាទតាមសហគមន៍ចំរុះ,* **ឱនាឌុ. ដំណោះ.ខិ.** លេខ៥៧ ខែកក្កដា ឆ្នាំ២០០២ នៅទំព័រ៤៤។ Minh Day, *ដំណោះស្រាយវិវាទក្រៅផ្លូវតុលាការ និងច្បាប់តាម ទំនៀមទម្លាប់ៈ ការដោះស្រាយវិវាទកម្មសិទ្ធិ នៅក្នុងប្រជាជាតិក្រោយសង្គ្រាម ករណីសិក្សានៃប្រទេសវ៉ាន់ដា,* GEO. I MMIGR. L.J. លេខ១៦ ទំព័រ ២៣៥, ២៤៧-៥១ (ឆ្នាំ២០០១),*ធ្វើគុណកថាដោយ* Austermiller កំណត់សម្គាល់ខាងលើលេខ៨៥ នៅទំព័រ ១៤៧ នៅសម្គាល់លេខ ១១៤។

[៩៤] Patterson, *et al.,* កំណត់សម្គាល់ *ខាងលើ* លេខ៩ នៅទំព័រ៩៥។ ខុសពីសន្ធានកម្មសម័យទំនើប ដែលជាធម្មតាភាគីតែងជួបមុខគ្នា និងរៀបចំកិច្ចប្រជុំនៅកន្លែងណាមួយនោះ អន្តរការីចិនធ្វើដំណើរទៅកាន់ភាគីទាំងពីរដើម្បីផ្តល់ព័ត៌មានអំពីវិវាទ និងដំណោះស្រាយរបស់វា។

ប្រព័ន្ធអង់ក្លូសាក់សុង ភាគីវិវាទថែមទាំងអាចសម្រុះសម្រួលវិវាទរបស់ពួកគេ ក្រោយពេលដែលតុលាការផ្លូវច្បាប់បានចេញសាលក្រមរួច ថែមទៀតផង ។[៩៥]

នៅមជ្ឈឹមសម័យ ការលេចឡើងនូវរដ្ឋប្រជាជាតិ បានបណ្ដាលឱ្យមានការលេចឡើងនូវប្រព័ន្ធតុលាការរដ្ឋាភិបាល ។ ជាលទ្ធផល សន្ធានកម្មបានថមថយប្រជាប្រិយភាពរបស់វា ។ ប៉ុន្តែនៅក្នុងសតវត្សរ៍ទីម្ភៃ សន្ធានកម្មបានត្រលប់មកជាវិធីសាស្ត្រដ៏មានសារៈសំខាន់ និងមានប្រជាប្រិយភាពឡើងវិញនៅក្នុងដំណោះស្រាយវិវាទ ។ ប្រជាប្រិយ-ភាពនាពេលថ្មីៗនេះ មួយផ្នែកគឺដោយសារតែមានទស្សនៈយល់ឃើញថាប្រព័ន្ធតុលាការផ្លូវការមានភាពយឺតយ៉ាវ និងមានតម្លៃថ្លៃ ។ វាក៏ដោយសារតែភាគីនៃសន្ធានកម្ម អាចបង្កើតដំណោះស្រាយដោយខ្លួនឯងផ្ទាល់ ដែលអាចបម្រើឱ្យផលប្រយោជន៍របស់ភាគីទាំងពីរបានកាន់តែប្រសើរ ដោយការនេះមានលក្ខណៈខុសពីការវិនិច្ឆ័យជាផ្លូវការដោយតុលាការ ។

### *៣. សន្ធានកម្មនៅប្រទេសកម្ពុជា*

នៅប្រទេសកម្ពុជា សន្ធានកម្មតែងតែដើរតួនាទីយ៉ាងសំខាន់នៅក្នុងសង្គម ។ មានរបាយការណ៍មួយបានថ្លែងថា "វប្បធម៌ និងប្រព័ន្ធច្បាប់របស់ប្រទេសកម្ពុជា មាននិន្នាការជាប្រពៃណីទៅរកដល់សន្ធានកម្ម ជាជាងជម្លោះជាគូបដិបក្ខ និងបណ្ដឹងទៅតុលាការ ។ ហេតុនេះ ដំណោះស្រាយតាមការស្រុះស្រួលគឺជាធម្មនិយម..." ។[៩៦] ឧទាហរណ៍ វិវាទគ្រួសារត្រូវបានសម្រុះសម្រួលតាមទម្លាប់ដោយសមាជិកគ្រួសារផ្សេងទៀត ឬដោយមេដឹកនាំនៅក្នុងមូលដ្ឋានដែលគេគោរព ។ សព្វថ្ងៃនេះ សន្ធានកម្មបន្តដើរតួនាទីយ៉ាងសំខាន់នៅក្នុងដំណោះស្រាយវិវាទនៅប្រទេសកម្ពុជា ។ ការអង្កេតមួយរបស់ធនាគារពិភពលោកអំពីសហគ្រាសខ្នាតតូចនៅក្នុងប្រទេសកម្ពុជាបានបង្ហាញឱ្យឃើញថា សន្ធានកម្មគឺជាវិធីសាស្ត្រដ៏ពេញនិយមជាងគេក្នុងដំណោះស្រាយវិវាទ បន្ទាប់ពីការចរចា ។[៩៧]

ដោយសារតែសារៈសំខាន់នៃសន្ធានកម្មចំពោះប្រទេសកម្ពុជា ក្របខ័ណ្ឌគតិយុត្តិជាតិបានវិវត្តទៅរកការដាក់បញ្ចូលនូវជម្រើសសន្ធានកម្មជាច្រើន ហើយភាគីវិវាទអាចស្វែងរកជំនួយពីប្រភពចំរុះជាច្រើនទៀត ។ ចំពោះជម្លោះគ្រួសារ ភាគីអាចស្វែងរកជំនួយសម្រុះសម្រួលពីមន្ត្រីក្រសួងមហាផ្ទៃ ឬពីក្រុមប្រឹក្សាឃុំ-សង្កាត់នៅក្នុងមូលដ្ឋាន ។ ប្រសិនបើភាគីម្ខាងកំពុងពិចារណាពីការលែងលះ ក៏នៅមានដំណើរការ "ផ្សះផ្សា" ចំនួន១៥ថ្ងៃ ដែលចាប់ផ្ដើមនៅថ្នាក់ឃុំ-សង្កាត់ មុននឹងរឿងក្ដីត្រូវបានបញ្ជូនទៅតុលាការដែរ ។[៩៨] ក្រសួងការងារជួយសម្រុះសម្រួលវិវាទការងារ រវាងនិយោជក

---

[៩៥] *ដូចមុន* ។

[៩៦] ក្រសួងពាណិជ្ជកម្មសហរដ្ឋអាមេរិក, *មគ្គុទ្ទេសក៍ពាណិជ្ជកម្មតាមប្រទេសសម្រាប់កម្ពុជា*, ទំព័រ៥៣ (ឆ្នាំ២០០៦) ។ *សូមមើលផងដែរ* សន្និសីទអង្គការសហប្រជាជាតិស្ដីពីពាណិជ្ជកម្ម និងអភិវឌ្ឍន៍ (UNCTAD) និងសភាពាណិជ្ជកម្មអន្តរជាតិ (ICC), *មគ្គុទ្ទេសក៍វិនិយោគនៅកម្ពុជា : កាលានុវត្តភាព និងល័ក្ខខ័ណ្ឌ*, ទំព័រ ៤៦, UNCTAD/IIE/IIA/2003/6 (ខែកញ្ញា ឆ្នាំ២០០៣) ។

[៩៧] ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តនៃប្រទេសកម្ពុជា, កំណត់សម្គាល់ *ខាងលើ* លេខ១០ នៅទំព័រ៤០ (ឆ្នាំ២០០៧) ។ ការអង្កេតបានរកឃើញថា សហគ្រាសក្នុងស្រុកជ្រើសរើសយកសន្ធានកម្មជាជម្រើសល្អបំផុតទីពីររបស់ខ្លួន ជាជាងបណ្ដឹងតុលាការ ។

[៩៨] **ច្បាប់កម្ពុជាស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ** មាត្រា ៤២ (ឆ្នាំ១៩៨៩) ។

និងនិយោជិត។[៩៩] ប្រសិនបើមានវិវាទដីធ្លី ភាគីអាចស្នើសុំសន្ធានកម្មពីគណៈកម្មការសុរិយោដីរបស់រាជរដ្ឋាភិបាល ឬពីអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។[១០០] ភាគីដែលមានវិវាទពាណិជ្ជកម្ម អាចស្វែងរកសន្ធានកម្មពីមជ្ឈមណ្ឌលជាតិផ្នែកមជ្ឈត្តការថ្មី ដែលស្ថិតនៅក្រោមការទំនុកបំរុងពីសំណាក់ក្រសួងពាណិជ្ជកម្ម។[១០១] វិវាទរដ្ឋប្បវេណីតូចតាច ដូចជា បញ្ហាបំណុល កិច្ចសន្យា ព្រំប្រទល់ដី កសិដ្ឋាន ការបរិហារកេរ្តិ៍ និងអំពើហិង្សាដែលមិនបង្ករបួសស្នាម អាចត្រូវបានសម្រុះសម្រួលជាផ្លូវការនៅត្រឹមកំរិតក្រុមប្រឹក្សាឃុំ-សង្កាត់នៅក្នុងមូលដ្ឋាន តាមរយៈកម្មវិធីមជ្ឈមណ្ឌលសេវាយុត្តិធម៌របស់រាជរដ្ឋាភិបាល (អាចហៅផងដែរថា " Maison de la Justice ")។[១០២] ចៅក្រមកម្ពុជា ក៏ត្រូវបានប្រគល់សិទ្ធិអំណាច ស្របតាមក្រមនីតិវិធីរដ្ឋប្បវេណីថ្មីដើម្បីសម្រុះសម្រួលរវាងភាគីនៃបណ្តឹងផងដែរ។[១០៣]

លើសពីនេះទៅទៀត ភាគីនៅតែអាចពឹងផ្អែកលើសន្ធានកម្មនៅខាងក្រៅក្របខ័ណ្ឌច្បាប់ជាផ្លូវការ។ តាមពិតសន្ធានកម្មប្រហែលជានៅតែជាវិធីដ៏មានប្រជាប្រិយភាពក្នុងដំណោះស្រាយវិវាទ ជាងតាមរយៈប្រព័ន្ធផ្លូវការដដែល។ អ្នកជំនាញការផ្នែកច្បាប់កម្ពុជាម្នាក់បានរកឃើញថា៖

> នៅតាមជនបទដាច់ស្រយាល ដែលតុលាការត្រូវបានចាត់ទុកថាមានលក្ខណៈឆ្ងាយ និងចម្លែកនៅក្នុងទស្សនៈរបស់អ្នកភូមិ វត្ត(ព្រះវិហារពុទ្ធសាសនា) គឺជាទីដែលគេស្គាល់ច្រើនជាង ហើយត្រូវបានប្រើប្រាស់ដោយប្រជាជនក្នុងមូលដ្ឋានសម្រាប់ដំណោះស្រាយជម្លោះរបស់ពួកគេ ដោយមានជំនួយពីព្រះសង្ឃ ឬអាចារ្យវត្ត។ ដំណោះស្រាយបែបនេះតែងត្រូវបានធ្វើឡើង ជាញឹកញាប់នៅក្នុងជីវិតប្រចាំថ្ងៃ។[១០៤]

---

[៩៩] **ច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា** មាត្រា ៣០០-៣០១, ៣០៣ (ឆ្នាំ១៩៩៧) [អំណើះតទៅហៅកាត់ថា "ច.ក.ព.ក"] ។ ឈ្មោះពេញរបស់អតីតក្រសួងទទួលបន្ទុកគឺ "ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា"។ នៅឆ្នាំ២០០៤ ឈ្មោះរបស់ក្រសួងបានប្តូរទៅជា "ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ"។ សម្រាប់សៀវភៅនេះ ក្រសួងទទួលបន្ទុកការងារ គឺសំដៅដល់ "ក្រសួងការងារ" ឬ "ក្រ.ក" ។ សូមមើលជំពូកអំពីមជ្ឈត្តការ សម្រាប់ព័ត៌មានលម្អិតបន្ថែមទៀត។

[១០០] **អនុក្រឹត្យលេខ៤៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មការសុរិយោដី** ប្រការ៧-១១, រាជរដ្ឋាភិបាលកម្ពុជា, (ឆ្នាំ២០០២)**ព្រះរាជក្រឹត្យស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី** មាត្រា៣ ,រាជកិច្ចនៃព្រះរាជាណាចក្រកម្ពុជា, លេខ១៥, ទំព័រ១១៩០ (ឆ្នាំ២០០៦)។

[១០១] **ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា**, រាជកិច្ចនៃព្រះរាជាណាចក្រកម្ពុជា, លេខ៣៧, ទំព័រ ៣០០០, (ឆ្នាំ២០០៦) [អំណើះតទៅហៅកាត់ថា "ច.ម.ព"]។

[១០២] **ប្រកាសអន្តរក្រសួង របស់ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ,** លេខ៨៥ ប្រការ ៣-៤ (ឆ្នាំ២០០៦)។

[១០៣] ក.ន.វ.-ព.ក. កំណត់សម្គាល់ *ខាងលើ* លេខ៧, មាត្រា៩៧ (ឆ្នាំ២០០៦) ("តុលាការអាចសាកល្បងធ្វើការផ្សះផ្សាបាន ទោះបីជាបណ្តឹងស្ថិតនៅក្នុងដំណាក់កាលណាក៏ដោយ។") និងមាត្រា១០៤ (" នៅក្នុង នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវសាកល្បងផ្សះផ្សាជាដំបូងសិន...")។ បទអត្ថាធិប្បាយផ្លូវការ ក.ន.វ.-ព.ក. បានបញ្ជាក់ថាមាត្រាទាំងនេះគឺសំដៅដល់ការសម្រុះសម្រួលដែលធ្វើឡើងដោយតុលាការ រួមទាំងការរៀបចំកិច្ចប្រជុំជាឯកជនផ្សេងៗ (ដែលអត្ថបទនោះហៅថា "ការសាកសួរឆ្លង")។ *ខាងលើ* សម្គាល់ទី១២, គន្លីទី៣ ជំពូកទី២ ផ្នែកទី២(២)(៣), ទំព័រ ៥០-៥១។

[១០៤] គង់ ផល្លាក់ *ការរៀបចំប្រព័ន្ធដោះស្រាយវិវាទក្រៅផ្លូវតុលាការនៅប្រទេសកម្ពុជា* និក្ខេបបទថ្នាក់អនុបណ្ឌិត មហាវិទ្យាល័យជាន់ខ្ពស់ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យណាហ្គោយ៉ា ទំព័រ៤៧ (ឆ្នាំ២០០១)។ លោក ផល្លាក់ ក៏បានរៀបរាប់ផងដែរអំពីប្រពៃណី

## សំណួរសិក្សា

- តើអ្នកធ្លាប់ចូលរួមនៅក្នុងសន្ធានកម្មដែរឬទេ? អាចជាសន្ធានកម្មក្រៅផ្លូវការមួយ ដែលពាក់ព័ន្ធនឹងគ្រួសារ ឬមិត្តភក្តិមែនទេ? ប្រសិនបើមាន តើមានលទ្ធផលយ៉ាងដូចម្តេចខ្លះ?
- តើអ្នកធ្លាប់ព្យាយាមដោះស្រាយបញ្ហារវាងមិត្តភក្តិពីរនាក់ឬទេ? បើធ្លាប់ តើអ្នកគឺជាអ្នកសម្រុះសម្រួលឬ?
- តើអ្នកធ្លាប់បានឃើញ ឬដឹងឮអំពីសន្ធានកម្មជាផ្លូវការ ដែលពាក់ព័ន្ធនឹងវិវាទតាមផ្លូវច្បាប់នៅប្រទេសកម្ពុជាដែរឬទេ ? ប្រសិនបើធ្លាប់ តើមានលទ្ធផលយ៉ាងដូចម្តេចខ្លះ?

សន្ធានកម្មអាចជួយដោះស្រាយបញ្ហាមួយចំនួនពាក់ព័ន្ធនឹងប្រព័ន្ធយុត្តិធម៌នៅប្រទេសកម្ពុជា។ ការសិក្សាមួយចំនួនបង្ហាញថាសន្ធានកម្មអាចកែលម្អការទទួលបានយុត្តិធម៌ តាមវិធីជាច្រើនយ៉ាង។ សន្ធានកម្ម អាចជួយឱ្យស្រទាប់ប្រជាពលរដ្ឋក្រីក្រនៅក្នុងសង្គមបានចូលរួមនៅក្នុងដំណោះស្រាយវិវាទ ក្នុងករណីដែលពួកគេមិនអាចមានលទ្ធភាពជួលមេធាវីសម្រាប់បណ្តឹងទៅតុលាការដែលមានពីមុនមក។[១០៥] សន្ធានកម្មអាចធ្វើឡើងនៅទីជនបទ ឬតំបន់ដែលមិនមានតុលាការ។[១០៦] សន្ធានកម្មអាចត្រូវបានធ្វើឡើងនៅចុងសប្តាហ៍ ឬនៅពេលល្ងាច ដើម្បីកុំឱ្យអ្នកចូលរួមត្រូវឈប់សម្រាកពីការងារធ្វើស្រែចំការ។ លក្ខណៈក្រៅផ្លូវការនៃសន្ធានកម្មក៏អាចមានភាពមិនសូវគំរាមកំហែងចំពោះប្រជាជនដែលសំលឹងមើលប្រព័ន្ធតុលាការ ឬរដ្ឋាភិបាល ដោយភាពសង្ស័យ និងភ័យខ្លាច។[១០៧]

សន្ធានកម្មក៏អាចកែលម្អឥរិយាបថរបស់ប្រជាពលរដ្ឋ ចំពោះប្រព័ន្ធតុលាការកម្ពុជាផងដែរ។ ការសង្កត់ធ្ងន់នៃសន្ធានកម្មទៅលើការសម្រេចចិត្តដែលផ្តោតលើភាគី អនុញ្ញាតឱ្យភាគីដោះស្រាយរឿងក្តី ស្របតាមផលប្រយោជន៍របស់ពួកគេ។ ដោយសារតែដំណោះស្រាយត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្ត សន្ធានកម្ម លុបបំបាត់នូវលក្ខណៈចាប់បង្ខំដែលតម្រូវដោយសាលក្រមតុលាការ។ ការសិក្សាមួយចំនួនបានបង្ហាញថាសន្ធានកម្ម ហាក់មានអត្រាបំពេញចិត្តអ្នកប្រើប្រាស់យ៉ាង

---

ដោះស្រាយវិវាទក្រៅផ្លូវតុលាការដ៏គួរឱ្យចាប់អារម្មណ៍មួយរបស់កម្ពុជា ហៅថា *ព្រះរាជសវនាការ* (សវនាការរបស់ព្រះរាជា) ដែលក្នុងនោះនោះព្រះមហាក្សត្រខ្មែរទ្រង់ព្រះសណ្តាប់អំពីរឿងរ៉ាវវិវាទផ្សេងៗ ព្រមទាំងផ្តល់ព្រះរាជតម្រិះដែលមិនភ្ជាប់កាតព្វកិច្ច។ ពិធីនេះត្រូវបានអនុវត្តនៅមុនឆ្នាំ១៩៧០ និងបង្កើតឡើងវិញក្នុងរយៈពេលមួយដ៏ខ្លីនៅក្នុងកំឡុងឆ្នាំ១៩៩៤ ហើយក្រោយមកក៏ត្រូវបានផ្អាកដោយមិនដឹងមូលហេតុ។ *ដូចមុន* នៅទំព័រ ៥៤-៥៥។

[១០៥] SCOTT BROWN ET AL. **មគ្គុទ្ទេសក៍សម្រាប់អ្នកអនុវត្តដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ** (មជ្ឈម. ដើម្បីលទ្ធិប្រជាធិបតេយ្យ និងអភិបាលកិច្ច, USAID ឆ្នាំ១៩៩៨) *មាននៅ* http://www.usaid.gov/our_work/democracy_and_governance/publications/pdfs/pnacb895.pdf [អំណឹះតទៅហៅកាត់ថា មគ្គុទ្ទេសក៍ ADR], ឧបសម្ព័ន្ធ ខ, *ករណីសិក្សាប្រទេសស្រីលង្កា, ករណីសិក្សាប្រទេសបង់ក្លាដែស*។

[១០៦] FRED E. JANDT & PAUL B. PEDERSEN **ការគ្រប់គ្រងជម្លោះប្រកបដោយភាពស្ថាបនា: ករណីអាស៊ីប៉ាស៊ីហ្វិក** (Thousand Oaks, ឆ្នាំ១៩៩៦), កត់សម្គាល់អំពីឧទាហរណ៍គួរឱ្យចាប់អារម្មណ៍នៃគណៈកម្មាធិការសម្រុះសម្រួលប្រជាជន ដែលស្ម័គ្រចិត្ត នៅតាមភូមិ ចំនួនជាងមួយលាន នៅប្រទេសចិន ដែលត្រូវបានបង្កើតឡើងដោយរដ្ឋធម្មនុញ្ញឆ្នាំ១៩៨២។

[១០៧] Alkon កំណត់សម្គាល់ *ខាងលើ* លេខ៩៣, នៅទំព័រ៣៥៤។

ខ្ពស់។[១០៨] ជាលទ្ធផល ភាគីនៃសន្ទានកម្មអាចចាប់ផ្តើមមើលឃើញប្រព័ន្ធតុលាការទូទៅកាន់តែមានភាពវិជ្ជមាន ដែលនឹងអាចជួយឱ្យគោលការណ៍នីតិរដ្ឋកាន់តែមានភាពប្រសើរឡើង។

នៅពេលខាងមុខ សន្ទានកម្មក៏អាចជួយពង្រឹងលទ្ធិប្រជាធិបតេយ្យនៅប្រទេសកម្ពុជាផងដែរ។ នៅក្នុងប្រទេសជាច្រើន សន្ទានកម្មមានតួនាទីរៀបចំមេដឹកនាំសហគមន៍ បង្កើននូវការចូលរួមពីសំណាក់ប្រជាពលរដ្ឋ និងបង្កើតដំណើរ-ការជាសាធារណៈដែលជួយសម្រួលដល់ការផ្លាស់ប្តូររចនាសម្ព័ន្ធ និងការផ្លាស់ប្តូរជាវិជ្ជមានរបស់សង្គម ដែលសុទ្ធសឹងតែជាអត្ថប្រយោជន៍។[១០៩] ឧទាហរណ៍ អ្នកនយោបាយអាហ្វ្រិកខាងត្បូងឈានមុខគេម្នាក់បានថ្លែងថា "ភាពជោគជ័យនៃសេវាសន្ទានកម្មជាច្រើន បានជួយតម្រង់ទិសប្រទេសនេះពីវប្បធម៌ហិង្សា ទៅជាវប្បធម៌ចរចា"។[១១០] ករណីដូចគ្នានេះក៏ប្រហែលជាអាចកើតមាននៅក្នុងប្រទេសកម្ពុជាបានដែរ។

លើសពីនេះទៅទៀត ការប្រើប្រាស់ដែលកាន់តែកើនឡើងរបស់សន្ទានកម្ម (ដោយមានការបណ្តុះបណ្តាលសមស្រប) អាចជួយកសាងវប្បធម៌ស្រុះស្រួលគ្នានៅក្នុងប្រទេសកម្ពុជា។ ដោយមានជំនួយពីពេលវេលា ភាគី និងតំណាងអាចប្រើប្រាស់កាន់តែច្រើនឡើង នូវវិធីដែលមិនប្រឈមមុខដាក់គ្នា ដើម្បីដោះស្រាយជម្លោះ និងចាប់ផ្តើមមានការទទួលខុសត្រូវផ្ទាល់ខ្លួនដើម្បីដោះស្រាយជម្លោះទាំងនោះ។ ប្រការនេះមានសារៈសំខាន់ណាស់សម្រាប់ការអភិវឌ្ឍ ដែលកំពុងតែបន្តទៅមុខ របស់ប្រទេសកម្ពុជា។

## សំណួរសិក្សា

តើវិវាទដែលប្រើរយៈពេលយូរនៅប្រទេសកម្ពុជាមានអ្វីខ្លះ? តើគេអាចដោះស្រាយវិវាទទាំងនោះតាមរយៈសន្ទានកម្មបានដែរឬទេ ?

---

[១០៨] នៅក្នុងកម្មវិធីសន្ទានកម្មដែលផ្តួចផ្តើមឡើងដោយធនាគារពិភពលោក/សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ នៅប្រទេសបូស្នៀ និងអែស៊ីហ្គោវិន ៩៦ភាគរយនៃអ្នកចូលរួមបានបង្ហាញឃើញថា ពួកគេនឹងប្រើប្រាស់សន្ទានកម្មនៅលើកក្រោយទៀត។ **គម្រោងគ្រាប់ពូជនៃធនាគារពិភពលោក/សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និងវិទ្យាស្ថានកាណាដា ដើម្បីដំណោះស្រាយវិវាទ,** VESNA DASOVIC-MARKOVIC & KENDEL RUST, **ការបញ្ចូលសន្ទានកម្មនៅក្នុងសាលាដំបូងនៅបានចាលូកា**, កថាខ័ណ្ឌ៧ (ខែកញ្ញា ឆ្នាំ២០០៤) មាននៅ http://www2.ifc.org/seed/PDFs/ADR_BiH_Final_Report.PDF (ចូលទស្សនាលើក ចុងក្រោយ ខែតុលា ឆ្នាំ២០០៨), [អំណឹះតទៅហៅកាត់ថា របាយការណ៍វាយតម្លៃ BiH ធនាគារពិភពលោក], ធ្វើគុណកថា ដោយ Steven Austermiller កំណត់សម្គាល់ *ខាងលើ* លេខ៨៥, នៅទំព័រ៨៥, សម្គាល់លេខ ១៨៦។ *សូមមើលផងដែរ* មគ្គុទ្ទេសក៏ ADR, កំណត់សម្គាល់ *ខាងលើ* លេខ១០៥, នៅឧបសម្ព័ន្ធ ខ, *ករណីសិក្សាប្រទេសស្រីលង្កា*, *ករណីសិក្សាប្រទេសបង់ក្លាដែស*។

[១០៩] Austermiller កំណត់សម្គាល់ *ខាងលើ* លេខ៨៥ នៅទំព័រ១៤៣ (ធ្វើគុណកថាពីឧទាហរណ៍នៃសន្ទានកម្មនៅប្រទេសអាហ្វ្រិកខាងត្បូង ប្រទេសហ្វីលីពីន និងប្រទេសអ៊ុយក្រែន)។

[១១០] *ដូចមុន* នៅទំព័រ១៤៣, គុណកថាពីករណីសិក្សាលើប្រទេសអាហ្វ្រិកខាងត្បូង នៅក្នុងមគ្គុទ្ទេសក៏ ADR, កំណត់សម្គាល់ *ខាងលើ* លេខ១០៥។

### ៤. សន្ទានកម្មធៀបនឹងការចរចា

ជួនកាល សន្ទានកម្មប្រៀបដូចជាការចរចាប្រភេទពិសេសមួយ។ វិធីសាស្ត្រទាំងពីរនេះអនុញ្ញាតឱ្យភាគីវិវាទឈានទៅដល់ការព្រមព្រៀងរវាងគ្នានិងគ្នា។ ទាំងក្នុងសន្ទានកម្ម និងការចរចា ដំណោះស្រាយនឹងមិនអាចកើតមានឡើយ លុះត្រាតែភាគីទាំងអស់មានការព្រមព្រៀងគ្នា។ លើសពីនេះទៅទៀត វិធីសាស្ត្រទាំងពីរនេះ ជាទូទៅ តែងប្រើប្រាស់ការវិភាគផ្អែកលើផលប្រយោជន៍ដើម្បីឈានទៅដល់ដំណោះស្រាយមួយ។ ជាចុងក្រោយ វិធីទាំងពីរនេះគឺជាដំណើរការក្រៅផ្លូវច្បាប់ ដែលមានការអាចអនុញ្ញាត ប៉ុន្តែមិនតម្រូវឱ្យកូនក្តីមានមេធាវីឡើយ។ ទោះជាយ៉ាងណាក៏ដោយ គេមិនត្រូវច្រឡំគ្នារវាង សន្ទានកម្ម និងការចរចាឡើយ។ វាមានភាពខុសគ្នាសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- នៅក្នុងសន្ទានកម្ម ភាគីវិវាទនឹងចូលរួមដោយផ្ទាល់ស្ទើរតែគ្រប់ពេលទាំងអស់ក្នុងដំណើរការសម្រុះសម្រួល។ រីឯនៅក្នុងការចរចាវិញ ភាគីជាទូទៅតែងចូលរួមដោយប្រយោល តាមរយៈមេធាវីរបស់ពួកគេ ឬតំណាងផ្សេងទៀត ហើយមានវត្តមានដោយផ្ទាល់តែនៅពេលចុងបញ្ចប់ប៉ុណ្ណោះ ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀង។ ការចូលរួមដោយប្រយោលនៅក្នុងការចរចាអាចអនុវត្តបានជាពិសេស នៅពេលដែលវិវាទនោះ មានពាក់ព័ន្ធនឹងក្រុមហ៊ុនធំៗ ឬភាគីអន្តរជាតិ។

- នៅក្នុងសន្ទានកម្ម ភាគីទីបីដែលអព្យាក្រឹតតែងតែធ្វើជាប្រធានកិច្ចប្រជុំជានិច្ច។ រីឯនៅក្នុងការចរចាវិញ មិនមានការចូលរួមពីសំណាក់ភាគីទីបីឡើយ។ វាគឺជាដំណើរការឯកជនសុទ្ធសាធដែលមាន ការចូលរួមតែពីសំណាក់ភាគីដែលពាក់ព័ន្ធតែប៉ុណ្ណោះ។

- ជាទូទៅ សន្ទានកម្មគឺជាព្រឹត្តិការណ៍តែមួយ និងផ្លូវការ ដែលមានរយៈពេលមួយ ឬច្រើនថ្ងៃ។ វាមានដំណើរការចាប់ផ្តើម ពាក់កណ្តាល និងបញ្ចប់ យ៉ាងច្បាស់លាស់។ ភាគីត្រូវយល់ព្រមចូលរួមនៅក្នុង សន្ទានកម្ម ហើយជាទូទៅត្រូវធ្វើផែនការសម្រាប់កិច្ចការនេះ ដោយកំណត់អំពី សន្ទានការី ដំណើរសន្ទានកម្ម កាលវិភាគ និងថ្លៃឈ្នួល (ប្រសិនបើមាន) ក្នុងចំណោមអ្វីៗជាច្រើនទៀត។ ផ្ទុយទៅវិញ ការចរចាអាចកើតឡើង ក្នុងរយៈពេលជាច្រើនខែ ឬឆ្នាំ។ វាអាចចាប់ផ្តើម និងបញ្ចប់ដោយគ្មានការជូនដំណឹង ឬការត្រៀមខ្លួន។ ការចរចាអាចត្រូវបានធ្វើឡើងតាមរយៈទូរស័ព្ទ ទូរសារ លិខិត អ៊ីមែល ឬការពិភាក្សាទល់មុខគ្នាដោយផ្ទាល់។

- ជាទូទៅ សន្ទានកម្មកើតឡើងនៅពេលចាប់ផ្តើមវិវាទ ឬនៅពេលណាមួយមុនពេលឡើងសវនាការចម្បងនៅក្នុងបណ្តឹងផ្លូវច្បាប់។ រីឯការចរចា អាចធ្វើឡើងនៅពេលណាមួយក៏បាន សូម្បីក្រោយពេលដែលវិវាទត្រូវបានវិនិច្ឆ័យរួចក្តី។

- សន្ទានកម្ម ជាទូទៅ ត្រូវបានធ្វើឡើងដោយគិតអំពីវិធីសាស្ត្រផ្អែកលើផលប្រយោជន៍។ ចំណែកឯការចរចាដូចបានពិភាក្សានៅក្នុងជំពូកមុននេះ អាចត្រូវបានធ្វើឡើងដោយវិធីសាស្ត្រផ្អែកលើជំហរ ឬលើផលប្រយោជន៍។

### ៥. តើវិវាទណាខ្លះដែលស័ក្តិសមបំផុតចំពោះសន្ទានកម្ម?

សន្ទានកម្មគឺសមស្របបំផុត នៅពេលដែលភាគីមានបំណងចង់រក្សាចំណងទាក់ទងជាបន្តទៀត។ ឧទាហរណ៍ ប្រសិនបើ ធីតា ធ្វើការនៅភោជនីយដ្ឋានរបស់ ប៊ុនសេង ហើយពួកគេទាំងពីរនាក់មានវិវាទនឹងគ្នាអំពីរឿងម៉ោងធ្វើការ ភាគីទាំងពីរអាចនឹងចង់ដោះស្រាយវិវាទដោយមានភាគីទីបីដែលអព្យាក្រឹត ដែលអាចស្វែងរកផលប្រយោជន៍របស់ពួកគេរៀង១ខ្លួន និងជួយពួកគេឱ្យរកបាននូវដំណោះស្រាយមួយដែលមានការពេញចិត្តទាំងសងខាង។ ឧទាហរណ៍មួយទៀតពាក់ព័ន្ធនឹងប្តីប្រពន្ធមួយគូដែលឈ្លោះប្រកែកគ្នាអំពីរឿងលុយកាក់។ ដោយសារតែភាគីទាំងពីរស្រឡាញ់គ្នា ហើយនៅតែចង់រួមរស់ជាមួយគ្នាតទៅទៀត វាគឺជាផលប្រយោជន៍ប្រសើរបំផុតសម្រាប់ពួកគេ ក្នុងការព្យាយាមដោះស្រាយបញ្ហានោះដោយសន្តិវិធី។ ជួនកាលភាគីទីបីអាចសម្រុះសម្រួលភាគីទាំងពីរ ហើយសក្សាបាននូវសម្ព័ន្ធភាព ដែលអាចមានសារៈ-សំខាន់ជាងកម្មវត្ថុជាក់ស្តែងនៃវិវាទនោះទៅទៀត។

សន្ទានកម្មក៏មានសារៈប្រយោជន៍ផងដែរ ប្រសិនបើភាគីបានបង្ហាញចំណាប់អារម្មណ៍ចំពោះដោះស្រាយដែលឆាប់រហ័ស និង/ឬ ជាឯកជន។ ឧទាហរណ៍ ក្រុមហ៊ុនពីរអាចមិនខ្វល់អំពីសម្ព័ន្ធភាពនាពេលអនាគតរបស់ពួកគេ ប៉ុន្តែអាចមានចំណាប់អារម្មណ៍ខ្លាំងក្នុងដំណោះស្រាយវិវាទជាឯកជន និងឱ្យបានឆាប់រហ័ស ដើម្បីជៀសវាងការជំនុំជម្រះជាសាធារណៈនៅក្នុងតុលាការ។

សន្ទានកម្មក៏សមស្របផងដែរ ប្រសិនបើភាគីមានចំណាប់អារម្មណ៍ចំពោះដំណោះស្រាយប៉ុន្តែមិនភាពជឿជាក់លើគ្នាទៅវិញទៅមក។ សន្ទានការីដ៏ជំនាញម្នាក់អាចជួយភាគីនីមួយៗ ឱ្យបង្ហាញសម្នើរបស់ខ្លួន ដល់ភាគីម្ខាងទៀតតាមរបៀបដែលអាចទទួលយកបាន។ វាជាប្រការសំខាន់ ពីព្រោះការសង្ស័យគ្នាទៅវិញទៅមករបស់ភាគីវិវាទ អាចបង្ការមិនឱ្យពួកគេយកសម្នើរបស់សមភាគីខ្លួនមកពិចារណាឱ្យបានហ្មត់ចត់ឡើយ។

សន្ទានកម្មក៏សមស្របផងដែរ ប្រសិនបើរឿងក្តីនោះមានសារៈសំខាន់ ហើយគ្មានភាគីណាមួយអាចចាញ់បាន។ មជ្ឈត្តការ និងបណ្តឹងទៅតុលាការ ហាក់ដូចជាផ្តល់នូវសេចក្តីសម្រេចតាមផ្លូវច្បាប់ ដែលជាញឹកញាប់ តែងតម្រូវឱ្យមានអ្នកចាញ់ និងអ្នកឈ្នះ។ ប្រសិនបើគ្មានភាគីណាមួយចង់ប្រថុយនឹងការចាញ់ នោះសន្ទានកម្មអនុញ្ញាតឱ្យភាគីទាំងពីរដោះស្រាយរឿងក្តីនោះដោយឱ្យភាគីទាំងសងខាងឈ្នះ។

ដូចគ្នានេះផងដែរ ប្រសិនបើភាគីចង់រក្សាការគ្រប់គ្រងលើរបៀបដោះស្រាយវិវាទ ពេលនោះសន្ទានកម្មគឺជាជម្រើសមួយដ៏ល្អបំផុត។ ឧទាហរណ៍ បងប្អូនប្រុសពីរនាក់អាចឈ្លោះគ្នាពីរឿងគ្រប់គ្រងអាជីវកម្មរបស់គ្រួសារ ហើយចង់ដោះស្រាយបញ្ហានេះ ដោយផ្អែកលើគោលការណ៍ឯកជនមួយចំនួន។ សន្ទានកម្មអនុញ្ញាតឱ្យមានការព្រមព្រៀង និងការរៀបចំជាពិសេស ដែលអាចមិនមែនជាលទ្ធភាពមួយនៅក្នុងបណ្តឹងទៅតុលាការ។

ទោះបីជាសន្ទានកម្មគឺជាដំណើរការកាន់តែមានលក្ខណៈផ្លូវការជាងការចរចាក៏ដោយ ក៏រឿងក្តីតូចតាចមួយចំនួននៅតែអាចដោះស្រាយប្រកបដោយប្រសិទ្ធភាពតាមរយៈសន្ទានកម្មដែរ។ ឧទាហរណ៍ ប្រសិនបើសុជាតា និងសុភាពមានការឈ្លោះប្រកែកគ្នារឿងអ្នកណាលាងចាន បន្ទាប់ពីអាហារពេលល្ងាចរួច បងស្រីរបស់ពួកគេឈ្មោះ គីមសាន់អាចធ្វើអន្តរាគមន៍ ហើយជួយពួកគេរកការព្រមព្រៀងគ្នាមួយ។ កិច្ចខិតខំប្រឹងប្រែងសម្រុះសម្រួលរបស់គីមសាន់អាចកន្លងទៅមិនលើសពីពីរ-បីនាទីមែន ប៉ុន្តែវាអាចដោះស្រាយបញ្ហាបាន នៅពេលដែលការចរចាបរាជ័យ។

## សំណួរសិក្សា

ចំពោះវិវាទខាងក្រោមនេះ តើវិធីសាស្ត្រដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការណាមួយដែលប្រសើរជាងគេៈ ការចរចា ឬសន្ទានកម្ម? ចូរពន្យល់មូលហេតុ។

១. សុនាថ រស់នៅក្នុងអាគារផ្ទះល្វែងមួយនៅខេត្តកំពត។ អ្នកគ្រប់គ្រងអាគារបានជួលកម្មករមួយចំនួនពីក្រុមហ៊ុនតូចមួយ ដើម្បីសម្អាតផ្នែកខាងក្រៅអាគារជាមួយនឹងសូលុយស្យុងអាស៊ីត។ ដោយសារតែអាស៊ីតអាចធ្វើឱ្យរលាក ពួកគេព្យាយាមបិទបង្អួចអាគារទាំងអស់។ ប៉ុន្តែ ពួកគេមិនបានបិទបង្អួចនៅផ្ទះរបស់ សុនាថ ដោយសារការធ្វេសប្រហែស។ នៅពេលគាត់ចេញក្រៅផ្ទះ ទឹកអាស៊ីតខ្លះជ្រាបចូល ហើយប៉ះត្រូវគ្រឿងតុបតែងលម្អមួយចំនួនដែលគាត់ដាក់នៅជិតបង្អួច។ នៅពេលគាត់ត្រឡប់មកផ្ទះវិញ គាត់បានព្យាយាមចាប់យកគ្រឿងតុបតែងលម្អមួយ ហើយក៏រលាកដៃរបស់គាត់។

សុនាថ ព្យាយាមសុំឱ្យក្រុមហ៊ុនសម្អាតសងការខូចខាតចំពោះការរលាកដៃរបស់គាត់ ប៉ុន្តែក្រុមហ៊ុននោះបដិសេធ។ គាត់ក៏បានព្យាយាមទាមទារសំណងពីម្ចាស់អាគារផងដែរ ដែលបានជួលអ្នកសម្អាត ប៉ុន្តែម្ចាស់អាគារក៏បដិសេធដែរ។ ការវះកាត់ដើម្បីព្យាបាលដៃរបស់គាត់ត្រូវចំណាយអស់ប្រាក់២៥០ដុល្លា។ នៅពេលគាត់ចង់បន្តប្តឹងទាមទារសំណងពីក្រុមហ៊ុនសម្អាត និងម្ចាស់អាគារ គាត់មានការព្រួយបារម្ភថា ការចំណាយទៅលើបណ្តឹងតុលាការ អាចច្រើនជាងប្រាក់ដែលគាត់ទាមទារពិតប្រាកដទៅទៀត។ លើសពីនេះទៅទៀត គាត់មានការព្រួយបារម្ភថាម្ចាស់អាគារអាចមានប្រតិកម្មតបត ហើយដំឡើងថ្លៃឈ្នួល ឬបញ្ចប់កិច្ចសន្យាជួលរបស់គាត់។

២. សុវណ្ណ ជាម្ចាស់កសិដ្ឋានវ័យចំណាស់ម្នាក់។ គាត់មានដីធ្វើកសិកម្ម ទំហំ ៤០ ហិចតានៅខេត្តកំពង់ស្ពឺ ។ គាត់មានកូន៤នាក់ ប្រុស ២ ស្រី ២។ នៅពេល សុវណ្ណ ទទួលមរណភាព គាត់បានបន្សល់ទុកដីកសិដ្ឋានរបស់គាត់ដល់កូនៗ ដោយក្នុងម្នាក់ៗទទួលបាន ១០ហិចតា។ ប៉ុន្តែ មានតែបងប្រុសច្បងឈ្មោះ ឆាយ ប៉ុណ្ណោះ ដែលដឹងអំពីរបៀបដំណើរការកសិដ្ឋាននោះ។ ប្អូនប្រុស ប្អូនស្រីផ្សេងទៀត ដែលធ្វើការនៅកន្លែងផ្សេងនៅក្នុងភូមិ និងមិនដែលពាក់ព័ន្ធនឹងកសិដ្ឋាន ក៏អនុញ្ញាតឱ្យបងប្រុសច្បងរបស់ខ្លួនគ្រប់គ្រងកសិដ្ឋានដែលជាចំណែករបស់ពួកគេដែរ។ ពួកគេទទួលបានប្រាក់ចំណូលមួយចំនួនពីចំណែកកសិដ្ឋាននោះ ទោះបីជា សុវណ្ណ ទទួលបានប្រាក់បៀវត្សរ៍ដ៏ខ្ពស់សម្រាប់ការគ្រប់គ្រងរបស់ខ្លួនក៏ដោយ។

អស់រយៈពេលជាច្រើនឆ្នាំក្រោយមក ប្រាក់ចំណូលពីកសិដ្ឋានបានធ្លាក់ចុះយ៉ាងខ្លាំង។ នៅចន្លោះពេលនោះ ប្រាក់បៀវត្សរ៍របស់ឆាយបានកើនឡើង។ តាមពិត គាត់ថែមទាំងបានទិញរថយន្តថ្មីជូនប្រពន្ធរបស់គាត់ទៀតផង។ ប្អូនប្រុសស្រីរបស់គាត់មានការព្រួយបារម្ភថា ឆាយ គ្រប់គ្រងកសិដ្ឋានមិនបានល្អ។ ប៉ុន្តែ ពួកគេមានការព្រួយបារម្ភក្នុងការប្រឈមមុខតទល់នឹងបងប្រុសរបស់ខ្លួន ជាពិសេសគាត់អាចចាកចេញ ប្រសិនបើពួកគេរិះគន់ការគ្រប់គ្រងរបស់គាត់។ ប្រសិនបើមានករណីនេះកើតឡើង ពួកគេអាចនឹងត្រូវតែលក់ដីរបស់ខ្លួន។

៣. គីម និង សារឿន រស់នៅក្នុងខេត្តកំពង់ធំ ។ ពួកគេបានរៀបការជាមួយគ្នាអស់រយៈពេល១០ឆ្នាំមកហើយ ហើយមានកូនពីរនាក់។ គេទាំងពីរនាក់ស្រឡាញ់កូនរបស់ពួកគេខ្លាំងណាស់។ ប៉ុន្តែ គីម និង សារឿន មានបញ្ហាខាងទំនាក់ទំនងរបស់ពួកគេ។ សារឿនរអ៊ូរទាំថា គីម ធ្វើការច្រើនពេក និងមិនដែលចំណាយពេលនៅជាមួយនាងឡើយ ប៉ុន្តែ គីម ស្រឡាញ់ការងាររបស់គាត់ ហើយមិនចង់ឈប់ធ្វើការនោះទេ។ នៅពេលគាត់ត្រូវបានដំឡើងដំណែង និងផ្ទេរទៅធ្វើការនៅការិយាល័យរាជធានីភ្នំពេញ សារឿន បដិសេធមិនព្រមទៅជាមួយ។ ពួកគេព្រមព្រៀងគ្នាលែងលះ។ ក្នុងនោះមានបញ្ហាហិរញ្ញវត្ថុមួយចំនួនដែលពួកគេទាំងពីរត្រូវដោះស្រាយ ប៉ុន្តែបញ្ហាធំបំផុតគឺរឿងចិញ្ចឹមបីបាច់ថែរក្សាកូន និងសិទ្ធិសួរសុខទុក្ខកូន។ ទាំង គីម និង សារឿន ចង់ឃើញកូនរបស់ខ្លួន ប៉ុន្តែក៏ចង់បានដំណោះស្រាយមួយដែលប្រកបដោយឧត្តមប្រយោជន៍របស់កូនផងដែរ។ ពួកគេមានការសង្ស័យខ្លះៗថា មានអ្នកខាងក្រៅជ្រៀតជ្រែកក្នុងបញ្ហាផ្ទាល់ខ្លួនរបស់ពួកគេ។

## ៦. តើសន្ធានកម្មគួរកើតឡើងនៅពេលណា?

ដូចបានរៀបរាប់ខាងលើ សន្ធានកម្មអាចកើតឡើងស្ទើរតែគ្រប់ពេលទាំងអស់ នៅក្នុងកំឡុងពេលមានវិវាទ។ ជាទូទៅ ភាគីនឹងព្យាយាមធ្វើការចរចាក្រៅផ្លូវការជាមុនសិន។ ប្រសិនការបើការចរចាទាំងនោះបរាជ័យ ជួនកាលភាគីវិវាទនឹងសាកល្បងសន្ធានកម្មវិញម្តង។ ខដោះស្រាយវិវាទជាច្រើននៅក្នុងកិច្ចសន្យានឹងបញ្ជាក់ថា ប្រសិនបើមានវិវាទកើតឡើង ភាគីយល់ព្រមធ្វើសន្ធានកម្ម មុននឹងដាក់ពាក្យបណ្តឹងទៅតុលាការ។ ដំណើរការពិសេសហៅថា *មជ្ឈត្តការសន្ធាន* (Med-Arb) ជួនកាលត្រូវបានបញ្ជាក់ថាជាដំណើរដំណោះស្រាយវិវាទនៅក្នុងកិច្ចសន្យាពាណិជ្ជកម្ម។ នៅក្នុងដំណើរការមជ្ឈត្តការសន្ធាន ភាគីសន្យាធ្វើសន្ធានកម្មជាមុនសិន ហើយប្រសិនបើពួកគេបរាជ័យក្នុងដំណោះស្រាយបញ្ហា ភាគីនឹងចាប់ ធ្វើមជ្ឈត្តការ។ ដូច្នេះ លំដាប់លំដោយទូទៅគឺៈ

ការចរចា → សន្ធានកម្ម → មជ្ឈត្តការ ឬបណ្តឹងទៅតុលាការ

លំដាប់លំដោយនេះមានលក្ខណៈជាតក្កនុលោម ពីព្រោះវិធីសាស្ត្រទីមួយដែលត្រូវប្រើមិនត្រូវចំណាយច្រើន ឆាប់រហ័ស និងក្រៅផ្លូវការ។ បន្ទាប់ពីនោះមក វិធីសាស្ត្រដទៃទៀតនឹងមានលក្ខណៈកាន់តែផ្លូវការ និងមានតម្លៃកាន់តែខ្ពស់ នៅពេលដែលភាគីចេះតែបន្តទៅមុខតាមបញ្ជីនោះ។

សន្ធានកម្មក៏អាចកើតឡើងផងដែរ ក្រោយពីពាក្យបណ្តឹងត្រូវបានដាក់ទៅតុលាការ។ ប្រព័ន្ធតុលាការមួយចំនួនអនុញ្ញាតឱ្យមានសន្ធានកម្មដែលគាំទ្រដោយស្ថាប័នតុលាការ បន្ទាប់ពីពាក្យបណ្តឹងដើមត្រូវធ្វើ។ ដូចបានរៀបរាប់ខាងលើ ក្រមនីតិវិធីរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាចែងថា ក្នុងនីតិវិធីត្រៀមមុនពេលទាញហេតុផលផ្ទាល់មាត់ (សវនាការ) ចៅក្រមគួរសាកល្បងសម្រុះសម្រួល ដើម្បីជួយភាគីឱ្យដោះស្រាយវិវាទរបស់ពួកគេ។[១១១] ហើយក្នុងប្បញ្ញត្តិមួយទៀត ចៅក្រមត្រូវបានប្រគល់សិទ្ធិអំណាចឱ្យដឹកនាំកិច្ចប្រជុំសម្រុះសម្រួល នៅដំណាក់កាលណាមួយក៏បាន នៅក្នុងដំណើរការនៃបណ្តឹង។[១១២]

ជាទូទៅ ការព្យាយាមសម្រុះសម្រួលកាន់តែឆាប់ នឹងអាចមានភាពជោគជ័យកាន់តែច្រើន ដោយសារតែមានមូលហេតុពីរយ៉ាង។ មូលហេតុទីមួយ នៅពេលចាប់ផ្តើមដំណើរការបណ្តឹង ភាគីអាចមិនចាំបាច់ចំណាយប្រាក់ច្រើនលើមេធាវី និងសោហ៊ុយផ្សេងទៀតឡើយ។ ដំណោះស្រាយដែលឆាប់រហ័សតាមរយៈសន្ធានកម្ម ជួយសន្សំសំចៃប្រាក់លើមេធាវី និងសោហ៊ុយផ្សេងទៀតបានយ៉ាងច្រើន តាមការសន្មត់ថាភាគីបង់ប្រាក់មេធាវីផ្អែកលើតម្រូវការពេលវេលាដែលមេធាវីធ្វើការនៅលើរឿងក្តីនោះ។ ដំណោះស្រាយតាមសន្ធានកម្មនាពេលក្រោយមកទៀត នៅក្នុងដំណើរការបណ្តឹង នៅតែអាចធ្វើបាន ប៉ុន្តែវាមិនជួយឱ្យសន្សំសំចៃប្រាក់កម្រៃទៅលើមេធាវីបានច្រើននោះទេ ដោយសារការចំណាយទាំងនេះអាច

---

[១១១] ក.ន.រ.-ព.ក. កំណត់សម្គាល់ *ខាងលើ* លេខ៧, មាត្រា ១៤០។

[១១២] *ដូចមុន*, មាត្រា ៩៧។

កើតឡើងរួចទៅហើយ។ សន្ទានកម្មកាន់តែឆាប់ ក៏កាន់តែអាចមានភាពជោគជ័យច្រើនផងដែរ ពីព្រោះនៅពេលដំណើរការតាមបែបប្រតិបក្សចាប់ផ្ដើម ភាគីអាចកាន់តែលុងជ្រៅទៅក្នុងជំហរ និងអារម្មណ៍របស់ខ្លួន។

***ដោយសារវិវាទទាំងអស់ខុសពីគ្នា ប្រការសំខាន់គឺត្រូវព្យាយាមកំណត់ថាតើវិវាទនោះអាចធ្វើសន្ទានកម្មបានឬទេ មុនពេលដែលធ្វើសន្ទ្ធា។***

សន្ទានកម្មអាចមានភាពឆាប់រហ័សពេក និងមិនសមស្រប មុនពេលមានហេតុការណ៍មួយចំនួន។ នៅពេលចាប់ផ្ដើមដំណើរការបណ្ដឹងទៅតុលាការ ភាគីអាចមិនបានត្រៀមខ្លួនក្នុងការចូលរួមឱ្យបានផុសផុល។ ពួកគេអាចមិនបានស៊ើបអង្កេតឱ្យបានពេញលេញអំពីច្បាប់អនុវត្តន៍ និងអង្គហេតុ។ ពួកគេអាចមិនបានពិចារណាអំពីផលប្រយោជន៍របស់ខ្លួន។ ហើយពួកគេអាចមិនចូលរួមក្នុងការផ្លាស់ប្ដូរឯកសារ (ដែលនៅសហរដ្ឋអាមេរិកគេហៅថា "ការផ្លាស់ប្ដូរព័ត៌មាន") និងការបង្ហាញគោលជំហររបស់ខ្លួន ហេតុនេះពួកគេមិនយល់ទាំងស្រុងអំពីការទាមទាររបស់ភាគីម្ខាងទៀត។ ប្រសិនបើសន្ទានកម្មត្រូវបានសាកល្បងមុនកិច្ចការចម្បងទាំងនេះ វាគឺជាការចំណាយពេលវេលា និងលុយកាក់ដែលឥតប្រយោជន៍។ ហើយអ្វីដែលអាក្រក់ជាងនេះទៅទៀតនោះ គឺវាអាចធ្វើឱ្យភាគីមានភាពប្រេះឆា ដោយធ្វើឱ្យពួកគេខឹងសម្បារនឹងគ្នា ដោយសារមើលឃើញចំពោះគ្នាថាមានការយល់ច្រលំអំពីខ្លួន ព្រមទាំងចចេសរឹងរូស។

## ខ. សន្ធានកម្មជាឯកជន និងសន្ធានកម្មចំណុះស្ថាប័នតុលាការ

សន្ធានកម្មកើតឡើងនៅក្នុងក្របខ័ណ្ឌពីរផ្សេងគ្នាៈ សន្ធានកម្មជាឯកជន និងសន្ធានកម្មចំណុះស្ថាប័នតុលាការ។ នៅក្នុងសន្ធានកម្មជាឯកជន ភាគីវិវាទព្រមព្រៀងគ្នាដោយខ្លួនឯងក្នុងការធ្វើសន្ធានកម្ម។ ការព្រមព្រៀងនោះ អាចត្រូវបានធ្វើឡើងនៅពេលចុះកិច្ចសន្យា មុនពេលមានវិវាទជាយូរ។ ឬក៏ ប្រសិនបើកិច្ចសន្យាមិនមានបទប្បញ្ញត្តិបែបនោះទេ ភាគីអាចព្រមព្រៀងគ្នាធ្វើសន្ធានកម្មក្រោយពេលមានវិវាទកើតឡើង។

សន្ធានកម្មជាឯកជន ដូចពាក្យនេះបានបញ្ជាក់ ត្រូវបានហៅបែបនេះ ពីព្រោះវាជាការព្រមព្រៀងជាឯកជនក្នុងការសម្រុះសម្រួលវិវាទ។ ជាទូទៅ មិនមានការចូលរួមពីស្ថាប័នតុលាការ នៅក្នុងដំណើរការសន្ធានកម្មនេះឡើយ។ ការលើកលែងគឺមានតែ នៅពេលដែលតុលាការត្រូវបានស្នើសុំឱ្យអនុវត្តនូវកិច្ចព្រមព្រៀងទុកជាមុន រវាងភាគីសន្ធានកម្មប៉ុណ្ណោះ។[១១៣] បើមិនដូច្នេះទេ វានឹងមានលក្ខណៈជាឯកជនសុទ្ធសាធ។ សន្ធានការី គឺជាបុគ្គលឯកជន ហើយវេទិការសន្ធានកម្មក៏មានលក្ខណៈឯកជន។ សន្ធានកម្មជាឯកជនអាចត្រូវបានធ្វើឡើងដោយគ្មានបណ្ដឹង ឬក្នុងកំឡុងពេល ដាក់ពាក្យបណ្ដឹងទៅតុលាការ (ក្នុងករណីណាក៏ដោយ ជាទូទៅ ពាក្យបណ្ដឹងនឹងត្រូវផ្អាកសិនរហូតទាល់តែគេដឹងអំពីលទ្ធផលនៃសន្ធានកម្មនោះសិន)។ ប្រសិនបើសន្ធានកម្មនាំឱ្យមានការស្រុះស្រួលគ្នា ពេលនោះគេត្រូវដកពាក្យបណ្ដឹងវិញ ហើយនៅក្នុងប្រទេសកម្ពុជា កំនត់ហេតុសះជានឹងត្រូវធ្វើឡើងដោយចៅក្រម។[១១៤] ប្រសិនបើសន្ធានកម្មមិនបណ្ដាលអោយមានការព្រមព្រៀងគ្នានោះទេ ដំណើរការបណ្ដឹងនឹងចាប់ផ្ដើមនៅក្នុងប្រព័ន្ធតុលាការ ដោយមិនមានភាពលម្អៀងលើភាគីណាមួយឡើយ។

នៅក្នុងសន្ធានកម្មចំណុះឱ្យស្ថាប័នតុលាការ[១១៥] តុលាការអាចដំណើរការកម្មវិធីសន្ធានកម្មតែមួយផ្នែក ឬទាំងស្រុងតែម្ដង។ វាកើតឡើងនៅក្នុងកំឡុងពេលមានបណ្ដឹងតាមច្បាប់។ គេឃើញមាននីតិវិធីសន្ធានកម្មចំណុះឱ្យស្ថាប័នតុលាការជាច្រើនប្រភេទនៅទូទាំងពិភពលោក។ ជួនកាល នីតិវិធីសន្ធានកម្មចំណុះឱ្យតុលាការ មានលក្ខណៈស្ម័គ្រចិត្ត ដែលមានចៅក្រម ឬមន្ត្រីតុលាការជាអ្នកវិភាគលើរឿងក្ដី ហើយស្នើឱ្យភាគីពិចារណាធ្វើសន្ធានកម្មនៅពេលសមស្រប។ នៅក្នុងនីតិវិធីប្រភេទនេះ សន្ធានកម្មអាចកើតឡើងបានដរាបណាភាគីទាំងអស់យល់ព្រមធ្វើតែប៉ុណ្ណោះ។ ប្រសិនបើពួកគេមិនយល់ព្រមទេ គេនឹងចាប់ផ្ដើមដំណើរការរឿងក្ដីនោះបន្តទៀត។ នៅក្នុងនីតិវិធីដទៃទៀត សន្ធានកម្មមានលក្ខណៈជាកាតព្វកិច្ច ដែលទាមទារឱ្យភាគីធ្វើសន្ធានកម្ម ជាផ្នែកមួយនៃដំណើរការបណ្ដឹងនោះ។ ទោះបីជាភាគីត្រូវបានតម្រូវឱ្យធ្វើសន្ធានកម្ម តាមការតម្រូវរបស់នីតិវិធីនោះក៏ដោយ ក៏ពួកគេនៅអាចរក្សាការគ្រប់គ្រងទាំងស្រុងក្នុងការឈានទៅដល់ ឬមិនដល់កិច្ចព្រមព្រៀងស្រុះស្រួលមួយបានដែរ។

នៅក្នុងប្រព័ន្ធតុលាការមួយចំនួន សម្ចីធ្វើសន្ធានកម្មត្រូវបានតម្រូវមុនពេលដាក់ពាក្យបណ្ដឹង។[១១៦] នេះមានន័យថាភាគីដើមបណ្ដឹង ត្រូវបានតម្រូវឱ្យស្នើទៅភាគីចុងចម្លើយក្នុងការធ្វើសន្ធានកម្ម មុននឹងដាក់ពាក្យបណ្ដឹងទៅតុលា-

[១១៣] តុលាការអាចត្រូវបានស្នើសុំផងដែរ ឱ្យសម្រេចលើទិដ្ឋភាពនៃដំណើរការសន្ធានកម្ម ឬការដាក់ឱ្យអនុវត្តលទ្ធផលសន្ធានកម្មនោះ។

[១១៤] ក.ន.រ.-ព.ក. កំណត់សម្គាល់ *ខាងលើ* លេខ៧, នៅមាត្រា ២២២។

[១១៥] ជួនកាល ហៅថា សន្ធានកម្មដែលគាំទ្រដោយតុលាការ ឬការសន្ធានកម្មដោយតុលាការ។

[១១៦] ជាទូទៅ ករណីនេះគឺជាការតម្រូវជាមុនសម្រាប់តែរឿងក្ដីប្រភេទខ្លះប៉ុណ្ណោះ ដូចជាការទាមទារតូចតាច ឬវិវាទនៃច្បាប់ស្ដីពីគ្រួសារ។

ការ។ ប្រសិនបើភាគីចុងចម្លើយយល់ព្រម ពេលនោះសន្ទានកម្មនឹងកើតឡើង។ ប្រសិនបើភាគីចុងចម្លើយបដិសេធ នោះនឹងមិនមានសន្ទានកម្មទេ ហើយភាគីដើមបណ្ដឹងបានបំពេញគ្រប់ល័ក្ខខ័ណ្ឌតម្រូវរបស់ខ្លួនរួចហើយ និងអាចបន្តដាក់បណ្ដឹងទៅតុលាការបាន។

អាស្រ័យទៅលើវិធីដែលគេរៀបចំ សន្ទានការីនៅក្នុងនីតិវិធីចំណុះឱ្យស្ថាប័នតុលាការអាចជាចៅក្រម[១១៧] ជាមេធាវី ឬជាអ្នកជំនាញក្នុងវិស័យឧស្សាហកម្មឯកជន ដែលចុះកិច្ចសន្យាជាមួយស្ថាប័នតុលាការ។ ជួនកាល សន្ទានការីមិនមែនជាអ្នកចុះកិច្ចសន្យាជាមួយតុលាការទេ ប៉ុន្តែត្រូវបានជួលដោយក្រុមហ៊ុនសន្ទាកម្មឯកជន ដែលផ្ដល់សេវាសន្ទាន-កម្មជំនួសឱ្យតុលាការនោះ។

ភាពខុសគ្នាដ៏សំខាន់មួយទៀតរវាងសន្ទានកម្មចំណុះឱ្យតុលាការ និងសន្ទានកម្មឯកជនគឺការអនុវត្ត។ នៅពេលសន្ទានកម្មចំណុះឱ្យតុលាការបានផលជាការព្រមព្រៀងមួយ ជាទូទៅវានឹងត្រូវកត់ត្រានៅក្នុងកំនត់ហេតុតុលាការ ហើយអាចអនុវត្តបានដោយស្វ័យប្រវត្តិដូចជាសាលក្រមដែរ។ ផ្ទុយទៅវិញ សន្ទានកម្មឯកជន មិនអាចអនុវត្តបានតាមគ្រប់ពេលវេលា តាមវិធីនោះឡើយ។

វិធានអនុវត្តសន្ទានកម្មឯកជនមានភាពខុសគ្នាយ៉ាងខ្លាំងនៅទូទាំងពិភពលោក។ នៅក្នុងរដ្ឋជាច្រើននៃប្រទេសអូស្ត្រាលី កិច្ចព្រមព្រៀងដែលធ្វើឡើងតាមរយៈសន្ទានកម្មក្រៅដែនកំនត់នៃបែបបទដែលចំណុះឱ្យតុលាការ មិនអាចត្រូវបានកត់ត្រាដោយតុលាការឡើយ លើកលែងតែដំណើរការបណ្ដឹងទៅតុលាការកំពុងប្រព្រឹត្តទៅ។[១១៨] វិធានទាំងនេះមានលក្ខណៈស្រដៀងគ្នានឹងនៅសហរដ្ឋអាមេរិកដែរ។ ក៏ប៉ុន្តែ ប្រសិនបើមានដំណើរការបណ្ដឹងទៅកាន់តុលាការសហរដ្ឋហើយជាទូទៅ តុលាការចេញដីកាបង្គាប់មួយដែលបញ្ចូលកិច្ចព្រមព្រៀងស្រុះស្រួលរបស់ភាគីទៅក្នុងសាលក្រម ហើយដែលអាចអនុវត្តបានដូចជាដីការបស់តុលាការដែរ។[១១៩] ប្រសិន បើតុលាការមិនបញ្ចូលកិច្ចព្រមព្រៀងនោះទៅក្នុងដីការបស់ខ្លួនទេនោះ កិច្ចព្រមព្រៀងសម្រុះសម្រួលគឺគ្រាន់តែជាកិច្ចសន្យាធម្មតាតែប៉ុណ្ណោះ ដែលអាចអនុវត្តបានតាមរយៈបណ្ដឹងពីបទរំលោភលើកិច្ចសន្យា។ មានការលើកលែងមួយគឺ ចំពោះបណ្ដឹងពាក់ព័ន្ធនឹងច្បាប់ស្ដីពីគ្រួសារ (ដូចជាការលែងលះ សិទ្ធិគ្រប់គ្រងថែរក្សាកូន សិទ្ធិសួរសុខទុក្ខ និងកាតព្វកិច្ចអាហារកិច្ចជាដើម) ដែលក្នុងនោះ កិច្ចព្រមព្រៀងសម្រុះសម្រួលត្រូវបានចាត់ទុកស្ទើរតែគ្រប់ករណីទាំងអស់ថាជាសាលក្រមតុលាការ។[១២០] នៅប្រទេសបូស្នី និងអ៊ែរហ្សេហ្គោវីន ច្បាប់ថ្មីស្ដីពីសន្ទានកម្ម តម្រូវឱ្យដំណោះស្រាយតាមសន្ទានកម្មទាំងអស់ ទោះជាឯកជន ឬចំណុះឱ្យតុលាការក្ដី អាចអនុវត្តបានដូចសាលក្រមតុលាការដែរ។[១២១]

---

[១១៧] នៅសហរដ្ឋអាមេរិក ចៅក្រមជាញឹកញាប់តែងធ្វើការសម្រុះសម្រួលនៅក្នុង "ការប្រជុំដោះស្រាយ" បុរេ-សវនាការក្រៅផ្លូវការ។

[១១៨] មគ្គុទ្ទេសក៍ផ្ទះផ្សា UNCITRAL កំណត់សម្គាល់ *ខាងលើ* លេខ៨៧ នៅ កថាខ័ណ្ឌ៩០។

[១១៩] *សូមមើល ជាឧទា.* **បទអធិប្បាយអំពីក្រមអនុវត្តនិងដំណោះស្រាយវដ្ឋប្បវេណីរដ្ឋតិចសាស់** ផ្នែកទី១៥៤.០៧១(a)(b) (West. Supp. ឆ្នាំ១៩៩៧)

[១២០] Patterson, *et al.* កំណត់សម្គាល់ *ខាងលើ* លេខ៩ នៅទំព័រ ១០៨។

[១២១] ZAKON O POSTUPKU MEDIJACIJE BOSNE I HERCEGOVINE [ច្បាប់ស្ដីពីនីតិវិធីសម្រុះសម្រួលប្រទេសបូស្នីអ៊ែក-ហ្សេហ្គោវីន] មាត្រា ២៥ (ឆ្នាំ២០០៤)។

នៅក្នុងយុត្តាធិការមួយចំនួនដូចជា អាល្លឺម៉ង់ ឥណ្ឌា ប៉េរមុយដា ហុងកុង និងចិន ដំណោះស្រាយតាមសន្ធានកម្មឯកជន អាចត្រូវបានបម្លែងទៅជាមជ្ឈត្តវិនិច្ឆ័យដែលមានប្រសិទ្ធិភាពអនុវត្តដូចសាលក្រមតុលាការដែរ ។[១២២] សន្ធានកម្មនៅកម្ពុជាក៏ទំនងជានឹងមានវិធានអនុវត្តន៏ប្រហាក់ប្រហែលគ្នានេះដែរ ។ ច្បាប់កម្ពុជាស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ច.ម.ពា) ចែងថាសេវាសម្រុះសម្រួលអាចត្រូវបានផ្តល់ជូនភាគីនៃមជ្ឈត្តការ ។[១២៣] ច.ម.ព. ក៏បានចែងបន្ថែមផងដែរថាដំណោះស្រាយតាមការសម្រុះសម្រួលដែលបានធ្វើឡើងនៅពេលនោះ អាចត្រូវបានកត់ត្រាជាមជ្ឈត្តវិនិច្ឆ័យ ដែលនឹងមានប្រសិទ្ធិភាពអនុវត្តដោយតុលាការយ៉ាងឆាប់រហ័សដូចគ្នានឹងមជ្ឈត្តវិនិច្ឆ័យផ្សេងទៀតផងដែរ ។[១២៤]

***នៅប្រទេសកម្ពុជា ដំណោះស្រាយតាមរយៈសន្ធានកម្មដែលអាចកើតឡើងនៅមជ្ឈមណ្ឌលមជ្ឈត្តការកម្ពុជានឹងត្រូវដាក់ឱ្យអនុវត្តបាន ដោយតុលាការកម្ពុជា ដូចជាសាលក្រមតុលាការក្នុងស្រុកផងដែរ ។***

ហើយដូចបានរៀបរាប់ពីខាងលើ ដំណោះស្រាយតាមរយៈសន្ធានកម្មដែលធ្វើឡើង នៅក្នុងកំឡុងពេលដែលដំណើរការបណ្តឹងកំពុងប្រព្រឹត្តទៅ និងត្រូវបានចាត់ទុកថាជា *ការសះជាតាមផ្លូវតុលាការ* ដែលនឹងទទួលបានការអនុវត្តដ៏ឆាប់រហ័សដូចជាសាលក្រមរបស់តុលាការក្នុងស្រុកផងដែរ ។[១២៥]

---

[១២២] *សូមមើល* **ច្បាប់ស្តីពីមជ្ឈត្តការ** (ឆ្នាំ១៩៨៦) (ប្រទេសប៉េរមុយដា), **បទបញ្ញត្តិស្តីពីមជ្ឈត្តការ និងការផ្សះផ្សា** មាត្រា ៧៣-៧៤ (ឆ្នាំ១៩៩៦) (ប្រទេសឥណ្ឌា), ZIVILPROZEßORDNUNG [**ក្រមនីតិវិធីរដ្ឋប្បវេណីអាល្លឺម៉ង់**] គន្ថីទី១០ កថាខណ្ឌ១០៥៣ (ប្រទេសអាល្លឺម៉ង់), **បទបញ្ញត្តិស្តីពីមជ្ឈត្តការ** កថាខណ្ឌ២គ ចំណងជើងទី៣៤១ (ឆ្នាំ១៩៩៧) (ទីក្រុងហុងកុង), **ច្បាប់ស្តីពីមជ្ឈត្តការនៃសាធារណរដ្ឋប្រជាមានិតចិន** មាត្រា ៥១ (ឆ្នាំ១៩៩៥) (ប្រទេសចិន) ។

[១២៣] ច.ម.ព កំណត់សម្គាល់ *ខាងលើ* លេខ១០១, មាត្រា ៣៨ ។

[១២៤] *ដូចមុន* មាត្រា ៣៨(២) -(៣) ។

[១២៥] ក.ន.រ.-ព.ក. កំណត់សម្គាល់ *ខាងលើ* លេខ៧, មាត្រា ២២២ ។

## គ. គុណសម្បត្តិ និងគុណវិបត្តិនៃសន្ធានកម្ម

### ១. *គុណសម្បត្តិ*

- **ល្បឿន**

សន្ធានកម្មអនុញ្ញាតឱ្យភាគីដោះស្រាយវិវាទលំបាកៗក្នុងរយៈពេលមួយដ៏ខ្លី ជាទូទៅ គឺក្នុងរយៈពេលមួយថ្ងៃ ឬតិចជាងនេះ។[១២៦] បណ្ដឹងទៅតុលាការ ឬមជ្ឈត្តការអាចប្រើពេលអស់ជាច្រើនខែ ឬច្រើនឆ្នាំ។ ការចរចាក៏មានសក្ដានុពលក្នុងការដោះស្រាយបញ្ហាបានឆាប់រហ័សដែរ ប៉ុន្តែដោយសារវាច្រើនតែកើតឡើងដោយគ្មានពេលកំណត់ ឬភាពបន្ទាន់ វាក៏អាចអូសបន្លាយពេលវេលាឱ្យយូរបានដែរ។ ផ្ទុយទៅវិញ សន្ធានកម្ម ជាទូទៅគឺជាព្រឹត្តិការណ៍តែមួយ ដែលកើតឡើងក្នុងរយៈពេលខ្លី ទើបវាអាចដោះស្រាយបញ្ហាបានឆាប់រហ័ស។[១២៧]

- **ការចំណាយ**

ស្របពេលដែលការចរចាជាឯកជន តែងតែជាបច្ចេកទេសដោះស្រាយវិវាទដែលមានតម្លៃថោកជាងគេបំផុតនោះ ការចំណាយសម្រាប់សន្ធានកម្មក៏ច្រើនតែមានតម្លៃទាបជាងជម្រើសដទៃទៀតដូចជា បណ្ដឹងទៅតុលាការ ឬមជ្ឈត្តការដែរ។[១២៨] ជាទូទៅសន្ធានកម្មមានរយៈពេលមួយ ឬពីរថ្ងៃ ដូច្នេះថ្លៃសោហ៊ុយមេធាវី និងថ្លៃឈ្នួលមជ្ឈមណ្ឌលសន្ធានកម្មក៏មានតម្លៃទាបតាមនោះដែរ។ ចំពោះវិវាទសាមញ្ញៗ សន្ធានកម្មដែលធ្វើឡើងដោយមិត្តភក្តិ ឬសាច់ញាតិ ក៏អាចមិនអស់ថ្លៃអ្វីទាំងអស់ ដូចជាការចរចាដូច្នោះដែរ។

- **ការគ្រប់គ្រងរបស់ភាគីចំពោះលទ្ធផល**

ជាមួយសន្ធានកម្ម ភាគីនៅតែជាអ្នកគ្រប់គ្រងលើលទ្ធផលដដែល។ ភាគីអាចសម្រេចថាតើនឹងមានដំណោះ-ស្រាយ ដែរឬទេ និងនៅក្នុងល័ក្ខខ័ណ្ឌអ្វីខ្លះ។ ភាគីធ្វើការកំនត់ផងដែរ ថាតើដំណើរការនោះជាការបង្ហិនពេលវេលាឬទេ ហើយគួរតែបញ្ចប់ ឬយ៉ាងណា។ គ្មាននរណាម្នាក់អាចបង្ខំភាគីសន្ធានកម្មឱ្យធ្វើអ្វីមួយនោះទេ។

- **ការរក្សាសម្ព័ន្ធភាពជាបន្ត**

ដូចជាការចរចាដែរ សន្ធានកម្មអនុញ្ញាតឱ្យភាគីអាចរៀបចំដំណោះស្រាយមួយ ដែលអាចរក្សាសម្ព័ន្ធភាពរបស់ពួកគេជាបន្តទៅទៀត។[១២៩] ប្រការនេះមានសារៈសំខាន់ណាស់សម្រាប់សង្គមខ្មែរ ពីព្រោះទំនាក់ទំនងផ្ទាល់ខ្លួនគឺជាកត្តាចាំបាច់សម្រាប់កិច្ចការជំនួញ នយោបាយ និងសកម្មភាពក្នុងវិស័យដទៃទៀត។ ឧទាហរណ៍ ប្រសិនបើដៃគូអាជីវកម្មមានវិវាទអំពីរឿងអចលនទ្រព្យ ហើយមានលទ្ធភាពចរចាលើកិច្ចព្រមព្រៀងមួយនោះ ពួកគេអាចរក្សាសម្ព័ន្ធភាពរបស់ខ្លួន ហើយបន្តទំនាក់ទំនងអាជីវកម្មដែលមានអត្ថប្រយោជន៍តទៅទៀត។ នៅក្នុង

---

[១២៦] Petterson, et al. កំណត់សម្គាល់ *ខាងលើ* លេខ៩ នៅទំព័រ៩៧។

[១២៧] *ឧទាហរណ៍* មគ្គុទ្ទេសក៍ ADR, កំណត់សម្គាល់ *ខាងលើ* លេខ១០៥, នៅទំព័រ ៧-៨។

[១២៨] *ដូចមុន* នៅទំព័រ១៦-១៧ ។

[១២៩] *ដូចមុន* នៅទំព័រ១២។

បណ្ដឹងទៅតុលាការ ឬមជ្ឈត្តការ ដែលមានភាគីទីបីជាអ្នកសម្រេចចំពោះបញ្ហានោះ ដំណោះស្រាយនោះអាចមិនជួយឱ្យភាគីទាំងសងខាងសប្បាយចិត្តគ្រប់គ្រាន់ ដើម្បីឱ្យពួកគេបន្តធ្វើការជាមួយគ្នាតទៅទៀតបានឡើយ ។

- **ភាពជាឯកជន**

ដំណើរសន្ទានកម្មតម្រូវឱ្យមានរក្សាការសម្ងាត់ ។ យុត្តាធិការជាច្រើនផ្ដល់ការការពារដល់ព័ត៌មានដែលពាក់ព័ន្ធទៅនឹងការចរចា ឬសន្ទានកម្ម ទោះបីជាវាមិនបណ្ដាលឱ្យមានការព្រមព្រៀង ហើយវិវាទនោះត្រូវតែបន្តការប្ដឹងផ្ដល់ក៏ដោយ ។ ឧទាហរណ៍ដូចជា ច្បាប់ស្ដីពីការផ្សះផ្សារបស់ UNCITRAL ចែងដូចខាងក្រោម៖[១៣០]

មាត្រា ៩ : ការរក្សាការសម្ងាត់

*លើកលែងតែមានការព្រមព្រៀងផ្ទុយពីនេះដោយភាគីវិវាទ ព័ត៌មានទាំងអស់ដែលពាក់ព័ន្ធទៅនឹងដំណើរការផ្សះផ្សាត្រូវរក្សាជាការសម្ងាត់ លុះណាតែច្បាប់តម្រូវឱ្យធ្វើការផ្សព្វផ្សាយ សម្រាប់គោលដៅអនុវត្ត និងដាក់ឱ្យអនុវត្តនូវកិច្ចព្រមព្រៀងស្រុះស្រួល ។*

នេះគឺជាបទប្បញ្ញត្តិរួមដែលគេឃើញមាននៅក្នុងយុត្តាធិការជាច្រើន ។ សន្ទានកម្មអាចធ្វើទៅបាន មួយផ្នែកគឺដោយសារតែភាគីអាចមានការជឿជាក់ថា ការពិភាក្សា និងសម្ដីដោះស្រាយរបស់ពួកគេ នឹងមិនត្រូវបានលើកឡើងម្ដងទៀត ឬប្រើប្រាស់ប្រឆាំងនឹងពួកគេម្ដងទៀតឡើយ នាពេលអនាគត ។ ផ្ទុយទៅវិញ ដំណើរការបណ្ដឹងតុលាការ ជាទូទៅត្រូវបានបើកចំហជាសាធារណៈ ។

- **លទ្ធភាពបត់បែន**

ភាគីវិវាទមានលទ្ធភាពបត់បែនជាច្រើនក្នុងការរៀបចំដំណើរការសន្ទានកម្ម ។ សន្ទានការីអាចដើរតួនាទីត្រឹមតែជួយសម្របសម្រួលធម្មតាដោយស្ដាប់ភាគីនីមួយៗ និងលើកទឹកចិត្តដល់ពួកគេ ។ ឬ សន្ទានការីអាចមានតួនាទីកាន់តែសកម្ម ដោយជួបប្រជុំជាមួយភាគីនីមួយៗដោយឡែកពីគ្នាដើម្បី ស្វែងយល់បន្ថែមអំពីផលប្រយោជន៍ និងជំហររបស់ពួកគេ ហើយនៅទីបំផុតថែមទាំងអាចស្នើឡើងនូវដំណោះស្រាយដែលអាចមានទៀតផង ។

ដូចគ្នានឹងការចរចាដែរ *លទ្ធផល* នៃសន្ទានកម្មក៏អាចមានលក្ខណៈបត់បែនណាស់ដែរ ។ ដោយសារតែ ភាគីវិវាទខ្លួនឯងជាអ្នកឈានទៅដល់ដំណោះស្រាយ ពួកគេអាចព្រមព្រៀងគ្នាទៅលើដំណោះស្រាយនានា ដែលប្រហែលជាមិនអាចទៅរួចឡើយក្នុងមជ្ឈត្តការ ឬបណ្ដឹងទៅតុលាការ ។ ឧទាហរណ៍ នៅក្នុងវិវាទមួយជាមួយ និយោជិតដែលត្រូវបានបញ្ឈប់ពីការងារ ក្រុមហ៊ុនអាចយល់ព្រមផ្ដល់ដល់និយោជិតដែលត្រូវបញ្ឈប់ពីការងារនោះនូវកិច្ចព្រមព្រៀងពិគ្រោះយោបល់ ជាថ្នូរនឹងការសន្យារបស់គាត់ ថានឹងមិនធ្វើការប្រកួតប្រជែងជាមួយអតីតនិយោជករបស់គាត់ឡើយ ។ ទោះជាការដែលភាគីទាំងពីព្រមព្រៀងយ៉ាងដូច្នេះ ពិតជាអាចធ្វើទៅបានក្ដី ជាទូទៅ តុលាការមិនមានសិទ្ធិអំណាចក្នុងការបញ្ចូលប្រការនេះទៅក្នុងសាលក្រមឡើយ ។

[១៣០] ច្បាប់ផ្សះផ្សា UNCITRAL, កំណត់សម្គាល់ *ខាងលើ* លេខ៤៨៧, មាត្រា ៩ ។

- **ការអនុវត្តដំណោះស្រាយ**

ដូចបានរៀបរាប់ខាងលើរួចមកហើយ ជាទូទៅកិច្ចព្រមព្រៀងដែលកើតពីសន្ទានកម្មដែលចំណុះឱ្យស្ថាប័នតុលាការអាចយកមកអនុវត្តដូចសាលក្រមតុលាការដែរ ដែលមានន័យថាវាមានដំណើរការអនុវត្តឆាប់រហ័ស។[១៣១] អាស្រ័យលើយុត្តាធិការនីមួយៗ កិច្ចព្រមព្រៀងចេញពីសន្ទានកម្មឯកជនក៏អាចត្រូវ បានអនុវត្តដូចសាលក្រមតុលាការដែរ។ នៅប្រទេសកម្ពុជា ដំណោះស្រាយដែលកើតចេញពីសន្ទានកម្មជាឯនជន ដែលធ្វើឡើងនៅវេទិកាធ្វេមជ្ឈត្តកម្មណាមួយគួរតែបានទទួលសិទ្ធិអនុវត្តយ៉ាងឆាប់រហ័សបែបនេះ។[១៣២] នេះគឺជាអត្ថប្រយោជន៍ដ៏ធំធេង ជាងដំណោះស្រាយតាមរយៈការចរចា ដែលមិនទទួលបាននូវសិទ្ធិអនុវត្តន៍ឆាប់រហ័សឡើយ។

- **ឱកាសខ្ពស់នៃការព្រមព្រៀង**

កម្មវិធីសន្ទានកម្មជាច្រើនរាយការណ៍ថាមានអត្រាព្រមព្រៀងខ្ពស់។[១៣៣] ផ្អែកលើតួលេខទាំងនេះ សន្ទានកម្មប្រហែលជាមានភាពជោគជ័យក្នុងការសម្រេចបានការព្រមព្រៀងជាងការចរចា។ សន្ទានកម្មជោគជ័យជាងការចរចាដោយសារមូលហេតុមួយចំនួន។ មូលហេតុទីមួយគឺថា នៅក្នុងសន្ទានកម្ម ភាគីវិវាទមានឱកាសពិសេសក្នុងការជួប និងស្តាប់រឿងរ៉ាវរបស់ភាគីម្ខាងទៀតនៅក្នុងក្របខ័ណ្ឌក្រៅផ្លូវការ។ មូលហេតុទីពីរគឺថា ការចរចាតាមរយៈមេធាវីអាចមានហានិភ័យដែលថាព័ត៌មាននឹងត្រូវបំប្លែង ឬយល់ខុស នៅពេលវាត្រូវបានបញ្ជូនពីភាគី "ក" ទៅមេធាវីរបស់ភាគី "ក"នោះ បន្ទាប់មក គឺពីមេធាវីរបស់ភាគី "ខ" ទៅភាគី "ខ" ផ្ទាល់។ នៅក្នុងសន្ទានកម្មការប្រាស្រ័យទាក់ទងគ្នាអាចត្រូវបានធ្វើឡើងដោយផ្ទាល់ និងច្បាស់លាស់។ មូលហេតុទីបី ការចរចាច្រើនតែធ្វើឱ្យជម្លោះបុគ្គលិកលក្ខណៈរបស់មេធាវីចរចាពីររូប កាន់តែមានភាពធ្ងន់ធ្ងរឡើង ចំណែកឯសន្ទានកម្មវិញអនុញ្ញាតឱ្យភាគីអព្យាក្រឹតដោះស្រាយបញ្ហាទាំងនោះ។ និងមូលហេតុទីបួន ក្នុងករណីមានការសង្ស័យគ្នា

---

[១៣១] *សូមមើល, ឧទា.* Betty Southard Murphy *ផលប៉ះពាល់នៃដំណោះស្រាយវិវាទក្រៅផ្លូវតុលាការទៅលើពាណិជ្ជកម្មអន្តរជាតិ,* **ធិនាន្ន. ជំរេណាះ. ទិ** លេខ ៤៨, ទំព័រ៦៨, ៧៣ (ឆ្នាំ១៩៩៣) (សំដៅដល់អត្រានៃការអនុវត្តតាម ចំនួន៩០ភាគរយ)។ មគ្គុទ្ទេសក៏ ADR, កំណត់សម្គាល់ *ខាងលើ* លេខ១០៥, ឧបសម្ព័ន្ធខ, *ករណីសិក្សាលើប្រទេសស្រីលង្ការ ករណីសិក្សាលើប្រទេសអាហ្វ្រិកខាងត្បូង*។

[១៣២] *សូមមើល* របាយការណ៍វាយតម្លៃ BiH ធនាគារពិភពលោក, កំណត់សម្គាល់ *ខាងលើ* លេខ១០៨, នៅទំព័រ ១៥៨, សម្គាល់លេខ ១៨៦ (គុណកថាអំពីអត្រាពេញចិត្តរបស់អ្នកប្រើប្រាស់ដែលមានចំនួន៩៦%)។ *សូមមើលផងដែរ* មគ្គុទ្ទេសក៏ ADR, កំណត់សម្គាល់ *ខាងលើ* លេខ១០៥, ឧបសម្ព័ន្ធខ, *ករណីសិក្សាលើប្រទេសស្រីលង្ការ ករណីសិក្សាលើប្រទេសបង់ក្លាដេស*។

[១៣៣] កម្មវិធីសន្ទានកម្មមានភាពជោគជ័យនៅទូទាំងពិភពលោកៈ អត្រាព្រមព្រៀង ៦៧% មាននៅប្រទេសបូស្នី និងអ៊ែរហ្សេហ្គោវីន (*ការបង្ហាញអំពីការសម្រុះសម្រួលនៅបានចាលូកា និងសារ៉ាហ្សេវ៉ូ,* MEDIJATOR, ខែវិច្ឆិកា ដល់ខែធ្នូ ឆ្នាំ២០០៥ នៅទំព័រ ៣)។ អត្រាព្រមព្រៀង ៥០-៦០% មាននៅប្រទេសអាល្លឺម៉ង់ (C. Buhring-Uhle *មជ្ឈត្តការ និងការសម្រុះសម្រួលនៅក្នុងអាជីវកម្មអន្តរជាតិៈ ការរៀបចំនីតិវិធីសម្រាប់ការគ្រប់គ្រងវិវាទប្រកបដោយប្រសិទ្ធភាព,* នៅទំព័រ ២៧៨ សម្គាល់លេខ៥៧ (ឆ្នាំ១៩៩៦) *សម្រង់សម្ដីរបស់* Klaus Rohl)។ អត្រាព្រមព្រៀង ៦២% នៅរដ្ឋអ៊ីលីន័ស សហរដ្ឋអាមេរិក (Lynn P. Cohn *សន្ទានកម្មៈ ជម្រើសប្រកបដោយយុត្តិធម៌ និងប្រសិទ្ធភាពក្រៅពីការជំនុំជម្រះ,* របាយការណ៍សង្ខេបរបស់គណៈមេធាវី DuPage County (ខែតុលា, ឆ្នាំ១៩៩៦)។ អត្រា៨៥-៨៥%មាននៅរដ្ឋតិចសាស់ សហរដ្ឋអាមេរិក (David S. Winston *បទដ្ឋានចូលរួមក្នុងលក្ខន្តិកៈសន្ទានកម្មជាកាតព្វកិច្ច, អ្នកអាចនាំសេះទៅរកទឹកផឹក..* **ធិនា.ជំ.ទិ. រដ្ឋអូហាយូ** ទំព័រ ១៨៧, ១៩០ (ឆ្នាំ១៩៩៦)។

ទៅវិញទៅមក សម្ចើដោះស្រាយដែលលើកឡើងដោយសន្ធានការី អាចត្រូវបានទទួលយកដោយប្រាកដប្រជា និងគ្មានការសង្ស័យ ជាងសម្ចើដែលលើកឡើងដោយមេធាវីបដិបក្ខរបស់ភាគីមួយ។

- **"ថ្ងៃឡើងតុលាការ" របស់ភាគីវិវាទ**

ជូនកាល វាជារឿងសំខាន់សម្រាប់ភាគីមួយ ក្នុងការមានឱកាសប្រាប់ភាគីម្ខាងទៀតអំពីរឿងរ៉ាវរបស់ខ្លួន និងមានអារម្មណ៍ដូចជាខ្លួនត្រូវបានគេស្តាប់។ ប្រការនេះអាចធ្វើឱ្យភាគីមានអារម្មណ៍ល្អប្រសើរជាងមុនបន្តិច ទោះជាមានល័ក្ខខ័ណ្ឌនៃការព្រមព្រៀងបែបណាក៏ដោយ។ នៅក្នុងប្រទេសមួយចំនួន ចំនុចនេះត្រូវបានគេហៅថាជាការមាន "ថ្ងៃឡើងតុលាការ"។ ជាធម្មតា ការចរចាមិនផ្តល់ឱកាសដែលរៀបចំឱ្យហេតុការណ៍នេះកើតឡើងឡើយ។

- **ជៀសវាងអំពើពុករលួយ**

លក្ខណៈស្ម័គ្រចិត្តនៃដំណោះស្រាយតាមសន្ធានកម្ម ធ្វើឱ្យអ្នកចូលរួមមិនសូវរងគ្រោះនឹងអំពើពុករលួយទេ។[១៣៤] សន្ធានការីមិនអាចទាមទារប្រាក់កម្រៃក្រៅផ្លូវការឡើយដោយសារខ្លួនមិនមាន ការគ្រប់គ្រង ឬសិទ្ធិអំណាចលើភាគីវិវាទឡើយ។

- **ការជ្រើសរើសភាគីអព្យាក្រឹត**

នៅក្នុងកិច្ចប្រជុំសន្ធានកម្ម ភាគីវិវាទតែងជ្រើសរើសភាគីអព្យាក្រឹតរបស់ខ្លួន ពោលគឺខុសពីដំណើរការបណ្តឹងទៅតុលាការ ដែលចៅក្រមត្រូវបានចាត់តាំងឡើង។ ការជ្រើសរើសនេះអាចជួយឱ្យភាគីមាន អារម្មណ៍ជឿជាក់ថាសន្ធានការីមិនមានភាពលម្អៀង។

## ២. *គុណវិបត្តិ*

- **ភាគីដែលគ្មានហេតុផល**

គ្មានភាគីណាមួយនៅក្នុងសន្ធានកម្មត្រូវបានបង្ខំឱ្យព្រមព្រៀងលើអ្វីមួយឡើយ។ ចំណុចនេះ ជាគុណសម្បត្តិផង និងជាគុណវិបត្តិផង។ ប្រសិនបើភាគីម្ខាងគ្មានហេតុផល ហើយមិនចង់ដោះស្រាយនោះ គ្មានអ្វីដែលសន្ធានការីអាចធ្វើបានឡើយ។ សន្ធានកម្មអាចក្លាយទៅជាការបំផ្លាញពេលវេលា និងលុយកាក់ឥតប្រយោជន៍ ប្រសិនបើមានភាគីណាមួយ ឬភាគីទាំងពីរ គ្មានហេតុផល ឬមិនមានឆន្ទៈក្នុងការដោះស្រាយ។ នៅក្នុងករណីខ្លះ ប្រការនេះអាចបណ្តាលឱ្យមានការកើនឡើងនូវកម្រិតសង្ស័យ និងស្អប់ខ្ពើមរវាងភាគីទាំងពីរថែមទៀត។

- **អំណាចចរចាមិនស្មើភាពគ្នា**

ប្រសិនបើភាគីមានអំណាចចរចាមិនស្មើភាពគ្នា សន្ធានកម្មអាចមានគ្រោះថ្នាក់សម្រាប់ភាគីដែលខ្សោយជាង ។ ឧទាហរណ៍ ក្រុមហ៊ុនធំមួយអាចមានអំណាចចរចាខ្លាំងជាង បើប្រៀបធៀបជាមួយហាងទំនិញជាលក្ខណៈគ្រួសារដ៏តូចមួយ។ ប្រសិនបើភាគីទាំងពីរធ្វើសន្ធានកម្ម ក្រុមហ៊ុនធំអាចគំរាមកំហែង ឬសម្លុតភាគីដែលទន់

---

[១៣៤] Austermiller កំណត់សម្គាល់ *ខាងលើ* លេខ៨៥ នៅទំព័រ១៤២ សម្គាល់លេខ៨០។ សន្ធានការីដែលពុករលួយនៅតែអាចព្យាយាមបង្ខំឱ្យភាគីព្រមព្រៀង តាមរយៈឧបាយកលដោះខ្លួន ឬការបង្ខិតបង្ខំ។

ខ្សោយជាងឱ្យព្រមព្រៀងលើដំណោះស្រាយដែលអយុត្តិធមិបាន។ នៅក្នុងករណីនេះ ភាគីទន់ខ្សោយជាងអាចទទួលបានការការពារប្រសើរជាងនេះ ដោយវត្តមានចៅក្រម ឬមជ្ឈត្តករ។

- **ការអនុវត្តដំណោះស្រាយ**

អាស្រ័យទៅតាមយុត្តាធិការនីមួយៗ ដំណោះស្រាយតាមរយៈសន្ធានកម្មជាឯកជនខ្លះអាច និងខ្លះមិនអាចមានវិធានអនុវត្តន៍ឆាប់រហ័ស។ ហេតុនេះ ភាគីត្រូវពិចារណាលើយុត្តាធិការនៅកន្លែងដែលខ្លួនចុះកិច្ចសន្យាដើម្បីធានាថាពួកគេយល់អំពីវិធានអនុវត្តន៍នៅទីនោះ។ ប្រសិនបើបើពួកគេស្ថិតនៅក្នុងយុត្តាធិការមួយ ដែលមិនផ្តល់នូវវិធានអនុវត្តន៍ឆាប់រហ័ស សម្រាប់ដំណោះស្រាយតាមការសម្រុះសម្រួលជាឯកជន ដូចជានៅប្រទេសអូស្ត្រាលីជាដើមនោះ សន្ធានកម្មអាចមានភាពទាក់ទាញកាន់តែតិច។

- **ការចំណាយ**

សន្ធានកម្មអាចមិនអស់ប្រាក់ ប្រសិនបើសន្ធានការីគឺជាសមាជិកគ្រួសារ ឬជាមិត្តភក្តិរបស់ភាគីទាំងពីរ។ ប៉ុន្តែប្រសិនបើវិវាទកើតឡើងក្នុងចំណោមអ្នកមិនមែនជាសាច់ញាតិ ឬក្រុមហ៊ុន ជាទូទៅសន្ធានការីគឺជាភាគីអព្យាក្រឹតដែលយកថ្លៃឈ្នួល។ ភាគីអាចមិនទាន់ចង់ចំណាយប្រាក់សម្រាប់សន្ធានកម្ម តែអាចសាកល្បងចរចាគ្នាជាមុនសិន ដើម្បីពិនិត្យមើលថាអាចមានដំណោះស្រាយដោយមិនចាំបាច់ចំណាយលើអ្នកខាងក្រៅឬទេ។[១៣៥]

- **ភាពជាឯកជន**

ទោះជាការប្រាស្រ័យទាក់ទងគ្នារវាងភាគីវិវាទ ពាក់ព័ន្ធនឹងសន្ធានកម្មត្រូវបានរក្សាជាការសម្ងាត់តាមច្បាប់ក្តី យុត្តាធិការមួយចំនួនដូចជាប្រទេសកម្ពុជាជាដើម មិនមានច្បាប់សន្ធានកម្ម ដែលការពារជាពិសេសដល់ការប្រាស្រ័យទាក់ទងគ្នាពាក់ព័ន្ធនឹងសន្ធានកម្មនៅឡើយទេ។ អាស្រ័យហេតុនេះ ភាគីមិនអាចធានាបាននូវភាពជាឯកជនមួយរយភាគរយឡើយ។ ទោះបីជានៅក្នុងយុត្តាធិការ ដែលមានការការពារដល់ការសម្ងាត់ក៏ដោយក៏ពួកគេនៅតែត្រូវជឿជាក់ថាសន្ធានការីនឹងមិនផ្សព្វផ្សាយព័ត៌មានសម្ងាត់នោះដែរ។ ចំណែកឯនៅក្នុងការចរចាវិញ គឺគ្មានភាគីទីបីណាមួយដែលគួរឱ្យព្រួយបារម្ភឡើយ។

[១៣៥] ទោះបីជាការចរចាអាចមានរយៈពេលវែង ដែលអាចចំណាយប្រាក់ច្រើនសម្រាប់កម្រៃមេធាវីក្តី។

# ឃ. ការធ្វើសេចក្តីព្រាងលើប្បញ្ញត្តិអំពីសន្ទានកម្ម

ទំនាក់ទំនងអាជីវកម្មភាគច្រើនតម្រូវឱ្យមានកិច្ចសន្យាជាលាយលក្ខណ៍អក្សរដែលមានបញ្ចូលនូវខអំពីដំណោះ-ស្រាយវិវាទ។ ខនេះត្រូវបានដាក់បញ្ចូលទៅក្នុងកិច្ចសន្យា ដើម្បីឱ្យភាគីយល់ដឹងយ៉ាងច្បាស់ អំពីរបៀបដែលពួកគេនឹងដោះស្រាយវិវាទនាពេលអនាគត។ ប្រការនេះគឺដើម្បីការពារភាគីទាំងសងខាង។ ខស្តីពីដំណោះស្រាយវិវាទអាចជ្រើសរើសយកវិធីសាស្ត្រណាមួយ ដូចជាបណ្តឹងតុលាការ ឬសន្ទានកម្ម។

***មេធាវីដែលឆ្លាត និងពិចារណាលើផលប្រយោជន៍នៃកូនក្តីរបស់ខ្លួន ដើម្បីធានាថាខស្តីពីដំណោះស្រាយវិវាទនោះ ផ្តល់នូវវិធីសាស្ត្រដែលស័ក្តិសមបំផុតសម្រាប់តម្រូវការរបស់កូនក្តីខ្លួន។***

ប្រសិនបើកូនក្តីចង់ធានាថា វិវាទត្រូវបានដោះស្រាយតាមរយៈសន្ទានកម្ម ខស្តីពីដំណោះស្រាយវិវាទត្រូវមានបញ្ជាក់អំពីសន្ទានកម្ម។ ប្បញ្ញត្តិនោះអាចចែងត្រឹមតែថា ភាគីនឹងដោះស្រាយវិវាទតាមរយៈសន្ទាកម្ម។ ឬលើសពីនេះទៅទៀត ប្បញ្ញត្តិនោះក៏អាចបញ្ជាក់ផងដែរអំពីទីកន្លែងដែលសន្ទានកម្មនឹងប្រព្រឹត្តិទៅ។ ខនេះត្រូវចែងពីរយៈពេលដែលសន្ទានកម្មត្រូវបញ្ចប់ មុនពេលធ្វើមជ្ឈត្តការ ឬដាក់បណ្តឹងទៅតុលាការ។

ខាងក្រោមនេះគឺជាខសម្រុះសម្រួលគម្រូចំនួនបួនដែលអាចត្រូវបានប្រើប្រាស់ក្នុងកិច្ចសន្យាមួយៈ

*១. ប្រសិនបើមានវិវាទកើតឡើង ចេញពី ឬពាក់ព័ន្ធនឹងកិច្ចសន្យានេះ ឬដោយសារការរំលោភកិច្ចសន្យានោះ ហើយប្រសិនបើវិវាទនោះមិនអាចត្រូវបានដោះស្រាយតាមការចរចា ភាគីវិវាទព្រមព្រៀងគ្នា ក្នុងការព្យាយាមដោយសុឆន្ទៈដើម្បីដោះស្រាយវិវាទនោះតាមរយៈសន្ទានកម្មដែលគ្រប់គ្រងដោយសមាគមមជ្ឈត្តការអាមេរិក ជាមុនសិន មុននឹងពឹងផ្អែកលើមជ្ឈត្តការ បណ្តឹងទៅតុលាការ ឬនីតិវិធីដោះស្រាយវិវាទផ្សេងទៀត។*

ឬ

*២. ក្នុងករណីមានវិវាទកើតឡើងរវាងភាគីនៃ [កិច្ចសន្យា កិច្ចសន្យាជួល ។ល។] នោះភាគីយល់ព្រមចូលរួមយ៉ាងហោចណាស់ ក្នុងសន្ទានកម្មក្នុងរយៈពេល៤ម៉ោង ស្របតាមនីតិវិធីសន្ទានកម្មរបស់មជ្ឈមណ្ឌលសន្ទានកម្មជាតិនៃប្រទេសកម្ពុជា។ ភាគីយល់ព្រមរ៉ាប់រងសោហ៊ុយនៃសន្ទានកម្មម្នាក់ពាក់កណ្តាល។ សន្ទានកម្មត្រូវគ្រប់គ្រងដោយ [ជម្រើសមួយក្នុងចំណោមជម្រើសដូចតទៅនេះៈ (១) ចាត់តាំងការិយាល័យពិសេសមួយ ដោយមានអាសយដ្ឋាន និងលេខទូរស័ព្ទ (២) ផ្តល់វិធីសាស្ត្រក្នុងការកំណត់ការិយាល័យត្រឹមត្រូវ ដូចជា "ទៅកន្លែងដែលរោងចក្រផលិតមានស្ថិតនៅ" ឬ (៣) បញ្ចូល "ការិយាល័យតាមមូលដ្ឋានណាមួយដែលត្រូវបានចាត់តាំងដោយទីស្នាក់ការកណ្តាល នៃមជ្ឈមណ្ឌលសន្ទានកម្មជាតិដែលនៃប្រទេសកម្ពុជា"។*

*សន្ទានកម្មទាមទារឱ្យភាគីនីមួយៗនៃវិវាទអង្គុយចុះជាមួយបុគ្គលមិនលម្អៀងម្នាក់ គឺសន្ទានការី ដើម្បីព្យាយាមស្វែងរកការព្រមព្រៀងដោយស្ម័គ្រចិត្តមួយ ។ សន្ទានកម្មមិនតម្រូវឱ្យមាននីតិវិធី ឬវិធានរបស់តុលាការជាផ្លូវការពាក់ព័ន្ធនឹងការបង្ហាញភស្តុតាងឡើយ ហើយសន្ទានការីមិនមានសិទ្ធិអំណាចអ្វីក្នុងការចេញសេចក្តីសម្រេចភ្ជាប់កាតព្វកិច្ចឡើយ ឬបង្ខំឱ្យភាគីព្រមព្រៀងគ្នាឡើយ ។*

ឬ

*៣. ប្រសិនបើមានវិវាទកើតចេញពី ឬពាក់ព័ន្ធនឹងកិច្ចសន្យានេះ ឬដោយការរំលោភកិច្ចសន្យានេះ ហើយប្រសិនបើវិវាទនោះ មិនអាចត្រូវបានដោះស្រាយតាមរយៈការពិភាក្សាគ្នាដោយផ្ទាល់នោះ ភាគីទាំងពីរព្រមព្រៀងគ្នាថានឹងខិតខំដោះស្រាយវិវាទនោះដោយសន្ទានកម្មដែលគ្រប់គ្រង ដោយសមាគមមជ្ឈត្តការអាមេរិក ជាមុនសិន តាមនីតិវិធីសន្ទានកម្មផ្នែកពាណិជ្ជកម្ម មុននឹងពឹងផ្អែកលើមជ្ឈត្តការ ។ ភាពខ្វែងគំនិតគ្នា ឬការទាមទារ ដែលមិនអាចដោះស្រាយបាន និងដែលកើតចេញពី ឬពាក់ព័ន្ធនឹងកិច្ចសន្យានេះ ឬដោយសារការរំលោភកិច្ចសន្យានេះ នឹងត្រូវដោះ-ស្រាយដោយមជ្ឈត្តការ ដែលគ្រប់គ្រងដោយសមាគមមជ្ឈត្តការអាមេរិក ស្របតាមវិធានមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ស្ថាប័ននេះ ហើយការសម្រេចលើមជ្ឈត្តវិនិច្ឆ័យដែលចេញដោយមជ្ឈត្តករ អាចបញ្ចូលក្នុងតុលាការណាមួយដែលមានយុត្តាធិការលើនោះ ។ ប្រសិនបើភាគីវិវាទទាំងអស់យល់ព្រម សន្ទានការីដែលបានចូលរួមធ្វើសន្ទានកម្មឱ្យភាគីទាំងនោះ អាចត្រូវបានស្នើសុំឱ្យធ្វើជាមជ្ឈត្តករបាន ។*

ឬ

*៤. នៅពេលមានវិវាទណាមួយកើតចេញពី ឬជាប់ពាក់ព័ន្ធនឹងកិច្ចសន្យានេះ ហើយភាគីវិវាទចង់ស្វែងរកដំណោះស្រាយមួយដោយសន្តិវិធីលើវិវាទនោះតាមរយៈការផ្សះផ្សា ការផ្សះផ្សានោះត្រូវធ្វើឡើងដោយអនុលោមតាមវិធានផ្សះផ្សា UNCITRAL ដែលមានជាធរមាន ។*[១៣៦]

---

[១៣៦] វិធានផ្សះផ្សា UNCITRAL, U.N GAOR, 35$^{Th}$ Sess., supp. 17 ឯកសារអ.ស.ប. លេខA35/52 កថាខ័ណ្ឌ ១០៥-១០៦ (ឆ្នាំ១៩៨០) *មាននៅអាសយដ្ឋាន* http://www.uncitral.org/uncitral/en/uncitral_texts/arbitration/1980Conciliation_rules.html (ចូលទស្សនាលើកចុងក្រោយថ្ងៃទី១០ តុលា ២០០៨) [អំណឹះតទៅហៅថា វិធានផ្សះផ្សា UNCITRAL]។ ទាំងនេះគឺជាវិធានគម្រូដែលខុសពីច្បាប់គម្រូដែលកំណត់នៅក្នុងច្បាប់ផ្សះផ្សា UNCITRAL, កំណត់សម្គាល់ *ខាងលើ* លេខ៨៧។ នៅក្នុងអាសយដ្ឋានដែលបានលើកជាគុណកថា ខាងលើ អ.ស.ប. អធិប្បាយអំពីវិធានទាំងនេះដូចតទៅ: "អនុម័តដោយ UNCITRAL នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៨០ វិធានផ្សះផ្សា UNCITRAL ផ្តល់ជាវិធានពេញលេញ ដែលតាមនេះភាគីវិវាទអាចព្រមព្រៀងគ្នាសម្រាប់ការរៀបចំដំណើរការផ្សះ-ផ្សា ដែលកើតចេញពីទំនាក់ទំនងពាណិជ្ជកម្មរបស់ពួកគេ។ វិធានទាំងនេះគ្រប់ដណ្តប់លើគ្រប់ទិដ្ឋភាពទាំងអស់នៃដំណើរការផ្សះផ្សា ផ្តល់នូវខផ្សះផ្សាគម្រូមួយ កំណត់នៅពេលការផ្សះផ្សាត្រូវបានចាត់ទុកថាបានចាប់ផ្តើម និងបញ្ចប់ ព្រមទាំងចែងអំពីទិដ្ឋភាពនៃនីតិវិធីពាក់ព័ន្ធទៅនឹងការតែងតាំង និងតួនាទីរបស់អ្នកផ្សះផ្សា និងការរៀបចំដំណើរការជាទូទៅ។ វិធានទាំងនេះក៏ចែងផងដែរអំពីបញ្ហានានាដូចជាការរក្សាការសម្ងាត់ ភាពអាចទទួលយកបាននៃភស្តុតាងនៅក្នុងដំណើរការដទៃទៀត និងការដាក់កម្រិតទៅលើ

ដូចបានរៀបរាប់ខាងលើ នៅក្នុងយុត្តាធិការភាគច្រើន វិធានរក្សាការសម្ងាត់នឹងការពារភាគីពីការផ្សព្វផ្សាយព័ត៌មាន ដែលមានផ្តល់នៅក្នុងកំឡុងវគ្គសន្ទានកម្ម។ ប៉ុន្តែដើម្បីឱ្យមានសុវត្ថិភាព ភាគីអាចបន្ថែមខស្តីពីរក្សាការសម្ងាត់ដូចខាងក្រោម ៖

*លើកលែងតែមានការព្រមព្រៀងផ្ទុយពីនេះដោយភាគី ព័ត៌មានទាំងអស់ពាក់ព័ន្ធនឹងដំណើរការសន្ទានកម្មត្រូវរក្សាជាការសម្ងាត់ លើកលែងតែច្បាប់តម្រូវឱ្យធ្វើការផ្សព្វផ្សាយ ក្នុងគោលបំណងអនុវត្ត និងដាក់ឱ្យអនុវត្តកិច្ចព្រមព្រៀងដោះស្រាយ។*

ខនេះគោរពតាមច្បាប់ផ្សះផ្សារបស់ UNCITRAL[១៣៧] ហើយផ្តល់នូវកម្រិតរក្សាការសម្ងាត់ក្នុងកម្រិតខ្ពស់បំផុតតាមដែលអាចធ្វើបាន។

## សំណួរសិក្សា

ក្រុមហ៊ុនដូងប្រេងរតនៈ ចុះកិច្ចសន្យាជាមួយក្រុមហ៊ុនអូស្ត្រាលី ដើម្បីលក់ចំណែកដ៏ធំនៃផលិតផលដូងប្រេងរបស់ខ្លួន។ ម្ចាស់ក្រុមហ៊ុនអូស្ត្រាលីមានឈ្មោះល្បីថាជាអ្នកចរចាដ៏តឹងរឹង និងឆាប់ខឹងបំផុត។ ដោយសារតម្លៃខ្ពស់ពេកធ្វើឱ្យក្រុមហ៊ុនរតនៈ មានការព្រួយបារម្ភថាក្រុមហ៊ុនអូស្ត្រាលី អាចខកខានមិនទទួលទទួលយកទំនិញ ឬអាចមិនព្រមបង់តម្លៃទិញរបស់ខ្លួនទាំងអស់នាពេលអនាគត ។

លោកអ្នកជាមេធាវីរបស់រតនៈ ហើយត្រូវធ្វើសេចក្តីព្រាងបទប្បញ្ញត្តិដោះស្រាយវិវាទសម្រាប់កិច្ចសន្យានេះ។

---

សិទ្ធិរបស់ភាគីក្នុងដំណើរការតុលាការ ឬមជ្ឈត្តការ នៅពេលការផ្សះផ្សាកំពុងប្រព្រឹត្តទៅ"។ *ដូចមុន*។ វិធានផ្សះផ្សារ UNCITRAL ត្រូវបាន បោះពុម្ពឡើងវិញទាំងស្រុងនៅក្នុងឧបសម្ព័ន្ធ ក នៃសៀវភៅនេះ។

[១៣៧] ច្បាប់ផ្សះផ្សារ UNCITRAL កំណត់សម្គាល់ *ខាងលើ* លេខ៨៧, មាត្រា ៩។

# ខ. ដំណើរការសន្ធានកម្ម

ដំណើរការសន្ធានកម្មជាអាទិ៍ មាន៧ដំណាក់កាល :

១. ការផ្តួចផ្តើមសន្ធានកម្ម

២. ការជ្រើសរើសសន្ធានការី

៣. ការផ្តល់ព័ត៌មានដល់សន្ធានការី

៤. ការបើកកិច្ចប្រជុំសម្រុះសម្រួល

៥. កិច្ចប្រជុំដោះស្រាយបញ្ហាទូទៅ

៦. ការប្រជុំជាឯកជន

៧. ការបញ្ចប់សន្ធានកម្ម

ការសិក្សានានាបង្ហាញថានីតិវិធីសន្ធានកម្ម គឺជាកត្តាចម្បងសម្រាប់ភាពជោគជ័យនៃសន្ធានកម្ម។ ប្រសិនបើភាគីយល់ឃើញថាដំណើរការនោះមានភាពយុត្តិធម៌ ពួកគេអាចនឹងតែចង់ដោះស្រាយ។ នៅពេលដែលភាគីបង្កើតវិធាននីតិវិធីដោយខ្លួនឯង អត្រានៃការព្រមព្រៀងនឹងរឹតតែខ្ពស់ថែមទៀត។[១៣៨] ដោយការចងចាំទុកនូវចំណុចនេះដំណាក់កាលខាងក្រោមនេះនឹងត្រូវពិនិត្យមើលឡើងវិញឱ្យកាន់តែលម្អិត។

## *១. ការផ្តួចផ្តើមសន្ធានកម្ម*

ដំណាក់កាលដំបូងបំផុតនៅក្នុងសន្ធានកម្មនីមួយៗ គឺការផ្តួចផ្តើមសន្ធានកម្ម។ ដូចគ្នានឹងដំណើរការ ADR ភាគច្រើនដទៃទៀតដែរ សន្ធានកម្មតែងកើតឡើង ប្រសិនបើមានកាលៈទេសៈណាមួយក្នុងចំណោមបីខាងក្រោមកើតឡើងៈ

១. ភាគីមាន ខសន្យាពីដំណោះស្រាយវិវាទ នៅក្នុងកិច្ចសន្យាដែលមានស្រាប់របស់ពួកគេ ដែលបានជ្រើសរើសយកមធ្យោបាយសន្ធានកម្មមកប្រើ។

២. ភាគីសម្រេចចិត្តធ្វើសន្ធានកម្ម បន្ទាប់ពីវិវាទបានកើតឡើង ឬ

៣. តុលាការបានបង្គាប់ ឬណែនាំឱ្យភាគីធ្វើសន្ធានកម្ម។

នៅក្នុងកាលៈទេសៈទី១ និងទី២ ភាគីដែលផ្តួចផ្តើមសន្ធានកម្មផ្ញើលិខិតអញ្ជើញជាលាយលក្ខណ៍អក្សរដើម្បីសម្រុះសម្រួលវិវាទនោះ។ លិខិតអញ្ជើញអាចដាក់បញ្ចូលនូវការស្នើឡើងអំពីទីតាំង និងវិធានសម្រាប់សន្ធានកម្មនោះ។ ភាគីម្ខាងទៀតអាចយល់ព្រមតាមការអញ្ជើញ ឬបដិសេធ។ ប្រសិនបើភាគីម្ខាងទៀតយល់ព្រម នោះភាគីទាំងពីរត្រូវ

---

[១៣៨] Douglas Henderson *ភាពជោគជ័យនៃការសម្រុះសម្រួលៈ ការវិភាគដែលសំអាងលើការពិសោធន៍,* **ធិនា.ជំ.ធិ. រដ្ឋអូហាយូ** លេខ១១ ទំព័រ ១៥០ (ឆ្នាំ១៩៩៦)។ *សូមមើលផងដែរ* Keith G. Allred *ភាពសកម្មនៃទំនាក់ទំនងក្នុងវិវាទ* **សៀវភៅណែនាំអំពីដំណោះស្រាយទិវាទ** នៅទំព័រ ៨៣, ៩១ (Michael L. Moffitt, Robert C. Bordone ed., ឆ្នាំ២០០៥)។

ចាប់ផ្ដើមកំណត់វិធាន និងស្វែងរកសន្ទានការី ។ ប្រសិនបើភាគីម្ខាងទៀតបដិសេធ សន្ទានកម្មនឹងមិនកើតមានឡើយ ហើយភាគីអាចអនុវត្តវិធីផ្សេងទៀត ។ ប្រសិនបើភាគីមានខស្ដីពីសន្ទានកម្មនៅក្នុងកិច្ចសន្យាពីមុនមក ហើយភាគីម្ខាងបដិសេធមិនព្រមធ្វើសន្ទានកម្ម នោះភាគីម្ខាងទៀតអាចស្វែងរកសេចក្ដីបង្គាប់ពីតុលាការដែលតម្រូវឱ្យធ្វើសន្ទានកម្ម ។ សេចក្ដីបង្គាប់របស់តុលាការបែបនេះនឹងតម្រូវឱ្យភាគី *ចូលរួម* នៅក្នុងសន្ទានកម្ម ប៉ុន្តែមិនអាចបង្គាប់ឱ្យភាគីត្រូវតែយល់ព្រមដោះស្រាយនៅក្នុងសន្ទានកម្មនោះឡើយ ។

យោងតាមវិធានស្ដីពីការផ្សះផ្សារបស់ UNCITRAL (បោះពុម្ពឡើងវិញនៅក្នុងឧបសម្ព័ន្ធ ក)[១៣៩] ប្រសិនបើភាគីដែលផ្ដួចផ្ដើមការផ្សះផ្សាមិនទទួលបានចម្លើយតបនៅក្នុងរយៈពេល៣០ថ្ងៃ ចាប់ពីថ្ងៃផ្ញើលិខិតអញ្ជើញនោះ ឬក្នុងរយៈពេលមួយដែលមានចែងនៅក្នុងលិខិតអញ្ជើញនោះ ភាគីនោះអាចចាត់ទុកថា ភាគីម្ខាងទៀតបដិសេធចំពោះការអញ្ជើញឱ្យមកផ្សះផ្សានោះ ។ ប្រសិនបើភាគីនោះចាត់ទុកថាដូច្នេះ ភាគីនោះត្រូវជូនដំណឹងដល់ភាគីម្ខាងទៀត ។

ប្រសិនបើតុលាការបានបង្គាប់ឱ្យមានសន្ទានកម្មដែលពាក់ព័ន្ធនឹងកម្មវិធីសន្ទានកម្មចំណុះឱ្យស្ថាប័នតុលាការ នោះតុលាការទំនងជានឹងផ្ដល់ដល់ភាគីនូវសន្ទានការី និងវិធានអនុវត្តន៍ផងដែរ ។

## ២. *ការជ្រើសរើសសន្ទានការី*

បន្ទាប់ពីសន្ទានកម្មត្រូវបានបង្កើតឡើងជាយន្តការដំណោះស្រាយវិវាទរួចមក ភាគីវិវាទត្រូវតែជ្រើសរើសយកសន្ទានការីមួយរូប ។ ប្រសិនបើភាគីមិនបានចាត់តាំងមជ្ឈមណ្ឌលសន្ទានកម្មជាក់លាក់ណាមួយនោះទេ ពួកគេអាចជ្រើសរើសអ្នកណាម្នាក់ក៏បានដែលខ្លួនចូលចិត្ត និងតាមរបៀបណាមួយដែលខ្លួនចូលចិត្ត ។ ប្រសិនបើពួកគេយល់ព្រមប្រើប្រាស់មជ្ឈមណ្ឌលសន្ទានកម្មជាក់លាក់ណាមួយនោះ ដូចជាមជ្ឈមណ្ឌលសន្ទានកម្មនៃប្រទេសសិង្ហបុរី វិធានរបស់មជ្ឈមណ្ឌលនោះនឹងកំណត់ថាតើមានសន្ទានការីណាខ្លះដែលអាចធ្វើបាន ព្រមទាំងរបៀបជ្រើសរើសពួកគេផងដែរ ។

សន្ទានកម្មជាច្រើនតម្រូវឱ្យមានអ្នកសម្រុះសម្រួលម្នាក់ ។ យ៉ាងណាមិញ គេក៏អាចធ្វើសន្ទានកម្មដែលមានសន្ទានការីពីរនាក់ ឬរហូតដល់បីនាក់ផងក៏បាន ។ លើកលែងតែមានមូលហេតុច្បាស់លាស់ក្នុងការធ្វើបែបនេះ ការណែនាំជាទូទៅគឺគេគួរធ្វើវាជាមួយសន្ទានការីតែម្នាក់ ។ មជ្ឈមណ្ឌលសន្ទានកម្មទំនងជានឹងផ្ដល់នូវបញ្ជីសន្ទានការីសក្ដានុភូតដល់ភាគី ឬប្រសិនបើពួកគេមិនយល់ព្រម ឬមិនចង់សម្រេចចិត្ត មជ្ឈមណ្ឌលក៏អាចតែងតាំងសន្ទានការីម្នាក់ សម្រាប់រឿងក្ដីនោះផងដែរ ។

ខាងក្រោមនេះគឺជាបញ្ជីបញ្ហាដើម្បីពិចារណា នៅពេលជ្រើសរើសសន្ទានការី ។ តើសន្ទានការីនោះ:

- មានអព្យាក្រឹតពេញលេញ និងគ្មានទំនាក់ទំនងជាមួយភាគីណាមួយ មែនឬទេ ?
- មានចំណេះដឹងអំពីបញ្ហាដែលជាកម្មវត្ថុនៃវិវាទ (ឧទាហរណ៍ដូចជា ស្ដង់ដារ និងវិធាននៃឧស្សាហកម្មសាងសង់អាគារ)ដែរឬទេ?
- មានបទពិសោធន៍នៅក្នុងសន្ទានកម្មដែរឬទេ?

---

[១៣៩] វិធានផ្សះផ្សា UNCITRAL, កំណត់សម្គាល់ *ខាងលើ* លេខ១៣៦ នៅមាត្រា ២(៤) ។

- ជាមេធាវី ចៅក្រម ឬជាអ្នកដែលគ្មានចំណេះដឹងខាងច្បាប់?
- ជាមន្ត្រីរដ្ឋាភិបាល?
- មានភាពលម្អៀងនៅក្នុងផ្លូវណាមួយ ដូចជាគាំទ្រនិយោជិត ឬស្អប់ជនបរទេស ដែរឬទេ?
- ត្រូវបានណែនាំដោយភាគីដទៃទៀតឬ?
- មានតម្លៃថ្លៃដែរឬទេ?
- ជាអ្នកស្តាប់ដ៏ល្អឬទេ?
- ពូកែបញ្ចុះបញ្ចូលដែរឬទេ?

## សំណួរសិក្សា

វិទ្ធី និង ម៉ូណា រស់នៅខេត្តកំពង់ចាម ហើយបានរៀបអាពាហ៍ពិពាហ៍នឹងគ្នាអស់រយៈពេល១០ឆ្នាំមកហើយ។ ម៉ូណា យល់ឃើញថា វិទ្ធី ចំណាយប្រាក់អស់យ៉ាងច្រើនទៅលើល្បែងស៊ីសង។ វិទ្ធី រអ៊ូរទាំថា ម៉ូណា ព្រងើយកន្តើយនឹងខ្លួន ហើយមិនមើលថែទាំផ្ទះ និងកូនចៅឱ្យបានត្រឹមត្រូវ។ វិទ្ធី ជាមនុស្សមាឌធំ និងចូលចិត្តគំរាមកំហែង ហើយ ម៉ូណា មិនដែលហ៊ានឈ្លោះប្រកែកជាមួយវិទ្ធីទេ ដោយសារខ្លាចគេវាយនាង។ ពួកគេមិនសប្បាយចិត្ត ហើយកំពុងពិចារណាពីការលែងលះគ្នា ប៉ុន្តែមិនចង់និយាយជាមួយសន្ធានការីសិន ដើម្បីឱ្យដឹងថាតើបញ្ហារបស់ពួកគេអាចដោះស្រាយបានដែរឬទេ។

ក្រុមប្រឹក្សាឃុំក្នុងមូលដ្ឋាន បានផ្តល់ដល់ឱ្យប្តីប្រពន្ធមួយគូនេះ នូវបញ្ជីសន្ធានការីដែលអាចទទួលដោះស្រាយវិវាទរបស់ពួកគេបាន។ ក្នុងនោះមានសន្ធានការីម្នាក់ឈ្មោះ លីម។ លីម គឺជាសន្ធានការីដែលល្បីល្បាញបំផុតនៅក្នុងខេត្តដែលត្រូវបានគេស្គាល់ពីភាពប៉ិនប្រសព្វក្នុងអាជីព និងភាពឈ្លាសវៃរបស់នាង។ ប៉ុន្តែ លីម មិនធ្លាប់រៀបអាពាហ៍-ពិពាហ៍ទេ។ តាមពិតនាងថែមទាំងបានប្រាប់មិត្តភក្តិទាំងអស់របស់នាងថា នាងមិនចង់រៀបអាពាហ៍ពិពាហ៍ទេ ពីព្រោះនាងជឿថាមនុស្សប្រុសភាគច្រើនខ្ជិល ហើយនាងមានការព្រួយបារម្ភអំពីការទំនុកបម្រុងជាលុយកាក់ដល់ប្តី។

តើនៅទីនេះ លីម គឺជាសន្ធានការីដ៏ល្អម្នាក់ដែរឬទេ? តើនាងអាចលុបបំបាត់ទស្សនៈផ្ទាល់ខ្លួនរបស់នាង ចេញពីកិច្ចការសន្ធានកម្ម ដែរឬទេ ?

## ៣. ការផ្តល់ព័ត៌មានចល់Snankar

នៅពេលដែលភាគីបានជ្រើសរើសសន្ធានការីមួយរូបមករួច ពួកគេត្រូវត្រៀមខ្លួនសម្រាប់កិច្ចប្រជុំសម្រុះ-សម្រួលនានា ដែលកើតនឹងមាន។ ជាទូទៅ ភារកិច្ចទីមួយគឺត្រូវផ្តល់ព័ត៌មានដល់សន្ធានការីអំពីរឿងរ៉ាវវិវាទនោះ។ សន្ធានការីត្រូវទុកព័ត៌មាននេះជាការសម្ងាត់ ហើយមិនត្រូវប្រាប់ទៅភាគីដទៃទៀតឡើយ។ ប្រសិនបើព័ត៌មាននេះមិនត្រូវបានរក្សាជាការសម្ងាត់នោះទេ ភាគីត្រូវយកចិត្តទុកដាក់ចំពោះព័ត៌មានដែលពួកគេផ្តល់។ នៅក្នុងករណីដែលសាមញ្ញ សន្ធានការីអាចត្រូវការព័ត៌មានតិចតួចបំផុត មុនពេលមានកិច្ចប្រជុំពិតប្រាកដ។ ចំពោះករណីដែលរឹតតែស្មុគស្មាញសន្ធាន-ការី អាចស្នើឱ្យភាគីផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរដែលពន្យល់អំពីអង្គហេតុ (អង្គហេតុដែលមានការព្រមព្រៀង និងអង្គហេតុដែលមានវិវាទ) ច្បាប់ដែលអាចអនុវត្តបាន និងភ័ស្តុតាងជាឯកសារដទៃទៀត ដែលគាំទ្រដល់ភាគីនីមួយៗ។

សន្ទានការីអាចនឹងចង់ឃើញជំហររបស់គូភាគីដែលបានដាក់ទៅតុលាការផងដែរ។ ហើយសន្ទានការីនោះក៏អាចចង់ដឹងអំពីសាក្សីដែលត្រៀមខ្លួនធ្វើសក្ខីកម្មឱ្យភាគីនីមួយៗផងដែរ។[១៤០] សន្ទានការីក៏អាចសុំឱ្យភាគីនីមួយៗបង្ហាញពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ខ្លួន ក៏ដូចជាការសាកល្បងពីមុនមកក្នុងការដោះស្រាយវិវាទនោះដែរ។

ព័ត៌មានមុនសន្ទានកម្មទាំងអស់នេះ នឹងជួយឱ្យសន្ទានការីដឹកនាំកិច្ចប្រជុំសម្រុះសម្រួលកាន់តែមានប្រសិទ្ធភាពថែមទៀត។ តួយ៉ាងដូចជា សន្ទានការីនឹងមិនចាំបាច់សួរសំណួរជាច្រើនអំពីអង្គហេតុ ឬច្បាប់ឡើយ ប្រសិនបើគាត់បានអានសេចក្តីដែលដាក់ជូនគាត់ពិនិត្យមុនពេលសន្ទានកម្មនោះរួចហើយ។ ការត្រៀមនេះក៏មានសារៈប្រយោជន៍ផងដែរចំពោះភាគី និងមេធាវីរបស់ពួកគេ នៅពេលដែលពួកគេចាប់ផ្តើមស្វែងរកលទ្ធភាពព្រមព្រៀងគ្នា។

សន្ទានការីក៏ត្រូវជ្រើសរើសទីតាំងអព្យាក្រឹតណាមួយ សម្រាប់កិច្ចប្រជុំសម្រុះសម្រួលផងដែរ។ ប្រសិនបើសន្ទានកម្មនោះធ្វើឡើងក្រោមការត្រួតពិនិត្យរបស់មជ្ឈមណ្ឌលសន្ទានកម្មណាមួយ មជ្ឈមណ្ឌលនោះទំនងនឹងក្លាយជាទីតាំងសន្ទានកម្មតែម្តង។ ពុំនោះទេ សន្ទានកម្មអាចធ្វើឡើងនៅការិយាល័យច្បាប់របស់សន្ទានការី ការិយាល័យគណៈមេធាវី ផ្ទះឯកជន មជ្ឈមណ្ឌលសហគមន៍ឬរដ្ឋាភិបាល។ កន្លែងណាក៏បាន ឱ្យតែមានភាពងាយស្រួល និងមានផាសុកភាពសម្រាប់គូភាគី ហើយផ្តល់ដល់អ្នកចូលរួមនូវភាពជាឯកជន។

**សំណួរសិក្សា**

តើព័ត៌មានអ្វីខ្លះ ប្រសិនបើមាន ដែលភាគីត្រូវផ្តល់ឱ្យសន្ទានការី មុនពេលមានកិច្ចប្រជុំដំបូង នៅក្នុងករណីខាងក្រោម?

- រឿងក្តីលែងលះ
- វិវាទរវាងអ្នកជិតខាងពីរនាក់អំពីរឿងព្រំប្រទល់ដី
- វិវាទអំពីការទិញដីដោយអ្នកនយោបាយដែលមានទ្រព្យសម្បត្តិម្នាក់ ពីសហគមន៍មូលដ្ឋានរបស់កសិករ
- វិវាទអំពីរឿងការបង់ប្រាក់ថ្លៃឈ្នួលផ្ទះរវាងម្ចាស់ផ្ទះ និងអ្នកជួលផ្ទះ
- វិវាទអំពីរឿងប្រាក់បៀវត្សរ៍ រវាងលេខាធិការម្នាក់ និងនិយោជករបស់ខ្លួន និង
- វិវាទរវាងបងប្អូនប្រុសពីរនាក់អំពីរឿងភាពជាម្ចាស់កម្មសិទ្ធិលើរថយន្ត ដែលឪពុករបស់ពួកគេទិញ ហើយដែលបានទទួលមរណភាពតាំងពីពេលនោះមក

## ៤. *ការបើកកិច្ចប្រជុំ*

នៅពេលភាគីបានផ្តល់ដល់អ្នកសម្រុះសម្រួលនូវព័ត៌មានផ្សេងៗមុនពេលសន្ទានកម្ម ហើយសន្ទានកម្មត្រូវបានកំណត់កាលវិភាគរួចរាល់ហើយ ដំណាក់កាលបន្ទាប់គឺជាការបើកកិច្ចប្រជុំ។ នៅពេលបើកកិច្ចប្រជុំ ភាគីវិវាទត្រូវជួបជាមួយសន្ទានការីដោយផ្ទាល់។ នៅក្នុងរឿងក្តីដែលសាមញ្ញ ឬតូចតាច ភាគីវិវាទអាចចូលរួមដោយមិនចាំបាច់មានមេធាវី

[១៤០] *សូមមើលផងដែរ ដូចមុន* មាត្រា ៥។

ហើយដំណើរការនោះមានលក្ខណៈក្រៅផ្លូវការជាង។ នៅក្នុងរឿងក្ដីដែលស្មុគស្មាញ ភាគីវិវាទនឹងចូលរួមដោយមានវត្តមានមេធាវីរបស់ខ្លួន។

***ប្រសិនបើភាគីត្រូវបានតំណាងដោយមេធាវីនៅក្នុងវិវាទនោះ វាជាការសំខាន់ដែលមេធាវី និងភាគីវិវាទខ្លួនឯងមានវត្តមានក្នុងដំណើរសន្ទានកម្មនោះទាំងមូល។***

ជាទូទៅសន្ទានការីច្រើនតែជួបជាមួយភាគីទាំងពីរព្រមគ្នា ដើម្បីសន្សំសំចៃពេលវេលា និងកាត់បន្ថយអាម្មរណ៍សង្ស័យ ឬភាពលម្អៀងនៅពេលចាប់ផ្ដើម។[១៤១] នឹងមិនមានការកត់ត្រានៅក្នុងសម័យប្រជុំទេ ហើយអ្នកខាងក្រៅក៏មិនត្រូវបានអនុញ្ញាតឱ្យចូលរួមដែរ។ ការបើកកិច្ចប្រជុំនេះមានគោលបំណងដូចខាងក្រោម៖

- ណែនាំអ្នកចូលរួមឱ្យស្គាល់គ្នា
- ពិភាក្សា និងពិនិត្យមើលឡើងវិញនូវដំណើរការសន្ទានកម្ម
- កំណត់អំពីវិធានដែលត្រូវអនុវត្តតាម
- ផ្ដល់ពេលវេលាឱ្យភាគីនីមួយៗរៀបរាប់អំពីវិវាទ និងជំហរអង្គច្បាប់ និងអង្គហេតុរបស់ពួកគេ
- ផ្លាស់ប្ដូរព័ត៌មានសំខាន់ៗគ្នាទៅវិញទៅមករវាងភាគីវិវាទ
- ផ្ដល់ដល់ភាគីនូវឱកាសបង្ហាញអំពីអារម្មណ៍ និងផលប្រយោជន៍របស់ខ្លួន និង
- កំណត់ផ្នែកដំបូងនៃការព្រមព្រៀង និងមិនព្រមព្រៀង[១៤២]

សន្ទានការីតែងចាប់ផ្ដើមដោយណែនាំអ្នកចូលរួមឱ្យស្គាល់គ្នាទៅវិញទៅមក។ បន្ទាប់មក សន្ទានការីនោះនឹងពិនិត្យមើលឡើងវិញនូវដំណើរការ និងវិធានសម្រាប់កិច្ចប្រជុំ។ មានពេលខ្លះ សន្ទានការីនឹងព្យាយាមពន្យល់អំពីតួនាទីរបស់ខ្លួននៅក្នុងដំណើរការនោះ ដើម្បីឱ្យភាគីនីមួយៗមានការរំពឹងទុកដូចៗគ្នា។ នៅពេលពន្យល់អំពីវិធាននៃកិច្ចប្រជុំសន្ទានការីត្រូវពន្យល់រឿងលម្អិតដូចជាថា ភាគីនីមួយៗត្រូវបន្តចូលរួមរហូតដល់កិច្ចប្រជុំនោះចប់ ឬក៏ថា ភាគីត្រូវស្ដាប់ និងមិនត្រូវនិយាយកាត់គេឡើយ។ ប្រសិនបើភាគីវិវាទឯកភាព សន្ទានការីនឹងពន្យល់ថា ខ្លួនអាចត្រូវដឹកនាំការប្រជុំជាឯកជនជាមួយភាគីនីមួយៗ ដើម្បីជួយសម្រួលឱ្យមានដំណោះស្រាយ។ សន្ទានការីនោះគួរសង្កត់ធ្ងន់ថា នឹងមិនមានការព្រមព្រៀងដោយចាប់បង្ខំឡើយ ហើយអ្វីដែលភាគីនីមួយៗនិយាយនឹងត្រូវរក្សាការសម្ងាត់ទាំងអស់ ព្រមទាំងត្រូវបញ្ជាក់ថាភាគីនីមួយៗត្រូវបានតំណាងដោយអ្នកណាម្នាក់ដែលមានសិទ្ធិអំណាចពេញលេញដើម្បីដោះស្រាយ។ ទីបញ្ចប់សន្ទានការីនឹងឆ្លើយសំណួរនានាដែលភាគីនីមួយៗមាន ពាក់ព័ន្ធនឹងវិធាន និងដំណើរការនៃសន្ទានកម្មទាំងមូល។ ប្រសិនបើសន្ទានកម្មត្រូវបានធ្វើឡើងនៅមជ្ឈមណ្ឌលសន្ទានកម្មដែលមានស្រាប់ វិធាននានាអាចមានជាលាយលក្ខណ៍អក្សររួចជាស្រេចសម្រាប់ភាគីវិវាទ។ ជាទូទៅ សន្ទានការីនឹងអនុញ្ញាតឱ្យមានការផ្លាស់ប្ដូរខ្លះៗនៅក្នុងវិធានទាំងនោះ ប្រសិនបើភាគីទាំងអស់ព្រមព្រៀងគ្នា។

---

[១៤១] Patterson, *et al,* កំណត់សម្គាល់ *ខាងលើ* លេខ៩, នៅទំព័រ ៥៩។

[១៤២] *ដូចមុន។*

បន្ទាប់ពីមានការពន្យល់តាមបទដ្ឋានជាបឋមទាំងនេះរួច សន្ទានការីនឹងអញ្ជើញភាគីនីមួយៗឱ្យបញ្ចេញមតិបើកកិច្ចប្រជុំរបស់ខ្លួន។ នៅមតិបើកកិច្ចប្រជុំនោះ ភាគីនឹងបង្ហាញពីដំណើររឿងតាមការដែលខ្លួនយល់ឃើញដោយបញ្ជាក់អំពីភស្តុតាង និងច្បាប់ផងដែរ។ នេះគឺជាឱកាសសម្រាប់ភាគីនីមួយៗក្នុងការបង្ហាញពីអារម្មណ៍របស់ខ្លួន ព្រមទាំងមានលទ្ធភាពប្រាប់ដល់ភាគីម្ខាងទៀតអំពីជំហរទាំងអស់របស់ខ្លួនតាមសម្រួល។ គេហៅចំណុចនេះថា ជា"ការបន្ធូរអារម្មណ៍"។

បើអាចធ្វើបាន ភាគីដែលនីមួយៗដែលឡើងបញ្ចេញមតិគួរពន្យល់ផងដែរអំពីផលប្រយោជន៍របស់ខ្លួន។ ជាការល្អបំផុតនោះ គឺមិនត្រូវទាមទារអ្វីពីភាគីម្ខាងទៀត ក្នុងកំឡុងពេលថ្លែងបើកកិច្ចប្រជុំនេះឡើយ។ ភាគីដែលស្តាប់នឹងទទួលបានអត្ថប្រយោជន៍ដែរ ពោលគឺ ជាទូទៅ ភាគីនោះបានស្តាប់នូវរឿងរ៉ាវទាំងមូលចេញពីទស្សនៈរបស់ភាគីម្ខាងទៀតជាលើកដំបូង។ មេធាវីរបស់ភាគីនីមួយៗគួរតែជាអ្នកឡើងបញ្ចេញមតិបើកកិច្ចប្រជុំ ដើម្បីធានាថាការឆ្លើយឆ្លងព័ត៌មានត្រូវបានធ្វើឡើងតាមរបៀបមួយដែលច្បាស់លាស់ មានប្រសិទ្ធភាព និងមិនមានចរិតចោទប្រកាន់។

ក្រោយពីភាគីទីមួយបានបញ្ចប់សេចក្តីថ្លែងរបស់ខ្លួនរួចហើយ សន្ទានការីអាចសួរសំណួរខ្លះៗដើម្បីបំភ្លឺ បញ្ហាមួយចំនួន។ ប្រសិនបើសន្ទានការីបានទទួលសេចក្តីផ្សេងៗ ដែលភាគីបានដាក់ជូនមុនពេលធ្វើសន្ទានកម្មរួចហើយ សន្ទានការីនោះប្រហែលជាមិនចាំបាច់សួរសំណួរដំបូងច្រើនពេកឡើយ។ បន្ទាប់ពីសំណួរទាំងនោះត្រូវបានឆ្លើយតបរួច ភាគីម្ខាងទៀតនឹងថ្លែងមតិបើកកិច្ចប្រជុំ ក្នុងលក្ខខណ្ឌដូចគ្នានឹងអ្នកទីមួយដែរ។ ជាទូទៅ សន្ទានការីនឹងធ្វើការកត់ត្រាយ៉ាងលម្អិតក្នុងកំឡុងពេលនេះ ដើម្បីធានាថាខ្លួនយល់បានទាំងស្រុងអំពីសេចក្តីនៃវិវាទ ក៏ដូចជាអារម្មណ៍ និងផលប្រយោជន៍របស់ភាគីដែលមានចំពោះមុខ។ នៅពេលភាគីទាំងអស់មានឱកាស ក្នុងការបង្ហាញជំហររបស់ខ្លួនរួចហើយ ជាទូទៅ សន្ទានការីនឹងសុំឱ្យមានការសម្រាករយៈពេលខ្លី។[១៤៣]

## សំណួរសិក្សា

- តើសន្ទានការីត្រូវនិយាយអ្វីខ្លះ ប្រសិនបើភាគីទាំងពីរចង់រំលងសេចក្តីផ្តើម ឈានចូលដល់បញ្ហាវិវាទតែម្តង?
- តើត្រូវធ្វើយ៉ាងដូចម្តេច ប្រសិនបើភាគីណាមួយមានបំណងចង់ថ្លែងបើកកិច្ចប្រជុំដោយខ្លួនឯង ជំនួសឱ្យមេធាវី?
- តើសន្ទានការីត្រូវមានការប្រុងប្រយ័ត្នជាមុន ឬនិយាយអ្វីផ្សេងឬទេ ប្រសិនបើភាគីមួយត្រូវបានតំណាងដោយមេធាវី ហើយភាគីមួយទៀតមិនមានមេធាវីនោះ?

[១៤៣] នៅក្នុងការអង្កេតមួយលើមេធាវីផ្នែកពាណិជ្ជកម្មដែលបានប្រើប្រាស់មធ្យោបាយសន្ទានកម្មនៅក្នុងឆ្នាំ២០០៧ មេធាវីជាច្រើនយល់ឃើញថា សេចក្តីថ្លែងបើកសម័យប្រជុំគឺជាការបង្ហិនពេលវេលាឥតប្រយោជន៍ ហើយក្នុងករណីខ្លះ អាចបង្កជាបញ្ហាបាន ដោយសារតែលក្ខណៈអុជអាលរបស់វា។ ការអង្កេតមិនបានបញ្ជាក់ទេថា នេះគឺជាទស្សនៈភាគច្រើននៅក្នុងចំណោមអ្នកដែលបានឆ្លើយតប។ John Lande និង Rachel Wohl *ស្តាប់អ្នកប្រើប្រាស់ដែលមានបទពិសោធន៍: ការកែលម្អគុណភាព និងការប្រើប្រាស់សន្ទានកម្មផ្នែកពាណិជ្ជកម្ម.* ទស្សនាវដ្តីសំណោះស្រាយវិវាទ ទំព័រ១៨ (និទាឃរដូវ ឆ្នាំ២០០៧)។

### ៥. កិច្ចប្រជុំដោះស្រាយបញ្ហាទូទៅ

នៅពេលភាគីត្រឡប់ចូលប្រជុំវិញ សន្ធានការីនឹងចាប់ផ្ដើមកិច្ចប្រជុំដោះស្រាយបញ្ហាទូទៅ។ នេះជាពេលដែលសន្ធានការី និងភាគីវិវាទព្យាយាមស្វែងរកឱកាសដោះស្រាយ។ នៅចំណុចនេះ ជាទូទៅ សន្ធានការីព្យាយាមបំភ្លឺផ្នែកដែលមានការព្រមព្រៀង និងមិនមានការព្រមព្រៀងគ្នា។ មានពេលខ្លះបន្ទាប់មកទៀត សន្ធានការីតែងតែបញ្ចូលនូវជំនួយពីមេធាវីរបស់ភាគី ដើម្បីព្យាយាមកំណត់ថាតើនឹងមានអ្វីកើតឡើង ប្រសិនបើវិវាទមិនត្រូវបានដោះស្រាយទេនោះ។ សន្ធានការីនោះក៏នឹងព្យាយាមគណនាថ្លៃចំណាយប្រហាក់ប្រហែលរបស់ភាគី ក្នុងការដោះស្រាយវិវាទតាមរយៈបណ្ដឹងទៅតុលាការ។[១៤៤] ប្រការនេះនឹងជួយឱ្យភាគីផ្ដោតលើផលវិបាកនៃការបរាជ័យក្នុងការឈានទៅដល់ការព្រមព្រៀងគ្នា។

សន្ធានការីក៏នឹងជួយសម្រួលឱ្យមានការពិភាក្សាគ្នាអំពីរបៀបដែលច្នៃប្រឌិត ដើម្បីឱ្យភាគីអាចដោះស្រាយបញ្ហាផ្សេងៗផងដែរ។ ប្រការនេះអាចធ្វើបានយ៉ាងល្អបំផុតតាមរបៀបសហការ និងមិនប្រឆាំងតបតគ្នា ដោយផ្ដោតអារម្មណ៍លើផលប្រយោជន៍ និងបញ្ហារបស់ភាគីវិវាទ មិនមែនលើភាគីនោះខ្លួនឯងឡើយ។ ជាទូទៅ សន្ធានការីនឹងព្យាយាមស្វែងយល់អំពីអាទិភាពរបស់ភាគី ហើយស្វែងរកចំនុចណាដែលអាចមានព្រមព្រៀងគ្នា ឬផលប្រយោជន៍រួមនានា (ដូចជាការជៀសវាងបណ្ដឹងទៅតុលាការដែលមានរយៈពេលយូរ និងចំណាយប្រាក់អស់ច្រើន)។

> ***ជាទូទៅសន្ធានការីនឹងជៀសវាងការនិយាយអំពីជំហរ ឬការទាមទារណាដែលពិបាកផ្លាស់ប្ដូរ។ ផ្ទុយទៅវិញ សន្ធានការីនឹងសួរអំពីគោលដៅ ការភ័យព្រួយ បំណងប្រាថ្នា និងផលប្រយោជន៍ផ្សេងៗរបស់ភាគី។***

មិនមានដំណើរការគម្រូណាមួយដែលអាចអនុវត្តលើគ្រប់កិច្ចប្រជុំសម្រុះសម្រួលទាំងអស់នោះទេ។ ប៉ុន្តែក្រាហ្វិក ខាងក្រោមផ្ដល់នូវគំនិតទូទៅអំពីរបៀបដែលកិច្ចប្រជុំសម្រុះសម្រួលអាចប្រព្រឹត្តទៅបាន:

[១៤៤] នេះគឺជាវិធីមួយដើម្បីធ្វើឱ្យភាគីផ្ដោតលើ "BATNA" របស់ខ្លួន (ជម្រើសប្រសើរបំផុតក្រៅពីការព្រមព្រៀងតាមការចរចា)។




ជំហានដែលធ្វើឡើងដោយសន្ទានការីគឺដូចគ្នាទៅនឹងជំហាន ដែលគេអាចធ្វើនៅក្នុងកំឡុងពេលចរចាផ្អែកលើផលប្រយោជន៍។ សន្ទានការីអាចនឹងព្យាយាមកំណត់បញ្ហាគន្លឹះនៅក្នុងរឿងក្តីនោះជាមុនសិន។ បន្ទាប់មក គាត់នឹងសួរទៅភាគីវិវាទអំពីផលប្រយោជន៍ជាអាទិភាពរបស់ពួកគេ។ ឧទាហរណ៍ ភាគីអាចជាអ្នកជិតខាងពីរនាក់ដែលឈ្លោះគ្នា នោះគឺ កញ្ញា និង សាព័រ។ បញ្ហាអាចជាព្រំប្រទល់ដីរវាងពួកគេ និងទស្សនៈយល់ឃើញថា ភាគីម្ខាង ឬភាគីទាំងពីរកំពុងរំលោភលើព្រំប្រទល់ដីរបស់ភាគីម្ខាងទៀត។ ផលប្រយោជន៍សម្រាប់កញ្ញា អាចជាការបង្កើតសន្តិភាព ភាពស្ងប់ស្ងាត់ និងភាពជាឯកជន។ នាងអាចមានដីជាច្រើន។ ផលប្រយោជន៍សម្រាប់សាព័រ អាចជាការកាន់កាប់ដីឱ្យបានច្រើនបំផុត ដោយសារនាងរំពឹងថានឹងលក់ដីនោះក្នុងរយៈពេលពីរឆ្នាំខាងមុខ ហើយផ្លាស់ទៅរស់នៅទីក្រុងជាមួយកូនស្រី។

ត្រង់ចំណុចនេះ សន្ទានការីនឹងបង្កើតនូវរបៀបវារៈដ៏សាមញ្ញមួយ ដើម្បីពិភាក្សាបញ្ហាទាំងអស់ព្រមគ្នា។ ចំណុចទីមួយអាចជាមធ្យោបាយដែលធានាបាននូវសន្តិភាព ភាពស្ងប់សុខ និងភាពជាឯកជនរបស់កញ្ញា។ ភាគីអាចពិភាក្សាគ្នាអំពីជម្រើសប្រកបដោយគំនិតច្នៃប្រឌិតដើម្បីជៀសវាងការរំខាន ដែលកញ្ញាយល់ឃើញថាកំពុងធ្វើឱ្យជីវិតរបស់នាងមានការលំបាកយ៉ាងខ្លាំង។ ត្រង់នេះមិនមែនមានន័យថាសាព័រ នឹងត្រូវធ្វើការសន្យា ឬការប្តេជ្ញាចិត្តអ្វីនោះទេ។ ប៉ុន្តែនេះគឺជាការស្វែងរកដើម្បីមើលថាតើមានជម្រើសអ្វីខ្លះដែលអាចធ្វើបាន។ ប្រហែលជាសាព័រ អាចរើគ្រឿងសង្ហារឹម

ខាងក្រៅផ្ទះរបស់នាង ដើម្បីកុំឱ្យពិធីជប់លៀងរបស់នាងនៅក្បែរកញ្ញាពេក ។ ឬប្រហែលជាសាព័រ អាចដាំដើមឈើធំៗនៅលើដីរបស់ខ្លួនដើម្បីកុំឱ្យកញ្ញា មើលឃើញ ឬស្ដាប់ឮពេលមានភ្ញៀវរបស់សាព័រមកលេង ។ នៅពេលដំណោះស្រាយសក្ដានុភូតទាំងអស់នេះត្រូវបានភាគីទាំងពីរចាត់ទុកថាអាចមានការព្រមព្រៀង សន្ធានការីនឹងឈាន ចូលទៅចំណុចមួយទៀត ។ ចំនុចនោះអាចជាកង្វល់របស់សាព័រអំពីការបង្កើនប្រាក់ចំណូលឱ្យច្រើនបំផុតនៅពេលនាងលក់ដី ។ ជាថ្មីម្ដងទៀតសន្ធានការីនឹងស្វែងរកដំណោះស្រាយនានាដែលប្រកបដោយគំនិតច្នៃប្រឌិត ។

ជួនកាល សន្ធានការីមិនមានភាពសកម្មជាអាជ្ញាកណ្ដាលនៅក្នុងការប្រកួតបាល់ទាត់នោះទេ ពេលគឺគ្រាត់គាន់តែសំលើងមើល និងទុកឱ្យភាគីដោះស្រាយបញ្ហារបស់ពួកគេដោយខ្លួនឯង ។ សន្ធានការីនៅទីនោះ គឺដើម្បីលើកទឹកចិត្តឱ្យមានបរិយាកាសស្ថាបនា ។ គាត់នឹងរារាំងមិនឱ្យមានការវាយប្រហារផ្ទាល់ខ្លួន ហើយនឹងព្យាយាមកាត់បន្ថយការខូចខាត ដែលអារម្មណ៍អវិជ្ជមានអាចបង្ករដល់ការចរចា ។ គាត់នឹងព្យាយាមអនុវត្តវិធានជាមូលដ្ឋានទាំងអស់ ដូចជាមិននិយាយកាត់ភាគីម្ខាងទៀត ប៉ុន្តែក្រៅពីនោះគាត់នឹងដើរតួនាទីមានកម្រិតទៅតាមតម្រូវការជាក់ស្ដែង ។ សន្ធានការីម្នាក់ៗ មានរបៀបធ្វើការងារ និងបុគ្គលិកលក្ខណៈផ្សេងៗគ្នា ហើយវិវាទនីមួយៗមានភាគី បញ្ហា និងអារម្មណ៍ផ្សេងៗគ្នា ។ វិធីសាស្រ្តមួយនឹងមិនមានប្រសិទ្ធិភាពចំពោះគ្រប់ករណីទាំងអស់នោះទេ ។

### ក) ការស្ដាប់

ជាទូទៅ ជំនាញសំខាន់បំផុតសម្រាប់សន្ធាការី នៅក្នុងកំឡុងដំណាក់កាលនេះ និងក្នុងដំណាក់កាលមុនៗ គឺការស្ដាប់ ។ សន្ធានការីត្រូវស្ដាប់យ៉ាងសកម្មចំពោះអ្វីដែលភាគីនិយាយ និងស្វែងរកផលប្រយោជន៍ដ៏សំខាន់ៗ ដែលអាចតម្រូវតាមបាននៅក្នុងការព្រមព្រៀងដោះស្រាយ ។ ការស្ដាប់មិនត្រូវកម្រិតត្រឹមចំពោះតែពាក្យសម្ដីនោះទេ ។ សន្ធានការីក៏ត្រូវសង្កេតមើលភាសាកាយវិការរបស់អ្នកចូលរួមផងដែរ ។ ជំពូកស្ដីពីការចរចានៅក្នុងសៀវភៅនេះ បរិយាយអំពីភាសាកាយវិការសំខាន់ៗមួយចំនួនដែលអ្នកចរចា ឬសន្ធានការីគួរពិចារណា ។

### លំហាត់ ៖ ស្វែងយល់អំពីការប្រាស្រ័យទាក់ទងដែលមិនមែនជាពាក្យសម្ដី

ចូរចាប់ដៃគូជាមួយអ្នកណាម្នាក់នៅក្នុងថ្នាក់ដែលអ្នកមិនស្គាល់ ឬមិនសូវស្គាល់ច្បាស់ ។

- ចំណាយពេលពីរនាទីដើម្បីប្រាប់ដល់ដៃគូ អំពីខ្លួនឯងដោយមិនចាំបាច់និយាយ ។ សម្ដែងកាយវិការពីផលប្រយោជន៍ ព្រឹត្តិការណ៍ គ្រួសារ មិត្តភក្តិ កីឡា ។ល ។ ឯអ្នកស្ដាប់ក៏មិនត្រូវនិយាយដែរ ។
- ចំណាយពេលពីរនាទីដើម្បីពិភាក្សាអំពីអ្វីដែលបានប្រាស្រ័យទាក់ទងរួច ។
- បន្ទាប់មក ប្ដូរតួនាទី ហើយធ្វើលំហាត់នេះម្ដងទៀត ក្នុងរយៈពេលពីរនាទី ។
- ចំណាយពេលពីរនាទីដើម្បីពិភាក្សាអំពីអ្វីដែលបានប្រាស្រ័យទាក់ទងរួច ។

តើព័ត៌មានប្រភេទអ្វីខ្លះដែលត្រូវបានបញ្ជូន ដោយមិនប្រើប្រាស់ពាក្យសម្ដី និងដោយរបៀបណា?

### ខ) ការបកស្រាយឡើងវិញ (re-framing)

ជំនាញដ៏សំខាន់មួយទៀតដែលសន្ធានការីប្រើប្រាស់នៅក្នុងកំឡុងដំណាក់កាលនេះ ហៅថាការបកស្រាយឡើង-វិញ។ ជំនាញនេះត្រូវបានប្រើប្រាស់ជាញឹកញាប់ទាំងនៅក្នុងជំនួបជាឯកជន និងកិច្ចប្រជុំជាក្រុម។ ការបកស្រាយឡើងវិញ គឺជាបច្ចេកទេសដែលត្រូវបានប្រើប្រាស់ដោយសន្ធានការី ដើម្បីនិយាយឡើងវិញនូវពាក្យសម្ដីដែលមិនអំណោយផលរបស់ភាគីម្ខាង ដើម្បីជំរុញការពិភាក្សាឱ្យមានទិសដៅកាន់តែមានភាពអព្យាក្រឹត និងវិជ្ជមាន។ ជំនួសឱ្យការបង្ករឱ្យមានការវាយបកដោយពាក្យសម្ដី ឬការនិយាយការពារខ្លួនពីភាគីម្ខាងទៀត ការបកស្រាយឡើងវិញ លើកទឹកចិត្តភាគីទាំងពីរឱ្យពិចារណាឡើងវិញ នូវស្ថានភាពរបស់ពួកគេ និងឈានទៅរកទិសដៅនៃដំណោះស្រាយ។

ដើម្បីស្វែងយល់អំពីការបកស្រាយឡើងវិញ យើងត្រូវយល់អំពីពាក្យថាបកស្រាយ។ ការបកស្រាយគឺជាការរៀបរាប់អំពីរបៀបដែលមនុស្សមើល និងយល់ឃើញអំពីស្ថានភាព ឬហេតុការណ៍មួយ។ ពាក្យថា "បកស្រាយឬ frame" ត្រូវបានប្រើប្រាស់ ពីព្រោះវារៀបរាប់អំពីរបៀបដែលអ្នកណាម្នាក់ដែលសម្លឹងមើលទៅកាន់ពិភពលោកខាងក្រៅតាមរយៈស៊ុមរូបភាព (the frame of a picture) ឬក្របខ័ណ្ឌនៃទិដ្ឋភាពមួយ។

យើងអាចផ្លាស់ប្ដូរបំណកស្រាយរបស់មនុស្ស ហើយអាចផ្លាស់ប្ដូររបៀបដែលពួកគេយល់ឃើញលើអ្វីមួយបាន។ នៅទីបំផុត ប្រការនេះអាចនឹងផ្លាស់ប្ដូរអាកប្បកិរិយារបស់ពួកគេ។ ឧទាហរណ៍ មានអ្នកចូលរួមមួយចំនួននៅក្នុងការពិសោធន៍ចិត្តសាស្ត្រមួយ លេងល្បែងមួយដែលពួកគេត្រូវជ្រើសរើសថាតើត្រូវសហការគ្នា ឬវត់ចោលគ្នា។ អ្នកចូលរួមត្រូវបានបែងចែកជាពីរក្រុម។ វិធានដូចគ្នាត្រូវបានប្រើសម្រាប់ក្រុមទាំងពីរ គ្រាន់តែឈ្មោះល្បែងខុសគ្នាប៉ុណ្ណោះ។ ក្រុមទីមួយត្រូវបានប្រាប់ថា ល្បែងនេះមានឈ្មោះថា"ល្បែង Wall Street"[១៤៥]។ ក្រុមទីពីរត្រូវបានប្រាប់ថា ល្បែងនេះមានឈ្មោះថា "ល្បែងសហគមន៍"។ អ្នកចូលរួមនៅក្នុងក្រុមទីមួយសហការគ្នាតែមួយភាគបីនៃពេលវេលាលេងតែប៉ុណ្ណោះ ចំណែកឯអ្នកចូលរួមនៅក្នុងក្រុមទីពីរ សហការគ្នាពីរភាគបីនៃពេលវេលា។[១៤៦] ឈ្មោះល្បែងមានអំណាចយ៉ាងខ្លាំង ដែលវាធ្វើឱ្យមានផលប៉ះពាល់ទៅលើអាកប្បកិរិយារបស់អ្នកចូលរួម។ គេអាចនិយាយម្យ៉ាងទៀតថា វាផ្ដល់ជាបំណកស្រាយដ៏ជាក់លាក់មួយដល់អ្នកចូលរួម និងបង្ហាញឱ្យឃើញពីអំណាចរបស់ពាក្យ។

***គំនិតដែលនៅពីក្រោយការបកស្រាយឡើងវិញ គឺដើម្បីបង្ហំភាគីឱ្យពិនិត្យមើលស្ថានភាព ឬហេតុការណ៍តាមរបៀបមួយផ្សេងទៀតហើយអាចមានអាកប្បកិរិយាផ្សេង-ដូចជាឈ្មោះនៅក្នុងការពិសោធន៍ចិត្តសាស្ត្រខាងលើជាដើម។***

មានគោលដៅចម្បងៗចំនួនបី ចំពោះការបកស្រាយឡើងវិញនៅក្នុងដំណោះស្រាយវិវាទ :

១. សម្រាល ឬកាត់បន្ថយ ភាពប្រទូសរ៉ាយរវាងគ្នា។

---

[១៤៥] Wall Street (វ៉ លស្ទ្រីត) គឺជាវិថីដ៏ល្បីល្បាញមួយនៅទីក្រុងញូវយ៉ក ដែលជាទីតាំងនៃទីផ្សារភាគហ៊ុន។ ពាក្យថា "Wall Street" ច្រើនបង្កប់នូវអត្ថន័យដែលពាក់ព័ន្ធនឹងប្រាក់កាស ការប្រកួតប្រជែង និងទ្រព្យសម្បត្តិ។

[១៤៦] *សូមមើល* Lee Ross និង Andrew Ward *ភាពប្រាកដនិយមឥតលាក់លៀមនៅក្នុងជីវិតប្រចាំថ្ងៃ: ភាពជាប់ជំពាក់សម្រាប់វិវាទ សង្គម និងការយល់ខុស,* **តម្លៃ និងចំណេះដឹង** (E.S. Reed, E. Turiel និង T. Brown ឆ្នាំ១៩៩៦)។

២. ផ្លាស់ប្តូរពីការផ្តោតអារម្មណ៍លើជំហរ ឱ្យទៅជា លើផលប្រយោជន៍វិញ ហើយ

៣. ផ្លាស់ប្តូរកង្វល់ ឬការរអ៊ូរទាំ ឱ្យទៅជាបញ្ហាដែលអាចដោះស្រាយបាន។

ការបកស្រាយឡើងវិញនូវសម្តីរបស់ភាគីអាចដោះស្រាយបាននូវទិដ្ឋភាពទាំងនេះមួយ ឬច្រើន។ សន្ទានការីត្រូវបកស្រាយឡើងវិញតាមរបៀបមួយដែលប្រកបដោយភាពប្រុងប្រយ័ត្ន និងសាកសួរ ក៏ដូចជាកុំឱ្យប៉ះពាល់ដល់អ្នកនិយាយពីដើមដំបូងផងដែរ។

ខាងក្រោមនេះគឺជាឧទាហរណ៍មួយចំនួនអំពីការបកស្រាយឡើងវិញ:

| **ពាក្យសម្តីដើម** | **ពាក្យសម្តីបកស្រាយឡើងវិញ ឬចម្លើយរបស់សន្ទានការី** |
|---|---|
| "តើអ្នកមិនដឹងពីអ្វីដែលប្រសើរជាងការដាក់សម្នើដែលនឹងមិនត្រូវបានទទួលយកទេឬ?" | "សុគន្ធា អ្នកអាចមានចំណុចល្អនៅទីនេះ។ តើអ្នកអាចកែលម្អសម្នើនេះ ឱ្យមានលក្ខណៈកាន់តែអាចទទួលយកបានយ៉ាងដូចម្តេច?" |
| "លោក ផារី កុហកយើង ហើយគាត់មិនមែនជាមនុស្សគួរឱ្យទុកចិត្តនោះទេ"។ | "កាលពីអតីតកាល លោក ផារី ធ្លាប់ផ្តល់ព័ត៌មានដែលប្រែទៅជាមិនពិតដល់ពួកគេ ដូច្នេះប្រហែលជាពួកគេមានការស្ទាក់ស្ទើរក្នុងការជឿ លើពាក្យសម្តីនាពេលបច្ចុប្បន្នរបស់គាត់។ |
| "អ្នកបានបំផ្លាញវិស្សមកាលរបស់យើង" ។ | "ស៊ីណែត មានបញ្ហាក្នុងការកំសាន្តក្នុងពេលវិស្សមកាលរបស់នាង ដោយសារតែហេតុការណ៍ដែលបានកើតឡើង" ។ |
| "អ្នកបានរំលោភកិច្ចព្រមព្រៀង" ។ | "ប្រាក់មិនត្រូវបានបង់ទាន់ពេលវេលា ហើយស្រីមុំជឿថាប្រការនេះធ្វើឱ្យមានការលំបាកក្នុងការបំពេញកាតព្វកិច្ចរបស់នាង ក្នុងការបង់ប្រាក់ដល់អ្នកផ្សេងទៀត"។ |
| "បញ្ញា ជាមនុស្សអត់សណ្តាប់ធ្នាប់សោះ" ។ | "វាជាការរំខានដល់ ស្រស់ នៅពេលគាត់ឃើញសម្លៀកបំពាក់របស់អ្នកនៅរាយប៉ាយពេញផ្ទះ" ។ |

ការបកស្រាយឡើងវិញមិនដោះស្រាយចំពោះវិវាទនោះទេ ប៉ុន្តែវាផ្តល់ឱកាសឱ្យគេអាចឈានចេញពីទស្សនៈ និងពាក្យសម្តីអវិជ្ជមាន ឬមិនអំណោយផល ទៅកាន់លក្ខខណ្ឌមួយដែលកាន់តែមានផ្លែផ្កា ដែលអ្នកចូលរួមអាចស្វែងរកជម្រើសនៃដោះស្រាយដែលធ្វើបាននានា។ វាជាមធ្យោបាយដ៏ល្អិតល្អន់ ប៉ុន្តែមានអំណាច ដែលអាចផ្លាស់ប្តូរទស្សនៈយល់ឃើញរបស់មនុស្ស និងមានលទ្ធភាពផ្លាស់ប្តូរអាកប្បកិរិយារបស់ពួកគេបាន។

## លំហាត់ ៦ ការបកស្រាយឡើងវិញ

ចូរព្យាយាមបកស្រាយឡើងវិញនូវពាក្យសម្ដីខាងក្រោម៖

- នៅក្នុងថ្នាក់រៀនប្រវត្តិវិទ្យា អាន និង ចេង ត្រូវធ្វើកិច្ចការជាមួយគ្នា ដើម្បីផ្ដល់នូវបទបង្ហាញរួមគ្នាមួយ។ អានរអ៊ូរទាំប្រាប់មិត្តភក្តិម្នាក់ថា "ខ្ញុំធ្វើកិច្ចការទាំងអស់។ ចេង គ្មានធ្វើអ្វីសោះ ទោះបីជាខ្ញុំសុំឱ្យគេធ្វើមួយពាន់ដងក៏ដោយ"។
- នៅក្នុងគ្រួសារមួយដែលបងប្អូនប្រុសពីរនាក់ជិះម៉ូតូមួយរួមគ្នា ហួត និយាយថា "ម៉ារ៉េត ជិះម៉ូតូរៀងរាល់យប់ថ្ងៃ ច័ន្ទ ដើម្បីសួរសុខទុក្ខមិត្តភក្តិរបស់គាត់ ទោះបីជាខ្ញុំត្រូវការជិះម៉ូតូនោះទៅសាលារៀនក៏ដោយ"។
- បុគ្គលិកធ្វើការក្នុងការិយាល័យពីរនាក់ដណ្ដើមគ្នាប្រើប្រាស់កុំព្យូទ័រមួយ។ តារា និយាយថា "គាត់យក កុំព្យូទ័រដោយមិនបានប្រាប់ខ្ញុំសោះ។ គាត់រំលោភលើគោលនយោបាយរបស់ក្រុមហ៊ុន។"
- បងប្អូនស្រីពីរនាក់ឈ្លោះគ្នាអំពីរឿងសម្លេងចេញពីបន្ទប់គេងរបស់ពួកគេរៀងៗខ្លួន។ សារឿននិយាយថា "នៅរៀងរាល់ពេលដែលខ្ញុំសុំឱ្យនាងស្ងៀមស្ងាត់ នាងស្រែកដាក់ខ្ញុំ ហើយបិទទ្វារឮសូរគ្រាំង!"។

ពិតប្រាកដណាស់ គោលដៅនៃការបកស្រាយឡើងវិញ និងបច្ចេកទេសផ្សេងទៀត គឺដើម្បីស្វែងរកដំណោះស្រាយដែលអាចទទួលយកបាន។ ប្រសិនបើដំណោះស្រាយត្រូវបានរកឃើញថា ឆ្លើយតបទៅនឹងផលប្រយោជន៍របស់ភាគីទាំងពីរ ពេលនោះគេអាចនឹងស្នើវាឡើងដើម្បីដោះស្រាយ។ សន្ធានការីអាចជួយសម្រួលការនេះ ដោយជួយនៅក្នុងដំណើរការបង្កើតជម្រើសសម្រាប់ការព្រមព្រៀង។ ជាទូទៅ គេគួរទុកឱ្យភាគីជាអ្នកបង្កើត និងស្នើឡើងនូវ ដំណោះ-ស្រាយដោយខ្លួនឯង ប្រសិនបើអាចទៅរួច។ តាមវិធីនេះ ដំណោះស្រាយទាំងនោះទំនងជាអាចទទួលយកបាន និងមានភាពស្ថិតស្ថេរជាង។ ប្រសិនបើអ្នកសន្ធានការីយល់ឃើញថា ភាគីមិនមានលទ្ធភាព ឬមិនមានឆន្ទៈស្នើឡើងនូវដំណោះ-ស្រាយទេនោះ គាត់អាចដើរតួនាទីឱ្យកាន់តែសកម្មជាងមុន ហើយអាចស្នើឡើងនូវដំណោះស្រាយដោយខ្លួនឯងផ្ទាល់។ មានកាលៈទេសៈមួយចំនួនដែលភាគីមិនជឿទុកចិត្តគ្នាទៅវិញទៅមក ហើយដំណោះស្រាយដែលស្នើឡើងដោយ ភាគីម្ខាង នឹងត្រូវបានភាគីម្ខាងទៀតសំលឹងមើលដោយភាពសង្ស័យ។ នៅក្នុងករណីនេះ សន្ធានការីគួរធ្វើសម្ដីដោយខ្លួនឯងដើម្បីកាត់បន្ថយភាពសង្ស័យទាំងនោះ។

### គ) ការបង្កើតជម្រើស

ដូចគ្នានឹងការចរចាដែរ គន្លឹះទៅរកជោគជ័យគឺការបង្កើតជម្រើសសម្រាប់ផលចំណេញទៅវិញទៅមក ចំណុចសំខាន់ៗ ដែលដូចគ្នានោះគឺមានភាពពាក់ព័ន្ធនៅទីនេះ។ សន្ធានការីត្រូវជួយភាគីក្នុងការ៖

១. បំបែកការបង្កើតជម្រើស ឱ្យដាច់ពីការវិនិច្ឆ័យជម្រើស។

២. ព្យាយាមពង្រីកជម្រើសដែលកំពុងពិចារណាជាជាងស្វែងរកចម្លើយតែមួយ។

៣. ស្វែងរកផលចំណេញទៅវិញទៅមក និង

៤. គិតអំពីវិធីធ្វើឱ្យការសម្រេចចិត្តរបស់ភាគីម្ខាងទៀតមានភាពងាយស្រួល[១៤៧]

---

[១៤៧] Fisher et al., កំណត់សម្គាល់ *ខាងលើ* លេខ៣១, នៅទំព័រ៤-៥។

អ្នកអានត្រូវពិនិត្យមើលឡើងវិញនូវជំពូកស្តីពីការចរចានៃសៀវភៅនេះ សម្រាប់ព័ត៌មានលម្អិតបន្ថែមទៀតអំពីភារកិច្ចសំខាន់ៗទាំងបួនដែលរួមបញ្ចូលនូវបច្ចេកទេសមួយចំនួន ដូចជាការរិះរកគំនិតថ្មីៗជាដើម។ ប៉ុន្តែ មានចំនុចពិសេសមួយដែលសន្ទានការីគួរប្រុងប្រយ័ត្នជាមុន។ ជួនកាល សន្ទានការីបង្កើតជម្រើសច្រើនពេកនៅក្នុងការស្វែងរក ដំណោះ-ស្រាយ។ ទោះជាវាហាក់ដូចជាគំនិតដែលល្អក្តី សន្ទានការីត្រូវយល់ដឹងអំពីបាតុភូតសំខាន់មួយ ដែលគេវាហៅថា ជា *ការជៀសវាងការសម្រេចចិត្ត* ។

នៅក្នុងការជៀសវាងការសម្រេចចិត្ត ជាក់ស្តែង ភាគីដែលមានជម្រើសច្រើនពេកនឹងហាក់ដូចជាមិនចង់ជ្រើសរើសជម្រើសព្រមព្រៀងណាមួយឡើយ នៅពេលប្រៀបធៀបជាមួយភាគីដែលមានជម្រើសដែលតិចតួច។ នៅក្នុងការសិក្សាគួរឱ្យចាប់អារម្មណ៍មួយ អ្នកស្រាវជ្រាវដាក់តាំងបង្ហាញកែវចាហួយនៅក្នុងផ្សារទំនើបមួយដើម្បីពិនិត្យមើលប្រតិកម្មរបស់អតិថិជន។ អតិថិជនដែលទៅជិតទីតាំងបង្ហាញនោះ ត្រូវបានអញ្ជើញឱ្យភ្លក់ចាហួយ ហើយនឹងទទួលបានប័ណ្ណបញ្ចុះតម្លៃចំនួន ១ដុល្លា ចំពោះចាហួយមួយកែវណាដែលអតិថិជននោះបានទិញ។ ទីតាំងបង្ហាញមួយមានចាហួយប្រាំមួយកែវផ្សេងៗគ្នា ចំណែកទីតាំងមួយទៀតមានចាហួយម្ភៃបួនកែវផ្សេងៗគ្នា។ អតិថិជនមានការចាប់អារម្មណ៍ចំពោះទីតាំងដែលធំ ប៉ុន្តែហាក់ដូចជាមិនសូវទិញអ្វីសោះ។ ប្រហែល៣០% នៃអតិថិជនចំនួន១០៤នាក់ ដែលឈប់នៅទីតាំងបង្ហាញដែលតូច ទិញចាហួយមួយកែវ ក្នុងខណៈដែល ៤%នៃអតិថិជនចំនួន១៤៥នាក់ ដែលឈប់នៅទីតាំងធំបានទិញចាហួយនោះ។[១៤៨] គេអាចនិយាយម្យ៉ាងទៀតថា៩៦% នៃអតិថិជនដែលឈប់នៅមុខទីតាំងបង្ហាញធំ ជ្រើសរើសមិនធ្វើការសម្រេចចិត្ត ពីព្រោះពួកគេត្រូវបានផ្តល់នូវជម្រើសដែលច្រើនពេក។

សន្ទានការីដែលស្នើជម្រើសច្រើនពេក ដូចជាចាហួយទាំង២៤កែវនៅក្នុងការសិក្សានោះ នឹងមានការប្រថុយប្រថានក្នុងការធ្វើឱ្យភាគីជៀសវាងជ្រើសរើសទាំងអស់គ្នា ហើយអាចនឹងមិនមានការព្រមព្រៀងណាមួយឡើយ។

***ទោះជាការបង្កើតជម្រើសជាទូទៅគឺជាលំហាត់ដ៏សំខាន់ក៏ដោយ ក៏គេត្រូវប្រុងប្រយ័ត្ន ដោយកុំធ្វើឱ្យភាគីទទួលយកមិនបាន ជាពិសេសប្រសិនបើពួកគេបង្ហាញនូវសញ្ញាថា ពួកគេខ្វាចក្នុងការធ្វើការជ្រើសរើសដែលលំបាក។***

## ៦. ជំនួបឯកជន

ប្រសិនបើសន្ទានកម្មនៅនឹងថ្កល់មួយកន្លែង (ដោយសារការជៀសវាងការសម្រេចចិត្ត ឬមូលហេតុផ្សេងទៀត) មានដំណោះស្រាយជានីតិវិធីរួមមួយ ដែលសន្ទានការីអាចនឹងប្រើប្រាស់ គឺការប្រជុំជាឯកជន។ ដូចបានឃើញនៅក្នុងក្រាហ្វិកខាងលើរួចមកហើយ ជាទូទៅការប្រជុំជាឯកជនធ្វើឡើងក្នុងកំឡុងពេលដែលភាគីកំពុងពិភាក្សាគ្នារកដំណោះស្រាយ ដែលអាចធ្វើបានចំពោះបញ្ហាវិវាទរបស់ខ្លួន។ វាមិនមែនជារឿងចម្លែកនោះទេ ដែលសន្ទានការីត្រូវជួបប្រជុំជាឯកជនចំនួនប្រាំ ឬរហូតដល់ដប់ដង នៅក្នុងពេលមានសន្ទានកម្មដែលលំបាកនោះ។ ជាទូទៅ ប្រសិនបើសន្ទានការីជួបប្រជុំគ្នាជាឯកជន

[១៤៨] S Iyengar និង M Lepper *នៅពេលជម្រើសមិនជំរុញទឹកចិត្ត: តើយើងអាចត្រូវការរឿងល្អច្រើនពេកទេ?* ទិនានុប្បវត្តិបុគ្គលភាព និងចិត្តសាស្ត្រសង្គម ទំព័រ ៧៦, ៩៩៥ - ១០០៦ (ឆ្នាំ២០០០)។

ជាមួយភាគីម្ខាង នោះគាត់នឹងជួបប្រជុំជាឯកជនជាមួយភាគីម្ខាងទៀតដែរ។ បន្ទាប់ពីមានការប្រជុំជាឯកជនទាំងពីរនេះ សន្ទានការីអាចកោះប្រជុំជាក្រុមរួម ឬបន្តជួបប្រជុំជាឯកជនចុះឡើងតទៅទៀត។

ជំនួបឯកជនអនុញ្ញាតឱ្យភាគីចែករំលែកព័ត៌មានឯកជនជាមួយសន្ទានការី ដែលពួកគេអាចមានភាពមិនស្រួលក្នុងចិត្តដើម្បីចែករំលែកនៅចំពោះមុខភាគីម្ខាងទៀត។ ឧទាហរណ៍ ភាគីម្ខាងអាចមិនចង់បង្ហាញឱ្យឃើញពីផលប្រយោជន៍ជាក់លាក់ណាមួយ (ដូចជាក្រុមហ៊ុនខ្វះសាច់ប្រាក់ ហើយអាចត្រូវប្រកាសក្ស័យធន/អសាធនភាពជាដើម)។ ឬភាគីនោះអាចចង់ស្វែងរក ជម្រើសសម្រាប់ព្រមព្រៀងបន្ថែមទៀត ដែលមានភាពមិនស្រួលចិត្ត នៅពេលយកឱ្យប្រាកដប្រជានៅចំពោះមុខភាគីម្ខាងទៀត ដោយខ្លាចមិនហ៊ានបង្ហាញនូវចំណុចខ្សោយរបស់ខ្លួន។

***ការប្រជុំជាឯកជននឹងអនុញ្ញាតឱ្យភាគីវិវាទទម្លាក់ចោលនូវបញ្ហា "ចុខចាត់" ដែលជួនកាលពួកគេត្រូវការបង្ហាញវាដល់ភាគីម្ខាងទៀត។***

តាមទស្សនៈរបស់សន្ទានការី ការប្រជុំជាឯកជនអនុញ្ញាតឱ្យខ្លួនទទួលបាននូវជំនឿទុកចិត្ត កាន់តែខ្លាំងពីអ្នកចូលរួម។ សន្ទានការីអាចបង្ហាញនូវការយល់ចិត្តកាន់តែច្រើនចំពោះភាគីនៅក្នុងកំឡុងពេលប្រជុំជាឯកជននោះ ដែលប្រហែលជាគាត់មិនអាចធ្វើបែបនេះបានឡើយនៅក្នុងសម័យប្រជុំជាក្រុម ដោយខ្លាចថាខ្លួននឹងមានកាយវិការលម្អៀង។ បរិយាកាសឯកជនក៏អនុញ្ញាតឱ្យសន្ទានការីមានលទ្ធភាពទម្លាក់ជំហររបស់ភាគីកាន់តែខ្លាំង និងបង្ខំពួកគេឱ្យពិចារណាយ៉ាងហ្មត់ចត់នូវអ្វីដែលភាគីម្ខាងទៀតបានស្នើឡើង។ សន្ទានការីថែម ទាំងអាចស្នើឡើងនូវដំណោះស្រាយសក្តានុភូតនានានៅក្នុងជំនួបជាឯកជននោះ ដែលអាចហាក់មានភាពលម្អៀង ឬមិនសមស្រប ប្រសិនបើស្នើឡើងនៅក្នុងកិច្ចប្រជុំជាក្រុម។ បរិយាកាសឯកជនក៏លើកទឹកចិត្តឱ្យមានការចូលរួមកាន់តែច្រើនពីសមណាក់ភាគីខ្លួនឯង ពីព្រោះជាញឹកញាប់មេធាវីគឺជាអ្នកដែលនិយាយនៅក្នុងការប្រជុំជាក្រុម (ជួនកាលមេធាវីប្រាប់កូនក្តីរបស់ខ្លួនកុំឱ្យនិយាយអ្វីទាំងអស់ លុះត្រាតែពួកគេឱ្យនិយាយ)។

ជំនួបឯកជនមិនមានភាពចាំបាច់រហូតនោះទេ ប៉ុន្តែជាញឹកញាប់វាមានសារៈប្រយោជន៍ក្នុងការជួយឱ្យភាគីស្ថិតនៅជាមួយគ្នា ជាពិសេសប្រសិនបើពួកគេជួបប្រទះនឹងស្ថានភាពទ័លច្រក។ លក្ខខ័ណ្ឌសមស្របបំផុតដែលជំនួបឯកជនមានភាពចាំបាច់ មានដូចខាងក្រោម:

- នៅពេលដែលមានភាគីវិវាទច្រើនជាងពីរ ដូចជាក្នុងរឿងក្តីខូចខាតទ្រព្យសម្បត្តិ ដែលមានដើមបណ្តឹងដែលជាអ្នកទទួលរងការខូចខាត ចុងចម្លើយដែលគេចោទថាបានបង្កការខូចខាត និងក្រុមហ៊ុនធានារ៉ាប់រង ជាដើម។
- នៅពេលរឿងក្តីមានភាពស្មុគស្មាញខ្លាំង។ ឧទាហរណ៍ នៅពេលក្រុមហ៊ុនសាងសង់អចលនវត្ថុត្រូវបាន អ្នកវិនិយោគទុនប្តឹង ពីបទពន្យារពេលក្នុងការបញ្ចប់គម្រោង ដោយសារអ្នកចុះកិច្ចសន្យាម៉ៅការបន្តរបស់ក្រុមហ៊ុនសាងសង់នោះមានបញ្ហា ហើយបន្ទោសលើអ្នកផ្គត់ផ្គង់សម្ភារៈ និងស្ថាបត្យករ។
- នៅពេលមានភាពខុសគ្នាខ្លាំងនៅក្នុងតុល្យភាពនៃអំណាច។ ឧទាហរណ៍ ក្នុងករណីនិយោជកពហុជាតិដ៏ធំមួយដែលបានបញ្ឈប់លេខាធិការដ៏ក្រីក្រម្នាក់ពីការងារ។ លេខាធិការនោះអាចទទួលរងនូវផលវិបាកដ៏ធ្ងន់ធ្ងរមួយ ប្រសិនបើនាងមិនបានទទួលការងារវិញទេ។ ក្រុមហ៊ុននោះនឹងមិនមានអ្វីជាកង្វល់ឡើយ ថែមទាំងអាចជួល

បុគ្គលិកផ្សេងទៀតបានយ៉ាងងាយស្រួល។ នៅក្នុងការជំនួបជាឯកជន សន្ទានការីអាចមានលទ្ធភាពផ្តល់ការលើកទឹកចិត្ត និងការគាំទ្រ ដែលការនេះនឹងមិនអាចកើតមាននៅក្នុងកិច្ចប្រជុំជាក្រុមឡើយ។

- នៅពេលភាគីរំលោភបំពាន ឬគំរាមកំហែងគ្នាទៅវិញទៅមក។ នេះគឺជាមូលហេតុទូទៅបំផុតសម្រាប់ជំនួបជាឯកជន។ ឧទាហរណ៍ ចំពោះវិវាទគ្រួសារ ភាគីអាចមានអារម្មណ៍រំជួលខ្លាំងដែលអាចមិនអំណោយផលដល់ដំណោះស្រាយ។ ឬអាចថា ប្តីគំរាមកំហែងប្រពន្ធនៅក្នុងសន្ទានកម្មអំពីការលែងលះ ហើយសម្ពាធនៃការប្រឈមមុខដាក់ប្តីនោះ ធ្វើឱ្យប្រពន្ធយល់ព្រមចំពោះការទាមទារទាំងអស់។ ជំនួបឯកជនអាចជួយស្តាតុល្យភាពនោះឡើយវិញ ក៏ដូចជាឧត្តមប្រយោជន៍របស់គ្រួសារនោះផងដែរ នៅទីបំផុត។

## ៧. ការបិទកិច្ចប្រជុំ

សន្ទានកម្មនឹងបញ្ចប់ ដោយមានលទ្ធផលមួយក្នុងចំណោមលទ្ធផលដែលអាចមានចំនួនបីដូចខាងក្រោម :

១. ភាគីបានឈានដល់ការព្រមព្រៀងគ្នាទាំងស្រុង។

២. ភាគីមិនបានឈានដល់ការព្រមព្រៀងគ្នាទាំងស្រុង ប៉ុន្តែនឹងបន្តសន្ទានកម្មនៅពេលក្រោយ ឬ

៣. ភាគីបានឈានទៅដល់ស្ថានភាពជាប់គាំង[១៤៩] ហើយសន្ទានកម្មត្រូវបានបញ្ចប់។

នៅក្នុងករណីទីមួយ សន្ទានការីនឹងលើកទឹកចិត្តឱ្យភាគីធ្វើពង្រាង និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងដោះស្រាយ មួយ។ ការពន្យាក្នុងការធ្វើពង្រាង និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងដោះស្រាយនៅថ្ងៃក្រោយ គឺជាការប្រថុយប្រថាន ពីព្រោះភាគីអាចពិចារណាឡើងវិញអំពីការស្រុះស្រួលរបស់ខ្លួន។ ពួកគេអាចទទួលរងសម្ពាធពីគ្រួសារ មិត្តភក្តិ ឬមិត្តរួមការងារ ឱ្យបន្តទាមទារផលប្រយោជន៍កាន់តែច្រើនជាងនោះ។ ជាលទ្ធផល ពួកគេអាចព្យាយាមទាមទារនូវសម្បទានចុងក្រោយពីភាគីម្ខាងទៀត និងអាចនឹងបំផ្លាញកិច្ចព្រមព្រៀងនោះតែម្តង។

ភាគីខ្លួនឯងគួរជាអ្នកធ្វើពង្រាងកិច្ចព្រមព្រៀងនោះ។ ប្រសិនបើសន្ទានការីធ្វើពង្រាងកិច្ចព្រមព្រៀង គាត់អាចប្រថុយជាមួយនឹងការលម្អៀងទៅភាគីម្ខាង ឬភាគីម្ខាងទៀត ដោយសារពាក្យបេចន៍ដែលគាត់ជ្រើសរើស។ យកល្អសន្ទានការីគួរសរសេរចូលនូវចំណុចជាមូលដ្ឋាននៃកិច្ចព្រមព្រៀងនៅចុងបញ្ចប់សម័យប្រជុំ ឱ្យភាគីចុះហត្ថលេខាលើនោះ ហើយទុកពេលវេលាដល់ភាគីឱ្យធ្វើពង្រាងកិច្ចព្រមព្រៀងទាំងមូលដោយខ្លួនឯង។ សន្ទានការីអាចត្រួតពិនិត្យកិច្ច ព្រម-ព្រៀងនោះបាន ប៉ុន្តែទោះជាយ៉ាងនេះក្តី គាត់ត្រូវមានការប្រុងប្រយ័ត្នចំពោះការជួយភាគីម្ខាងច្រើន ជាងភាគីម្ខាងទៀត។ វាគឺជាស្ថានភាពដែលរសើបបំផុត នៅពេលភាគីពីរដែលមានជម្លោះនឹងគ្នា បែរជាស្រុះស្រួលគ្នា ហើយព្យាយាមរំលឹកពីកិច្ចព្រមព្រៀងរបស់ពួកគេ។ អាស្រ័យហេតុនេះ សន្ទានការីត្រូវប្រុងប្រយ័ត្នថែមទៀត ដើម្បីធានាថាខ្លួននឹងមិនធ្វើអ្វីឱ្យប៉ះទង្គិចដល់តុល្យភាពនោះឡើយ។

---

[១៤៩] ជួនកាលពាក្យនេះត្រូវបានគេហៅថា "ភាពទ័លច្រក"។

ប្រសិនបើលទ្ធផលទីពីរកើតឡើង (ត្រូវសម្រុះសម្រួលបន្ថែមទៀតនាពេលក្រោយ) សន្ធានការីត្រូវសង្កត់ធ្ងន់លើការរីកចម្រើនដែលបានបង្កើតឡើង និងផ្តល់សម្មើមួយចំនួនសម្រាប់ការពិចារណានាសម្រាប់កិច្ចប្រជុំលើកក្រោយ។ កិច្ចប្រជុំបន្ទាប់ត្រូវកំណត់កាលបរិច្ឆេទឱ្យបានឆាប់ ដើម្បីជួយរក្សាភាពជឿនលឿនដែលទទួលបាននៅក្នុងកិច្ចប្រជុំមុន។

លទ្ធផលទីបីអាចកើតឡើងនៅគ្រប់ពេលទាំងអស់។ ភាគីណាម្ខាងអាចបញ្ចប់កិច្ចប្រជុំសម្រុះសម្រួលកាន់តែឆាប់ ប្រសិនបើពួកគេខឹង ឬមិនមានឆន្ទៈក្នុងការបន្តការពិភាក្សាតទៅទៀត។ សន្ធានការីមិនអាចធ្វើអ្វីបានទាំងអស់ ប្រសិនបើភាគីណាមួយបដិសេធយ៉ាងដាច់អហង្ការក្នុងការពិភាក្សាដំណោះស្រាយតទៅទៀត។ សន្ធានការី ក៏អាចជ្រើសរើសយកការបញ្ចប់កិច្ចប្រជុំផងដែរ ប្រសិនបើមិនមានការព្រមព្រៀងណាមួយអាចកើតឡើងបាន។ ទោះបីជាសន្ធានកម្មគឺជាមធ្យោបាយដ៏ប្រសើរបំផុតសម្រាប់ដោះស្រាយ ក៏ទីបំផុតគឺវាអាស្រ័យតែទៅលើភាគីវិវាទខ្លួនឯង ហើយវិវាទមួយចំនួនក៏មិនអាចយកមកសម្រុះសម្រួលដោយជោគជ័យដែរ។ នៅពេលសន្ធានកម្មត្រូវបានបញ្ចប់បែបនេះ ភាគីមានសេរីភាពក្នុងការបន្តវិវាទរបស់ពួកគេនៅក្នុងវេទិកាផ្សេងទៀត ដូចជាមជ្ឈត្តការ ការចរចាជាឯកជន ព្រមទាំងបណ្តឹងទៅតុលាការ។

## ច. តួនាទីរបស់សន្ធានការី

ជាទូទៅ សន្ធានការីត្រូវមានភាពចុះសម្រុងជាមួយមនុស្សគ្រប់ប្រភេទទាំងអស់។ សន្ធានការីត្រូវតែជាអ្នកស្តាប់ដ៏ពូកែម្នាក់។ សន្ធានការីត្រូវមានឆន្ទៈក្នុងការស្វែងយល់អំពីចំណុចខ្លាំង និងចំណុចខ្សោយនៃការទាមទាររបស់ភាគីនីមួយៗ ហើយត្រូវមានលទ្ធភាពក្នុងការជួយឱ្យអ្នកចូលរួមបានយល់ដឹងអំពីវាឱ្យបានគ្រប់ជ្រុងជ្រោយ។ សន្ធានការីត្រូវតែលើកទឹកចិត្តដល់ភាគី ទោះបីជាស្ថានភាពហាក់ដូចជាមិនល្អក៏ដោយ។ ទីបញ្ចប់ សន្ធានការីត្រូវមានភាពច្នៃប្រឌិតនៅក្នុងការគិតរបស់ខ្លួន ដើម្បីអនុញ្ញាតឱ្យភាគីពិចារណាអំពីជម្រើសជាច្រើនសម្រាប់ដោះស្រាយ។ មានល័ក្ខខ័ណ្ឌតម្រូវមួយចំនួនដែលសន្ធានការីដែលមានភាពជោគជ័យគួរមាន។ ខាងក្រោមនេះ គឺជាបញ្ជីលក្ខណៈពិសេសជាក់លាក់មួយចំនួនដែលកំនត់ជារួមអំពីសន្ធានការីដែលមានភាពជោគជ័យ។[១៥០] សន្ធានការីនោះ:

- ត្រូវនៅតែមានភាពអព្យាក្រឹត ទោះបីជាមានរឿងអ្វីកើតឡើងក៏ដោយ
- ត្រូវតែជាអ្នកតស៊ូមតិសម្រាប់ដំណើរសន្ធានកម្ម នៅទីបំផុត (មិនមែនសម្រាប់ភាគីណាមួយ ឬជំហរ ឬដំណោះស្រាយជាក់លាក់ណាមួយឡើយ)
- តែងមានភាពសណ្តោស និងយល់ចិត្តថ្លើមដល់ភាគីវិវាទ
- ផ្តោតលើការពិភាក្សាអំពីផលប្រយោជន៍ ជំនួសឱ្យអំពីជំហរ របស់ភាគី
- ព្យាយាមធ្វើឱ្យដំណើរការវិវត្តទៅមុខ (ដោយផ្តោតលើជម្រើស និងបញ្ហា មិនមែនលើភាគីឡើយ)
- រក្សាភាពវិជ្ជមាន និងភាពលើកទឹកចិត្ត ទោះបីជានៅចំពោះមុខស្ថានភាពលំបាកក៏ដោយ
- មិនភាពក្រាញននាល
- មានឆន្ទៈក្នុងការសាកល្បងវិធីសាស្ត្រផ្សេងៗ ដោយផ្អែកលើចរិតនៃវិវាទ និងបុគ្គលិកលក្ខណៈផ្សេងៗហើយ
- ស្វែងរកជម្រើសដំណោះស្រាយដែលអាចមានជានិច្ច

បញ្ហាចុងក្រោយពាក់ព័ន្ធទៅនឹងប្រការដែលថា តើសន្ធានការីត្រូវដើរតួនាទីហួសពីការត្រឹមតែជួយសម្របសម្រួលដែរឬទេ។ តើសន្ធានការីត្រូវផ្តល់មតិយោបល់ ឬជម្រើស ចំណុចផ្លូវច្បាប់ ឬបញ្ហាផ្សេងទៀតដែរឬទេ? តើសន្ធានការីត្រូវផ្តល់សម្មើសម្រាប់ដោះស្រាយដែរឬទេ? ជួនកាល គេហៅចំណុចទាំងនេះថាជាតួនាទី "វាយតម្លៃ"។ អ្នកវិជ្ជាជីវៈខាងដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មានទស្សនៈខុសគ្នាចំពោះបញ្ហាទាំងនេះ។ វាអាស្រ័យទៅលើកត្តាជាច្រើនរួមទាំងគោលការណ៍ច្បាប់ និងវប្បធម៌ដែលជាមានភាពកាន់តែទូលំទូលាយ ការរំពឹងទុករបស់ភាគីវិវាទ បុគ្គលិកលក្ខណៈរបស់សន្ធានការី និងវិធានច្បាប់ក្នុងមូលដ្ឋានផងដែរ។ យុត្តាធិការមួយចំនួនអាចចាត់ទុកសន្ធានការី ដែលមិនមែនជាមេធាវីថាអនុវត្តច្បាប់ដោយមិនមានការអនុញ្ញាត ប្រសិនបើគាត់ត្រូវផ្តល់ទស្សនៈផ្លូវច្បាប់ដល់ភាគីវិវាទនៅក្នុងសន្ធានកម្មនោះ។ ការអនុវត្តដែលប្រសើរបំផុតសម្រាប់សន្ធានការីគឺត្រូវលើកពីបញ្ហានេះក្នុងពេលពិភាក្សាបើកកិច្ចប្រជុំ ហើយត្រូវកំណត់ថា

---

[១៥០] មួយផ្អែកឃើញមាននៅក្នុង Patterson, et al កំណត់សម្គាល់ *ខាងលើ* លេខ៩ នៅទំព័រ ៦៧-៦៩។

តើភាគីពេញចិត្តនឹងឱ្យខ្លួនដើរតួនាទីវាយតម្លៃដែលសកម្មដែរឬទេ។ ប្រសិនបើភាគីមានភាពមិនពេញចិត្តនឹងចំនុចនេះទេ សន្ទានការីត្រូវរក្សាតួនាទីអសកម្ម និងសម្របសម្រួលវិញ។

## សំណួរសិក្សា

ទាមយោបល់របស់លោកអ្នក តើតួនាទីរបស់សន្ទានការីបែបណាមួយ (សម្របសម្រួល ឬអ្នកវាយតម្លៃ) ដែលជាទូទៅ មានប្រសិទ្ធភាពជាង សម្រាប់វិវាទខាងក្រោមនេះ:

- វិវាទរវាងប្តីដែលពូកែត្រួតត្រា និងប្រពន្ធដែលស្តាប់បង្គាប់ អំពីរឿងលុយកាក់
- វិវាទរវាងដៃគូអាជីវកម្មដែលឆ្លាតវៃពីរនាក់
- វិវាទរវាងពលរដ្ឋកម្ពុជា និងពលរដ្ឋអូស្រ្តាលី
- វិវាទរវាងនិយោជក និងនិយោជិត
- វិវាទរវាងសហគមន៍កសិករនៅតាមមូលដ្ឋាន និងមន្ត្រីរដ្ឋាភិបាល អំពីរឿងផ្តល់សម្បទានដីធ្លី
- វិវាទរវាងអ្នកជិតខាងពីរនាក់
- វិវាទរវាងអ្នកបើកបរម៉ូតូ និងអ្នកថ្មើរជើង ដែលគាត់បើកបុក

## ឆ. តួនាទីរបស់មេធាវី

ដូចបានរៀបរាប់ពីខាងលើ សន្ធានកម្មមួយចំនួនប្រព្រឹត្តទៅដោយគ្មានវត្តមានរបស់មេធាវីទេ។ ឧទាហរណ៍នៃសន្ធានកម្មបែបនេះ គឺជាវិវាទតូចមួយរវាងប្តី និងប្រពន្ធ។ ជាញឹកញាប់ សេវាសន្ធានកម្មនៅតាមសហគន៍ ដូចជានៅក្រុមប្រឹក្សាឃុំ-សង្កាត់នៅតាមមូលដ្ឋាន គឺជាសេវាមិនគិតថ្លៃ និងមានលក្ខណៈក្រៅផ្លូវការណាស់។ ប៉ុន្តែ ប្រសិនបើភាគីត្រូវបានតំណាងដោយមេធាវីមួយរូប នោះមេធាវីគួរតែចូលរួមនៅក្នុងសន្ធានកម្មនោះ។ ប្រសិនបើភាគីម្ខាងត្រូវបានតំណាងដោយមេធាវីមួយរូប ភាគីម្ខាងទៀតគួរតែមានមេធាវីមួយរូបជាតំណាងរបស់ខ្លួនដែរ។

***នោះជាមានមេធាវីឬគ្មានក្តី ភាគីដែលត្រូវធ្វើសន្ធានកម្មត្រូវមានសិទ្ធិពេញលេញក្នុងការដោះស្រាយវិវាទនោះ។***

នេះមិនមែនមានន័យថាមេធាវីគឺជាដំណើរការនោះទេ។ តាមពិត ភាគីមានលទ្ធភាពគ្រប់គ្រងស្ថានការណ៍នៅក្នុងសន្ធានកម្ម ច្រើនជាងនៅក្នុងការចរចា។ ខុសពីការចរចា ភាគីខ្លួនឯងតែងតែមានវត្តមាននៅក្នុងកិច្ចប្រជុំសម្រុះសម្រួលជានិច្ច ហើយត្រូវតែព្រមព្រៀងចំពោះដំណោះស្រាយ ឬការស្រុះស្រួលនោះ។ ពួកគេអាចនិយាយនៅក្នុងកិច្ចប្រជុំជាក្រុម ឬជាឯកជន ហើយជាញឹកញាប់ នឹងត្រូវបានលើកទឹកចិត្តដោយសន្ធានការីឱ្យធ្វើដូច្នោះ។ ហេតុនេះ តើមេធាវីត្រូវធ្វើអ្វីខ្លះ?

ពីដំបូង មេធាវីត្រូវសម្រេចចិត្តថាតើសង្កត់ធ្ងន់លើខសម្រុះសម្រួលនៅក្នុងកិច្ចសន្យារបស់ភាគីដែរឬទេ។ នៅក្នុងករណីមួយចំនួន សន្ធានកម្មអាចជួយសន្សំសំចៃពេលវេលា និងប្រាក់កាសបាន។ ប្រសិនបើមេធាវីចូលទៅពាក់ព័ន្ធនឹងវិវាទនោះ បន្ទាប់ពីកិច្ចសន្យាដែលទាក់ទងនឹងវិវាទនោះត្រូវបានចុះហត្ថលេខារួច ហើយមិនមានខស្តីពីដំណោះស្រាយវិវាទទេនោះ មេធាវីអាចពិចារណាអំពីសន្ធានកម្ម ប្រសិនបើការចរចាជាមូលដ្ឋានមិនអាចដោះស្រាយបញ្ហាបានទេ។

***ជាទូទៅ សន្ធានកម្មមានតម្លៃថ្លៃជាងការចរចា ហើយដូចបានរៀបរាប់ពីខាងលើ សន្ធានកម្មអាចធ្វើទៅបានលុះត្រាតែភាគីទាំងសងខាងមានឆន្ទៈក្នុងការព្យាយាមដោះស្រាយវិវាទដោយពេញចិត្តតែប៉ុណ្ណោះ។***

តួនាទីពីដំបូងផ្សេងទៀត រួមដូចជា ជួយកូនក្តីឱ្យស្វែងរកសន្ធានការីដែលមានសមត្ថភាព និងអព្យាក្រឹតភាព ការជ្រើសរើសមជ្ឈមណ្ឌលសន្ធានកម្ម ប្រសិនបើសមស្រប និងដាក់ឱ្យសន្ធានការីត្រួតពិនិត្យនូវ ឯកសារផ្សេងៗមុនពេលសន្ធានកម្ម។ តួនាទីសំខាន់ជាងគេបំផុតមួយរបស់មេធាវីមុនពេលធ្វើសន្ធានកម្ម គឺការរៀបចំខ្លួនកូនក្តីរបស់ខ្លួន។ មេធាវីត្រូវរៀបចំខ្លួនកូនក្តីឱ្យគិតអំពីយុទ្ធសាស្ត្រដោះស្រាយ *មុនពេល* កិច្ចប្រជុំសម្រុះសម្រួលចាប់ផ្តើម។ នេះមានន័យថាពិនិត្យមើលឡើងវិញនូវ BATNA តម្លៃបម្រុង អង្គហេតុ អង្គច្បាប់ ផលប្រយោជន៍ លទ្ធភាពស្រុះស្រួល និង "ជំហរចុងក្រោយ" ជាមួយកូនក្តីរបស់ខ្លួន។ កូនក្តីអាចមិនបានគិតច្បាស់លាស់អំពីផលប្រយោជន៍របស់ខ្លួន ពីព្រោះគាត់អាចគិតតែអំពីថាតើភាគីម្ខាងទៀតបានធ្វើឱ្យខូចប្រយោជន៍ដល់ខ្លួនយ៉ាងដូចម្តេចតែប៉ុណ្ណោះ។ មេធាវីត្រូវលើកទឹកចិត្តកូនក្តីឱ្យគិតដោយមិនលម្អៀងអំពីចំណុចខ្សោយនៃការទាមទាររបស់ខ្លួន និងកំណត់ឱ្យឃើញពីផលវិបាកនៃការខកខានមិនបានដោះស្រាយផងដែរ។

ជាចុងក្រោយ មានចំនុចដែលត្រូវពិចារណាមួយចំនួនសម្រាប់កិច្ចប្រជុំសម្រុះសម្រួល ។ តើអ្នកណានឹងត្រូវនិយាយពេលបើកសម័យប្រជុំ? ជាធម្មតា នេះគឺជាការងាររបស់មេធាវី ។ តើអ្នកណានឹងនិយាយនៅក្នុងកំឡុងពេលពិភាក្សាជាក្រុម? ប្រហែលជាទាំងមេធាវីទាំងកូនក្តីនឹងត្រូវនិយាយ ប៉ុន្តែពួកគេត្រូវសម្រេចចិត្តថាតើពួកគេនឹងលើកយកបញ្ហាអ្វីខ្លះមកនិយាយាដើម្បីកុំឱ្យមានការយល់ច្រឡំ ។ កូនក្តីក៏ត្រូវយល់ថា សន្ធានការីមិនមែនជាចៅក្រមទេ ហើយក៏មិនអាចបង្ខំឱ្យខ្លួនធ្វើអ្វីមួយបានឡើយ ។ អ្វីៗគឺផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត ។ គេក៏ត្រូវលើកទឹកចិត្តកូនក្តីឱ្យស្តាប់នូវអ្វីដែលសន្ធានការី និងភាគីម្ខាងទៀតនិយាយផងដែរ ។

ជាចុងក្រោយ មេធាវីត្រូវពិភាក្សាអំពីអាកប្បកិរិយារបស់ខ្លួននៅពេលដែលមានកិច្ចប្រជុំដោះស្រាយ ។ កូនក្តីអាចមានភាពច្របូកច្របល់ ឬព្រួយបារម្ភ ប្រសិនបើមេធាវីមានភាពម៉ឺងម៉ាត់ និងប្រឆាំងភាគីម្ខាងទៀតនៅក្នុងកិច្ចប្រជុំជាក្រុម ប៉ុន្តែបន្ទាប់មកហាក់ដូចជាកាន់ជើងសន្ធានការី ជាងកូនក្តីរបស់ខ្លួនឯងនៅក្នុងជំនួបជាឯកជនទៅវិញ ។ មេធាវីត្រូវពន្យល់ថា សន្ធានការីអាចនឹងព្យាយាមជួយកូនក្តីនោះឱ្យយល់អំពីចំណុចខ្សោយរបស់ខ្លួននៅក្នុងជំនួបឯកជន ។ មេធាវីក៏អាចទទូចឱ្យមានដំណោះស្រាយជាក់លាក់ណាមួយដែរ ប៉ុន្តែខ្លួនតែងតែធ្វើអ្វីៗដើម្បីផលប្រយោជន៍ប្រសើរបំផុតរបស់កូនក្តីតែប៉ុណ្ណោះ ។

នៅពេលបើកកិច្ចប្រជុំ និងពិភាក្សាជាក្រុម មេធាវីត្រូវប្រុងប្រយ័ត្នក្នុងការថ្លឹងថ្លែងរវាងការដើរតួជាអ្នកតស៊ូមតិដ៏ខ្លាំងក្លា និងការសំដែងភាពបើកចំហចំពោះការស្រុះស្រួល ។ វេទិការនេះមិនមែនជាតុលាការទេ ហើយទោះបីជាការងាររបស់មេធាវីគឺតស៊ូមតិដើម្បីកូនក្តីរបស់ខ្លួនក៏ដោយ ក៏មេធាវីចង់ឱ្យកិច្ចប្រជុំសម្រុះសម្រួលនេះ ទទួលបានលទ្ធផលជាផ្លែផ្កាដែរ ។ ប្រសិនបើមេធាវីផ្តល់នូវសម្បទានណាមួយ ប្រហែលជាភាគីម្ខាងទៀតនឹងផ្តល់នូវសម្បទានធំជាងនេះលើរឿងអ្វីមួយផ្សេងទៀតវិញក៏មាន ។

នៅក្នុងកំឡុងពេលសម្រាក និងក្នុងកំឡុងពេលដែលសន្ធានការីស្ថិតនៅក្នុងជំនួបឯកជនជាមួយភាគីម្ខាងទៀត មេធាវីអាចជួយកូនក្តីឱ្យវាយតម្លៃអំពីការវិវត្តន៍ និងពិចារណាជម្រើសផ្សេងៗ ។ ពួកគេអាចត្រូវធ្វើការវាយតម្លៃឡើងវិញអំពីយុទ្ធសាស្ត្ររបស់ពួកគេ ដោយផ្អែកលើការអះអាងរបស់ភាគីម្ខាងទៀត ។ មេធាវីមិនត្រូវគ្រាន់តែអង្គុយ និងទុកឱ្យកូនក្តីស្វែងរកវិធីដោះស្រាយបញ្ហាដោយខ្លួនឯងនោះទេ ។

***មេធាវីត្រូវដើរតួនាទីយ៉ាងសកម្មនៅក្នុងការស្វែងរក និងវិភាគលើដំណោះស្រាយនានាជាមួយកូនក្តី ។***

នៅចុងបញ្ចប់នៃដំណើរការសន្ធានកម្ម មេធាវីត្រូវដឹកនាំការធ្វើពង្រាងកិច្ចព្រមព្រៀងដោះស្រាយជាមួយភាគីម្ខាងទៀត ។ វិធីមួយក្នុងការធ្វើដូច្នេះ គឺអនុញ្ញាតឱ្យមេធាវីរបស់ភាគីម្ខាងធ្វើពង្រាងដំបូងជាមុនសិន ហើយបន្ទាប់មកដាក់ឱ្យភាគីម្ខាងទៀតពិនិត្យ ។ វិធីម្យ៉ាងទៀតគឺមេធាវីទាំងពីរនាក់អង្គុយជាមួយគ្នា ហើយសរសេរកិច្ចព្រមព្រៀងនោះតែម្តង ។ នៅក្នុងករណីទាំងពីរ មេធាវីនឹងត្រូវពន្យល់អំពីបទប្បញ្ញត្តិនីមួយៗដល់ កូនក្តីរបស់ខ្លួនដើម្បីប្រាកដថា ពួកគេយល់ដឹង និងឯកភាពលើបទប្បញ្ញត្តិទាំងនោះ ។ ប្រសិនបើមានវិវាទអំពីល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀង មេធាវីអាចសុំឱ្យសន្ធានការីជួយ ប៉ុន្តែសន្ធានការីត្រូវប្រុងប្រយ័ត្នកុំឱ្យមានភាពលម្អៀងទៅរកភាគីណាមួយ ។

# ៥. ក្រមសីលធម៌សម្រាប់សន្ធានការី

សន្ធានកម្មលើកឡើងនូវបញ្ហាក្រមសីលធម៌ដ៏សំខាន់ៗ ដែលមានសារៈសំខាន់ចំពោះសន្ធានការី ភាគី ក៏ដូចជាប្រព័ន្ធយុត្តិធម៌ទាំងមូល។ សន្ធានការីក៏ដូចជាចៅក្រម ឬមជ្ឈត្តករដែរ អាចមានអំណាចដ៏ធំធេងទៅលើប្រជាពលរដ្ឋទូទៅ។ អំណាចនោះអាចត្រូវបានយកមកប្រើប្រាស់សម្រាប់គោលបំណងល្អ ឬអាក្រក់។ ខណៈពេលដែលចៅក្រម និងមជ្ឈត្តករហាក់ដូចជានៅឆ្ងាយពីភាគីវិវាទ ជួបជាមួយពួកគេតែក្នុងបរិយាកាសដែលមានកម្រិត និងជាផ្លូវការ សន្ធានការីគឺមានទំនាក់ទំនងយ៉ាងសំបូរបែប និងជិតស្និទ្ធជាមួយភាគីជាង។ ខុសពីចៅក្រម និងមជ្ឈត្តករ សន្ធានការីអាចមានជំនួបជាឯកជនជាច្រើនជាមួយភាគី ដើម្បីពិភាក្សាអំពីអារម្មណ៍ ផលប្រយោជន៍ កង្វល់ និងការព្រួយបារម្ភរបស់ពួកគេ។ ជួនកាល ពួកគេអាចព្យាយាមបញ្ចុះបញ្ចូលភាគីថែមទៀត។ ទោះបីជាភាគច្រើន ប្រការនេះគឺជាផលប្រយោជន៍ដ៏ល្អបំផុតសម្រាប់មនុស្សគ្រប់រូបក៏ដោយ ក៏មានកង្វល់ពាក់ព័ន្ធនឹងក្រមសីលធម៌ជាច្រើនដែលអាចកើតឡើងផងដែរ។

វិធីងាយស្រួលបំផុតក្នុងការសង្ខេបអំពីកង្វល់ក្រមសីលធម៌ចម្បងៗ គឺដកស្រង់នូវបទដ្ឋានចំនួនប្រាំបួន ដែលត្រូវបានកំណត់នៅក្នុងបទដ្ឋានប្រតិបត្តិគម្រូសម្រាប់សន្ធានការីរបស់គណៈមេធាវីអាមេរិក។[១៥១] អត្ថបទទាំងស្រុងមានផ្ដល់ជូននៅក្នុងឧបសម្ព័ន្ធខនៃសៀវភៅសិក្សានេះ។

**បទដ្ឋានទី I: សិទ្ធិស្វ័យសម្រេច**

សន្ធានការីត្រូវធ្វើការសម្រុះសម្រួលដោយផ្អែកលើគោលការណ៍ស្វ័យសម្រេចរបស់ភាគី។ សិទ្ធិស្វ័យសម្រេច គឺជាកិរិយានៃការឈានដល់ការសម្រេចចិត្តដោយស្ម័គ្រចិត្ត និងគ្មានការបង្ខិតបង្ខំ ដែលក្នុងនោះ ភាគីនីមួយៗ ធ្វើការជ្រើសរើសដោយសេរី និងដោយជ្រួតជ្រាបអំពីដំណើរការ និងលទ្ធផល។ ភាគីអាចអនុវត្ត សិទ្ធិស្វ័យសម្រេចនៅគ្រប់ដំណាក់កាលទាំងអស់នៃសន្ធានកម្ម រួមទាំងការជ្រើសរើសសន្ធានការី ការរៀបចំដំណើរការ ការចូលរួម ឬការដកខ្លួនចេញពីដំណើរការ និងលទ្ធផលផ្សេងៗ។

**បទដ្ឋានទីII: អនាគតិ**

សន្ធានការីត្រូវបដិសេធចំពោះសន្ធានកម្ម ប្រសិនបើសន្ធានការីនោះមិនអាចធ្វើការសម្រុះសម្រួលក្នុងរបៀបមិនលម្អៀងបាន។ អនាគតិ សំដៅទៅលើអវត្តមាននៃភាពគាំទ្រនិយម អគតិ ឬបុរេ វិនិច្ឆ័យ។ សន្ធានការីត្រូវធ្វើការសម្រុះសម្រួលនៅក្នុងរបៀបមិនលម្អៀង និងត្រូវចៀសវាងកិរិយាណាដែលស្ដែងឱ្យឃើញពីភាពលម្អៀង។ ប្រសិនបើនៅពេលណាមួយសន្ធានការីមិនអាចធ្វើការសម្រុះសម្រួលក្នុងលក្ខណៈមិនលម្អៀងបាននោះទេ សន្ធានការីត្រូវដកខ្លួនចេញ។

**បទដ្ឋានទីIII: ទំនាស់ផលប្រយោជន៍**

សន្ធានការីត្រូវចៀសវាងទំនាស់ផលប្រយោជន៍ ឬការលេចឡើងនូវទំនាស់ផលប្រយោជន៍ក្នុងពេល និងក្រោយពេលសន្ធានកម្ម។ ទំនាស់ផលប្រយោជន៍ អាចកើតឡើងចេញពីការជាប់ពាក់ព័ន្ធរវាងសន្ធានការី ជាមួយនិងបញ្ហាដែលជា

---

[១៥១] **បទដ្ឋានប្រតិបត្តិគម្រូសម្រាប់សន្ធានការី** គណៈមេធាវីអាមេរិក សមាគមមជ្ឈត្តការអាមេរិក និងសមាគមដោះស្រាយវិវាទ (ឆ្នាំ២០០៥) មាននៅ http://w ww.abanet.org/dispute/news/ModelStandardsofConduct forMediatorsfinal05.pdf (ចូលទស្សនាលើកចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨)។ នេះគឺជាក្រមសីលធម៌ដ៏មានឥទ្ធិពលបំផុតសម្រាប់សន្ធានការី។ អត្ថបទទាំងស្រុងនៃក្រមនេះអាចរកបាននៅក្នុងឧបសម្ព័ន្ធនៃសៀវភៅនេះ។

កម្មវត្ថុនៃវិវាទ ឬពីទំនាក់ទំនងណាមួយរវាងសន្ទានការី និងអ្នកចូលរួមក្នុងសន្ទានកម្ម ទាំងក្នុងពេលអតីតកាល ឬបច្ចុប្បន្នកាល ទាំងបែបផ្ទាល់ខ្លួន ឬបែបវិជ្ជាជីវៈ ដែល ទាំងអស់នេះនាំឱ្យមានចំណោទដល់អនាគតិរបស់សន្ទានការី ។

**បទដ្ឋានទីIV: សមត្ថភាព**

សន្ទានការីអាចធ្វើសន្ទានកម្មបាន តែនៅពេលដែលខ្លួនមានសមត្ថភាពគ្រប់គ្រាន់ដើម្បីបំពេញតាមការរំពឹងទុកដ៏សមស្របរបស់ភាគីវិវាទប៉ុណ្ណោះ ។

**បទដ្ឋានទីV: ការរក្សាការសម្ងាត់**

សន្ទានការីត្រូវរក្សាការសម្ងាត់ចំពោះព័ត៌មានទាំងឡាយដែលខ្លួនទទួលបានក្នុងកិច្ចការសម្រុះសម្រួល លើកលែងតែភាគីវិវាទមានការព្រមព្រៀងផ្សេងពីនេះ ឬជាការតំរូវតាមច្បាប់ដែលត្រូវអនុវត្ត ។

**បទដ្ឋានទីVI: គុណភាពនៃដំណើរការ**

សន្ទានការីត្រូវដឹកនាំសន្ទានកម្មឱ្យស្របនឹងបទដ្ឋានទាំងនេះ និងនៅក្នុងរបៀបមួយដែលលើកកម្ពស់ ការយកចិត្តទុកដាក់កាលានុវត្ត សុវត្ថិភាព វត្តមានអ្នកចូលរួមដែលសមស្រប ការចូលរួមរបស់ភាគី ភាពត្រឹមត្រូវតាមនីតិវិធី សមត្ថភាពរបស់ភាគី និងការគោរពទៅវិញទៅមករវាងអ្នកចូលរួមទាំងអស់ ។

**បទដ្ឋានទីVII: ការឃោសនា និងផ្សព្វផ្សាយ**

សន្ទានការីត្រូវតែនិយាយតែការពិត ហើយឥតបំផ្លើស នៅពេលឃោសនា ផ្សព្វផ្សាយ ឬនៅពេល ផ្ដល់ព័ត៌មានតាមវិធីផ្សេងទៀត ស្ដីអំពីគុណវុឌ្ឍិ បទពិសោធន៍ សេវាកម្ម និងថ្លៃឈ្នួល របស់សន្ទានការីនោះ ។

**បទដ្ឋានទីVIII: ថ្លៃឈ្នួល និងសោហ៊ុយដទៃទៀត**

សន្ទានការីត្រូវផ្ដល់ឱ្យភាគីនិមួយៗ ឬតំណាងរបស់ភាគីនិមួយៗនូវព័ត៌មានពិតប្រាកដ និងពេញលេញ អំពីថ្លៃឈ្នួលសម្រុះសម្រួល ថ្លៃចំណាយនានា ព្រមទាំងថ្លៃសោហ៊ុយជាក់ស្ដែង និងសក្ខានុភូតផ្សេងទៀត ដែលអាចមានពាក់ព័ន្ធនឹងសន្ទានកម្ម ។

**បទដ្ឋានទីIX: ការរីកចំរើននៃការអនុវត្តសន្ទានកម្ម**

សន្ទានការីគួរប្រព្រឹត្តខ្លួនក្នុងរបៀបមួយ ដែលជម្រុញការអនុវត្តសន្ទានកម្មឱ្យមានភាពរីកចំរើន ។ សន្ទានការីត្រូវបង្ហាញការគោរពចំពោះទស្សនៈផ្សេងៗគ្នានៅក្នុងវិស័យសន្ទានកម្ម ស្វះស្វែងរៀនសូត្រ ពីសន្ទានការីដទៃទៀត និងធ្វើការងាររួមគ្នាជាមួយសន្ទានការីដទៃទៀត ដើម្បីស្ថាបនាអាជីពរបស់ខ្លួន និងបម្រើអ្នកដែលមានទំនាស់ឱ្យបានកាន់តែប្រសើរ ។

**លំហាត់ ៖ ក្រមសីលធម៌សន្ទានការី**

ទោះបីជាស្តង់ដារទាំងនេះអាចហាក់ដូចជាមានភាពសាមញ្ញ និងមានភាពសមហេតុសមផលក៏ដោយ ក៏ជួនកាលវាមានការលំបាកក្នុងការអនុវត្តនៅក្នុងស្ថានភាពនៃពិភពពិតដែរ ។ សម្រាប់លទ្ធភាពជាទ្រឹស្ដីនីមួយៗដូចខាងក្រោម សូមពិនិត្យឡើងវិញនូវបទដ្ឋានប្រតិបត្តិគម្រូសម្រាប់សន្ទានការី និងគូសរង្វង់លើផ្លូវប្រតិបត្តិដែលល្អបំផុត ក្នុងចំណោមជម្រើសចំនួនបីដែលបានផ្ដល់ជូនគឺ ក, ខ ឬ គ។ ត្រូវឧបមាថាអ្នកគឺជាសន្ទានការីឯករាជ្យ ហើយជួបប្រទះនូវហេតុការណ៍ដូចដែលមាននៅក្នុងប្រអប់នីមួយៗ:[១៥២]

[១៥២] យកលំនាំតាម Patterson, *et al.* កំណត់សម្គាល់ *ខាងលើ* លេខ៩ នៅទំព័រ៩៣ ។

## លំហាត់ ៗ ក្រមសីលធម៌សន្ធានការីៈ មុនពេលធ្វើសន្ធានកម្ម

| | សំនួរ ឬបញ្ហា | ចម្លើយតបតាមក្រមសីលធម៌ |
|---|---|---|
| ១ | អ្នកឮថាសាច់ញាតិម្នាក់របស់អ្នក ប្រហែលជានឹងត្រូវបានតែងតាំងជាសាក្សីជំនាញនៅក្នុងរឿងក្ដីដែលគេស្នើឱ្យអ្នកធ្វើជាសន្ធានការី ។ | ក. ជូនដំណឹងដល់ភាគីវិវាទ ហើយបន្តសន្ធានកម្ម បើពួកគេយល់ព្រម ។<br>ខ. ដកខ្លួនចេញពីសន្ធានកម្ម ។<br>គ. ស្នើឱ្យសាច់ញាតិដកខ្លួនចេញ ប្រសិនបើគេបដិសេធ ដកខ្លួនចេញពីសន្ធានកម្មនោះ ។ |
| ២ | ភាគីវិវាទប្រាប់អ្នកថាពួកគេមិនអាចរ៉ាប់រងថ្លៃសម្រុះសម្រួលជាស្តង់ដារបានទេ ប៉ុន្តែ ពួកគេពិតជាចង់បានអ្នកធ្វើជាសន្ធានការី ។ | ក. ដកខ្លួនចេញពីសន្ធានកម្ម ។<br>ខ. ចរចាយកតម្លៃថោកជាងមុន ដរាបណាវាមិនធ្វើឱ្យអ្នកលម្អៀងទៅរកភាគីទេនោះ ។<br>គ. ប្រាប់ភាគីកុំឱ្យព្រួយបារម្ភអំពីរឿងកម្រៃ រហូតដល់ទទួលបានលទ្ធផល ។ បន្ទាប់មក អាស្រ័យទៅលើលទ្ធផល ព្យាយាមគណនាតម្លៃដែលសមស្រប ។ |
| ៣ | ភាគីវិវាទពិតជាត្រូវការដំណោះស្រាយរឿងក្ដីរបស់ពួកគេមែនទែន ។ ពួកគេផ្តល់ឱ្យអ្នក នូវតម្លៃមួយជាពីរ ប្រសិនបើមានការព្រមព្រៀង ប៉ុន្តែ ផ្តល់តម្លៃធម្មតា ប្រសិនបើមិនមានការព្រមព្រៀងនោះទេ ។ | ក. ដកខ្លួនចេញពីសន្ធានកម្ម ។<br>ខ. បញ្ជាក់ថាអ្នកយកតែតម្លៃធម្មតាប៉ុណ្ណោះ ទោះជាមានលទ្ធផលយ៉ាងដូចម្ដេចក៏ដោយ ។<br>គ. យល់ព្រមចំពោះសម្ដីនោះ ហើយបន្ទាប់មក នៅពេលបញ្ចប់សន្ធានកម្ម បដិសេធមិនយកតម្លៃលើសពីធម្មតា ប្រសិនបើលទ្ធផលគឺមិនមានការព្រមព្រៀងទេ ។ |
| ៤ | ភាគីម្ខាងមានកង្វល់ថា អ្នកគឺជាមិត្តភក្តិរបស់ចៅក្រម ដែលត្រូវបានចាត់តាំងធ្វើរឿងក្ដីនោះ ។ | ក. ពន្យល់ប្រាប់ភាគីថាលោកអ្នកនៅតែមានភាពអព្យាក្រឹតនៅក្នុងសន្ធានកម្ម (ដូចជាចៅក្រមនោះដែរ) ។ បន្តធ្វើសន្ធានកម្ម ប្រសិនបើពួកគេយល់ព្រម ។<br>ខ. ប្រាប់ពីមិត្តភាពរបស់អ្នកដល់ភាគីទាំងអស់ ហើយបន្តធ្វើ សន្ធានកម្ម ប្រសិនបើពួកគេយល់ព្រម ។<br>គ. ដកខ្លួនចេញពីសន្ធានកម្ម ។ |
| ៥ | ភាគីម្ខាងដឹងថាអ្នកមិនធ្លាប់ សម្រុះ-សម្រួលវិវាទពាក់ព័ន្ធនឹងឧស្សាហកម្មកាត់ដេរទេ ហើយមានចម្ងល់ថាតើអ្នកមានគុណសម្បត្តិគ្រប់គ្រាន់អាចសម្រុះសម្រួលវិវាទផ្នែកអាជីវកម្មកាត់ដេររបស់ខ្លួន បានដែរឬទេ ។ | ក. ដកខ្លួនចេញពីសន្ធានកម្ម ។<br>ខ. ពន្យល់ប្រាប់ដល់ភាគីវិវាទ អំពីមូលហេតុដែលអ្នកយល់ឃើញថាខ្លួនមានសមត្ថភាព ហើយប្រសិនបើភាគីណាមួយនៅតែសង្ស័យពីសមត្ថភាពអ្នកនោះ ទើបដកខ្លួនចេញ ។<br>គ. ពន្យល់ប្រាប់ដល់ភាគីទាំងអស់អំពីមូលហេតុដែលអ្នកយល់ឃើញថាខ្លួនមានសមត្ថភាព ហើយបន្តធ្វើសន្ធានកម្ម ។ |

| | | |
|---|---|---|
| ៦ | ភាគីម្ខាងនិយាយថាអ្នកចូលរួមទាំងពីរមានមានចំណេះដឹងច្រើនហើយ និងស្នើឱ្យអ្នករំលងផ្នែកជាច្រើននៃការបើកកិច្ចប្រជុំសន្ទានកម្ម ដើម្បីសន្សំសំចៃពេលវេលា។ | ក. ធ្វើការអង្កេតដើម្បីមើលថាតើពួកគេពិតជាមានចំណេះដឹងច្រើនដល់កម្រិតណា ហើយបន្ទាប់មកពិចារណារំលងផ្នែកណាមួយនៃការបើកកិច្ចប្រជុំសន្ទានកម្ម។<br>ខ. បដិសេធសម្នើនោះ ការបើកកិច្ចប្រជុំសន្ទានកម្មមានសារៈសំខាន់ណាស់ ហើយដំណើរសន្ទានកម្មត្រូវតែទទួលបាននូវការការពារ។<br>គ. យល់ព្រមទទួលយកសម្នើដើម្បីកសាងទំនុកចិត្ត ដរាបណាមានការព្រមព្រៀងពីភាគីវិវាទ។ |
| ៧ | មុននឹងកិច្ចប្រជុំចាប់ផ្ដើម អ្នកដឹងថាភាគីម្ខាងមិនមានសិទ្ធិអំណាចពេញលេញ ក្នុងដំណោះស្រាយទេ។ ប៉ុន្តែគាត់តវ៉ាថាប្រធានរបស់គាត់ត្រៀមខ្លួនឆ្លើយទូរស័ព្ទ ប្រសិនបើគាត់ត្រូវការទូរស័ព្ទទៅរក។ | ក. ទូរស័ព្ទទៅប្រធាន ហើយទាមទារថាគាត់ត្រូវតែមានពេលទំនេរចាំឆ្លើយទូរស័ព្ទជាញឹកញាប់ ពីតំណាងរបស់គាត់បាន។ ប្រសិនបើអាចធ្វើបាន ហើយភាគីទាំងអស់យល់ព្រម ទើបចាប់ផ្ដើមធ្វើសន្ទានកម្ម។<br>ខ. ចាប់ផ្ដើមធ្វើសន្ទានកម្ម ប្រសិនបើភាគីទាំងអស់យល់ព្រមចំពោះការរៀបចំបែបនេះ។<br>គ. មិនធ្វើសន្ទានកម្មរហូតដល់ភាគីទាំងអស់ដែល មានវត្តមានមានសិទ្ធិអំណាចដោះស្រាយ។ |

## លំហាត់ ~ ក្រមសីលធម៌សន្ធានការី៖ ក្នុងកំឡុងពេលធ្វើសន្ធានកម្ម

| | សំនួរ ឬបញ្ហា | ចម្លើយតបតាមក្រមសីលធម៌ |
|---|---|---|
| ១ | នៅក្នុងជំនួបជាឯកជន មេធាវីរបស់ភាគីម្ខាងទាមទារថាកូនក្តីមិនគួរនិយាយអ្វីទាំងអស់ ហើយទុកឱ្យខ្លួនជាអ្នកនិយាយ ។ | ក. បញ្ឈប់សន្ធានកម្ម ។<br>ខ. ព្យាយាមបញ្ចុះបញ្ចូលមេធាវីនោះថា ដំណើរការសន្ធានកម្មតម្រូវឱ្យភាគីទាំងអស់ចូលរួម ហើយប្រសិនបើគាត់នៅតែមិនយល់ព្រម ត្រូវបញ្ឈប់សន្ធានកម្មនោះ ។<br>គ. ព្យាយាមបញ្ចុះបញ្ចូលមេធាវីនោះ ថាដំណើរការសន្ធានកម្មតម្រូវឱ្យភាគីទាំងអស់ចូលរួម ហើយប្រសិនបើគាត់នៅតែមិនយល់ព្រម ទើបបន្តសន្ធានកម្មទៀត ប្រសិនបើភាគីទាំងអស់យល់ព្រម ។ |
| ២ | ក្នុងជំនួបជាឯកជនជាមួយភាគីម្ខាង ភាគីនោះសារភាពថា បានលួចទ្រព្យសម្បត្តិរបស់ភាគីម្ខាងទៀត ។ | ក. ប្រាប់ទៅភាគីវិវាទថា អ្នកត្រូវតែជូនដំណឹងដល់តុលាការ ឬអាជ្ញាធរនគរបាលថាភាគីម្ខាងបានប្រព្រឹត្តបទល្មើស ។ ហើយត្រូវបញ្ឈប់សន្ធានកម្មនោះ ។<br>ខ. ប្រាប់ទៅភាគីដែលសារភាពនោះតែប៉ុណ្ណោះថា អ្នកត្រូវជូនដំណឹងនេះ ទៅតុលាការ ឬអជ្ញាធរនគរបាលថា ខ្លួនបានប្រព្រឹត្តបទល្មើស ។ ហើយត្រូវបញ្ឈប់សន្ធានកម្មនោះ ។<br>គ. បន្តធ្វើសន្ធានកម្មតទៅទៀត អ្នកមិនចាំបាច់ប្រាប់អ្នកណាទាំងអស់អំពីបទល្មើសពីមុនមក ។ |
| ៣ | អ្នកបានឈានមកជិតដល់ទីបញ្ចប់ នៃសន្ធានកម្មដ៏វែងឆ្ងាយមួយ ហើយអ្នកក៏ដឹងថាអ្នកច្បាប់ដែលជាដៃគូរបស់អ្នកធ្លាប់ធ្វើជាតំណាងឱ្យភាគីម្ខាងកាលពីអតីតកាលនៅក្នុងកំឡុងពេលដែលអ្នកជាដៃគូការងាររបស់គាត់ ។ | ក. ប្រាប់ដល់ភាគីវិវាទទាំងអស់ ហើយបន្តធ្វើសន្ធានកម្មល្គិកណាតែពួកគេទាំងអស់យល់ព្រមទាំងអស់គ្នា ។<br>ខ. ប្រាប់ដល់ភាគីវិវាទ ហើយបញ្ឈប់សន្ធានកម្មនោះ ។<br>គ. បញ្ឈប់សន្ធានកម្មនោះ ដោយមិនចាំបាច់ប្រាប់ពីមូលហេតុអ្វីទាំងអស់ គ្រាន់តែបញ្ជាក់ថាអ្នកទើបតែដឹងអំពីទំនាស់ផលប្រយោជន៍មួយបានហើយ ។<br>ឃ. បន្តធ្វើសន្ធានកម្មតទៅទៀត ហើយមិនចាំបាច់ប្រាប់ដល់ភាគីវិវាទឡើយ ។ មិនមានទំនាស់ផលប្រយោជន៍អ្វីទេ ព្រោះការតំណាងបានបញ្ចប់មុនសន្ធានកម្មនេះទៅហើយ ។ |

| | | |
|---|---|---|
| ៤ | ក្នុងជំនួបជាឯកជន ភាគីម្ខាងដែលមិនមានមេធាវីសួរអ្នកថា តើគាត់គួរតែយល់ព្រមទទួលសម្ដើរបស់ភាគីម្ខាងទៀតដែរឬទេ។ | ក. ផ្ដល់ចម្លើយទៅគាត់ ប៉ុន្តែត្រូវបញ្ជាក់ថានេះគឺជាអ្វីដែលអ្នកខ្លួនឯងនឹងធ្វើ នៅក្នុងស្ថានភាពនេះប៉ុណ្ណោះ។ ភាគីនោះត្រូវសម្រេចចិត្តដោយខ្លួនឯង។<br>ខ. បដិសេធមិនផ្ដល់ចម្លើយ អ្នកត្រូវនៅជាអព្យាក្រឹត។<br>គ. ផ្ដល់ព័ត៌មានដូចជាគុណសម្បត្តិ និងគុណវិបត្តិនៃសម្ដើនោះ ប៉ុន្តែមិនត្រូវណែនាំពីអ្វីដែលត្រូវធ្វើឡើយ។ |
| ៥ | ភាគីទាំងពីរត្រូវបានតំណាងដោយមេធាវី។ នៅក្នុងជំនួបជាឯកជន អ្នកដឹងថាភាគីម្ខាងបានផ្ដល់ព័ត៌មានដែលខុសយ៉ាងធ្ងន់ធ្ងរ ពាក់ព័ន្ធនឹងអង្គហេតុដែលយោងតាមនោះ ភាគីម្ខាងទៀតយកមកពិចារណាដោះស្រាយ។ | ក. បន្តសន្ទានកម្ម មិននិយាយអ្វីទាំងអស់ ហើយត្រូវស្ថិតនៅជាអព្យាក្រឹត។<br>ខ. បញ្ឈប់សន្ទានកម្មនោះ។<br>គ. ព្យាយាមបញ្ចុះបញ្ចូលភាគីដែលមានកំហុសថា គាត់ត្រូវសារភាពអំពីព័ត៌មានមិនពិតនោះ។ ប្រសិនបើគេបដិសេធ ត្រូវបន្តធ្វើសន្ទានកម្មតទៅទៀត។ |
| ៦ | នៅក្នុងកំឡុងសន្ទានកម្ម អ្នកបានដឹងថាភាគីម្ខាងបានជំនួសសម្ភារៈសំណង់ដែលមិនត្រឹមត្រូវ នៅក្នុងគម្រោងសាងសង់មួយ។ អ្នកជឿថាវានឹងធ្វើឱ្យអាគារនោះមិនមានសុវត្ថិភាព ប៉ុន្តែភាគីម្ខាងទៀតមិនដឹង អំពីការជំនួសនេះទេ ។ | ក. ប្រាប់ដល់ភាគីទាំងពីរអំពីអ្វីដែលអ្នកបានដឹង ហើយថាអ្នកមានបំណងចង់ទាក់ទងទៅអាជ្ញាធរមានសមត្ថកិច្ច និងបញ្ឈប់សន្ទានកម្មនោះ។<br>ខ. ប្រាប់ដល់ភាគីទាំងពីរអំពីអ្វីដែលអ្នកបានដឹង ហើយត្រូវព្យាយាមសម្រុះសម្រួលរកដំណោះស្រាយមួយ ដែលរួមបញ្ចូលទាំងដំណោះស្រាយចំពោះបញ្ហាសុវត្ថិភាពនោះដែរ។ ប្រសិនបើមិនជោគជ័យ ត្រូវប្រាប់ដល់អាជ្ញាធរ។<br>គ. ប្រាប់ដល់ភាគីទាំងអស់ថាអ្នកត្រូវបញ្ឈប់សន្ទានកម្មនោះ ប៉ុន្តែមិនត្រូវនិយាយថាហេតុអ្វីនោះទេ។ ប្រាប់ដល់អាជ្ញាធរជាបន្ទាន់។ |

## លំហាត់ ៖ ក្រមសីលធម៌សន្ធានការីៈ ក្រោយពេលសន្ធានកម្ម

| | សំនួរ ឬបញ្ហា | ចម្លើយតបតាមក្រមសីលធម៌ |
|---|---|---|
| ១ | នៅពេលអ្នកជូនដំណឹងទៅចៅក្រម ឬវេទិកាមជ្ឈត្តកម្មថា រឿងក្តីមិនទាន់បានដោះស្រាយ ចៅក្រម (ឬវេទិកា) នោះសួរថាហេតុអ្វី ។ | ក. បដិសេធមិនផ្តល់សេចក្តីលម្អិត ។<br>ខ. ផ្តល់សេចក្តីលម្អិត លុះត្រាតែភាគីទាំងអស់យល់ព្រមតែប៉ុណ្ណោះ ។<br>គ. ផ្តល់សេចក្តីលម្អិត ដរាបណាតុលាការ ឬវេទិកា យល់ព្រមរក្សាព័ត៌មាននោះជាការសម្ងាត់ ។ |
| ២ | ភាគីវិវាទមិនអាចស្វែងរកដំណោះ-ស្រាយ ដូច្នេះពួកគេស្នើឱ្យអ្នកធ្វើជាមជ្ឈត្តការលើរឿងក្តីនេះ ដោយត្រូវធ្វើមជ្ឈត្តវិនិច្ឆ័យភ្ជាប់កាតព្វកិច្ចផង ។ | ក. បដិសេធសម្ព ពីព្រោះអ្នកបានដឹងពីព័ត៌មានសម្ងាត់ ។<br>ខ. ប្រាប់ដល់ភាគីអំពីគ្រោះថ្នាក់ដែលអាចមាន និងយល់ព្រមចំពោះសម្ព លុះត្រាតែភាគីទាំងអស់យល់ព្រម ។ |
| ៣ | អ្នកបានសម្រុះសម្រួលរឿងក្តីមួយអំពីទំនាក់ទំនងក្នុងគ្រួសារ រវាងប្តី និងប្រពន្ធបានដោយជោគជ័យ ។ ប្តីធ្វើពង្រាងកិច្ចព្រមព្រៀង ហើយអ្នកដឹងថាកិច្ចព្រមព្រៀងនោះ មិនដូចបេះបិទទៅនឹងអ្វីដែលបានព្រមព្រៀងគ្នា នៅក្នុងកិច្ចប្រជុំចុងក្រោយនោះទេ ។ ពួកគេទាំងពីរគ្មានមេធាវីទេ ។ | ក. រក្សាទុកកិច្ចព្រមព្រៀងដែលសរសេររួចនោះ នៅដដែលប្រសិនបើប្រពន្ធអាន និងយល់ព្រម ។<br>ខ. លើកពីបញ្ហានេះជាបន្ទាន់ មកជជែកជាមួយភាគីទាំងពីរ (ដើម្បីឱ្យប្រពន្ធដឹងអំពីភាពខុសគ្នា) ហើយទុកឱ្យពួកគេសម្រេចអំពីអ្វីដែលត្រូវធ្វើ ។<br>គ. លើកពីបញ្ហានេះជាបន្ទាន់ មកជជែកជាមួយភាគីទាំងពីរ (ដើម្បីឱ្យប្រពន្ធដឹងអំពីភាពខុសគ្នា) ហើយទាមទារឱ្យកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរនោះឆ្លុះបញ្ចាំងនូវការព្រមព្រៀងដែលទាំងអស់គ្នាបានធ្វើឡើង នៅចុងបញ្ចប់នៃកិច្ចប្រជុំសន្ធានកម្ម ។ |
| ៤ | ពីរខែក្រោយពីអ្នកបានសម្រុះសម្រួលដោយជោគជ័យនូវរឿងក្តី វិវាទដីធ្លី ភាគីម្ខាងក៏មកទាក់ទងអ្នក ហើយសួរលោកអ្នកថា តើចាប់អារម្មណ៍ក្នុងការវិនិយោគគម្រោងអភិវឌ្ឍន៍ដីធ្លីបន្ទាប់របស់គាត់ដែរឬទេ ។ | ក. បដិសេធមិនធ្វើការវិនិយោគ ពីព្រោះលោកអ្នកត្រូវរក្សារូបភាពថ្លៃថ្នូររបស់ខ្លួន ។<br>ខ. យល់ព្រមធ្វើការវិនិយោគ ប៉ុន្តែលុះត្រាតែភាគីម្ខាងទៀតយល់ព្រមជាលក្ខណ៍អក្សរថា វាមិនពាក់ព័ន្ធទៅនឹងវិវាទរបស់ពួកគេប៉ុណ្ណោះ ។<br>គ. យល់ព្រមធ្វើការវិនិយោគ ប្រសិនបើអ្នកចង់ ។ មិនមានទំនាស់ផលប្រយោជន៍ជាមួយរឿងក្តីចាស់ទេ ពីព្រោះវាមិនពាក់ព័ន្ធទៅនឹងគម្រោងនេះទេ ។ |

## ឈ. ការផ្តល់អាជ្ញាប័ណ្ណ និងគុណវុឌ្ឍិ

ដូចបានរៀបរាប់ពីខាងលើនេះ សន្ទានកម្មមិនតម្រូវឱ្យមានឯកទេសច្បាប់ទេ។ ប្រភេទជាច្រើននៃសន្ទានកម្មតាមសហគមន៍ អាចធ្វើឡើងដោយសន្ទានការីដែលបានសិក្សាខាងវិស័យច្បាប់។ ប្រទេសមួយចំនួនមិនមានល័ក្ខខ័ណ្ឌតម្រូវក្នុងការចេញអាជ្ញាប័ណ្ណសន្ទានកម្មនោះទេ។ នៅសហរដ្ឋអាមេរិកមិនមានអាជ្ញាប័ណ្ណជាទូទៅនោះទេ ប៉ុន្តែកម្មវិធីសន្ទានកម្មក្នុងស្រុកមួយចំនួនតម្រូវឱ្យមានអាជ្ញាប័ណ្ណ។ ក្រុមហ៊ុនធ្វើសន្ទានកម្មឯកជនជាច្រើន និងកម្មវិធីចំណុះនឹងស្ថាប័នតុលាការមានបទដ្ឋានអប្បបរមា និងល័ក្ខខ័ណ្ឌតម្រូវផ្នែកអប់រំបន្ត។ វិទ្យាស្ថានសន្ទានកម្មអន្តរជាតិ[១៥៣] កំពុងបង្កើតអាជ្ញាប័ណ្ណសម្រុះសម្រួលថ្នាក់អន្តរជាតិជាលើកទីមួយ។[១៥៤] គោលដៅរបស់វាគឺដើម្បីផ្តល់ការធានាគុណភាពខាងសន្ទានកម្មទាំងថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ ជាពិសេសនៅក្នុងតំបន់នានានៅក្នុងពិភពលោកដែលសន្ទានកម្មមិនមានលក្ខណៈទូទៅ។[១៥៥]

នៅប្រទេសកម្ពុជាមិនមានច្បាប់ស្តីពីសន្ទានកម្មនោះទេ ហើយក៏មិនមានអាជ្ញាប័ណ្ណសន្ទានកម្មទូទៅ ឬបទដ្ឋានអប្បបរមាដែរ។ ប៉ុន្តែបុគ្គលដែលធ្វើជាអ្នកសន្ទានការីនៅមជ្ឈមណ្ឌលមជ្ឈត្តការជាតិ ត្រូវតែមានគុណវុឌ្ឍិជាមជ្ឈត្តករស្របច្បាប់ជាមុនសិន។[១៥៦]

---

[១៥៣] វិទ្យាស្ថានសន្ទានកម្មអន្តរជាតិ (IMI) ដែលមានមូលដ្ឋាននៅទីក្រុងឡាអេ ប្រទេសហូល្លង់ ត្រូវបានបង្កើតឡើងដោយសមាគមមជ្ឈត្តការអាមេរិក មជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិប្រទេសសិង្ហបុរី និងវិទ្យាស្ថានសន្ទានកម្មប្រទេសហូល្លង់។ *សូមមើល* វែបសាយត៍របស់ IMI *មាននៅអាសយដ្ឋាន* http://www.imimediation.org/ (ចូលទស្សនាលើកចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨)។

[១៥៤] *ចេញផ្សាយឆាប់ៗខាងមុខនេះ: វិញ្ញាបនកម្មសន្ទានការីអន្តរជាតិ* ទិនានុប្បវត្តិគណៈមេធាវីអាមេរិក ទំព័រ១១ (ខែតុលា ឆ្នាំ២០០៧)។

[១៥៥] *ដូចមុន* ។

[១៥៦] អនុក្រឹត្យរបស់ក្រសួងពាណិជ្ជកម្មស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មមានចែងពីបទដ្ឋាននានានៃគុណវុឌ្ឍិមជ្ឈត្តករនៅមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ។ ជាលទ្ធផលបញ្ញត្តិទាំងនោះក្លាយជាបទដ្ឋានសម្រាប់មជ្ឈត្តករនៃស្ថាប័នដដែលនេះ ។ សូមមើល **អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម** មាត្រា ២៨-៣៨ រាជរដ្ឋាភិបាលកម្ពុជា លេខ ១២៤ (ឆ្នាំ ២០០៩) [ អំពើះតទៅហៅកាត់ថា អនុក្រឹត្យស្តីពី ម.ជ.ម ] ។

## ៣. លំហាត់សន្ធានកម្មគម្រូ

គេអាចបែងចែកអ្នកចូលរួមជាក្រុមដែលមានគ្នាបីនាក់។ ក្រុមនីមួយៗនឹងមានមនុស្សម្នាក់ដើរតួជាសន្ធានការី ហើយពីរនាក់ផ្សេងទៀតដើរតួជាភាគីវិវាទ។

**១.** ភារកិច្ចទីមួយរបស់សន្ធានការីគឺត្រូវណែនាំអំពីដំណើរការ និងវិធាននៃសន្ធានកម្ម។ សន្ធានការីត្រូវធានាថា អ្នកចូលរួមយល់ថា:

- ដំណើរការនេះនឹងត្រូវរក្សាជាការសម្ងាត់
- ដំណើរការនេះផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត
- គ្មាននរណាម្នាក់អាចកាត់មតិរបស់គេបានឡើយ
- សន្ធានការីអាចធ្វើកិច្ចប្រជុំជាក្រុម និងជំនួបជាឯកជន
- ភាគីវិវាទនៅទីនេះដើម្បីដោះស្រាយវិវាទរបស់ខ្លួន

**២.** បន្ទាប់មក សន្ធានការីត្រូវអញ្ជើញភាគីឱ្យនិយាយយ៉ាងសង្ខេបអំពីរឿងរ៉ាវរបស់ពួកគេរៀងខ្លួន។ សន្ធានការីត្រូវស្តាប់យ៉ាងយកចិត្តទុកដាក់ និងព្យាយាមស្វែងយល់អំពីបញ្ហារបស់ភាគី ក៏ដូចជាផលប្រយោជន៍របស់ពួកគេនៅក្នុងវិវាទនោះ។ សន្ធានការីត្រូវរៀបរៀងបញ្ជីផលប្រយោជន៍ និងបញ្ហា ដោយប្រើប្រាស់តារាងផលប្រយោជន៍ និងបញ្ហាដែលមាននៅទំព័របន្ទាប់នេះ។ ភាគីវិវាទត្រូវជួយសន្ធានការីនៅក្នុងដំណើរការនេះ ហើយពន្យល់ប្រាប់គាត់ប្រសិនបើសន្ធានការីនោះសរសេរខុស ភ្លេច ឬបកស្រាយមិនបានត្រឹមត្រូវលើចំនុចណាមួយ។

**៣.** ក្រោយពេលសន្ធានការីមានបញ្ជីបញ្ហាហើយ គាត់ត្រូវដឹកនាំការពិភាក្សាជាបន្តបន្ទាប់អំពីបញ្ហាជាក់លាក់នីមួយៗជាមួយភាគីវិវាទ។ សន្ធានការីលើឡើងអំពីបញ្ហានីមួយៗ ហើយព្យាយាមបកស្រាយបញ្ហានោះតាមរបៀបមួយដែលវិជ្ជមាន។ ភាគីវិវាទនឹងចូលរួមនៅក្នុងការពិភាក្សានោះ ដែលមានទិសដៅទៅរកគ្នាទៅវិញទៅមក ស្របពេលដែលសន្ធានការីជួយសម្របសម្រួលដល់ដំណើរការនោះ ដោយធានាថាគេអាចគ្រប់គ្រងបាននូវអារម្មណ៍រំជួលនានា ហើយបញ្ហាផ្សេងៗត្រូវបានបកស្រាយដោយគំនិតវិជ្ជមាន។ គោលបំណងនៃការពិភាក្សាអំពីបញ្ហាទាំងនេះ គឺដើម្បីធានាថាភាគីទាំងពីរយល់អំពីបញ្ហាទាំងអស់។

**៤.** បន្ទាប់មកទៀត ក្រោយពេលដែលភាគីមានឱកាសក្នុងការពន្យល់អំពីទស្សនៈយល់ឃើញរបស់ពួកខ្លួន ចំពោះបញ្ហាទាំងអស់រួច សន្ធានការីត្រូវដឹកនាំកិច្ចប្រជុំដំណោះស្រាយបញ្ហាដោយកិច្ចសហការ។ វាអាចមានទម្រង់ជាការរិះរកគំនិតថ្មីៗ (brainstorming) ឬវិធីបង្កើតជម្រើសផ្សេងទៀត។ គោលដៅរបស់វាគឺដើម្បីបង្កើតជម្រើស ដែលបំពេញឱ្យផលប្រយោជន៍របស់ភាគីវិវាទ។ សន្ធានការីត្រូវធ្វើការដោះស្រាយបញ្ហា ដោយដើរតួនាទីលើកទឹកចិត្ត និងបកស្រាយឡើងវិញនូវពាក្យពេចន៍ទាំងឡាយណាដែលមិនអំណោយផល ប្រសិនបើសមស្រប។

**៥.** ប្រសិនបើវិវាទត្រូវបានដោះស្រាយរួច ភាគីវិវាទត្រូវសរសេរល័ក្ខខ័ណ្ឌជាមូលដ្ឋាននៃកិច្ចព្រមព្រៀង ដោយប្រើ-ប្រាស់តារាងដំណោះស្រាយដែលបានផ្តល់ជូន។

## លំហាត់ ៖ រឿងក្តីសន្ធានកម្មទី១៖ របងរលំ

កាលពីមួយសប្តាហ៍មុន រ៉េមី និងមិត្តភក្តិរបស់គាត់មួយចំនួនបានដើរត្រលប់មកផ្ទះគាត់វិញ បន្ទាប់ពីចំណាយពេលមួយយប់ពេញនៅរង្គសាលខារ៉ាអូខេ ហើយពួកគេឆ្លងកាត់តាមទីធ្លាផ្ទះរបស់លោករតនៈ។ ពួកគេបានលោតរំលងរបងឈើរបស់លោករតនៈ។ រ៉េមីបានធ្វើឱ្យបាក់របងដោយចៃដន្យអស់ប្រហែលបីម៉ែត្រ នៅពេលកាត់លើកជើងរំលងរបងនោះ។ លោករតនៈពេលនោះកំពុងអង្គុយនៅលើរានហាល ហើយបានមើលឃើញព្រឹត្តិការណ៍ដែលបានកើតឡើងនោះ។ គាត់រត់ទៅចាប់បានរ៉េមី ប៉ុន្តែអ្នកផ្សេងទៀតរត់អស់។ លោករតនៈទាមទារឱ្យរ៉េមីសងប្រាក់ថ្លៃជួសជុលវា។ រ៉េមីនិយាយថាគាត់នឹងសង ហើយពួកគេក៏ឱ្យលេខទូរស័ព្ទគ្នាទៅវិញទៅមក។

នៅថ្ងៃបន្ទាប់លោក រតនៈក៏បានទូរស័ព្ទទៅប្រាប់រ៉េមីថាអំពីតម្លៃប៉ាន់ប្រមាណ គឺប្រហែលជា៣០០ដុល្លា តែរ៉េមីឆ្លើយថាគាត់គ្មានប្រាក់ទេ ហើយគិតថាវាជាចំនួនដ៏"ហួសហេតុ"មួយ។ លោករតនៈ និយាយថាគាត់នឹងប្តឹងរ៉េមីទៅតុលាការ ប្រសិនបើមិនសង ប៉ុន្តែ យល់ព្រមព្យាយាមធ្វើសន្ធានកម្មជាមុនសិន។

រ៉េមីមានការព្រួយបារម្ភ ពីព្រោះគាត់មានបញ្ហារួចទៅហើយដោយសារតែការផឹកស៊ីរបស់ខ្លួនពីមុនមក។ គាត់ចង់ជៀសឱ្យឆ្ងាយពីបញ្ហានេះ ប៉ុន្តែគាត់មិនមានប្រាក់៣០០ ដុល្លាទេ។ រ៉េមីក៏សង្ស័យផងដែរថា លោករតនៈបានបំប៉ោងតម្លៃដើម្បីដាក់ទណ្ឌកម្មចំពោះគាត់។ លោករតនៈមិនសប្បាយចិត្តសោះឡើយ ពីព្រោះក្មេងៗតែរត់ឆ្លងកាត់តាមទីធ្លារបស់គាត់រាល់លើក ដែលធ្វើឱ្យរុក្ខជាតិ និងផ្ការបស់គាត់ត្រូវរងាប់។ លោករតនៈ យល់ឃើញថារ៉េមីមានសំណាងហើយ ពីព្រោះគាត់មិនបានហៅនគរបាលឱ្យចាប់ខ្លួន។

## លំហាត់ ~ រឿងក្តីសន្ធានកម្មទី២៖ ការប្រកែកគ្នាអំពីកិច្ចការរដ្ឋបាល

សាកលវិទ្យាធិការមហាវិទ្យាល័យនីតិសាស្ត្រអាស៊ីអាគ្នេយ៍នៅរាជធានីភ្នំពេញ (SALS) ត្រូវបានអញ្ជើញឱ្យធ្វើសន្ធានកម្មលើវិវាទមួយរវាងនិយោជិតពីរនាក់របស់ខ្លួន គឺនាយករដ្ឋបាល និងនិយោជិតថ្មីម្នាក់។ នាយករដ្ឋបាលនោះឈ្មោះសុភារី ហើយបានធ្វើការនៅ SALS អស់រយៈពេលជាងដប់ឆ្នាំមកហើយ ហើយទទួលខុសត្រូវក្នុងការគ្រប់គ្រងបុគ្គលិកចំនួនដប់នាក់។ ហៃ ធ្វើការឱ្យសុភារី ហើយទើបតែធ្វើការនៅ SALS បានប្រាំមួយខែតែប៉ុណ្ណោះ។ កាលពីពេលថ្មីៗនេះ ហៃបានស្នើសុំផ្លាស់ប្តូរកាលវិភាគការងារ ដើម្បីចេញយឺតនៅថ្ងៃច័ន្ទ និងថ្ងៃអង្គារ ហើយមកធ្វើការយឺតនៅរៀងរាល់ព្រឹកថ្ងៃ ព្រហស្បតិ៍។ សុផារី បដិសេធសម្នើនេះ។ ហៃ ក៏ស្វែងរកសន្ធានកម្មពីសាកលវិទ្យាធិការ។

នៅក្នុងកន្លែងធ្វើការមុនរបស់ហៃ គាត់បានផ្តល់គំនិតជាច្រើននៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងមានម៉ោងធ្វើការដែលអាចបត់បែនបាន។ ប៉ុន្តែ គាត់យល់ឃើញថានៅក្នុងការងារនេះ សុភារីមិនទាំងស្តាប់គំនិតរបស់គាត់ផង។ ហៃស្នើផ្លាស់ប្តូរកាលវិភាគ ពីព្រោះ៖

១. គាត់ចង់ទៅរៀនគួរពិសេសភាសាបារាំងនៅថ្ងៃព្រហស្បតិ៍ព្រឹក។

២. ថ្ងៃច័ន្ទ និងថ្ងៃអង្គារ ជាថ្ងៃដែលមមាញឹកបំផុត និង

៣. និស្សិតអាចពេញចិត្ត បើមានម៉ោងណាត់ជួបនៅការិយាល័យកាន់តែយូរ។

ប៉ុន្តែគាត់យល់ឃើញថាគាត់មិនទាំងមានឱកាសផ្តល់មូលហេតុសម្រាប់ការផ្លាស់ប្តូរម៉ោងនេះផង។ សុភារីហាក់ដូចជាដាច់ណាត់ជាមួយគាត់ពេក ដោយនិយាយភ្លាមៗថាវាមិនអាចទៅរួចទេ ទើបធ្វើឱ្យហៃស្ទាក់ស្ទើរក្នុងការលើកមកនិយាយម្តងទៀត។

សុភារី ត្រូវបានគេចាត់ទុកថាជានាយកដែលម៉ឺងម៉ាត់ និងគួរឱ្យគោរព។ នាងយល់ឃើញថាបុគ្គលិកអាចធ្វើសំណូមពរបាន ប៉ុន្តែនៅពេលដែលមានការសម្រេចចិត្តរួចហើយ គេត្រូវតែគោរពតាមនោះ។ សុភារី គិតថាហៃជាមនុស្សចម្លែកបន្តិច ហើយជឿថាជួនកាលសម្នើរបស់ហៃដូចជាមានភាពឆ្កួតឡប់។ គាត់មិនជំទាស់នឹងការផ្លាស់ប្តូរទេ ដរាបណាវាមានការគិតពិចារណាបានល្អិតល្អន់ និងមានហេតុផលសមស្រប។ គាត់មានអារម្មណ៍តានតឹងយ៉ាងខ្លាំងនាពេលថ្មីៗនេះពីព្រោះការងារមានភាពមមាញឹកយ៉ាងខ្លាំង ហើយគាត់មិនមានពេលគ្រប់គ្រាន់នៅជាមួយគ្រួសារ។ គាត់ដឹងថា ជួនកាលគាត់ឆាប់ខឹងសម្បារនឹងអ្នកដទៃដែរ។ គាត់មានការសង្ស័យខ្លះអំពីសន្ធានកម្មនេះ ហើយខ្លាចថាវានឹងប៉ះពាល់ដល់អំណាចរបស់គាត់ជានាយក។ តើវានឹងទៅជាយ៉ាងណា ប្រសិនបើមនុស្សគ្រប់គ្នាមានប្រតិកម្មចំពោះរាល់ការសម្រេចចិត្តរបស់គាត់បែបនេះ ហើយអ្វីៗត្រូវតែឆ្លងកាត់សន្ធានកម្មបែបនេះ ? គាត់មិនអាចគ្រប់គ្រងដេប៉ាតឺម៉ង់របស់គាត់បានទេ។ ហើយជាងនេះទៅទៀត ការរៀនគួរភាសារបារាំងគ្មានអ្វីសំខាន់ជាងកិច្ចការរបស់ហៃនៅសាលាឡើយ។

## លំហាត់ ៖ រឿងក្តីសន្ធានកម្មទី៣៖ ការប្រកែកគ្នាអំពីគម្រោងរួម

និយោជិតជានិស្សិតទើបបញ្ចប់ការសិក្សាពីររូបនៅសាកលវិទ្យាល័យវិទ្យាសាស្ត្រកម្ពុជា ឥឡូវនេះកំពុងតែគេចមុខពីគ្នា បន្ទាប់ពីមានការប៉ះសម្តីគ្នាយ៉ាងក្តៅគគុកប្រហែលមួយសប្តាហ៍កន្លងទៅនេះ។ ទំនួលខុសត្រូវរបស់ពួកគេនៅក្នុងដេប៉ាតឺម៉ង់នេះ គឺតម្រូវឱ្យពួកគេធ្វើការជាមួយគ្នាលើគម្រោងនានា ហើយពួកគេធ្វើការជាមួយគ្នាបានយ៉ាងល្អរហូតមកទល់ពេលថ្មីៗកន្លងទៅនេះ។ វិវាទរបស់ពួកគេពាក់ព័ន្ធនឹងថាតើអ្នកណាជាអ្នកទទួលបានគុណសម្បត្តិសម្រាប់ការងារដែលធ្វើជាក្រុម។ ថាវីរីមានអារម្មណ៍ថា វី ដែលជាមិត្តរួមការងាររបស់នាង យកគុណសម្បត្តិច្រើនពេកសម្រាប់ការងារដែលនាងបានបំពេញ ។ វី មានអារម្មណ៍ថា ជំហររបស់ថាវីរីគឺជាការវាយប្រហារដោយអយុត្តិធម៌មកលើរូបខ្លួន ហើយក៏ជៀសវាងការទំនាក់ទំនងជាមួយថាវីរីតាំងពីពេលនោះមក។

ថាវីរីមានការព្រួយបារម្ភអំពីទំនាក់ទំនងការងាររបស់នាងជាមួយ វី។ នៅក្នុងគម្រោងដែលត្រូវធ្វើរួមគ្នាចំនួនបួនចុងក្រោយ នាងមានអារម្មណ៍ថា វី យកគុណសម្បត្តិចំពោះគំនិតដែលជារបស់នាង។ នៅក្នុងកំឡុងពេលធ្វើរបាយការណ៍ជូនគណៈកម្មាធិការមហាវិទ្យាល័យ ជាញឹកញាប់ ថាវីរីតែងតែឮ វីបង្ហាញលទ្ធផលនៃគម្រោងរបស់ពួកគេ ដោយមិនបានបញ្ជាក់ពីការចូលរួមរបស់នាងឡើយ។ នាងជឿផងដែរថា គាត់ប្រើពាក្យ "ខ្ញុំ" ជាជាងពាក្យថា "យើង"។ ដោយសារមូលហេតុមួយចំនួន វី តែងតែត្រូវបានលោកនាយកស្នើ ឱ្យធ្វើរបាយការណ៍អំពីលទ្ធផលជូនគណៈកម្មាធិការមហាវិទ្យាល័យជានិច្ច។

ថាវីរីមានការតូចចិត្ត នៅពេលចុងក្រោយដែលនាងស្តាប់ឮបទបង្ហាញរបស់ វី។ នាងក៏ជួបតទល់ជាមួយគាត់នៅឯមន្ទីរពិសោធន៍ ប៉ុន្តែគាត់បានស្រែកដាក់នាង ហើយគេចពីនាងតាំងពីពេលនោះមក។ ថាវីរី និង វី ជាមិត្តចាស់នឹងគ្នាមកពីខេត្តកំពត ហើយអ្នកទាំងពីរនៅតែចង់ធ្វើជាមិត្តនឹងគ្នា។ ថាវីរីមានការព្រួយបារម្ភអំពីការឡើងតំណែងរបស់នាងនៅឯសាកលវិទ្យាល័យ ហើយមានអារម្មណ៍ថានាងមិនអាចជឿជាក់លើ វី បានឡើយ។

វី មានការតូចចិត្តយ៉ាងខ្លាំងដែលថាវីរីតវ៉ាដល់លោកនាយករបស់ពួកគេថា គាត់បង្ហាញការងាររួមរបស់ពួកគេខុសពីការពិត។ នាងដឹងថាឈ្មោះរបស់នាងមាននៅលើគ្រប់របាយការណ៍ទាំងអស់។ គាត់ក៏មានអារម្មណ៍ដែរថា នៅក្នុងកំឡុងពេលធ្វើគម្រោងរួមគ្នា គំនិតដែលលេចឡើង នឹងក្លាយជាគំនិត។ ទំនួលខុសត្រូវក្នុងការបង្ហាញគម្រោងដែលបានបញ្ចប់ តែងតែធ្លាក់មកលើរូបគាត់ជានិច្ច។ ដោយសារការបង្ហាញទាំងនេះមានការលំបាក ហើយទាមទារឱ្យធ្វើការងារបន្ថែមទៀតនោះ ហេតុអ្វីបានជានាងត្រូវភ្ញាក់ផ្អើល នៅពេលអ្នកផ្សេងផ្តល់គុណសម្បត្តិដល់គាត់?

គាត់មានអារម្មណ៍ថា ថាវីរីតឹងរឹងចំពោះខ្លួនខ្លាំងពេក ហើយដោយសារតែ វី ស្អប់ជម្លោះ គាត់ក៏សម្រេចចិត្តឈប់ទាក់ទងជាមួយនាងតាំងពីពេលនោះមក។ ប៉ុន្តែគាត់ដឹងថា ថាវីរី ជាមនុស្សឆ្លាតណាស់ ហើយពួកគេជាក្រុមដ៏ល្អនៅឯការិយាល័យ។ គាត់មានការព្រួយបារម្ភថាការឈ្លោះគ្នានេះធ្វើឱ្យសាកលវិទ្យាល័យយល់ថា គាត់ជាមនុស្សអាក្រក់ ហើយយល់ឃើញថានាងត្រូវសុំទោសគាត់ចំពោះការដែលធ្វើឱ្យរឿងនេះឱ្យទៅជាបញ្ហាមួយដែលធំ។

## លំហាត់ ៤ រឿងក្ដីសន្ធានកម្មទី៤៖ តារាភាពយន្ត

ឡេង ចិន្ដា គឺជាតារាភាពយន្ដវ័យក្មេងដ៏ស្រស់ស្អាតម្នាក់។ កាលពីប៉ុន្មានឆ្នាំកន្លងទៅនេះ នាងបានបញ្ចប់ការសិក្សាពីមហាវិទ្យាល័យនាដ្តសាស្ដ្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ១ភ្រភច ហើយចាប់ផ្ដើមអាជីពជាអ្នកសម្ដែងនៅរាជធានីភ្នំពេញ។ នាងដើរតួរាយរងនៅក្នុងភាពយន្ដខ្នាតតូចពីរបីរឿង បន្ទាប់មកក៏ចាប់ឱកាសដ៏ធំមួយ នៅពេលនាងជួបនឹងលោក ឡាយ យ៉ែម នៅក្នុងពិធីជប់លៀងមួយ។ លោក យ៉ែម គឺជាផលិតករ និងអ្នកដឹកនាំរឿងដ៏ល្បី ឈ្មោះមួយរូបនៅប្រទេសកម្ពុជា។ គាត់យល់ព្រមឱ្យនាងសាកល្បងសម្ដែងជាតួរងមួយ នៅក្នុងខ្សែភាពយន្ដមួយដែលមានចំណងជើងថា "គ្រួសារឡប់ៗរបស់ខ្ញុំ"។ អ្នកដឹកនាំរឿងនោះក៏បានអនុញ្ញាតិឱ្យនាងចេញសម្ដែង។ រឿងនេះទទួលបានជោគជ័យយ៉ាងធំធេង ហើយទស្សនិកជនក៏បានស្រឡាញ់ចូលចិត្ដនាង។

កាលពីខែមុន លោកយ៉ែមប្រកាសថា គាត់នឹងផលិតរឿងធំបំផុតនៅក្នុងប្រវត្ដិសាស្ដ្រភាពយន្ដកម្ពុជា។ រឿងនោះមានចំណងជើងថា " ព្រះមហាវីរៈក្សត្រ ព្រះបាទជ័យវរ្ម័នទី៧"។ គាត់នឹងចំណាយប្រាក់ប្រហែលជាជាង ដប់លានដុល្លា ដើម្បីថតរឿងនេះ ហើយបានស្នើបញ្ចាំងរឿងនេះនៅមហោស្រពភាពយន្ដកាននៅប្រទេសបារាំង នាពេលក្រោយ នៅក្នុងឆ្នាំនេះ។ ក្រុមហ៊ុនចែកចាយខ្សែភាពយន្ដអាមេរិកក៏បានបង្ហាញចំណាប់អារម្មណ៍ចំពោះរឿងនេះដែរ។

ពីរ-បីថ្ងៃក្រោយពេលប្រកាស លោក យ៉ែម ក៏ទូរស័ព្ទទៅអ្នកនាងចិន្ដា ហើយប្រាប់នាងឱ្យមកកាន់ការិយាល័យរបស់គាត់។ គាត់ប្រាប់ថាគាត់ចង់ឱ្យនាងរួមសម្ដែងជាតួមហេសីរបស់ព្រះមហាវីរៈក្សត្រនោះ។ តួនេះនឹងធ្វើឱ្យនាងក្លាយជាតារា ភាពយន្ដដ៏ល្បីបំផុតនៅប្រទេសកម្ពុជា។ នាងថែមទាំងអាចក្លាយជាតួល្បីនៅអឺរ៉ុប និងអាមេរិកទៀតផង។ គាត់សួរទៅចិន្ដាថា តើនាងមានប្រវត្ដិអ្វីដែលគួឱ្យអាម៉ាស ឬមានបញ្ហាចម្រូងចម្រាសពីអតីតកាលដែរឬទេ។ នាងឆ្លើយថាគ្មានទេ។ គាត់ក៏ផ្ដល់ប្រាក់ដល់នាង មួយលានដុល្លាសម្រាប់ការសម្ដែងនេះ។ កិច្ចការនេះត្រូវរួមបញ្ចូលទាំងកាតព្វកិច្ចឃោសនាផ្សព្វផ្សាយ និងអាចមានដំណើរជុំវិញពិភពលោកផងដែរ។ នាងយល់ព្រម ហើយបានចុះហត្ថលេខាលើកិច្ចសន្យាមួយ នាថ្ងៃនោះតែម្ដង។ ដំណឹងនេះបានផ្សព្វផ្សាយដល់សាធារណជន នៅថ្ងៃបន្ទាប់ ។

ប៉ុន្មានសប្ដាហ៍ក្រោយមកលោក សុង ម៉ារ៉ា ជានាយកដឹកនាំការសម្ដែង បានមកលេងចិន្ដា ហើយបង្ហាញនាងនូវលិខិតមួយច្បាប់ដែលគាត់ទទួលបានពីប្រភពអនាមិកមួយដែលបញ្ជាក់ថា ចិន្ដាមិនមានដើមកំណើតជាជនជាតិខ្មែរទេ គឺជាវៀតណាមច្រើនជាង។ នាងអះអាងថាមែន ប៉ុន្ដែមិនយល់ថាហេតុអ្វីបានជាសំខាន់នោះទេ ។ លោក ម៉ារ៉ា ពន្យល់ថាលោកយ៉ែមមិនសប្បាយចិត្ដទាល់តែសោះអំពីបញ្ហានេះ។ ពួកគេមិនអាចអនុញ្ញាតឱ្យតារាភាពយន្ដដើមកំណើតវៀតណាមមកសម្ដែងជាតួមហេសីព្រះបាទជ័យវរ្ម័នបាននោះទេ។ គាត់និយាយថា វាអាចបង្ករភាពចម្រូងចម្រាសយ៉ាងខ្លាំងនៅក្នុងប្រទេសកម្ពុជា។ លោកយ៉ែម ក៏មានការអន់ចិត្ដផងដែរដែលចិន្ដាមិនបាននិយាយប្រាប់គាត់អំពីបញ្ហានេះ នៅពេលគាត់សួរនាងថាតើមានបញ្ហាអ្វីគួរឱ្យអាម៉ាស ឬមានបញ្ហាចម្រូងចម្រាសអំពីនាងដែរឬទេ។ លោក យ៉ែម បានបង្គាប់ឱ្យលោក ម៉ារ៉ា បញ្ឈប់កិច្ចសន្យាជាមួយចិន្ដា។

ចិន្ដា មានការអន់ចិត្ដយ៉ាងខ្លាំង ។ ឥឡូវនេះ អាជីពទាំងមូលរបស់នាងកំពុងធ្លាក់ក្នុងភាពអន្ដរាយ។ នាងយល់ឃើញថាវាមិនមានបញ្ហាអ្វីនោះទេ បើនាងជាជនជាតិវៀតណាម ឬខ្មែរនោះ។ នាងអាចសម្ដែងតួនេះ ហើយបានល្អទៀតផង។ នាងចង់សម្ដែងតួនោះ ប៉ុន្ដែយ៉ាងហោចណាស់ក៏នាងចង់ល្បីល្បាញដែរ ហើយយល់ឃើញថានាងស័ក្ដិសមនឹងទទួលបានអ្វីៗល្អជាងនេះ។ ប៉ុន្ដែនាងមិនចង់មានឈ្មោះល្បីថាជាមនុស្សដែលពិបាកធ្វើការជាមួយនោះដែរ។ ដូច្នេះ នាងក៏ស្នើសុំ

ធ្វើសន្ទានកម្មលើបញ្ហានេះជាឯកជន។

លោក យ៉ែម មិនអាចប្រថុយឱ្យអ្នកដែលមានប្រវត្តិចម្រូងចម្រាស់បែបនេះមកសម្តែងឡើយ ដោយនាងអាចធ្វើឱ្យគម្រោងទាំងមូលបរាជ័យបាន។ នៅពេលគាត់រើសយកនាង គាត់មិនបានដឹងថានាងជាជនជាតិវៀតណាមឡើយ។ គាត់យល់ថានាងគួរតែបានប្រាប់គាត់ពីបញ្ហានេះ។ លោកយ៉ែម ចង់ជៀសវាងឱ្យបាន នូវភាពចម្រូសចម្រាស់ជាសាធារណៈ ហើយត្រូវការដោះស្រាយរឿងនេះឱ្យបានឆាប់រហ័ស ដើម្បីខ្លួនអាចចាប់ផ្តើមផលិតកុននេះបាន។ ផលិតកររឿងនេះមិនទាន់តែងតាំងតួឯកថ្មីទេ ហើយការបញ្ឈប់កិច្ចសន្យាជាមួយចិន្តាក៏មិនទាន់ត្រូវបានផ្សព្វផ្សាយជាសាធារណៈដែរ។

## ១. ធំព័រកិច្ចការៈ ផលប្រយោជន៍ និងបញ្ហា

| | ភាគី "ក" | ភាគី "ខ" |
|---|---|---|
| ផលប្រយោជន៍ | | |
| បញ្ហា | | |

## ២- ទំព័រកិច្ចការៈ ដំណោះស្រាយចេញពីសន្ធានកម្ម

| បញ្ហា | ល័ក្ខខ័ណ្ឌដោះស្រាយ |
| --- | --- |
| | |

# ជំពូកទី៤: មជ្ឈត្តការ




**ចេះច្បាប់មិនខ្លាចក្តី ចេះវិន័យមិនខ្លាចសង្ឃ។**

## ក. តើមជ្ឈត្តការគឺជាអ្វី?

មជ្ឈត្តការគឺជាវិធីសាស្ត្រដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (ADR) ចម្បងទីបី។ នៅក្នុងមជ្ឈត្តការ គូភាគីដាក់វិវាទរបស់ខ្លួនជូនទៅភាគីទីបីដែលអព្យាក្រឹតមួយ (ដែលជាទូទៅហៅថា "មជ្ឈត្តករ" ឬ ប្រសិនបើច្រើនជាងម្នាក់ហៅថា "ក្រុមមជ្ឈត្តករ" ឬ "វេទិកាមជ្ឈត្តកម្ម")។ ភាគីទីបីនេះពិចារណាអំពីភស្តុតាងដែលភាគីវិវាទបានដាក់ជូន និងចេញសេចក្តីសម្រេចមួយ ហៅថា "មជ្ឈត្តវិនិច្ឆ័យ"។ ដូចដែលនឹងលើកយកមកពិភាក្សានៅក្នុងអត្ថបទខាងក្រោមនេះ មជ្ឈត្តវិនិច្ឆ័យ ជាទូទៅ គឺមានភ្ជាប់កាតព្វកិច្ចចំពោះគូភាគីទាំងអស់ យ៉ាងណាមិញក្នុងករណីខ្លះ មជ្ឈត្តវិនិច្ឆ័យក៏អាចមិនភ្ជាប់កាតព្វកិច្ចចំពោះគូភាគីដែរ។

### ១. *ប្រវត្តិនៃមជ្ឈត្តការ*

មជ្ឈត្តការមានប្រវត្តិដ៏យូរលង់ណាស់មកហើយ។ មជ្ឈត្តការ ត្រូវបានលើកឡើងមកនិយាយនៅក្នុងអក្សរចំណាររបស់ក្រិចសម័យបុរាណ និងនៅក្នុងព្រះគម្ពីរប៊ីប្លីរបស់សាសនាគ្រិស្ត។[១៥៧] មជ្ឈត្តការផ្នែកពាណិជ្ជកម្មទំនើបត្រូវបានបង្កើតឡើងជាលើកដំបូងនៅទ្វីបអឺរ៉ុបក្នុងយុគមជ្ឈិមសម័យ។[១៥៨] ជាញឹកញាប់ ពាណិជ្ជករធ្វើដំណើរក្នុងចម្ងាយដ៏ឆ្ងាយដើម្បីទៅធ្វើជំនួញនៅកន្លែងដែលពួកគេទិញ និងលក់ទំនិញ ព្រមទាំងសេវាកម្មផ្សេងៗ។ ដោយហេតុថាការធ្វើដំណើរមាន

---

[១៥៧] STEVEN C. BENNETT, **មជ្ឈត្តការឧសុវនាធានសំខាន់ៗ** ទំព័រ៩ (ALM ed., ឆ្នាំ២០០២)។

[១៥៨] Sarah Rudolph Cole and Kristen M. Blankley *មជ្ឈត្តការ,* **សៀវភៅណែនាំអំពីការដោះស្រាយវិវាទ** ទំព័រទី ៣១៨, ៣២០ (Moffitt and Bordone, ed., ឆ្នាំ២០០៥)។

គ្រោះថ្នាក់ច្រើន និងមានតម្លៃថ្លៃ វិវាទនានាត្រូវដោះស្រាយឱ្យបានឆាប់រហ័ស និងនៅជិតទីកន្លែងធ្វើជំនួញនោះ ។ យ៉ាងណាមិញ នៅពេលនោះតុលាការអចិន្ត្រៃយ៍មិនអាចដោះស្រាយវិវាទទាំងនោះឱ្យបានឆាប់រហ័សឡើយ និងគ្មានចំណេះដឹងអំពីបទដ្ឋានឧស្សាហកម្មរបស់អ្នកជំនួញឡើយ។ នេះគឺជាចំណុចសំខាន់ ដោយសារបទដ្ឋានឧស្សាហកម្មទាំងនេះត្រូវបានបង្កើតឡើង ដើម្បីជួយសម្រួលទំនាក់ទំនងពាណិជ្ជកម្ម ក្នុងចំណោមគូភាគីដែលមកពីប្រទេស និងវប្បធម៌ផ្សេងៗគ្នា។ ដោយសមត្ថកិច្ចរបស់តុលាការនៅមានកម្រិត ពាណិជ្ជករបានបង្កើតវេទិកាធ្វើមជ្ឈត្តការជាឯកជន ដែលអាចដោះស្រាយវិវាទប្រកបដោយប្រសិទ្ធភាព ហើយដែលជាញឹកញាប់តែងប្រើប្រាស់អ្នកជំនាញឧស្សាហកម្ម និងបទដ្ឋានឧស្សាហកម្មផងដែរ។[១៥៩]

នៅពេលដែលនិគមជនអង់គ្លេសផ្លាស់ទីលំនៅទៅទ្វីបអាមេរិកនៅកំឡុងសតវត្សរ៍ទី១៧ និងទី១៨ ពួកគេបាននាំមកជាមួយខ្លួននូវបែបផែនមជ្ឈត្តការទាំងនេះផង។ ជាលទ្ធផល មជ្ឈត្តការបានដើរតួនាទីសំខាន់នៅក្នុងដំណោះស្រាយវិវាទផ្នែកពាណិជ្ជកម្មនៅក្នុងទឹកដីអាណានិគមអង់គ្លេសក្នុងទ្វីបអាមេរិក។[១៦០] ក្នុងឆ្នាំ១៧៦៨ ស្ថាប័នមជ្ឈត្តការអចិន្ត្រៃយ៍ដំបូងបង្អស់ ត្រូវបានបង្កើតឡើងដោយសភាពាណិជ្ជកម្មក្រុងញូវយ៉ក។[១៦១] គេថែមទាំងបានរាយការណ៍ថា ប្រធានាធិបតីទីមួយរបស់អាមេរិក គឺលោក ចច វ៉ាស៊ីងតុន (George Washington) បានបញ្ចូលខចែងស្តីពីមជ្ឈត្តការនៅក្នុងមរតកសាស្ត្ររបស់គាត់ទៀតផង ដើម្បីគ្រប់គ្រងវិវាទក្នុងចំណោមអត្ថគាហកទាំងឡាយ។[១៦២] ទោះជាយ៉ាងនោះក្តី នៅសម័យនោះ តុលាការនៅក្នុងសហរដ្ឋអាមេរិក ក៏ដូចជាក្នុងបណ្តាប្រទេសមួយចំនួនទៀត មិនអាចអនុវត្តមជ្ឈត្តវិនិច្ឆ័យបានឡើយ ដោយចាប់ពីពេល នោះមក ទើបគេរក្សាការធ្វើមជ្ឈត្តការនេះឱ្យស្ថិតនៅខាងក្រៅប្រព័ន្ធតុលាការជាផ្លូវការ។

នៅសតវត្សរ៍ទី២០ ដោយហេតុថាសំណុំរឿងក្តីដែលត្រូវធ្វើការដោះស្រាយចាប់ផ្តើមកើនឡើង តុលាការនៃប្រទេសជាច្រើនបានចាប់ផ្តើមទទួលយកមជ្ឈត្តការ ថាជាវិធីសាស្ត្រស្របច្បាប់មួយក្នុងដំណោះស្រាយវិវាទ។ នៅក្នុងសហរដ្ឋអាមេរិក ច្បាប់ស្តីពីមជ្ឈត្តការរដ្ឋសហព័ន្ធឆ្នាំ១៩២៥ (FAA) បានផ្តល់សុពលភាពដល់ខចែងស្តីពីមជ្ឈត្តការនៅក្នុងកិច្ចសន្យាពាណិជ្ជកម្មឱ្យធ្វើការអនុវត្តបាន។[១៦៣] ប្រទេសផ្សេងៗបានអនុវត្តតាមយ៉ាងឆាប់រហ័ស ដែលនាំឱ្យវេទិកាធ្វើមជ្ឈត្តការមានការកើនឡើងយ៉ាងឆាប់រហ័សនៅពាសពេញពិភពលោកទាំងមូល។[១៦៤] ក្នុងឆ្នាំ១៩២៣ សភាពាណិជ្ជកម្មអន្តរជាតិទីក្រុងប៉ារីស (ICC) បានបង្កើតតុលាការមជ្ឈត្តការអន្តរជាតិ ដែលបានក្លាយជាវេទិកាធ្វើមជ្ឈត្តការដែល

---

[១៥៩] *ដូចមុន។*

[១៦០] ក្រុងបូស្តុនក៏ដូចជាសហគមន៍អាណានិគមអាមេរិកជាច្រើនដែរ បានអនុម័តច្បាប់ដែលលើកទឹកចិត្តឱ្យមានមជ្ឈត្តការ ។ Patterson et al., កំណត់សម្គាល់ *ខាងលើ* លេខ៩, ទំព័រ១១៨។

[១៦១] Bennett, កំណត់សម្គាល់ *ខាងលើ* លេខ១៥៧, ទំព័រទី ៩។

[១៦២] Patterson et al., កំណត់សម្គាល់ *ខាងលើ* លេខ៩, ទំព័រ១១៨។

[១៦៣] *សូមមើល* **ច្បាប់ស្តីពីមជ្ឈត្តការរដ្ឋសហព័ន្ធ** 9 U.S.C. § 1 – 307 (1970)។

[១៦៤] បច្ចុប្បន្ននេះ សាជីវកម្មអន្តរជាតិជាច្រើននិយមធ្វើមជ្ឈត្តការអន្តរជាតិជាងទម្រង់ទាំងអស់ផ្សេងទៀតនៃការដោះស្រាយវិវាទ ។ *សូមមើល ឧទាហរណ៍* Dr. Loukas Mistelis *មជ្ឈត្តការអន្តរជាតិ-ឥរិយាបថ និងទម្លាប់អនុវត្តន៍សាជីវកម្ម-ការធ្វើតេស្តលើការដឹងដោយវិញ្ញាណទាំង ១២: របាយការណ៍ស្រាវជ្រាវរឿងព្រេងកថា ទិន្នន័យ និងការវិភាគ,* **ព្រឹត្តិបត្រអាមេរិកស្តីពីមជ្ឈត្តការអន្តរជាតិ** ទំព័រទី ៥២៥, ៥៣៨ (ឆ្នាំ២០០៤)។

ល្បីល្បាញបំផុតមួយនៅក្នុងពិភពលោក។[១៦៥] វេទិកាធ្វើមជ្ឈត្តការសំខាន់ផ្សេងៗទៀត រួមមាន សមាគមមជ្ឈត្តការអាមេរិកទីក្រុងញូវយ៉ក[១៦៦] និងតុលាការមជ្ឈត្តការអន្តរជាតិទីក្រុងឡុងដ៍។[១៦៧] នៅទសវត្សរ៍កន្លងទៅនេះ កំណើនសេដ្ឋកិច្ចនៅអាស៊ី បាននាំឱ្យមានការកើនឡើងដ៏គួរឱ្យកត់សម្គាល់នៃវេទិកាធ្វើមជ្ឈត្តការនៅអាស៊ី។ បច្ចុប្បន្ននេះ វេទិកានៅអាស៊ីដ៏ធំបំផុត ចំនួនបីរួមមាន គណៈកម្មការមជ្ឈត្តការផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្មអន្តរជាតិប្រទេសចិន (CIETAC)[១៦៨] មជ្ឈមណ្ឌល មជ្ឈត្តការអន្តរជាតិទីក្រុងហុងកុង (HKIAC)[១៦៩] និងមជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិសិង្ហបុរី (SIAC)[១៧០]។ ហើយក៏មានវេទិកាធ្វើមជ្ឈត្តការផ្សេងៗទៀតនៅក្នុងប្រទេសជប៉ុន ថៃ វៀតណាម ម៉ាឡេស៊ី តៃវ៉ាន់ ឥណ្ឌា និង ឥណ្ឌូនេស៊ីផងដែរ។ ដូចដែលនឹងពិភាក្សាខាងក្រោមនៅក្នុងជំពូកនេះ ប្រទេសកម្ពុជាបានដាក់បញ្ចូលមជ្ឈមណ្ឌលមជ្ឈត្តការជាតិថ្មី របស់ខ្លួននៅក្នុងបញ្ជីនេះដែរ។[១៧១]

### ២. *មជ្ឈត្តការសម្រាប់ប្រភេទវិវាទជាច្រើន*

ក្នុងខណៈដែលវេទិកាភាគច្រើនខាងលើផ្តោតលើដំណោះស្រាយវិវាទផ្នែកពាណិជ្ជកម្ម ជាសំខាន់ គេត្រូវយល់ថាមជ្ឈត្តការក៏អាចអនុវត្តចំពោះវិស័យផ្សេងទៀតនៃច្បាប់ផងដែរ។ នៅក្នុងប្រទេសជាច្រើន វិវាទការងារក៏ត្រូវបានដោះស្រាយមជ្ឈត្តការដែរ ក្នុងពេលបច្ចុប្បន្ន។ កិច្ចព្រមព្រៀងអនុសញ្ញារួមតែងតែមានខចែងស្តីពីមជ្ឈត្តការដែលទាមទារឱ្យគូភាគីបញ្ជូនវិវាទទៅធ្វើមជ្ឈត្តការ។ កីឡាអាជីពជាច្រើន ប្រើប្រាស់មជ្ឈត្តការដើម្បីដោះស្រាយបញ្ហាប្រាក់បៀវត្សរ៍។ សូម្បីតែកីឡាអូឡាំពិកក៏បានប្រើប្រាស់មជ្ឈត្តការដើម្បីដោះស្រាយវិវាទដែរ។[១៧២] កិច្ចសន្យាសាងសង់រវាងអ្នកសាងសង់

---

[១៦៥] *សូមមើល* វែបសាយត៍របស់សភាពាណិជ្ជកម្មអន្តរជាតិ *មាននៅ* http://www.iccwbo.org/policy/arbitration/id2882/index.html (ចូលទស្សនាចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨)។

[១៦៦] *សូមមើល* វែបសាយត៍របស់សមាគមមជ្ឈត្តការអាមេរិក *មាននៅ* http://www.adr.org/ (ចូលទស្សនាចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨)។

[១៦៧] *សូមមើល*វែបសាយត៍របស់តុលាការមជ្ឈត្តការអន្តរជាតិក្រុងឡុងដ៍ *មាននៅ* http://www.lcia-arbitration.com/ (ចូលទស្សនាចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨)។

[១៦៨] *សូមមើល* វែបសាយត៍របស់គណៈកម្មាធិការសេដ្ឋកិច្ចអន្តរជាតិ និងមជ្ឈត្តការផ្នែកពាណិជ្ជកម្មចិន *មាននៅ* http://www.cietac.org.cn/index_english.asp (ចូលទស្សនាចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨)។

[១៦៩] *សូមមើល* វែបសាយត៍របស់មជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិក្រុងហុងកុង *មាននៅ* http://www.hkiac.org/HKIAC/HKIAC_English/main.html (ចូលទស្សនាចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨)។

[១៧០] *សូមមើល*វែបសាយត៍របស់មជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិក្រុងសិង្ហបុរី *មាននៅ* http://www.siac.org.sg/ (ចូលទស្សនាចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨)។

[១៧១] *សូមមើល* ជំពូកទី ៤ (ង) ក្នុងផ្នែកនេះ *ខាងក្រោម*។

[១៧២] *សូមមើល* វែបសាយត៍របស់ Tribunal Arbitral du Sport (តុលាការមជ្ឈត្តការសម្រាប់វិស័យកីឡា) *មាននៅ* http://www.tas-cas.org/ (ចូលទស្សនាចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨)។

និងម្ចាស់សំណង់ តែងតែមានខចែងស្តីពីមជ្ឈត្តការ ។ លើសពីនេះទៀត ខចែងស្តីពីមជ្ឈត្តការក៏បានក្លាយជាបទដ្ឋានមួយនៅក្នុង កិច្ចសន្យាធានា កិច្ចព្រមព្រៀងកម្មសិទ្ធិបញ្ញា និង កិច្ចសន្យាលក់សម្រាប់អ្នកប្រើប្រាស់ជាច្រើនប្រភេទ ។

### ៣. តើមជ្ឈត្តការខុសប្លែកពីបណ្តឹងទៅតុលាការ និងសន្ធានកម្ម យ៉ាងដូចម្តេច?

**បណ្តឹងទៅតុលាការ:** ដំណើរការមជ្ឈត្តការមានភាពស្រដៀងទៅនឹងការដាក់ពាក្យប្តឹងទៅតុលាការដែលមានពីមុនមក ដូច្នេះដែរ ។ វិធីសាស្ត្រទាំងពីរតម្រូវឱ្យមានការចូលរួមពីភាគីវិវាទ ដែលបានដាក់ភស្តុតាងជូនទៅភាគីអព្យាក្រឹតមួយ ដែលជាអ្នកចេញសេចក្តីសម្រេច ។ ជាទូទៅ វិធីសាស្ត្រទាំងពីរនេះទាមទារឱ្យមានជំនួយពីមេធាវី ឬអ្នកតំណាង ស្រប ច្បាប់ និងមានសេចក្តីសម្រេចមួយដែលចងភ្ជាប់កាតព្វកិច្ច (ដែលអាចអនុវត្តបានដោយតុលាការ) ចំពោះគូភាគី ដែលត្រូវ តែគោរពតាម ។ ប៉ុន្តែក៏មានភាពខុសគ្នាចម្បងៗមួយចំនួនរវាងដំណើរការមជ្ឈត្តការ និងបណ្តឹងតុលាការដែរ ដូចជា:

- នៅក្នុងមជ្ឈត្តការ គូភាគីជាអ្នកសម្រេចចិត្តលើលក្ខខណ្ឌនៃដំណើរការមជ្ឈត្តការនោះ ។ ម្យ៉ាងទៀត គូភាគីជា អ្នកសម្រេចចិត្តថាតើមជ្ឈត្តការនឹងធ្វើឡើងនៅកន្លែងណា និងនៅពេលណា វិធានច្បាប់ និងនីតិវិធីសំខាន់ៗ អ្វីខ្លះដែលត្រូវអនុវត្ត នរណានឹងធ្វើជាមជ្ឈត្តករ បញ្ហាអ្វីខ្លះដែលត្រូវស្ថិតនៅក្រោមដំណើរការមជ្ឈត្តការ និង មានមធ្យោបាយអ្វីខ្លះដើម្បីធ្វើការដោះស្រាយ ។ នៅក្នុងបណ្តឹងទៅតុលាការ គូភាគីស្ទើរតែគ្មានជម្រើសនៅក្នុង បញ្ហាទាំងនេះទាល់តែសោះ ។
- មជ្ឈត្តការមាននិន្នាការបញ្ចប់បញ្ហាបានឆាប់រហ័សជាងបណ្តឹងតុលាការ ។ នៅក្នុងប្រទេសជាច្រើន បណ្តឹងទៅ តុលាការអាចអូសបន្លាយអស់រយៈពេលជាច្រើនឆ្នាំ ។ ជាទូទៅ កត្តានេះកើតឡើងដោយសារ មានការកកស្ទះ រឿងក្តី ដែលត្រូវធ្វើការដោះស្រាយ និងបន្ទុកនៃចំនួនរឿងក្តីច្រើនពេកនៅក្នុងតុលាការ ។ ផ្ទុយទៅវិញ នៅក្នុងមជ្ឈត្តការ គូភាគីអាចជ្រើសរើសវេទិកាមួយដែលរៀបចំជាស្រេច ដើម្បីធ្វើការដោះស្រាយវិវាទរបស់ ខ្លួនឱ្យបានឆាប់រហ័ស ។
- មជ្ឈត្តការមាននិន្នាធ្វើការដោះស្រាយវិវាទដោយចំណាយតិចជាងការដាក់ពាក្យប្តឹងទៅតុលាការ ។ នេះក៏ដោយ សារតែមជ្ឈត្តការគឺជាដំណើរការដែលមានភាពរលូនជាង ។ បើធៀបនឹងដំណើរការបណ្តឹងនៅតុលាការ គូភាគី ដែលពាក់ព័ន្ធនឹងមជ្ឈត្តការចំណាយពេលវេលាតិចជាង ក្នុងការបង្ហាញភស្តុតាងនិង សាក្សី ។ អាស្រ័យហេតុនេះ ភាគីវិវាទអាចជៀសផុតពីទម្រង់បែបបទ និងវិធានដែលតម្រូវឱ្យមានក្នុងស្ថាប័នតុលាការ ហើយអាចឈានដល់ ដំណោះស្រាយលើវិវាទនោះយ៉ាងងាយស្រួល ។
- ជាទូទៅ មជ្ឈត្តការត្រូវធ្វើឡើងជាអសាធារណៈ ចំណែកបណ្តឹងតុលាការត្រូវធ្វើឡើងជាសាធារណៈ ។
- ផ្ទុយពីដំណើរការបណ្តឹងទៅតុលាការ មជ្ឈត្តវិនិច្ឆ័យជាទូទៅមិនអាចប្តឹងឧបាស្រ័យបានឡើយ ។
- ហើយជាចុងក្រោយ ដំណោះស្រាយតាមមជ្ឈត្តការមានលក្ខណៈទន់ភ្លន់ជាងតុលាការ ។

**សន្ធានកម្ម:** មជ្ឈត្តការមានលក្ខណៈស្រដៀងគ្នាមួយចំនួនជាមួយសន្ធានកម្ម ។ វិធីសាស្ត្រទាំងពីរគឺជារបៀបដោះស្រាយ ជាឯកជន ដែលជាចម្លាស់ទៅនឹងបណ្តឹងតុលាការដែលត្រូវធ្វើឡើងជាសាធារណៈ ។ វិធីសាស្ត្រទាំងពីរអាចធ្វើឡើងនៅក្នុង

បន្ទប់ប្រជុំឯកជន ឬនៅទីកន្លែងផ្សេងទៀតនៅខាងក្រៅតុលាការ។ វិធីសាស្ត្រទាំងពីរធ្វើការដំណោះស្រាយវិវាទដោយចំណាយតិច និងឆាប់រហ័សជាងដំណើរការបណ្តឹងទៅតុលាការ។ ប៉ុន្តែ មជ្ឈត្តការក៏មានចំណុចខុសគ្នាផងដែរពីសន្ធានកម្មៈ

- បន្ទាប់ពីបានពិនិត្យ និងពិចារណាលើភស្តុតាងរួចហើយ មជ្ឈត្តករនឹងធ្វើសេចក្តីសម្រេច និងមានអំណាចក្នុងការបង្គាប់ឱ្យសងសំណងការខូចខាតដល់ភាគីណាមួយ។ សន្ធានការីពុំមានអំណាចរបៀបនេះឡើយ ហើយគ្រាន់តែអាចស្នើឡើងនូវដំណោះស្រាយដែលអាចកើតមានតែប៉ុណ្ណោះ។ គេអាចនិយាយម្យ៉ាងទៀតថា ក្នុងដំណើរការមជ្ឈត្តការ អំណាចក្នុងការធ្វើការសម្រេចចិត្តគឺស្ថិតនៅក្នុងកណ្តាប់ដៃរបស់មជ្ឈត្តករ ចំណែកឯនៅក្នុងដំណើរសន្ធានកម្ម អំណាចក្នុងការធ្វើការសម្រេចចិត្តគឺស្ថិតនៅក្នុងកណ្តាប់ដៃរបស់គូភាគី។
- នៅក្នុងដំណើរការមជ្ឈត្តការ មជ្ឈត្តករត្រូវពិនិត្យមើលឡើងវិញនូវអង្គហេតុ និងអង្គច្បាប់ដូចចៅក្រមដែរ ហើយត្រូវប្រើការពិចារណាលើតក្កសាស្ត្រ និងហេតុផលផ្លូវច្បាប់ ដើម្បីឈានដល់ការធ្វើសេចក្តីសម្រេច។ ក្នុងន័យនេះ គឺគេត្រូវផ្តោតការយកចិត្តទុកដាក់លើការស្វែងរកលទ្ធផលដែលផ្អែកទៅតាមច្បាប់។ ផ្ទុយទៅវិញ នៅក្នុងសន្ធានកម្ម សន្ធានការីប្រហែលជាត្រូវប្រើជំនាញផ្នែកសង្គម និងការវិភាគតាមបែបប្រធានវិស័យ ដើម្បីឈានដល់ដំណោះស្រាយ។ អាស្រ័យហេតុនេះ នៅក្នុងសន្ធានកម្ម គេត្រូវផ្តោតការយកចិត្តទុកដាក់លើការស្វែងរកលទ្ធផល ដែលឆ្លើយតបយ៉ាងប្រសើរបំផុតទៅនឹងផលប្រយោជន៍របស់គូភាគី។
- នៅក្នុងមជ្ឈត្តការ ចំណុចដែលត្រូវផ្តោតការយកចិត្តទុកដាក់គឺជាមជ្ឈត្តករ។ ភាគីវិវាទត្រូវព្យាយាមបញ្ចុះ-បញ្ចូលឱ្យមជ្ឈត្តករជឿថា ពួកគេគួរតែឈ្នះក្តី។ នៅក្នុងសន្ធានកម្ម ចំណុចដែលត្រូវផ្តោតការយកចិត្តទុកដាក់គឺជាភាគីនៃវិវាទ។ សន្ធានការីត្រូវស្តាប់អំណះអំណាងរបស់គូភាគី ហើយព្យាយាមស្វែករកនូវមធ្យោយដែលអាចឆ្លើយតបនឹងផលប្រយោជន៍របស់ពួកគេបាន។

## ៤. *ប្រភេទផ្សេងៗនៃមជ្ឈត្តការ*

ជាទូទៅ មជ្ឈត្តការត្រូវបានចាត់ទុកថាជាវិធីសាស្ត្រដោះស្រាយវិវាទមួយដែលចងភ្ជាប់កាតព្វកិច្ច។ ភាគីវិវាទត្រូវបង្ហាញភស្តុតាងរបស់ខ្លួន ហើយមជ្ឈត្តករជាអ្នកចេញសេចក្តីសម្រេចមួយដែលចងភ្ជាប់កាតព្វកិច្ចលើគូភាគីនោះ។ ភាគីវិវាទត្រូវគោរពតាមសេចក្តីសម្រេចនេះ។ ពួកគេមានសិទ្ធិតិចតួចបំផុតក្នុងការប្តឹងឧបាស្រ័យ។ សេចក្តីសម្រេចនេះអាចដាក់ឱ្យអនុវត្តដោយប្រព័ន្ធតុលាការសាធារណៈ។ នេះគឺជាទម្រង់នៃមជ្ឈត្តការបែបបុរាណ និងទូទៅបំផុត ហើយត្រូវបានហៅឈ្មោះតាមពាក្យបច្ចេកទេសថា *"មជ្ឈត្តការភ្ជាប់កាតព្វកិច្ច"*។

ប៉ុន្តែ ថ្មីៗនេះ *មជ្ឈត្តការមិនភ្ជាប់កាតព្វកិច្ច* ក៏កំពុងក្លាយជាជម្រើសដ៏ពេញនិយមមួយផងដែរ។ *មជ្ឈត្តការមិនភ្ជាប់កាតព្វកិច្ច* គឺស្រដៀងគ្នានឹង *មជ្ឈត្តការចងភ្ជាប់កាតព្វកិច្ច* ដែរ ដោយខុសគ្នាត្រង់ថា ភាគីនីមួយៗអាចបដិសេធសេចក្តីសម្រេចរបស់មជ្ឈត្តករក្នុងរយៈពេលដ៏ខ្លីមួយ ក្រោយពេលចេញសេចក្តីសម្រេចរួច។ *មជ្ឈត្តការមិនភ្ជាប់កាតព្វកិច្ច* ពេលខ្លះ ត្រូវបានប្រើប្រាស់ដើម្បីជួយរក្សាទំនាក់ទំនងរបស់ភាគីវិវាទ។ មជ្ឈត្តករអាចចេញសេចក្តីសម្រេចដែលមានលក្ខណៈជាជម្រើស ជាជាងការអនុវត្តសេចក្តីសម្រេចដោយបង្ខំលើគូភាគីនោះ។ ភាគីប្រើប្រាស់សេចក្តីសម្រេចនេះជាមធ្យោបាយចរចានៅក្នុងការដោះស្រាយវិវាទរបស់ខ្លួន។ ភាគីវិវាទក៏អាចទទួលយកសេចក្តីសម្រេចនេះបានដែរ ក្នុងករណី

ដែលសេចក្ដីសម្រេចនោះឆ្លើយតបនឹងផលប្រយោជន៍របស់ខ្លួន។ ទោះជាយ៉ាងណា គុណវិបត្តិស្ថិតនៅត្រង់ថា វាអាចជាការខ្ជះខ្ជាយពេលវេលា និងធនធាន ប្រសិនបើគូភាគីបដិសេធសេចក្ដីសម្រេចនោះ ហើយ សម្រេចចិត្តបន្តយកវិវាទរបស់ពួកគេប្ដឹងទៅតុលាការ ឬកន្លែងផ្សេងទៀត។

*មជ្ឈត្តការមិនភ្ជាប់កាតព្វកិច្ច* ស្រដៀងគ្នានឹងសន្ធានកម្មជាងដំណើរការបណ្ដឹងតុលាការ ដោយសារតែវាមានផ្នែកមួយដែលជាការចរចាគ្នា ហើយតាមរយៈនោះ គូភាគីគឺជាអ្នកគ្រប់គ្រងលើដំណើរការ និងលទ្ធផលនៃការចរចានោះទាំងស្រុង។ ផ្ទុយមកវិញ *មជ្ឈត្តការភ្ជាប់កាតព្វកិច្ច* មាននិន្នាការដូចគ្នាទៅនឹងដំណើរការបណ្ដឹងទៅតុលាការជាងសន្ធានកម្ម ដោយសារតែនីតិវិធីនេះមានការពាក់ព័ន្ធនឹងសេចក្ដីសម្រេចចុងក្រោយ ដែលត្រូវធ្វើឡើងដោយភាគីអព្យាក្រឹតមួយ។ សម្រាប់ជំពូកនេះផ្ទាល់ នៅពេលដែលមជ្ឈត្តការត្រូវបានលើកមកពិភាក្សា ពាក្យថាមជ្ឈត្តការគឺសំដៅដល់មជ្ឈត្តការតាមបែបបុរាណដែលជា *មជ្ឈត្តការភ្ជាប់កាតព្វកិច្ច* លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។ *មជ្ឈត្តការមិនភ្ជាប់កាតព្វកិច្ច* នឹងមានរៀបរាប់លម្អិតនៅចុងបញ្ចប់នៃជំពូកនេះ នៅក្នុងផ្នែកដែលពិភាក្សាអំពីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដែលទទួលបានជោគជ័យបំផុតនៅក្នុងប្រទេសកម្ពុជា។[១៧៣]

គួរកត់សម្គាល់ផងដែរថា ជាទូទៅ គូភាគីត្រូវសម្រេចចិត្តនៅពេលចុះកិច្ចសន្យាថា តើមជ្ឈត្តការដែលពួកគេព្រមព្រៀងប្រើប្រាស់នោះ គឺជាមជ្ឈត្តការភ្ជាប់កាតព្វកិច្ច ឬមិនភ្ជាប់កាតព្វកិច្ច។ ចំណុចលម្អិតទាំងនេះគឺមានរៀបរាប់នៅក្នុងខចែងស្ដីពីមជ្ឈត្តការនៅក្នុងកិច្ចសន្យារបស់គូភាគីនោះ។ ខចែងស្ដីពីមជ្ឈត្តការនេះ នឹងមានរៀបរាប់បន្ថែមទៀតនៅក្នុងជំពូកនេះ។

មជ្ឈត្តការក៏អាចត្រូវបានបែងចែកជាប្រភេទមជ្ឈត្តការដែល*មានការគ្រប់គ្រង* ឬ មជ្ឈត្តការ *ពិសេស*។ *មជ្ឈត្តការមានការគ្រប់គ្រង* សំដៅលើមជ្ឈត្តការដែលធ្វើឡើងនៅមជ្ឈមណ្ឌលមជ្ឈត្តការ ដូចជា ICC នៅក្រុងប៉ារីស ឬក្រុមប្រឹក្សាអាជ្ញាកណ្ដាលកម្ពុជា។ មជ្ឈមណ្ឌលមជ្ឈត្តការទាំងនេះមានផ្ដល់នូវបន្ទប់មួយសម្រាប់ធ្វើសវនាការ បញ្ជីរាយនាមមជ្ឈត្តករ ការចែងវិធាននីតិវិធីសម្រាប់ដំណើរការ និងសេវាកម្មដទៃផ្សេងទៀត ដែលជាទូទៅត្រូវមានការបង់ថ្លៃ។ មជ្ឈត្តការពិសេសសំដៅដល់ជម្រើសរបស់គូភាគីក្នុងការបង្កើតវេទិកាផ្ទាល់របស់ខ្លួន សម្រាប់គោលបំណងជាក់លាក់ណាមួយក្នុងដំណោះស្រាយវិវាទតែមួយប៉ុណ្ណោះ។ ជាទូទៅ សេចក្ដីសម្រេចរវាងមជ្ឈត្តការមានការគ្រប់គ្រង និងមជ្ឈត្តការពិសេស ត្រូវបានធ្វើឡើង នៅពេលបង្កើតកិច្ចសន្យា។

***នៅពេលចរចាចុះកិច្ចសន្យា ប្រសិនបើគូភាគីចង់ដោះស្រាយវិវាទរបស់ខ្លួនតាមរយៈមជ្ឈត្តការ ពួកគេត្រូវព្រមព្រៀងគ្នាចំពោះទម្រង់មជ្ឈត្តការណាមួយ ហើយត្រូវបញ្ជាក់វានៅក្នុងខចែងស្ដីពីមជ្ឈត្តការនៃកិច្ចសន្យានោះ។***

គុណសម្បត្តិដ៏ជាក់លាក់មួយរបស់មជ្ឈត្តការ *មានការគ្រប់គ្រង* គឺថា សេចក្ដីលម្អិតភាគច្រើននៃដំណើរការត្រូវបានកំណត់រួចជាស្រេច។ គូភាគីគ្រាន់តែត្រូវគោរពតាមនីតិវិធីរបស់វេទិកាដែលបានជ្រើសរើសប៉ុណ្ណោះ ដើម្បីចាប់ផ្ដើមដំណើរការមជ្ឈត្តការ។ អាស្រ័យហេតុនេះ ទើបភាគីវិវាទភាគច្រើនធ្វើការជ្រើសរើសយកមជ្ឈត្តការ *មានការ*

---

[១៧៣] *សូមមើល* ជំពូកទី ៤ (ឆ) ក្នុងផ្នែកនេះ *ខាងក្រោម*។

*គ្រប់គ្រង*។[១៧៤] នៅក្នុងករណី មជ្ឈត្តការពិសេស គូភាគីត្រូវសម្រេចចិត្តអំពីចំណុចលម្អិត (វិធាននីតិវិធី ថ្លៃចំណាយមជ្ឈត្តករ ។ល។) នៅពេលចុះកិច្ចសន្យា ឬក្រោយពេលវិវាទបានកើតឡើងហើយ ហើយទំនងជានឹងត្រូវការមេធាវីម្នាក់ក្នុងការតាក់តែងវិធានទាំងនេះ។ ប៉ុន្តែ មជ្ឈត្តការពិសេសអនុញ្ញាតឱ្យគូភាគីមានភាពបត់បែនច្រើន លើចំណុចលម្អិតនានារួមទាំងថ្លៃចំណាយផងដែរ ដោយសារពួកគេមិនចាំបាច់ត្រូវគោរពតាមវិធានរបស់មជ្ឈមណ្ឌលមជ្ឈត្តការណាមួយឡើយ។

មជ្ឈត្តការ *មានការគ្រប់គ្រង* និងមជ្ឈត្តការ*ពិសេស* អាចជាមជ្ឈត្តការភ្ជាប់កាតព្វកិច្ច ឬ មិនភ្ជាប់កាតព្វកិច្ច។

## សំណួរសិក្សា

នៅក្នុងវិវាទខាងក្រោមនេះ ចូរជ្រើសរើសមជ្ឈត្តការប្រភេទណាមួយដែលសមស្របបំផុត:

ជម្រើសទី ១ : មជ្ឈត្តការ *មានការគ្រប់គ្រង* ដែលភ្ជាប់កាតព្វកិច្ច

ជម្រើសទី ២ : មជ្ឈត្តការ *មានការគ្រប់គ្រង* ដែលមិនភ្ជាប់កាតព្វកិច្ច

ជម្រើសទី ៣ : មជ្ឈត្តការពិសេសដែលភ្ជាប់កាតព្វកិច្ច

ជម្រើសទី ៤ : មជ្ឈត្តការពិសេសដែលមិនភ្ជាប់កាតព្វកិច្ច

ក. វុត្ថា ផ្តល់សេវាថតចម្លង ហើយ ស្រស់ ចង់ចុះកិច្ចសន្យាទិញសេវាថតចម្លងក្នុងតម្លៃ ១.០០០ ដុល្លារក្នុងមួយខែសម្រាប់រយៈពេលមួយឆ្នាំ ហើយដែលអាចបន្តទៅទៀតបាននៅចុងឆ្នាំ។

ខ. នីន គឺជាស្ថាបត្យករ ហើយកំពុងផ្តល់សេវាកម្មឱ្យក្រុមហ៊ុនសំណង់កូរ៉េ ដែលនឹងត្រូវការនាងឱ្យជួយគូសប្លង់ផ្សារទំនើបមួយដែលត្រូវសាងសង់នៅក្នុងខេត្តសៀមរាប។

គ. ណារី ចង់ទិញរថយន្តពិសេសមួយគ្រឿងពី សុផល។

ឃ. ក្រុមហ៊ុន Cambo Oil Company ចាប់អារម្មណ៍ក្នុងការធ្វើទំនាក់ទំនងជាមួយក្រុមហ៊ុនបូមប្រេងម៉ាឡេស៊ី ឱ្យបូមប្រេងនៅជិតឆ្នេរក្រុងកំពង់សោម។

ង. សហព័ន្ធកីឡាបាល់ទាត់អាជីពកម្ពុជាថ្មី នឹងស្នើឱ្យអ្នករៀបចំកិច្ចសន្យាមួយ ដែលសហព័ន្ធនឹងផ្តល់ដល់កីឡាករបាល់ទាត់ទាំងអស់នៅក្នុងសហព័ន្ធថ្មីនេះ ។

[១៧៤] សាជីវកម្ម ៧៦% ចូលចិត្តធ្វើមជ្ឈត្តការ *មានការគ្រប់គ្រង* ជាងមជ្ឈត្តការ*ពិសេស*។ *សូមមើល* Mistelis កំណត់ សម្គាល់*ខាងលើ* លេខ១៦៤ ទំព័រទី ៥៦១។

## ខ. គុណសម្បត្តិ និងគុណវិបត្តិនៃមជ្ឈត្តការ

### ១. *គុណសម្បត្តិ*

- **ថ្លៃចំណាយៈ** មជ្ឈត្តការប្រើចំណាយតិចជាងបណ្តឹងតុលាការ។ នេះដោយសារតែមជ្ឈត្តការ មានភាពរលូនជាងបើធៀបទៅនឹងវិធានតុលាការ។ មួយវិញទៀត ក៏ដោយសារតែមជ្ឈត្តការ ជាទូទៅ ពុំមានការប្តឹងឧបាស្រ័យ។
- **ល្បឿនៈ** មជ្ឈត្តការមានការដោះស្រាយវិវាទបានឆាប់រហ័សជាងដំណើរការបណ្តឹងទៅតុលាការ។ ដូចដែលបានរៀបរាប់នៅខាងលើរួចហើយ មជ្ឈត្តការខុសពីបណ្តឹងតុលាការ ដោយ ជាទូទៅ គឺមិនអនុញ្ញាតឱ្យមានការប្តឹងឧបាស្រ័យឡើយ។ ផ្ទុយមកវិញ តាមរយៈដំណើរការបណ្តឹងតុលាការ គូភាគីអាចប្តឹងឧបាស្រ័យយ៉ាងហោចណាស់ម្តង ហើយជួនកាលច្រើនដងទៀតផង។ លើសពីនេះទៀត ប្រព័ន្ធតុលាការមានរឿងក្តីដែលរងចាំការដោះស្រាយគរយ៉ាងច្រើន ដែលបង្ខំឱ្យគូភាគីរង់ចាំការជំនុំជម្រះយ៉ាងយូរ។
- **លក្ខណៈស្ថាពរៈ** ដោយហេតុថាមជ្ឈត្តការមិនអាចការប្តឹងឧបាស្រ័យបាន ជាទូទៅសេចក្តីសម្រេចរបស់មជ្ឈត្តករមានលក្ខណៈស្ថាពរ។ ជាញឹកញាប់ ប្រការនេះគឺជាគុណសម្បត្តិធំធេងចំពោះគូភាគី។
- **ការដាក់ឱ្យអនុវត្តថ្នាក់ជាតិៈ** ដោយហេតុថា ប្រទេសកម្ពុជាបានអនុម័តច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ខ្លួន តុលាការកម្ពុជាអាចដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យដោយផ្ទាល់។ ដំណោះស្រាយតាមការចរចា ឬសន្ធានកម្ម មិនអាចដាក់ឱ្យអនុវត្តបានដោយងាយស្រួលបែបនេះឡើយ។[១៧៥]
- **ការដាក់ឱ្យអនុវត្តថ្នាក់អន្តរជាតិៈ** ដោយអនុលោមតាមអនុសញ្ញាក្រុងញូវយ៉កស្តីពីការទទួលស្គាល់ និង ការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេស ("អនុសញ្ញាក្រុងញូវយ៉ក") ដែលប្រទេសកម្ពុជាបានចុះហត្ថលេខាផងដែរនោះ មជ្ឈត្តវិនិច្ឆ័យដែលធ្វើឡើងនៅក្នុងប្រទេសហត្ថលេខី អាចដាក់ឱ្យអនុវត្តបានដោយស្វ័យប្រវត្តិនៅក្នុងបណ្តាប្រទេសហត្ថលេខីផ្សេងទៀតទាំងអស់។[១៧៦] ប្រការនេះគឺជាគុណសម្បត្តិដ៏ធំសម្រាប់ដោះស្រាយវិវាទអន្តរជាតិ ដោយសារតែគ្មានប្រព័ន្ធដាក់ឱ្យអនុវត្តជាអន្តរជាតិស្រដៀងគ្នានេះ សម្រាប់សេចក្តីសម្រេចរបស់តុលាការនៅឡើយ។[១៧៧]

---

[១៧៥] ទោះជាយ៉ាងណា ក៏នៅមានករណីលើកលែងមួយដូចមានកំណត់នៅក្នុងជំពូកមុនស្តីពីការចរចា និងសន្ធានកម្ម។ គូភាគីដែលកំពុងប្តឹងផ្តល់នៅក្នុងតុលាការកម្ពុជា អាចសាកល្បងដោះស្រាយរឿងក្តីរបស់ខ្លួនបាន។ ប្រសិនបើ ពួកគេឈានដល់ "ការសះជាតាមផ្លូវតុលាការ" ដែលមានកត់ត្រានៅក្នុងពិធីសារតុលាការ (កំណត់ហេតុតុលាការ) វានឹងមានអានុភាព និង ប្រសិទ្ធភាពដូចសាលក្រមតុលាការដែរ ហើយអាចអនុវត្តបានតាមរយៈតុលាការ ។ ក.ន.រ.ព.ក. កំណត់សម្គាល់ *ខាងលើ* លេខ៧, មាត្រា ២២២។

[១៧៦] មានប្រទេសជាង ១៤០ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្រុងញូវយ៉ក។

[១៧៧] *ប៉ុន្តែសូមមើល* ***អនុសញ្ញាក្រុងឡាអេស្តីពីការជ្រើសរើសកិច្ចព្រមព្រៀងតុលាការ***, សន្និសីទក្រុងឡាអេស្តីពីនីតិអន្តរជាតិឯកជន *មាននៅ* http://www.hcch.net/index_en.php?act=conventions.text&cid=98 (ចូលទស្សនាចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨)។ អនុសញ្ញានេះអនុញ្ញាតិឱ្យទទួលស្គាល់ និងអនុវត្ត ខចែងស្តីពីការជ្រើសរើសវេទិកា និងសាលក្រមសម្រេចនៅក្នុងវិវាទពាណិជ្ជកម្ម ក្នុងចំណោមប្រទេសហត្ថលេខី ។ អនុសញ្ញានេះត្រូវបានធ្វើពង្រាងរួចហើយ ហើយកំពុងរង់ចាំការផ្តល់

- **ការរក្សាទំនាក់ទំនង:** ទោះបីជាមជ្ឈត្តការមានទិដ្ឋភាពបដិបក្ខក៏ដោយ ជាទូទៅមជ្ឈត្តការមានភាពបដិបក្ខតិចជាងដំណើរការបណ្តឹងនៅតុលាការ ។ កត្តានេះអាចជួយរក្សាទំនាក់ទំនងរវាងគូភាគីបាន ។
- **ភាពជាឯកជន:** ផ្ទុយពីដំណើរការបណ្តឹងនៅតុលាការ ជាទូទៅមជ្ឈត្តការគឺជាដំណើរការជាឯកជន ។ ប្រការនេះអាចជាគុណសម្បត្តិដ៏ធំ ប្រសិនបើគូភាគីមិនចង់ឱ្យសាធារណជនដឹងអំពីចំណុចលម្អិតនៃវិវាទរបស់ពួកគេ ។
- **ដំណោះស្រាយដែលអាចបត់បែនបាន:** មជ្ឈត្តករតែងអាចមានភាពបត់បែនក្នុងការដាក់ចេញនូវមធ្យោបាយដោះស្រាយដែលប្រកបដោយភាពច្នៃប្រឌិត ដែលតុលាការមិនអាចធ្វើបានឡើយ ដូចជាការសម្រេចឱ្យភាគីដែលឈ្នះក្តីចេញថ្លៃមេធាវីជាដើម ។
- **ជំនាញរបស់មជ្ឈត្តករ:** គូភាគីអាចជ្រើសរើសមជ្ឈត្តករដែលមានជំនាញនៅក្នុងវិស័យអាជីវកម្ម ដែលត្រូវនឹងវិស័យការងាររបស់គេ ឧទាហរណ៍នៅក្នុងវិស័យកាត់ដេរ ឬបូមយកប្រេងជាដើម ។ ម្យ៉ាងទៀត ប្រព័ន្ធតុលាការភាគច្រើន ពុំមានចៅក្រមជំនាញសម្រាប់វិស័យនៃច្បាប់ណាមួយជាក់លាក់នោះទេ ហេតុដូច្នេះហើយភាគីវិវាទអាចត្រូវមានចៅក្រមអធិបតីម្នាក់ ដែលគ្មានចំណេះដឹងជាក់លាក់អំពីវិស័យឧស្សាហកម្មរបស់ខ្លួន ។ ហេតុនេះ ក្នុងករណីដែលចំណេះដឹងជាក់លាក់អំពីវិស័យអាជីវកម្ម ឬច្បាប់មានភាពសំខាន់ ដំណើរការមជ្ឈត្តការអាចផ្តល់លទ្ធផលកាន់តែត្រឹមត្រូវ និងផ្តល់ភាពជ្រួតជ្រាបបានល្អ ។
- **អព្យាក្រឹតភាពរបស់មជ្ឈត្តករ:** គូភាគីនៃវិវាទអន្តរជាតិ តែងតែព្រួយបារម្ភថាចៅក្រមនៅក្នុងប្រទេសដើមកំណើតរបស់ភាគីម្ខាង អាចនឹងមានភាពលម្អៀងទៅលើភាគីនោះ ជួនកាលហៅថា "គុណសម្បត្តិនៃតុលាការលំនៅ" ។ ប៉ុន្តែ នៅក្នុងមជ្ឈត្តការគូភាគីអាចជ្រើសរើសមជ្ឈត្តករបាន ហេតុនេះគឺអាចលុបបំបាត់ភាពលម្អៀងលើជាតិសាសន៍ដែលអាចកើតមាន ។
- **នីតិវិធីដែលអាចបត់បែនបាន:** ជារឿយៗ គូភាគីអាចជ្រើសរើសថាតើពួកគេចង់បាននីតិវិធីស្មុគស្មាញ ដែលមើលទៅមានលក្ខណៈដូចជាដំណើរការបណ្តឹងនៅតុលាការ ឬនីតិវិធីដែលមានលក្ខណៈសាមញ្ញជាងនេះ ។ នៅក្នុងបណ្តឹងតុលាការ ភាគីវិវាទត្រូវតែគោរពតាមនីតិវិធីច្បាប់ ទោះបីជាពួកគេមិនពេញចិត្តនឹងនីតិវិធីនោះក៏ដោយ ។ នៅក្នុងការសិក្សាស្រាវជ្រាវនៅឆ្នាំ២០០៤ គុណសម្បត្តិនេះត្រូវបានគេលើកឡើងថា ជាមូលហេតុចម្បងដែលក្រុមហ៊ុនអន្តរជាតិធ្វើការជ្រើសរើសយកមធ្យោបាយមជ្ឈត្តការ ។[១៧៨]

---

សច្ចាប័ន ។ នៅពេល តាក់តែង មានតែប្រទេសមួយប៉ុណ្ណោះគឺប្រទេសម៉ិចស៊ិក ដែលបានផ្តល់សច្ចាប័នលើអនុសញ្ញានេះ ។ *សូមមើល អនុសញ្ញាឈានទៅមុខមួយកម្រិត,* ព្រឹត្តបត្រគណៈមេធាវីអាមេរិក ទំព័រទី ៦០ (ខែធ្នូ ឆ្នាំ២០០៧) ។

[១៧៨] Mistelis, កំណត់សម្គាល់ *ខាងលើ* លេខ១៦៤ ទំព័រទី ៥៤៣ ។

## ២. *គុណវិបត្តិ*

- **ថ្លៃចំណាយ:** ទោះបីជាមជ្ឈត្តការ ជាទូទៅមានការចំណាយទាបជាងដំណើរការកាត់ក្ដីដោយតុលាការក៏ដោយ ក៏មជ្ឈត្តការនៅតែអាចមានតម្លៃថ្លៃដដែល។ គូភាគីត្រូវបង់ថ្លៃសម្រាប់ពេលវេលារបស់មជ្ឈត្តករ បន្ទប់សវនាការ ថ្លៃវេទិកាធ្វើមជ្ឈត្តការ ព្រមទាំងថ្លៃដំណើរការកាត់ក្ដីធម្មតាផ្សេងៗទៀតដូចជា ថ្លៃជួលមេធាវី និងថ្លៃចំណាយដែលពាក់ព័ន្ធដទៃទៀត។ ជាទូទៅ ដំណើរការនេះមានតម្លៃថ្លៃជាងការចរចា ហើយជួនកាលថ្លៃជាងសន្ទានកម្មទៅទៀត។
- **ល្បឿន:** ទោះបីជាមជ្ឈត្តការ ជាទូទៅ ដំណោះស្រាយវិវាទឆាប់រហ័សជាងដំណើរការបណ្ដឹងតុលាការក៏ដោយ ក៏មជ្ឈត្តការអាចមានល្បឿនយឺតជាងការចរចា និងសន្ទានកម្មដែរ។ ជាធម្មតា គូភាគីត្រូវការពេលវេលាច្រើនដើម្បីរៀបចំរឿងក្ដីរបស់ខ្លួនសម្រាប់ការធ្វើមជ្ឈត្តការ បើប្រៀបធៀបនឹងការធ្វើសន្ទានកម្ម ឬការចរចា។
- **អនុលោមភាពមានកម្រិតទាប:** ដោយហេតុថាមជ្ឈត្តវិនិច្ឆ័យមិនមែនបានមកពីការការចរចា និងការស្រុះស្រួលគ្នា ហេតុនេះគឺអាចមានលទ្ធភាពច្រើននៃការមិនអនុលោមតាមមជ្ឈត្តវិនិច្ឆ័យ។ ហេតុដូច្នេះហើយ គូភាគីអាចត្រូវចំណាយបន្ថែមកាន់តែច្រើនលើថ្លៃមេធាវី ដែលចាំបាច់ដើម្បីបន្តសុំការអនុវត្តតាមប្រព័ន្ធតុលាការ។
- **សវនាការជាអសាធារណៈ:** ក្នុងស្ថានភាពខ្លះ ភាគីម្ខាងអាចចង់ឱ្យមានសវនាការជាសាធារណៈ ឧទាហរណ៍ដូចជាដើម្បីការពារខ្លួនជាសាធារណៈប្រឆាំងនឹងការប្ដឹងទាមទារ ឬដើម្បីដាក់ទណ្ឌកម្មភាគីម្ខាងទៀតឱ្យមានការអាម៉ាស់មុខជាសាធារណៈជាដើម។ ដោយសារតែមជ្ឈត្តការមិនអនុញ្ញាតឱ្យមានចំណុចនេះ ទើបវាគឺជាគុណវិបត្តិដែលអាចនឹងកើតមានចំពោះគូភាគីនៅក្នុងស្ថានភាពជាក់លាក់មួយចំនួន។
- **ការរក្សាទំនាក់ទំនង:** ទោះបីជាមជ្ឈត្តការអាចរក្សាទំនាក់ទំនងរបស់គូភាគីបានប្រសើរជាងបណ្ដឹងតុលាការក៏ដោយ ក៏ទម្រង់នៃដំណោះស្រាយវិវាទផ្សេងទៀតចំនួនពីរទៀត គឺការចរចា និងសន្ទានកម្ម កាន់តែមានប្រសិទ្ធភាពនៅក្នុងការរក្សាទំនាក់ទំនងរបស់គូភាគី។
- **លទ្ធផលមិនប្រាកដប្រជា:** ប្រសិនបើមជ្ឈត្តករបំពេញតួនាទីជា*អ្នកជួយសម្រុះសម្រួល* ពួកគេនឹងវិនិច្ឆ័យរឿងក្ដីដោយផ្អែកលើគោលការណ៍សមភាព មិនចាំបាច់មានច្បាប់សំរាប់គ្រប់គ្រងឡើយ ។ ប្រការនេះអាចនាំឱ្យមានលទ្ធផលមិនច្បាស់លាស់។

## គ. កិច្ចព្រមព្រៀងមជ្ឈត្តការ

ដោយអនុលោមតាមច្បាប់ថ្មីស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ប្រទេសកម្ពុជាដែលត្រូវបានបោះពុម្ពឡើងវិញទាំងស្រុង និងត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធ(ង) នៅក្នុងសៀវភៅនេះ វិវាទពាណិជ្ជកម្មត្រូវតែដោះស្រាយតាមមជ្ឈត្តការ ក្នុងករណីដែលមានខចែងស្តីពីមជ្ឈត្តការត្រូវបានសរសេរជាលាយលក្ខណ៍អក្សរ នៅក្នុងកិច្ចសន្យារបស់គូភាគី ឬប្រសិនបើពួកគេព្រមព្រៀងទទួលយកការធ្វើមជ្ឈត្តការ នៅក្នុងកិច្ចព្រមព្រៀងសតីពីមជ្ឈត្តការ ជាលាយ-លក្ខណ៍អក្សរដាច់ដោយឡែកមួយ។[១៨០] កិច្ចព្រមព្រៀងទទួលយកមជ្ឈត្តការត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ប៉ុន្តែលក្ខខណ្ឌតម្រូវនេះអាចបំពេញបាន ដោយការសរសេរលិខិតឆ្លើយឆ្លងគ្នាទៅវិញទៅមក ដែលបង្ហាញឱ្យឃើញអំពីការព្រមព្រៀងទទួលយកការធ្វើមជ្ឈត្តការ។[១៨១] ឧទាហរណ៍គូភាគីអាចផ្ញើអ៊ីមែល ឬលិខិតឆ្លើយឆ្លងជូនគ្នា ដែលបញ្ជាក់ថាពួកគេព្រមព្រៀងទទួលយកដំណោះស្រាយវិវាទរបស់ផងខ្លួនដោយមជ្ឈត្តការ ប៉ុន្តែខកខានមិនបានបញ្ចូលខចែងនោះក្នុងកិច្ចព្រមព្រៀងរបស់ពួកគេ។ យោងតាមមាត្រា៧ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ការសរសេរលិខិតឆ្លើយឆ្លងបែបនេះអាចមានភាពគ្រប់គ្រាន់ក្នុងការធ្វើជាកិច្ចព្រម ព្រៀងទទួលយកដំណោះស្រាយដោយមជ្ឈត្តការបាន។

### ១. *ខចែងស្តីពីមជ្ឈត្តការជាមូលដ្ឋាននៅក្នុងកិច្ចសន្យា*

ជាទូទៅ គូភាគីយល់ព្រមទទួលយកដំណោះស្រាយដោយមជ្ឈត្តការ នៅពេលចុះហត្ថលេខាលើកិច្ចសន្យាដើមរបស់ខ្លួន។ ខាងក្រោម គឺជាខចែងស្តីពីមជ្ឈត្តការស្តង់ដារ ដែលធ្វើឡើងដោយសមាគមមជ្ឈត្តការអាមេរិក(AAA)។ ខចែងស្តង់ដារនេះ និងខចែងស្តង់ដារផ្សេងទៀត ដែលលើកឡើងមកនេះ គ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ ហើយគូភាគីមានសេរីភាពពេញលេញក្នុងការបង្កើតខចែងស្តីពីមជ្ឈត្តការផ្ទាល់របស់ខ្លួន។

**ខចែងស្តីពីមជ្ឈត្តការរបស់សមាគមមជ្ឈត្តការអាមេរិក**

*រាល់ភាពចម្រូងចម្រាស់ ឬការទាមទារណាមួយដែលកើតចេញពី ឬទាក់ទងនឹងកិច្ចសន្យានេះ ឬការរំលោភនៃកិច្ចសន្យានេះ នឹងត្រូវដោះស្រាយតាមមជ្ឈត្តការ ដែលគ្រប់គ្រងដោយសមាគមមជ្ឈត្តការអាមេរិក ស្របតាមវិធានមជ្ឈត្តការផ្នែកពាណិជ្ជកម្ម [ឬផ្នែកដទៃទៀត] របស់សមាគមនេះ ហើយសាលក្រមលើមជ្ឈត្តវិនិច្ឆ័យដែលចេញដោយមជ្ឈត្តករ អាចធ្វើឡើងនៅក្នុងតុលាការណាមួយដែលមានយុត្តាធិការក្នុងការងារនេះ។*

ក្នុងឧទាហរណ៍នេះ គូភាគីបានព្រមព្រៀងដោះស្រាយវិវាទរបស់ខ្លួនតាមវិធានមជ្ឈត្តការដែលគ្រប់គ្រងដោយសមាគមមជ្ឈត្តការអាមេរិក។

---

[១៧៩] សូមមើលកំណត់សម្គាល់លេខ ១០១ *ខាងលើ*។

[១៨០] *ដូចមុន* មាត្រា ៧។

[១៨១] *ដូចមុន* មាត្រា ៧ (២)។

ប្រសិនបើគូភាគី **ពុំមាន** កិច្ចព្រមព្រៀងស្តីពីមជ្ឈត្តការនោះទេ ប៉ុន្តែមានវិវាទកើតឡើង ហើយពួកគេចង់ដោះស្រាយវិវាទនេះតាមរយៈមជ្ឈត្តការនោះ សមាគមមជ្ឈត្តការអាមេរិកផ្តល់នូវខចែងស្តង់ដារដូចខាងក្រោម:

**ខចែងស្តីពីមជ្ឈត្តការក្រោយពេលមានវិវាទ**

*យើងខ្ញុំទាំងអស់គ្នា ជាគូភាគីដែលមានចុះហត្ថលេខាខាងក្រោម យល់ព្រមទទួលយកដំណោះស្រាយតាមរយៈមជ្ឈត្តការ ដែលគ្រប់គ្រងដោយសមាគមមជ្ឈត្តការអាមេរិក ស្របតាមវិធានមជ្ឈត្តការផ្នែកពាណិជ្ជកម្ម [ឬផ្នែកដទៃទៀត] លើទំនាស់ដូចខាងក្រោម:*

*[សូមរៀបរាប់ដោយសង្ខេប] ។ យើងខ្ញុំយល់ព្រមបន្ថែមទៀតថា សាលក្រមរបស់តុលាការដែលមានយុត្តាធិការ អាចធ្វើឡើងចំពោះមជ្ឈត្តវិនិច្ឆ័យនេះបាន ។*

## ២. *ការតាក់តែងខចែងស្តីពីមជ្ឈត្តការ*

ដើម្បីដោះស្រាយវិវាទរបស់ខ្លួនដោយមជ្ឈត្តការ គូភាគីត្រូវមានខចែងស្តីពីមជ្ឈត្តការដែលមានសុពលភាព និងអាចអនុវត្តបាននៅក្នុងកិច្ចសន្យារបស់ខ្លួន ។ ដើម្បីឱ្យខចែងនោះមានសុពលភាព ខចែងនោះត្រូវសរសេរជាលាយលក្ខណ៍អក្សរ ហើយមានភាពច្បាស់លាស់ ។ ប្រការនេះមានន័យថា ខចែងស្តីពីមជ្ឈត្តការត្រូវបញ្ជាក់ច្បាស់ថា គូភាគីចង់ដោះស្រាយដោយមជ្ឈត្តការ ក្នុងករណីមានវិវាទកើតឡើង ។ ប៉ុន្តែ ក្រៅពីលក្ខខណ្ឌតម្រូវសាមញ្ញទាំងនេះ ខចែងនេះក៏ត្រូវស្ថិតនៅលើគូភាគី ឬមេធាវីរបស់ពួកគេ ដែលជាអ្នកបន្ថែមចំណុចលម្អិតសំខាន់ៗ ។ ក្នុងស្ថានភាពមួយចំនួន ខចែងស្តីពីមជ្ឈត្តការជាមូលដ្ឋាន ដែលបានរៀបរាប់ដូចខាងលើ គឺមានភាពគ្រប់គ្រាន់ហើយ ។ ប៉ុន្តែ ក្នុងស្ថានភាពផ្សេងទៀត ចំណុចលម្អិតបន្ថែមទៀតអាចត្រូវការជាចាំបាច់ ។ ក្នុងករណីទាំងពីរនេះ ខចែងស្តីពីមជ្ឈត្តការគឺមានសារៈសំខាន់យ៉ាងខ្លាំងក្នុងដំណោះស្រាយដោយមជ្ឈត្តការដ៏ជោគជ័យ ។

នៅពេលកំណត់អំពីចំណុចលម្អិតដែលត្រូវបន្ថែមក្នុងខចែងស្តីពីមជ្ឈត្តការជាមូលដ្ឋាននោះ គូភាគីត្រូវពិចារណាអំពីបញ្ហាគន្លឹះមួយចំនួន ។ បញ្ហាទាំងនេះនឹងកើតឡើងនៅក្នុងដំណើរការមជ្ឈត្តការ (ដែលនឹងត្រូវពិភាក្សាលម្អិតបន្ថែមទៀតដូចខាងក្រោម) ។ មេធាវីដ៏ល្អម្នាក់ត្រូវគិតទុកជាមុនអំពីបញ្ហាទាំងនេះ ហើយនៅក្នុងដំណើរការចុះកិច្ចសន្យាដំបូងត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះបញ្ហាទាំងនេះ ដើម្បីជួយកូនក្តីរបស់ខ្លួនឱ្យមានប្រៀប ប្រសិនបើមានតម្រូវការធ្វើមជ្ឈត្តការ ។ ខាងក្រោម នេះគឺជាសំណួរគន្លឹះដែលត្រូវពិចារណា:

### ក) តើមជ្ឈត្តការនោះគួរភ្ជាប់កាតព្វកិច្ចដែរឬទេ?

ជាទូទៅ ហេតុផលសំខាន់មួយដែលគូភាគីជ្រើសរើសដំណោះស្រាយដោយមជ្ឈត្តការ គឺដើម្បីទទួលបាននូវវិធីសាស្ត្រដោះស្រាយវិវាទមួយដែលឆាប់រហ័ស និងមានប្រសិទ្ធភាព ។ ប្រសិនបើមជ្ឈត្តការមិនចងភ្ជាប់កាតព្វកិច្ចទេនោះ គ្មានភាគីណាមួយអាចទទួលបានមជ្ឈត្តវិនិច្ឆ័យស្ថាពរឡើយ ហើយមជ្ឈត្តវិនិច្ឆ័យនោះ គ្រាន់តែបំពេញមុខងារដូចជាអនុសាសន៍ដែលផ្តល់ឱ្យ នៅពេលបញ្ចប់ដំណើរសន្ទានកម្មដូច្នោះដែរ ។ នៅក្នុងករណីនេះ ដំណើរការមិនអាចមានភាពឆាប់រហ័ស និងប្រសិទ្ធភាពឡើយ ។

នេះគឺជាឧទាហរណ៍មួយនៃខចែងដែលបញ្ជាក់ច្បាស់ថា មជ្ឈត្តការគឺមានការចងភ្ជាប់កាតព្វកិច្ច ។

**មជ្ឈត្តការចងភ្ជាប់កាតព្វកិច្ច**

*រាល់វិវាទដែលកើតចេញពី ឬទាក់ទងនឹងកិច្ចសន្យានេះ ត្រូវបញ្ជូនទៅនៅគណៈកម្មការមជ្ឈត្តការផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្មអន្តរជាតិចិន ដើម្បីធ្វើការដោះស្រាយតាមរយៈមជ្ឈត្តការ ដែលនឹងត្រូវធ្វើឡើងស្របតាមវិធានមជ្ឈត្តការរបស់គណៈកម្មការនេះដែលមានជាធរមាន ក្នុងពេលធ្វើការដោះស្រាយវិវាទនោះ។ មជ្ឈត្តវិនិច្ឆ័យ គឺជាសេចក្ដីបង្គាប់ស្ថាពរ និង ចងភ្ជាប់កាតព្វកិច្ចចំពោះគូភាគីទាំងពីរ។*

**៩) តើមជ្ឈត្តការនោះគួរតែជាមជ្ឈត្តការមានការគ្រប់គ្រង ឬមជ្ឈត្តការពិសេស?**

មជ្ឈត្តការពិសេស ផ្ដល់ជូនគូភាគីនូវភាពបត់បែនច្រើនក្នុងការបង្កើតនីតិវិធី និងវិធាន ដើម្បីតម្រូវនឹងវិវាទនោះ។ ទោះបីជាយ៉ាងណា មជ្ឈត្តការមានការគ្រប់គ្រង ជាទូទៅត្រូវបានជ្រើសរើសយកមកធ្វើការដោះស្រាយ ដោយសារតែមជ្ឈត្តការមានការគ្រប់គ្រងនេះមានការគាំទ្រទូលំទូលាយ និង ផ្ដល់ជម្រើសច្រើនទៅលើមជ្ឈត្តករដែលនឹងធ្វើការដោះស្រាយជូន ព្រមទាំងវិធានទាំងឡាយដែលគូភាគីអាចជ្រើសរើសបានយ៉ាងឆាប់រហ័ស។ នៅពេលចុះកិច្ចសន្យា គូភាគីជាច្រើនចង់សន្សំសំចៃពេលវេលា និងកិច្ចខិតខំប្រឹងប្រែង ហើយក៏ ជ្រើសរើសយកមជ្ឈមណ្ឌលមជ្ឈត្តការចម្បងណាមួយដែលមានការគ្រប់គ្រង។

**ឥ) តើមជ្ឈត្តការនឹងធ្វើឡើងនៅកន្លែងណា?**

ទីកន្លែងសម្រាប់ដំណើរការមជ្ឈត្តការមានសារៈសំខាន់ ជាពិសេសចំពោះវិវាទអន្តរជាតិ។ ទីកន្លែងអាចកំណត់អំពីថ្លៃចំណាយនៃដំណើរការដោះស្រាយវិវាទ។ ប្រសិនបើគូភាគី សាក្សី ភស្ដុតាង ឯកសារ ។ល។ នៅឆ្ងាយ ដំណើរការដោះស្រាយវិវាទនឹងមានតម្លៃថ្លៃខ្លាំង។ ទីកន្លែងក៏អាចកំណត់ផងដែរថា តើតុលាការជាតិណាមួយនឹងមានយុត្តាធិការទៅលើដំណើរការមជ្ឈត្តការនោះ។ លើសពីនេះទៀត គូភាគីត្រូវពិចារណាថាតើមានបណ្ដុំមជ្ឈត្តករដែលមានសមត្ថភាព និងអព្យាក្រឹត នៅកន្លែងនោះដែរឬទេ។ ជាចុងក្រោយ ទីកន្លែងអាចមានឥទ្ធិពលលើការអនុវត្តមជ្ឈត្តវិនិច្ឆ័យ។ ប្រសិនបើទីកន្លែងស្ថិតនៅក្នុងប្រទេសដែលមិនមែនជាហត្ថលេខីនៃអនុសញ្ញាក្រុងញូវយ៉ក មជ្ឈត្តវិនិច្ឆ័យនោះអាចមានបញ្ហាក្នុងការដាក់ឱ្យអនុវត្ត។ ខាងក្រោមនេះគឺជាឧទាហរណ៍មួយនៃខចែង ដែលចែងអំពីទីកន្លែងនៃមជ្ឈត្តការៈ

**ទីកន្លែងមជ្ឈត្តការ**

*រាល់ទំនាស់ ឬការទាមទារដែលកើតចេញពី ឬទាក់ទងនឹងកិច្ចសន្យានេះ ឬការរំលោភលើកិច្ចសន្យានេះ ត្រូវដោះស្រាយដោយមជ្ឈត្តការ ដែលគ្រប់គ្រងដោយមជ្ឈមណ្ឌលដោះស្រាយវិវាទផ្នែកពាណិជ្ជកម្មអន្តរជាតិអាស៊ី/ប៉ាស៊ីហ្វិក នៃសមាគមមជ្ឈត្តការអាមេរិក ប្រចាំនៅទីក្រុងសាន់ហ្វ្រាន់ស៊ីស្កូ ស្របតាមវិធានមជ្ឈត្តការផ្នែកពាណិជ្ជកម្ម [ឬផ្នែកដទៃទៀត] ហើយសាលក្រមស្ដីពីមជ្ឈត្តវិនិច្ឆ័យដែលចេញដោយមជ្ឈត្តករ អាចធ្វើឡើងក្នុងតុលាការណាដែលមានយុត្តាធិការក្នុងការងារនេះ។*

**ខ) ផែនដីសាចញ្ញាស្តីពីទីកន្លែងមជ្ឈត្តការ**

*ទីកន្លែងនៃមជ្ឈត្តការ នឹងត្រូវធ្វើឡើងនៅក្នុងក្រុងភ្នំពេញប្រទេសកម្ពុជា។*

**ឃ) តើត្រូវជ្រើសរើសមជ្ឈត្តករប៉ុន្មាននាក់ និងប្រើប្រាស់វិធីសាស្ត្រអ្វីក្នុងការជ្រើសរើស?**

សំណួរដ៏មានសារៈសំខាន់បំផុតមួយគឺថា តើនរណានឹងធ្វើជាមជ្ឈត្តករ។ ជាធម្មតា គូភាគីត្រូវយល់ព្រមឱ្យមាន មជ្ឈត្តករម្នាក់ ឬបីនាក់។ វិធីសាស្ត្រស្តង់ដាររបស់សមាគមមជ្ឈត្តការអាមេរិក គឺត្រូវផ្តល់ដល់ភាគីនីមួយៗនូវបញ្ជីឈ្មោះ មជ្ឈត្តករដែលមានការឯកភាពពីសមាគមមជ្ឈត្តការអាមេរិក និង អនុញ្ញាតឱ្យភាគីនីមួយៗគូសចោលនូវឈ្មោះមជ្ឈត្តករ ណាដែលមិនអាចទទួលយកបាន។ ឈ្មោះមជ្ឈត្តករដែលនៅសល់នឹងត្រូវរៀបតាមលំដាប់ថ្នាក់។ ហើយបន្ទាប់មក សមាគមមជ្ឈត្តការអាមេរិកជ្រើសរើសវេទិកា មជ្ឈត្តកម្មមួយផ្អែកតាមការជ្រើសរើសរបស់គូភាគី។ វិធីសាស្ត្រទូទៅ មួយទៀត គឺត្រូវអនុញ្ញាតឱ្យភាគីនីមួយៗជ្រើសរើសមជ្ឈត្តករម្នាក់មួយៗ ហើយឱ្យមជ្ឈត្តករទាំងពីរនាក់នោះជ្រើសរើស មជ្ឈត្តករទីបីម្នាក់។ ផ្អែកតាមការជ្រើសរើសនោះ គូភាគីក៏អាចកំណត់បុគ្គលជាក់លាក់ម្នាក់នៅក្នុងខចែងស្តីពីមជ្ឈត្តការ ផងដែរ។ ការធ្វើដូច្នេះមានភាពប្រថុយណាស់ព្រោះបុគ្គលនោះ អាចរកមិនបាន ប្រសិនបើវិវាទកើតឡើងជាច្រើនឆ្នាំ ក្រោយមក។ គូភាគីក៏អាចជ្រើសរើសធ្វើការកំណត់ប្រភេទបុគ្គលដែលត្រូវធ្វើជាមជ្ឈត្តករផងដែរ ដូចជាថា ជាចៅក្រម ឬ ពលរដ្ឋកម្ពុជា។

ខាងក្រោមនេះ គឺជាឧទាហរណ៍មួយចំនួន :

**ការជ្រើសរើសមជ្ឈត្តករ**

*មជ្ឈត្តករដែលជ្រើសរើសដោយភាគីប្តឹង និងមជ្ឈត្តករដែលជ្រើសរើសដោយភាគីឆ្លើយតបត្រូវ ជ្រើសរើសមជ្ឈត្តករអព្យាក្រឹតទីបីម្នាក់ ក្នុងរយៈពេលដប់ថ្ងៃក្រោយពេលតែងតាំង។ ក្នុងករណីដែល ពួកគេមិនអាចធ្វើដូច្នេះបាន គូភាគី ឬមេធាវីរបស់ខ្លួន អាចស្នើឱ្យសមាគមមជ្ឈត្តការអាមេរិកធ្វើការ តែងតាំងមជ្ឈត្តករអព្យាក្រឹតទីបីបាន។ មុនពេលចាប់ផ្តើមសាវនាការ មជ្ឈត្តករនីមួយៗដែលបាន ទទួលការតែងតាំងត្រូវធ្វើសច្ចាប្រណិធាន ឬ សន្យាថាខ្លួននឹងមិនលម្អៀងឡើយ។*

ឬ

*ក្នុងករណីដែលតម្រូវឱ្យមានមជ្ឈត្តការជាចាំបាច់ [ឈ្មោះរបស់មជ្ឈត្តករជាក់លាក់ណាមួយ] ត្រូវធ្វើជា មជ្ឈត្តករ។*

ឬ

*មជ្ឈត្តករត្រូវជាគណនេយ្យករសាធារណៈដែលមានការទទួលស្គាល់ច្បាស់លាស់។*

ឬ

*មជ្ឈត្តករត្រូវជាពលរដ្ឋ [ ឬជនជាតិ ] នៃប្រទេសកម្ពុជា ។*

ឬ

*មជ្ឈត្តករ <u>មិន</u> ត្រូវជាពលរដ្ឋ [ ឬជនជាតិ ] នៃប្រទេសកម្ពុជា ឬប្រទេសវៀតណាមឡើយ ។*

**ង) តើគូភាគីគួរធ្វើការចរចា ឬសន្ទានកម្មជាមុនសិនដែរឬទេ?**

ពេលខ្លះ គូភាគីត្រូវព្យាយាមធ្វើការចរចា ឬធ្វើសន្ទានកម្មជាមុនសិន មុនពេលឈានដល់ដំណើរការមជ្ឈត្តការ ។ គូភាគីអាចនឹងទទួលផលប្រយោជន៍ពីកិច្ចខិតខំប្រឹងប្រែងរបៀបនេះ មុនពេលដាក់វិវាទនេះទៅកាន់ដំណើរការដែលប្រកបដោយភាពបដិបក្ខនឹងគ្នា ដូចជាមជ្ឈត្តការនេះជាដើម ។ ខាងក្រោមនេះ គឺជាឧទាហរណ៍មួយនៃខដែលចែងអំពីការធ្វើការចរចាជាមុន និងធ្វើមជ្ឈត្តការជាក្រោយៈ

**ខចែងស្តីពីការចរចា/មជ្ឈត្តការ**

*ក្នុងករណីមានវិវាទ ការទាមទារ បញ្ហា ឬការមិនចុះសម្រុងគ្នាដែលកើតចេញពី ឬទាក់ទងនឹងកិច្ចព្រមព្រៀងនេះ ឬមានការរំលោភកិច្ចព្រមព្រៀងនោះ គូភាគីត្រូវខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាពដើម្បីដោះស្រាយវិវាទ ការទាមទារ បញ្ហា ឬការមិនចុះសម្រុងគ្នានោះ ។ ដើម្បីធ្វើដូច្នេះបាន ពួកគេត្រូវធ្វើការពិគ្រោះយោបល់ និងចរចាជាមួយគ្នាដោយសុទ្ធចិត្ត និងធ្វើការទទួលស្គាល់អំពីផលប្រយោជន៍របស់ខ្លួនទៅវិញទៅមក ព្យាយាមធ្វើឱ្យសម្រេចឈានទៅដល់ដំណោះស្រាយមួយដែលត្រឹមត្រូវ និងមានសមធម៌ និងដែលអាចបំពេញចិត្តភាគីទាំងពីរបាន ។ ប្រសិនបើពួកគេមិនអាចសម្រេចបាននូវដំណោះស្រាយនោះបានទេ ក្នុងរយៈពេល៦០ថ្ងៃបន្ទាប់ពីភាគីម្ខាងបានជូនដំណឹងដល់ភាគីម្ខាងទៀត រាល់វិវាទ ការទាមទារ បញ្ហា ឬភាពខ្វែងគំនិតគ្នាទាំងអស់ ត្រូវដោះស្រាយជាចុងក្រោយដោយមជ្ឈត្តការ ដែលគ្រប់គ្រងដោយសមាគមមជ្ឈត្តការអាមេរិក ស្របតាមបញ្ញត្តិនៃវិធានមជ្ឈត្តការពាណិជ្ជកម្ម ។*

វិធីម្យ៉ាងទៀត គូភាគីក៏អាចធ្វើសន្ទានកម្មជាមុនដែរ ហើយប្រសិនបើសន្ទានកម្មនោះមិនទទួលបានជោគជ័យ ទើបចាប់ផ្តើមធ្វើមជ្ឈត្តការជាក្រោយ ។ ច្បាប់កម្ពុជាស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ពិចារណាយ៉ាងច្បាស់អំពីលទ្ធភាពនេះ នៅក្នុងមាត្រា៣៨ ដែលស្ថិតនៅក្រោមផ្នែកស្តីពី "ដំណោះស្រាយ" ។[១៨២] សមាគមមជ្ឈត្តការអាមេរិក ផ្តល់នូវខចែងស្តង់ដារដូចខាងក្រោមសម្រាប់ យុទ្ធសាស្ត្រនេះ ពេលខ្លះហៅថា "មជ្ឈត្តការសន្ទាន" ( Med-Arb ):

---

[១៨២] *ដូចមុន* មាត្រា ៣៨ ។

**មជ្ឈត្តការសន្ទាន**

*ប្រសិនបើមានវិវាទមួយកើតចេញពី ឬទាក់ទងនឹងកិច្ចសន្យានេះ ឬមានការរំលោភនឹងកិច្ចសន្យានេះ ហើយប្រសិនបើវិវាទមិនអាចដោះស្រាយបានតាមរយៈការពិភាក្សាដោយផ្ទាល់ទេ គូភាគីយល់ព្រម ព្យាយាមដោះស្រាយវិវាទនោះជាដំបូងដោយសន្ទានកម្ម ដែលគ្រប់គ្រងដោយសមាគមមជ្ឈត្តការ អាមេរិក ស្របតាមនីតិវិធីសន្ទានកម្មផ្នែកពាណិជ្ជកម្ម មុនពេលឈានទៅដល់ការធ្វើមជ្ឈត្តការ។ រាល់ការមិនចុះសម្រុងគ្នា ឬការទាមទារដែលមិនអាចដោះស្រាយបានដែលកើតចេញពី ឬទាក់ទង នឹងកិច្ចសន្យានេះ ឬការរំលោភកិច្ចសន្យានេះ ត្រូវដោះស្រាយដោយមជ្ឈត្តការដែលគ្រប់គ្រងដោយ សមាគមមជ្ឈត្តការអាមេរិក ស្របតាមវិធានមជ្ឈត្តការពាណិជ្ជកម្ម ហើយសាលក្រមស្ដីពីមជ្ឈត្តវិនិច្ឆ័យ ដែលចេញដោយមជ្ឈត្តករ អាចធ្វើឡើងនៅក្នុងតុលាការដែលមានយុត្តាធិការក្នុងការងារនេះ។ ប្រសិនបើគូភាគីទាំងអស់នៃវិវាទយល់ព្រម សន្ទានការីដែលបានដឹកនាំធ្វើសន្ទានកម្មលើវិវាទនោះ អាចធ្វើជាមជ្ឈត្តករបាន។*

**ច) តើវេទិកាមជ្ឈត្តកម្មនឹងមានអំណាចក្នុងការចេញវិធានការបណ្ដោះអាសន្នដែរឬទេ?**

ពេលខ្លះ គូភាគីនឹងចង់ឱ្យវេទិកាមជ្ឈត្តកម្មចេញវិធានការបណ្ដោះអាសន្នឬវិធានការបឋមមុនពេល កាត់សេចក្ដីលើ វិវាទទាំងមូល។ ឧទាហរណ៍ ភាគីម្ខាងចង់ឱ្យភាគីម្ខាងទៀតឈប់បោះពុម្ពឯកសារមិនពិត ឬដែលនាំឱ្យមានការ ភ័ន្តច្រឡំ។ នៅក្នុងឧទាហរណ៍នេះ ប្រសិនបើគូភាគីត្រូវរង់ចាំរយៈពេលប្រាំមួយខែ ដើម្បីកាត់សេចក្ដីលើវិវាទទាំងស្រុង នោះវាអាចនឹងមានការយឺតយ៉ាវជ្រុល។ ដូច្នេះ ដើម្បីទប់ស្កាត់ការខូចខាតដែលនឹងមានជាបន្ត វេទិកាមជ្ឈត្តកម្មអាចបង្គាប់ ឱ្យភាគីនោះឈប់បោះពុម្ពឯកសារទាំងនោះភ្លាមៗ (ពេលខ្លះគេហៅថា "សេចក្ដីបង្គាប់") រហូតដល់វេទិកាមជ្ឈត្តកម្មអាច ធ្វើការសម្រេចលើអង្គហេតុទាំងស្រុង។

**វិធានការបណ្ដោះអាសន្ន**

*ភាគីនីមួយៗអាចដាក់ពាក្យស្នើសុំទៅមជ្ឈត្តករ ដើម្បីស្វែងរកការចេញសេចក្ដីបង្គាប់ រហូតមជ្ឈត្តវិនិច្ឆ័យ ត្រូវបានសម្រេចឡើង ឬការមិនចុះសម្រុងគ្នាត្រូវបានដោះស្រាយ។ ដោយមិនបោះបង់ ចោលនូវវិធី ដោះស្រាយតាមរយៈកិច្ចព្រមព្រៀងនេះ ភាគីនីមួយៗក៏អាចស្នើសុំការលើកលែងលើលក្ខខណ្ឌតាម កិច្ចព្រមព្រៀងនេះ ឬស្វែងរកការចេញដីកាបន្ទាន់ ឬដីកាបណ្ដោះអាសន្នពីតុលាការណាដែលមាន យុត្តាធិការ ដែលមានភាពចាំបាច់ ដើម្បីការពារសិទ្ធិ ឬទ្រព្យសម្បត្តិរបស់ភាគីនោះ ក្នុងខណៈពេល រង់ចាំបង្កើតវេទិកាមជ្ឈត្តកម្ម (ឬខណៈពេលរង់ចាំការសម្រេចសេចក្ដី លើការមិនចុះសម្រុងគ្នានោះ ដែលនឹងត្រូវធ្វើឡើងដោយវេទិកាមជ្ឈត្តកម្ម)។*

### ឆ) *តើគូភាគីអាចរួមបញ្ចូលមជ្ឈត្តការរបស់ពួកគេជាមួយរបស់អ្នកដទៃបានដែរឬទេ ?*

នៅក្នុងករណីធំៗ និងស្មុគស្មាញ ជាញឹកញាប់ តែងមានភាគីច្រើនជាងពីរមានការជាប់ពាក់ព័ន្ធ។ ឧទាហរណ៍ នៅក្នុងករណីពាក់ព័ន្ធនឹងការសាងសង់ គូភាគីនៃវិវាទអាចរាប់បញ្ចូលទាំងម្ចាស់អចលនទ្រព្យ ធនាគារដែលផ្តល់ប្រាក់កម្ចីឱ្យកម្មសិទ្ធិករ ក្រុមហ៊ុនម៉ៅការសំណង់ទូទៅ ក្រុមហ៊ុនម៉ៅការសំណង់បន្ត ដែលត្រូវបានជួលដោយក្រុមហ៊ុនម៉ៅការទូទៅ អ្នកផ្គត់ផ្គង់សម្ភារៈ និងអាចជាក្រុមហ៊ុនដែលមានផែនការជួលទីតាំងពីកម្មសិទ្ធិករក្រោយពេលសាងសង់ចប់រួចផងដែរ ។ នៅក្នុង ស្ថានភាពទាំងនេះការប្រមូលផ្តុំវិវាទបញ្ចូលគ្នា នឹងធ្វើឱ្យគូភាគីចំណេញពេលវេលា និងប្រាក់កាស ។

**ការប្រមូលផ្តុំ**

*កម្មសិទ្ធិករ ក្រុមហ៊ុនម៉ៅការ និងក្រុមហ៊ុនម៉ៅការបន្តទាំងអស់ ជាពិសេសក្រុមហ៊ុនម៉ៅការជំនាញ អ្នកផ្គត់ផ្គង់សម្ភារៈ វិស្វករ អ្នកគូរប្លង់ ស្ថាបត្យករ អ្នកផ្តល់ប្រាក់កម្ចីផ្នែកសំណង់ ក្រុមហ៊ុនទំនាក់ទំនង និងភាគីផ្សេងទៀត ដែលពាក់ព័ន្ធនឹងការសាងសង់រចនាសម្ព័ន្ធនេះ នឹងត្រូវបានចងភ្ជាប់កាតព្វកិច្ចទៅវិញទៅមក ដោយខចែងស្តីពីមជ្ឈត្តការនេះ ក្នុងករណីដែលពួកគេបានចុះហត្ថលេខាលើកិច្ច-សន្យានេះ ឬលើកិច្ចសន្យាដែលមានបញ្ចូលកិច្ចសន្យានេះតាមរយៈការយោង ឬចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្សេងទៀតដែលត្រូវចងភ្ជាប់កាតព្វកិច្ចតាមខចែងស្តីពីមជ្ឈត្តការនេះ។ ភាគីនីមួយៗទាំងនេះ យល់ព្រមថាខ្លួនអាចនឹងចូលរួមជាភាគីបន្ថែម នៅក្នុងដំណើរការមជ្ឈត្តការដែលពាក់ព័ន្ធដោយភាគីផ្សេងទៀត យោងតាមកិច្ចព្រមព្រៀងនេះ។ ប្រសិនបើមានមជ្ឈត្តការច្រើនជាងមួយបានចាប់ផ្តើមក្រោមកិច្ចព្រមព្រៀងនេះ ហើយភាគីណាមួយអះអាងថា មានមជ្ឈត្តការពីរ ឬច្រើនមានការពាក់ព័ន្ធយ៉ាងខ្លាំង ហើយថាបញ្ហាទាំងនោះត្រូវតែធ្វើសវនាការនៅក្នុងដំណើរការតែមួយ មជ្ឈត្តករដែលជ្រើសរើសឡើងនៅក្នុងបណ្តឹងទីមួយ ត្រូវកំណត់ថាតើដំណើរការនោះត្រូវរួមបញ្ចូលគ្នា ដើម្បីដាក់ជូនមជ្ឈត្តករនោះ (ទាំងនោះ)ដែរឬទេ ដើម្បីជាប្រយោជន៍ដល់យុត្តិធម៌ និងប្រសិទ្ធភាព។*

### ជ) តើនឹងមានការតម្រូវឱ្យគូភាគីបង្ហាញព័ត៌មានក្នុងកម្រិតណា?

នៅក្នុងប្រព័ន្ធតុលាការមួយចំនួន ដូចជានៅក្នុងសហរដ្ឋអាមេរិកជាដើម ការបង្ហាញព័ត៌មានលម្អិតមុនសវនាការ ត្រូវបានតម្រូវចំពោះគូភាគី ដូចជាឯកសារ និងសេចក្តីអំណះអំណាងរបស់សាក្សី និងភាគីវិវាទផ្ទាល់។ នៅក្នុងប្រព័ន្ធច្បាប់ Common Lawគេហៅដំណើរការនេះថា "ការផ្លាស់ប្តូរពត៌មាន" ។ ប៉ុន្តែ តាមប្រព័ន្ធច្បាប់ស៊ីវិលដូចជានៅប្រទេសបារាំងជាដើម លក្ខខណ្ឌតម្រូវក្នុងការចែករំលែកព័ត៌មានមានលក្ខណៈរឹតត្បិត ជាង។ ស្រដៀងគ្នានេះនៅក្នុងវិធានមជ្ឈត្តការភាគច្រើន លក្ខខណ្ឌតម្រូវនៃការបង្ហាញព័ត៌មានចេញមុនសវនាការក៏ មានភាពរិតត្បិតដែរ។ ទោះជាយ៉ាងនេះក្តី គូភាគីអាចក៏កំណត់ពីកម្រិតនៃការបង្ហាញព័ត៌មានមុនសវនាការ ដែលពួកគេ ចង់បានដែរ ។

## ការបង្ហាញព័ត៌មាន

*អនុលោមតាមចរិតមជ្ឈត្តការដែលមានផាពឆាប់រហ័ស និងប្រសិទ្ធភាព ភាគីនីមួយៗនឹងផ្តល់ភ្លាមៗ ដល់ភាគីម្ខាងទៀតនូវសំណៅចម្លងនៃឯកសារ [ដែលទាក់ទងនឹងបញ្ហាដែលកើតឡើងដោយសារ ការប្តឹងទាមទារ ឬការប្តឹងតប] ទៅតាមសម្ផើជាលាយលក្ខណ៍អក្សររបស់ភាគីម្ខាងទៀត [ដោយ តាមរយៈឯកសារទាំងនេះ ភាគីដែលផ្តល់នឹងប្រើប្រាស់វាដើម្បីគាំទ្រ ឬប្រឆាំងចំពោះការទាមទារ ឬការ តវ៉ាផ្សេងៗ]។ រាល់វិវាទដែលទាក់ទងនឹងពត៌មានដែលបានផ្តល់ ឬការជាប់ពាក់ព័ន្ធ ឬក្របខ័ណ្ឌរបស់ នឹងត្រូវ សម្រេចដោយ [មជ្ឈត្តករ] [ប្រធានវេទិកាមជ្ឈត្តកម្ម] នោះ ហើយការសម្រេចនេះត្រូវមាន លក្ខណៈស្ថាពរ។ ការផ្លាស់ប្តូរព័តិមាននេះ នឹងត្រូវបញ្ចប់ក្នុងរយៈពេល [៤៥] [៦០] ថ្ងៃក្រោយពេល តែងតាំងមជ្ឈត្តករ។*

### ឈ) តើមជ្ឈត្តករអាចដាក់ចេញនូវដំណោះស្រាយអ្វីខ្លះ?

គូភាគីត្រូវពិចារណាមើលថា តើមានដំណោះស្រាយអ្វីជាក់លាក់ដែលពួកគេអាចចង់ឱ្យមជ្ឈត្តករដាក់ចេញ។ ម្យ៉ាង ទៀត ពួកគេក៏ត្រូវពិចារណាផងដែរអំពីដំណោះស្រាយណាមួយដែលពួកគេ**មិន** ចង់ឱ្យមជ្ឈត្តករដាក់ចេញ។

## ដំណោះស្រាយ

*មជ្ឈត្តករនឹងគ្មានសិទ្ធិអំណាចក្នុងការចេញមជ្ឈត្តវិនិច្ឆ័យដែលដាក់ពិន័យ ឬសំណងដទៃទៀត ដែលមិន បានវាស់ពីទំហំនៃការខូចខាតជាក់ស្តែងរបស់ភាគីដែលឈ្នះឡើយ លើកលែងតែមានការតម្រូវដោយ ច្បាប់។*

ឬ

*ទោះជាក្នុងករណីណាក៏ដោយ មជ្ឈត្តវិនិច្ឆ័យនៅក្នុងមជ្ឈត្តការដែលផ្តួចផ្តើមឡើងស្របតាមខចែងនេះ មិនត្រូវមានតម្លៃលើសពី__________ ដុល្លាឡើយ។*

ឬ

*មជ្ឈត្តវិនិច្ឆ័យនៅក្នុងមជ្ឈត្តការដែលផ្តួចផ្តើមឡើងស្របតាមខចែងនេះ ត្រូវកម្រិតត្រឹមសំណងជំងឺចិត្តជា ទឹកប្រាក់ និងមិនត្រូវរាប់បញ្ចូលនូវសេចក្តីបង្គាប់ ឬសេចក្តីណែនាំចំពោះភាគីណាមួយ ផ្សេងពីសេចក្តី ណែនាំឱ្យបង់ប្រាក់ឡើយ។*

ឬ

*ប្រសិនបើមជ្ឈត្តកររកឃើញថាមានការទទួលខុសត្រូវនៅក្នុងមជ្ឈត្តការដែលផ្តួចផ្តើមឡើងក្រោមខចែង នេះ ពួកគេត្រូវចេញមជ្ឈត្តវិនិច្ឆ័យឱ្យសងជំងឺចិត្តក្នុងទឹកប្រាក់ចំនួន________ ដុល្លា។*

### ញ) តើវិធានអ្វីនឹងគ្រប់គ្រងដំណើរការនេះ?

វិធាននីតិវិធីគឺស្ថិតនៅលើគូភាគីជាអ្នកជ្រើសរើសទាំងស្រុង។ គូភាគីអាចតាក់តែងវិធានផ្ទាល់របស់ខ្លួន ប៉ុន្តែករណីបែបនេះមិនសូវមានឡើយ ដោយសារតែកម្រិតនៃការខិតខំប្រឹងប្រែងដែលកិច្ចការនេះតម្រូវ និងដោយសារតែមជ្ឈមណ្ឌលមជ្ឈត្តការភាគច្រើន បានបង្កើតនីតិវិធីជាច្រើនសម្រាប់ឱ្យជ្រើសរើស។ មជ្ឈមណ្ឌលមជ្ឈត្តការភាគច្រើនក៏នឹងអនុញ្ញាតឱ្យគូភាគីប្រើប្រាស់វិធានរបស់មជ្ឈមណ្ឌលមជ្ឈត្តការផ្សេងដែរ។ ឧទាហរណ៍ សមាគមមជ្ឈត្តការអាមេរិកនឹងអនុញ្ញាតឱ្យគូភាគីជ្រើសរើសយកសមាគមមជ្ឈត្តការអាមេរិកធ្វើជាអ្នកគ្រប់គ្រងប៉ុន្តែប្រើវិធានមជ្ឈត្តការគម្រូរបស់ UNCITRAL បាន។ គូភាគីក៏អាចកែប្រែនីតិវិធីទាំងនេះខ្លះដើម្បីឱ្យត្រូវគ្នានឹងតម្រូវការពិសេសរបស់ខ្លួន ៖ ឧទាហរណ៍ តម្រូវការនៃល្បឿនដំណើរជាដើម។

**វិធាននីតិវិធីដែលគ្រប់គ្រង**

*រាល់ការមិនចុះសម្រុងគ្នា ឬការទាមទារដែលកើតចេញពី ឬទាក់ទងនឹងកិច្ចសន្យានេះ ឬរាល់ការរំលោភលើកិច្ចសន្យានេះ នឹងត្រូវដោះស្រាយដោយមជ្ឈត្តការ ដែលគ្រប់គ្រងដោយសមាគមមជ្ឈត្តការអាមេរិកស្របតាមវិធានមជ្ឈត្តការឧស្សាហកម្មសំណង់របស់សមាគម ហើយសាលក្រមអំពីមជ្ឈត្តវិនិច្ឆ័យដែល ចេញដោយមជ្ឈត្តករអាចធ្វើបាននៅក្នុងតុលាការដែលមានយុត្តាធិការក្នុងការងារនេះ។*

### ដ) តើភាសាអ្វីនឹងត្រូវប្រើនៅក្នុងដំណើរការមជ្ឈត្តការនេះ?

នៅក្នុងកិច្ចសន្យាដែលមានការចូលរួមពីគូភាគីអន្តរជាតិ ការបញ្ចូលបញ្ញត្តិដែលចែងអំពីភាសាដែលនឹងត្រូវប្រើនៅក្នុងដំណើរការមជ្ឈត្តការ ពិតជាមានសារប្រយោជន៍ណាស់។

**ការជ្រើសរើសភាសា**

*មជ្ឈត្តការត្រូវធ្វើឡើងជាភាសាខ្មែរ។ ដោយមានសម្មតិ និងចំណាយថវិការបស់ភាគីម្ខាង ឯកសារ និងសក្ខីកម្មនានាអាចបកប្រែទៅភាសាអង់គ្លេស ឬពីភាសាអង់គ្លេសមកវិញ។*

### ឋ) តើច្បាប់ណាដែលនឹងគ្រប់គ្រងដំណើរការនេះ?

គូភាគីត្រូវកំណត់អំពីច្បាប់ចម្បងដែលនឹងគ្រប់គ្រងដំណើរការនេះ។ គេហៅការកំណត់នេះថា "បញ្ញត្តិស្តីពីជម្រើសនៃច្បាប់"។ វាជាការសំខាន់ដែលគូភាគីត្រូវដឹងអំពីប្រការនេះនៅគ្រប់ពេលដែលចុះកិច្ចសន្យា។ បើមិនដូច្នោះទេ ប្រសិនបើមានវិវាទកើតឡើង បទបញ្ញត្តិរបស់តុលាការ ឬស្ថាប័នមជ្ឈត្តការ ដែលស្តីពីទំនាស់នៃបញ្ញត្តិនឹងត្រូវប្រើដើម្បីកំណត់ថាតើច្បាប់ណាមួយដែលនឹងយកមកអនុវត្ត។ ការធ្វើដូច្នេះបង្កើតនូវភាពមិនច្បាស់លាស់សម្រាប់គូភាគី។ ជាលទ្ធផល បញ្ញត្តិស្តីពីជម្រើសនៃច្បាប់ តែងតែត្រូវបានបញ្ចូលនៅក្នុងកិច្ចសន្យាអន្តរជាតិស្ទើរតែទាំងអស់។

**ជម្រើសនៃច្បាប់**

*កិច្ចព្រមព្រៀងនេះត្រូវគ្រប់គ្រង និង បកស្រាយស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។*

គូភាគីអាចនឹងចង់ពិចារណាអំពីការផ្តល់អំណាចដល់តុលាការឱ្យធ្វើជា*អ្នកសម្រុះសម្រួល* (ធ្វើសេចក្តីសម្រេចដោយផ្អែកលើអ្វីដែលត្រឹមត្រូវ) ជំនួសឱ្យចៅក្រម (ធ្វើសេចក្តីសម្រេចដោយផ្អែកលើច្បាប់) ។

***អ្នកជួយសម្រុះសម្រួល*** *(Amiable Compositeur)*

*ភាគីវិវាទផ្តល់សិទ្ធិអំណាចជាឯកឆន្ទ និងយ៉ាងច្បាស់លាស់ដល់វេទិការមជ្ឈត្តកម្ម ក្នុងការដើរតួនាទីជាអ្នកជួយសម្រុះសម្រួល (តាមគោលការណ៍សមធម៌ [ex aequo et bono]) ។*

ឬ

*វេទិការមជ្ឈត្តកម្មត្រូវដើរតួនាទីជាអ្នកជួយសម្រុះសម្រួល (តាមគោលការណ៍សមធម៌ [ex aequo et bono]) តែក្នុងករណីដែល ភាគីទាំងអស់ផ្តល់ការ អនុញ្ញាតជាលាយលក្ខណ៍អក្សរ យ៉ាងច្បាស់លាស់ និងជាឯកឆន្ទចំពោះតួនាទីបែបនេះតែប៉ុណ្ណោះ ។*

**ឌ) តើដំណើរការនេះត្រូវទុកជាការសម្ងាត់ដែរឬទេ?**

ជាទូទៅ ដំណើរការមជ្ឈត្តការត្រូវបានរក្សាជាការសម្ងាត់។ មជ្ឈមណ្ឌលមជ្ឈត្តការធំៗភាគច្រើន តែងរក្សាការសម្ងាត់។ ប៉ុន្តែ ប្រសិនបើគូភាគីមានការព្រួយបារម្ភខ្លាំងអំពីការសម្ងាត់ ឬប្រសិនបើពួកគេកំពុងតាក់តែងវិធានមជ្ឈត្តការ*ពិសេស* ផ្ទាល់របស់ខ្លួន ពួកគេអាចនឹងចង់សង្កត់ធ្ងន់លើចំណុចនេះនៅក្នុងកិច្ចព្រមព្រៀងរបស់ខ្លួន។

**ការរក្សាការសម្ងាត់**

*លើកលែងតែមានការតម្រូវដោយច្បាប់ទាំង ទាំងភាគី ទាំងមជ្ឈត្តករ មិនអាចផ្សព្វផ្សាយអំពីអត្ថិភាព ខ្លឹមសារ ឬលទ្ធផលនៃមជ្ឈត្តការនេះ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីសំណាក់ភាគីទាំងពីរជាមុនឡើយ ។*

លើសពីនេះទៀត ភាគីវិវាទអាចជ្រើសរើសធ្វើការកែប្រែភាសា ដើម្បីរឹតត្បិតការផ្សព្វផ្សាយកម្មវត្ថុមួយចំនួនដូចជារឹតត្បិតការផ្សព្វផ្សាយការសម្ងាត់ពាណិជ្ជកម្មផ្សេងៗជាដើម។

**ឍ) តើមជ្ឈត្តករត្រូវតែធ្វើការពន្យល់ជាលាយលក្ខណ៍អក្សរដែរឬទេ?**

មជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិភាគច្រើនមានវិធានដែលទាមទារឱ្យវេទិការមជ្ឈត្តកម្មរៀបចំសេចក្តីសម្រេចដែលភ្ជាប់ជាមួយហេតុផល។ ប៉ុន្តែ មជ្ឈមណ្ឌលមជ្ឈត្តការជាតិមួយចំនួនពុំមានលក្ខខណ្ឌតម្រូវបែបនេះទេ។ គុណសម្បត្តិម្យ៉ាងនៃការមានសេចក្តីសម្រេចដោយបញ្ជាក់ហេតុផល គឺថាគូភាគីនឹងយល់កាន់តែច្បាស់អំពីសេចក្តីសម្រេច ហើយ

អាចមិនតវ៉ាអំពីការលម្អៀង ឬភាពអយុត្តិធម៌នៃលទ្ធផល។ គុណវិបត្តិម្យ៉ាង គឺវានឹងក្លាយជាមូលដ្ឋានសក្តានុពលមួយសម្រាប់ការពិនិត្យឡើងវិញរបស់តុលាការ ក្នុងករណីភាគីម្ខាងចង់គេចវេសពីសេចក្តីសម្រេច។

**សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ**

*មជ្ឈត្តវិនិច្ឆ័យត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដែលត្រូវចុះហត្ថលេខាដោយមជ្ឈត្តករភាគច្រើន និង ត្រូវរួមបញ្ចូលទាំងអះអាងដែលបញ្ជាក់អំពីហេតុផលនៃបញ្ញត្តិលើការទាមទារណាមួយផងដែរ។*

ឬ

*មជ្ឈត្តវិនិច្ឆ័យត្រូវមានរួមបញ្ចូលទាំងសេចក្តីសម្រេចលើអង្គហេតុ និងសេចក្តីសន្និដ្ឋានលើអង្គច្បាប់។*

***ណ) តើនរណាជាអ្នកចង់ថ្លៃចំណាយ?***

ជាទូទៅ ភាគីវិវាទត្រូវបង់ថ្លៃមេធាវី និងចំណាយផ្ទាល់របស់ខ្លួន នៅពេលពួកគេទូទាត់វិក្កយបត្រមជ្ឈត្តការ។ ប៉ុន្តែប្រសិនបើគូភាគីចង់លើកទឹកចិត្តឱ្យមានដំណោះស្រាយមុនពេលធ្វើមជ្ឈត្តការ ពួកគេអាចយល់ព្រមប្រគល់ថ្លៃមេធាវី និងថ្លៃចំណាយនិង/ឬវិក្កយបត្រមជ្ឈត្តការឱ្យទៅ"ភាគីឈ្នះ"នៅក្នុងមជ្ឈត្តការ។ ការបញ្ចូលបញ្ញត្តិប្រភេទនេះ នៅក្នុងកិច្ចព្រមព្រៀងមជ្ឈត្តការ ធ្វើឱ្យមជ្ឈត្តការកាន់តែមានភាពប្រថុយប្រថានសម្រាប់គូភាគី និងអាចលើកទឹកចិត្តឱ្យឆាប់មានដំណោះស្រាយ។

**សោហ៊ុយ និងថ្លៃចំណាយផ្សេងៗ**

*ភាគីនីមួយៗត្រូវរ៉ាប់រងសោហ៊ុយ និងការចំណាយផ្ទាល់របស់ខ្លួន ព្រមទាំងចេញចំណែកស្មើគ្នាសម្រាប់ថ្លៃមជ្ឈត្តករ និងកិច្ចការរដ្ឋបាលរបស់មជ្ឈត្តការ។*

ឬ

*មជ្ឈត្តករត្រូវផ្តល់ឱ្យភាគីឈ្នះក្តីនូវសោហ៊ុយ និងការចំណាយផ្សេងៗរបស់ភាគិនោះ ប្រសិនបើមាន និងដូចដែលបានកំណត់ដោយមជ្ឈត្តករ។ "សោហ៊ុយ និងថ្លៃចំណាយ" មានន័យថា រាល់សោហ៊ុយសមហេតុផលទាំងអស់របស់មជ្ឈត្តការនោះ ដែលត្រូវចំណាយមុនពេលចេញមជ្ឈត្តវិនិច្ឆ័យ រួមទាំងថ្លៃឈ្នួលមជ្ឈត្តករ ថ្លៃចំណាយរដ្ឋបាល សោហ៊ុយធ្វើដំណើរ សោហ៊ុយចំណាយផ្ទាល់ខ្លួននានា ដូចជាថ្លៃថតចម្លង និងថ្លៃទូរសព្ទ ប្រាក់ប្រដាប់ក្តីនៅតុលាការ ថ្លៃឈ្នួលសាក្សី និងមេធាវីជាដើម។*

## សំណួរសិក្សាៈ ការតាក់តែងខចែងស្តីពីមជ្ឈត្តការ

អ្នកគឺជាមេធាវីដែលត្រូវបានស្នើសុំឱ្យធ្វើការតាក់តែងខចែងស្តីពីមជ្ឈត្តការ នៅក្នុងករណីដូចខាងក្រោម។ ចូរពិនិត្យមើលឡើងវិញអំពីបញ្ហានីមួយៗក្នុងចំណោមបញ្ហាទាំង១៥ ដែលបានពិភាក្សានៅខាងលើ ហើយចូរកំណត់ថាតើបញ្ហាមួយណា ប្រសិនបើមាន ដែលត្រូវបញ្ចូលនៅក្នុងខចែងស្តីពីមជ្ឈត្តការរបស់អ្នក។ បន្ទាប់មក ចូរតាក់តែងខចែងស្តីពីមជ្ឈត្តការសម្រាប់ករណីនីមួយៗខាងក្រោម។

ក. អ្នកតំណាងឱ្យ វិមាន។ គាត់ចង់ទិញគ្រឿងអលង្ការធ្វើពីមាសតម្លៃ២០.០០០ ដុល្លាពីអ្នកលក់ក្នុងស្រុកម្នាក់។

ខ. អ្នកតំណាងឱ្យ មធុរ៉ា ។ គាត់ចង់លក់ដីរបស់គាត់នៅខេត្តសៀមរាបឱ្យវិនិយោគិនកូរ៉េម្នាក់។

គ. អ្នកតំណាងឱ្យក្រុមហ៊ុន Southern Rice Company ។ ក្រុមហ៊ុននេះចង់ទិញអង្ករក្នុងតម្លៃ ១០.០០០ ដុល្លា ជារៀងរាល់ខែ សម្រាប់រយៈពេលមួយឆ្នាំពីអ្នកលក់ក្នុងស្រុកមួយ ។

ឃ. អ្នកតំណាងឱ្យក្រុមហ៊ុនទូរស័ព្ទបាត់ដំបង។ ក្រុមហ៊ុននេះចង់លក់សេវាទូរសព្ទចល័តឱ្យពលរដ្ឋកម្ពុជា និង កំពុងតាក់តែងកិច្ចសន្យាស្តង់ដារសម្រាប់កិច្ចព្រមព្រៀងផ្តល់សេវានីមួយៗដែលក្រុមហ៊ុនលក់។

ង. អ្នកតំណាងឱ្យក្រុមហ៊ុនជប៉ុនមួយឈ្មោះថា J-Car ។ ក្រុមហ៊ុន J-Car ចង់សាងសង់រោងចក្រមួយកន្លែងនៅក្រុងព្រះសីហនុ។ ក្រុមហ៊ុន J-Car ត្រូវចុះកិច្ចសន្យាម៉ៅការសាងសង់ជាមួយក្រុមហ៊ុនសំណង់ក្នុងស្រុកមួយ។

ច. អ្នកតំណាងឱ្យ ណូរ៉ូ ។ ណូរ៉ូ គឺជាអ្នកចម្រៀងល្បីម្នាក់ ហើយ ចាប់អារម្មណ៍ចង់ចុះកិច្ចសន្យាជាមួយក្រុមហ៊ុនមួយនៅក្នុងក្រុងភ្នំពេញ ដើម្បីថតចម្រៀង និង ផ្សព្វផ្សាយស៊ីឌីថ្មីរបស់ខ្លួន។

ឆ. អ្នកតំណាងឱ្យក្រុមហ៊ុន Air Cambodia ដែលជាក្រុមហ៊ុនអាកាសចរណ៍ថ្មីមួយ។ ក្រុមហ៊ុននេះបានស្នើឱ្យអ្នកតាក់តែងកិច្ចសន្យាការងារមួយសម្រាប់បុគ្គលិកថ្មីនីមួយៗរបស់ខ្លួន។

## ឃ. ដំណើរការមជ្ឈត្តការ

ដំណើរការមជ្ឈត្តការទូទៅមានប្រាំមួយដំណាក់កាល ។ ផ្នែកនេះនឹងលើកឡើងអំពីដំណាក់កាលនីមួយៗហើយពិភាក្សាត្រួសៗអំពីទិដ្ឋភាពសំខាន់ៗនៃដំណាក់កាលទាំងនោះ ។ ដំណាក់កាលទាំងប្រាំមួយ រួមមាន :

១. ការផ្តួចផ្តើមមជ្ឈត្តការ
២. ការជ្រើសរើសវេទិការមជ្ឈត្តកម្ម
៣. នីតិវិធីមុនសវនាការ
៤. សវនាការមជ្ឈត្តការ
៥. ការធ្វើសេចក្តីសម្រេច
៦. ការប្តឹងឧបាស្រ័យ និងការដាក់ឱ្យអនុវត្ត

ផ្នែកនេះនឹងយោងដល់បញ្ញត្តិនៃច្បាប់ថ្មីស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ច.ម.ព.) របស់ប្រទេសកម្ពុជា។[១៨៣] នៅខែមិថុនា ឆ្នាំ២០០៦ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ប្រទេសកម្ពុជាបានចូលជាធរមាន។ ប្រទេសកម្ពុជាមានកាតព្វកិច្ចអនុម័តច្បាប់នេះ នៅពេលប្រទេសកម្ពុជាបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ("WTO") ក្នុងឆ្នាំ២០០៤ ។[១៨៤] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម យកលំនាំជាច្រើនតាមច្បាប់គម្រូរបស់ UNCITRAL ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មអន្តរជាតិ[១៨៥] ("ច្បាប់មជ្ឈត្តការ UNCITRAL") ដោយមានភាពខុសគ្នាគួរឱ្យកត់សម្គាល់

---

[១៨៣] *ដូចមុន* ។ ទោះជាយ៉ាងនេះក្តី គម្រូអន្តរជាតិផ្សេងទៀតនឹងត្រូវលើកមកពិភាក្សានៅពេលមានភាពខុសគ្នាគួរកត់សម្គាល់ ។

[១៨៤] ច្បាប់ពាណិជ្ជកម្មសំខាន់ៗមួយចំនួនទៀត នៅមិនទាន់ប្រកាសឱ្យប្រើ នៅពេលសរសេរឯកសារនេះ រួមមាន ច្បាប់ស្តីពីជំនួញដូរដែលមានការធានា ច្បាប់ស្តីពីកិច្ចសន្យាជួលផ្នែកពាណិជ្ជកម្ម ច្បាប់ស្តីពីការចេញ និងធ្វើអាជីវកម្មលើមូលប័ត្រមិនមែនរដ្ឋាភិបាល ច្បាប់ស្តីពីអសាធនភាព ច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម ច្បាប់ស្តីពីការប្រកួតប្រជែង និងច្បាប់ស្តីពីការបង្កើតតុលាការពាណិជ្ជកម្ម ។

[១៨៥] **ច្បាប់គម្រូ** UNCITRAL **ស្តីពីមជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ** (ឆ្នាំ២០០៦), វែបសាយត៍ UNCITRAL *មាននៅ* http://1.1.1.1/482468920/477512240T071020171406.txt.binXMysM0dapplication/pdfXsysM0dhttp://www.uncitral.org/pdf/english/texts/arbitration/ml-arb/MLARB-english_revised%2006.pdf (ចូលទស្សនាចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨) [អំណើះតទៅហៅថា "ច្បាប់មជ្ឈត្តការ UNCITRAL "] ។ UNCITRAL សំដៅដល់ គណៈកម្មាធិការច្បាប់ពាណិជ្ជកម្មអន្តរជាតិរបស់អង្គការសហប្រជាជាតិ ។ យោងតាម UNCITRAL:

> ច្បាប់គម្រូនេះត្រូវបានបង្កើតឡើងដើម្បីជួយដល់រដ្ឋនានាក្នុងការធ្វើកំណែទម្រង់ និងទំនើបកម្មច្បាប់របស់ខ្លួនស្តីពីនីតិវិធីមជ្ឈត្តការ ក៏ដូចជាដើម្បី ពិនិត្យមើលលក្ខណៈពិសេស និងតម្រូវការនៃមជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ ...។ ច្បាប់នេះឆ្លុះបញ្ចាំងជាសាកលអំពីការស្រុះស្រួលគ្នាជា ឯកច្ឆ័ន្ទលើទិដ្ឋភាពគន្លឹះនៃទម្លាប់អនុវត្តន៍មជ្ឈត្តការអន្តរជាតិ ដែលត្រូវបានទទួលយកដោយបណ្តារដ្ឋនៃគ្រប់តំបន់ទាំងអស់ និង ប្រព័ន្ធច្បាប់ ឬសេដ្ឋកិច្ចផ្សេងៗនៅទូទាំងពិភពលោក ។

បន្តិចបន្តួច ។ ជាលទ្ធផល បច្ចុប្បន្ននេះ វិធានមជ្ឈត្តការរបស់ប្រទេសកម្ពុជា មានភាពស៊ីសង្វាក់គ្នាជាមួយប្រទេសប្រហែល ៥០ប្រទេស រួមមាន ដៃគូពាណិជ្ជកម្ម សំខាន់ៗដូចជា ប្រទេសជប៉ុន កូរ៉េខាងត្បូង សិង្ហបុរី ថៃ និងអូស្ត្រាលីជាដើម ។[១៨៦]

ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មគ្របដណ្តប់លើគ្រប់ទិដ្ឋភាពនៃបញ្ហាមជ្ឈត្តការ រួមមាន: កិច្ចព្រមព្រៀងផ្សះផ្សា សមាសភាព និងយុត្តាធិការរបស់វេទិការមជ្ឈត្តកម្ម ការដឹកនាំដំណើរការ ការទទួលស្គាល់ និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យ និងផ្នែកមួយដែលមានចំណងជើងថា "មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម"។ ច្បាប់នេះគ្រប់-គ្រងតែលើវិវាទពាណិជ្ជកម្មប៉ុណ្ណោះ ប៉ុន្តែនិយមន័យរបស់វាត្រូវបានអនុញ្ញាតឱ្យធ្វើបកស្រាយយ៉ាងទូលំទូលាយដូចគ្នានឹងនិយមន័យដែលមានចែងនៅក្នុងច្បាប់គម្រូ UNCITRAL ដែរ ។[១៨៧]

> ***ដោយសារតែនិយមន័យដ៏ទូលំទូលាយនេះ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនឹងទំនងជាគ្របដណ្តប់លើសវនាការមជ្ឈត្តការនាពេលអនាគត ភាគច្រើននៅក្នុងប្រទេសកម្ពុជា ។[១៨៨]***

---

វែបសាយត៍របស់ UNCITRAL *មាននៅ*
http://www.uncitral.org/uncitral/en/uncitral_texts/arbitration/1985Model_arbitration.html
(ចូលទស្សនាចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨) ។

[១៨៦] រដ្ឋដែលបានអនុម័តច្បាប់គម្រូនេះ រួមមាន : អូស្ត្រាលី អូទ្រីស (ឆ្នាំ២០០៥) អាស៊ែបៃហ្សង់ បារ៉ែន បង់ក្លាដែស បេឡារូស ប៊ុលហ្គារី កម្ពុជា (ឆ្នាំ២០០៦) កាណាដា ឈីលី ក្នុងប្រទេសចិនមាន: តំបន់រដ្ឋបាលពិសេសហុងកុង តំបន់រដ្ឋបាលពិសេសម៉ាកាវ ក្រូអាត ហ្ស៊ីព្រ ដាណឺម៉ាក (ឆ្នាំ២០០៥) អេហ្ស៊ីព អាល្លឺម៉ង់ ក្រិច ហ្គាតាម៉ាឡា ហុងគ្រី ឥណ្ឌា (សាធារណរដ្ឋអ៊ីស្លាម) អ៊ីរ៉ង់ អៀរឡង់ ជប៉ុន ហ្សកដានី កែនយ៉ា លីទុយអានី ម៉ាដាហ្គាស្កា ម៉ាល់តា ម៉ិចស៊ិក ញូវហ្សេឡែន នីការ៉ាហ្គ័រ (ឆ្នាំ២០០៥) នីហ្សេរីយ៉ា ន័រវេស (ឆ្នាំ២០០៤) អូម៉ង់ ប៉ារ៉ាហ្គាយ ប៉េរូ ហ្វីលីពីន ប៉ូឡូញ (ឆ្នាំ២០០៥) សាធារណរដ្ឋកូរ៉េ សហព័ន្ធរុស្ស៊ី សិង្ហបុរី អេស្ប៉ាញ ស្រីលង្កា ថៃ ទុយនេស៊ី ទួរគី (ឆ្នាំ២០០១) អ៊ុយក្រែន នៅក្នុងចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង : ស្កុតឡែន នៅក្នុងប៉ែរមុយដា ដែនដីនាយសមុទ្រនៃចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង នៅក្នុងសហរដ្ឋអាមេរិក : កាលីហ្វរនីញ៉ា ខនិកធីខាត់ អ៊ិលីន័រ លូស្ស៊ីយ៉ាណា អូរីហ្គុង និងតិចសាស់ ប្រទេសហ្ស៊ំប៊ី និងហ្ស៊ីមបាវេ ។ វែបសាយត៍ UNCITRAL *មាននៅ*
http://www.uncitral.org/uncitral/en/uncitral_texts/arbitration/1985Model_arbitration_status.html
(ចូលទស្សនាចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨) ។

[១៨៧] មាត្រា ២(ឈ) នៃច្បាប់មជ្ឈត្តការផ្នែកពាណិជ្ជកម្ម ចែងថា "ពាក្យថា "ពាណិជ្ជកម្ម" ត្រូវបកស្រាយឱ្យបានទូលំទូលាយដើម្បីគ្របដណ្តប់លើធុរកិច្ចនានាដែលកើតចេញ ពីទំនាក់ទំនងទាំងអស់ដែលមានប្រភេទជាពាណិជ្ជកម្ម ទោះបីជាមាន ឬគ្មានកិច្ចសន្យាក៏ដោយ ហើយទំនាក់ទំនងដែលមានប្រភេទជាពាណិជ្ជកម្មរួមមាន តែមិនកម្រិតត្រឹម ជំនួញដូចខាងក្រោម : កិច្ចការជំនួញដើម្បីផ្គត់ផ្គង់ ឬផ្លាស់ប្តូរទំនិញ [sic] ឬសេវាផ្សេងៗ កិច្ចព្រមព្រៀងនៃការចែកចាយតំណាង ឬទីភ្នាក់ងារពាណិជ្ជកម្ម ការផលិត ការជួលទីតាំង ការងារស្ថាបនា ការពិគ្រោះយោបល់វិស្វកម្ម ការចេញអាជ្ញាប័ណ្ណ ការវិនិយោគទុន ការផ្តល់ហិរញ្ញវត្ថុ ការធ្វើអាជីវកម្មធនាគារ ធានារ៉ាប់រង កិច្ចព្រមព្រៀងធ្វើអាជីវកម្ម ឬសម្បទាន ក្រុមហ៊ុនចម្រុះ និងប្រភេទផ្សេងៗទៀតនៃសហប្រតិបត្តិការឧស្សាហកម្ម ឬពាណិជ្ជកម្ម និងការដឹកជញ្ជូន ទំនិញ ឬអ្នកដំណើរតាមផ្លូវអាកាស សមុទ្រ ផ្លូវដែក ឬផ្លូវគោក" ។ ច.ម.ព កំណត់សម្គាល់ *ខាងលើ* លេខ១០១ មាត្រា ២(ឈ)

[១៨៨] ប្រហែលជាមានករណីលើកលែងចំពោះក្រុមប្រឹក្សាអាជ្ញាកណ្តាលកម្ពុជា ។

ដូចនេះ ផ្នែកនេះនឹងផ្តោតលើដំណើរការមជ្ឈត្តការដែលចែងនៅក្នុងច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។

ជាការសំខាន់គួរកត់សម្គាល់ថា ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មគឺជាច្បាប់មជ្ឈត្តការ ដែលចែងអំពីបទដ្ឋានមជ្ឈត្តការ។ ភាគីវិវាទអាចធ្វើបង្វែរចេញពីបទដ្ឋាននេះបាន ជាពិសេសទាក់ទងនឹងវិធានមជ្ឈត្តការនានា។ ឧទាហរណ៍ ប្រសិនបើគូភាគីជ្រើសរើសយកស្ថាប័ន AAA ឬ ICC ធ្វើជាអ្នកគ្រប់គ្រងមជ្ឈត្តការរបស់ខ្លួន ពួកគេមុខជានឹងជ្រើសរើសយកវិធានមជ្ឈត្តការរបស់ AAA ឬ ICC ដែរ។ វិធានទាំងនេះមានភាពខុសគ្នាបន្តិចបន្តួចពីវិធាននៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ប៉ុន្តែច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មអនុញ្ញាតឱ្យគូភាគីធ្វើដូច្នោះបាន។

ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មយកលំនាំតាមច្បាប់គម្រូ UNCITRAL ក្នុងការដាក់កំហិតអន្តរាគមន៍របស់តុលាការនៅក្នុងដំណើរការនានានៃមជ្ឈត្តការ។[១៨៩] ប៉ុន្តែមានការភ័ន្តច្រឡំគ្នាមួយចំនួនទាក់ទងនឹងតួនាទីគ្រប់គ្រងរបស់តុលាការ។ មាត្រា៦ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មបញ្ជាក់ថាមុខងារត្រួតពិនិត្យជាច្រើន (ដូចជាការតែងតាំង ការជំទាស់ ការបញ្ចប់ ការខកខានក្នុងការបំពេញមុងារ របស់មជ្ឈត្តករ ក៏ដូចជាយុត្តាធិការរបស់តុលាការ) ត្រូវ "អនុវត្តដោយតុលាការ (តុលាការពាណិជ្ជកម្ម សាលាឧទ្ធរណ៍ ឬតុលាការកំពូល) ឬមជ្ឈមណ្ឌលមជ្ឈត្តការជាតិ។"[១៩០] ខ្លឹមសារត្រង់ចំណុចនេះគេអាចបកស្រាយថាមានការចង្អុរបង្ហាញដល់ភាគីថា ខ្លួនអាចប្តឹងឧបាស្រ័យដោយផ្ទាល់ទៅស្ថាប័ន*ណាមួយ*ក្នុងចំណោមស្ថាប័នទាំងបួននេះ ដើម្បីស្នើសុំជំនួយផ្នែកគ្រប់គ្រងនានា។[១៩១] ខ្លឹមសារត្រង់ចំណុចនេះក៏បានចង្អុលបង្ហាញផងដែរថា មានតែជម្រើសពីរយ៉ាងតែប៉ុណ្ណោះក្នុងការប្តឹងឧបាស្រ័យៈ ទី១គឺ "តុលាការ" ដែលសំដៅទៅលើប្រព័ន្ធតុលាការជាទូទៅ ឬ ទី២គឺមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ។ ដោយសារខ្លឹមសារ ត្រង់ចំណុចនេះនៅមានភាពស្រពិចស្រពិល ការភ័ន្តច្រឡំអាចកើតមាន ហើយការអនុវត្តអាចមានភាពមិនស៊ីសង្វាក់គ្នាខ្លះៗ។ ផ្អែកលើស្ថានភាពបច្ចុប្បន្ននេះ ប្រការដែលល្អបំផុត ក្នុងការស្វែងរកជំនួយត្រួតពិនិត្យពីតុលាការ គឺដាក់ញត្តិទៅសាលាឧទ្ធរណ៍[១៩២]។ ចំណុចនេះគួរត្រូវបានលើកមកពិនិត្យ នៅពេលកែតម្រូវឡើងវិញនាពេលអនាគតចំពោះច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនេះ។

### ***១. ការផ្តួចផ្តើមចំណើរការមជ្ឈត្តការ***

មជ្ឈត្តការអាចផ្តួចផ្តើមឡើងតាមវិធីបីយ៉ាងគឺៈ ១) ការស្នើឱ្យធ្វើមជ្ឈត្តការស្របតាមកិច្ចព្រមព្រៀងស្តីពីមជ្ឈត្តការដែលមានស្រាប់ ២) ការព្រមព្រៀងឱ្យធ្វើមជ្ឈត្តការនៅពេលវិវាទកើតឡើង និង៣) មជ្ឈត្តការ ដែលត្រូវអនុវត្តតាមបង្គាប់របស់តុលាការ។ វិធីទីមួយក្នុងចំណោមវិធីទាំងបី ពោលគឺការស្នើឱ្យធ្វើមជ្ឈត្តការស្របតាមកិច្ចព្រមព្រៀងមជ្ឈត្តការដែលមានស្រាប់ ត្រូវបានអនុវត្តជាទូទៅបំផុត។

---

[១៨៩] *ដូចមុន* មាត្រា ៥ ។

[១៩០] *ដូចមុន* មាត្រា ៦, ១៩(៣), ១៩(៤), ១៩(៥), ២១(៣), ២២ និង ២៤(៣) ។

[១៩១] តុលាការពាណិជ្ជកម្មដែលនិយាយនៅទីនេះ មិនទាន់បង្កើតឡើងនៅឡើយទេ ។

[១៩២] សាលាឧទ្ធរណ៍គឺជាតុលាការជាតិជាន់ទាបបំផុតដែលកំពុងដំណើរការ ដែលមានរៀបរាប់នៅក្នុងមាត្រា ៦ ។

## ក) ការដាក់ពាក្យរបស់ភាគីប្ដឹង

ប្រសិនបើគូភាគីមានកិច្ចព្រមព្រៀងមជ្ឈត្តការជាមុនស្រាប់ ដែលជាទូទៅគឺជាផ្នែកមួយនៃកិច្ចសន្យាដើម ភាគីម្ខាងត្រូវបង្ហាញដល់ភាគីម្ខាងទៀតនូវសម្ដីជាលាយលក្ខណ៍អក្សរ (ពេលខ្លះហៅថា "លិខិតជូនដំណឹង") ដើម្បីធ្វើមជ្ឈត្តការ។ យោងតាមច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម សម្ដីជាលាយលក្ខណ៍អក្សរនោះត្រូវប្រគល់ដល់ភាគីម្ខាងទៀតដោយផ្ទាល់ ឬទៅដល់កន្លែងអាជីវកម្ម លំនៅស្ថានអចិន្ត្រៃយ៍ ឬអាសយដ្ឋានប្រៃសណីយ៍របស់គាត់។[១៨៣] ភាគីដែលផ្ដួចផ្ដើមធ្វើមជ្ឈត្តការ គេហៅថា"ភាគីប្ដឹង" ហើយភាគីដែលទទួលសម្ដី គេហៅថា "ភាគីឆ្លើយតប"។ ដំណើរការមជ្ឈត្តកម្មចាប់ផ្ដើមនៅកាលបរិច្ឆេទដែលភាគីឆ្លើយតបបានទទួលសម្ដី ។[១៨៤]

ប្រសិនបើគូភាគីបានជ្រើសរើសយកវិធានមជ្ឈត្តការរបស់ UNCITRAL[១៨៥] (ដែលត្រូវបានធ្វើការបោះពុម្ពឡើងវិញ និងភ្ជាប់មកជាមួយនៅក្នុងឧបសម្ព័ន្ធ គ) ឬវិធានមជ្ឈត្តការអន្តរជាតិរបស់សមាគមមជ្ឈត្តការអន្តរជាតិ[១៨៦] ឬវិធានមជ្ឈត្តការរបស់ ICC[១៨៧] នៅក្នុងកិច្ចព្រមព្រៀងមជ្ឈត្តការរបស់ខ្លួន នោះសម្ដី ឬ លិខិតជូនដំណឹងរបស់ពួកគេត្រូវចែងអំពីចំណុចដូចជា:

- ឈ្មោះ និង ព័ត៌មានលម្អិតរបស់គូភាគី
- សេចក្ដីបរិយាយអំពីវិវាទ
- សេចក្ដីបញ្ជាក់អំពីការស្វែងរកជំនួយ និង
- កិច្ចព្រមព្រៀងពាក់ព័ន្ធទាំងអស់ រួមទាំងកិច្ចព្រមព្រៀងមជ្ឈត្តការ។[១៨៨]

ប្រសិនបើគូភាគីបានជ្រើសរើសមជ្ឈមណ្ឌលមជ្ឈត្តការជាតិ ("NAC") ពួកគេនឹងត្រូវគោរពតាមវិធានមជ្ឈត្តការរបស់មជ្ឈមណ្ឌលមជ្ឈត្តការជាតិនោះ ដែលមិនទាន់ត្រូវបានអនុម័តនៅឡើយ នៅពេលដែលសៀវភៅនេះត្រូវបានរៀប

---

[១៨៣] ច.ម.ព. កំណត់សម្គាល់ *ខាងលើ* លេខ១០១ មាត្រា ៣។

[១៨៤] *ដូចមុន* មាត្រា ២៩។

[១៨៥] **វិធានមជ្ឈត្តការ** UNCITRAL មាត្រា ៣ *មាននៅ* http://1.1.1.1/468278784/468291592T080320091030.txt.binXMysM0dapplication/pdfXsysM0dhttp://www.uncitral.org/pdf/english/texts/arbitration/arb-rules/arb-rules.pdf (ចូលទស្សនាចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨) [អំណើះតទៅហៅកាត់ថា "វិធានមជ្ឈត្តការ UNCITRAL"]។

[១៨៦] សមាគមមជ្ឈត្តការអាមេរិក, **វិធានមជ្ឈត្តការអន្តរជាតិ**, មាត្រា ៣ *មាននៅ* http://www.adr.org/sp.asp?id=33994#INTERNATIONAL%20ARBITRATION%20RULES (ចូលទស្សនាចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨) [អំណើះតទៅហៅកាត់ថា "វិធានមជ្ឈត្តការAAA"]។

[១៨៧] **វិធានមជ្ឈត្តការ** ICC មាត្រា ៤ ( *មាននៅ* http://www.iccwbo.org/ (ចូលទស្សនាចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨) [អំណើះតទៅហៅកាត់ថា "វិធានមជ្ឈត្តការ ICC"]។

[១៨៨] វិធានទាំងបីបទនេះ ក៏រួមបញ្ចូលនូវ ចំនួន និងជម្រើសមជ្ឈត្តករនៅក្នុងពាក្យរបស់ភាគីប្ដឹង ។វិធានមជ្ឈត្តការ AAA មាត្រា ២(៣)(ឆ) វិធានមជ្ឈត្តការ UNCITRAL មាត្រា ៤(៣)(ឆ) និងវិធានមជ្ឈត្តការICC មាត្រា ៣(៣)(ឆ) និងមាត្រា ៤ (ក)-(ខ)។

រៀងឡើង។ អ្នកនិពន្ធសៀវភៅរំពឹងថា វិធានមជ្ឈត្តការរបស់ NAC ទំនងជាមានលំនាំស្រដៀងគ្នាទៅនឹងបទដ្ឋានអន្តរជាតិ ដែលមាននៅក្នុងវិធានរបស់ UNCITRAL ឬ AAA ឬ ICC ។

ទោះជាយ៉ាងនេះក្តី ប្រសិនបើវិធាននោះមិនត្រូវបានជ្រើសរើសដោយគូភាគីនៅក្នុងកិច្ចព្រមព្រៀងមជ្ឈត្តការរបស់ពួកគេទេ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មមានចែងអំពីបញ្ញត្តិទូទៅមួយចំនួន ដែលក្នុងនោះគូភាគីត្រូវដាក់លិខិតបញ្ជាក់អំពីការប្តឹងទាមទារ ដែលត្រូវមាន: ១) អង្គហេតុដែលនាំឱ្យមានការទាមទារ ២) ចំណុចដែលមានបញ្ហា និង ៣) ដំណោះស្រាយដែលខ្លួនចង់បាន។

### ខ) ការដាក់ពាក្យរបស់ភាគីឆ្លើយតប

នៅពេលដែលភាគីប្តឹងដាក់ពាក្យរួច ភាគីឆ្លើយតបក៏ត្រូវដាក់ពាក្យរបស់ខ្លួនដែរ។ យោងតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងវិធានរបស់ UNCITRAL ភាគីឆ្លើយតបត្រូវធ្វើពាក្យដោះសាររបស់ខ្លួន ដែលឆ្លើយតបទៅនឹងចំណុចដែលបានលើកឡើងនៅក្នុងបណ្តឹងទាមទារ ព្រមទាំងត្រូវភ្ជាប់ឯកសារពាក់ព័ន្ធ និងបណ្តឹងតបដែលខ្លួនមានផង។[១៩៩] ករណីនេះពុំមានការកំហិតពេលវេលាឡើយ លើកលែងតែមានបញ្ជាក់ដោយមជ្ឈត្តករ។ យោងតាមវិធានរបស់ AAA[២០០] និងវិធានរបស់ ICC[២០១] ភាគីឆ្លើយតបមានពេលវេលាចំនួន៣០ថ្ងៃ ចាប់ពីពេលទទួលបានលិខិតជូនដំណឹងជាលើកដំបូង ឱ្យធ្វើពាក្យដោះសារ (ICC ហៅការធ្វើពាក្យដោះសារនេះថា "ការឆ្លើយតប") និងបណ្តឹងតប។

## ២. ការជ្រើសរើស និងការចំទាស់នឹងវេទិកាមជ្ឈត្តកម្ម

### ក) ការជ្រើសរើសមជ្ឈត្តករ

ក្រោយពេលដាក់បណ្តឹងទាមទារបឋម ភាគីវិវាទត្រូវជ្រើសរើសវេទិកាមជ្ឈត្តកម្ម។ យោងតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ភាគីវិវាទមានសេរីភាពក្នុងការកំណត់ចំនួនមជ្ឈត្តករ ប៉ុន្តែចំនួននោះត្រូវតែជាចំនួនដែលសេស។[២០២] ក្នុង ករណីគ្មានការកំណត់បែបនេះ មជ្ឈត្តករត្រូវមានចំនួនបីនាក់។[២០៣]

ភាគីវិវាទមានសេរីភាពក្នុងការជ្រើសរើសយកវិធីសាស្ត្រណាមួយក៏បានក្នុងការជ្រើសរើសមជ្ឈត្តករ។ ជាទូទៅពួកគេនឹងអនុវត្តតាមវិធីសាស្ត្រជ្រើសរើសរបស់មជ្ឈមណ្ឌលមជ្ឈត្តការដែលខ្លួនបានជ្រើសរើស ដូចជា AAA[204], ICC[២០៥]

---

[១៩៩] វិធានមជ្ឈត្តការ UNCITRAL មាត្រា ១៩ ។

[២០០] វិធានមជ្ឈត្តការ AAA មាត្រា ៣។

[២០១] វិធានមជ្ឈត្តការ ICC មាត្រា ៥។

[២០២] ច.ម.ព. កំណត់សម្គាល់ *ខាងលើ* លេខ១០១ មាត្រា ១៨ ។

[២០៣] ជាការគួរឱ្យចាប់អារម្មណ៍ ចំនួនមជ្ឈត្តករជាស្វ័យប្រវត្តិក្រោមវិធានមជ្ឈត្តការ AAA និងវិធានមជ្ឈត្តការ ICC គឺម្នាក់ លើកលែងតែរឿងក្តីអនុញ្ញាត្តិឱ្យមានបីនាក់ ។ វិធានមជ្ឈត្តការ AAA មាត្រា ៥ ។ វិធានមជ្ឈត្តការ ICC មាត្រា ៨(២) ។

[២០៤] វិធានមជ្ឈត្តការ AAA មាត្រា ៦ ។

[២០៥] វិធានមជ្ឈត្តការ ICC មាត្រា ៩ ។

ឬក្នុងពេលអនាគត គឺមជ្ឈមណ្ឌលមជ្ឈត្តការជាតិ (NAC)។ ក្នុងករណីដែលពួកគេមិនបានជ្រើសរើសយកវិធីសាស្ត្រណាមួយនោះទេ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មចែងថា ភាគីនីមួយៗត្រូវតែងតាំងមជ្ឈត្តករម្នាក់ ហើយមជ្ឈត្តករទាំងពីរនាក់ត្រូវតែងតាំងមជ្ឈត្តករទីបី។[២០៦] ប្រសិនបើ ការតែងតាំងមជ្ឈត្តករទីបីមិនត្រូវបានធ្វើឡើងក្នុងរយៈពេល ៣០ ថ្ងៃ ក្រោយពេលតែងតាំងមជ្ឈត្តករទាំងពីរនាក់ដំបូង តុលាការកម្ពុជា ឬ NAC នឹងធ្វើការតែងតាំង ក្រោយពេលមានសំណើរបស់ភាគីណាមួយក្នុងចំណោមភាគីទាំងពីរ។[២០៧]

ប្រសិនបើត្រូវមានតែមជ្ឈត្តករម្នាក់ ហើយភាគីវិវាទមិនបានចាត់តាំងមជ្ឈមណ្ឌលមជ្ឈត្តការណាមួយធ្វើជាស្ថាប័នគ្រប់គ្រង ហើយពួកគេមិនអាចឯកភាពគ្នាចំពោះមជ្ឈត្តករណាមួយនោះទេ តុលាការកម្ពុជា ឬ NAC នឹងធ្វើការតែងតាំងនេះ ក្រោយពេលមានសំណើ។[២០៨]

### ៩) ការជំទាស់នឹងមជ្ឈត្តករដែលត្រូវបានជ្រើសរើស

យោងតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម មុនពេលតែងតាំង មជ្ឈត្តករត្រូវបង្ហាញឱ្យដឹងនូវកាលៈទេសៈណាមួយ "ដែលអាចបង្កការសង្ស័យដោយមូលហេតុសមរម្យ ទាក់ទងនឹងអព្យាក្រឹតភាព ឬឯករាជភាពរបស់ខ្លួន"។[២០៩] ចំណុចនេះអាចរាប់បញ្ចូលទាំងទំនាស់ផលប្រយោជន៍ជាមួយភាគីម្ខាង ឬច្រើនផងដែរ។

មជ្ឈត្តករអាចត្រូវបានជំទាស់ដោយសារមូលហេតុពីរយ៉ាង : ១) *"ប្រសិនបើមានកាលៈទេសៈដែលបង្កការសង្ស័យដោយមូលហេតុសមស្រប ពាក់ព័ន្ធនឹងអព្យាក្រឹតភាព ឬឯករាជភាពរបស់គាត់" ឬ ២) "ប្រសិនបើគាត់គ្មានលក្ខណសម្បត្តិដែលភាគីវិវាទបានព្រមព្រៀង"*។[២១០] នៅពេលចុះកិច្ចសន្យា គូភាគីមានសេរីភាពក្នុងការយល់ព្រមចំពោះនីតិវិធីជំទាស់ណាមួយ រួមទាំងនីតិវិធីដែលមាននៅក្នុងវិធានរបស់ ICC[២១១] ឬវិធានរបស់ AAA។[២១២] ប្រសិនបើគ្មានកិច្ចព្រមព្រៀងបែបនេះទេ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនឹងផ្តល់នីតិវិធីផ្ទាល់របស់ខ្លួន។ ទីមួយ ភាគីដែលធ្វើការជំទាស់ត្រូវផ្ញើបណ្តឹងជាលាយលក្ខណ៍អក្សរ ដែលបញ្ជាក់អំពីមូលហេតុនៃការជំទាស់ក្នុងរយៈពេល១៥ថ្ងៃ ក្រោយពេលដែលបានដឹងអំពីកាលៈទេសៈដែលអាចនាំឱ្យមានបញ្ហា ឬការតែងតាំងដែលមានបញ្ហា។[២១៣] បន្ទាប់មក វេទិកាមជ្ឈត្តកម្មនឹងពិចារណា និងសម្រេចថាតើត្រូវយល់ព្រមតាមការជំទាស់នោះដែរឬទេ។ ប្រសិនបើយល់ព្រម មជ្ឈត្តករថ្មីម្នាក់ទៀតនឹងត្រូវតែងតាំងឡើង។ ប្រសិនបើមិនយល់ព្រមទេ មជ្ឈត្តករដែលត្រូវប្តឹងទាស់នេះ នឹងនៅតែទទួលខុសត្រូវលើ

---

[២០៦] ច.ម.ព. កំណត់សម្គាល់ *ខាងលើ* លេខ១០១ មាត្រា ១៩(៣)(ក)។

[២០៧] *ដូចមុន*។

[២០៨] *ដូចមុន* មាត្រា ១៩(៣)(ខ)។

[២០៩] *ដូចមុន* មាត្រា ២០។

[២១០] *ដូចមុន* មាត្រា ២០។

[២១១] វិធានមជ្ឈត្តការ ICC មាត្រា ១១។

[២១២] វិធានមជ្ឈត្តការ AAA មាត្រា ៨-៩ ។

[២១៣] ច.ម.ព. កំណត់សម្គាល់ *ខាងលើ* លេខ១០១ មាត្រា ២១(២)។

ដំណើរការមជ្ឈត្តការនោះដដែល។ បន្ទាប់មក ភាគីដែលប្ដឹងទាស់ អាចធ្វើការប្ដឹងបន្តលើសេចក្ដីសម្រេចរបស់វេទិកាមជ្ឈត្តកម្មនោះ ក្នុងរយៈពេល ៣០ថ្ងៃ ទៅកាន់តុលាការកម្ពុជា ឬ NAC។[២១៤] ឧទាហរណ៍ៈ

> ក្រុមហ៊ុន Kandal Tool Company និង រោងចក្រកាត់ដេរ Blue Sky Garment Factory កំពុងតែជាប់ពាក់ព័ន្ធនៅក្នុងដំណើរការមជ្ឈត្តការមួយ។ ក្រុមហ៊ុន Kandal បានតែងតាំងមជ្ឈត្តករម្នាក់ ដែលរោងចក្រ Blue Sky ជឿថាមិនអព្យាក្រឹត ដោយសារគ្រួសាររបស់គាត់ធ្លាប់ធ្វើជំនួញជាមួយក្រុមហ៊ុន Kandal នោះ។ យោងតាមវិធាននៃច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម រោងចក្រ Blue Sky មានពេលវេលាចំនួន ១៥ថ្ងៃ ចាប់ពីពេលខ្លួនបានដឹងអំពីការតែងតាំង ឬ ដឹងអំពីការធ្វើ ជំនួញរបស់មជ្ឈត្តករនោះជាមួយ ក្រុមហ៊ុន Kandal ដើម្បីដាក់បណ្ដឹងជំទាស់របស់ខ្លួន។ បណ្ដឹងជំទាស់ត្រូវដាក់ទៅវេទិកាមជ្ឈត្តកម្មដោយខ្លួនឯង។ ប្រសិនបើវេទិកាមជ្ឈត្តកម្ម ចេញសេចក្ដីសម្រេចលើកចោលការជំទាស់នោះ ពេលនោះក្រុមហ៊ុន Blue Sky មានពេលវេលាចំនួន ៣០ថ្ងៃ ក្នុងការដាក់បណ្ដឹងបន្តទៅតុលាការកម្ពុជា ឬ ទៅ NAC។

### ឆ) ការជំទាស់នឹងយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម

មាត្រា៨នៃច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មចែងថា តុលាការកម្ពុជាត្រូវបញ្ជូនរឿងក្ដីទៅធ្វើមជ្ឈត្តការ ប្រសិនបើមានកិច្ចព្រមព្រៀងដែលមានសុពលភាព។[២១៥] ប៉ុន្តែ គូភាគីក៏អាចជំទាស់នឹងយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្មនោះផងដែរ ក្នុងការជំនុំរឿងក្ដីនោះមួយផ្នែកឬទាំងអស់។ ឧទាហរណ៍ ភាគីម្ខាងអាចអះអាងថា ខ្លួនមិនដែលយល់ព្រមធ្វើមជ្ឈត្តការវិវាទណាមួយឡើយ ហើយប្រហែលជាចង់បញ្ជូនបណ្ដឹងតវ៉ានោះទៅតុលាការតាមច្បាប់។ ជាដំបូង ភាគីនេះធ្វើការទាមទារនេះជាមួយវេទិកាមជ្ឈត្តកម្មនោះសិន។ វេទិកាមជ្ឈត្តកម្ម *"អាចសម្រេចអំពីយុត្តាធិការផ្ទាល់របស់ខ្លួន រួមទាំងការជំទាស់ទាក់ទងនឹងអត្ថិភាព ឬសុពលភាពរបស់កិច្ចព្រមព្រៀងមជ្ឈត្តការផងដែរ"*។[២១៦] ចំណុចនេះស្រដៀងគ្នាទៅនឹងវិធានរបស់ UNCITRAL វិធាន មជ្ឈត្តការរបស់ AAA និង វិធានមជ្ឈត្តការរបស់ ICCដែរ។

ភាគីដែលជំទាស់ត្រូវលើកឡើងអំពីបញ្ហានេះ ក្នុងកំឡុងពេល ឬមុនកាលបរិច្ឆេទកំណត់សម្រាប់ការ ដាក់ពាក្យដោះសាររបស់ខ្លួន។[២១៧] បន្ទាប់មកសេចក្ដីសម្រេចរបស់វេទិកាមជ្ឈត្តកម្មអំពីបញ្ហាយុត្តាធិការ អាចត្រូវបានប្ដឹងបន្តទៅតុលាការកម្ពុជា ក្នុងរយៈពេល៣០ថ្ងៃ ក្រោយពេលចេញសេចក្ដីសម្រេចរបស់វេទិកាមជ្ឈត្តកម្ម។[២១៨]

---

[២១៤] *ដូចមុន* មាត្រា ២១(៣)។

[២១៥] *ដូចមុន* មាត្រា ៨(១)។ អាណត្តិបញ្ជូនមិនកំហិតត្រឹមមជ្ឈត្តការ*កម្ពុជា*ទេ។ នេះគឺជាការអភិវឌ្ឍដ៏គួរឱ្យចង់បានដែលក្នុងនោះ តុលាការកម្ពុជា នឹងត្រូវបានតម្រូវឱ្យផ្ដល់ការទទួលស្គាល់ពេញលេញនូវកិច្ចព្រមព្រៀងមជ្ឈត្តការ ទោះជាកិច្ចព្រមព្រៀងមជ្ឈត្តការដែលជ្រើសរើសធ្វើមជ្ឈត្តការ នៅក្រៅប្រទេសកម្ពុជាក៏ដោយ។

[២១៦] *ដូចមុន* មាត្រា ២៤(១)។ គួរកត់សម្គាល់ផងដែរថា សេចក្ដីសម្រេចរបស់វេទិការមជ្ឈត្តកម្មដែលថា កិច្ចសន្យារវាងភាគីវិវាទនោះត្រូវបានទុកជាមោឃៈ មិនជំនួស*តាមអង្គច្បាប់* នៃសុពលភាពនៃខចែងស្ដីពីមជ្ឈត្តការនោះទេ។ *ដូចមុន*។

[២១៧] *ដូចមុន* មាត្រា ២៤(២)។

## ៣. *ដំណើរការមុនសវនាការ*

ដំណើរការមុនសានាការបង្កើតបានជាដំណាក់កាលបន្ទាប់ ។ ក្រោយពេលមជ្ឈត្តករត្រូវបានជ្រើសរើសរួច ហើយយុត្តាធិការត្រូវបានកំណត់រួច ភាគីវិវាទមានបញ្ហាសំខាន់ៗជាច្រើនដែលត្រូវដោះស្រាយ ហើយជាទូទៅបញ្ហានេះត្រូវបញ្ចប់នៅក្នុងការប្រជុំពិភាក្សាមុនសាវនាការដែលនីតិវិធី ទីតាំង ការបង្ហាញសក្ខីកម្ម និងបញ្ហាផ្សេងទៀតនឹងត្រូវបានសម្រេច នៅពេលដែលខចែងស្តីពីមជ្ឈត្តការនៅក្នុងកិច្ចសន្យាដែលមិនបានចែង ឬមានភាពមិនច្បាស់លាស់អំពីបញ្ហាទាំងនេះ ។

### ក) វិធានស្តីពីនីតិវិធី

ដូចគ្នាទៅនឹងវិស័យផ្សេងៗទៀតដែរ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មចែងថា ភាគីវិវាទអាចកំណត់អំពីវិធាន នីតិវិធីផ្ទាល់របស់ខ្លួន ។ មជ្ឈមណ្ឌលមជ្ឈត្តការជាច្រើនបានបង្កើតវិធាននីតិវិធីផ្សេងៗ ហើយជាទូទៅ ភាគីវិវាទតែងអនុម័តយកវិធានរបស់មជ្ឈមណ្ឌលដែលពួកគេបង្ហាញខ្លួន ។ ប៉ុន្តែ ពួកគេក៏អាចយល់ព្រមទទួលយកវិធានផ្ទាល់របស់ពួកគេដែរ ប្រសិនបើពួកគេបានជ្រើសរើស ។ ក្នុងករណីគ្មានវិធានស្តីពីនីតិវិធីដែលបានព្រមព្រៀងនោះទេ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មចែងថា វេទិកាមជ្ឈត្តកម្មត្រូវដឹកនាំដំណើរការមជ្ឈត្តការក្នុងរបៀបមួយដែលខ្លួនយល់ថាត្រឹមត្រូវ ។[២១៩]

### ខ) ទីកន្លែងធ្វើមជ្ឈត្តការ

ភាគីវិវាទមានសេរីភាពក្នុងការកំណត់ទីកន្លែងធ្វើមជ្ឈត្តការ នៅក្នុងកិច្ចព្រមព្រៀងរបស់ពួកគេ ឬនៅក្នុងលិខិតផ្សេងទៀត ។ ក្នុងករណីដែលពួកគេមិនបានព្រមព្រៀងគ្នាលើរឿងនេះ ទីកន្លែងធ្វើមជ្ឈត្តការត្រូវកំណត់ដោយវេទិកាមជ្ឈត្តកម្ម *"ដោយពិចារណាអំពីកាលៈទេសៈនៃរឿងក្តី..."*[២២០] លើកលែងតែត្រូវបានព្រមព្រៀងគ្នាផ្សេងពីនោះដោយភាគីវិវាទវេទិកាអាច :

> *ប្រជុំនៅកន្លែងណាមួយដែលសមស្រប ដើម្បីពិគ្រោះយោបល់ក្នុងចំណោមសមាជិករបស់វេទិកា ស្តាប់សាក្សី អ្នកជំនាញការ ឬភាគីវិវាទ ឬ ធ្វើអធិការកិច្ច[sic] លើសម្ភារៈ កម្មសិទ្ធិ ឬ ឯកសារដទៃទៀត ។*[២២១]

ទីកន្លែងធ្វើមជ្ឈត្តការមានសារៈសំខាន់ណាស់ ព្រោះច្បាប់ស្តីពីមជ្ឈត្តការរបស់ប្រទេសម្ចាស់ផ្ទះនឹងមានភាពខុសៗគ្នា ។

---

[២១៨] *ដូចមុន* មាត្រា ២៤(៣) ។ សេចក្តីសម្រេចរបស់តុលាការកម្ពុជាលើយុត្តាធិការ មិនអាចប្តឹងឧបាស្រ័យទៅតុលាការជាន់លើទេ ។

[២១៩] *ដូចមុន* មាត្រា ២៧ ។

[២២០] *ដូចមុន* មាត្រា ២៨ ។

[២២១] *ដូចមុន* ។

**ត) ភាសា**

គូភាគីមានសេរីភាពក្នុងការយល់ព្រមលើភាសានៃដំណើរការមជ្ឈត្តការ។ ប្រសិនបើពួកគេមិនយល់ព្រមទេ វេទិកាមជ្ឈត្តកម្មនឹងធ្វើការកំណត់អំពីភាសានោះ។[២២២]

**ឋ) សន្ធានកម្ម**

ដូចបានកំណត់រួចហើយ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មចែងអំពីលទ្ធភាពក្នុងការធ្វើសន្ធានកម្ម។ មាត្រា ៣៨នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មចែងថា:

*មុនពេលចាប់ផ្តើមដំណើរការមជ្ឈត្តការផ្លូវការ វេទិកាមជ្ឈត្តកម្មត្រូវពិភាក្សាជាមួយភាគីវិវាទ ដើម្បីស្វែងរកមានលទ្ធភាពនៃការដោះស្រាយវិវាទ ដោយស្ម័គ្រចិត្តរបស់ភាគី :*

*១) ប្រសិនបើភាគីវិវាទព្រមដោះរសាយវិវាទដោយស្ម័គ្រចិត្ត [sic] វេទិកាមជ្ឈត្តកម្មត្រូវជួយភាគីវិវាទ ទៅតាមបែបបទដែលសមស្រប...*[២២៣]

មាត្រានេះគឺជាមាត្រាដ៏គួរឱ្យចាប់អារម្មណ៍មួយ។ មាត្រានេះអនុញ្ញាតឱ្យវេទិកាមជ្ឈត្តកម្មស្វែងរកនូវដំណោះស្រាយ តាមរយៈសន្ធានកម្ម ប៉ុន្តែលុះត្រាតែភាគីទាំងពីរស្នើឱ្យធ្វើដូច្នេះតែប៉ុណ្ណោះ។ គំនិតនៃការធ្វើសន្ធានកម្មជាមុនបន្ទាប់មកទើបធ្វើមជ្ឈត្តការ ដែលពេលខ្លះគេហៅថា "មជ្ឈត្តការសន្ធាន (Med-Arb)" ។[២២៤]

មជ្ឈត្តការសន្ធាន លើកឡើងអំពីបញ្ហាសំខាន់មួយដែលត្រូវតែពិចារណា ពោលគឺថាតើសន្ធានការីដដែលអាចធ្វើជាមជ្ឈត្តករបានដែរឬទេ ក្នុងករណីដែលភាគីវិវាទបរាជ័យក្នុងការដោះស្រាយបញ្ហាទាំងអស់នៅក្នុងសន្ធានកម្ម។ ក្នុងករណីភាគច្រើន គេមិនសូវចង់ឱ្យសន្ធានការីធ្វើជាមជ្ឈត្តករនៅក្នុងវិវាទតែមួយទេ។ ទីមួយ ប្រសិនបើគូភាគីដឹងថាសន្ធានការីក្លាយជាមជ្ឈត្តករ ពួកគេអាចមិនមានភាពស្មោះត្រង់ទៅលើគោលជំហរនៃដំណោះស្រាយរបស់ពួកគេឡើយ ដោយហេតុនេះ ពួកគេធ្វើឱ្យសន្ធានកម្មមិនអាចប្រព្រឹត្តទៅបាន។ ទីពីរ មជ្ឈត្តករអាចទទួលឥទ្ធិពលមិនសមស្របពីការប្រាស្រ័យទំនាក់ទំនង *តែម្ខាង* ដែលធ្វើឡើងដោយភាគីវិវាទ ដែលជាធម្មតាមជ្ឈត្តករនឹងមិនទទួលបានឡើយ ប្រសិនបើខ្លួនមិនបានធ្វើជាសន្ធានការីពីមុនមកនោះទេ។ ដោយហេតុផលទាំងអស់នេះហើយ គេតែងតែចង់ឱ្យមជ្ឈត្តករ

---

[២២២] *ដូចមុន* មាត្រា ៣០ ។ ក្រោយពេលភាសាត្រូវបានកំណត់រួច វេទិកាអាចបង្គាប់ឱ្យបកប្រែឯកសារភ័ស្តុតាងទៅភាសានោះបាន។

[២២៣] *ដូចមុន* មាត្រា ៣៨ ។

[២២៤] ពិតណាស់ អនុក្រឹត្យស្តីពីមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មមិនមានបញ្ជាក់ច្រើនទេចំពោះជម្រើសនេះ ប៉ុន្តែបានផ្តល់ជាសញ្ញាណអំពីចំនុចនេះទៅក្នុងបញ្ញត្តិដែលថាតួនាទីមួយរបស់ ម.ជ.ម គឺ " ផ្តល់សេវាដោះស្រាយវិវាទផ្នែកពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការ " ។ *សូមមើល* អនុក្រឹត្យស្តីពី ម.ជ.ម កំណត់សម្គាល់ *ខាងលើ* លេខ ១៥៦ មាត្រា ២ ។

នៅក្នុងដំណើរការមជ្ឈត្តការសន្ទានគឺជាមនុស្សផ្សេងគ្នាពីសន្ទានការី។ ការធ្វើដូច្នេះ អាចត្រូវបានធានាដោយការដាក់ភាសាសមស្របមួយ នៅក្នុងខចែងស្តីពីមជ្ឈត្តការសន្ទាន។

**ង) វិធានការបណ្តោះអាសន្ន**

វិធានការបណ្តោះអាសន្នមានសារៈសំខាន់ណាស់។ នៅក្នុងស្ថានភាពមួយចំនួន ភស្តុតាងសំខាន់ៗអាចទទួលការខូចខាត ឬមានការបំផ្លាញចោល ដរាបណាគ្មានការធានាសុវត្ថិភាពយ៉ាងត្រឹមត្រូវដោយតតិយជន។ ឬក៏ប្រហែលភាគីម្ខាងអាចនឹងត្រូវការឱ្យភាគីម្ខាងទៀត បញ្ឈប់សកម្មភាពមួយចំនួនភ្លាមៗ។ ស្រដៀងគ្នាទៅនឹងវិធានរបស់មជ្ឈមណ្ឌលមជ្ឈត្តការភាគច្រើនផ្សេងទៀតដែរ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មផ្តល់ដល់វេទិកាមជ្ឈត្តកម្ម នូវសិទ្ធិអំណាចក្នុងការចេញវិធានការបណ្តោះអាសន្នទាំងនេះ។[២២៥] វេទិកាមជ្ឈត្តកម្មក៏អាចស្នើឱ្យភាគីម្ខាង ផ្តល់ប្រាក់ធានាសមស្របទាក់ទងនឹងវិធានការទាំងនេះផងដែរ។[២២៦]

ភាគីនីមួយៗក៏អាចស្វែងរកការចេញដីកាសម្រេចជាបណ្តោះអាសន្នពីតុលាការកម្ពុជាផងដែរ។ យោងតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ត្រង់ចំណុចនេះ "នៅមុនពេល ឬក្នុងពេលកំពុងដំណើរការមជ្ឈត្តកម្ម ការធ្វើសំណូមពររបស់ភាគីវិវាទមួយទៅតុលាការឱ្យផ្តល់វិធានការបណ្តោះអាសន្ន ដើម្បីការពារ និងការផ្តល់នូវវិធាននោះដោយតុលាការពុំមានវិសមិតភាពជាមួយកិច្ចព្រមព្រៀងផ្សះផ្សាឡើយ"។[២២៧] ខចែងនេះអាចជាបញ្ហាដ៏មានសក្តានុពល សម្រាប់ភាគីបរទេសដែលមានបំណងចង់គេចពីប្រព័ន្ធតុលាការក្នុងស្រុក។ វិធីម្យ៉ាងក្នុងការគេចពីប្រព័ន្ធតុលាការនេះ គឺត្រូវដាក់លក្ខខណ្ឌសមស្រប ទៅក្នុងខចែងស្តីពីមជ្ឈត្តការ ដែលរារាំងភាគីណាមួយមិនឱ្យប្តឹងទៅតុលាការដើម្បីស្នើសុំវិធានការបណ្តោះអាសន្ន។[២២៨]

**ច) ការបង្ហាញព័ត៌មានឱ្យដឹង ឬការផ្ទេរឯកសារគ្នាទៅវិញទៅមក**

ដូចបានរៀបរាប់ពីខាងលើរួចហើយ នៅក្នុងប្រព័ន្ធតុលាការមួយចំនួន ដូចជានៅសហរដ្ឋអាមេរិកជាដើម ការបង្ហាញព័ត៌មានមានលក្ខណៈទូលំទូលាយមុនសវនាការ ត្រូវបានតម្រូវចំពោះភាគីវិវាទ ក្នុងនោះរួមមានទាំងឯកសារ និងកស្សិណរបស់សាក្សី និងភាគីនានាជាដើម។ នៅក្នុងប្រព័ន្ធច្បាប់ Common Law គេហៅលក្ខខណ្ឌតម្រូវនេះថា *ការផ្លាស់ប្តូរព័ត៌មាន*។ ប៉ុន្តែយោងតាមប្រព័ន្ធច្បាប់ Civil Law ការតម្រូវនេះមានលក្ខណៈរឹតត្បិតជាង។ យោងតាម

---

[២២៥] ច.ម.ព. កំណត់សម្គាល់ *ខាងលើ* លេខ១០១ មាត្រា ២៥។ ទោះជាយ៉ាងណាក៏ដោយ ផ្នែកដែលមានចែងអំពី "វិធានការបណ្តោះអាសន្ន" នៃច.ម.ព. បាលលុបចោលនូវរបបដ៏សំខាន់ទាក់ទងនឹង សេចក្តីបង្គាប់ដំបូង ព្រមទាំងការទទួលស្គាល់ និងការអនុវត្តវិធានការបណ្តោះអាសន្ន ដែលមាននៅក្នុងច្បាប់គម្រូស្តីពីមជ្ឈត្តការរបស់ UNCITRAL។ *សូមមើល* ច្បាប់មជ្ឈត្តការ UNCITRAL, កំណត់សម្គាល់ *ខាងលើ* លេខ១៨៥ មាត្រា ១៧ - ១៧(៣)។

[២២៦] *ដូចមុន* ។

[២២៧] *ដូចមុន* មាត្រា ៩ ។

[២២៨] នៅក្នុងការអនុវត្តជាក់ស្តែង នៅមានភាពមិនច្បាស់លាស់នៅឡើយដែលថាតុលាការកម្ពុជានឹងធ្វើតាមការនិយមរបស់ភាគីត្រង់ចំនុចនេះ ។ ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជាកាលពីថ្មីៗនេះបានកំណត់ថា តុលាការអាចដោះស្រាយបើមានភាគីណាមួយស្នើ ហើយច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម " មិនកម្រិតអំណាចយុត្តាធិការនៃតុលាការឡើយ " ។ អត្ថន័យត្រង់ចំនុចនេះមិនមានភាពច្បាស់លាស់ទាំងស្រុងឡើយ ។ ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា សេចក្តីសម្រេចលេខ ១០៣/00 (ឆ្នាំ២០០៦)

វិធានមជ្ឈត្តការភាគច្រើន លក្ខខណ្ឌតម្រូវឱ្យបង្ហាញព័ត៌មានចេញមុនសវនាការគឺមានលក្ខណៈរឹតត្បិត។ ប៉ុន្តែភាគីវិវាទអាចកំណត់អំពីកម្រិតនៃការបង្ហាញព័ត៌មានចេញមុនសវនាការដែលពួកគេចង់បាននៅក្នុងមជ្ឈត្តការរបស់ខ្លួន។

យោងតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម គូភាគីត្រូវបង្ហាញព័ត៌មានដល់គ្នាទៅវិញទៅមកនូវ *"រាល់សេចក្តីថ្លែង ឯកសារ ឬព័ត៌មានដទៃទៀត"* ដែលបានដាក់ជូនវេទិកាមជ្ឈត្តកម្ម។[២២៩] មុនពេលមានសវនាការមជ្ឈត្តការណាមួយ ភាគីវិវាទមានឱកាសក្នុងការត្រួតពិនិត្យ *"សម្ភារៈ ទំនិញ ទ្រព្យសម្បត្តិ ឬឯកសារផ្សេង"*។[២៣០] ពិតណាស់ភាគីវិវាទមានសេរីភាពក្នុង ការអនុម័តវិធានផ្សេងទៀត ស្តីពីការផ្លាស់ប្តូរព័ត៌មនដែលកាន់តែមានលក្ខណៈទូលំទូលាយថែមទៀត។ ការព្រមព្រៀងនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ក្នុងករណីដែលភាគីវិវាទត្រូវបង្ហាញដល់វេទិកាមជ្ឈត្តកម្មថាតើចំណុចអ្វីដែលត្រូវបង្ហាញចេញ ប៉ុន្តែ បែរជាមិនបានបង្ហាញចេញទៅវិញ។

វិធានស្តីពីការផ្លាស់ប្តូរព័ត៌មានដែលកាន់តែមានលក្ខណៈទូលាយ នឹងនាំឱ្យមានការពន្យារពេលនៃដំណើរការមជ្ឈត្តការ និងថ្លៃមេធាវីកាន់តែខ្ពស់។ ផ្ទុយទៅវិញ ការផ្លាស់ប្តូរព័ត៌មានដែលមានលក្ខណៈរិតត្បិត និងមិនគ្រប់គ្រាន់អាចនាំឱ្យមានការភ្ញាក់ផ្អើល និងការយឺតយ៉ាវក្នុងពេលសវនាការ នៅពេលភាគីម្ខាងត្រូវស្នើសុំពេលវេលាបន្ថែមដើម្បីឆ្លើយតបនឹងបញ្ហា និងភស្តុតាងដែលមិនព្រៀងទុកជាមុន។

### ឆ) អ្នកជំនាញ

ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មបានផ្តល់សិទ្ធិអំណាចដល់មជ្ឈត្តករក្នុងការតែងតាំងអ្នកជំនាញ លើកលែងតែភាគីវិវាទបានយល់ព្រមផ្សេងពីនេះ។ ភាគីវិវាទត្រូវផ្តល់ដល់អ្នកជំនាញនូវព័ត៌មានពាក់ព័ន្ធទាំងអស់ និងមានសិទ្ធិត្រួតពិនិត្យអ្នកជំនាញនោះនៅពេលសវនាការ ក្រោយពេលសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញនោះត្រូវបានដាក់ជូនទៅវេទិកាមជ្ឈត្តកម្មរួច។[២៣១]

## ៤. *សវនាការមជ្ឈត្តការ*

ជាទូទៅ ដំណើរការមជ្ឈត្តការតម្រូវឱ្យមានសវនាការមួយដែលស្រដៀងគ្នាទៅនឹងការដំណើរការជំនុំជម្រះនៅក្នុងតុលាការ common law ដែរ។ ជាទូទៅ ភាគីវិវាទតែងធ្វើសេចក្តីថ្លែងបើក ដែលបញ្ជាក់អំពីអង្គហេតុ និងអង្គច្បាប់។ បន្ទាប់មកភាគីប្តឹងធ្វើការបង្ហាញសាក្សី និងឯកសារជាភស្តុតាងរបស់ខ្លួន។ សាក្សីត្រូវធ្វើការស្បថស្បែរដូចនៅក្នុងដំណើរការកាត់ក្តីនៅតុលាការដែរ។ វេទិកាមជ្ឈត្តកម្មនឹងសម្រេចថាតើសាក្សីដែលមិនមែនជាភាគីវិវាទអាចមានវត្តមាននៅក្នុងពេលធ្វើមជ្ឈត្តការដែរឬទេ។

[២២៩] *ដូចមុន* មាត្រា ៣២(៣)។
[២៣០] *ដូចមុន* មាត្រា ៣២(២)។
[២៣១] *ដូចមុន* មាត្រា ៣៤។

ភាគីប្តឹង ឬមេធាវីរបស់ខ្លួន នឹងសួរសំណួរដល់សាក្សីដែលមានវត្តមានដោយផ្ទាល់នៅចំពោះមុខវេទិកាមជ្ឈត្តកម្ម។ ពេលខ្លះវេទិកាមជ្ឈត្តកម្មនឹងសួរសំណួរបន្ថែម ដែលស្រដៀងគ្នាទៅនឹងចៅក្រមនៅក្នុងតុលាការនៃច្បាប់ Civil Law ដែរ។ ភាគីឆ្លើយតបក៏មានសិទ្ធិលើកជាសំណួសួរទៅសាក្សីរបស់ភាគីប្តឹងដែរ។[២៣២]

ក្រោយពេលភាគីប្តឹងបានបង្ហាញនូវភស្តុតាងទាំងអស់របស់ខ្លួនរួច ភាគីឆ្លើយតបនឹងមានឱកាសបង្ហាញសាក្សី និងឯកសារជាភស្តុតាងរបស់ខ្លួនវិញម្តង។ ជាថ្មីម្តងទៀត វេទិកាមជ្ឈត្តកម្ម និងភាគីប្តឹងក៏អាចសួរសំណួរទៅសាក្សីទាំងនោះបានដែរ។ បន្ទាប់មក គូភាគីនឹងផ្លាស់វេនគ្នាធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ ហើយបន្ទាប់ពីនោះមក វេទិកាមជ្ឈត្តកម្មនឹងពិភាក្សាដើម្បីសម្រេចរឿងក្តីនេះ។

ជាទូទៅ សវនាការមជ្ឈត្តការមានលក្ខណៈមិនផ្លូវការជាងដំណើរការកាត់ក្តីនៅតុលាការ។ បញ្ហានីតិវិធី ឬបញ្ហាភស្តុតាងមានភាពទន់ភ្លន់ជាងនៅក្នុងតុលាការ។ ប្រសិនបើគូភាគីយល់ព្រម ពួកគេមិនចាំបាច់ធ្វើសវនាការផ្ទាល់មាត់នោះទេ។ គូភាគីអាចជ្រើសរើសធ្វើត្រឹមតែការបង្ហាញភស្តុតាងជាឯកសារ និងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដាក់ជូនវេទិកាមជ្ឈត្តកម្មដើម្បីពិចារណាក៏បាន។ ប៉ុន្តែ ប្រសិនបើភាគីណាមួយចង់ឱ្យមានសវនាការផ្ទាល់មាត់នោះ ពេលនោះសវនាការផ្ទាល់មាត់ត្រូវតែធ្វើឡើង។[២៣៣] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មក៏តម្រូវឱ្យគូភាគីទទួលបាននូវការជូនដំណឹងអំពីសវនាការបែបនោះឱ្យបានគ្រប់គ្រាន់ផងដែរ។[២៣៤]

មជ្ឈមណ្ឌលមជ្ឈត្តការផ្សេងៗ ដូចជា AAA និង ICC មានវិធានផ្ទាល់របស់ខ្លួនដែលអាចកែប្រែបានដោយការព្រមព្រៀងរវាងភាគីវិវាទ។

## *៥. ការធ្វើសេចក្តីសម្រេច*

ក្រោយពេលសវនាការមជ្ឈត្តការបានបញ្ចប់សព្វគ្រប់ វេទិកាមជ្ឈត្តកម្មត្រូវបង្វែរការយកចិត្តដាក់ទៅលើការធ្វើសេចក្តីសម្រេច។ ដូចបានរៀបរាប់ពីខាងលើ យោងតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ភាគីវិវាទអាចជ្រើសរើសច្បាប់ណាមួយនៃយុត្តាធិការមកអនុវត្តក៏បាន។[២៣៥] ពេលខ្លះគេហៅការព្រមព្រៀងនេះថា បទបញ្ញត្តិអំពីជម្រើសនៃច្បាប់នៅក្នុងកិច្ចព្រមព្រៀងរបស់ភាគីវិវាទ។ ក្នុងករណីដែលគ្មានបញ្ញត្តិស្តីពីជម្រើសនៃច្បាប់នោះទេ វេទិកាមជ្ឈត្តកម្មមានសេរីភាពក្នុងការជ្រើសរើសច្បាប់ណាមួយដែលខ្លួនយល់ថាសមស្របមកអនុវត្ត។[២៣៦]

---

[២៣២] វិធីនេះ គេហៅថា "ការសាកសួរឆ្លង" នៅក្នុងតុលាការនៃប្រព័ន្ធច្បាប់ Common Law ។

[២៣៣] *ដូចមុន* មាត្រា ៣២ ។

[២៣៤] *ដូចមុន ។*

[២៣៥] *ដូចមុន* មាត្រា ៣៦(១) ។

[២៣៦] *ដូចមុន* មាត្រា ៣៦(២) ។

### ក) ជាចៅក្រម ឬជាអ្នកជួយសម្រុះសម្រួល?

ភាគីវិវាទអាចយល់ព្រមផ្តល់សិទ្ធិឱ្យវេទិកាមជ្ឈត្តកម្មក្នុងការធ្វើជាអ្នកជួយសម្រុះសម្រួល (ពោលគឺធ្វើសេចក្តីសម្រេចដោយផ្អែកលើអ្វីដែលត្រឹមត្រូវ) ជាជាងធ្វើជាចៅក្រម (ដែលធ្វើសេចក្តីសម្រេចដោយផ្អែកលើច្បាប់)។[២៣៧] តាមវិធានស្រុះស្រួល វេទិកាមជ្ឈត្តកម្មចាំបាច់ត្រូវធ្វើសេចក្តីសម្រេចដោយយោងតាមគោលការណ៍សមធម៌ និងយុត្តិធម៌ ជាជាង គោលការណ៍ច្បាប់។[២៣៨] ការធ្វើដូច្នេះអាចនាំឱ្យមានសេចក្តីសម្រេចដែលមើលទៅដូចជាការស្រុះស្រួលគ្នា ដែលក្នុងនោះភាគីនីមួយៗទទួលបានអ្វីម្យ៉ាង។ ការធ្វើដូច្នេះក៏អាចនាំឱ្យមានការធ្វើសេចក្តីសម្រេចដែលផ្អែកលើស្មារតីយុត្តិធម៌របស់មជ្ឈត្តករម្នាក់ៗ ពោលគឺសុទ្ធតែផ្អែកលើច្បាប់ឡើយ។ ទោះបីជាការធ្វើដូច្នេះប្រហែលជាមធ្យោបាយធ្វើចំណាត់ការដ៏ល្អមួយសម្រាប់ភាគីដែលមានអារម្មណ៍ថា ខ្លួនបានធ្វើខុសក៏ដោយ ក៏វាបង្កើតឱ្យមានភាពមិនច្បាស់លាស់កាន់តែធំចំពោះលទ្ធផល។ ជម្រើសនេះអាចរកបានលុះត្រាតែភាគីទាំងអស់យល់ព្រម ពុំនោះទេវេទិកាមជ្ឈត្តកម្មធ្វើសេចក្តីសម្រេចដោយផ្អែកលើច្បាប់ដែលមានជាធរមាន។[២៣៩]

### ខ) បទដ្ឋានឧស្សាហកម្ម ឬពាណិជ្ជកម្ម

ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មក៏ចែងផងដែរថា ក្នុងគ្រប់ករណីទាំងអស់ "វេទិកាមជ្ឈត្តកម្មត្រូវយកចិត្តទុកដាក់ផងដែរ ដល់ទម្លាប់ផ្នែកពាណិជ្ជកម្ម ដែលអនុវត្តបានចំពោះមុខជំនួញ"។[២៤០] ខ្លឹមសារត្រង់នេះ ហាក់ដូចជាចង្អុលបង្ហាញថា បញ្ញត្តិនេះនឹងអនុវត្តទោះបីជាច្បាប់ដែលភាគីវិវាទបានជ្រើសរើស មិនបានពិចារណាអំពីទម្លាប់ផ្នែកពាណិជ្ជកម្ម និងឧស្សាហកម្មក៏ដោយ។[២៤១]

### គ) សេចក្តីសម្រេចដោយសម្លេងភាគច្រើន

ប្រសិនបើវេទិកាមានមជ្ឈត្តករច្រើនជាងម្នាក់ នោះសេចក្តីសម្រេចរបស់វេទិកាអាចធ្វើឡើងដោយសម្លេងភាគច្រើននៃសមាជិក។[២៤២]

---

[២៣៧] *ដូចមុន* មាត្រា ៣៦(៣)។ ប្រការនេះមិនបញ្ជាក់ថា ការអនុញ្ញាតនេះត្រូវតែមាននៅក្នុងកិច្ចព្រមព្រៀងដើមរបស់ភាគីវិវាទឡើយ ។ គូតែមានភាពប្រាកដតាំងពីពេលចាប់ផ្តើមដំណើរការ ថាតើមជ្ឈត្តករបានទទួលអំណាចឱ្យធ្វើក្នុងសមត្ថភាពនេះឬទេ ។ *ការជួយស្រុះស្រួល* ពេលខ្លះ នៅក្នុងភាសាឡាតាំង សំដៅដល់ *សមធម៌* ដែលមានន័យត្រង់ថា "ស្របតាមអ្វីដែលត្រូវ និងអ្វីដែលល្អ"។

[២៣៨] *The Halbout & Matenec HG v. Hanin,* Court de Cassation [France], សាលារដ្ឋប្បវេណីទី ២ (ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០១)។

[២៣៩] *ដូចមុន ។*

[២៤០] *ដូចមុន* មាត្រា ៣៦(៤)។

[២៤១] នេះគឺជាផ្នែកដែលអាចមានភាពមិនច្បាស់លាស់ ។ មជ្ឈត្តករអាចមានទំនាស់រវាងច្បាប់ដែលអនុវត្ត និងលក្ខខណ្ឌតម្រូវនៃច្បាប់មជ្ឈត្តការផ្នែកពាណិជ្ជកម្មនេះ។

[២៤២] *ដូចមុន* មាត្រា ៣៧ ។

### ឃ) វិធានក្នុងករណីខកខាន

ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មមិនមានផ្តល់នូវវិធានក្នុងករណីដែលភាគីម្ខាងខកខានមិនបានគោរព តាមវិធានទាំងនោះឡើយ ។ ប្រសិនបើភាគីប្តឹងបានខកខានមិនបានបញ្ជូនបណ្តឹងទាមទាររបស់ខ្លួន ឱ្យស្របតាមវិធាននេះ វេទិកាមជ្ឈត្តកម្មត្រូវបញ្ចប់ដំណើរការនោះ ។[២៤៣] ផ្ទុយមកវិញ ប្រសិនបើភាគីឆ្លើយតបខកខានមិនបានបញ្ជូនពាក្យដោះសាររបស់ខ្លួនទេ វេទិកាត្រូវបន្តដំណើរការមជ្ឈត្តការនោះនិង មិនត្រូវបកស្រាយថាការខកខាននោះគឺជាការសារភាពឡើយ ។[២៤៤]

ប្រសិនបើភាគីទាំងពីរខកខានមិនបានបង្ហាញខ្លួននៅក្នុងសវនាការ ឬខកខានមិនបានផ្តល់ភស្តុតាងជាឯកសារនានានោះ វេទិកា*អាច* បន្តដំណើរការកាត់ក្តី និងធ្វើមជ្ឈត្តវិនិច្ឆ័យអំពីភស្តុតាងដែលមាននោះបាន ។[២៤៥] ការប្រើប្រាស់ពាក្យថា *អាច* នៅក្នុងប្រយោគនេះ ជំនួសឱ្យពាក្យថា *ត្រូវ* នោះបញ្ជាក់ថានៅក្នុងស្ថានភាពបែបនេះ វេទិកាអាចជ្រើសរើសមិនបន្តដំណើរការកាត់ក្តីតទៅទៀតបាន ។

គួរកត់សម្គាល់ផងដែរថា មជ្ឈមណ្ឌលមជ្ឈត្តការនានាមានវិធានក្នុងករណីខកខាន ដែលគេអាចជ្រើសរើសជំនួសឱ្យវិធានទាំងនេះរបស់ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់កម្ពុជា ។

### ង) ទម្រង់នៃមជ្ឈត្តវិនិច្ឆ័យ

ដើម្បីចងភ្ជាប់កាតព្វកិច្ច និងដើម្បីឱ្យអាចអនុវត្តបានតាមរយៈតុលាការ មជ្ឈត្តវិនិច្ឆ័យត្រូវ:

- ធ្វើឡើងជាលាយលក្ខណ៍អក្សរ និងចុះហត្ថលេខាដោយសម្លេងភាគច្រើននៃមជ្ឈត្តករ ។[២៤៦]
- បញ្ជាក់អំពីហេតុផលដែលចេញមជ្ឈត្តវិនិច្ឆ័យយោងតាម ។[២៤៧]
- បែងចែកក្នុងចំណោមភាគីវិវាទនូវថ្លៃចំណាយលើមជ្ឈត្តការតាមដែលវេទិកាមជ្ឈត្តកម្មយល់ថាសមស្រប លើកលែងតែភាគីវិវាទមានការព្រមព្រៀងគ្នាផ្សេងពីនោះ ។ ថ្លៃឈ្នួលមេធាវីដែលសមស្របរបស់ភាគីឈ្នះក្តីក៏អាចត្រូវបានបង្គាប់ឱ្យទៅភាគីម្ខាងទៀតដែរ ។[២៤៨]
- បញ្ជាក់អំពីកាលបរិច្ឆេទ និងទីកន្លែងធ្វើមជ្ឈត្តការ ។[២៤៩]

---

[២៤៣] *ដូចមុន* មាត្រា ៣៣(១) ។ វាមិនច្បាស់ទេ ថាវានឹងក្លាយជាការបញ្ជាក់ឡើងវិញចុងក្រោយ អំពីការទាមទារធ្វើមជ្ឈត្តការដដែលក្នុងពេលអនាគត ។

[២៤៤] *ដូចមុន* មាត្រា ៣៣(២) ។

[២៤៥] *ដូចមុន* មាត្រា ៣៣(៣) ។

[២៤៦] *ដូចមុន* មាត្រា ៣៩(១) ។ សម្លេងភាគច្រើន (ជំនួសឱ្យហត្ថលេខាទាំងអស់) ត្រូវបានអនុញ្ញាត ដរាបណាមានមូលហេតុសម្រាប់ការលុបចោលហត្ថលេខាណាមួយ ។

[២៤៧] *ដូចមុន* មាត្រា ៣៩(២) ។ មានការលើកលែងពីរយ៉ាង : លើកលែងតែគូភាគីបានព្រមព្រៀងគ្នាថា មិនចាំបាច់មានមានហេតុផល ឬលើកលែងតែមជ្ឈត្តវិនិច្ឆ័យធ្វើឡើងដោយផ្អែកលើការដោះស្រាយស្របតាមមាត្រា ៣៨ ។

[២៤៨] *ដូចមុន* មាត្រា ៣៩(៣) ។

- ភាគីនីមួយៗត្រូវទទួលបានមជ្ឈត្តវិនិច្ឆ័យដែលមានចុះហត្ថលេខាមួយច្បាប់។[២៥០]

រាល់ការស្រុះស្រួលដែលសម្រេចបានក្រោមមាត្រា៣៨ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ត្រូវគោរពតាមលក្ខខណ្ឌតម្រូវដូចគ្នានេះ ដើម្បីធ្វើឱ្យមានអានុភាព និងប្រសិទ្ធភាពជាសាលក្រម។[២៥១] ការស្រុះស្រួលនោះក៏ត្រូវបញ្ជាក់ផងដែរថា វាគឺជាមជ្ឈត្តវិនិច្ឆ័យ។[២៥២]

## ៦. *ការប្តឹងតវាស្រ័យ និងការដាក់ឱ្យអនុវត្ត*

### ក) ការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ

យោងតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងច្បាប់ស្តីពីមជ្ឈត្តការអន្តរជាតិភាគច្រើន មជ្ឈត្តវិនិច្ឆ័យ**មិន**អាចប្តឹងជំទាស់បានឡើយ លើកលែងតែនៅក្នុងកាលៈទេសៈដែលរិតត្បិតបំផុត។ ការអនុញ្ញាតឱ្យភាគីម្ខាងធ្វើការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យដោយងាយស្រួល នឹងធ្វើឱ្យបាត់អត្ថប្រយោជន៍របស់មជ្ឈត្តការដ៏សំខាន់បំផុតមួយ ពោលគឺលទ្ធភាពក្នុងការផ្តល់នូវដំណោះស្រាយវិវាទយ៉ាងឆាប់រហ័ស មានប្រសិទ្ធភាព និងប្រកបដោយលក្ខណៈវិជ្ជាជីវៈ។ គេអាចនិយាយម្យ៉ាងទៀតថា ភាគីវិវាទនឹងមិនរកបាននូវការលើកទឹកចិត្តពិតប្រាកដក្នុងការចាប់ផ្តើមមជ្ឈត្តការឡើយ ប្រសិនបើសេចក្តីសម្រេចរបស់វា អាចត្រូវបានប្តឹងជំទាស់យ៉ាងងាយស្រួលទៅតុលាការនោះ។

ដោយហេតុនេះ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មចែងតែអំពីមូលហេតុតិចតួចបំផុតប៉ុណ្ណោះក្នុងការ *លុបចោល* (ធ្វើមោឃកម្ម) នូវមជ្ឈត្តវិនិច្ឆ័យណាមួយ។ មិនមានមូលហេតុណាមួយទាំងនេះតម្រូវឱ្យមានការពិនិត្យមើលឡើងវិញអំពីលក្ខណសម្បត្តិនៃភស្តុតាង និងសេចក្តីសម្រេចឡើយ។ ទោះជាយ៉ាងណា តុលាការកម្ពុជាអាចលុបចោលនូវមជ្ឈត្តវិនិច្ឆ័យណាមួយបានប្រសិនបើៈ

- ភាគីមួយនៃកិច្ចព្រមព្រៀងផ្សះផ្សា...អសមត្ថភាពនៅពេលចុះកិច្ចព្រមព្រៀងនោះ ឬមួយ កិច្ចព្រមព្រៀងនោះគ្មានសុពលភាព យោងតាមច្បាប់ដែលគ្រប់គ្រងវា ឬ
- ភាគីម្ខាងមិនបានទទួលការជូនដំណឹងត្រឹមត្រូវអំពីការតែងតាំងមជ្ឈត្តករ ឬអំពីដំណើរការមជ្ឈត្តការនោះ ឬមិនអាចបង្ហាញពីអង្គហេតុរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ឬ
- មជ្ឈត្តវិនិច្ឆ័យដែលទាក់ទិននឹងវិវាទនោះ ពុំគោរពតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងផ្សះផ្សា ឬ
- ការបង្កើតវេទិកាមជ្ឈត្តកម្ម ឬដំណើរការមជ្ឈត្តការ ពុំស្របតាមកិច្ចព្រមព្រៀងមជ្ឈត្តការ ឬ
- កម្មវត្ថុនៃវិវាទមិនអាចដោះស្រាយបានដោយមជ្ឈត្តការឡើយ យោងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬ
- មជ្ឈត្តវិនិច្ឆ័យនោះ នឹងផ្ទុយពីនយោបាយសាធារណៈរបស់ព្រះរាជាណាចក្រកម្ពុជា។[២៥៣]

---

[២៤៩] *ដូចមុន* មាត្រា ៣៩(៤)។

[២៥០] *ដូចមុន* មាត្រា ៣៩(៥)។

[២៥១] *ដូចមុន* មាត្រា ៣៨(៣)។

[២៥២] *ដូចមុន*។

មូលហេតុចំនួនបួនដំបូងត្រូវតែបានលើកឡើង និងបញ្ជាក់ដោយភាគី។ តុលាការដែលទទួលពិនិត្យឡើងវិញ អាចពិចារណាអំពីមូលហេតុចំនួនពីរចុងក្រោយ *sua sponte* (តាមការព្រមព្រៀងផ្ទាល់របស់ខ្លួន)។[២៥៤] ចូរកត់សម្គាល់ថា ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មចែងថា តុលាការកម្ពុជា*អាច* លុបចោលមជ្ឈត្តវិនិច្ឆ័យដោយយោងតាមមូលហេតុទាំងនេះ ប៉ុន្តែមិន *តម្រូវ* ថាត្រូវតែធ្វើដូច្នេះនោះទេ។ ភាគីដែលស្វែងរកការលុបចោលមជ្ឈត្តវិនិច្ឆ័យ ត្រូវដាក់ពាក្យសុំទៅសាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល៣០ថ្ងៃ ក្រោយពេលទទួលបានលិខិតជូនដំណឹងអំពីមជ្ឈត្តវិនិច្ឆ័យនោះ។[២៥៥] បណ្តឹងសាទុក្ខពីសាលាឧទ្ធរណ៍ទៅតុលាការកំពូលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើឡើងក្នុងរយៈពេល១៥ថ្ងៃ ក្រោយពេលសាលាឧទ្ធរណ៍ចេញសាលដីការួច។[២៥៦] នៅក្នុងកាលៈទេសៈសមស្រប តុលាការកម្ពុជាអាចផ្អាកដំណើរការកាត់ក្តីនៅក្នុងតុលាការសិន ដើម្បីអនុញ្ញាតឱ្យវេទិកាមជ្ឈត្តកម្មបន្តដំណើរការកាត់ក្តី ឬចាត់វិធានការលុបបំបាត់មូលហេតុនៃការលុបចោលមជ្ឈត្តវិនិច្ឆ័យនោះ ដើម្បីឱ្យវេទិកាមជ្ឈត្តកម្មអាចបញ្ចប់ដំណើរការមជ្ឈត្តការនោះស្របតាមច្បាប់។

### ៩) ការទទួលស្គាល់ និងការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ

ក្រោយពេលចេញមជ្ឈត្តវិនិច្ឆ័យរួច ភាគីឈ្នះក្តីត្រូវតែដាក់ឱ្យអនុវត្តនូវមជ្ឈត្តវិនិច្ឆ័យនេះ ប្រសិនបើភាគីចាញ់ក្តីខកខានមិនបានគោរពតាមវិមជ្ឈត្តវិនិច្ឆ័យនេះ។ វេទិកាមជ្ឈត្តកម្មគ្មានអំណាចក្នុងការអនុវត្តដោយខ្លួនឯងទេ។ ពោលគឺពុំមាននគរបាលផ្នែកមជ្ឈត្តការឡើយ។ អាស្រ័យហេតុនេះ ភាគីវិវាទត្រូវផ្អែកលើប្រព័ន្ធតុលាការដើម្បីអនុវត្តមជ្ឈត្តវិនិច្ឆ័យនោះ។ យោងតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម មជ្ឈត្តវិនិច្ឆ័យ នៅពេលដែលបានចូលជាធរមានរួច គឺមានភាពដូចគ្នានឹងសាលក្រមតុលាការដែរ ក្នុងការដាក់ឱ្យអនុវត្ត។

ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មចែងថា:

---

[២៥៣] *ដូចមុន* មាត្រា ៤៤(២)(ក)-(ខ)។ ពាក់ព័ន្ធនឹងកាលៈទេសៈចុងក្រោយ, គោលនយោបាយសាធារណៈ កំណត់ពន្យល់របស់ UNICTRAL ចែងថា ចំណុចនេះនឹងត្រូវគេយល់ថាជា "ការងាកចេញយ៉ាងខ្លាំងពីដំណើរការយុត្តិធម៌តាមនីតិវិធីជាមូលដ្ឋាន"។ កំណត់ពន្យល់របស់លេខាធិការដ្ឋាន UNCITRAL ស្តីពីច្បាប់គម្រូស្តីពីមជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ ឆ្នាំ១៩៨៥ តាមវិសោធនកម្មឆ្នាំ២០០៦ កថាខ័ណ្ឌ ៤៦ (ឆ្នាំ២០០៦) *មាននៅ* http://1.1.1.1/482468920/477512240T071020172009.txt.binXMysM0dapplication/pdfXsysM0dhttp://www.uncitral.org/pdf/english/texts/arbitration/ml-arb/MLARB_explanatory_note.pdf (ចូលទស្សនាចុងក្រោយ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨) [អំណឹះតទៅហៅកាត់ថា កំណត់ពន្យល់ UNCITRAL]។

[២៥៤] *ដូចមុន* មាត្រា ៤៤(២)(ខ), មាត្រា ៤៦។ ភាសានេះមានភាពមិនច្បាស់លាស់ ពាក់ព័ន្ធ នឹងថាតើភាគីដែលចង់ប្តឹងអាចលើកឡើងនូវមូលហេតុមួយ ឬទាំងពីរនៃមូលហេតុចុងក្រោយទាំងនេះដែរឬទេ ។ ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្តែង តុលាការប្រហែលជាមានករណីយកិច្ចត្រូវធ្វើការពិចារណាអំពីបញ្ហាទាំងនេះ ជាពិសេសប្រសិនបើតុលាការចង់អនុវត្តមជ្ឈត្តវិនិច្ឆ័យ។

[២៥៥] *ដូចមុន* មាត្រា ៤២ និង ៤៤(៣)។ ចំណុចនេះមានភាពតឹងតែងជាងច្បាប់មជ្ឈត្តការ UNCITRAL ដែលផ្តល់ពេលវេលាចំនួនបីខែ សម្រាប់ដាក់ ពាក្យសុំលុបចោល។ នៃច្បាប់មជ្ឈត្តការ UNCTIRAL កំណត់សម្គាល់ *ខាងលើ* លេខ១៨៥ មាត្រា ៣៤(៣)។

[២៥៦] *ដូចមុន* មាត្រា ៤៣។

*មជ្ឈត្តវិនិច្ឆ័យ ទោះបីជាបានធ្វើនៅប្រទេសណាក៏ដោយ ក៏ត្រូវបានទទួលស្គាល់ថាជាកាតព្វកិច្ច ហើយបន្ទាប់ពីបានពាក្យសុំជាលាយលក្ខណ៍អក្សរទៅតុលាការមានសមត្ថកិច្ចរួច ត្រូវបានអនុវត្ត ...*[២៥៧]

ពាក់ព័ន្ធនឹងបញ្ហានីតិវិធី ភាគីដែលស្វែងរកការទទួលស្គាល់ និងដាក់ឱ្យអនុវត្ត ត្រូវផ្តល់ដល់តុលាការនូវសំណៅដើម ឬសំណៅចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវ នៃមជ្ឈត្តវិនិច្ឆ័យ និងកិច្ចព្រមព្រៀងមជ្ឈត្តការ ព្រមទាំងសំណៅបកប្រែជាភាសាខ្មែរដែលមានការបញ្ជាក់ត្រឹមត្រូវ ក្នុងករណីដែលសំណៅដើមមិនមែនសរសេរជាភាសាខ្មែរ។[២៥៨] នេះគឺជាបញ្ហាគម្រូមួយ ហើយក្រោយពេលដាក់ជូនត្រឹមត្រូវរួច តុលាការត្រូវទទួលស្គាល់ និងអនុវត្តមជ្ឈត្តវិនិច្ឆ័យប្រៀបដូចជាមជ្ឈត្តវិនិច្ឆ័យនោះគឺជាសាលក្រមស្ថាពរ និងអាចអនុវត្តបានដូច្នោះដែរ។

ទោះជាយ៉ាងនេះក្តី តុលាការអាចអាចបដិសេធក្នុងការអនុវត្តមជ្ឈត្តវិនិច្ឆ័យនោះបាន ដោយយោងតាមកាលៈទេសៈរឹតត្បិតមួយចំនួនដូចខាងក្រោម:

- ភាគីម្ខាងនៃកិច្ចព្រមព្រៀងផ្សះផ្សា អសមត្ថភាពនៅពេលចុះកិច្ចព្រមព្រៀងនេះ ឬកិច្ចព្រមព្រៀងនេះគ្មានសុពលភាពយោងតាមច្បាប់គ្រប់គ្រង ឬ
- ភាគីម្ខាងពុំបានព័ត៌មានត្រឹមត្រូវអំពីការតែងតាំងមជ្ឈត្តករ ឬអំពីដំណើរការមជ្ឈត្តកម្ម ឬ ពុំអាចបង្ហាញពីករណីរបស់ខ្លួនបានដោយប្រសិទ្ធភាព ឬ
- មជ្ឈត្តវិនិច្ឆ័យដែលទាក់ទងនឹងវិវាទនោះ ពុំគោរពតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងផ្សះផ្សា ឬ
- ការបង្កើតវេទិកាមជ្ឈត្តកម្ម ឬដំណើរការមជ្ឈត្តការពុំស្របតាមកិច្ចព្រមព្រៀងរបស់ភាគីវិវាទ ឬ
- មជ្ឈត្តវិនិច្ឆ័យពុំបានក្លាយជាកាតព្វកិច្ចនៅឡើយ សម្រាប់ភាគីវិវាទ ឬ
- កម្មវត្ថុនៃវិវាទនោះពុំអាចដោះស្រាយតាមមជ្ឈត្តការឡើយ យោងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬ
- ការទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យ អាចផ្ទុយនឹងនយោបាយសាធារណៈរបស់ព្រះរាជាណាចក្រកម្ពុជា។[២៥៩]

មូលហេតុចំនួនប្រាំដំបូងត្រូវតែបានលើកឡើង និងបញ្ជាក់ដោយភាគីម្ខាង។ មូលហេតុចំនួនពីរចុងក្រោយអាចលើកឡើងដោយតុលាការដោយខ្លួនឯង។ ចូរកត់សម្គាល់ថា មូលហេតុក្នុងការបដិសេធការទទួលស្គាល់ ឬការអនុវត្តមជ្ឈត្តវិនិច្ឆ័យទាំងនេះ គឺស្ទើរតែដូចគ្នាទាំងស្រុងនឹងមូលហេតុសម្រាប់ការលុបចោលមជ្ឈត្តវិនិច្ឆ័យ ដែលបានរៀបរាប់ពីខាងលើ។ មូលហេតុបន្ថែមដើម្បីបដិសេធការអនុវត្តគឺថា មជ្ឈត្តវិនិច្ឆ័យមិនទាន់ភ្ជាប់កាតព្វកិច្ចលើគូភាគី នៅក្នុងប្រទេសដែលមជ្ឈត្តវិនិច្ឆ័យនោះត្រូវបានធ្វើឡើង។ ចូរកត់សម្គាល់ផងដែរថា ខ្លឹមសារដែលបានប្រើគឺមានលក្ខណៈស្រដៀងគ្នា

---

[២៥៧] *ដូចមុន* មាត្រា ៤៥(១)។

[២៥៨] *ដូចមុន* មាត្រា ៤៥(២)។ *សូមមើលផងដែរ* ក.ន.រ-ព.ក.,កំណត់សម្គាល់ *ខាងលើ* លេខ ៧ មាត្រា ៣៥៣ ដែលឆ្លុះបញ្ចាំងភាគច្រើនអំពីការអនុវត្ត ច.ម.ព ។

[២៥៩] *ដូចមុន* មាត្រា ៤៦(១)-(២)។ *ដូចមុន* មាត្រា ៤៤(២)(ក)-(ខ)។ ពាក់ព័ន្ធនឹងកាលៈទេសៈចុងក្រោយ, គោលនយោបាយសាធារណៈ កំណត់ពន្យល់របស់ UNICTRAL ចែងថា ចំណុចនេះនឹងត្រូវគេយល់ថាជា "ការងាកចេញយ៉ាងខ្លាំងពីដំណើរការយុត្តិធម៌តាមនីតិវិធីជាមូលដ្ឋាន"។ កំណត់ពន្យល់របស់ UNCITRAL កំណត់សម្គាល់ *ខាងលើ* លេខ២៥៣, កថាខ័ណ្ឌ៤៦។

ទៅនឹងបញ្ញត្តិដែលថា តុលាការកម្ពុជា *អាច* បដិសេធការអនុវត្តមជ្ឈត្តវិនិច្ឆ័យផ្នែកតាមមូលហេតុទាំងនេះ ប៉ុន្តែ មិន*តម្រូវ*ឱ្យត្រូវតែដូច្នេះឡើយ។

តុលាការអាចផ្អាកដំណើរការដាក់ឱ្យអនុវត្ត ដោយរង់ចាំលទ្ធផលនៃវិធានការនៅក្នុងតុលាការផ្សេងទៀត ដែលតាមរយៈនោះ ភាគីម្ខាងកំពុងតែស្វែងរកការលុបចោលមជ្ឈត្តវិនិច្ឆ័យ។ តុលាការក៏អាចបង្គាប់ឱ្យភាគីដែលស្វែងរកការអនុវត្តត្រូវផ្ដល់នូវប្រាក់ធានាសមស្របផងដែរ។[២៦០]

### ត) ការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យអន្តរជាតិ

ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មអនុវត្តចំពោះមជ្ឈត្តការទាំងក្នុងស្រុក ទាំងអន្តរជាតិ។ មជ្ឈត្តការត្រូវបានចាត់ទុកថាជា "អន្តរជាតិ" ប្រសិនបើៈ

(១) ភាគីវិវាទ និងកិច្ចព្រមព្រៀងផ្សះផ្សា មានទីកន្លែងធ្វើពាណិជ្ជកម្មនៅក្នុងប្រទេសផ្សេងពីគ្នា ក្នុងពេលសម្រេចកិច្ចព្រមព្រៀងនោះ ឬ

(២) ទីកន្លែងមួយក្នុងចំណោមទីកន្លែងខាងក្រោម ស្ថិតនៅក្រៅប្រទេសធ្វើពាណិជ្ជកម្មរបស់ភាគីវិវាទៈ

- ទីកន្លែងធ្វើមជ្ឈត្តការៈ ប្រសិនបើបានកំណត់នៅក្នុង ឬ បានយោងក្នុងកិច្ចព្រមព្រៀងផ្សះផ្សា
- ទីកន្លែងដែលកាតព្វកិច្ចសំខាន់នៃទំនាក់ទំនងពាណិជ្ជកម្មបានប្រព្រឹត្តទៅ ឬទីកន្លែងដែល ជិតជាងគេពាក់ព័ន្ធនឹងវិវាទ ឬ

(៣) ភាគីវិវាទបានព្រមព្រៀងជាក់លាក់ថា រឿងនៃកិច្ចព្រមព្រៀងផ្សះផ្សា ទាក់ទងនឹងប្រទេសលើសពីមួយ។[២៦១]

តាមគោលបំណងនៃកថាខណ្ឌនេះ :

- ប្រសិនបើភាគីមួយមានទីកន្លែងប្រកបពាណិជ្ជកម្មលើសពីមួយ ទីកន្លែងដែលដែលមានទាក់ទងជិតស្និទ្ធជាងគេបំផុតនឹង កិច្ចព្រមព្រៀងផ្សះផ្សា គឺជាទីកន្លែងពាណិជ្ជកម្ម
- ប្រសិនបើភាគីមួយមិនមានទីកន្លែងប្រកបពាណិជ្ជកម្មទេ ការយោងក្នុងច្បាប់នេះគឺទីលំនៅអចិន្ត្រៃយ៍របស់ភាគី នោះ។[២៦២]

ពាក់ព័ន្ធនឹងមជ្ឈត្តការអន្តរជាតិ ការអនុម័តច្បាប់ស្ដីពីមជ្ឈការផ្នែកពាណិជ្ជកម្ម បានធ្វើឱ្យប្រទេសកម្ពុជាបំពេញតាមលក្ខខណ្ឌតម្រូវនៃអនុសញ្ញាក្រុងញូវយ៉កស្ដីពីការទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យបរទេសឆ្នាំ១៩៥៨ ("អនុសញ្ញាក្រុងញូវយ៉ក") បានទាំងស្រុង។ អនុសញ្ញាក្រុងញូវយ៉ក ផ្ដល់នូវក្របខណ្ឌអន្តរជាតិដ៏ចម្បងសម្រាប់ការទទួលស្គាល់ និងការ

---

[២៦០] *ដូចមុន* មាត្រា ៤៦(៣)។

[២៦១] *ដូចមុន* មាត្រា ២(ជ)(១)-(៣)។

[២៦២] *ដូចមុន* មាត្រា ២(៤)។

អនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេស និងមជ្ឈត្តវិនិច្ឆ័យដែលមានលក្ខណៈអន្តរជាតិ។ អនុសញ្ញានេះត្រូវបានអនុម័តឡើង ក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិមុនពេលបង្កើត UNCITRAL។ អនុសញ្ញាក្រុងញូវយ៉កបានចូលជាធរមាននៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ១៩៦០។[២៦៣] មានប្រទេសចំនួនជាង ១៤២ បានផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងនេះ រួមទាំងដៃគូពាណិជ្ជកម្មចម្បងៗទាំងអស់របស់ប្រទេសកម្ពុជាផងដែរ។[២៦៤]

យោងតាមអនុសញ្ញាក្រុងញូវយ៉ក ប្រទេសកម្ពុជាត្រូវបានតម្រូវឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេស។ ប៉ុន្តែពុំមានវិធីសាស្ត្រអនុវត្តច្បាស់លាស់ទេ រហូតទាល់តែច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនេះត្រូវបានអនុម័ត។ ឥឡូវនេះដោយសារតែច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម បានចូលជាធរមាន កម្ពុជាមានក្របខណ្ឌផ្លូវច្បាប់ច្បាស់លាស់មួយសម្រាប់ដំណើរការអនុវត្តនេះ។ ដូចជាមាត្រា៤៥បានចែងថា *"មជ្ឈត្តវិនិច្ឆ័យ ទោះជាបានធ្វើនៅក្នុងប្រទេសណាក៏ដោយត្រូវបានគេទទួលស្គាល់ថាជាកាតព្វកិច្ច...ត្រូវបានអនុវត្ត..."*[២៦៥]។ លើកលែងតែមានមូលហេតុមួយចំនួនតូចប៉ុណ្ណោះសម្រាប់បដិសេធ តុលាការកម្ពុជាត្រូវអនុវត្តមជ្ឈត្តវិនិច្ឆ័យនោះ។

ដូច្នេះ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មមិនត្រឹមតែចែងអំពីការអនុវត្តមជ្ឈត្តវិនិច្ឆ័យកម្ពុជាប៉ុណ្ណោះទេ ថែមទាំងចែងអំពីការអនុវត្តមជ្ឈត្តវិនិច្ឆ័យអន្តរជាតិផងដែរ។ ជាឧទាហរណ៍ វិវាទរវាងក្រុមហ៊ុនកូរ៉េ និងក្រុមហ៊ុនថៃត្រូវបានធ្វើមជ្ឈត្តការនៅក្នុងក្រុងហុងកុង និងអាចអនុវត្តប្រឆាំងនឹងភាគីនីមួយៗនៅក្នុងប្រទេសកម្ពុជា ប្រសិនបើភាគីនីមួយៗមានទ្រព្យសម្បត្តិនៅទីនេះ។

អនុសញ្ញានេះ និងរបបអនុវត្តន៍ជាអន្តរជាតិ គឺជាមូលហេតុមួយក្នុងចំណោមមូលហេតុដែលក្រុមហ៊ុនអន្តរជាតិចូលចិត្តធ្វើមជ្ឈត្តការជាង។ ក្នុងករណីមានវិវាទ នឹងមានការធានាថាមជ្ឈត្តវិនិច្ឆ័យនឹងអាចអនុវត្តបានស្ទើរតែនៅគ្រប់ទីកន្លែងនៅក្នុងពិភពលោក។ ដោយសារប្រទេសកម្ពុជាគឺជាផ្នែកមួយនៃប្រព័ន្ធអនុវត្តន៍នេះ ក្រុមហ៊ុនអន្តរជាតិកាន់តែមានបំណងចង់ធ្វើការវិនិយោគនៅក្នុងប្រទេសកម្ពុជាថែមទៀត។

---

[២៦៣] *សូមមើល* វេបសាយត៍របស់ UNCITRAL *មាននៅ* http://www.uncitral.org/uncitral/en/uncitral_texts/arbitration/NYConvention_status.html (ចូលទស្សនាចុងក្រោយថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨)។ ក្នុងឆ្នាំ២០០១ ប្រទេសកម្ពុជាបានអនុម័ត **ច្បាប់ស្តីពីការអនុវត្តនៃអនុសញ្ញាក្រុងញូយ៉កស្តីពីការទទួលស្គាល់ និងអនុវត្ត មជ្ឈត្តវិនិច្ឆ័យបរទេស,** ដែលផ្តល់សច្ចាប័នអោយប្រទេសកម្ពុជាចូលរួមក្នុងរបបអនុវត្តនេះនៅទូទាំងពិភពលោក។ យ៉ាងណាមិញ រហូតមកទល់បច្ចុប្បន្ននេះ នៅមិនទាន់មានករណីដែលតុលាការកម្ពុជាចេញសេចក្តីសម្រេចលើលទ្ធភាពអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេសនៅឡើយ។ *សូមមើល* ក្រសួងពាណិជ្ជកម្មសហរដ្ឋអាមេរិក, *មគ្គុទ្ទេសក៍ពាណិជ្ជកម្មតាមប្រទេសសម្រាប់ប្រទេសកម្ពុជា,* ទំព័រ៥៤ (ឆ្នាំ២០០៦)។

[២៦៤] *ដូចមុន។*

[២៦៥] ច.ម.ព កំណត់សម្គាល់ *ខាងលើ* លេខ១០១, មាត្រា ៤៥។

១. [illegible]

[illegible] UNCITRAL [illegible]
[illegible]
[illegible]
[illegible]
[illegible]
[illegible]
[illegible]
[illegible]
[illegible]
[illegible]
[illegible] UNCITRAL [illegible]

[illegible]
[illegible]
**[illegible]**
**[illegible]**

[illegible]

[illegible]

[illegible]

[illegible]

*ម.ជ.ម មានសក្តានុពលក្នុងការធ្វើការកែលម្អគួរឱ្យកត់សម្គាល់ដល់បរិយាកាសពាណិជ្ជកម្មដោយផ្តល់ដល់វិស័យពាណិជ្ជកម្មនូវជម្រើសដែលចាំបាច់ច្រើន ចំពោះយន្តដំណោះស្រាយវិវាទដែលមានស្រាប់ ។ ម.ជ.ម ក៏អាចកែលម្អបរិយាកាសពាណិជ្ជកម្មរបស់ប្រទេសកម្ពុជាផងដែរ ដោយលើកកម្ពស់ការទុកចិត្តផ្នែកពាណិជ្ជកម្ម ការបង្កើនភាពច្បាស់លាស់ និងការបង្ហាញនូវឆន្ទៈពីសំណាក់រដ្ឋាភិបាលក្នុងការបង្កើតបរិយាកាសច្បាប់ និងបទដ្ឋានគតិយុត្តិកាន់តែប្រសើរ ។*[២៧០]

នាពេលអនាគត ម.ជ.ម អាចក្លាយជាគូប្រកួតប្រជែងក៏សំខាន់ចំពោះដៃគូក្នុងតំបន់របស់ខ្លួននៅក្នុងក្រុងសិង្ហបុរី កូឡាឡាំពួរ និងបាងកក ។ ជាមួយ ម.ជ.ម ក្រសួងពាណិជ្ជកម្មមានឱកាសដ៏គួរឱ្យចាប់អារម្មណ៍មួយ ក្នុងការបង្កើតឥទ្ធិពលជាវិជ្ជមានលើសបាតុមន៍ច្បាប់ និងពាណិជ្ជកម្មនៅក្នុងប្រទេសកម្ពុជា ។

---

[២៧០] [illegible] **ត្របញ្ហាពាណិជ្ជកម្ម** ធនាគារពិភពលោក/សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ, ខែសីហា ឆ្នាំ២០០៧, នៅទំព័រទី ៤, manenA http://www.ifc.org/ifcext/mekongpsdf.nsf/AttachmentsByTitle/BIB-14-CAM-Eng/$FILE/BIB-14-CAM-Eng.pdf (ចូលទស្សនាចុងក្រោយ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨) ។

## ច. បញ្ហាក្រមសីលធម៌

ដូចគ្នានឹងជាចៅក្រមដែរ មជ្ឈត្តករគឺត្រូវគិតពីបញ្ហាក្រមសីលធម៌។ កង្វះខាតខាងក្រមសីលធម៌គឺជាបញ្ហាដ៏អាក្រក់សម្រាប់មជ្ឈមណ្ឌលមជ្ឈត្តការ។ ក្នុងឆ្នាំ១៩៥៦ គណៈមេធាវីអាមេរិក និងសមាគមមជ្ឈត្តការអាមេរិក បានបង្កើតក្រមសីលធម៌មួយសម្រាប់មជ្ឈត្តករនៅក្នុងវិវាទពាណិជ្ជកម្ម។ ខាងក្រោមនេះ គឺជាបញ្ជីចំណងជើងនៃបញ្ញត្តិនីមួយៗនៅក្នុងក្រមនេះ ។ បញ្ជីនេះមានប្រយោជន៍ក្នុងការបង្ហាញអំពីប្រភេទនៃបញ្ហាប្រឈមដែលមជ្ឈត្តករជួបប្រទះ:

| | |
|---|---|
| គោលការណ៍ទី ១ | មជ្ឈត្តករត្រូវប្រកាន់ខ្ជាប់នូវសច្ចធម៌ និង យុត្តិធម៌នៃដំណើរការមជ្ឈត្តការ។ |
| គោលការណ៍ទី ២ | មជ្ឈត្តករត្រូវលាតត្រដាងអំពីផលប្រយោជន៍ ឬ ទំនាក់ទំនងដែលទំនងជាមានឥទ្ធិពលលើភាពមិន លម្អៀង ឬ ដែលអាចបង្កើតនូវរូបភាពនៃភាពលម្អៀង។ |
| គោលការណ៍ទី ៣ | មជ្ឈត្តករត្រូវជៀសវាងភាពមានអាកប្បកិរិយាមិនសមរម្យឬការស្តែងឱ្យឃើញភាពមានអាកប្បកិរិយា មិនសមរម្យនៅក្នុងការទំនាក់ទំនងជាមួយគូភាគី។ |
| គោលការណ៍ ៤ | មជ្ឈត្តករត្រូវដឹកនាំវេទិកាមជ្ឈត្តកម្មដោយយុត្តិធម៌ និង ដោយខ្នះខ្នែង។ |
| គោលការណ៍ទី ៥ | មជ្ឈត្តករត្រូវធ្វើសេចក្តីសម្រេចប្រកបដោយយុត្តិធម៌ ឯករាជ្យ និង វិចារណញ្ញាណ។ |
| គោលការណ៍ ៦ | មជ្ឈត្តករត្រូវមានភាពស្មោះត្រង់ចំពោះទំនាក់ទំនងនៃទំនុកចិត្ត និង ការរក្សាការសម្ងាត់ដែលនៅជាប់នឹងមុខងារនេះ។ |
| គោលការណ៍ទី ៧ | មជ្ឈត្តករត្រូវប្រកាន់ខ្ជាប់នូវស្តង់ដារនៃសច្ចធម៌ និងយុត្តិធម៌ នៅពេលធ្វើការរៀបចំសម្រាប់ទូទាត់ និង សងការចំណាយ។ |
| គោលការណ៍ ៨ | មជ្ឈត្តករអាចចាប់ផ្តើមធ្វើការផ្សព្វផ្សាយ ឬណែនាំអំពីសេវាមជ្ឈត្តការដែលត្រឹមត្រូវ និងពិតប្រាកដ។ |
| គោលការណ៍ទី ៩ | មជ្ឈត្តករដែលតែងតាំងឡើងដោយភាគីម្ខាង មានករណីយកិច្ចក្នុងការកំណត់ និង លាតត្រដាងអំពីឋានៈរបស់ខ្លួន និងគោរពតាមក្រមសីលធម៌នេះ លើកលែងតែមានករណីលើកលែងនៅក្នុងគោលការណ៍ទី ១០។ |
| គោលការណ៍ទី ១០ | អញ្ញត្រកម្មសម្រាប់មជ្ឈត្តករដែលត្រូវបានតែងតាំងឡើងដោយភាគីម្ខាង ដែលមិនស្ថិតក្រោមវិធាន នៃអព្យាក្រឹតភាព។[២៧១] |

មេធាវីដែលតំណាងឱ្យកូនក្តីនៅក្នុងមជ្ឈត្តការអន្តរជាតិ ក៏ត្រូវយល់ដឹងអំពីការពិចារណាលើក្រមសីលធម៌នេះផងដែរ។ ឧទាហរណ៍ ប្រសិនបើក្រុមហ៊ុនអាមេរិកត្រូវបានបង្ខំឱ្យចាប់ផ្តើមមជ្ឈត្តការអន្តរជាតិនៅក្នុងប្រទេសកម្ពុជា តើក្រុមហ៊ុនអាមេរិកនោះអាចជួលមេធាវីអាមេរិករបស់ខ្លួនដើម្បីតំណាងឱ្យក្រុមហ៊ុនរបស់ខ្លួនបានដែរឬទេ? ឬថា តើការធ្វើ

[២៧១] **ក្រមសីលធម៌សម្រាប់មជ្ឈត្តករនៅក្នុងវិវាទពាណិជ្ជកម្ម**, គណៈមេធាវីអាមេរិក និងសមាគមមជ្ឈត្តការអាមេរិក (ឆ្នាំ២០០៤), *មាននៅ* http://www.adr.org/si.asp?id=4582 (ចូលទស្សនាចុងក្រោយ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨)។ អត្ថបទទាំងស្រុងនៃក្រមនេះ មានបញ្ចូលនៅក្នុងឧបសម្ព័ន្ធនៃសៀវភៅនេះ។

ដូច្នេះត្រូវបានចាត់ទុកថាខុសច្បាប់យោងតាមច្បាប់កម្ពុជាដែរឬទេ? ឧទាហរណ៍ ប្រសិនបើកិច្ចព្រមព្រៀងមជ្ឈត្តការនោះជ្រើសរើសច្បាប់ជប៉ុនមកអនុវត្ត ប៉ុន្តែមជ្ឈត្តការធ្វើឡើងនៅក្នុងប្រទេសកម្ពុជា តើវិធានក្រមសីលធម៌នៃយុត្តាធិការណាដែលអនុវត្តចំពោះមេធាវីនៅក្នុងមជ្ឈត្តការនោះ: ជប៉ុន? កម្ពុជា? ឬ អាមេរិក? តើវិធាននៃយុត្តាធិការណាដែលអនុវត្តនៅក្នុងផ្នែកដូចជា ការរក្សាការសម្ងាត់ ករណីយកិច្ចក្នុងការរាយការណ៍អំពីអាកប្បកិរិយាអសីលធម៌ ទំនាស់ផលប្រយោជន៍ ការមិនលាតត្រដាងអំពីភស្តុតាង និង ការប៉ុនប៉ងក្នុងការជះឥទ្ធិពលលើមជ្ឈត្តករ?

ពេលខ្លះ គ្មានចម្លើយច្បាស់លាស់ចំពោះសំណួរអំពីក្រមសីលធម៌មជ្ឈត្តការទេ ជាពិសេសនៅក្នុងបរិបទអន្តរជាតិ។ ប៉ុន្តែ យ៉ាងហោចណាស់ជាការសំខាន់ត្រូវពិចារណាអំពីបញ្ហាទាំងនេះ នៅពេលតាក់តែង និងរៀបចំធ្វើមជ្ឈត្តការដែរ។

## លំហាត់: ក្រមសីលធម៌មជ្ឈត្តករ

ក. អ្នកគឺជាមេធាវីតំណាងឱ្យ ណារី នៅក្នុងរឿងក្តីការងារមួយ ដែលនាងទាមទារថានិយោជករបស់នាង គឺក្រុមហ៊ុនសណ្ឋាគារ PP បានបញ្ឈប់នាងពីការងារដោយអយុត្តិធម៌។ កិច្ចសន្យាការងាររបស់នាងតម្រូវឱ្យធ្វើមជ្ឈត្តការលើវិវាទ។ វិធាននោះតម្រូវឱ្យភាគីទាំងសងខាងជ្រើសរើសមជ្ឈត្តករម្នាក់ ហើយបន្ទាប់មកមជ្ឈត្តករទាំងពីរនាក់ នឹងជ្រើសរើសមជ្ឈត្តករទីបី។ មជ្ឈត្តករដែលជ្រើសរើសដោយសណ្ឋាគារPP មានឈ្មោះថា វ៉ាតា ដែលជាមជ្ឈត្តករដែលទទួលបានការគោរពជាអន្តរជាតិ។ ប៉ុន្តែអ្នកបានដឹងតាមរយៈការស្រាវជ្រាវឯកជនថា ក្មួយរបស់វ៉ាតា គឺជាបុគ្គលិករបស់ក្រុមហ៊ុនអាមេរិក ដែលមានភាគហ៊ុនចំនួន ១០% នៅក្នុងសណ្ឋាគារ PP នោះ។

- តើអ្នកចង់ដក វ៉ាតា ចេញពីមជ្ឈត្តករដែរឬទេ?
- តើវេទិកាមជ្ឈត្តកម្មត្រូវសម្រេចដូចម្តេច?
- តើវាមានបញ្ហាដែរឬទេដែល មជ្ឈត្តករទាំងអស់ដែលត្រូវបានជ្រើសរើសដោយភាគី បានព្រមព្រៀងថាខ្លួននឹងរក្សាអព្យាក្រឹតភាព និងឯករាជ្យភាព?
- តើវានឹងមានបញ្ហាដែរឬទេ ប្រសិនបើក្មួយម្នាក់នោះរបស់ វ៉ាតា គឺជាអ្នកបោសសំអាតដែលមានប្រាក់ខែទាបទៅវិញ?
- តើវានឹងមានបញ្ហាដែរឬទេ ប្រសិនបើក្មួយម្នាក់នោះរបស់វ៉ាតា គឺជាអ្នកគ្រប់គ្រងដែលមានប្រាក់ខែខ្ពស់ និងមានភាគហ៊ុន នៅក្នុងក្រុមហ៊ុននោះ?

ខ. អ្នកគឺជាមជ្ឈត្តករទោលនៅក្នុងរឿងក្តីមួយដែលប្តឹងដោយពលរដ្ឋមួយក្រុម ប្រឆាំងនឹងក្រុមហ៊ុនគីមីមេគង្គ។ ពលរដ្ឋដែលរស់នៅជិតរោងចក្ររបស់ក្រុមហ៊ុនមេគង្គ ទាមទារថារោងចក្រកំពុងបញ្ចេញកាកសំណល់ដែលមានគ្រោះថ្នាក់ទៅក្នុងបរិយាកាសដែលបង្កឱ្យមានបញ្ហាផ្លូវដង្ហើមដល់ប្រជាពលរដ្ឋរស់នៅក្បែរនោះ។ អ្នកមិនមែនជាអ្នករស់នៅជិតរោងចក្រនោះទេ ដូច្នេះអ្នកមិនជឿថាអ្នកមានទំនាស់ផលប្រយោជន៍នៅក្នុងរឿងក្តីនេះឡើយ។ ប៉ុន្តែនៅក្នុងដំណាក់កាលចុងក្រោយនៃដំណើរការមជ្ឈត្តការ អ្នកបានដឹងពីឯកសារខ្លះថា ក្រុមហ៊ុនមេគង្គ អាចលុបបំបាត់ចោលទាំងស្រុងនូវការបំពុលខ្យល់អាកាស ដោយការបំពាក់ប្រព័ន្ធបញ្ចេញទឹកដែលនឹងនាំកាកសំណល់ទៅកាន់ទន្លេដែលនៅក្បែរនោះ។ លទ្ធផលគឺនឹងធ្វើឱ្យមានខ្យល់អាកាសបរិសុទ្ធ ប៉ុន្តែមានការបំពុលនៅក្នុងទន្លេ។

អ្នករស់នៅឯងខ្សែទឹកខាងក្រោមចម្ងាយប្រហែលម្ភៃគីឡូម៉ែត្រពីនាះ ហើយនៅលើច្រាំងទន្លេនោះតែម្តង។ អ្នកចង់ទៅស្ទូចត្រីនៅក្នុងទន្លេនៅចុងសប្តាហ៍។ អ្នកមានការព្រួយបារម្ភថា ប្រសិនបើប្រឆាំងនឹងក្រុមហ៊ុនមេគង្គ ពួកគេនឹងត្រូវបំពាក់ប្រព័ន្ធបញ្ចេញទឹក និងបំពុលទន្លេ។ គ្មានភាគីណាមួយបានលើកឡើងពីប្រព័ន្ធបញ្ចេញទឹកនៅក្នុងរឿងក្តីនេះឡើយ ហើយអ្នកសង្ស័យថា ប្រជាពលរដ្ឋថៃមទាំងមិនដឹងអំពីជម្រើសនេះទៀតផង។ អ្នកមិនអាចប្រាកដក្នុងចិត្តថា ក្រុមហ៊ុនមេគង្គនឹងបំពាក់ប្រព័ន្ធបញ្ចេញជាតិពុលទៅក្នុងទឹក ក្នុងករណីចាញ់មជ្ឈត្តការឡើយ ព្រោះពួកគេអាចមានជម្រើសផ្សេងទៀតដែលអ្នកមិនដឹង។ អ្នកក៏មាន អារម្មណ៍ដឹងថា ក្រុមហ៊ុនមេគង្គមានអំណះអំណាងការពារខ្លួនដ៏រឹងមាំ ហើយទោះបីជាអ្នកមិនព្រួយបារម្ភអំពីទន្លេក៏ដោយ អ្នកប្រហែលជានៅតែលម្អៀងទៅរកក្រុមហ៊ុនមេគង្គ ហើយប្រឆាំងនឹងប្រជាពលរដ្ឋដដែល។

មជ្ឈត្តការនោះបានធ្វើឡើងជាងប្រាំមួយខែទៅហើយ ភាគីវិវាទបានចំណាយអស់ប្រាក់យ៉ាងច្រើនសន្ធឹកសន្ធាប់រួចមកដែរ រួមទាំងប្រជាពលរដ្ឋក្រីក្រដែលរស់នៅក្បែរនោះ។ អ្នកមានការព្រួយបារម្ភថា ប្រសិនបើអ្នកដកខ្លួនចេញនៅពេលនេះ វានឹងធ្វើឱ្យមានការចំណាយបន្ថែមជាច្រើនសន្ធឹកសន្ធាប់ចំពោះភាគីទាំងពីរ ដោយសារពួកគេនឹងត្រូវចាប់ផ្តើមចេញថ្លៃចំណាយបន្ថែម ជាពិសេសគឺក្នុងកម្រិតដែលប្រជាពលរដ្ឋដែលមិនមានលទ្ធភាពបង់បាន។

តើអ្នកត្រូវធ្វើអ្វី ?

- ប្រាប់ភាគីវិវាទថា អ្នកនឹងដកខ្លួនចេញដោយសារទំនាស់ផលប្រយោជន៍ដែលអាចមាន ហើយដែលអ្នកមិនអាចបញ្ជាក់បាន ?
- ប្រាប់ភាគីវិវាទថា អ្នកនឹងដកខ្លួនចេញដោយសារទំនាស់ផលប្រយោជន៍ដែលអាចមាន និង ពន្យល់អំពីទំនាស់ផលប្រយោជន៍នោះ: មានប្រព័ន្ធបញ្ចេញទឹកចូលទន្លេដែលក្រុមហ៊ុនមេគង្គអាចបំពាក់ ប៉ុន្តែ វានឹងធ្វើឱ្យខូចដល់ទន្លេដែលអ្នកកំពុងរស់នៅតាមនោះ?
- ប្រាប់គូភាគីថា អ្នកមានទំនាស់ផលប្រយោជន៍ ដោយពន្យល់អំពីទំនាស់នោះ ហើយរង់ចាំមើលថាតើភាគីនីមួយៗចង់ដកអ្នកចេញដែរឬទេ?
- មិននិយាយអ្វីទាំងអស់ ហើយកាត់ក្តីឱ្យក្រុមហ៊ុនមេគង្គឈ្នះ។ ថ្លៃចំណាយនៃការការដកខ្លួនចេញមានកម្រិតខ្ពស់ ហើយអ្នកជឿថាអ្នកអាចកាត់ក្តីគាំទ្រក្រុមហ៊ុនមេគង្គដោយស្មោះត្រង់ និងត្រឹមត្រូវ ដោយមិនគិតអំពីការព្រួយបារម្ភរបស់អ្នកអំពីទន្លេឡើយ។ តើហេតុអ្វីត្រូវបង្ខំឱ្យភាគីទាំងពីររ៉ាប់រងថ្លៃចំណាយបន្ថែមក្នុងការចាប់ផ្តើមធ្វើមជ្ឈត្តការឡើងវិញជាថ្មី ហើយមជ្ឈត្តករថ្មី ក៏ប្រហែលជានឹងសម្រេចដូចគ្នាដដែលនោះ?

## ឆ. ក្រុមប្រឹក្សាអាជ្ញាកណ្ដាលកម្ពុជា

### *១. យុត្តាធិការ*

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលកម្ពុជា (Arbitration Council [AC]) ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៣ និងជាផ្នែកមួយនៃក្របខ័ណ្ឌ ADR សម្រាប់វិវាទការងារ។ មធ្យោបាយដ៏ងាយស្រួលជាងគេបំផុតក្នុងការយល់ថាតើ AC ចូលទៅក្នុងក្របខ័ណ្ឌនោះដែរឬទេ គឺត្រូវយល់អំពីជំហានរបស់វានីមួយៗជាមុនសិន។

ទីមួយ គូភាគីត្រូវមានវិវាទការងារ។ ប្រសិនបើវាជាវិវាទ *បុគ្គល* (មានពិភាក្សានៅខាងក្រោម) ភាគីនីមួយៗ អាចស្នើសុំធ្វើសន្ទានកម្មទៅក្រសួងការងារ (MOL)។[២៧២] នេះគឺជាដំណើរការស្ម័គ្រចិត្ត។ ប្រសិនបើគ្មានភាគីណាមួយ ចាប់អារម្មណ៍ក្នុងការផ្សះផ្សា/សន្ទានកម្មនៅក្រសួងការងារទេនោះ ភាគីនីមួយៗអាចដាក់ពាក្យបណ្ដឹងទៅតុលាការកម្ពុជា ដើម្បីដោះស្រាយបញ្ហានោះ។ ទោះជាយ៉ាងនេះក្ដី ប្រសិនបើភាគីម្ខាងស្នើសុំសន្ទានកម្មនៅក្រសួងការងារ ភាគីម្ខាងទៀត ត្រូវតែមានវត្តមានចូលរួម។ ប្រសិនបើកិច្ចប្រឹងប្រែងនោះមិនធ្វើឱ្យមានដំណោះស្រាយទេនោះ ភាគីនីមួយៗអាចដាក់ ពាក្យបណ្ដឹងទៅតុលាការកម្ពុជាក្នុងរយៈពេលពីរខែ។[២៧៣]

ប្រសិនបើវិវាទគឺជាវិវាទ *រួម* (មានពិភាក្សានៅខាងក្រោម) សន្ទានកម្មដោយក្រសួងការងារ គឺជាកាតព្វកិច្ច។[២៧៤] ប្រសិនបើកិច្ចប្រឹងប្រែងនោះមិនឈានដល់ដំណោះស្រាយទេ គូភាគីត្រូវចូលរួមធ្វើមជ្ឈត្តការនៅ AC ។[២៧៥] ដូច្នេះ AC មានយុត្តាធិការបើកសវនាការលើវិវាទការងាររួមបាន លុះត្រាតែការខំប្រឹងប្រែងធ្វើសន្ទានកម្មទៅលើវិវាទទាំងនោះ ដោយក្រសួងការងារបានបរាជ័យតែប៉ុណ្ណោះ។

តាមច្បាប់ ភាគីវិវាទ (និយោជក និងនិយោជិត) អាចយល់ព្រមចំពោះវិធីសាស្ត្រផ្សេងមួយក្នុងការដោះស្រាយ វិវាទនៅក្នុងកិច្ចព្រមព្រៀងអនុសញ្ញារួមរបស់ខ្លួន និងដែលអាចរំលង AC បាន។ ប៉ុន្តែ កិច្ចព្រមព្រៀងអនុសញ្ញារួម ជាច្រើននៅក្នុងប្រទេសកម្ពុជា បច្ចុប្បន្ននេះចែងអំពីដំណើរដំណោះស្រាយវិវាទ ដែលមានរៀបរាប់នៅក្នុងកថាខណ្ឌ ខាងលើ។ ដំណើរការនេះមានកិត្តិសព្ទរឹងមាំផ្នែកយុត្តិធម៌ និងបានផ្ដល់នូវលទ្ធផលជាទីគាប់ប្រសើរ។ ដំណើរការនេះទទួល បានការនិយម ក៏ដោយសារតែ ទាំងដំណើរការផ្សះផ្សា ទាំងដំណើរកាត់ក្ដីដោយអជ្ញាកណ្ដាល គឺសុទ្ធតែមិនគិតថ្លៃ។

ក្រាហ្វិកខាងក្រោមនេះ បង្ហាញអំពីក្របខណ្ឌច្បាប់ជាមូលដ្ឋាន សម្រាប់វិវាទការងារ:

---

[២៧២] **ច្បាប់ស្ដីពីការងារនៃព្រះរាជាណាចក្រកម្ពុជា,** មាត្រា ៣០០ - ៣០១ (ឆ្នាំ១៩៩៧) [តទៅនេះហៅកាត់ថា **ច្បាប់ការងារ**]។ ឈ្មោះពេញរបស់ក្រសួងអតីត គឺ "ក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា"។ ក្នុងឆ្នាំ២០០៤ ឈ្មោះនេះបានប្ដូរទៅជា "ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ"។ នៅក្នុងសៀវភៅនេះ ក្រសួងទទួលបន្ទុក ផ្នែកការងារត្រូវហៅកាត់ថា "ក្រសួងការងារ"។

[២៧៣] **ច្បាប់ការងារ** មាត្រា ៣០១។

[២៧៤] *ដូចមុន* មាត្រា ៣០៣។

[២៧៥] *ដូចមុន* មាត្រា ៣០២ - ៣១៦ ។ *សូមមើលផងដែរ* **ប្រកាសក្រសួងការងារ** លេខ ៣១៧-០១ (ឆ្នាំ២០០១)។

# ដ្យាក្រាមនៃវិវាទការងារ



បញ្ហាចម្បងដែលត្រូវកំណត់គឺថា តើវិវាទនោះគឺជា "វិវាទបុគ្គល" ឬ "វិវាទរួម"។ ដូចដែលបានឃើញនៅក្នុងក្រាហ្វិកខាងលើ ដំណើរការសម្រាប់វិវាទបុគ្គលមានភាពខុសគ្នាពីវិវាទរួម។ មានតែវិវាទរួមប៉ុណ្ណោះដែលអាចយកទៅដោះស្រាយដោយអាជ្ញាកណ្ដាលនៅ AC បាន។ មានតែវិវាទរួមប៉ុណ្ណោះ ដែលមានការផ្សះផ្សា/សម្រុះសម្រួលជាកាតព្វកិច្ចនៅក្រសួងការងារ។ ច្បាប់ស្ដីពីការងារកំណត់អំពីអ្វីដែលមានភាពចាំបាច់ ដើម្បីឱ្យវិវាទមួយត្រូវបានចាត់ទុកថាជាវិវាទ "រួម"។ លក្ខខណ្ឌទាំងបីខាងក្រោម ត្រូវតែបំពេញឱ្យបាន ៖

១. វិវាទគឺជាវិវាទរវាងនិយោជក និងក្រុមកម្មករនិយោជិត

២. កម្មវត្ថុនៃវិវាទទាក់ទងនឹងលក្ខខណ្ឌការងារ សិទ្ធិបង្កើត/ការទទួលស្គាល់អង្គការវិជ្ជាជីវៈ ឬ បញ្ហានៅក្នុងទំនាក់ទំនងរវាងនិយោជក និងកម្មករនិយោជិត និង

៣. វិវាទអាចនាំឱ្យមានការរំខានដល់សហគ្រាស ឬគំរាមកំហែងដល់ស្ថិរភាពសង្គម។

**សំណួរសិក្សា**

តើវិវាទខាងក្រោមនេះ គ្រប់លក្ខណៈដើម្បីយកទៅដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាលដែរឬទេ ?

១. សាន ធ្វើការនៅសណ្ឋាគារព្រះច័ន្ទពេញវង់។ គាត់ត្រូវបានចោទប្រកាន់ថាបានលួចទ្រព្យសម្បត្តិខ្លះរបស់សណ្ឋាគារ និងទទួលរងការដាក់ពិន័យ។ គាត់យល់ឃើញថា គាត់ត្រូវបានចោទប្រកាន់ដោយមិនត្រឹមត្រូវដោយសារគាត់កំពុងព្យាយាមរៀបចំបង្កើតសហជីពនៅក្នុងសណ្ឋាគារ។ សណ្ឋាគារនិយាយថា ការចោទប្រកាន់នេះមិនទាក់ទងនឹងកិច្ចខិតខំប្រឹងប្រែងរបស់គាត់ក្នុងការបង្កើតសហជីពនោះទេ។

២. សុជាតា ប្ដឹងរោងចក្រកាត់ដេរស្ដារ៍ថា ទឹកថ្នាំដែលប្រើជ្រលក់សម្លៀកបំពាក់ខ្លះ បំភាយក្លិនអាក្រក់ដែលនឹងធ្វើឱ្យពួកនាងមានជំងឺ។ នាងយល់ថាកម្មករផ្សេងទៀតក៏ប្រហែលជាយល់ឃើញដូចគ្នានេះដែរ ប៉ុន្តែពួកគេមិនហ៊ាននិយាយអ្វីទាំងអស់ ដោយសារខ្លាចបាត់បង់ការងាររបស់ខ្លួន ដូច្នេះ នាងគឺជាមនុស្សតែម្នាក់ប៉ុណ្ណោះដែលបានប្ដឹង។

៣. ធា និងមិត្តភក្ដិផ្សេងទៀតជាច្រើន បានឈប់ធ្វើការនៅសណ្ឋាគារយើង។ ពួកគេមានការងារល្អជាងនេះនៅកន្លែងផ្សេង។ ក្រោយពេលចាកចេញ ពួកគេប្ដឹងថា សណ្ឋាគារមិនព្រមប្រគល់ឱ្យពួកគេដោយមិនត្រឹមត្រូវនូវចំណែកនៃប្រាក់ទឹកតែដែលបានមកពីអតិថិជន និងចង់ឱ្យក្រុមប្រឹក្សាអាជ្ញាកណ្ដាលដោះស្រាយបញ្ហានេះ ទោះបីជាពួកគេលែងជាបុគ្គលិករបស់សណ្ឋាគារនោះទៀតក៏ដោយ។

## ២. *ដំណើរការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល*

ដំណើរការដោះស្រាយវិវាទរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល មានចែងនៅក្នុងវិធាននីតិវិធីរបស់ស្ថាប័ននេះ។[២៧៦] វិធាននេះស្រដៀងគ្នានឹងនីតិវិធីដោះស្រាយដោយមជ្ឈត្តការភាគច្រើនដែរ។ គូភាគីនីមួយៗជ្រើសរើសអាជ្ញាកណ្តាលម្នាក់ពីបញ្ជីឈ្មោះអជ្ញាកណ្តាល (ដែលមានបញ្ជីមួយសម្រាប់និយោជក និងបញ្ជីមួយទៀតសម្រាប់និយោជិត) ហើយអាជ្ញាកណ្តាលទីបីនឹងត្រូវបានជ្រើសរើសដោយអាជ្ញាកណ្តាលទាំងពីរដំបូង។[២៧៧] ទោះបីជាពួកគេត្រូវបានជ្រើសរើសឡើងដោយភាគីវិវាទក៏ដោយ ក៏អាជ្ញាកណ្តាលទាំងពីរនាក់ដំបូងមានករណីយកិច្ចដូចគ្នានឹងអាជ្ញាកណ្តាលទីបី ដែលតម្រូវឱ្យមានភាពមិនលម្អៀង។ មជ្ឈត្តការទាំងអស់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវមាន "ក្រុមអាជ្ញាកណ្តាល" ដែលមានសមាសភាពបីរូប។[២៧៨]

បន្ទាប់មក ក្រុមអាជ្ញាកណ្តាលនោះ បានទទួលអំណាចឱ្យធ្វើសេចក្តីសម្រេចតែលើបញ្ហាពីរប្រភេទតែប៉ុណ្ណោះ:

- បញ្ហាដែលបញ្ជាក់នៅក្នុងរបាយការណ៍មិនសះជា (ដែលដាក់ជូនដោយក្រសួងការងារ ក្នុងករណីដែលការផ្សះផ្សារបស់ក្រសួងត្រូវបរាជ័យ) និង
- បញ្ហាលេចចេញពីហេតុការណ៍ដែលកើតឡើងក្រោយរបាយការណ៍ និងដែលផ្តល់ផលវិបាកផ្ទាល់ដល់វិវាទ។[២៧៩]

គួរកត់សម្គាល់ថា ក្រុមអាជ្ញាកណ្តាលអាចបើកសវនាការជំនុំជម្រះអំពីអ្វីដែលខ្លួនហៅថា ទំនាស់"សិទ្ធិ" និងទំនាស់ "ផលប្រយោជន៍" ។ ទំនាស់សិទ្ធិគឺជាបញ្ហាបច្ចេកទេសច្បាប់ ដែលផ្អែកលើអនុសញ្ញារួម កិច្ចសន្យា ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិរបស់ព្រះរាជាណាចក្រកម្ពុជា។ ទំនាស់ផលប្រយោជន៍ទាក់ទងនឹងអត្ថប្រយោជន៍ ឬគោលនយោបាយដែលមិនផ្អែកលើច្បាប់ ឬកិច្ចសន្យា ឬសិទ្ធិស្របច្បាប់ដទៃទៀត។ ឧទាហរណ៍មួយគឺថា នៅពេលកម្មករស្នើសុំឡើងប្រាក់ខែ ដែលមិនត្រូវបានពិចារណានៅក្នុងកិច្ចសន្យារបស់ខ្លួន។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើសេចក្តីសម្រេចអំពីទំនាស់ផលប្រយោជន៍ ដោយផ្អែកលើគោលការណ៍សមភាព និងយុត្តិធម៌ជាមូលដ្ឋាន។[២៨០]

---

[២៧៦] *សូមមើលជាទូទៅ* **វិធានស្តីពីនីតិក្រុមប្រឹក្សាអាជ្ញាកណ្តាល,** *ឧបសម្ព័ន្ធនៃ* ប្រកាសក្រសួងការងារលេខ ៩៩ (ឆ្នាំ២០០៤) [តទៅនេះ ហៅកាត់ថា "វិធានក្រុមប្រឹក្សាអាជ្ញាកណ្តាល"]។ ដំបូងឡើយ វិធាននេះគឺជាឧបសម្ព័ន្ធនៃប្រកាសក្រសួងការងារលេខ ៣៣៨ (ឆ្នាំ២០០២) ហើយ បន្ទាប់មកត្រូវបានចេញឡើងវិញក្រោមប្រកាសក្រសួងការងារលេខ ៩៩។

[២៧៧] វិធានក្រុមប្រឹក្សាអាជ្ញាកណ្តាល ៣.១ - ៣.១៤។

[២៧៨] វិធានក្រុមប្រឹក្សាអាជ្ញាកណ្តាល ប្រើពាក្យអង់គ្លេសថា panel ដើម្បីសំដៅអាជ្ញាកណ្តាលចំនួនបីរូប ដែលសម្រេចសេចក្តីលើរឿងក្តីណាមួយ។ ផ្ទុយមកវិញ ICC, AAA និងវិធាននៃ UNICTRAL សុទ្ធតែប្រើពាក្យថា tribunal ។ ច្បាប់មជ្ឈត្តការផ្នែកពាណិជ្ជកម្មក៏ប្រើពាក្យ tribunal នេះដែរ។ ពាក្យទាំង ពីរនេះ អាចជំនួសគ្នាទៅវិញទៅមកបាន ហើយវាសំដៅដល់អង្គភាពតែមួយ - គឺក្រុមមជ្ឈត្តករដែលសម្រេចសេចក្តីលើរឿងក្តីមួយ។

[២៧៩] *សូមមើលឧទាហរណ៍ ករណីសណ្ឋាគារ Raffles Le Royal* (ក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ២២/០៤)។

[២៨០] **ច្បាប់ការងារ** មាត្រា ៣១២(២)។

ការបែកដាច់ពីគ្នារវាងទំនាស់សិទ្ធិ និងទំនាស់ផលប្រយោជន៍នេះមានសារៈសំខាន់ណាស់។ តុលាការកម្ពុជា អាចអនុវត្តយុត្តាធិការរបស់ខ្លួនលើទំនាស់សិទ្ធិ ប៉ុន្តែមិនអាចអនុវត្តលើទំនាស់ផលប្រយោជន៍បានឡើយ ដោយសារទំនាស់ផលប្រយោជន៍មិនទាក់ទងនឹងសិទ្ធិតាមផ្លូវច្បាប់ឡើយ។

ប្រការដែលថាក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចជំនុំជម្រះ និងសម្រេចអំពីទំនាស់ផលប្រយោជន៍ គឺជាប្រការដ៏សំខាន់ ដោយសារតែការធ្វើដូច្នេះអាចជួយដោះស្រាយបញ្ហាទាំងអស់រវាងភាគីវិវាទ មិនមែនត្រឹមតែបញ្ហាបច្ចេកទេស ឬច្បាប់ប៉ុណ្ណោះទេ។

## សំណួរសិក្សា

តើទំនាស់ខាងក្រោមនេះ គឺជាទំនាស់ "សិទ្ធិ" ឬ "ផលប្រយោជន៍" ?

- និយោជិតចាស់ៗនៅរោងចក្រកាត់ដេរមួយ ចង់ស្នើសុំប្រាក់បន្ថែមសម្រាប់អតីតភាពការងារ ឱ្យដូចគ្នានឹងនិយោជិតចាស់ ដែលទទួលបាននៅក្នុងរោចក្រផ្សេងទៀត។
- កម្មករនៅសណ្ឋាគារធំមួយ ស្នើសុំប្រាក់បន្ថែមម៉ោងស្មើនឹង ១,៥ ដងនៃប្រាក់ខែធម្មតា។
- កម្មករស្នើសុំប្រាក់រង្វាន់ជាស្តង់ដារក្នុងឱកាសចូលឆ្នាំខ្មែរ។
- កម្មកររោងចក្រគំរាមធ្វើកូដកម្ម ដោយសារមានការបៀតបៀនពីភ្នាក់ងាររបស់ថ្នាក់គ្រប់គ្រង។
- កម្មករជាស្ត្រីនៅក្នុងសណ្ឋាគារមួយ តវ៉ាថាថ្នាក់គ្រប់គ្រងមានរើសអើងប្រឆាំងនឹងពួកខ្លួន ទាក់ទងនឹងការដំឡើងដំណែង។
- កម្មករនៅក្នុងរោងចក្រគីមីមួយ ត្អូញត្អែរអំពីការឈឺក្បាល និងបញ្ហាសុខភាពផ្សេងទៀត ដែលពួកគេជឿថាបណ្តាលមកពីការប្រឈមនឹងសារធាតុគីមីដែលមានគ្រោះថ្នាក់នៅក្នុងរោងចក្រ។

ក្រោយពេលដែលយុត្តាធិការត្រូវបានបង្កើតឡើង ហើយក្រុមអាជ្ញាកណ្តាលត្រូវបានជ្រើសរើសរួច ក្រុមអាជ្ញាកណ្តាលនោះត្រូវតែចាប់បើកសវនាការ។[២៨១] នៅក្នុងសវនាការនេះ ភាគីវិវាទអាចតំណាងដោយមេធាវី ឬបុគ្គលផ្សេងទៀត។[២៨២] ដំណើរការកាត់ក្តីគឺធ្វើឡើងជាភាសាខ្មែរ ប៉ុន្តែភាគីម្ខាងអាចជ្រើសរើសនិយាយភាសាផ្សេងទៀតបានប្រសិនបើមានអ្នកបកប្រែម្នាក់អាចធ្វើការបកប្រែដោយត្រឹមត្រូវមកជាភាសាខ្មែរ។[២៨៣] ដំណើរការកាត់ក្តីគឺធ្វើឡើងជាឯកជន។[២៨៤]

គូភាគីអាចផ្តល់ឯកសារ និងភស្តុតាងផ្សេងទៀតឱ្យក្រុមអាជ្ញាកណ្តាល។ ក្រុមអាជ្ញាកណ្តាលក៏អាចតម្រូវឱ្យភាគីណាមួយផ្តល់ភស្តុតាងជាក់លាក់មួយចំនួន ដូចជាឯកសារជាដើម។ ក្រុមអាជ្ញាកណ្តាលក៏អាចស្នើសុំភស្តុតាងពីអ្នកជំនាញផងដែរ។[២៨៥] ជាចុងក្រោយ ក្រុមអាជ្ញាកណ្តាល និងភាគីវិវាទអាចសាកសួរសាក្សីនៅក្នុងសវនាការ។[២៨៦]

---

[២៨១] **ប្រកាសក្រសួងការងារ** លេខ ៩៩ មាត្រា ១៨ (ឆ្នាំ២០០៤)។

[២៨២] *ដូចមុន* មាត្រា ១៩។

[២៨៣] *ដូចមុន* មាត្រា ២៣។

[២៨៤] *ដូចមុន* មាត្រា ២៩។

[២៨៥] *ដូចមុន* មាត្រា ២៤។

ក្រុមអាជ្ញាកណ្តាលក៏អាចធ្វើការការខិតខំប្រឹងប្រែងសម្រុះសម្រួលរវាងភាគីវិវាទផងដែរ ។[287] ប្រសិនបើការសម្រុះសម្រួលនោះបានជោគជ័យ គូភាគីអាចព្រមព្រៀងធ្វើកិច្ចសន្យាស្រុះស្រួលមួយ ជាផ្នែកមួយនៃសេចក្តីបង្គាប់ស្រុះស្រួល ដែលមានអំណាចដូចគ្នានឹងសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះដែរ ។[288]

នៅក្នុងកំឡុងពេលដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើដំណើរការកាត់ក្តី ភាគីវិវាទត្រូវចៀសវាងការធ្វើកូដកម្ម ឬការបិទសកម្មភាព ឬអំពើផ្សេងៗទៀតដែលអាចធ្វើឱ្យស្ថានភាពរវាងគូភាគីកាន់តែធ្ងន់ធ្ងរថែមទៀតឡើយ ។[289] នៅពេលចាប់ផ្តើម គូភាគីក៏អាចព្រមព្រៀងផ្លាស់ប្តូរដំណើរការ ដើម្បី ឱ្យដំណើរការនេះគឺជាដំណោះស្រាយមជ្ឈត្តការដែល *ភ្ជាប់កាតព្វកិច្ច* ជំនួសឱ្យលក្ខណៈ *មិនភ្ជាប់កាតព្វកិច្ច* ជាធម្មតា របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ភាគីទាំងអស់ ត្រូវយល់ព្រមជាលាយលក្ខណ៍អក្សរ ដើម្បីឱ្យការផ្លាស់ប្តូរនេះអាចធ្វើទៅបាន ។[290]

### ៣. *សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល*

ក្រោយពេលសវនាការ ក្រុមអាជ្ញាកណ្តាលត្រូវចេញសេចក្តីបង្គាប់មួយ ។ សេចក្តីបង្គាប់គឺជាសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរចុងក្រោយរបស់ក្រុមអាជ្ញាកណ្តាល ។ សេចក្តីបង្គាប់ត្រូវប្រកាសជាសាធារណៈ និងបញ្ជាក់អំពីសេចក្តីសង្ខេបនៃនីតិវិធី ការពិពណ៌នាអំពីការប្តឹងទាមទារ និងមូលហេតុសម្រាប់ការធ្វើសេចក្តីសម្រេច ។[291] លើកលែងតែភាគីទាំងពីរយល់ព្រមចំពោះការពន្យារពេល ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវធ្វើការជំនុំជម្រះរឿងក្តី និងចេញសេចក្តីបង្គាប់ក្នុងរយៈពេល១៥ថ្ងៃ ក្រោយពេលវិវាទនោះត្រូវបានបញ្ជូនមកពីក្រសួងការងារ ។[292] ច្បាប់បានផ្តល់ដល់ក្រុមអាជ្ញាកណ្តាលរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នូវអំណាចក្នុងការចេញសេចក្តីបង្គាប់ឱ្យមាន *"សំណង ឬការតម្រូវផ្នែករដ្ឋប្បវេណីដែលខ្លួនយល់ថាត្រឹមត្រូវ និងយុត្តិធម៌"* រួមមានៈ

- សេចក្តីបង្គាប់ឱ្យទទួលនិយោជិតដែលត្រូវបានបញ្ឈប់ឱ្យចូលធ្វើការវិញ
- សេចក្តីបង្គាប់ឱ្យបើកប្រាក់ខែសម្រាប់ការងារដែលបានធ្វើ
- សេចក្តីបង្គាប់ឱ្យបញ្ឈប់សកម្មភាពកម្មករ ( ដូចជា កូដកម្ម ជាដើម)
- សេចក្តីបង្គាប់ឱ្យបញ្ឈប់សកម្មភាពខុសច្បាប់ ឬសកម្មភាពដែលត្រូវហាមឃាត់
- សេចក្តីបង្គាប់ឱ្យបញ្ចុះតម្លៃ
- សេចក្តីបង្គាប់ដែលទាក់ទងនឹងការព្រមព្រៀងគ្នារវាងគូភាគី និង

---

[286] *ដូចមុន* មាត្រា ២៦ ។
[287] *ដូចមុន* មាត្រា ៣០ ។
[288] *ដូចមុន* មាត្រា ៣៤(ច) ។
[289] **ប្រកាសក្រសួងការងារ** លេខ ៣៣៨ មាត្រា ២០ ( ឆ្នាំ២០០២) ។
[290] *សូមមើល* **ប្រកាសក្រសួងការងារ** លេខ ៩៩ មាត្រា ៤២ ។
[291] *ដូចមុន* មាត្រា ៣៨ ។
[292] **ច្បាប់ការងារ** មាត្រា ៣១៣ ។ **ប្រកាសក្រសួងការងារ**លេខ ៩៩ មាត្រា ៥៩ ។

• ការបង្កើតលក្ខខណ្ឌសម្រាប់កិច្ចព្រមព្រៀងអនុសញ្ញារួម ។[២៩៣]

ប្រសិនបើគូភាគីបានព្រមព្រៀងធ្វើដំណោះស្រាយដោយអាជ្ញាកណ្តាល*ដែលភ្ជាប់កាតព្វកិច្ច* ឬប្រសិនបើកិច្ចព្រមព្រៀងអនុសញ្ញារួមរបស់ពួកគេ តម្រូវឱ្យមានដំណោះស្រាយដោយអាជ្ញាកណ្តាល*ដែលភ្ជាប់កាតព្វកិច្ច* សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងអាចដាក់ឱ្យអនុវត្តភ្លាមៗបាន ។[២៩៤] ប៉ុន្តែនៅក្នុងគ្រប់ករណីផ្សេងទៀត (ហើយច្រើនតែជាករណីទូទៅសម្រាប់ក្រុមប្រឹក្សាអាជ្ញាកនណ្តាល) សេចក្តីបង្គាប់អាជ្ញាកណ្តាលដែលចេញដោយក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺ*មិនភ្ជាប់កាតព្វកិច្ច* ទេ។ នេះមានន័យថា ភាគីនីមួយៗអាចដាក់បណ្តឹងជំទាស់ទៅលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សានេះក្នុងរយៈពេលប្រាំបីថ្ងៃក្រោយថ្ងៃចេញសេចក្តីបង្គាប់ ។ ការដាក់បណ្តឹងជំទាស់ ធ្វើឱ្យសេចក្តីបង្គាប់មិនអាចអនុវត្តបានឡើយ ។[២៩៥] នៅត្រង់ចំណុចនេះ ភាគីវិវាទមានសេរីភាពក្នុងការបន្តធ្វើបណ្តឹងផ្សេងទៀត ដើម្បីដោះស្រាយវិវាទរបស់ខ្លួន រួមទាំងការដាក់ពាក្យបណ្តឹងទៅតុលាការកម្ពុជា (ក្នុងករណីដែលជាទំនាស់សិទ្ធិ) ឬធ្វើសកម្មភាពកម្មករដូចជាកូដកម្ម ឬបិទសកម្មភាពជាដើម (ក្នុងករណីដែលជាទំនាស់សិទ្ធិ ឬទំនាស់ផលប្រយោជន៍)។ ប្រព័ន្ធច្បាប់តម្រូវឱ្យភាគីវិវាទធ្វើដំណើរតាមរយៈជំហានផ្សេងៗនៃ ADR ដូចជាសន្ធានកម្មនៅក្រសួងការងារ និងដំណោះស្រាយដោយអាជ្ញាកណ្តាលរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល មុនពេលពួកគេ អាចចាត់វិធានការធ្ងន់ដូចជាកូដកម្មជាដើម ។

ដំណើរការ *មិនភ្ជាប់កាតព្វកិច្ច*នេះ តែងតែនាំឱ្យមានសេចក្តីបង្គាប់ ដែលភាគីវិវាទយល់ព្រមទទួលយក ។ ទោះបីជាពួកគេដាក់បណ្តឹងទាស់ក៏ដោយ សេចក្តីបង្គាប់គឺជាឯកសារព័ត៌មានដ៏មានប្រយោជន៍បំផុត សម្រាប់ឱ្យភាគីវិវាទពិចារណានៅក្នុងវិវាទរបស់ខ្លួន ។ សេចក្តីបង្គាប់នេះប្រាប់ពួកគេអំពីអ្វីដែលទំនងជានឹងកើតឡើង ប្រសិនបើពួកគេបានដាក់ពាក្យបណ្តឹងទៅតុលាការកម្ពុជា ។ សំខាន់បំផុត សេចក្តីបង្គាប់នេះជួយលើកទឹកចិត្តឱ្យភាគីវិវាទដោះស្រាយរឿងក្តីជាលក្ខណៈឯកជន ទោះបីជាភាគីម្ខាងដាក់បណ្តឹងទាស់ និងធ្វើឱ្យសេចក្តីបង្គាប់មិនអាចអនុវត្តបានក៏ដោយ ។

ប្រសិនបើគ្មានភាគីណាមួយដាក់បណ្តឹងទាស់ ក្នុងរយៈពេលប្រាំបីថ្ងៃទេនោះ សេចក្តីបង្គាប់នឹងចូលជាស្ថាពរ ហើយអាចអនុវត្តបាន ។[២៩៦] ប្រសិនបើសេចក្តីបង្គាប់ក្លាយជាស្ថាពរ ហើយភាគីម្ខាងបដិសេធមិនគោរពតាមសេចក្តីបង្គាប់នេះ ភាគីម្ខាងទៀតអាចអាចដាក់ពាក្យប្តឹងទៅកាន់តុលាការកម្ពុជាដើម្បីស្នើសុំការអនុវត្តសេចក្តីបង្គាប់នោះ ។ តាមច្បាប់ តុលាការកម្ពុជាត្រូវអនុវត្តសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ឱ្យដូចសេចក្តីបង្គាប់របស់តុលាការដែរ លើកលែងតែសេចក្តីបង្គាប់នេះមានភាពមិនត្រឹមត្រូវដោយសារមានភាពមិនប្រក្រតីគួរឱ្យកត់សម្គាល់ផ្នែកនីតិវិធី ឬដោយសារតែក្រុមប្រឹក្សាអជ្ញាកណ្តាល ចេញសេចក្តីបង្គាប់ដែលហួសពីសិទ្ធិអំណាចផ្លូវច្បាប់របស់ខ្លួនតែប៉ុណ្ណោះ ។[២៩៧]

ផ្នែកណាមួយនៃសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលទាក់ទងនឹងទំនាស់ផលប្រយោជន៍មានឋានៈជាកិច្ចព្រមព្រៀងអនុសញ្ញារួម ដែលមិនអាចកែប្រែបានសម្រាប់រយៈពេលមួយឆ្នាំ ។[២៩៨]

---

[២៩៣] **ប្រកាសក្រសួងការងារ** លេខ ៩៩ មាត្រា ៣៤ ។

[២៩៤] *ដូចមុន* មាត្រា ៤២ ។

[២៩៥] *ដូចមុន* មាត្រា ៤០ ។

[២៩៦] **ច្បាប់ការងារ** មាត្រា ៣១៣ - ៣១៤ ។ **ប្រកាសក្រសួងការងារ** លេខ ៩៩ មាត្រា ៤០ - ៤១ ។

[២៩៧] **ប្រកាសក្រសួងការងារ** លេខ ៩៩ មាត្រា ៤៧ ។

[២៩៨] *ដូចមុន* មាត្រា ៤៣ - ៤៤ ។

ដ្យាក្រាមខាងក្រោមនេះ បង្ហាញពីរបបអនុវត្តន៍សម្រាប់វិវាទការងាររួមៈ



## លំហាត់ រឿងក្ដីមជ្ឈត្តការៈ ការបៀតបៀននៅកន្លែងធ្វើការ

អ្នកគឺជាមេធាវីរបស់ លី លីង។ នាងបានប្រាប់អ្នកអំពីរឿងរ៉ាវដូចតទៅៈ នាងធ្វើការនៅការិយាល័យមួយនៅក្នុងក្រុងភ្នំពេញ ដែលផលិត និងលក់ផលិតផលក្រដាសឱ្យក្រុមហ៊ុនផ្សេងៗ។ នាងត្រូវបានទទួលឱ្យធ្វើការដោយលោក ស៊ូ ភេន នាយកចាត់ការទូទៅ។ ដំបូង នាងគឺជាអ្នកទទួលភ្ញៀវ ប៉ុន្តែទីបំផុត នាងត្រូវបានដំឡើងតំណែងជាអ្នកលក់ ដោយសារការខិតខំធ្វើការរបស់នាង។

លោក ភេន បានជួយបង្រៀនបច្ចេកទេសលក់ដល់ លីង ដោយសារនាងគ្មានបទពិសោធន៍ផ្នែកលក់ទេ។ គាត់តែងតែធ្វើការរហូតដល់ល្ងាចជាមួយនាង ហើយនាងបានចាត់ទុកគាត់ជាមិត្តរបស់នាង។ នាងបានក្លាយជាបុគ្គលិកដ៏ពូកែម្នាក់ ហើយលក់ផលិតផលបានច្រើនជាងអ្នកលក់ផ្សេងទៀត។

យប់មួយនៅការិយាល័យ លោក ភេន បានធ្វើឱ្យនាងភ្ញាក់ផ្អើល ដោយបានប្រាប់នាងថា គាត់ស្រឡាញ់នាង។ គាត់ចង់ឱ្យនាងត្រឡប់ទៅផ្ទះរបស់គាត់ និងនៅជាមួយគាត់។ លីង បដិសេធនឹងសម្តីនេះ ដោយប្រាប់គាត់ថា នាងមានសង្សាររួចហើយ និងថានាងគ្រាន់តែជាមិត្តភក្តិរបស់គាត់ប៉ុណ្ណោះ គ្មានអ្វីលើសពីនេះទេ។ម្យ៉ាងទៀត លោក ភេន ក៏មានប្រពន្ធរួចហើយដែរ។

នៅថ្ងៃបន្ទាប់នៅកន្លែងធ្វើការ លោក ភេន បានប្រកាសថា គាត់បានបង្កើតមុខតំណែងថ្មីមួយ គឺ "ប្រធានផ្នែកលក់" ។ មុខតំណែងនេះគឺជាការដំឡើងតំណែងដ៏ធំ និង ផ្តល់ប្រាក់បៀវត្សរ៍ទ្វេមួយជាពីរនៃប្រាក់បៀវត្សរ៍របស់អ្នកលក់ទូទៅ ។ តាមធម្មតា លីង បានគិតថានាងនឹងទទួលមុខតំណែងនេះ។ នៅល្ងាចថ្ងៃនោះ លោក ភេន បានសួរទៅ លីង ថាតើនាងនឹងពិចារណាសម្តីរបស់គាត់ឡើងវិញដែរឬទេ។ គាត់បាននិយាយថា គាត់នឹងឱ្យនាងធ្វើជាប្រធានផ្នែកលក់ ប្រសិនបើនាងយល់ព្រមធ្វើជាសង្សាររបស់គាត់។ បន្ទាប់មក គាត់បានព្យាយាមថើបនាង ប៉ុន្តែនាងបានច្រានគាត់ចេញដោយនិយាយថា "ទេ អរគុណ" ។

នៅថ្ងៃបន្ទាប់ លោក ភេន បានប្រកាសថា ស៊ុយ អាន ដែលជាអ្នកលក់ម្នាក់ទៀត ដែលមានអត្រាលក់ តិចជាង លីង យ៉ាងច្រើន ត្រូវបានដំឡើងតំណែងជាប្រធានផ្នែកលក់។ លីង ខឹងខ្លាំងណាស់។ ការលក់របស់លីង ជារៀងរាល់ខែតែងតែឈានដល់ចំណុចកំពូលនៅក្នុងឆ្នាំចុងក្រោយនេះ។ តើលោក ភេន អាចមើលរំលងនាង ដោយជ្រើសរើសយក អាន បានយ៉ាងដូចម្តេច ?

មួយសប្តាហ៍ក្រោយមក លីង មកធ្វើការយឺត ៣០ នាទី ដោយសារស្ទះចរាចរណ៍។ ទោះបីជាបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនតម្រូវឱ្យបុគ្គលិកទាំងអស់ចាប់ផ្តើមធ្វើការនៅម៉ោង ៨:០០ ព្រឹកក៏ដោយ ក៏វាគឺជារឿងទូទៅសម្រាប់បុគ្គលិកទាំងអស់ដែលត្រូវមានការយឺតយ៉ាវម្តងម្កាល ដោយសារបញ្ហាចរាចរណ៍ ឬបញ្ហាផ្សេងទៀត។ បុគ្គលិកមកយឺតនឹងនៅបន្ថែមម៉ោង ឬធ្វើការនៅម៉ោងអាហារថ្ងៃត្រង់ ដើម្បីទូទាត់ម៉ោងដែលយឺត។ នៅពេល លីង ដើរចូលក្នុងការិយាល័យ លោក ភេន បានប្រាប់នាងថា នាងត្រូវបានបញ្ឈប់ពីការងារដោយសារនាងបានរំលោភគោលនយោបាយស្តីពីម៉ោងធ្វើការរបស់ក្រុមហ៊ុន។ ភ្លាមៗនោះ នាងត្រូវបានគេនាំចេញក្រៅក្រុមហ៊ុន។

លីង គ្មានគ្រួសារនៅក្នុងក្រុងភ្នំពេញទេ ហើយមានការព្រួយបារម្ភអំពីប្រាក់កាស។ នាងមិនអាចរកការងារល្អដូចនេះពីក្រុមហ៊ុនផ្សេងទៀតឡើយ ប្រសិនបើគ្មានលិខិតបញ្ជាក់ការងារពីលោក ភេន ទេនោះ ដែលហាក់ដូចជាពិបាក

ទទួលបានណាស់នៅពេលនេះ។ នាងគិតថា រឿងរ៉ាវរបស់នាងនឹងមានភាពអាម៉ាសណាស់សម្រាប់លោក ភេន និង ក្រុមហ៊ុន ប្រសិនបើរឿងនេះត្រូវបានដឹងជាសាធារណៈ។ ក្នុងពេលដែលអ្នកធ្វើការស៊ើបអង្កេត អ្នកបានរកឃើញថា អតីតបុគ្គលិកផ្សេងទៀតចំនួនបីនាក់ មានរឿងរ៉ាវស្រដៀងគ្នាអំពីលោក ភេន មុនពេលពួកគេត្រូវបានបញ្ឈប់ពីការងារ ដោយសារមូលហេតុបច្ចេកទេសដូចជា ការមកយឺតជាដើម។ ហើយមានភស្តុតាងបង្ហាញថា លោក ភេន ប្រហែលជាបានបង្ខំ ស៊ុយ អាន ឱ្យធ្វើជាសង្សាររបស់ខ្លួនជាថ្នូរនឹងការដំឡើងតំណែងរបស់នាង។ លីង ក៏បានដឹងផងដែរថា អ្នកលក់ជាស្ត្រីផ្សេងទៀតមួយចំនួន ក៏ត្រូវបានលោក ភេន សុំស្រឡាញ់ដែរ។

- ដោយសន្មត់ថា និយោជិតគឺជាសមាជិកសហជីព ហើយ សហជីពមានកិច្ចព្រមព្រៀងអនុសញ្ញារួមដែលចែងអំពីដំណោះស្រាយដោយអាជ្ញាកណ្តាលចំពោះវិវាទរួម នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល តើក្រុមប្រឹក្សានេះមានយុត្តាធិការក្នុងការជំនុំជម្រះករណីពិសេសនេះដែរឬទេ ? ហេតុអ្វី ?
- ដោយសន្មត់ថា ករណីនេះបានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងនាមជាមេធាវីឱ្យនិយោជិត តើអ្នកស្នើឱ្យដំណោះស្រាយដោយអាជ្ញាកណ្តាលនោះត្រូវភ្ជាប់កាតព្វកិច្ច ឬ មិនភ្ជាប់កាតព្វកិច្ច ? ហេតុអ្វី ?
- ដោយសន្មត់ថា អ្នកគឺជាតំណាងឱ្យ *និយោជក* នៅក្នុងករណីនេះ តើអ្នកស្នើឱ្យដំណោះស្រាយដោយអាជ្ញាកណ្តាល ត្រូវភ្ជាប់កាតព្វកិច្ច ឬមិនភ្ជាប់កាតព្វកិច្ច? ហេតុអ្វី ?
- ដោយពិចារណាអំពីផលប្រយោជន៍របស់ភាគីទាំងពីរនៅក្នុងករណីនេះ តើដំណោះស្រាយដោយអាជ្ញាកណ្តាលដែលចងភ្ជាប់កាតព្វកិច្ច មានគុណសម្បត្តិ និង គុណវិបត្តិអ្វីខ្លះ បើធៀបនឹងដំណើរការកាត់ក្តីនៅតុលាការ ? ឬ តើគ្មានភាពខុសគ្នាទេឬ ?
- តើក្រុមប្រឹក្សាអាជ្ញាកណ្តាល *អាច* ចេញសេចក្តីបង្គាប់ដូចម្តេចចំពោះនិយោជិត នៅក្នុងករណីនេះ?
- តើក្រុមប្រឹក្សាអាជ្ញាកណ្តាល *ត្រូវ* ចេញសេចក្តីបង្គាប់ដូចម្តេចចំពោះនិយោជិត នៅក្នុងករណីនេះ? ហេតុអ្វី? តើព័ត៌មានបន្ថែមអ្វីខ្លះដែលនឹងជួយអ្នកក្នុងការធ្វើសេចក្តីសម្រេច ?
- ប្រសិនបើ បន្ទាប់ពីដោះស្រាយដោយអាជ្ញាកណ្តាលដែលមិនចងភ្ជាប់កាតព្វកិច្ចរួចមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលបង្គាប់ឱ្យបុគ្គលិក នីមួយៗដែលត្រូវបានបញ្ឈប់ពីការងារចូលធ្វើការវិញ ហើយបើកប្រាក់ខែសម្រាប់រយៈពេលមិនធ្វើការ តើអ្នកនឹងស្នើថា ពួកគេគួរ

  ១) ដាក់បណ្តឹងជំទាស់ ឬ

  ២) យល់ព្រមទទួលយកសេចក្តីបង្គាប់ ឬ

  ៣) ព្យាយាមធ្វើការចរចារកដំណោះស្រាយប្រសើរជាងនេះ និងប្រសិនបើបរាជ័យទើបដាក់បណ្តឹងជំទាស់ ឬ

  ៤) ព្យាយាមធ្វើការចរចា រកដំណោះស្រាយប្រសើរជាងនេះ ហើយប្រសិនបើបរាជ័យយល់ព្រមទទួលយក សេចក្តីបង្គាប់ឬ ? ហេតុអ្វី ?

# ជំពូកទី៥: សន្និដ្ឋាន

ដូចបានបង្ហាញជូនជាភ័ស្តុតាងនៅក្នុងជំពូកនានានៃសៀវភៅនេះ វិវាទអាចត្រូវបានដោះស្រាយតាមវិធីសាស្ត្រជាច្រើនផ្សេងៗគ្នា។ សៀវភៅនេះផ្តោតលើជម្រើសចម្បងៗចំនួនបី ជំនួសឱ្យដំណោះស្រាយវិវាទតាមប្រព័ន្ធតុលាការគឺៈ ការចរចា សន្ទានកម្ម និងមជ្ឈត្តការ។ ដំណើរការនីមួយៗត្រូវបានពន្យល់លម្អិត នៅក្នុងជំពូកនីមួយៗដាច់ដោយឡែកពីគ្នា។ ក្នុងជំពូកនេះ យើងធ្វើការប្រៀបធៀបដោយសង្ខេបនូវដំណើរការទាំងបី ដើម្បីឱ្យអ្នកអានធ្វើការសម្រេចចិត្តថាតើដំណើរការមួយណាដែលសមស្របបំផុតចំពោះវិវាទជាក់លាក់ណាមួយ។ រូបភាពខាងក្រោមនេះផ្តល់នូវការប្រៀបធៀបជាមូលដ្ឋាន លើទម្រង់ទាំងបីនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងបណ្តឹងទៅតុលាការដែលមានពីមុនមកៈ



## គ. ការប្រៀបធៀបដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យរួម

វិធីមួយដើម្បីធ្វើការប្រៀបធៀបទម្រង់ផ្សេងៗនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺត្រូវស្វែងយល់ថាតើទម្រង់ទាំងនេះខុសគ្នារបៀបណា ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលត្រូវបានប្រើប្រាស់ជាទូទៅបំផុត :

- ការគ្រប់គ្រងរបស់ភាគី
- បែបបទ
- ល្បឿន
- ភាពជាឯកជន
- ការចំណាយ

ក្រាហ្វិចខាងក្រោមនេះប្រៀបធៀបបច្ចេកទេសដោះស្រាយវិវាទផ្សេងៗ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យរួមទាំងនេះ :

## ការប្រៀបធៀបដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ-លក្ខណៈវិនិច្ឆ័យរួម

| ការធ្វើមិនដឹងមិនឮចំពោះបញ្ហា/មិនចាត់វិធានការអ្វីទាំងអស់ | ការដោះស្រាយដោយខ្លួនឯង | ការចរចា | សន្ធានកម្ម | មជ្ឈត្តការ | បណ្តឹងទៅតុលាការ |
|---|---|---|---|---|---|
| ការសម្រេចជា ឯកជនដែលធ្វើឡើងដោយភាគីវិវាទ | ការសម្រេចជាឯកជនដែលធ្វើឡើងដោយភាគីវិវាទ | ការសម្រេចជាឯកជនដែលធ្វើឡើងដោយភាគីទាំងពីរ | ការសម្រេចពាក់កណ្តាលឯកជនដែលធ្វើឡើងដោយភាគីទាំងពីរ | ការសម្រេចពាក់កណ្តាលឯកជនដែលធ្វើឡើងដោយភាគីទីបី | ការសម្រេចជាសាធារណៈដែលធ្វើឡើងដោយភាគីទីបី |




ដូចយើងបានឃើញស្រាប់ហើយ ទម្រង់ទាំងអស់នៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការផ្តល់ដល់ភាគីវិវាទនូវលទ្ធភាពគ្រប់គ្រងលើដំណើរការច្រើនជាងការប្តឹងទៅតុលាការដែលមានពីមុនមក។ ប៉ុន្តែទម្រង់មួយចំនួននៃ ដំណោះ-ស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដូចជាមជ្ឈត្តការជាដើម នៅតែទាមទារឱ្យគូរភាគីលះបង់យ៉ាងច្រើននូវ លទ្ធភាពនៃការគ្រប់គ្រងលើដំណើរការដោះស្រាយវិវាទ។ ទម្រង់នានានៅខាងឆ្វេងបង្ហាញនូវកម្រិតខ្ពស់បំផុតនៃលទ្ធភាពគ្រប់គ្រងរបស់ភាគីលើដំណើរការ។ រីឯទម្រង់នៅខាងស្តាំវិញ មានទំនោរទៅរកលក្ខណៈផ្លូវការជាងគេបំផុត និងជាដំណោះស្រាយវិវាទដែលយឺតជាងគេបំផុត ។ ទម្រង់ពីរនៅខាងឆ្វេងបំផុតពោលគឺ ការមិនអើពើនឹងបញ្ហា និងការដោះស្រាយដោយខ្លួនឯងផ្តល់ដល់ភាគីនូវការគ្រប់គ្រងច្រើនជាងគេបំផុតដល់ភាគីវិវាទ ហើយវាក៏ជាទំរង់នៃ ដំណោះស្រាយវិវាទដែលលឿននិងចំណាយតិចបំផុតផងដែរ ។

## ខ. ការប្រៀបធៀបដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដោយផ្អែកលើភាពបត់បែននៃលទ្ធផល

ទម្រង់មួយចំនួននៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មានលក្ខណៈបត់បែនជាងទម្រង់ផ្សេងទៀត ដោយសារវានាំមកនូវដំណោះស្រាយដែលអាចទទួលយកបានទៅវិញទៅមក ។

**ការប្រៀបធៀបដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ-ភាពបត់បែននៃលទ្ធផល**

| សន្ធានកម្ម | ការចរចា | ដោះស្រាយដោយខ្លួនឯង | មជ្ឈត្តការ | បណ្តឹងទៅតុលាការ | ការធ្វើមិនដឹងមិនឮចំពោះបញ្ហា/មិនចាត់វិធានការអ្វីទាំងអស់ |
|---|---|---|---|---|---|
| ភាគីទីបីធ្វើការជាមួយភាគីវិវាទដើម្បីស្វែងរកដំណោះស្រាយដែលអាចទទួលយកបានទៅវិញទៅមក | ភាគីវិវាទធ្វើការជាមួយគ្នាដើម្បីស្វែងរកដំណោះស្រាយដែលអាចទទួលយកបានទៅវិញទៅមក | ភាគីវិវាទធ្វើការដាច់ដោយឡែកពីគ្នាលើដំណោះស្រាយវិវាទ | ភាគីទីបីដែលត្រូវបានជ្រើសរើសរួមគ្នានោះដោះស្រាយវិវាទដោយផ្អែកលើវិធានដែលបានព្រមព្រៀងគ្នា | ចៅក្រមដោះស្រាយវិវាទ ដោយផ្អែកលើច្បាប់ជាធរមាន | គ្មានដំណោះស្រាយពិតប្រាកដ |

**មានលក្ខណៈបត់បែនខ្លាំង** **គ្មានលក្ខណៈបត់បែន**

សន្ធានកម្មគឺប្រហែលជាដំណើរការដែលមានភាពច្នៃប្រឌិត និងបត់បែនខ្លាំងជាងគេបំផុតក្នុងការស្វែងរកដំណោះស្រាយ ។ ភាគីទាំងអស់ដែលចូលរួមដំណើរការ រួមទាំងភាគីអព្យាក្រឹតផងនោះ ស្វែងរកការព្រមព្រៀងដែលអាចទទួលយកបាន។ ការពិភាក្សាគ្នាដោយបើកចំហ ជួយសម្រួលដល់គំនិតច្នៃប្រឌិតជាអតិបរមា។ ការចរចាក៏មានភាពបត់បែនដែរ ប៉ុន្តែបើគ្មានការចូលរួមពីសំណាក់ភាគីអព្យាក្រឹតទីបីទេ ជួនកាលភាគីមិនមានឱកាសក្នុងការស្វែងរកដំណោះស្រាយប្រកបដោយការច្នៃប្រឌិតឱ្យបានច្រើនឡើយ ។ មជ្ឈត្តការ និងការប្តឹងទៅតុលាការ ត្រូវបានរិតត្បិតផ្នែកគំនិតច្នៃប្រឌិត និងភាពបត់បែន ពីព្រោះតុលាការ ឬមជ្ឈត្តករត្រូវគោរពតាមគោលការណ៍ច្បាប់ នៅក្នុងការដោះស្រាយវិវាទ ។

## គ. ការប្រៀបធៀបដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការផ្អែក លើការរក្សាទំនាក់ទំនងរបស់ភាគី

ផ្នែកមួយទៀតនៃការប្រៀបធៀប គឺសមត្ថភាពរបស់វិធីសាស្ត្រនីមួយៗ នៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ក្នុងការរក្សាទំនាក់ទំនងរបស់ភាគី។ ចំពោះវិវាទមួយចំនួន ដំណើរការនិងលទ្ធផលដែលអាចរក្សាបាននូវទំនាក់ទំនងរវាងភាគីវិវាទ គឺជាលក្ខណៈវិនិច្ឆ័យសំខាន់ជាងគេបំផុត។ ដូចបានបង្ហាញជូននៅក្នុងក្រាហ្វិចខាងក្រោម វិធីសាស្ត្រ មួយចំនួន មានភាពប្រសើរជាងវិធីសាស្ត្រផ្សេងទៀត :

**ការប្រៀបធៀបដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ-ការរក្សាទំនាក់ទំនងរបស់ភាគី**

| ការចរចា | សន្ទានកម្ម | ការធ្វើមិនដឹងមិនឮចំពោះបញ្ហា/មិនចាត់វិធានការអ្វីទាំងអស់ | ការដោះស្រាយដោយខ្លួនឯង | មជ្ឈត្តការ | បណ្តឹងតុលាការ |
|---|---|---|---|---|---|
| ភាគីធ្វើការរួមគ្នាដើម្បីស្វែងរកដំណោះស្រាយដែលអាចទទួលយកបានទៅវិញទៅមក | ភាគីទីបីជួយភាគីវិវាទឱ្យស្វែងរកដំណោះស្រាយដែលអាចទទួលយកបានទៅវិញទៅមក | គ្មានការប្រឈមមុខដាក់គ្នាដោយផ្ទាល់ | ភាគីវិវាទធ្វើការដាច់ដោយឡែកពីគ្នា ដំណោះស្រាយជម្លោះ | ភាគីវិវាទប្រកួតប្រជែងគ្នាដោយប្រើប្រាស់វិធានដែលពួកគេបានព្រមព្រៀងគ្នានៅចំពោះមុខភាគីអព្យាក្រឹតដែលពួកគេបានជ្រើសរើស | ភាគីវិវាទប្រកួតប្រជែងគ្នានៅក្នុងបរិយាកាសប្រឆាំងគ្នា |




ការចរចារទំនងជាវិធីសាស្ត្រដែលមានប្រសិទ្ធភាពជាងគេបំផុត ក្នុងដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ចំពោះការរក្សាទំនាក់ទំនងរបស់ភាគី។ នៅពេលដែលភាគីទាំងពីរមកជួបគ្នាជាឯកជនដើម្បីដោះស្រាយវិវាទ ពួកគេមានឱកាសច្រើនក្នុងការរក្សាទំនាក់ទំនងរបស់គេ។ សន្ទានកម្មក៏មានចំណុចខ្លាំងដូចគ្នាដែរក្នុងបរិបទនេះ ប៉ុន្តែវត្តមានរបស់ភាគីខាងក្រៅដែលជួយភាគីអាចដោះស្រាយវិវាទរបស់គេ បានធ្វើឱ្យទម្រង់នេះមានប្រសិទ្ធភាពតិចជាង ក្នុងការរក្សា

ទំនាក់ទំនងរបស់ភាគីវិវាទ។ ទោះជាយ៉ាងណាក៏ដោយ សន្ទានកម្មជាធម្មតាគឺជាវិធីដ៏ប្រសើរបំផុតក្នុងការរក្សាទំនាក់ទំនងរបស់ភាគី។ អាស្រ័យទៅលើកាលៈទេសៈនិងលក្ខណៈវិវាទ ជួនកាលសន្ទានកម្មអាចមានភាពជោគជ័យច្រើនជាងការចរចា។

ការនៅស្ងៀមធ្វើអ្វីគឺស្ថិតនៅចំណុចកណ្តាល ពីព្រោះវាអាចរក្សាទំនាក់ទំនងក្នុងរយៈពេលខ្លី ប៉ុន្តែវាអាចប៉ះពាល់ដល់ទំនាក់ទំនងក្នុងរយៈពេលវែង។ ឧទាហរណ៍ ប្រសិនបើប្រពន្ធសម្រេចចិត្តមិនរអ៊ូរទាំអំពីការលេងល្បែង ស៊ីសងរបស់ប្ដី ទំនាក់ទំនងរបស់គាត់អាចត្រូវបានរក្សាសម្រាប់រយៈពេលខ្លី ប៉ុន្តែយូរទៅ គាត់អាចមិនសប្បាយចិត្តខ្លាំងឡើងៗ ហើយគាត់អាចបង្ហាញនូវភាពមិនពេញចិត្តច្រើនឡើងម្ដងបន្តិចៗ តាមរយៈការមិនជួយយកអាសារ ឬរហូតឈានដល់ការបែកបាក់គ្នា។

ការដោះស្រាយដោយខ្លួនឯង គឺមានភាពកម្សោយក្នុងការរក្សាទំនាក់ទំនង ពីព្រោះវាត្រូវបានចាត់ទុកថាជាសកម្មភាពឯកតោភាគី ដែលត្រូវបានធ្វើឡើងដោយមិនពិគ្រោះយោបល់ជាមួយភាគីម្ខាងទៀតទេ។ អាស្រ័យលើទម្រង់លក្ខណៈនៃការដោះស្រាយទំនាស់ដោយខ្លួនឯង ដែលភាគីជ្រើសរើស (ដូចជាអំពើហិង្សាលើរូបរាងកាយ) ដំណោះស្រាយនេះអាចជាមធ្យោបាយដែលមានបញ្ហាធំបំផុតនៅក្នុងការរក្សាសម្ព័ន្ធភាព។ ដូចគ្នានេះដែរ មជ្ឈត្តការ ឬការប្ដឹងទៅតុលាការមានភាពប្រកួតប្រជែងយ៉ាងខ្លាំង ហើយជាលទ្ធផលគឺមានអ្នកចាញ់និងអ្នកឈ្នះ ដែលធ្វើឱ្យមានការលំបាកដល់ការរក្សាទំនាក់ទំនងរបស់ភាគីទាំងពីរ។ យ៉ាងហោចណាស់មជ្ឈត្តការអនុញ្ញាតឱ្យមាននីតិវិធី កាន់តែក្រៅផ្លូវការ និងអាចបត់បែនបាន ដែលអាច "សម្រួល" ចំណុចនេះបាន ។

## ឃ. ការប្រៀបធៀបដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ចំពោះវិវាទអំពីគោលការណ៍

វិវាទមួយចំនួនមិនពាក់ព័ន្ធនឹងរឿងលុយកាក់នោះទេ ប៉ុន្តែពាក់ព័ន្ធនឹងគោលការណ៍ទៅវិញ។ វិវាទទាំងនេះអាចពាក់ព័ន្ធទៅនឹងសិទ្ធិមនុស្ស ឬការបរិហារកេរ្តិ៍ ។ ឧទាហរណ៍ ភាគីម្ខាងអាចមានអារម្មណ៍ថា សារព័ត៌មានមួយបានចោទប្រកាន់ខ្លួនដោយមិនត្រឹមត្រូវពីបទប្រព្រឹត្តខុសមួយ ។

**ការប្រៀបធៀបដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ-វិវាទអំពីគោលការណ៍**

| បណ្តឹងតុលាការ | មជ្ឈត្តការ | សន្ទានកម្ម | ការចរចា | ការដោះស្រាយដោយខ្លួនឯង | ការធ្វើមិនដឹងមិនឮ ចំពោះបញ្ហា/មិនចាត់វិធានការអ្វីទាំងអស់ |
|---|---|---|---|---|---|
| ភាគីទីបីសម្រេចជាសាធារណៈថា តើអ្នកណាខុស អ្នកណាត្រូវ | ភាគីទីបីសម្រេចជាឯកជនថាតើ អ្នកណាខុស អ្នកណាត្រូវ | ភាគីទីបីជួយភាគីឱ្យទទួលបានដំណោះស្រាយ និងការដោះស្រាយជាឯកជន | ដំណោះស្រាយ និងដំណោះស្រាយជាឯកជន | សកម្មភាពជាឯកជន គ្មានការដោះស្រាយ គ្មានការសម្រេចថាតើអ្នកណាខុស អ្នកណាត្រូវ | គ្មានការដោះស្រាយ គ្មានការសម្រេចថាតើ អ្នកណាខុស អ្នកណាត្រូវ |




នៅពេលដោះស្រាយវិវាទអំពីគោលការណ៍ ដូចជា តើអ្នកណាខុស អ្នកណាត្រូវលើបញ្ហាមួយ ការវិនិច្ឆ័យដោយតុលាការគឺជាជម្រើសដ៏ប្រសើរបំផុត ពីព្រោះវាផ្តល់សេចក្តីសម្រេចជាសាធារណៈចំពោះបញ្ហា។ មជ្ឈត្តការផ្តល់នូវសេចក្តីសម្រេចជាឯកជន ដែលអាចមានលក្ខណៈគ្រប់គ្រាន់ចំពោះវិវាទមួយចំនួន។ សន្ទានកម្ម និងការចរចា មិនសម្រេចលើបញ្ហាគោលការណ៍ទេ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ភាគីវិវាទអាចឈានទៅដល់ការយោគយល់ និងព្រមព្រៀងគ្នាមួយ។ ដំណោះស្រាយដោយខ្លួនឯង និងការនៅស្ងៀម ជាទូទៅមិនបានផ្តល់នូវលើបញ្ហាជាចម្បងឡើយ ។

## ខ. ការប្រៀបធៀបដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នៅក្នុងករណីអតុល្យភាពនៃអំណាច

វិវាទមួយចំនួនមានអតុល្យភាពនៃអំណាច ។ ភាគីម្ខាងអំណាចខ្លាំងជាងភាគីម្ខាងទៀត ។ កំលាំងទាំងនោះអាចបណ្តាលមកពីទំហំ និងទ្រព្យសម្បត្តិរបស់ភាគី។ ឬមួយក៏វាអាចបណ្តាលកាលៈទេសៈនានា។ ឧទាហរណ៏ សូមពិចារណាលើក្រុមហ៊ុនដ៏ធំមួយ និងបុគ្គលម្នាក់។ ករណីនេះអាចមានអតុល្យភាពលម្អៀងទៅខាងក្រុមហ៊ុន ដោយសារតែធនធានទ្រព្យសម្បត្តិ និងក្រុមមេធាវីដ៏ធំ។ នៅក្នុងករណីនេះបុគ្គលម្នាក់នោះអាចចង់បានការការពារមួយ ចំនួនប្រឆាំងនឹងក្រុមហ៊ុនដែលមានអំណាច។ ម្យ៉ាងវិញទៀតអតុល្យភាពអាចស្ថិតនៅក្នុងទិសដៅមួយផ្ទុយពីនេះ។ ក្រុមហ៊ុនអាចត្រូវការបុគ្គលនេះយ៉ាងខ្លាំង ពីព្រោះគាត់មានចំណេះដឹងយ៉ាងច្រើនអំពីប្រព័ន្ធកុំព្យូទ័ររបស់ក្រុមហ៊ុន។ នៅក្នុងវិវាទអំពីរឿងប្រាក់បៀវត្សរ៍របស់គាត់ បុគ្គលនោះមានអំណាចខ្លាំងជាងក្រុមហ៊ុន។ នៅក្នុងករណីនេះ បុគ្គលនោះមិនត្រូវការនូវការការពារនោះឡើយ ។

**ការប្រៀបធៀបដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ-ករណីអតុល្យភាពនៃអំណាច**

| បណ្តឹងទៅតុលាការ | មជ្ឈត្តការ | សន្ធានកម្ម | ការចរចា | ការដោះស្រាយដោយខ្លួនឯង | ការធ្វើមិនអើពើ ឬ មិនចាត់ធ្វើអ្វី |
|---|---|---|---|---|---|
| ភាគីទីបីសម្រេចជាសាធារណៈថាអ្នកណាឈ្នះ | ភាគីទីបីរក្សាយុត្តិធមិខាងនីតិវិធី និងលទ្ធផល | ភាគីទីបីជួយទប់ស្កាត់កុំឱ្យភាគីខ្លាំងគំរាមកំហែងភាគីខ្សោយ | ភាគីមានអំណាចអាចបង្ខំឱ្យភាគីខ្សោយចុះចាញ់ | ភាគីមានអំណាចឈ្នះ | ភាគីមានអំណាចឈ្នះ |

ការការពារដែលរឹងមាំ ↔ ការការពារដែលមិនរឹងមាំ

ដូចក្រាហ្វិចខាងលើបានបង្ហាញ ការវិនិច្ឆ័យដោយតុលាការផ្តល់នូវការការពារខ្ពស់បំផុតសម្រាប់ភាគីខ្សោយ នៅក្នុងវិវាទមួយ។ ចៅក្រមនឹងធានាថា ភាគីទាំងពីរគោរពតាមវិធានដូចគ្នា ហើយនឹងដោះស្រាយវិវាទដោយផ្អែកលើច្បាប់ដោយមិនគិតពីអំណាចរបស់ភាគីឡើយ។ ផ្ទុយទៅវិញ ការចរចាគឺគ្រាន់តែធ្វើឡើងរវាងភាគីពីរប៉ុណ្ណោះ។ ហេតុនេះភាគីដែលមានអំណាចខ្លាំងជាង អាចយកប្រៀបដើម្បីបង្ខំឱ្យភាគីម្ខាងទៀតឱ្យយល់ព្រមទទួល យកដំណោះស្រាយដែលមានភាពលម្អៀងមកខាងភាគីដែលមានអំណាច។ ឧទាហរណ៏ នៅក្នុងករណីដែលបានរៀបរាប់ខាងលើ និយោជិតដែលមានចំណេះដឹងជំនាញខាងកុំព្យូទ័រ អាចបង្ខំឱ្យក្រុមហ៊ុនដំឡើងប្រាក់បៀវត្សរ៍របស់ខ្លួន ពីព្រោះ គាត់អាចជះឥទ្ធិពលដោយអំណាចខ្លាំងរបស់គាត់ ដើម្បីឈាន ទៅដល់ការព្រមព្រៀងដែលបំពេញបំណងខ្លួន។

## លំហាត់ ៖ តុព្រះមហាក្សត្រ

លំហាត់នេះត្រូវបានរៀបចំឡើង ដើម្បីជួយបង្ហាញអំពីភាពខុសគ្នានៃលទ្ធផល និងដំណើរការ រវាងការសម្រុះ-សម្រួល និងមជ្ឈត្តការ ។

**សេចក្តីណែនាំ ៖**

លោកអ្នកនឹងត្រូវបានប្រគល់តួនាទីជាមជ្ឈត្តករ/អ្នកសម្រុះសម្រួលរបស់ស៊ីថា ឬហ៊ាង ។ ដោយជួបប្រជុំក្នុងក្រុមដែលមានគ្នាបីនាក់ លោកអ្នកនឹងមានរយៈពេល ២០ នាទីដំបូង ដើម្បីដោះស្រាយរឿងក្តីដោយមជ្ឈត្តការ (សូមចងចាំថា នៅក្នុងមជ្ឈត្តការ ភាគីនីមួយៗបង្ហាញនូវអំណះអំណាងដ៏ល្អបំផុតរបស់ខ្លួន ដើម្បីបញ្ចុះបញ្ចូលមជ្ឈត្តករអំពីជំហររបស់ខ្លួន ។ មជ្ឈត្តករអាចសួរសំណួរមួយចំនួន ប៉ុន្តែមិនលើកទឹកចិត្តឱ្យពិភាក្សាដោះស្រាយនោះទេ) ។ មិនត្រូវប្រកាសការសម្រេច ចិត្តរបស់លោកអ្នកប្រាប់ដល់ភាគីឡើយ ។

បន្ទាប់មក មជ្ឈត្តករទៅកាន់ក្រុមមួយទៀត ដែលខ្លួនមានរយៈពេល ២០ នាទី ដើម្បីសម្រុះសម្រួលរឿងក្តី (សូមចងចាំថា នៅក្នុងសន្ទានកម្ម តួនាទីរបស់ភាគីអព្យាក្រឹតគឺជួយសម្រួលដល់ការពិភាក្សារវាងភាគី ដើម្បីជួយឱ្យពួកគេស្វែងរកដំណោះស្រាយដែលអាចទទួលយកបានទៅវិញទៅមក) ។

**អង្គហេតុ ៖**

ស៊ីថា និង ហ៊ាង ជាមិត្តចាស់នឹងគ្នា ។ ពួកគេបានបើកការិយាល័យមេធាវីជាមួយគ្នាអស់រយៈពេលជិត ១៥ឆ្នាំមក ហើយ ។ ដោយសារតែមានការខ្វែងគំនិតគ្នាមួយចំនួនក្នុងការគ្រប់គ្រង ពួកគេបានសម្រេចចិត្តបញ្ចប់ភាពជាដៃគូខាងច្បាប់របស់ពួកគេ ។ ពួកគេចរចាគ្នាអំពីការបែងចែកទ្រព្យសម្បត្តិទាំងអស់របស់ពួកគេ លើកលែងតែតុព្រះមហាក្សត្រ ។ ស៊ីថា និងហ៊ាង មិនមានបញ្ហាក្នុងការបែងចែកអតិថិជន សៀវភៅ គ្រឿងបរិក្ខារកុំព្យូទ័រ ការជួលការិយាល័យ ឬបុគ្គលិកនោះទេ ។ ប៉ុន្តែ អ្នកទាំងពីរមិនព្រមព្រៀងគ្នាលើតុព្រះមហាក្សត្រ ។

តុព្រះមហាក្សត្រគឺជាតុបុរាណដែលធ្លាប់តម្កល់នៅក្នុងព្រះបរមរាជវាំងនៃព្រះមហាក្សត្រខ្មែរ ក្នុងកំឡុងទសវត្សឆ្នាំ១៨០០ ។ នៅពេលស៊ីថា និងហ៊ាងចាប់ផ្តើមបើកការិយាល័យមេធាវីជាមួយគ្នា ប្រពន្ធរបស់ស៊ីថាដែលបានទៅហាងបុរាណ និងបាន ចូលរួមការដេញថ្លៃលក់ឡាយឡុងវត្ថុបុរាណជាច្រើន បានស្វែងរកអស់រយៈពេលជាយូរមកហើយនូវតុដ៏ល្អឥតខ្ចោះមួយ សម្រាប់បន្ទប់សន្និសីទសំខាន់របស់មេធាវី ។ នាងបានទិញតុ កៅអី និងអំពូលចាស់ៗជាច្រើន ដែលស៊ីថា និងហ៊ាងមិនមាន បញ្ហាក្នុងបែងចែកទេ ប៉ុន្តែមិនមានលទ្ធភាពក្នុងការស្វែងរកយ៉ាងងាយស្រួលនូវតុដ៏ល្អឥតខ្ចោះមួយសម្រាប់បន្ទប់សន្និសីទ សំខាន់របស់ស៊ីថា និងហ៊ាងទេ ។

តុព្រះមហាក្សត្រត្រូវបានប្រទះឃើញនៅក្នុងហាងមួយក្បែរទីក្រុងភ្នំពេញ ។ មិនមានអ្នកណាទិញតុនេះឡើយ ពីព្រោះតុនេះត្រូវបានលាបជាមួយនឹងថ្នាំជាច្រើនស្រអាប់ យ៉ាងអាក្រក់បំផុត ហើយមានបាក់បែកនិងស្នាមប្រឡាក់ ហើយជ្រុងមួយទាបជាងជ្រុងមួយទៀត ។ ប៉ុន្តែប្រពន្ធរបស់ ស៊ីថាចំណាំបានភ្លាមៗថា វាជាតុព្រះមហាក្សត្រ ។ នៅពេលស៊ីថា និង ហ៊ាង ឃើញតុ ពួកគេដឹងភ្លាមៗថា នាងធ្វើបានល្អ ណាស់ ។

ហ៊ាង ជាជាងឈើ បានកោសថ្នាំចាស់ចេញយ៉ាងប្រុងប្រយ័ត្ន សម្រួលស្នាមបែកនៃតុ ធ្វើឱ្យផ្ទៃតុស្មើគ្នា

ដោយបន្ថែមឈើគុណភាពខ្ពស់លើជើងតុម្ខាង រំលីងផ្ទៃតុ ហើយធ្វើឱ្យតុមានសម្រស់ដូចដើម ។

ទាំងស៊ីថា ទាំងហ៊ាង បានប្រើប្រាស់យ៉ាងមានមោទនភាព ហើយបានថែទាំតុនោះអស់រយៈពេល ១៥ ឆ្នាំកន្លងមកហើយ ។ កូនក្តីរបស់ពួកគេ មេធាវីផ្សេងទៀត និងភ្ញៀវដែលមកការិយាល័យរបស់ពួកគេ តែងតែនិយាយអំពីភាពកម្រ និងសម្រស់របស់តុនោះ ។ ស៊ីថា និងហ៊ាង ជឿថា តុនេះមានតម្លៃមិនអាចកាត់ថ្លៃបាន ។ ជាលទ្ធផល ទាំងស៊ីថា ទាំងហ៊ាង មិនមានឆន្ទៈក្នុងការបែងចែកតុនោះទេ ហើយក៏មិនលក់តុនោះឱ្យអ្នកផ្សេងដែរ ទោះជាក្នុងតម្លៃប៉ុន្មានក៏ដោយ ។

- តើមជ្ឈត្តការមានលទ្ធផលយ៉ាងណា ?
- តើសន្ទានកម្មមានលទ្ធផលយ៉ាងណា ?
- តើវិធីទាំងពីរនេះខុសគ្នាដូចម្តេច?
- តើបទពិសោធន៍ខុសគ្នាយ៉ាងដូចម្តេច ?
- តើអ្នកមានអារម្មណ៍យ៉ាងណាចំពោះដៃគូរបស់លោកអ្នក បន្ទាប់ពីបញ្ចប់ជំនឿមួយៗ?

## ច. ការជ្រើសរើសដំណើរការដ៏ប្រសើរបំផុត

មិនមានវិធីសាស្ត្រតែមួយមុខនៃដំណោះស្រាយវិវាទដែលមានលក្ខណៈប្រសើរលើសវិធីសាស្ត្រឯទៀតនោះទេ។ មធ្យោបាយល្អបំផុតដែលមេធាវី ឬភាគីអាចធ្វើបាន នៅពេលជ្រើសរើសវិធីសាស្ត្រដោះស្រាយវិវាទផ្សេងៗគ្នា គឺត្រូវពិចារណាលើលក្ខណៈវិនិច្ឆ័យដែលបានពិភាក្សាខាងលើ ហើយព្យាយាមកំណត់ថាតើលក្ខណៈវិនិច្ឆ័យណាមួយ ដែលស្ថិតក្នុងផលប្រយោជន៍ដ៏ប្រសើរបំផុតចំពោះភាគី។ ខាងក្រោមនេះគឺជាបញ្ជីលក្ខណៈវិនិច្ឆ័យមួយចំនួន ដើម្បីធ្វើការពិចារណា:

- **លទ្ធភាពគ្រប់គ្រងរបស់ភាគី**

  តើភាគីចង់បានភាពបត់បែនដើម្បីបង្កើតវិធានផ្ទាល់ខ្លួនដែរឬទេ ? ឬវិធានបទដ្ឋានមានភាពប្រសើរជាង?

- **ភាពផ្លូវការ**

  តើគាត់ទទួលបានប្រយោជន៍កាន់តែច្រើនជាងមុន ជាមួយវិធានតុលាការផ្លូវការដែលក្រុមហ៊ុនរបស់ខ្លួន មានទម្លាប់ធ្វើ ? ឬតើភាគីចង់បាន ដំណើរការក្រៅផ្លូវការ ដោយសារតែកម្រិតទាបនៃភាពទាន់សម័យរបស់ខ្លួន?

- **ល្បឿន**

  តើមានតម្រូវការបន្ទាន់ដើម្បីស្រាយបញ្ហាដែរឬទេ? ឬតើភាគីទទួលបានប្រយោជន៍ច្រើនជាងមុន ដោយការបង្ខំភាគីម្ខាងទៀតឱ្យតតាំងអស់រយៈពេលជាច្រើនឆ្នាំដែរឬទេ?

- **ភាពជាឯកជន**

  តើវិវាទមានពាក់ព័ន្ធនឹងមានព័ត៌មានរសើបអំពីភាគីដែលអាចបណ្តាលឱ្យមានភាពអាម៉ាស នៅពេលផ្សព្វផ្សាយជាសាធារណៈដែរឬទេ ?

- **ការចំណាយ**

  តើភាគីជាក្រុមហ៊ុនពហុជាតិដ៏ធំ ឬគ្រាន់តែជាមនុស្សក្រីក្រម្នាក់? ឧទាហរណ៍ តើវិវាទនោះពាក់ព័ន្ធនឹងទឹកប្រាក់មួយលានដុល្លារ ឬគ្រាន់តែពាក់ព័ន្ធនឹងទូរស័ព្ទដៃខូចមួយគ្រឿង?

- **ភាពបត់បែននៃលទ្ធផល**

  តើលទ្ធផលតុលាការជាស្តង់ដារ ដូចជាសំណងទឹកប្រាក់មានភាពគ្រប់គ្រាន់ដែរឬទេ ឬភាគីចង់បានជម្រើសលទ្ធផលច្រើនជាងនេះ?

- **ទំនាក់ទំនងរបស់ភាគី**

  តើវាមានសារៈសំខាន់យ៉ាងណាដែលភាគីរក្សាទំនាក់ទំនងរបស់ពួកគេ?

- **ទំនាស់លើគោលការណ៍**

តើនេះគឺជាវិវាទអំពីគោលការណ៍ដូចជាភាគីចង់បានសេចក្តីសម្រេចមួយ ដែលបង្ហាញថាអ្នកណាខុសអ្នកណាត្រូវឬ?

- **តុល្យភាពនៃអំណាច**

  តើមានអតុល្យភាពនៃអំណាច ដូចជាភាគីចង់បានការការពារដែរឬទេ?

- **ផលប្រយោជន៍សាធារណៈ**[២៩៩]

  តើនេះជារឿងក្តីពាក់ព័ន្ធនឹងផលប្រយោជន៍សាធារណៈដែរឬទេ? ឧទាហរណ៍រឿងក្តីដើម្បីការពារការផ្តល់សម្បទានកាប់ឈើនៅក្នុងតំបន់ព្រៃការពារ ។

- **ភាពយូរអង្វែង**[៣០០]

  ភាពយូរអង្វែងសំដៅ ថាតើភាគីចង់បានដំណោះស្រាយដែលមានលក្ខណៈ "យូរអង្វែង" ពោលគឺការចូលជាធរមាន ។ ឧទាហរណ៍ កិច្ចព្រមព្រៀងដោះស្រាយតាមការចរចាជាឯកជនមួយ អាចដោះស្រាយបញ្ហានៅថ្ងៃនេះ ប៉ុន្តែនៅថ្ងៃស្អែក ភាគីណាមួយអាចរំលោភលើកិច្ចប្រមព្រៀងនោះបាន ។ ភាគីអាចត្រូវការសេចក្តីសម្រេចភ្ជាប់កាតព្វកិច្ចមួយ ដែលអាចយកមកអនុវត្តបាន ។

វាជាប្រការសំខាន់មួយដែលត្រូវទទួលស្គាល់ថា វិធីសាស្ត្រដោះស្រាយវិវាទប្រសើរបំផុតសម្រាប់ភាគីវិវាទមួយ អាចមិនមែនជាវិធីសាស្ត្រប្រសើរបំផុតសម្រាប់ភាគីមួយទៀតឡើយ ។ ឧទាហរណ៍ នៅក្នុងវិវាទជាមួយនឹងអតុល្យភាពនៃអំណាចដ៏ធំមួយ ភាគីខ្លាំងអាចចង់ចរចាជាឯកជន ដើម្បីទាញយកអត្ថប្រយោជន៍ពីអំណាចរបស់ខ្លួន ។ ប៉ុន្តែភាគីខ្សោយអាចចង់ប្តឹងទៅតុលាការដើម្បីឱ្យចៅក្រមការពារខ្លួន ។ ប៉ុន្តែនៅក្នុងករណីជាច្រើនផ្សេងទៀត វិធីសាស្ត្រដោះស្រាយក្រៅផ្លូវតុលាការមួយ គឺមានលក្ខណៈសមស្របបំផុតសំរាប់ភាគីទាំងសងខាង ។

---

[២៩៩] លក្ខណៈវិនិច្ឆ័យនេះមិនមានរៀបរាប់នៅខាងលើទេ ពីព្រោះវាមិនស៊ីគ្នានឹងទម្រង់ក្រាហ្វិច ។

[៣០០] លក្ខណៈវិនិច្ឆ័យនេះមិនមានរៀបរាប់នៅខាងលើទេ ពីព្រោះវាមិនស៊ីគ្នានឹងទម្រង់ក្រាហ្វិច ។

## សំណួរសិក្សា

ខាងក្រោមនេះគឺជាបញ្ជីវិវាទ។ ចំពោះវិវាទនីមួយៗ ចូរកំណត់ថាតើវិធីសាស្ត្រណាមួយក្នុងចំណោមវិធីសាស្ត្រទាំង៦ នៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មានភាពសមស្របបំផុតសម្រាប់ភាគីនីមួយៗ។ នៅក្នុងវិវាទមួយចំនួន ភាគីទាំងពីរនឹងត្រូវការវិធីសាស្ត្រដូចគ្នា ចំណែកឯនៅក្នុងវិវាទផ្សេងទៀត ពួកគេនឹងត្រូវការវិធីសាស្ត្រផ្សេងពីគ្នា ។ វាអាចមានចម្លើយលើសពីមួយ ។ ឧទាហរណ៍ ការចរចា និងសន្ទានកម្ម អាចមានភាពសមស្របស្មើគ្នាចំពោះ ភាគីមួយ ។

វិធីសាស្ត្រទាំង ៦ នៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមាន: ១) ការដោះស្រាយដោយខ្លួនឯង ២) ការនៅស្ងៀម ៣) ការចរចា ៤) សន្ទានកម្ម ៥) មជ្ឈត្តការ និង ៦) ការប្តឹងទៅតុលាការ។

១. វុធគិតថា ឪពុករបស់គាត់មានភាពតឹងតែងពេកជាមួយគាត់ ។ ឪពុករបស់គាត់មិនយល់ស្រប ។

វិធីសាស្ត្រប្រសើរបំផុតនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការចំពោះវុធ: ____________________

វិធីសាស្ត្រប្រសើរបំផុតនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការចំពោះឪពុកវុធ: ____________________

២. ក្រុមហ៊ុនផលិតលំដាប់ផ្កាយបួនមានមូលដ្ឋាននៅទីក្រុងប៉េកាំង ជំពាក់ប្រាក់ក្រុមហ៊ុនកៅស៊ូមណ្ឌលគីរីចំនួន ៥០.០០០ ដុល្លារអាមេរិក ។ ក្រុមហ៊ុនកៅស៊ូមណ្ឌលគីរីមានការព្រួយបារម្ភអំពីការសងប្រាក់ ពីព្រោះក្រុមហ៊ុនផ្កាយបួនគ្មានទ្រព្យ-សកម្ម នៅក្នុងប្រទេសកម្ពុជា ។

វិធីសាស្ត្រប្រសើរបំផុតនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការចំពោះក្រុមហ៊ុនមណ្ឌលគីរី: ____________

វិធីសាស្ត្រប្រសើរបំផុតនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការចំពោះក្រុមហ៊ុនលំដាប់ផ្កាយបួន: ________

៣. សាព័រ មិនចូលចិត្តទង្វើដែលចៅហ្វាយរបស់ខ្លួនគឺ ភិរក្ស ដែលបដិសេធមិនឱ្យនាងឈប់សម្រាកចំនួន៤ថ្ងៃ នាពេលបុណ្យភ្ជុំបិណ្ឌ។

វិធីសាស្ត្រប្រសើរបំផុតនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការចំពោះសាព័រ: ____________________

វិធីសាស្ត្រប្រសើរបំផុតនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការចំពោះភិរក្ស: ____________________

៤. ធីរិទ្ធិគឺជាគ្រូបង្វឹកក្រុមបាល់ទាត់ជម្រើសជាតិកម្ពុជា ។ ប៊ុនសេងគឺជាកីឡាករឆ្នើមបំផុតនៅក្នុងប្រទេសកម្ពុជា ។ ប៉ុន្តែ ប៊ុនសេង និងធីរិទ្ធិមិនចូលចិត្តគ្នា ហើយភាគីម្ខាងបដិសេធមិនចូលរួម ប្រសិនបើភាគីម្ខាងទៀតនៅក្នុងក្រុម ។

វិធីសាស្ត្រប្រសើរបំផុតនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការចំពោះធីរិទ្ធិ : ____________________

វិធីសាស្ត្រប្រសើរបំផុតនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការចំពោះប៊ុនសេង: ____________________

៥. ក្រុមហ៊ុនស្បៀងអាហារ Happy Hunting បានចុះកិច្ចសន្យាជាមួយភោជនីយដ្ឋាន Big Meal ដើម្បីផ្គត់ផ្គង់ដល់ភោជនីយដ្ឋាននូវសាច់មាន់ ។ បន្ទាប់ពីក្រុមហ៊ុន Happy Hunting បានប្រគល់សាច់មាន់ជាលើកទីពីរចំនួនពេញមួយឡាន ភោជនីយដ្ឋាន Big Meal បានប្រាប់ក្រុមហ៊ុន Happy Hunting ថាខ្លួនមិនអាចបង់ប្រាក់ថ្លៃសាច់មាន់បានទេ ពីព្រោះខ្លួនមានបញ្ហាហិរញ្ញវត្ថុ ។

វិធីសាស្ត្រប្រសើរបំផុតនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការចំពោះ Happy Hunting: ______________

វិធីសាស្ត្រប្រសើរបំផុតនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការចំពោះ Big Meal: __________________

៦. ក្រុមហ៊ុនអភិវឌ្ឍន៍ Megabucks បានសម្រេចថា ខ្លួនចង់សាងសង់សណ្ឋាគារដ៏ធំមួយនៅលើដីដែលប្រជាជនក្រីក្រកំពុងប្រើប្រាស់ធ្វើជាលំនៅដ្ឋានរបស់ពួកគេ។ ប្រជាជនក្រីក្រមិនមានប័ណ្ណសម្គាល់កម្មសិទ្ធិកាន់កាប់ដីស្របច្បាប់នោះទេ ប៉ុន្តែអះអាងថាពួកគេបានកាន់កាប់ដីនោះអស់រយៈពេលជាង ៥ ឆ្នាំមកហើយ។ ក្រុមហ៊ុន Megabucks បានទិញប័ណ្ណសម្គាល់កម្មសិទ្ធិ ប៉ុន្តែ ឥឡូវនេះ ត្រូវពិចារណាអំពីកិច្ចការដែលត្រូវធ្វើជាមួយប្រជាជនក្រីក្រ ដែលមិនព្រមចាកចេញពីព្រោះពួកគេអះអាងថាមានសិទ្ធិលើដី។

វិធីសាស្ត្រប្រសើរបំផុតនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការចំពោះ Megabucks: __________________

វិធីសាស្ត្រប្រសើរបំផុតនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការចំពោះប្រជាជនក្រីក្រ: ___________________

៧. ក្រុមហ៊ុនទឹកស្អុយសាផុន បានទទួលពាក្យបណ្តឹងពីប្រជាជនមួយចំនួននៅរាជធានីភ្នំពេញថា ទឹកស្អុយកំពុងបំពុលទឹកទន្លេ ដែលពួកគេប្រើប្រាស់សម្រាប់ផឹក បោកគក់ នេសាទ និងកំសាន្ត។

វិធីសាស្ត្រប្រសើរបំផុតនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការចំពោះក្រុមហ៊ុនសាផុន: _______________

វិធីសាស្ត្រប្រសើរបំផុតនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការចំពោះប្រជាជនក្នុងមូលដ្ឋាន: ____________

៨. នគរបាលមួយរូបវាយក្បាលស៊ីសុវណ្ណានឹងដំបង នៅពេលនាងជិះម៉ូតូ។ នគរបាលនិយាយថា នេះគឺជាគ្រោះថ្នាក់។ ស៊ីសុវណ្ណាមានរបួសធ្ងន់ ហើយបានចំណាយប្រាក់អស់ជាង ២.០០០ ដុល្លារនៅមន្ទីរពេទ្យ។

វិធីសាស្ត្រប្រសើរបំផុតនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការចំពោះស៊ីសុវណ្ណា: ___________________

វិធីសាស្ត្រប្រសើរបំផុតនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការចំពោះនគរបាល: ___________________

៩. គន្ធាខឹងនឹងសុផលយ៉ាងខ្លាំង។ សុផលបានខ្ចីម៉ូតូនាង ហើយបដិសេធមិនព្រមសងវិញ។ បន្ទាប់មកសុផលលក់ម៉ូតូឱ្យភាគី ទីបី ហើយម៉ូតូក៏បាត់។

វិធីសាស្ត្រប្រសើរបំផុតនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការចំពោះគន្ធា: ______________________

វិធីសាស្ត្រប្រសើរបំផុតនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការចំពោះសុផល: ______________________

១០. ក្រុមហ៊ុន Brilliant Diamond បានទិញត្បូងមួយចំនួនពីរិទ្ធី ដែលត្រូវបានរកឃើញថាជាត្បូងក្លែងក្លាយ។ ក្រុមហ៊ុន Brilliantចង់ប្រមូលការខាតបង់មកវិញពីរិទ្ធី ហើយកំពុងបារម្ភថារិទ្ធិមិនស្មោះត្រង់ ហើយបានលាក់លុយទុក។

វិធីសាស្ត្រប្រសើរបំផុតនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការចំពោះក្រុមហ៊ុន Brilliant: ______________

វិធីសាស្ត្រប្រសើរបំផុតនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការចំពោះរិទ្ធី: __________________________

១១. តារាភាពយន្ត "ស៊ីណា" ដឹងថាទស្សនាវដ្ដីផ្កាយព្រឹកបានចុះផ្សាយព័ត៌មានមិនពិត និងរឿងភ័ន្តច្រឡំមួយអំពីជីវិតផ្ទាល់របស់នាង។

វិធីសាស្ត្រប្រសើរបំផុតនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការសំរាប់ស៊ីណា: _______________________

វិធីសាស្ត្រប្រសើរបំផុតនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការសំរាប់ទស្សនាវដ្ដីផ្កាយព្រឹក: ______________

## ឆ. វិធីសាស្ត្រថ្មីៗនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

បន្ថែមពីលើវិធីសាស្ត្រនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការទាំងបី មានវិធីសាស្ត្រជាច្រើនផ្សេងទៀតក្នុងការដោះស្រាយវិវាទដែលត្រូវបានគេបង្កើតឡើងនៅតាមបណ្តាកន្លែងផ្សេងៗគ្នា។ ខាងក្រោមនេះគឺជាបញ្ជីនៃបណ្តាវិធីសាស្ត្រទាំងនេះ

- **ការជំនុំជម្រះទ្រង់ទ្រាយតូច**

នៅក្នុងការជំនុំជម្រះទ្រង់ទ្រាយតូច ភាគីចូលរួមនៅក្នុងការជំនុំជម្រះរយៈពេលខ្លីមួយ មុននឹងភាគីអព្យាក្រឹតបង្ហាញនូវភ័ស្តុតាងនិងសាក្សីសំខាន់ៗ ព្រមទាំងសេចក្តីប្រកាសបើកនិងបិទខ្លីៗ។ ភាគីអព្យាក្រឹតផ្តល់នូវមតិយោបល់ណែនាំដោយផ្អែកលើភ័ស្តុតាងដែលមាន។ មតិយោបល់នោះជួយឱ្យភាគីអាចព្យាករណ៍ទុកជាមុនអំពីរបៀបដែលតុលាការសម្រេចរឿងក្តី ប្រសិនបើការចរចារបស់ភាគីមិនអាចសំរេចបាន ហើយតម្រូវឱ្យពួកគេត្រូវឈានទៅដោះស្រាយតាមរយៈដំណើរការវិនិច្ឆ័យដោយតុលាការ។ ភាគីទទួលបានព័ត៌មាននេះ ត្រឡប់ទៅការចរចាវិញ ហើយប្រើប្រាស់វានៅក្នុងការពិភាក្សាចរចា។ នេះគឺជាដំណើរការដោះស្រាយដោយមានការចំណាយច្រើន ដែលជាធម្មតា ត្រូវបានប្រើប្រាស់សម្រាប់វិវាទដែលមានទ្រង់ទ្រាយធំ និងស្មុគស្មាញ ។

ការប្រែប្រួលត្រូវបានហៅថា ការជំនុំជម្រះសង្ខេបដោយគណៈវិនិច្ឆ័យ ដែលស្រដៀងគ្នាទៅនឹងការជំនុំជម្រះទ្រង់ទ្រាយតូចដែរ ប៉ុន្តែគេប្រើគណៈវិនិច្ឆ័យជំនួសឱ្យចៅក្រម ដើម្បីចេញសេចក្តីសម្រេចភ្ជាប់កាតព្វកិច្ច។ វិធីសាស្ត្រនេះត្រូវបានប្រើប្រាស់សម្រាប់រឿងក្តីធំៗ ដែលនឹងបញ្ជូនទៅចំពោះមុខគណៈវិនិច្ឆ័យ ប្រសិនបើភាគីវិវាទមិនអាចឈានដល់ការព្រមព្រៀងគ្នា។

- **ការវាយតម្លៃជាមុនដោយភាគីអព្យាក្រឹត**

វិធីសាស្ត្រនេះដូចគ្នាទៅនឹងការជំនុំជម្រះទ្រង់ទ្រាយតូចដែរ ប៉ុន្តែវាត្រូវការរយៈពេលខ្លីជាង ហើយវាជាផ្នែកមួយនៃកម្មវិធីសន្ទានកម្មភ្ជាប់នឹងស្ថាប័នតុលាការ ។ ភាគីធ្វើបទបង្ហាញរៀងៗខ្លួន មួយជូនភាគី អព្យាក្រឹត ដែលបន្ទាប់មកភាគីអព្យាក្រិតផ្តល់ការព្យាករណ៍ដ៏ខ្លីដែលមិនភ្ជាប់កាតព្វកិច្ចទៅលើលទ្ធផល នៃរឿងក្តីប្រសិនបើពួកគេត្រូវទៅដោះស្រាយនៅតុលាការ។ វិធីសាស្ត្រនេះជួយដល់ភាគីវិវាទក្នុងការចរចា។ វាអាចត្រូវបានគេធ្វើមុន ឬក្រោយដំណើរការវិនិច្ឆ័យដោយតុលាការ។

- **កិច្ចប្រជុំដោះស្រាយ**

វិធីសាស្ត្រនេះត្រូវបានឃើញមានដំបូងបំផុតនៅសហរដ្ឋអាមេរិក ប៉ុន្តែកំពុងទទួលបានប្រជាប្រិយភាពនៅកន្លែងផ្សេងៗទៀត។ នៅក្នុងកិច្ចប្រជុំដោះស្រាយ ចៅក្រម ឬតុលាការ ដែលស្ថិតនៅក្នុងប្រព័ន្ធតុលាការដឹកនាំការសម្រុះសម្រួលក្រៅផ្លូវការមួយ ដែលខ្លួនព្យាយាមកំណត់ថាតើរឿងក្តីអាចត្រូវបានដោះស្រាយដែរឬទេ។ ជានិច្ចកាល វាគឺជានីតិវិធីចំណុះនឹងតុលាការ ហើយជាធម្មតាត្រូវបានធ្វើឡើងយ៉ាងខ្លីមុនពេលជំនុំជម្រះក្តី។ ក្រមនីតិ

វិធីរដ្ឋប្បវេណីកម្ពុជា ចែងដូចគ្នាពីដំណើរការត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ [៣០១]។ នៅប្រទេសកម្ពុជា ចៅក្រមដដែល ដែលធ្វើជាអធិបតីលើរឿងក្តី នឹងចូលរួមនៅក្នុងសន្ទានកម្ម។ នៅសហរដ្ឋអាមេរិក ជួនកាលគេក៏ធ្វើដូច្នេះដែរ ប៉ុន្តែជាញឹកញាប់ចៅក្រម ឬតុលាការដែលមានតួនាទីជាសន្ទានការីនោះ នឹងមាននាទីខុសគ្នា ពីចៅក្រម ឬតុលាការ ដែលធ្វើជាចៅក្រមនៅក្នុងសាវនាការ។

- **មជ្ឈតការសន្ទាន**[៣០២]

ពាក្យនេះមានន័យថាមជ្ឈត្តការដោយសន្ទានកម្ម។ ដូចបានពិភាក្សាជាសង្ខេបក្នុងជំពូកមជ្ឈត្តការ ទស្សនាទាននេះអនុញ្ញាតឱ្យភាគីសាកល្បងដោះស្រាយដោយធ្វើសន្ទានកម្មជាមុនសិន។ ប្រសិនបើបរាជ័យក្នុងដំណោះស្រាយបញ្ហាទាំងអស់នោះ ពួកគេឈានទៅដោះស្រាយរឿងក្តីដោយធ្វើមជ្ឈត្តការ ដែលតាមរយៈនោះ មជ្ឈត្តករចេញសេចក្តីសម្រេចភ្ជាប់កាតព្វកិច្ច។ មានការមិនយល់គ្នាមួយចំនួនអំពី ថាតើបុគ្គលដដែលអាចធ្វើជាអ្នកសម្រុះសម្រួលផងនិងជាមជ្ឈត្តករផងបានដែរឬទេ។ អត្ថប្រយោជន៍ក្នុងការមានបុគ្គលតែមួយ គឺថាគេអាចដឹកនាំមជ្ឈត្តការនៅក្នុងរយៈពេលខ្លី ពីព្រោះគេបានដឹងរួចទៅហើយអំពីបញ្ហាទាំងអស់។ ប៉ុន្តែកង្វល់អំពីជម្លោះ និងការផ្សព្វផ្សាយព័ត៌មានសម្ងាត់ បានជំរុញឱ្យអ្នកមានវិជ្ជាជីវៈជាច្រើនណែនាំឱ្យយកមនុស្សផ្សេងគ្នាធ្វើជាមជ្ឈត្តករ ។

- **អ្នកស្វែងរកអង្គហេតុអព្យាក្រឹត**

នៅក្នុងនីតិវិធីនេះ ភាគីអព្យាក្រឹតធ្វើការស៊ើបអង្កេតវិវាទ ហើយពិចារណាលើសេចក្តីសន្និដ្ឋានពីការបញ្ជូនភាគីវិវាទ*និង*ភ័ស្តុតាងដែលខ្លួនទទួលបានដោយឯករាជ្យ។ ភាគីអព្យាក្រឹតចេញរបាយការណ៍មួយ (ជួនកាលមានអនុសាសន៍នានា) ពេលនោះភាគីវិវាទអាចពិចារណានៅក្នុងការចរចាដោះស្រាយរបស់ពួកគេ។ វិធីសាស្ត្រនេះមានភាពសមស្របបំផុត នៅពេលមានវិវាទពិតប្រាកដច្រើននៅក្នុងរឿងក្តី។

- **មជ្ឈត្តការបាល់បោះ**

នៅក្នុងមជ្ឈត្តការបាល់បោះ ភាគីបង្ហាញភ័ស្តុតាងដូចជានៅក្នុងមជ្ឈត្តការស្តង់ដារដែរ ប៉ុន្តែនៅចុងបញ្ចប់ភាគីនីមួយៗ ស្នើរសុំមជ្ឈត្តវិនិច្ឆ័យជាសាច់ប្រាក់ទៅកានមជ្ឈតករ។ មជ្ឈត្តករត្រូវជ្រើសរើសសម្នើរទឹកប្រាក់មួយក្នុងចំណោម សម្នើជាច្រើនដែលបានស្នើឡើងដោយមិនបានធ្វើការកែប្រែអ្វីទាំងអស់។ ដំណើរការនេះបង្ខំឱ្យភាគី

---

[៣០១] **ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា** រាជកិច្ចនៃព្រះរាជាណាចក្រកម្ពុជា លេខ៥៥, ទំព័រ៥២៩៦, ៥៣៣៦ មាត្រា១០៤ ("នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ តុលាការត្រូវសាកល្បងផ្សះផ្សាជាដំបូងសិន...") (ឆ្នាំ២០០៦) ។ សេចក្តីអត្ថាធិប្បាយជាផ្លូវការរបស់ក្រមនេះ បញ្ជាក់ថា មាត្រាទាំងនេះសំដៅដល់ តុលាការជាអ្នកធ្វើការផ្សះផ្សាវិវាទ រួមទាំងការរៀបចំជំនួបជាឯកជន (ដែលអត្ថបទបានហៅថា "ការសម្ភាសន៍ឆ្លង")។ បទអធិប្បាយ ក.ន.រ-ព.ក. គន្លឹះទី ៣ ជំពូកទី២ ផ្នែកទី២ (២)(៣) នៅទំព័រ ៥១-៥២។

[៣០២] ចំពោះការពិភាក្សាគួរឱ្យចាប់អារម្មណ៍នៃមជ្ឈត្តការសន្ទាននៅប្រទេសចិន សូមមើល Carlos de Vera *ភាពសុខដុមនៃមជ្ឈត្តការៈ "មជ្ឈត្តការសន្ទាន" និងចំណុចប្រសព្វនៃវប្បធម៌ និងនីតិរដ្ឋ នៅក្នុងការដោះស្រាយវិវាទពាណិជ្ជកម្ម អន្តរជាតិនៅប្រទេសចិន* **ឌិនា.សាកលវិ.ភូមិន្ទបៀ ស្តីពីច្បាប់អាស៊ី** លេខ ១៨ ទំព័រ១៤៩ (ឆ្នាំ២០០៤)។

បង្ហាញនូវសម្មតិសមហេតុផល និងកម្រិតឆន្ទានុសិទ្ធិរបស់មជ្ឈត្តករ ។ វិធីសាស្ត្រ បែបនេះត្រូវបានបង្កើតឡើងជាដំបូងដោយយកឈ្មោះតាមប្រភេទកីឡាបេសបលអាមេរិក។ ជួនកាលវាត្រូវបានគេហៅថា មជ្ឈត្តការ "សម្មតិចុងក្រោយ" ។ វិធីសាស្ត្រនេះប្រើបានល្អបំផុតនៅពេលដែលមានចំណុចបញ្ហាតែមួយ ដូចជាកម្រិតប្រាក់ប្រៀវត្សរ៍ ឬចំនួនប្រាក់សំណងជាដើម ។

- **ភ្នាក់ងារសង្កេតតាមដាន (Ombudsman)**

ជាធម្មតា ភ្នាក់ងារសង្កេតតាមដានត្រូវបានឃើញមាននៅក្នុងស្ថាប័នធំមួយ។ ភ្នាក់ងារនោះធ្វើជាភាគីអព្យាក្រឹតដែលស្វែងរក និងស្តាប់ពាក្យបណ្តឹង ហើយព្យាយាមជួយសម្រួលដល់ដំណោះស្រាយដូចជាអ្នកសម្រុះសម្រួលដែរ។ ភាក់ងារនោះត្រូវបានតែងតាំងដោយស្ថាប័ន ហើយព្យាយាមទប់ស្កាត់មិនឱ្យជម្លោះរីករាលដាលធ្ងន់ធ្ងរ ឬធំពេកទេ។ ភាក់ងារសង្កេតតាមដាន មិនមានអំណាចក្នុងការសម្រេចលើវិវាទទេ ប៉ុន្តែជាញឹកញាប់ អាចបោះពុម្ពផ្សាយនូវរបាយការណ៍ ឬលទ្ធផល ដែលស្ថាប័ននោះអាច ឬមិនអាចជ្រើសរើសធ្វើតាម។

- **មជ្ឈត្តការ និងសន្ធានកម្មមិនភ្ជាប់កាតព្វកិច្ចចំណុះឱ្យស្ថាប័នតុលាការ**

នៅក្នុងប្រទេសជាច្រើន កម្មវិធីសន្ធានកម្មភ្ជាប់នឹងស្ថាប័នតុលាការអនុញ្ញាតឱ្យភាគីចូលរួមនៅក្នុង មជ្ឈត្តកម្ម ឬសន្ធានកម្មរយៈពេលខ្លីនិងមិនភ្ជាប់កាតព្វកិច្ច។ នេះគឺសំដៅជួយសម្រួលឱ្យមានការព្រមព្រៀង និងកាត់បន្ថយភាពយឺតយ៉ាវនៃរឿងក្តី ។វិធីសាស្ត្រសន្ធានកម្មអាចមានលក្ខណៈជាក់ស្តែង ប៉ុន្តែមជ្ឈត្តការត្រូវការនូវការពន្យល់។

ជាមួយនឹងកម្មវិធីមជ្ឈត្តការមិនភ្ជាប់កាតព្វកិច្ច ជាធម្មតាមជ្ឈត្តករចេញសេចក្តីបង្គាប់ ដូចជាវិធីសាស្ត្រវាយតម្លៃជាមុនដោយភាគីអព្យាក្រឹតដែរដែលជួយដល់ភាគីនៅក្នុងការចរចារបស់ពួកគេ។ ប៉ុន្តែសេចក្តីសម្រេចនេះភ្ជាប់កាតព្វកិច្ចបាន ប្រសិនបើភាគីណាមួយមិនបដិសេធសេចក្តីសម្រេចនោះនៅក្នុងរយៈពេលខ្លី[៣០៣] ទេនោះ។ កម្មវិធីចំណុះនឹងតុលាការជាច្រើន បង្កើតនូវការលើកទឹកចិត្តឱ្យមានការព្រមព្រៀង ដែលតាមរយៈនោះ ភាគីដែលបដិសេធសេចក្តីមជ្ឈត្តវិនិច្ឆ័យ ត្រូវសម្រេចបានលទ្ធផលល្អប្រសើរជាងនៅក្នុងការជំនុំជម្រះនាពេលអនាគតដោយតុលាការ ឬមានការទោសពិន័យជាប្រាក់ចំពោះពួកគេ។

- **ច្បាប់សហការ**

ច្បាប់សហការគឺជាវិធីសាស្ត្រជំនួសនៃដំណោះស្រាយវិវាទពាក់ព័ន្ធនឹងច្បាប់ស្តីពីគ្រួសារ។ ច្បាប់នេះត្រូវបានបង្កើតឡើងនៅសហរដ្ឋអាមេរិក ហើយទទួលបានប្រជាប្រិយភាពនៅក្នុងប្រទេសផ្សេងទៀត កាលពីប៉ុន្មានឆ្នាំចុងក្រោយនេះ។ នៅក្នុងច្បាប់សហការ មេធាវីរបស់ភាគីយល់ព្រមដកខ្លួនចេញពីការតំណាងនៅក្នុងរឿងក្តី ប្រសិនបើពួកគេបរាជ័យក្នុងការស្វែងរកដំណោះស្រាយមួយមុនពេលជំនុំជម្រះ។ កិច្ចព្រមព្រៀងបួនភាគីនេះ លើកទឹកចិត្ត

---

[៣០៣] ក្រុមប្រឹក្សាអាជ្ញាកណ្តាលកម្ពុជាមានប្រព័ន្ធស្រដៀងគ្នានេះ។

ឱ្យមានការព្រមព្រៀងពីព្រោះភាគីនឹងត្រូវចាប់ផ្តើមជាមួយមេធាវីថ្មី ប្រសិនបើពួកគេមិនអាចឈានដល់ ការព្រម-ព្រៀង គ្នានោះទេ។ នៅពេលនេះច្បាប់សហការត្រូវបានកម្រិត យ៉ាងខ្លាំងត្រឹមរឿងក្តីលែងលះ[៣០៤] ប៉ុណ្ណោះ ។

- **ដំណោះស្រាយវិវាទតាមអ៊ីនធើណិត**

តាំងពីចុងទសវត្សឆ្នាំកៅសិបមក សេវាដោះស្រាយវិវាទតាមអ៊ីនធឺណិត (ODR) ទទួលបានប្រជាប្រិយភាព យ៉ាងខ្លាំងនៅសហរដ្ឋអាមេរិក និងនៅកន្លែងផ្សេងៗទៀត។ សេវាដោះស្រាយវិវាទតាមអ៊ីនធឺណិត អាចជា ដំណើរការវិវាទតាមអ៊ីនធឺណិតសុទ្ធសាធ ដែលផ្តល់ដោយក្រុមហ៊ុននានា ដូចជា Cybersettle និង SquareTrade ដែលនៅទីនោះភាគីផ្តល់ព័ត៌មាន និងសម្ដីទាំងអស់តាមអ៊ីនធឺណិត។ សេវានេះអាចជាដំណើរការចំរុះជាង សេវា ដែលផ្តល់ដោយស្ថាប័នផ្តល់សេវាដែលមានពីមុនមក ដូចជាសមាគមមជ្ឈត្តការ អាមេរិកជាដើម ដែលភាគីត្រូវផ្តល់ ព័ត៌មានមួយចំនួនតាមអ៊ីមែល ទម្រង់វែបសាយត៍ និងសន្និសីទវីដេអូតាមវែបសាយត៍ ប៉ុន្តែនៅតែត្រូវជួបមុខគ្នាផ្ទាល់ ឬតាមទូរស័ព្ទនៅពេលក្រោយទៀត[៣០៥] ។

---

[៣០៤] ច្បាប់សហការកំពុងរីកលូតលាស់យ៉ាងឆាប់រហ័សនៅក្នុងចំណោមអ្នកអនុវត្តខាងច្បាប់ស្តីពីគ្រួសារ នៅសហរដ្ឋអាមេរិក ពីព្រោះវា មានភាពជោគជ័យក្នុងការជួយដោះស្រាយរឿងក្តី ។ *សូមមើល អ្នកពិគ្រោះយោបល់សហការ* **ទិនានុប្បវត្តិគណៈមេធាវីអាមេរិក** ទំព័រ ៥២ (ខែមិថុនា ឆ្នាំ២០០៦) ។ ប៉ុន្តែ យ៉ាងហោចណាស់ គណៈកម្មាធិការក្រមសីលធម៌នៃរដ្ឋមួយបានរកឃើញថា វា រំលោភលើវិធានទំនួលខុសត្រូវវិជ្ជាជីវៈ។ *ការព្រមានចំពោះអ្នកសហការ* **ទិនានុប្បវត្តិគណៈមេធាវីអាមេរិក** ទំព័រ ២២ (ខែឧសភា ឆ្នាំ២០០៧) ។ អត្ថបទនោះកត់សម្គាល់ថា យុត្តាធិការប្រាំផ្សេងទៀតនៅសហរដ្ឋអាមេរិកបានរកឃើញថា ច្បាប់សហការ មិនរំលោភលើវិធានក្រមសីលធម៌ទេ ។ *ដូចមុន*។

[៣០៥] *សូមមើល ឧទាហរណ៍ ដោះស្រាយវាតាមវែបសាយត៍* **ទិនានុប្បវត្តិគណៈមេធាវីអាមេរិក** ទំព័រ ៤០ (ខែតុលា ឆ្នាំ២០០៧) ។

# អក្ខរានុក្រមនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

ខាងក្រោមនេះគឺជាអក្ខរានុក្រមនៃពាក្យសម្រាប់ប្រើប្រាស់ ទាក់ទងនឹងបច្ចេកទេសដោះស្រាយវិវាទៈ

**ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការៈ** សំដៅដល់បច្ចេកទេសផ្សេងៗ ដែលត្រូវបានប្រើប្រាស់ដើម្បីដោះស្រាយវិវាទក្រៅពីការដាក់បណ្តឹងទៅតុលាការ ។ បច្ចេកទេសដែលទូទៅបំផុតរួមមាន ការចរចា សន្ធានកម្ម និងមជ្ឈត្តការ ។

**មជ្ឈត្តការៈ** មជ្ឈត្តការគឺជាដំណើរការដែលស្រដៀងគ្នានឹងដំណើរការកាត់ក្តីដោយតុលាការដែរ ។ ភាគីបង្ហាញភ័ស្តុតាងមានកម្រិតទៅមជ្ឈត្តករ បន្ទាប់មកមជ្ឈត្តករក៏ធ្វើសេចក្តីសម្រេច ។ ដំណើរការនេះអាចកម្រិតបំផុត ឬអូសបន្លាយបំផុតដែរ អាស្រ័យលើការព្រមព្រៀងរបស់ភាគីវិវាទ ។ ការសម្រេចនោះអាចភ្ជាប់ ឬមិនភ្ជាប់កាតព្វកិច្ច ហើយជាទូទៅអាចប្តឹងឧបាស្រ័យបានតែក្នុងកាលៈទេសៈដ៏រឹតត្បិតបំផុត ។ ការចូលរួមធ្វើមជ្ឈត្តការអាចផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត ឬដោយការតម្រូវ អាស្រ័យលើកាលៈទេសៈ ។

**មជ្ឈត្តវិនិច្ឆ័យៈ** មជ្ឈត្តវិនិច្ឆ័យគឺជាពាក្យដែលគេតែងប្រើដើម្បីបញ្ជាក់ពីសេចក្តីសម្រេចរបស់ក្រុមមជ្ឈត្តករ លើរឿងក្តីណាមួយ ។ តាមច្បាប់ភាគច្រើន មជ្ឈត្តវិនិច្ឆ័យត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ។ តាមច្បាប់មជ្ឈត្តការផ្នែកពាណិជ្ជ-កម្ម របស់កម្ពុជា មជ្ឈត្តវិនិច្ឆ័យត្រូវបានចាត់ទុកថាអាចអនុវត្តបានដូចជាសាលក្រមតុលាការដូច្នោះដែរ ។ ជាងនេះទៅទៀត តាមច្បាប់ដដែលនេះ ភាគីវិវាទអាចដោះស្រាយវិវាទរបស់ខ្លួនមុនពេល ឬក្នុងកំឡុងពេលដំណើរការមជ្ឈត្តការ ហើយចាត់ទុកវាថាជាមជ្ឈត្តវិនិច្ឆ័យតែម្តង ។

**ភ្ជាប់កាតព្វកិច្ចៈ** កិច្ចព្រមព្រៀង ឬសេចក្តីសម្រេច ដែលភ្ជាប់កាតព្វកិច្ច គឺជាអ្វីដែលភាគីវិវាទត្រូវតែធ្វើតាម ពីព្រោះវាអាចអនុវត្តបានតាមផ្លូវច្បាប់ ។ មជ្ឈត្តវិនិច្ឆ័យដែលភ្ជាប់កាតព្វកិច្ច អាចអនុវត្តតាមផ្លូវច្បាប់ ដូចជាសាលក្រមតុលាការដូច្នោះដែរ ។

**ជំនួបៈ** ជំនួប គឺជាការប្រជុំជាឯកជនក្នុងកំឡុងពេលធ្វើសន្ធានកម្ម រវាងសន្ធាការី និងភាគី ។ គេប្រើវិធីនេះដើម្បីបិភាក្សាអំពីបញ្ហានានា នៅពេលភាគីម្ខាងទៀតអវត្តមាន ។ ភាគីវិវាទ ពេលខ្លះមានភាពស្មោះត្រង់ និងមានហេតុផលនៅក្នុងជំនួបមួយ ជាងនៅពេលដែលពួកគេនិយាយនៅចំពោះមុខភាគីដទៃទៀត ។

**ការផ្សះផ្សាៈ** ការផ្សះផ្សាសំដៅដល់ដំណើរការគ្រប់បែបយ៉ាង ដែលមានបុគ្គលអព្យាក្រឹតម្នាក់ ជួយភាគីវិវាទឱ្យឈានដល់ដំណោះស្រាយប្រកបដោយការស្រុះស្រួលគ្នា ។ នៅក្នុងប្រពៃណីមួយចំនួន អ្នកអព្យាក្រឹតនោះត្រូវបានផ្តល់សេរីភាពក្នុងការលើកកម្ពស់ដំណោះស្រាយយ៉ាងសកម្ម តាមរយៈការជួបជាឯកជនជាមួយភាគីវិវាទ (ដែលគេហៅថាជំនួប) និង

តាមរយៈការស្នើដំណោះស្រាយផ្សេងៗ។ នៅក្នុងប្រពៃណីខ្លះទៀត អ្នកអព្យាក្រឹតនោះ ប្រើវិធីអកម្មជាង ហើយទុកឱ្យភាគីវិវាទ ជាអ្នកគ្រប់គ្រងដំណើរការនោះ។ វិធីសាស្ត្រទាំងពីមានសុពលភាពដូចគ្នា។

ពាក្យថាការផ្សះផ្សា ត្រូវបានប្រើជំនួសគ្នាទៅវិញទៅមកនឹងពាក្យថា *សន្ធានកម្ម*។ សម្រាប់សៀវភៅនេះ ពាក្យសន្ធានកម្ម ត្រូវបានលើកយកប្រើដើម្បីសំដៅដល់ទាំងការផ្សះផ្សា និងសន្ធានកម្ម។ យ៉ាងណាមិញ នៅពេលដែលមានច្បាប់ណាមួយប្រើពាក្យថាការផ្សះផ្សា ពាក្យនោះក៏ត្រូវបានប្រើតាមនោះដែរ។

**អ្នកផ្សះផ្សា:** អ្នកផ្សះផ្សា គឺជាបុគ្គលអព្យាក្រឹត នៅក្នុងដំណើរការផ្សះផ្សា។

**ការរក្សាការសម្ងាត់:** ព័ត៌មានដែលផ្សព្វផ្សាយក្នុងកំឡុងពេលមានដំណើរការ ADR តែងត្រូវបានចាត់ទុកថាជាការសម្ងាត់ ហើយដែលមិនត្រូវបញ្ចេញទៅពិភពខាងក្រៅបានឡើយ។ នេះគឺជាមូលហេតុសំខាន់មួយ ដែលភាគីវិវាទនិយម ADR ជាងវិធីសាស្ត្រដោះស្រាយវិវាទដទៃទៀត។

**ADR ចំណុះឱ្យស្ថាប័នតុលាការ:** កម្មវិធី ADR ចំណុះឱ្យស្ថាប័នតុលាការ គឺជាកម្មវិធីដែលគាំទ្រដោយស្ថាប័នតុលាការតាមរូបភាពផ្សេងៗ។ កម្មវិធី ADR ចំណុះឱ្យស្ថាប័នតុលាការ អាចផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត ឬជាការតម្រូវ។

**ចុងចម្លើយ:** ចុងចម្លើយគឺជាភាគីនៃវិវាទ ដែលត្រូវបានដើមបណ្តឹងបានប្តឹងក្នុងទម្រង់ណាមួយនៃបណ្តឹង ឬការទាមទារ។

**សវនាការ:** សវនាការគឺជានីតិវិធី ដែលក្នុងនោះភស្តុតាងនៃអង្គហេតុ ត្រូវបានដាក់ជូនទៅភាគីអព្យាក្រឹត ដើម្បីឱ្យភាគីនោះ អាចរៀបចំការសម្រេចចិត្តខាន។ សវនាការ អាចបញ្ចូលទាំងការធ្វើកស្សិណដោយផ្ទាល់ពីសាក្សី ឯកសារ និងទម្រង់ផ្សេងទៀតនៃភ័ស្តុតាង ដែលត្រូវបង្ហាញដល់ភាគីអព្យាក្រឹត។

**សន្ធានកម្ម:** សន្ធានកម្មគឺជាការចរចាដែលមានការជួយជ្រោមជ្រែង ឬសម្របសម្រួល។ សន្ធានកម្មជាទូទៅ រួមមានភាគីវិវាទចំនួនពីរ ឬច្រើន ដែលព្យាយាមចរចារកដំណោះស្រាយ ដោយមានជំនួយពីភាគីទីបីម្នាក់ គឺសន្ធានការី ដែលមានអព្យាក្រឹតចំពោះភាគីវិវាទ និងលទ្ធផលរបស់វា។ សន្ធានការីពុំមានសិទ្ធិអំណាចក្នុងការដាក់ដំណោះស្រាយណាមួយឡើយ។

នៅក្នុងប្រពៃណីមួយចំនួន អ្នកអព្យាក្រឹតនោះត្រូវបានផ្តល់សេរីភាព ក្នុងការលើកកម្ពស់ដំណោះស្រាយយ៉ាងសកម្ម តាមរយៈការជួបជាឯកជនជាមួយភាគីវិវាទ (ដែលគេហៅថាជំនួប) និង តាមរយៈការស្នើដំណោះស្រាយផ្សេងៗ។ នៅក្នុងប្រពៃណីខ្លះទៀត អ្នកអព្យាក្រឹតនោះ ប្រើវិធីអកម្មជាង ហើយទុកឱ្យ ភាគីវិវាទ ជាអ្នកគ្រប់គ្រងដំណើរការនោះ។ វិធីសាស្ត្រទាំងពីមានសុពលភាពដូចគ្នា។

ពាក្យថាសន្ធានកម្ម ត្រូវបានប្រើជំនួសគ្នាទៅវិញទៅមកនឹងពាក្យថា *ការផ្សះផ្សា*។ សម្រាប់សៀវភៅនេះ ពាក្យសន្ធានកម្ម ត្រូវបានលើកយកប្រើដើម្បីសំដៅដល់ទាំងការផ្សះផ្សា និងសន្ធានកម្ម។ យ៉ាងណាមិញ នៅពេលដែលមានច្បាប់ណាមួយប្រើពាក្យថាការផ្សះផ្សា ពាក្យនោះក៏ត្រូវបានប្រើតាមនោះដែរ។

**សន្ធានការី:** សន្ធានការីគឺជាបុគ្គលអព្យាក្រឹត នៅក្នុងដំណើរការសន្ធានកម្ម ។

**ការចរចា:** ការចរចាគឺជាដំណើរការដោះស្រាយវិវាទក្រៅផ្លូវការ ដែលភាគីពីរ ឬច្រើន ពិភាក្សាគ្នាអំពីជំហររបស់ពួកគេរៀងៗខ្លួន ហើយព្យាយាមធ្វើកិច្ចព្រមព្រៀងមួយ។ នេះគឺជាទម្រង់ទូទៅបំផុតនៃ ADR។

**អ្នកអព្យាក្រឹត:** អ្នកអព្យាក្រឹតគឺជាមនុស្សម្នាក់ដែលឯករាជ្យពីភាគីវិវាទ ហើយត្រូវបានផ្តល់អំណាចតាមវិធីណាមួយក្នុងការជួយដោះស្រាយវិវាទ។ អ្នកអព្យាក្រឹតនោះអាចធ្វើជាសន្ទានការី អ្នកផ្សះផ្សា អ្នកសម្របសម្រួល ឬមជ្ឈត្តករ។ តួនាទីអ្នកអព្យាក្រឹតនោះ អាចមានភាពសកម្ម ឬអកម្មអាស្រ័យលើកាលៈទេសៈផ្សេងៗ។

**មិនភ្ជាប់កាតព្វកិច្ច:** កិច្ចព្រមព្រៀង ឬសេចក្តីសម្រេចមិនភ្ជាប់កាតព្វកិច្ច គឺជាអ្វីដែលភាគីវិវាទមិនមានកាតព្វកិច្ចផ្លូវច្បាប់ក្នុងការអនុវត្តតាមឡើយ ពីព្រោះវាមិនអាចអនុវត្តបានតាមផ្លូវច្បាប់បានទេ។ តួយ៉ាងដូចជា សេចក្តីសម្រេចមជ្ឈត្តការមិនភ្ជាប់កាតព្វកិច្ច គឺមិនអាចអនុវត្តតាមផ្លូវច្បាប់បានឡើយ។

**ក្រុមមជ្ឈត្តករ:** ក្រុមមជ្ឈត្តករគឺជាមជ្ឈត្តករមួយក្រុមដែលជាទូទៅមានចំនួនបីរូប ហើយធ្វើជាអ្នកអព្យាក្រឹតនៅក្នុងដំណើរការមជ្ឈត្តការណាមួយ។ តួនាទីរបស់ពួកគេ គឺស្រដៀងគ្នានឹងចៅក្រមនៅក្នុងបណ្តឹងតុលាការដែលមានពីមុនមកដូច្នោះដែរ។ នៅចុងបញ្ចប់នៃដំណើរការ ក្រុមមជ្ឈត្តករតែងចេញ *មជ្ឈត្តវិនិច្ឆ័យ* មួយ ទៅឱ្យភាគីមួយ ឬច្រើន។ ជួនកាល គេហៅក្រុមមជ្ឈត្តករមួយថា *តុលាការមជ្ឈត្តការ* ឬ *វេទិកាមជ្ឈត្តកម្ម*។ ពាក្យថា ក្រុម ឬវេទិកា សំដៅលើអង្គភាពតែមួយ។

**ភាគីវិវាទ:** ភាគីវិវាទគឺជាបុគ្គល និង/ឬ នីតិបុគ្គលដែលជាប់ពាក់ព័ន្ធនឹងវិវាទណាមួយ។

**ដើមបណ្តឹង:** ដើមបណ្តឹងគឺជាភាគីនៃវិវាទមួយ ដែលបានប្តឹងក្នុងទម្រង់ជាបណ្តឹង ឬការទាមទារប្រឆាំងនឹងចុងចម្លើយ។

**វេទិកា:** ពាក្យថាទិកាគឺជាទូទៅ សំដៅដល់តុលាការមជ្ឈត្តការណាមួយ។ តុលាការមជ្ឈត្តការនោះ (ជួនកាលហៅថា *ក្រុមមជ្ឈត្តករ ឬវេទិកាមជ្ឈត្តកម្ម*) គឺជាមជ្ឈត្តករមួយក្រុម ដែលជាទូទៅមានចំនួនបីរូប ហើយធ្វើជាអ្នកអព្យាក្រឹតនៅក្នុងដំណើរការមជ្ឈត្តការណាមួយ។ តួនាទីរបស់ពួកគេ គឺស្រដៀងគ្នានឹងចៅក្រមនៅក្នុងបណ្តឹង តុលាការដែលមានពីមុនមកដូច្នោះដែរ។ នៅចុងបញ្ចប់នៃដំណើរការ ក្រុមមជ្ឈត្តករតែងចេញ *មជ្ឈត្តវិនិច្ឆ័យ*មួយ ទៅឱ្យភាគីមួយ ឬច្រើន។ ជួនកាលគេហៅក្រុមមជ្ឈត្តករមួយថា *តុលាការមជ្ឈត្តការ* ឬ *វេទិកាមជ្ឈត្តកម្ម*។ ពាក្យថា ក្រុម ឬវេទិកា គឺសំដៅលើអង្គភាពតែមួយ។

# ឧបសម្ព័ន្ធ ក

## គណៈកម្មការអង្គការសហប្រជាជាតិស្ដីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ (UNCITRAL)

### វិធានផ្សះផ្សា UNCITRAL

## មាតិកា


**សេចក្ដីសម្រេចរបស់សន្និបាតអង្គការសហប្រជាជាតិ ៣៥/៥២**

**វិធានផ្សះផ្សារបស់** UNCITRAL

មាត្រា ១: ការអនុវត្តន៍វិធាន

មាត្រា ២: ការចាប់ផ្ដើមដំណើរការផ្សះផ្សា

មាត្រា ៣: ចំនួនអ្នកផ្សះផ្សា

មាត្រា ៤: ការតែងតាំងអ្នកផ្សះផ្សា

មាត្រា ៥: ការដាក់បណ្ដឹងទៅអ្នកផ្សះផ្សា

មាត្រា ៦: តំណាង និងជំនួយ

មាត្រា ៧: តួនាទីរបស់អ្នកផ្សះផ្សា

មាត្រា ៨: ជំនួយផ្នែករដ្ឋបាល

មាត្រា ៩: ការឆ្លើយឆ្លងរវាងអ្នកផ្សះផ្សា និងភាគីវិវាទ

មាត្រា ១០: ការបង្ហាញព័ត៌មាន

មាត្រា ១១: ការសហការរបស់ភាគីវិវាទជាមួយអ្នកផ្សះផ្សា

មាត្រា ១២: សំណូមពររបស់ភាគីដើម្បីបញ្ចប់វិវាទ

មាត្រា ១៣: កិច្ចព្រមព្រៀងបញ្ចប់វិវាទ

មាត្រា ១៤: ការរក្សាការសម្ងាត់

មាត្រា ១៥: ការបញ្ឈប់ដំណើរការផ្សះផ្សា

មាត្រា ១៦: ឧបាស្រ័យតាមនីតិវិធីមជ្ឈត្តការ ឬតុលាការ

មាត្រា ១៧: ថ្លៃចំណាយផ្សេងៗ

មាត្រា ១៨: ប្រាក់តម្កល់

មាត្រា ១៩: តួនាទីអ្នកផ្សះផ្សានៅក្នុងនីតិវិធីដទៃទៀត

មាត្រា ២០: ការទទួលភស្ដុតាងនៅក្នុងនីតិវិធីដទៃទៀត

**ខគម្រូស្ដីពីការផ្សះផ្សា**

# សេចក្ដីសម្រេចលេខ៣៥/៥២អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃ ទី៤ ធ្នូ ១៩៨០

## ៣៥/៥២

## វិធានផ្សះផ្សានៃគណៈកម្មការអង្គការសហប្រជាជាតិស្ដីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ

មហាសន្និបាតអង្គការសហប្រជាជាតិ

**ដោយទទួលស្គាល់**តំលៃនៃការផ្សះផ្សាថា ជាវិធីសាស្ត្រដោះស្រាយដោយសន្តិវិធីលើវិវាទនានា ដែលកើតមានឡើងក្នុងបរិបទទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ។

**ដោយយល់ស្របថា** ការបង្កើតវិធានផ្សះផ្សាដែលអាចទទួលយកបាននៅក្នុងប្រទេសនានា ដែលមានប្រព័ន្ធច្បាប់សង្គម និងសេដ្ឋកិច្ចផ្សេងៗគ្នា នឹងចូលរួមចំណែកយ៉ាងសំខាន់ចំពោះការអភិវឌ្ឍន៍ទំនាក់ទំនងសេដ្ឋកិច្ចអន្តរជាតិដោយសុខដុមរមនា។

**ដោយកត់សំគាល់**ថា វិធានផ្សះផ្សារបស់គណៈកម្មការអង្គការសហប្រជាជាតិស្ដីអំពីច្បាប់ ពាណិជ្ជកម្មអន្តរជាតិ ត្រូវបានអនុម័តដោយគណៈកម្មការនៅឯកិច្ចប្រជុំលើកទីដប់បី[៣០៦] បន្ទាប់ពីបានពិចារណា លើសេចក្ដីសង្កេតរបស់រដ្ឋាភិបាល និងអង្គការដែលមានចំណាប់អារម្មណ៍នានា។

១. **ដាក់ជាអនុសាសន៍** ឱ្យប្រើប្រាស់វិធានផ្សះផ្សារបស់គណៈកម្មការអង្គការសហប្រជាជាតិស្ដីអំពីច្បាប់ពាណិជ្ជកម្មអន្តរជាតិក្នុងករណីទាំងឡាយដែលវិវាទកើតឡើង ក្នុងបរិបទនៃទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ ហើយឱ្យភាគីវិវាទស្វែងរកដំណោះស្រាយដោយសន្តិវិធីចំពោះវិវាទនោះដោយអាស្រ័យលើ ការផ្សះផ្សា។

២. **ស្នើរ**អគ្គលេខាធិការរៀបចំឱ្យមានការចែកចាយវិធានផ្សះផ្សារនេះ ឱ្យបានទូលំទូលាយបំផុតតាមដែលអាចធ្វើបាន។

[306] កំណត់ត្រាផ្លូវការនៃមហាសន្និបាត កិច្ចប្រជុំលើកទី៣៥ អត្ថបទបន្ថែមលេខ ១៧ (A/៣៥/17) កថាខ័ណ្ឌ ១០៥ និង ១០៦

# វិធានផ្សះផ្សា UNCITRAL

## ការអនុវត្តវិធាន

### មាត្រា ១

(១) វិធានទាំងនេះអនុវត្តចំពោះការផ្សះផ្សាវិវាទកើតចេញពី ឬពាក់ព័ន្ធទៅនឹងទំនាក់ទំនងកិច្ចសន្យា ឬទំនាក់ទំនងផ្លូវច្បាប់ដទៃទៀត ដោយក្នុងនោះ ភាគីវិវាទដែលស្វែងរកដំណោះស្រាយដោយសន្តិវិធីចំពោះវិវាទរបស់ខ្លួន បានព្រមព្រៀងយកការប្រើប្រាស់វិធានផ្សះផ្សា UNCITRAL ។

(២) ភាគីវិវាទអាចព្រមព្រៀងគ្នាដោយមិនរាប់បញ្ចូល ឬផ្លាស់ប្តូរវិធានណាមួយបានគ្រប់ពេល ។

(៣) នៅពេលដែលមានវិធានណាមួយ មានទំនាស់នឹងបទប្បញ្ញត្តិនៃច្បាប់ ដែលភាគីវិវាទមិនអាចធ្វើបដិប្បញ្ញត្តិ បាននោះ បទប្បញ្ញត្តិនៃច្បាប់នោះនឹងត្រូវយកមកអនុវត្ត ។

## ការចាប់ផ្តើមដំណើរការផ្សះផ្សា

### មាត្រា ២

(១) ភាគីដែលផ្តួចផ្តើមការផ្សះផ្សា ត្រូវផ្ញើលិខិតអញ្ជើញជាលាយលក្ខណ៍អក្សរទៅកាន់ភាគីម្ខាងទៀត ដើម្បីផ្សះផ្សាតាមវិធាននេះ ដោយធ្វើការបង្ហាញកម្មវត្ថុនៃវិវាទនោះដោយសង្ខេបផង ។

(២) ដំណើរការផ្សះផ្សា ចាប់ផ្តើមនៅពេលភាគីម្ខាងទៀតទទួលយកការអញ្ជើញដើម្បីផ្សះផ្សា ។ ក្នុងករណីដែលការទទួលយកនោះធ្វើឡើងដោយផ្ទាល់មាត់ ជាការល្អគួរតែធ្វើសេចក្តីបញ្ជាក់ជាលាយលក្ខណ៍អក្សរដែរ ។

(៣) ប្រសិនបើភាគីម្ខាងទៀតបដិសេធការអញ្ជើញនោះ ដំណើរការផ្សះផ្សានឹងមិនកើតឡើងឡើយ ។

(៤) ប្រសិនបើភាគីដែលផ្តួចផ្តើមការផ្សះផ្សា មិនបានទទួលចម្លើយតបក្នុងរយៈពេលសាមសិបថ្ងៃ ចាប់ពីថ្ងៃផ្ញើរលិខិតអញ្ជើញមក ឬក្នុងរយៈពេលផ្សេងទៀតដូចមានបញ្ជាក់នៅក្នុងលិខិតអញ្ជើញ ភាគីនោះអាចសម្រេចចិត្តដោយចាត់ទុកថានេះជាការបដិសេធការអញ្ជើញដើម្បីផ្សះផ្សា ។ ប្រសិនបើមានការសម្រេចយ៉ាងដូច្នេះ ភាគីផ្តួចផ្តើមត្រូវជូនដំណឹងនេះទៅភាគីម្ខាងទៀត ។

## ចំនួនអ្នកផ្សះផ្សា

### មាត្រា ៣

អ្នកផ្សះផ្សាមានតែមួយរូប លើកលែងតែភាគីវិវាទព្រមព្រៀងឱ្យមានអ្នកផ្សះផ្សាពីរ ឬបីរូប ។ ជាវិធានទូទៅ នៅពេលដែលមានអ្នកផ្សះផ្សាលើសពីមួយរូប ពួកគេគួរតែធ្វើការរួមគ្នា ។

**ការតែងតាំងអ្នកផ្សះផ្សា**

**មាត្រា ៤**

(១) (ក) នៅក្នុងដំណើរការផ្សះផ្សាដែលមានអ្នកផ្សះផ្សាម្នាក់ ភាគីវិវាទគួរតែខិតខំខ្នែងឱ្យឈានទៅដល់ការឯកភាពគ្នាលើឈ្មោះអ្នកផ្សះផ្សាតែម្នាក់គត់។

(ខ) នៅក្នុងដំណើរការផ្សះផ្សាដែលមានអ្នកផ្សះផ្សាពីររូប ភាគីនិមួយៗត្រូវតែងតាំងអ្នកផ្សះផ្សាម្នាក់រៀងខ្លួន។

(គ) នៅក្នុងដំណើរការផ្សះផ្សាដែលមានអ្នកផ្សះផ្សាបីរូប ភាគីនិមួយៗតែងតាំងអ្នកផ្សះផ្សាម្ខាងម្នាក់។ ភាគីវិវាទគួរតែខិតខំខ្នែងឱ្យឈានទៅដល់ការឯកភាពគ្នាលើឈ្មោះអ្នកផ្សះផ្សាទីបី។

(២) ភាគីវិវាទអាចរកជំនួយពីស្ថាប័ន ឬបុគ្គលណាមួយដែលសមស្រប ក្នុងទំនាក់ទំនងនៃការតែងតាំងអ្នកផ្សះផ្សា។ ជាពិសេស:

(ក) ភាគីម្ខាងអាចស្នើស្ថាប័ន ឬបុគ្គលនោះឱ្យឧទ្ទេសនាមបុគ្គលសមស្របដើម្បីធ្វើជាអ្នកផ្សះផ្សា ឬ

(ខ) ភាគីវិវាទអាចព្រមព្រៀងឱ្យមានការតែងតាំងអ្នកផ្សះផ្សាម្នាក់ ឬច្រើនដោយស្ថាប័ន ឬបុគ្គលនោះផ្ទាល់ ។

នៅក្នុងការឧទ្ទេសនាម ឬតែងតាំងបុគ្គលណាមួយឱ្យធ្វើជាអ្នកផ្សះផ្សា ស្ថាប័ន ឬបុគ្គលនោះត្រូវធ្វើការពិចារណានានាដែលអាចធានាបាននូវការតែងតាំងអ្នកផ្សះផ្សាដែលឯករាជ្យ និងមិនលម្អៀង ហើយនៅពេលជ្រើសរើសអ្នកផ្សះផ្សាតែម្នាក់ ឬអ្នកផ្សះផ្សាទីបី ត្រូវពិចារណាពីលទ្ធភាពនៃការតែងតាំងអ្នក ផ្សះផ្សាមួយរូបណាដែលមានសញ្ជាតិក្រៅពីសញ្ជាតិរបស់ភាគីវិវាទ ។

**ការដាក់បណ្តឹងទៅអ្នកផ្សះផ្សា**

**មាត្រា ៥**

(១) អ្នកផ្សះផ្សា* បន្ទាប់ពីការតែងតាំងរួច ត្រូវស្នើរភាគីនិមួយៗឱ្យផ្ញើរបណ្តឹងលាយលក្ខណ៍អក្សរជា សង្ខេបដែលពិព៌ណ៌នាពីចរិតទូទៅនៃវិវាទនិងចំនុចដែលចោទជាបញ្ហា។ ភាគីនិមួយៗក៏ត្រូវផ្ញើរច្បាប់ចំលង នៃបណ្តឹងរបស់ខ្លួនទៅភាគីម្ខាងទៀតដែរ។

* នៅក្នុងមាត្រានេះនិងមាត្រាខាងក្រោមទាំងអស់ ពាក្យ "អ្នកធ្វើការផ្សះផ្សា" សំដៅលើអ្នកធ្វើការផ្សះផ្សាមួយរូប ពីររូប ឬបីរូបទៅតាមករណីនីមួយៗ ។

(២) អ្នកផ្សះផ្សាអាចស្នើភាគីនិមួយៗឱ្យផ្ញើរសេចក្ដីថ្លែងជាលាយលក្ខណ៍អក្សរបន្ថែមទៀត ស្ដីពីគោលជំហររបស់ខ្លួន ព្រមទាំងអង្គហេតុនិងមូលដ្ឋានគាំទ្រផ្សេងៗភ្ជាប់ទៅដោយឯកសារ និងភស្ដុតាងទាំងឡាយណាដែលភាគីនោះយល់ថាសមស្រប ។ ភាគីត្រូវផ្ញើរឯកសារចំលងមួយច្បាប់ទៅភាគីម្ខាង ទៀតផងដែរ ។

(៣) នៅក្នុងដំណាក់កាលណាក៏ដោយនៃដំណើរការផ្សះផ្សា អ្នកផ្សះផ្សាអាចស្នើភាគីណាមួយឱ្យផ្ញើរព័ត៌មានបន្ថែមទាំងនោះ តាមការដែលខ្លួនយល់ឃើញថាសមស្រប ។

**តំណាង និងជំនួយ**

**មាត្រា ៦**

ភាគីវិវាទអាចមានអ្នកតំណាង ឬអ្នកផ្ដល់ជំនួយជាបុគ្គលដែលខ្លួនជ្រើសរើស ។ ឈ្មោះ និង អាសយដ្ឋានរបស់បុគ្គលទាំងនោះ ត្រូវតែបានផ្ដល់ព័ត៌មានជាលាយលក្ខ័អក្សរទៅកាន់ភាគីម្ខាងទៀត និងអ្នកផ្សះផ្សាផងដែរ ដោយត្រូវបញ្ជាក់ថាការតែងតាំងនោះធ្វើឡើងក្នុងគោលបំណងសម្រាប់ធ្វើជាអ្នកតំណាង ឬធ្វើជាអ្នកផ្ដល់ជំនួយ ។

**តួនាទីរបស់អ្នកផ្សះផ្សា**

**មាត្រា ៧**

(១) អ្នកផ្សះផ្សាជួយភាគីវិវាទក្នុងរបៀបមួយដែលឯករាជ្យ និងមិនលម្អៀង ក្នុងការដែលខ្លួនខ្នះខ្នែងដើម្បីបានឈានទៅដល់ដំណោះស្រាយមួយប្រកបដោយសន្ដិវិធីចំពោះវិវាទរបស់ពួកគេ ។

(២) អ្នកផ្សះផ្សាត្រូវប្រើប្រាស់គោលការណ៍អញ្ញាថាភាពត្រឹមត្រូវ និងយុត្តិធម៌ជាត្រីមុខ ដោយត្រូវពិចារណាលើកត្តាផ្សេងៗដូចជាសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីវិវាទ ទម្លាប់ប្រើប្រាស់នៃជំនួញដែលពាក់ព័ន្ធ និងកាលៈ-ទេសៈនានានៅជុំវិញវិវាទ រួមទាំងបែបបទអាជីវកម្មដែលភាគីវិវាទបានអនុវត្តន៍ពីមុនមក ។

(៣) អ្នកផ្សះផ្សាអាចដឹកនាំដំណើរការផ្សះផ្សា ក្នុងបែបបទមួយដែលខ្លួនយល់ថាសមស្រប ដោយលើកមកពិចារណានូវកាលៈទេសៈផ្សេងៗនៃរឿងក្ដី បំណងប្រាថ្នាដែលភាគីវិវាទអាចបង្ហាញ រួមទាំងសម្ដើរបស់ភាគីម្ខាងឱ្យអ្នកផ្សះផ្សាស្ដាប់បំនកស្រាយផ្ទាល់មាត់ ព្រមទាំងតម្រូវការនូវដំណោះស្រាយដ៏ឆាប់រហ័សមួយនៃវិវាទជាដើម ។

(៤) នៅគ្រប់ដំណាក់កាលនៃដំណើរការផ្សះផ្សា អ្នកផ្សះផ្សាអាចធ្វើសម្ដើនានាក្នុងការបញ្ចប់វិវាទ។ សម្ដើទាំងនោះមិនចាំបាច់ធ្វើជាលាយលក្ខណ៍អក្សរ និងមិនចាំបាច់អមដោយសេចក្ដីអធិប្បាយអំពីហេតុផល នៃសម្ដើនោះឡើយ ។

**ជំនួយផ្នែករដ្ឋបាល**

**មាត្រា ៨**

(១) ដើម្បីជួលសម្រួលដល់ការដឹកនាំដំណើរការផ្សះផ្សា ភាគីវិវាទ ឬអ្នកផ្សះផ្សា ដោយមានការឯកភាពពីភាគីវិវាទ អាចចាត់ឱ្យមានជំនួយរដ្ឋបាលពីសំណាក់ស្ថាប័ន ឬដោយបុគ្គលណាមួយដែលសមស្រប។

**ការឆ្លើយឆ្លងរវាងអ្នកផ្សះផ្សានិងភាគីវិវាទ**

**មាត្រា ៩**

(១) អ្នកផ្សះផ្សាអាចអញ្ជើញភាគីវិវាទឱ្យមកជួបខ្លួន ឬអាចឆ្លើយឆ្លងជាមួយពួកគេដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ។ អ្នកផ្សះផ្សាអាចជួប ឬឆ្លើយឆ្លងជាមួយភាគីវិវាទរួមគ្នា ឬជាមួយភាគីនិមួយៗ ដោយឡែកពីគ្នា ។

(២) លើកលែងតែភាគីវិវាទបានព្រមព្រៀងលើទីកន្លែងសម្រាប់ធ្វើការប្រជុំជាមួយអ្នកផ្សះផ្សា ទីកន្លែងប្រជុំនឹងត្រូវសម្រេចដោយអ្នកផ្សះផ្សា បន្ទាប់ពីបានប្រឹក្សាយោបល់ជាមួយភាគីវិវាទ ដោយមើលតាមកាលៈទេសៈផ្សេងៗនៃដំណើរការផ្សះផ្សា។

**ការបង្ហាញព័ត៌មាន**

**មាត្រា ១០**

នៅពេលដែលអ្នកផ្សះផ្សាទទួលព័ត៌មានស្តីពីអង្គហេតុទាក់ទងនឹងវិវាទពីភាគីម្ខាង អ្នកផ្សះផ្សាបង្ហាញខ្លឹមសារនៃព័ត៌មាននោះដល់ភាគីម្ខាងទៀត ដើម្បីឱ្យភាគីម្ខាងទៀតអាចមានឱកាសក្នុងការបង្ហាញបំនកស្រាយណាមួយដែលខ្លួនគិតថាសមស្រប។ ក៏ប៉ុន្តែ នៅពេលដែលភាគីម្ខាងផ្តល់ព័ត៌មានទៅកាន់អ្នកផ្សះផ្សា ដោយភ្ជាប់នូវលក្ខខ័ណ្ឌជាក់លាក់ថាត្រូវរក្សាការសម្ងាត់ អ្នកផ្សះផ្សាមិនបង្ហាញព័ត៌មាន ទៅភាគីម្ខាងទៀតឡើយ។

**ការសហការរបស់ភាគីវិវាទជាមួយអ្នកផ្សះផ្សា**

**មាត្រា ១១**

ភាគីវិវាទត្រូវសហការដោយស្មោះត្រង់ជាមួយអ្នកផ្សះផ្សា ហើយជាពិសេសត្រូវខ្នះខ្នែងធ្វើតាមសម្នើ របស់អ្នកផ្សះផ្សា ក្នុងការផ្ញើឯកសារលាយលក្ខណ៍អក្សរនានា ការផ្តល់ភស្តុតាង និងការចូលរួមប្រជុំ ។

**សំណូមពររបស់ភាគីដើម្បីបញ្ចប់វិវាទ**

**មាត្រា ១២**

ភាគីនិមួយៗ អាចផ្ញើរទៅកាន់អ្នកផ្សះផ្សានូវសំណូមពររបស់ខ្លួនដើម្បីបញ្ចប់វិវាទ តាមការផ្តួចផ្តើមផ្ទាល់ ខ្លួន ឬតាមការអញ្ជើញរបស់អ្នកផ្សះផ្សា។

### កិច្ចព្រមព្រៀងបញ្ចប់វិវាទ

### មាត្រា ១៣

(១) នៅពេលដែលអ្នកផ្សះផ្សាមើលឃើញថាមានធាតុផ្សំផ្សេងៗសម្រាប់បញ្ចប់វិវាទ ដែលភាគីវិវាទ អាចទទួលយកបាន អ្នកផ្សះផ្សាតាក់តែងលក្ខខណ្ឌផ្សេងៗនៃលទ្ធភាពបញ្ចប់វិវាទ ហើយផ្ញើរទៅកាន់ភាគីវិវាទដើម្បីធ្វើការសង្កេត។ បន្ទាប់ពីទទួលបានសេចក្ដីសង្កេតពីភាគីវិវាទរួច អ្នកផ្សះផ្សាអាចតាក់តែង ឡើងវិញនូវលក្ខខណ្ឌផ្សេងៗនៃលទ្ធភាពបញ្ចប់វិវាទ ដោយផ្អែកទៅលើសេចក្ដីសង្កេតទាំងនោះ ។

(២) ប្រសិនបើភាគីវិវាទឈានដល់ការព្រមព្រៀងបញ្ចប់វិវាទ ពួកគេត្រូវរៀបរៀង និងចុះហត្ថលេខាលើលិខិតព្រមព្រៀងបញ្ចប់វិវាទនោះ។** ប្រសិនបើមានសម្ដីពីភាគីវិវាទ អ្នកផ្សះផ្សាក៏ត្រូវធ្វើពង្រាង ឬជួយភាគីវិវាទនៅក្នុងការធ្វើពង្រាងកិច្ចព្រមព្រៀងបញ្ចប់វិវាទនោះ។

(៣) ដោយការចុះហត្ថលេខាលើកិច្ចព្រមព្រៀងបញ្ចប់វិវាទ ភាគីវិវាទដាក់វិវាទរបស់ខ្លួនជាអាវសាន ហើយត្រូវជាប់កាតព្វកិច្ចតាមកិច្ចព្រមព្រៀងនោះ។

### ការរក្សាការសម្ងាត់

### មាត្រា ១៤

អ្នកផ្សះផ្សា និងភាគីវិវាទត្រូវរក្សាការសម្ងាត់ចំពោះរាល់បញ្ហាដែលទាក់ទងនឹងដំណើរការផ្សះផ្សា។ ការសម្ងាត់ក៏ត្រូវរក្សាឱ្យបានផងដែរនៅក្នុងកិច្ចព្រមព្រៀងបញ្ចប់វិវាទ លើកលែងតែ ការបញ្ចេញការសម្ងាត់នោះមានភាពចាំបាច់នៅក្នុងគោលបំណងអនុវត្ត និងជំរុញការអនុវត្ត។

### ការបញ្ចប់ដំណើរការផ្សះផ្សា

### មាត្រា ១៥

ដំណើរការផ្សះផ្សាត្រូវបញ្ចប់តាមកាលវេលាដូចក្នុងករណីខាងក្រោមៈ

(ក) បើមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងបញ្ចប់វិវាទដោយភាគីវិវាទ គឺត្រឹមកាលបរិច្ឆេទនៃកិច្ច-ព្រមព្រៀងនោះ ឬ

(ខ) បើមានសេចក្ដីប្រកាសជាលាយលក្ខណ៍អក្សររបស់អ្នកផ្សះផ្សា បន្ទាប់ពីមានការប្រឹក្សាយោបល់ជាមួយភាគីវិវាទ ចំពោះលទ្ធផលដែលថាកិច្ចខិតខំប្រឹងប្រែងផ្សះផ្សាបន្តទៀតនោះលែងជាការត្រឹមត្រូវ គឺត្រឹមកាលបរិច្ឆេទនៃសេចក្ដីប្រកាសនោះ ឬ

---

** គូភាគីអាចចង់ពិចារណាបញ្ចូលនៅក្នុងកិច្ចព្រមព្រៀងបញ្ចប់វិវាទនូវខមួយដែលចែងថាវិវាទទាំងឡាយដែលកើតឡើងពីឬពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងបញ្ចប់វិវាទនឹងត្រូវបញ្ជូនទៅធ្វើមជ្ឈត្តការ។

(គ) បើមានសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ ធ្វើឡើងដោយភាគីវិវាទទៅកាន់អ្នកផ្សះផ្សា ចំពោះលទ្ធផលដែលថា ដំណើរការផ្សះផ្សានឹងត្រូវបញ្ឈប់ គឺត្រឹមកាលបរិច្ឆេទនៃសេចក្តីប្រកាសនោះ ឬ

(ឃ) បើមានសេចក្តីប្រកាសជាលាយលក្ខណ៍អក្សររបស់ភាគីម្ខាងទៅភាគីម្ខាងទៀត ព្រមទាំងអ្នក ផ្សះផ្សា ប្រសិនបើមានការតែងតាំងរួចហើយ ចំពោះលទ្ធផលដែលថា ដំណើរការផ្សះផ្សានឹងត្រូវបញ្ឈប់ គឺត្រឹមកាលបរិច្ឆេទនៃសេចក្តីប្រកាសនោះ។

**ឧបាស្រ័យតាមនីតិវិធីមជ្ឈត្តការ ឬតុលាការ**

**មាត្រា ១៦**

ក្នុងពេលមានដំណើរការផ្សះផ្សា ភាគីវិវាទត្រូវឯកភាពថាមិនផ្តួចផ្តើមដំណើរការមជ្ឈត្តការ ឬនីតិវិធី តុលាការចំពោះវិវាទដែលជាកម្មវត្ថុនៃដំណើរការនេះឡើយ លើកលែងតែថាមានភាគីណាមួយយល់ ឃើញថានីតិវិធីទាំងនេះមានភាពចាំបាច់ក្នុងការការពារសិទ្ធិរបស់ខ្លួន ទើបភាគីនោះអាចផ្តួចផ្តើម ដំណើរការមជ្ឈត្តការ ឬនីតិវិធីតុលាការបាន។

**ថ្លៃចំណាយផ្សេងៗ**

**មាត្រា ១៧**

(១) នៅពេលដែលដំណើរការផ្សះផ្សាត្រូវបានបញ្ចប់ អ្នកផ្សះផ្សាត្រូវកំនត់ថ្លៃចំណាយលើការផ្សះផ្សា និងផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ភាគីវិវាទ។ ពាក្យថា "ថ្លៃចំណាយ" រួមមានត្រឹមតែ:

(ក) ថ្លៃឈ្នួលសម្រាប់អ្នកផ្សះផ្សាដែលត្រូវមានចំនួនសមរម្យ

(ខ) ថ្លៃធ្វើដំណើរ និងការចំណាយដទៃទៀតរបស់អ្នកផ្សះផ្សា

(គ) ថ្លៃធ្វើដំណើរ និងការចំណាយដទៃទៀតរបស់សាក្សីដែលបានស្នើឡើងដោយអ្នកផ្សះផ្សា និងដោយមានការយល់ព្រមពីភាគីវិវាទ

(ឃ) ថ្លៃពិគ្រោះជាមួយអ្នកជំនាញការដែលបានស្នើឡើងដោយអ្នកផ្សះផ្សា និងដោយមានការយល់ព្រមពីភាគីវិវាទ

(ង) ថ្លៃចំណាយលើជំនួយដែលបានផ្តល់ឱ្យ ដូចមានចែងក្នុងមាត្រា៤ កថាខ័ណ្ឌ(២)(ខ) និងមាត្រា៨ នៃវិធាននេះ។

(២) ថ្លៃចំណាយ ដូចក្នុងនិយមន័យខាងលើ គឺជាបន្ទុកស្មើគ្នារបស់ភាគីវិវាទលើកលែងតែកិច្ចព្រមព្រៀងបញ្ចប់វិវាទមានចែងពីការបែងចែកផ្សេងពីនេះ។ រាល់សោហ៊ុយផ្សេងទៀតដែលភាគីម្ខាងបានចំណាយ គឺជាបន្ទុករបស់ភាគីនោះ។

**ប្រាក់តម្កល់**

**មាត្រា ១៨**

(១) នៅពេលត្រូវបានតែងតាំង អ្នកផ្សះផ្សាអាចស្នើភាគីនិមួយៗឱ្យតម្កល់ប្រាក់ចំណាយស្មើៗគ្នាដែលជាប្រាក់កក់សម្រាប់ថ្លៃចំណាយផ្សេងៗដូចមានរៀបរាប់នៅក្នុងមាត្រា១៧ កថាខ័ណ្ឌ(១) តាមការដែលខ្លួនរំពឹងថានឹងត្រូវការដើម្បីទូទាត់។

(២) នៅក្នុងពេលដំណើរការផ្សះផ្សា អ្នកផ្សះផ្សាអាចស្នើសុំប្រាក់តម្កល់បន្ថែមនៅក្នុងចំនួនស្មើគ្នាពីភាគីនិមួយៗ។

(៣) ប្រសិនបើភាគីវិវាទទាំងសង្ខាងមិនបានបង់ប្រាក់តម្កល់ដែលបានតម្រូវក្នុងកថាខ័ណ្ឌ(១) និង(២) នៃមាត្រានេះ ឱ្យបានគ្រប់ក្នុងរយៈពេលសាមសិបថ្ងៃនោះទេ អ្នកផ្សះផ្សាអាចពន្យាដំណើរការ ឬអាចធ្វើសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរអំពីការបញ្ឈប់ដំណើរការនោះ ជូនទៅភាគីវិវាទ ដែលមានប្រសិទ្ធិភាពចាប់ពីថ្ងៃប្រកាសនោះតទៅ។

(៤) នៅពេលបញ្ឈប់ដំណើរការផ្សះផ្សា អ្នកផ្សះផ្សាត្រូវប្រគល់ជូនរបាយការណ៍គណនេយ្យដល់ភាគីវិវាទដែលបានបង់ប្រាក់តម្កល់ និងត្រូវប្រគល់សមតុល្យដែលមិនបានចំណាយជូនភាគីទាំងនោះវិញ ។

**តួនាទីអ្នកផ្សះផ្សានៅក្នុងនីតិវិធីផ្សេងទៀត**

**មាត្រា ១៩**

ភាគីវិវាទ និងអ្នកផ្សះផ្សាត្រូវទទួលយល់ព្រមថា អ្នកផ្សះផ្សានឹងមិនដើរតួជាមជ្ឈត្តករ ឬជាតំណាង ឬជាអ្នកពិគ្រោះយោបល់របស់ភាគីម្ខាងនៅក្នុងដំណើរការមជ្ឈត្តការ ឬនីតិវិធីតុលាការ ពាក់ព័ន្ធនឹងវិវាទដែលជាកម្មវត្ថុនៃដំណើរការផ្សះផ្សានោះឡើយ។ ភាគីវិវាទក៏ត្រូវទទួលយល់ព្រមផងដែរថា ខ្លួននឹងមិនយកអ្នកផ្សះផ្សាធ្វើជាសាក្សីនៅក្នុងដំណើរការមជ្ឈត្តការ ឬនីតិវិធីតុលាការនោះឡើយ។

**ការប្រើប្រាស់ភស្តុតាងនៅក្នុងដំណើរការផ្សេងទៀត**

**មាត្រា ២០**

នៅក្នុងដំណើរការមជ្ឈត្តការ ឬនីតិវិធីតុលាការ ទោះជានីតិវិធីទាំងនោះពាក់ព័ន្ធ ឬមិនពាក់ព័ន្ធនឹងវិវាទដែលជាកម្មវត្ថុនៃដំណើរការផ្សះផ្សានេះក៏ដោយ ភាគីវិវាទត្រូវទទួលយល់ព្រមថាមិននឹងពឹងផ្អែក ឬប្រើប្រាស់ជាភស្តុតាងនូវៈ

(ក) ទស្សនៈដែលបានសំដែងចេញ ឬសំណូមពររបស់ភាគីម្ខាងទៀតដែលពាក់ព័ន្ធនឹងលទ្ធភាពនៃការបញ្ចប់វិវាទ

(ខ) ការព្រមទទួលយករបស់ភាគីម្ខាងទៀតក្នុងអំឡុងពេលនៃដំណើរការផ្សះផ្សា

(គ) សម្ដីដែលធ្វើឡើងដោយអ្នកផ្សះផ្សា

(ឃ) ហេតុដែលថាភាគីម្ខាងទៀតបានសំដែងឆន្ទៈរបស់ខ្លួនក្នុងការទទួលសម្ដីបញ្ចប់វិវាទ ដែលធ្វើឡើងដោយអ្នកផ្សះផ្សា ។

**ខផ្សះផ្សាគម្រូ**

នៅពេលមានវិវាទណាមួយកើតចេញពី ឬជាប់ពាក់ព័ន្ធនឹងកិច្ចសន្យានេះ ហើយភាគីវិវាទចង់ស្វែងរកដំណោះស្រាយមួយដោយសន្តិវិធីលើវិវាទនោះតាមរយៈការផ្សះផ្សា ការផ្សះផ្សានោះត្រូវធ្វើឡើងដោយអនុលោមតាមវិធានផ្សះផ្សា UNCIT RAL ដែលមានជាធរមាន ។

(ភាគីវិវាទអាចព្រមព្រៀងលើខផ្សះផ្សាដទៃទៀត ។)

---

ពត៌មានបន្ថែមអាចទទួលពី:

អគ្គលេខាធិការដ្ឋាន UNCITRAL

មជ្ឈមណ្ឌលអន្តរជាតិនៅក្រុងវៀន

ប្រអប់សំបុត្រ P.O Box 500

A- 1400 ទីក្រុងវៀន ប្រទេសអូទ្រីស

ទូរស័ព្ទ: (+៤៣ ១) ២៦០៦០-៤០៦០

ហ្វាក់: (+៤៣ ១) ២៦០៦០- ៥៨១៣

អ៊ិនធឺណែត: http://www.uncitral.org

អ៊ីមែល: uncitral@uncitral.org

# ឧបសម្ព័ន្ធ ខ

## បទដ្ឋានប្រតិបត្តិតម្រូវសម្រាប់សន្ធានការី

### បទដ្ឋានទី I: សិទ្ធិស្វ័យសម្រេច

ក. សន្ធានការីត្រូវធ្វើការសម្រុះសម្រួលដោយផ្អែកលើគោលការណ៍ស្វ័យសម្រេចរបស់ភាគី។ សិទ្ធិស្វ័យសម្រេច គឺជាកិរិយានៃការឈានដល់ការសម្រេចចិត្តដោយស្ម័គ្រចិត្ត និងគ្មានការបង្ខិតបង្ខំ ដែលក្នុងនោះភាគីនីមួយៗ ធ្វើការជ្រើសរើសដោយសេរី និងដោយជ្រួតជ្រាបអំពីដំណើរការ និងលទ្ធផល។ ភាគីអាចអនុវត្ត សិទ្ធិស្វ័យសម្រេចនៅគ្រប់ដំណាក់កាលទាំងអស់នៃសន្ធានកម្ម រួមទាំងការ ជ្រើសរើសសន្ធានការី ការរៀបចំដំណើរការ ការចូលរួម ឬការដកខ្លួនចេញពីដំណើរការ និងលទ្ធផលផ្សេងៗ។

១. ទោះបីសិទ្ធិស្វ័យសម្រេចរបស់ភាគីក្នុងកិច្ចការរៀបចំដំណើរការ គឺជាគោលការណ៍ចម្បងក្នុងការអនុវត្តសន្ធានកម្មក្តី សន្ធានការីអាចនឹងត្រូវធ្វើការថ្លឹងថ្លែងរវាងសិទ្ធិស្វ័យសម្រេចនៃភាគីជាមួយនិងភារកិច្ចរបស់ខ្លួន ក្នុងការដឹកនាំដំណើរការមួយប្រកបដោយគុណភាព ស្របតាមបទដ្ឋានទាំងនេះ។

២. សន្ធានការីមិនអាចធានាដោយខ្លួនឯងផ្ទាល់ ថាភាគីនីមួយៗបានធ្វើជម្រើសផ្សេងៗដោយសេរី និងដោយមានការជ្រួតជ្រាប ដើម្បីឈានទៅដល់ការសម្រេចចិត្តជាក់លាក់ណាមួយនោះឡើយ ប៉ុន្តែនៅពេលសមស្រប សន្ធានការីគួរធ្វើឱ្យភាគីវិវាទយល់ដឹងពីសារៈសំខាន់នៃការប្រឹក្សាយោបល់ជាមួយអ្នកជំនាញផ្សេងៗ ដើម្បីជួយឱ្យពួកគេធ្វើជម្រើសដោយមានការជ្រួតជ្រាប។

ខ. សន្ធានការីមិនត្រូវឱ្យប៉ះពាល់សិទ្ធិស្វ័យសម្រេចរបស់ភាគី ដែលធ្វើឡើយដោយភាគីណាមួយដោយសារហេតុផលផ្សេងៗ ដូចជាអាត្រាសំណងបញ្ហាវិវាទខ្ពស់ ប្រយោជន៍ផ្ទាល់ខ្លួន កំណើនថ្លៃឈ្នួល ឬក៏សម្ពាធ ខាងក្រៅពីសំណាក់បុគ្គលិក តុលាការ អ្នកគ្រប់គ្រងកម្មវិធី ស្ថាប័នគាំទ្រ ប្រព័ន្ធព័ត៌មាន ឬផ្នែកដទៃ ទៀតនោះឡើយ។

### បទដ្ឋានទី II: អនាគតិ

ក. សន្ធានការីត្រូវបដិសេធចំពោះសន្ធានកម្ម ប្រសិនបើសន្ធានការីនោះមិនអាចធ្វើការសម្រុះសម្រួលក្នុងរបៀបមិនលម្អៀងបាន។ អនាគតិ សំដៅទៅលើអវត្តមាននៃភាពគាំទ្រនិយម អគតិ ឬបុរេ វិនិច្ឆ័យ។

ខ. សន្ធានការីត្រូវធ្វើការសម្រុះសម្រួលនៅក្នុងរបៀបមិនលម្អៀង និងត្រូវចៀសវាងកិរិយាណាដែលស្តែងឱ្យឃើញពីភាពលម្អៀង។

១. សន្ធានការីមិនគួរប្រព្រឹត្តខ្លួនឱ្យមានភាពលម្អៀង ឬបុរេវិនិច្ឆ័យ ដោយផ្អែកលើលក្ខណៈផ្ទាល់ខ្លួន ប្រវត្តិ តម្លៃ និងជំនឿ ឬអាកប្បកិរិយាក្នុងពេលសន្ធានកម្ម របស់អ្នកចូលរួម ឬដោយសារមូលហេតុដទៃទៀតឡើយ ។

២. សន្ធានការីមិនគួរផ្តល់ឱ្យ ឬទទួលយក អំណោយ គុណប្រយោជន៍ កម្ចី ឬវត្ថុមានតម្លៃដទៃទៀត ដែលនាំឱ្យមានចំណោទចំពោះអនាគតិជាក់ស្តែង ឬដែលគេសន្មត់ របស់សន្ធានការីនោះឡើយ ។

៣. សន្ធានការីអាចទទួល ឬផ្តល់អំណោយដ៏ស្តួចស្តើង ឬវត្ថុ ឬសេវាកម្មបន្ទាប់បន្សំដែលគេផ្តល់ឱ្យដើម្បីសម្របសម្រួលដល់សន្ធានកម្ម ឬគោរពតាមទំនៀមទម្លាប់វប្បធម៌ ដរាបណាការអនុវត្តបែបនោះ មិនបង្កឱ្យមានចំណោទចំពោះអនាគតិជាក់ស្តែង ឬដែលគេសន្មត់ របស់សន្ធានការីនោះ ។

គ. ប្រសិនបើនៅពេលណាមួយសន្ធានការីមិនអាចធ្វើការសម្រុះសម្រួលក្នុងលក្ខណៈមិនលម្អៀងបាននោះទេ សន្ធានការីត្រូវដកខ្លួនចេញ ។

## បទដ្ឋានទី III ទំនាស់ផលប្រយោជន៍

ក. សន្ធានការីត្រូវចៀសវាងទំនាស់ផលប្រយោជន៍ ឬការលេចឡើងនូវទំនាស់ផលប្រយោជន៍ក្នុងពេលនិងក្រោយពេលសន្ធានកម្ម ។ ទំនាស់ផលប្រយោជន៍ អាចកើតឡើងចេញពីការជាប់ពាក់ព័ន្ធរវាងសន្ធានការី ជាមួយនិងបញ្ហាដែលជាកម្មវត្ថុនៃវិវាទ ឬពីទំនាក់ទំនងណាមួយរវាងសន្ធានការី និងអ្នកចូលរួមក្នុងសន្ធានកម្ម ទាំងក្នុងពេលអតីតកាល ឬបច្ចុប្បន្នកាល ទាំងបែបផ្ទាល់ខ្លួន ឬបែបវិជ្ជាជីវៈ ដែលទាំងអស់នេះនាំឱ្យមានចំណោទដល់អនាគតិរបស់សន្ធានការី ។

ខ. សន្ធានការីអាចធ្វើការស៊ើបសួរដើម្បីកំនត់ថាតើ មានអង្គហេតុណាមួយដែលនាំឱ្យបុគ្គលសមស្របណាមួយ យល់ឃើញថានឹងអាចបង្កឱ្យមានជាទំនាស់ផលប្រយោជន៍ជាក់ស្តែង ឬជាសក្តានុភូតសម្រាប់សន្ធានការី ។ វិធានការរបស់សន្ធានការី ដែលមានភាពចាំបាច់ដើម្បីសម្រេចការស៊ើបសួរអំពីទំនាស់ផលប្រយោជន៍ជាសក្តានុភូត អាចមានភាពខុសគ្នាទៅតាមបរិបទនៃការអនុវត្ត ។

គ. សន្ធានការីត្រូវបង្ហាញព័ត៌មានឱ្យបានឆាប់បំផុតតាមដែលអាចអនុវត្តបាន អំពីរាល់ទំនាស់ផល-ប្រយោជន៍ជាក់ស្តែង និងជាសក្តានុភូតដែលសមនឹងអាចដឹងបានដោយសន្ធានការី ហើយមានហេតុផលអាចឱ្យគេមើលឃើញថានាំឱ្យមានចំណោទចំពោះអនាគតិរបស់សន្ធានការី ។ បន្ទាប់ពីបានបង្ហាញព័ត៌មានរួច បើមានការឯកភាពពីភាគីវិវាទ សន្ធានការីអាចបន្តធ្វើសន្ធានកម្មបាន ។

ឃ. ក្រោយពេលព្រមព្រៀងលើសន្ធានកម្ម ប្រសិនបើសន្ធានការីណាម្នាក់ដឹងពីតថភាពណាមួយដែលនាំឱ្យមានចំណោទចំពោះទំនាស់ផលប្រយោជន៍ជាសក្តានុភូត ពាក់ព័ន្ធនឹងភារកិច្ចរបស់ខ្លួន សន្ធានការីត្រូវបង្ហាញព័ត៌មាននោះឱ្យបានឆាប់បំផុតតាមដែលអាចអនុវត្តបាន។ បន្ទាប់ពីបង្ហាញព័ត៌មានរួច បើមានការឯកភាពពីភាគីវិវាទ សន្ធានការីអាចបន្តធ្វើការសម្រុះសម្រួលបាន។

ង. ផ្ទុយទៅវិញ ប្រសិនបើទំនាស់ផលប្រយោជន៍របស់សន្ធានការីណាម្នាក់ មានហេតុផលអាចឱ្យគេយល់ឃើញថាបង្ករអន្តរាយដល់សុចរិតភាពរបស់ខ្លួន សន្ធានការីអាចដកខ្លួន ឬបដិសេធក្នុងការបន្តធ្វើសន្ធានកម្មបាន ទោះបីជាមានបំណងប្រាថ្នា ឬការព្រមព្រៀងដ៏ជាក់លាក់ពីសំណាក់ភាគីវិវាទក្តី។

ច. បន្ទាប់ពីសន្ធានកម្ម សន្ធានការីមិនត្រូវបង្កើតទំនាក់ទំនងមួយផ្សេងទៀតជាមួយអ្នកចូលរួមណាម្នាក់ក្នុងកិច្ចការណាដែលអាចនាំឱ្យមានចំណោទចំពោះសុចរិតភាពនៃសន្ធានកម្មនោះឡើយ។ នៅពេលដែលសន្ធានការីណាម្នាក់បង្កើតទំនាក់ទំនងផ្ទាល់ខ្លួន ឬបែបវិជ្ជាជីវៈជាមួយភាគីវិវាទ បុគ្គលឬស្ថាប័នដទៃ ទៀតបន្ទាប់ពីសន្ធានកម្មណាមួយដែលមានជាប់ពាក់ព័ន្ធនឹងពួកគេ សន្ធានការីគួរធ្វើការពិចារណាលើកត្តានានាដូចជា ពេលវេលាកន្លងផុតបន្ទាប់ពីសន្ធានកម្មនោះ ចរិតនៃទំនាក់ទំនងដែលបានបង្កើតឡើងព្រមទាំងសេវាកម្មនានាដែលត្រូវផ្តល់ នៅពេលដែលខ្លួនកំនត់ថា តើទំនាក់ទំនងទាំងនោះអាចបង្កើតជាទំនាស់ប្រយោជន៍ជាក់ស្តែង ឬដែលគេសន្មត់ ដែរឬទេ។

## បទដ្ឋានទី IV សមត្ថភាព

ក. សន្ធានការីអាចធ្វើសន្ធានកម្មបាន តែនៅពេលដែលខ្លួនមានសមត្ថភាពគ្រប់គ្រាន់ដើម្បីបំពេញតាមការរំពឹងទុកដ៏សមស្របរបស់ភាគីវិវាទប៉ុណ្ណោះ។

១. គេអាចជ្រើសរើសបុគ្គលណាម្នាក់ធ្វើជាសន្ធានការីក៏បាន ដរាបណាភាគីទាំងអស់ពេញចិត្តនឹងសមត្ថភាព និងគុណវុឌ្ឍិរបស់សន្ធានការីនោះ។ ការបណ្តុះបណ្តាល បទពិសោធន៍នៅក្នុងសន្ធានកម្ម ជំនាញ ការយល់ដឹងពីវប្បធម៌ ព្រមទាំងគុណវុឌ្ឍិដទៃទៀត រមែងជាកត្តាចាំបាច់នៃសមត្ថភាពរបស់សន្ធានការី។ អ្នកដែលព្រមធ្វើជាសន្ធានការីត្រូវបង្កើត ការរំពឹងទុកថាខ្លួនមានសមត្ថភាពសម្រុះសម្រួលយ៉ាងមានប្រសិទ្ធិភាព។

២. សន្ធានការីគួរចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលផ្សេងៗ និងសកម្មភាពពាក់ព័ន្ធដទៃទៀត ដើម្បីពង្រីង និងលើកកម្ពស់ចំណេះដឹង ព្រមទាំងជំនាញរបស់ខ្លួនដែលពាក់ព័ន្ធនឹងសន្ធានកម្ម។

៣. សន្ធានការីគួរតែត្រៀមសម្រាប់ភាគី នូវព័ត៌មានទាក់ទងនឹងការបណ្តុះបណ្តាល ការអប់រំ បទពិសោធន៍ និង វិធីសាស្ត្រក្នុងការដឹកនាំសន្ធានកម្មរបស់ខ្លួន។

ខ. ប្រសិនបើក្នុងកំឡុងពេលសន្ធានកម្ម សន្ធានការីសម្រេចថាខ្លួនមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការសម្រុះសម្រួលទេនោះ សន្ធានការីត្រូវលើកយកការសម្រេចនោះទៅពិភាក្សាជាមួយភាគីវិវាទឱ្យបានឆាប់បំផុតតាមដែលអាចអនុវត្តបាន និងចាត់វិធានការដោះស្រាយស្ថានភាពនោះ ដោយក្នុងនោះរួមមាន (តែមិនកម្រិតត្រឹមតែប៉ុណ្ណឹងទេ) ការដកខ្លួន ឬការស្នើរសុំជំនួយសមស្របជាដើម។

គ. ប្រសិនបើសមត្ថភាពសន្ធានការីក្នុងការដឹកនាំសន្ធានកម្ម ចុះអន់ថយដោយសារថ្នាំញៀន សុរា ការប្រើថ្នាំពេទ្យ ឬក្រៅពីនេះ សន្ធានការីមិនត្រូវដឹកនាំសន្ធានកម្មឡើយ។

**បទដ្ឋានទី V ការរក្សាការសម្ងាត់**

ក. សន្ធានការីត្រូវរក្សាការសម្ងាត់ចំពោះព័ត៌មានទាំងឡាយដែលខ្លួនទទួលបានក្នុងកិច្ចការសម្រុះសម្រួល លើកលែងតែភាគីវិវាទមានការព្រមព្រៀងផ្សេងពីនេះ ឬជាការតំរូវតាមច្បាប់ដែលត្រូវអនុវត្ត។

១. ប្រសិនបើភាគីវិវាទនៃសន្ធានកម្មព្រមព្រៀងឱ្យសន្ធានការីបង្ហាញព័ត៌មាន ដែលទទួលបាននៅក្នុងកំឡុងពេលនៃសន្ធានកម្ម សន្ធានការីអាចបង្ហាញព័ត៌មាននោះបាន។

២. សន្ធានការីមិនត្រូវឆ្លើយឆ្លងទៅកាន់អ្នកដែលមិនបានចូលរួម អំពីកិរិយារបស់ភាគីវិវាទនៅក្នុងពេលសន្ធានកម្មឡើយ។ ប្រសិនសិនបើចាំបាច់ សន្ធានការីអាចរាយការណ៍ថាតើភាគីវិវាទមានវត្តមាន ឬអវត្តមាននៅក្នុងកិច្ចសម្រុះសម្រួល តាមកាលដែលបានកំណត់ និងថាតើភាគីវិវាទបានឈានដល់ដំណោះស្រាយណាមួយឬទេ។

៣. ប្រសិនបើសន្ធានការីណាម្នាក់ចូលរួមនៅក្នុងការបង្រៀន ការស្រាវជ្រាវ ឬការវាយតម្លៃអំពីសន្ធានកម្ម សន្ធានការីនោះគួរតែការពារអនាមិកភាពរបស់ភាគីវិវាទ ហើយគោរពតាមការរំពឹងទុកដ៏សមស្របរបស់ពួកគេពាក់ព័ន្ធនឹងការរក្សាការសម្ងាត់។

ខ. សន្ធានការីដែលជួបជាមួយបុគ្គលណាម្នាក់ក្នុងជំនួបជាឯកជន ក្នុងកំឡុងពេលសន្ធានកម្ម មិនត្រូវផ្តល់ព័ត៌មានដែលខ្លួនទទួលបានក្នុងជំនួបឯកជននោះដល់បុគ្គលម្នាក់ទៀត ទោះដោយផ្ទាល់ ឬដោយប្រយោលក្តី ដោយគ្មានការយល់ព្រមពីបុគ្គលនោះឡើយ។

គ. សន្ធានការីត្រូវលើកកម្ពស់ការយល់ជ្រួតជ្រាបក្នុងចំណោមភាគីវិវាទ អំពីកម្រិតដែលភាគីវិវាទត្រូវរក្សាការសម្ងាត់ចំពោះព័ត៌មានដែលពួកគេទទួលបានក្នុងសន្ធានកម្ម។

ឃ. អាស្រ័យលើកាលៈទេសៈនៃសន្ធានកម្ម ភាគីវិវាទអាចមានការរំពឹងទុកខុសៗគ្នាទាក់ទងនឹងការរក្សាការសម្ងាត់ដែលសន្ធានការីគួរដោះស្រាយ។ ភាគីទាំងអស់អាចបង្កើតវិធានផ្ទាល់ខ្លួនពាក់ព័ន្ធនឹងការរក្សាការសម្ងាត់ ឬការអនុវត្តរបស់សន្ធានការីឬស្ថាប័នណាមួយ ដែលមានការទទួលស្គាល់ អាចដាក់ចុះជាការរំពឹងទុកជាក់លាក់មួយចំនួន។

## បទដ្ឋានទី VI គុណភាពនៃដំណើរការ

ក. សន្ធានការីត្រូវដឹកនាំសន្ធានកម្មឱ្យស្របនឹងបទដ្ឋានទាំងនេះ និងនៅក្នុងរបៀបមួយដែលលើកកម្ពស់ការយកចិត្តទុកដាក់ កាលាអនុវត្ត សុវត្ថិភាព វត្តមានអ្នកចូលរួមដែលសមស្រប ការចូលរួមរបស់ភាគីភាពត្រឹមត្រូវតាមនីតិវិធី សមត្ថភាពរបស់ភាគី និងការគោរពទៅវិញទៅមករវាងអ្នកចូលរួមទាំងអស់។

១. សន្ធានការីគួរព្រមព្រៀងសម្រុះសម្រួល លុះត្រាណាតែខ្លួនត្រៀមជាស្រេចនឹងផ្តល់ការយកចិត្តទុកដាក់ដែលចាំបាច់សំរាប់ការធ្វើសន្ធានកម្មដែលប្រកបដោយប្រសិទ្ធិភាព។

២. សន្ធានការីគួរទទួលរឿងក្តី តែនៅពេលដែលខ្លួនអាចបំពេញតាមការរំពឹងទុកសមស្របរបស់ភាគីវិវាទពាក់ព័ន្ធនឹងការពេលកពេលវេលានៃសន្ធានកម្ម។

៣. វត្តមាន ឬអវត្តមានរបស់បុគ្គលផ្សេងៗក្នុងពេលសម្រុះសម្រួលគឺអាស្រ័យលើការព្រមព្រៀងរវាងភាគីវិវាទ និងសន្ធានការី។ ភាគីវិវាទ និងសន្ធានការីអាចឯកភាពគ្នាថាអ្នកដទៃផ្សេងទៀតអាចនឹងត្រូវដកចេញពីវគ្គសម្រុះសម្រួលមួយចំនួន ឬទាំងអស់។

៤. សន្ធានការីគួរលើកកម្ពស់ភាពស្មោះត្រង់ និងការមិនលាក់លៀមរវាង និងក្នុងចំណោមអ្នកចូលរួមទាំងអស់ ហើយសន្ធានការីម្នាក់មិនត្រូវបកស្រាយខុស ដោយចេតនា ចំពោះខ្លឹមសារ អង្គហេតុ ឬកាលៈទេសៈណាមួយ នៅក្នុងកំឡុងពេលនៃសន្ធានកម្មឡើយ។

៥. តួនាទីរបស់សន្ធានការីម្នាក់ខុសគ្នាស្រលះពីតួនាទីអាជីពដទៃទៀត។ ការច្របូកតួនាទីសន្ធានការីជាមួយតួនាទីអាជីពមួយទៀតអាចបង្ករជាបញ្ហា ហេតុដូច្នេះហើយសន្ធានការីគួរតែបែងចែករវាងតួនាទីទាំងនេះឱ្យដាច់ពីគ្នា។ សន្ធានការីអាចផ្តល់ព័ត៌មានថា ខ្លួនមានគុណវុឌ្ឍិតាមរយៈការបណ្តុះបណ្តាល ឬបទពិសោធន៍ក្នុងអាជីព ក្នុងលក្ខខណ្ឌដែលថាខ្លួនអាចធ្វើដូច្នេះបាន ដោយស្របទៅតាមបទដ្ឋានទាំងនេះ។

៦. សន្ធានការីម្នាក់មិនត្រូវដឹកនាំនីតិវិធីដោះស្រាយទំនាស់ណាមួយក្រៅពីសន្ធានកម្ម ប៉ុន្តែដាក់ស្លាកថាជាសន្ធានកម្ម ក្នុងកិច្ចប្រឹងប្រែងស្វែងរកការការពារពីសំណាក់វិធានលក្ខន្តិកៈ ឬអាជ្ញាធរគ្រប់គ្រងដទៃទៀតដែលពាក់ព័ន្ធនឹងសន្ធានកម្មនោះឡើយ។

៧. នៅពេលដែលសមស្រប សន្ធានការីអាចណែនាំឱ្យភាគីទាំងអស់ពិចារណាការដោះស្រាយទំនាស់របស់ពួកគេតាមរយៈមជ្ឈត្តការ ការប្រឹក្សាយោបល់ ការវាយតម្លៃអព្យាក្រឹត ឬក៏តាមរយៈដំណើរការផ្សេងទៀត។

៨. សន្ធានការីមិនត្រូវទទួលតួនាទីដោះស្រាយវិវាទមួយផ្សេងទៀត នៅក្នុងបញ្ហាតែមួយដោយគ្មានការព្រមព្រៀងពីភាគីវិវាទឡើយ។ មុននឹងផ្តល់សេវាកម្មបែបនោះ សន្ធានការី

ត្រូវផ្តល់ព័ត៌មានដល់ភាគីវិវាទអំពីលទ្ធភាពនៃបំលាស់ប្តូរនៅក្នុងដំណើរការ ព្រមទាំងមានការឯកភាពពីអ្នកទាំងនោះចំពោះការផ្លាស់ប្តូរនោះផង។ សន្ទានការីដែលធ្វើតួនាទីបែបនេះមានភារកិច្ច និងការទទួលខុសត្រូវផ្សេង ដែលអាចត្រូវបានគ្រប់គ្រងដោយបទដ្ឋានដទៃទៀត។

៩. ប្រសិនបើសន្ទានកម្មត្រូវបានគេប្រើដើម្បីបន្តប្រព្រឹត្តបទល្មើសណាមួយ សន្ទានការីគួរតែចាត់វិធានការណ៍សមស្របរួមមាន ប្រសិនបើចាំបាច់ ការពន្យាពេល ការដកខ្លួន ឬការបញ្ឈប់សន្ទានកម្មនោះ។

១០. ប្រសិនបើភាគីណាមួយបង្ហាញឱ្យឃើញថា ខ្លួនមានការលំបាកក្នុងការស្វែងយល់ពីដំណើរ-ការ បញ្ហា ឬជម្រើសបញ្ចប់វិវាទផ្សេងៗ ឬការលំបាកក្នុងការចូលរួមសម្រុះសម្រួល សន្ទានការីគួរស្វែងរកកាលៈទេសៈ ព្រមទាំងសុវិធា ការកែប្រែ ឬការកែតំរូវ សក្តានុភូតផ្សេងៗ ដែលផ្តល់លទ្ធភាពឱ្យភាគីមានសមត្ថភាពស្វែងយល់ ចូលរួម និងប្រើសិទ្ធិស្វ័យសម្រេចរបស់ខ្លួន។

ខ. ប្រសិនបើសន្ទានការីបានដឹងថាមានការរំលោភបំពានក្នុងគ្រួសារ ឬអំពើហិង្សា កើតមានរវាងភាគីជាគូវិវាទ សន្ទានការីអាចចាត់វិធានការណ៍សមស្របនានា ប្រសិនបើចាំបាច់ រួមមានការពន្យាពេល ការដកខ្លួន ឬការបញ្ឈប់សន្ទានកម្ម។

គ. ប្រសិនបើសន្ទានការីជឿជាក់ថាការប្រព្រឹត្តរបស់អ្នកចូលរួម រួមទាំងរបស់សន្ទានការីផងដែរ នាំអោយអន្តរាយដល់ការដឹកនាំសន្ទានកម្មដែលស្របនឹងបទដ្ឋាននេះ សន្ទានការីអាចចាត់វិធានការណ៍សមស្របនានា ប្រសិនបើចាំបាច់ រួមមាន ការពន្យាពេល ការដកខ្លួន ឬការបញ្ឈប់ការសម្រុះសម្រួល។

## បទដ្ឋានទី VII ការឃោសនា និងផ្សព្វផ្សាយ

ក. សន្ទានការីត្រូវតែនិយាយតែការពិត ហើយឥតបង្វែង នៅពេលឃោសនា ផ្សព្វផ្សាយ ឬនៅពេលផ្តល់ព័ត៌មានតាមវិធីផ្សេងទៀត ស្តីអំពីគុណវុឌ្ឍិ បទពិសោធន៍ សេវាកម្ម និងថ្លៃឈ្នួល របស់សន្ទានការីនោះ។

១. សន្ទានការីម្នាក់មិនត្រូវដាក់បញ្ចូលការសន្យាផ្សេងៗពាក់ព័ន្ធនឹងលទ្ធផលឡើយ នៅក្នុងការឆ្លើយឆ្លងព័ត៌មានទាំងឡាយ ដូចជានាមប័ណ្ណ សម្ភារៈក្នុងការិយាល័យ ឬការឆ្លើយឆ្លងផ្សេងៗ ដោយប្រើម៉ាស៊ីនកុំព្យូទ័រ។

២.	សន្ទានការីគួរអះអាងថាខ្លួនអាចបំពេញតាមគុណវុឌ្ឍិរបស់សន្ទានការី ដែលកំណត់ដោយអង្គភាពរដ្ឋាភិបាល ឬអង្គការឯកជនណាមួយ ដរាបណាអង្គភាព ឬអង្គការនោះមាននីតិវិធីវាយតម្លៃសន្ទានការីដែលមានការទទួលស្គាល់ ហើយស្ថាប័ននោះផ្តល់ឋានៈនោះដល់ខ្លួន ។

ខ. សន្ទានការីមិនត្រូវធ្វើការផ្សព្វផ្សាយក្នុងរបៀបមួយដែលបង្កើតជារូបភាពលម្អៀងទៅគាំទ្រ ឬប្រឆាំងនឹងភាគីណាមួយ ឬក្រៅពីនេះទៀត ធ្វើឱ្យអាប់ឱនដល់សុចរិតភាពនៃដំណើរការសន្ទានកម្មឡើយ ។

គ. សន្ទានការីមិនត្រូវឆ្លើយឆ្លងជាមួយអ្នកដទៃ តាមរយៈសម្ភារៈផ្សព្វផ្សាយ ឬតាមរូបភាពដទៃទៀតនៃការឆ្លើយឆ្លងព័ត៌មាន ដោយប្រើឈ្មោះរបស់បុគ្គលនានាដោយគ្មានការអនុញ្ញាតពីសាម៉ីខ្លួនគេឡើយ ។

## បទដ្ឋានទី VIII ថ្លៃឈ្នួល និងសោហ៊ុយដទៃទៀត

ក. សន្ទានការីត្រូវផ្តល់ឱ្យភាគីនិមួយៗ ឬតំណាងរបស់ភាគីនិមួយៗនូវព័ត៌មានពិតប្រាកដ និងពេញលេញអំពីថ្លៃឈ្នួលសម្រុះសម្រួល ថ្លៃចំណាយនានា ព្រមទាំងថ្លៃសោហ៊ុយជាក់ស្តែង និងសក្តានុភូតផ្សេងទៀតដែលអាចមានពាក់ព័ន្ធនឹងសន្ទានកម្ម ។

១. ប្រសិនបើសន្ទានការីម្នាក់យកថ្លៃឈ្នួលផ្សេងៗ សន្ទានការីនោះត្រូវបង្កើតថ្លៃឈ្នួលនោះដោយផ្អែកលើកត្តាដែលពាក់ព័ន្ធទាំងអស់រួមមាន ប្រភេទ និងភាពស្មុគស្មាញនៃបញ្ហា គុណវុឌ្ឍិរបស់សន្ទានការី ពេលវេលាដែលត្រូវការ និងអាត្រាថ្លៃឈ្នួល ដែលមានលក្ខណៈជាទំលាប់សម្រាប់សេវាកម្មសម្រុះសម្រួលបែបនោះ ។

២. ការកំនត់ថ្លៃឈ្នួលរបស់សន្ទានការីគួរធ្វើឡើងជាលាយល័ក្សអក្សរ លើកលែងតែភាគីវិវាទស្នើអោយធ្វើផ្សេងពីនេះ ។

ខ. សន្ទានការីមិនត្រូវគិតថ្លៃឈ្នួលក្នុងរបៀបមួយដែលធ្វើឱ្យអនាគតិរបស់ខ្លួនអាប់ឱនឡើយ ។

១.	សន្ទានការីមិនគួរទទួលព្រមព្រៀងលើថ្លៃឈ្នួល ដែលអាស្រ័យលើលទ្ធផលនៃសន្ទានកម្ម ឬតម្លៃសំណងពេលបញ្ចប់វិវាទឡើយ ។

២.	ទោះជាសន្ទានការីអាចទទួលយកថ្លៃឈ្នួលមិនស្មើគ្នាពីភាគីវិវាទក៏ដោយ ក៏សន្ទានការីមិនត្រូវប្រើប្រាស់ការកំនត់ថ្លៃឈ្នួលណា ដែលត្រលប់ទៅប៉ះពាល់ដល់លទ្ធភាពរបស់ខ្លួន ក្នុងការដឹកនាំសន្ទានកម្មមួយតាមរបៀបមិនលម្អៀងឡើយ ។

## បទដ្ឋានទី IX ការរីកចំរើននៃការអនុវត្តសន្ធានកម្ម

ក. សន្ធានការីគួរប្រព្រឹត្តខ្លួនក្នុងរបៀបមួយ ដែលជម្រុញការអនុវត្តសន្ធានកម្មឱ្យមានភាពរីកចំរើន ។ សន្ធានការីលើកកម្ពស់បទដ្ឋានទាំងនេះដោយផ្សារភ្ជាប់នឹងសកម្មភាពមួយចំនួន ឬទាំងអស់ដូចខាងក្រោម:

១. លើកស្ទួយចំរុះភាពនៅក្នុងវិស័យសន្ធានកម្ម

២. ប្រឹងប្រែងធ្វើឱ្យសេវាសន្ធានកម្មងាយរកបានសម្រាប់អ្នកដែលជ្រើសយកមធ្យោបាយនេះ ដូចជាផ្តល់សេវាកម្មផ្សេងៗដោយអាត្រាចុះតម្លៃ ឬផ្អែកលើមូលដ្ឋានឥតគិតថ្លៃ តាមការគួរ ។

៣. ចូលរួមនៅក្នុងកិច្ចការស្រាវជ្រាវ នៅពេលដែលមានឱកាស ដូចជាការប្រមូលមតិវាយតម្លៃរបស់អ្នកចូលរួម នៅពេលណាដែលសមស្រប ។

៤. ចូលរួមនៅក្នុងកិច្ចខិតខំប្រឹងប្រែងពង្រីកចំណេះដឹង និងអប់រំផ្សេងៗ ដើម្បីជួយឱ្យសាធារណៈជនបង្កើត និងបង្កើនការយល់ដឹងបន្ថែម និងឱ្យតម្លៃទៅលើសន្ធានកម្ម ។

៥. ជួយសន្ធានការីជំនាន់ក្រោយតាមរយៈការបណ្តុះបណ្តាល ការណែនាំ និងការចងបណ្តាញកាងារ ។

ខ. សន្ធានការីត្រូវបង្ហាញការគោរពចំពោះទស្សនៈផ្សេងៗគ្នានៅក្នុងវិស័យសន្ធានកម្ម ស្វះស្វែងរៀនសូត្រពីសន្ធានការីដទៃទៀត និងធ្វើការងាររួមគ្នាជាមួយសន្ធានការីដទៃទៀត ដើម្បីស្ថាបនាអាជីពរបស់ខ្លួន និងបម្រើអ្នកដែលមានទំនាស់ឱ្យបានកាន់តែប្រសើរ ។

# ឧបសម្ព័ន្ធ គ

## គណៈកម្មការអង្គការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ (UNCITRAL)

## វិធានមជ្ឈត្តការនៃ UNCITRAL

**ផ្នែកទី I : វិធានផ្តើម**

ដែនកំណត់នៃការអនុវត្តន៍ (មាត្រា ១) និងខគម្រូស្តីពីមជ្ឈត្តការ

ការជូនដំណឹង ការគណនាពេលវេលា (មាត្រា ២)

ការជូនដំណឹងអំពីមជ្ឈត្តការ (មាត្រា ៣)

តំណាង និងជំនួយ (មាត្រា ៤)

**ផ្នែកទី II : សមាសភាពនៃវេទិកាមជ្ឈត្តកម្ម**

ចំនួនមជ្ឈត្តករ ( មាត្រា ៥)

ការតែងតាំងមជ្ឈត្តករ ( មាត្រា ៦ ដល់ ៨)

ការជំទាស់ទៅនឹងមជ្ឈត្តករ ( មាត្រា ៩ ដល់ ១២)

ការផ្លាស់ប្តូរមជ្ឈត្តករ ( មាត្រា ១៣ )

ការធ្វើសវនាការឡើងវិញក្នុងករណីមានការផ្លាស់ប្តូរមជ្ឈត្តករ ( មាត្រា ១៤ )

**ផ្នែកទីIII : និតិវិធីមជ្ឈត្តការ**

បទប្បញ្ញាត្តិទូទៅ ( មាត្រា ១៥)

ទីកន្លែងធ្វើមជ្ឈត្តការ ( មាត្រា ១៦ )

ភាសា ( មាត្រា ១៧ )

បណ្តឹងទាមទារ ( មាត្រា ១៨ )

បណ្តឹងដោះសា ( មាត្រា ១៩ )

ការកែប្រែលើបណ្តឹងទាមទារ ឬ ដោះសា ( មាត្រា ២០)

ការជំទាស់ចំពោះសមត្ថកិច្ចរបស់វេទិកាមជ្ឈត្តកម្ម ( មាត្រា ២១)

បណ្តឹងលាយលក្ខណ៍អក្សរបន្ថែមដទៃទៀត ( មាត្រា ២២ )

ថេរៈវេលាផ្សេងៗ ( មាត្រា ២៣ )

ភស្តុតាង និងសវនាការ ( មាត្រា ២៤ និង ២៥ )

វិធានការណ៏បណ្តោះអាសន្នដើម្បីការពារ ( មាត្រា ២៦ )

ជំនាញការ ( មាត្រា ២៧ )

ការខកខាន ( មាត្រា ២៨ )

ការបិទសវនាការ ( មាត្រា ២៩ )

ការលើកលែងចំពោះវិធានផ្សេងៗ ( មាត្រា ៣០ )

**ផ្នែកទី** IV : **មជ្ឈត្តវិនិច្ឆ័យ**

ការសម្រេចផ្សេងៗ ( មាត្រា ៣១ )

ទម្រង់ និងអានុភាពនៃមជ្ឈត្តវិនិច្ឆ័យ ( មាត្រា ៣២ )

ប្រព័ន្ធច្បាប់សម្រាប់អនុវត្ត ការស្រុះស្រួល (*umiable compositer)* ( មាត្រា ៣៣ )

ការស្រុះស្រួល ឬមូលដ្ឋានដទៃទៀតដើម្បីបញ្ចប់វិវាទ ( មាត្រា ៣៤ )

ការបកស្រាយមជ្ឈត្តវិនិច្ឆ័យ ( មាត្រា ៣៥)

កំណែតម្រូវលើមជ្ឈត្តវិនិច្ឆ័យ ( មាត្រា ៣៦ )

មជ្ឈត្តវិនិច្ឆ័យបន្ថែម ( មាត្រា ៣៧)

ថ្លៃចំណាយផ្សេងៗ ( មាត្រា ៣៨ ទៅ ៤០)

ការតម្កល់ប្រាក់ចំណាយ ( មាត្រា៤១)

# សេចក្តីសម្រេច លេខ ៣១/៩៨ អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី ១៥ ធ្នូ ១៩៧៦

៣១/៩៨ វិធានមជ្ឈត្តការរបស់គណៈកម្មការអង្គការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ

**មហាសន្និបាត**

**ដោយទទួលស្គាល់**នូវតម្លៃនៃមជ្ឈត្តការ ថាជាវិធីដោះស្រាយវិវាទមួយដែលកើតមានឡើងនៅក្នុងបរិបទនៃទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ ។

**ដោយជឿជាក់**ថា ការបង្កើតវិធានសម្រាប់ការធ្វើមជ្ឈត្តការពិសេស ដែលអាចទទួលយកបាននៅក្នុងប្រទេសនានាដែលមានប្រព័ន្ធច្បាប់ សង្គម និងសេដ្ឋកិច្ចផ្សេងៗគ្នា នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការងារអភិវឌ្ឍន៍ទំនាក់ទំនងសេដ្ឋកិច្ចអន្តរជាតិដោយសុខដុមរមនា ។

**ដោយគូសចំណាំថា** វិធានមជ្ឈត្តការនៃគណៈកម្មការអង្គការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ បានរៀបចំឡើងបន្ទាប់ពីមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយស្ថាប័ន និងមជ្ឈមណ្ឌលមជ្ឈត្តការនានា ក្នុងវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្មអន្តរជាតិ ។

**ដោយកត់សម្គាល់ថា** វិធានមជ្ឈត្តការត្រូវបានអនុម័តដោយគណៈកម្មការអង្គការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ នៅឯកិច្ចប្រជុំទី៩[៣០៧] បន្ទាប់ពីការពិភាក្សាយ៉ាងហ្មត់ចត់រួច ។

១. **ដាក់ជាអនុសាសន៍** ឱ្យប្រើប្រាស់វិធានមជ្ឈត្តការរបស់គណៈកម្មការអង្គការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិនៅក្នុងការដោះស្រាយវិវាទ ដែលកើតមាននៅក្នុងបរិបទនៃទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ ជាពិសេសដោយអនុលោមតាមវិធានមជ្ឈត្តការនៅក្នុងកិច្ចសន្យាពាណិជ្ជកម្ម ។

២. **ស្នើ**អគ្គលេខាធិការអង្គការសហប្រជាជាតិ រៀបចំឱ្យមានការចែកចាយវិធានមជ្ឈត្តការនេះឱ្យបានទូលំទូលាយបំផុតតាមដែលអាចធ្វើបាន ។

---

[៣០៧] កំណត់ត្រាផ្លូវការរបស់មហាសន្និបាត កិច្ចប្រជុំលើកទី៣១ អត្ថបទបន្ថែមលេខ ១៧ (A/៣១/១៧) ជំពូក V ផ្នែក C ។

## វិធានមជ្ឈត្តការ UNCITRAL

## ផ្នែកទី I: វិធានផ្ដើម

**វិសាលភាពនៃការអនុវត្ត**

**មាត្រា ១**

១. នៅពេលដែលគូរភាគីនៃកិច្ចសន្យាណាមួយបានយល់ស្របជាលាយលក្ខណ៍អក្សរ* ថាវិវាទទាំងឡាយណាដែលកើតចេញពីកិច្ចសន្យានោះ នឹងត្រូវយកមកធ្វើមជ្ឈត្តការក្រោមវិធានមជ្ឈត្តការ UNCITRAL វិវាទទាំងនោះនឹងត្រូវបានដោះស្រាយឱ្យស្របទៅនឹងវិធានទាំងនេះ វាវលែងតែមានកំណែប្រែណាដែលភាគីវិវាទអាចព្រមព្រៀងជាលាយលក្ខណ៍អក្សរ។

២. វិធានទាំងនេះត្រូវគ្រប់គ្រងលើការធ្វើមជ្ឈត្តការនោះ លើកលែងតែមានវិធានណាផ្ទុយទៅនឹងបទប្បញ្ញត្តិនៃច្បាប់សម្រាប់អនុវត្តចំពោះមជ្ឈត្តការនោះ ដែលភាគីវិវាទមិនអាចធ្វើបដិប្បញ្ញត្តិបាន ទើបត្រូវយកបទប្បញ្ញត្តិនោះមកអនុវត្ត។

---

*ខគម្រូស្ដីពីមជ្ឈត្តការ

វិវាទ វាទប្បដិវាទ ឬការទាមទារណាមួយ ដែលកើតចេញពីឬមានទំនាក់ទំនងនឹងកិច្ចសន្យានេះ ឬក៏ការរំលោភ ការបញ្ចប់ ឬទុពលភាពនៃកិច្ចសន្យានេះ នឹងត្រូវដោះស្រាយតាមបែបមជ្ឈត្តការ ដោយអនុលោមតាមវិធានមជ្ឈត្តការនៃ **UNCITRAL** ដែលមានជាធរមាន។

កំណត់សម្គាល់- ភាគីទាំងអស់អាចពិចារណាបន្ថែមនូវព័ត៌មានដូចខាងក្រោម:

(ក) អង្គាធរដែលត្រូវបានជ្រើសតាំងឡើងគឺជា....... (ឈ្មោះនីតិបុគ្គល ឬរូបវន្តបុគ្គល)

(ខ) ចំនួនមជ្ឈត្តករគឺ................. (មួយ ឬបី)

(គ) ទីកន្លែងធ្វើមជ្ឈត្តការគឺ... (ឈ្មោះក្រុង ឬប្រទេស)

(ឃ) ភាសា (មួយ ឬច្រើន) ប្រើនៅក្នុងដំណើរការនីតិវិធីមជ្ឈត្តការគឺ...............

---

**ការជូនដំណឹង ការគណនាពេលវេលា**

**មាត្រា ២**

១. នៅក្នុងវិធានទាំងនេះ ការជូនដំណឹងតាមរូបភាពណាមួយ រួមទាំងការផ្ដល់ដំណឹង លិខិតឆ្លើយឆ្លង ឬសម្ដើ នឹងត្រូវចាត់ទុកថាបានទទួល ប្រសិនបើការជូនដំណឹងនោះ ត្រូវបានបញ្ជូនទៅដល់អសយដ្ឋាន

អ្នកទទួលនោះផ្ទាល់ ឬត្រូវបានផ្ញើទៅលំនៅស្ថានអចិន្ត្រៃយ៍ ទីកន្លែងអាជីវកម្ម ឬអសយដ្ឋានទទួលសំបុត្ររបស់អ្នកទទួល ឬក្នុងករណីដែល បន្ទាប់ពីបានស៊ើបសួររួចមក គេមិនអាចរកឃើញអសយដ្ឋានទាំងនោះទេ ការជូនដំណឹងនេះត្រូវផ្ញើទៅនិវាសដ្ឋាន ឬកន្លែងអាជីវកម្មដែលគេស្គាល់ចុងក្រោយបង្អស់។ ការជូន ដំណឹង ត្រូវសន្មតថាបានទទួលនៅថ្ងៃដែលបានផ្ញើទៅដល់។

២. ក្នុងការគណនាពេលវេលាក្រោមវិធានទាំងនេះ គេត្រូវគិតពេលវេលានោះចាប់ពីថ្ងៃ បន្ទាប់ពីថ្ងៃដែលការប្រកាស សេចក្តីជូនដំណឹង លិខិតឆ្លើយឆ្លង ឬសំណើណាមួយត្រូវបានទទួល។ ប្រសិនបើថ្ងៃចុងក្រោយនៃថេរៈវេលានោះជាថ្ងៃវិសម្យកាលផ្លូវការ ឬថ្ងៃឈប់សម្រាកពីការងារនៅឯលំនៅស្ថាន ឬកន្លែងអាជីវកម្មរបស់អ្នកទទួល ថេរៈវេលានោះនឹងត្រូវពន្យារហូតដល់ថ្ងៃធ្វើការដំបូងបន្ទាប់ពីនោះមក។ វិសម្យកាលផ្លូវការ ឬថ្ងៃឈប់សម្រាកដែលមានក្នុងចន្លោះពេលនោះ នឹងត្រូវរាប់បញ្ចូលក្នុងពេលវេលាដែលត្រូវគណនាជាធម្មតា។

**ការជូនដំណឹងអំពីមជ្ឈត្តការ**

**មាត្រា ៣**

១. ភាគីដែលផ្តើមបណ្តឹងមជ្ឈត្តការ (អំណើះតទៅហៅថា "ភាគីប្តឹង") ត្រូវផ្តល់ដល់ភាគីម្ខាងទៀត (អំណើះតទៅហៅថា "ភាគីឆ្លើយតប") នូវការជូនដំណឹងអំពីមជ្ឈត្តការ។

២. នីតិវិធីមជ្ឈត្តការត្រូវបានសន្មតថាចាប់ផ្តើមនៅថ្ងៃដែលភាគីឆ្លើយតបទទួលបានការជូនដំណឹង អំពីមជ្ឈត្តការនោះ។

៣. ការជូនដំណឹងអំពីមជ្ឈត្តការត្រូវរួមបញ្ចូលនូវៈ

(ក) ការទាមទារឱ្យមានការដោះស្រាយវិវាទដោយវិធានមជ្ឈត្តការ

(ខ) ឈ្មោះ និងអសយដ្ឋានរបស់ភាគីទាំងអស់

(គ) សំណៅយោងលើខស្តីពីមជ្ឈត្តការ ឬលើកិច្ចព្រមព្រៀងមជ្ឈត្តការដោយឡែកណាមួយដែលត្រូវយកមកអនុវត្ត។

(ឃ) សំណៅយោងលើកិច្ចសន្យាដែលបង្ករ ឬទាក់ទងនឹងវិវាទនោះ ។

(ង) ចរិតទូទៅនៃការទាមទារ និងការលើកឡើងអំពីចំនួនទឹកប្រាក់ដែលពាក់ព័ន្ធ ប្រសិនបើមាន

(ច) ការអនុគ្រោះ ឬដំណោះស្រាយដែលចង់បាន

(ឆ) សំណើអំពីចំនួនអាជ្ញាកណ្តាល ( មួយ ឬ បី) ប្រសិនបើភាគីទាំងអស់មិនបានព្រមព្រៀងពីមុនមកទេ។

៤. ការជូនដំណឹងអំពីមជ្ឈត្តការអាចរួមបញ្ចូលផងដែរនូវៈ

(ក) សម្ចើដើម្បីឱ្យមានការតែងតាំងមជ្ឈត្តករតែមួយរូបណាមួយ និងអាជ្ញាធរតែងតាំងមួយ ដូចមានរៀបរាប់ក្នុងមាត្រា ៦ កថាខ័ណ្ឌ ១។

(ខ) ការជូនដំណឹងអំពីការតែងតាំងមជ្ឈត្តករដូចមានចែងក្នុងមាត្រា ៧។

(គ) បណ្តឹងទាមទារដូចមានចែងក្នុងមាត្រា ១៨។

**តំណាង និងជំនួយ**

**មាត្រា ៤**

ភាគីទាំងអស់អាចជ្រើសរើសអ្នកតំណាង ឬអ្នកផ្តល់ជំនួយដោយខ្លួនឯង។ ឈ្មោះ និង អសយដ្ឋានរបស់បុគ្គលទាំងនោះ ត្រូវតែបានឆ្លើយឆ្លងជាលាយលក្ខ័អក្សរទៅកាន់ភាគីម្ខាងទៀត ដោយត្រូវបញ្ជាក់ថាការតែងតាំងនោះធ្វើឡើងក្នុងគោលបំណងសម្រាប់ធ្វើជាតំណាង ឬក៏សម្រាប់ផ្តល់ជំនួយ។

## ផ្នែកទី II: សមាសភាពនៃវេទិកាមជ្ឈត្តកម្ម

**ចំនួនមជ្ឈត្តករ**

**មាត្រា ៥**

ប្រសិនបើភាគីទាំងអស់មិនទាន់បានព្រមព្រៀងពីមុនមកអំពីចំនួនមជ្ឈត្តករ (មួយរូប ឬបីរូប) ហើយប្រសិនបើក្នុងរយៈពេលដប់ប្រាំថ្ងៃបន្ទាប់ពីភាគីឆ្លើយតប បានទទួលការជូនដំណឹងអំពីមជ្ឈត្តការរួច ភាគីវិវាទនៅតែមិនទាន់ព្រមព្រៀងថាត្រូវមានមជ្ឈត្តករតែមួយរូបទេនោះ គេត្រូវតែងតាំងមជ្ឈត្តករចំនួនបីរូប។

**ការតែងតាំងមជ្ឈត្តករ ( មាត្រា៦ ដល់៨)**

**មាត្រា ៦**

១. ប្រសិនបើត្រូវតែងតាំងមជ្ឈត្តករតែមួយរូប ភាគីម្ខាងអាចស្នើទៅភាគីម្ខាងទៀតនូវៈ

(ក) ឈ្មោះរូបវ័ន្តបុគ្គលមួយ ឬច្រើន ដែលម្នាក់ក្នុងចំណោមនោះនឹងត្រូវធ្វើការជាមជ្ឈត្តករតែមួយរូប ព្រមទាំង

(ខ) ឈ្មោះរូបវ័ន្តបុគ្គល ឬនីតិបុគ្គលមួយឬច្រើន ដែលមួយក្នុងចំណោមនោះនឹងត្រូវធ្វើជាអាជ្ញាធរតែងតាំង បើភាគីវិវាទមិនទាន់បានឯកភាពគ្នាលើអាជ្ញាធរតែងតាំងណាមួយនោះទេ។

២. ប្រសិនបើក្នុងរយៈពេលសាមសិបថ្ងៃបន្ទាប់ពីភាគីម្ខាងបានទទួលសម្ចើណាមួយ ដែលបានធ្វើឡើងដូចក្នុងកថាខ័ណ្ឌ១ ភាគីវិវាទមិនទាន់បានព្រមព្រៀងគ្នាលើការជ្រើសរើសមជ្ឈត្តករតែមួយរូបណាមួយនោះទេ មជ្ឈត្តករមួយរូបនោះត្រូវតែងតាំងឡើងដោយអាជ្ញាធរតែងតាំង ដែលមានការព្រមព្រៀងពីភាគីវិវាទ។ ប្រសិនបើ ពុំមានអាជ្ញាធរតែងតាំងណាមួយត្រូវបានព្រមព្រៀងដោយភាគីវិវាទ ឬប្រសិនបើ

អាជ្ញាធរតែងតាំងដែលមានការព្រមព្រៀងរបស់ភាគីវិវាទ បដិសេធ ឬខកខានមិនបានតែងតាំងមជ្ឈត្តករក្នុងរយៈពេលហុកសិបថ្ងៃ បន្ទាប់ពីទទួលបានសម្នើរបស់ភាគីវិវាទរួច ភាគីវិវាទណាមួយក៏បានអាចស្នើទៅអគ្គលេខាធិការនៃតុលាការអចិន្ត្រៃយ៍ផ្នែកមជ្ឈត្តការនាទីក្រុងឡាអេ ឱ្យជ្រើសតាំងអាជ្ញាធរតែងតាំងមួយឡើង។

៣. នៅពេលមានសម្នើរបស់ភាគីវិវាទ អាជ្ញាធរតែងតាំងត្រូវតែងតាំងមជ្ឈត្តករតែមួយរូបណាមួយយ៉ាងរហ័សបំផុតតាមដែលអាចធ្វើបាន។ ដើម្បីធ្វើការតែងតាំង អាជ្ញាធរតែងតាំងត្រូវប្រើនីតិវិធីតាមបញ្ជីឈ្មោះ ដូចរៀបរាប់ខាងក្រោម លើកលែងតែថាភាគីវិវាទឯកភាពថានីតិវិធីតាមបញ្ជីឈ្មោះនេះមិនគួរលើកយកមកប្រើ ឬក៏ថាអាជ្ញាធរតែងតាំងសម្រេចដោយឆន្ទានុសិទ្ធិរបស់ខ្លួនថា ការប្រើប្រាស់នីតិវិធីតាមបញ្ជីឈ្មោះនេះមិនមានលក្ខណៈសមស្របចំពោះរឿងក្តីនោះ

(ក) យោងតាមសម្នើសុំរបស់ភាគីណាមួយ អាជ្ញាធរតែងតាំងនឹងបញ្ជូនទៅភាគីវិវាទនូវបញ្ជីឈ្មោះដូចគ្នា ដែលក្នុងនោះមានឈ្មោះយ៉ាងតិចចំនួនបី

(ខ) ក្នុងកំឡុងពេលដប់ប្រាំថ្ងៃបន្ទាប់ពីទទួលបាននូវបញ្ជីឈ្មោះរួច ភាគីនិមួយៗអាចបញ្ជូនបញ្ជីនោះត្រលប់មកអជ្ញាធរតែងតាំងវិញ បន្ទាប់ពីលុបឈ្មោះមួយ ឬច្រើនដែលខ្លួនជំទាស់ ហើយរៀបឈ្មោះដែលនៅសេសសល់ក្នុងបញ្ជីតាមលំដាប់នៃការពេញចិត្តរបស់ខ្លួន

(គ) ក្រោយពេលដែលថេរវេលាខាងលើផុតកំណត់ អាជ្ញាធរតែងតាំងនឹងតែងតាំងមជ្ឈត្តករមួយរូបចេញពីឈ្មោះទាំងអស់ដែលគូរភាគីបានសម្រេចនៅក្នុងបញ្ជីដែលបានបញ្ជូនត្រលប់មកវិញ និងស្របតាមលំដាប់នៃជំរើសរបស់ភាគីវិវាទ។

(ឃ) បើសិនដោយហេតុផលណាមួយ ការជ្រើសតាំងមិនអាចធ្វើឡើងទៅបានស្របនឹង នីតិវិធីនេះទេ អាជ្ញាធរតែងតាំងអាចប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីតែងតាំងមជ្ឈត្តករតែមួយរូបនោះបាន។

៤. នៅក្នុងកិច្ចការតែងតាំង អាជ្ញាធរតែងតាំងត្រូវផ្អែកលើការពិចារណាជាច្រើនដើម្បីធានាឱ្យបាននូវការតែងតាំងមជ្ឈត្តករមួយរូបដែលឯករាជ្យ និងមិនលម្អៀង ហើយត្រូវពិចារណាផងដែរអំពីលទ្ធភាពក្នុងការតែងតាំងមជ្ឈត្តករមួយរូបដែលមានសញ្ជាតិមួយផ្សេងពីសញ្ជាតិរបស់ភាគីវិវាទតាមការគួរ។

**មាត្រា ៧**

១. ប្រសិនបើត្រូវតែងតាំងមជ្ឈត្តករបីរូប ភាគីវិវាទទាំងសង្ខាងត្រូវតែងតាំងមជ្ឈត្តករមួយរូបរៀងខ្លួន។ មជ្ឈត្តករទាំងពីររូបត្រូវជ្រើសរើសមជ្ឈត្តករទីបីដែលនឹងក្លាយជាមជ្ឈត្តករអធិបតីនៃវេទិកា។

២. ប្រសិនបើក្នុងរយៈពេលសាមសិបថ្ងៃ បន្ទាប់ពីទទួលបានការជូនដំណឹងរបស់ភាគីម្ខាងអំពីការតែងតាំងមជ្ឈត្តករមួយរូបរួចមក ភាគីម្ខាងទៀតនៅមិនទាន់បានជូនដំណឹងដល់ភាគីទីមួយអំពីមជ្ឈត្តករដែលខ្លួនបានតែងតាំងទេនោះ:

(ក) ភាគីទីមួយអាចស្នើទៅអាជ្ញាធរតែងតាំងដែលភាគីទាំងពីរបានជ្រើសតាំងពីមុនមក ឱ្យតែងតាំង មជ្ឈត្តករទី២ ឬ

(ខ) ប្រសិនបើពុំមានអាជ្ញាធរតែងតាំងដែលភាគីវិវាទបានជ្រើសតាំងពីមុនទេ ឬបើសិនអាជ្ញាធរតែងតាំងដែលត្រូវបានជ្រើសតាំងនោះជំទាស់ ឬខកខានមិនបានតែងតាំងមជ្ឈត្តករក្នុងរយៈពេលសាមសិបថ្ងៃបន្ទាប់ពីទទួលបានសម្នើរបស់ភាគីណាមួយនោះ ភាគីទីមួយអាចស្នើអគ្គលេខាធិ-ការនៃតុលាការអចិន្ត្រៃយ៍ផ្នែកមជ្ឈត្តការនាទីក្រុងឡាអេ ឱ្យជ្រើសតាំងអាជ្ញាធរតែងតាំងមួយ ។ បន្ទាប់មកភាគីទីមួយអាចស្នើអាជ្ញាធរតែងតាំងដែលបានជ្រើសតាំងឡើងនោះ ឱ្យតែងតាំងមជ្ឈត្តករទីពីរ ។ ក្នុងករណីទាំងពីរអាជ្ញាធរតែងតាំងអាចប្រើឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការតែងតាំងមជ្ឈត្តករនោះ ។

៣. ប្រសិនបើក្នុងរយៈពេលសាមសិបថ្ងៃ បន្ទាប់ពីមានការតែងតាំងមជ្ឈត្តករទីពីររួចមក មជ្ឈត្តករទាំងពីរមិនទាន់បានព្រមព្រៀងលើការជ្រើសរើសមជ្ឈត្តករមួយរូបទៀតជាអធិបតីនោះ អាជ្ញាធរតែងតាំងនឹងតែងតាំងមជ្ឈត្តករអធិបតីតាមវិធានដូចគ្នានឹងការតែងតាំងមជ្ឈត្តករតែមួយរូបក្នុងមាត្រា៦ ដែរ ។

**មាត្រា ៨**

១. នៅពេលដែលអាជ្ញាធរតែងតាំងត្រូវបានស្នើឱ្យតែងតាំងមជ្ឈត្តករ ដូចដែលមានចែងក្នុងមាត្រា៦ ឬ៧ ភាគីដែលធ្វើសម្នើត្រូវផ្ញើច្បាប់ចម្លងនៃការជូនដំណឹងអំពីមជ្ឈត្តការមួយច្បាប់ កិច្ចសន្យាដែលបង្ករ ឬជាប់ពាក់ព័ន្ធនឹងវិវាទមួយច្បាប់ ព្រមទាំងកិច្ចព្រមព្រៀងស្តីពីមជ្ឈត្តការមួយច្បាប់ ប្រសិនបើមិនមានចែងនៅក្នុងកិច្ចសន្យានោះទេ។ អាជ្ញាធរតែងតាំងអាចតម្រូវឱ្យភាគីមួយផ្តល់ព័ត៌មានទាំងនេះ នៅពេលដែលយល់ឃើញថា វាជាការចាំបាច់ក្នុងការបំពេញតួនាទីរបស់ខ្លួន ។

២. ការស្នើឈ្មោះរូបវ័ន្តបុគ្គលម្នាក់ ឬច្រើននាក់ដើម្បីតែងតាំងជាមជ្ឈត្តករត្រូវធ្វើឡើងដោយមានបញ្ជាក់នូវឈ្មោះពេញ អសយដ្ឋាន និងសញ្ជាតិ ព្រមជាមួយនឹងការពណ៌នាអំពីគុណសម្បត្តិនៃបុគ្គលទាំងនោះ ។

**ការជំទាស់នឹងមជ្ឈត្តករ ( មាត្រា៩ ដល់១២)**

**មាត្រា ៩**

១. មជ្ឈត្តករដែលគេរំពឹងទុក ត្រូវបង្ហាញដល់អ្នកដែលពឹងពាក់ទាំងអស់នូវកាលៈទេសៈទាំងឡាយណាដែលពាក់ព័ន្ធនឹងលទ្ធភាពតែងតាំងខ្លួន និងដែលអាចនាំឱ្យកើតមានសេចក្តីមន្ទិលសមស្របនានា ចំពោះ

អនាគតិ ឬឯករាជ្យភាពរបស់ខ្លួន។ បន្ទាប់ពីត្រូវបានតែងតាំង ឬជ្រើសរើសរួចមក មជ្ឈត្តករត្រូវបង្ហាញពីកាលៈទេសៈទាំងនេះទៅកាន់ភាគីវិវាទ វាររំលែងតែភាគីវិវាទបានទទួលនូវព័ត៌មានទាំងនេះរួចហើយ។

**មាត្រា ១០**

១. គេអាចជំទាស់មជ្ឈត្តករណាមួយ ប្រសិនបើមានកាលៈទេសៈទាំងឡាយណាដែលនាំឱ្យកើតមានមន្ទិលសមស្របផ្សេងៗចំពោះអនាគតិ ឬឯករាជ្យភាពនៃមជ្ឈត្តករនោះ។

២. ភាគីម្ខាងអាចជំទាស់ចំពោះមជ្ឈត្តករដែលខ្លួនបានតែងតាំងបាន ក្នុងករណីដែលខ្លួនទើបតែបានដឹងអំពីមូលហេតុ បន្ទាប់ពីធ្វើការតែងតាំងរួចប៉ុណ្ណោះ។

**មាត្រា ១១**

១. ភាគីដែលមានបំណងជំទាស់នឹងមជ្ឈត្តករណាម្នាក់ ត្រូវផ្ញើលិខិតជូនដំណឹងអំពីការជំទាស់របស់ខ្លួនក្នុងអំឡុងពេលដប់ប្រាំថ្ងៃ ក្រោយពេលដែលភាគីនោះទទួលបានដំណឹងអំពីការតែងតាំងមជ្ឈត្តករដែលត្រូវជំទាស់នោះ ឬក្នុងរយៈពេលដប់ប្រាំថ្ងៃបន្ទាប់ពីភាគីនោះដឹងពីកាលៈទេសៈផ្សេងៗដូចមានចែងក្នុងមាត្រា៩ និង មាត្រា១០។

២. ការជំទាស់ត្រូវតែមានជូនជាដំណឹងដល់ភាគីម្ខាងទៀត ដល់មជ្ឈត្តករដែលត្រូវជំទាស់ និងដល់សមាជិកដទៃទៀតនៃវេទិកាមជ្ឈត្តកម្ម។ ការជូនដំណឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ព្រមទាំងមានបញ្ជាក់ពីហេតុផលនៃការជំទាស់នោះផង ។

៣. នៅពេលដែលមជ្ឈត្តករមួយរូបត្រូវបានជំទាស់ដោយភាគីម្ខាង ភាគីម្ខាងទៀតអាចយល់ស្របនឹងការជំទាស់នោះបាន។ រីឯមជ្ឈត្តករនោះផ្ទាល់ក៏អាចធ្វើការដកខ្លួនបានដែរ បន្ទាប់ពីមានការជំទាស់។ ករណីខាងលើ ពុំគួរបញ្ជាក់ពីសុពលភាពនៃកត្តាសម្អាងសម្រាប់ការជំទាស់នោះឡើយ។ បើមានករណីទាំងពីរនេះ គេអាចលើកយកមកប្រើប្រាស់បានយ៉ាងពេញលេញនូវនីតិវិធីដូចមានចែងក្នុង មាត្រា៦ ឬមាត្រា៧ ក្នុងការតែងតាំងមជ្ឈត្តករជំនួស ទោះបីក្នុងដំណើរការតែងតាំងមជ្ឈត្តករដែលត្រូវបានជំទាស់នោះ ភាគីម្ខាងមិនបានប្រើសិទ្ធិរបស់ខ្លួនក្នុងការតែងតាំង ឬចូលរួមតែងតាំងក៏ដោយ។

**មាត្រា ១២**

១. ប្រសិនបើភាគីម្ខាងទៀតមិនយល់ស្របនឹងការជំទាស់ ហើយមជ្ឈត្តករដែលត្រូវបានជំទាស់នោះមិនបានដកខ្លួនទេនោះ សេចក្តីសម្រេចលើការជំទាស់នោះនឹងត្រូវធ្វើឡើងដោយៈ

(ក) ក្នុងករណីដែលការតែងតាំងដំបូងធ្វើឡើងដោយអាជ្ញាធរតែងតាំងមួយ អាជ្ញាធរនោះជាអ្នកសម្រេច។

(ខ) ក្នុងករណីដែលការតែងតាំងដំបូងមិនបានធ្វើឡើងដោយអាជ្ញាធរតែងតាំងមួយទេ ប៉ុន្តែមានអជ្ញាធរតែងតាំងមួយត្រូវបានជ្រើសតាំងពីមុនមក អាជ្ញាធរនោះជាអ្នកសម្រេច ។

(គ) នៅរាល់ករណីដទៃទៀត ត្រូវសម្រេចដោយអាជ្ញាធរតែងតាំង ដែលគេត្រូវជ្រើសតាំងឡើងស្របតាមនីតិវិធីក្នុងការជ្រើសតាំងអាជ្ញាធរតែងតាំងដូចមានចែងក្នុងមាត្រា ៦ ។

២. ប្រសិនបើអាជ្ញាធរតែងតាំងរក្សារការជំទាស់នោះ មជ្ឈត្តករជំនួសមួយរូបនឹងត្រូវបានតែងតាំង ឬជ្រើសរើស ឱ្យស្របតាមនីតិវិធីសម្រាប់អនុវត្តក្នុងតំណែងតាំង ឬជម្រើសមជ្ឈត្តករ ដូចមានចែងពីមាត្រា ៦ ដល់មាត្រា៩ លើកលែងតែពេលដែលនីតិវិធីនេះតម្រូវឱ្យមានការជ្រើសតាំងនូវអាជ្ញាធរតែងតាំងណាមួយ ការតែងតាំងមជ្ឈត្តករត្រូវធ្វើឡើងដោយអាជ្ញាធរតែងតាំងដែលបានសម្រេចលើការជំទាស់នោះ ។

**ការផ្លាស់ប្តូរមជ្ឈត្តករ**

**មាត្រា ១៣**

១. នៅក្នុងករណីដែលមជ្ឈត្តករបាត់បង់ជីវិត ឬលាលែងពីការងាររបស់ខ្លួន ក្នុងកំឡុងពេលដំណើរការនីតិវិធីមជ្ឈតការ មជ្ឈត្តករជំនួសមួយរូបនឹងត្រូវបានតែងតាំង ឬជ្រើសរើសស្របតាមនីតិវិធីដូចមានចែងក្នុងមាត្រា៦ ដល់៩ ដូចដែលបានអនុវត្តចំពោះការតែងតាំង ឬជ្រើសរើសមជ្ឈត្តករដែលគេជំនួសនោះ ។

២. ក្នុងករណីដែលមជ្ឈត្តករខកខានមិនបានធ្វើកិច្ចការ ឬពុំមានលទ្ធភាពក្នុងការបំពេញមុខងាររបស់ខ្លួនដោយ*ហេតុផលច្បាប់* ឬ*ហេតុផលជាក់ស្តែង*ណាមួយ នីតិវិធីទាក់ទងនឹងការជំទាស់ និងការផ្លាស់ប្តូរមជ្ឈត្តករដូចមាន ចែងនៅក្នុងមាត្រាទាំងឡាយស្តីពីដំណើរការនេះនឹងត្រូវលើកយកមកប្រើប្រាស់ ។

**ការធ្វើសវនាការឡើងវិញក្នុងករណីមានការផ្លាស់ប្តូរមជ្ឈត្តករ**

**មាត្រា ១៤**

ប្រសិនបើមជ្ឈត្តករតែមួយរូប ឬមជ្ឈត្តករអធិបតីណាមួយត្រូវបានផ្លាស់ប្តូរ តាមមាត្រា១១ ដល់មាត្រា ១៣ សវនាការទាំងឡាយណាដែលធ្វើឡើងពីមុនមកនឹងត្រូវធ្វើឡើងសារជាថ្មី ហើយប្រសិនបើមានមជ្ឈត្តករផ្សេងទៀត ត្រូវបានប្តូរដែរនោះ សវនាការពីមុនដទៃទៀតអាចធ្វើឡើងជាថ្មីបានក្រោមឆន្ទានុសិទ្ធិ នៃវេទិកាមជ្ឈត្តកម្មទាំងមូល ។

## ផ្នែកទី III - នីតិវិធីមជ្ឈត្តការ

**បទប្បញ្ញត្តិទូទៅ**

**មាត្រា ១៥**

១. ដោយអនុលោមតាមបទប្បញ្ញតិនេះ វេទិកាមជ្ឈត្តកម្មអាចធ្វើមជ្ឈត្តការតាមរបៀបដែលខ្លួនយល់ឃើញថាសមស្រប ដោយត្រូវមានការប្រព្រឹត្តចំពោះភាគីវិវាទប្រកបដោយសមភាព ហើយទោះជាស្ថិត

ក្នុងដំណាក់កាលណាមួយនៃដំណើរការក៏ដោយ ត្រូវផ្តល់ឱកាសយ៉ាងពេញលេញដល់ភាគីនីមួយៗ ក្នុងការបង្ហាញរឿងហេតុរបស់ខ្លួន។

២. ប្រសិនបើមានការស្នើសុំដូច្នោះពីភាគីណាមួយ នៅក្នុងដំណាក់កាលណាមួយនៃដំណើរការមជ្ឈត្តការ វេទិកាមជ្ឈត្តកម្មត្រូវផ្អាកសវនាការរបស់ខ្លួន ដើម្បីផ្តល់លទ្ធភាពឱ្យសាក្សីទាំងអស់ រួមទាំងសាក្សីជំនាញផង ធ្វើការបង្ហាញភស្តុតាង ឬទឡ្ហីករណ៍ផ្ទាល់មាត់។ ប្រសិនបើគ្មានសម្ទើបែបនោះទេ វេទិកាមជ្ឈត្តកម្មត្រូវសម្រេចថាតើត្រូវផ្អាកដំណើរការមជ្ឈត្តការ ឬគួរបន្តដំណើរការនោះឬទេ ដោយផ្អែកលើមូលដ្ឋានឯកសារ និងសំណៅដទៃទៀត។

៣. ឯកសារ ឬព័ត៌មានទាំងអស់ដែលភាគីម្ខាងផ្តល់ដល់វេទិកាមជ្ឈត្តកម្ម ត្រូវតែបញ្ជូនព្រមគ្នាទៅកាន់ភាគីម្ខាងទៀតផងដែរ ដោយភាគីនោះ។

**ទីកន្លែងធ្វើមជ្ឈត្តការ**

**មាត្រា ១៦**

១. លើកលែងតែភាគីវិវាទបានព្រមព្រៀងគ្នាអំពីទីកន្លែងដែលមជ្ឈត្តការនឹងប្រព្រឹត្តទៅ ទីកន្លែងធ្វើមជ្ឈត្តការត្រូវកំណត់ដោយវេទិកាមជ្ឈត្តកម្ម ដោយផ្អែកទៅលើកាលៈទេសៈផ្សេងៗនៃមជ្ឈត្តការនោះ។

២. វេទិកាមជ្ឈត្តកម្មអាចកំណត់កន្លែងប្រព្រឹត្តទៅនៃមជ្ឈត្តការ នៅក្នុងប្រទេសដែលភាគីវិវាទបានព្រមព្រៀង។ វេទិកាមជ្ឈត្តកម្មក៏អាចសវនៈសាក្សី និងរៀបចំកិច្ចប្រជុំនានាដើម្បីឱ្យសមាជិករបស់ខ្លួនបានប្រឹក្សាយោបល់គ្នានៅទីកន្លែងណាក៏ដោយដែលខ្លួនយល់ថាសមស្រប យោងតាមកាលៈទេសៈផ្សេងៗនៃមជ្ឈត្តការនោះ។

៣. វេទិកាមជ្ឈត្តកម្មអាចជួបប្រជុំនៅទីកន្លែងណាក៏ដោយដែលខ្លួនយល់ថាសមស្រប ដើម្បីត្រួតពិនិត្យលើទំនិញ ទ្រព្យសម្បត្តិ ឬឯកសារដទៃទៀត។ ភាគីវិវាទត្រូវទទួលបានការជូនដំណឹងគ្រប់គ្រាន់ដើម្បីជួយសំរួលឱ្យពួកគេអាចមានវត្តមាននៅពេលធ្វើការត្រួតពិនិត្យនោះ។

៤. ការផ្តល់មជ្ឈត្តវិនិច្ឆ័យត្រូវធ្វើនៅទីកន្លែងធ្វើមជ្ឈត្តការ។

**ភាសា**

**មាត្រា ១៧**

១. បន្ទាប់ពីត្រូវបានតែងតាំងភ្លាម វេទិកាមជ្ឈត្តកម្មត្រូវកំណត់យកភាសាណាមួយ ឬភាសាណាខ្លះសម្រាប់ប្រើប្រាស់នៅក្នុងដំណើរការមជ្ឈត្តការ ដោយមានការព្រមព្រៀងពីភាគីវិវាទផង។ ការកំណត់នេះនឹងត្រូវលើកយកមកអនុវត្តនៅក្នុងបណ្តឹងទាមទារ បណ្តឹងដោះសារ និងបណ្តឹងបន្ថែមជាលាយ

លក្ខណ៍អក្សរដទៃទៀត ព្រមទាំងភាសាមួយ ឬច្រើន ដែលត្រូវយកមកប្រើក្នុងសវនាការផ្ទាល់មាត់នានា ប្រសិនបើសវនាការទាំងនោះត្រូវប្រព្រឹត្តឡើង។

២. វេទិកាមជ្ឈត្តកម្មអាចបង្គាប់ឱ្យមានការបកប្រែជាភាសាមួយ ឬច្រើន ដែលបានព្រមព្រៀងដោយភាគីវិវាទ ឬដែលបានកំណត់ដោយវេទិកាមជ្ឈត្តកម្មនោះ អមជាមួយឯកសារជាភាសាដើមទាំងឡាយណាដែលភ្ជាប់នឹងបណ្ដឹងទាមទារ ឬបណ្ដឹងដោះសារ ព្រមទាំងឯកសារ ឬសំណៅតាំងបង្ហាញផ្សេងៗដែលបានដាក់ឱ្យត្រួតពិនិត្យក្នុងកំឡុងពេលដំណើរការមជ្ឈត្តការ។

**បណ្ដឹងទាមទារ**

**មាត្រា ១៨**

១. ក្នុងថេរៈវេលាមួយដែលត្រូវបានកំណត់ដោយវេទិការពាណិជ្ជកម្ម ភាគីប្ដឹងត្រូវផ្ញើបណ្ដឹងទាមទាររបស់ខ្លួនជាលាយលក្ខណ៍អក្សរទៅកាន់ភាគីឆ្លើយតប និងទៅកាន់មជ្ឈត្តករនីមួយៗ លើកលែងតែបណ្ដឹងទាមទារនោះមានបញ្ចូលនៅក្នុងការជូនដំណឹងអំពីមជ្ឈត្តការរួចទៅហើយ។ ភាគីត្រូវភ្ជាប់មកជាមួយផងដែរ នូវខ្លឹមសារចម្លងនៃកិច្ចសន្យា ព្រមទាំងកិច្ចព្រមព្រៀងស្ដីពីមជ្ឈត្តការ ប្រសិនបើមិនមានចែងនៅក្នុងកិច្ចសន្យានោះទេ។

២. បណ្ដឹងទាមទារត្រូវរួមបញ្ចូលចំណុចលម្អិតដូចខាងក្រោម:

(ក) ឈ្មោះ និងអសយដ្ឋាននៃភាគីវិវាទទាំងអស់

(ខ) សេចក្ដីថ្លែងអង្គហេតុដែលគាំទ្រដល់ការទាមទារនោះ

(គ) ចំណុចទាំងឡាយដែលចោទជាបញ្ហា

(ឃ) ការអនុគ្រោះ ឬសំនងដែលចង់បាន

ភាគីប្ដឹងអាចភ្ជាប់ជាមួយបណ្ដឹងទាមទាររបស់ខ្លួន នូវឯកសារទាំងអស់ដែលខ្លួនយល់ថាមានជាប់ពាក់ព័ន្ធ ឬ បន្ថែមឯកសារយោងលើឯកសារ ឬភស្តុតាងដទៃទៀតដែលខ្លួននឹងដាក់ឱ្យត្រួតពិនិត្យ។

**បណ្ដឹងដោះសារ**

**មាត្រា ១៩**

១. ក្នុងថេរៈវេលាមួយដែលត្រូវបានកំណត់ឡើងដោយវេទិកាមជ្ឈត្តកម្ម ភាគីឆ្លើយតបត្រូវផ្ញើបណ្ដឹងដោះសាររបស់ខ្លួនជាលាយលក្ខណ៍អក្សរ ទៅភាគីប្ដឹង និងមជ្ឈត្តករគ្រប់រូប។

២. បណ្ដឹងដោះសារត្រូវឆ្លើយតបទៅនឹងចំនុចលម្អិត (ខ)(គ) និង (ឃ) នៃបណ្ដឹងទាមទារ (មាត្រា ១៨ កថាខ័ណ្ឌ ២)។ ភាគីឆ្លើយតបអាចភ្ជាប់ជាមួយបណ្ដឹងរបស់ខ្លួន នូវឯកសារដែលខ្លួនប្រើជាបង្អែកដើម្បីដោះសារ ឬអាចបន្ថែមសំណៅយោងលើឯកសារ ឬភស្តុតាងដទៃទៀតដែលខ្លួនដាក់ឱ្យពិនិត្យ។

៣. ភាគីឆ្លើយតបអាចធ្វើបណ្តឹងទាស់ចេញពីកិច្ចសន្យាដដែល ឬផ្អែកលើបណ្តឹងថ្មីមួយចេញពីកិច្ចសន្យាដដែលនោះដើម្បីទាមទារការទូទាត់ នៅក្នុងបណ្តឹងដោះសាររបស់ខ្លួន ឬនៅដំណាក់កាលក្រោយមកទៀត នៃដំណើរការមជ្ឈត្តការ ប្រសិនបើវេទិកាមជ្ឈត្តកម្មសម្រេចថាការពន្យានោះមានលក្ខណៈសមស្របតាមកាលៈទេសៈ។

៤. ប្បញ្ញត្តិក្នុងមាត្រា១៨ កថាខ័ណ្ឌ២ នឹងត្រូវយកមកប្រើលើបណ្តឹងទាស់ និងបណ្តឹងដែលគេធ្វើជាបង្អែកដើម្បីទាមទារការទូទាត់។

**ការកែប្រែបណ្តឹងទាមទារ ឬបណ្តឹងដោះសារ**

**មាត្រា ២០**

ក្នុងពេលដំណើរការមជ្ឈត្តការ ភាគីណាក៏អាចកែប្រែ ឬបំពេញលើបណ្តឹងទាមទារ ឬដោះសាររបស់ខ្លួនបានដែរ លើកលែងតែថាវេទិកាមជ្ឈត្តកម្មចាត់ទុកថាការអនុញ្ញាតិឱ្យមានកំណែរប្រែនោះ ជាការមិនគប្បីដោយពិចារណាទៅលើការអូសបន្លាយពេលដើម្បីធ្វើកំណែរប្រែនោះ ឬការលម្អៀងចំពោះភាគីម្ខាងទៀត ឬដោយសារកាលៈទេសៈដទៃទៀត។ យ៉ាងណាមិញគេមិនអាចកែប្រែបណ្តឹងមួយបានឡើយ បើសិនជាបណ្តឹងដែលបានកែប្រែនោះ ហួសពីដែនកំណត់នៃខស្តីពីមជ្ឈត្តការ ឬកិច្ចព្រមព្រៀងដោយឡែកស្តីពីមជ្ឈត្តការដែលមាន។

**ការជំទាស់ពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់វេទិកាមជ្ឈត្តកម្ម**

**មាត្រា ២១**

១.វេទិកាមជ្ឈត្តកម្មត្រូវមានអំណាចសម្រេចលើការជំទាស់ផ្សេងៗដែលថា ខ្លួនមិនមានសមត្ថកិច្ចដោះ-ស្រាយ រួមទាំងការជំទាស់ពាក់ព័ន្ធនឹងអត្ថិភាព ឬសុពលភាពនៃខស្តីពីមជ្ឈត្តការ ឬកិច្ចព្រមព្រៀងដោយឡែកស្តីពីមជ្ឈត្តការ ផងដែរ។

២. វេទិកាមជ្ឈត្តកម្មត្រូវមានសិទ្ធិសម្រេចលើអត្ថិភាព ឬសុពលភាពនៃកិច្ចសន្យាដែលក្នុងនោះមានខស្តីពីមជ្ឈត្តការជាផ្នែកមួយផងដែរ។ សម្រាប់មាត្រា២១នេះ ខស្តីពីមជ្ឈត្តការដែលជាផ្នែកនៃកិច្ចសន្យាណាមួយ ហើយដែលកំណត់ពីមជ្ឈត្តការស្របតាមវិធាននេះ ត្រូវចាត់ទុកជាកិច្ចព្រមព្រៀងឯករាជ្យពីលក្ខខ័ណ្ឌដទៃ ទៀតនៃកិច្ចសន្យានោះ។ សេចក្តីសម្រេចរបស់វេទិកាមជ្ឈត្តកម្មដែលចាត់ទុកកិច្ចសន្យានោះជាមោឃៈ នឹងមិនបណ្តាលឱ្យខស្តីពីមជ្ឈត្តការនោះមានទុពលភាពតាមវិធានច្បាប់ឡើយ។

៣. ទឡ្ហីករណ៍ណាមួយដែលថាវេទិកាមជ្ឈត្តកម្មពុំមានសមត្ថកិច្ចដោះស្រាយនោះ មិនត្រូវធ្វើក្រោយពេលធ្វើបណ្តឹងដោះសារ ឬបណ្តឹងតបទៅនឹងបណ្តឹងទាស់ណាមួយ ក្នុងករណីដែលមានបណ្តឹងទាស់នោះឡើយ។

៤. ជាទូទៅ វេទិកាមជ្ឈត្តកម្មត្រូវសម្រេចលើការជំទាស់ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួនជាមុនសិន។ យ៉ាងណាមិញ វេទិកាមជ្ឈត្តកម្មក៏អាចបន្តដំណើរការកិច្ចការមជ្ឈត្តការ ហើយសឹមសម្រេចលើការជំទាស់នោះ នៅក្នុងមជ្ឈត្តវិនិច្ឆ័យស្ថាពររបស់ខ្លួន ក៏បានដែរ។

**បណ្តឹងលាយលក្ខណ៍អក្សរបន្ថែមផងទៃទៀត**

**មាត្រា ២២**

វេទិកាមជ្ឈត្តកម្មត្រូវសម្រេចថា ក្រៅពីបណ្តឹងទាមទារ និងបណ្តឹងដោះសារ មានបណ្តឹងលាយលក្ខណ៍អក្សរបន្ថែមណាខ្លះទៀត ដែលខ្លួនត្រូវការ ឬដែលភាគីវិវាទអាចយកមកបង្ហាញបាន ហើយត្រូវកំណត់ថេរៈវេលាដើម្បីបញ្ជូនបណ្តឹងទាំងនោះមកផង។

**ថេរៈវេលាផ្សេងៗ**

**មាត្រា ២៣**

ពេលវេលាដែលកំណត់ដោយវេទិកាមជ្ឈត្តកម្ម សម្រាប់ការបញ្ជូនបណ្តឹងលាយលក្ខណ៍អក្សរផ្សេងៗ (រួមទាំងបណ្តឹងទាមទារ និងបណ្តឹងដោះសារ) មិនត្រូវលើសពីសែសិបប្រាំថ្ងៃឡើយ។ យ៉ាងណាមិញ វេទិកាមជ្ឈត្តកម្ម អាចពន្យាពេលកំណត់នេះប្រសិនបើខ្លួនសន្និដ្ឋានថា ការពន្យានោះមានភាពសមស្រប។

**ភស្តុតាង និងសវនាការ ( មាត្រា២៤ និង២៥)**

**មាត្រា ២៤**

១. ភាគីនិមួយៗត្រូវទទួលបន្ទុកបង្ហាញអង្គហេតុដែលប្រើដើម្បីគាំទ្រការទាមទារ ឬដោះសាររបស់ខ្លួន។

២. ប្រសិនបើខ្លួនយល់ថាសមស្រប វេទិកាមជ្ឈត្តកម្មអាចទាមទារឱ្យភាគីណាមួយផ្តល់មកឱ្យខ្លួន និងភាគីម្ខាងទៀត នូវខ្លឹមសារសង្ខេបនៃឯកសារ និងភស្តុតាង ដទៃទៀតដែលភាគីនោះត្រៀមនឹងបង្ហាញជាការគាំទ្រដល់អង្គហេតុដែលចោទជាបញ្ហា ដូចមានរៀបរាប់នៅក្នុងបណ្តឹងទាមទារ ឬបណ្តឹងដោះសារ នៅក្នុងរយៈពេលមួយដែលវេទិការមជ្ឈត្តកម្មនោះបានកំណត់។

៣. នៅខណៈពេលណាក៏ដោយក្នុងដំណើរការមជ្ឈត្តការ វេទិកាមជ្ឈត្តកម្មអាចតម្រូវឱ្យភាគីទាំងអស់រៀបចំឯកសារ សំណៅតាំងបង្ហាញ ឬភស្តុតាងដទៃទៀតតាមថេរៈវេលាដែលខ្លួនកំណត់។

**មាត្រា ២៥**

១. ក្នុងករណីមានសវនាការផ្ទាល់មាត់ វេទិកាមជ្ឈត្តកម្មត្រូវផ្តល់ការជូនដំណឹងជាមុន ដល់ភាគីវិវាទអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងឱ្យបានសមល្មម។

២. បើមានសាក្សីនានាត្រូវចូលរួមសវនាការ ភាគីនិមួយៗត្រូវបញ្ជូនព័ត៌មានមកកាន់វេទិកាមជ្ឈត្តកម្ម និងភាគីម្ខាងទៀត យ៉ាងតិចដប់ប្រាំថ្ងៃមុនពេលសវនាការ ក្នុងនោះរួមមានឈ្មោះ និងអសយដ្ឋានរបស់

សាក្សីដែលខ្លួនត្រៀមយកមកបង្ហាញ កម្មវត្ថុ និងភាសាទាំងអស់ដែលសាក្សីទាំងនោះនឹងប្រើនៅក្នុងកសិណរបស់ខ្លួន។

៣. វេទិកាមជ្ឈត្តកម្មត្រូវរៀបចំឱ្យមានការបកប្រែពំនោលផ្ទាល់មាត់ដែលធ្វើឡើងក្នុងសវនាការ និងត្រូវឱ្យមានកំណត់ហេតុនៃសវនាការ ប្រសិនបើខ្លួនចាត់ថាទាំងពីរយ៉ាងនេះគឺជាការចាំបាច់ ផ្អែកលើកាលៈទេសៈនៃរឿងក្តីនោះ ឬប្រសិនបើភាគីទាំងអស់បានព្រមព្រៀងលើចំនុចនេះ ហើយបានផ្ញើការព្រមព្រៀងនោះមកកាន់វេទិកាយ៉ាងតិចដប់ប្រាំថ្ងៃមុនពេលសវនាការ។

៤. លើកលែងតែភាគីវិវាទព្រមព្រៀងផ្សេងពីនេះ សវនាការត្រូវធ្វើឡើងជាអសាធារណៈ។ វេទិកា-មជ្ឈត្តកម្មអាចតម្រូវឱ្យសាក្សីម្នាក់ ឬច្រើននាក់ចាកចេញ ខណៈពេលសាក្សីដទៃទៀតផ្តល់កសិណរបស់ខ្លួន។ វេទិកាមជ្ឈត្តកម្មអាចកំណត់របៀបសាកសួរសាក្សីទាំងអស់ដោយសេរី ។

៥. គេក៏អាចយកមកបង្ហាញផងដែរនូវភស្តុតាងនៃកសិណសាក្សី ក្នុងទម្រង់ជាសេចក្តីថ្លែងការណ៍លាយ-លក្ខណ៍អក្សរ ដែលមានហត្ថលេខារបស់សាក្សីទាំងនោះ។

៦. វេទិកាមជ្ឈត្តកម្មត្រូវកំណត់លើ ភាពយកជាការបាន ភាពជាប់ពាក់ព័ន្ធ សម្ភារភាព ក៏ដូចជាទម្ងន់របស់ភស្តុតាងដែលបានផ្តល់ឱ្យ ។

**វិធានការបណ្តោះអាសន្នដើម្បីការពារ**

**មាត្រា ២៦**

១. តាមការស្នើសុំពីភាគីវិវាទណាមួយ វេទិកាមជ្ឈត្តកម្មអាចចាត់វិធានការបណ្តោះអាសន្នផ្សេងៗដែលខ្លួនចាត់ថាការចាំបាច់យោងតាមកម្មវត្ថុនៃវិវាទ រួមទាំងវិធានការដើម្បីថែរក្សាទំនិញដែលបង្កើតបានជាកម្មវត្ថុនៃវិវាទ ដូចជាការបញ្ជាឱ្យតម្កល់ទំនិញទាំងនោះជាមួយតតិយជនណាម្នាក់ ឬឱ្យលក់ចេញនូវទំនិញដែលឆាប់ខូចជាដើម។

២. វិធានការបណ្តោះអាសន្នទាំងនេះ អាចត្រូវបានធ្វើឡើងក្នុងទម្រង់ជាមជ្ឈត្តវិនិច្ឆ័យបណ្តោះអាសន្ន។ វេទិកាមជ្ឈត្តកម្មមានសិទ្ធិតម្រូវឱ្យមានប្រាតិភោគ សម្រាប់ធានាលើការចំណាយនៃវិធានការទាំងនេះ។

៣. សម្មើដែលភាគីណាមួយធ្វើទៅកាន់អាជ្ញាធរតុលាការ ដើម្បីសុំវិធានការបណ្តោះអាសន្ន មិនត្រូវបានចាត់ទុកថាវិសមិតជាមួយកិច្ចព្រមព្រៀងមជ្ឈត្តការ ឬជាការបដិសេធចោលកិច្ចព្រមព្រៀងនោះទេ។

**ចំនាញការ**

**មាត្រា ២៧**

១. វេទិកាមជ្ឈត្តកម្មអាចតែងតាំងជំនាញការមួយឬច្រើនរូប ដើម្បីរាយការណ៍មកខ្លួន ជាលាយលក្ខណ៍-អក្សរ លើបញ្ហាលម្អិតមួយចំនួនដែលកំណត់ដោយវេទិកានោះ។ ច្បាប់ចម្លងនៃលក្ខខ័ណ្ឌការងាររបស់ជំនាញការដែលវេទិកាបានរៀបចំឡើង នឹងត្រូវផ្ញើទៅកាន់ភាគីវិវាទទាំងអស់។

២. ភាគីទាំងអស់ត្រូវផ្តល់ដល់ជំនាញការនូវព័ត៌មានពាក់ព័ន្ធ ឬរៀបចំ សម្រាប់ការត្រួតពិនិត្យរបស់ជំនាញការ នូវឯកសារ ឬទំនិញតាមការតម្រូវរបស់ជំនាញការនោះ។ រាល់វិវាទរវាងភាគីណាមួយជាមួយជំនាញការ លើភាពជាប់ពាក់ព័ន្ធនៃព័ត៌មាន ឬផលិតកម្មដែលបានតម្រូវនោះ ត្រូវបញ្ជូនមកវេទិកាមជ្ឈត្តកម្មធ្វើការសម្រេច ។

៣. នៅពេលទទួលបានរបាយការណ៍របស់ជំនាញការ វេទិកាមជ្ឈត្តកម្មត្រូវផ្ញើច្បាប់ចម្លងនៃរបាយការណ៍នោះទៅកាន់ភាគីវិវាទ ដែលនឹងត្រូវបានផ្តល់ឱកាសឱ្យបង្ហាញពីទស្សនៈរបស់ខ្លួនជាលាយលក្ខណ៍អក្សរតបនឹងរបាយការណ៍នោះ។ ភាគីវិវាទមានសិទ្ធិត្រួតពិនិត្យមើលឯកសារទាំងឡាយណាដែលជំនាញការប្រើប្រាស់សំរាប់សរសេររបាយការណ៍របស់ខ្លួន ។

៤. តាមការស្នើសុំពីភាគីណាមួយ បន្ទាប់ពីបានបញ្ជូនរបាយការណ៍របស់ខ្លួនរួច អ្នកជំនាញការអាចចូលបំភ្លឺក្នុងសវនាការ ដែលក្នុងនោះភាគីវិវាទនឹងមានឱកាសចូលរួម និងចោទសួរអ្នកជំនាញការនោះ។ ក្នុងសវនាការនេះ ភាគីនិមួយៗអាចបង្ហាញសាក្សីជំនាញដើម្បីធ្វើកសិណលើចំនុចដែលជាបញ្ហាឡើង។ បទប្បញ្ញត្តិនៃមាត្រា ២៥ អាចយកមកអនុវត្តបានក្នុងនីតិវិធីនេះ។

**ការខកខាន**

**មាត្រា ២៨**

១. ប្រសិនបើ ក្នុងថេរៈវេលាមួយដែលកំណត់ដោយវេទិកាមជ្ឈត្តកម្ម ភាគីប្តឹងមិនបានដាក់បណ្តឹងទាម-ទាររបស់ខ្លួន ដោយមិនបានបង្ហាញមូលហេតុនៃការខកខាននោះឱ្យបានគ្រប់គ្រាន់ វេទិកាមជ្ឈត្តកម្មត្រូវចេញដីការបង្គាប់ឱ្យបញ្ឈប់ដំណើរការមជ្ឈត្តការនោះ។ ប្រសិនបើ ក្នុងថេរៈវេលាមួយដែលកំណត់ដោយវេទិកាមជ្ឈត្តកម្ម ភាគីឆ្លើយតបមិនបានផ្ញើបណ្តឹងដោះសាររបស់ខ្លួន ដោយមិនបានបង្ហាញមូលហេតុនៃការខកខាននោះឱ្យបានគ្រប់គ្រាន់ វេទិកាមជ្ឈត្តកម្មត្រូវចេញដីការបង្គាប់ឱ្យបន្តដំណើរការមជ្ឈត្តការនោះតទៅទៀត។

២. ប្រសិនបើភាគីវិវាទមិនបានបង្ហាញខ្លួននៅសវនាការ ដោយមិនបានបង្ហាញ មូលហេតុនៃការខកខាននោះឱ្យបានគ្រប់គ្រាន់ វេទិកាមជ្ឈត្តកម្មអាចបន្តដំណើរការមជ្ឈត្តការនោះបាន ។

៣. បន្ទាប់ពីបានទទួលការជូនដំណឹងតាមវិធាននេះរួច ប្រសិនបើ ក្រោយពីត្រូវបានកោះហៅឱ្យរៀបចំឯកសារជាភស្តុតាង ក្នុងថេរៈវេលាមួយដែលបានកំណត់ មានភាគីណាមួយមិនបានធ្វើតាម ដោយមិនបាន

បង្ហាញមូលហេតុនៃការខកខាននោះឱ្យបានគ្រប់គ្រាន់ វេទិកាមជ្ឈត្តកម្មអាចធ្វើមជ្ឈត្តវិនិច្ឆ័យផ្អែកលើភស្តុតាងដែលមានចំពោះមុខនៅពេលនោះ។

**ការបិទសវនាការ**

**មាត្រា ២៩**

១. វេទិកាមជ្ឈត្តកម្មអាចសួរទៅភាគីវិវាទ ប្រសិនបើពួកគេមានភស្តុតាងដទៃទៀតដែលត្រូវបង្ហាញ ឬសាក្សីដទៃទៀតដែលត្រូវសវនៈ ឬឯកសារដទៃទៀតដែលត្រូវដាក់ឱ្យត្រួតពិនិត្យ ប្រសិនបើពុំមានទេ វេទិការមជ្ឈត្តកម្មអាចប្រកាសបិទសវនាការបាន។

២. ក្នុងកាលៈទេសៈពិសេសដែលខ្លួនយល់ឃើញថាមានការចាំបាច់ វេទិកាមជ្ឈត្តកម្មអាចសម្រេចដោយមតិរបស់ខ្លួន ឬនៅពេលមានភាគីណាមួយស្នើឡើង ដើម្បីបើកសវនាការជាថ្មីទៀតនាពេលណាមួយមុនពេលធ្វើមជ្ឈត្តវិនិច្ឆ័យ។

**ការលើកលែងចំពោះវិធានផ្សេងៗ**

**មាត្រា ៣០**

បើមានភាគីណាមួយដឹងថាមានប្បញ្ញត្តិ ឬតម្រូវការណាមួយនៃវិធានទាំងនេះមិនត្រូវបានគេអនុវត្តតាម ប៉ុន្តែនៅតែបន្តធ្វើមជ្ឈត្តការ ដោយពុំបានសំដែងការជំទាស់របស់ខ្លួនភ្លាមៗចំពោះការមិនអនុវត្តតាមនោះ នឹងត្រូវចាត់ទុកថាបានបាត់បង់សិទ្ធិជំទាស់របស់ខ្លួន។

**ផ្នែកទី IV: មជ្ឈត្តវិនិច្ឆ័យ**

**ការសម្រេចផ្សេងៗ**

**មាត្រា ៣១**

១. នៅដែលពេលមានមជ្ឈត្តករ៣រូប មជ្ឈត្តវិនិច្ឆ័យ ឬសេចក្តីសម្រេចដទៃទៀតរបស់វេទិកាមជ្ឈត្តកម្មនឹងធ្វើត្រូវឡើងដោយមតិភាគច្រើននៃមជ្ឈត្តករ។

២. នៅពេលដែលគ្មានមតិភាគច្រើន ឬពេលដែលវេទិកាមជ្ឈត្តកម្មសម្រេចយ៉ាងដូច្នេះ មជ្ឈត្តករអធិបតីអាចធ្វើការសម្រេចដោយឯកច្ឆ័ន្ទក្នុងករណីមានបញ្ហាផ្នែកនីតិវិធី លើកលែងតែមានការសើរើឡើងវិញដោយវេទិកាមជ្ឈត្តកម្មនោះ។

**ទម្រង់ និងអានុភាពនៃមជ្ឈត្តវិនិច្ឆ័យ**

**មាត្រា ៣២**

១. ក្រៅពីមជ្ឈត្តវិនិច្ឆ័យស្ថាពរ វេទិកាមជ្ឈត្តកម្មមានសិទ្ធិធ្វើមជ្ឈត្តវិនិច្ឆ័យបណ្តោះអាសន្ន ឬមជ្ឈត្តវិនិច្ឆ័យរបៀប ឬមជ្ឈត្តវិនិច្ឆ័យមិនពេញលេញ។

២. មជ្ឈត្តវិនិច្ឆ័យត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ព្រមទាំងមានលក្ខណៈស្ថាពរ និងភ្ជាប់កាតព្វកិច្ច ចំពោះភាគីវិវាទ ។ ភាគីវិវាទមានតួនាទីត្រូវអនុវត្តនូវមជ្ឈត្តវិនិច្ឆ័យនោះដោយឥតបង្អង់ឡើយ ។

៣. វេទិកាមជ្ឈត្តកម្មនឹងបញ្ជាក់ហេតុផលនានាដែលមជ្ឈត្តវិនិច្ឆ័យនោះសម្អាងលើ លើកលែងតែភាគីវិវាទឯកភាពថាមិនបាច់បញ្ជាក់ហេតុផលទាំងនោះ ។

៤. មជ្ឈត្តវិនិច្ឆ័យត្រូវតែបានចុះហត្ថលេខាដោយមជ្ឈត្តករ ហើយត្រូវមានចុះកាលបរិច្ឆេទ និងទីកន្លែងដែលធ្វើមជ្ឈត្តវិនិច្ឆ័យនោះផង។ នៅពេលដែលមានមជ្ឈត្តករបីរូប ហើយមួយរូបមិនបានចុះហត្ថលេខា មជ្ឈត្តវិនិច្ឆ័យត្រូវបញ្ជាក់ពីហេតុផលដែលនាំឱ្យមានអវត្តមាននៃហត្ថលេខានោះផង។

៥. មជ្ឈត្តវិនិច្ឆ័យអាចធ្វើឡើងជាសាធារណៈបាន លុះត្រាតែមានការយល់ព្រមពីភាគីទាំងពីរប៉ុណ្ណោះ។

៦. វេទិកាមជ្ឈត្តកម្មត្រូវផ្ញើច្បាប់ចម្លងនៃមជ្ឈត្តវិនិច្ឆ័យ ដែលបានចុះហត្ថលេខាដោយមជ្ឈត្តករទាំង-អស់ ទៅកាន់ភាគីវិវាទ។

៧. ប្រសិនបើច្បាប់មជ្ឈត្តការនៃប្រទេសដែលមជ្ឈត្តវិនិច្ឆ័យត្រូវបានធ្វើឡើង តម្រូវឱ្យវេទិកាមជ្ឈត្ត-កម្មចងក្រងជាឯកសារ ឬចុះបញ្ជីមជ្ឈត្តវិនិច្ឆ័យនោះ វេទិកាមជ្ឈត្តកម្មត្រូវអនុវត្តតាមតម្រូវការនោះ ក្នុងថេរៈវេលាដែលច្បាប់នោះបានកំណត់។

**ប្រព័ន្ធច្បាប់សម្រាប់អនុវត្ត ការស្រុះស្រួល**

១. វេទិកាមជ្ឈត្តកម្មត្រូវអនុវត្តច្បាប់ ដែលភាគីវិវាទបានកំណត់ថាអាចអនុវត្តបានចំពោះកម្មវត្ថុនៃវិវាទនោះ។ ក្នុងករណីដែលភាគីវិវាទមិនបានធ្វើការកំណត់ដូច្នោះទេ វេទិកាមជ្ឈត្តកម្មត្រូវប្រើប្រាស់ច្បាប់ដែលកំណត់ឡើងតាមវិវាទនៃច្បាប់ នូវវិធានណាដែលខ្លួនចាត់ថាអាចអនុវត្តបាន ។

២. វេទិកាមជ្ឈត្តកម្មអាចសម្រេចតាមការស្រុះស្រួល ឬតាមសមធម៌ លុះត្រាតែភាគីវិវាទផ្តល់សិទ្ធិយ៉ាងជាក់លាក់ឱ្យខ្លួនធ្វើដូច្នោះ ហើយច្បាប់សម្រាប់លើនីតិវិធីមជ្ឈត្តការនោះ អនុញ្ញាតិឱ្យធ្វើមជ្ឈត្តការរបៀបនោះបាន។

៣. នៅគ្រប់ករណីទាំងអស់ វេទិកាមជ្ឈត្តកម្មត្រូវធ្វើសេចក្តីសម្រេចស្របតាម លក្ខខ័ណ្ឌនាននៃកិច្ចសន្យា និងត្រូវយកមកពិចារណានូវរាល់ទម្លាប់ផ្នែកពាណិជ្ជកម្មនានាដែលអាចអនុវត្តបានចំពោះជំនួញនេះ។

**ការស្រុះស្រួល ឬចូលដ្ឋានដទៃទៀតដើម្បីបញ្ចប់វិវាទ**

**មាត្រា ៣៤**

១. ប្រសិនបើមុនពេលដែលមជ្ឈត្តវិនិច្ឆ័យត្រូវបានធ្វើឡើង ភាគីវិវាទឯកភាពលើដំណោះស្រាយណាមួយចំពោះវិវាទនោះ វេទិកាមជ្ឈត្តកម្មអាចចេញដីការបង្គាប់ដើម្បីបញ្ចប់ដំណើរការមជ្ឈត្តការនោះ ឬធ្វើកំណត់ត្រាដំណោះស្រាយនោះក្នុងទម្រង់ជា**មជ្ឈត្តវិនិច្ឆ័យដែលផ្អែកលើការស្រុះស្រួល** ប្រសិនបើមានការ

ស្នើសុំភាគីទាំងសង្ខាង ហើយវេទិកាមជ្ឈត្តកម្មនោះបានទទួលយល់ព្រម។ វេទិកាមជ្ឈត្តកម្មមិនចាំបាច់បញ្ជាក់ពីហេតុផលផ្សេងៗក្នុងការធ្វើមជ្ឈត្តវិនិច្ឆ័យប្រភេទនេះឡើយ ។

២. ប្រសិនបើមុនពេលដែលមជ្ឈត្តវិនិច្ឆ័យត្រូវបានធ្វើឡើង ការបន្តដំណើរការមជ្ឈត្តការប្រែជាមិនចាំបាច់ ឬមិនអាចទៅរួច ដោយសារមូលហេតុដែលមិនមានចែងក្នុងកថាខ័ណ្ឌ១ វេទិកាមជ្ឈត្តកម្មត្រូវជូនដំណឹងទៅភាគីវិវាទ អំពីគោលបំណងរបស់ខ្លួនដែលចង់ចេញដីការបង្គាប់បញ្ចប់ដំណើរការមជ្ឈត្តការនោះ។ វេទិកាមជ្ឈត្តកម្មមានសិទ្ធិក្នុងការចេញដីការបែបនេះ លើកលែងតែភាគីណាមួយមានមូលដ្ឋានសមស្របដើម្បីជំទាស់។

៣. វេទិកាមជ្ឈត្តកម្មត្រូវផ្ញើជូនភាគីវិវាទទាំងអស់ នូវច្បាប់ចម្លងនៃដីការបញ្ចប់ដំណើរការមជ្ឈត្តការ ឬ*មជ្ឈត្តវិនិច្ឆ័យដែលផ្អែកលើការស្រុះស្រួល* ដោយមានហត្ថលេខារបស់មជ្ឈត្តករទាំងអស់ផង។ ប្រសិនបើ**មជ្ឈត្តវិនិច្ឆ័យដែលផ្អែកលើការស្រុះស្រួល**ត្រូវបានធ្វើឡើង បទប្បញ្ញត្តិនៃមាត្រា៣២ កថាខ័ណ្ឌ២ និងកថាខ័ណ្ឌ៤ ដល់ ៧ នឹងត្រូវយកមកអនុវត្ត ។

**ការបកស្រាយមជ្ឈត្តវិនិច្ឆ័យ**

**មាត្រា ៣៥**

១. ក្នុងកំឡុងពេលសាមសិបថ្ងៃបន្ទាប់ពីបានទទួលមជ្ឈត្តវិនិច្ឆ័យរួចមក ភាគីម្ខាងអាចស្នើទៅវេទិកា-មជ្ឈត្តកម្ម ឱ្យធ្វើការបកស្រាយមជ្ឈត្តវិនិច្ឆ័យនោះ ដោយមានការជូនដំណឹងទៅភាគីម្ខាងទៀតផង។

២. ការបកស្រាយត្រូវធ្វើជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេលសែសិបប្រាំថ្ងៃបន្ទាប់ពីទទួលបានសម្នើ។ ការបកស្រាយត្រូវចាត់ចូលជាផ្នែកមួយនៃមជ្ឈត្តវិនិច្ឆ័យ ហើយប្បញ្ញត្តិនៃមាត្រា៣២ កថាខ័ណ្ឌ២ ដល់ ៧ នឹងត្រូវយកមកអនុវត្ត ។

**កំណែតម្រូវលើមជ្ឈត្តវិនិច្ឆ័យ**

**មាត្រា ៣៦**

១. ក្នុងកំឡុងពេលសាមសិបថ្ងៃបន្ទាប់ពីបានទទួលមជ្ឈត្តវិនិច្ឆ័យរួចមក ភាគីម្ខាងអាចស្នើទៅវេទិកា-មជ្ឈត្តកម្ម ដោយមានជូនដំណឹងទៅភាគីម្ខាងទៀតផង ឱ្យធ្វើកំណែរតម្រូវនៅក្នុងមជ្ឈត្តវិនិច្ឆ័យរាល់កំហុសផ្នែកកុំព្យូទ័រ កំហុសផ្នែកកិច្ចការរដ្ឋបាល និងកំហុសផ្នែកបោះពុម្ភ ឬកំហុសដទៃទៀតដែលមានលក្ខណៈស្រដៀងនោះ។ វេទិកាមជ្ឈត្តកម្មអាចធ្វើកំណែតម្រូវដោយគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ ក្នុងរយៈពេលសាមសិបថ្ងៃបន្ទាប់ពីបានផ្សព្វផ្សាយមជ្ឈត្តវិនិច្ឆ័យរួចមក។

២. កំណែរតម្រូវទាំងនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយប្បញ្ញត្តិនៃមាត្រា៣២ កថាខ័ណ្ឌ២ ដល់៧ នឹងត្រូវ យកមកអនុវត្ត។

### មជ្ឈត្តវិនិច្ឆ័យបន្ថែម

### មាត្រា ៣៧

១. ក្នុងរយៈពេលសាមសិបថ្ងៃបន្ទាប់ពីទទួលបានមជ្ឈត្តវិនិច្ឆ័យ ភាគីម្ខាង អាចស្នើទៅវេទិកាមជ្ឈត្តកម្ម ដោយមានការជូនដំណឹងទៅភាគីម្ខាងទៀតផង ឱ្យធ្វើមជ្ឈត្តវិនិច្ឆ័យបន្ថែម អំពីការទាមទារដែលបាន លើកឡើងក្នុងដំណើរការមជ្ឈត្តការ ប៉ុន្តែមិនបានដាក់ចូលនៅក្នុងមជ្ឈត្តវិនិច្ឆ័យនោះ។

២. ប្រសិនបើវេទិកាមជ្ឈត្តកម្មយល់ឃើញថាសម្នើសុំធ្វើមជ្ឈត្តវិនិច្ឆ័យបន្ថែមមានភាពត្រឹមត្រូវ ហើយ យល់ឃើញថាខ្លួនអាចកែតម្រូវលើចំនុចដែលបាត់បង់បាន ដោយមិនចាំបាច់មានសវនាការឬ ភស្តុតាង ដទៃទៀតនោះ វេទិកាមជ្ឈត្តកម្មត្រូវបំពេញមជ្ឈត្តវិនិច្ឆ័យរបស់ខ្លួនក្នុងរយៈពេលហុកសិបថ្ងៃ បន្ទាប់ពី ទទួលបានសម្នើ។

៣. នៅពេលធ្វើមជ្ឈត្តវិនិច្ឆ័យបន្ថែម ប្បញ្ញត្តិនៃមាត្រា៣២ កថាខ័ណ្ឌ២ដល់៧ នឹងត្រូវយកមកអនុវត្ត។

### ថ្លៃចំណាយផ្សេងៗ

### មាត្រា ៣៨

វេទិកាមជ្ឈត្តកម្មត្រូវកំណត់ក្នុងមជ្ឈត្តវិនិច្ឆ័យរបស់ខ្លួននូវថ្លៃចំណាយផ្សេងៗដើម្បីធ្វើមជ្ឈត្តការ។ ពាក្យ ថា "ថ្លៃចំណាយ" រួមមានត្រឹមតែ:

(ក) ថ្លៃឈ្នួលនៃវេទិកាមជ្ឈត្តកម្ម ដោយមានបញ្ជាក់កម្រៃសម្រាប់មជ្ឈត្តករនីមួយៗ ដោយឡែកពីគ្នា និង ត្រូវបានកំណត់ដោយវេទិកាមជ្ឈត្តកម្មផ្ទាល់ស្របតាមមាត្រា៣៩

(ខ) ថ្លៃធ្វើដំណើរ និងចំណាយដទៃទៀតរបស់មជ្ឈត្តករទាំងអស់

(គ) ថ្លៃដំបូន្មានជំនាញការ និងជំនួយដទៃទៀតដែលតម្រូវដោយវេទិកាមជ្ឈត្តកម្ម

(ឃ) ថ្លៃធ្វើដំណើរ និងចំណាយដ៏ទៃទៀតរបស់សាក្សី តាមកម្រិតដែលវេទិកាមជ្ឈត្តកម្មអនុម័ត

(ង) ថ្លៃចំណាយលើតំណាង និងជំនួយផ្នែកច្បាប់របស់ភាគីឈ្នះ ប្រសិនបើតម្លៃនោះត្រូវបានទាមទារក្នុង ពេលដំណើរការមជ្ឈត្តការ និងត្រឹមតែកម្រិតមួយដែលវេទិកាមជ្ឈត្តកម្មកំណត់ថាជាចំនួនសមរម្យ។

(ច) ថ្លៃឈ្នួល និងចំណាយផ្សេងៗរបស់អាជ្ញាធរតែងតាំង ក៏ដូចជាចំណាយផ្សេងៗរបស់អគ្គលេខាធិការ នៃតុលាការអចិន្ត្រៃយ៍ផ្នែកមជ្ឈត្តកម្មនាទីក្រុងឡាអេ។

### មាត្រា ៣៩

១. ថ្លៃឈ្នួលនៃវេទិកាមជ្ឈត្តកម្មត្រូវមានចំនួនសមរម្យ ដោយយកកត្តាចំនួនទឹកប្រាក់ក្នុងវិវាទ ភាព ស្មុំគស្មាញនៃបញ្ហា ពេលវេលាដែលមជ្ឈត្តករចំណាយ និងកាលៈទេសៈដទៃទៀតនៃរឿងក្តីនោះមកធ្វើការ ពិចារណាផងដែរ។

២. ប្រសិនបើអាជ្ញាធរតែងតាំងមួយត្រូវបានភាគីវិវាទព្រមបង្កើតឡើង ឬត្រូវបានជ្រើសតាំងដោយអគ្គ-លេខាធិការនៃតុលាការអចិន្ត្រៃយ៍ផ្នែកមជ្ឈត្តកម្មនាទីក្រុងឡាអេ ហើយប្រសិនបើអាជ្ញាធរនោះបានធ្វើតារាងតម្លៃសម្រាប់មជ្ឈត្តករនៅក្នុងរឿងក្តីអន្តរជាតិដែលខ្លួនគ្រប់គ្រង វេទិកាមជ្ឈត្តកម្មត្រូវយកតារាងតម្លៃនោះមកពិចារណាដើម្បីកំណត់ថ្លៃឈ្នួលរបស់ខ្លួន ក្នុងកម្រិតមួយដែលខ្លួនយល់ថាសមស្របនឹងកាលៈទេសៈនៃរឿងក្តី ។

៣. ប្រសិនបើអាជ្ញាធរតែងតាំងនោះមិនបានបង្កើតតារាងតម្លៃសម្រាប់មជ្ឈត្តករក្នុងរឿងក្តីអន្តរជាតិទេ ភាគីណាក៏បានអាចស្នើទៅអាជ្ញាធរតែងតាំង នៅពេលណាមួយ ឱ្យចេញសេចក្តីថ្លែងមួយដែលចែងពីអំពីមូលដ្ឋាននៃការយកថ្លៃឈ្នួលសម្រាប់ប្រើជាទំលាប់ក្នុងរឿងក្តីអន្តរជាតិនានាដែលអជ្ញាធរនោះតែងតាំង មជ្ឈត្តករឱ្យដោះស្រាយ ។ ប្រសិនបើអាជ្ញាធរតែងតាំងយល់ព្រមចេញសេចក្តីថ្លែងបែបនោះ វេទិកាមជ្ឈត្តកម្មត្រូវយកព័តិមានក្នុងនោះមកពិចារណាដើម្បីកំណត់ថ្លៃឈ្នួលរបស់ខ្លួន ក្នុងកំឬតមួយដែលខ្លួនយល់ថាសមស្របនឹងកាលៈទេសៈនៃរឿងក្តី ។

៤. នៅក្នុងករណីដែលបានលើកឡើងក្នុងកថាខ័ណ្ឌ២ និង៣ នៅពេលដែលមានសម្ណើពីភាគីម្ខាង ហើយអាជ្ញាធរតែងតាំងយល់ព្រមបំពេញនាទីនោះ មុននឹងកំណត់ថ្លៃឈ្នួលរបស់ខ្លួន វេទិកាមជ្ឈត្តកម្មត្រូវពិគ្រោះយោបល់ជាមួយអាជ្ញាធរតែងតាំងជាមុនសិន ដោយអជ្ញាធរនោះអាចផ្តល់យោបល់ទាំងឡាយណាដែល ខ្លួនចាត់ថាសមស្របចំពោះវេទិកាមជ្ឈត្តកម្មកម្មពាក់ព័ន្ធនឹងតម្លៃប្រាក់ឈ្នួលទាំងនោះ ។

**មាត្រា ៤០**

១. លើកលែងតែដូចមានចែងក្នុងកថាខ័ណ្ឌ២ ថ្លៃចំណាយលើមជ្ឈត្តការ ជាគោលការណ៍ ត្រូវទទួលបន្ទុកដោយភាគីដែលចាញ់។ យ៉ាងណាមិញ វេទិកាមជ្ឈត្តកម្មអាចបែងចែកបន្ទុកចំណាយឱ្យភាគីនិមួយៗ ប្រសិនបើខ្លួនយល់ថាមានលក្ខណៈសមស្រប ផ្អែកលើកាលៈទេសៈផ្សេងៗនៃរឿងក្តី ។

២. ពាក់ព័ន្ធនឹងការចំណាយលើតំណាង និងជំនួយផ្នែកច្បាប់ដូចមានចែងក្នុងមាត្រា៣៨ កថាខ័ណ្ឌ(ង) វេទិកាមជ្ឈត្តកម្មមានសេរីភាពក្នុងការសម្រេចថា ភាគីណាត្រូវទទួលបន្ទុកលើការចំណាយនោះ ឬក៏អាចបែងចែកបន្ទុកចំណាយនោះឱ្យភាគីនិមួយៗ ប្រសិនបើខ្លួនយល់ថាការបែងចែកនោះមានភាពសមហេតុសមផល ផ្អែកលើកាលៈទេសៈទាំងឡាយនៃរឿងក្តី ។

៣. នៅពេលចេញដីការបញ្ចប់ដំណើរការមជ្ឈត្តការ ឬធ្វើមជ្ឈត្តវិនិច្ឆ័យតាមការស្រុះស្រួល វេទិកា-មជ្ឈត្តកម្ម ត្រូវកំណត់ថ្លៃចំណាយលើមជ្ឈត្តការដូចមានចែងក្នុងមាត្រា៣៨ និងមាត្រា៣៩ កថាខ័ណ្ឌ១ នៅក្នុងដីការ ឬមជ្ឈត្តវិនិច្ឆ័យនោះ ។

៤. វេទិកាមជ្ឈត្តកម្មមិនអាចយកថ្លៃឈ្នួលបន្ថែមសម្រាប់ការបកស្រាយ ឬការកែតម្រូវ ឬការបំពេញមជ្ឈត្តវិនិច្ឆ័យរបស់ខ្លួន ដូចមានចែងក្នុងមាត្រា៣៥ ដល់៣៧ បានឡើយ ។

**ការតម្កល់ប្រាក់ចំណាយ**

មាត្រា ៤១

១. នៅពេលចាប់បង្កើតឡើង វេទិកាមជ្ឈត្តកម្មអាចស្នើឱ្យភាគីនីមួយៗតម្កល់ប្រាក់ស្មើៗគ្នា សម្រាប់ថ្លៃចំណាយផ្សេងៗដូចមានចែងក្នុងមាត្រា ៣៨ កថាខ័ណ្ឌ (ក) (ខ) និង (គ) ។

២. ក្នុងពេលដំណើរការមជ្ឈត្តការ វេទិកាមជ្ឈត្តកម្មអាចស្នើប្រាក់តម្កល់បន្ថែមពីភាគីវិវាទ ។

៣. ប្រសិនបើមានអាជ្ញាធរតែងតាំងមួយ ត្រូវបានព្រមព្រៀងដោយភាគីវិវាទ ឬជ្រើសតាំងដោយ អគ្គលេខាធិការនៃតុលាការអចិន្ត្រៃយ៍ផ្នែកមជ្ឈត្តកម្មនាទីក្រុងឡាអេ និងនៅពេលមានសម្មើពីភាគីម្ខាង ហើយអាជ្ញាធរតែងតាំងយល់ព្រមបំពេញតួនាទីនោះ វេទិកាមជ្ឈត្តកម្មត្រូវពិគ្រោះយោបល់ជាមួយអាជ្ញាធរតែងតាំងនោះជាមុនសិន មុននឹងកំណត់តម្លៃប្រាក់តម្កល់ ឬប្រាក់តម្កល់បន្ថែម ដោយអជ្ញាធរនោះ អាចផ្តល់យោបល់ទាំងឡាយណាដែលខ្លួនចាត់ថាសមស្របចំពោះវេទិកាមជ្ឈត្តកម្ម ពាក់ព័ន្ធនឹងតម្លៃប្រាក់តម្កល់ ឬប្រាក់តម្កល់បន្ថែមទាំងនោះ ។

៤. ប្រសិនបើពុំមានការបង់ប្រាក់តម្កល់ដែលបានតម្រូវនោះ ឱ្យបានគ្រប់ចំនួន ក្នុងរយៈពេលសាមសិបថ្ងៃបន្ទាប់ពីបានទទួលសម្មើនោះទេ វេទិកាមជ្ឈត្តកម្មត្រូវជូនដំណឹងដល់ភាគីវិវាទដើម្បីឱ្យ ភាគីណាមួយអាចធ្វើការបង់ប្រាក់ដែលបានតម្រូវនោះ ។ ប្រសិនបើពុំមានការបង់ប្រាក់ទេ វេទិកាមជ្ឈត្តកម្មអាចបញ្ជាឱ្យពន្យាពេល ឬបញ្ចប់ដំណើរការមជ្ឈត្តការនោះ ។

៥. បន្ទាប់ពីធ្វើមជ្ឈត្តវិនិច្ឆ័យរួច វេទិកាមជ្ឈត្តកម្មត្រូវផ្តល់របាយការណ៍គណនេយ្យមួយដល់ភាគីវិវាទដែលបានបង់ប្រាក់តម្កល់ និងត្រូវប្រគល់សមតុល្យដែលមិនបានចំណាយដល់ភាគីទាំងនោះវិញ ។

---

ព័ត៌មានបន្ថែមអាចទទួលពី:

អគ្គលេខាធិការដ្ឋាន UNCITRAL

មជ្ឈមណ្ឌលអន្តរជាតិទីក្រុងវៀន

ប្រអប់សំបុត្រ P.O Box 500

A- 1400 ទីក្រុងវៀន ប្រទេសអូទ្រីស

ទូរស័ព្ទ: (+៤៣ ១) ២៦០៦០-៤០៦០

ហ្វាក់: (+៤៣ ១) ២៦០៦០- ៥៨១៣

អ៊ិនធឺណែត: http://www.uncitral.org

អ៊ីមែល: uncitral@uncitral.org

# ឧបសម្ព័ន្ធ ឃ

## ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មជ្ឈត្តករនៅក្នុងវិវាទពាណិជ្ជកម្ម
## ចូលជាធរមាននៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៤

**គោលការណ៍ទី១៖ មជ្ឈត្តករត្រូវរក្សាភាពសុចរិត និងយុត្តិធម៌នៃនីតិវិធីមជ្ឈត្តការ។**

**ក.** មជ្ឈត្តករមិនត្រឹមតែមានការទទួលខុសត្រូវចំពោះភាគីវិវាទប៉ុណ្ណោះទេ ប៉ុន្តែចំពោះដំណើរការមជ្ឈត្តការផងដែរ ហើយត្រូវប្រតិបត្តិតាមបទដ្ឋានកម្រិតខ្ពស់នៃក្រមសីលធម៌វិជ្ជាជីវៈ សំដៅរក្សាឱ្យបាននូវភាពសុចរិត និងយុត្តិធម៌ដំណើរការ។ ព្រមជាមួយគ្នានេះ មជ្ឈត្តករត្រូវស្គាល់ពីទំនួលខុសត្រូវរបស់ខ្លួនចំពោះសាធារណជន ចំពោះភាគីវិវាទដែលសិទ្ធិរបស់ពួកគេនឹងត្រូវយកមកសម្រេច និងចំពោះអ្នកពាក់ព័ន្ធដទៃទៀតនៅក្នុងដំណើរការ។ ទំនួលខុសត្រូវនេះអាចរួមបញ្ចូលទាំងការបម្រើឱ្យប្រយោជន៍សាធារណៈក្នុងនាមជាមជ្ឈត្តករទៅតាមការគួរផងដែរ។

**ខ.** បុគ្គលម្នាក់គួរព្រមទទួលតំណែងតាំងជាមជ្ឈត្តករ លុះត្រាណាដែលខ្លួន៖

(១) អាចបំពេញការងារដោយមិនលម្អៀង

(២) អាចបំពេញការងារដោយឯករាជ្យពីភាគីវិវាទ សាក្សីសក្ខានុភូត និងមជ្ឈត្តករដទៃ

(៣) មានសមត្ថភាពបំពេញការងារ និង

(៤) មានលទ្ធភាពចាប់ផ្តើមមជ្ឈត្តការស្របតាមលក្ខខណ្ឌតម្រូវនៃដំណើរការ និងអំណើះក្រោយមក អាចលះបង់ពេលវេលា និងផ្តល់ការយកចិត្តទុកដាក់បំពេញដំណើរការនោះទៅតាមការរំពឹងទុកដ៏សមស្របដែលភាគីវិវាទអាចនឹងមាន។

**គ.** បន្ទាប់ពីទទួលបានការតែងតាំង និងក្នុងកំឡុងពេលធ្វើជាមជ្ឈត្តករ បុគ្គលម្នាក់គួរជៀសវាងការចូលប្រឡូកក្នុងទំនាក់ទំនងផ្នែកជំនួញ ផ្នែកវិជ្ជាជីវៈ ឬទំនាក់ទំនងផ្ទាល់ខ្លួន ឬទទួលផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ឬផលប្រយោជន៍ផ្ទាល់ខ្លួនណាមួយ ដែលអាចបណ្តាលឱ្យប៉ះពាល់ដល់អនាគតិ ឬដែលមានហេតុផលអាចបណ្តាលឱ្យស្តែងចេញជាភាពលម្អៀង។ ក្នុងរយៈពេលមួយដែលសមស្រប បន្ទាប់ពីសម្រេចលើបណ្តឹងណាមួយរួច បុគ្គលទាំងឡាយដែលបានធ្វើជាមជ្ឈត្តករគួរជៀសវាង ការចូលប្រឡូកក្នុងទំនាក់ទំនង ឬទទួលផលប្រយោជន៍ ដូចខាងលើនៅក្នុងកាលៈទេសៈមួយដែលមានហេតុផលអាចបណ្តាលឱ្យស្តែងឡើងថា ខ្លួនបានទទួលឥទ្ធិពលនៅក្នុងការធ្វើមជ្ឈត្តការ តាមរយៈការប្រមើល ឬរំពឹងទុកពីទំនាក់ទំនង ឬផលប្រយោជន៍ នោះ។

អត្ថិភាពនៃបញ្ហា ឬកាលៈទេសៈណាមួយដែលបានរៀបរាប់ក្នុងកថាខណ្ឌ **គ** មិនបណ្តាលឱ្យវាងចាកពីក្រមសីលធម៌វិជ្ជាជីវៈឡើយសម្រាប់បុគ្គលណាមួយ ដែលទទួលធ្វើជាមជ្ឈត្តករដោយមានការយល់ព្រមពីភាគីវិវាទក្នុងការតែងតាំងជាមជ្ឈត្តករ ឬបន្តមុខងារខ្លួន បន្ទាប់ពីបានបង្ហាញរឿងរ៉ាវពាក់ព័ន្ធដូចខាងលើស្របតាមគោលការណ៍ទី II ។

**ឃ.** មជ្ឈត្តករគួរប្រកាន់ជំហរខ្លួនឱ្យមានភាពយុត្តិធម៌ចំពោះភាគីវិវាទទាំងអស់ ហើយមិនគួរមានភាពទោរទន់ដោយសារសម្ពាធខាងក្រៅ ការទាមទាររបស់សាធារណៈជន និងការភ័យខ្លាចចំពោះការរិះគន់ ឬប្រយោជន៍ផ្ទាល់ខ្លួនឡើយ។ មជ្ឈត្តករត្រូវតែជៀសវាងពីការប្រព្រឹត្ត និងពាក្យសម្តីដែលស្តែងចេញជាភាពលម្អៀងទៅរក ឬប្រឆាំងនឹងភាគីណាមួយ។

**ង.** នៅពេលដែលសិទ្ធិអំណាចមជ្ឈត្តករកើតចេញពីការព្រមព្រៀងរបស់ភាគីវិវាទ មជ្ឈត្តករមិនគួរធ្វើលើសពីសិទ្ធិអំណាចនោះ ឬធ្វើតិចជាងអ្វីដែលបានតម្រូវក្នុងការប្រើប្រាស់សិទ្ធិអំណាចនោះឱ្យបានពេលលេញនោះឡើយ។ នៅពេលដែលការព្រមព្រៀងរបស់ភាគីវិវាទមានចែងពីនីតិវិធីដើម្បីអនុវត្តតាមនៅក្នុងដំណើរការមជ្ឈត្តការ ឬយោងលើវិធានសំរាប់អនុវត្តតាមនោះ មជ្ឈត្តករមានកាតព្វកិច្ចក្នុងការបំពេញឱ្យស្របតាមនីតិវិធី ឬវិធានទាំងនោះ។ មជ្ឈត្តករនឹងមិនមានកាតព្វកិច្ចផ្នែកសីលធម៌វិជ្ជាជីវៈអ្វីឡើយ ក្នុងការគោរពតាមការព្រមព្រៀង នីតិវិធី ឬវិធានទាំងឡាយណាដែលមិនស្របច្បាប់ ឬដែលមជ្ឈត្តករយល់ឃើញថាមិនស្របជាមួយក្រមសីលធម៌វិជ្ជាជីវៈនេះ។

**ច.** មជ្ឈត្តករត្រូវដឹកនាំដំណើរការមជ្ឈត្តការ ក៏ដូចជាជំរុញឱ្យមានដំណោះស្រាយប្រកបដោយយុត្តិធម៌ និងប្រសិទ្ធភាព ចំពោះបញ្ហាដែលបានដាក់ឱ្យខ្លួនសម្រេច។ មជ្ឈត្តករគួរផ្តល់កិច្ចខិតខំប្រឹងប្រែងដ៏សមស្របក្នុងការទប់ស្កាត់ល្បិចពន្យារពេល ការរុករកគួនរបស់ភាគីវិវាទ ឬអ្នកចូលរួមដទៃទៀត ឬការរំលោភ ឬការបង្អាក់ដទៃទៀតក្នុងដំណើរការមជ្ឈត្តការ។

**ឆ.** កាតព្វកិច្ចផ្នែកសីលធម៌វិជ្ជាជីវៈរបស់មជ្ឈត្តករ ចាប់ផ្តើមនៅដែលពេលខ្លួនព្រមទទួលយកការតែងតាំង និងបន្តនៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការ។ ក្រៅពីនេះ ដូចដែលមានចែងនៅក្នុងក្រមនេះ កាតព្វកិច្ចសីលធម៌វិជ្ជាជីវៈមួយចំនួន ចាប់ផ្តើមនៅពេលដែលបុគ្គលម្នាក់ ត្រូវបានស្នើឱ្យធ្វើជាមជ្ឈត្តករ ហើយមួយចំនួនទៀតបន្តកើតមាន ក្រោយពេលសេចក្តីសម្រេចនៅក្នុងដំណើរការត្រូវបានផ្តល់ជូនដល់ភាគីវិវាទរួច។

**ជ.** នៅពេលដែលមជ្ឈត្តករម្នាក់ទទួលយកការតែងតាំងរួច មជ្ឈត្តករមិនគួរដកខ្លួន ឬបោះបង់ចោលការតែងតាំងឡើយលើកលែងតែចាំបាច់ត្រូវធ្វើដូច្នេះ ដោយសារមានកាលៈទេសៈឥតព្រាងទុកនានា ដែលតំរូវឱ្យការតែងតាំងមិនអាចបន្តបាន ឬមិនអាចអនុវត្តបាន។ នៅពេលដែលមជ្ឈត្តករម្នាក់ត្រូវទទួលការតបស្នងចំពោះសេវាកម្មរបស់ខ្លួន មជ្ឈត្តករនោះអាចដកខ្លួន ប្រសិនបើភាគីវិវាទខកខាន ឬជំទាស់ក្នុងការបង់សោហ៊ុយចំណាយ ដូចដែលបានព្រមព្រៀង។

**ឈ.** មជ្ឈត្តករដែលដកខ្លួនមុនពេលបញ្ចប់ដំណើរការមជ្ឈត្តការត្រូវបានបញ្ចប់ ដោយការផ្តួចផ្តើមរបស់មជ្ឈត្តករនោះ ឬដោយការស្នើឡើងរបស់ភាគីមួយ ឬច្រើន ត្រូវចាត់វិធានការសមស្របដើម្បីការពារផលប្រយោជន៍របស់ភាគីវិវាទនៅក្នុងមជ្ឈត្តការ ដូចជាការប្រគល់ជូនវិញនូវសម្ភារៈជាភស្តុតាង និង ការរក្សាការសម្ងាត់ជាដើម។

*យោបល់អំពីគោលការណ៍ទី I*

មជ្ឈត្តករដែលគេរំពឹងទុក មិនចាត់ថាមានអគតិ ឬភាពលម្អៀង ដោយសារតែខ្លួនមានការយល់ដឹងអំពីភាគីវិវាទ ច្បាប់សំរាប់អនុវត្ត ឬទំនៀមទម្លាប់ និងការប្រព្រឹត្តទៅនៃអាជីវកម្មដែលពាក់ព័ន្ធឡើយ។ មជ្ឈត្តករក៏អាចមានបទពិសោធន៍ ឬឯកទេសពិសេសនៅក្នុងវិស័យជំនួញ ពាណិជ្ជកម្ម ឬបច្ចេកវិទ្យាដែលពាក់ព័ន្ធនៅក្នុងដំណើរការមជ្ឈត្តការផងដែរ។ មជ្ឈត្តករមិនល្មើសនឹងគោលការណ៍នេះឡើយប្រសិនបើយោងតាមបទពិសោធន៍ ឬឯកទេសនេះ មជ្ឈត្តករមើលឃើញពីបញ្ហាទូទៅមួយចំនួន ដែលអាចកើតមាននៅក្នុងដំណើរការមជ្ឈត្តការ ប៉ុន្តែមជ្ឈត្តករអាចមិនបានវិនិច្ឆ័យជាមុនចំពោះ ការកំណត់ផ្នែកអង្គហេតុ ឬអង្គច្បាប់ណាមួយ ដើម្បីដោះស្រាយក្នុងកំឡុងពេលដំណើរការមជ្ឈត្តការ។

ក្នុងពេលធ្វើមជ្ឈត្តការ មជ្ឈត្តករអាចធ្វើការសំណេះសំណាលជាមួយនឹងភាគីវិវាទ ឬស្នាក្តីរបស់ពួកគេទាញចេញនូវទឡ្ហីកម្ម ឬអំណះអំណាងផ្សេងៗ ផ្តល់យោបល់អំពីច្បាប់ ឬភស្តុតាង ចេញសេចក្តីសម្រេចបណ្តោះអាសន្ន និងក្រៅពីនេះទៀត គឺអាចធ្វើការគ្រប់គ្រង ឬដឹកនាំមជ្ឈត្តការ។ សកម្មភាពទាំងនេះជាផ្នែកចំបងនៃដំណើរការមជ្ឈត្តការ។ កថាខណ្ឌ **ឃ** នៃគោលការណ៍ទី I មិនមានគោលបំណងរារាំង ឬក៏រិតចំពោះការពិភាក្សាពេញលេញអំពីបញ្ហានានា ក្នុងកំឡុងពេលដំណើរការមជ្ឈត្តការឬរបៀបគ្រប់គ្រងរបស់មជ្ឈត្តករលើដំណើរការនោះឡើយ។

**គោលការណ៍ទី៣ៈ មជ្ឈត្តករត្រូវបង្ហាញអំពីផលប្រយោជន៍ ឬទំនាក់ទំនងណាមួយដែលអាចប៉ះពាល់ដល់អនាគតិ ឬអាចស្តែងចេញជារូបភាពភាពលម្អៀង។**

**ក.** ជនទាំងឡាយដែលត្រូវបានស្នើសុំឱ្យធ្វើជាមជ្ឈត្តករ មុននឹងខ្លួនយល់ព្រម គួរបង្ហាញពីៈ

(១) ផលប្រយោជន៍ហិរញ្ញវត្ថុ ឬផលប្រយោជន៍ផ្ទាល់ខ្លួន ដោយផ្ទាល់ ឬដោយប្រយោលណាមួយ ដែលខ្លួនដឹង ចេញពីលទ្ធផលនៃមជ្ឈត្តការនោះ។

(២) ទំនាក់ទំនងផ្នែកហិរញ្ញវត្ថុ ជំនួញ វិជ្ជាជីវៈ ឬទំនាក់ទំនងផ្ទាល់ខ្លួន ដែលកំពុងកើតមាន ឬនៅក្នុងអតីតកាល ដែលខ្លួនបានដឹង និងដែលទំនងនឹងបណ្តាលឱ្យប៉ះពាល់ដល់អនាគតិ ឬបណ្តាលឱ្យមានកង្វះខាតនូវឯករាជភាព នៅក្នុងក្រសែភ្នែកភាគីណាមួយ។ ឧទាហរណ៍ មជ្ឈត្តករដែលគេរំពឹងទុក គួរប្រាប់ឱ្យគេដឹងពីទំនាក់ទំនងដូចខាងលើ ដែលខ្លួនមានជាមួយភាគី ឬមេធាវីរបស់ភាគី ឬសហមជ្ឈត្តករណាមួយ ឬជាមួយបុគ្គលណាម្នាក់ ដែលខ្លួនដឹងថានឹងត្រូវធ្វើជាសាក្សី។ មជ្ឈត្តករក៏ត្រូវប្រាប់ឱ្យគេដឹងពីទំនាក់ទំនងដូចខាងលើ ដែលពាក់ព័ន្ធជាមួយគ្រួសារ ឬសមាជិកក្នុងផ្ទះ ឬនិយោជកបច្ចុប្បន្ន ដៃគូ ឬអ្នករួមអាជីព ឬមុខជំនួញរបស់ខ្លួន ដែលខ្លួនអាចស្រាវជ្រាវឃើញតាមរយៈការខិតខំសមស្របនានា។

(៣) លក្ខណៈ និងទំហំនៃការយល់ដឹងជាមុនដែលខ្លួនមានពាក់ព័ន្ធនឹងវិវាទ និង

(៤) បញ្ហា ទំនាក់ទំនង ឬផលប្រយោជន៍ដទៃទៀត ដែលខ្លួនមានកាតព្វកិច្ចនឹងបង្ហាញតាមរយៈការព្រមព្រៀងរបស់ភាគីវិវាទ វិធាន ឬការអនុវត្តរបស់ស្ថាប័នមួយ ឬច្បាប់សំរាប់អនុវត្តដែលប្បញ្ញត្តិអំពីការបង្ហាញព័ត៌មានរបស់មជ្ឈត្តករ។

**ខ.** ជនទាំងឡាយណា ដែលត្រូវបានស្នើឱ្យទទួលយកការតែងតាំងជាមជ្ឈត្តករ ត្រូវផ្តល់កិច្ចខិតខំប្រឹងប្រែងសមស្របដើម្បីធ្វើឱ្យខ្លួនឯងបានដឹងអំពីផលប្រយោជន៍ ឬទំនាក់ទំនងទាំងឡាយដូចដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ**ក**។

**គ.** កាតព្វកិច្ចក្នុងការបង្ហាញព័ត៌មានពីផលប្រយោជន៍ឬ ទំនាក់ទំនងដូចមានរៀបរាប់នៅក្នុងកថាខណ្ឌ **ក** គឺជាកាតព្វកិច្ចបន្តរហូត ដែលតំរូវឱ្យអ្នកដែលទទួលការតែងតាំងជាមជ្ឈត្តករត្រូវបង្ហាញព័ត៌មានភ្លាម តាមដែលអាចអនុវត្តបាន អំពីផលប្រយោជន៍ ឬទំនាក់ទំនងទាំងនោះដែលនឹងអាចកើតមាន ឬដែលអាចគិតឬរកឃើញ នៅគ្រប់ដំណាក់កាលនៃដំណើរការមជ្ឈត្តការ។

**ឃ.** សេចក្តីមន្ទិលដែលថាតើការបង្ហាញព័ត៌មានត្រូវធ្វើឬមិនធ្វើ គួរត្រូវបានដោះស្រាយដោយប្រកាន់យកការបង្ហាញព័ត៌មាន។

**ង.** ការបង្ហាញព័ត៌មានគួរតែត្រូវបានធ្វើចំពោះភាគីទាំងអស់ វាលែងតែមាននីតិវិធីផ្សេងទៀតសម្រាប់ការបង្ហាញព័ត៌មាន ដែលមានចែងនៅក្នុងការព្រមព្រៀងរបស់ភាគីវិវាទ វិធាន ឬការ

អនុវត្តរបស់ស្ថាប័នណាមួយដែលអាចយកមកប្រើបាន ឬច្បាប់ដែលមានធរមាន។ ក្នុងករណីដែលមានមជ្ឈត្តករលើសពីម្នាក់ត្រូវបានតែងតាំងឡើង មជ្ឈត្តករម្នាក់ៗគួរផ្តល់ព័ត៌មានដល់មជ្ឈត្តករដទៃទៀតអំពីបញ្ហាទាំងអស់ដែលខ្លួនបានបង្ហាញ។

**ច.** ក្នុងករណីដែលភាគីវិវាទដឹងពីផលប្រយោជន៍ និងទំនាក់ទំនងនានារបស់បុគ្គលណាមួយហើយនៅតែចង់ឱ្យបុគ្គលនោះធ្វើជាមជ្ឈត្តករ បុគ្គលនោះអាចធ្វើជាមជ្ឈត្តករបានយ៉ាងត្រឹមត្រូវ។

**ឆ.** ប្រសិនបើភាគីវិវាទស្នើសុំឱ្យមជ្ឈត្តករម្នាក់ដកខ្លួនចេញ មជ្ឈត្តករនោះត្រូវតែធ្វើដូច្នោះ។ ប្រសិនបើមជ្ឈត្តករម្នាក់ត្រូវបានស្នើសុំឱ្យដកខ្លួន ដោយភាគីតិចជាងទាំងអស់ ដោយសារការចោទប្រកាន់ថាមានភាពលម្អៀង មជ្ឈត្តករគួរតែដកខ្លួនចេញ លើកលែងតែកាលៈទេសៈណាមួយក្នុងចំណោមខាងក្រោមនេះកើតមានៈ

(១) ការព្រមព្រៀងរបស់ភាគីវិវាទ ឬវិធានមជ្ឈត្តការដែលបានព្រមព្រៀងដោយភាគីទាំងអស់ ឬច្បាប់សំរាប់អនុវត្ត មានចែងពីនីតិវិធីសម្រាប់កំណត់ការជំទាស់ចំពោះមជ្ឈត្តករ ទោះក្នុងករណីណាក៏ដោយនីតិវិធីទាំងនោះត្រូវតែបានអនុវត្តតាម ឬ

(២) ក្នុងករណីពុំមាននីតិវិធីសំរាប់អនុវត្ត ប្រសិនបើមជ្ឈត្តករ បន្ទាប់ពីពិចារណាយ៉ាងល្អិតល្អន់ទៅលើបញ្ហានោះហើយ កំនត់ថាមូលហេតុសម្រាប់ការជំទាស់មិនមានទម្ងន់នោះទេ ហើយខ្លួននៅតែអាចដំណើរការ និងសម្រេចរឿងក្តីដោយអនាគតិ និងយុត្តិធម៌។

**ជ.** ក្នុងករណីការប្រតិបត្តិរបស់មជ្ឈត្តករដែលគេរំពឹងទុក តាមបទប្បញ្ញត្តិណាមួយនៃក្រមនេះតម្រូវឱ្យមានការបង្ហាញព័ត៌មានជាសម្ងាត់ ឬជាឯកសិទ្ធិ មជ្ឈត្តករដែលគេរំពឹងទុកត្រូវៈ

(១) ធានាឱ្យមានការស្ម័គ្រចិត្តពីសំណាក់បុគ្គលដែលផ្តល់ព័ត៌មាន ឬ ជាម្ចាស់ឯកសិទ្ធិ ឬ

(២) ដកខ្លួន។

## គោលការណ៍ទីIII: មជ្ឈត្តករគួរជៀសវាងអំពើឆ្គាំឆ្គង ឬការស្តែងឡើងនូវភាពឆ្គាំឆ្គងក្នុងការប្រាស្រ័យទាក់ទងជាមួយភាគីវិវាទ។

**ក.** ប្រសិនបើការព្រមព្រៀងណាមួយរបស់ភាគី ឬវិធានមជ្ឈត្តការដែលអាចអនុវត្តបានបង្កើតជារបៀបរបប ឬខ្លឹមសារនៃការប្រាស្រ័យទាក់ទងរវាងមជ្ឈត្តករ និងភាគីវិវាទ មជ្ឈត្តករត្រូវធ្វើតាមនីតិវិធីទាំងនោះ ទោះជាមានបញ្ញត្តិផ្ទុយណាមួយនៃកថាខណ្ឌ ខ និងគ ក៏ដោយ។

**ខ.** មជ្ឈត្តករ ឬមជ្ឈត្តករដែលគេរំពឹងទុក មិនត្រូវពិភាក្សាអំពីដំណើរការជាមួយភាគីណាមួយនៅពេលភាគីម្ខាងទៀតអវត្តមានឡើយ លើកលែងតែក្នុងកាលៈទេសៈណាមួយដូចខាងក្រោមៈ

(១) នៅពេលដែលការតែងតាំងមជ្ឈត្តករដែលគេរំពឹងទុកកំពុងស្ថិតនៅក្នុការពិចារណា មជ្ឈត្តករដែលគេរំពឹងទុកនោះ:

(ក) អាចសួរអំពីអត្តសញ្ញាណរបស់ភាគីវិវាទ ស្មាក្តី ឬសាក្សី និងលក្ខណៈទូទៅនៃរឿងក្តី និង

(ខ) អាចឆ្លើយតបនឹងការសួរនាំពីសំណាក់ភាគីណាមួយ ឬស្មាក្តីដែលគេចាត់ឱ្យសម្រេចលើភាពស័ក្តិសម និងលទ្ធភាពរបស់មជ្ឈត្តករក្នុងការទទួលការតែងតាំង។ នៅក្នុងកិច្ចសន្ទនាណាមួយបែបនេះ មជ្ឈត្តករដែលគេរំពឹងទុក អាចទទួលព័តិមានពីភាគីម្ខាង ឬស្មាក្តីរបស់គេដែលនឹងផ្តល់ព័តិមានអំពីចរឹតទូទៅនៃវិវាទ ប៉ុន្តែមិនគួរអនុញ្ញាតឱ្យគេពិភាក្សាអំពីគុណតម្លៃនានានៃរឿងក្តីនោះឡើយ។

(២) នៅក្នុងមជ្ឈត្តការដែលក្នុងនោះ មជ្ឈត្តករទាំងពីរដែលត្រូវបានតែងតាំងឡើងដោយភាគីវិវាទត្រូវបានរំពឹងឱ្យតែងតាំងមជ្ឈត្តករទីបីនោះ មជ្ឈត្តករនីមួយៗដែលត្រូវបានតែងតាំងដោយភាគីវិវាទអាចប្រឹក្សាជាមួយភាគីដែលតែងតាំងមជ្ឈត្តករនោះអំពីជម្រើសមជ្ឈត្តករទីបី។

(៣) នៅក្នុងមជ្ឈត្តការដែលមានមជ្ឈត្តករច្រើនតែងតាំងដោយភាគីវិវាទ មជ្ឈត្តករនីមួយៗដែលភាគីតែងតាំងអាចធ្វើការពិភាក្សាជាមួយនឹងភាគីដែលបានតែងតាំងខ្លួន អំពីការរៀបចំបង់ប្រាក់សគុណដល់មជ្ឈត្តករដែលភាគីនោះតែងតាំង។ ការដាក់ឱ្យពិនិត្យជាប្រចាំ នូវសម្មើលាយលក្ខណ៏អក្សរសម្រាប់ការបង់ប្រាក់សគុណ និងចំណាយនានាស្របនឹងការរៀបចំនោះ និងការឆ្លើយឆ្លងជាលាយលក្ខណ៏អក្សរពាក់ព័ន្ធតែនឹងសម្មើទាំងនោះ មិនចាំបាច់ផ្ញើទៅឱ្យភាគីម្ខាងទៀតឡើយ។

(៤) នៅក្នុងមជ្ឈត្តការដែលមានមជ្ឈត្តករច្រើនតែងតាំងដោយភាគីវិវាទ មជ្ឈត្តករនីមួយៗដែលភាគីតែងតាំងអាចធ្វើការពិភាក្សាជាមួយនឹងភាគីដែលបានតែងតាំងខ្លួន អំពីឋានៈរបស់មជ្ឈត្តករ (ដូចជាអព្យាក្រឹត ឬ មិនអព្យាក្រឹត) ដូចដែលបានសង្កេតនៅក្នុងកថាខណ្ឌ គ នៃគោលការណ៏ IX ។

(៥) ការពិភាក្សាអាចត្រូវបានធ្វើឡើងជាមួយភាគីដែលពាក់ព័ន្ធនឹងបញ្ហាចលនុបត្ថម្ភ ដូចជាការកំណត់ពេលវេលា និងទីតាំងសវនាការ ឬធ្វើការរៀបចំដទៃទៀតសម្រាប់ដំណើរការមជ្ឈត្តការ។ យ៉ាងណាមិញមជ្ឈត្តករនីមួយៗគួរជូនដំណឹងគ្នាភ្លាមៗអំពីការពិភាក្សា ហើយមិនគួរធ្វើការសំរេចចុងក្រោយទាក់ទងនឹងបញ្ហាដែលបានពិភាក្សា មុនពេលផ្តល់ឱកាសឱ្យភាគីអវត្តមាននីមួយៗបានបញ្ចេញទស្សនៈរបស់ខ្លួន ឬ

(៦) ប្រសិនបើភាគីម្ខាងអវត្តមានក្នុងសវនាការមួយ បន្ទាប់ពីបានទទួលបានការជូនដំណឹងយ៉ាងត្រឹមត្រូវ ឬប្រសិនបើភាគីទាំងអស់ព្រមព្រៀមយ៉ាងច្បាស់លាស់រួច មជ្ឈត្តករអាចពិភាក្សាអំពីរឿងក្តីជាមួយភាគីណាមួយដែលមានវត្តមានបាន។

គ. លើកលែងតែមានចែងផ្សេងពីនេះនៅក្នុងគោលការណ៍នេះ ក្នុងវិធានមជ្ឈត្តការដែលអាចអនុវត្តបាន ឬនៅក្នុងការព្រមព្រៀងរបស់ភាគី នៅពេលណាដែលមជ្ឈត្តករម្នាក់ឆ្លើយឆ្លងជាលាយលក្ខណ៍អក្សរ ជាមួយនឹងភាគីមួយ ក្នុងពេលជាមួយគ្នានេះដែរ មជ្ឈត្តករគួរច្បាប់ចម្លងមួយច្បាប់ទៅគ្រប់ភាគីដទៃទៀត ហើយនៅពេលណាដែលមជ្ឈត្តករម្នាក់ទទួលលិខិតឆ្លើយឆ្លងជាលាយលក្ខណ៍អក្សរទាក់ទងនឹងរឿងក្តីពីភាគីមួយ ដែលមិនបានផ្ញើទៅភាគីដទៃផ្សេងទៀត មជ្ឈត្តករនោះគួរផ្ញើ ឬទាមទារឱ្យលិខិតនោះបានផ្ញើទៅកាន់ភាគីដទៃទៀតផងដែរ ។

**គោលការណ៍ទីIV: មជ្ឈត្តករត្រូវដឹកនាំដំណើរការដោយយុត្តិធម៌និងសេចក្តីអំណត់ព្យាយាម ។**

ក. មជ្ឈត្តករត្រូវដឹកនាំដំណើរការនៅក្នុងរបៀបរបបមួយដែលគ្មានការលម្អៀង។ មជ្ឈត្តករត្រូវតែមានការអត់ធ្មត់ និងសុភាពរាបសារចំពោះភាគីវិវាទ អ្នកតំណាងរបស់ពួកគេ និងសាក្សីទាំងអស់ ហើយគួរលើកទឹកចិត្តឱ្យមាន ការតវ៉ាយាបទស្រដៀងគ្នាដោយអ្នកចូលរួមទាំងអស់ ។

ខ. មជ្ឈត្តករត្រូវផ្តល់ឱ្យភាគីទាំងអស់នូវសិទ្ធិបញ្ចេញយោបល់ និងទទួលបានការជូនដំណឹងត្រឹមត្រូវអំពីពេលវេលា និងទីកន្លែងនៃសវនាការណាមួយ ។ មជ្ឈត្តករត្រូវអនុញ្ញាតឱ្យភាគីនីមួយៗមានឱកាសស្មើគ្នាដើម្បីបង្ហាញភស្តុតាង និងទឡ្ហីករណ៍របស់ខ្លួន ។

គ. មជ្ឈត្តករមិនត្រូវបដិសេធឱកាសរបស់ភាគីណាមួយក្នុងការមានតំណាងដោយស្មាក្តី ឬដោយអ្នកដទៃទៀតដែលភាគីនោះបានជ្រើសរើស ។

ឃ. ប្រសិនបើ ភាគីណាមួយខកខានមិនបានបង្ហាញខ្លួន បន្ទាប់ពីបានទទួលការជូនដំណឹង ត្រឹមត្រូវមក មជ្ឈត្តករត្រូវបន្តធ្វើមជ្ឈត្តការនៅពេលខ្លួនត្រូវបានអនុញ្ញាតឱ្យធ្វើដូច្នេះ ប៉ុន្តែ ដរាបណាតែមានការអះអាងថា ការជូនដំណឹងសមស្របត្រូវបានផ្តល់ឱ្យចំពោះភាគីអវត្តមានតែ ប៉ុណ្ណោះ ។

ង. នៅពេលដែលមជ្ឈត្តករកំណត់ថាខ្លួនត្រូវការព័ត៌មានបន្ថែមលើ ព័ត៌មានទាំងឡាយដែលបានបង្ហាញដោយភាគីទាំងអស់ ដើម្បីធ្វើការសម្រេចលើរឿងក្តីនោះ មិនមែនជាការខុសទាស់អ្វីឡើយដែលមជ្ឈត្តករធ្វើការចោទសួរសំនួរបន្ថែម កោះហៅសាក្សី និង ស្នើសុំឯកសារ ឬភស្តុតាងដទៃទៀត រួមទាំងកសិណរបស់អ្នកជំនាញផងដែរ ។

ច. ទោះបីវាមិនមែនជាការខុសទាស់ក្តី ដែលមជ្ឈត្តករស្នើដល់ភាគីវិវាទពិភាក្សាអំពីលទ្ធភាពក្នុងការស្រុះស្រួល ឬប្រើសន្ធានកម្ម ឬដំណើរការដោះស្រាយវិវាទដទៃទៀតនោះ មជ្ឈត្តករមិនត្រូវដាក់សម្ពាធលើភាគីណាមួយឱ្យស្រុះស្រួល ឬប្រើប្រាស់ដំណើរការដោះស្រាយវិវាទដទៃ

ទៀតឡើយ។ មជ្ឈត្តករត្រូវមានវត្តមាន ឬចូលរួមតាមវិធីដទៃទៀត នៅក្នុងការពិភាក្សា ស្រុះស្រួល ឬដើរតួនាទីជាសន្ធានការីឡើយ លុះត្រាតែភាគីវិវាទបានស្នើសុំឱ្យធ្វើដូច្នោះ។

**ឆ.** សហមជ្ឈត្តករទាំងឡាយត្រូវផ្តល់ឱកាសពេញលេញឱ្យគ្នាទៅវិញទៅមកក្នុងការចូលរួម ក្នុងគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការ។

*យោបល់លើកថាខណ្ឌ ឆ:*

កថាខណ្ឌ**ឆ** នៃគោលការណ៍ទី IV មិនមានគោលបំណងរារាំងមជ្ឈត្តករ មិនឱ្យបំពេញមុខងារនៅក្នុងស្ថានភាពមួយចំនួនតូច (ដូចជាការសម្រេចលើបញ្ហាដែលបានរកឃើញ) ដែលត្រូវបានអនុញ្ញាតិដោយការព្រមព្រៀងរបស់ភាគីវិវាទ វិធាន ឬច្បាប់ដែលអាចអនុវត្តបាន ហើយក៏មិនរារាំងមជ្ឈត្តករភាគច្រើន មិនឱ្យដំណើរការផ្នែកណាមួយនៃមជ្ឈត្តការ ប្រសិនបើមជ្ឈត្តករណាមួយមិនអាច ឬគ្មានឆន្ទៈក្នុងការចូលរួម ហើយដែលវិធានការបែបនេះត្រូវបានអនុញ្ញាតិដោយការព្រមព្រៀងរបស់ភាគីវិវាទ ឬវិធានឬច្បាប់ដែលអាចអនុវត្តបាន។ គោលការណ៍នេះក៏មិនរារាំងភាគីម្ខាង មិនឱ្យស្នើសុំវិធានការបណ្តោះអាសន្នដែរ។

**គោលការណ៍ទីV: មជ្ឈត្តករគួរធ្វើសេចក្តីសម្រេចក្នុងលក្ខណៈយុត្តិធម៌ ឯករាជ្យ និងស្អិតល្អន់**

**ក.** បន្ទាប់ពីពិចារណាយ៉ាងប្រុងប្រយ័ត្នមក មជ្ឈត្តករគួរសម្រេចលើគ្រប់បញ្ហាទាំងអស់ដែលបានដាក់ឱ្យខ្លួនធ្វើការពិនិត្យសម្រេច។ មជ្ឈត្តករមិនគួរសម្រេចលើបញ្ហាផ្សេងទៀតឡើយ។

**ខ.** មជ្ឈត្តករគួរសម្រេចលើបញ្ហាទាំងអស់ឱ្យបានត្រឹមត្រូវ ប្រើសិទ្ធិសម្រេចសេចក្តីដោយឯករាជ្យ និងមិនត្រូវអនុញ្ញាតឱ្យសម្ពាធខាងក្រៅប៉ះពាល់ដល់ការសម្រេចចិត្តនោះឡើយ។

**គ.** មជ្ឈត្តករមិនគួរផ្ទេរករណីកិច្ចក្នុងការសម្រេចឱ្យដល់បុគ្គលណាម្នាក់ដទៃទៀតឡើយ។

**ឃ.** ក្នុងករណីដែលភាគីទាំងអស់ព្រមព្រៀងលើដំណោះស្រាយចំពោះបញ្ហាដែលវិវាទ ហើយស្នើសុំឱ្យមជ្ឈត្តករបញ្ចូលការព្រមព្រៀងនោះក្នុងមជ្ឈត្តវិនិច្ឆ័យ មជ្ឈត្តករអាចធ្វើដូច្នោះបាន ប៉ុន្តែមិនត្រូវបានដាក់កំហិតឱ្យធ្វើដូច្នោះឡើយលើកលែងតែខ្លួនមានការពេញចិត្តចំពោះភាពសមស្រប នៃលក្ខខណ្ឌស្រុះស្រួលនោះ។ នៅពេលណាដែលមជ្ឈត្តករបញ្ចូលការព្រមព្រៀងស្រុះស្រួលរបស់ភាគីវិវាទទៅក្នុងមជ្ឈតវិនិច្ឆ័យ មជ្ឈត្តករត្រូវបញ្ជាក់ក្នុងមជ្ឈត្តវិនិច្ឆ័យនោះថាជាការយោងទៅតាមការព្រមព្រៀងរបស់ភាគីវិវាទ។

**គោលការណ៍ទីVI: មជ្ឈត្តករគួរមានភាពស្មោះត្រង់ចំពោះទំនាក់ទំនងនៃទំនុកចិត្ត និងការរក្សាការសម្ងាត់ ដែលផ្សាភ្ជាប់នឹងតួនាទីនោះ**

**ក.** មជ្ឈត្តករមួយរូបស្ថិតនៅក្នុងទំនាក់ទំនងនៃទំនុកចិត្តចំពោះភាគីវិវាទ ហើយក្នុងពេលណាក៏ដោយ ខ្លួនមិនគួរប្រើប្រាស់ព័ត៌មានសម្ងាត់ដែលទទួលបាន នៅក្នុងកំឡុងពេលដំណើរការមជ្ឈត្តការដើម្បីទាញយកប្រយោជន៍ផ្ទាល់ខ្លួន ឬផលប្រយោជន៍សម្រាប់អ្នកដទៃ ឬធ្វើឱ្យត្រលប់ទៅប៉ះពាល់ដល់ ផលប្រយោជន៍របស់បុគ្គលម្នាក់ទៀតឡើយ ។

**ខ.** មជ្ឈត្តករគួររក្សាជាការសម្ងាត់នូវរាល់បញ្ហាទាំងអស់ដែលទាក់ទងនឹងដំណើរការ និងសេចក្តីសម្រេចនៃមជ្ឈត្តការ ។ មជ្ឈត្តករអាចទទួលបានជំនួយពីសហការី អ្នកជំនួយការស្រាវជ្រាវ ឬអ្នកដទៃទៀត ដែលមានទំនាក់ទំនងនឹងការឈានទៅដល់សេចក្តីសម្រេចរបស់ខ្លួន ប្រសិនបើមជ្ឈត្តករផ្តល់ព័ត៌មាន ទៅភាគីវិវាទអំពីការប្រើជំនួយបែបនេះ ហើយអ្នកទាំងនោះយល់ព្រមគោរពតាមបទប្បញ្ញត្តិនៅក្នុងគោលការណ៍នេះ ។

**គ.** ទោះជាពេលណាក៏ដោយ ក៏វាជាការមិនគប្បីឡើយ ដែលមជ្ឈត្តករជូនដំណឹងទៅអ្នកណាម្នាក់អំពីការសម្រេចចិត្តរបស់ខ្លួនមុនដល់ពេលដែលត្រូវជូនដំណឹងគ្រប់ភាគីទាំងអស់ ។ ក្នុងដំណើរការដែលមានមជ្ឈត្តករលើសពីម្នាក់ ទោះជាពេលណាក៏ដោយ ក៏វាជាការមិនគប្បីឡើយដែលមជ្ឈត្តករណាម្នាក់ ធ្វើការជូនព័ត៌មានដល់ភាគីណាមួយអំពីខ្លឹមសារនៃការរែកញែកពិភាក្សារបស់មជ្ឈត្តករទាំងអស់ ។ ក្រោយពេលដែលមជ្ឈត្តវិនិច្ឆ័យត្រូវបានចេញរួច វាជាការមិនគប្បីឡើយដែលមជ្ឈត្តករណាម្នាក់ជួយជំរុញឱ្យអនុវត្ត ឬជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យនោះ ក្នុងពេលមានដំណើរការមជ្ឈត្តការ ។

**ឃ.** លើកលែងតែមានការស្នើសុំពីភាគីវិវាទ មជ្ឈត្តករមិនគួរតែងតាំងខ្លួនឯងឱ្យបំពេញកិច្ចការដោយឡែកមួយទៀតដែលពាក់ព័ន្ធនឹងបញ្ហាកំពុងវិវាទ ដូចជាធ្វើជាអ្នកទទួលគ្រប់គ្រង ឬអ្នកចាត់ចែងទ្រព្យឡើយឯគណៈមជ្ឈត្តករក៏មិនត្រូវតែងតាំងសមាជិកខ្លួនឱ្យធ្វើកិច្ចការបែបនេះដែរ ។

**គោលការណ៍ទីVII: មជ្ឈត្តករគួរប្រកាន់ខ្ជាប់បទដ្ឋាននៃសុចរិតភាព និងយុត្តិធម៌ នៅពេលរៀបចំសម្រាប់ការសងសគុណ និងការទូទាត់ចំណាយផ្សេងៗ**

**ក.** មជ្ឈត្តករដែលត្រូវទទួលបានការតបស្នងសម្រាប់សេវាកម្ម ឬទូទាត់សម្រាប់ការចំណាយរបស់ខ្លួន ត្រូវប្រកាន់ខ្ជាប់បទដ្ឋាននៃសុចរិតភាព និងយុត្តិធម៌ នៅពេលរៀបចំឱ្យមានការបង់ប្រាក់ទាំងនោះ ។

**ខ.** មានការអនុវត្តមួយចំនួនពាក់ព័ន្ធនឹងការបង់ប្រាក់ ដែលត្រូវបានទទួលស្គាល់ជាទូទៅថាឈានទៅរកការរក្សាឱ្យបាននូវភាពសុចរិត និងយុត្តិធម៌នៃដំណើរការមជ្ឈត្តការ។ ការអនុវត្តទាំងនេះ រួមមានៈ

(១) មុនពេលដែលមជ្ឈត្តករទទួលយកការតែងតាំងនៅទីបំផុត មូលដ្ឋាននៃការបង់ប្រាក់ រួមមានថ្លៃលុបចោលការតែងតាំង ថ្លៃសំណងក្នុងករណីដកខ្លួនចេញ ថ្លៃសគុណសំរាប់ពេលវេលាសិក្សាស្រាវជ្រាវ និងត្រៀមរៀបចំ ព្រមទាំងថ្លៃឈ្នួលដទៃទៀត គួរត្រូវបានកំណត់ជាស្រេច។ លើកលែងចំពោះតែការរៀបចំថ្លៃទូទាត់សំរាប់មជ្ឈត្តករដែលតែងតាំងដោយភាគីម្ខាងៗ ភាគីទាំងអស់គួរត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីលក្ខខណ្ឌនានាដែលបានរៀបចំឡើង។

(២) នៅក្នុងដំណើរការនានាដែលធ្វើឡើងនៅក្រោមវិធាន ឬការគ្រប់គ្រងរបស់ស្ថាប័នណាមួយដែលបង្កើតឡើងសម្រាប់ជួយរៀបចំសំរាប់ការបង់ថ្លៃផ្សេងៗ ការឆ្លើយឆ្លងពាក់ព័ន្ធនឹងការទូទាត់ប្រាក់គួរធ្វើឡើងតាមរយៈស្ថាប័ននោះ។ នៅក្នុងដំណើរការដែលភាគីវិវាទមិនបានប្រើប្រាស់ស្ថាប័នណាមួយនោះទេ ការប្រាស្រ័យទំនាក់ទំនងជាមួយមជ្ឈត្តករទាំងឡាយ (ក្រៅពីមជ្ឈត្តករដែលតែងតាំងដោយភាគីម្ខាងៗ) ដែលពាក់ព័ន្ធនឹងការបង់ថ្លៃ គួរធ្វើឡើងដោយមានវត្តមានរបស់ភាគីទាំងអស់ ហើយ

(៣) លើកលែងកាលៈទេសៈវិសាមញ្ញមួយចំនួន មជ្ឈត្តករមិនគួរសុំតំឡើងថ្លៃផ្សេងៗ ដោយសំអាងលើថ្លៃសគុណរបស់ខ្លួនក្នុងកំឡុងពេលដំណើរការឡើយ។

## គោលការណ៍ទីVIII: មជ្ឈត្តករអាចធ្វើការឃោសនា ឬផ្សព្វផ្សាយអំពីសេវាកម្មមជ្ឈត្តការដែលសច្ចៈ និងពិតត្រង់

**ក.** ការឃោសនា ឬផ្សព្វផ្សាយអំពីឆន្ទៈ និងលទ្ធភាពរបស់បុគ្គលណាម្នាក់ក្នុងការធ្វើជាមជ្ឈត្តករត្រូវតែពិតត្រង់ ហើយមិនងាយនឹងនាំឱ្យភ័ន្តច្រឡំបាន។ ការរៀបរាប់អំពីគុណភាពការងាររបស់មជ្ឈត្តករនោះ ឬជោគជ័យនៃការអនុវត្តរបស់មជ្ឈត្តករនោះត្រូវតែសច្ចៈ។

**ខ.** ការឃោសនា និងការផ្សព្វផ្សាយមិនត្រូវចង្អុរបង្ហាញពីឆន្ទៈណាមួយ ក្នុងការទទួលយកការតែងតាំង ខុសពីអ្វីដែលស្របនឹងក្រមនេះឡើយ។

*យោបល់អំពីគោលការណ៍ទី VIII*

គោលការណ៍នេះមិនរារាំងមជ្ឈត្តករណាម្នាក់ មិនឱ្យធ្វើការបោះពុម្ព ផ្សព្វផ្សាយ ឬការចែកចាយការឃោសនារបស់ខ្លួន ស្របទៅតាមបទដ្ឋានទាំងនេះ តាមប្រព័ន្ធអេឡិកត្រូនិក ឬប្រព័ន្ធបោះពុម្ពផ្សេងៗ ឬមិនឱ្យធ្វើបទឧទ្ទេសនាមផ្ទាល់ខ្លួនដល់អតិថិជន ដែលគេរំពឹងថានឹងប្រើប្រាស់សេវាកម្មមជ្ឈត្តការ ស្រប

តាមបទដ្ឋានទាំងនេះ ឬមិនឱ្យឆ្លើយតបចំពោះការស៊ើបសួរពាក់ព័ន្ធនឹងលទ្ធភាព គុណសម្បត្តិ បទពិសោធន៏ របស់មជ្ឈត្តករ ឬការយកថ្លៃឈ្នួលផ្សេងៗនោះឡើយ។

**គោលការណ៍ទីIX: មជ្ឈត្តករដែលតែងតាំងឡើងដោយភាគីម្ខាងមានករណីយកិច្ចកំណត់ និងបង្ហាញអំពីឋានៈរបស់ខ្លួន ព្រមទាំងអនុវត្តតាម ក្រមនេះរាល់ផ្នែកតែមានករណីលើកលែងដូចមានចែងនៅក្នុងគោលការណ៍ទីX**

**ក.** នៅក្នុងបែបផែនមជ្ឈត្តការមួយចំនួនដែលក្នុងនោះរួមមានមជ្ឈត្តករចំនួនបីរូប ភាគីនីមួយៗជាទម្លាប់ ត្រូវតែងតាំងមជ្ឈត្តករមួយរូបដោយខ្លួនឯង។ ក្នុងករណីនេះ មជ្ឈត្តករទីបីត្រូវបានតែងតាំងឡើងតាមរយៈការព្រមព្រៀងរបស់ភាគីវិវាទ ឬរបស់មជ្ឈត្តករទាំងពីររូបក៏បាន ឬតាមរយៈស្ថាប័ន ឬបុគ្គល ឯករាជ្យណាមួយក្នុងករណីដែលគ្មានការព្រមព្រៀងដូចខាងលើ។ នៅក្នុងមជ្ឈត្តការត្រីភាគីដែលក្រមនេះត្រូវអនុវត្ត មជ្ឈត្តករទាំងបីរូបត្រូវសន្មត់ថាអព្យាក្រឹត ហើយត្រូវបានរំពឹងឱ្យគោរពតាមបទដ្ឋាន ទាំងនេះ ដូចមជ្ឈត្តករទីបីដែរ។

ខ. ទោះជាមានការសន្មត់បែបនេះក៏ដោយ ក៏មានបែបផែនមជ្ឈត្តការត្រីភាគីមួយចំនួន ដែលគេរំពឹងថា មជ្ឈត្តករពីររូបដែលភាគីទាំងពីរតែងតាំង អាចត្រូវបានចាត់ជាមុនអោយគាំទ្រភាគីដែលតែងតាំងខ្លួន។ មជ្ឈត្តករទាំងនោះ ក្រមនេះបានចាត់ថាជា "មជ្ឈត្តករក្នុងគោលការណ៍ទីX" ហើយមិនចាំបាច់ទទួលខុសត្រូវចំពោះ បទដ្ឋានអព្យាក្រឹត និងឯករាជ្យដែលអនុវត្តចំពោះមជ្ឈត្តករដទៃទៀតឡើយ។ គោលការណ៍ទី X ពិពណ៌នាអំពីកាតព្វកិច្ចសីលធម៌វិជ្ជាជីវៈពិសេសមួយចំនួន របស់មជ្ឈត្តករដែលតែងតាំងដោយភាគីម្ខាងៗ និងដែលមិនត្រូវបានរំពឹងថាអាចបំពេញបទដ្ឋានអព្យាក្រឹតបាន។

គ. មជ្ឈត្តករដែលតែងតាំងដោយភាគីម្ខាងៗ មានកាតព្វកិច្ចបញ្ជាក់ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន និងមិនឱ្យយឺតជាងកិច្ចប្រជុំលើកដំបូងរវាងមជ្ឈត្តករទាំងអស់ និងភាគីវិវាទអំពីការណ៍ដែលថា តើភាគីវិវាទឯកភាពថាមជ្ឈត្តករទាំងនោះនឹងធ្វើជាអ្នកអព្យាក្រឹត ឬត្រូវស្ថិតនៅក្រោមគោលការណ៍ទីX ព្រមទាំងត្រូវផ្តល់របាយការណ៍ឱ្យបានទាន់ពេលវេលា អំពីសេចក្តីសន្និដ្ឋានរបស់ខ្លួន ដល់ភាគីទាំងវិវាទ ក៏ដូចជាមជ្ឈត្តករដទៃទៀតផងដែរ:

(១) មជ្ឈត្តករដែលតែងតាំងដោយភាគីម្ខាងៗ គួរពិនិត្យកិច្ចព្រមព្រៀងរបស់ភាគីវិវាទ វិធានសំរាប់អនុវត្ត និងច្បាប់ដែលអាចអនុវត្តបាន ពាក់ព័ន្ធនឹងអព្យាក្រឹតភាពរបស់ខ្លួន។ ក្នុងការពិនិត្យលើកិច្ចព្រមព្រៀងរបស់ភាគីវិវាទ មជ្ឈត្តករដែលតែងតាំងដោយភាគីម្ខាងៗ គួរគោរពតាមលក្ខខណ្ឌជាក់លាក់

មួយចំនួន ក្នុងកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ដែលស្តីអំពីមជ្ឈត្តការ។ អាចជាការគប្បីផងដែរ ដែលពួកគេជជីករកកិច្ចព្រមព្រៀងផ្សេងៗដែលមិនទាន់បានចែងឱ្យបានច្បាស់ ប៉ុន្តែអាចត្រូវបានគេសំដៅយកតាមរយៈការប្រាស្រ័យទាក់ទងគ្នារបស់ភាគីវិវាទ ឬទំនៀមទម្លាប់ និង ការប្រើប្រាស់ដែលមានការទទួលស្គាល់នៅក្នុងជំនួញដូរ ឬអាជីពរបស់ពួកគេ។

(២) នៅពេលដែលមជ្ឈត្តករដែលតែងតាំងដោយភាគីម្ខាងៗ សន្និដ្ឋានថាភាគីវិវាទមានបំណងឱ្យខ្លួន បំពេញមុខងារជាអព្យាក្រឹតនោះ មជ្ឈត្តករត្រូវជូនដំណឹងនេះទៅភាគីវិវាទ ព្រមទាំងមជ្ឈត្តករដទៃ ទៀត។ មជ្ឈត្តករទាំងនោះអាចប្រត្តិបត្តិដូចដែលមានចែងនៅក្នុងគោលការណ៍ទីX វាវលែងតែ ឬលុះត្រា តែមានការកំណត់ផ្សេងទៀតអំពីឋានៈរបស់ពួកគេ ដែលធ្វើឡើងដោយភាគីវិវាទ ស្ថាប័នគ្រប់គ្រង ណាមួយ ឬគណៈមជ្ឈត្តករនោះ និង

(៣) លុះត្រាតែមជ្ឈត្តករដែលតែងតាំងដោយភាគីម្ខាងៗ សន្និដ្ឋានថាភាគីវិវាទមិនមានបំណងឱ្យខ្លួន បំពេញមុខងារជាអព្យាក្រឹត ឬក្នុងករណីដែលមជ្ឈត្តករដែលតែងតាំងដោយភាគីម្ខាងៗ មិនអាចបង្កើត ការជឿជាក់ដ៏សមស្របមួយអំពីឋានៈរបស់ខ្លួនចេញពីប្រភពពីមុនមក ហើយមិនទាន់មានការសម្រេច ណាមួយធ្វើឡើងដោយភាគីវិវាទ ស្ថាប័នគ្រប់គ្រងណាមួយ ឬគណៈមជ្ឈត្តករនោះទេ មជ្ឈត្តករគួរ ប្រតិបត្តិតាមកាតព្វកិច្ចទាំងអស់របស់មជ្ឈត្តករអព្យាក្រឹត ដូចដែលបានកំណត់នៅក្នុងក្រមនេះ។

ឃ. មជ្ឈត្តករតែងតាំងដោយភាគីដែលមិនស្ថិតនៅក្រោមគោលការណ៍ទីឃ ត្រូវគោរពទៅតាម កាតព្វកិច្ច ទាំងអស់ពីគោលការណ៍ទី I ដល់ទី VIII លើកលែងតែមិនតម្រូវដោយកិច្ចព្រមព្រៀង របស់ភាគី នីតិវិធី ឬច្បាប់សំរាប់អនុវត្តទាំងនោះ។

## គោលការណ៍ទីX: អណ្ណត្រកម្មសម្រាប់មជ្ឈត្តករដែលតែងតាំងដោយភាគីម្ខាង និងដែលមិនស្ថិតក្រោម វិធានអព្យាក្រឹតភាព

មជ្ឈត្តករក្នុងគោលការណ៍ទីXត្រូវបានរំពឹងឱ្យគោរពកាតព្វកិច្ចសីលធម៌វិជ្ជាជីវៈទាំងអស់ ដែលបានកំណត់ ដោយក្រមនេះ លើកលែងតែមានការអនុគ្រោះច្បាស់លាស់នៅក្នុងគោលការណ៍ទី X។

***ក. កាតព្វកិច្ចនៅក្នុងគោលការណ៍ទី I***

មជ្ឈត្តករក្នុងគោលការណ៍ទី X ត្រូវគោរពតាមរាល់កាតព្វកិច្ចនៃគោលការណ៍ I លើកលែងតែចំពោះ ប្បញ្ញត្តិដូចខាងក្រោម:

(១) មជ្ឈត្តករក្នុងគោលការណ៍ទីX អាចត្រូវបានចាត់ជាមុនអោយគាំទ្រភាគីដែលបានតែងតាំងខ្លួនបាន ប៉ុន្តែនៅរាល់កិច្ចការដទៃទៀត មជ្ឈត្តករមានកាតព្វកិច្ចបំពេញដោយទៀងត្រង់ សុចរិត និងយុត្តិធម៌។

ឧទាហរណ៍ មជ្ឈត្តករក្នុងគោលការណ៍ទីX មិនគួរចូលរួមក្នុងការប្រើល្បិចពន្យារពេល ឬរុកគួនដល់ភាគី ឬសាក្សីណាមួយ ហើយមិនគួរថ្លែងនូវពាក្យដែលខ្លួនដឹងថាមិនពិត និងបោកបញ្ឆោត ទៅកាន់មជ្ឈត្តករដទៃទៀតឡើយ និង

(២) បទប្បញ្ញត្តិដែលមាននៅក្នុងកថាខណ្ឌ**ខ**(១) **ខ**(២) និងកថាខណ្ឌ**គ** និង**ឃ** នៃគោលការណ៍ទីI ទាំងឡាយណាដែលពាក់ព័ន្ធនឹងភាពលម្អៀង ទំនាក់ទំនង និងផលប្រយោជន៍ នឹងមិនអនុវត្តចំពោះមជ្ឈត្តករក្នុងគោលការណ៍ទី X នេះឡើយ ។

***ខ. កាតព្វកិច្ចនៅក្នុងគោលការណ៍ទី II***

(១) មជ្ឈត្តករក្នុងគោលការណ៍ទី X ត្រូវបង្ហាញព័ត៌មានដល់ភាគីវិវាទ និងមជ្ឈត្តករដទៃទៀត ស្តីពីផល-ប្រយោជន៍ និងទំនាក់ទំនងផ្សេងៗដែលគោលការណ៍ទី II តម្រូវឱ្យបង្ហាញ។ ការបង្ហាញព័ត៌មាន ដែលតម្រូវដោយគោលការណ៍ទី II គឺដើម្បីជាប្រយោជន៍មិនត្រឹមតែសម្រាប់ភាគីដែលតែងតាំងមជ្ឈត្តករនោះទេ ប៉ុន្តែក៏សម្រាប់ភាគី និងមជ្ឈត្តករដទៃទៀត ដោយពួកគេអាច ដឹងអំពីភាពលម្អៀងដែលអាចកើតមាន ឬ ក៏ហាក់ដូចជានឹងអាចកើតមាន ហើយ

(២) មជ្ឈត្តករក្នុងគោលការណ៍ទី X មិនមានកាតព្វកិច្ចដកខ្លួនចេញដូចមានចែងនៅក្នុងកថាខណ្ឌ**ឆ** នៃគោល ការណ៍ទី II ឡើយ ប្រសិនបើមានតែមានតែភាគីដែលមិនបានតែងតាំងខ្លួន ជាអ្នកស្នើសុំឱ្យនោះ ។

***គ. កាតព្វកិច្ចនៅក្នុងគោលការណ៍ទី III***

មជ្ឈត្តករក្នុងគោលការណ៍ទី X ត្រូវគោរពកាតព្វកិច្ចទាំងអស់នៃគោលការណ៍ III លើកលែងតែចំពោះបទប្បញ្ញត្តិខាងក្រោម:

(១) ដូចមជ្ឈត្តករអព្យាក្រឹតដែលតែងតាំងដោយភាគីម្ខាងៗដែរ មជ្ឈត្តករក្នុងគោលការណ៍ទី X អាចប្រឹក្សាជាមួយភាគីដែលបានតែងតាំងខ្លួន នៅក្នុងកម្រិតដែលបានអនុញ្ញាតនៅក្នុងកថាខណ្ឌ ខ នៃគោល-ការណ៍ទី III ។

(២) នៅវេលាដែលឆាប់បំផុតតាមដែលអាចអនុវត្តបាន មជ្ឈត្តករក្នុងគោលការណ៍ទី X ត្រូវបង្ហាញព័ត៌មានទៅមជ្ឈត្តករដទៃទៀត និងភាគីវិវាទ ថាពួកគេមានបំណងឆ្លើយឆ្លងព័ត៌មានជាមួយនឹងភាគីដែលបានតែងតាំងខ្លួនដែរឬទេ។ ប្រសិនបើពួកគេបានបង្ហាញឱ្យដឹងពីគោលបំណងក្នុងការធ្វើទំនាក់ទំនងនោះរួច អំណើះក្រោយមក ពួកគេអាចទាក់ទងជាមួយនឹងភាគីដែលតែងតាំងខ្លួនទាំងនោះ ពាក់ព័ន្ធនឹងទិដ្ឋភាពផ្សេងៗនៃរឿងក្តី លើកលែងតែមានចែងនៅក្នុងកថាខណ្ឌ (៣) ។

(៣) ប្រសិនបើការឆ្លើយឆ្លងរបៀបនោះកើតមានមុនពេលខ្លួនត្រូវបានតែងតាំងជាមជ្ឈត្តករ ឬមុនពេលសវនការទីមួយ ឬការប្រជុំផ្សេងៗទៀតរវាងភាគីវិវាទជាមួយនឹងមជ្ឈត្តករទាំងអស់ មជ្ឈត្តករក្នុងគោល

ការណ៍ទី X គួរបង្ហាញព័ត៌មាន ក្នុងពេល ឬមុនពេលសវនាការទីមួយ ឬការប្រជុំរបស់មជ្ឈត្តករជាមួយភាគីវិវាទ អំពីហេតុដែលថា ការឆ្លើយឆ្លងបែបនោះបានកើតមានរួចទៅហើយ ។ ដោយអនុវត្តតាមបទប្បញ្ញត្តិនៃអនុកថាខណ្ឌនេះ គឺជាការគ្រប់គ្រាន់ហើយដែលមានការបើកចំហរព័ត៌មាន អំពីហេតុដែលថាការឆ្លើយឆ្លងបែបនោះកើតមានរួចហើយ ដោយមិនចាំបាច់បង្ហាញឱ្យដឹង អំពីខ្លឹមសារនៃការឆ្លើយឆ្លងនោះឡើយ ។ ការបង្ហាញព័ត៌មានតែម្តងគត់ អោយបានទាន់ពេលវេលា អំពីគោលបំណងរបស់មជ្ឈត្តករក្នុងគោលការណ៍ទី X ក្នុងការចូលរួមឆ្លើយឆ្លងរបៀបនោះក្នុងពេលអនាគត គឺជាការគ្រប់គ្រាន់ហើយ ។

(៤) ក្នុងពេលណាក៏ដោយនៃកំឡុងពេលធ្វើមជ្ឈត្តការ មជ្ឈត្តករក្នុងគោលការណ៍ទី X មិនអាចៈ

(ក) បង្ហាញព័ត៌មានពីការពិចារណារបស់មជ្ឈត្តករទាំងអស់អំពីចំណោទ ឬបញ្ហាណាមួយដែលបានដាក់ឱ្យពួកគេដើម្បីធ្វើការសម្រេច ។

(ខ) ឆ្លើយឆ្លងជាមួយភាគីដែលបានតែងតាំងខ្លួនពាក់ព័ន្ធនឹងចំណោទ ឬបញ្ហាណាមួយដែលស្ថិតក្នុងការពិចារណាដោយគណៈមជ្ឈត្តករ បន្ទាប់ពីការបញ្ចប់កំណត់ត្រា ឬក៏បន្ទាប់ពីចំណោទ ឬបញ្ហានោះ ត្រូវបានដាក់ជូនឱ្យសម្រេច ឬ

(គ) បង្ហាញសេចក្តីសម្រេចស្ថាពរ ឬណ្តោះអាសន្នណាមួយ នៅមុនពេលដល់ពេលវេលាដែលត្រូវផ្តល់ព័ត៌មានអំពីសេចក្តីសម្រេចនេះទៅដល់ភាគីទាំងអស់ ។

(៥) លើកលែងតែមានការយល់ព្រមពីមជ្ឈត្តករទាំងអស់ និងភាគីវិវាទ មជ្ឈត្តករក្នុងគោលការណ៍ទី X មិនអាចឆ្លើយឆ្លងដោយផ្ទាល់មាត់ជាមួយមជ្ឈត្តករអព្យាក្រឹតអំពីចំណោទ ឬបញ្ហាណាមួយដែលលេចឡើង ឬដែលរំពឹងថានឹងលេចឡើងក្នុងមជ្ឈត្តការ ក្នុងពេលអវត្តមានរបស់មជ្ឈត្តករក្នុងគោលការណ៍ទី X ដទៃទៀតនោះឡើយ ។ ក្នុងករណីមជ្ឈត្តករក្នុងគោលការណ៍ទី X ឆ្លើយឆ្លងជាលាយលក្ខណ៍អក្សរជាមួយមជ្ឈត្តករអព្យាក្រឹត មជ្ឈត្តករនោះគួរផ្តល់ច្បាប់ចម្លងនៃការឆ្លើយឆ្លងនោះមួយច្បាប់ ឱ្យដល់មជ្ឈត្តករក្នុងគោលការណ៍ទី X ដទៃទៀតព្រមជាមួយគ្នានោះដែរ ។

(៦) នៅពេលដែលមជ្ឈត្តករក្នុងគោលការណ៍ទី X ឆ្លើយឆ្លងដោយផ្ទាល់មាត់ជាមួយភាគីដែលបានតែង-តាំងខ្លួនអំពីបញ្ហាណាមួយ ដែលក្រមនេះអនុញ្ញាតិអោយប្រាស្រ័យទាក់ទង មជ្ឈត្តករទាំងនោះមិនមានកាតព្វកិច្ចបង្ហាញអំពីខ្លឹមសារនៃការឆ្លើយឆ្លងដោយផ្ទាល់មាត់ទាំងនោះ ដល់ភាគី ឬមជ្ឈត្តករដទៃទៀតឡើយ ហើយ

(៧) នៅពេលដែលមជ្ឈត្តករក្នុងគោលការណ៍ទី X ឆ្លើយឆ្លងជាលាយលក្ខណ៍អក្សរ ជាមួយភាគីដែលបានតែងតាំងខ្លួនអំពីបញ្ហាណាមួយ ដែលក្រមនេះអនុញ្ញាតិអោយប្រាស្រ័យទាក់ទង មជ្ឈត្តករទាំងនោះ

មិនមានកាតព្វកិច្ចបង្ហាញអំពីខ្លឹមសារនៃការឆ្លើយឆ្លងលាយលក្ខណ៍អក្សរទាំងនោះ ដល់ភាគី ឬមជ្ឈត្តករដទៃទៀតឡើយ ។

**ឃ. *កាតព្វកិច្ចនៅក្នុងគោលការណ៍ទី IV***

មជ្ឈត្តករក្នុងគោលការណ៍ទី X ត្រូវគោរពតាមកាតព្វកិច្ចទាំងអស់នៅក្នុងគោលការណ៍ទី IV ។

**ង. *កាតព្វកិច្ចនៅក្នុងគោលការណ៍ទី V***

មជ្ឈត្តករក្នុងគោលការណ៍ទី X ត្រូវគោរពរាល់កាតព្វកិច្ចទាំងអស់នៃគោលការណ៍ទីV លើកលែងតែថាពួកគេអាចត្រូវបានចាត់ជាមុនអោយសម្រេចចិត្តដោយគាំទ្រភាគីដែលបានតែងតាំងខ្លួន ។

**ច. *កាតព្វកិច្ចនៅក្នុងគោលការណ៍ទី VI***

មជ្ឈត្តករក្នុងគោលការណ៍ទី X ត្រូវគោរពតាមកាតព្វកិច្ចទាំងអស់នៅក្នុងគោលការណ៍ទី VI ។

**ឆ. *កាតព្វកិច្ចនៅក្នុងគោលការណ៍ទី VII***

មជ្ឈត្តករក្នុងគោលការណ៍ទី X ត្រូវគោរពតាមកាតព្វកិច្ចទាំងអស់នៅក្នុងគោលការណ៍ទី VII ។

**ជ. *កាតព្វកិច្ចនៅក្នុងគោលការណ៍ទី VIII***

មជ្ឈត្តករក្នុងគោលការណ៍ទី X ត្រូវគោរពតាមកាតព្វកិច្ចទាំងអស់នៅក្នុងគោលការណ៍ទី VIII ។

**ឈ. *កាតព្វកិច្ចនៅក្នុងគោលការណ៍ទី IX***

បទប្បញ្ញត្តិនៃកថាខណ្ឌ **ឃ** នៃគោលការណ៍ទី IX មិនអាចអនុវត្តបានចំពោះមជ្ឈត្តករក្នុងគោលការណ៍ទី X ឡើយ លើកលែងត្រឹមតែកាតព្វកិច្ចទាំងឡាយណាដែលមានចែងផងដែរនៅក្នុងគោលការណ៍នេះ ។

# ឧបសម្ព័ន្ធ ១

# ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងសម្រួលដល់ការដោះស្រាយជាបន្ទាន់ តាមការផ្សះផ្សានូវវិវាទពាណិជ្ជកម្មដែលកើតមានឡើងក្នុងព្រះរាជាណាចក្រកម្ពុជាស្របតាមការស្ម័គ្រចិត្តរបស់ភាគីវិវាទដើម្បីការពារសិទ្ធិនិងផលប្រយោជន៍នៃភាគីវិវាទទាំងនេះ និងដើម្បីលើកស្ទួយការអភិវឌ្ឍន៍សេដ្ឋកិច្ច ។

ច្បាប់នេះមិនប៉ះពាល់ដល់អានុភាពគតិយុត្តិនៃច្បាប់នានាឯទៀតរបស់ព្រះរាជាណាចក្រកម្ពុជាដែលនៅក្នុងនោះ ករណីវិវាទខ្លះផ្សះផ្សាបាន ឬ ដោះស្រាយបានតាមនីតិវិធីផ្សេងៗទៀត និងវិវាទខ្លះទៀតផ្សះផ្សាមិនបាន ។

**មាត្រា ២.-**

និយមន័យ និងវិធាននៃការបកស្រាយពាក្យដែលប្រើក្នុងច្បាប់នេះ :

ក- “មជ្ឈត្តការ” គឺជាការផ្សះផ្សាវិវាទដោយប្រើប្រាស់វេទិកាមជ្ឈត្តកម្ម ហើយអាចស្ថិតនៅក្នុង ឬ នៅក្រៅក្របខ័ណ្ឌនៃការគ្រប់គ្រងរបស់ស្ថាប័នផ្សះផ្សាអចិន្ត្រៃយ៍ ។

ខ- “វេទិកាមជ្ឈត្តកម្ម” គឺជាមជ្ឈត្តករមួយនាក់ ឬ មួយក្រុម ។

គ- “តុលាការ” គឺជាស្ថាប័ន ឬ អង្គការនៃប្រព័ន្ធតុលាការរបស់ប្រទេសមួយ ។

ឃ- “កិច្ចព្រមព្រៀងផ្សះផ្សា” ជាកិច្ចព្រមព្រៀងរវាងភាគីវិវាទក្នុងការធ្វើមជ្ឈត្តការវិវាទទាំងអស់ ឬ វិវាទបែបណាមួយដែលកើតឡើង ឬ ដែលអាចកើតឡើងរវាងភាគីវិវាទនានា ដោយគោរពតាមទំនាក់ទំនងកំណត់ដោយច្បាប់ ទោះបីជាមានកិច្ចសន្យា ឬ គ្មានក៏ដោយ ។

ង-ក្រៅពីមាត្រា ៣៦ កាលណាបទប្បញ្ញត្តិនានានៃច្បាប់នេះទុកសេរីភាពឱ្យភាគីវិវាទកំណត់ពីបញ្ហាណាមួយ សេរីភាពនេះគឺរាប់បញ្ចូលទាំងសិទ្ធិរបស់ភាគីវិវាទក្នុងការអនុញ្ញាតឱ្យមានភាគីទី ៣ រួមបញ្ចូលទាំងស្ថាប័នមួយ ដើម្បីធ្វើការសម្រេចលើបញ្ហានោះ ។

ច-ក្នុងករណីដែលបទប្បញ្ញត្តិនៃច្បាប់នេះ យោងតាមអ្វីដែលភាគីវិវាទបានព្រមព្រៀង ឬ អាចនឹងព្រមព្រៀងគ្នា ឬ យោងតាមមធ្យោបាយផ្សេងទៀតនៃកិច្ចព្រមព្រៀងរបស់ភាគីវិវាទ កិច្ចព្រមព្រៀងនោះ ។

ឆ-ក្រៅពីមាត្រា ៣៣ (១) និងមាត្រា ៤០ (១) នៃច្បាប់នេះ កាលណាបទប្បញ្ញត្តិនៃច្បាប់នេះយោងតាមការប្តឹងទាមទារ បទប្បញ្ញត្តិនោះក៏ត្រូវអនុវត្តចំពោះការប្តឹងទាមទារបកវិញដែរ ហើយនៅពេលដែលយោងតាមការដោះសាពីការប្តឹងទាមទារ ក៏ត្រូវអនុវត្តចំពោះការដោះសាពីការប្តឹងទាមទារបកវិញដែរ ។

ជ-មជ្ឈត្តការមានលក្ខណៈជា “អន្តរជាតិ” ក្នុងករណី :

ជ.១-ភាគីវិវាទ និងកិច្ចព្រមព្រៀងផ្សះផ្សាមានទីកន្លែងធ្វើពាណិជ្ជកម្មនៅក្នុងប្រទេសផ្សេងពីគ្នា ក្នុងពេលសម្រេចកិច្ចព្រមព្រៀងនោះ ឬ

ជ.២-ទីកន្លែងមួយក្នុងចំណោមទីកន្លែងខាងក្រោមនោះ ស្ថិតនៅក្រៅប្រទេសធ្វើពាណិជ្ជកម្មរបស់ភាគីវិវាទ :

-ទីកន្លែងធ្វើមជ្ឈត្តការ : ប្រសិនបើបានកំណត់ ឬ បានយោងក្នុងកិច្ចព្រមព្រៀងផ្សះផ្សា ។

-ទីកន្លែងដែលកាតព្វកិច្ចសំខាន់នៃទំនាក់ទំនងពាណិជ្ជកម្មបានប្រព្រឹត្តទៅ ឬ ទីកន្លែងជិតជាងគេនៃរឿងពាក់ព័ន្ធនឹងវិវាទ ។

ជ.៣-ភាគីវិវាទបានព្រមព្រៀងជាក់លាក់ថា រឿងនៃកិច្ចព្រមព្រៀងផ្សះផ្សាទាក់ទងទៅនឹងប្រទេសលើសពីមួយ ។

ជ.៤-តាមគោលបំណងក្នុងកថាខណ្ឌ (ជ) នេះ :

-ប្រសិនបើភាគីវិវាទមួយមានទីកន្លែងប្រកបពាណិជ្ជកម្មលើសពីមួយកន្លែង ទីកន្លែងដែលមានទាក់ទងជិតស្និទ្ធជាងគេបំផុតទៅនឹងកិច្ចព្រមព្រៀងផ្សះផ្សាគឺជាទីកន្លែងពាណិជ្ជកម្ម ។

-ប្រសិនបើភាគីវិវាទមួយមិនមានទីកន្លែងប្រកបពាណិជ្ជកម្មទេ ការយោងក្នុងច្បាប់នេះគឺទីលំនៅអចិន្ត្រៃយ៍របស់ភាគីនោះ ។

ឈ-ពាក្យថា “ពាណិជ្ជកម្ម” ត្រូវបកស្រាយឱ្យបានទូលំទូលាយ ដើម្បីគ្របដណ្តប់លើធុរកិច្ចដែលមានប្រភេទជាពាណិជ្ជកម្ម ទោះបីជាមានកិច្ចសន្យា ឬ គ្មានកិច្ច

សន្យាក៏ដោយ ។ ធុរកិច្ចដែលមានប្រភេទជាពាណិជ្ជកម្មមានជាអាទិ៍ ៖ កិច្ចការជំនួញដើម្បីផ្គត់ផ្គង់ ឬ ការផ្លាស់ប្តូរទំនិញ ឬ សេវាផ្សេងៗ កិច្ចព្រមព្រៀងនៃការចែកចាយតំណាង ឬ ទីភ្នាក់ងារពាណិជ្ជកម្ម ការទិញ-លក់គណនីក្រុមហ៊ុន ការជួលទីតាំង ឬ សម្ភារៈវត្ថុ ការងារស្ថាបនា ការពិគ្រោះយោបល់ វិស្វកម្ម ការចេញអាជ្ញាប័ណ្ណ ការវិនិយោគទុន ការផ្តល់ហិរញ្ញវត្ថុ ការធ្វើអាជីវកម្មធនាគារ ការធានារ៉ាប់រង កិច្ចព្រមព្រៀងធ្វើអាជីវកម្ម ឬ សម្បទាន ក្រុមហ៊ុនចំរុះ និងប្រភេទផ្សេងៗទៀតនៃសហប្រតិបត្តិការឧស្សាហកម្ម ឬ ពាណិជ្ជកម្ម និងការដឹកជញ្ជូនទំនិញ ឬ អ្នកដំណើរតាមផ្លូវអាកាស ផ្លូវទឹក ផ្លូវគោក ។

**មាត្រា ៣.–**

លើកលែងតែភាគីទាំងអស់បានព្រមព្រៀងផ្សេងពីនេះ ៖

១-លិខិតឆ្លើយឆ្លងជាលាយលក្ខណ៍អក្សរ ត្រូវចាត់ទុកថាបានទទួល ក្នុងករណីដែលបានប្រគល់ឱ្យអ្នកទទួលដោយផ្ទាល់ដៃ ឬ ប្រគល់ដល់កន្លែងប្រកបពាណិជ្ជកម្ម ឬ ទីលំនៅអចិន្ត្រៃយ៍ ឬ អាសយដ្ឋានប្រៃសណីយ៍របស់អ្នកទទួល ។ ប្រសិនបើរកកន្លែងទាំងនោះមិនឃើញទេ ក្រោយពីការស្វះស្វែងរកយ៉ាងល្អិតល្អន់រួចមក លិខិតឆ្លើយឆ្លងជាលាយលក្ខណ៍អក្សរ ត្រូវចាត់ទុកថាបានទទួលក្នុងករណីបានធ្វើតាមរយៈលិខិតអនុសិដ្ឋ ឬ តាមមធ្យោបាយផ្សេងៗដែលផ្តល់ហេតុផលថា ពិតជាបានខំប្រឹងប្រែងប្រគល់លិខិតទៅដល់កន្លែងប្រកបពាណិជ្ជកម្ម ឬ ទីលំនៅអចិន្ត្រៃយ៍ ឬ អាសយដ្ឋានរបស់អ្នកទទួលដែលស្គាល់ចុងក្រោយបំផុត ។

២-បទប្បញ្ញត្តិនានាក្នុងមាត្រា ៣ នៃច្បាប់នេះ មិនយកទៅអនុវត្តលើលិខិតឆ្លើយឆ្លងក្នុងពេលដំណើរការកាត់ក្តីរបស់តុលាការទេ ។

**មាត្រា ៤.–**

ត្រូវបានចាត់ទុកថាបានបោះបង់សិទ្ធិជំទាស់របស់ខ្លួន ប្រសិនបើភាគីវិវាទមួយបានដឹងថាភាគីវិវាទផ្សេងទៀត អាចប្រព្រឹត្តខុសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬ ពុំគោរពតាមការតម្រូវរបស់កិច្ចព្រមព្រៀងផ្សះផ្សា ប៉ុន្តែភាគីវិវាទនោះនៅតែបន្តដំណើរការមជ្ឈត្តការដោយមិនបានជំទាស់ទៅនឹងការមិនគោរពនោះ ហើយក្នុងករណីដែលមានចែងពីរយៈពេលកំណត់សម្រាប់ការជំទាស់ ភាគីវិវាទនោះពុំបានធ្វើការពន្យារពេលជាចាំបាច់ ។

**មាត្រា ៥.-**

នៅក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ តុលាការធ្វើអន្តរាគមន៍បានតែក្នុងករណីទាំងឡាយណាដែលច្បាប់នេះបានចែង ។

**មាត្រា ៦.-**

មុខងារផ្សេងៗដែលមានចែងក្នុងមាត្រា ១៩ កថាខណ្ឌទី ៣, ៤ និង ៥ មាត្រា ២១ កថាខណ្ឌទី ៣ មាត្រា ២២ មាត្រា ២៤ កថាខណ្ឌទី ៣ នៃច្បាប់នេះ ត្រូវបំពេញដោយតុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តកការផ្នែកពាណិជ្ជកម្ម ។

## ជំពូកទី ២
## កិច្ចព្រមព្រៀងផ្សះផ្សា

**មាត្រា ៧.-**

កិច្ចព្រមព្រៀងផ្សះផ្សារួមមានខចែងស្តីពីមជ្ឈត្តការដែលបានចែងនៅក្នុងកិច្ចសន្យា ឬ ក្នុងកិច្ចព្រមព្រៀងដោយឡែក ។

កិច្ចព្រមព្រៀងផ្សះផ្សាត្រូវសរសេរជាលាយលក្ខណ៍អក្សរ ។ ដែលហៅថាកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ គឺជាកិច្ចព្រមព្រៀងដែលស្ថិតនៅក្នុងឯកសារចុះហត្ថលេខាដោយភាគីវិវាទ ឬ ដែលស្ថិតនៅក្នុងការផ្ទេរលិខិតស្នាម ឬ មធ្យោបាយទូរគមនាគមន៍តាមប្រព័ន្ធអេឡិចត្រូនិច ដែលផ្តល់កំណត់ត្រាបញ្ជាក់ពីការព្រមព្រៀងគ្នា ឬ ដែលស្ថិតនៅក្នុងការប្តូរគ្នាទៅវិញទៅមកនូវពាក្យទាមទារ ឬ ពាក្យដោះសាដែលក្នុងនោះ ភាគីវិវាទមួយបានទាមទារ ហើយមិនត្រូវបានបដិសេធដោយភាគីវិវាទម្ខាងទៀត ។ សេចក្តីយោងក្នុងកិច្ចសន្យា និង ឯកសារមួយដែលមានប្រការស្តីពីមជ្ឈត្តការអាចក្លាយជាកិច្ចព្រមព្រៀងផ្សះផ្សាបានល្គឹកណាកិច្ចសន្យានោះសរសេរជាលាយលក្ខណ៍អក្សរ ហើយសេចក្តីយោងនោះគឺជាប្រការដែលក្លាយជាផ្នែកមួយនៃកិច្ចសន្យា ។

**មាត្រា ៨.–**

នៅពេលដោះស្រាយបណ្តឹងវិវាទ តុលាការដែលទទួលដោះស្រាយវិវាទដែលជាកម្ម-វត្ថុកិច្ចព្រមព្រៀងផ្សះផ្សា ត្រូវបញ្ជូនភាគីវិវាទទៅធ្វើមជ្ឈត្តការ ប្រសិនបើមានសំណើពីភាគីវិវាទមួយ វៀរលែងតែតុលាការនោះរកឃើញថាកិច្ចព្រមព្រៀងផ្សះផ្សានោះត្រូវចាត់ទុកជាមោឃៈ ឬ មិនអាចអនុវត្តបាន ។

ទោះបីជាមានបណ្តឹងទាមទារទៅតុលាការដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះក៏ដោយ ក៏ដំណើរការរបស់វេទិកាមជ្ឈត្តកម្មអាចចាប់ផ្តើម ឬ បន្តដំណើរការបានតទៅទៀត ហើយតុលាការត្រូវបង្វែរសមត្ថកិច្ចជូនទៅវេទិកាមជ្ឈត្តកម្មវិញ ដោយរង់ចាំការសម្រេចរបស់វេទិកាមជ្ឈត្តកម្ម ។

**មាត្រា ៩.–**

នៅមុនពេល ឬ ក្នុងពេលកំពុងដំណើរការមជ្ឈត្តការ ការធ្វើសំណូមពររបស់ភាគីវិវាទមួយទៅតុលាការឱ្យផ្តល់វិធានការបណ្តោះអាសន្ន ដើម្បីការពារ និងការផ្តល់នូវវិធានការទាំងនោះដោយតុលាការពុំមានវិសមិតភាពជាមួយកិច្ចព្រមព្រៀងផ្សះផ្សាឡើយ ។

## ជំពូកទី ៣
## មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

**មាត្រា ១០.–**

ត្រូវបានបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការមួយឯករាជ្យ នៅក្រោមការឧបត្ថម្ភរបស់ក្រសួងពាណិជ្ជកម្ម ។ គោលបំណងនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការគឺ :

១-ជម្រុញការដោះស្រាយវិវាទពាណិជ្ជកម្ម តាមរយៈការផ្សះផ្សានៅក្នុងព្រះរាជាណាចក្រកម្ពុជា

២-បង្កើតរចនាសម្ព័ន្ធ និងវិធានចាំបាច់សម្រាប់គ្រប់គ្រងរឿងមជ្ឈត្តការនៅក្នុងព្រះរាជាណាចក្រកម្ពុជានៅពេលដែលកិច្ចព្រមព្រៀងជាក់ច្បាស់មួយនៃភាគីវិវាទ ដាក់វិវាទទៅមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ

៣-ធានាឱ្យមជ្ឈត្តការនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានគុណភាពខ្ពស់ ។ គោល

បំណាងនេះរួមបញ្ចូលការកំណត់ស្តង់ដាសម្រាប់លក្ខណៈសម្បត្តិរបស់មជ្ឈត្តករ ។

**មាត្រា ១១.-**

រូបវន្តបុគ្គលមានសញ្ជាតិខ្មែរ ឬ បរទេសដែលជាមជ្ឈត្តករត្រូវចុះបញ្ជីនៅមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ។ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការមានភារកិច្ចកំណត់ពីលក្ខណៈសម្បត្តិរបស់មជ្ឈត្តករ ហើយត្រូវធ្វើសេចក្តីប្រកាសជាសាធារណៈនូវបញ្ជីឈ្មោះមជ្ឈត្តករជារៀងរាល់ឆ្នាំ ។ បញ្ជីនេះមិនមានលក្ខណៈដាច់ណាត់ទេ ភាគីវិវាទអាចជ្រើសរើសមជ្ឈត្តករក្រៅពីបញ្ជីក៏បាន ។

**មាត្រា ១២.-**

អាចសុំចូលជាសមាជិកមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការបាន រូបវន្តបុគ្គល និងនីតិបុគ្គលដូចខាងក្រោម :

-រូបវន្តបុគ្គលជាមជ្ឈត្តករដែលបានចុះឈ្មោះក្នុងបញ្ជីរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ

-សភាពាណិជ្ជកម្ម

-គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

-រាល់សមាគមដែលប្រមូលផ្តុំពាណិជ្ជករ ឧស្សាហករ អាជីវករ និង សេវាករ ។

សំណើសុំចូលជាសមាជិកមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ត្រូវបានពិនិត្យដោយក្រុមប្រឹក្សាប្រតិបត្តិនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការដែលមានចំនួនមិនលើសពីប្រាំពីរ (៧) នាក់ ។ សមាជិកក្រុមប្រឹក្សាប្រតិបត្តិមានអាណត្តិរយៈពេលបី (៣) ឆ្នាំ ហើយអាចឈរឈ្មោះបន្តមួយអាណត្តិទៀតបាន ។

**មាត្រា ១៣.-**

សភាពាណិជ្ជកម្មអាចរៀបចំមជ្ឈមណ្ឌលមជ្ឈត្តកម្មមួយនៅភ្នំពេញ ។ រាល់សមាគមដែលប្រមូលផ្តុំពាណិជ្ជករ ឧស្សាហករ អាជីវករ និងសេវាករ អាចបង្កើតមជ្ឈមណ្ឌលមជ្ឈត្តកម្មរបស់ខ្លួនដោយឡែកសម្រាប់ដោះស្រាយវិវាទរវាងសមាជិក និងរវាងសមាជិកជាមួយអ្នកដទៃ ។

**មាត្រា ១៤.–**

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ត្រូវគ្រប់គ្រងដោយ :

-មហាសន្និបាត

-ក្រុមប្រឹក្សាប្រតិបត្តិ ។

ភារកិច្ចសំខាន់ៗរបស់មហាសន្និបាតមាន :

-ប្រជុំមួយដង ឬ ពីរដងក្នុងមួយឆ្នាំ តាមការអញ្ជើញរបស់ប្រធានមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ឬ តាមសំណើរបស់សមាជិកភាគច្រើននៃក្រុមប្រឹក្សាប្រតិបត្តិ ។

-ជ្រើសតាំងក្រុមប្រឹក្សាប្រតិបត្តិ

-ពិនិត្យរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាប្រតិបត្តិ

-សម្រេចលើស្ថានភាពហិរញ្ញវត្ថុរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ

-កំណត់សោហ៊ុយ ដែលជាតម្លៃនៃការធ្វើមជ្ឈត្តការ

-ពិនិត្យសម្រេចលើរាល់សំណើកែប្រែលិខិតបទដ្ឋានដែលទាក់ទងដល់ដំណើរការមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ និងដំណើរការមជ្ឈត្តការ ។

-បំពេញភារកិច្ចផ្សេងទៀត ដែលកំណត់ដោយអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ។

**មាត្រា ១៥.–**

មហាសន្និបាតរួមប្រជុំដោយសមាជិកជារូបវន្តបុគ្គល និងតំណាងមួយរូបរបស់សមាជិកជានីតិបុគ្គលនិមួយៗ ។

**មាត្រា ១៦.–**

សមាសភាពក្រុមប្រឹក្សាប្រតិបត្តិដែលគ្រប់គ្រងមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការត្រូវបានបោះឆ្នោតជ្រើសតាំងក្នុងចំណោមសមាជិកដោយមហាសន្និបាត ។ ប្រធានក្រុមប្រឹក្សាប្រតិបត្តិ គឺជាប្រធានរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការ ។

**មាត្រា ១៧.-**

ការរៀបចំ និងការប្រព្រឹត្តិទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៤
## សមាសភាពនៃវេទិកាមជ្ឈត្តកម្ម

**មាត្រា ១៨.-**

ភាគីវិវាទមានសិទ្ធិកំណត់ចំនួនមជ្ឈត្តករនៃវេទិកាមជ្ឈត្តកម្ម ។ មជ្ឈត្តករត្រូវមានចំនួនសេស ។

បើគ្មានការកំណត់ពីភាគីវិវាទទេ មជ្ឈត្តករត្រូវមានចំនួនបី (៣) នាក់ ។

**មាត្រា ១៩.-**

ការជ្រើសតាំងមជ្ឈត្តករត្រូវអនុវត្តតាមបែបបទដូចខាងក្រោម :

១-មិនត្រូវបដិសេធជនណាម្នាក់មិនឱ្យធ្វើមជ្ឈត្តករ ដោយសារមូលហេតុនៃសញ្ជាតិរបស់គេឡើយ លើកលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ។

២-ភាគីវិវាទអាចព្រមព្រៀងលើនីតិវិធីនៃការតែងតាំងមជ្ឈត្តករមួយ (១) នាក់ ឬ ច្រើននាក់ យោងតាមបទប្បញ្ញត្តិក្នុងកថាខណ្ឌទី ៤ និងកថាខណ្ឌទី ៥ នៃមាត្រានេះ ។

៣-ករណីមិនបានព្រមព្រៀងពីនីតិវិធីនេះ :

ក-ក្នុងការធ្វើមជ្ឈត្តការដែលមានមជ្ឈត្តករបី (៣) នាក់ ភាគីវិវាទនីមួយៗត្រូវជ្រើសតាំងមជ្ឈត្តករមួយ (១) នាក់ ហើយមជ្ឈត្តករទាំងពីរនាក់នេះ ត្រូវជ្រើសតាំងមជ្ឈត្តករទីបី ។ ប្រសិនបើភាគីវិវាទណាមួយពុំបានជ្រើសតាំងមជ្ឈត្តករក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ក្រោយពេលទទួលសំណើជ្រើសតាំងពីភាគីវិវាទម្ខាងទៀត ឬ ប្រសិនបើមជ្ឈត្តករទាំងពីរ (២) នាក់ ពុំបានព្រមព្រៀងលើការតែងតាំងមជ្ឈត្តករទីបីក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ក្រោយពីត្រូវបានគេជ្រើសតាំងរួចមក តុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជ-

កម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ត្រូវជ្រើសតាំងមជ្ឈត្តករទី ៣ តាមការស្នើសុំនៃភាគីវិវាទណាមួយ ។

ខ-ក្នុងការធ្វើមជ្ឈត្តការដែលមានមជ្ឈត្តករតែមួយនាក់ ប្រសិនបើភាគីវិវាទមិនអាចព្រមព្រៀងលើការជ្រើសតាំងមជ្ឈត្តករទេនោះ តុលាការ (តុលាការ ពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះត្រូវជ្រើសតាំងមជ្ឈត្តករតាមសំណូមពររបស់ភាគីវិវាទណាមួយ ។

៤-តាមនីតិវិធីជ្រើសតាំងមជ្ឈត្តករ ដែលបានព្រមព្រៀងដោយភាគីវិវាទភាគីវិ-វាទណាក៏ដោយ អាចធ្វើសំណូមពរទៅតុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមា-ត្រា ៦ នៃច្បាប់នេះឱ្យចាត់វិធានការចាំបាច់ ក្នុងករណីណាមួយដូចខាងក្រោម :

ក-ភាគីវិវាទមួយមិនបានប្រតិបត្តិតាមការតម្រូវក្នុងនីតិវិធី ឬ

ខ-ភាគីវិវាទ ឬ មជ្ឈត្តករពីរ (២) នាក់ មិនអាចឈានដល់ការព្រមព្រៀងដូចដែលគេរំពឹងទុកតាមនីតិវិធីនេះ ឬ

គ-ភាគីទីបី ដោយរាប់បញ្ចូលទាំងស្ថាប័នមួយផង មិនបានអនុវត្តតួនាទីណាមួយដូចដែលបានប្រគល់ឱ្យក្នុងនីតិវិធីនោះ ។ មាត្រានេះ មិនត្រូវបានយកមកអនុវត្តទេ ប្រសិនបើការព្រមព្រៀងស្តីពីនីតិវិធីជ្រើសតាំងមជ្ឈត្តករមានចែងពីវិធីផ្សេងទៀតសម្រាប់ធានាដល់ការជ្រើសតាំងនោះ ។

៥-ការជ្រើសតាំងរបស់តុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ លើបញ្ហាណាមួយតាមកថាខណ្ឌទី ៣ ឬ កថាខណ្ឌទី ៤ នៃមាត្រានេះ គឺជាការសម្រេចដែលមិនអាចតវ៉ាបានឡើយ ។ នៅក្នុងការជ្រើសតាំងមជ្ឈត្តករម្នាក់ តុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ត្រូវពិចារណាពីលក្ខណៈសម្បត្តិរបស់មជ្ឈត្តករដែលបានចែងក្នុងកិច្ចព្រមព្រៀងរបស់ភាគីវិវាទ ដើម្បីធានាដល់ការជ្រើសតាំងមជ្ឈត្តករដែលឯករាជ្យ និងមិនលម្អៀង ។ ក្នុងករណីមានមជ្ឈត្តករតែមួយនាក់

ឬ មានមជ្ឈត្តករទីបី នៅក្នុងការធ្វើមជ្ឈត្តការដែលមានលក្ខណៈអន្តរជាតិ តុលាការ ( តុលា-ការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ត្រូវពិនិត្យលទ្ធភាពជ្រើសតាំងមជ្ឈត្តករដែលមានសញ្ជាតិផ្សេងពីសញ្ជាតិរបស់ភាគីវិវាទ ដូចមានចែងក្នុងចំណុច ១ នៃមាត្រា ១៩ នៃច្បាប់នេះ ។

**មាត្រា ២០.-**

បុគ្គលម្នាក់ដែលត្រូវគេជ្រើសតាំងជាមជ្ឈត្តករ ត្រូវបង្ហាញពីលក្ខណៈពិសេសដែលអាចបង្កឱ្យមានការសង្ស័យពីភាពមិនលម្អៀង ឬ ពីភាពឯករាជ្យរបស់ខ្លួន ចាប់ពីពេលដែលត្រូវគេជ្រើសតាំងមក រហូតដល់ពេលបញ្ចប់ដំណើរការមជ្ឈត្តការ ។ មជ្ឈត្តករត្រូវបង្ហាញពីលក្ខណៈពិសេសទាំងនោះឱ្យភាគីវិវាទបានដឹង ដោយគ្មានពន្យារពេល លើកលែងតែភាគីវិវាទបានដឹងពីលក្ខណៈសម្បត្តិរបស់មជ្ឈត្តករនោះរួចហើយ ។

មជ្ឈត្តករម្នាក់អាចត្រូវជំទាស់តែក្នុងករណីដែលកើតមានការសង្ស័យពីលក្ខណៈពិសេសដែលប៉ះពាល់ដល់ភាពមិនលម្អៀង ឬ ភាពឯករាជ្យរបស់ខ្លួន ឬ នៅពេលដែលខ្លួនមិនមានលក្ខណៈសម្បត្តិដូចដែលភាគីវិវាទបានព្រមព្រៀង ។ ភាគីវិវាទមួយអាចជំទាស់នឹងមជ្ឈត្ត-ករដែលខ្លួនបានជ្រើសតាំង ឬ បានចូលរួមជ្រើសតាំងតែក្នុងករណីដែលមូលហេតុនៃការជំទាស់នោះត្រូវបានដឹងក្រោយពេលជ្រើសតាំងរួចប៉ុណ្ណោះ ។

**មាត្រា ២១.-**

ភាគីវិវាទដែលមានបំណងជំទាស់ទៅនឹងមជ្ឈត្តករ ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោមៈ

១-ភាគីវិវាទ អាចព្រមព្រៀងលើនីតិវិធីនៃការជំទាស់នឹងមជ្ឈត្តករដោយអនុលោមតាមបទប្បញ្ញត្តិនៃកថាខណ្ឌទី ៣ ក្នុងមាត្រានេះ ។

២-ក្នុងករណីគ្មានការព្រមព្រៀងលើនីតិវិធីនៃការជំទាស់នេះ ភាគីវិវាទមួយដែលមានបំណងជំទាស់នឹងមជ្ឈត្តករ ត្រូវធ្វើលិខិតតវ៉ាបញ្ជាក់មូលហេតុពីការជំទាស់នោះជាលាយលក្ខណ៍អក្សរទៅកាន់វេទិកាមជ្ឈត្តកម្ម ក្នុងរយៈពេលដប់ប្រាំ (១៥) ថ្ងៃ ក្រោយពេលបង្កើតវេទិកាមជ្ឈត្តកម្ម ឬ ក្រោយពេលបានដឹងពីលក្ខណៈពិសេស ដូចចែងក្នុងមាត្រា ២០ នៃកថាខណ្ឌទី ២ ។ វេទិកាមជ្ឈត្តកម្មត្រូវសម្រេចលើការជំទាស់ លើកលែងតែមជ្ឈត្តករដែល

គេជំទាស់នោះ ដកខ្លួនថយពីមុខតំណែង ឬ លើកលែងតែភាគីវិវាទមួយទៀតបានឯកភាព នឹងការជំទាស់នោះ ។

៣-ប្រសិនបើការជំទាស់ដែលត្រូវធ្វើតាមនីតិវិធីដែលព្រមព្រៀងដោយភាគីវិវាទ ឬ តាមនីតិវិធីក្នុងកថាខណ្ឌទី ២ នៃមាត្រានេះពុំបានសម្រេចទេនោះ ភាគីជំទាស់អាចស្នើសុំឱ្យតុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះធ្វើការសម្រេចចុងក្រោយលើការជំទាស់ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ បន្ទាប់ពីបានទទួលសេចក្ដីជូនដំណឹងបដិសេធការជំទាស់ ។ ក្នុងពេលរង់ចាំការសម្រេចរបស់តុលាការលើសំណើជំទាស់នេះ វេទិកាមជ្ឈត្តកម្មក្នុងនោះមានទាំងមជ្ឈត្តករដែលត្រូវគេជំទាស់ផងអាចបន្តដំណើរការមជ្ឈត្តការ ហើយអាចធ្វើសេចក្ដីសម្រេចបាន ។

**មាត្រា ២២.–**

ប្រសិនបើមជ្ឈត្តករម្នាក់ពុំអាចបំពេញមុខងាររបស់ខ្លួនបានដោយមូលហេតុខាងច្បាប់ ឬ មូលហេតុជាក់ស្ដែងណាមួយ ឬ មូលហេតុដទៃទៀតក្នុងរយៈពេលមួយសមស្របនោះ អាណត្តិរបស់មជ្ឈត្តករនោះត្រូវបានបញ្ចប់ដោយមជ្ឈត្តករនោះដកខ្លួនថយពីមុខតំណែង ឬ ដោយភាគីវិវាទឯកភាពបញ្ចប់អាណត្តិនោះ ។ ផ្ទុយពីនេះ បើនៅតែមានភាពខ្វែងគ្នាស្ដីពីមូលហេតុណាមួយ ក្នុងចំណោមមូលហេតុទាំងនេះ ភាគីណាក៏ដោយអាចស្នើសុំឱ្យតុលាការ (តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាកាកំពូល) ឬ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះធ្វើការសម្រេចចុងក្រោយពីការបញ្ចប់អាណត្តិនោះ ។

តាមមាត្រានេះ ឬ មាត្រា ២១ កថាខណ្ឌទី ២ នៃច្បាប់នេះ ប្រសិនបើមជ្ឈត្តករម្នាក់ដកខ្លួនថយពីមុខតំណែង ឬ ប្រសិនបើភាគីមួយឯកភាពចំពោះការបញ្ចប់អាណត្តិរបស់មជ្ឈត្តករនោះ ហេតុការណ៍នេះមិនបណ្ដាលឱ្យមានការទទួលយកជាការបាននូវមូលហេតុណាមួយដែលចែងក្នុងមាត្រានេះ ឬ មាត្រា ២០ កថាខណ្ឌទី ២ នៃច្បាប់នេះឡើយ ។

**មាត្រា ២៣.–**

ក្នុងករណីដែលអាណត្តិរបស់មជ្ឈត្តករម្នាក់ត្រូវបញ្ចប់តាមបញ្ញត្តិនៃមាត្រា ២១ ឬ មាត្រា ២២ នៃច្បាប់នេះ មជ្ឈត្តករជំនួសនឹងត្រូវជ្រើសតាំងស្របតាម វិធាននៃមាត្រា ១៩ នៃច្បាប់នេះ ។

## ជំពូកទី ៥
## សមត្ថកិច្ចរបស់វេទិកាមជ្ឈត្តកម្ម

**មាត្រា ២៤.–**

សមត្ថកិច្ចរបស់វេទិការមជ្ឈត្តកម្មត្រូវកំណត់ដូចខាងក្រោម ៖

១-វេទិកាមជ្ឈត្តកម្មអាចសម្រេចទៅតាមសមត្ថកិច្ចរបស់ខ្លួន ក្នុងនោះមានការជំទាស់នានាដែលទាក់ទងនឹងអត្ថិភាព ឬ សុពលភាពនៃកិច្ចព្រមព្រៀងផ្សះផ្សា ។ សម្រាប់គោលដៅនេះ ខចែងស្តីពីការផ្សះផ្សាដែលបង្កើតបានជាផ្នែកមួយនៃកិច្ចសន្យា ត្រូវចាត់ទុកថាជាកិច្ចព្រមព្រៀងដោយឡែក ដែលមិនទាក់ទិនទៅនឹងល័ក្ខខ័ណ្ឌដទៃទៀតក្នុងកិច្ចសន្យាឡើយ ។ ការសម្រេចរបស់វេទិកាមជ្ឈត្តកម្ម ដែលចាត់ទុកកិច្ចសន្យាថាមោឃៈ និងអសារឥតការមិននាំអោយខចែងស្តីពីការផ្សះផ្សានោះបាត់សុពលភាពឡើយ ។

២-ទឡ្ហីករណ៍ដែលបញ្ជាក់ថា វេទិកាមជ្ឈត្តកម្មពុំមានអំណាចធ្វើមជ្ឈត្តការនោះ ត្រូវបង្ហាញឱ្យឃើញមុនការដាក់ជូនពាក្យដោះសា ។ មិនត្រូវហាមឃាត់ភាគីវិវាទមួយមិនឱ្យលើកឡើងពីទឡ្ហីករណ៍បែបនេះ ដោយសារតែភាគីនោះបានតែងតាំង ឬ បានចូលរួមតែងតាំងមជ្ឈត្តករឡើយ ។ ទឡ្ហីករណ៍ដែលបញ្ជាក់ថា ក្របខ័ណ្ឌជំលោះដែលមានកំរិតហួសពីក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់វេទិកាមជ្ឈត្តកម្មត្រូវបង្ហាញភ្លាមៗនៅពេលដែលបញ្ហាហួសក្របខ័ណ្ឌសមត្ថកិច្ចនេះ ត្រូវបានគេលើកឡើងក្នុងពេលធ្វើមជ្ឈត្តការ ។ ក្នុងចំណោមករណីទាំងពីរ វេទិកាមជ្ឈត្តកម្មអាចទទួលយកទឡ្ហីករណ៍ ដែលលើកឡើងក្រោយរយៈពេលកំណត់ ប្រសិនបើពិចារណាឃើញថា ការយឺតយ៉ាវនេះមានភាពត្រឹមត្រូវ ។

៣-វេទិកាមជ្ឈត្តកម្មអាចធ្វើសេចក្តីសម្រេចលើទឡ្ហីករណ៍ដូចចែងក្នុងកថាខណ្ឌ

ទី ២ នៃមាត្រានេះ ដោយចាត់ទុកថាជាបញ្ហាដំបូង ឬ ថាជាការសម្រេចតាមជាក់ស្តែង ។ ប្រសិនបើវេទិកាមជ្ឈត្តកម្មចាត់ទុកថាជាបញ្ហាដំបូងដែលខ្លួនមានអំណាចសម្រេចនោះ ភាគីណាក៏ដោយ ក៏អាចធ្វើសំណើទៅតុលាការ ( តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ) ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ឱ្យសម្រេចចុងក្រោយលើបញ្ហានេះក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ក្រោយពីបានទទួលសេចក្តីជូនដំណឹងពីការសម្រេចនោះរបស់វេទិកា ។ ការសម្រេចរបស់តុលាការក្នុងរឿងនេះគឺជាការសម្រេចដែលមិនអាចតវ៉ាបាន ។ ក្នុងពេលរង់ចាំការសម្រេចពីតុលាការនោះ វេទិកាមជ្ឈត្តកម្មអាចបន្តដំណើរការមជ្ឈត្តការ និងអាចធ្វើមជ្ឈត្តវិនិច្ឆ័យបាន ។

### មាត្រា ២៥.-

តាមការស្នើសុំរបស់ភាគីវិវាទមួយ វេទិកាមជ្ឈត្តកម្មអាចបង្គាប់ឱ្យភាគីណាមួយចាត់វិធានការបណ្តោះអាសន្នទៅតាមការចាំបាច់ទាក់ទិននឹងកម្មវត្ថុវិវាទ វៀរលែងតែភាគីវិវាទបានព្រមព្រៀងគ្នាផ្សេងពីនេះ ។ វេទិកាមជ្ឈត្តកម្មអាចតម្រូវឱ្យភាគីវិវាទណាមួយបង់ប្រាក់ធានាសមស្របសម្រាប់វិធានការនេះ ។

## ជំពូកទី ៦
## ដំណើរការនៃនីតិវិធីមជ្ឈត្តការ

### មាត្រា ២៦.-

ភាគីវិវាទត្រូវបានទទួលការយកចិត្តទុកដាក់ស្មើៗគ្នា និងត្រូវបានផ្តល់ឱកាសពេញលេញ ដើម្បីបង្ហាញពីរឿងរ៉ាវរបស់ខ្លួនរួមទាំងសិទ្ធិតែងតាំងជនណាម្នាក់ឱ្យធ្វើជាតំណាងរបស់ខ្លួនបាន ។

### មាត្រា ២៧.-

ភាគីវិវាទអាចព្រមព្រៀង ឬ មិនព្រមព្រៀងលើនីតិវិធីដែលវេទិកាមជ្ឈត្តកម្ម ត្រូវអនុវត្តដើម្បីចាត់ចែងដំណើរការមជ្ឈត្តការ ។

ក្នុងករណីគ្មានការព្រមព្រៀងពីនីតិវិធីនេះទេ វេទិកាមជ្ឈត្តកម្មអាចចាត់ចែងការធ្វើមជ្ឈត្តការទៅតាមបែបបទណាដែលវេទិកាយល់ឃើញថាសមស្រប ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។ អំណាចដែលត្រូវបានប្រគល់ឱ្យទៅវេទិកាមជ្ឈត្តកម្មរួមមានអំ-ណាចក្នុងការកំណត់ពីភាពយកជាការបាននៃភស្តុតាងណាមួយ ។

**មាត្រា ២៨.–**

ភាគីវិវាទអាចព្រមព្រៀងពីទីកន្លែងមជ្ឈត្តការ ។ ក្នុងករណីមិនបានព្រមព្រៀងពីទីកន្លែងទេ វេទិកាមជ្ឈត្តកម្មត្រូវកំណត់ទីតាំងដោយគិតគូរពីលក្ខណៈពិសេសនៃវិវាទ ក្នុងនោះត្រូវមានការឯកភាពពីភាគីវិវាទផង ។

ថ្វីបើមានបទប្បញ្ញត្តិក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះក៏ដោយ ក៏វេទិកាមជ្ឈត្តកម្មអាចប្រជុំនៅកន្លែងណាមួយដែលសមស្របក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ក្នុងបំណងពិគ្រោះយោបល់ក្នុងចំណោមសមាជិករបស់វេទិកា ស្តាប់សាក្សី ស្តាប់អ្នកជំនាញការ ស្តាប់ភាគីវិវាទ ឬ ធ្វើអធិការកិច្ចលើសម្ភារៈ កម្មសិទ្ធិ ឬ ឯកសារដទៃទៀត ។

**មាត្រា ២៩.–**

ដំណើរការមជ្ឈត្តការដែលទាក់ទងនឹងវិវាទណាមួយ ចាប់ផ្តើមឡើងនៅថ្ងៃនៃកាលបរិ-ច្ឆេទ ដែលភាគីឆ្លើយតបបានទទួលសំណើសុំឱ្យធ្វើមជ្ឈត្តការ វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ។

**មាត្រា ៣០.–**

ភាគីវិវាទអាចព្រមព្រៀងលើភាសាណាមួយ ឬ លើសពីមួយ ដែលត្រូវប្រើប្រាស់ក្នុងដំណើរការធ្វើមជ្ឈត្តការ ។ ក្នុងករណីគ្មានការឯកភាពលើភាសាទេ វេទិកាមជ្ឈត្តកម្មត្រូវកំណត់ភាសាណាមួយ ឬ លើសពីមួយសម្រាប់ប្រើប្រាស់ក្នុងដំណើរការមជ្ឈត្តការ ។

វេទិកាមជ្ឈត្តកម្មអាចបង្គាប់ឱ្យមានការបកប្រែភ្ជាប់ជាមួយនឹងឯកសារ ភស្តុតាង ដោយប្រើប្រាស់ភាសាណាមួយ ឬ លើសពីមួយ ដែលបានឯកភាពដោយភាគីវិវាទ ឬ ដែលបានកំណត់ដោយវេទិកាមជ្ឈត្តកម្ម ។

**មាត្រា ៣១.–**

នៅក្នុងរយៈពេលដែលឯកភាពដោយភាគីវិវាទ ឬ កំណត់ដោយវេទិកាមជ្ឈត្តកម្ម អ្នកប្តឹងទាមទារត្រូវបញ្ជាក់ពីអង្គហេតុ ដើម្បីគាំទ្រការទាមទាររបស់ខ្លួនព្រមទាំងបញ្ជាក់ពីចំណុចជាក់លាក់នៃបញ្ហា និងសំណងការខូចខាតដែលត្រូវទាមទារ ហើយភាគីឆ្លើយតបត្រូវឆ្លើយបញ្ជាក់ពីការដោះសាលើចំណុចទាំងនេះ វៀរលែងតែភាគីវិវាទបានព្រមព្រៀងថា ក្នុងបណ្តឹងទាមទារ ឬ ការដោះសា ត្រូវបញ្ជាក់ផ្សេងពីនេះ ។ ភាគីវិវាទអាចភ្ជាប់ឯកសារទាំងអស់ដែលយល់ថាទាក់ទងនឹងពាក្យបណ្តឹងទាមទារ ឬ ពាក្យដោះសា ឬ អាចបន្ថែមការយោងលើឯកសារ ឬ ភស្តុតាងដទៃទៀត ដែលភាគីទាំងនោះត្រូវដាក់ជូនវេទិកាមជ្ឈត្តកម្ម ។

វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ភាគីវិវាទមួយអាចសុំកែសម្រួល ឬ បំពេញបន្ថែមលើពាក្យបណ្តឹងទាមទារ ឬ ពាក្យដោះសារបស់ខ្លួនបាន ក្នុងពេលកំពុងដំណើរការធ្វើមជ្ឈត្តការ លើកលែងតែវេទិកាមជ្ឈត្តកម្មយល់ថា ការសុំពន្យារពេលដើម្បីកែសម្រួលនេះពុំមានលក្ខណៈសមស្រប ។

**មាត្រា ៣២.–**

លើកលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ វេទិកាមជ្ឈត្តកម្មត្រូវសម្រេចថា តើត្រូវធ្វើសវនាការដោយផ្ទាល់មាត់ដើម្បីបង្ហាញពីភស្តុតាង ឬ ទឡ្ហីករណ៍ផ្ទាល់មាត់ ឬ ក៏ត្រូវដំណើរការមជ្ឈត្តការដោយផ្អែកលើមូលដ្ឋាននៃឯកសារ ឬ លិខិតស្នាមដទៃទៀត ។ ក៏ប៉ុន្តែបើមានសំណើពីភាគីវិវាទមួយ វេទិកាមជ្ឈត្តកម្មត្រូវរៀបចំសវនាការបែបនេះ ក្នុងដំណាក់កាលសមស្របណាមួយនៃមជ្ឈត្តការ វៀរលែងតែភាគីវិវាទបានឯកភាពថា មិនត្រូវធ្វើសវនាការ ។

ត្រូវជូនដំណឹងឱ្យបានគ្រប់គ្រាន់ជាមុនដល់ភាគីវិវាទស្តីពីសវនាការ ឬ ក៏ការប្រជុំណាមួយរបស់វេទិកាមជ្ឈត្តកម្ម ដែលមានគោលបំណងធ្វើអធិការកិច្ចលើសម្ភារៈ ទំនិញ ទ្រព្យសម្បត្តិ និងឯកសារដទៃទៀត ។

រាល់សេចក្តីថ្លែង ឯកសារ ឬ ព័ត៌មានដទៃទៀត ដែលភាគីវិវាទមួយផ្តល់ជូនវេទិកាមជ្ឈត្តកម្ម ក៏ត្រូវបញ្ជូនទៅឱ្យភាគីវិវាទម្ខាងទៀតដែរ ។ របាយការណ៍របស់អ្នកជំនាញការ ឬ

ឯកសារភស្តុតាងណាមួយ ដែលវេទិកាមជ្ឈត្តកម្មអាចយកជាសំអាង ដើម្បីធ្វើការសម្រេច ក៏ត្រូវបញ្ជូនជាដំណឹងឱ្យភាគីវិវាទដែរ ។

**មាត្រា ៣៣.–**

វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ហើយបើគ្មានការបង្ហាញមូលហេតុគ្រប់គ្រាន់ :

១-វេទិកាមជ្ឈត្តកម្មត្រូវបញ្ចប់ដំណើរការមជ្ឈត្តការ ក្នុងករណីដែលអ្នកប្តឹងពុំមានបញ្ជាក់លើពាក្យបណ្តឹងទាមទាររបស់ខ្លួនតាមមាត្រា ៣១ នៃ កថាខណ្ឌទី ១ នៃច្បាប់នេះ ។

២-បើភាគីឆ្លើយតបពុំអាចផ្តល់សេចក្តីដោះសាររបស់ខ្លួនដូចចែងក្នុងមាត្រា ៣១ នៃកថាខណ្ឌទី ១ នៃច្បាប់នេះ វេទិកាមជ្ឈត្តកម្មត្រូវបន្តដំណើរការមជ្ឈត្តការដោយពុំចាត់ទុកការខកខាននេះថា ជាការទទួលស្គាល់ពាក្យចោទប្រកាន់របស់ភាគីប្តឹងទាមទារឡើយ ។

៣-បើភាគីវិវាទណាមួយពុំបានបង្ហាញមុខនៅសវនាការ ឬ ពុំបានផ្តល់ឯកសារភស្តុតាង វេទិកាមជ្ឈត្តកម្មអាចបន្តដំណើរការ ហើយធ្វើសេចក្តីសម្រេចដោយផ្អែកលើភស្តុ-តាងដែលមាននៅចំពោះមុខ ។

**មាត្រា ៣៤.–**

វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ វេទិកាមជ្ឈត្តកម្មអាច :

១-តែងតាំងអ្នកជំនាញការម្នាក់ ឬ ច្រើននាក់ ដើម្បីរាយការណ៍ឱ្យខ្លួនស្តីពីបញ្ហាជាក់លាក់នានា ដែលកំណត់ដោយវេទិកាមជ្ឈត្តកម្ម ។

២-តម្រូវឱ្យភាគីវិវាទមួយផ្តល់ព័ត៌មាន ឬ ឯកសារ ឬ អនុញ្ញាតឱ្យអ្នកជំនាញការពិនិត្យលើឯកសារ សម្ភារៈដែលសមស្របផ្សេងៗដែលទាក់ទងដល់ការធ្វើអធិការកិច្ចរបស់អ្នកជំនាញការ ។

វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ប្រសិនបើមានភាគីវិវាទមួយស្នើសុំ ឬ វេទិកាមជ្ឈត្តកម្មយល់ថាចាំបាច់ អ្នកជំនាញការបន្ទាប់ពីបានបង្ហាញរបាយការណ៍ផ្ទាល់មាត់ ឬ លាយលក្ខណ៍អក្សររួចហើយ ត្រូវចូលរួមក្នុងសវនាការដែលក្នុងឱកាសនោះ ភាគីវិវាទអាចលើកសំណួរ និងអញ្ជើញជំនាញការផ្សេងទៀត ក្នុងនាមជាសាក្សី ដើម្បីបញ្ជាក់ពីចំណុចជាក់លាក់នៃជម្លោះ ។

**មាត្រា ៣៥.–**

វេទិកាមជ្ឈត្តកម្ម ឬ ភាគីវិវាទមួយដោយបានការឯកភាពពីវេទិកាមជ្ឈត្តកម្ម អាចស្នើសុំជំនួយពីតុលាការ (តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬ តុលាការកំពូល) ក្នុងការត្រួតពិនិត្យភស្តុតាង ។ តុលាការ (តុលាការពាណិជ្ជកម្ម ឬ សាលាឧទ្ធរណ៍ ឬតុលាការកំពូល) អាចអនុវត្តតាមសំណើនេះនៅក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន និងដោយអនុលោមតាមវិធានស្តីពីការត្រួតពិនិត្យភស្តុតាង ។

## ជំពូកទី ៧
## ការធ្វើមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម
## និងការបញ្ចប់ដំណើរការមជ្ឈត្តការ

**មាត្រា ៣៦.–**

ក្នុងការធ្វើមជ្ឈត្តវិនិច្ឆ័យវេទិកាមជ្ឈត្តកម្មត្រូវ :

១-សម្រេចពីវិវាទមួយទៅតាមវិធាននៃច្បាប់ ដែលជ្រើសរើសដោយភាគីវិវាទ និងដែលអនុវត្តបានចំពោះកម្មវត្ថុនៃវិវាទនេះ ។ ការកំណត់យកច្បាប់ ឬ ប្រព័ន្ធច្បាប់នៃប្រទេសណាមួយដែលត្រូវយកទៅបកស្រាយ គឺមិនត្រូវបកស្រាយដោយសំអាងលើភាពផ្ទុយគ្នានៃច្បាប់ ឬវិធាននៃច្បាប់នោះឡើយ វៀរលែងតែមានការបញ្ជាក់ផ្សេងពីនេះ ។

២-ប្រើប្រាស់ច្បាប់ណាដែលយល់ថាអាចអនុវត្តបាន ក្នុងករណីដែលភាគីវិវាទមិនបានធ្វើការកំណត់លើប្រព័ន្ធច្បាប់ទេនោះ ។

៣-ធ្វើមជ្ឈត្តវិនិច្ឆ័យស្របតាមសមធម៌ ឬ តាមការស្រុះស្រួលតែក្នុងករណីដែលភាគីវិវាទអនុញ្ញាតច្បាស់លាស់ឱ្យធ្វើដូច្នោះ ។

៤-ធ្វើមជ្ឈត្តវិនិច្ឆ័យឱ្យស្របតាមល័ក្ខខ័ណ្ឌនៃកិច្ចសន្យា និងត្រូវយកចិត្តទុកដាក់ផងដែរដល់ទម្លាប់ផ្នែកពាណិជ្ជកម្ម ដែលអនុវត្តបានចំពោះមុខជំនួញនោះ ។

**មាត្រា ៣៧.–**

ក្នុងដំណើរការមជ្ឈត្តការដែលមានមជ្ឈត្តករលើសពីមួយនាក់ មជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម ត្រូវធ្វើឡើងតាមមតិភាគច្រើនដោយប្រៀបនៃមជ្ឈត្តករ ដែលជាសមាជិកនៃវេទិកាមជ្ឈត្តកម្ម ។

**មាត្រា ៣៨.–**

មុនពេលចាប់ផ្តើមដំណើរការមជ្ឈត្តការផ្លូវការ វេទិកាមជ្ឈត្តកម្មត្រូវពិភាក្សាជាមួយភាគីវិវាទ ដើម្បីស្វែងរកលទ្ធភាពនៃការដោះស្រាយវិវាទដោយស្ម័គ្រចិត្តរបស់ភាគី :

១-ប្រសិនបើភាគីវិវាទព្រមដោះស្រាយវិវាទដោយស្ម័គ្រចិត្ត វេទិកាមជ្ឈត្តកម្មត្រូវជួយភាគីវិវាទទៅតាមបែបបទដែលសមស្រប ។

២-ប្រសិនបើភាគីវិវាទបានស្រុះស្រួលគ្នាមុនពេលចាប់ផ្តើម ឬ ក្នុងពេលកំពុងធ្វើមជ្ឈត្តការជាផ្លូវការ វេទិកាមជ្ឈត្តកម្មត្រូវបញ្ចប់ដំណើរការ ។ ប្រសិនបើមានការស្នើសុំពីភាគីវិវាទ វេទិកាមជ្ឈត្តកម្មអាចកត់ត្រាទុកការដោះស្រាយនោះ ក្នុងមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម ។

៣-មជ្ឈត្តវិនិច្ឆ័យដែលផ្អែកលើការស្រុះស្រួល ត្រូវធ្វើឡើងតាមបទប្បញ្ញត្តិក្នុងមាត្រា ៣៩ នៃច្បាប់នេះ ហើយត្រូវបញ្ជាក់ថាជាមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម ។ មជ្ឈត្តវិនិច្ឆ័យនេះមានលក្ខណៈ និង ឥទ្ធិពលដូចមជ្ឈត្តវិនិច្ឆ័យដទៃទៀតដែលវេទិកាមជ្ឈត្តកម្មធ្វើដោយផ្អែកលើភាពជាក់ស្តែងនៃវិវាទដែរ ។

**មាត្រា ៣៩.–**

មជ្ឈត្តវិនិច្ឆ័យត្រូវមានទ្រង់ទ្រាយ និងខ្លឹមសារដូចខាងក្រោម :

១-មជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្មត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវចុះហត្ថលេខាដោយមជ្ឈត្តករ ។ ក្នុងដំណើរការមជ្ឈត្តការដែលមានមជ្ឈត្តករលើសពីមួយនាក់ ហត្ថលេខារបស់សមាជិកភាគច្រើនក្នុងវេទិកាមជ្ឈត្តកម្មត្រូវចាត់ទុកថាគ្រប់គ្រាន់ លើកណាមានការបញ្ជាក់ពីមូលហេតុដែលមជ្ឈត្តករដទៃទៀតមិនបានចុះហត្ថលេខា ។

២-មជ្ឈត្តវិនិច្ឆ័យត្រូវបញ្ជាក់ពីមូលហេតុនានាដែលបានយកមកធ្វើជាគោលបង្អែក វៀរលែងតែភាគីវិវាទបានព្រមព្រៀងគ្នាថាមិនចាំបាច់បញ្ជាក់ពីមូលហេតុទេ ឬ វៀរលែងតែ

**មាត្រា ៣៧.–**

ក្នុងដំណើរការមជ្ឈត្តការដែលមានមជ្ឈត្តករលើសពីមួយនាក់ មជ្ឈត្តវិនិច្ឆ័យរបស់វេទិ-កាមជ្ឈត្តកម្ម ត្រូវធ្វើឡើងតាមមតិភាគច្រើនដោយប្រៀបនៃមជ្ឈត្តករ ដែលជាសមាជិកនៃវេទិកាមជ្ឈត្តកម្ម ។

**មាត្រា ៣៨.–**

មុនពេលចាប់ផ្ដើមដំណើរការមជ្ឈត្តការផ្លូវការ វេទិកាមជ្ឈត្តកម្មត្រូវពិភាក្សាជាមួយភាគីវិវាទ ដើម្បីស្វែងរកលទ្ធភាពនៃការដោះស្រាយវិវាទដោយស្ម័គ្រចិត្តរបស់ភាគី :

១-ប្រសិនបើភាគីវិវាទព្រមដោះស្រាយវិវាទដោយស្ម័គ្រចិត្ត វេទិកាមជ្ឈត្តកម្មត្រូវជួយភាគីវិវាទទៅតាមបែបបទដែលសមស្រប ។

២-ប្រសិនបើភាគីវិវាទបានស្រុះស្រួលគ្នាមុនពេលចាប់ផ្ដើម ឬ ក្នុងពេលកំពុងធ្វើមជ្ឈត្តការជាផ្លូវការ វេទិកាមជ្ឈត្តកម្មត្រូវបញ្ឈប់ដំណើរការ ។ ប្រសិនបើមានការស្នើសុំពីភាគីវិវាទ វេទិកាមជ្ឈត្តកម្មអាចកត់ត្រាទុកការដោះស្រាយនោះ ក្នុងមជ្ឈត្តវិនិច្ឆ័យរបស់វេ-ទិកាមជ្ឈត្តកម្ម ។

៣-មជ្ឈត្តវិនិច្ឆ័យដែលផ្អែកលើការស្រុះស្រួល ត្រូវធ្វើឡើងតាមបទប្បញ្ញត្តិក្នុងមាត្រា ៣៩ នៃច្បាប់នេះ ហើយត្រូវបញ្ជាក់ថាជាមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម ។ មជ្ឈ-ត្តវិនិច្ឆ័យនេះមានលក្ខណៈ និង ឥទ្ធិពលដូចមជ្ឈត្តវិនិច្ឆ័យដទៃទៀតដែលវេទិកាមជ្ឈត្តកម្មធ្វើដោយផ្អែកលើភាពជាក់ស្តែងនៃវិវាទដែរ ។

**មាត្រា ៣៩.–**

មជ្ឈត្តវិនិច្ឆ័យត្រូវមានទ្រង់ទ្រាយ និងខ្លឹមសារដូចខាងក្រោម :

១-មជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្មត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវចុះហត្ថលេខាដោយមជ្ឈត្តករ ។ ក្នុងដំណើរការមជ្ឈត្តការដែលមានមជ្ឈត្តករលើសពីមួយនាក់ ហត្ថលេខារបស់សមាជិកភាគច្រើនក្នុងវេទិកាមជ្ឈត្តកម្មត្រូវចាត់ទុកថាគ្រប់គ្រាន់ ល្អីកណាមានការបញ្ជាក់ពីមូលហេតុដែលមជ្ឈត្តករដទៃទៀតមិនបានចុះហត្ថលេខា ។

២-មជ្ឈត្តវិនិច្ឆ័យត្រូវបញ្ជាក់ពីមូលហេតុនានាដែលបានយកមកធ្វើជាគោលបង្អែកវៀរលែងតែភាគីវិវាទបានព្រមព្រៀងគ្នាថាមិនចាំបាច់បញ្ជាក់ពីមូលហេតុទេ ឬ វៀរលែងតែ

មជ្ឈត្តវិនិច្ឆ័យដែលផ្អែកលើការស្រុះស្រួលរបស់ភាគី ដូចមានចែងក្នុងមាត្រា ៣៨ នៃច្បាប់នេះ ។

៣-មជ្ឈត្តវិនិច្ឆ័យត្រូវបញ្ជាក់ពីសោហ៊ុយចំណាយក្នុងការធ្វើមជ្ឈត្តការ ដែលភាគីវិវាទមានចំណែកត្រូវចេញ ក្នុងនោះមានប្រាក់កម្រៃសម្រាប់មជ្ឈត្តករនិងការចំណាយផ្សេងៗដែលបានបម្រុងទុកជាមុន ដោយអនុលោមតាមបែបបទដែលព្រមព្រៀងដោយភាគីវិវាទ ឬ អនុលោមតាមការយល់សមស្របរបស់មជ្ឈត្តករ ប្រសិនបើគ្មានការព្រមព្រៀងដោយភាគីទេ ។ មជ្ឈត្តវិនិច្ឆ័យអាចចែងផងដែរពីសោហ៊ុយចំណាយសមស្របសម្រាប់ការពិគ្រោះច្បាប់ដែលត្រូវសងទៅឱ្យភាគីឈ្នះ ប្រសិនបើភាគីវិវាទបានព្រមព្រៀងដូច្នោះ ឬ មជ្ឈត្តករយល់ថាសមស្រប ។

៤-មជ្ឈត្តវិនិច្ឆ័យត្រូវចែងពីកាលបរិច្ឆេទ និងទីកន្លែងផ្សះផ្សាដូចកំណត់ក្នុងមាត្រា ២៨ កថាខណ្ឌទី ១ នៃច្បាប់នេះ ។ ត្រូវចាត់ទុកទីកន្លែងធ្វើមជ្ឈត្តការជាទីកន្លែងធ្វើមជ្ឈត្ត-វិនិច្ឆ័យ ។

៥-បន្ទាប់ពីធ្វើមជ្ឈត្តវិនិច្ឆ័យរួចហើយ អត្ថបទចម្លងនៃមជ្ឈត្តវិនិច្ឆ័យនោះ ដែលចុះហត្ថលេខាដោយមជ្ឈត្តករតាមបែបបទក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវបញ្ជូនទៅឱ្យភាគីវិវាទនីមួយៗ ។

## មាត្រា ៤០.-

ដំណើរការមជ្ឈត្តការត្រូវបញ្ចប់ដោយធ្វើមជ្ឈត្តវិនិច្ឆ័យជាស្ថាពរ ឬ ដោយដីកាបង្គាប់របស់វេទិកាមជ្ឈត្តកម្មស្របតាមកថាខណ្ឌទី ២ នៃមាត្រានេះ ។

វេទិកាមជ្ឈត្តកម្មចេញដីកាបង្គាប់ដើម្បីបញ្ចប់ដំណើរការមជ្ឈត្តការ នៅក្នុងករណីដែល :

១-ភាគីប្ដឹងទាមទារដកពាក្យទាមទាររបស់ខ្លួន វៀរលែងតែភាគីឆ្លើយតបធ្វើការជំទាស់នឹងការដកពាក្យនោះ ហើយវេទិកាមជ្ឈត្តកម្មទទួលស្គាល់ពីអត្ថប្រយោជន៍ស្របច្បាប់របស់ភាគីឆ្លើយតបក្នុងការទទួលដំណោះស្រាយវិវាទជាស្ថាពរ ។

២-ភាគីវិវាទឯកភាពឱ្យបញ្ចប់ដំណើរការមជ្ឈត្តការ ។

៣-វេទិកាមជ្ឈត្តកម្មរកឃើញមូលហេតុដទៃទៀត ដែលបញ្ជាក់ពីភាពមិនចាំបាច់សម្រាប់បន្តដំណើរការ ឬ ការធ្វើមជ្ឈត្តការនោះពុំអាចបន្តទៅទៀតកើត ។

អាណត្តិរបស់វេទិកាមជ្ឈត្តកម្មបញ្ចប់ជាមួយនឹងការបញ្ចប់ដំណើរការមជ្ឈត្តការតាមបទប្បញ្ញត្តិនៃមាត្រា ៤១ និងមាត្រា ៤២ កថាខណ្ឌទី ៤ នៃច្បាប់នេះ ។

**មាត្រា ៤១.-**

ការកែតម្រូវនិងការបកស្រាយមជ្ឈត្តវិនិច្ឆ័យត្រូវគោរពតាមល័ក្ខខ័ណ្ឌដូចខាងក្រោម :

១-ក្នុងកំឡុងពេលសាមសិប (៣០) ថ្ងៃ យ៉ាងយូរបន្ទាប់ពីទទួលមជ្ឈត្តវិនិច្ឆ័យ វៀរលែងតែភាគីវិវាទបានព្រមព្រៀងលើរយៈពេលបន្តទៀត :

ក-ភាគីវិវាទមួយដែលបានជូនដំណឹងដល់ភាគីវិវាទម្ខាងទៀតអាចស្នើសុំឱ្យវេទិកាមជ្ឈត្តកម្មកែតម្រូវកំហុសផ្នែកគណនា កំហុសផ្នែកការងារលេខាធិការ និងកំហុសនៃការបោះពុម្ព ឬ កំហុសដទៃទៀត ដែលមានលក្ខណៈស្រដៀងគ្នា ។

ខ-ភាគីវិវាទមួយដែលបានជូនដំណឹងដល់ភាគីវិវាទម្ខាងទៀត អាចស្នើសុំឱ្យវេទិកាមជ្ឈត្តកម្មផ្តល់ការបកស្រាយ ឬ ការបំភ្លឺលម្អិតពីចំណុច ឬ ផ្នែកណាមួយនៃមជ្ឈត្តវិនិច្ឆ័យ ប្រសិនបើភាគីវិវាទបានព្រមព្រៀងដូច្នេះ ។ ប្រសិនបើយល់ថាសំណើនោះសមស្របវេទិកាមជ្ឈត្តកម្មត្រូវបកស្រាយ ឬ បំភ្លឺលម្អិតក្នុងរយៈពេលយ៉ាងយូរសាមសិប (៣០) ថ្ងៃ បន្ទាប់ពីទទួលសំណើ ។ ការបកស្រាយ ឬ ការបំភ្លឺលម្អិតនោះ ត្រូវបញ្ចូលជាផ្នែកមួយនៃមជ្ឈត្តវិនិច្ឆ័យ ។

២-ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃយ៉ាងយូរ ក្រោយកាលបរិច្ឆេទចេញមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្មអាចកែតម្រូវកំហុសដូចដែលចែងក្នុងកថាខណ្ឌទី ១ក នៃមាត្រានេះ ទៅតាមគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ ។

៣-វៀរលែងតែភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ក្នុងរយៈពេលយ៉ាងយូរសាមសិប (៣០) ថ្ងៃ ក្រោយពីទទួលបានមជ្ឈត្តវិនិច្ឆ័យ ភាគីវិវាទមួយដែលបានជូនដំណឹងដល់ភាគីវិវាទម្ខាងទៀត អាចស្នើសុំឱ្យវេទិកាមជ្ឈត្តការធ្វើមជ្ឈត្តវិនិច្ឆ័យបន្ថែម ដូចជាដោយសារការទាមទារនានា ដែលលើកឡើងក្នុងដំណើរការមជ្ឈត្តការនោះ មិនបានដាក់ចូលទៅក្នុងមជ្ឈត្តវិនិច្ឆ័យ ។ ប្រសិនបើយល់ឃើញថាសំណើនោះសមស្របវេទិកាមជ្ឈត្តកម្ម ត្រូវធ្វើមជ្ឈត្តវិនិច្ឆ័យបន្ថែមក្នុងរយៈពេលយ៉ាងយូរសាមសិប (៣០) ថ្ងៃ ។

៤-ប្រសិនបើចាំបាច់ និងដោយបានជូនដំណឹងដល់ភាគីវិវាទ វេទិកាមជ្ឈត្តកម្ម អាចពន្យារយៈពេលដែលកំណត់សម្រាប់ការកែតម្រូវការបកស្រាយ ការបំភ្លឺលម្អិត ឬ ការធ្វើមជ្ឈត្តវិនិច្ឆ័យបន្ថែមតាមកថាខណ្ឌទី ១ និងកថាខណ្ឌទី ៣ នៃមាត្រានេះ ។

៥-បទប្បញ្ញត្តិនានានៃមាត្រា ៣៩ នៃច្បាប់នេះ ត្រូវយកទៅអនុវត្តសម្រាប់កែតម្រូវការបកស្រាយ ឬ ការបំភ្លឺលម្អិតលើមជ្ឈត្តវិនិច្ឆ័យ ឬ ការចេញមជ្ឈត្តវិនិច្ឆ័យបន្ថែម ។

## ជំពូកទី ៨
## ការប្តឹងជំទាស់ ការទទួលស្គាល់
## និង ការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ

### ផ្នែកទី១
### ស្ថាប័នមានសមត្ថកិច្ចក្នុងការប្តឹងជំទាស់
### ការទទួលស្គាល់ និងការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ

**មាត្រា ៤២.–**

សេចក្តីសម្រេចលើការប្តឹងជំទាស់ ការទទួលស្គាល់ និងការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ ជាសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤៣.–**

តុលាការកំពូលជាសាលាជំនុំជម្រះក្តីចុងក្រោយ ដែលមានសមត្ថកិច្ចជំនុំជម្រះបណ្តឹងជំទាស់របស់ភាគីវិវាទ ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ក្នុងរយៈពេលដប់ប្រាំថ្ងៃ (១៥) ថ្ងៃ ។

### ផ្នែកទី ២
### បណ្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យ

**មាត្រា ៤៤.–**

ភាគីវិវាទអាចប្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យតាមទ្រង់ទ្រាយជាបណ្តឹងបដិសេធ និងតាមបែបបទដូចខាងក្រោម :

១-បណ្តឹងបដិសេធទៅនឹងមជ្ឈត្តវិនិច្ឆ័យតាមផ្លូវតុលាការ អាចធ្វើទៅបានលុះត្រាតែស្របតាមល័ក្ខខ័ណ្ឌ ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ២ និងវាក្យខ័ណ្ឌទី ៣ នៃមាត្រានេះ ។

២-សាលាឧទ្ធរណ៍ និង តុលាការកំពូលអាចបដិសេធមជ្ឈត្តវិនិច្ឆ័យរបស់មជ្ឈត្តករបានក្នុងករណី :

ក-ភាគីដែលដាក់ពាក្យសុំបដិសេធបានផ្តល់ភស្តុតាងគ្រប់គ្រាន់ថា :

ក.១-ភាគីមួយនៃកិច្ចព្រមព្រៀងផ្សះផ្សាដូចមានយោងក្នុងមាត្រា ៧ នៃច្បាប់នេះ បានបាត់បង់សិទ្ធិមួយចំនួនខាងផ្លូវច្បាប់ ឬ កិច្ចព្រមព្រៀងផ្សះផ្សានោះ ពុំអាចយកជាការបាន បើយោងតាមច្បាប់ដែលភាគីវិវាទបានសំអាង ឬ កិច្ចព្រមព្រៀងផ្សះផ្សាពុំបានគោរពតាមបញ្ញត្តិណាមួយនៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ក.២-ភាគីដែលដាក់ពាក្យសុំបដិសេធនោះ មិនបានទទួលដំណឹងត្រឹមត្រូវពីការតែងតាំងមជ្ឈត្តករ ឬ ពីដំណើរការមជ្ឈត្តការ ឬ ភាគីនេះពុំអាចបង្ហាញពីអង្គហេតុរបស់ខ្លួនបានដោយប្រសិទ្ធភាព ។

ក.៣-មជ្ឈត្តវិនិច្ឆ័យដែលទាក់ទិននឹងវិវាទនោះពុំឆ្លើយតប ឬ ពុំគោរពល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងផ្សះផ្សា ។ ប្រសិនបើបញ្ហាដែលដាក់ឱ្យធ្វើមជ្ឈត្តការនោះ អាចផ្តាច់ចេញពីបញ្ហាដែលមិនបានដាក់ឱ្យធ្វើមជ្ឈត្តការ ការបដិសេធអាចធ្វើទៅបានតែត្រង់ផ្នែកមួយនៃមជ្ឈត្តវិនិច្ឆ័យ លើបញ្ហាដែលបានដាក់ឱ្យធ្វើមជ្ឈត្តការពីមុនប៉ុណ្ណោះ ។

ក.៤-ការបង្កើតវេទិកាមជ្ឈត្តកម្ម ឬ ដំណើរការមជ្ឈត្តការ ពុំស្របនឹងកិច្ចព្រមព្រៀងរបស់ភាគីវិវាទ ក្នុងករណីដែលកិច្ចព្រមព្រៀងនោះស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។ ក្នុងករណីដែលគ្មានកិច្ចព្រមព្រៀងផ្សះផ្សាទេ ការបង្កើតវេទិកាមជ្ឈត្តកម្ម ឬ ដំណើរការមជ្ឈត្តការខាងលើមិនសមស្របតាមច្បាប់នេះ ។

ខ-សាលាឧទ្ធរណ៍ និង តុលាការកំពូលរកឃើញថា :

ខ.១- កម្មវត្ថុនៃវិវាទនោះ ពុំអាចដោះស្រាយបានតាមរយៈការធ្វើមជ្ឈត្តការឡើយ បើយោងទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ខ.២-មជ្ឈត្តវិនិច្ឆ័យនោះផ្ទុយនឹងនយោបាយសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ។

៣-ការដាក់ពាក្យសុំបដិសេធមិនអាចធ្វើបានឡើយ បើរយៈពេលបានកន្លងផុតសាមសិប (៣០) ថ្ងៃ គិតពីថ្ងៃដែលភាគីសុំបដិសេធនោះទទួលបានមជ្ឈត្តវិនិច្ឆ័យ ឬ ប្រសិនបើសំណើនោះធ្វើឡើងតាមមាត្រា ៤១ នៃច្បាប់នេះ រយៈពេលសាមសិប (៣០) ថ្ងៃ គិតពីកាលបរិច្ឆេទដែលវេទិកាមជ្ឈត្តកម្មបានដោះស្រាយលើសំណើនោះ ។

៤-នៅពេលទទួលដំណឹងបដិសេធមជ្ឈត្តវិនិច្ឆ័យ បើមានលក្ខណៈសមស្របហើយមានសំណើពីភាគីមួយ សាលាឧទ្ធរណ៍ និង តុលាការកំពូលអាចផ្អាកដំណើរការបដិសេធនេះ នៅក្នុងរយៈពេលមួយដែលកំណត់ដោយសាលាឧទ្ធរណ៍ និង តុលាការកំពូល ដើម្បីផ្តល់ឱកាសដល់វេទិកាមជ្ឈត្តកម្មធ្វើដំណើរការមជ្ឈត្តការឡើងវិញ ឬ ចាត់វិធានការមួយតាមការយល់ឃើញរបស់វេទិកាថា អាចនឹងលុបបំបាត់មូលហេតុនៃការសុំបដិសេធនោះបាន ។

## ជំពូកទី ៣
## ការទទួលស្គាល់ និងការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ

### មាត្រា ៤៥.-

មជ្ឈត្តវិនិច្ឆ័យ ទោះជាបានធ្វើនៅប្រទេសណាក៏ដោយត្រូវបានគេទទួលស្គាល់ថាជាកាតព្វកិច្ច ហើយបន្ទាប់ពីបានដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរទៅសាលាឧទ្ធរណ៍រួចមកត្រូវបានអនុវត្តដោយយោងតាមបទប្បញ្ញត្តិក្នុងមាត្រានេះ និងមាត្រា ៤៤ ។

ភាគីដែលសំអាងលើមជ្ឈត្តវិនិច្ឆ័យ ឬ ដែលដាក់ពាក្យសុំឱ្យមានការអនុវត្តមជ្ឈត្តវិនិច្ឆ័យត្រូវផ្តល់ច្បាប់ដើមត្រឹមត្រូវពិតប្រាកដនៃមជ្ឈត្តវិនិច្ឆ័យ និងច្បាប់ដើមនៃកិច្ចព្រមព្រៀងផ្សះផ្សាដូចចែងក្នុងមាត្រា ៧ នៃច្បាប់នេះ ឬ អត្ថបទថតចម្លងដែលបញ្ជាក់ថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។ ប្រសិនបើមជ្ឈត្តវិនិច្ឆ័យ ឬ កិច្ចព្រមព្រៀងនោះមិនបានធ្វើជាភាសាខ្មែរទេ ភាគីនោះត្រូវផ្តល់សេចក្តីបកប្រែជាភាសាខ្មែរ ដែលមានការបញ្ជាក់ត្រឹមត្រូវតាមច្បាប់ដើម ។

### មាត្រា ៤៦.-

ទោះបីជាមជ្ឈត្តវិនិច្ឆ័យធ្វើនៅប្រទេសណាក៏ដោយ ការជំទាស់ទៅនឹងការទទួលស្គាល់ ឬ ជំទាស់ទៅនឹងការដាក់ឱ្យអនុវត្តនូវមជ្ឈត្តវិនិច្ឆ័យ អាចធ្វើបានតែក្នុងករណី :

១-អនុវត្តន៍តាមសំណើរបស់ភាគីជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យ ដោយភាគីនោះផ្តល់ភស្តុតាងដល់សាលាឧទ្ធរណ៍ថា ៖

ក-ភាគីមួយនៃកិច្ចព្រមព្រៀងផ្សះផ្សាដូចបានយោងក្នុងមាត្រា ៧ បានបាត់បង់សិទ្ធិមួយចំនួនខាងផ្លូវច្បាប់ ឬ កិច្ចព្រមព្រៀងនោះពុំអាចយកជាការបាន បើយោងតាមច្បាប់ដែលភាគីវិវាទបានសំអាង ឬ កិច្ចព្រមព្រៀងផ្សះផ្សាពុំបានគោរពតាមការកំណត់ណាមួយនៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ឬ

ខ-ភាគីដែលជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យនោះ ពុំទទួលបានព័ត៌មានត្រឹមត្រូវពីការតែងតាំងមជ្ឈត្តករ ឬ ពីដំណើរការមជ្ឈត្តការពុំអាចបង្ហាញពីករណីរបស់ខ្លួនបានដោយប្រសិទ្ធភាព ឬ

គ-មជ្ឈត្តវិនិច្ឆ័យដែលទាក់ទងនឹងវិវាទនោះពុំឆ្លើយតប ឬ ពុំគោរពលក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងផ្សះផ្សា ឬ ក៏បញ្ហាដែលបានសម្រេចនោះហួសពីក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងផ្សះផ្សា ។ ប្រសិនបើការសម្រេចលើបញ្ហាដែលបានដាក់ជូនឱ្យផ្សះផ្សា អាចផ្តាច់ចេញពីបញ្ហាដែលពុំបានដាក់ឱ្យផ្សះផ្សានោះ ផ្នែកមួយនៃមជ្ឈត្តវិនិច្ឆ័យលើបញ្ហាដែលបានដាក់ជូនអាចត្រូវគេទទួលស្គាល់ និងដាក់អោយអនុវត្ត ឬ

ឃ-ការបង្កើតវេទិកាមជ្ឈត្តកម្ម ឬ ដំណើរការមជ្ឈត្តការពុំសមស្របជាមួយនឹងកិច្ចព្រមព្រៀងរបស់ភាគីវិវាទ ឬ ប្រសិនបើគ្មានកិច្ចព្រមព្រៀងផ្សះផ្សានោះទេ ការបង្កើតវេទិកាមជ្ឈត្តកម្ម ឬ ដំណើរការមជ្ឈត្តការ គឺពុំសមស្របទៅនឹងច្បាប់នៃប្រទេសដែលការផ្សះផ្សាបានប្រព្រឹត្តទៅ ឬ

ង-មជ្ឈត្តវិនិច្ឆ័យនោះពុំទាន់បានក្លាយទៅជាកាតព្វកិច្ចនៅឡើយសម្រាប់ភាគីវិវាទ បើយោងតាមច្បាប់នៃប្រទេសដែលធ្វើសេចក្តីសម្រេចនោះ ឬ ម្យ៉ាងទៀតមជ្ឈត្តវិនិច្ឆ័យត្រូវបានបដិសេធ ឬ ព្យួរទុក ដោយតុលាការនៃប្រទេសដែលធ្វើមជ្ឈត្តវិនិច្ឆ័យ ឬ

២-ប្រសិនបើសាលាឧទ្ធរណ៍រកឃើញថា ៖

ក-កម្មវត្ថុនៃវិវាទនោះ ពុំអាចដោះស្រាយបានតាមការធ្វើមជ្ឈត្តការឡើយ បើយោងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬ

ខ-ការទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យនោះ អាចផ្ទុយនឹងនយោបាយសាធារណៈ នៃព្រះរាជាណាចក្រកម្ពុជា ។

បើមានការសុំឱ្យសាលាឧទ្ធរណ៍បដិសេធ ឬ ព្យួរទុកមជ្ឈត្តវិនិច្ឆ័យ ដូចមានចែងក្នុងកថាខណ្ឌទី ១ (ង) នៃមាត្រានេះ ហើយប្រសិនបើសាលាឧទ្ធរណ៍យល់ថាត្រឹមត្រូវ សាលាឧទ្ធរណ៍ដែលភាគីវិវាទស្នើសុំការទទួលស្គាល់ ឬ ការអនុវត្តមជ្ឈត្តវិនិច្ឆ័យនោះ អាចបញ្ឈប់ការសម្រេចរបស់ខ្លួន ហើយអាចបញ្ជាឱ្យភាគីវិវាទម្ខាងទៀតផ្តល់ការធានាសមស្របទៅតាមសំណូមពររបស់ភាគីដែលសុំឱ្យមានការទទួលស្គាល់ ឬ ការអនុវត្តមជ្ឈត្តវិនិច្ឆ័យ ។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

**មាត្រា ៤៧.-**

បទប្បញ្ញត្តិទាំងឡាយណាក្នុងវិស័យមជ្ឈត្តការពាណិជ្ជកម្មដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ច្បាប់នេះ ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ ។

ភ្នំពេញ,ថ្ងៃទី ខែ មីនា ឆ្នាំ ២០០៦

**អនុប្រធានទី ១ រដ្ឋសភា**

**ហេង សំរិន**

# ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ - ប្រទេសកម្ពុជា
## សៀវភៅសិក្សាស្ដីពីទស្សនាទានសំខាន់ៗ
### ស៊ីវិន ផែម អូស្ទើរបឺឡឺរ៍

សៀវភៅនេះ ពន្យល់អំពីទស្សនាទានជាមូលដ្ឋានមួយចំនួន នៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ស្របពេលដែលប្រទេសកម្ពុជាបានយកមកអនុវត្ត។ ប្រធានបទសំខាន់ៗរួមមាន:

- ទស្សនាទានចម្បងៗស្ដីពី ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- ការចរចាបែបបែងចែក
- ការចរចាផ្អែកលើផលប្រយោជន៍
- យុទ្ធវិធីចរចា
- ទ្វេគ្រោះរបស់អ្នកទោស
- សន្ទានកម្ម
- ការពង្រាងខចែងអំពីដំណោះស្រាយវិវាទ
- មជ្ឈត្តការ
- ច្បាប់ថ្មីរបស់ប្រទេសកម្ពុជាស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- ក្រុមប្រឹក្សាអជ្ញាកណ្ដាលកម្ពុជា
- ការប្រៀបធៀបបច្ចេកទេសផ្សេងៗនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- ក្រមសីលធម៌ក្នុង ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- ការផ្ដល់អជ្ញាប័ណ្ណ
- ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់អន្តរជាតិ
- ប្រវត្តិ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- ការអនុវត្តសេចក្ដីសម្រេច និងកិច្ចព្រមព្រៀង ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- ក្របខ័ណ្ឌច្បាប់បច្ចុប្បន្នសម្រាប់អនុវត្ត ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅកម្ពុជា
- លំហាត់ និងសំនួរសិក្សាផ្អែកលើរឿងក្ដី
- ក្រដាសកិច្ចការ និងទិនានុប្បវត្តស្ដីពី ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- ច្បាប់ និងក្រមគម្រូអន្តរជាតិសំខាន់ៗស្ដីពីដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ


**United States Agency for International Development**
1300 Pennsylvania Ave., NW
Washington, DC 20523
www.usaid.gov

**East-West Management Institute**
575 Madison Ave., 25th floor
New York, NY 10022
www.ewmi.org

**American Bar Association—Rule of Law Initiative**
740 15th Street, N.W.
Washington, DC 20005-1019
www.abanet.org/rol

Printing by: